ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣២ លេខ ១ ខែមករា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ


*ផ្នែកសាសនា* បញ្ជីរឿង ទំព័រ

- ព្រះសមណគោតមសម្មាសម្ពុទ្ធ លោកវរលេខាធិការ ស្វ-ណែម រៀបរៀង . . ១
- ព្រះពុទ្ធសាសនា ជាគតិនាំទៅកាន់សេចក្ដីសុខ លោក ភិយ-អ៊ុក រៀបរៀង ១០
- មធុរសវាហិនី សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈឹម ពិនិត្យ . . . . ២២
- មហោសថជាតក លោក អ៊ឹម-ភេម ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-ទួរ ពិនិត្យ . . . . . . . ៤១

*ផ្នែកអក្សរសាស្ត្រ*

- រឿងមរណមាតា (តមក) លោក ឌី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . ៥១
- រឿងព្រេងអេហ្ស៊ីប ដែលអំពីការវិនិច្ឆ័យនៃភាពប្លែក ភិក្ខុ ម៉ែន-វៀម ប្រែពីភាសាអង់គ្លេស . . . . . . . ៥៩
- សុភាសិតជាតិហ៊ីល និងគន្លងសៀវ លោក ភិយ-អ៊ុក ប្រែពីភាសាបារាំង . . ៦៥
- រឿងសាមកុក (តមក) ឧកញ៉ា តូ-កេ ប្រែ . . . . . ៧២
- ពាក្យវប្បធម៌ លោក សម-ថាំង សមាជិកគណកម្មការវប្បធម៌ រៀបរៀង . ៨០

*ផ្នែកកំណត់ទិនប្បវត្តិការណ៍*

- កិច្ចប្រជុំមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៦ លោកជង-វង រៀបរៀង.. ៩៨
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ជាំង-ជាន់ រៀបរៀង . . ១១៨



ខួបឆ្នាំ ទី២៨ លេខ ១២ សៀវភៅ ដំឡៃជាវ ២៥០៛០០

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
Publiée par l'Institut Bouddhique de Phnom-Penh

---

## sommaire

### Partie religieuse :

— Le Buddha Gotama par M. SO-NEM. . . . . . . 1

— Le Bouddhisme est la religion qui conduit à la paix par M. RAY-BUC. . . . . . . . . . . . . 10

— Madhurasavahini traduit par Samdec Prah Dhammalikhita Louis-Em. revu et corrigé par Vén-NHEAN-CHHOEUN . . . . . . . . . . . . . 22

— Prah Mahesothajataka relevé du manuscrit sur feuilles de latanier par M. IM-PHON et revu par Vén-KEM-TO 41

### Partie littéraire :

—Légende de Marana Mâtâ(suite) relevée du manuscrit sur feuilles de latanier par M.BY-SOVANN . . . . . . . 51

— Contes et légendes égyptiens «Judgment of Karakoush» traduit de l'anglais par Vén-MEN-RIEM . . . . . 59

— Recueil de proverbes et maximes Peuls et Toucouleurs traduit du français par M. RAY-BUC. . . . . . . 65

— Histoire de Sam-Kok(suite)traduite par l'Oknha NOU-KAN. 72

— Activités de la Commission culturelle par M. SAM-THANG 91

### Notes et Chroniques :

— Seizième réunion annuelle, des dignitaires religieux pour l'année par M. THANG-VONG. . . . . . . . 98

— Dictionnaire Sanscrit-khmer (suite) par Vén-PANG-KHAT 118

---

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

**ផ្នែកសាសនា**

# ព្រះសមណគោតមសម្មាសម្ពុទ្ធ

លោក ស៊ូ-ណៃម រដ្ឋលេខាធិការក្រសួងធម្មការ រៀបរៀង

---

ព្រះសមណគោតមសម្មាសម្ពុទ្ធ ទ្រង់ប្រសូតក្នុង ៥៦០ ឆ្នាំ ទ្រង់ព្រះផ្នួសក្នុង ៥៣១ ឆ្នាំមុនគ្រិស្តសករាជ ។

ពិតមែនតែបងប្អូនជនរួមជាតិ បានកាន់ខ្ជាប់នូវព្រះពុទ្ធសាសនាជាយូរអង្វែងមកហើយ លើកលែងតែបងប្អូនខ្មែរខ្លះ ដែលកាន់សាសនាកាតូលិកនិងសាសនាឥស្លាម ។ តែពេលនេះ សូមលើកជីវប្រវត្តិព្រះសមណគោតមបរមគ្រូដោយត្រួសៗ ជាថ្មីទៀត ដើម្បីជាទីរំលឹក ជាទីគោរពនិងជាទីពិចារណាតទៅ ។

ដូចបុព្វជនទាំងឡាយ ដែលកាលកន្លងវែងឆ្ងាយពុំអាចឲ្យការចងចាំនៃមនុស្សយើងដកល់ទុកបានដ៏ច្បាស់លាស់ នូវអនុស្សាវរីយ៍ណាមួយ អនុស្សាវរីយ៍ដែលកាលកន្លងទៅនោះ តែងពង្រីកថែមថយយ៉ាងទូលំទូលាយ អនុស្សាវរីយ៍ចំពោះព្រះបរមគ្រូក៏ដូច្នោះដែរ ។ បើគេពិនិត្យពុទ្ធប្រវត្តិតាមគម្ពីរនានា គេនឹងអាចសង្កេតឃើញថា ពុទ្ធប្រវត្តិជាប្រវត្តិប្រកបដោយអច្ឆរិយហេតុគ្រប់អន្លើចាប់តាំងពីគព្ភាភិនិក្ខមនៈ រហូតព្រះបរិនិព្វាន ។

ដូច្នេះហើយ បញ្ហាប្រវត្តិសាស្ត្រ ក៏បានកើតមានឡើងដោយថា

ព្រះពុទ្ធបានគង់ព្រះជន្មមានពិតមែនឬ ? ឬក៏គ្រាន់តែជានិមិត្តបុគ្គលទេ ? (personnage légendaire mezibu) ។

ចំពោះរឿងនេះ អ្នកប្រវត្តិសាស្ត្រជំនាញខាងការស្រាវជ្រាវមាន យោបល់បែកៗគ្នា តែទោះជាយ៉ាងណាក៏ដោយ សព្វថ្ងៃពុំមានអ្នកណាអាចទុកព្រះពុទ្ធជានិមិត្តបុគ្គលបានឡើយ ។ ព្រះបរមពោធិសត្វពិតជាមនុស្សមួយរូប ពុំមែនជាអាទិទេព ឬជាតំណាងនៃអាថ៌កំបាំងមើលមិនឃើញឯណាឡើយ ដោយហេតុបុរាណវិទ្យា (archéaléogie) បានបង្អួលនូវភស្តុតាងដ៏ច្បាស់លាស់ណាស់ ភស្តុតាងដែលបានស្គាល់មកតាំងពីសតវត្សទី៣ មុនគ្រិស្តសករាជម្ល៉េះ ។

ដូច្នេះហើយ អ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រយល់ថា គេពុំអាចដកអច្ឆរិយហេតុពីព្រះពុទ្ធ ឬព្រះពុទ្ធពីអច្ឆរិយហេតុ ដោយពុំប៉ះពាល់ធ្វើឲ្យខូចដល់ព្រះពុទ្ធសាសនា ព្រោះជីវភាពព្រះពុទ្ធនេះពិតជាឧទាហរណ៍ ជាវិចិត្រកម្មដ៏ល្អបំផុតជាពិសេសក្រៃលែង សំរាប់ព្រះធម៌ ការប្រៀនប្រដៅរបស់ព្រះពុទ្ធ ព្រោះជីវភាពនេះ ជាជីវភាពគំរូសំរាប់ជនទាំងឡាយ ដែលស្វែងរកសុភមង្គល ឬព្រះនិព្វាន ។

ព្រះបរមពោធិសត្វ ជាព្រះរាជបុត្រនៃព្រះបាទសុទ្ធោទនៈ និងព្រះមហាមាយាទេវី ត្រកូលគោតម (គោ ព្រះអាទិត្យ តម ប្រសើរ)=ពូជវង្សនៃព្រះអាទិត្យដ៏ប្រសើរ, ជាស្តេចសាក្យនៅនគរកបិលពស្តុ ។ ព្រះអង្គ

ប្រសូតនៅលុម្ពិនីវ័នឧទ្យាន ជាចន្លោះនគរកបិលភស្តុ នឹងទេវទហៈនគរ នេបាលរដ្ឋសព្វថ្ងៃ ។

ពុទ្ធិតានបានដំណាលថា ព្រះបរមពោធិសត្វប្រសូតមក ក៏ឈរលើផែនដី ហើយឈានព្រះជំហានទៅទិសខាងកើត ៧ លុះផ្តោះព្រះនេត្រគ្រប់ទិសទាំង ១០ ហើយ ក៏បន្លឺវាចាថា :

អគ្គោហមស្មិ លោកស្ស
សេដ្ឋោហមស្មិ លោកស្ស
ជេដ្ឋោហមស្មិ លោកស្ស
អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោ ។

ដែលមានន័យថា : ខ្លួនអញជាកំពូលនៃលោក ជាបុគ្គលប្រសើរជាងគេក្នុងលោក ជាច្បងជាងគេទាំងអស់ក្នុងលោក ហើយកំណើតនេះជាកំណើតក្រោយបំផុតរបស់អញ អំណើះតទៅមុខ អញគ្មានកើតទៀតឡើយ ។

## និមិត្ត ៤ និងការទ្រង់ចេញទៅបួស

កាលប្រសូតបាន ៥ ថ្ងៃហើយ ព្រាហ្មណ៍ ៨ នាក់បានតាំងពិធីរើសព្រះនាមថ្វាយ ហើយបានថ្វាយព្រះនាមថា សិទ្ធាថ៌ (បាលី សិទ្ធត្ថ) មានន័យថា អ្នកដែលមានប្រយោជន៍ ឬមានបំណងសម្រេចហើយ អ្នក

សម្រេចប្រយោជន៍តាមបំណង ។

ក្រោយដែលបានពិនិត្យលក្ខណៈនៃរូបព្រះសិទ្ធត្ថ, ព្រាហ្មណ៍ ៧ នាក់លើកម្រាមដៃ ២ ហើយពាយថា « បើនៅក្នុងនគរ ព្រះរាជកុមារនេះ នឹងបានជាស្ដេចចក្រពត្រាធិរាជ, បើចេញពីនគរនឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ » ។

ឯព្រាហ្មណ៍ទី ៨ ឈ្មោះកោណ្ឌញ្ញព្រាហ្មណ៍ លើកម្រាមដៃតែមួយ ពាយថា « ព្រះរាជកុមារនេះ ប្រាកដជាបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ» ។ ព្រាហ្មណ៍ទាំងឡាយក៏បានបញ្ជាក់ថា ព្រះរាជកុមារនឹងចេញចាកនគរទៅបួស នៅវេលាដែលបានឃើញនិមិត្ត ៤ យ៉ាង: ឃើញមនុស្សជរា ១ ព្យាធិ ១ មរណៈ ១ និងភិក្ខុ ១ ។

ព្រះបាទសិរីសុទ្ធោទនព្រះវរបិតា ក៏ជាត់ការម៉ឺងម៉ាត់ប្រយ័ត្នកុំឲ្យព្រះអយ្យបុត្រឃើញនិមិត្តទាំងនេះ ទុកឲ្យឋិតនៅតែក្នុងទីសប្បាយ ទីរីករាយ សម្បូណ៌ទៅដោយភោគទ្រព្យ និងគ្រឿងជំរុគគ្រប់យ៉ាង ព្រមទាំងស្រីស្នំ ៤ ម៉ឺន ជាបរិវារ ពុំឲ្យអារម្មណ៍ទាក់ទាញចិត្តគិតដល់សេចក្ដីអនិច្ចព្រះទ័យ សេចក្ដីព្រួយជាទុក្ខបែបណាបន្តិចសោះឡើយ ។

ដល់ព្រះជន្ម ១៦ ឆ្នាំ ទ្រង់អភិសេកព្រះនាងយសោធរា ឬហៅម្យ៉ាងទៀតថា ពិម្ពាព្រះអគ្គជាយា ប្រកបដោយរូបឆោមលោមព័ណ៌ជាចម្បងនៃអស់ស្នំឯង ។ ទ្រង់សោយសុខសម្បត្តិដរាបដល់ព្រះជន្ម២៩ឆ្នាំ

ទើបមានព្រះរាជឱរសមួយអង្គព្រះនាមព្រះរាហុលកុមារ ។ តែទោះជាយ៉ាងណាក៏ដោយ ព្រះបរមពោធិសត្វពុំអាចចៀសឲ្យផុតពីសង្គមមនុស្ស និងពីដំណើរដែលជាច្បាប់របស់ធម្មជាតិនៃមនុស្ស ។

លុះបានប្រទះនិមិត្តទាំង ៤ ប្រការគឺ មនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងបព្វជិតហើយ ព្រះសិទ្ធត្ថទ្រង់ជាប់អារម្មណ៍ គាំងព្រះទ័យ នឹងចេញបព្វជ្ជាចាកឃរាវាស ដោយទ្រង់យល់ថា មានតែបព្វជ្ជាទេ ដែលអាចបើកឱកាសស្វែងរកផ្លូវដោះស្រាយ បញ្ហាចាស់ ឈឺ ស្លាប់ ដែលគ្របសង្កត់សព្វសត្វក្នុងសកលលោកបាន ។

តាមផ្លូវចិត្តសាស្ត្រ សេចក្ដីប្រាថ្នារបស់ព្រះពោធិសត្វ អាចទុកជាការធម្មតាបាន ដោយសំអាងទៅលើហេតុផល ។ ការស្គាល់តែសេចក្ដីសប្បាយ ពុំដែលស្គាល់សោះនូវទុក្ខ ស្គាល់តែសេចក្ដីត្រេកត្រអាល ពុំស្គាល់សោះនូវព្រួយ ស្គាល់តែរូបល្អស្អាតបំព្រង ពុំស្គាល់សោះនូវរូបអាក្រក់ក្រខ្វក់អសុភ ហើយថ្ងៃមួយស្រាប់តែទៅឃើញ ទៅប្រទះដំណើរដែលផ្ទុយដាច់ស្រឡះពីការដែលធ្លាប់ដឹង ធ្លាប់ឮ ធ្លាប់ស្មានក្មាម គឺជាហេតុដែលអាចធ្វើឲ្យប្រែគំនិតសតិអារម្មណ៍ដូច្នេះបានពិតប្រាកដ ។

ផ្ទុយទៅវិញ បើព្រះបាទសិរីសុទ្ធោទន៍ជាព្រះបិតាពុំចាត់វិធានការដូចតាមនិទានទេ ពុំបានបង្ខាំងព្រះរាជបុត្រទេ នោះប្រហែលជាព្រះសិទ្ធត្ថពុំបានសម្រេចព្រះទ័យទៅបួសឡើយ ព្រោះអារម្មណ៍ព្រះអង្គទាំងឡាយ

មិនស្របតាមរបៀបទម្លាប់ ច្បាប់ដែលចិត្តសាស្ត្រ បានពោលថា « ទម្លាប់បង្កើនទុក្ខការក្រោកធ្ងល » ។

សេចក្តីត្រង់នេះ ជាខមួយបង្ហាញឲ្យឃើញថា ព្រះពុទ្ធសាសនា ស្របទៅតាមហេតុនិយមដែលជាគោលនៃវិទ្យាសាស្ត្រ ។

ក្នុងអធ្រាត្រនៃថ្ងៃដែលព្រះអង្គចាកចោលព្រះនគរ គម្ពីរទាំងឡាយ បាននិទានថា ទ្រង់មានព្រះហឫទ័យ ចង់ឃើញព្រះរាជបុត្រមុននឹងចេញ ។ តែលុះចូលក្នុងព្រះក្រឡាបន្ទំព្រះអគ្គមហេសី ហើយបានឃើញព្រះរាជទេពីដាក់ព្រះហស្តលើព្រះរាជកុមារ ក៏ទ្រង់ពុំហ៊ានទាញចាប់ត្រកងព្រះរាជបុត្រវិញ ។

ដំណើរនេះជាហេតុបង្អួលឲ្យឃើញថា កាមតណ្ហា សេចក្តីស្រឡាញ់ ស្អប់ ដែលជាចំណងនៃសត្វលោកទូទៅ ក៏ជាវត្ថុដែលបានចាប់ចងព្រះពោធិសត្វដែរ ។ ខណណាទៀយមិនអាចកាត់សេចក្តីលោភ សេចក្តីស្រឡាញ់ ទ្រព្យ រាជសម្បត្តិ កូន ប្រពន្ធ ញាតិ មិត្ត បានដោយងាយបែបនេះ ។

ហើយដំណើរដដែលនេះ ក៏ជាហេតុបង្អួលឲ្យឃើញថា ព្រះអង្គពុំមែនទៅបួសដោយសេចក្តីខ្លាច ពុំហ៊ានតស៊ូនឹងជីវភាពរបស់ខ្លួន នេះម្យ៉ាង និងឲ្យឃើញថា ព្រះអង្គពុំមែនជាអត្តទត្តបុគ្គល (personne égoiste) រត់ចោលកូនប្រពន្ធ សង្គមជាតិ ដើម្បីស្វែងរកសេចក្តីសុខ

ស្រួលតែម្នាក់ឯងនោះម្យ៉ាងទៀត ។

ផ្ទុយទៅវិញ ព្រះសិទ្ធត្ថជាព្រះវិញ្ញូជន ដែលពោរពេញទៅដោយបរត្ថភាព (altruisme) ទ្រង់ចេញបព្វជ្ជា ដើម្បីស្វែងរកអនុត្តរសម្មាសម្ពោធិញ្ញាណ ពោលគឺលោកុត្តរធម៌ (ធម៌ដែលអាចឲ្យផុតពីការកើត ចាស់ ឈឺ ស្លាប់) នេះឯង ដើម្បីត្រាច់រកសារធម៌ សំរាប់ជួយស្រោចស្រង់សត្វលោកឲ្យផុតពីសេចក្ដីវិនាស កុំឲ្យលង់ក្នុងវដ្ដសង្សារ ។

ក្នុងរឿងប្លូដទិយហ៊្វុះនេះ យើងពុំអាចរកបាននូវព្រឹត្តិការណ៍ដ៏អស្ចារ្យមួយដែលប្រវត្តិសាស្ត្រសាកលលោក និងប្រវត្តិសាស្ត្រខ្មែរបានទុកជាព្រឹត្តិការណ៍ ក្រមទីងជួបប្រទះក្នុងលោកសន្និកសយើង ត្រង់ដែលព្រះបាទសម្ដេចព្រះនរោត្តម-សីហនុវរ្ម័ន ទ្រង់លះបង់រាជសម្បត្តិ មកជាសម្ដេចព្រះឧបយុវរាជ ។

សម្ដេចព្រះឧបយុវរាជ ដែលទ្រង់លាលែងពីដំណែងព្រះមហាក្សត្រ គឺពុំមែនសម្រេចទៅដោយមានព្រះហឫទ័យក្ដួចប៉ងប្រាថ្នា នូវប្រយោជន៍ផ្ទាល់ព្រះអង្គទេ ។ ព្រះអង្គទ្រង់មានព្រះមេត្តាករុណាដល់ជាតិមាតុប្រទេស ចង់ឲ្យប្រជារាស្ត្រខ្មែរដែលទទួលនូវសេចក្ដីអាប់ឱន អន់ថយកិត្តិយសជាយូរឆ្នាំហើយ បានស្គាល់នូវសេចក្ដីសុខ សេចក្ដីចំរើន សមស្របជាអារ្យជនក្នុងលោកនឹងគេ និងចង់ឲ្យចៀសផុតពីសេចក្ដីវិនាស

គ្រប់យ៉ាង មានសេចក្ដីវិនាសដែលកើតមកពីការខ្វះសាមគ្គីជាដើម ។

រីឯព្រះសង្ឃដែលជាមិស្សនៃព្រះពុទ្ធ ព្រះសង្ឃដែលជាតំណាងនៃព្រះបរមគ្រូ ដែលជាអ្នកទ្រទ្រង់ធម៌ ក៏ដូច្នេះដែរ ។

ការបួសគឺពិតជាការប្រព្រឹត្តទៅតាមគន្លងព្រះពុទ្ធោវាទ គោលគឺការលះបង់នូវកាមកិលេសតណ្ហា ការរំដោះខ្លួនឲ្យឃ្លាតឆ្ងាយពីសេចក្ដីលោភ ដែលជាមូលហេតុនៃកងទុក្ខគ្រប់ប្រការ ។

ការបួស គឺពិតជាធ្វើទៅដោយយល់ច្បាស់នូវបេសកកម្មនៃបព្វជ្ជា ។ ក្នុងជំនាន់មុន កុលបុត្រខ្មែរទាំងឡាយសឹងចូលទៅសូមកាន់បព្វជ្ជាគ្រប់ៗរូប ពុំសូវមានចន្លោះរូបណាឡើយ ។ ដំណើរនេះ បានបិតមកជាប្រពៃណីខ្មែរអស់កាលជាយូរ ដោយបុព្វបុរសយើងទាំងឡាយបានទទួលយល់ដឹងច្បាស់លាស់ថា «មាតាបិតាមានគុណូបការៈលើកូនធ្ងន់ពន់ប្រមាណ ហើយមធ្យោបាយដែលអាចទុកជាកតញ្ញូកតវេទីសមល្មម មានតែមធ្យោបាយមួយបែប គឺបព្វជ្ជា» ។

បព្វជ្ជាក៏ជាមធ្យោបាយម្យ៉ាងទៀត ដើម្បីស្វែងរកវិជ្ជា ដើម្បីអប់រំកាយវាចាចិត្តក្រោមការដឹកនាំនៃព្រះឧបជ្ឈាយ៍អាចារ្យ ។

អាស្រ័យហេតុទាំងនេះ សាមណេរនិងភិក្ខុជាច្រើន កាលបើបានសូត្ររៀនសមល្មមហើយ ព្រមដោយសេចក្ដីកោតក្រែង ការស្អុះស្អាប់រត់តាមទាន់ ក៏រមែងវិលត្រឡប់មកជាគ្រហស្ថវិញ ប្រកបដោយភាពជា

ពលរដ្ឋយ៉ាងថ្លៃថ្នូរពេញសមត្ថភាព ។

ពុទ្ធបរិស័ទឯទៀត ដោយសទ្ធាជ្រះថ្លាយ៉ាងមុតមាំចំពោះព្រះធម៌នៃព្រះពុទ្ធ គឺឋិតនៅជាគិហិរហូតទល់នឹងអស់ព្រះជន្មាយុតែម្តង ក៏សាងដោយមុឺងម៉ាត់នូវទាន សីល ភាវនា និងសីល សមាធិ បញ្ញា ។

ព្រះអង្គជាអប្បិច្ឆបុគ្គល (បុគ្គលប្រាថ្នាតិច) ជាព្រះឧបជ្ឈាយ៍ អាចារ្យស្មោះស្ម័គ្រជាទីពឹងផ្អែក ជាទីស្រឡាញ់ទីជាទីគោរពនៃឧបាសក ឧបាសិកា កុលបុត្រ កុលធីតាខ្មែរទូទៅ ។

ក្នុងបច្ចុប្បន្នកាលនេះ ប្រពៃណីដូចបានរៀបរាប់មក ក៏គង់វង់នៅដូចដើម មានការប្រែប្រួលតែត្រង់ព្រះភិក្ខុសង្ឃទាំងឡាយ ក្រោមការដឹកនាំនៃសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ បានគោរពដោយហ្មត់ចត់លើសដើម និងដោយសទ្ធាស្មោះពីដួងព្រះទ័យ ចំពោះព្រះពុទ្ធភាគទ មានព្រះវិន័យជាដើម និងបានយល់ជាក់នូវបេសកកម្មដ៏ថ្លៃថ្លាចំពោះជាតិ ព្រះពុទ្ធសាសនានិងព្រះមហាក្សត្រ ។ ពុទ្ធិកសិក្សាក៏បានរៀបចំសមតាមសម័យ អាចធ្វើឲ្យព្រះពុទ្ធបេសកសមណៈទាំងឡាយ មានសមត្ថភាពបរិបូណ៌ក្នុងការផ្សាយព្រះធម៌ដ៏ឧត្តម ក្នុងការផ្តល់នូវការអប់រំ ដល់អ្នកប្រាថ្នាសុខចំរើនទាំងឡាយ ។

# ព្រះពុទ្ធសាសនាជាសាសនានាំទៅកាន់សេចក្ដីសុខ

លោក ភ៊យ-ប៊ុក រៀបរៀង

---

ព្រះពុទ្ធសាសនា ជាសាសនានាំសេចក្ដីសុខមកឲ្យ :

១– បំពោះខ្លួន,

២– បំពោះគ្រួសារ,

៣– បំពោះជាតិ,

៤– បំពោះសកលលោក ។

## អធិប្បាយ

### ១– ព្រះពុទ្ធសាសនានាំសេចក្ដីសុខមកឲ្យបំពោះខ្លួន :

អ្នកកាន់ព្រះពុទ្ធសាសនា ឬអ្នកដែលស័ក្យព្រះពុទ្ធសាសនា ដែលបានប្រតិបត្តិតាមព្រះពុទ្ធោវាទ មានធ្វើទាន រក្សាសីលជាដើម តែងបានសេចក្ដីសុខចំពោះខ្លួន ។

ទាន គឺការធ្វើអំណោយ ចំពោះសមណយាចក ចំពោះអ្នកក្រីក្រលំបាកតោកយ៉ាក ចំពោះសមាគម ចំពោះក្រុម ចំពោះព្រះសង្ឃជាដើម ឈ្មោះថា ជាការសម្រាលទុក្ខសេចក្ដីទុក្ខលំបាក ចំពោះសត្វលោក ។ ការដែលធ្វើ បរិច្ចាគ របស់ខ្លួនទៅឲ្យនេះ ជាបុណ្យ ឈ្មោះថា ឲ្យសុខដល់អ្នកដទៃ ។ អ្នកណាឲ្យសុខដល់អ្នកដទៃ អ្នកនោះនឹងបាន

សុខវិហារៈខ្លួនវិញ, សមដូចពុទ្ធភាសិតក្នុងគម្ពីរអង្គុត្តរនិកាយ បញ្ចក-និបាត ទានវគ្គថា :

សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ

ប្រែថា: អ្នកមានប្រាជ្ញា ជាអ្នកឲ្យនូវសេចក្ដីសុខ (ដល់អ្នកឯទៀត ហើយ) តែងបាននូវសេចក្ដីសុខ (នោះមកខ្លួនវិញ) ។

មិនតែប៉ុណ្ណោះ អ្នកធ្វើទាន តែងចំរើនដោយបុណ្យជាយ៉ាងក្រៃពេក ព្រមទាំងអាយុ វណ្ណៈ យស កេរ្តិ៍ឈ្មោះ សុខនិងកម្លាំងដ៏លើស ។ អ្នកធ្វើទាន តែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃជនទាំងឡាយដ៏ច្រើន ។

ព្រោះហេតុដូច្នេះ, អ្នកធ្វើទាន តែងមានចិត្តកក្ដី កិត្តិនាមល្បីខ្ចរខ្ចាយទៅគ្រប់ទិសទាំងផង, ដូចជា សម្ដេចព្រះឧបយុវរាជ ទ្រង់បានស្ថាបនានូវក្រុមបន្ទិភវាតិ ដើម្បីទ្រង់ធ្វើព្រះអំណោយ ចំពោះអ្នកដែលគ្រោះថ្នាក់ ដោយអគ្គិភ័យ រោគភ័យ ឃាតកភ័យ និងចំពោះសេចក្ដីទុក្ខគ្រប់យ៉ាង របស់ជនតូចតាចជាដើម ។ល។ ទ្រង់បានបំពេញព្រះរាជបេសកកម្មព្រមទាំងធ្វើជាតិឲ្យបានឯករាជ្យ ដោយសម្បូណ៌ ឧបត្ថម្ភព្រះពុទ្ធសាសនាឲ្យរុងរឿងចំរើន បានជាព្រះកិត្តិនាមរបស់ព្រះអង្គល្បីខ្ចរខ្ចាយទៅដល់ពលរដ្ឋនៃគ្រប់រូបក្នុងព្រះរាជអាណាចក្រទាំងមូល ព្រមទាំងនានាប្រទេសពេញសកលលោក ។ ដោយហេតុនេះហើយ បានជាពលរដ្ឋខ្មែរ មានសេចក្ដីស្នេហាស្រឡាញ់ព្រះអង្គ ថ្វាយព្រះនាមព្រះអង្គថា ព្រះបិតាឯករាជ្យ

ជាតិ ។ បើទ្រង់ស្ដេចយាងទៅកន្លែងណា ប្រជារាស្ត្រខ្មែរទាំងប្រុសស្រី ក្មេង ចាស់ អ្នកមាន-អ្នកក្រ តែងតែចាំទទួលគោរពចំពោះព្រះអង្គ មានខ្លះអុជទៀនធូប ធ្វើសក្ការបូជាព្រះអង្គ, ទុកព្រះអង្គជាព្រះមហា-វីរបុរសនៃប្រជាជាតិខ្មែរទាំងមូល ។ នេះមិនមែនមកពីអ្វី គឺមកពីទ្រង់មានព្រះមហាករុណាធិគុណ ទ្រង់ធ្វើព្រះអំណោយផលចំពោះមុខ គឺថាអ្នកណាមានទុក្ខព្រះអង្គទ្រង់ជួយសម្រាលទុក្ខទៅ, អ្នកណាមានភ័យ ទ្រង់ព្រះពិចារណាលៃលកធ្វើភ័យនោះឲ្យបាត់ទៅ ដូចជាទ្រង់កសាងគេហ-ដ្ឋានប្រទានដល់អ្នកក្រីក្រ ឬសាងសាលារៀន ឬទ្រង់ចូលព្រះរាជកុសលសាងវត្តអារាម គុដិ ព្រះវិហារជាដើម; ទាំងអស់នេះ ធ្វើឲ្យព្រះអង្គមានព្រះអាយុ ព្រះវណ្ណៈ ព្រះយស ព្រះកេរ្តិ៍ឈ្មោះ សុខនឹងកម្លាំងដ៏លើសលុប, សមដូចពុទ្ធភាសិតក្នុងខុទ្ទកនិកាយ ឥតិវុត្តកៈ សុត្តន្តបិដកថា:

អគ្គស្មឹ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ
អគ្គ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ ។

ប្រែថា បុណ្យដ៏ប្រសើរលើស រមែងចំរើនដល់ពួកជនអ្នកឲ្យទានក្នុងវត្ថុ (អ្នកទទួល) ដ៏ប្រសើរលើស, អាយុ វណ្ណៈ យស កេរ្តិ៍ឈ្មោះ សុខនឹងកម្លាំងដ៏ប្រសើរលើសក៏ចំរើនដែរ ។

ព្រោះហេតុដូច្នេះ ទានដែលបុគ្គលធ្វើដោយល្អចំពោះជនដទៃតែងនាំសុខមកឲ្យចំពោះខ្លួន ។

ចំណែកសីលនោះ ក៏ឲ្យសុខចំពោះខ្លួនដែរ ព្រោះថា អ្នកមាន
សីល ៥ គឺ ការមិនសម្លាប់សត្វ ១, ការមិនលួចទ្រព្យសម្បត្តិរបស់
អ្នកដទៃ ១, ការមិនប្រព្រឹត្តកន្លងក្នុងកាម ១, ការមិនកុហកគេ ១,
ការមិនសេពសុរានិងមេរ័យ ១ ៗ សីលទាំង ៥ នេះ ជាករណីយកិច្ច
របស់ឧបាសក ឧបាសិកាទាំងឡាយ ៗ បើពុទ្ធមាមកជនបានប្រព្រឹត្ត
ប្រតិបត្តិតាមព្រះពុទ្ធវចនៈនេះពេញលក្ខណៈហើយ ក៏អាចនឹងចៀស
វាងនូវកំហុសក្នុងលោកិយ មានការក្តីក្តាំ ការឈ្លោះទាស់ទែងគ្នា
ការទទួលទណ្ឌកម្ម មានការជាប់គុកច្រវាក់ខ្នោះឃ្នាងជាដើម ៗ ការធ្វើ
ខ្លួនឲ្យផុតពីទណ្ឌកម្មនៃផ្លូវលោកនេះឯង ហៅថាបានសុខចំពោះខ្លួន ៗ

សីលនេះជាទីពឹងផ្អែករបស់កុលបុត្រទាំងឡាយក្នុងព្រះពុទ្ធសាសនា
ជាទឹកដ៏បរិសុទ្ធស្អាត សម្រាប់ជម្រះនូវមន្ទិលរបស់សត្វទាំងឡាយ ក្នុង
លោកនេះ ជាឥណជាគង់ត្រជាក់ក្រៃលែង អាចរម្ងាប់នូវសេចក្តីក្រហល់
ក្រហាយរបស់សត្វទាំងឡាយបាន ជាផ្លិតដែលអាចបក់ទៅបាន ទាំង
បណ្តាលខ្យល់ ទាំងច្រាសខ្យល់ ជាជណ្តើរកែវសម្រាប់ឡើងទៅកាន់
ស្ថានសួគ៌ ស្ថានព្រហ្ម ជាមាគ៌ាដ៏វិសេសវិសាល សម្រាប់ទៅកាន់
លោកុត្តរភូមិនិងព្រះនិព្វាន ៗ សីលជាមូលដ្ឋាននៃគុណទាំងឡាយ
មានអានិសង្សអាចឲ្យសុខចំពោះខ្លួនមែនពិត ៗ

ត្រង់បទនេះ មានសំអាង ដូចពុទ្ធភាសិតគាថាមួយបទក្នុង

សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា ថា ៖

សីលំ សេតុ មហេសក្ខោ សីលំ គន្ធោ អនុត្តរោ
សីលំ វិលេបនំ សេដ្ឋំ យេន ដាតិ ទិសោ ទិសំ ។

ប្រែថា សីលជាស្ពានដ៏មានសក្តិធំ សីលជាក្លិនដែលមិនមានក្លិនដទៃប្រសើរជាង សីលជាគ្រឿងលាបលេបយ៉ាងប្រសើរខ្ចរខ្ចាយទៅគ្រប់ទិស ។

ដោយហេតុនេះហើយ បានជាថាខាងឯសីល បើគ្នាណាបាន បំពេញហើយ រមែងនាំសុខមកឲ្យចំពោះខ្លួនមែនពិត ។

ក្រៅពីនេះនៅមានធម៌ឯទៀត គឺ កតញ្ញូតាធម៌សេចក្តីដឹងគុណចំពោះ គុណអ្នកដ៏មានគុណ មានមាតាបិតាគ្រូបាអាចារ្យ និងសច្ចធម៌ សប្បុរស-ធម៌ ។ល។ ក៏នាំសុខមកឲ្យចំពោះខ្លួនដែរ ។ ព្រោះហេតុនេះបានជាថា ព្រះពុទ្ធសាសនាជាសាសនានាំសុខមកឲ្យចំពោះខ្លួន ។

## ២– ព្រះពុទ្ធសាសនា នាំសេចក្តីសុខមកឲ្យចំពោះគ្រួសារ ៖

គ្រួសារគឺមាតាបិតា បុត្រធីតា កូនប្រសាប្រុស កូនប្រសាស្រី ដ៏ដូនជីតា ក្មួយ មា មីង ជាដើម ។ អ្នកទាំងអស់ក្នុងគ្រួសារ ត្រូវមានករណីយកិច្ច ដែលត្រូវបំពេញទៅវិញទៅមក គឺស្វាមីចំពោះភរិយា មាតាបិតាចំពោះបុត្រធីតាជាដើម ។ ដូចព្រះពុទ្ធភាទ

ក្នុងសិង្គាលោវាទសូត្រ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដែងចំពោះសិង្គាលមាណពថា :

ករណីយកិច្ចដែលមាតាបិតា ត្រូវទំនុកបំរុងបុត្រធីតា មាន ស្ថាន ៥ គឺ

ក) ហាមមិនឲ្យបុត្រធីតាប្រព្រឹត្តអំពើទុច្ចរិត;

ខ) ទូន្មានបុត្រធីតាឲ្យតាំងនៅក្នុងកុសលធម៌;

គ) ទូន្មានបុត្រធីតាឲ្យសិក្សាសិល្បៈវិជ្ជា;

ឃ) រកភរិយាឲ្យបុត្រ ឬស្វាមីឲ្យធីតា តាមសមគួរ;

ង) ចែកទ្រព្យសម្បត្តិដល់បុត្រធីតា តាមសមគួរ ។

បើមាតាបិតា បានប្រព្រឹត្តករណីយកិច្ចទាំង៥ស្ថាន ចំពោះបុត្រធីតា តាមព្រះពុទ្ធភាសិតខាងលើនេះ ឈ្មោះថា មាតាបិតានាំសេចក្តីសុខមកឲ្យចំពោះបុត្រធីតា ហើយគ្រួសារនេះ នឹងបានសេចក្តីសុខជាតិយេ្យភាពតទៅ ។

លំដាប់តមក ព្រះអនាវរណញ្ញាណទ្រង់ទូន្មានសិង្គាលមាណពថា :

មាតាបិតាទុកជាបុរត្ថិមទិស ( ទិសបូព៌ា ) គឺ បុត្រធីតាគប្បីទំនុកបំរុងដោយស្ថាន ៥ គឺ

ក ) លោកបានចិញ្ចឹមខ្ញុំមកហើយ ត្រូវខ្ញុំចិញ្ចឹមលោកវិញ ;

ខ ) ជួយធ្វើកិច្ចការរបស់លោក :

គ) ទំនុកបំរុងវង្សត្រកូលមិនឲ្យសាបសូន្យ ;

ឃ) ប្រតិបត្តិខ្លួនឲ្យសមគួរជាអ្នកទទួលមត៌ក ;

ង) កាលបើលោកធ្វើមរណកាល ត្រូវធ្វើបុណ្យឧទ្ទិសផលជូនលោក ។

ភរិយាទុកជាបច្ចិមទិស (ទិសបស្ចិម) គឺ ស្វាមីគប្បីទំនុកបំរុងដោយស្ថាន ៥ គឺ

ក) រាប់អានលើកមុខជាភរិយា;

ខ) មិនមើលងាយ;

គ) មិនប្រព្រឹត្តកន្លងចិត្ត គឺមិនក្បត់ចិត្តភរិយា;

ឃ) ប្រគល់ការៈជាធំក្នុងផ្ទះឲ្យ;

ង) ឲ្យគ្រឿងតែងខ្លួន ។

ភរិយាគប្បីប្រតិបត្តិស្វាមីដោយស្ថាន ៥ គឺ

ក) ចាត់ការងារដោយល្អ;

ខ) សង្គ្រោះញាតិខាងស្វាមីដោយល្អ;

គ) មិនប្រព្រឹត្តកន្លងចិត្តស្វាមី គឺមិនក្បត់ចិត្តប្តី,

ឃ) រក្សាទ្រព្យដែលស្វាមីរកបានមក,

ង) មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង ។

ទាសកម្មករទុកជាហេដ្ឋិមទិស (ទិសខាងក្រោម) គឺ ចៅហ្វាយនាយ

គប្បីទំនុកបំរុងដោយស្ថាន ៥ គឺ

ក) ចាត់ការងារឲ្យធ្វើតាមសមគួរដល់កម្លាំង;

ខ) ឲ្យភោជនាហារនិងរង្វាន់;

គ) ព្យាបាលក្នុងវេលាមានជម្ងឺ;

ឃ) ចែកភោជនាហារដ៏មានឱជារសប្លែក ៗ ឲ្យបរិភោគ,

ង) បើកឲ្យសប្បាយក្នុងកាលគួរ ៗ

ទាសកម្មករគប្បីប្រតិបត្តិចៅហ្វាយនាយដោយស្ថាន ៥ គឺ

ក) ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ;

ខ) លែងធ្វើការងារក្រោយចៅហ្វាយនាយ;

គ) កាន់យកតែរបស់ដែលចៅហ្វាយនាយឲ្យ;

ឃ) ធ្វើការងារដោយយកចិត្តទុកដាក់,

ង) នាំគុណសម្បត្តិរបស់ចៅហ្វាយនាយទៅសរសើរក្នុងទីដទៃ ៗ

ព្រះពុទ្ធោវាទចំពោះសិង្គាលមាណពនេះ បើគ្រហស្ថណាមួយ ៗ យកទៅប្រព្រឹត្តប្រតិបត្តិតាម មុខជានឹងបានសេចក្តីសុខ ចំរើន ជាពិតប្រាកដ, ព្រោះថា ព្រះពុទ្ធោវាទនេះ ព្រះអង្គទ្រង់ចែងទៅតាមអធ្យាស្រ័យ លក្ខណៈចិត្ត ចរិត និស្ស័យ គុណសម្បត្តិ គុណវិបត្តិ មនោសញ្ចេតនា ។ល។ នៃមនុស្សខាងលើ បានជាថា ករណីយកិច្ចដែលមនុស្សទាំងឡាយត្រូវបំពេញនោះនឹងមានផល មានប្រយោជន៍ពិតៗ ដោយ

ហេតុនេះហើយ បានជាថា ព្រះពុទ្ធសាសនាជាសាសនានាំសុខមកឲ្យចំពោះគ្រួសារ ។

## ៣- ព្រះពុទ្ធសាសនានាំសេចក្ដីសុខមកឲ្យចំពោះជាតិ:

នៅប្រទេសកម្ពុជាយើង មានព្រះភិក្ខុសង្ឃជាធម្មកថិក តែងនិមន្តទៅគ្រប់និគមជនបទ ដើម្បីនឹងសំដែងធម៌ទេសនាចំពោះមហាជនខ្មែរ ពន្យល់បំភ្លឺពុទ្ធសាសនិកជន ឲ្យប្រព្រឹត្តប្រតិបត្តិតាមព្រះពុទ្ធោវាទ, ឲ្យមានសាមគ្គីភាព ដូច្នេះឈ្មោះថាលោកនាំសុភមង្គល នឹងសេចក្ដីសុខមកឲ្យពលរដ្ឋខ្មែរ ។ ម្យ៉ាងទៀត គោលបំណងនៃពុទ្ធសាសនា គឺ វិសិដ្ឋភាពជាមនុស្សជាតិ ១, ការលើកទឹកចិត្ត ១, ការស្វែងរកសុភមង្គលនឹងសេចក្ដីស្ងប់១, ការប្រយុទ្ធនឹងភេគាពាធនឹងទុគ្គតភាព១, ការកិលទៅជិតព្រះនិព្វានបើមិនទាន់បានដល់១ ។ បើជនជាតិខ្មែរប្រតិបត្តិទៅតាមគោលបំណងនៃព្រះពុទ្ធសាសនានេះ, ព្រះពុទ្ធ-សាសនា នឹងបានឡើងទៅកាន់វឌ្ឍនភាព ជាតិខ្មែរនឹងបានជួបប្រទះនូវសុភមង្គល នឹងសម្បូណ៌ភាពពុំខាន, ។ មិនតែប៉ុណ្ណោះ អ្នកដែលប្រតិបត្តិតាមព្រះពុទ្ធោវាទ នឹងបានជួបប្រទះនូវលាភ យស សេចក្ដីសរសើរគ្រប់យ៉ាងមិនខាន សមដូចពុទ្ធភាសិតក្នុងខុទ្ទកនិកាយធម្មបទថា :

ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ

សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។

ប្រែថា យសតែងចំរើនដល់អ្នកមានព្យាយាមរៀសរៃ១, អ្នកមានស្មារតី១, អ្នកមានការងារស្អាត១ អ្នកមានប្រក្រតីពិចារណារួចទើបធ្វើ១ អ្នកប្រុងប្រយ័ត្ន១ អ្នកមានប្រក្រតីរស់នៅដោយធម៌១ អ្នកមិនប្រមាទ១ ។

ពុទ្ធសាសនាមានពុទ្ធភាសិតជាអនេកប្បការ តែខ្ញុំគ្រាន់តែយកគាថាមួយបទមកចុះក្នុងទីនេះ ដើម្បីបង្ហាញបងប្អូនរួមជាតិថា ការប្រព្រឹត្តប្រតិបត្តិទៅតាមពុទ្ធភាសិតនេះ អាចរេចនាបុគ្គលទីមួយ ៗ ឲ្យមានគុណធម៌ សីលធម៌ដ៏ឧត្តុង្គឧត្តម បើបុគ្គលចំរើនហើយ ជាតិក៏ចំរើនដែរ ។

ដើម្បីនឹងឲ្យជនជាតិខ្មែរចេះវិជ្ជាខាងព្រះពុទ្ធសាសនា មានតែព្រះសង្ឃនេះឯង ជាមគ្គុទ្ទេសក៍អ្នកណែនាំពន្យល់បង្ហាញពុទ្ធបរិស័ទទាំងឡាយឲ្យដើរតាមពីក្រោយ ៗ ពិតមែនតែព្រះសង្ឃទាំងឡាយនេះមិនមែនជាព្រះខីណាស្រព បំតែនៅជាសម្មតិសង្ឃនៅឡើយ ក៏គង់ការទេសនារបស់លោក ជាទេសនាល្អមធ្យ័តដោយយកពុទ្ធភាសិតជាមូលដ្ឋាន ។ ឧបាសក ឧបាសិកាណា បានស្ដាប់ធម៌ទេសនានេះហើយ ត្រង់សេចក្ដីណាដែលងឿងឆ្ងល់ បានសាកសួរពន្យល់សព្វគ្រប់ហើយ យកពុទ្ធភាសិតដែលស្ដាប់បានយល់ច្បាស់លាស់នោះ មកអនុវត្តចំពោះជីវភាពសព្វៗថ្ងៃ ទុកជាមូលដ្ឋាននៃការប្រព្រឹត្តប្រតិបត្តិ. ឧបាសក ឧបាសិកានោះ ឈ្មោះថា

បានរំដោះខ្លួនឲ្យផុតពីអបាយភូមិទាំង៤ និងផុតពីអកុសលទាំងឡាយ បានតាំងអាត្មានៅក្នុងសង្គមដោយប្រពៃ ដូចបានយកថ្មមួយដុំ មកសាងគេហដ្ឋានជាតិ គឺប្រទេសកម្ពុជាឲ្យរឹងមុតមាំឡើង ៗ ព្រោះហេតុដូច្នេះ បានជាថាព្រះពុទ្ធសាសនានាំសុខមកឲ្យចំពោះជាតិ ។

## ៤– ព្រះពុទ្ធសាសនានាំសេចក្ដីសុខមកឲ្យចំពោះសកលលោក:

សម្ដេចព្រះឧបយុវរាជ ទ្រង់មានព្រះបន្ទូលទាត់ ក្នុងព្រះរាជសុន្ទរកថា ដែលទ្រង់ថ្លែងក្នុងឱកាសបើកការសិក្សាពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ និងសម្ពោធគ្រឹះស្ថានព្រះសីហនុ កាលពីថ្ងៃទី១០មិថុនា១៩៥៩ ថា :

« ទោះបីនៅក្នុងសម័យបរមាណូយើងនេះក៏ដោយ ព្រះពុទ្ធសាសនាក៏នៅតែមានថេរភាពនិងជាក់ស្ដែងដដែល ៗ ពិភពលោកសព្វថ្ងៃដែលបិតនៅក្នុងការព្រួយបារម្ភដោយអនាគតមិនគួរស្មាន បើប្រសិនជាយកធម៌ព្រះពុទ្ធមកពិចារណា អាចនឹងដោះស្រាយអស់ទាំងបញ្ហាគ្រប់យ៉ាងរបស់ខ្លួនបាន ទុកជាបញ្ហានោះស្មុគ្រស្មាញយ៉ាងណាក៏ដោយ ៗ នេះហើយដែលជាសេចក្ដីជឿស៊ប់នៃប្រជាជាតិ ដែលមានចំនួនកាន់តែច្រើនឡើងក្នុងលោក សូម្បីតែអ្នកកាន់សាសនាដទៃ ក៏ចាប់ផ្ដើមសិក្សាលទ្ធិព្រះពុទ្ធសាសនាដែរ ៗ ស្ទើរតែគ្រប់ប្រទេសក្នុងពិភពលោក មានអ្នកកាន់ មានទីសមាគម អ្នកពិនិត្យស្រាវជ្រាវខាងធម៌នៃព្រះពុទ្ធអង្គ » ។

មែនពិត ព្រះរាជបន្ទូលនៃសម្ដេចសហជីវិន ដែលទ្រង់ថ្លែងមានលើនេះ គឺទ្រង់បញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនា ជាសាសនាដោះស្រាយនូវបញ្ហាពិភពលោក ដែលបិតនៅក្នុងការតានតឹងព្រួយបារម្ភ ឲ្យរួចដោះចាកការតានតឹងព្រួយបារម្ភបាន បើពិភពលោកបានយកទៅពិចារណា ទៅពិសោធ ទៅកាន់តាម ដោយម៉ឺងម៉ាត់ ។

ព្រះបន្ទូលនេះ មានអត្ថន័យគម្ភីរភាពជ្រាលជ្រៅ ត្រូវតាមគោលពុទ្ធភាសិតពិតមែន ព្រោះថាព្រះពុទ្ធសាសនា ជាសាសនាប្រដៅឲ្យលះបង់អកុសលធម៌ មានទិដ្ឋិ មានះ លោភះ ទោសះ មោហះ ជាដើម ឲ្យចំរើនកុសលធម៌ មានហិរិឱត្តប្ប ទំនះមេត្តាករុណាជាដើម បើមហាអំណាចក្នុងពិភពលោកបានយកព្រះពុទ្ធសាសនាទៅត្រិះរិះពិចារណា ទៅពិសោធ ទៅកាន់តាម ព្រមទាំងបានលះបង់អកុសលធម៌ ចំរើនកុសលធម៌ទាំងនោះ តាមគន្លងដែលព្រះពុទ្ធសាសនាប្រៀនប្រដៅហើយ មុខជាលែងប្រកាន់គ្នា ស្រឡាញ់រាប់អានយោគយល់គ្នាទៅវិញទៅមក ឥតចាស់ចែងខ្វែងគំនិតគ្នា ឥតធ្វើបង្ក្រាមទឹកគ្នាឡើយ កាលបើដូច្នេះ លោកសន្និវាសនេះ មុខជានឹងទៅជាស្ថានសួគ៌មួយ មានតែសេចក្ដីសុខ សេចក្ដីចំរើន ឥតទុក្ខព្រួយជាពិតប្រាកដពុំខាន ។

ព្រោះហេតុនោះ បានជាថា ព្រះពុទ្ធសាសនាជាសាសនានាំសេចក្ដីសុខមកឲ្យចំពោះសកលលោក ។

---

# សំនាំដើម

## នៃគម្ពីរមធុរសវាហិនី

គម្ពីរមធុរសវាហិនីនេះ មុនដំបូងព្រះអរហន្តទាំងឡាយនៅមហាវិហារក្នុងលង្កាទ្វីប បានរៀបរៀងជាភាសាសីហឡៈ ។

ក្រោយមក ព្រះរដ្ឋបាលត្ថេរ នៅវង្កបរិវេណ បានប្រែពីភាសាសីហឡៈមកជាភាសាបាលី ។

ដល់មក ព.ស. ២៤៧៦ គ.ស. ១៩៣៤ សម្តេចព្រះធម្មលិខិត លី-ឯម ឧត្តមប្រឹក្សា គណៈមហានិកាយ ចៅអធិការវត្តលង្កា ក្រុងភ្នំពេញ កាលនៅជាព្រះសិរីសម្មតិវង្ស តាងគ្រូនៃសាលាបាលីជាន់ខ្ពស់នៅឡើយ បានប្រែអំពីភាសាបាលីមកជាភាសាខ្មែរ រៀបរៀងជាសេចក្តីទេសនា ហើយបានយកដំកល់ទុកនៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ ដើម្បីឲ្យបោះពុម្ពផ្សាយ ជាសាធារណប្រយោជន៍ដល់សិក្ខាកាមកុលបុត្រទូទៅ, តែពេលនោះ មន្ទីរពុទ្ធសាសនបណ្ឌិត្យពុំទាន់មានឱកាសបោះពុម្ពផ្សាយបាននៅឡើយ ។

លុះដល់មក ព.ស ២៥០២ គ.ស. ១៩៦០ លោកអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ បានសុំឲ្យខ្ញុំពិនិត្យមើល បើឃើញថាគួរ នឹងចាត់ការបោះពុម្ពផ្សាយ ។ ខ្ញុំក៏បានយកចិត្តទុកដាក់ពិនិត្យកែសម្រួលពាក្យពេចន៍ខ្លះ ដោយសេចក្តីសោមនស្ស ដើម្បីឲ្យគម្ពីរនេះបានរីកសាយជាសាធារណប្រយោជន៍តទៅ ។

វត្តលង្កា ក្រុងភ្នំពេញ ថ្ងៃ ១ មករា ព.ស. ២៥០២ គ.ស. ១៩៦០

ព្រះញាណកោសល ញាណ-ឈឹម

# មធុរសវាហិនី

សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

## ភាគ ៣ ជង់

មធុរសវាហិនី វណ្ណាមិ ធម្មានុសន្ធិ ព្រះសទ្ធម្មទេសនានេះ ទើបបានជាបុព្វាចារ្យលោកចាប់រៀបរៀង ជាដំណាលសេចក្ដីតាមអំពីធម្មកថិកសម្ដែងមកអំពីមុនគេ, គម្ពីរឯណាដែលប្រដាប់ដោយរឿងនិទានមួយរយគត់ មានអត្ថសេចក្ដីពីរោះផ្អែមល្ហែម មានឈ្មោះថា "មធុរសវាហិនី" ខ្ញុំនឹងពណ៌នានូវសេចក្ដីនៃគម្ពីរនោះក្នុងកាលឥឡូវនេះ ។

ព្រះអដ្ឋកថាចារ្យ កាលដែលលោកប្រារព្ធសម្ដែងគម្ពីរឈ្មោះមធុរសវាហិនីដ៏មានធម្មរសនិងអត្ថរសមានទំនុកសារដ៏វិចិត្រ ដោយន័យដ៏ឧត្ដមនេះ លោកបានប្រកាសបទរតនត្តយប្បណាម តាមសេចក្ដីអធិប្បាយនៃបុព្វាចារ្យទាំងឡាយពីបុរាណ ហើយទើបសម្ដែងនូវពុទ្ធរតន-ប្បណាមជាមុន ដោយបទព្រះគាថាដូច្នេះថា:

សត្ថុប្បសន្នចរណំ សរណំ ជនានំ
ព្រហ្មាទិមោលិមណិរំសិសមាវហន្តិ
បត្តេរុហាភមុទុកោមលចារុវណ្ណំ
វន្ទាមិ ចក្កវរលក្ខណសន្និធានំ ។

អធិប្បាយថា "ស្នាមព្រះបាទទាំងគូដ៏ប្រសើរឯណា របស់ព្រះបរមគ្រូ

សាហ្គ្រនីលោក ព្រមទាំងទេវលោក ជាកន្លែងមនុស្សនឹងទេវតា ទាំងឡាយ បូជា បរមសី ហើយ ជាទីពឹងក្ដួនកោនជ្រក នៃជនទាំងផង ទាំងឡាយ ជាទំនាមកនូវផ្កាឈូកដ៏មានត្របកទន់ល្មន់ក្រៃពេក មាន ពណ៌ដូចមាស រុងរឿងប្រាកដស្មើដោយរស្មីនៃកែវមណី ដ៏ប្រដាប់ទៅ គន្ធកំពូលមកុដនៃទេវតាទាំងឡាយមានមហាព្រហ្មជាដើម ប្រកបដោយ លក្ខណៈកង់ចក្រដ៏ប្រសើរពេញដោយអាការទាំងពួង មានទាំងជុំទំនិងខ្នង កង់ដ៏រុងរឿងដោយរស្មីមួយពាន់ មានប្រាកដក្នុងកណ្ដាលផ្ទៃនៃព្រះបាទ ទាំងគូជាអស្ចារ្យ ខ្ញុំព្រះករុណា សូមបង្អោនអង្គលើកកំបង់អញ្ចលីថ្វាយ បង្គំចំពោះព្រះបាទទាំងគូរបស់ព្រះសាស្ដាចារ្យនោះ យ៉ាងនេះឯង ។

ព្រះអដ្ឋកថាចារ្យ បានធ្វើពុទ្ធរតនប្បណាមចប់ស្រេចហើយ ទើប សម្ដែងធម្មរតនប្បណាមតទៅទៀត ដោយបទព្រះគាថាដូច្នេះថា:

សិទ្ធំ ជនេន ចិរកាលមភិត្ថិតេន
យស្មា វិនា សមធិគច្ឆតិ ខេមមត្តំ
យោ កប្បកោដិចិតនា ជមហាវិភាតី
តំ ធម្មមគ្គមសមំ បណមាមិ និច្ចំ ។

អធិប្បាយថា ព្រះបរិយត្តិធម៌ ព្រមទាំងព្រះនព្វលោកុត្តរធម៌ឯណា គឺប្រជុំជនមិនខ្វល់ប្រអូសខំទស្សាហ៍ចំរើនហើយ ដ៏សម្រេចអស់កាលដ៏យូរ ព្រះធម៌នោះសោត អាចញ៉ាំងប្រជុំជនឲ្យសម្រេចនូវសេចក្ដីសុខក្សេម

ក្សាន្តជាប្រមាណពិត ព្រះបរិយត្តិធម៌ ព្រមទាំងព្រះនព្វលោកុត្តរឯណា ដ៏រុងរឿង អាចឲ្យនូវប្រយោជន៍ទាំងពួងដល់ប្រជុំជនតាមប្រាជ្ញាបាន បីដូចជាដើមកល្បព្រឹក្ស ពុំនោះសោត ដូចជាកែវមណីដ៏អាចឲ្យនូវសេចក្ដីរុងរឿង និងសេចក្ដីប្រាជ្ញាតាមចិត្តដល់ជនទាំងពួងពិត ខ្ញុំព្រះករុណា សូមបន្ទោនអង្គលើកកំបង់អញ្ជលីថ្វាយបង្គំ ចំពោះព្រះបរិយត្តិធម៌ ព្រមទាំងព្រះនព្វលោកុត្តរធម៌នោះ ដ៏ប្រសើរផុតកែត្រីដទៃស្មើឡើយ សព្វ ៗ កាលដោយគោរព ។

ព្រះគន្ធរចនាចារ្យ បានសំម្ដែងធម្មគុណប្បណាមចប់ស្រេចហើយ ក៏សំម្ដែងសង្ឃគុណប្បណាមតទៅទៀត ដោយបទព្រះគាថាដូច្នេះថាៈ

សទ្ធិន្ទ្រិយំ សុគតសូនុវរំ វិសុទ្ធំ
យំ ទក្ខិណេយ្យគាមុធំ សុចិបុញ្ញខេត្តំ
តាណេសិនំ សរណមុជ្ឈិតសព្វទុក្ខំ
វន្ទាមិ សង្ឃមធិឃំ សិរសា មហាគ្ឃំ ។

អធិប្បាយថា ព្រះអរិយសង្ឃឯណាដ៏បរិសុទ្ធ ជាបុត្រដ៏ប្រសើរនៃព្រះសុគត មានឥន្ទ្រិយទាំង ៦ ស្ងប់រម្ងាប់ហើយ ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ គួរទទួលទក្ខិណាទានរបស់សត្វលោក ជាបុគ្គលមានទឹកថ្លាស្អាតចាកសេចក្ដីសៅហ្មងគឺកិលេសជាស្រេច ជាស្រែបុណ្យរបស់សត្វលោក ជាបុគ្គលស្វែងរកទីពឹងដល់សត្វលោក ដ៏បង្កើតជាទីពឹងដល់សត្វលោក

ជាបុគ្គលស្តារឡើងនូវទុក្ខទាំងពួងដល់សត្វលោក ខ្ញុំព្រះករុណា សូមបង្អោនអង្គលើកកំបង់អញ្ជលីថ្វាយបង្គំ ចំពោះព្រះអរិយសង្ឃនោះ លោកផុតមានទុក្ខប្រាកដស្មើដោយកែវមណីមានដំឡៃច្រើន ដោយសេចក្តីគោរពដោយត្បូងសិរសា ។

លុះព្រះគន្ធវនាចារ្យ បានអធិប្បាយបទរតនត្តយប្បណាមចប់ស្រេចហើយ ក៏សម្តែងសរសើរផលានិសង្សរតនប្បណាមតទៅទៀត ដោយបទព្រះគាថាដូច្នេះថា :

យម្បត្តមេត្ថរតនត្តយវន្ទនេន
បុញ្ញេន តេន ទុរិតំ សកលំ បនុជ្ជ
វក្ខាមហំ សុមធុរំ រសវាហិនិន្តំ
តោ តោ សុណន្តុ សុជនាកុមុទាវហាសា ។

អធិប្បាយថា ផលបុណ្យឯណាដែលខ្ញុំបានសម្រេចហើយ ដោយកិរិយាពណ៌នាសរសើរនូវគុណព្រះរតនត្រ័យ ក្នុងបទបណាមគាថានេះ ផលបុណ្យដែលហូរជូនមកពុំដាច់ កើតឡើងក្នុងចិត្តរបស់ខ្ញុំទាំងអស់នោះ ខ្ញុំសូមធ្វើនូវសេចក្តីអន្តរាយទាំងពួងឲ្យឃ្លាតចេញទៅឆ្ងាយ អំពីកាយរបស់ខ្ញុំ ហើយនឹងសម្តែងនូវគម្ពីរឈ្មោះមធុរសវាហិណីនោះ ដោយប្រពៃពិតបពិត្រអ្នកទាំងឡាយដ៏ចំរើនៈអើយ! ចូរអ្នកទាំងឡាយប្រុងផ្ទង់សោតបសាទ ត្រងត្រងស្តាប់ធម្មរសនឹងអត្ថរសគម្ពីរមធុរសវាហិណីនោះចុះ ឯគម្ពីរមធុរសវាហិណីនោះ នឹងនាំមកនូវសេចក្តីត្រេកអរចិត្ត ដល់សប្បុរសទាំងឡាយ

ដោយពិត ។

រឿងនិទានដែលមានក្នុងគម្ពីរនេះ គឺព្រះអរហន្តទាំងឡាយពីមុន លោកបានសម្តែងជ្រើសរើសរឿងនិទាន ដែលកើតមានឡើងក្នុងទីនោះៗ ប្រមូលមកផ្តល់ទុកដោយសីហឡភាសា រក្សាទុកក្នុងមហាវិហារដើម្បី មួនពុំឲ្យបានវិបត្តិឡើយ ដល់មកខាងក្រោយមានព្រះថេរមួយអង្គព្រះនាមពុទ្ធឃោស នៅសំណាក់ក្នុងវត្តវិហារ លោកប្រកបដោយសីលគុណនិង គាវាគុណ បានប្រែពីសីហឡភាសា ត្រឡប់មកជាមគធភាសា (គាថាបាលីវិញ) ដើម្បីប្រយោជន៍ដល់ប្រជុំជនច្រើន មានភិក្ខុសង្ឃជាដើម ត្រាច់នឹងសិក្សារៀនសូត្របានដោយងាយ ។

គម្ពីរនេះចែកជាពីរផ្នែកគឺ មធុររសវាហិនីជម្ពុទីបៈ ១ មធុររសវាហិនីលង្កាទីបៈ ១ ។ ផ្នែកមធុររសវាហិនីជម្ពុទីបៈ មាន ៤ វគ្គ ក្នុងវគ្គមួយៗ មានរឿងនិទានដប់ៗ ត្រូវជានិទាន ៤០ គត់ ដែលកើតមាននៅក្នុងជម្ពូទ្វីប (ឥណ្ឌា) ។ ផ្នែកមធុររសវាហិនីលង្កាទីបៈ មាន ៦ វគ្គ ក្នុងវគ្គមួយៗ មានរឿងនិទានដប់ៗ ត្រូវជានិទាន ៦០ គត់ ដែលកើតមានក្នុងលង្កាទ្វីប រួមទាំងពីរផ្នែកបាន ១០០ រឿងគត់ ពុំលើសពុំខ្វះឡើយ ។

ខ្ញុំសូមរៀបរៀងវគ្គ ព្រមទាំងរឿងនិទានទាំងនោះដូចតទៅនេះ :

## ជម្ពុសោណ្ណកវគ្គទី ១ មាននិទាន ១០ គឺ:

ទី ១ ជម្ពុសោណ្ណកមហាកដ់វត្ថុកថា សម្តែងរឿង

ព្រះបាទធម្មសោណ្ឌកមហាពជក្នុងវគ្គទី ១ តាមបទបាលីដូច្នេះថា :

អព្ភាគតំ ភគវតោ ជាដើម អធិប្បាយថា កាលពីមុនព្រះមានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់នៃយើង ពុំទាន់បានត្រាស់ដឹងនៅឡើយ គ្រានោះ ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ ព្រះអង្គបានត្រាស់ឡើងប្រាកដ ក្នុងកប្បនេះ តែងសម្តែងធម៌ទេសនាប្រោសវេនេយ្យសត្វឲ្យបានសម្រេចដល់ព្រះនិព្វាន តាមគំណត់ដូចព្រះសម្មាសម្ពុទ្ធអំពីបុរាណរៀងមក ហើយព្រះអង្គទ្រង់ចូលព្រះបរិនិព្វានទៅ ។ លុះដល់សាសនារបស់ព្រះមានព្រះភាគអង្គនោះ វិនាសរាបសូន្យបាត់បង់ទៅមិនយូរប៉ុន្មាន កាលនោះ ព្រះបរមពោធិសត្វជាអម្ចាស់នៃយើង ព្រះអង្គកំពុងកសាងបន្ទុំប្រមូលបារមីទៅឡើយ ព្រះអង្គបានច្យុតចុះចាកទេវលោក មកចាប់បដិសន្ធិក្នុងផ្ទៃព្រះអគ្គមហេសីនៃស្តេចពារាណសី ជាស្តេចឧត្តមខ្ពង់ខ្ពស់ប្រសើរជាងស្តេចទាំងពួងក្នុងជម្ពូទ្វីប ។

ក្នុងកាលដែលព្រះបរមពោធិសត្វនៅក្នុងផ្ទៃព្រះមាតា គ្រប់ ១០ ខែបរិបូណ៌ហើយ ក៏ប្រសូតចេញចាកផ្ទៃព្រះមាតានោះក៏ជាអស្ចារ្យ មានធម្មសញ្ញា សេចក្តីសំគាល់ក្នុងធម៌ បណ្តាលកើតឡើងក្នុងចិត្តនៃសត្វពល់រូប សត្វទាំងនោះ សឹងមានប្រាថ្នាចង់ស្តាប់ធម៌គ្រប់ ៗគ្នា ក្នុងកាលនោះដែរ ។

ព្រោះហេតុនោះ ព្រះបរមក្សត្រិយ៍ជាព្រះវរមាតាបិតា ព្រមទាំងព្រះ

រាជវង្សក្នុងវង្សបានសន្មតព្រះនាមថា ធម្មសោណ្ឌកកុមារ ក្នុងកាលនោះ ឯង ៗ ព្រះរាជកុមារនោះ បានចំរើនដោយយសបរិវារជាច្រើន លុះដល់វ័យធំឡើងហើយ ក៏បានសិក្សារៀនសិល្បសាស្ត្រទាំងពួងចេះចាំស្ទាត់ សម្តេចព្រះរាជបិតា ទ្រង់ប្រទានឋានន្តរស័ក្តិជាព្រះមហាឧបរាជ ។ ព្រះធម្មសោណ្ឌកឧបរាជ ទ្រង់អង្គតែងបំពេញកុសលកម្មបថទាំង ១០ និងបុញ្ញកិរិយាវត្ថុ១០ មានទានជាដើម លុះអំណើះពីសម្តេចព្រះរាជបិតាហើយ ក៏សេនាបតីនិងព្រាហ្មណ៍បុរោហិត ចាត់ចែងថ្វាយរាជសម្បត្តិអភិសេកឧបរាជជាព្រះបរមក្សត្រិយ៍ស្នងសម្តេចព្រះរាជបិតា ក្នុងកាលនោះៗ

ចំណែកឯព្រះឧបរាជបរមពោធិសត្វបានសោយរាជសម្បត្តិជាស្តេចដ៏ប្រសើរ ទ្រង់ព្រះនាមព្រះបាទធម្មសោណ្ឌកមហារាជ មានព្រះកិត្តិគុណ ល្បីល្បាញប្រាកដស្មើដោយស្តេចព្រះបរមចក្រពត្តិ ក្នុងនគរពារាណសី ៗ នគរនោះក៏រុងរឿងប្រាកដដូចទេវនគរ លុះព្រះអង្គគ្រងរាជសម្បត្តិគង់នៅបានកន្លះខែហើយ ស្តេចគង់នៅលើទីក្រឡាព្រះបន្ទំដ៏មានសិរីសួស្តី ហើយទ្រង់រំពឹងពិចារណានូវហេតុផ្សេង ៗ ជាដើមថា:

កិរិយាដែលអាត្មាអញបានសោយរាជសម្បត្តិ ដ៏មានសិរីយ៉ាងនេះហើយប្រាសចេញចាកព្រះធម៌ពុំបានស្តាប់ព្រះធម៌ដូច្នេះ ដូចជាអាកាសដែលប្រាសចាកព្រះអាទិត្យពុំមានរស្មីអាចបំភ្លឺលោក ដូច្នោះដែរ ៗ លុះទ្រង់រំពឹងដូច្នេះហើយ ក៏រំពឹងតទៅទៀតថា អាត្មាអញបានរាជសម្បត្តិ

ប្រសើរយ៉ាងនេះ  ព្រោះតែបុណ្យដែលពុំបានខ្ជិលច្រអូសខំឧស្សាហ៍ខ្វល់ខ្វាយបំពេញបុញ្ញកិរិយាវត្ថុមានទានសីលជាដើមពីមុនមក  គឺដោយរាជ-រិទ្ធិដ៏ស្តុកស្តម្ភដូចជាទេវរាជ  ដែលបានសោយសម្បត្តិទិព្វក្នុងទេវនគរដោយពិត ៗ ម្យ៉ាងទៀតអាត្មាអញមានអានុភាពបានសម្រេចដោយសម្បត្តិទាំងឡាយគឺរូបជាទីគាប់ចិត្ត  ល្បែងមហោស្រពគួរទស្សនាជាទីពេញចិត្ត  សម្លេងពីរោះគួរចង់ស្តាប់ដោយប្រពៃ  គ្រឿងក្រអូបគួរដល់កិរិយាហិតស្រូបយកក្លិនជាទីពេញចិត្ត  រសអាហារឆ្ងាញ់ពិសាគួរជញ្ជប់ជ្រួតជ្រាបដោយអណ្តាត  សម្ផស្សដ៏ទន់ត្រជាក់ស្រួលគួរប៉ះពាល់ដោយកាយដូច្នេះអាត្មាអញនឹងកាន់សេចក្តីប្រមាទ ដោយសម្បត្តិមានប្រមាណប៉ុណ្ណោះពុំគួរសោះឡើយ  គួរតែលះបង់ឲ្យទានខ្លួនប្តូរនឹងឲ្យទានជីវិត  ឲ្យទានស្រូវអង្ករ ព្រមទាំងសម្បត្តិទ្រព្យដល់ស្មូមទាំងឡាយ ទើបប្រពៃ ៗ តមកព្រះអង្គមានព្រះរាជហឫទ័យ  ជ្រះថ្លាប្រាថ្នាចង់ស្តាប់ព្រះធម៌ទេសនាដែលព្រះជិនស្រីទ្រង់សំដែងតែងតាំងទុកមក  ជាធម៌ឲ្យនូវព្រះនិព្វានជាទីក្សេមចាកយោគៈ  ជាធម៌អាចប្រហារបង់នូវជាតិជរាព្យាធិនិងមរណៈឲ្យអស់ទៅដោយពិត ៗ ម្យ៉ាងទៀត  អណ្តូងស្រះប្រាសចាកទឹកភ្លៀង  មិនមានទឹកដក់នៅ មិនរុងរឿងល្អមានឧបមាយ៉ាងណា កិរិយាដែលអាត្មាអញសោយរាជ្យជាស្តេច  ហើយប្រាសចាកព្រះធម៌  ពុំបានស្តាប់ធម៌ទេសនាពុំរុងរឿងល្អមានឧបមេយ្យយ៉ាងនោះដែរ  ។ រាត្រីប្រាសចាកព្រះចន្ទជាទីពឹង

ទិស  មិនរុងរឿងល្អមានឧបមាយ៉ាងណា  កិរិយាដែលអាត្មាអញសោយ-
រាជ្យជាស្តេច ហើយប្រាសចាកព្រះធម៌ ពុំបានស្តាប់ធម៌ទេសនា គឺមិនរុង
រឿងល្អមានឧបមេយ្យយ៉ាងនោះដែរ ។ ដំរីអាជានេយ្យដ៏ប្រសើរដែលចង
គ្រឿងប្រដាប់ហើយប្រាសចាកគុត  មិនរុងរឿងល្អមានឧបមាយ៉ាងណា
កិរិយាដែលអាត្មាអញសោយរាជ្យជាស្តេច ហើយប្រាសចាកព្រះធម៌ពុំបាន
ស្តាប់ធម៌ទេសនា  មិនរុងរឿងល្អមានឧបមេយ្យយ៉ាងនោះដែរ ។ ទឹក
សមុទ្រប្រាសចាកត្រើយមិនរុងរឿងល្អមានឧបមាយ៉ាងណា  កិរិយាដែល
អាត្មាអញសោយរាជ្យជាស្តេចហើយប្រាសចាកព្រះធម៌  ពុំបានស្តាប់ព្រះ
ធម៌ទេសនាក៏មិនរុងរឿងល្អមានឧបមេយ្យយ៉ាងនោះដែរ ។ ព្រះបរមក្សត្រិយ៍
មានគ្រឿងប្រដាប់ដ៏ល្អហើយទ្រង់ព្រះពស្ត្រដាចអាក្រក់  មិនរុងរឿងល្អ
មានឧបមាយ៉ាងណា  កិរិយាដែលអាត្មាអញសោយរាជ្យជាស្តេចហើយ
ប្រាសចាកព្រះធម៌ ពុំបានស្តាប់ធម៌ទេសនា ក៏មិនរុងរឿងល្អមានឧបមេយ្យ
យ៉ាងនោះដែរ ។ បើដូច្នេះ គួរតែអញស្វែងរកស្តាប់ព្រះធម៌ទេសនាត្រាតែ
បាន  លុះទ្រង់ព្រះដំរិះដូច្នេះហើយ  ក៏មានព្រះហឫទ័យចង់ស្តាប់ព្រះធម៌
ដែលជាធម៌បណ្តុះបណ្តាលឲ្យបានសម្បត្តិទាំង ៣ ប្រការគឺសម្បត្តិមនុស្ស១
ទេវតា១ ព្រះនិព្វាន១  ពុំបេះដាច់ឡើយ ។ ឯវំ ចិន្តេត្វា បាតោ
ព្រះនរិន្ទ្រាធិបតី  បរមពោធិសត្វ  ព្រះអង្គទ្រង់ពិចារណាយ៉ាងនេះ
ហើយ  លុះវេលាព្រឹកព្រាងស្វាងព្រះសុរិយា  ព្រះអរុណក៏ច្បាស់ស្រឡះ

ហើយ ព្រះអង្គទ្រង់យាងចេញអំពីទីសោយប្រាសាទដ៏មានសិរីសួស្តី ចេញទៅប្រថាប់នាចុងព្រះរាជរោង ដ៏មានពួកអមាត្យហោមរោមគាល់បម្រើដោយជុំវិញ ស្តេចគង់នៅលើរាជបល្ល័ង្កដ៏ប្រសើរ ដែលមានស្វេតច្ឆត្រគឺបុគ្គលលើកឡើងបើកបាំងពីលើ ដ៏ប្រដាប់ដោយកែវទាំង ៧ ប្រការដ៏រុងរឿងដូចព្រះឥន្ទ្រាធិរាជជាស្តេចនៃទេវតា ហើយស្តេចមានព្រះរាជឱង្ការទៅនឹងអមាត្យទាំងឡាយថា ភោន្តោ ម្នាលអ្នកទាំងឡាយដ៏ចំរើនអើយ បណ្តាព្រះធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងតែងតាំងទុកមកហើយ បើអ្នកណាបានចេះដឹងនូវព្រះធម៌នោះខ្លះ អ្នកនោះត្រូវសម្តែងព្រះធម៌នោះមកឲ្យយើងបានស្តាប់ផង ដ្បិតយើងមានសេចក្តីប្រាថ្នាចង់ស្តាប់ព្រះធម៌ទេសនាពន់ពេកណាស់ ។ ឯអមាត្យទាំងអស់ក៏ក្រាបបង្គំទូលព្រមគ្នាថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គទាំងឡាយពុំបានដឹង ពុំបានចេះចាំព្រះធម៌នោះដល់តិចតួចឡើយ សូមព្រះអង្គទ្រង់ជ្រាប ។

ព្រះបរមពោធិសត្វ កាលបើទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ មានសេចក្តីទោមនស្សតូចព្រះហឫទ័យ ហើយទ្រង់ពិចារណាថា បើដូច្នេះគួរតែអញឲ្យដម្កល់នូវប្រាក់មួយពាន់កហាបណៈ លើ-កនៃដំរីឲ្យបុរសវាយស្គរត្រេចទៅក្នុងនគរទាំងអស់ គង់មានបុគ្គលណាមួយលោភចង់បានទ្រព្យរបស់អញ សម្តែងធម៌ទេសនាដោយបទព្រះគាថាប្រកបដោយបាទបួនដល់អញ ពុំលែងឡើយ កិច្ចដែលអញបានស្តាប់ព្រះធម៌នោះនឹងមាន

សេចក្ដីសុខ សេចក្ដីចំរើនអស់កាលជាយូរអង្វែងទៅអនាគតដោយពិត ៗ លុះព្រះពោធិសត្វទ្រង់គិតដូច្នេះហើយក៏ចាត់សេវកាមាត្យទាំងឡាយឲ្យធ្វើដូចព្រះតម្រិះនោះ លុះបានធ្វើទៅហើយ ក៏ពុំមានបុគ្គលណាមួយអាចនឹងសម្ដែងធម៌បានឡើយ ទើបព្រះអង្គត្រាស់បង្គាប់ឲ្យបង្កើនកហាបណៈច្រើនឡើងជាលំដាប់តាំងពី ពីរពាន់ បីពាន់ បួនពាន់ឡើងទៅ ដរាបដល់មួយកោដិជាកំណត់ថា អ្នកណាអាចសម្ដែងធម៌ទេសនាតែមួយព្រះគាថា ដែលមានបាទបួន ឲ្យយើងស្ដាប់យើងនឹងឲ្យប្រាក់មួយកោដិ សូម្បីទ្រង់ផ្សាយដូច្នេះក្ដី ក៏គង់ពុំមានបុគ្គលណាមួយអាចសម្ដែងធម៌ទេសនាថ្វាយព្រះអង្គបានឡើយ លំដាប់ជាខាងក្រោយមក ព្រះអង្គចាត់សេវកាមាត្យឲ្យវាយស្គរត្រួចទៅក្នុងនគរទាំងអស់ទៀតថា បើអ្នកណាអាចសម្ដែងធម៌ទេសនាឲ្យយើងស្ដាប់ យើងនឹងឲ្យធ្វើជាធំក្នុងស្រុកនិគមនិងជនបទ ពុំនោះសោតយើងនឹងឲ្យធ្វើជាសេដ្ឋី ជាសេនាបតីឬជាឧបរាជ មួយទៀតយើងឲ្យស្នុត·ប្ដូត្រកូលសម្បត្តិទាំងមូល ឯចំណែកយើងនឹងលះបង់នូវភាពជាស្ដេចហើយធ្វើខ្លួនឲ្យជាខ្ញុំបម្រើអ្នកនោះហោង ៗ ទោះបីព្រះអង្គត្រាស់បង្គាប់ដូច្នេះក្ដី ក៏ពុំបានជួបប្រទះបុគ្គលណាមួយចេះចាំធម៌អាចនឹងសម្ដែងថ្វាយព្រះអង្គបានឡើយ ៗ បពិត្រសប្បុរសទាំងឡាយ យើងគួរតែមានសម្បជញ្ញៈភ្ញាក់ខ្លួនថា ការដែលបានជួបប្រទះនឹងធម៌ទេសនាម្ដងៗនេះ ជាការក្រពន់ពេកណាស់ បើបានប្រទះបានស្ដាប់ធម៌ទេសនាហើយ ឈ្មោះថាជាបុគ្គលមានកំពូមាន

សាសនាធំបំផុតទីរករកអ្វីប្រៀបផ្ទឹមគ្មានឡើយ ។ ចំណែកឯព្រះបរមពោធិសត្វ កាលបើព្រះអង្គរកបុគ្គលអ្នកសម្តែងធម៌ទេសនាពុំបានហើយ ក៏ដល់នូវសំវេគស្លុតស្លុបក្នុងព្រះរាជហឫទ័យថា អញប្រាសចាកធម៌ទេសនាហើយ ប្រយោជន៍អ្វីនឹងសោយរាជសម្បត្តិតទៅទៀត លុះទ្រង់ព្រះចិន្តាដូច្នេះហើយ ក៏លះបង់រាជសម្បត្តិប្រគល់ដល់អមាត្យទាំងឡាយ ស្រេចហើយព្រះអង្គចេញចាកព្រះនគរទៅក្នុងកាលនោះឯង ។ ព្រះបាទធម្មសោណ្ឌកមហារាជ កាលដែលព្រះអង្គចេញស្វែងរកព្រះសទ្ធម្ម តាមលំដាប់ស្រុកនិគមជនបទរាជធានីហួរហែទៅ ក៏បានទៅដល់ព្រៃហិមពាន្ត ។

ព្រោះហេតុនោះ ព្រះអរហន្តទាំងឡាយបាននាំរឿងនិទាននេះយកមកសម្តែងទុកក្នុងគម្ពីរមធុរសវាហិនីនេះ លោកពោលជាបទព្រះគាថាថា បុរេ កេរិញ្ញាកបេត្វា ធម្មសោណ្ឌោ ឧភានីតោ ជាដើម អធិប្បាយថា ព្រះបាទធម្មសោណ្ឌកពោធិសត្វ ជាទីពឹងនៃជនទាំងឡាយ ព្រះអង្គចាត់សេវកាមាត្យឲ្យវាយស្គរគ្រប់ទៅក្នុងនគរស្វែងរកអ្នកប្រាជ្ញចេះសម្តែងធម៌ទេសនា ទ្រង់នឹងព្រះរាជទានរង្វាន់តាំងពីពីរពាន់កហាបណៈ ដរាបដល់មួយកោដិ ក៏ពុំមានបុគ្គលណាមួយអាចហ៊ានទទួលយកឡើយ ហើយស្តេចឲ្យដំឡើងថ្លៃតាំងពីឲ្យធ្វើជាធំក្នុងស្រុកជនបទ ដរាបដល់ឲ្យសោយរាជសម្បត្តិជាស្តេច ព្រះអង្គទ្រង់ធ្វើជាខ្ញុំបម្រើវិញ ក៏ពុំមានបុគ្គលណាមួយ អាចទទួលសម្តែងធម៌ទេសនាថ្វាយព្រះអង្គបានឡើយ ។

ព្រះបរមក្សត្រិយ៍នោះ កាលបើព្រះអង្គរកបុគ្គលអ្នកសម្តែងធម៌ពុំបានហើយ ក៏ទ្រង់លះបង់រាជសម្បត្តិក្រោមស្វេតច្ឆត្រជាទីគ ម្រកប្រគល់ឲ្យអមាត្យទាំងឡាយ ពុំមានព្រះហឫទ័យអាល័យឡើយ ហើយស្តេចចេញទៅកាន់ព្រៃហិមពាន្ត ក្នុងកាលនោះហោង ។ ដោយតេជៈបុណ្យព្រះមហាសត្វ ទីអាសនៈសម្តេចអមរិន្ទ្រាធិរាជ ក៏បណ្តាលឡើងឲ្យក្តៅក្រហាយគួរជាទីអស្ចារ្យ ព្រះឥន្ទ្រស្តេចគង់ពុំបានកើតរំខានក្នុងព្រះទ័យ ក្នុងខណៈដែលព្រះអង្គចូលទៅដល់ព្រៃមហាវ័ននោះឯង ។

គ្រានោះ សក្កទេវរាជទ្រង់ព្រះចិន្តាថា: បណ្ឌុកម្ពលសិលាសនៈរបស់អញកើតជាក្តៅក្រហាយ នឹងអង្គុយពុំបាន តើព្រោះហេតុអ្វីហ្ន៎? ព្រះអង្គទ្រង់រំពឹងគិតដូច្នេះហើយ ក៏បើកទិព្វចក្ខុប្រមើលមើលមនុស្សលោក ហើយពិនិត្យមើលជម្ពូទ្វីបទាំងអស់ បានឃើញព្រះបាទធម្មសោណ្ឌកមហារាជ ស្តេចស្វែងរកបុគ្គលអ្នកចេះសម្តែងធម៌ទេសនាពុំបាន ហើយទ្រង់លះបង់រាជសម្បត្តិឥតអាល័យ ស្តេចចូលមកកាន់ព្រៃហិមពាន្ត ។ លុះព្រះឥន្ទ្រាធិរាជទ្រង់បានឃើញដូច្នេះហើយ ក៏គិតពិចារណាតទៅទៀតថា ព្រះបាទធម្មសោណ្ឌកមហារាជអង្គណាដែលទ្រង់លះបង់រាជសម្បត្តិ ព្រមទាំងព្រះញាតិវង្សទាំងជីវិតនៃខ្លួនដើម្បីស្វែងរកស្តាប់ព្រះសទ្ធម្មក្នុងគ្រានេះ, ព្រះបាទធម្មសោណ្ឌកមហារាជអង្គនោះមិនមែនជាសាមញ្ញសត្វដទៃផ្តេសផ្តាសទេ គឺជាអង្គពោធិសត្វនឹងបាន

ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធមួយព្រះអង្គក្នុងកប្បនេះដោយពិត ព្រះអង្គមានព្រះហឫទ័យចង់ស្តាប់ធម៌ទេសនា ប៉ុន្តែស្វែងរកបុគ្គលអ្នកប្រាជ្ញដេះសម្តែងធម៌ពុំបាន ហើយទ្រង់ចូលមកកាន់ព្រៃធំនេះ បើទ្រង់ពុំបានស្តាប់ធម៌ហើយ ក៏នឹងដល់នូវសេចក្តីទុក្ខធំដោយពិត បើអញមិនទៅសង្គ្រោះផងទេ យល់ឃើញជាពុំសមហេតុផលឡើយ, គួរតែអញទៅក្នុងទីនោះនៅថ្ងៃនេះ ដើម្បីស្រោចស្រប់ព្រះពោធិសត្វនោះ ដោយទឹកអម្រឹតសេគឺព្រះធម៌ ហើយនាំយកទៅដម្កល់ទុកក្នុងរាជសម្បត្តិដែលវិញទើបគួរ ។ សម្តេចព្រះសហស្សនេត្រទ្រង់គិតយ៉ាងនេះហើយ ក៏ហោះចុះមកពីស្ថានតាវតឹង្សទេវលោកទាយមកកាន់ស្ថានមនុស្សលោក ទ្រង់លះបង់អត្តភាពប្រក្រតីហើយ កាន់យកភេទជាយក្សអាក្រក់ទឹកយ៉ាងធំ គួរខ្លាចស្ញប់ស្ញែងពន់ពេកដើរចូលមក មានមុខឆ្ពោះទៅកាន់សំណាក់ព្រះមហាសត្វ ហើយសម្តែងខ្លួនឲ្យប្រាកដស្ថិតនៅក្នុងទីពុំឆ្ងាយពីព្រះបរមពោធិសត្វនោះឡើយ ។ ព្រោះហេតុនេះ បានជាព្រះអរហន្តទាំងឡាយលោកសម្តែងជាបទព្រះគាថាដូច្នេះថា ព្យគ្ឃរូបសីហាមហាភេរគហាត្តី ជាដើម អធិប្បាយថា ព្រះនរិន្ទ្រាធិបតីធម្មសោណ្ឌករាជ ព្រះអង្គមានសេចក្តីអផ្សុកមានប្រាថ្នាចង់ស្តាប់ធម៌ ហើយស្តេចចេញទៅអំពីនគរពារាណសី ត្រេចចូលទៅក្នុងព្រៃសេលព្រឹក្ស ប្រកបដោយញាតស្បាតដ៏ជិតសុខ្ញតែបន្ទាដ៏ប្រចូររីករាលដោយសត្វសាហាវ មានខ្លាធំ ខ្លាឃ្មុំ សត្វសីហៈឧនក្របីព្រៃគោព្រៃ , ដំរី

ខ្វាដម្បងជាដើម , នៅអាស្រ័យក្នុងព្រៃទាំងឯង , ដោយគេជះអានុភាព បុណ្យបារមីព្រះពោធិសត្វនោះ កាលនោះផ្ទៃដីមានពណ៌ល្អដូចសំពត់ កម្ពលក្រហមលឿងរបស់ព្រះឥន្ទ្រាធិរាជ ក៏បង្កើតក្តៅក្រហាប់ក្រហាយ ឥន្ទគង់ពុំបាន នាំអោយខានក្នុងព្រះទ័យ ទើបបើកទិព្វចក្ខុរមិលមើល ស្ថានមនុស្សលោក លុះបានជ្រាបហេតុនោះសព្វគ្រប់ហើយ ក៏ហោះ ចុះមកពីស្ថានទេវលោកនាយ មកកាន់ស្ថានមនុស្ស ហើយនិម្មិតអាត្មា ជាយក្សកាចបើងវែងរូបសគួរខ្លាចពន់ពេក មានសម្បុរខៀវស្រងាត់ដូចជា កំពូលភ្នំអញ្ជន មានមាត់ធំ មានចង្កូមគួរខ្លាច លៀនចេញមកខាងក្រៅ មានភ្នែកទាំងពីរធំក្រហមច្រាលដូចជាគំនរសម្រាមដែលភ្លើងឆេះ ហើយ មានច្រមុះខ្ទង់កណ្តាល មានចុងច្រមុះក្រហម មានសក់ខៀវពុកមាត់ជា ដុំរង មានពណ៌ក្រហមដូចរណ្តាតក្តើរ មានផ្ទៃពោះពណ៌ខៀវ មាន សម្បុរផ្ទៃទឹកដូចផ្កាលានគួរស្ញើម មានក្រចកជើងប្រឡាក់ដោយឈាម ជាប់ជានិច្ច មានបាតដៃធំពុំដែលលាងទឹកម្តង មានដម្បងដែកគ្រឿងអាវុធ ក្នុងដៃជាប់មិនដាច់ មានចង្កូមទាំងបួនមាត់គួរស្ញើម មានថ្ពាស់ប្រកប ដោយសរសៃជ្រួញ ៗ ដូចជាវល្លិ៍ មានតែសាច់មនុស្សជាអាហារបរិភោគ ប្រក្រតី មានជើងទាំងពីរក្រហមដូចដើមគ្រើន សម្តែងខ្លួនឈរនៅក្នុង បន្ទោះភ្នំ ឲ្យប្រាកដដល់ព្រះនរាធិបតីធម្មសោណ្ឌកមហារាជនោះឯង ។

គ្រានោះ ព្រះមហាសត្វបានឃើញឥន្ទ្រយក្សស្ថិតនៅក្នុងទីជិតនៃខ្លួន

ដូច្នោះហើយ ក៏ពុំបានខ្លាចញាប់ញ័រតក់ ឬរួញចិត្តនឹងព្រឺព្រួចក្រោឡើយ ព្រោះព្រះឥន្ទ្របានរំពឹងគិតថា យក្សដែលមានសភាពយ៉ាងនេះ មុខជាចេះសម្តែងធម៌ទេសនាដោយពិត, បើដូច្នោះ ត្រូវតែអញចូលទៅជិតក្នុងសំណាក់អារក្សទឹកនោះហើយនឹងស្តាប់ធម៌ទេសនា ដ្បិតកិរិយាដែលបានស្តាប់ធម៌ទេសនានោះជាទីនាំមកនូវសេចក្តីសុខ និងប្រយោជន៍ដល់អញអស់កាលជាយូរអង្វែងទៅឯអនាគតពុំលែងឡើយ លុះព្រះបរមពោធិសត្វទ្រង់គិតដូច្នេះហើយ ក៏ទ្រង់រំពឹងគិតទៅទៀតថា ថ្ងៃនេះត្រូវតែអញចូលទៅជិតយក្សនោះហើយសួរយក្សមើលគួរ ទើបព្រះឥន្ទ្រយាងចូលទៅជិតនិយាយសន្ទនាជាមួយនឹងយក្សនោះ ពោលជាបទព្រះគាថាដូច្នេះថា អស្មឹ វនស្មឹ តរុសណ្ឋាន ណ្ឌិតោ ជាដើម អធិប្បាយថា បពិត្រមហាយក្ស ! ជំមានខ្លួនប្រដាប់ដោយទ្រង់ទ្រាយពេញជំរង់ គួរអ្នកមានអានុភាពច្រើន សឹងប្រដាប់ដោយគ្រឿងអាភរណៈផ្សេង ៗ ស្ថិតនៅក្នុងព្រៃនេះ អ្នកជាបុគ្គលមានចិត្តពុំបានតក់ស្លុតខ្លាចអ្វីឡើយ ចំណែកខាងយើងបានលះបង់រាជសម្បត្តិនឹងពួកញាតិទាំងឡាយដើរស្វែងរកបុគ្គលអ្នកសំដែងធម៌ទេសនា បានចូលមកកាន់ព្រៃនេះ បើយើងសួរនូវសេចក្តីសង្ស័យឯណាចំពោះអ្នកសូមអ្នកសម្តែងប្រាប់សេចក្តីសង្ស័យនោះដល់យើង បពិត្រយក្ស ! ថាបើអ្នកបានចេះព្រះធម៌ សូមអ្នកសម្តែងធម៌ក្នុងបទព្រះគាថាមួយ

ដែលព្រះសុគតបានសម្ដែងហើយ ដល់យើងឥឡូវនេះផង ។

លំដាប់នោះឥន្ទយក្សតបវិញថា បពិត្រមហាពជ ! យើងបានបេះព្រះធម៌ដែលព្រះជិនស្រីទ្រង់សម្ដែងទុកមកដោយចំណែកមួយ ជាធម៌ដ៏ប្រសើរវិសេសជាងរសទាំងពួងមែន តែបើយើងសម្ដែងធម៌នោះដល់ព្រះអង្គហើយ តើព្រះអង្គនឹងប្រទានវត្ថុអ្វីដល់យើងជាអ្នកសម្ដែងធម៌វិញ ? ។

គ្រានោះ ព្រះមហាសត្វតបថា បពិត្រមហាយក្សដ៏ចំរើន! បើយើងស្ថិតនៅក្នុងរាជសម្បត្តិនៅក៏ យើងនឹងប្រទានផ្ដល់អ្នកឱ្យវិសេសប្រសើរនៅបាន ឥឡូវយើងចូលមកក្នុងព្រៃនេះតែម្នាក់ឯង បើវៀរលែងតែរាងកាយរបស់យើងចេញហើយ យើងនឹងរកវត្ថុវិសេសប្រទានដូចម្ដេចបាន ប្រសិនបើ អ្នកប្រាថ្នាចង់បរិភោគសាច់ឈាមរបស់យើង ។ នឹងលះរាងកាយនេះបូជាព្រះធម៌ ឱ្យអ្នកបរិភោគជាអាហារក្នុងថ្ងៃនេះឯង ដ្បិតស្បៀងអាហារដទៃរបស់អ្នកក៏ពុំមានដែរ អ្នកត្រូវសំដែងធម៌ទេសនាឱ្យយើងស្ដាប់ជាមុនសិនចុះ យើងនឹងលះរាងកាយនេះបូជាដល់អ្នកបរិភោគក្នុងកាលជាខាងក្រោយដោយពិត ។ ឥន្ទយក្សបានស្ដាប់ហើយពោលតបថា បពិត្រមហាពជ! យើងមានសេចក្ដីស្រេកឃ្លានពេកណាស់ ដរាបណាយើងបានបរិភោគសាច់នឹងផឹកឈាមឱ្យឆ្អែតស្រួលខ្លួន បន្ទាប់នឹងនៅសេចក្ដីក្រវល់ក្រវាយក្នុងកាយ

ជាមុនសិន ដកបនោះទើបអាចនឹងសម្ដែងធម៌ទេសនាឲ្យព្រះអង្គស្ដាប់បាន ដ្បិតយើងអត់អាហារយូរថ្ងៃណាស់ហើយ សេចក្ដីស្រេកឃ្លានកែនបៀតបៀនញាប់ញ័រសព្វសពាង្គកាយ ទឹងសម្ដែងធម៌ទេសនាដូចម្ដេចបាន ។

លំដាប់នោះ ព្រះមហាបត្តបានស្ដាប់ហើយក៏ពោលថា បពិត្រយក្ស! ប្រសិនបើ អ្នកបរិភោគយើងមុនហើយ សឹមសម្ដែងធម៌ទេសនាជាខាងក្រោយ តើនឹងសម្ដែងធម៌ឲ្យអ្នកណាស្ដាប់ បើយើងស្លាប់ទៅហើយ , ចំណែកអ្នក មានលាភបានទទួលសាច់បរិភោគ ព្រោះតែការបានសម្ដែងធម៌ឲ្យយើងស្ដាប់ប៉ុណ្ណោះឯង , ដូច្នេះត្រូវអ្នកពិចារណាឲ្យបានដឹងដោយសមគួរតាមពិតចុះ ។

លុះព្រះបរមពោធិសត្វទ្រង់ត្រាស់យ៉ាងនេះហើយ ឥន្ទ្រយក្សក៏ទូលតបវិញថា បពិត្រមហាកដ! ពាក្យនេះប្រពៃហើយ , បើដូច្នោះត្រូវព្រះអង្គស្ដេចឡើងទៅលើភ្នំនេះហើយ ស្ថិតនៅលើកំពូលភ្នំទំលាក់ព្រះកាយចុះមកសំដៅមាត់ខ្ញុំ, កាលបើព្រះអង្គលោតទំលាក់ព្រះកាយចុះមកហើយ ខ្ញុំនឹងសម្ដែងធម៌ទេសនាឲ្យព្រះអង្គស្ដាប់បណ្ដើរកាលនោះឯង, បើព្រឹត្តិការណ៍បែបនេះសមហេតុហើយលាភដ៏ប្រសើរ ដែលព្រះអង្គបានស្ដាប់ធម៌ទេសនាក្ដី លាភដែលខ្ញុំបានបរិភោគសាច់ឈាមក្ដី នឹងបានស្មើគ្នាតាមពិត , ការដែលខ្ញុំបរិភោគនូវសាច់នឹងឈាមសោត ក៏នឹងមានប្រាកដដូច្នេះឯង ។

(នៅមានត)

# មហោសថជាតក

លោកអ៊ឹម-កន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កិម-គួរ ពិនិត្យ

## ឆមោ ៣ ជិង

បញ្ចាលោ សព្វសេនាយាតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ អត្តនោ បញ្ញាបារមឹ អារព្ភ កថេសិ ។

សត្ថា គឺ សត្ថវាហោ សត្ថនាយកោ ព្រះអង្គជា នាយក នៃពួកនាំគៀរគេប្រមូលបញ្ចូលអស់ពពួកសត្វទាំងអស់ឲ្យរួចរស់ទៅតាមទុស្សបត្តផលទាំងឡាយជាក់ដល់ជាក់លំពួកដំបូងទី ដំសិរីទ្ធិបរិបូណ៌ គោលតឹមអម្រឹតបូរីស្រីមហានគរនិព្វាន ដ៏ជាឋានបរមសុខក្សេមប្រសើរ វិហរន្តោ គឺ ចតូសុ ឥរិយាបថេសុ វត្តមា-នោ កាលព្រះអង្គគង់សម្រេចសម្រាន្ត ដោយបន្ទូរព្រះឥរិយាបថស្រគត់កំណត់ព្រះអង្គនោះមានបួន មិនឲ្យជួនទូលេទ្ធិតិរេចិត្តនៃបត្តផលទាំង-ឡាយ ជេតវនេ គ្រង់ឋានអារាមនាមហៅព្រះស្រីជេតពនសុគន្ធ-កុដីស្រីមហាវិហារ អារព្ភ គឺ អារម្មណំ កត្វា ព្រះអង្គធ្វើឲ្យវាហេតុ ជាអារម្មណ៍បន្ទិចស្រេចហើយ ទ្រង់ប្រារព្ធនូវការបញ្ញាបារមី ថ្វីនៃព្រះអង្គឯង កថេសិ គឺ ធម្មំ ទេសេសិ ទើបព្រះអង្គសំដែងថ្វីនៃព្រះធម៌វិសេសទេសនា ឥទំ មហោសថជាតកំ នូវទិពានជំ·

ណាលកាលព្រះអង្គស្ដេចត្រាច់ត្រង់ ទៅកាន់ទីតពរផ្កសព្វព្រៃគ្រាលហោន យកកំណើតកើតជាព្រះពោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាមករបវរវិសេស ឈ្មោះព្រះមហោសថនេះ ។ អាធិកាថាបនេន អត្ថជា ឧប-លក្ខិតំ ទើបព្រះអង្គមកកត់សំគាល់នូវទំនងគន្ធដើមបទកំណត់អក្សរ បវរព្រះគាថានេះជាដើមអាទិគឺ បញ្ហលោ សត្វសេនា ឃាតិ នេះឯងដ៏ជាប្រធានដើមបទកំណត់ព្រះមហោសថជាតកនោះឯងហោង ។

ឯកាធិវសម្ហិ ភិក្ខូ ធម្មសភាយំ សន្និសិន្នា តថា-គតស្ស បញ្ញាបារមី វណ្ណយន្តា និសីទិសុ បពិត្រអើយ មានកាលសម័យថ្ងៃមួយ រីអស់ពពួកភិក្ខុសង្ឃអង្គអហេត្តាំណា ស្រពង់តាំងឡាយ សឹងដ៏មានចិត្តៈខាៈបព្យាយពេះកាយ បបួលគ្នាទៅអង្គុយជុំនុំនៅឯធម្មសភាសាលា ដ៏ជាឋានជុំនុំនែងទីស្ដាប់ធម៌វិសេសទេសនា នោះហើយ មានភិក្ខុព្រឺទួយព្រះអង្គគង់ឯដើមកាសនាជាបង្អស់ ហើយ បណ្ដាលនូវពាក្យមេត្រីទៅនឹងអស់ភិក្ខុកំឡោះផងតាំងឡាយថា ភិក្ខវេ ម្នាលភិក្ខុផងតាំងឡាយអើយ រីព្រះដ៏មានបុណ្យអម្ចាស់វិសេសថ្លៃនៃយើងនេះ មហាបញ្ញោ ព្រះអង្គមានព្រះប្រាជ្ញានោះដ៏ច្រើនមហិមាក្រៃ ឥតអ្នកឯណាដទៃផ្ទឹមស្មើនឹងព្រះអង្គនោះបានឡើយ ។ បុថុបញ្ញោ ព្រះអង្គមានព្រះប្រាជ្ញានោះក្រាស់មហិមាក្រៃពេក ។ ហាសបញ្ញោ

ព្រះអង្គមានព្រះប្រាជ្ញានោះ ដ៏ជ្រៅអាចសម្រេចសម្រួលបញ្ចូលចិត្តឲ្យជាទីស្រឡាញ់នៃអស់មនុស្សសត្វទាំងឡាយ ។ គម្ភីរបញ្ញា ព្រះអង្គមានព្រះប្រាជ្ញានោះ ដ៏ជ្រៅឆ្ងាយទូលាយក្រៃ ។ បុថុបញ្ញា ព្រះអង្គមានព្រះប្រាជ្ញានោះ ដ៏ផុលដ៏និងឯង ឥតគ្រូពីព្រេងណាទៅប្រៀនប្រដៅព្រះអង្គឡើយ ។ លហុបញ្ញា ព្រះអង្គមានប្រាជ្ញានោះដ៏ស្រាលស្រេចល្អលួះមហិមាក្រៃ ។ ជវនបញ្ញា ព្រះអង្គមានព្រះប្រាជ្ញានោះ ដ៏ឈ្លាសវៃលឿនឆាប់មហិមាក្រៃលែងដូចជវនមហាហង្ស ។ តិក្ខបញ្ញា ព្រះអង្គមានព្រះប្រាជ្ញានោះ ដ៏មុតថ្លាមហិមាក្រៃលែងដូចបំពៃវិតតាចក្រវត្តិក្រុងភារាធិរាជ ។ និព្វេធិកបញ្ញា ព្រះអង្គមានព្រះប្រាជ្ញានោះវៃនិងអាចឲ្យសត្វផងទាំងឡាយទំព្យួសនូវបង់ ។ បរប្បវាទមទ្ទនោ. អត្ថោ បញ្ញាទុកាវេឌ ព្រះអង្គមានព្រះប្រាជ្ញានោះ ផ្ចាញ់ញាំញីបុកបែនគិនប្រាជ្ញាអ្នកដទៃឥតបើទីងហើយប្រកួតផងបានឡើយ ធម្មិត្តា ព្រះអង្គអាចឲ្យទៅទដំបូន្មានលោមលួងប្រដៅ ព្រាហ្មណោ នូវអស់ព្រាហ្មណ៍ផងទាំងឡាយ ក្ខូជឧត្តានយោ ជាម មានឈ្មោះកូដទន្តព្រាហ្មណ៍ឯងជាដើម បរិព្វាជកោ នូវអស់បរិព្វាជកផងទាំងឡាយ សភិយោ មានសភិយព្រាហ្មណ៍ឯងជាដើម យក្ខោ កំ. នូវអស់យក្សផងទាំងឡាយ អាឡវកោ យោ ដ៏មានអាឡវកយក្សឯងជាដើម ទេវតាយោ នូវអស់ទេវតាផងទាំងឡាយ សក្កាន-

យោ ដ៏មានឥន្ទ្រាធិកដឯងជាដើម ព្រហ្មា ចោ ច នូវអស់ព្រហ្មផង ទាំងឡាយ ៣ តក្កាធ យោ ដ៏មានពកព្រហ្មឯងជាដើម ៗ រីព្រះ តថាគតអង្គាសវិសេសថ្លៃនៃយើងនេះ ព្រះអង្គអាចឲ្យទ្រង់ដំបូន្មានលោម លួងប្រដៅ ដោយនូវអានុភាពព្រះប្រាជ្ញាចិត្តថ្លៃនៃព្រះអង្គ អាចធ្វើឲ្យ អស់មហាជនផងទាំងឡាយទីព្យសនបង់នោះហើយ ព្រះអង្គអាចឲ្យទ្រង់ ដំបូន្មានដល់អ្នកបួសនោះ មួយអន្លើនូវអស់ពពួកមហាជនផងទាំងឡាយក៏ គឺព្រះអង្គអាចនាំទៅសណ្ឋិតនៅក្នុងលើផ្លូវមគ្គផលអំពល់នូវនិព្វាន ដ៏ ជាឋានបរមសុខក្សេមប្រសើរហោង ៗ

បពិត្រអើយ រីអស់ភិក្ខុសង្ឃផងទាំងឡាយនោះ មកជុំគ្នាស្រដី សរសើរអំពីព្រះប្រាជ្ញាបារមីថ្លៃនៃព្រះដ៏មានបុណ្យនោះហើយ វាមិនសោះ សូន្យទេឡើយ ក៏សំរិទ្ធជ្រួតជ្រាបដកបរទៅដល់ព្រះសោតទិព្វថ្លៃ វិសេសនៃព្រះដ៏មានបុណ្យ ព្រះអង្គជ្រាបដំណឹងហើយ ព្រះអង្គទ្រង់ព្រះ ចិន្តាពិចារណាថា ឥឡូវនេះ អស់ភិក្ខុសង្ឃផងទាំងឡាយ ទៅអង្គុយ ជំនុំនៅក្នុងធម្មសភាសាលា ហើយសឹងស្រដីសរសើរដំណើរអំពីព្រះបារមី ចិត្តថ្លៃនៃអញតថាគតហើយ ហះនូ ! យើ ! ទីងកប់ជាអស្ចារ្យក៏ទេអ្វីដូច្នេះ ហ្នឹង ! អញតថាគតបានត្រាស់ជាព្រះពុទ្ធប្រាកដហើយ បើដូច្នេះហើយ រីធម៌វិសេសទេសនានៃអញតថាគតកាលកើតជាមហោសថបណ្ឌិតអ្នក ប្រាជ្ញនោះ សមនឹងប្រាកដក្នុងកណ្តាលជំនុំនៃអស់ភិក្ខុសង្ឃផងទាំង

ឡាយ ទៅញុំធម្មសភាសាលានោះឯងមិនទេឡើយ ម្ល៉ោះហើយទើប ព្រះអង្គស្រង់ទឹកទៅទ្វារទឹកអបត្រឡប់ ទ្វារគន្ធពិដោរ គឺកិច្ចផងតែងផង គ្រឿងនាំមកទូបង្អួចប៉ារ៉ា ព្រះអង្គស្រង់ស្រេចហើយ ទើបស្តេចទ្រង់នូវត្រៃ ចីវរបរមហាបង្សុកូល ឃុំគ្រលុំស្រេចស្តេចលីលា យាត្រាចេញទៅអំពី ព្រះសុគន្ធកុដិសិរីមហាវិហារ ដំមានព្រះដំណើរនោះសីហនាទគគាតបីដូច ដំណើរកេសរាជសីហ៍ចេញកំឡោះ ផ្លោះចេញអំពីលង្ហែកគុហាមាស ដំប្រាសលែងក្តុកខ្លាចនូវម្រឹគផងទាំងឡាយ កាលណាបើព្រះអង្គស្តេច លីលាទៅដល់ធម្មសភាសាលានោះហើយ ព្រះអង្គឡើងទៅគង់ញុំដំលើ ត្រៃបញ្ញត្តបវរពុទ្ធាសនា ដំប្រដាប់ប្រសើរប្រពៃ ទើបព្រះអង្គមានព្រះ ពុទ្ធដីកាដណ្តឹងថា ម្នាលអាវុសោភិក្ខុផងទាំងឡាយអើយ នាអាវុ-សោបបួលគ្នាមកអង្គុយជុំគ្នានូវញុំធម្មសភាសាលានេះ តើមានបើស្រដី និយាយអំពីដំណើររឿងអ្វីខ្លះ ៗ ហ្ន៎! ម្តេចក៏អាវុសោមិនបបួលគ្នាចេញ ទៅសង្គ្រោះគ្រងទំនេរមេត្តាករុណា ប្រាថ្នាសម្បត្តិអរហត្តនិព្វានដ៏ជាឋាន ប្រសើរទីទៃ ៗ ហ្ន៎, ម្តេចក៏មកអង្គុយស្ងៀមព្រងើយអ្វីនៅនេះដូច្នេះ ? ៗ

៩ មាឃ ឆាមាត្ន រុំត្ត រីអស់ភិក្ខុផងទាំងឡាយនោះ ស្តាប់ព្រះ បន្ទូលថ្លៃនៃព្រះដ៏មានបុណ្យដូច្នោះហើយ សឹងលុតជង្គង់លើកកំបង់អញ្ជ-លីផាក់លើសិរសាតាត្ថាភាព ក្រាបថ្វាយបង្គំទូលថា ករុណា ករុណា បពិត្រព្រះដ៏មានបុណ្យអម្ចាស់វិសេសថ្លៃខ្ញុំអើយ រីអស់យើងខ្ញុំទាំង

អម្បាលនេះ មកអង្គុយជុំគ្នានៅធម្មសភាសាលានេះ មិនស្រដីអំពី ឥត្ថីភាព បុរិសភាព ឲ្យជាមន្ទិលពិកាល់ក្នុងកំឡុងព្រះសាសនាព្រះអង្គ ដ៏ជាអម្ចាស់នេះឡើយ, បពិត្រព្រះដ៏មានបុណ្យអើយ នាយើងខ្ញុំទាំង អម្បាលនេះ មកស្រដីសរសើរតែអំពីព្រះប្រាជ្ញា ព្រះបារមីថ្លៃនៃព្រះអង្គ នោះ យល់កើតជាអស្ចារ្យក្រៃកាល ប្រសើរក្រៃពេកឮដ៏លោកនេះ ឥត បុរសបុគ្គលឯណាមួយ ទឹងផ្ទឹមឲ្យត្រឹមស្មើនឹងព្រះអង្គឡើយ ។ អស់ភិក្ខុផង ទាំងឡាយ ទូលព្រះដ៏មានបុណ្យនូវប្រការអម្បាលនោះហើយ ទើបព្រះ ដ៏មានបុណ្យព្រះអង្គបន្ទូលវិញថា ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយ អើយ ទឹងពប់ហៅថាអស្ចារ្យអ្វីដូច្នេះ នាអញតថាគតបានត្រាស់ ច្បាស់ប្រាជ្ញាសពេជ្ញតាញាណបានជាព្រះពុទ្ធប្រាកដហើយនេះ ដែល លោកទឹងពប់ហៅជាអស្ចារ្យនោះ គឺនាកាលមុននាយឡើយនោះ កាលអញតថាគតមានប្រាជ្ញាពុំទាន់ចាស់ បារមីពុំទាន់ទុំ តែងសង្វាត សន្សំសាងបន្ទំពោធិសម្ភារបារមី ខ្ញុំក្រវើនខំបំរើនឲ្យបានត្រាស់ជាព្រះពុទ្ធ ប្រាកដនោះ គឺកាលអញតថាគតយោនយកកំណើត កើតជាពោធិសត្វ មួយព្រះអង្គទ្រង់ព្រះនាមឈ្មោះចៅមហោសថបណ្ឌិតអ្នកប្រាជ្ញ អាចផ្ចាញ់ ព្រះបាទចុលណីព្រហ្មទត្តរាជ ហើយនូវអាចារ្យកេវដ្ដព្រាហ្មណ៍នោះគូរ ទើបហៅថាអស្ចារ្យក្រៃកាលក្រៃអេះ ។ វត្វា តុណ្ហី អហោសិ ព្រះដ៏មានបុណ្យ ព្រះអង្គមានព្រះបន្ទូលសំដែងថ្លែងធ្វើឲ្យជាហេតុជាទំនង -

គន្ធិនបន្តិចទៅទៀត ព្រះអគ្គិគង់ស្ងៀមស្ងប់បញ្ចប់ព្រះពុទ្ធដីកាវិញហោង ។ ភោហិ យាចិតោ អគ្គិំ អាហារ៍ បពិត្រអើយ ក្នុងកាលនោះ រីអស់ភិក្ខុសង្ឃអគ្គអរហន្តាទីណាស្រេចផងទាំងឡាយនោះ បានដឹងហេតុ ព្រះដ៏មានបុណ្យនូវប្រការអម្បាលនោះហើយ សឹងជីលើកគំបង់អញ្ជលី ដាក់លើសិរសាអាត្មាភាព ក្រាបថ្វាយបង្គំប្រណាម្យសូមអារាធនានិមន្ត ព្រះដ៏មានបុណ្យទូលថា ករេត្ថ ករោហិ បពិត្រព្រះដ៏មានបុណ្យប្រសើរ អើយ សូមទានទាកាលអម្បាញ់មិញនោះ ព្រះអគ្គិមានព្រះបន្ទូលថាកាល មុននាយនោះ ព្រះអគ្គិយោនយកកំណើតកើតសម្ភពប្រសូតជាពោធិសត្វ មួយព្រះអគ្គិ ទ្រង់ព្រះនាមករវេវិសេសឈ្មោះហៅ ព្រះមហោសថ នោះ គឺមោះយើងខ្ញុំនឹងបានយល់ បានដឹងដាក់ច្បាស់ប្រាកដ ឲ្យឆ្ងាយ ទូលាយនោះឥតអគ្គិមានឡើយ បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ សូមទានរីអស់យើងខ្ញុំទាំងអម្បាលនេះ សូមអារាធនានិមន្តព្រះអគ្គិ សូម ព្រះអគ្គិយកនូវប្រាជ្ញាទិព្វវិសេសមួយឈ្មោះ បុព្វេនិវាសានុស្សតិញាណ ដ៏ជាសំណាញ់តេទមកក្រាលឱបក្រសោបនូវព្រះជាតិកំណើតព្រះអគ្គិនោះ នាំមកបារំលែងសំដែងនូវព្រះធម៌វិសេសទេសនា ជាសណ្តាប់ប្រាប់អស់ យើងខ្ញុំនាគណ្តាលជំនុំឥឡូវនេះហោង ។ រីព្រះដ៏មានបុណ្យព្រះអគ្គិ ស្តេចទ្រង់នូវព្រះសណ្តាប់អស់ភិក្ខុផងទាំងឡាយនោះហើយ ព្រះអគ្គិ ទទួលយកនិមន្តអស់ភិក្ខុផងទាំងឡាយស្រេចហើយ ទើបព្រះអគ្គិបន្ទូល

សូត្រជាបទព្រះគាថាដូច្នេះ :

អតីតេ ភិក្ខវេ មិថិលាយំ វិទេហរដ្ឋេ វិទេហោ នាម រាជា រជ្ជំ ការេសិ ។ ប្រែថា ភិក្ខវេ ម្នាលអាវុសោភិក្ខុផងទាំងឡាយអើយ អតីតេ កាលេ ក្នុងកាលកន្លងហួសអន្តរកប្បកល្បទាំងកំប៉ុងប៉ាត់ស្ងាត់ កន្លងរម្លងទៅហើយនោះ ក្សណនោះ មានមហាក្សត្រាធិរាជមួយព្រះអង្គទ្រង់ព្រះនាមករបវរវិសេស ឈ្មោះហៅព្រះបាទវិទេហរាជសោយរាជសម្បត្តិ ស្ថិតនៅដោយនូវទសពិធរាជធម៌សម្មាអាជីវៈ ចិញ្ចឹមអស់រាស្ត្រប្រជាមហាជនផងទាំងឡាយ នៅក្នុងមិថិលាបុរីស្រីមហានគរបវររាជដ្ឋាន ហើយមានអ្នកប្រាជ្ញទាំង៤នោះជាអ្នកចេះធម៌អាថ៌សេចក្តីលោកិយលោកា ជាភ្នាក់ងារតែងទូន្មានប្រៀនប្រដៅនៃព្រះមហាក្សត្រាធិរាជនោះឯងហោង ។ អ្នកប្រាជ្ញទាំង៤នាក់នោះសោត មួយឈ្មោះអាចារ្យសេនក, មួយឈ្មោះអាចារ្យបុក្កុស, មួយឈ្មោះអាចារ្យកាមិន្ទ, មួយឈ្មោះអាចារ្យទេវិន្ទ ។ អ្នកប្រាជ្ញទាំង៤នោះ សឹងមានប្រាជ្ញាស្មើគ្នាទាំង ៤ នាក់នោះឯងហោង ។

តទា រាជា ពោធិសត្តស្ស បដិសន្ធិគ្គហណទិវសេ បច្ចូសកាលេ ឯវរូបំ សុបិនំ អទ្ទស ។ល។ វាតិតំ សាសបពីជមត្តម្បិ បញ្ញាយតិ ។ បពិត្រអើយ ក្តី

កាលនោះ រីព្រះបាទវិទេហរាជ ស្ដេចចូលទៅផ្ទំនៅក្នុងក្រឡាព្រះបន្ទំ បរមសុខសួស្ដីប្រសើរ ដ៏ប្រដាប់មានសិរីសួស្ដីប្រពៃ ស្ដេចផ្ទំលក់ជាសុខសប្បាយ លុះទៀបហៀបនឹងព្រឹកបែកបច្ចូសកាលជាលព្រាលឡើងស្ដេចទ្រង់ព្រះសុបិនឃើញដ៏កាលថ្ងៃដែលចាប់បដិសន្ធិនៃព្រះពោធិសត្វនោះឯង ៗ ព្រះមហាក្សត្រាធិរាជ ស្ដេចទ្រង់ព្រះសុបិន មានសុភាពបន្ទូលថាដូច្នេះ ស្ដេចយល់ហាក់ដូចគំនរភ្លើងធំទាំង ៤ ឆេះឡើងក្នុងរឿង ជាបន្ទាយ ហាក់យល់គំនរឡើងមួយក្នុងត្រឡឹងប៉ុនអំពិលអំពែក ឆេះផ្ទែកជាលពល លេចឡើងឃើញកណ្ដាលគំនរភ្លើងធំទាំង ៤ នោះឯង ដ៏ឆេះជាលពលឡើងត្រឡឹងប៉ុនអំពិលអំពែកនោះ សឹងក្ដីឡើងរៀងកបដកបទៅដល់ព្រហ្មនាលេដ៏ពណ្ណរាយល្អ ដ៏អាចឲ្យក្ដីរៀងទៅដល់សកលកំពែងចក្រវាឡជាលទៅអស់ទ្វីបទាំង ៤ ហើយស្ងិតទៅ ដោយហេតុទៅសោត នៅសល់ប្រមាណប៉ុនគ្រាប់ស្ពៃ ប្រាយកាយជ្រុសមកឃើញផ្លែក្រមសឹងដ៏យល់ប្រាកដ ៗ រីអស់លោកជនពេលទាំងទេវតា សឹងនាំទូវសាធុការបណ្ណាការមកបូជានាគំនរភ្លើងតូចនេះជាដើម គឺទៀនធូបគន្ធមាលាផ្កាមាសរតនាករផង ទាំងគណនា គ្រាប់ពុំបានឡើយ ហើយរីអស់មហាជនជនទាំងឡាយ សឹងដើរទៅដើរមកដោយខ្ទួវឃើញដ៏លផ្ទែកភ្លើងនោះក៏ សូម្បីនឹងមានមាត្រាកំដៅដល់ រោមមួយក្ដីក៏មិនក្ដៅឡើយ ៗ រីព្រះបាទវិទេហរាជ ទ្រង់ព្រះសុបិនស្រេចស្ដេចទ្រង់តើងឡើងអំពីក្រឡា

ព្រះបន្ទំ ហើយស្តេចមានព្រះហឫទ័យនោះ ភិតខ្វាចពុំអាចនឹងទប់បាន ឡើយ ហើយស្តេចតើនឡើងអំពីក្រឡាព្រះបន្ទំ ហើយស្តេចមានព្រះរាជហឫទ័យទ្រង់ព្រះចិន្តាពិចារណាថា ឱ! សម្តិអញនេះ នឹងកើតមានប្រការនោះតើដូចម្តេចទៅអេះ? ព្រះអង្គទ្រង់ព្រះចិន្តាពិចារណាស្រេចហើយស្តេចគង់ស្ងៀមនៅហោង ។

អរុណាំ ឧដ្ឋាបេសិ លុះព្រះអាទិត្យជិតជាលប្រាលឡើងបន្តិចក្តី អាចារ្យទាំង ៤ នោះមកកាន់ឋានព្រះមហាក្សត្រអំពីព្រឹកព្រហាមប្រយោជន៍នៅបំរើគាល់ហៅ ចូលទៅក្នុងព្រះរាជមន្ទីរកើ្តអំពីបុកណានៃស្តេចស្រេចហើយ ក្រាបថ្វាយបង្គំប្រណម្យទូលសួរដណ្តឹងថា ទេវៈ បពិត្រព្រះនរបតីស្រីសម្មតិទេពមហារាជក្សត្រថ្លៃអម្ចាស់វិសេសខ្ញុំអើយ នាព្រះអង្គស្តេចផ្ទំកំឡុងរាត្រីនេះ តើជាសុខសប្បាយទូលាយកំឡុងព្រះហឫទ័យថ្ងៃឬមួយពុំសុខសប្បាយ? ។ ក្សិណនោះ ព្រះបាទវិទេហរាជស្តេចស្តាប់ពាក្យនៃអាចារ្យទាំង ៤ ទូលសួរដណ្តឹងដូច្នោះហើយក្តី ស្តេចបន្ទូលវិញថា ហៃអាចារ្យទាំង ៤ អើយ សុខំ មេ សុខនៃអញ, ឯ កុតោ នឹងមានអំពីឯណា ពៅអើយ នាអញដេកយប់មិញនេះ អញយល់សប្តិមានសភាពបង្គួរថាដូច្នេះ ។

(នៅមានត)

# រឿងមរណមាតា

(តមក)

លោកកវី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត

## បទព្រហ្មគីតិ

លង់លុះសាយណ្ហ សូរ្យាទេវទន្លាបទៅ មរណមាតាទៅ

ចូលបង្គំជើងព្រឹក្សា ៗ ស្រេចហើយនាងវិលវិញ វិលទៅដេញគោ

យាត្រា ផ្ទោះមកបានត្រឹមហា ដើរដេញបលុះដល់មក ៗ ដល់បាន

ឃ្មានចំណី ស្ងួនឥតបានស្ងួរក បាយត្តាំងទូវបាយកក លុះដល់មក

បំរើគេ ៗ ព្រឹកល្ងាចរៀងរាល់ថ្ងៃ កិច្ចការធ្វើស្ងួនធ្ងន់ថៃ រងទុក្ខគេដាក់

ដៅ គ្មានបោលល្ហប្រាណស្រណុក ៗ រងតាំងពីដប់ឆ្នាំ ទុក្ខទ្រូងក្រាំជាំ

តាំងមុខ ផ្អេះផ្អាបត្រីប្រហុក កក់សាបម៉េគោពោរពេញកាយ ៗ សំពត់

មួយចង្កេះ ស្អុយផ្អាបផ្អេះផាច់យោយ ឥតឈ្នួលទីទ្រគបកាយ ខ្លួនទទេ

ទុបអង្គប្រាណ ៗ នឿយព្រួយក្តៅក្រោ រកនរណាករុណាគ្មាន ពោះ

អត់ពោះស្រេកឃ្លាន ពោះឈឺចុកត់ឥតគេថៃ ៗ ស៊ីបាយបានតិចណាស់

ដោយបាតខ្ទះសល់ដែលគេ ស្ងួនអើយសង្សារថៃ បានបរិភោគកន្ទះពោះ ៗ

មិនដែលផ្អែតបានម្តង ស្គមពេកពង់ស្ទើរមិនរស់ ស្គមឃើញឆ្អឹង

តាំងអស់ ពោះធ្លូស្ទិតជិតថ្លឹងខ្លួន ៗ ម្លោះប្រើមិនប្រណី ទឹងស៊ុំឆ្អក់សំពង
បែកឈាមផ្លែពាសខ្លួន ដូចគេសាប់ឥតចន្លោះ ៗ មិនមានទឹកប្រណី
មេឆាលីឥតសប្បុរស ខ្ទួនរាក់រាយមិនអស់ ហើយប្រើគួនរាក់រាយដៅ ៗ គា
ស្បូវស្មួនកំព្រា ទល់ទុក្ខាមិនមានល្ហែ លុះយប់នាងរៀបថៃ ទ្រព្យរបស់នាង
ដេកទៅ ៗ យាមេអន្ធរត្តេ ទៀបទៅឯពេលយប់ជ្រៅ បិសាចមាតានៅ
ដើមល្វើសប្រែកាឡា ប្រែប្រាណដូចនារីស្រី កុលគេសីវាមាតា ដើរដល់
ឡើងគ្រឹហា នាងមរណមាតាទៅៗ ចរចូលក្នុងដំណេក ឃើញកូនដេកកើត
មិនសៅ ទាក់ផ្សាភ្ជួលក្តៅ ក្លួលខ្សឹកខ្សួលពុំស្រួលស្មោះ ៗ ពុកណែនសែន
អនេក គាណ៌តតេកចោរពេញពោះ កើតទុក្ខសោកស្រណោះ ទឹក
គាស្សូរកាណិតកូន ៗ បិសាចជាមាតា សែនសោកាថាទស្សួន ដេកម្នាក់
ឯងសោះសូន្យ សមកូនស្ងួននាងអើ ៗ ដេកទបដៃក្របិត គ្មានសំពត់
គ្របអង្គា កន្ទេលគ្មានក្រឡា ដេកនោបផ្ទាល់ទទេ ៗ មាសម្តាយម្តេចពិបាក
ខ្វនគោកយាកម្ល៉េះមាសម៉ែ កន្លួបខ្លួនជាំស៊េ ដូចគេសាប់សព្វបញ្ញត្តិ ៗ
សំពត់ដាចរហ៊ែ ស្គមអង្គកាយឃើញតែពង កម្សត់មកផ្តល់នាង
ឲ្យវេទម្ល៉េះណាំ មាសម៉ែ ៗ មូសខាំពោសរំពៃ ពងពាសសាប់ឥតគៃថៃ
ម្តាយមើលមុខមាសស្នេហ៍ មាសម៉ែមានទរលក្ខណ៍គ្រប់ ៗ ដេក
លក់មុខប៉ប្រឹម សើចញញឹមស្រស់ចំប្រប់ មិនមានបើកប្រអប់ ពពី
មាត់ដូចអស់ស្រី ៗ ដាក់ដៃដូចប្រណម្យ ថ្វាយបង្គំកែវតាំងបី សក់

ស្ងួនជាប់ស៊ិរស៊ី មិនប្រួតសាត់សោះ ៗ មិនមានជាមមើ ត្រអៀន
អើប្រុះប្រែកាយ ហេតុកម្មស្ងួនឯងម្តាយ យើរ៍ចាំងពីមកពីព្រេង ៗ
អើបឲ្យកូនស្ងួនឯង បុណ្យច្រើនហោងមែនជាក់ស្តែង តែកម្មនាំ
បង្អែង បំភ្លាត់ចេញឲ្យឆ្ងាយបុណ្យ ៗ យល់ជាដូច្នោះមាន កម្មបុពណ
តាមមកតាន់ ផ្ដេកះចេញឲ្យបាត់បុណ្យ ចូលមិនតាន់ទឹងជួយបាន ៗ
បិសាចកុលគេសី សោះៗបុត្រី ហើយក្រោកក្រោន្ត បន្ទោសោកកំសាន្ត
ហើយថ្លែងថាំកូនថៃថា ៗ អំពីនេះត ទៅ ចូរកូនទៅបង់ទុក្ខា ម្តាយមក
នៅគេហ ដើមរល្អួយចាំងពីនោះ ៗ ចូរនាងកំហានចិត្ត លែងកំយកគិត
ចោលឡើស ម្តាយនឹងមើលពិគ្រោះ គិតប្រយោជន៍ឲ្យមាសម្តាយ ៗ
បិសាចកុលគេសី ប្រាប់បុត្រីសព្វស្រុះសាយ សព្វសុះពាក្យបរិយាយ
ហើយនិមិត្តទៅបង់បាត់ ៗ សាបិតាព្យែត្តា កុមារិកាភ្ញាក់ឡើង
ថ្វាត់ ដៃស្ទាបរកម្តាយបាត់ ពិតពុំយល់កើតទុក្ខា ៗ ពិលាបសែន
សោកសល់ នាងទឹកដល់គុណមាតា លើកដៃដាក់សិរសា ប្រណម្យ
សែនសោកសល់ខ្លាត ៗ ក្តៅក្តួលក្នុងឥន្ទ្រិយ សោកដេនទីពីអញ្ញាត្រ
លុះព្រឹកភ្លឺឡើងស្អាត សោកស្រយុតអស់អង្គកាយ ៗ ស្ងួនទំរសាយ
ទុក្ខ ទៅលុបមុខលាងផ្ទាំងបាយ បំអិនគោដនំចាំងឡាយ លើកយក
ទៅជូនបិតា ៗ ហើយនាងធ្វើចំណី គោជន៍សាលីត្រីញាំភ្លា ហូប
ហើយនាងគោក្តា ហើយនាងក្រោកបុត្រីហា ៗ មើលក្រោលឲ្យគោ

ចេញ ហើយនាងដេញទៅម្នីម្នា តៀងគោះទៅព្រឹក្សា ដល់ហើយ នាងបេះផ្កាភ្ញី ៗ ម្ទះរូតខ្ទឹងម្ទះលា យុប្ផាមហាហឹង្សមារតី ក្តាំងផ្កាស្រលី ស្រលិតនួនស្រីគីការ ៗ ហើយនាងធ្វើចំណី គោរជន៍សាលីត្រីញាំភ្លា ឆត្រទង់ជ័យរៀបជា ជួរជុំវិញព្រឹក្សានោះ ៗ ហើយនាងលើកភ័ស្តុការ គ្រឿងបូជាដាក់ចំពោះ បូជាព្រឹក្សានោះ នាងទឹកគន់មន់ស្រន់ថា ៗអ្នកម៉ែអ្នកមានគុណ គុណមហាធ្ងន់ឥតឧបមា អញ្ជើញអ្នកមាតា មកទទួលភ័ស្តុតាំងឡាយ ៗ នូវអស់គ្រឿងបូជា តាំងភ្ញីផ្កាផែលខ្ញុំថ្វាយ ខ្ញុំបួមសុខសប្បាយ គាត់ខ្ញុំកំព្រាព្រាត់ ៗ សូមអ្នកម៉ែមេត្តា ប្រែកាយាឲ្យប្រាកដ ដូចមុនដូចកំណត់ ឲ្យឃើញច្បាស់ជាក់កុំឃ្លាត ៗ គេដ:នាងសព្វា ឯមាតាកាយាស្អាត ជាមនុស្សជាក់ស្តុខសោភកុលគេស៍ស្រីមាតា ៗ ដូចកាលរស់ជាមនុស្ស មុខស្រៀចស្រស់សមកាយាចេញមកពីព្រឹក្សា ឈរចំពោះមុខទេវី ៗ នាងមរណមាតា លើកហត្ថទៀនវន្ទីយ មាតាហើយទេវី អរគេប្រៀបឥតឧបមា ៗ នាងថាអ្នកម្តាយអើយ ថ្ងៃនេះហើយស្បើយទុក្ខា កូនយល់ដួងកក្រា អ្នកល្អលន់ពន់ប្រមាណ ៗ អញ្ជើញអ្នកមាតា មករក្សាបិតនៅឋាន រក្សាកូនឲ្យបាន សុខសប្បាយតទៅមុខ ៗ ទោះគានូវក្រថី ឃ្វាលប្រក្រតីសូមឲ្យសុខ ទោះមនុស្សចិត្តអាក្រក់ សូមសាយក្លាយបាត់ទៅ ៗ បិសាចស្លាប់បុត្រីទើបស្រដីថាហៃពៅ មាសមេតើនេះទៅ ម្តាយមកនៅចាំរក្សា ៗ ការក្រែងអស់សត្រូវ កុំកូនទៅព្រួយចិត្តា ថាហើយប្រែកាយា និម្មិតបាត់

រំពេចទៅ ៗ កុមារីមើលយល់ច្បាស់ កើតទុក្ខក្តាត់សោកសុះសៅ
តាំងពីថ្ងៃនេះទៅ នាងប្រណិបត៌ន៍ដើមព្រឹក្សា ៗ ព្រឹកល្ងាចជាប្រក្រតី
ធ្វើចំណីគោជនា ផ្កាក្បូរទៅបូជា ពល់ៗថ្ងៃពុំដែលដាច់ ៗ

## បទពំនោល

ន័យនេះឈប់ម្ចុះនិទាន ថ្ងៃនឹងក្សត្រក្សាន្ត ព្រះបាទនិមលធម្មរាជ ៗ ឯកអគ្គីទ្រើសទ្រង់អំណាច សេពសុខសោយរាជ្យ បូរីពេជស្រីវង្សា ៗ មួយថ្ងៃព្រះជ័យក្សត្រា ចង់លេងព្រឹក្សា ក្រសាលកំសាន្តព្រះទ័យ ៗ ត្រាស់ប្រើអមាត្យចាប់វៃ រៀបយានចំប្រពៃ ទីនាំនឹគជេន្ទ្រប្រញាប់ ៗ អមាត្យបត់បាទទទួលស្តាប់ បន្ទូលបង្គាប់ បង្គំប្រណម្យលុតលា ៗ ទៅប្រាប់បង្គាប់សេនា នៅពលរក្សា គជេន្ទ្រទាំងក្សត្រថ្ងៃ ៗ សេនាយោធាត្រាស់ក្រៃ រៀបរួចចាប់វៃ ក៏ឡើងក្រាបទូលក្សត្រា ៗ ស្តេចប្រដាប់សព្វគ្រប់ប្រការ ព្រះបាទក្សត្រា ស្តេចចេញចុះពេជរត្នរម្យ ៗ ហៅអស់នាម៉ឺនតូចធំ អករយាយជួបជុំ បង្គំប្រយត្នរក្សា ៗ ពពាំងទោះតាំងវណ្ណា ស្រីស្នំក្រមការ ពាំយាមប្រយ័ត្នប្ញ៉ា ៗ ផ្តាំស្អាកព្រះបាទចក្រីចេញស្រង់ពារ៍ ហើយសោយព្រះស្វាយទុដា ៗ ពុំលង់ព្រះអង្គក្សត្រា ទ្រង់គ្រឿងវេទនា មកុដអាភរណ៍កាយ ៗ រង្សីរស្មីឆើតឆាយ ឆើតឆោមពណ្ណកាយ ពព្រាកពព្រាយល្អល្អះ ៗ អស់អង្គគ្រប់ទ្រង់ក្រេះ ដូចបន្ទ្រៃចន្ទភ្លឺស្រស់ បារមីកណ្តាលវេហា ៗ ទ្រង់ស្រេចសម្តេចក្សត្រា

បាតទ័សុវណ្ណ ស្តេចយាងព្រះបាទទៀងគន់ ៗ គជេន្ទ្រនរេន្ទ្រកិមផ្គល
គាប់បញ្ចង់ នរនាថកណ្ដាលយោធា ៗ ជើងអគ្គជើងពន្សមហិមា ជើង
រិទ្ធិបេស្កា ប្រកបប្រៃកខ្ពង់ខ្ពស់ ៗ សំទ្វៃគ្រគុំហាតិរេះ ក្ងួនភ្ជាក់ប្រគោះ
ប្រគំនិគ្រ័យល្ងេន ៗ សេនាថ្មើរជើងឥតគ្រង ឆាត់ធំដាក់ស្កន ក្រអឹត
ក្រអួនក្រពា ៗ សំពៅមគ្រមីមមហិមា បំគុមុតហានក្លា កំរៀបដង្ហែជាមុខ ៗ
បេះសិល្បសាគមតង់គុន ធុតធាប់ពេកពន់ បន្ទូបបង្អាក់បេះស្ទាត់ ៗ
ពលសេះៗសោតធំធាត់ ក្ងៀវក្លាស្ទុះស្ទាត់ កំរៀបក្រោយពលថ្មើរជើង ៗ
ពលរថប្រាកដប្រាសលៀង ពលគជេន្ទ្រជើង បន្ទាប់ទ័តាំងក្បត្រា ៗ ស្តេច
ចេញបាកប្រាង្គសុវណ្ណ តាំងហោបីត្រា ពួកង៌ពាង៌ពន្ទឹក ៗ កាំភ្លើងបាញ់ឮ
សន្ធឹក ស្គរទ័ពតគ្រឹក តគ្រាំតគ្រេងសព្ទសាន ៗ យោធាសេនាពាហន
ហៃក្បត្រចេះថ្កាន បរចូលព្រះព្រៃព្រឹក្សា ៗ រំលោងស្រាង៌ស្រាង
សាខា ជិតជើងបព៌្វតា ស្រទូតស្រណាត់ទូរគម ៗ គគីរស្មរតីកំពង់កំ កកោះ
សុក្រំ គ្រសាំងត្រភាឃសាខា ៗ ព្រះពាយផាត់ផាយបុប្ផា ផ្កុំគុំខគន្ធា
ក្រអូបក្រអែបល្ហើបល្ហេង ៗ គ្រាបគ្រៀកឆ្ងាឆ្ងល់ថ្កៃស្រេង ប្រមូ ខ្ញុំកែង
ប្រមែងប្រមូលឆាំរោ ៗ ស្តីស្ត្រង់ពក់នភិការ ភិកុលទន្សោ ទន្ទាប់
ប្រដាក់ជើងបាប ៗ ព្រឹក្សាធាធងពង គ្មានខ្ពស់គ្មានទាប មិនតូច
មិនធំស្មើគ្នា ៗ ស្តេចយាងទៅព្រៃព្រឹក្សា សប្បាយទយា ធរអារម្មា
ក្សេមក្សាន្ត ៗ ព្រឹក្សាផលាមែនមាន ព្រីងព្រួសគូរាន ប្រមូងប្រមូល

ខ្ទេខ្ទា ៗ បេកបាន់សណ្តាន់សណ្តា សណ្តែកទៀបតា· ទឹមទេសធួរេខ
លាំងសាគ ៗ មាក់ប្រាងមាក់សាងមាក់បាត មាក់ដោកស្វាយស្វាគ
ពង្រីពាង្រៀងក្រូចក្រាយ ៗ យោធាសេនាទាំងឡាយ ឡើងបេះ
ប្រញាយ ប្រញាប់ដណ្តើមគ្នាបេះ ៗ ស្វាយផ្លែគគាប់មែកប្រឡេះ ខ្ទះ
ផ្ទុកទេះ ខ្ទះបេះមកថ្វាយក្សត្រា ៗ ហេតុពលសកលបរិវារ សប្បាយ
មហិមា ប្រឡូកប្រឡែងសើចសាទ ៗ ស្តេចដល់មណ្ឌលមួយមាន ស្រះ
ស្រាន់ផលស្អាត គន្ធាថ្វាយផ្ទាល់ដី ៗ មច្ឆានៅនាស្រះស្រី ច្រើនក្រៃផត
ម៉ ផតបើរៀបរាប់គណនា ៗ ឈូកព្រាលត្នោលសីផ្កា ឈូកសបុប្ផា
កេសរសំញែងពេញពាស ៗ លំពង់ស្ពង្គដេរដាស សម្បុរដូចមាស
បុប្ផាក្រអូបឈ្ងួយឈ្ងប់ ៗ ក្សត្រគន្ធសម្រាន្តក្រោមម្លប់ ពលពាសគ្រាន់
គ្រប់ រៀបសង់ពន្លាថ្វាយក្សត្រ ៗ សង់ស្រេចរំពេចរួចថ្វាត់ រួចថ្វាយមហា-
ក្សត្រ ស្តេចឡើងលើពន្លាជ័យ ៗ សត្វសត្វស្រទាត់ពេកក្រៃ ចបាតប្រ-
លៃ ប្រឡំរំងើផ្ទើយគ្នា ៗ ប៉ោលតោកញ្ញោកទទា ក្រូចគ្រៀលសារិកាគ្រលីង
គ្រលោនមានក្រៃ ៗ សុរិយាវេលាល្ងាចថ្ងៃ ទំពុងព្រឹក្សព្រៃ ចូលឈប់
ព្រលប់សន្ធ្យា ៗ តែងតាំងប្រទីបផ្កាលា ព្រោងព្រាត់មហិមា ស្តេចចូល
ក្រឡាបន្ទំ ៗ ភ្លេងផ្លូវដន្ត្រីប្រគំ គ្រេសង្គីតតួសម រងំពីរោះមហិមា ៗ
បរៀងច្រៀងជួចផ្ទើយគ្នា មានតែសកវាទ សឹងជារឿងលោមលេងថ្វាយ ៗ
សត្វនោះពីរោះគ្បោះក្បាយ សូរស័ព្ទធ្វាយ គឹកកងរំពងព្រៃភ្នំ ៗ ក្នុងព្រៃ

សត្វរយោសយំ ផ្សាផ្សប់ប្រឡំ ទីងសត្វចំរៀងសកកាំ ។ ព្រះពាយ
ផាត់ផាយបុប្ផា ការកេសរផ្កា រំពេករំពាកប្រយង្គ ។ រំដួលក្លិនឈ្ងួលធុំហ៊ឹង
ផាយផាត់ត្រូវត្រង់ គ្រឃូបក្រវែអបល្អប់ល្អួន ។ ក្តាំងឆាចម្ប៉ាមហាហង្ស កន្ទុំង
រេត្រកត្រង់ ហើយត្រាច់ត្រេកត្រេះកេសរ ។ ផ្កាផង់ល្អប់ល្អងខ្វាយខ្វរ ក្លិន
ក្រៃចគន្ធ គ្រឡប់តាំងព្រះពន្លា ។ ដោយខ្យល់បក់ដល់ក្សត្រា ឈ្ងុយ
ឈ្ងប់មហិមា ស្រងូតស្រងាត់ហឫទ័យ ។ ឯពួកក្រុមមឿងច្រើនក្រៃ គយ
គន់វៃត យាមល្បាតសត្វព្រៃសព្វកាល ។ កាន់ភ្លើងភ្លឺឡើងរន្ទាល រគាម
គុបភ្លឺប្រាល ពព្រាតពព្រោងពេញព្រៃ ។ ប្រយ័ត្នមហាក្សត្រជៀសជ័យ
កាន់គ្រឿងគ្រប់ដៃ កាំភ្លើងលំពែងស្នាដាវ ។ ដាក់ទ័ពកាយដួរក្នុងក្រៅ
ស្កាត់ខ្ទាត់មកទៅ ក្រវើនក្រវែលគ្មានឈប់ ។ ពួកចោរដើរប្រោមពលគ្រប់
គយល្បាតយាមយប់ មិនឈប់គ្រប់ច្រកព្រឹក្សព្រៃ ។ ស្តេចផ្ទំបរមសុខ
សោយ្យ ស្កុលស្កប់ហឫទ័យ លុះព្រាងព្រឹក្សព្រះសុរិយា ។ ស្តេចតើនចាក
ព្រះសុវណ្ណ ស្រប់ព្រះភក្ត្រា រួចសោយព្រះស្រីសួងបាន ។ សេនាយោ-
ធាតាមដាន គង់គាល់ច្រើនជាន់ ជាជួរជុំជិតក្សត្រា ។ ទើបស្តេចមានព្រះ
ទូន្ទារ បង្គាប់សេនា ឲ្យអស់ពលពាលសេនីយ ។ រៀបយានស្វេរ្យកាន្តរង្សី
តង្កៀតព្រះចក្រី ស្តេចចេញប្រពាតព្រឹក្សា ។ មន្ត្រីសេនីយសេនា រៀបរង់
ក្សត្រា របបរបៀបរៀបរៀង ។ នាយពួកព្រះក្មស់ព្រះក្មេង ព្រះអង្គស្ដាំ
ឆ្វេង ព្រះពាតព្រះស្រីស្រេចស្រាប់ ។ (នៅមានត)

# រឿងព្រេងអេហ្ស៊ីប

## ចែងអំពីការវិនិច្ឆ័យនៃកាកឃូស

## ភិក្ខុ ម៉ែន - រៀម

*សិស្សពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ប្រែចេញពីភាសាអង់គ្លេស*

---

នៅប្រទេស អេហ្ស៊ីប កាលណាបើច្បាប់ត្រឹមត្រូវល្អ ត្រូវគេដឹកនាំឲ្យទៅលើផ្លូវលលា ខ្ទេចខ្ទាស (មិនយុត្តិធម៌) ពួកជនជាតិអេហ្ស៊ីប តែងពោលសុភាសិតមួយបទឡើងថា "ដូចការវិនិច្ឆ័យនៃការាឃូស" (Judgment of Karakoush) ។

រឿងនេះតើដូចម្តេចទៅ ?

រឿងនេះ មាននិទានថា :

គ្រាមួយ មានចោរម្នាក់ លបចូលទៅលួចទ្រព្យសម្បត្តិ ក្នុងផ្ទះមួយ, វាឡើងតាមរបងសួនច្បារ ទៅប្រឹងគាស់បើកបង្អួចផ្ទះឲ្យបើកដើម្បីចូល ។ ដោយស៊ុមបង្អួចមិនសូវមាំទាំ ហើយស្រាប់តែរបើកឃ្វាំងឡើងទៅទាំងក្នុងភ្លាមនោះ, ចោរក៏របូតហក់ធ្លាក់ទៅក្នុងផ្ទះ បណ្តាលឲ្យបាក់ជើង ។

ថ្ងៃក្រោយមក ចោរនោះស្រែកថ្ងូរដោយការឈឺចាប់ព្រោះបាក់ជើង ទៅឈរនៅពីមុខលោកចាងហ្វាងតុលាការឈ្មោះ ការាឃូស

បង្ហាញជើងបាក់ដល់លោកចៅហ្វាយហើយ វានិយាយប្តឹងថា:

– ព្រះតេជព្រះគុណ! វិជ្ជាជីវៈ របស់ខ្ញុំបាទគឺធ្វើជាចោរ, ពម្សិលមិញនេះ ខ្ញុំបាទបានចូលទៅកាន់ផ្ទះបុរសម្នាក់ កាលដែលខ្ញុំបាទកំពុងតែខំខ្វេះគាស់បង្អួចផ្ទះឲ្យរបើកមកខាងក្រៅ ស្រាប់តែវារបើកឃ្វាំងទៅខាងក្នុងវិញ ធ្វើឲ្យខ្ញុំបាទហក់ធ្លាក់បាក់ជើងដូច្នេះឯង ។

កាពយូស ស្រែកប្រាប់ពួកអ្នកយាមក្រសួងតុលាការឲ្យទៅនាំខ្លួនម្ចាស់ផ្ទះនោះ មកឲ្យគាត់ ។ ពេលនោះម្ចាស់កម្មសិទ្ធិផ្ទះ តក់ស្លុតជាខ្លាំងដោយសេចក្តីខ្លាច ព្រោះមិនដឹងជាខ្លួនមានរឿងអ្វី បានជាស្រាប់តែត្រូវគេប្រអូសប្រទាញ មកឲ្យឈរនៅចំពោះមុខលោកចៅហ្វាយកាពយូសដូច្នោះ ។

កាពយូស បានជាប់និយាយពីការបោទប្រកាន់របស់ចោរ ចំពោះម្ចាស់ផ្ទះ, ហើយគាត់ថែមថា៖

– ព្រោះហេតុអ្វី បានជាអ្នកឯងធ្វើបង្អួចខ្ជីខ្ជា មិនឲ្យមាំទាំ ដែលជាហេតុឲ្យវាបាក់ចូលទៅខាងក្នុង នាំបណ្តាលឲ្យមានគ្រោះថ្នាក់បាក់ជើងចោរយ៉ាងនេះ ?

បន្ទុកនៃសំនួរបែបនេះ តើឲ្យគ្នាអ្នកម្ចាស់ផ្ទះឆ្លើយយ៉ាងណា ? ហើយតាំងពីកាលណា ៗ មក ដែលឃើញមានចោរណាមានសិទ្ធិការពារខ្លួន ប្រឆាំងនឹងមនុស្សសុចរិតជាម្ចាស់របស់ដែលវាព្យាយាមលួចបែប

នេះទេ ? ។ ប៉ុន្តែ ដោយអ្នកម្ចាស់ផ្ទះ បានដឹងថា "ការប្រកែកជាមួយកាកយូស ជាការឥតផល", ទើបគាត់គិតមួយសន្ទុះ រួចឆ្លើយថា :

— ព្រះតេជព្រះគុណ ! បន្ទប់ផ្ទះខ្ញុំបាទ ដែលធ្វើឡើង មិនបានជាប់លាប់ត្រឹមត្រូវនោះ មិនមែនជាកំហុសរបស់ខ្ញុំបាទទេ; ខ្ញុំបាទសូមស្បថជូនថា «រូបខ្ញុំបាទពិតជាបានបង់ថ្លៃឈ្នួលឲ្យជាងឈើគ្រប់គ្រាន់រួចស្រេច ហើយថែមទាំងបានប្រាប់ជាងឈើនោះឲ្យធ្វើបន្ទប់យ៉ាងមាំ ដើម្បីនឹងចៀសវាងគ្រោះថ្នាក់បែបនេះដែរ ទាន ! " ។

ពេលនោះ កាកយូសបានបង្គាប់ដោយប្រើសំឡេងដូចរន្ទះថា :

— បើយ៉ាងហ្នឹង ទៅនាំជាងឈើមក !

កាលជាងឈើមកដល់, លោកចៅហ្វានកាកយូស និយាយដោយពចសាថា :

— អ្នកម្ចាស់ផ្ទះនេះ គាត់និយាយអះអាងថា «ខ្លួនគាត់បានជួលអ្នកឯងឲ្យធ្វើបន្ទប់យ៉ាងមាំឲ្យគាត់ ដោយថ្លៃឈ្នួលពេញលេញ. ចុះហេតុអ្វី បានជាកាលៈនោះ អ្នកឯងត្រឡប់ជាធ្វើបន្ទប់គគ្រេតគគ្រេត មិនឲ្យមាំទាំ ដែលជាហេតុបណ្ដាលឲ្យបាក់ជើងចោរកំសត់នេះ នៅពេលដែលវាចំគាស់ឲ្យរបើកនោះទៅវិញ ?

ចំពោះជុំសំនួរនេះ ជាងឈើភ័យឡើងមុខស្លាំង ព្រោះគាត់គ្មានទឹក. នាដល់ការចោទប្រកាន់បែបនេះឡើយ ។ ប៉ុន្តែ ជាងឈើក៏បានដឹងថា

« វាគ្មានប្រយោជន៍អ្វី នឹងជជែកតក់ជាមួយ កាពយូស », ដូច្នេះហើយ បន្ទាប់ពីការឈប់ផ្អាកបន្តិចមក, គាត់ឆ្លើយថា :

— ព្រះតេជព្រះគុណ ! ស៊ុមបង្អួចដែលមិនជាប់លាប់ត្រឹមត្រូវនោះ មិនមែនជាកំហុសរបស់ខ្ញុំករុណាទេ, ពីព្រោះកាលដែលខ្ញុំបាទកំពុងតែបោះដែកគោល ឲ្យជាប់ត្រឹមត្រូវនោះ មាននារីប្រកបដោយរូបឆោមលោមពណ៌ម្នាក់ ស្លៀកសំពត់ក្រហមឆ្អៅ ដើរកាត់ក្រោមបង្អួចនោះ; ម៉្លោះហើយ ខ្ញុំបាទក៏ទៅជារំភើបខ្លួនប្រែប្រួលចិត្ត ដោយសារទិដ្ឋភាពនោះ បណ្តាលឲ្យខ្ញុំបាទវាយដែកគោលវៀចតែម្តងទៅ ។

កាពយូស ចង់ដឹងឈ្មោះស្ត្រីនោះ បានឲ្យគេទៅនាំនាងនោះមកឲ្យគាត់មើល ។ កាលនាងនោះមកដល់, ចាន់ហ្វាន់កាពយូស ក៏ញញឹមដាក់ និយាយឡើងវិញ នូវពាក្យដែលជាងហាំបានជូនប្រាប់គាត់, គាត់ពោលថា :

— បើកុំតែមានរូបឆោមលោមពណ៌ល្អ និងសំពត់ក្រហមរបស់នាងឯងហ្នឹង ម៉្លេះសមជាងឈើគ្មានកក្តាំងរំភើបចិត្តដោយសារទេ, បង្អួចក៏បានស្អាតល្អ ហើយចោរក៏គ្មានគ្រោះថ្នាក់ធ្លាក់បាក់ជើងដូច្នេះឡើយ ។

ចំពោះការចោទប្រកាន់នេះ, នាងនោះបានឆ្លើយដោយញញឹមថា:

— រូបឆោមដំណើតរបស់ខ្ញុំ គឺបានមកពីព្រះអាល្ល៉ោហ៍, រីឯសំពត់ក្រហមខ្ញុំវិញ គឺបានមកពីជាងជ្រលក់; ជាងជ្រលក់នោះឯងហើយ

ដែលបានជ្រលក់សំពត់នេះឲ្យក្រហម ធ្វើឲ្យរូបខ្ញុំ ទៅជាទីទាក់ចិត្តនៃជាងឈើ ។

កាកយូស ស្រែកបង្គាប់ថា :

— ហ៊ឺ ! បើអ៊ីចឹង ទៅហៅតាជាងជ្រលក់នោះមកឲ្យអញ ។

ពីរ-បីនាទីក្រោយមក ជាងជ្រលក់បានមកដល់, ឈរពីមុខតានីហ្វាន៍កាកយូស ។ ស្រែកបន្ទាប់ថា :

— យី ! តាជាងជ្រលក់ផ្ដេសផ្ដាស , គ្មានគិតក្រែងរអែងអ្វីសោះ, ហេតុយ៉ាងម៉េច បានជាឯងជ្រលក់សំពត់នាងនេះឲ្យក្រហម នាំឲ្យមានការទាក់ចិត្តដល់ជាងឈើ ដែលជាហេតុឲ្យគាត់វាយដែកគោលវៀច នាំឲ្យស៊ុមបង្អួចមិនមាំ ហើយបណ្ដាលឲ្យធ្លាក់ជើងចោរនេះ ទៅពេលដែលវាចំទៅគាស់ខ្ទះឲ្យរបើក ? ។

ជាងជ្រលក់សំពត់ងឿងឆ្ងល់ ទៅជាឡប់បាត់ស្មារតី ។ គាត់និយាយអង្វរសុំទោស ដោយសំដីដាច់ៗ ច្រើនបែបច្រើនយ៉ាងណាស់, ប៉ុន្តែ សុំទោសយ៉ាងណាក៏ដោយ មិនអាចឲ្យកាកយូសស្ងប់ស្ងាត់បាត់ចោលបានឡើយ ។ ទីបំផុត គាត់ស្រែកបង្គាប់ទៅតាហានថា :

— នាំគាត់នេះ យកទៅចងព្យួរនឹងទ្វារគុកទៅ ! ។

កាលនោះ ដោយជាងជ្រលក់នោះជាមនុស្សខ្ពស់ប្លែក , កាលដែលតាហាននាំគាត់ទៅចងព្យួរនឹងទ្វារគុក , ទ្វារគុកនោះទាបហួស

រកចង្ព្យមិនកើត ។ ម្ល៉ោះហើយតាហាន ក៏រត់ទៅប្រាប់កាកឃូសវិញថា «ពួកខ្ញុំចង្ព្យមិនកើតទេ ពីព្រោះជាតិជ្រលក់ខ្ពស់ពេក មិនល្មមនឹងចង្ព្យបានឡើយ» ។

កាកឃូស ដែលមិនធ្លាប់ឲ្យគេកោតខ្លាចដោយស្រួល ៗ ស្រែកសន្ធាប់ឲ្យតាហានដែលកំពុងតែញាប់ញ័រភ័យតក្កមានោះវិញថា :

– ចេញទៅ ! ទៅរកអាជាតិជ្រលក់ណាដែលតាប យកចង្ព្យរវាំ ជំនួសអាខ្ពស់នោះទៅ !

កាលនោះ តាហានបានចេញទៅតាមបង្គាប់លោកចៅហ្វាយ ហើយរកបានជាតិជ្រលក់តាបម្នាក់ ៗ ទុកណាជាជាតិជ្រលក់តាបនេះអង្វរករថា ខ្ញុំគ្មានទោសពៃរ៍យ៉ាងណាក៏ដោយ តាហានក៏ឥតស្ដាប់សោះ គិតតែពីប្រមូលប្រទាញគាត់ យកទៅចង្ព្យគ្រង់ទ្វារគុកតាលតែបាន ៗ

ដូច្នេះហើយ បានជា នៅប្រទេសអេហ្ស៊ីប កាលណាអំពើយុត្តិធម៌ ឬហេតុការណ៍បើកផ្លូវទៅរកអំពើពលលាផ្ដេសផ្ដាស ដែលគ្រប់ដណ្ដប់បៀតបៀនមកលើអំពើសុចរិតឥតទោសនោះ ហើយឲ្យសេរីភាពទៅលើអំពើអយុត្តិធម៌ គឺថា កាលណាគេយកអំពើអយុត្តិធម៌មកជះជាន់គ្របសង្កត់ពីលើអំពើយុត្តិធម៌ ដោយឲ្យសេរីភាពទៅលើអំពើអយុត្តិធម៌វិញនោះ ពួកជនជាតិអេហ្ស៊ីប តែងនិយាយថា:

« ដូចការវិនិច្ឆ័យនៃកាកឃូស » ។

# សុភាសិតជាតិប៉ឺល(១) និងទូគូលឿរ(២)

លោក ភិយ-ប៊ុក ប្រែពីភាសាបារាំង

១– ចិត្តមិនមែនដូចផ្ដៅ ដែលគេបត់បែនបានតាមបំណងទេ ។

២–សេចក្ដីស្នេហាប្រៀបដូចជាសត្វលា ដែលគេផ្ដាច់កន្ទុះចេញ ។

៣– អង្កាម បើទុកជាមានពណ៌សម្បុរស្រស់យ៉ាងណា ក៏គេមិនអាចយកទៅធ្វើជាម្សៅបានទេ ។

៤– កល្យាណមិត្តមានប្រាជ្ញា ប្រសើរជាងកល្យាណមិត្តល្ងង់ទៅ ។

៥– ស្រឡាញ់នារីដែលគេមិនស្រឡាញ់ខ្លួន ប្រៀបដូចជាយកដំបងគោះកូនឈើតូច ឲ្យជ្រុះទឹកសន្សើម ។

៦– ការប្រាស្រ័យនឹងមនុស្សល្ងង់ខ្លៅ ដូចមនុស្សមានម្រាមដៃមួយដំបៅ បើកាត់ម្រាមដៃនោះចេញនាំឲ្យឈឺ បើទុកម្រាមដៃនោះដំបៅនឹងធ្វើឲ្យពងខ្ទុះឈាមរលុះរលួយមិនខាន ។

៧– បើយើងចង់ដើរឲ្យឆាប់រហ័សតាមផ្លូវ ត្រូវកុំទៅជាមួយនឹងសត្វបន្ទុយ ។

៨– ត្រូវទៅម្នាក់ឯង ប្រសើរជាងទៅជាមួយមនុស្សពាលទុច្ចរិត ។

៩– អ្នកណាដែលមិនបានជ្រើសរើសទីកន្លែង មុននឹងអង្គុយ

(១) ជាតិប៉ឺល ៖ ជាប្រជាជាតិនៃទ្វីបអាហ្វ្រិក សម្បុរស្បែកស ។ (២) ជាតិទូគូលឿរ ៖ ជាជាតិសេណេកាល់ ដែលជាកូនកាត់ពួកជាតិប៉ឺល នឹងជាតិស្បែកខ្មៅ ឬពួកម៉ូរ ។

ដល់អន្ដុយទៅ មុខជាក្រោកឡើងជាប់ចំបើងនឹងខោអាវមិនខាន ។

១០- នារីដែលគ្មានទរណាខ្ទុន្មាន ច្រើនតែមានប្ដីអកុសល ។

១១- នារីជាទឹកត្រជាក់ ដែលធ្វើឲ្យបុរសស្លាប់ ឬទឹកជ្រៅល្មម នឹងធ្វើឲ្យបុរសលិចលង់បាន ។

១២- តាបដល់ពេលអរុណរះ តែងហើរទៅរកស្រែចម្ការ មិន ដែលឃើញស្រែចម្ការមកឯកតាបទេ ។

១៣- កិច្ចការអ្វីដែលគេពិសោធតាំងពីបុរាណកាលមកមិនបាន ការ យើងត្រូវតែលះបង់ ។

១៤- បុរសជាអ្នកធ្វើគេហដ្ឋានឲ្យសំបូណ៌ដោយគោគទ្រព្យ ប្រពន្ធ ជាមេគេហដ្ឋាន ។

១៥- អ្នកដែលជាមេគ្រួសារ ត្រូវតែធ្វើក្លែកខ្វាក់ត្រចៀកថ្លង់ បើ មិនដូច្នោះទេ គ្រួសារនោះនឹងអន្តរាយតទៅអនាគត ។

១៦- ការបិតនៅម្នាក់ឯង ប្រសើរជាងការបិតនៅជាមួយ មនុស្សពាលទុច្ចរិត ។

១៧- គេហដ្ឋានសង់នៅជិតគ្នាពុំប្រសើរឡើយ ចិត្តបិតនៅជិត គ្នាប្រសើរជាង ។

១៨- បើពាក្យសួរជាប្រាក់ ពាក្យឆ្លើយនឹងទៅជាមាស ។

១៩- គេដឹងព្រឹក្សាដែលមានផ្លែច្រើន តាំងពីវាចេញផ្កា ។

២០- ធ្នូដែលគេលីលើស្មា នឹងចាប់ម្រឹគមិនបានទេ ។

២១- គេលញ់ដីឥដ្ឋក្នុងពេលវានៅទន់ ។

២២- ព្រះរាជអាណាចក្រ ភរិយា នឹងកាំភ្លើង គេមិនដែលឲ្យអ្នកដទៃខ្ចីទេ ។

២៣- បើទុកជាចចកសូត្រធម៌តាំងយប់តាំងថ្ងៃ កូនពពែក៏នៅតែមិនទុកចិត្ត ។

២៤- អ្នកដែលមិនធ្លាប់ឆ្លងទន្លេ មិនត្រូវប្រមាថមើលងាយអ្នកដែលលិចលង់ក្នុងទន្លេនោះទេ ។

២៥- ស៊ូឲ្យស្អប់ កុំឲ្យប្រមាថមើលងាយ ។

២៦- សំលៀកបំពាក់បិទបាំងនូវកាយបាន តែមិនអាចបិទបាំងពូជអំបូរបានទេ ។

២៧- អ្នកមានភោគទ្រព្យ គង់ចៀសក្រមិនរួច ។

២៨- អ្នកឈ្នះ គង់ថ្ងៃណាចាញ់មិនខាន ។

២៩- សេចក្ដីស្រេកឃ្លានជារោគ មានអានុភាពជាងរោគទាំងឡាយ ។

៣០- អាហារដែលឆ្ងាញ់ពិសា គឺអាហារដែលគេនាំមកដល់កំពុងឃ្លាន ។

៣១- ការចេះបទនឹងទទួលទុក្ខលំបាកមុន មិនមែនធ្វើឲ្យវែហក

ពោះនោះទេ ។

៣២- មនុស្សមិនមែនដូចជាហោប៉ៅស្បែក ដែលគេជ្រើសរើសយកតែធំនោះទេ ។

៣៣- មាសនឹងទង់ដែង មើលមួយភ្លែត មានសភាពប្រហែលគ្នា តែធម្មជាតិខាងក្នុងនៃវត្ថុទាំងពីរនោះខុសគ្នា ។

៣៤- កាំភ្លើងស្ថិតនៅស្ទៀម តែវាមិនមែនគេទេ ។

៣៥- ទឹកពិតមែនតែត្រជាក់ តែអាចសម្លាប់មនុស្សបាន ។

៣៦- បើឯងពោលពាក្យ ត្រូវពោលតែពាក្យ ចំពោះអ្នកណាដែលស្ដាប់បាន ។

៣៧- បើវាចាឈឺ ឲ្យតែត្រចៀកជាបានហើយ ។

៣៨- អ្នកណាអួតខ្លួនឯង អ្នកនោះនឹងស្អប់ខ្លួន ។

៣៩- ចូរទុកឲ្យក្រពតវាចោងតាមចិត្តចុះ កាលណាវាបែកពោះវាឈប់ចោងឯង ។

៤០- អ្នកណាកាន់អាហារឆ្ងាញ់ អ្នកនោះមុខជាលើកអាហារតម្រង់ចំមាត់ខ្លួនមិនខាន ។

៤១- វត្ថុជារបស់ខ្លួនប្រសើរជាងវត្ថុអ្នកដទៃ ។

៤២- ទទួលចំណែកនៃភោគទ្រព្យ ប្រសើរជាងការទទួលពរ ។

៤៣- អ្នកណាលោភ អ្នកនោះមុខជាមានសេចក្ដីទុក្ខលំបាកមិន

ខាន ។

៨៤- អ្នកដែលឡើងដើមឈើធំទើបបានបេះផ្លែបរិភោគ អ្នកដែលគ្រាន់តែស្ថិតនៅក្រោមដើមឈើធំនោះ ប្រាកដជាវិលត្រឡប់មកផ្ទះវិញទទេ ។

៨៥- ទន្លេបើទុកជាមានទឹកពេញត្រៀបយ៉ាងណាក៏ដោយ នៅតែចង់បានទឹកថែមទៀត ។

៨៦- អ្នកណាពោលថា អញចំណេញ អ្នកនោះមិនញ៉ាំងក្រឡ ដេញតាមពីក្រោយ ។

៨៧- អ្នកណាចង់បានកូនហួសប្រមាណ អ្នកនោះមុខជារៀបវិវាហមង្គល ទឹងស្រីដើមមិនខាន ។

៨៨- អណ្ដាត បើវាទៅជាសិង្ហ វាលោតខាំម្ចាស់វា ។

៨៩- អណ្ដាត វាលក់ក្បាលម្ចាស់វា ។

៩០- អណ្ដាតចញ្ចឹមមាត់ ។

៩១- កុំមើលអ្នកបានលាភ ត្រូវមើលអ្នកឲ្យលាភវិញ ។

៩២- មានពាក្យពិតខ្លះ ដែលគេមិនអាចពោលបាន សូម្បីពោលទៅដើម្បីស្រោចស្រង់ជីវិតបិតាក៏មិនត្រូវពោលដែរ ។

៩៣- បើអ្នកណាស្គាល់ឯង ហើយស្អប់ឯង អ្នកនោះមុខជានិយាយតែពាក្យអាក្រក់ពីឯង ។

៥៤- វាចាប្រៀបដូចជាទឹក ទឹកបើហូរចេញពីទីកន្លែងណាហើយ មិនដែលត្រឡប់មកកន្លែងដើមវិញទេ ។

៥៥- អ្នកដែលគ្រាន់តែនិយាយ ហើយមិនធ្វើ រមែងមិនសម្រេចប្រយោជន៍អ្វីឡើយ ។

៥៦- សច្ចៈជាមាស មាសបើគេកប់ទុកក្នុងដីឬទុកក្នុងទូ ក៏នៅតែមាសដដែល ។

៥៧- ចិត្តជាធម្មជាតិរហ័សណាស់ ដូចសេះដ៏លឿន ប៉ុន្តែមិនអាចលះវិចិកិច្ឆាឱ្យស្រឡះបានទេ ។

៥៨- បើពាក្យកុហក ទៅតាមផ្លូវពីព្រឹក សច្ចៈចេញដំណើរពេលល្ងាច សច្ចៈនោះនឹងដេញទាន់កុហកមិនខាន ។

៥៩- ពាក្យកុហកក្ដៅដូចទឹកពុះ តែមិនអាចចំអិនវត្ថុអ្វីបានឡើយ

៦០- មុននឹងពោលពាក្យផរុសវាទ ចូរឯងក្រឡេកមើលពីក្រោយខ្លួនឯងសិន ។

៦១- រុក្ខជាតិមានផ្កា ពួកភមរជាតិតែងទៅបោមរោម ។

៦២- ការដើរសូមទានគេ មិនអាចធ្វើខ្លួនឱ្យទៅជាសេដ្ឋីបានទេ ។

៦៣- អ្នកណាមួយកំពុងមានកំលាំងមិនធ្វើការ បែរទៅជាដេក អ្នកនោះនឹងត្រូវក្រោកឈរឡើងវិញ ដល់ពេលខ្សោយធ្វើការមិនកើត ។

៦៤- ចំណេះដូចគ្នានឹងចម្ការ បើចម្ការនោះមិនបានភ្ជួររាស់ មិន

បានថែទាំ លទ្ធផលក៏គ្មាន ។

៦៥- បើចង់ឲ្យបាតដៃស្អាត ត្រូវយកបាតដៃទាំងពីរដុសគ្នាទៅវិញទៅមក ។

៦៦- អ្នកមានចិត្តខន្តីជាគ្រូមនុស្សក្នុងពិភពលោក អ្នកគ្មានចិត្តខន្តីមិនអាចធ្វើគ្រូអ្នកដទៃបានទេ ។

៦៧- អ្នកណាមិនមានចិត្តខន្តីចំពោះការរងផ្សែងភ្លើង អ្នកនោះនឹងមិនបានធ្យូងឈើទេ ។

៦៨- បើចង់បានទឹកឃ្មុំ ត្រូវតែកុំខ្លាចឃ្មុំទិច ។

៦៩- ការហ៊ានហួសប្រមាណនឹងធ្វើឲ្យខូចខាតមិនខាន ។

៧០- ដាស់មនុស្សដែលដេកលក់ស៊ប់ ប្រសើរជាងដាស់មនុស្សដែលធ្វើជាដេកលក់ ។

៧១- មនុស្សមាន ៣ ពួកគឺ ពួកទី ១ ប្រៀបដូចចំណីគ្មានអ្នកណាជៀសវាងរួច ត្រូវតែចូលទៅជិតខានមិនបាន ។ ពួកទី ២ ប្រៀបដូចជាឱសថ មានគេត្រូវការមួយដងមួយកាល ។ ពួកទី ៣ ប្រៀបដូចជារោគ គ្មានអ្នកណាត្រូវការសោះឡើយ ។

៧២- គ្រឿងសំលៀកបំពាក់ចាស់ សម្រាប់ការពារគ្រឿងសំលៀកបំពាក់ថ្មី ។

៧៣- ខ្លួនមិនមែនជាពស់ ទៅបរិភោគអាហារពស់មុខជាស្លាប់មិនខាន ។

៧៤- ដីញ្ចក់ដែលដេកផ្ងារពោះ ខ្លួនទល់ដី គឺដីញ្ចក់ស្លាប់ ។

# រឿងសាមកុក

## ភាគទី ៣៩

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តទៅ)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នករាជការឆ្លាតបើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ។

តាំងពីជីវយីដឹងថា ក្វាន់អ៊ូលើកទ័ពមកក្នុងស្រុកកេងជិវ ជីវយីមកដល់ស្រុកកាំងតាំង ស៊ុនអានសកសុំខ្ចីខឿយធ្វើមេទ័ពធំ លើកទៅដល់ស្រុកកាំងហែ ឡៀតពីទៅរកជីវយីដល់បន្ទាយ ក្វាន់អ៊ូមានសំបុត្រទៅដល់ជីវយី ។

---

នាងង៉ូកុកថៃនិយាយថា កូនអើយ! កាលបិតាអ្នកឯងជិតនឹងមរណភាពបានផ្តាំទុកថា ការអ្វី ៗ ខាងក្នុង បើមិនបានស្រេច ក៏ឲ្យប្រឹក្សាសាកសួរទៀវចៀវ ការអ្វីខាងមុខ បើមិនសម្រេចឲ្យសួរជីវយី សេចក្តីទាំង ២ ខនេះកូនភ្លេចហើយឬ? ។ ស៊ុនក្វនឮដូច្នោះ ក៏ត្រេកអរឃើញបានដូចគេស្រាយទុក្ខអស់ចេញ ប្រៀបដូចដេកលក់ហើយភ្ញាក់ឡើង មានសេចក្តី

គ្រែកអរណាស់រកទីបំផុតគ្មាន ទើបបង្គាប់មនុស្សបំរើឲ្យទៅប្រាប់ជីវយើង ស្រុកគួនយ៉ុន លុះបំរើមិនទាន់ចេញទៅ ទទួលជីវយើដឹងថា ចូច្ចលើកកងទ័ពមកតាំងនៅជាយទន្លេស្រុកកេនដ៏រ បំណងនឹងមកវាយយកស្រុកកាំងតាំង ជីវយើក៏ស្រូតរូតចូលមក ។

ឡេក្លាសុកដឹងថា ជីវយើមកដល់ក៏រួសរាន់ទៅសួរ ហើយប្រាប់សេចក្ដីដែលស៊ិនគួនប្រឹក្សាពិគ្រោះរិះគិតតបរាំងនឹងចូច្ចនោះគ្រប់ប្រការ ។ ជីវយើថា ការនេះអ្នកកុំវិតក្កអ្វីឡើយ ទុកជាធុរៈលើខ្លួនខ្ញុំចុះ ខ្ញុំនឹងបានរិះគិតធ្វើការនោះ អ្នកចូរស្រូតជាប្រញាប់ទៅអញ្ជើញខុនបង់ឲ្យមកជួបនឹងខ្ញុំបន្តិចចុះ ។ ឡេក្លាសុកក៏ឡើងសេះប្រញាប់ទៅអញ្ជើញខុនបង់ ។

ខណៈនោះទៀវចៀវ, កោះយ៉ុង, ទៀវហៀន, ប៉ោដិត ចូលទៅសួរជីវយើ គំនាប់គ្នាហើយ ទៀវចៀវសួរថា អ្នកទៅធ្វើការឯស្រុកគួនយ៉ុននោះ បានឮដំណឹងកិច្ចការពលការដូចម្ដេចខ្លះ? ។ ជីវយើឆ្លើយថា មិនដឹង ។ ទៀវចៀវថា ឥឡូវចូច្ចលើកកងទ័ពមកតាំងនៅឆ្ងាយទន្លេស្រុកកេនដ៏រ ឲ្យមានសំបុត្រមកបញ្ចុះបញ្ចូលស៊ិនគួន ឲ្យចេញទៅទទួលចំណុះទើបមិនប្រទូសរ៉ាយ តែឃើញថាមិនមែនជាពាក្យសុចរិត គិតប្រទូសរ៉ាយយើងជាប្រាកដ អស់យើងខ្ញុំបានពិគ្រោះប្រឹក្សាថា ត្រូវឲ្យស៊ិនគួនចេញទៅទទួលចំណុះតាមប្រវេណី ឥឡូវឡេក្លាសុក ទៅនាំខុនបេងមកនិយាយនឹងលោកហ្លួយើង នឹងឲ្យចេញទៅតស៊ូនឹងចូច្ចូ ទាំងខ្លួន

ទៀងសុកក៏យល់ឃើញដូច្នោះដែរ យើងខ្ញុំកាលគ្នាមិនពេញចិត្ត ព្រោះឃើញថា ខ្ញុំបើរនោះខុសគ្នានឹងច្បាប់ រះគិតតែនឹងសងសឹកគ្នាជាដរាប និងជឿកាន់យកពាក្យនោះជាពិតប្រាកដមិនពាន់បាន សេចក្តីទាំងអម្បាលនេះក៏នៅតែមិនពាន់ចុះសម្រុងគ្នា ទម្រាំតែអ្នក ឥឡូវអ្នកទេកះលើយ ចូរទៅប្រឹក្សាឲ្យឃើញច្បាស់លាស់ខុសនឹងត្រូវចុះ ។

ជីវយ៍ពួជដូច្នោះក៏សួរថា អស់អ្នកកាលគ្នាប្រឹក្សាយល់ថាឲ្យចេញទៅតំនាប់ចួចនោះព្រមគ្នាហើយឬ ? ។ ទៀវទៀវថា ទីប្រឹក្សាយល់ឃើញព្រមគ្នាហើយ ។ ជីវយ៍ថា ដែលនឹងទៅតំនាប់ចួចនោះ ខ្ញុំក៏យល់ឃើញដង ដែលថាវេលានេះអ្នកនាំគ្នាទៅវិញសិនចុះ ចាំព្រឹកស្អែកសឹមខ្ញុំទៅជួបនឹងស៊ុនគួន របនឹងនិយាយឲ្យចុះសម្រុងគ្នាតែម្តង ទីប្រឹក្សាទាំងអស់ក៏លាទៅវិញ ។ ទៀវកៅ នឹងហាន់តុង អ៊ុយកាយ ខាងពួកតា–ហានក៏ចូលទៅរកជីវយ៍គំនាប ហើយនិយាយថា លោកដឹងឬទេ ? ស្រុកកាំងតាំងនេះ ជារបស់អ្នកដទៃហើយ ។ ជីវយ៍តបថា ខ្ញុំមិនដឹងសោះ ។ ទៀវកៅ ឆ្លើយថា យើងខ្ញុំកាលគ្នាជាខ្ញុំរាជការរបស់បិតាស៊ុនគួន មានសេចក្តីទុកស្រឡាញ់តាមមក ស៊ូធ្វើការច្បាំង ១០០ គ្រា មិនបានគិតដល់ជីវិត លុះបានមកតាំងខ្លួននៅស្រុកកាំងតាំងនេះ ឥឡូវចៅហ្វាយខ្ញុំជឿស្តាប់ពាក្យសំដីប្រឹក្សាទាំងពួង នឹងលើកយកស្រុកទៅ

ប្រគល់ឲ្យចូច្ចូកសេចក្ដីទៀនខ្លាសត្វាន យើងខ្ញុំពលគ្នាខំទ្រាំអត់សង្កត់ចិត្ត គិតមិនឃើញផ្លូវសោះ គ្រានេះអ្នកក៏អញ្ជើញមកហើយ សូមឲ្យទៅនិយាយដំរាបដល់ស៊ុនគួន កុំឲ្យធ្វើតាមពាក្យអ្នកទាំងអម្បាលណោះ ត្រូវតែការពារស្រុកទុក ទោះបីចូច្ចូលើកមក យើងខ្ញុំពលគ្នានឹងយកជីវិតដាក់ជាមុខ ស៊ូចំបាំងតាលតែស្លាប់ទៅចុះ ។

ជីវយើសួរថា អ្នកទាំងអស់ យល់ឃើញព្រមគ្នា ហើយឬ? ។ អ៊ុយកាយឮហើយ ក្រោកឡើងយកដៃចាប់ក្បាលកន្ត្រាក់ឆក់ហើយថា ទោះបីក្បាលនេះនឹងធ្លាក់ចេញ គឺមិនទៅសុំលំអុតលំឱនចូច្ចូឡើយ ។ នាយទាហានទាំងពួងក៏ស្រែកឡើងព្រមគ្នាថា យើងក៏ជាចិត្តមួយនឹងគ្នាទាំងអស់ ។ ជីវយើថា អ្នកពលគ្នាយល់ឃើញព្រមគ្នាដូចម្ដេច យើងក៏យល់ឃើញតាមដែរ តែវេលានេះឲ្យត្រឡប់វិលទៅវិញសិនចុះ ព្រឹកស្អែកយើងនឹងទៅជួបស៊ុនគួន ទើបនិយាយឲ្យចុះសម្រុងគ្នាបាន ។ ទៀតនៅនូវអស់នាយទាហានក៏គំនាប់លាជីវយើចេញទៅ ។

វេលាល្ងាច ឡោសុកក៏នាំខុងបេងទៅជួបនឹងជីវយើ ឲ្យអង្គុយទីសមគួរហើយ ឡោសុកក៏សួរជីវយើថា ឥឡូវចូច្ចូគិតនឹងប្រទូសរ៉ាយយើងៗ នឹងចេញទៅគំនាប់ដោយល្អឬនឹងធ្វើប្រការម្ដេច សូមឲ្យអ្នកមានប្រសាសន៍ឲ្យច្បាស់ចុះ ។ ជីវយើថា ឯចូច្ចូគិតធ្វើការទាំងនេះ គឺការន៍យកព្រះតម្រាស់ព្រះចៅហៀនតេជាធំ យើងនឹងរើងទទឹងសោតក៏ដូច

ជាតិតក្សត់ទីផែនដី មួយទៀតទាហានបួចក៏ច្រើនសុទ្ធតែមានចិត្តខ្លាំង
ពូកែណាស់ ខាងយើងក៏មានទាហានតិចស្តួចស្តើង ឃើញថាគង់ទីង
ច្បាំមិនបាន បើប្រសិនជាចេញទៅលំអុកលំឱនច្បាំញប្រហែលជា
បានសេចក្ដីសុខ ខ្ញុំយល់ឃើញដូច្នេះជាប្រាកដ វេលាព្រឹកស្អែកនឹង
ចូលទៅដឹកបសុិនគួនឲ្យប្រើមនុស្សចេញទៅគំនាប់តាមប្រវេណី ៗ ឡោ-
សុកបានឮដូច្នោះខឹងណាស់ឆ្លើយថា អ្នកនិយាយនោះខុសណាស់ ឯកា-
ណាខេត្តស្រុកកាំងតាំងនេះ បាននិយាយពជការជាតំណាមក លុះដល់
៣ជួរមនុស្សហើយ មិនដែលទៅចំណុះចុះចូលអ្នកឯណា គ្រានេះអ្នក
លើកទៅឲ្យចូចុះនោះព្រោះឃើញប្រយោជន៍អ្វី កាលសុិនសេកនឹងដល់
សេចក្ដីស្លាប់នោះ បានផ្ដាំទុកនឹងខ្ញុំថា ឲ្យជួយទំនុកបំរុងសុិនគួនជាប្អូន
ប្រាជ្ញាថានឹងឲ្យស្រុកកាំងតាំងនៅខ្ជាប់ខ្ជួនដូចបានបន្ទែកទៅលើក្នុ ហេតុ
ម្ដេចបើការភ័យអាសន្នមកដល់ហើយ អ្នកត្រឡប់លះបង់មិនជួយទំនុក
បំរុងវិញ ចបណ្ដោយទៅតាមពាក្យមនុស្សប្រចុបប្រចៃង ផ្ដេសផ្ដាស
ដូច្នេះ ៗ ដីវ៉េយថា ស្រុកកាំងតាំងនេះមានអាណាខេត្តឡើងដល់ ៦
មណ្ឌល មនុស្សចំណុះស្រុកក៏ច្រើន បើយើងប្រាជ្ញាឲ្យគស៊ូទីងចូច្រា
ខេះ ក៏ដូចជាធ្វើឲ្យអាណាប្រជានុរាស្ត្របានសេចក្ដីទុក្ខក្ដៅ ទីងមាន
ពាក្យតហោនិន្ទាដល់យើងម្នាក់ឯង ហេតុដូច្នេះទើបយើងឲ្យសុិនគួនចេញ
ទៅគំនាប់ចូច្រាប្ដាទីងឲ្យបណ្ដាពស្ត្របានសេចក្ដីសុខ ។

ខុនបេនឃើញដំរីឃើទឹងឡោសុកដេញដោលគ្នាមិនចុះរុះ ក៏អង្គុយញញឹមចាំស្តាប់ ។ ដំរីឃើថា អ្នកសើចចំអកខ្ញុំឬ ? ។ ខុនបេនថា ដែលខ្ញុំសើចដូច្នេះមិនមែនចំអកឲ្យអ្នកទេ ខ្ញុំអត់ញញឹមទឹងឡោសុកមិនបាន ព្រោះគ្មានដឹងលក្ខណៈខុសត្រូវអ្វីសោះ មានតែមាត់និយាយហើយមកដេញដោលអ្នក ។ ឡោសុកថា ហេតុម្តេចបានជាលោកអាចារ្យសើចចំអកឲ្យខ្ញុំថាមិនដឹងអ្វីដូច្នេះ ។ ខុនបេនថា ដែលដំរីឃើនិយាយនោះ គឺឲ្យទៅគំនាប់លានតួច្ច ខ្ញុំក៏យល់ឃើញដែរ ។ ឡោសុកថា ហេតុម្តេចបានជាលោកមកចរចាដូច្នេះវិញ ។ ខុនបេនថា ឯតូចនោះមានគំនិតគិតដោយបញ្ញា យ៉ាងសុខុមជ្រៅទូលាយណាស់ ដឹងចាស់ថែងតាហាន គង់ការសង្គ្រាមថាធ្ងន់ឬស្រាល បើយើងទៅប្រឹងតស៊ូទឹងតូច ក៏រមែងដល់នូវសេចក្តីវិនាសដល់ជីវិតពុំខាន ទៀតពីនៅហ្វាយខ្ញុំក៏កាន់ទិដ្ឋិមានៈហ៊ានតស៊ូទឹងតូច ក៏ដល់នូវសេចក្តីព្រួយលំបាកពលតែក្បាត់មកនៅស្រុកកាំងហៃ ឯដំរីឃើជាមនុស្សបេះគិតល្អិតល្អណាស់ ទើបអាចលះទិដ្ឋិទៅគំនាប់តូច ព្រោះថាទឹងគេគ្រាប់គ្រងរិយាទឹងអាណាប្រជាទុកព្រឹទ្ធឲ្យបានសេចក្តីសុខនោះក៏គួរហើយ ។ ឡោសុកទឹងណាស់ថា លោកនិយាយនេះដូចដឹកដៃខ្ញុំទៅលុតជង្គង់គំនាប់តូច អាសត្រូវពជសម្បត្តិគួរហើយឬ ? ។

ខុនបេនថា អ្នកកុំទឹងទឹងខ្ញុំឡើយ ដែលទឹងទៅគំនាប់តូចនោះ

ខ្ញុំមិនឲ្យលំបាកទេ ចំពោះតែខ្លួន ១ ត្រូវឆ្លងទឹកទន្លេទៅ បើលោក
អ្នកមិនទៅក៏បានដូចគ្នា ហើយឧបាយរបស់ខ្ញុំ ១ នឹងយកតែមនុស្ស
២ នាក់ ចុះទូកតូច ១ ឆ្លងទៅកេបួន ៗក៏នឹងនាំទាហាន ១០០ ម៉ឺន
លើកទ័ពត្រឡប់ទៅវិញភ្លាម ៗ ដឹះយើស្សរថា ដែលអ្នកនឹងឲ្យមនុស្ស
តែ ២ នាក់ឆ្លងទៅកេបួនក៏អាចនឹងឲ្យចូចូលើកទ័ពត្រឡប់ទៅវិញនោះដូច
ម្ដេច? ចូរថាឲ្យច្បាស់ស៊ិន ៗ ខុងបេងថា កាលខ្ញុំនៅឯភ្នំង៉ាឡុងកាំង
នោះឮយើងនោះ ខ្ញុំដឹងថាចូចូឲ្យធ្វើប្រាសាទទុកនៅកន្លែង ១ ប្រចាំឆ្នេរ
ទន្លេទៀតហៅជាទ័សប្បាយ ហើយបាត់យកស្រីដែលមានរូបល្អមកទុក
ជាច្រើន ព្រោះចិត្តចូចូនោះក្រាស់ក្ដីធ្ងន់កាមគុណខ្លាំង ហើយដឹងថា
នាងទៀវកុកឡោ នៅស្រុកកាំងតាំងមានបុត្រី ២ នាក់ មានរូបល្អស្អាត
ទីឯគេស្រឹងទៀតផ្ទឹមស្មើគ្នា ចូចូមានចិត្តកំណាន់ក្នុងការប្រតិព័ទ្ធ បាន
និយាយទុកថា បើបង្រាំងយកស្រុកកាំងតាំងបានហើយ នឹងទទួល
យកស្រីទាំង ២ នាក់នោះនៅទុកជាទីបំរើផ្គាប់ខ្លួន ទោះបីនឹងស្លាប់ទៅ
ក៏មិនបានវិលវល់ក្នុងសន្ដានចិត្ត ដែលចូចូលើកទ័ព ១០០ ម៉ឺនមកនេះ
ក៏ព្រោះប្រាថ្នាគួរយកស្រី ២ នាក់ជាប្រុសភ្លក់ក្នុងចិត្ត ប្រសិនបើអ្នកយក
មាសតែមួយកម្ទីងទៅជូននាងទៀវកុកឡោ ទិញយកបុត្រីទាំង ២ នាក់
នោះទៅជូនចូចូបានដូចសេចក្ដីប្រាថ្នារបស់ចូចូហើយ ចូចូក៏លើកទ័ព
ត្រឡប់ទៅវិញជាប្រាកដ សូមឲ្យអ្នកខំរិះគិតថ្នាក់ថ្នមធ្វើតាមពាក្យខ្ញុំនេះ

ចុះ បើបានហើយមិនព្រួយជផែកគ្នាតទៅទៀតឡើយ ៗ ជីវយើថា ដែលចូលមានសេចក្ដីគំណាន់ចិត្តគិតប្រតិព័ទ្ធចំពោះស្ត្រីទាំង ២ នាក់នោះ ហេតុម្ដេចបានជាអ្នកដឹងប្រាកដ មានអ្វីជាកស្តុតាងនៅខ្លះ ? ៗ

ខ្ញុំបេងថា ឯចិត្តចូលស្រឡាញ់ស្រីទាំង ២ នាក់នោះ បានសរ-សេរជាពាក្យកាព្យឃ្លោងទុក ខ្ញុំក៏បានចាំសេចក្ដីជាសំខាន់ រួចខ្ញុំបេងក៏សូត្រពាក្យឃ្លោងនោះឲ្យជីវយើស្ដាប់ថា :

អនិច្ចាវែនវ៊ ២ ឆ្វេងស្ដាំ | បងចាំរៀបទុកដាក់បំណាង
មួយឈ្មោះយ៉ុកឡូងមួយឌឹមហាង | ទីដ៏បីត្រកងនុបថើបស្រី ៗ
គឺនាមនាងគៀវស្រៀវស្រៀបស្រស់ | ទាំង២ឲ្យអស់ចិត្តបេតី
មួយឆ្វេងមួយស្ដាំលើកបួមបី | ឲ្យប្អូនប្រិមប្រិយសុខសំពន្ធ ៗ

ជីវយើបានឮចំឈ្មោះនាងគៀវទាំង ២ ដូច្នោះ ក៏ខឹងខ្នាំងណាស់ ដូចគេយកភ្លើងទៅដុតចំលើថ្ងើមប្រមាត់ ក៏ស្ទុះក្រោកឡើងលើកដៃចង្អុលទៅត្រង់ទិសឯជើង ចំលើស្រុកកេងជីវថា ម៉ែអាសត្រូវផែនដីម្ដេចក៏ឯងព្រហើន ហ៊ានចរចាប្រមាថមើលងាយអញដាំស្បែងលេង ៗ ខ្ញុំបេងឃើញជីវយើប្រឡោតខឹងដូច្នោះ ក៏ក្រោកឡើងធ្វើជាហាមឃាត់ថា ហេតុម្ដេចផែនដីអ្នកមិនស្រឡាញ់ ក៏ទៅស្រឡាញ់ឯស្រី ២ នាក់នោះវិញ ទីងបានជាប្រយោជន៍អ្វី ?

ជីវយើថា អ្នកមិនដឹងទេថ្ង នាងតែគៀវជាបងនោះ គឺជាភរិយា

ស៊ិនសេកទៅហាយខ្ញុំ នាងសៀវកៀវជាប្អូនគឺជាភរិយារបស់ខ្ញុំ ចួច ចរបាមើលឆាយយ៉ាងនេះបានជាខ្ញុំខឹងក្តៅណាស់ ៗ ខុងបេងធ្វើជាភ័យតក់ស្លុត ចុះទៅតំនាប់ហើយថា ខ្ញុំមិនដឹងសោះឡើយបានជានិយាយហួសទៅ ដូច្នេះខុសខ្លាំងណាស់ សូមឲ្យអ្នកអាណិតអត់ទោសទៅចុះ ៗ ជីវយើថា អាសត្វកញ្ឆាស់នេះ ខ្ញុំមិនសុំជាន់ផែនដីរួមគ្នាឡើយ ៗ

ខុងបេងថា អ្នកកុំធ្វើការដោយទោសោដូច្នោះ ត្រូវតែគិតថ្នាក់ថ្នមឲ្យបានល្អ ដែលខឹងប្រឡេតតាមចិត្តខឹងដូច្នោះ ករទៅមុខក៏ខឹងថ្ងស់ការមិនខាន ៗ ជីវយើថា អ្នកនិយាយនោះត្រូវហើយ ឯខ្លួនខ្ញុំក៏បានទទួលពាក្យស៊ិនគួនពីដើមមក ដែលខឹងទៅលំទុនប្ដូនោះ ខ្ញុំស៊ូតែស្ងាប់មិនព្រមទៅតំនាប់សោះឡើយ ខ្ញុំមកពីស្រុកគួនយ៉ឺងក្នុងគ្រានេះ ក៏គិតថាខឹងមកបាត់បែងរៀបចំតាហានបំរុងខឹងតស៊ូ តែជាកំឡាំងសេចក្ដីគិតរបស់ខ្ញុំតែម្នាក់ឯងឃើញមិនស្រួល សូមឲ្យអ្នកជួយអនុគ្រោះទំនុកបំរុងផង ៗ

ខុងបេងថា បើអ្នកមិនមានសេចក្ដីរង្កៀសក្នុងចិត្តទេ ខឹងឲ្យខ្ញុំជួយក៏ល្មមនឹងរិះគិតទៅបាន បើខុសត្រូវប្រការម្ដេចទៅខាងមុខសឹមជួយផាស់គៀនតាមដម្រេះប្រាជ្ញា ៗ ជីវយើថា អ្នកនិយាយនេះក៏ត្រូវល្អហើយ បើដូច្នោះពេលព្រឹកស្អែក ខ្ញុំនឹងចូលទៅជំរាបស៊ិនគួន ឋឹងនិយាយឲ្យរៀបចាត់បែងតាហានទុកឲ្យស្រេច ដើម្បីនឹងលើកទៅកំចាត់ប៊ួចឲ្យបាន ៗ ខុងបេង

ទឹងឡោស៊ុកបានស្តាប់ហើយ ក៏គិតទាប់លាជីវយីមកកាន់ទីសំណាក់វិញ ។

លុះពេលព្រឹក ស៊ិនគួនទឹងពួកនាម៉ឺនខាងក្រសួងរដ្ឋបាល ទឹងពួកក្រុមព្រះនគរបាលព្រមគ្នាទៅជួបជុំ ។ ជីវយីចូលទៅគិតទាប់ហើយនិយាយថា ឥឡូវនេះខ្ញុំបានដឹងថា ចូឆូលើកទ័ពមកទឹង ធ្វើអន្តរាយដល់ស្រុកយើងនោះ តើលោកគិតប្រការម្ដេច? ។ ស៊ិនគួនឃើញជីវយីចូលមកនិយាយដូច្នោះ មានអំណរណាស់ ទើបយកសំបុត្រដែលចូឆូឱ្យមកនោះ ហុចឱ្យទៅជីវយីមើល ។ ជីវយីហែកសំបុត្រមើលហើយថា អាសត្រូវផែនដីកញ្ឆាស់នោះវាគិតថា ស្រុកកាំងតាំងគ្មានមនុស្សល្អទឹងដឹងដល់វា វាប្រាថ្នាទឹងបញ្ចុះបញ្ចូលឱ្យយើងស្ងាប់ចិត្ត ។ ស៊ិនគួនបានឮដូច្នោះក៏សួរថា សេចក្តីទាំងអម្បាលនេះ អ្នកយល់ឃើញប្រការម្ដេច ? ។ ជីវយីថា លោកបានប្រឹក្សាទឹងអស់អ្នកពល់គ្នាហើយឬ? យល់ឃើញត្រូវគ្នាប្រការម្ដេចខ្លះ? ។

ស៊ិនគួនថា ខ្ញុំប្រឹក្សាមិនទាន់ចុះរុះគ្នាសោះ ដែលទឹងឱ្យយើងទៅគិតទាប់ក៏ថា ទឹងឱ្យតស៊ូក៏ថា សេចក្តីទាំង ២ នេះបែកខ្វែកគ្នាដោយខ្លួន បានជាឱ្យអញ្ជើញអ្នកមកគ្រានេះ ប្រាថ្នាទឹងឱ្យនិយាយ ឱ្យបានដាច់ស្រេច ។ ជីវយីថា ដែលប្រឹក្សាឃើញថា ទឹងឱ្យទៅចំណុះចូឆូនោះ គឺនរណាខ្លះ? ។ ស៊ិនគួនពប់ប្រាប់ឈ្មោះឱ្យស្តាប់ ។ ជីវយីក៏សួរទៀតទៀតថា ដែលអ្នកទឹងឱ្យចេញទៅគិតទាប់ធ្វើនោះ ដោយយល់ឃើញប្រការម្ដេច? ចូរថាឱ្យច្បាស់មកចុះ ។ ទៀតទៀតថា ខ្ញុំឃើញថាចូឆូមកប្រាបប្រាម

ប្រកទេសទាំងអស់នេះ ព្រោះតាំងព្រះជម្រាស់ព្រះចៅហៀនគេជាធំ, មួយទៀត ចូច្នបានស្រុកគេឯងជាប្រមូលផ្សេងហានទុកជាច្រើន ឃើញថាមានកំឡាំងធំទូលាយឆ្ងាយណាស់ យើងតស៊ូមិនបានទេ បានជាយល់ថាត្រូវទៅចំណុះចុះចូលតាមប្រវេណីសិន គទៅមុខសឹមគិតប្រែប្រួលទៅតាមការ អ្នកកាលគ្នាមកប្រឹក្សាឃើញត្រូវព្រមគ្នាដូច្នេះ សុទ្ធតែមនុស្សមិនកើតទាំងអស់ ព្រោះស្រុកកាំងតាំងនេះ មានចៅហ្វាយស្រុកតគ្នាមកដល់ ៣ ដួរហើយ មិនដែលទៅចំណុះអ្នកណាសោះ ហេតុអ្វីគ្រានេះអ្នកកាលគ្នាប្រឹក្សាឲ្យលះបង់ប្រវេណីចេញដូច្នោះ នឹងជាប្រយោជន៍អ្វី ? ។

ស៊ុនគួនថា កាលពួកអ្នកតាំងនេះប្រឹក្សាយល់ដូច្នោះហើយ បើខាងអ្នកមិនយល់ឃើញតាមទេ នឹងនាំឲ្យធ្វើប្រការដូចម្តេចវិញ ? ។ ជីវយើថា ចូច្នោះជាមហាទុបកដកមែន តែជាសត្រូវពងសម្បត្តិរបស់ព្រះចៅហៀនគេ ឯខ្លួនលោកក៏ជាមនុស្សមានប្រាជ្ញាទឹងតម្រេះរិះគិត ហើយប្រកបដោយសេចក្តីកតញ្ញូស្ចរិតណាស់ មិនគួរនឹងទៅចំណុះចុះចូលចូច្នដែលជាមនុស្សអកតញ្ញូទ្រស្តក្បត់ផែនដីនោះទេ, មួយទៀត ស្រុកកាំង-តាំងបរិបូណ៌ដោយស្រូវអង្ករចំណីត្រីសាច់ ព្រះទាំងមនុស្សចំណុះស្រុកក៏ច្រើន គួរតែកំចាត់សត្រូវផែនដីឲ្យស្ងប់ចេញទើបប្រពៃ ដែលចូច្នលើកកងទ័ពមកនោះទ័ពនោះក៏យូរហើយ ខាងម៉ាបេងទឹងហានស៊ុយក៏ជាហាវគ្នាដែរ ឃើញថាទឹងហាវរៀងគ្នាជាខាងក្រោយ, ប្រការមួយទៀតតាហានចូច្នសុទ្ធ

តែមនុស្សពួកអ្នកលើ មិនប៉ុនប្រសប់ការដើរទឹកសោះ ទោះលើកមក ច្បាំងក៏មិនសូវស្ទាត់ ហើយវេលានេះជាវេរប្រាំង ស្ទឹងទឹងចំបើងតាំងពួង ក៏ឃើញថាមិនមានទឹកជួនល្មមនឹងមាត់សេះបរកោគ ឯការហានតាំងពួង សោតក៏សុទ្ធតែមនុស្សព្រៃ នឹងស៊ីទឹកប្រើទំកងទន្ទេកុំសរ ទ្នាប់ប្រើនតែឈើ ច្នាត់គ្រប់គ្នា ឃើញថាកំឡាំងកងទ័ពទីងថយចុះគ្រប់វេលា ទោះបីធ្វើ ការតៃដជាប់គ្នា ក៏គង់ទឹងចាញ់ប្រៀបខាងយើង ការសឹកបង្ក្រាមជាន់នេះ ខ្ញុំគ្មានគិតគួរសោះឡើយ ទឹងសូមការសាលោកលើកទ័ពទៅតាំងនៅកំពង់ ស្រុកកាំងហៃ កំចាត់ចូចូះចេញឲ្យបាន ៗ

ស៊ុនគួនបានស្តាប់សព្វគ្រប់មានអំណរណាស់ ទើបនិយាយថា ដែលអ្នកគិតកស៊ូនឹងចូចូះនោះក៏ដូចចិត្តរបស់ខ្ញុំ ៗ ជីវយើវា ឯទុនខ្ញុំបាទ នេះ ទោះបីទឹងស្តាប់កូនសង្គ្រាមក៏មិនបានគិតស្តាយជីវិតសោះ ខ្ញុំបាទ មកគិតមិនអស់ចិត្តតែនឹងលោកព្រែងទិន្នមាំភ្ជួន ៗ ស៊ុនគួនហូតយក គ្រប់ចេញមកហើយ ក៏កាប់ចំមុមតុប្រកាបជាអាជ្ញាសិទ្ធិតុកថា ឱរណា ទីវេកនិយាយឲ្យយើងចេញទៅចំណុះចូចូនឹងនេះទៀត ទឹងត្រូវកាត់ ក្បាលចេញ និយាយហើយក៏ហុចគ្រប់នោះ ទៅឲ្យជីវយើកាន់ជាអាជ្ញា សិទ្ធិក្នុងកងទ័ពបម្រាប់មុខអ្នកនាម៉ឺនធំ ទ័ពបួនឲ្យទៀតៅជាច្បាប់ បើអ្នកឯណាមិនបាននៅក្នុងបង្គាប់បញ្ជាទេ ត្រូវឲ្យកាត់ក្បាលអ្នកនោះ ចេញ ជីវយើគិតទាប់ហើយ ក៏ទទួលយកគ្រប់លើកប្រកាសឡើង

ដល់ថ្ណា ចៅហាវ៉ះតាំងពួនថា ឥឡូវយើងបានកញ្ចាំសិទ្ធិមកជាទីសម្រេចកិច្ចការក្នុងកងទ័ពហើយ ចូរអ្នកពលគ្នាតាំងចិត្តធ្វើការកុំបីប្រមាទ ដែលយើងលើកទ័ពទៅតតាំងបក្សងទីងបូធូគ្រានេះ ត្រូវទៅព្រមគ្នាឯក្បែរជាយចទ្ទ បើនណា ឃើតយូរគេងកំណាន មិនទាន់ការពារ យើងនឹងឲ្យដាក់ទោសអ្នកនោះដោយសហ័ស និយាយហើយក៏លាស៊ិនគួនចេញទៅដល់ផ្ទះ ហើយឲ្យអញ្ជើញខុងបេងចូលទៅប្រឹក្សាថា ឥឡូវចៅហ្វាយខ្ញុំព្រះឲ្យតស៊ូទីងបូធូហើយ សុំឲ្យអ្នកជួយគិតឧបាយដែលនឹងធ្វើកិច្ចការនោះផងចុះ ។

ខុងបេងថា ដែលអ្នកនឹងឲ្យខ្ញុំជួយគិតការនោះក៏មិនជាអ្វីទេ ល្មមនឹងជួយគិតតាមជម្រះប្រាជ្ញាបានខ្លះដែរ តែថានៅមិនទាន់ទុកចិត្ត ដោយឃើញអារម្មណ៍ចៅហ្វាយអ្នកនៅវិលវល់ណាស់ ។ ជីវយ៉េថា អ្នកឃើញយ៉ាងម្តេចបានជាថាដូច្នេះ ? ។

ខុងបេងថា ខ្ញុំឃើញចៅហ្វាយអ្នកឮដំណឹងថា ទាហានចូលច្រើនបារម្ភព្រួយថា ទាហានខាងនេះតិចក្រែងតស៊ូមិនបាន សូមកុំឲ្យអ្នកភ្ញាក់ផ្អើលធ្វើអ្វី ត្រឡប់ចូលទៅនិយាយយកចិត្តយកថ្លើមចៅហ្វាយអ្នកកុំឲ្យភ័យតក់ស្លុតរន្ធត់ដូច្នោះ ត្រូវតែខំប្រឹងឲ្យមាំមួន ទើបខ្ញុំនឹងបានគិតការស្រួល ។ ជីវយ៉េថា អ្នកនិយាយនេះត្រូវណាស់ ហើយជីវយ៉េក៏ត្រឡប់ចូលទៅជួបនឹងស៊ិនគួនៗក៏សួរថា ពេលយប់ងងឹតដូច្នេះ អ្នកចូលមកមានកិច្ចធុរៈអ្វី? ។

ជីវយើថា ខ្ញុំបាទទឹងកេណ្ឌអាហារទាំងពួងនោះ នៅគិតធ្ងន់ក្នុងចិត្តបន្តិច ទើបត្រឡប់មកជួបនឹងលោក ប្រាថ្នានឹងចង់ដឹងថា លោកមានសេចក្ដីវិតក្កអ្វីខ្លះឬគ្មានទេ ៗ ស៊ិនតួនថា ដែលអ្នកត្រឡប់មកសួរខ្ញុំយ៉ាងនេះត្រូវហើយ ខ្ញុំក៏នៅមានសេចក្ដីវិតក្កបន្តិចដែរ ព្រោះចុងភៅមានអាហារច្រើន ខាងយើងមានអាហារតិចណាស់ ក្រែងគេស៊ីនឹងគេមិនបានទឹងផ្ទប់ការទៅ ៗ

ជីវយើថា ការនេះឯងហើយ បានជាខ្ញុំបាទចូលមកជំរាបលោក ប្រាថ្នានឹងពន្យល់ឲ្យលោកចូលចិត្ត ព្រោះចុងភៅមានសំបុត្រមកថា មានអាហារ ១០០ម៉ឺននោះ សេចក្ដីនេះមិនមែនទេ គឺជាកលឧបាយបញ្ឆោតទេតើ ឯអាហារចុងភៅនោះមានប្រហែល ១៥·១៦ម៉ឺនប៉ុណ្ណោះ ដរាបអាហារអ៊ីនសៀវជាមនុស្សតាំងចិត្ត គិតតែនឹងដោះខ្លួនចេញពីចុងភៅគ្រប់ពេលព្រឹកល្ងាច ទោះបីនឹងធ្វើការក៏មិនពេញដៃ មួយទៀតអាហារចុងភៅក៏ដើរមកផុតថ្វាយ សព្វសារពើអ្វីៗក៏ទាញទាល់ទាំងគ្រប់អស់ហើយ យើងនៅផឹកស្បៀងអាហារគ្រប់បរិបូណ៌គ្រប់សព្វទាំងអស់នឹងស៊ីមិនបានឬ ទោះបីច្រើនក៏ដូចតិច លោកកុំវិតក្កៈឡើយ ខ្ញុំបាទទឹងសុំអាសាយកអាហារយើងតែ ៥ម៉ឺន ទឹងគិតធ្វើការកំចាត់ចុងភៅចេញឲ្យបាន ៗ ស៊ិនតួនបានស្ដាប់ដូច្នោះ ក៏ពេញចិត្តណាស់ លើកដៃស្ទាបអង្អែលខ្នងជីវយើហើយថា ដែលអ្នកពន្យល់ឲ្យយើងអស់សង្ស័យដូច្នេះ ជាគុណច្រើនណាស់ នេះហាក់

ជាបានអ្នកជួយឧបត្ថម្ភ បើត្រឹមតែលើសនេះទៀត ទៀតខ្ញុំក៏ពឹងមិនបាន ពីថ្ងៃនេះទៅខ្ញុំអស់សេចក្ដីព្រួយវិតក្កទៀតហើយ អ្នកនឹងទៀតទៅ ឡោសុក ចូរចាំតាត់ចែងប្រមូលអាហារប្រុងលើកទៅចុះ ខ្លួនខ្ញុំនឹងលើកអាហារជូនទៅតាមក្រោយ បើខ្វះខាតប្រការម្ដេច ចូរប្រើបំរើឲ្យមកប្រាប់ខ្ញុំ សឹមខ្ញុំលើកទៅតស៊ូនឹងចូជាយខ្លួនឯង ។ ដីវឃើញថ្នូរឡោះរំអស់បង្ស៊ុយគំនាប់លាត្រឡប់ចេញទៅវិញ ទើបគិតថាខ្ញុំបើនេះនិយាយបក់និរវៃម៉ាម្ទួនណាប់ដឹងចិត្តរបស់ទៅហ្វាយ ពេលយើងជាដាន់យើងទៅទៀត, មួយទៀតនឹងគិតការអ៊ុំកំល្អុ តឹមត្រូវដូចនឹងដើរបើក្បាលយើងបាន បើយើងស្ងៀមចុកត្រានេះ យូរទៅរ៉ំនឹងត្រឡប់ជាបត្រូវ ត្រូវតែគិតកំចាត់ចេញឲ្យបានហើយឲ្យហៅឡោសុកបួលទូរ ព្រោះសេចក្ដីស្មាត់ដែលវីរគិតសម្លាប់ខ្ញុំបើនចេញឲ្យស្លាប់គ្រប់ប្រការ ។

ឡោសុកថា អ្នកគិតដូច្នេះមិនត្រូវសោះ ព្រោះបួងលើកទ័ពមកនឹងប្រទូសរ៉ាយដល់យើង តែទៅកំចាត់ចេញមិនទាន់បាន បើអ្នកទៅសម្លាប់ខ្ញុំបងចេញហើយ ការសឹកសង្គ្រាមកំនឹងជាប់ដៃគ្នាតទៅថ្ងៃមុខជាអង្វែង តែខ្លួនអ្នកមួយគ្មានទេណាជួយគិតសោះ នឹងមិនជូនកងដើមទ្រង់ណាប់ទៅថ្ម ? ឯខ្ញុំបងនេះ មានដម្រេះប្រាជ្ញាគួរនឹងជួយអ្នកបាន , មួយទៀតដូកាត់គិតបង់ខ្ញុំបងកំទៅកងស្រុកកាន់តាំងដែរ បើប្រទៅនិយាយបបួលឲ្យចូលមកនៅជួយធ្វើពុដការខាងយើងនឹង

មិនល្អទេឬ ? ។ ជីវយើឮហើយក៏យល់ថា ត្រូវ លុះវេលាព្រឹកក៏ឲ្យទៅហៅនាម៉ឺនមុខមន្ត្រីចូលមកជុំគ្នាក្នុងទីប្រជុំ ។ ខណៈនោះ ទៀតសោតមានសេចក្តីតូចចិត្តថា ខ្ញុំអញជាចាស់ជាងអាយុជីវយើ ។ នៅក្មេងឡើងអង្គុយទីខ្ពស់ នឹងឲ្យយើងជាចាស់ទាបមុខ ទៅអង្គុយប្រឹក្សាការក្នុងទីទាប ឲ្យបុត្រមកជំនួសហើយប្រាប់ថាឈឺ ។

ជីវយើក៏និយាយនឹងនាម៉ឺនទាំងពួងថា កងទ័ពបូធូលើកមកគ្រានេះចំសន្ធឹកសន្ធាប់ណាស់ ឯយើងនឹងគិតធ្វើការនោះនឹងធ្វើខ្ជះខ្ជោះពុំបានទេ អ្នកពល់គ្នានឹងធ្វើការជាមួយនឹងយើង មិនត្រូវខ្ជិលច្រអូសមានពុតត្បុតគេចវេះ បើនរណាមិនពេញចិត្តប្រឹងធ្វើការទេ យើងនឹងកាត់ក្បាលចេញតាមអយ្យការសឹក ហើយជីវយើក៏តាំងអ៊ុយកាយ ហានគុង ជានាយកងទ័ពស្រេច លើកទាហានចុះទូកចម្បាំងឲ្យព្រមព្រៀងគ្នា ឲ្យជីវយឹម, ជីវថាយ លើកទាហានមួយកង, ឲ្យខ្សែកសុន តាំងសុត លើកទាហានមួយកង, តាំងលីហាង ជួទី លើកទាហានជាកងល្បាត ។

លុះជីវយើចាត់ចែងនាយទ័ពនាយកងសម្រេចហើយក៏បង្គាប់ថា អ្នកពល់គ្នាចូរស្រេចប្រញាប់ទៅត្រៀមប្រចាំឲ្យមូលគ្នា បើបានឮស្គរពារវេលាណា យើងនឹងលើកកងទ័ពចេញទៅតាំងនៅមាត់ជ្រោយស្រុកសាំកាំង នាយទ័ពនាយកងទាំងពួង ក៏គំនាប់លាចេញទៅចាត់ចែងទាហានត្រៀមទុកស្រេច តាមពាក្យជីវយើបង្គាប់ ។

ឯទៀវដូបុត្រទៀតៅ ឃើញជីវ័យតាត់វែងទាហាន ព្រមទាំង-ទ័ពគោកទ័ពទឹកដូច្នោះ ក៏យកសេចក្តីទៅជំរាបទៀតៅជាបិតាគ្រប់ប្រការ ទៀតៅឮដូច្នោះក៏យំណាស់ យកដៃគក់ដើមទ្រូងហើយថា ជីវ័យនេះ អញគិតថាជាក្មេងមិនទាន់ដឹងអ្វី ឥឡូវឃើញចេះដឹងជាងមនុស្សចាស់ ទៅទៀត ត្រឡប់មានជម្រះប្រាជ្ញាអង់អាច ដឹងរៀបចំទាហានក្នុង-កងទ័ពត្រឹមត្រូវតាមក្បួនទ័ពក្នុងសង្គ្រាម ល្អសមគួរដែលនឹងធ្វើជា មេកងធំបាន ដែលខ្លួនអញមកគិតប្រមាថមើលងាយខុសដូច្នេះមិនគួរ-សោះ ទៀតៅក៏ទៅរកជីវ័យដល់ទីលំនៅ ហើយក៏និយាយសូមទោស ថា ខ្ញុំបានជាកាន់ទិដ្ឋិមានះព្រោះថាចាស់ មើលងាយអ្នកដ្បិតនៅក្មេង មិនបានមកប្រឹក្សាការរាជការ គំនាប់អ្នកនោះខុសពេកណាស់ សុំឲ្យ អ្នកអាណិតអត់ទោសខ្ញុំចុះ ។ ជីវ័យអស់សំណើចហើយថា ដែល អ្នកប្រមាថមើលងាយនោះ ខ្ញុំមិនប្រកាន់ទោសទេកុំឲ្យព្រួយ ។ ទៀ-តៅបានឮកាសដូច្នោះហើយក៏លាត្រឡប់ទៅវិញ ។

លុះវេលាព្រឹក ជីវ័យឲ្យហៅដូគាត់ក៏ចូលមកនិយាយថា ខ្ញុំ បងប្អូនអ្នកជាមនុស្សមានជម្រះប្រាជ្ញា ហេតុម្តេចទៅធ្វើទូតនឹងឡៅពី ដូច្នោះ មិនសមសោះគួរតែនឹងមកនៅនឹងស៊ិនគួនទៅហ្វាយយើង ក៏នឹង មានយសបណ្តាស័ក្តិជាសុខសាន្ត អ្នកប្តូទៅនិយាយល្បួងល្អងឡោម ខ្ញុំបងប្អូនអ្នកឲ្យកលឡៅពីទៅមកនៅធ្វើការរួមដៃនឹងជាមួយគ្នានឹង

យើង ព្រោះខ្លួនអ្នកនៅទីនេះដែរ បងប្អូនទឹងបានឃើញមុខគ្នាព្រឹកល្ងាច ទាំងមិនល្អឬ ? ។ ជូកាត់កិនថា ខ្ញុំមកនៅទីនេះស៊ីនគួននេះ ក៏មិនទាន់មានសេចក្ដីគាប់ប្រសើរអ្វីសោះ បើដូច្នោះ ខ្ញុំនឹងទៅនិយាយនឹងប្អូនខ្ញុំមើល បើព្រមមកនៅនឹងអ្នកជាសេចក្ដីគាប់ប្រសើររបស់ខ្ញុំស្រាប់ , ជូកាត់កិនគំនាប់ហើយក៏ឡើងសេះស្រុតរូតទៅ ជួបនឹងខុងបេងដល់ទីសំណាក់ ។ ខុងបេងឃើញជូកាត់កិនជាបងមកដូច្នោះក៏មានអំណរណាស់ ចេញមកគំនាប់ហើយក៏នាំចូលទៅក្នុង អ្នកទាំង ២ ក៏យំលើកគ្នាព្រោះឃាតពាគមកយូរ ។

ជូកាត់កិនក៏និយាយនឹងខុងបេងថា ប៉ែះអ៊ី , សុកថៃ ពីដើមនោះដឹងឬទេ ? ។ ខុងបេងបានឮសំដីដូច្នោះក៏ដឹងថា ជាវយីប្រើឧបាយឲ្យមកនិយាយបញ្ឆោះបញ្ឆោលទើបឆ្លើយថា ប៉ែះអ៊ី , សុកថៃ ជាមនុស្សជាន់បុរាណ ត្រូវការអ្វីក៏នាំមកនិយាយឡើយ ។ ជូកាត់កិនថា ប្អូននិយាយនេះដូចជាគេគិតបងប្អូនគ្មានសោះហើយ ឯប៉ែះអ៊ី , សុកថៃ បងប្អូន ២ នាក់កើតផ្ទៃជាមួយ ធំកចំកៈដោះជាមួយគ្នា ព្រោះដោយសេចក្ដីស្រឡាញ់ ដូចប្អូននឹងបងកើតរួមៗ ដោយមួយគ្នា បៅដោះជាមួយគ្នា ទោះនឹងទៅធ្វើការអ្វី ។ នៅទីឯណាក៏ត្រូវតែទៅជាមួយគ្នា ទោះនឹងស្លាប់វេលាណាក៏ត្រូវតែស្លាប់ជាមួយគ្នាដែរ ដោយហេតុសេចក្ដីស្រឡាញ់ បើប្អូននឹងបងកើតមកជាមួយគ្នា ហើយទៅធ្វើជាការនៅទីខ្ទៃៗ ពីគ្នា មិន

បានឃើញមុខគ្នាព្រឹកល្ងាចដូច្នេះ ក៏មិនដូចប្រវេណីបងប្អូនគេពីដើម ម៉ឹង មិនមានសេចក្ដីអប្បយសដល់គេទាំងពួងឬ ? ។

ខុនបេងថា ដែលបងមានប្រសាសន៍នោះ ខ្ញុំបាទមិនទាន់ឃើញផងសោះ ព្រោះឃើញបងប្អូនកើតក្នុងផែនដីព្រះចៅហៀនគេ គួរណាស់តែកាន់ចិត្តគិតតែទ្រព្យនឹងផែនដី ហេតុដូច្នេះបានជា ខ្ញុំបាទស៊ូទៅនៅទីនេះឡើតី ព្រោះឃើញថាជាតុជព្រះឈ្នៀងព្រះចៅហៀនគេ ដើម្បីមិនឲ្យបង់ប្រវេណីបុរាណ ហេតុម្ដេចបានជាបងលះបង់ចោលផែនដីព្រះចៅហៀនគេស្រឡះ ស្វះស្វែងមកនៅក្នុងស្រុកកាំងតាំងឲ្យតែតែឆ្ងាយបងប្អូនទៅទៀត ដូចជាគ្មានចិត្តគិតទៀតទេក្រែកអាល័យសោះឡើយ ពេលនេះហើយគួរតែបងលះបង់ចោលស្រុកកាំងតាំងចេញ វិលទៅនៅផ្ទះដើមការទីនខ្ញុំបាទវិញ ឲ្យបានឃើញមុខគ្នាយប់ព្រឹកទើបគួរ ។ ដូកាត់ក៏ខបាន ស្ដាប់ដូច្នោះក៏គិតថា ខុនអញសុំអាសាយកល្បងល្បងលោមខុនបេង ឥឡូវខុនបេងត្រឡប់ល្បងលួងលោមឯងវិញដូច្នេះ ក៏ទាល់គំនិតមិនដឹងបើនឹងគិតនិយាយដូចម្ដេចទៅទៀត, ដូកាត់ក៏ខកំលាខុនបេងត្រឡប់ទៅ ប្រាប់ដំរិយ៍គ្រប់ប្រការ ។

ដំរិយ៍ឮហើយក៏មិនបានជាប្រការម្ដេច ... ជាលាស៊ីខគួន ហើយនិយាយថា ខ្ញុំនឹងសុំអាសាលើកទ័ពទៅចាប់ខ្ញុំខុនចុច ។ (នៅមានត)

ពាក្យវប្បធម៌

## លោក សម - ហ៊ាំង

*សមាជិកគណៈកម្មការវប្បធម៌ រៀបរៀង*

---

អស់លោកអ្នកអានទាំងឡាយ !

ពាក្យវប្បធម៌ ដែលចុះផ្សាយទៅលើទំព័រទស្សនាវដ្ដីកម្ពុជសុរិយានេះ ជាសេចក្ដីថ្មីតាមសំឡេងគណៈកម្មការវប្បធម៌ ដែលមានផ្សាយតាមវិទ្យុជាតិពីក្នុងឆ្នាំ១៩៥៩រួចមកហើយ ។ ហេតុដែលបានជាយកមកបោះពុម្ពផ្សាយក្នុងទីនេះទៀត មកពីលោក ចាប-ពិន អធិបតីក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ជាអ្នកចាត់ការខាងទស្សនាវដ្ដីកម្ពុជសុរិយា មានបំណងចង់ឲ្យសំឡេងគណៈកម្មការវប្បធម៌ ដែលបានផ្សាយរួចហើយនោះ ជាប់ជាលាយល័ក្ខណ៍អក្សរលើទំព័រទស្សនាវដ្ដីនេះផង បានសុំយកមកចុះផ្សាយ ដើម្បីជាសាធារណប្រយោជន៍ដល់សិក្សាកាមជនតទៅ ។ ខ្ញុំជាតំណាងគណៈកម្មការវប្បធម៌ បានយល់ព្រមតាមការសុំនេះហើយ ។

ឯសំឡេងគណៈកម្មការវប្បធម៌ ដែលបានផ្សាយតាមវិទ្យុជាតិ

ជាច្រើនពេកមកហើយនោះ ចែងអំពីរបៀបកែតម្រង់ពាក្យក្នុងភាសាជាតិ ឲ្យបានត្រឹមត្រូវតាមក្បួនខ្នាត ។ ឥឡូវនេះយើងសូមស្រង់យកពាក្យខ្លះ ដែលជាប់ទាក់ទង ដោយពាក្យបាលីមកអធិប្បាយពន្យល់ជូនក្នុងទំព័រ ទស្សនាវដ្ដីកម្ពុជសុរិយានេះម្ដងទៀត ។

ពាក្យដែលយើងបានស្រង់យកមកអធិប្បាយជូនក្នុងពេលនេះ មាន ៥ ម៉ាត់ដូចខាងក្រោម៖

១-អដ្ឋិសង្ខលិកា ;

២-អវេជ្ជាភាស ,

៣-អត្ថសង្គហៈ ;

៤-អត្ថន័យ ;

៥-អត្ថសញ្ញាណលិខិត ។

អដ្ឋិសង្ខលិកា កុំអាន អដ្ឋ-សាំង-លិក ឬ អដ្ឋ-សង-លិក ព្រោះមានជើង ខ នៅខាងក្រោមតួ-ង-ផង ត្រូវអានឲ្យអស់តួអក្សរថា អាត់-ថិ-ស័ង-ខៈ លិក, ត្រង់ ខៈលិក សុំកុំអានថា ខៈ លឹក ព្រោះ លិ ទីង ក អានថា លិក ពុំមែន លឹ ទឹង ក ដែលត្រូវអានថា លឹកទេ ។ អដ្ឋិសង្ខលិក សរសេរ = អ-ដ-ជើង ឋ មុខដ: ស្រៈ ឥ. ស-ង ជើង ខ-ល-ស្រៈឥ ទីង ក ។ អដ្ឋិសង្ខលិក ជាភាសាបាលី គេក

មកពីស័ព្ទ ២ គឺ អដ្ឋិ ១ និងសង្ខលិកៈ ១ , ពាក្យ ១ មានកើតមកពីស័ព្ទច្រើនរួមគ្នាដូច្នេះ លោកឲ្យឈ្មោះថា " សមាសនាម " ។ អដ្ឋិ ប្រែថា ឆ្អឹង, សង្ខលិកៈ ប្រែថា ការប្រមូលផ្តុំ , ប្រជុំ , គ្រោង ។ អដ្ឋិសង្ខលិក ប្រែតាមអត្ថានុរូបថា ការប្រមូលផ្តុំឆ្អឹង; តាមអត្ថប្បដិរូបថា គ្រោងឆ្អឹង ឬ មនុស្សស្គមកំព្រឹង , សំដៅគ្រោងឆ្អឹងទាំងមូលរបស់មនុស្ស , សត្វ ដែលគេយកសាច់ និងសរសៃចេញ នៅសល់តែគ្រោងឆ្អឹងទាំងអស់ ។ សូម្បីតែគ្រោងឆ្អឹងដុះ ឬទាក់ ក៏ហៅថា អដ្ឋិសង្ខលិកបានដែរ ។ ពាក្យនេះមានទំហំន័យប៉ុនគ្នានឹងពាក្យបារាំងថា (Squelette) ។

សុំជូនឧទាហរណ៍ ជាប្រយោគឲ្យយល់អំពីរបៀបប្រើ ដូចខាងក្រោម ៖

នៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ មានអដ្ឋិសង្ខលិកនៃមនុស្ស និងសត្វជាច្រើនគ្រោង សម្រាប់បង្រៀនសិស្សឲ្យយល់ច្បាស់ អំពីវិទ្យា. សាស្ត្រធម្មជាតិ ។

នៅមាត់កំពង់ផ្សារស្ទួនចាស់ មានអដ្ឋិសង្ខលិក នាវា ជាច្រើនគ្រឿងគ្រា ដែលជានឹកពុំនៃគួរផុល ។

អដ្ឋិសង្ខលិក នៃដំរី ធំជាគ្រោង ជាងអដ្ឋិសង្ខលិកនៃមនុស្ស, សត្វទាំងអស់ ។

ឧទាហរណ៍ ទាំងប្រយោគខាងលើនេះ បញ្ជាក់ជូនទស្សលោក

អ្នកឲ្យយល់អំពីរបៀបប្រើពាក្យអដ្ឋិសង្ខលិកៈហើយ ។

តពីនេះ សូមអញ្ជើញអានពាក្យមួយម៉ាត់ទៀត សុំអញ្ជើញអាន !

អជ្ឈោកាស សូមកុំអាន អៈ-ឈោ-កាស ព្រោះមានអក្សរ -ជ- តម្រួតលើជើង -ឈ- ផង, ត្រូវអានឲ្យគ្រប់តួអក្សរថា អាច់-ឈោ-កាស ។ អជ្ឈោកាស សរសេរ= អ-ជ-ជើងឈ ស្រៈឱ-ក-ស្រៈអា ទីងស ។ អជ្ឈោកាស ជាភាសាបាលី កើតមកពីស័ព្ទ២គឺអធិ ដែលផ្លាស់ជា អជ្ឈៈ១ និងឱកាសៈ ១ ។ ពាក្យមួយម៉ាត់ដែលរួមមកពីស័ព្ទច្រើនរូបដូច្នេះ លោកហៅថា "សមាសនាម" ។ អធិ ឬ អជ្ឈៈ ប្រែថា ក្រៅ គោក ក្រៅលែង; ឱកាសៈ ប្រែថា ទីវាល, ចំនេរ ។ អជ្ឈោកាសប្រែតាមអត្ថន័យរូបថា ទីវាល, ទីចំនេរក្រៅគោក តាមអត្ថប្បដិរូបថា ទីវាលស្រឡះ, ទីវាលកណ្ដាលថ្ងៃ សំដៅទីវាលស្រឡះល្ហល្ហៃដែលគ្មានគុម្ពោតបាំងខ្ទប់ ។

សូមជូនឧទាហរណ៍ ជាប្រយោគដូចខាងក្រោមនេះ ។

កុមារ កុមារីទាំងឡាយ, ប្អូនអ្នក-នាង នាំគ្នាទៅលំហែកាយក្នុងអជ្ឈោកាសឲ្យបានញឹកញយ ទើបអ្នកនាងនឹងមានសុខភាពល្អ ។

នៅកំពង់ផែ នាក្រុងព្រះសីហនុ មានអជ្ឈោកាសល្អណាស់ ។

ឧទាហរណ៍ប៉ុណ្ណេះ ល្មមអស់លោកអ្នកអាន យល់អំពីពាក្យអជ្ឈោកាសបានហើយ ។

តទៅនេះ សុំអញ្ជើញអានពាក្យ ១ ម៉ាត់ទៀត អញ្ជើញអាន!

អត្ថសង្គហៈ  សូមកុំអាន  អាត់-ស័ង.ហ. ព្រោះមាន ជើង ថ ទន្ដ:នៅពីក្រោមអក្សរ ត, មានជើង គ នៅខាងក្រោមគួ ង ផង ត្រូវអានឲ្យអស់តួអក្សរថា អាត់-ថ:.ស័ង-គ:.ហ: ។ អត្ថសង្គហ: សរសេរ=អ-ត ជើង ថ ទន្ដ: ស-ង-ជើង គ ទីងហ ។ ពាក្យនេះជាពាក្យ បាលី កើតមកពីសព្ទ២ គឺ អត្ថ + សង្គហៈ;អត្ថៈប្រែថា ផលប្រយោជន៍, សេចក្ដីពន្យល់, ពាក្យប្រែស្រាយ , សេចក្ដីចំរើន , គតិ , រឿង , ហេតុ ការណ៍,ផល ,បំណង, សេចក្ដីប្រាថ្នា,ទ្រព្យ,សម្បត្តិ,របស់ វត្ថុ;អំពើន;កិច្ច; កិច្ចការធុរ:,រវល់ ។ សង្គហ:ប្រែថា ការសង្គ្រោះ,ការកាន់យកឬការស្រង់ៗ មែសព្ទទាំង២ចូលគ្នាបានជាអត្ថសង្គហ:ហៅថា «សមាសនាម» បើប្រែ តាមអត្ថានរូបថា ការសង្គ្រោះឬការស្រង់សេចក្ដី ។ តាមអត្ថប្បដិរូប ជាឈ្មោះសៀវភៅដែលគេស្រង់អត្ថបទផ្សេងៗ យកមកចងក្រងទុក ត្រូវ ទីងពាក្យបារាំងថា (Recueil) ។

សុំជូនប្រយោគជាឧទាហរណ៍ ដូចខាងក្រោម៖

ទិស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានបោះពុម្ពសៀវភៅអត្ថសង្គហ: នៃច្បាប់តុលាការរៀងរាល់ខែ ជាបារាំងហៅថា (Recueil judiciaire) ។

ឧទាហរណ៍ប៉ុណ្ណេះ ល្មមអស់លោកអ្នកអាន យល់បានអំពីពាក្យ អត្ថសង្គហ: នេះហើយ ។

តទៅសុំអញ្ជើញអានពាក្យ១ម៉ាត់ទៀត អញ្ជើញអាន !

អត្ថន័យ សរសេរ=អ-ត.ជើងថទន្តជៈន-យ-ទាំងសំយោគសញ្ញា ។ សុំកុំអានថា អត្ថៈ-ណៃ ត្រូវអានថា អាត់.ថៈ នៃ,ពាក្យនេះជាភាសាបាលី កើតមកពីស័ព្ទពីរ គឺអត្ថៈ ប្រែថា ផល, ផលប្រយោជន៍, សេចក្ដី, សេចក្ដីពន្យល់, ពាក្យប្រែស្រាយ, សេចក្ដីចំរើន, គតិ, រឿង, ហេតុ, ការណ៍ , បំណង,សេចក្ដីប្រាថ្នា, ទ្រព្យ, សម្បត្តិ, របស់, វត្ថុ, អីវ៉ាន់, កិច្ច, កិច្ចការធុរៈ, រវល់ ទាំងនយៈឬន័យប្រែថា ការណែនាំអធិប្បាយ, សេចក្ដីពន្យល់, ហេតុ, ទំនង, លំនាំ; រួមបានជា អត្ថន័យ(ជាសមាសនាម) ។ អត្ថន័យប្រែថា សេចក្ដីអធិប្បាយពន្យល់អំពីគតិ, ហេតុ, ការណ៍, ត្រូវនឹងពាក្យបារាំងថា (Définition) ។

សុំជូនប្រយោគជាឧទាហរណ៍ដូច្នេះ៖

ពាក្យប្រៀនប្រដៅ របស់បណ្ឌិតមានអត្ថន័យជ្រាលជ្រៅណាស់ ទោះបីជាពាក្យខ្លីសោះ ក៏គង់មានអត្ថន័យវែងឆ្ងាយដែរ ។

ឧទាហរណ៍ប៉ុណ្ណោះ ល្មមអស់លោកអ្នកអានយល់បានអំពីពាក្យថា អត្ថន័យ នេះហើយ ។

បន្ទាប់ពីនេះ សុំអញ្ជើញអានពាក្យមួយតទៀត អញ្ជើញអាន !

អត្ថសញ្ញាណលិខិត សរសេរ=អ-ត-ជើងថ-ស-ញ ស្រះអា-ជើងញ-ណ-ល-ស្រះឥ-ខ-ស្រះឥទាំងត ។ កុំអានថា អៈ-តៈព្រោះតួ ត មានសំយោគ ទាំងកុំអានថា: សៈ-ញាណព្រោះតួ ញ ក៏មានសំយោគដែរ,

ត្រូវអានថា អាត់-តៈ-សាញ់-ញ៉ា-ណៈ-លិខិត ។ កុំអានថា អ័ត-តៈ-សាញ់-ញាន ត្រូវអានថា សាញ់-ញ៉ាន ព្រោះមានអក្សរ ស នៅពីខាងដើមត្រូវអានថា ញ៉ា ដូចពាក្យថាសញ្ញា, បរិញ្ញាដែរ គឺត្រូវអានថា សាញ់-ញ៉ា, ប៉រិញ-ញ៉ា កុំអានថា ញា ។

ពាក្យនេះជាពាក្យបាលី រួមមកពីសព្ទ៣គឺៈ អត្តៈ ប្រែថា ខ្លួនឬចិត្ត១ សញ្ញាណៈ ការសំគាល់១ និងលិខិតៈ ប្រែថា សរសេរ,គូរ;សំបុត្រ, បុតហ្វាយ១ រួមគ្នាទាំង៣សព្ទជា អត្តសញ្ញាណលិខិត ប្រែថា សំបុត្រសម្រាប់សំគាល់ខ្លួន; ត្រូវនឹងពាក្យបារាំងថា(Pièce d'identité) ។ សព្ទច្រើនរួបរួមគ្នាបានជាពាក្យមួយម៉ាត់ដូច្នេះ ហៅថា "សមាសនាម,, ។

សុំជូនឧទាហរណ៍ ជាប្រយោគឲ្យងាយយល់ ដូចខាងក្រោមនេះៈ

ពលរដ្ឋគ្រប់សញ្ជាតិក្នុងលោក ដែលនឹងអាចឆ្លងកាត់ប្រទេសមួយៗបាន ដោយឥតទាស់ខុសនឹងបញ្ញត្តិច្បាប់ លុះត្រាតែមានអត្តសញ្ញាណលិខិតគ្រប់គ្រាន់ ។

ឧទាហរណ៍ ជាប្រយោគប៉ុណ្ណេះ ជាការបញ្ជាក់ជូនអស់លោកអ្នកអាន ឲ្យយល់អំពីពាក្យ អត្តសញ្ញាណលិខិតហើយ ។

## ផ្នែកកំណត់ដំណើរប្រវត្តិការណ៍

# អនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៦

លោក ប៊ង - វង រៀបរៀង

---

កាលពីថ្ងៃទី ២១ មករា ១៩៦០ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត មានធ្វើពិធីអនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃជាលើកទី ១៦ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃព្រះមហាក្សត្រទាំងពីរព្រះអង្គ ។

នៅមុនពេលបើកពិធីនេះ យើងបានសង្កេតឃើញព្រះសង្ឃទាំងឡាយ ដែលមានសមណសក្តិជាគណៈបាលានុក្រម ព្រមទាំងព្រះសង្ឃជាមេគណ អនុគណ ចៅអធិការ ដែលគង់នៅក្នុងព្រះរាជធានីភ្នំពេញ និងខេត្តក្រៅជាច្រើនពាន់អង្គ ទាំងពីរគណៈ បាននិមន្តមកកាន់ទីប្រជុំ នៅឯពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ដែលនៅក្នុងឱកាសនោះ សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ព្រមទាំងព្រះពោធិវង្ស ហួត-តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត និងព្រះមហាព្រហ្មមុនី ទេព-អ៊ូ ចាងហ្វាងរងនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

បានទទួលមកជាប្រធានផង ។

ចំណែកឥស្សរជន ដែលបានអញ្ជើញទៅរង់ចាំគោរពព្រះមហាក្សត្រគឺ ព្រះអង្គម្ចាស់ក្សត្រី ប៉ិង-ប៉ោះយុគន្ធរ លោក ជួប-ហែល លោក ឯក-យីអ៊ុន ជាប្រធាននៃសភាទាំងពីរ ព្រមដោយសមាជិកសភាខ្លះ លោក សឺន-សាន ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស លោក ញឹក-ជូឡុង ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងផែនការអប់រំជាតិ ព្រមទាំងសមាជិករដ្ឋាភិបាលខ្លះ លោក ស្វ-ណែម រដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងបុគ្គលិកនៃក្រសួងនេះ លោក យួន ណៃ ចាងហ្វាងមន្ទីរសង្ឃពេទ្យព្រះកុសុមៈ លោក ជា-អ៊ុន នាយកក្រុមពិធីការក្នុងព្រះបរមរាជវាំង ព្រមទាំងមន្ត្រីអ្នករាជការជាច្រើនទៀត បានយាង បានអញ្ជើញមកកាន់កន្លែងប្រកបពិធី ។

នៅវេលាម៉ោង ៨ និង ៣០ នាទីព្រឹក ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រិយានី · ដោយមានសម្តេចចៅហ្វាវាំង វរវៀងជ័យអធិបតីស្រីធរា ប៉ែន-នុត ឯកឧត្តម សាន-យុន អគ្គនាយកនៃក្រសួងនានាក្នុងព្រះបរមរាជវាំង ឯកឧត្តម ជូ-ព្រឿង ព្រឿង-កាង ទេព-ផន មៀច-គន្ធ ជាសមាជិកឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ លោក អ៊ុង-ហ៊ុងសាច លេខាធិការរងទី ១ នៃឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ លោក ម៉ៅ-ចយ ទីប្រឹក្សាបច្ចេកទេស នៅការិយាល័យការងារប្រជា-

ក្រស្តទឹងលោកវរសេនីយត្រី ស-ហោ ព្រះរាជអង្គរក្ស ហែអមព្រះអង្គផង បានស្តេចយាងមកដល់កន្លែងប្រកបពិធី ដែលពេលនោះក្រុមតាហានរក្សាព្រះអង្គ និងក្រុមភ្លេងព្រះរាជទ្រព្យបានលើកអាវុធវន្ទា ទាំងបន្លឺបទចរ-យាត្រាថ្វាយជាព្រះរាជកិត្តិយស ។

ក្រោយដែលព្រះមហាក្សត្របានទទួលបដិសណ្ឋារកិច្ចអំពីឥស្សរជន និងយាងចូលថ្វាយបង្គំព្រះសង្ឃរួចហើយ តមក ក្រុមតន្ត្រីព្រះរាជទ្រព្យក៏បានបន្លឺឡើង នូវបទនគររាជថ្វាយព្រះមហាក្សត្រជាទីគោរព ។

ឥស្សរជនទាំងឡាយដែលនៅរង់ចាំថ្វាយបង្គំទទួល និងសំដែងសេចក្តីស្វាមីភក្តិចំពោះព្រះមហាក្សត្រទាំងពីរព្រះអង្គ ក៏បានដង្ហែព្រះអង្គចូលគង់ប្រថាប់លើព្រះសុវណ្ណកោដ្ឋៈ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

ក្រោយដែលព្រះមហាក្សត្រទាំងពីរព្រះអង្គទ្រង់សំដែងគារវកិច្ច ចំ.ពោះព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធានរួចហើយ តមក លោក ស៊ូ-ណែម រដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថាមួយ មានសេចក្តីដូចតទៅនេះ :-

សូមព្រះតេជះតំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល ព្រះករុណា ជាអម្ចាស់ជីវិតទាំង ២ ព្រះអង្គ,

សូមព្រះរាជទានក្រាបបង្គំទូល សម្តេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ

សូមទ្រង់ជ្រាបក្រោមលម្អងធូលីព្រះបាទ ។

ក្នុងនាមនៃក្រសួងធម្មការ និងសាសនសិក្សាធិការ និងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានថ្លែងនូវអំណរព្រះគុណ ទិតុណាជាទីបំផុត ព្រមទាំងកតញ្ញូធម៌ដ៏ជ្រាលជ្រៅ និងដោយគោរពចំពោះព្រះករុណាថ្លៃវិសេស ទាំង២ព្រះអង្គ និងសម្តេចដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកជាព្រះរាជាធិបតីក្នុងឱកាសពិធីបើកអនុសំវច្ឆរៈមហាសន្និបាត មន្ត្រីសង្ឃ ទី ១៦ សម្រាប់ឆ្នាំកុរនេះ ដោយសោមនស្សចេតនាដ៏ឧត្តម ។

សូមទ្រង់ព្រះមេត្តាប្រោស,

ក្នុងវារៈនៅ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះរាជឱកាស លម្អងធូលីព្រះបាទ ដើម្បីប្រគេនពតិភនខ្លះ ចំពោះព្រះថេរានុត្ថេរៈ មានសម្តេចទាំង ២ ព្រះអង្គជាប្រធាន ដែលបាននិមន្តមករួមប្រជុំក្នុងទីនេះ ។

សូមថ្វាយបង្គំសម្តេចទាំង ២ ព្រះអង្គ ព្រមទាំងព្រះថេរានុត្ថេរៈជាព្រះរាជាគណៈ មេគណ អនុគណ ចៅអធិការទាំងអស់ដោយគោរព ។

ខ្ញុំព្រះករុណា សូមថ្លែងនូវសោមនស្សរីករាយយ៉ាងក្រៃលែងចំពោះសម្តេចនិងព្រះករុណាគ្រប់ព្រះអង្គ ព្រោះការជួបជុំនេះ ជាឱកាសមួយ

ប្រពៃ ដែលអាចបង្វែរមកនូវសេចក្ដីរុងរឿង សេចក្ដីចំរើនជាអនេកប្បការជូនជាតិ សាសនា ព្រះមហាក្សត្រ ។

សម្ដេច,

ព្រះករុណាគ្រប់ព្រះអង្គ,

ដូចសម្ដេច ព្រះករុណាគ្រប់ព្រះអង្គ បានជ្រាបច្បាស់ស្រាប់ តាំងពីដើមរៀងដរាបមក ព្រះពុទ្ធសាសនាតែងបានទទួលនូវការវិវត្តន៍ត ៗ ជាលំដាប់រហូតមកដល់សព្វថ្ងៃ ដែលបានទទួលនូវឯកភាពដ៏បរិបូណ៌នេះ ។ ខ្មែរទូទៅសុទ្ធសឹងជាពុទ្ធសាសនិក មានសទ្ធាដ៏បរិសុទ្ធចំពោះត្រៃសរណគមន៍ ។ លទ្ធផលដ៏ប្រសើរ គឺការរីកសាយទូលំទូលាយនៃព្រះពុទ្ធសាសនាក្នុងកម្ពុជាណាចក្រនេះ ក៏អាស្រ័យដោយបុព្វហេតុជាច្រើន តែជាពិសេសគឺដោយព្រះរាជូបត្ថម្ភដ៏ជ្រះថ្លាយ៉ាងមុះមុត នៃព្រះមហាក្សត្រយើងគ្រប់ៗ អង្គ ព្រមទាំងព្រះរាជវង្សានុវង្ស ។

សព្វថ្ងៃនេះ ក៏ដូចកាលជំនាន់ព្រះបាទអសោករាជ ព្រះរាជបល្ល័ង្កនិងព្រះរាជវង្សានុវង្ស ព្រមដោយព្រះរាជរដ្ឋាភិបាល ដែលមានសម្ដេចព្រះឧបយុវរាជ ជាព្រះអគ្គនាយកមគ្គុទ្ទេសក៍ បានយកព្រះទ័យទុកដាក់ ទំនុះខ្នងលើកស្ទួយពុទ្ធនិយមឲ្យមានរបៀបរៀបរយ សេចក្ដីថ្លៃថ្នូរខ្ពង់ខ្ពស់សមជាទីពឹងផ្អែកនៃសព្វសត្វ និងជាទីគោរពនៃជនានុជនគ្រប់ប្រភេទគ្រប់ជាន់ថ្នាក់ បានធ្វើឲ្យកិត្តិសព្ទ កិត្តិនាម នៃព្រះពុទ្ធសាសនាឲ្យលេចឮខ្ទរពេញ

ពិភពលោក ។ ប្រទេសទាំងឡាយដែលជាពុទ្ធសាសនិកក្ដី ដែលពុំមែនជាពុទ្ធសាសនិកក្ដី សឹងបានសំដែងនូវសេចក្ដីកោតសរសើរ បានទទួលស្គាល់ថា ប្រទេសកម្ពុជាមានភ័ព្វសំណាងល្អណាស់ ព្រោះជារដ្ឋកាន់ព្រះពុទ្ធសាសនា មានសេចក្ដីប្រតិបត្តិហ្មត់ចត់ពុំមានល្អៀងពីព្រះពុទ្ធវាទឡើយ ព្រោះព្រះសង្ឃខ្មែរទាំងឡាយ ទោះភិក្ខុក្ដី សាមណេរក្ដី ក្រោមការដឹកនាំនៃសម្ដេច នឹងព្រះតេជព្រះគុណ មេគណ អនុគណ ចៅអធិការ ឧបជ្ឈាយាចារ្យ ពុំបានភ្លេចនូវបណ្ដាំព្រះពុទ្ធបរមគ្រូដែលទ្រង់បានពោលថា: «ព្រះពុទ្ធសាសនានឹងបានថ្កុំថ្កើងក្ដី នឹងសាបសូន្យទៅវិញក្ដី គឺអាស្រ័យដោយកូនចៅតថាគត» ។

ដើម្បីជាទស្សនានុត្តរិយៈ ខ្ញុំព្រះករុណាសូមបញ្ជាក់ថា ទោះជាមានមធ្យោបាយដ៏ខ្សត់ខ្សោយយ៉ាងណាក៏ដោយ ក្នុងក្របខណ្ឌនៃចលនាសង្គមរាស្ត្រនិយមប្រទេសយើងបានឧបត្ថម្ភដ៏ពេញទំហឹងដល់ព្រះពុទ្ធសាសនា ថែមទាំងបានរៀបចំពិធីបុណ្យធំៗ យ៉ាងដូចជាបុណ្យអរហន្តធាតុ បុណ្យពុទ្ធសករាជ២៥០០ដ៏ឧត្តុង្គឧត្ដមនឹងបានចាត់គណៈប្រតិភូជាច្រើនឲ្យទៅរួបរួមក្នុងពិធីបុណ្យពុទ្ធសករាជ២៥០០ ច្រើនដង ឲ្យទៅរួមប្រជុំក្នុងសន្និបាតនានា មានមហាសន្និបាតនៃពុទ្ធិកសមាគមពិភពលោកជាដើម ។

សូមទ្រង់ព្រះមេត្តាប្រោស,

ក្នុងនាមនៃពុទ្ធមាមកជនទាំងឡាយ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរម-

រាជានុញ្ញាតព្រះករុណាថ្លៃវិសេស ទៀតឱកាសដ៏ប្រពៃនេះ ដើម្បីថ្លែងជាជូនកតញ្ញូធម៌យ៉ាងជ្រាលជ្រៅ ជាពិសេស ចំពោះសម្ដេចព្រះបិតាឯករាជ្យជាតិ ដែលក្នុងពេលថ្មីនេះ ទ្រង់បានតាំងព្រះហឫទ័យជាទីងតាក់ឲ្យរៀបចំធ្វើមហាសន្និបាតទី ៦ នៃពុទ្ធសមាគមពិភពលោក សម្រាប់ឆ្នាំ ១៩៦០ នៅក្នុងរាជធានីភ្នំពេញយើង ។ មហាសន្និបាតនេះ ដែលនឹងត្រូវរួមប្រជុំប្រហែល ៣០ ប្វាយ គណៈប្រតិភូនៃប្រទេសកាន់ព្រះពុទ្ធ-សាសនា មុខជានឹងនាំឲ្យគុណធម៌ដ៏ប្រសើរ ដែលជាមូលដ្ឋាននៃព្រះពុទ្ធសាសនា បានដល់ អហឹសា គឺការមិនបៀតបៀនដល់អ្នកដទៃ មេត្តាធម៌ គឺការផ្សាយសេចក្ដីអាណិតអាសូរទៅរកសព្វសត្វ ករុណាធម៌ គឺការផ្សាយសេចក្ដីពប់អានសង្គ្រោះទៅរកសព្វសត្វ សប្បុរិសធម៌ គឺការមិនធ្វើអំពើអាក្រក់ដល់មនុស្សដោយកាយវាចាចិត្តជាដើម ដើម្បីសន្តិភាព ពោលគឺសេចក្ដីសុខ សេចក្ដីចំរើននៃសាកលលោក ព្រមទាំងធ្វើឲ្យសាកលលោក ស្គាល់នូវគុណភាពនៃប្រទេសខ្មែរកាន់តែជាក់ច្បាស់ឡើងទៀត ។

មួយផ្នែកវិញទៀត ក្នុងឋានៈជាពលរដ្ឋខ្មែរមួយរូប ដែលចង់ឲ្យជាតិ សាសនា ព្រះមហាក្សត្រ ពោលគឺប្រជាជាតិបានស្គាល់នូវវឌ្ឍន-ភាពគ្រប់គ្រាន់ ឲ្យបានទទួលនូវសេចក្ដីចំរើនរុងរឿង សមនឹងឋានៈជាអារ្យប្រទេស នឹងក្នុងឋានៈជាសមាជិកនៃព្រះរាជរដ្ឋាភិបាល ទទួលភារៈ

ខាងផ្នែកសាសនា ទូលព្រះបង្គំជាខ្ញុំ មានសេចក្ដីត្រេកអរជាពន់ពេក ដោយបានសង្កេតឃើញថា ព្រះថេរានុត្ថេរខ្មែរទាំងឡាយ ដែលឋិតនៅក្នុងព្រះរាជាណាចក្រ នៅក្រៅព្រះរាជាណាចក្រ ឬដែលបានចេញទៅបន្តវិជ្ជានៅបរទេសក្ដី សុទ្ធបានប្រាថ្នានឹងយល់ច្បាស់នូវគោលហេតុទាំងឡាយ ដែលទូលព្រះបង្គំជាខ្ញុំក្រោមល្អងធូលីព្រះបាទ បានពណ៌នាមកស្រួស ៗ ពីខាងដើមនេះ ។ ព្រះសង្ឃដែលធ្លាប់តែជួយទ្រទ្រង់នូវជាតិនិយមខ្មែរ គោលគឺជាតិ សាសនា ព្រះមហាក្សត្រ ដែលបានទ្រទ្រង់រៀងដរាបមកនូវអារ្យធម៌ នូវវប្បធម៌ខ្មែរ ក៏បានជួយទ្រទ្រង់ពេញទំហឹងទាំងដោយកាយ ទាំងដោយវាចា ទាំងដោយចិត្ត នូវព្រះរាជបេសកកម្ម និងព្រះរាជនយោបាយដ៏ឆ្នើមនៃសម្ដេចព្រះឧបយុវរាជ គឺនយោបាយអព្យាក្រឹត ៗ អព្យាក្រឹតជាមាគ៌ាស្របនឹងផ្លូវដែលព្រះពុទ្ធបរមគ្រូបានត្រាយទុកមក និងនយោបាយលើកតំកើងជីវភាពពលរដ្ឋ ព្រោះកាលបើពលរដ្ឋដែលជាពុទ្ធសាសនិកជននេះ មិនបានសម្បូណ៌សប្បាយខ្ពស់ថ្កើងទេ ព្រះពុទ្ធសាសនាដែលមានព្រះសង្ឃជាតំណាង ក៏ពុំអាចលូតលាស់ឲ្យសមតាមសេចក្ដីប្រាថ្នា នៃយើងទាំងអស់គ្នាឡើយ ៗ ដូច្នោះហើយ បានជាពុទ្ធចក្រ និងអាណាចក្រក្នុងប្រទេស មានការប្រាស្រ័យគ្នាកាន់តែជិតស្និទ្ធឡើង និងអាចជួយបំពេញមុខការ និងប្រយោជន៍ផ្សេង ៗ ដល់គ្នានឹងគ្នាទៅវិញទៅមក ។

មុននឹងបញ្ចប់ ទូលព្រះបង្គំជាខ្ញុំ ក្រោមល្អងធូលីព្រះបាទ ខ្ញុំព្រះករុណា ជឿជាក់ចំពោះភាសិតនៃព្រះពុទ្ធបរមគ្រូ ដែលមានសម្តែងថា

សច្ចំ វេ អមតា វាចា ពាក្យសច្ចៈមិនចេះស្លាប់,

សតញ្ច ធម្មោ ន ជរំ ឧបេតិ ធម៌របស់សប្បុរសមិនចេះចាស់ ។

គឺអាស្រ័យអានិសង្សនៃសេចក្តីបរិសុទ្ធទាំងនេះ ដោយអានិសង្សនៃកុសលផលដែលខ្ញុំបានសាងទុកមកជាយូរឆ្នាំ នូវអំពើល្អ អំពើត្រូវ ដែលកំពង់តែកសាងសព្វថ្ងៃនេះ ដោយព្រះតេជបារមីនៃព្រះករុណាថ្លៃវិសេសទាំង ៣ ព្រះអង្គ ប្រទេសកម្ពុជានឹងពុំជួបប្រទះនូវចង្រៃទុក្ខភ័យអ្វីមួយឡើយ ។ បច្ចាមិត្រ សត្រូវទាំងឡាយ មានពួកក្បត់ឧត្តមប្រយោជន៍នៃជាតិ សាសនា ព្រះមហាក្សត្រ ជាដើម មុខជានឹងវិនាសសាបសូន្យ ។

ជាទីបំផុត ទូលព្រះបង្គំជាខ្ញុំក្រោមល្អងធូលីព្រះបាទ សូមប្រសិទ្ធពរបួងសួងដល់គុណព្រះរតនត្រ័យ ព្រមទាំងទេវតាទាំងមួយម៉ឺនលោកធាតុ សូមជួយអភិបាលព្រះពុទ្ធសាសនា ព្រមទាំងព្រះករុណាថ្លៃវិសេសទាំង ២ ព្រះអង្គ និងសម្តេចសហជីវិន សូមព្រះអង្គគង់នៅជាបរមសុខក្នុងរាជ-សម្បត្តិ ដើម្បីជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋគ្រប់ប្រភេទតទៅ ។

មួយវិញទៀត សូមព្រះករុណាគ្រប់ព្រះអង្គ មានសម្តេចទាំង ២ ជាប្រធាន បានប្រកបដោយសេចក្តីសុខ-ចំរើនគ្រប់ប្រការ រក្សាព្រះពុទ្ធសា-

សនាឲ្យបានចំរើនរុងរឿងរហូតដល់ ៥០០០ ព្រះវស្សា កុំបីឃ្លាតឡើយ ។

លុះចប់សុន្ទរកថានេះហើយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់សព្វព្រះរាជហឫទ័យ ថ្លែងព្រះរាជសុន្ទរកថាមួយដូចតទៅនេះ -

សូមពិតពុទ្ធដីកា សម្តេច ព្រះតេជព្រះគុណគ្រប់ព្រះអង្គ,

ខ្ញុំករុណាមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានឃើញ សម្តេច ព្រះតេជព្រះគុណទាំងអស់ និមន្តមកកាន់មហាសន្និបាតនេះ ដើម្បីជ្រោមទូវកិច្ចការទាំងឡាយខាងពុទ្ធចក្រនិងអាណាចក្រ ដែលបាន ប្រព្រឹត្តតាំងពីក្នុងមហាសន្និបាតទី ១៤ មកទល់នឹងសព្វថ្ងៃនេះ ព្រម ទាំងកិច្ចការដែលនឹងប្រព្រឹត្តទៅអនាគតទៀតផង ។

ខ្ញុំករុណាមានសេចក្តីជឿជាក់ថា សម្តេច ព្រះតេជព្រះគុណ គ្រប់អង្គ ដែលបាននិមន្តមកជួបជុំក្នុងទីនេះក្តី ដែលពុំបាននិមន្តមកក្តី នឹង ជួយជ្រោមជ្រែងព្រះពុទ្ធសាសនានៅក្នុងប្រទេសយើងនេះ ឲ្យរឹតតែ ចំរើនលើសដើម ដោយការមិនបង្កើតនូវវត្តអារាមយើកយោក ដោយ ការទំនុកបម្រុងរៀបចំវត្តអារាមដែលមានហើយ ឲ្យមានសភាពកាន់តែថ្កុំថ្កើង ឡើង ព្រមដោយការគោរពធម្មវិន័យ ឲ្យបានសម្រេចនូវមគ្គផលដ៏ បរិបូណ៌តាមមាគ៌ាដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាយទុកមក ។

ម្យ៉ាងទៀត ខ្ញុំករុណាមានសេចក្តីរីករាយជាពន់ពេក ដោយបាន ឃើញថា ក្នុងពេលដែលព្រះពុទ្ធសាសនាបានស្គាល់នូវសេចក្តីរុងរឿង

យ៉ាងប្រសើរក្នុងបច្ចុប្បន្នកាលនេះ សម្តេចព្រះតេជព្រះគុណគ្រប់ព្រះអង្គ បានជួយឧបត្ថម្ភដោយម៉ឺងម៉ាត់ដល់ពង្រឹងស្ថិរភាព ក្នុងការចំរើនមាតុប្រទេស ឲ្យបានដំណើរយ៉ាងឆាប់រហ័ស ទៅកាន់ខ្ពង់ខ្ពស់ ។ និងសុភមង្គលដ៏ឧត្តមតរៀងទៅ ។

ទៅទីបំផុត ខ្ញុំករុណា សូមប្រគេនសព្ទសាធុការពរចំពោះសម្តេចព្រះតេជព្រះគុណគ្រប់ព្រះអង្គ សូមឲ្យបានប្រកបដោយនូវសេចក្តីសុខចំរើន រហូតដល់ព្រះនិព្វាន ហើយខ្ញុំករុណាសូមប្រកាសបើកមហាសន្និបាតលើកទី ១៦ ។

លុះចប់ព្រះរាជសុន្ទរកថានេះហើយ ព្រះតេជព្រះគុណព្រះសាសនសំវរ កាន់-កែល អនុគណស្រុកមុខកំពូល (កណ្ដាល) បានថ្លែងសុន្ទរកថាតមកទៀត មានសេចក្តីដូចតទៅនេះ ៖

សូមថ្វាយព្រះពរព្រះករុណាជាអម្ចាស់ជីវិតទាំងពីរព្រះអង្គ ,

សូមថ្វាយព្រះពរសម្តេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ

សូមទ្រង់ជ្រាប ។

ក្នុងនាមនៃមន្ត្រីសង្ឃនិងព្រះថេរានុត្ថេរៈទាំងឡាយ សូមថ្វាយព្រះពរថ្លែងនូវអំណរព្រះគុណដ៏ខ្ពង់ខ្ពស់បំផុត ចំពោះព្រះករុណាជាវិសេសទាំងពីរព្រះអង្គ និងសម្តេចព្រះបិតាឯករាជ្យជាតិ ដែលទ្រង់ព្រះមេត្តាប្រោសស្តេចយាងមកជាព្រះរាជាធិបតី ក្នុងពិធីអនុស្សរណៈមហាសន្និបាតទី ១៦នៃ

មន្ត្រីបរិស័ទនេះដោយព្រះរាជហឫទ័យសោមនស្សចំពោះសន្និសីទមហាសន្និបាតៗ

សូមទ្រង់ព្រះមេត្តាប្រោស,

ក្នុងបំណាច់គេទៅ អាត្មាភាពសូមព្រះរាជទានព្រះរាជឱកាសដើម្បីថ្វាយពតិមានខ្លះ ព្រមទាំងថ្វាយតបសុន្ទរកថានៃលោកវេដ្ឋលេខាធិការក្រសួងធម្មការ ដូចសេចក្ដីរៀបរាប់ថ្វាយដោយសង្ខេបតទៅនេះ ៖

ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ដែលទទួលនូវវឌ្ឍនភាពចំរុងរឿង ជាប់តមកដល់សព្វថ្ងៃនេះ ដោយអំណាចព្រះមហាក្សត្រដែលមានព្រះរាជហឫទ័យជ្រះថ្លាទំនុកបំរុងព្រះពុទ្ធសាសនា ព្រមទាំងពុទ្ធបរិស័ទ ទាំងបព្វជិតទាំងគ្រហស្ថ តាំងពីអតីតកាលរៀងរាបដរាបមករហូតដល់សព្វថ្ងៃនេះ ព្រះករុណាជាម្ចាស់ជីវិតទាំងពីរព្រះអង្គ គឺសម្ដេចព្រះបិតាឯករាជ្យជាតិ សុទ្ធតែជាអគ្គពុទ្ធសាសនូបត្ថម្ភក៍ ព្រមទាំងព្រះរាជរដ្ឋាភិបាល ដែលមានសម្ដេចព្រះឧបយុវរាជជាព្រះអគ្គនាយកនៃរាជរដ្ឋាភិបាល បានបំពេញព្រះរាជបេសកកម្ម ទាំងផ្លូវពុទ្ធចក្រនិងអាណាចក្រ ឲ្យមានតុល្យភាព ឲ្យមានរបៀបរៀបរយល្អ ។ កិត្តិស័ព្ទដ៏ពិរោះរបស់ព្រះពុទ្ធសាសនានៃប្រទេសកម្ពុជាយើង សឹងល្បីលេចឮប្រាកដក្នុងសកលលោក ។ ក្នុងបណ្ដាប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាឬប្រទេសក្រៅពីនេះ តែងលាន់ឮពាក្យសរសើរថា ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ជាពុទ្ធសាសនាដ៏បរិសុទ្ធ ដែលប្រជាពលរដ្ឋតែងសិក្សា

រៀនសូត្រប្រតិបត្តិដោយម៉ត់ចត់ប្រកាសខ្លួនថាជាពុទ្ធសាសនិកគ្រប់ ៗ គ្នា តាំងការគ្រប់គ្រងគណៈសង្ឃនៃកម្ពុជរដ្ឋ ក៏កាន់តែមានរបៀបរៀបរយ មានល្បឿនឈានទៅរកវឌ្ឍនភាពរៀងរាល់ឆ្នាំ ក្រោមការដឹកនាំនៃសម្ដេច-សង្ឃនាយកតាំងពីគណៈ ព្រមទាំងមន្ត្រីសង្ឃគ្រប់ស្រុក គ្រប់ខេត្ត ៗ

ព្រះពុទ្ធសាសនានៃប្រទេសកម្ពុជាយើង ជាសាសនាឋិតនៅក្នុងការឧបត្ថម្ភនៃព្រះរាជរដ្ឋាភិបាល ។ រដ្ឋធម្មនុញ្ញក៏មានចែងថា "ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ" ។ ពាក្យថាសាសនារបស់រដ្ឋនេះ គឺសាសនារបស់ប្រទេសខ្មែរទាំងមូល ៗ គោលបំណងរបស់មន្ត្រីសង្ឃ ដែលមានសម្ដេចព្រះសង្ឃនាយកតាំងពីព្រះអង្គជាប្រធាន ដើម្បីឲ្យព្រះពុទ្ធសាសនារីកផ្សាយឈានទៅរកសេចក្ដីចំរើនរុងរឿង ៗ គោលបំណងនោះក៏ចេះតែមានល្បឿនចំរើនឡើងម្ដងបន្តិចៗ ដោយកម្លាំងនៃសេចក្ដីប្រឹងប្រែងរបស់គណៈសង្ឃ ដែលប្រាស្រ័យទាក់ទងរួមកម្លាំងគ្នា ជាមួយនឹងព្រះរាជរដ្ឋាភិបាលមានក្រសួងធម្មការជាដើម ៗ គោលបំណងក្នុងការពង្រីកព្រះពុទ្ធសាសនានៃគណៈសង្ឃនោះ ទោះបីពុំទាន់សម្រេចដោយបរិបូណ៌ ក៏ឈ្មោះថា មានសេចក្ដីចំរើនឈានទៅមុខ ជាលំដាប់រៀងរាល់ឆ្នាំដែរ ៗ

ការផ្ដើមធ្វើអនុសិរប្បរៈមហាសន្និបាតមន្ត្រីសង្ឃតាមថ្វការ ដោយមានព្រះករុណាជាអម្ចាស់ជីវិត និងសម្ដេចជាព្រះមគ្គុទ្ទេសក៍នេះ ជាការប្រសើរខ្ពង់ខ្ពស់ក្រៃលែង ដើម្បីពិនិត្យស្ទាបស្ទង់ការរីកសេចក្ដីចំរើនល្អគលាស់នៃ

ជាតិ សាសនា ព្រះមហាក្សត្រ ។ ការប្រជុំមន្ត្រីបរិស័ទនេះ ចាត់ជា ករណីយកិច្ចមួយរបស់ព្រះរាជរដ្ឋាភិបាល ដែលត្រូវមានការប្រុងប្រយ័ត្នទាក់ ទងគ្នារវាងរាជរដ្ឋាភិបាលនិងគណៈសង្ឃ ដែលជាចំណុចមួយយ៉ាងធំ ដើម្បីមិត្តភាពនៃពុទ្ធសាសនិកជនដូចគ្នា ។ ព្រះបរមពុទ្ធោវាទក្នុងអបរិហា- និយធម្មសូត្រថា "ការប្រជុំគ្នារឿយ ៗ ដើម្បីពិគ្រោះពិភាក្សាគ្នានេះ ទុកថាជាវឌ្ឍនភាពមួយ អាចនាំមកនូវសេចក្ដីសុខចំរើនដោយពិត ព្រោះជាហេតុនាំឲ្យបាននូវផលសំរេចរបស់ការប្រជុំទាំងអស់គ្នា ចម្រើនការងារនោះ អំពីទីប្រជុំជាមួយគ្នា អាចនឹងបាននូវយោបល់គ្នាទៅវិញទៅមក ទទួលស្គាល់ ទទួលគោរពនូវផលសំរេចរបស់ទីប្រជុំជាមួយគ្នា ។

ពិធីអង្គប្រជុំមហាសន្និបាត ក្រោមព្រះរាជាធិបតីភាពនេះ ជាអង្គការមួយដ៏ប្រសើរ ទុកជាចំណុចនៃសាមគ្គីភាពរវាងពុទ្ធិកនិងពុទ្ធិក រវាងពុទ្ធចក្រនិងអាណាចក្រ ដើម្បីទុកជាទិដ្ឋានុគតិនៃប្រជាពលរដ្ឋពុទ្ធបរិស័ទជាស្ពានតរៀងទៅ ។ គ្រាន់ការនៃគណសង្ឃគង់ផ្ទៃពុទ្ធិកសក្យក្ដី ក្នុងការគ្រប់គ្រងសង្ឃមណ្ឌលក្ដី បើនៅមានបញ្ហាសំញ៉ាំខ្លះ ពុំទាន់បានដោះស្រាយនៅឡើយ គឺនឹកឃើញថា អំណឹះតទៅនឹងចេះតែរកមធ្យោ-បាយរៀបចំដោះស្រាយបញ្ហា ដែលនៅសេសសល់ឲ្យរួចជ្រះស្រឡះពុំខាន ដោយរួមជាមួយនឹងព្រះរាជរដ្ឋាភិបាល ។

ច្បាប់របស់ព្រះរាជាណាចក្រ ឬច្បាប់ព្រះពុទ្ធសាសនាដែលកើតមាន

ទៀត ពុំអាចនឹងអនុវត្តន៍ឲ្យគ្រប់គ្រាន់បានភ្លាម ៗ ទេ នេះជាទំនៀម របស់ច្បាប់ក្នុងសាកលលោក ។

ដើម្បីពវកេវៃកញ្ញការរកសេចក្តីពិត រកសេចក្តីសុខសេចក្តីចំរើន ដល់ជាតិ សាសនា មហាក្សត្រនេះ ត្រូវអាស្រ័យការប្រជុំរឿយ ៗ ដែល ទុកជាជាគោលការមួយដ៏ប្រសើរ ក្នុងបណ្តាគោលការឯទៀត ៗ ។

ព្រះពុទ្ធសាសនាមានទ្រឹស្តី មានអត្ថបទល្អច្រើនណាស់ ដែលអាច នាំអ្នកប្រតិបត្តិឲ្យបានទទួលសេចក្តីសុខស្ងប់ តាំងអំពីជាតិនេះ រហូត ដល់មគ្គផលនិព្វាន ។

ព្រះពុទ្ធសាសនាប្រៀបដូចជានាវាមួយរបស់រដ្ឋ ដែលមានសម្តេច ព្រះសង្ឃនាយក មន្ត្រីសង្ឃ នឹងព្រះថេរានុត្ថេរៈ ជាអ្នកកាន់ចង្កូត ។ ពុទ្ធបរិស័ទខាងគ្រហស្ថគ្រប់ជាន់ថ្នាក់ ជាអ្នកអុំជាអ្នកចែវ ទើបពុទ្ធនាវាអាច លឿនទៅកាន់កោះត្រើយ គឺសេចក្តីចំរើនបាន ។ ព្រះពុទ្ធសាសនា ប្រាប់ប្រយោជន៍បច្ចុប្បន្នទាំងបរលោក ស្រោចស្រង់សត្វលោកឲ្យរួចចាក ទុក្ខភ័យ រួចចាកពាលភាព ទលិទ្ទភាព គឺភាពទ័លក្រ ឲ្យឈមទៅ រកបណ្ឌិតភាព មហទ្ធភាព គឺភាពជាអ្នកប្រាជ្ញ នឹងភាពមានបានទ្រព្យ សម្បត្តិគ្រប់យ៉ាង ។

នៅអវសាននេះ អាត្មាភាព ក្នុងនាមព្រះសង្ឃទាំងមូល សូម ថ្វាយព្រះពរបវរសួស្តី ជោគជ័យមហាមង្គលវិបុលសុខគ្រប់ប្រការ ចំពោះ

ព្រះករុណាជាម្ចាស់ជីវិតតាំងពីព្រះអង្គ ចំពោះសម្តេចព្រះវរបយុវរាជ ជាអគ្គមគ្គុទ្ទេសក៍ខ្ពស់បំផុតរបស់ប្រទេសកម្ពុជា ។ សូមព្រះមហាក្សត្រ តាំងពីព្រះអង្គប្រកបដោយព្រះជន្មវស្សាយឺនយូរ ទីឃាយុកាល មានព្រះសុខភាពបរិបូណ៌ឈ្នះមារសត្រូវគ្រប់ទិសទី កុំបីឃ្លៀងឃ្លាតឡើយ ។

បន្ទាប់មក លោករដ្ឋលេខាធិការក្រសួងធម្មការ ក៏បានលើកយកសៀវភៅពុទ្ធិកសិក្សា លេខពិសេសថ្វាយព្រះនរបតីតាំងពីព្រះអង្គ រួចហើយព្រះនរបតីតាំងពីព្រះអង្គ មានព្រះរាជតម្រាស់ប្រាស្រ័យជាមួយព្រះសង្ឃដែលនិមន្តមកកាន់មហាសន្និបាត ប្រកបដោយសេចក្តីរីករាយជាទីបំផុត ។

នៅវេលាម៉ោង ៩, ៣០នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនឹងសម្តេចព្រះមហាក្សត្រិយានី ស្តេចយាងត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ដោយមានឥស្សរជនជាភជបរិពារដែលហែហមព្រះអង្គ នឹងមានធ្វើការកិច្ចថ្វាយ ជាព្រះរាជកិត្តិយសដូចកាលស្តេចយាងមក ។

នៅវេលាម៉ោង១០,៤០នាទីព្រឹកនោះ មន្ត្រីអគ្គរាជការនៅក្រសួងធម្មការបានតាក់តែងប្រគេនភត្តាហារចំពោះព្រះសង្ឃ ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រតាំងពីព្រះអង្គ នៅទីចំពោះមុខលោករដ្ឋលេខាធិការក្រសួងធម្មការ ក្នុងគ្រឹះស្ថានព្រះសីហនុ ជាការបញ្ចប់ពិធីនៅពេលព្រឹក

នោះ ។

លុះដល់ពេលរសៀលថ្ងៃដដែល សម្តេចព្រះបិតាឯករាជ្យជាតិ ព្រះអង្គទ្រង់ឆ្លៀតយកឱកាសដ៏ប្រសើរយាងមកធ្វើកិច្ចប្រាស្រ័យ ជាមួយនឹងព្រះសង្ឃទាំងឡាយ ដែលគង់នៅក្នុងរាជធានីនិងនិមន្តមកពីខេត្តក្រៅ ដើម្បីមកប្រជុំក្នុងពិធីអនុស្សាវរីយ៍មហាសន្និបាតមន្ត្រីសង្ឃទី១៦ ដែលធ្វើឡើងនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។

នៅមុនពេលដែលសម្តេចទ្រង់យាងមកដល់ យើងបានសង្កេតឃើញព្រះសង្ឃ ដែលមានសមណស័ក្តិទិពជាគណៈ ឋានានុក្រម និងលោកគ្រូចៅអធិការ ព្រមទាំងព្រះសង្ឃទាំងពីរគណៈដែលគង់នៅរាជធានីនិងនិមន្តមកពីខេត្តក្រៅជាច្រើនរយអង្គ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន និងពុទ្ធបរិស័ទជាច្រើនរយនាក់ បាននិមន្តបានអញ្ជើញមកដល់កន្លែងប្រារព្ធពិធី ។

ឥស្សរជនជាន់ខ្ពស់ទាំងឡាយដែលយើងបានសង្កេតឃើញជាអាទិ៍គឺ លោកជួប-ហែល, លោកឯក-យីអ៊ុន ជាប្រធាននៃសភាទាំងពីរ ព្រមទាំងសមាជិកខ្លះ, លោកសឺន-សាន ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេស លោកញ៉ុក-ជូឡុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងនៃការអប់រំជាតិ, ព្រមទាំងសមាជិករាជរដ្ឋាភិបាលខ្លះ និងអ្នករាជការក្រសួងធម្មការជាច្រើនទៀត អញ្ជើញមកកាន់ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

ដើម្បីរង់ចាំទទួល និងក្រាបថ្វាយបង្គំគោរពសម្តេចព្រះបិតាឯករាជ្យជាតិ ។

នៅម៉ោង៤,៥នាទីរសៀល សម្តេចប្រមុខរាជរដ្ឋាភិបាល ដោយមានសម្តេច ប៉ែន-នុត ព្រឹទ្ធសមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជា, ឯកឧត្តម ផូ-ព្រឿង, ទេព-ផន, ព្រឿង-កាង ជាសមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជា, លោក អ៊ឹង-ហ៊ុងសាង អគ្គលេខាធិការរងទី១ នៃឧត្តមក្រុមប្រឹក្សាព្រះរាជា, លោក ម៉ៅ-ចយ ទីប្រឹក្សាបច្ចេកទេស ការិយាល័យការងារប្រជារាស្ត្រ, លោកវរសេនីយទោ មាស-ហ៊ុល រាជង្គរក្ស ហែហមព្រះអង្គផង ទ្រង់ស្តេចយាងមកដល់ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ដែលជាកន្លែងប្រារព្ធពិធី ។

ក្រោយដែលព្រះអង្គទ្រង់បានទទួលបដិសណ្ឋារកិច្ចអំពីលោក ស្វូ-ណែម រដ្ឋលេខាធិការក្រសួងធម្មការសាសនសិក្សាធិការ ព្រមទាំងអំពីឥស្សរជនជាន់ខ្ពស់ទាំងឡាយរួចហើយ សម្តេចសហជីវិន ទ្រង់ស្តេចយាងចូលទៅក្នុងយ៉ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ថ្វាយបង្គំព្រះសង្ឃដែលមានសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយនិងសម្តេចព្រះសុគន្ធាធិបតីសង្ឃនាយកគណៈធម្មយុត្តិកនិកាយជាប្រធាន ។ បន្ទាប់មកទៀត សម្តេចសហជីវិននាយករដ្ឋមន្ត្រីព្រះអគ្គមគ្គុទ្ទេសក៍ ទ្រង់សព្វព្រះរាជហឫទ័យថ្វេនព្រះសង្ឃជាមួយ ដោយបញ្ជាក់អំពីបញ្ហាជាច្រើនដែលមានជាអាទិ៍ បញ្ហាការទាក់ទងនឹងប្រទេសជាមិត្តទាំងឡាយ បញ្ហា

សិក្សាធិការជាតិ បញ្ហាសេដ្ឋកិច្ចជាតិ បញ្ហាធ្វើការហត្ថកម្ម មានធ្វើផ្ទះជូនរាស្ត្រក្រីក្រ លើកទំនប់សន្សំទឹកទុកឲ្យប្រជារាស្ត្រជាដើម ។

ជាពិសេស ព្រះអង្គទ្រង់ផ្ចាញ់ផ្ចាក់អំពីជនក្បត់ជាតិ ដែលជ្រកនៅក្នុងប្រទេសជិតខាង ចេះតែពោលមួលបង្កាច់ឥតសមហេតុផល ប្រឆាំងចំពោះប្រទេសជាតិជាដើម ។ល។

លុះចប់ព្រះសង្កថានេះហើយ ព្រះសង្ឃទាំងឡាយដែលមានសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន បានសូធ្យាយន៍ធម៌ជយន្តោថ្វាយពរសព្វសាធុការ ជោគជ័យចំពោះសម្ដេចសហជីវិន សូមព្រះអង្គទ្រង់គង់នៅ ប្រកបដោយព្រះបរមសុខក្នុងព្រះដំណែងដឹកនាំព្រះពុទ្ធសាសនានិងប្រជាជាតិខ្មែរ ឆ្ពោះទៅកាន់អភិវឌ្ឍនភាពអស់កាលជាអង្វែង ។

បន្ទាប់មកទៀត សម្ដេចសហជីវិន ទ្រង់សព្វព្រះរាជហឫទ័យចាត់ឲ្យឯកឧត្ដម ទៀវ-កាង ចាងហ្វាងនៃការផ្សាយសារព័ត៌មាន អ្នកជាតិនិយម ប្រគេនកាសែតអ្នកជាតិនិយមចំពោះព្រះសង្ឃទាំងឡាយ តាមនាមគណៈកម្មាធិការកណ្ដាលប្រតិបត្តិការនៃសង្គមរាស្ត្រនិយម ។

នៅវេលាម៉ោង ៩,៣៥ នាទី សម្ដេចសហជីវិន ដោយមានព្រះរាជបរិវារដែលហែហមព្រះអង្គផង បានស្ដេចយាងត្រឡប់ទៅកាន់ព្រះរាជដំណាក់វិញ ។

សូមបញ្ជាក់ថា អនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទី ១៦ នេះ មាន៥ថ្ងៃគត់ គឺផ្ដើមពីពេលសៀលថ្ងៃពុធ ៧កើត ដល់ថ្ងៃចន្ទ ១២កើត ខែបុស្ស ឆ្នាំកុរឯកស័ក ព.ស. ២៥០២ (២០-២៤ មករា ១៩៦០)។

មហាសន្និបាតក្នុងឆ្នាំនេះ បានជាច្រើនថ្ងៃជាងឆ្នាំមុន ១ ព្រោះសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ ព្រមទាំងក្រសួងធម្មការ ប្រាថ្នាដាស់តឿនក្រើនរំលឹកមន្ត្រីសង្ឃក្នុងក្រុងនិងខែត្រក្រៅ ដោយរបៀបការៈ និងសេចក្ដីរំលឹកផ្សេង ១ ឲ្យខំយកព្រះទ័យទុកដាក់ណែនាំលោកគ្រូចៅអធិការ និងភិក្ខុ-សាមណេរ ដែលនៅក្នុងឱវាទរបស់ខ្លួន ឲ្យខំសិក្សារៀនសូត្រ និងប្រតិបត្តិតាមធម៌វិន័យ ឲ្យរឹងរឹតតែចំរើនឡើង ព្រមទាំងឲ្យមានសេចក្ដីសាមគ្គីព្រមព្រៀងគ្នាជាតិយោភាព ដើម្បីរុងរឿងចំរើនដល់ជាតិ សាសនា និងព្រះមហាក្សត្រតទៅ ។

## វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

### ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

អតិក្ឫច្ឆ្រ គុ. ដែលលំបាកក្រៃលែង ។ ប៉ុ. ឈ្មោះឋាននរក ។ អតិក្ឫច្ឆ្រម៑ ក្រិ. វិ ដោយលំបាកក្រៃលែង ។

អតិក្ឫត គុ. ដែលធ្វើដោយក្រៃលែង ។

អតិក្ឫតាបិ គុ. ដែលមានប្រយោជន៍ធ្វើហើយដោយក្រៃលែង, ដែលស្ទាត់ជំនាញណាស់ ។

អតិក្ឫតិ ស្ត្រី. កិរិយាធ្វើដោយក្រៃលែង ។

អតិក្ឫឝ គុ. ស្គមក្រៃពេក ។

អតិក្ឫឞ្ណ គុ. ខ្មៅក្រៃលែង, ខ្មៅព្រិក ។

អតិកោប ប៉ុ. សេចក្តីក្រោធក្រៃលែង ។ គុ ដែលមានក្រោធក្រៃពេក ។

អតិក្រម៑ ធាតុ. កន្លងទៅ, ប្រព្រឹត្តកន្លង, កន្លង (ទោស, វេលា) អតិក្រាន្ត គុ ដែលប្រព្រឹត្តកន្លង ។ នបុំ. អតីតកាល ។

(នៅមានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣២ លេខ ២ ខែកុម្ភៈ

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

| *ផ្នែកសាសនា* បញ្ជីរឿង | ទំព័រ |
| --- | --- |
| - វិបារណកថា លោក ស៊ុន-ហ៊ាន រៀបរៀង | ១២១ |
| - ចក្កធម្មកថា របស់ព្រះមហា ទូច-សាន | ១២៩ |
| - មធុរសាភិណី (តមក) សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ ឈឹន ពិនិត្យ | ១៤១ |
| - មហោសថជាតក (តមក) លោក អ៊ឹម-ភាន បម្រួលពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ | ១៤៥ |
| *ផ្នែកអក្សរសាស្ត្រ* | |
| - រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ បម្រួងពីសាស្ត្រាស្លឹករឹត | ១៦៣ |
| - រឿងព្រេងរុស្ស៊ី ចែងអំពីវិទ្យាសាស្ត្រដ៏ប៉ុនប្រសប់ ស-សកាភ ប្រែពីភាសាបារាំង | ១៧១ |
| - សត្រូវរបស់ខ្ញុំ លោក ក្លី-ប៊ួ រៀបរៀង | ១៨២ |
| - រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ | ១៨៨ |
| - ពាក្យវប្បធម៌ (តមក) លោក សម-ថាំង សមាជិកគណៈកម្មការវប្បធម៌ រៀបរៀង | ២២១ |
| *ផ្នែកកំណត់ទីនីប្រវត្តិការណ៍* | |
| - ពិធីហែសព ឧកញ៉ាសោភណមន្ត្រី ដួន-ខុត លោក ជាប-ពិន រៀបរៀង | ២២៧ |
| - វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ជាំង-ខាត់ រៀបរៀង | ២៣៨ |

ថ្លៃឆ្នាំ មាន ១២ សៀវភៅ ដំឡៃជារៀល ២៣០.០០

# KAMBUJASURIYA

Revue mensuelle de culture religieuse et litteraire
Publiée par l'Institut Bouddhique de Phnom Penh

## sommaire

### Partie religieuse :

— Editorial par M. SIN-HEAN. . . . . . . . . . 121
— Cakkadhammakatha par PRAH MAHA TOUCH-SANI . 129
— Madhurasavahini (suite) traduit par Samdec Prah Dhammalikhita Louis-Em revu et corrigé par Vén-NHEAN-CHHOEUN . . . . . . . . . . . . . . 141
— Prah Mahcsothajataka (suite) relevé du manuscrit sur feuilles de la tanier par M. IM-PHON et revu par Vén-KEM-TO 155

### Partie littéraire :

—Légende de Marana Mâtâ(suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . . 163
— Contes et légendes russes «La Science ingénieuse» traduit du français par S SARHA . . . . . . . . 171
— Mon Ennemi par M BOU-PO . . . . . . 182
— Histoire de Sam-Kok(suite)traduite par l'Oknha NOU-KAN. 188
— Activités de la Commission culturelle (suite) par M. SAM-THANG. . . . . . . . . . . . . . 221

### Notes et Chroniques :

— Funérailles de l'Oknha Sobhana Montrei Choun Nouth par M. CHAP PIN. . . . . . . . . . . 227
— Dictionnaire Sanscrit-khmer (suite) par Vén PANG-KHAT 238

Prix d'abonnement annuel (comprenant 12 numéros : 230$00 .

## ផ្នែកសាសនា

# វិចារណកថា

## អំពីសេចក្ដីចំរើនតាមរបៀបពុទ្ធសាសនា

លោក ស៊ុន · ហាន រៀបរៀង

---

យើងបានសម្លឹងមើលទៅឈើមួយដើម ដែលសម្បូណ៌ទៅដោយដើមដងត្រសុំសាខា គឺដើមស្លឹកផ្កា និងផ្លែសព្វគ្រប់ហើយ ក្នុងក៏ធ្វើឲ្យសេចក្ដីព្យាករណ៍ទៅឲ្យចិត្តថា ដើមឈើមួយដើមនេះ មានសេចក្ដីចំរើនល្អណាស់ ៗ យើងពិចារណាតទៅទៀតថា ដើមឈើមួយដើមនេះ ដែលមានសេចក្ដីចំរើនដូច្នោះ ក៏ព្រោះបានទទួលដីជាតិល្អ និងអាកាសល្អដោយសព្វគ្រប់ ហើយឫសក៏ចាក់ចុះទៅក្នុងដីយ៉ាងមាំមួនផង ៗ

ដើមឈើដែលចំរើនល្អនោះ យើងគ្រាន់តែសម្លឹងមើលទៅឃើញក្លាម ក៏ជាទីសប្បាយក្នុងពន់ពេក ព្រមទាំងអាចបាននាំយកទៅប្រកបឲ្យកើតប្រយោជន៍ដល់ខ្លួនជាច្រើន ដូចនាំយកផ្លែទៅបរិភោគ នាំយកមែកទៅធ្វើអុស ឬធ្វើជាម្ជប់សម្រាប់ជ្រកស្នាក់ក្នុងវេលាដើរផ្លូវជាដើម ៗ គ្រាប់ផ្លែនៃឈើទាំងអស់នេះ តែងឲ្យសម្រេចប្រយោជន៍ដល់ជនអ្នកត្រូវ

ការដោយប្រពៃ ។ កាលបើបែរមកពិនិត្យមើលចំពោះធម្មជាតិរបស់ដើមឈើដែលដុះជិតគ្នា ឬដុះតំណាលគ្នាវិញហើយ តែងឃើញនូវសេចក្តីចំរើនលូតលាស់ប្រណាំងប្រជែងគ្នាជាពុំខាន ។

ក្នុងកាលពីព្រេងនាយ វិវឌ្ឍនាការរបស់សត្វលោក ព្រមទាំងមនុស្សយើងនេះបានចំរើនរុងរឿង ផ្លាស់ប្តូរពីសម័យព្រេងនាយ មកដល់សម័យកណ្តាល ដរាបដល់សម័យបច្ចុប្បន្ននេះ ។ សភាពការណ៍របស់សង្គមមនុស្ស មិនមែនត្រូវការតែសេចក្តីជំពាក់នៃកាយ ដើម្បីស្វះស្វែងរកអាហារដែលជាការចាំបាច់ ឬត្រូវការតែកម្លាំងកំហែងរឹងប៉ឹងប៉ុណ្ណោះទេ ។ សង្គមមនុស្សត្រូវការបុគ្គលដែលមានសមត្ថភាព សេចក្តីចេះដឹងប្រព្រឹត្តល្អស្គាល់ការខុសត្រូវ និងស្គាល់ការចាំបាច់ដទៃ ៗ ទៀត ដែលត្រូវមានសេចក្តីចំរើនតាមទីវសភាពការណ៍របស់សង្គមមនុស្ស ក្នុងបច្ចុប្បន្នផង ។ សភាពរបស់មនុស្សកើតមក ព្រោះអាស្រ័យធម្មជាតិ ឋិតនៅក្នុងធម្មជាតិ ត្រូវតែចេះធ្វើខ្លួនឲ្យរស់នៅលើធម្មជាតិ ដូចចេះនាំយករបស់ក្តៅមកបង្កឲ្យឆេះឡើង ចេះនាំយករបស់ត្រជាក់មកលត់ការពារក្សាវិញជាដើម ។

ព្រះពុទ្ធសាសនារបស់យើងបានកើតឡើងមកក្នុងកណ្តាលចំណោមនៃមេលទ្ធិផ្សេង ៗ ដែលប្រៀនប្រដៅសង្គមមនុស្សក្នុងសម័យនោះដែរ ។ កាលបើពោលដោយគោលការណ៍ធំ ៗ នៃលទ្ធិទាំងនោះ គឺប្រៀនប្រដៅ

ឲ្យអង្វរករព្រះជាម្ចាស់សួគ៌ដូចការបែរបន់,បួងសួង,បូជាយញ្ញព្រះអាទិត្យ ព្រះចន្ទជាដើម ។ លទ្ធិខ្លះ ប្រៀនប្រដៅឲ្យបំពេញតបៈខាងក្រៅដូចប្រដៅឲ្យទុក្ខទោសកាយ ឲ្យអត់អាហារ ឲ្យស្លៀកដណ្ដប់នូវស្បែកខ្លាជាដើម ។ ការប្រៀនប្រដៅឲ្យបំពេញវត្ត ជាតបៈដ៏ខ្ពង់ខ្ពស់យ៉ាងនេះ ដើម្បីបង្ហាញឲ្យឃើញថាជាអ្នកល្អ ជាអ្នកបន្ទយ ជាអ្នកសន្តោស ។ លទ្ធិខ្លះ ប្រៀនប្រដៅឲ្យចុះត្រាំទឹកក្នុងទន្លេគង្គា ដើម្បីឲ្យបាននូវសេចក្ដីបរិសុទ្ធ ។ បើប្រសិនជាធ្វើដូច្នោះហើយបាននូវសេចក្ដីបរិសុទ្ធពិតមែន, បណ្ដាទ័យជាតិ ទាំងមច្ឆាជាតិ គង់ទាំងមានសេចក្ដីបរិសុទ្ធស្អាតជាងមនុស្សឃើញដោយពិតប្រាកដពុំខាន ។

ព្រះពុទ្ធសាសនាមិនបានប្រៀនប្រដៅបន្ថែមមនុស្សដូច្នោះទេ តែងប្រៀនប្រដៅមនុស្សឲ្យព្រមទទួលស្គាល់នូវភាពមនុស្សជាមុន គឺឲ្យព្រមទទួលស្គាល់នូវវិវឌ្ឍនាការរបស់មនុស្សដែលចំរើនមកដោយលំដាប់ ត្រូវតាមគោលនៃវិទ្យាសាស្ត្រ។ ទ្រង់បញ្ញត្តសីល៥ដែលជាគោលធ្វើមនុស្សឲ្យជាមនុស្សសម្បូណ៌គឺសំដែងថា ព្រះពុទ្ធសាសនានេះសាងសេចក្ដីចំរើនខាងនាមធម៌ឲ្យដល់មនុស្សដែលកំពុងចំរើនមក ដោយរូបធម៌ ។ ព្រះពុទ្ធ-សាសនាបានយកវត្ថុនៃធម៌ដែលសំដែងពីសេចក្ដីចំរើន ខាងនាមធម៌មកគ្រោបព័ទ្ធជុំវិញរូបធម៌ដូច្នេះ ដើម្បីកុំឲ្យមនុស្សយើងធ្វើនូវការរំលោភដល់គ្នានឹងគ្នាតាមអំពើចិត្ត គឺព្រះពុទ្ធជាបរមគ្រូទ្រង់ប្រៀនប្រដៅមិនឲ្យ

សម្លាប់គ្នា មិនឲ្យបៀតបៀនគ្នា ក្រៅពីនេះទ្រង់ប្រៀនប្រដៅឲ្យតាំងនៅក្នុងសេចក្ដីប្រាថ្នាល្អ និងបំណងល្អដល់គ្នានិងគ្នាទៀត ព្រមទាំងទ្រង់ប្រៀនប្រដៅ ឲ្យទាត់សាងនូវរបបនៃសង្គមមនុស្សឲ្យបានឋិតថេរ ជាសង្គមដែលមានរបៀបរៀបរយ មិនឲ្យត្រូវនឹងសុភាសិតថា «ចំពោះមុខផ្អែមខ្នងល្វីង» តែបានមុខផ្អែមខ្នងផ្អែមទៀតផង ។ កាលបើដូច្នេះ សង្គមមនុស្សយើងអាចនឹងរស់នៅជាមួយគ្នាបានសុខសប្បាយ ។

មែនពិតព្រះពុទ្ធសាសនារបស់យើង ប្រដៅមនុស្សឲ្យទៅជាមនុស្សមានចិត្តទូលាយឲ្យចេះអភ័យគ្នា មិនមែនប្រដៅមនុស្សឲ្យជាមនុស្សយើញតែប្រយោជន៍ផ្ទាល់ខ្លួនទេ ។ មិនតែប៉ុណ្ណោះ ព្រះពុទ្ធសាសនាបានប្រៀនប្រដៅឲ្យចេះគោរពសិទ្ធិមនុស្សជនបទិទ្ធិក្នុងទ្រព្យសម្បត្តិ សិទ្ធិក្នុងការប្រើប្រាស់ចាយវាយកោកទ្រព្យរបស់ខ្លួនតាមការ ដែលគេបានមក កាលបើព្រះពុទ្ធសាសនា ព្រមទទួលស្គាល់នូវវិជ្ជានាការរបស់មនុស្សដូច្នេះហើយ គឺឈ្មោះថា ព្រមទទួលស្គាល់នូវសិទ្ធិដែលកើតឡើងដល់មនុស្សក្នុងឋានៈជាបច្ចេកជននិងមហាជន ។ ពិសេស គឺព្រះពុទ្ធសាសនាប្រដៅមនុស្ស ឲ្យផុតចាកទាសភាពទាំងខាងក្នុងនិងខាងក្រៅ ។ ទាសភាពខាងក្នុងបានដល់ទាសភាពរបស់កិលេស ទាសភាពខាងក្រៅបានដល់ទាសភាពរបស់បុគ្គលដទៃ ។ កាលបើមនុស្សមានការងាររស់ខ្លួនឯង តែងមានសិទ្ធិគ្រប់គ្រងនូវការងារនោះ ។ កាលបើមានចិត្ត

ជារបស់ខ្លួន ក៏រមែងធ្វើចិត្តឲ្យមានឥស្សរភាពបានតាមហេតុផល តែកាលបើចិត្តត្រូវរុំព័ទ្ធដោយទុក្ខកិលេស ឬមានតណ្ហាហើយ ក៏មិនអាចឈានឡើងទៅកាន់ឥស្សរភាពបានទេ តែងតែធ្លាក់ចុះទៅកាន់ទាសភាពវិញជាប្រាកដ ព្រមទាំងវិលត្រឡប់ខ្លួនទៅរកសេចក្តីសាបសូន្យពុំខាន ។ កាលបើបុគ្គលមានសតិសម្បជញ្ញៈដឹងទាន់ ហើយចេះទប់គំនិតចិត្តមិនលង់លុះដោយអំណាចនៃសេចក្តីលោភ និងសេចក្តីវង្វេងដែលជាការនាំឲ្យវិនាស ឈ្មោះថា បានធ្វើនូវសេចក្តីចំរើនឲ្យដល់ខ្លួនឯងដោយពិតប្រាកដ ។

កាលបើមនុស្សយើងមានការរស់នៅចំរើនឡើង មានចំនួនកាន់តែក្រាស់ក្រែបឡើង ដំណើរការណ៍ដែលត្រូវទាក់ទងគ្នា តែងតែមានច្រើនឡើងជាធម្មតាដែរ ។ ការនិយាយដោយស្មោះត្រង់នឹងគ្នា នាំឲ្យកើតមេត្រីនឹងគ្នា ព្រោះថាការនិយាយ ដើម្បីឲ្យកើតប្រយោជន៍, តែការនិយាយនេះទៀត ជាគ្រឿងសំដែងចេញរបស់ចិត្តដែលនាំឲ្យដឹងដល់សេចក្តីចំណង់ផ្សេង ៗ សមដូចសុភាសិតលោកពោលថា "សំដីជាឯក លេខជាទោ វិជ្ជាជាត្រី សេចក្តីល្អអាក្រក់ជាត្រា" ខាងព្រះពុទ្ធសាសនាបានប្រៀនប្រដៅមនុស្សឲ្យនិយាយតែការពិត និយាយចំពោះរឿងដែលជាប្រយោជន៍ និយាយពាក្យពីរោះ វៀរចាកការនិយាយញុះញង់ចាក់ដោតនិងពាក្យឥតផលប្រយោជន៍ ។ គោលសំខាន់បំផុត គឺការនិយាយសមគួរដល់កាលៈទេសៈ រឿងអ្វីដែលនិយាយទៅហើយ

មានសេចក្ដីមិនពិតច្រើនជាងពិតឬនាំឲ្យមានទៅសេចក្ដីវិនាស មិនគួរនិយាយឲ្យសោះតែម្ដង ។ ការចាំបាច់របស់សង្គមមនុស្ស មិនព្រមបណ្ដោយឲ្យយើងចេះតែនិយាយអ្វីបានទាំងអស់ ។ ព្រះសម្ពុទ្ធជាបរមគ្រូនៃយើងទ្រង់ប្រៀនប្រដៅនូវគោលនៃបរិសញ្ញតា គាត់ជាអ្នកស្គាល់បរិស័ទនឹងប្រជុំជន ក៏ដើម្បីឲ្យមនុស្សស្គាល់ថា ប្រជុំជនឬសមាគមនេះ កាលបើទៅរកត្រូវធ្វើកិរិយាយ៉ាងនេះ ។ មិនឲ្យទទឹងទាស់ចំពោះសេចក្ដីនិយមនឹងច្បាប់ទំលាប់របស់គេ មិនឲ្យអ្វីស្រេចតែនឹងចិត្តរបស់ខ្លួនឯង តែទោះយ៉ាងណាក៏ដោយ យើងត្រូវប្រកាន់គោលថានិយាយតែការពិតនិយាយតែការល្អនិយាយហើយមិនឲ្យគេតិះទោសទៀត នេះឯងជាគោលនៃសេចក្ដីចំរើនខាងការនិយាយ ។ ក្នុងប្រជុំជនដែលមានសេចក្ដីចំរើនហើយនោះ គេមិននិយាយនូវពាក្យឥតផលប្រយោជន៍ និងពាក្យកុហកភូតភរឡើយ ។

កាលៈលោកចំរើនឡើង ការចូលចិត្តសិក្សាចំពោះនាទីរបស់បុគ្គលម្នាក់ ៗ កាន់តែមានច្រើនឡើងដែរ ការសិក្សានេះឯងជារឿងចំរើនរបស់សង្គមមនុស្ស ព្រោះថាបើអ្នកណាបានសិក្សាមកអស់វេលាជាយូរហើយក៏ឈ្មោះថាបានដំណើរតាមគោលវិវឌ្ឍនាការចំពោះនាទីរបស់ខ្លួន ដោយបរិបូណ៌ ។ មនុស្សយើងកាលបើមានសេចក្ដីចំរើនមកដោយការសិក្សាហើយ ចេះប្រកាន់ចំពោះនាទីរបស់ខ្លួន ដូចនាទីរបស់អ្នកគ្រប់គ្រង គឺមាតាបិតា, នាទីរបស់បុត្រធីតា, នាទីរបស់ស្វាមីភរិយា ដែលត្រូវ

តបស្នងដល់ទីងគ្នា នោះក៏ជារឿងចាំបាច់មួយ គួរតែប្រតិបត្តិចំពោះគ្នាឲ្យល្អបំផុត កុំចូលចិត្តរឿងដទៃក្រៅពីនេះ ថាជារឿងធំ រឿងសំខាន់ទៅវិញ ក្រុបទឹកនាថា នាទីរបស់ខ្លួនយ៉ាងដូចម្ដេចនោះ ៗ កាលបើដូច្នេះ យើងគួរតែនាំគ្នាផ្ដើមសាងឲ្យស្គាល់នាទីរបស់ខ្លួនជាមុន គឺមានសច្ចៈក្នុងនាទីដែលខ្លួនត្រូវមាន មានសុចរិតជាគ្រឿងការពារក្នុងខណៈធ្វើ មានការឆារធ្វើជាប់តគ្នាមិនដាច់ព្រមគ្រៀងគ្នាចំលាយពោលនូវឧបសគ្គណា ដែលប្រុងទីងមកកាត់ផ្ដាច់នូវសេចក្ដីចំរើនមិនឲ្យដំណើរការណ៍ទៅរួចនោះ ៗ ការមានសច្ចៈចំពោះនាទីនេះ រមែងជាគ្រឿងសាងនូវសេចក្ដីចំរើនឲ្យដល់មនុស្សគ្រប់គ្នា ៗ សេចក្ដីចំរើនតាមន័យដែលបានពោលមកនេះ សំគាល់ដល់សេចក្ដីចំរើនដែលជាគោលរបស់ជីវិត ព្រមទាំងដំណើរការណ៍តាមគោលទិដ្ឋធម្មិកត្ថប្រយោជន៍ខាងព្រះពុទ្ធសាសនា ដែលអាចតាំងខ្លួនឲ្យបានចំរើនឡើងវិសេសជាងដើម គឺប្រតិបត្តិខ្លួនទៅតាមគោលនៃសង្គមមនុស្ស ដោយមានមេត្តាករុណាសាងមេត្រីភាពចំពោះគ្នានឹងគ្នា ជួយលើកជំរើងគ្នាតាមគោលរបស់សង្គមមនុស្ស ដែលចំរើនហើយ ៗ តែសេចក្ដីចំរើននេះ ត្រូវអាស្រ័យពេលានៃការអប់រំចិត្តឲ្យបានបវត្រឹមត្រូវមកជាមុនដែរ បើមិនដូច្នោះទេ សញ្ញាតញ្ញាណដើម តែងវិលត្រឡប់ទៅកាន់ការប្រព្រឹត្តតាមទំលាប់វិញពុំខាន ព្រោះហេតុនេះ បុគ្គលគួរតែពិន័យផ្ដន្ទាទោសខ្លួនឯងឲ្យមានសណ្ដាប់ធ្នាប់ល្អឡើង ដោយមាន

ស្មារតីប្រុងប្រយ័ត្នជានិច្ច កុំឲ្យចិត្តធ្លាក់ទៅកាន់ឋានៈទាបថោក ប្រព្រឹត្ត
កាយវាចាឲ្យមានរបៀបរៀបរយចំពោះសង្គមជាតិ មានចិត្តគោរពចំពោះ
សិទ្ធិនិងនាទីរបស់មនុស្សផងគ្នា មិនគួរធ្វើចិត្តឲ្យធ្លាក់ទាសភាព គួរតែធ្វើ
ខ្លួនឲ្យទៅជាបេសកកម្មនៃសង្គមជាតិដោយពិតប្រាកដ ទោះបីមនុស្សនោះ
មិនបានធ្វើខ្លួនឲ្យចំរើនដល់ទីបំផុត ឬត្រឹមបំណាន់នៃសង្គមជាតិក៏ដោយ ក៏
សូមឲ្យជាមនុស្សចំរើនស្មើ ដែលសង្គមជាតិមិនបានរង្កៀស ជាមនុស្សល្អ
ចំរើនតាមគោលនៃព្រះពុទ្ធសាសនា គឺចំរើនទាំងខាងក្នុងនិងខាងក្រៅ
គួរបាត់របបជីវិតការរស់នៅឲ្យមានរបៀប និងទីនៅអាស្រ័យឲ្យស្អាតបាត
សម្លឹងមើលជុំវិញខ្លួនយើង មើលតួយ៉ាងល្អរបស់មិត្តភក្តិក្នុងស្រុកជាមួយ
គ្នា ៗ ការសម្លឹងមើលលោកឲ្យឃើញពិត មើលឲ្យដឹង មើលយ៉ាង
ពិនិត្យពិច័យរកសេចក្តីចំរើន ហើយនាំមកពិន័យក្តីទោសខ្លួនឯងឲ្យបាន
ចំរើនល្អវិសេសឡើង ៗ

នៅអវសាននៃវិចារណកថានេះ នរជនណាដែលមានសេចក្តីចំរើន
ល្អដោយកាយ វាចា ចិត្ត មិននៅក្រោមអំណាចនៃសេចក្តីទាបថោកនិង
ប្រតិបត្តិត្រង់តាមនាទីរបស់ខ្លួនពិតៗ នរជននោះចាត់ថាជាមនុស្សល្អ
មនុស្សចំរើន ដោយមានជីជាតិគឺសីលធម៌ដ៏ឧត្តម សន្មតថា អ្នក
នោះជាបេសកកម្មនៃសង្គមជាតិមែនៗ ព្រះពុទ្ធសាសនាបានប្រៀន
ប្រដៅមនុស្ស ឲ្យចំរើនដោយសេចក្តីល្អយ៉ាងនេះឯង ៗ

# ចក្កធម្មកថា

របស់ព្រះមហា ឌួច - សានី វត្តលង្កា

ឆមោ ៣ ៨៨

សូមនមស្ការ ចំពោះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ អង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដោយសេចក្ដីគោរព)។

សូមពណ៌នាអំពី "ចក្កធម៌" ដែលមានក្នុងគម្ពីរអង្គុត្តរនិកាយ ដូចតទៅនេះ៖

ចក្កធម៌ ប្រែថា ធម៌បីដូចជាកង់រថ នាំទៅកាន់សេចក្ដីចំរើន គ្រប់យ៉ាង ។ ចក្កធម៌ នេះមាន ៤ យ៉ាងគឺ :

១- បដិរូបទេសវាសៈ នៅក្នុងប្រទេសដ៏សមគួរ;

២- សប្បុរិសូបសំសេវៈ សេពគប់នឹងសប្បុរស;

៣- អត្តសម្មាបណិធិ តាំងខ្លួនដោយប្រពៃ;

៤ បុព្វេកតបុញ្ញតា បានធ្វើបុណ្យទុកមកក្នុងកាលមុន ។

ធម៌ទាំង ៤ យ៉ាងនេះ ព្រះសម្ពុទ្ធបរមគ្រូជាម្ចាស់នៃយើង ទ្រង់សំដែងប្រៀបធៀបនឹងកង់រថ, កាលបើបុគ្គលណា មានបំណងបរទៅកាន់ទីណាមួយ ដោយកង់រថ ៗ រមែងនាំទៅកាន់ទីនោះ ៗ បានតាមបំណងប៉ងប្រាថ្នាយ៉ាងណាមិញ, ធម៌ទាំង ៤ នេះ បើបុគ្គលណាមួយ បានប្រព្រឹត្តឲ្យត្រឹមត្រូវ បានធ្វើឲ្យសមហេតុ_ផលហើយ ក៏រមែងធ្វើសេចក្ដីចំរើន ឲ្យកើតមានឡើងតាមលំដាប់ថ្នាក់យ៉ាងនោះដែរ ។

សូមៈលើកយក ចក្កធម៌ ទាំង ៤ មកពង្រីកសេចក្ដី មួយមាតិកា ម្ដងៗ ដូចតទៅនេះ ៖

ទី១- បដិរូបទេសវាសៈ ប្រែថា នៅក្នុងប្រទេសដ៏សមគួរ: ដែលហៅថា ប្រទេសដ៏សមគួរនោះ គឺសំដៅយកប្រទេសណា ដែលសម្បូណ៌ដោយអ្នកប្រាជ្ញ កវី, ពហុបណ្ឌិត ចេះដឹងច្រើន ជាពហុស្សូត ប៉ិនប្រសប់ដោយការរៀនសូត្រ, ចេះរៀបចំប្រជាជាតិ, ពលរដ្ឋ ឲ្យសិក្សា ចំណេះវិជ្ជា និងធម៌ផ្លូវព្រះពុទ្ធសាសនា ជាគ្រឿងប្រដៅចិត្ត ឲ្យមានមេត្តាករុណាធម៌ ចេះសង្គ្រោះគ្នា, ចេះស្រឡាញ់រាប់អានគ្នា, ចែកសេចក្ដីសុខដល់គ្នា, ប្រាប់ប្រយោជន៍ដល់គ្នា ដើម្បីញ៉ាំងជនរួមជាតិជាមួយគ្នា ឲ្យមានសេចក្ដីថ្លៃថ្នូរ អង់អាច ក្នុងការចេះដឹង ។ ប្រទេសយ៉ាងនេះ លោកហៅថា "ប្រទេសដ៏សមគួរ" គឺប្រទេសប្រកបដោយធម៌ ល្មមធ្វើខ្លួនប្រាណជ្រកអាស្រ័យរកប្រយោជន៍បាន ។

មួយទៀត ប្រទេសណាដែលមានព្រះមហាក្សត្រសោយរាជ្យគ្រប់គ្រងផែនដី ប្រកបដោយទសពិធរាជធម៌ ចាត់ចែងអង្គការរដ្ឋតាមប្រពៃណី របស់ព្រះមហាក្សត្រទ្រង់ធម៌, មានសេចក្ដីអាណិតអាសូរអនុគ្រោះ ដល់ប្រជាពលរដ្ឋ រៀបចំប្រជាជាតិ ឲ្យមានការសិក្សាចំណេះវិជ្ជាទាំងផ្លូវលោក ផ្លូវធម៌ឲ្យគ្រប់គ្រាន់ ។

ឯវិជ្ជាខាងផ្លូវលោក មាន ៨ យ៉ាងគឺ:

១- នីតិវិជ្ជា គឺការចេះដឹងច្បាប់សម្រាប់លោក សំរាប់សាសនា ស្គាល់កិច្ចការឈមមុខទៅរកសុខចំរើនគ្រប់យ៉ាង តាំងពីអក្សរសាស្ត្រឡើងទៅ។

២- រដ្ឋវិជ្ជា ការចេះដឹងច្បាប់រដ្ឋបាល សម្រាប់រក្សាប្រទេស ស្គាល់ផ្លូវរដ្ឋប្រសាសនោបាយ ក្នុងប្រទេសរបស់ខ្លួន នឹងប្រទេសដទៃ អាចប្រាស្រ័យចរចាទៅនឹងនានាជាតិដទៃ បានដោយស្រួល ។

៣- វេជ្ជវិជ្ជា ការចេះដឹងក្នុងផ្លូវវេជ្ជសាស្ត្រ ស្គាល់សមុដ្ឋាននៃរោគ ស្គាល់វិធីផ្សំថ្នាំ សម្រាប់រម្ងាប់រោគ ។

៤- យន្តវិជ្ជា ការចេះដឹងក្នុងផ្លូវបច្ចេកទេស ឬការជាងដែលអាចធ្វើចក្រយន្តយាន តាមកាលសម័យនៃលោកនិយមបាន ។

៥- យុទ្ធវិជ្ជា ការចេះដឹងក្នុងយុទ្ធសាស្ត្រ សម្រាប់ការពារប្រទេសជាតិ។

ឯវិជ្ជាខាងផ្លូវធម៌នោះគឺ ការចេះដឹងពុទ្ធវចនៈ ពោលគឺព្រះត្រៃបិដក ចាំស្ទាត់ចូលចិត្តមិនភាន់ច្រឡំ ចេះប្រែសេចក្តីត្រឹមត្រូវតាមរបៀបវេយ្យាករណ៍ជាដើម ហើយនឹងសិល្បកម្មផ្សេងៗសំបូណ៌ដោយស្រែចំការច្បារដំណាំទាំងរបរខាងសេដ្ឋកិច្ច គឺពាណិជ្ជកម្ម, កសិកម្មសំបូណ៌ដោយស្ទឹងបឹងបួ,ព្រែក,ទន្លេ សម្រាប់អ្នកត្រូវការ មានការបង្ហូរទឹកចេញចូលដាក់ស្រែចំការច្បារដំណាំជាដើមព្រមទាំងគ្រឿងប្រើប្រាស់គ្រឿងឧបភោគបរិភោគ គ្រឿងស្លៀកពាក់ នឹងគ្រឿងការពារសត្រូវជាដើម យ៉ាងនេះហៅថាប្រទេសដ៏សមគួរតាមផ្លូវលោក ទាំងប្រជាជាតិដែលមានភ័ព្វសំណាង

វាសនាមកកើតជួបប្រទះនឹងសេចក្ដីសុខចំរើន ក្នុងប្រទេសដែលសំបូណ៌ ដោយចំណេះវិជ្ជា,ភោគសម្បទ ដែលខាងពោលមកខាងលើទៀតសោត ក៏ត្រូវតែកសាងកម្លាំង កាយ វាចា ចិត្ត ឲ្យរឹងប៉ឹងតាមសេចក្ដីព្យាយាម កាច់បំបាក់និស្ស័យថោកទាប ខ្ជិលច្រអូស ធុញទ្រាន់ ប្រមាថមើលងាយ នោះចោលចេញ ហើយផ្គង់កាយវាចានឹងចិត្តឲ្យរឹងប៉ឹងក្លៀវក្លាមានខន្តីមានបរិបេសក្នុងអត្តពលកម្មអត់ធ្មត់ទ្រាំទ្រកសិប្បនឹងកិច្ចធុរៈ ការងារគ្រប់យ៉ាង ឲ្យផុះផាលលូតលាស់ចំរើនឡើង ដើម្បីបង្វិល កំពូសំណាងវាសនាថោកទាបនោះ ឲ្យវិលទៅកាន់សេចក្ដីចំរើនកុំបណ្ដោយវាសនាទៅតាមយថាកម្ម កុំដេកចាំព្រេងសំណាងនោះ ឯព្រេងសំណាងដែលនឹងផ្ដល់ឲ្យនោះ លុះតែខំប្រឹងរៀនប្រឹងរក, ប្រឹងប្រព្រឹត្ត ទើបជាគវាសនានឹងផ្ដល់ឲ្យតាមលំដាប់ខ្ពស់ទាបបាន សមដូចពុកណាកាសិតថា "ចេះពីរៀន មានពីរក" យ៉ាងនេះហៅថា បានប្រយោជន៍ព្រោះនៅក្នុងប្រទេសដ៏សមគួរ ។

ប្រទេសនីមួយៗ ដែលនឹងលូតលាស់ចំរើនឡើងទៅកាន់អារ្យធម៌ នឹងឋានៈខ្ពង់ខ្ពស់បាន, លុះតែប្រកបដោយផ្លូវទាំងពីរយ៉ាង គឺ ផ្លូវលោក ផ្លូវធម៌ អាស្រ័យគ្នា ប្រព្រឹត្តទៅជាមួយគ្នា ដើរទៅទន្ទឹមគ្នា ទើបអាចនឹងចំរើនរុងរឿងសុខក្សេមក្សាន្តបាន ។ ផ្លូវទាំងពីរត្រូវឲ្យដើរទៅជាមួយគ្នា គឺផ្លូវលោកនៅត្រង់ណា ផ្លូវធម៌ក៏ឲ្យនៅត្រង់នោះ ផ្លូវធម៌នៅត្រង់ណា ផ្លូវលោកក៏ឲ្យនៅត្រង់នោះដែរ, ឲ្យផ្លូវលោកស្ថិតនៅជាបណា

ឲ្យផ្លូវធម៌ក៏ស្ថិតនៅដកបនោះដែរ ។ បើមានតែផ្លូវធម៌ម្យ៉ាង មិនមានការរៀបចំ ឲ្យមានគ្រោងការរក្សាប្រទេសជាតិ នឹងភោគសម្បត្តិរបស់ប្រទេសទេ ប្រទេសជាតិនឹងក្លាយទៅជាក្រីក្រលំបាក ទៅជាព្រៃផ្សៃ ទៅជាប្រទេសមិនមានតម្លៃថ្លៃថ្នូរទៅវិញ ។ ឬក៏មានតែផ្លូវលោកម្យ៉ាង ប្រទេសនឹងក្លាយទៅជាភ្លើងឆេះពេញលោកទាំងមូល ព្រោះមនុស្សប្រកបដោយ លោភៈ ទោសៈ មោហៈ ច្រើន មិនមានមេត្តាករុណាធម៌សម្រាប់លត់ភ្លើង គោលគឺ លោភៈ ទោសៈ មោហៈ នោះបានឡើយ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ឈ្វេងយល់ ហេតុផលនេះហើយ ទើបទ្រង់សំដែងនូវផ្លូវទាំងពីរប្រការនេះទុកមក, រាប់ថាជាមង្គលមួយ យ៉ាងប្រសើរដោយសុខចំរើន នេះជា ចក្កធម៌ទី ១ ។

ទី ២ – សប្បុរិសូបសំសេវៈ ប្រែថា ការសេពគប់នឹងសប្បុរសៈ មានសេចក្តីអធិប្បាយថា បណ្តាមនុស្សទាំងអស់ក្នុងសកលលោក សូម្បីមានកម្លាំងកាយ កម្លាំងប្រាជ្ញា នឹងកម្លាំងចិត្តគំនិតសម្រាប់ចិញ្ចឹមជីវិតរបស់ខ្លួន នឹងអ្នកដទៃ ឬឲ្យសម្រេចប្រយោជន៍អ្វីមួយបាន ដល់ក្រុមញាតិសាច់សាលោហិត រហូតដល់ប្រទេសជាតិមាតុភូមិ មិនឲ្យប្រទេសអន្តរាយ ទាំងធ្វើឫកពាមារយាទ ឲ្យល្អកើតឡើងបាន នោះ ក៏ត្រូវតែធ្វើសេចក្តីស្និទ្ធស្នាលសេពគប់រាប់រក នឹងសប្បុរសជាមុន ដើម្បីនឹងឲ្យស្គាល់ហេតុការណ៍ ទំនងការនោះសិន ទើបកិច្ចការដើរទៅ

កាន់សេចក្ដីសុខ សេចក្ដីចំរើនបាន ។

ឯបុគ្គលជាសប្បុរស មិនកំណត់រូបណាមួយឡើយ ទោះបីជាស្ត្រី បុរស, គ្រហស្ថ និងបព្វជិតក៏ដោយ ឲ្យតែមានចរិយាល្អ ឋិតនៅក្នុងធម៌ របស់សប្បុរស ឈ្មោះថាជាវៃប៉ិនប្រសប់ ចេះដឹងផ្លូវលោកនិងផ្លូវធម៌ បរិបូណ៌ ក៏ហៅថាសប្បុរសបានទាំងអស់ ។

សប្បុរសនេះ ជាបុគ្គលថ្លៃថ្នូរ ក្នុងសាកលលោកអាចយកចិត្តទុក ដាក់ជួយស្រោចស្រង់រំដោះទុក្ខប្រជាជាតិមាតុប្រទេស ឲ្យឡើងទៅកាន់ សីលធម៌ អារ្យធម៌ និងថ្នាក់ជាន់ខ្ពស់បាន ។

ហេតុនេះ យើងទាំងអស់គ្នា ជាអ្នកស្រឡាញ់សេចក្ដីសុខសេចក្ដី ចំរើន ត្រូវតែផ្ចិតចំឡងយកបែបបទសណ្ដាប់ធ្នាប់ និងការចេះដឹងពីលោក អ្នកសប្បុរសចេះដឹងឲ្យបានគ្រប់គ្រាន់ទាន់សម័យ កុំបង្អែបង្អង់ឲ្យកាល វេលាចេះតែកន្លងទៅ, ដើម្បីនឹងសាងជាតិមាតុភូមិរបស់យើងឲ្យរឹងជំហរ មាំមួន លើកខ្លួនឲ្យរួចចាកភាពថោកទាបដែលទទួលគ្រោះថ្នាក់ គឺសេចក្ដី លង់ខ្លៅក្រីក្រលំបាកមកអស់ច្រើនសតវត្សហើយ ។

មួយទៀតសប្បុរសនេះ បើនរណាបានចូលទៅគប់ប្រសព្វយកជា មិត្ត ឬសូមធ្វើជាគ្រូបាអាចារ្យ ហើយខំស្ដាប់រៀនសូត្រប្រតិបត្តិតាម លោក បើទុកជាមិនធ្លាប់ជាបណ្ឌិតមកពីដើម ក៏គង់ក្លាយទៅជាបណ្ឌិត តាមលោកមិនខាន ព្រោះលោកនេះឯង តែងមានឧបាយចេះនិយាយ

ណែនាំអ្នកដែលចូលទៅសេពគប់នឹងលោកនោះ ឲ្យប្រព្រឹត្តតាមផង ។

បើនរជនណា បានចូលទៅសេពគប់នឹងសប្បុរស ហើយប្រឹងយកចិត្តទុកដាក់តាមឱវាទលោក នរជនៈនោះមិនយូរប៉ុន្មានគង់នឹងបានដឹងរសធម៌ ដោយឆាប់ហ័ស ឧបមាដូចអណ្តាតដែលឆាប់ដឹងរសសម្លដូច្នោះដែរ ។ ដូចមានពុទ្ធភាសិត ក្នុងពាលវគ្គ នៃធម្មបទ ខុទ្ទកនិកាយថា:

មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។

ប្រែថា: បុគ្គលអ្នកមានប្រាជ្ញា បើចូលទៅអង្គុយជិតជនជាបណ្ឌិត សូម្បីតែមួយរំពេច ក៏អាចដឹងច្បាស់នូវធម៌យ៉ាងឆាប់ដូចជាអណ្តាតអាចដឹងនូវរសនៃសម្ល (យ៉ាងនោះដែរ) ។

សប្បុរសមានគុណគឺសេចក្តីល្អ គួររាប់អានមានឧបមាដូចជាគ្រឿងក្រអូប មានក្រស្នា ទឹកកម្រងផ្កាជាដើម, ឯអ្នកដែលចូលទៅគប់ប្រសព្វដូចស្លឹកឈើឬស្បោតខ្ចប់ឬដែលរុំគ្រឿងក្រអូប ទោះស្លឹកឈើឬស្បោតមិនមានគ្រឿងក្រអូបសោះ ក៏គង់ក្លាយទៅជាមានក្លិនក្រអូបតាមសេចក្តីប្រាថ្នា ។

សមដូចពុទ្ធភាសិតថា: នរជនខ្ចប់ក្លិនក្រស្នា ដោយស្លឹកឈើ បើទុកជាស្លឹកឈើ (មិនធ្លាប់ក្រអូបពីដើម) ក៏គង់តែក្លាយទៅជាក្រអូបឈ្ងុយឈ្ងប់ គួរឲ្យជាប់ចិត្តយ៉ាងណាមិញ , ការដែលចូលទៅសេពគប់នឹងអ្នកប្រាជ្ញ (ក៏មានកិត្តិស័ព្ទក្រអូបខ្ចរខ្ចាយ) យ៉ាងនោះដែរ ។

សប្បុរសនេះ លោកមិនបានពន្យល់ប្រាប់តែផ្លូវសុខសួគ៌និព្វាន ដែលយើងមើលមិនឃើញនោះទេ គឺលោកពន្យល់បង្ហាញផ្លូវបច្ចុប្បន្ន ដែលមើលឃើញជាក់ស្តែងនឹងភ្នែកយើងកល់គ្នាផង ដូចជាពន្យល់ឲ្យរៀនចំណេះវិជ្ជាផ្លូវលោកផ្លូវធម៌ ឲ្យប្រឹងរិះស្វែងរកទ្រព្យសម្បត្តិ កុំឲ្យសេពគប់គប់ប្រសព្វនឹងបុគ្គលពាលដូច្នេះជាដើម ។ ព្រោះហេតុនោះ សាធុជនទាំងឡាយកាលបើបានជួបសេចក្តី ដែលបានពណ៌នាមកខាងលើនេះ គួរតែសេពគប់ជាមួយនឹងសប្បុរសតែម្យ៉ាង ដើម្បីផ្ចិតចម្លងសណ្តាប់ធ្នាប់ចំណេះវិជ្ជាអំពីលោក កុំសេពគប់ជាមួយនឹងបុគ្គលពាលដាច់ខាត ។ ព្រោះការសេពគប់នឹងបុគ្គលពាល មិនមែននាំយើងទៅកាន់សេចក្តីសុខសេចក្តីចំរើនទេ, បើបុរសបុគ្គលអ្នកស្វែងរកសេចក្តីសុខសេចក្តីចំរើនពុំគួរចង់ឲ្យជួបប្រទះ ពុំគួរសេពគប់ជាដាច់ខាត, ព្រោះជនពាលតែងញុំាងខ្លួនឯងផង ញុំាងជនដទៃដែលធ្វើតាមផង ឲ្យបានសេចក្តីវិនាសដោយអំពើដែលខ្លួនបានប្រព្រឹត្តអាក្រក់តាមនោះពុំខាន ។ ត្រូវតែសេពគប់នឹងសប្បុរសម្យ៉ាងទើបបាត់ជាមង្គលមួយ នេះរាប់ជាជា បក្ខធម៌ ទី ២ ។

ទី៣- អត្តសម្មាបណិធិ ប្រែថា: ការតាំងខ្លួនបានដោយប្រពៃ: ដែលហៅថា តាំងខ្លួនដោយប្រពៃនោះ គឺបុគ្គលណាមួយបានសេពគប់នឹងសប្បុរស បានសិក្សារៀនចំណេះវិជ្ជា ផ្ចិតចំឡងយកបែបបទ សណ្តាប់ធ្នាប់ពីលោកបានហើយ ត្រូវផ្តាច់និស្ស័យចោកពាប

គឺគំនិតចាស់ដែលធ្លាប់កាន់ ធ្លាប់ជឿ ធ្លាប់ប្រព្រឹត្ត ធ្លាប់ខ្ជិលប្រអូសធុញទ្រាន់ ធ្វេសប្រហែសនោះចោលចេញបាន ហើយស្រវាឱបក្រសោបចាប់យកនិស្ស័យជាទំនួសដែលបានសន្សំអប់រំនោះ មកដំកល់ទុកក្នុងដួងចិត្តរបស់ខ្លួន ដើម្បីនឹងសាងអត្តភាព នឹងប្រទេសជាតិមាតុភូមិ ឲ្យឡើងទៅកាន់អារ្យធម៌ជាទំនួសយ៉ាងនេះហៅថា ការតាំងខ្លួនដោយប្រពៃ ។

ឯគ្រោងការសាងអត្តភាព នឹងប្រទេសជាតិមាតុភូមិឲ្យឡើងកាន់អារ្យធម៌ជាទំនួសនោះ សំដៅយកប្រយោជន៍ពីរប្រការគឺ : ប្រយោជន៍ដែលត្រូវបានឃើញទាន់ភ្នែកក្នុងជាតិនេះហៅថា ទិដ្ឋធម្មិកប្រយោជន៍ ១, ប្រយោជន៍ដែលត្រូវបានក្នុងកាលអនាគតឬខាងមុខ ហៅថា សម្បរាយិកប្រយោជន៍ ១ ។

ទិដ្ឋធម្មិកប្រយោជន៍ ជាហេតុឲ្យកើតសេចក្ដីសុខចំរើនក្នុងជាតិនេះអស់មួយជីវិត បែកចេញជា៤យ៉ាងគឺ :

១-ការបរិបូណ៌ដោយសេចក្ដីព្យាយាមប្រឹងប្រែងប្រកបកិច្ចការ វិជ្ជាជីវៈរកស៊ីចិញ្ចឹមជីវិតដោយការងារត្រូវធ្វើផ្សេង ៗ នឹងចំពោះវិជ្ជាគ្រប់បែបដកបដល់បានលទ្ធផល គឺ គោគសម្បទ័ នឹង វិជ្ជាសម្បទ័ ដែលកើតមកពីហេតុ គឺសេចក្ដីខ្មីឃ្មាតប្រកបការងារនោះៗ ហៅថា ឧដ្ឋានសម្បទា ។

២-ការបរិបូណ៌ដោយការថែរក្សា ថែទាំទ្រព្យ សម្បត្តិនឹងវិជ្ជាសម្បត្តិមិនឲ្យបាត់បង់នឹងភ្លេចចោល ដែលខ្លួនបានសន្សំ បានរៀនរួចមកហើយ

នោះ មិនឲ្យខូចខាតអន្តរាយដោយហេតុផ្សេងៗ មានអបាយមុខជាដើម ហៅថា អារក្ខសម្បទា ។

៣- ការចេះចាយវាយទ្រព្យសម្បត្តិចិញ្ចឹមជីវិត ល្មមសមគួរដល់កម្លាំងទ្រព្យដែលរកបាន មិនរឹតពេក មិនកញ្ជះកញ្ជាយពេក ខ្ជះខ្ជាយដៃពេក ហៅថា សមជីវិតា ។

៤- ការសេពគប់នឹងកល្យាណមិត្រ គឺមិត្រដែលប្រព្រឹត្តត្រឹមត្រូវល្អដោយកាយ វាចា ចិត្ត ហៅថា កល្យាណមិត្តតា ។

នេះជាប្រយោជន៍ក្នុងបច្ចុប្បន្នជាតិនេះ ។

ឯសម្បរាយិកប្រយោជន៍ ជាប្រយោជន៍ដែលបានក្នុងកាលខាងមុខនោះ ចែកចេញជា ៤ យ៉ាងដែរ៖

១- ការបរិបូណ៌ដោយសទ្ធា គឺជំនឿចំពោះវត្ថុដែលគួរជឿ មានជឿថា ធ្វើអាក្រក់បានអាក្រក់ ធ្វើល្អបានល្អ នឹងជឿគុណព្រះរតនត្រ័យជាដើម យ៉ាងនេះ ហៅថា សទ្ធាសម្បទា ។

២- ការបរិបូណ៌ដោយការរក្សាកាយវាចាចិត្ត ឲ្យពេបសា មិនឃើសឃ្លង់ មិនបៀតបៀនសត្វដទៃ មិនលួចមិនឆក់ដណ្ដើមនៃបន្ទំយកទ្រព្យសម្បត្តិអ្នកដទៃ ដែលគេមិនបានឲ្យដោយកាយ វាចា ចិត្ត, មិនលួចក្នុងប្រពន្ធអ្នកដទៃ មិននិយាយពាក្យកុហក មិនក្រេបផឹកទឹកស្រវឹង គឺមានបរិយាបុកពាល្អ គួរឲ្យអ្នកផងស្រឡាញ់ចូលចិត្ត ចង់គោរពបូជា

យ៉ាងនេះ ហៅថា សីលសម្បទា ។

៣-ការបរិបូណ៌ដោយការអាណិតអាសូរ ចំពោះអ្នកកំសត់ទុគ៌តហើយ លះបង់ទ្រព្យសម្បត្តិ ចែកឲ្យតាមបានតាមមានឥតរើសមុខ ទីងបូជាគុណមាតាបិតា និងគ្រូអាចារ្យជាដើម ហៅថា ចាគសម្បទា ។

៤-ការបរិបូណ៌ ដោយការសិក្សារៀនសូត្រ ឬស្ដាប់ពាក្យប្រៀនប្រដៅ ដើម្បីឲ្យកើតប្រាជ្ញា បេះពិចារណាស្គាល់គុណ ទោស ស្គាល់ខុសត្រូវ ស្គាល់ ល្អ អាក្រក់ ស្គាល់ហេតុផល ស្គាល់សេចក្ដីវិនាសចំរើន ឬពិចារណាសង្ខារឲ្យឃើញថា ធម្មជាតិគ្រប់យ៉ាង ជារបស់មិនទៀងជាដើម ហៅថាបញ្ញាសម្បទា ។ សម្បទា ៤ យ៉ាងនេះ ជាប្រយោជន៍ដែលយើងត្រូវសន្សំទុកទៅបរលោក ឬទៅអនាគត ។ ប្រយោជន៍ទាំងពីរយ៉ាងដូចបានពោលមកនេះ បើជនណាបានធ្វើបានសន្សំហើយ ជននោះឈ្មោះថា បានតាំងខ្លួនដោយប្រពៃ រមែងនៃវទៅកាន់សេចក្ដីសុខចំរើនតាមប្រាជ្ញាពប់ជាជាមគ្គិលមួយ នេះជា បក្កធម៌ ទី ៣ ។

ទី៤-បុព្វេកតបុញ្ញតា ប្រែថា ភាពជាអ្នកបានធ្វើសេចក្ដីល្អទុកមកក្នុងកាលមុន ។ សេចក្ដីថាជនជាតិទីមួយៗ ដែលមានគោគសម្បត្តិយសសក្តិរូបកន៍សណ្ឋានទ្រង់ទ្រាយល្អ ឬចិត្តថ្លើមយ៉ាងណាៗ ក៏សុទ្ធតែមកពីកំពូសំណាងវាសនា បានអប់រំសន្សំទុកមកពីក្នុងកាលមុន បើយើងធ្វើយ៉ាងណា ប្រព្រឹត្តយ៉ាងណា នោះចិត្តចក្ដី ច្រើនក្ដី លទ្ធផលត្រឡប់ទៅវិញ

ក៏រមែងទាញបង្វិលឲ្យទៅតាមតំរូវដើម មិនខុសហេតុខុសផលយ៉ាងនោះឡើយ ។ សូមទាញឧទាហរណ៍ឲ្យឃើញក្នុងបច្ចុប្បន្ននេះថា ព្រះពុទ្ធជាម្ចាស់ក្តី ព្រះបច្ចេកពុទ្ធក្តី អរហន្តសាវកដទៃក្តី ដែលបានត្រាស់ជាព្រះពុទ្ធជាអរហន្ត លះកិលេសចូលទៅកាន់ព្រះនិព្វានហើយមានព្រះកិត្តិនាមល្បីក្នុងត្រៃភពនោះ ក៏អាស្រ័យមកអំពីបុណ្យកុសល ដែលបានកសាងសន្សំទុកក្នុងអតីតជាតិ ។ ពុំនោះសោត ដូចយ៉ាងឥស្សរជនមានព្រះរាជាធិរាជនាម៉ឺនសព្វមុខមន្ត្រីធំតូចគ្រប់ដំណែងជាន់ខ្ពស់ កណ្តាល ឬទាបបានយ៉ាងនេះ ក៏អាស្រ័យមកអំពីការសិក្សារៀនសូត្រពីខាងដើមតាមជាន់ថ្នាក់ ទើបអាចនឹងឡើងកាន់ដំណែងនានាបាន, មិនមែនចេះតែឡើងទៅឯងៗបាននោះ ។ អ្នកមានសម្បត្តិនឹងអ្នកខ្សត់សម្បត្តិក៏ដូចគ្នា, លុះតែខំប្រឹងរកទំធ្វើពីខាងដើមដែរ ទើបសម្រេចប្រយោជន៍ក្នុងកាលខាងក្រោយទៅបាន ។

សេចក្តីពណ៌នាមកប៉ុណ្ណេះ ដើម្បីនឹងទាញឲ្យឃើញថាសេចក្តីល្អដែលយើងបានធ្វើទុកមកពីក្នុងកាលមុនយ៉ាងណា ដល់មកខាងក្រោយក៏រមែងឲ្យផលយ៉ាងនោះដែរ ។ ព្រោះហេតុនោះ ព្រះពុទ្ធបរមគ្រូទ្រង់សំដែងថា ភាពជាអ្នកធ្វើសេចក្តីល្អទុកមកក្នុងកាលមុនពាត់ជាចក្កធម៌មួយ រមែងវិលទៅកាន់សេចក្តីសុខចំរើនក្នុងលោកនេះរាប់ថាជាចក្កធម៌ទី ៤ ។

ពណ៌នាអំពីចក្កធម៌ដែលប្រែថា ធម៌ដូចជាកង់នៃរថនាំទៅកាន់សេចក្តីចំរើន ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

# មធុរសភាសិណី

## សម្តេចព្រះធម្មលិខិត ល្វី–ឯម ប្រែរៀបរៀង

(៧១៣)

---

ព្រះមហាសត្វទ្រង់បានស្តាប់ពាក្យយក្សហើយ ទ្រង់ពិចារណាថា អាត្មាអញបានអន្ទាលទៅមកក្នុងវដ្តសង្សារដោយយូរអង្វែង ដែលកប់ខ្លួនជាតិកំណើតត្រូវសត្វសាហាវទាំងឡាយ មានសីហៈ ខ្លាធំ ខ្លាឃ្មុំ ត្រីអណ្តើកនិងសត្វស្លាបជាដើម ទាំពាំយកទៅស៊ីជាចំណីអាហាររបស់វា ជាតិកំណើតទាំងនោះនឹងកប់ពុំបានឡើយ, ថ្ងៃនេះ ត្រូវអាត្មាអញលះបង់ជីវិតខ្លួន, ដើម្បីប្រយោជន៍បូជាព្រះធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធទើបត្រូវ, លុះព្រះបរមពោធិសត្វទ្រង់រំពឹងគិតដូច្នេះហើយ ក៏ទ្រង់ត្រាស់នឹងមហាយក្សថា បពិត្រមហាយក្សដ៏ចំរើន ! ជនទាំងឡាយក្នុងសង្សារវដ្តដែលវិនាសអន្តរាយ ដល់នូវសេចក្តីទុក្ខវេទនាជាទម្ងន់ច្រើនពេកណាស់, សេចក្តីពិតថា បុគ្គលប្រព្រឹត្តសម្លាប់សត្វ លួចទ្រព្យគេ សេពប្រពន្ធកូនគេ ពោលពាក្យកុហកបញ្ឆោតឲ្យគេវិនាសបាត់ប្រយោជន៍ ផឹកទឹកស្រវឹងគឺសុរានិងមេរ័យនេះ ជាការសូន្យទទេ បានតែសេចក្តីទុក្ខលំបាក មិនជាប្រយោជន៍ដល់ខ្លួននិងបុគ្គលដទៃឡើយ, អំពើបាណាតិបាតជាដើមនោះ គ្រាន់តែផ្តល់ឲ្យនូវទោសដោយពិត បពិត្រមហាយក្ស! មួយទៀត អំពើដែលបុគ្គលរំលងទំលាក់ខ្លួនចុះពីដើមឈើឲ្យស្លាប់ក្តី បង

កសម្លាប់ខ្លួនឯងក្ដី ផឹកថ្នាំពិសសម្លាប់ខ្លួនក្ដី ឬស្លាប់ដោយព្យាធិជម្ងឺឈឺចាប់ ដោយសេចក្ដីទុក្ខវេទនាដ៏ក្រៀមក្រំផ្សេង ៗ ដោយប្រែប្រួលរដូវពុំស្មើក្ដី អំពើទាំងអស់នេះ មិនជាប្រយោជន៍ដល់ខ្លួននិងបុគ្គលដទៃឡើយ , បពិត្រមហាយក្ស! យើងដែលអន្ទោលទៅក្នុងសង្សារវដ្ដ គ្រាន់តែស្លាប់ហើយ បានជាចំណីនៃខ្លាធំ ខ្លាដម្បង ត្រី ក្រពើ ត្មាមមករនេះរាប់ពុំបានឡើយ , ការដែលស្លាប់ទាំងអស់នេះ ស៊ីឥតសោះសូន្យទទេ ពុំបានជាប្រយោជន៍ដល់ខ្លួននិងបុគ្គលដទៃឡើយ ទើបតែថ្ងៃនេះយើងបានស្ដាប់ធម៌ទេសនា បានឲ្យទានជីវិតខ្លួន ដែលជាទានដ៏បុគ្គលដទៃឲ្យបានដោយកម្រនេះ បានឈ្មោះថាស្លាប់មានផលប្រយោជន៍យ៉ាងធំបំផុត មុខជាខ្ញុំនឹងបានសម្រេចនូវសម្បត្តិសព្វញ្ញុតញ្ញាណ ដើម្បីនឹងញុំាងសត្វលោកទាំងឡាយ ឲ្យរលាស់ចេញចាកសង្សារទុក្ខដោយពិត បពិត្រយក្សជាសំឡាញ់ដ៏មានធុរៈស្មើ! អ្នកបានឈ្មោះថាជាបុគ្គលមានគុណឧបការច្រើនដល់យើង ព្រោះហេតុនោះខ្ញុំអាចនឹងធ្វើតាមពាក្យរបស់អ្នកឥឡូវនេះឯង សូមអ្នកកុំមានសេចក្ដីរង្កៀសសង្ស័យឡើយ ត្រូវតែសម្ដែងធម៌ទេសនាមកឲ្យយើង, សេចក្ដីប្រាថ្នារបស់យើង មុខជានឹងបានសម្រេចបរិបូណ៌ក្នុងកាលឥឡូវនេះឯង ៗ លុះព្រះមហាសត្វទ្រង់ទទួលប្ដេជ្ញាយ៉ាងនេះស្រេចហើយ ក៏ស្ដេចឡើងទៅលើកំពូលភ្នំទ្រង់ស្ថិតឈរនៅលើកំពូលភ្នំ ហើយទ្រង់ត្រាស់ថា ថ្ងៃនេះអាត្មាអញបានឲ្យទានជីវិតឯង ឲ្យទានសាច់ទាំងអស់ក្នុងសរីរៈ

ព្រមទាំងកេជសម្បត្តិផង ដើម្បីបូជាធម៌ទេសនាដោយស្មោះចំពោះ រួចហើយព្រះអង្គក៏ដល់នូវសេចក្តីសោមនស្សជ្រះថ្លា បានពោលជូនទៀតនឹងមហាយក្សថា នែយក្ស! ត្រូវអ្នកសម្តែងធម៌ទេសនាមកចុះ យើងប្រុងនឹងស្តាប់ហើយទំលាក់ខ្លួនចុះឥឡូវនេះឯង ។ ឥឡូវយក្សនោះស្ទុះទៅឈរខាងក្រោម បើកមាត់ហាឡើងដ៏មានចង្កូមធំពន្លឹកប្រុងនឹងសម្តែងធម៌ទេសនា ។ ព្រះមហាសត្វក៏បែរព្រះភ័ក្ត្រទៅត្រង់មហាយក្សនោះ ហើយលោតទំលាក់ព្រះកាយចុះមកក្នុងវេលានោះដែរ ។ កាលនោះ សក្កទេវរាជជាធំជាងពួកទេវតា ក៏បានព្រះហ្ឫទ័យសោមនស្សជ្រះថ្លាដល់នូវសេចក្តីស្ញើចឆ្ងល់ជាទីអស្ចារ្យពន់ពេក ទើបលះបង់នូវអត្តភាពជាយក្សហើយ និម្មិតអត្តភាពជាទិព្វវិញ សឹងមានគ្រឿងប្រដាប់សុទ្ធតែកែវដ៏រុងរឿងភ្លឺថ្លា បីដូចជាព្រះអាទិត្យពេញកម្លាំងរះឡើងកណ្តាលអាកាស ហើយយកព្រះហស្តទាំងពីរចាប់ទ្រព្រះមហាសត្វដែលលោតចុះពីលើអាកាសវិហារយ៉ាងមាំ នាំហោះឡើងទៅកាន់ស្ថានតាវតិង្សសួគ៌ទេវលោកនាយ ទើបដាក់ព្រះអង្គឲ្យគង់លើថ្មបណ្ឌុកម្ពលសិលាសនៈដ៏ប្រសើរ ស្រេចហើយបូជាព្រះមហាសត្វដោយគ្រឿងសក្ការៈទាំងឡាយ មានគ្រឿងក្រអូបនិងផ្កាកម្រងទិព្វជាដើម ហើយស្តាប់ធម៌ទេសនាព្រះបរមពោធិសត្វដោយព្រះអង្គឯង (១) ក៏ដល់នូវ

---

១-ប្រហែលជាព្រះរាជសាសន៍ដ៏ព្រោះព្រៀងទាក់ទងដោយធម៌អាថិទ្ធៈ ។

អាការដ៏ជ្រះថ្លាក្រៃពេក ។ បន្ទាប់អំពីនោះសម្តេចព្រះអម្រិន្ទ្រាធិរាជទ្រង់សម្តែងព្រះធម៌ទេសនាមានអនិច្ចលក្ខណៈជាដើម តាមលំអានដែលព្រះសម្ពុទ្ធទ្រង់ព្រះនាមកស្សបសម្តែងទុកមក ហើយថ្វាយព្រះបរមពោធិសត្វដោយបទព្រះគាថាដូច្នេះថា:

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។

អធិប្បាយថា យើងទាំងឡាយគួរមានសេចក្តីសំវេគថា សង្ខារធម៌ទាំងឡាយជារបស់មិនទៀង តែងតែកើតឡើង ហើយនឹងវិនាសទៅវិញជាធម្មតា គ្រាន់តែកើតឡើង ហើយតែងរលត់សូន្យទៅវិញឥតមានវត្ថុអ្វីឃាត់បាន លុះតែរម្ងាប់នូវសង្ខារធម៌ទាំងឡាយនោះបាន ទើបនាំមកនូវសេចក្តីសុខក្សេមក្សាន្ត ។

សម្តេចព្រះបមត្រៃត្រឹង្សភព ទ្រង់បានសម្តែងធម៌ទេសនានេះចប់ហើយ ព្រះអង្គញុំាងសេចក្តីប្រាថ្នានៃព្រះមហាសត្វឲ្យដល់នូវសេចក្តីសម្រេចសមតាមបំណង ហើយទ្រង់សម្តែងប្រាប់នូវសម្បត្តិដ៏មានសិរីសួស្តីដ៏ប្រសើរក្នុងស្ថានទេវលោក រួចហើយក៏នាំព្រះបរមពោធិសត្វហោះចុះត្រឡប់មក កាន់ស្ថានមនុស្សលោកវិញ ថ្វាយព្រះមហាសត្វ ឲ្យស្ថិតនៅក្នុងរាជសម្បត្តិរបស់ព្រះអង្គដដែលវិញ ព្រម

តាំងថ្វាយទាន មិនឲ្យព្រះអង្គប្រមាទប្រហែសធ្វេសក្នុងការជាកុសលឡើយ លុះស្រេចកិច្ចហើយ ព្រះឥន្ទ្រាធិរាជក៏ហោះឡើងទៅកាន់ស្ថានទេវលោកនាយវិញហោង ។

ព្រោះហេតុនោះ ព្រះអរហន្តទាំងឡាយដែលបានសម្តែងរឿងនិទានជាតកនេះលោកពោលថា : អ្នកប្រាជ្ញជាសប្បុរសពីបុរាណកាលលោកពុំមានព្រះទ័យអាល័យទ្រព្យសម្បត្តិដ៏មានសិរី ទំនងជាតែរបស់លោកឡើយ អាចលះបង់ហើយចេញទៅស្វែងរកព្រះធម៌ដែលព្រះអរិយទាំងឡាយតែងសរសើរដោយពិត ។ សត្វទាំងឡាយក្នុងលោកនេះ ដែលមានទ្រព្យសម្បត្តិតិច មានអាយុខ្លី មានជម្ងឺរាបីតាបក៏ច្រើន ព្រោះតែខ្លួនកាន់សេចក្តីប្រមាទក្នុងការជាកុសលពីជាតិមុនមកនោះឯង ។

សម្តែងរឿងនិទាន ព្រះបាទធម្មសោណ្ឌកមហារាជទី ១ ក្នុងវគ្គជាបឋម ដែលមានក្នុងគម្ពីរមធុរសវាហិនីនេះ ក៏ចប់ដោយសង្ខេបតែប៉ុណ្ណេះឯង ។

x

x x

២-មិគលុទ្ធកវត្ថុកថា សម្តែងរឿងនិទានព្រានព្រៃ ជាគំរប់ពីរតទៅទៀតដោយបទបាលីថា:

ឥតោ កិរ ឯកតឹសេ កប្បេ ជាដើម សេចក្តីថា ក្នុងកប្បជាគំរប់៣១ រាប់អំពីកប្បនេះ កាលនោះ ព្រះសិខីសម្មាសម្ពុទ្ធ ព្រះ

អង្គបានកសាងសន្សំបារមីទាំង៣០គត់ ពេញបរិបូណ៌ហើយ ទ្រង់បានបរមាភិសេកសម្ពោធិញ្ញាណ ជាអង្គព្រះអរហន្តវិសេសប្រាកដក្នុងលោក ព្រះអង្គតែងមានព្រះទ័យមេត្តាករុណាសម្តែងធម៌ទេសនាប្រោសសត្វទាំងឡាយឲ្យបានសម្រេចនូវមគ្គនិងផល ព្រះអង្គទ្រង់ស្តារចម្លងមនុស្សលោកព្រមទាំងទេវលោកឲ្យបានឆ្លងផុតចាកផ្លូវឆ្ងាយគឺសំសារវដ្តជ្រះស្រឡះ ព្រះអង្គបង្កើតនូវគ្រឿងកែវ គឺធម្មរសនឹងអត្ថរស ផ្សាយទៅសព្វសត្វទាំងអស់ ព្រះអង្គវាយប្រហារស្គរធម្មភេរីជ័យ ឲ្យលាន់ឮខ្ទរខ្ទារសាយសព្វទៅក្នុងលោក ព្រះអង្គលើកឡើងនូវធង់ទង់គឺព្រះធម៌ជាទីលំអក្នុងលោក ។ លុះដល់សម័យថ្ងៃមួយព្រះអង្គមានប្រាថ្នានឹងបម្រើនសមណធម៌ក្នុងវិវេកស្ថាន ទ្រង់បានចូលទៅកាន់ដងព្រៃធំមួយ លុះចូលទៅដល់ព្រៃធំជាទីរហោស្ថានសប្បាយហើយ ព្រះអង្គក្រាលសន្ថាដ៏មានជាន់បួនស្រេចហើយ ទ្រង់គង់នៅលើផែនប្ថពីដ៏មានពណ៌ល្អគួរជាទីត្រេកក្សេមក្សាន្តក្នុងព្រះទ័យ, ជាព្រៃដែលពួកម្រឹគបក្សីច្រើនជាអនេក នៅពឹងពាក់សំណាក់អាស្រ័យក្នុងទីនោះ ៗ ឯព្រៃនោះសោតដ៏ប្រឡំដោយវល្លិ៍ផ្សេងៗ មានវល្លិ៍ម្លិះត្រួមម៉ះលាជាដើម ដ៏មានផ្ការីកស្គុះស្គាយក្រអូបឈ្ងុយឈ្ងប់ទាំងប្រដាប់ដោយដើមឈើធំៗមានដើមខ្នឹងទឹង ដើមឫសនាគជាដើម ដ៏មានផ្ការីកពេញធុំក្លិនក្រអូបសព្វសាយក្នុងព្រៃ, ឯអង្គព្រះសិទ្ធិសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់បញ្ចេញឆព្វណ្ណរង្សីទាំង៦ពណ៌ ផ្សាយទៅសព្វទិសានុទិស ដ៏មានពន្លឺ

ក៏ស្វាងរុងរឿងដូចជាពន្លឺព្រះចន្ទរះឡើងមួយពាន់ដួងក្នុងទីនោះឯង ។

កាលនោះ ពួកសត្វទាំងឡាយ មានទេវតាព្រហ្មនាគគ្រុឌជាដើម សឹងបង្កើតជាកោលាហលជ្រួលជ្រើមចូលទៅប្រជុំគ្នាក្នុងព្រៃនោះ ហើយពោលសរសើរធ្វើនមស្ការថ្វាយបង្គំបូជាព្រះមានព្រះភាគ ដោយគ្រឿងបូជាផ្សេងៗ មានគ្រឿងក្រអូបនិងផ្កាកម្រងទិព្វជាដើម ហើយលើកដៃឡើងប្រណម្យស្ថិតនៅទីនោះ ។

ឯព្រះមានព្រះភាគព្រះអង្គទ្រង់សម្តែងធម៌ទេសនា ដ៏ប្រកបដោយព្រះចតុរារិយសច្ចទាំងបួនដ៏វិសេស ដោយបញ្ចេញព្រះសូរសៀងដ៏ពីរោះផ្អែមល្ហែមឥតមានអាក់ បីដូចជាទេវតាបង្អុរទឹកភ្លៀងអម្រឹតឲ្យធ្លាក់ពីអាកាសដូច្នោះ ដើម្បីជាទីសណ្ដាប់ប្រជុំជនទាំងឡាយក្នុងទីនោះដែរ ។

គ្រានោះ មានព្រានព្រៃម្នាក់ តែងដើរចូលទៅក្នុងព្រៃរកបាញ់សត្វ ដើម្បីយកទៅលក់ចំណាយខ្វះស៊ីខ្វះ ក៏បានដើរទៅដល់ទីនោះបានឃើញព្រះមានព្រះភាគកំពុងតែសម្តែងធម៌ទេសនា ក៏ឈររង់ចាំស្ដាប់ធម៌ទាល់តែចប់ ហើយមានចិត្តជ្រះថ្លា សុំសមាទានសីលជាប់ជានិច្ច ពុំបានប្រព្រឹត្តអំពើបាណាតិបាតទៀតឡើយ ៗ ដោយផលានិសង្សដែលបានស្តាប់ធម៌ទេសនានោះ លុះច្យុតអំពីជាតិជាព្រានព្រៃហើយបានឡើងទៅកើតក្នុងស្ថានទេវលោក សោយទិព្វសម្បត្តិទាំង ១០ ជា

សុខក្សេមក្សាន្ត គ្រាន់តែអន្លោលទៅវិញទៅមកក្នុងកាមាវចរសួគ៌ទាំង ៦ ជាន់ នឹងស្ថានមនុស្សបានសោយសម្បត្តិដ៏មានសិរីដ៏ប្រសើរជាងដនដាច់, ដរាបមកដល់ភទ្ទកប្បនេះបាន ៣១ កប្បគត់ ពុំដែលធ្លាក់ទៅសោយទុក្ខវេទនាក្នុងអបាយភូមិដល់ម្តងឡើយ ។ លុះមកក្នុងពុទ្ធុប្បាទនៃព្រះសម្ពុទ្ធជាអម្ចាស់របស់យើងនេះ ព្រាននៃព្រៃនោះក៏បានច្យុតមកពីស្ថានសួគ៌ទេវលោកនាយ មកកើតក្នុងត្រកូលដ៏ស្តុកស្តម្ភមួយក្នុងនគរសាវត្ថី លុះដល់ប្រសូតចាកផ្ទៃនៃមាតាបានចំរើនវ័យធំឡើង ហើយក៏លាមាតាបិតាចេញទៅបួសក្នុងសំណាក់ព្រះមានព្រះភាគ ហើយបានស្តាប់ធម៌ទេសនា ដ៏ប្រកបដោយព្រះចតុរារិយសច្ចទាំង ៤ ប្រការ ដែលព្រះមានព្រះភាគទ្រង់សម្តែងប្រទាន, ក៏បានបាក់ធ្ងះ នូវព្រះអរិយសច្ចទាំងបួនមួយរំពេច បានសម្រេចព្រះអរហត្តផល ព្រមទាំងបដិសម្ភិទាញាណ ដោយ។បនិស្ស័យដែលបានស្តាប់ព្រះចតុរារិយសច្ចពីមុនមកនោះឯង ។ ថ្ងៃមួយជាខាងក្រោយមក ព្រះថេរនោះចូលទៅកាន់ទីប្រជុំព្រះភិក្ខុសង្ឃ អង្គុយនៅត្រង់ពាក់កណ្តាលទីប្រជុំ ហើយបន្លឺឡើងនូវវាចាប្រកបដោយបីតិសោមនស្សជ្រះថ្លា ឲ្យលាន់ឮឡើង ប្រកាសប្រាប់នូវអំពើកម្មជាកុសលដែលខ្លួនបានធ្វើអំពីបុព្វជាតិថា ៖

«ឯកាគិសេបិ ន់តោ កាប្បេ លោកោ ឧប្បជ្ជិ ជាយតោ ដូច្នេះជាដើម អធិប្បាយថា កាលសម្តេចព្រះសិទ្ធិសម្មាសម្ពុទ្ធៈលោកនាយក ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ តាំង ៣២ និងអនុព្យញ្ជនៈ ៨០ ព្រះអង្គបានត្រាស់ដឹងសព្វញ្ញុតញ្ញាណ ជាព្រះពុទ្ធប្រាកដក្នុងលោក ក្នុងកប្ប ៣១ មុនភទ្ទកប្បនេះ , ព្រះអង្គដូចជាប្រទីបដ៏មានពន្លឺដល់សត្វលោក ឬដូចជាព្រះអាទិត្យរះឡើងនាកណ្តាលអាកាស ព្រះអង្គជាស្តេចហេតុធម៌ដ៏ល្បីខ្ទរទៅក្នុងទីប្រជុំជន ព្រះអង្គជាទីពឹងនៃសត្វលោក ហើយញុំាងសត្វលោកទាំងអស់ឲ្យស្ថិតនៅលើសំពៅគឺព្រះធម៌ ទ្រង់ចម្លងឲ្យឆ្លងផុតពាក់ផ្លូវឆ្ងាយគឺសំសារទុក្ខ នាំទៅដល់ទុកក្នុងសន្តិភូមិ ដែលជាភូមិអាចរម្ងាប់ខ្វល់ក្នុងទុក្ខទាំង៤គឺអមតមហានិព្វានបាន ព្រះអង្គលើកឡើងនូវទង់ជ័យគឺព្រះធម៌ ហើយប្រហារនូវស្គរជ័យគឺព្រះចតុរារិយសច្ច ឲ្យលាន់ឮផ្សាយទៅក្នុងលោក ។ លុះក្នុងសម័យមួយ ព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រះអង្គប្រាថ្នានូវវិវេកស្ថាន ទ្រង់បានចូលទៅកាន់ដងព្រៃ ជាទីរហោស្ថានដ៏ស្ងាត់ ហើយព្រះអង្គក្រាលសន្ថាដ៏មានជាន់បួន លើថ្មនោសិលាគល់នៅក្នុងទីនោះ ទ្រង់សម្តែងព្រះអរិយសច្ចទាំងបួនដល់ប្រជុំជន មានទេវតាព្រហ្មនាគគ្រុឌជាដើម ដ៏មានព្រះសូរសៀងពីរោះអស្ចារ្យ ។ កាលនោះ ខ្ញុំបានកើតជាព្រានព្រៃតែងសម្លាប់ម្រឹគបក្សី លក់ដូរយកថ្លៃចិញ្ចឹមជីវិតនៃខ្លួនទីង

កូនប្រពន្ធជានិច្ច ថ្ងៃមួយ ខ្ញុំបានចូលទៅក្នុងព្រៃនោះស្វែងរកបាញ់
សត្វតាមធម្មតា ក៏បានឃើញព្រះសម្មាសម្ពុទ្ធទ្រង់កំពុងតែសំដែងព្រះចតុ-
រារិយសច្ចធម៌ ខ្ញុំក៏មានចិត្តសោមនស្សជ្រះថ្លាឈររង់ចាំស្តាប់ធម៌ទេសនា
ដរាបដល់ចប់ ហើយខ្ញុំបានសោយនូវសេចក្តីសោមនស្សចំពោះធម៌នោះ ពុំ
បានដាច់ឡើយ ។

ដោយបុញ្ញកម្មដែលខ្ញុំបានសន្សំហើយនោះ ក៏បានទៅកើតក្នុង
កាមាវចរសួគ៌ទាំង ៦ ជាន់ ដោយទិព្វសម្បត្តិដ៏មានសេរី មានពួក
ទេវតាចោមរោមជាបរិវារ ស្ថិតនៅក្នុងវិមានប្រកបដោយកែវ ៧ ប្រការ
ត្រាច់តែវិលចុះវិលឡើង ជាអនុលោមបដិលោមក្នុងស្ថានសួគ៌ទាំង ៦ ជាន់
ជាច្រើនជាតិ លុះច្យុតពីស្ថានសួគ៌មកកើតក្នុងស្ថានមនុស្សលោកនេះ
គឺបរិបូណ៌ដោយភោគសម្បត្តិពុំមានខ្វះខាតអ្វីឡើយ, លុះកន្លងទៅបាន
៣៦កប្ប ដល់មកភទ្ទកប្បនេះ ខ្ញុំបានមកកើតក្នុងត្រកូលព្រាហ្មណ៍
មហាសាលក្នុងនគរសាវត្ថី ដ៏ស្តុកស្តម្ភមាំមួនដោយភោគសម្បត្តិ និង
បរិវារសម្បត្តិ លុះចំរើនវ័យធំឡើងហើយ ខ្ញុំបានត្រេចទៅកាន់ចារិក
នៃព្រះនគរ បានចូលទៅកាន់ព្រះជេតវនារាម ស្តាប់ធម៌ទេសនាក៏មានចិត្ត
ជ្រះថ្លាសុំអនុញ្ញាតមាតាបិតាចេញមកបួស ក្នុងសំណាក់ព្រះពុទ្ធសា-
សនាពុំទាន់បានយូរប៉ុន្មាន ខ្ញុំបានស្តាប់មធុរធម្មកថា ដ៏ប្រកាសនូវចតុ
រារិយសច្ចទាំងបួន ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងក្នុងទីប្រជុំនោះ

ខ្ញុំបានស្ដាប់តែមួយរំពេចក៏បានចាក់ធ្លុះព្រះចតុរារិយសច្ចទាំងបួន ហើយបានសំរេចព្រះអរហត្តផលព្រមទាំងបដិសម្ភិទាញាណ ជ្រាបច្បាស់នូវព្រះនិព្វានដ៏ឧត្ដមជាធម៌ដ៏ត្រជាក់ឥតមានចាស់ជរាឈឺស្លាប់ឡើយ , ផលានិសង្សដែលបានស្ដាប់ព្រះធម៌ទេសនានោះជាអស្ចារ្យពេកណាស់ ចិរវេលាកន្លងទៅ ៣១ កប្បហើយ ខ្ញុំពុំបានទៅកើតក្នុងអបាយដល់ម្ដងឡើយ ខ្ញុំឥតមានទុក្ខ មានភ័យអ្វីមកបៀតបៀនដែរ តែងតែសោយសេចក្ដីសុខក្នុងស្ថានមនុស្សនឹងទេវតា ដរាបមកដល់បច្ឆិមភពនេះឯង , ខ្ញុំបានពណ៌នានូវអំពើ ដែលខ្ញុំបានធ្វើជាប្រធានដល់លោកទាំងឡាយសូមបានជ្រាបប៉ុណ្ណោះ ដូច្នេះសូមលោកទាំងឡាយធ្វើនូវខ្ញុំឲ្យជាឧបមាចុះ ហើយចូរខ្វល់ខ្វាយស្ដាប់ធម៌ទេសនាដោយសេចក្ដីគោរព ក៏នឹងបានផលានិសង្សសំរេចនូវសម្បត្តិទាំង ៣ ប្រការ ដូចខ្ញុំដោយពិត " ។

លុះព្រះថេរអង្គនោះបានពោលយ៉ាងនេះហើយ បានញុំាងសត្វទាំងឡាយឲ្យប្រកបព្រម ក្នុងការស្ដាប់ធម៌ទេសនាពុំឲ្យដាច់ឡើយ ។

ព្រោះហេតុដូច្នេះ ព្រះអរហន្តទាំងឡាយដែលបានសម្ដែងរឿងនិទានចប់ហើយ ក៏សូត្របទព្រះគាថាតទៅថា:

ឥតិ តន្ទុត្តរកាលំ សានុគាម្ហិ សុណិត្វា
អធិគតវិភវានំ អានុភាវំ បុណិត្វា
ភវតិ ភវសុខមារម្ភា បត្ថយន្តា តុសិតំ

ជហាថ សុណាថ ធម្មំ ទុល្លភំ ទុល្លភស្ស ។

អធិប្បាយថា: បុគ្គលអ្នកបានស្តាប់នូវសាធុកម្មអំពើប្រពៃគឺធម៌ទេសនា អស់កាលពិសេសជាងកាលដូចបានពណ៌នាហើយហ្នឹងនេះ ដឹងបាន ដល់នូវអានុភាព គឺបានសោយសម្បត្តិដែលខ្លួនបានហើយប្រាកដ ក្នុងលោក បពិត្រសប្បុរសទាំងឡាយដ៏ចំរើន! កាលបើអ្នកទាំងឡាយ ប្រាថ្នាចង់បាននូវសេចក្តីសុខក្នុងឯកត ត្រូវតែលះបង់នូវសេចក្តីខ្ជិលច្រអូស ជាមន្ទិលដល់កាយឲ្យស្រឡះចេញ ហើយត្រូវខំស្តាប់ព្រះធម៌ដែល គេរកបានដោយកម្រ ជាធម៌របស់ព្រះមានព្រះភាគជាបុគ្គលក្រក្នុង លោក ( នេះ ) ។

សម្តែងរឿងនិទានព្រានព្រៃ ជាគំរប់ពីរ គឺចប់ដោយសង្ខេបតែ ប៉ុណ្ណេះ ។

x

x x

៣ តិណ្ណំ ជនានំ វត្ថុកថា សម្តែងរឿងនិទាននៃជន ៣នាក់ ជារឿងគំរប់បីតទៅទៀត ដោយបទបាលីថា:

ជម្ពូទីបស្មឹ កិរ បុព្វេ មហាធនា យោ អហោសិ ដូច្នេះជាដើម អធិប្បាយថា ក្នុងកាលពីមុន មានរដូវមួយជារដូវខែប្រាំង កំដៅក្តៅហួតហែងយ៉ាំងខ្លាំង ប្រាកដក្នុងជម្ពូទ្វីប ជាចម្លែកពន់ពេក ណាស់ ។

កាលនោះ ព្រះអាទិត្យរះឡើងដ៏មានកំដៅ ក្តៅផ្សាយទៅសព្វទិសានុទិសដូចចំហាយភ្លើង បណ្តាទឹកដែលមានក្នុងបឹង ត្រពាំងស្រះបោក្ខរណី និងស្ទឹងតូច ស្ទឹងធំ ជ្រោះកំរ ហែងក្នុងជាដើម ក៏រីងស្ងួតហួតហែងអស់ពុំមានសេសសល់ឡើយ, សត្វទឹកទាំងឡាយមានត្រីអណ្តើកក្រពើជាដើមក៏ដល់នូវសេចក្តីវិនាសស្លាប់អស់ ។ ចំណែកឯរុក្ខជាតិលតាជាតិទាំងឡាយ មានដើមឈើស្មៅស្លឹកជាដើម ដែលមានក្នុងស្រុកក្តី ក្នុងព្រៃក្តី សឹងស្វិតស្រពោនវិនាសទៅអស់ដោយច្រើន ។ ទាំងហ្វូងម្រឹគត្រេចចរទៅលើផែនដីក្តី ហ្វូងបក្សីត្រេចចរទៅលើអាកាសក្តី សឹងមានសេចក្តីស្រេកឃ្លានមកបៀតបៀនជានិច្ច តែងស្វែងរកទឹកផឹកពុំបាន ក៏សំគាល់ថ្ងៃបណ្តើរគួនស្មានថាជាទឹកប្រែងស្រះតែហើរទៅ លុះពុំបានទឹកផឹកក៏ដល់នូវសេចក្តីទុក្ខវេទនាជាទម្ងន់ក្រៃលែង ។

កាលនោះ មានសេកមួយស្រេកទឹកខ្លាំងពេក ក៏បានហើរទៅស្វែងរកទឹកក្នុងទីនោះៗ ស្រាប់តែបានធុំក្លិនទឹកក្នុងអណ្តូង ដែលមានជម្រៅហុកសិបហត្ថទៀបដើមឈើមួយក្នុងព្រៃធំ, ហើយមានសេចក្តីលោភចង់ផឹកទឹក ក៏ហើរចុះទៅក្នុងអណ្តូងនោះដើម្បីនឹងផឹក, លុះបានផឹកឆ្អែតបានស្ងួត ១ ទឹកស្លាបមានភារៈ កាយធ្ងន់ពេកហើរឡើងពុំរួច ក៏ធ្លាក់ទៅវិញក្នុងអណ្តូងនោះឯង ។ ដល់កាលជាខាងក្រោយ មានជនពីរនាក់ដទៃទៀត គឺពស់

មួយនឹងមនុស្សមួយ បានគេចទៅស្វែងរកទឹកផឹកក៏ធ្លាក់ចុះទៅក្នុងអណ្តូងទឹកនោះជាមួយ ឡើងពុំរួចឡើយ ។ ធម្មតាឯពស់តំងឡាយ បើបានទីស្ងាត់ទើបលះបង់អត្តភាពបាន (១) ព្រោះហេតុដូច្នោះ ពស់នោះពុំបានទីស្ងាត់ មិនអាចនឹងលះបង់អត្តភាពឡើងមកលើបានឡើយ ក៏សម្ងំនៅក្នុងអណ្តូងនោះឯង, ចំណែកឯមនុស្សសោតក៏ពុំបានវត្ថុអ្វីល្មមនឹងតោងឡើងបាន ក៏នៅសម្ងំក្នុងអណ្តូងនោះដែរ ។

ឯជនតំងបីនាក់នោះ កាលបើពុំអាចនឹងឡើងបានដូច្នោះហើយ ក៏មានសេចក្តីខ្លាចស្លាប់ពុំបានបៀតបៀនគ្នាទៅវិញទៅមកឡើយ នៅជ្រកក្នុងអណ្តូងតំងបីនាក់នោះឯង ។

ក្រោយពីនោះមក មានជនអ្នកសប្បុរសម្នាក់នៅក្នុងក្រុងពារាណសី បានដើរចូលទៅកាន់ព្រៃនោះ ដើម្បីស្វែងរកទឹកនឹងផឹកដែរ លុះបានដើរទៅដល់មាត់អណ្តូង ក៏បានឃើញជនតំងបីនាក់ដែលធ្លាក់នៅក្នុងអណ្តូងទឹកនោះហើយក៏មានចិត្តករុណាគតស្លុតញាប់ញ័រ បានយកវល្លិចងនឹងកញ្ជើធ្វើជាសៃជ្រកដាក់សំយុងចុះទៅក្នុងអណ្តូងបាន យោងស្រង់ជនតំងបីនាក់នោះឡើងដាក់លើមាត់អណ្តូងក្នុងកាលនោះឯង ។

១- លាក់បំពួនខ្លួន

(នៅមានត)

# មហោសថជាតក

(តមក)

លោក អ៊ឹម-គន ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស គឹម-តូរ ពិនិត្យ

---

រីអាចារ្យសេនកៈទូលថា បើអម្ចាស់យល់សប្តិហ្នឹង , ទើបស្តេចបន្ទូលវិញថា អើ! អញយល់សប្តិទៅ! អាចារ្យសេនកៈទូលឆ្លើយវិញថា បពិត្រព្រះបាទអម្ចាស់អើយ! បើអម្ចាស់យល់សប្តិដូច្នោះក្តី ចូរអម្ចាស់សំដែងថ្លែងប្រាប់មកយើងខ្ញុំឲ្យប្រាកដ ដោយទូលបទបរិយាយសប្តិនោះតើដូចម្តេចខ្លះ ៗ ប្រាប់ខ្ញុំឲ្យបានដឹងហោង ៗ រីព្រះបាទវិទេហរាជ ស្តេចស្តាប់ពាក្យអាចារ្យសេនកៈនោះហើយ ទើបស្តេចបន្ទូលប្រាប់អំពីសប្តិដូចការព្រះអង្គបានឃើញសព្វគ្រប់នោះហោង ៗ ក្នុងណានោះ អាចារ្យសេនកៈអ្នកប្រាជ្ញស្តាប់ព្រះបន្ទូលមហាក្សត្រហើយទូលវិញថា មហារាជ បពិត្រមហារាជអើយ! រីសប្តិនេះ កុំបីអម្ចាស់ព្រួយព្រះរាជហឫទ័យនឹងសប្តិនោះឡើយ , មហារាជអើយ! រីសប្តិនេះប្រសើរណាស់ហោង នឹងកើតជាមង្គលសួស្តីសិរីវុឌ្ឍិ ចំរើនអម្ចាស់ឲ្យថ្កុំថ្កើនរុងរឿង នោះសមនឹងមានពុំលែងឡើយ ៗ រីព្រះមហាក្សត្រាធិរាជ ស្តេចបន្ទូលវិញទៀតថា សេនកា ហៃអាចារ្យសេនកៈអើយ! រីព្រះស្តែងតាយថា សប្តិអញនេះ ប្រសើរជាមង្គលអំពល់ខ្លួ

ក្តីចំរើននោះ តើនឹងមានប្រការដូចម្តេចហ្ន៎? ។ ទើបអាចារ្យសេនកៈ ក្រាបថ្វាយបង្គំប្រណម្យទូលថា បពិត្រសម្តេចមហារាជអើយ! ដាបើ ដោយទំនាយខ្ញុំទាយនិមិត្តសុបិន្តនេះហើយ ថានឹងមានអ្នកប្រាជ្ញមួយវិញ ទៀតជាគំរប់ ៥ ទី អស់យើងខ្ញុំទាំង ៤ នេះមិនលៃលងឡើយ , បពិត្រមហារាជអើយ! អ្នកប្រាជ្ញនោះសោត កើតមកប្រកបល្អប្រសើរនូវក្តីចំរើន នៃអម្ចាស់ថ្លៃ ហើយតែនឹងផ្ចាញ់នូវអស់យើងខ្ញុំទាំង៤ នាក់ ជាអ្នកប្រាជ្ញ ព្រះអង្គនេះប្រាកដហោង អ្នកប្រាជ្ញនោះសោត នឹងធ្វើឲ្យអប្បយសនៃ អស់យើងខ្ញុំទាំង ៤ នេះឯងមិនលៃលងឡើយ , មហារាជអើយ! រីយើងខ្ញុំ ទាំង ៤ នេះ ឧបមាដូចភ្នក់ភ្លើងធំទាំង ៤ នោះហោង ។ អ្នកមួយ ឯងកើតមកវិញទៀត ដ៏ជាគំរប់ ៥ នោះ ឧបមាដូចភ្លើងតូចមួយនេះ កណ្តាលភ្នក់ភ្លើងធំទាំង ៤ នោះហោង , បពិត្រអម្ចាស់អើយ! អ្នកនោះ ឯងកើតឡើងកាលឯណាហើយ ជាប្រទីបពន្លឺនៃលោកផងទាំងពួងហោង អំពល់នូវអស់ទេវតា ឥតអ្នកឯណាមួយនឹងស្មើអ្នកនោះបានឡើយ, មហារាជអើយ! កុំបីអម្ចាស់គិតថប់បារម្ភឡើយ ។ ព្រះបាទវិទេហរាជមានព្រះបន្ទូលដណ្តឹងវិញទៀតថា សេណក ម្នាលអាចារ្យសេនកៈអើយ! អ្នកប្រាជ្ញមួយនោះ តើឥឡូវនេះនៅឋានឯណាហ្ន៎? ទើបអាចារ្យសេនកៈ ក្រាបទូលវិញថា បពិត្រមហារាជអើយ! ឥឡូវនេះសោត អ្នកប្រាជ្ញនោះមានកាលទើបមកចាប់យកបដិសន្ធិនៅក្នុងផ្ទៃម្តាយ មានកាល

ទើបប្រសូតចេញមកអំពីផ្លែស្វាយនោះហោង ។ កាលឥតព្រាំ គប្បីមានប្រាកដ ដូច្នេះឯងមិនលែងឡើយ ។ ព្រះមហាក្សត្រាព្រះអង្គស្តាប់ពាក្យអាចារ្យ សេនកៈតាមស្រាយទំនិមិត្តព្រះសុបិនថ្វៃមហាក្សត្រនោះ ប្រាកដហាក់ដូច បានយល់នឹងភ្នែកទិព្វការតា ល្មមយល់ដោយខ្លួនកំឡាំង ប្រាជ្ញាសិល្ប សាស្ត្រនៃព្រះអង្គនោះហោង ។ ម្ល៉ោះហើយចាប់ដើមអំពីនោះទៅ ស្តេចមានព្រះហឫទ័យនោះមមៃមមាញឹក តែងលើកទូវពាក្យអាចារ្យសេនកៈ ពុំក្ងរឡើយ ។

គ្រានោះមានស្រុកធំតាំង ៤ មួយឈ្មោះទក្ខិណយវមជ្ឈគ្រាម , មួយឈ្មោះបច្ចិមយវមជ្ឈគ្រាម, មួយឈ្មោះឧត្តរយវមជ្ឈគ្រាម, មួយឈ្មោះ បាចីនយវមជ្ឈគ្រាម ។ ស្រុកធំតាំង ៤ នោះឯង តែងជាក្តាព្រោះនគរ នោះហោង ។ ឯទីលែងស្រុកធំតាំង ៤ នោះ មានសេដ្ឋីជាធំ មួយ ៗ គ្រប់ស្រុក ជាក្តាព្រោះនគរនោះហោង ។ ស្រុកធំមួយនោះ មានសេដ្ឋីជាធំឈ្មោះសិរិវឌ្ឍកសេដ្ឋី , គាត់បិតនៅក្នុងស្រុកមួយឈ្មោះ បាចីនយវមជ្ឈគ្រាម ប្រពន្ធសេដ្ឋីនោះឈ្មោះនាង សុមនទេវី មាន ទ្រព្យសម្បត្តិច្រើន ហើយមានសេដ្ឋីមួយពាន់ ជាបរិវារសម្រាប់សិរិវឌ្ឍក-សេដ្ឋីនោះឯងហោង ។

កាលនោះរីពោធិសត្វមហាបុរសតែងវិសេសនៃយើងស្តេចធ្វើព្រះអធិ មុត្តកាលកិរិយាច្យុតចុះចាកពីភពត្រៃត្រឹង្សសួគ៌មកលោកនាយនោះ ព្រះអង្គ

មកចាប់បដិសន្ធិនៅក្នុងគភ៌ព្រះមាតុទេវបវរវង្ស នៃនាងសុមនទេវីនោះ ឯងហោង ។ រីអស់ទេវបុត្តឯទៀតក្រៅលែងអំពីពោធិសត្វនោះមួយពាន់សោត សឹងច្យុតចុះមកអំពីត្រៃត្រឹង្សសួគ៌ាល័យនោះមកយកបដិសន្ធិនៅក្នុងកំឡុងផ្ទៃនៃភរិយាសេដ្ឋីតូច-ធំផងទាំងឡាយ គ្រប់ទាំងមួយពាន់នោះហោង ។ រីនាងសុមនទេវីដ៏ជាព្រះកន្ទ្រាន់ផ្ទៃនៃពោធិសត្វនោះ នាងទ្រង់គភ៌បាន ១០ ខែគ្រប់បរិបូណ៌ពុំខ្វះឡើយ នាងប្រសូតកូនប្រុស ១ ដ៏មានពណ៌សម្បុរស្មើ នាររុងរឿងល្អ បីដូចមាសនព្វគុណទាំងអ្នកទៀងដ៏ល្អប្រពៃ ក្នុងអំណើះខែ ១០ នោះមិញបរិបូណ៌ហោង ។

បពិត្រអើយ ! ក្នុងកាលនោះ រីសម្តេចព្រះឥន្ទ្រាធិរាជ អ្នកទ្រង់ព្រះចិន្តាពិចារណា បើកទិព្វចក្ខុទាំងមួយពាន់ ស្ដេចទតពិតពិលមើលមកកាន់មនុស្សលោកនេះហើយ អ្នកជ្រាបសុភាពថាពោធិសត្វ ស្ដេចទើបចាកចេញអំពីព្រះទេវព្រះកន្ទ្រានោះហើយ អ្នកក៏ថា ទុបើដូច្នោះហើយ គួរគប្បីអញនឹងទៅបំពេញមហាបុរសរ័តន៍ដ៏ជាពន្ធុកព្រះពុទ្ធនោះឲ្យប្រាកដឥឡូវនេះបានអេះ ! ។ សម្ដេចព្រះឥន្ទ្រាធិរាជ អ្នកទ្រង់ព្រះចិន្តាពិចារណាទូវប្រការអំបាលនោះហើយ ពុំយូរឡើយ អ្នកហោះផ្ទោះចុះមកកាន់ពោធិសត្វ អ្នកសំដែងកាត្ថាកាឡាឲ្យយល់ប្រាកដហើយ ទើបអ្នកយកទឹកទៅនូវថ្នាំទិព្វមួយកំណាត់មកសំដែងទុកក្នុងកណ្ដាលបាតដៃនៃពោធិសត្វស្រេចហើយ ទើបសម្ដេចព្រះឥន្ទ្រាធិរាជ អ្នកហោះ

ស្មោះវិលទៅកាន់ឋានលំនៅអាត្មាទាំងពីរនៃព្រះត្រៃឫស្សីនោះវិញហោង ។ វីពោធិសត្វមហាបុរសរតនវិសេសថ្លៃនោះមិញ អ្នកកាន់យកនូវកំណាត់ថ្នាំទិព្វនោះខ្ជាប់នៅដៃហើយលីលាចេញអំពីព្រះទេវបរិមាតា ព្រះអគ្គសោត នាំបីហៅដាំទុកអង្ករដល់តិចនោះឥតអគ្គីមានឡើយ ហើយព្រះមហាសត្វ នាកាលអ្នកលីលាចាកចេញមកអំពីព្រះទេវបរិមាតានោះ សិងជាសុខសប្បាយប្រសើរពេក ទបមាប័ដ្ឋចទឹកហូរធ្លាក់ចេញអំពីធម្មក្រក ស្រក់ទៅលើក្រឡាមហាប្រឹថពីនោះមួយរំពេចហោង ។

រីនាងសុមនទេវីនោះសោត នាងមើលមើលយល់កំណាត់ថ្នាំទិព្វនៅដៃព្រះមហាសត្វនោះប្រាកដដូច្នោះហើយ នាងដណ្ដឹងសួរដូច្នេះថា ម្នាលកូនស្ងួនត្រកូលបណ្ឌិតបុត្រពន្លកអាសថ្លៃសំឡាញ់ម្ដាយអើយ បាបានអ្វីកាន់មកផងដូច្នេះ ចូរបាប្រាប់ម្ដាយឲ្យឆាប់ៗ ហោង ។ ទើបពោធិសត្វមហាបុរសរតន អ្នកប្រាប់ព្រះវរមាតាថា អម្ម បពិត្រអ្នកព្រះមេដ៏មានគុណធ្ងន់វិសេសអម្ចាស់ខ្ញុំអើយ ! នេះឯងហៅកំណាត់ថ្នាំទិព្វអម្ចាស់ ។ ព្រះមហាសត្វអ្នកប្រាប់ម្ដាយហើយ អ្នកហុចថ្នាំទិព្វនោះដាក់ទៅលើបាតដៃនៃព្រះមាតាហើយអ្នកប្រាប់ថា អម្ម បពិត្រព្រះមេអម្ចាស់ខ្ញុំអើយ ! រីឯថ្នាំទិព្វនេះ ថាបើអ្នកឯណាមួយមានជម្ងឺពេកពាធព្យាធិដាក់មកបៀតបៀនហើយ ក៏ចូរផ្ទុកមេឲ្យទៅ អ្នកដ៏មានជម្ងឺដ៏កាត់នោះដុសលាបហោង ។

សា មាជ្ជប្បមាជ្ជា សិរីវឌ្ឍកោ សេដ្ឋិនោ អាកោចេសិ ។ តស្ស បន សត្តវស្សិកោ សីសាតាពោ អត្ថិ ។ រីនាង សុមនទេវីនាងមានចិត្តត្រេកអរសាទរ ទទួលយកថ្នាំចិត្តនោះហើយ នាង ប្រាប់សិរីវឌ្ឍកសេដ្ឋីដ៏ជាប្ដី ដ្បិតមហាសេដ្ឋីជាអាពុកនោះឯង មានជម្ងឺ ឈឺក្បាលនោះអស់ ៧ ឆ្នាំហើយពុំស្បើយឡើយ ។ សិរីវឌ្ឍកសេដ្ឋីនោះ ស្ដាប់ឮហើយ មានចិត្តត្រេកអរសាទរមហិមាក្រៃ គិតថា ឱក្មេងកូន អញនេះប្រសើរពេកហោះ កើតចេញមកអំពីផ្ទៃម្ដាយមួយក៏អាចកាន់យក ថ្នាំចិត្តមកផង ហើយសឹងបានស្រដីមួយអន្ទើនឹងម្ដាយ និយាយឮដឹង កាលកើតមកនោះឯងហោង រីក្មេងកូនអញនេះសោត សឹងអ្នកមានបារមី ច្រើនមិនទេឡើយ ម្ល៉ោះហើយសិរីវឌ្ឍកសេដ្ឋីជាអាពុកនោះមិញ អ្នក ឲ្យយកថ្នាំចិត្តនោះមកដុសបន្ដក់លាយនឹងទឹក ហើយលាបព្រំដ៏បុសនោះ ហោង ។ រីជម្ងឺក្បាលសិរីវឌ្ឍកសេដ្ឋីដែលឈឺគំរប់ ៧ ឆ្នាំនោះមិញ សឹងថ្ងៃប្រមៀល ចាក់ចេញមួយរំពេច ដូចមាប់ដូចទឹកហៀរចេញ អំពីស្មុកល្អូកនោះហោង ។ រីមហាសេដ្ឋីនោះសោត មានចិត្តនោះ ត្រេកអរសាទរមហិមា ថា ថ្នាំចិត្តប្រសើរកូនអញនេះហើយ មានគុណ-ភាពពុតប្រាកដជាអស្ចារ្យគួរមាល្បាយហ្នះ ។ មហាសត្តស្ស ជាមកមហាណាទិវសេ បន មហាសេដ្ឋី ចិន្ដេសិ ។ បពិត្រអើយ! រីសម្ដីមនុស្សម្នាមហាជនទាំងឡាយ បានដឹងបានឮហើយ

សឹងស្រដីប្រាប់ទៅមកនូវគ្នាថា ម្នាលគ្នាយើងផងទាំងឡាយអើយ ។ ឥឡូវនេះឮថា កូនសិរីវឌ្ឍកសេដ្ឋី ប្រសូតចេញមកកាន់យកទាំងថ្នាំទិព្វមកផង ម្ល៉ោះហើយក៏បបួលគ្នាមករកសិរីវឌ្ឍកសេដ្ឋី ហើយមកសុំថ្នាំទិព្វនោះ ៗ ទើបមហាសេដ្ឋីយកថ្នាំនោះមកដុសខ្នែកលាយនឹងទឹកឲ្យទៅអ្នកដ៏មានអាពាធរោគាផងនោះលាប អស់ជម្ងឺអាពាធព្យាធិផងទាំងពួងនោះសោត សឹងម្នាប់បាត់ខាត់ចេញអំពីសរីរអាត្មាទីទៃ ៗ ដោយនូវតេជះតបៈអានុភាពថ្នាំទិព្វនោះបានស្បើយ នាកាលលាបលើខ្លួននោះហោង ៗ អស់មនុស្សម្នាមហាជនផងទាំងឡាយនោះ សឹងលុះនូវសុខប្រសើរពេក ហើយសឹងមានពាក្យនោះស្រដីសរសើរអឺងកងតែងថា នុថ្នាំទិព្វនេះហើយ យល់មានបារមីឫទ្ធិអានុភាពអំណាចឲ្យបានជាសុខសប្បាយនៃអស់យើងទីទៃ ៗ ប្រពៃក្រអូមល្ហាយហើយ អេះ ស្រដីសរសើរហើយ ក្រាបលាសិរីវឌ្ឍកសេដ្ឋីទៅកាន់ផ្ទះអាត្មាទីទៃ ៗ វិញហោង ៗ ឮកាលសម័យថ្ងៃទីសត្តនាមករនៃពោធិសត្វនោះសោត សិរីវឌ្ឍកសេដ្ឋីជាអាពុកនោះ មកគិតជញ្ជឹងថា នាកូនអញនេះ ជាអ្នកមានបុណ្យបារមីច្រើន ឥឡូវនេះ អញនឹងគិតឲ្យឈ្មោះដូចជាសារសន្ទានដីដូនដីតាអំពីបុរាណនោះយល់ពុំគួរឡើយ ថាបើដូច្នោះហើយ គួរគប្បីអញឲ្យឈ្មោះកូនអញនេះ ដោយនូវហេតុឈ្មោះថ្នាំទិព្វនោះ ក៏យល់ហាក់គាប់គួរពេបាង , អត្ថព្រះបាលីថា ឱសថ ៗ នេះ

បន្ទូលថា ថ្នាំទិព្វប្រសើរ ដោយហេតុនោះហោង, សិរីវឌ្ឍកសេដ្ឋី នោះ យកហេតុអត្ថព្រះបាលីថ្នាំទិព្វនោះឯង មកសន្មតកត់ព្រះនាម ករបវរចំរើនព្រះពោធិសត្វនោះឯង ហៅឈ្មោះថា មហោសថកុមារ អំពីថ្ងៃនោះទៅហោង ។

អថស្ស ឯតទហោសិ មម បុត្តោ មហាបុញ្ញោ ន ឯកាកោ និព្វត្តិស្សតិ ឥមិនា សទ្ធិំ ជាតទារកេហិ ច ភវិតព្វន្តិ ។ បពិត្រអើយ ! ក្នុងកាលនោះ រីតម្រិះចិត្តគំនិតនៃ សិរីវឌ្ឍកសេដ្ឋីនោះ គាត់គិតជញ្ជឹងរំពឹងយល់យោបល់ថា ទុចៅមហោ-សថបុត្រសំឡាញ់អញនេះ កើតមកយល់ហាក់មានបារមីបុណ្យអានុភាពបេ-ស្កា ជាត្រកាលអស្ចារ្យចំឡែកប្លែកខឹងគេម្ល៉េះ កើតមកតែម្នាក់ឯង កណ្ដាលកណ្ដាចអសារទេឬ ។ គប្បីមានក្មេងដទៃក្រៃលែងនេះ ក៏កើត មកផងច្រើន ព្រមមួយអន្ទើនឹងកូនអញនេះហោង ។ ទើបសិរីវឌ្ឍកសេដ្ឋី នោះ ប្រើអស់អ្នកផងទាំងឡាយឱ្យទៅមើលផ្ទះសេដ្ឋីផងទាំងមួយពាន់កើត ព្រមថ្ងៃមួយនឹងពោធិសត្វនោះឯងហោង ។ ទើបអស់អ្នកផងទាំងឡាយ វិលត្រឡប់មកប្រាប់មហាសេដ្ឋីនោះវិញ ។ ទើបសិរីវឌ្ឍកសេដ្ឋីនោះតែង ឱ្យធ្វើគ្រឿងប្រដាប់សម្រាប់ជាគ្រឿងប្រឡែងល្អប្រពៃ ឱ្យពោធិសត្វនោះ សឹងតែមាសពិចិត្រស្រេចហើយ ទើបប្រើឱ្យជូនទៅអស់គ្រប់ មន្ទិរក្មេងទាំង មួយពាន់នាំមកជាកំណាន់ តែងឱ្យបំរើចៅមហោសថកុមារជាសំឡាញ់ នៃអាត្មានោះ ។

(នៅមានត)

ផ្នែកអក្សរសាស្ត្រ

# រឿងមរណមាតា

(តមក)

លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រស្លឹករឹត

ព្រះឈុតព្រះនៅសម្រាប់ ព្រះពានប្រដាប់ ដំកល់ព្រះកន្និដ្ឋា ។ រៀបរួច
ឡើងទូលក្សត្រា ស្តេចហោយនុជា ក្រយាទិព្វទេសសកល ។ មន្ត្រី
សេនាបរិពល កោកាស្កប់ស្កល់ ហើយរៀបដំរីក្សត្រា ។ ផ្ទើរ
ដើរក្រុមមឿងសេនា ហែមុខក្សត្រា ជាស្រួចគ្រុងជង្គុំ ។ ទង់ជ័យ
លៃលប៉ល្បៀ នៅរេងគមជុំ ស្តាំឆ្វេងទង់ជ័យប្រយ័ត្ន ។ បេះគុណអា-
គមអាពត្ត រូបកងធំធាត់ ចិត្តមុតគន្ធគក្រៀវក្លា ។ ពាក់មួកក្បូរក្បាច់បេទា
ដាំក្បូនមុក្តា ដ័ក្តុំខ្ទាលភាក់ពន្ធ ។ ស្លៀកហូលជាយដរប៉ាជាំទ
សំងមាសកំណាត់ កំណាត់ប្រាំពាន់ថ្កុល់ថ្កើង ។ ក្រោយនោះពាហាន
តាំភ្លើង រៀបរៀងរុងរឿង គាកាន់កាំភ្លើងគ្រប់ដៃ ។ ក្រោយនោះពា-
ហានយនោម័យ សេះសោតស្ពុមស្តៃ គាកាន់ខ្ញូគ្រឿងគ្រប់ខ្លួន ។ រូប
កងឆាត់ធំម៉ាំមួន ក្រអើតក្រអួន ទ្រមើមសម្បើមសោះសា ។
ក្រោយនោះដំរួតគ្រួតគ្រា ខរទាចហានក្លា គាកាន់ពាត់ផ្គៅទឹក ។
បែកស្តាំឆ្វេងក្រោយមុខសឹក គ្រៀបគ្រានគឹក សន្ធឹកសន្ធាប់ស្កូរខ្ទាំង ។
ព្រះទំរង់គ្រប់ព្រះទីនាំង ព្រះកូស់បើកបាំង ត្រសុំត្រសាយខ្ពង់ខ្ពស់ ។

ក្រោយនោះព្រះពាទព្រះពស្ត្រ ព្រះសព្វសេ ព្រះកនិដ្ឋាមាលំ ៗ អមាត្យ
សេនាទីនាំង គេដង្រួសម្រាំង បង្គួបចំពោះមុខមួន ៗ ទីទាំងអស្សគជពួន
បង់គ្រឿងសមស្នួន សឹងមាសឡើលកាយា ៗ ទីនាំងរាជយានរថ បង
គ្រឿងសុវណ្ណា ទឹមសេះមង្គលជាតិធំ ៗ ភ្លេងដូងរងត្រើនធំ ត្រែស័ង្ខប្រគំ
សូរស័ព្ទរំពងពេញព្រៃ ៗ ស្ដេចចេញចាកតន្ទាជ័យ ពលពាសច្រើន
ក្រៃ គគ្រឹកគគ្រេងត្រៀបត្រា ៗ ចូលដល់មណ្ឌលព្រឹក្សា ព្រឹក្សព្រៃអញ្ជា
ស្រងូតស្រងាត់ឈឹងឈប់ ៗ ព្រឹក្សាទាំងមានគ្រប់ ស្រោងស្រឹងសឹង
មូប ប្រកបផលាបុប្ផា ៗ មង្ឃុតល្មុតសេដា ធុរេនខ្នុរ ពុទ្រា
ទន្លាប់ដូងត្រោះ ៗ ទ្រមូងទ្រមែងខ្វិតខ្វះ ខ្វិទុំក្រែលក្រាស់ ឡើងបេះ
ថ្វាយព្រះរាជា ៗ សព្វព្រាយក្អាកក្អាយមហិមា ក្រេមក្សាទទ័យា មនោរមាភិ.
រម្យ ៗ ព្រឹក្សាផលាតាសទុំ ផ្អែមដូចទឹកឃ្មុំ ភិនភេកបរិជោរជាប់មាត់ ៗ
ឈ្មុយឈ្មប់គ្រឿបពេកក្ដាត់ ពួកពលបរិស័ទ កំបេះកល់គ្នាគោក្ដា ៗ
ស្ដេចទតមើលម្រឹគត្រៀបត្រា ខ្ទីងខ្លាំងសូកក រមាសរមាំងប្រើសក្រោយ ៗ
ខ្លាខ្លាងទទេរ្យងទន្សាយ ពោលពែកប្រែប្រាយ ប្រឡងប្រដេញលេង
លោត ៗ ដំរីសារសេះគោគោត ព្រៃព្រះបក្សមួជ ចៀមរឹចៀមរកសិង្ហសីហ៍ ៗ
ព្រះបាទនរនាថធិបតី ស្ដេចទតបក្សី បក្សាហេរហើរទំ ៗ សារិកា
ហើរទៅក្រទុំ ទំហើយយាសយំ សំឡេងពីរោះគ្រលួច ៗ ត្រយង
កេងកងត្រៀលត្រួច យាសយំគ្រលួច ស្រងាត់ស្រងូតពេកពន់ ៗ
បក្សាគណនាច្រើនលន់ ទឹងរបក្ខតតន់ អនន្តអនេកក្រាស់ក្រៃ ៗ

ក្សត្រាកំសាន្តហឫទ័យ ប្រពាតព្រឹក្សព្រៃ លុះដល់បៀលសុរិយា ។
រៀនរៀបទេទៀបវេលា ស្ដេចយាងយាត្រា វិលទៅព្រះពន្លាជ័យ ។
សេនាយោធាក្រាស់ក្រៃ ហែក្សត្រវិលវៃ ចូលក្នុងទ័ពតាមព្រះពន្លា ។
ស្ដេចចុះចាកយានសុវណ្ណា សម្ដេចក្សត្រា ស្ដេចយាងព្រះបាទឆ្ពោះត្រង់ ។
ស្រះស្រីនាទីថ្វាយបង់ សេនាចតុរង្គ ហែស្ដេចចុះស្រង់គង្គា ។

## បទកុង្តលីលា

ដល់ស្រះសម្ដេចក្សត្រា ផ្លាស់ព្រះពស្ត្រា ទៅឆ្នេរស្រះស្រង់ ។ បុប្ផាលតាធំហ្វង់ ដើមដុះហោង់ លើព្រះគង្គា ។ មាលតីចំប៉ីចំប៉ា មិះរតមិះលា លំនិទ្ធមាហាង ។ ព្រះពាបដាំផាបត្រូវត្រង់ ផ្កាយផ្សព្វអប់អង្គ ព្រះបាទក្សត្រា ។ ស្ដេចយាងទតឆ្នេរជលសា ខ្សាច់សរថ្លា ដូចប្រាក់ក្លឹះ ។ ដងទឹកនៅឆ្នេរស្រះនោះ ក្លិនផ្កាប្រោងប្រុះ ដូចកែវថ្លាលា ។ ទតស្រះសម្ដេចកញ្ញា ចុះស្រង់គង្គា កំសាន្តព្រះទ័យ ។ ស្រះស្រង់កំពង់ប្រពៃ ប្រាំងទាបវិស័យ ដូចភគថាសដាក់ ។ មច្ឆាកេពួនពាក់ ពួនពីងទឹកកក់ ចឹកចាប់គោក្ដា ។ ក្រឹមក្រាញ់វៀលលេញត្រីខ្ញា ផ្លោះផ្លូកច្រាំ កំពឹស ក្រាងព្រាត ។ ទឹកជ្រៅមើលទៅថ្លាស្អាត ត្រីធំទនោង ហែលហាក់ហែក ។ ជៀបឆ្នោតីពោធជា កល់ពងថ្ងាមាំ ផ្កាប្រូប្រាព្រួល ។ ព្រះទ័យក្សត្រថ្លៃស្រស់ស្រួល ទ្រង់ព្រះសំរួលទៀនទតមច្ឆា ។ មន្ត្រីសេនីយសេនា ចុះងូតកល់គ្នា ហែក្សត្រថ្កើនថ្កានៗ ខ្លះបេះប្រឡេះផ្កាភ្នា នាំថ្វាយក្សត្រក្សាន្ត ស្ដេចទ្រង់បុប្ផា ។ ពួកពល

សាគលបរិវារ ហែលហក់ក្តាប់គ្នា សប្បាយសើចសាទ ៗ ប្រឡែង
ហែលលេងប្រពាន ប្រពួនឲ្យទ្រាន កាន់កាច់ប៉ុប្បា ៗ កញ្ច្រោកញោក
ផាបគន្ធា ស្ងួតស្ទួនទា រលបលេក ៗ សប្បាយខ្លួនខ្លាយទៅមក ខ្លះ
ហែលទៅរក បេះផ្កាសប្បាយ ៗ ក្រអៅឈូកទៅទុកថ្វាយ ស្តេច
សោយសប្បាយ កំសាន្តហឫទ័យ ៗ ខ្លះបេះកញ្ចុកពេញព្រៃ ត្រកួន
ច្រើនក្រៃ ចងបាច់រៀបទុក ៗ ធ្វើជាបន្ទែអន្ទូក ខ្លះហែលលុយលុក បេះ
បានផ្កាស្មោ ៗ ជ្រៀងជ្រើមជណ្តើមគ្នាទៅ ខ្លះលុកលុយទៅ ដកស្នាប
ប្រវ៉ាំ ៗ ខ្លះលោតបញ្ចោតមច្ឆា ចាប់បានត្រីប្រា អពេទប្រមាណ ៗ
សេនាយោធាក្សេមក្សាន្ត សប្បាយគ្រប់ប្រាណ បេះបរិភោគផល ៗ
បណ្តាបរិវារហ៊ោតការ ពាសពេញដោរដល រកក័ស្តុភោគ្គា ៗ សប្បាយ
រួសរាយរាល់គ្នា បេះបានផលា ឈូកខ្ញីបរិភោគ ៗ លេងលន់ពុំចង់
ឡើងគោក ករញ្ជៀវករញ្ជោក ពាសពេញគង្គា ៗ ស្រង់ស្រេចសម្តេច
រាជា ផ្លាស់ពារពស្ត្រ អាភរណ៍កាយ ៗ សេនាយោធាទាំងឡាយ
ហែក្សត្រពណ្ណរាយ ឡើងលើព្រះពន្លា ៗ

បទពំណោល

ពិសេសគ្រឿងទេសក្រយា លើកថ្វាយក្សត្រា ស្តេចសោយ
សប្បាយ ៗ មន្ត្រីសេនីយទាំងឡាយ គ្រប់ពួកគ្រប់នាយ នូវអស់បរិវារភោ
គ្គា ៗ រួចស្រេចសំរេចគិតការ គិតគូរគ្នាក់គារ កម្រួតត្រាត្រួតយាមយប់ ៗ

គយល្បាតសង្កាត់គ្នានឈប់ ក្តីនឹកទកល់យប់ ពុំខានសម្រាន្តមួយថ្ងៃ ។ ស្តេចតែងប្រកាតព្រឹក្សព្រៃ ចុះស្រង់ផលស័យ សព្វថ្ងៃអំលុងមាសា ។ គ្រៀមក្សាន្តពុំមានទុក្ខា ចតុរង្គសេនា ក៏សុខសប្បាយពេកក្រៃ ។ ស្តេចទតកំ-សាន្តហឫទ័យ ប្អូនថែក្សត្រថ្ងៃ ស្តេចវិលវិលវិញយាត្រា ។ ពលពង្ស ចតុរង្គសេនា ថែក្សត្រត្រៀបត្រា ក៏ផ្ទោះបាទពដបុរី ។ ជូនយប់ព្រលប់ កត្រី ក្សត្រក្សាន្តធិបតី បញ្ឈប់ពួកពលយោធា ទៀបដើមល្ហុសសុវណ្ណា ដែលនាងធីតា មរណមាតាដាំទុកៗ យោធាសេនាមាត្យមុខ-មន្ត្រីស្តុកស្តុក ក៏ៈបោះទ័ពកយជុំវិញ ។ រកនក្តីនក្តីចេ្តងពាសពេញ គយល្បាតជុំវិញ ចាំយាមប្រយ័ត្នក្សត្រថ្ងៃ ។ រវាតរវាមពេញព្រៃ គ្មាននរណាថៃ ទីងឃើញល្ហុសនោះសោះ ។ ស្តេចផ្ទុំសុខសមយប់នោះ ឥតមានមៃមោះ ក៏សុខកំសាន្តទ័យា ។

## បធព្រហ្មគតិ

រីយនេះស្ទុះទុកទី-ខានអំពីដើមព្រឹក្សា នាងមរណមាតា ប្រ-ណិប័តន៍សព្វទិនកត្រី ។ កាលនោះមានទេពតា នៅរក្សាឈើពិសី បាទយល់កុមារី ធ្វើពលិការសព្វវេលា ។ ទេពតាកុលកេសី ទីកប្រ-ណីបុត្រពុំងា តាំងពីម្តាយមរណា នាងលំបាកពីថ្ងៃនោះ ។ ដេរឃ្លាលគោសព្វថ្ងៃ ស្គមល្ហិតល្ហៃស្មើពុំរស់ ទេពតាគិតសង្គ្រោះ កូនកំសត់ឲ្យសប្បាយ ។ ឲ្យបានជាមហេសី ក្សត្រធិបតីរៀបសាយ គ្រង់សម្បត្តិទាំង

ខ្លាយ ឲ្យសម្រេចដូចប្រាថ្នា ។ ទេពតាយល់មហាក្សត្រ ផ្ទំស្ងប់ស្ងាត់ជិត ព្រឹក្សា កេសីទេពធីតា មានចិត្តត្រេកអរពេកក្រៃ ។ គិតថាបើក្សត្រ ក្សាន្ត គេងទៀងបានពាក់សុខស័យន៍ នឹងនាំចិត្តក្សត្រថ្ងៃ ឲ្យទតយល់ ដើមព្រឹក្សា ។ យល់ហើយឲ្យព្រះអង្គ កើតគិតសរសើរជាប់ស្នេហា ស្រ-ឡាញ់ដើមព្រឹក្សា នឹងសួរគេដល់នាងហោង ។ គិតហើយកុលកេសី ចរ ចេញពីព្រឹក្សាធំ ដំណើរដើរញ៉ែងញ៉ង ចូលជន្មក្សត្រប្រណាម ។ និពន នេះទៀងទេ គតិខ្សែមួយមកមាន ដំណើរពោលនិពន ពីនាងមរណ-មាតា ។ លំបាកគោកយ៉ាកយូរ ដោយគិតគូរជាប់វស្សា លុះដល់មហា ក្សត្រា ស្តេចផ្ទំជិតឈើតាំងសង ។ ដំណើរដំណាលមក លើកលៃលក ដូចវែងចង វែងចប់គ្រប់ចំនង ជាខ្សែពីរបរិបូណ៌បាន ។

មឧកាកាគតិ

នេះនិងនាំនិ.ពានគតិខ្សែពីរ ជាថ្ងៃវេលាយដាន កាលព្រះមហាក្សត្រ ចក្រពត្តិចេងថ្កាន ស្តេចផ្ទំសម្រាន្ត សម្រេចសុខស័យន៍ ។ ព្រះ បាទវិមល ធម្មកជើងកល់ បរមក្សត្រថ្ងៃ លង់លុះព្រឹកព្រាង ស្រេច ស្រានទុច័យ តើទៅពាក់សុខស័យន៍ ស្រែបក្រិត្រក្សត្រា ។ ស្តេចទតទៅ បូតិ យល់ឃើញកំនត្ត ល្អសសុវណ្ណ ទទួមត្រឹមត្រង់ លំពង់សាខា បុប្ផាផលា សឹងមសង្ខិនផ្កា ។ បរមក្សត្រា មានព្រះទ្រង់ការ មធុរក្រស ដណ្តឹងថាអើ ដើមឈើមាសផ្កា អមាត្យអើយទៅ ខឹងឈើនោណា ។

ប្តាំផុះឯង អមាត្យថ្វាថែង ស្នងព្រះឱង្ការ ពុំបោព្រះអង្គ ទ្រង់ព្រះ មេត្តា ពុំអាចដឹងជា នរណាដាំទុក ។ ស្ដេចត្រាស់ទៀតថា បើ ដូច្នោះណា ទៅសួរអ្នកស្រុក អមាត្យក្រាបលា យោធាទូវមុខ មន្ត្រី ចូលស្រុក ចូរសួរគ្រប់គ្នា ។ សឹងថាពុំដឹង ពុំមានដំណឹង ជាឈើនរ-ណា អមាត្យវិលមក ដើរកេសួរសា សួរក្មេងដែលរ៉ា ឃ្វាលគោ ប្រាប់ជាក់ ។ ថាឈើនេះណា មរណមាតា នាងដាំពីកត្តិ រក្សាសព្វ ថ្ងៃ ថែរួមរក្ស អមាត្យដឹងជាក់ ទៅទូលក្សត្រា ។ ស្ដេចប្រើទៅ យក កុមារីនោះមក អមាត្យម្នា ហៅក្មេងជូនទៅ លំនៅធីតា ដល់ ឃើញកុមារិកា នៅក្រោមម្លប់ឈើ ។ ក្មេងឃ្វាលគោថា មរណមាតា នៅនោះទេតើ អមាត្យដើរដល់ មណ្ឌលម្លប់ឈើ ឈប់ឈរគន់មើល រំពឹងគិតថា ។ អាសូរក្មួននេះ ក្រក្រីអើម៉្លេះ ក្មួនទៅនរណា ប្តូតគុម៉ែ សោះទេកំព្រា ជាំងញាតិកា គ្មានសោះស្រុកអាយ ។ មើលទៅខ្លួននោះ គ្មានឈួតប៉ិតដោះ ដៃឱបអង្គកាយ សំពត់រលែច ដាច់ដាចយ៉ាយ ប្រសិនមានក្តាយ មិនយ៉ាំងដូច្នេះ ។ អមាត្យរំពិត រំពើអាណិត ក្មួន ទ្រូងស្មើរប្រេះ ទុក្ខនរណា សាធារណ៍ដល់ម៉្លេះ មើលសព្វគួរវេះ គួរ រើអាណិត ។ គិតហើយស្តីថា ហៃនាងកុមារិកា នាងកុំតូចចិត្ត អា-ស្វរនាងណា នាងថាឲ្យពិត សព្វថ្ងៃនាងឥត ម៉ែឪរក្សា ។ ម្តងនាងក្រីក្រ កំដឹងកំដរ ទ្រព្យធននរណា នាងប្រាប់មកឥឡូវនេះធាប់ពី រឯកុមារិកា

ស្ដាប់ហើយស្រដី ៗ ប្រាប់ពីដើមដាន ដើមដែលសុខសាន្ត ជាកូន
សេដ្ឋី ដកបមកដល់ ទល់ទុក្ខក្រក្រី ប្រាប់តាំពីកាលី ញុះញង់បិតា ៗ
នាំម្ដាយនាងទៅ សម្លាប់ចោលទៅ គង្គានោះណា ប្រាប់គ្រប់នាង
យំ ក្រៀមក្រំភក្ត្រា អមាត្យសេនា សឹងយំអាណិត ៗ ស្រេចហើយ
ឆ្លើយថា ហៃនាងកុមារិកា នាងកុំព្រួយចិត្ត គ្រង់អាវសំពត់ ក្រខ្សត់
ភ័យភិត ទៀតហាក់លើកចិត្ត លើកពោលចេញទៅ ៗ ថាហើយរៀម
ផ្លាស់ សំពត់ចាស់ៗ យកផ្ទិនផ្ទៅ ហុចឲ្យនាងថា កុមារិកាមាសឪ
នាងស្លៀកឱនទៅ ឡើងគាល់ក្សត្រា ៗ ខ្ទះទឹកអាណិត ស្រាយ
ឈ្មួតពិចិត្រ ហុចទៅធីតា ខ្ទះឲ្យរាបកថ្មី ពណ៌ស៊ីចំប៉ា ខ្ទះឲ្យ
ក្រមា ទឹកអប់ល្អកលាប ៗ ឲ្យនាងរៀបស្អាង ផ្ទិតទឹកផុះលាង ក្លិន
ក្លាយឆ្អេះឆ្អាប ញើសក្អែបគក់ដី អាក្រក់ដកប ៗ ខ្ទះឲ្យប្រេងលាប
ជូននាក្លិនសាយ ៗ មហាណាមាតា ទទួលភក្ត្រា គ្រឿងទេសតាំង
ឡាយ នាងផ្ទិតទឹកលាង សាតសាងអង្គកាយ អង្គការៈឆើតឆាយ
ឆើតសព្វសព្វាង្គ ៗ ដូចទេព្វអប្សរ ល្អល្អះបវរ ឆោមឆាយរូបពង
ស្រេចហើយមន្ត្រី សេនីយយាសយាន បណ្ដើរនាំនាង ទៅថ្វាយ
ក្សត្រា ៗ ដល់ហើយនាំឡើង គាល់ក្សត្រកំជើន ឥស្សរសិរសា
ស្ដេចឃើញសព្វាង្គ នៃនាងកុមារិកា យល់តាមធាយា ប្រកបនលក្ខណ៍ ៗ

(នៅមានត)

# រឿងព្រេងរុស្ស៊ី

## ប្រែងអំពីវិទ្យាសាស្ត្រដ៏ប៉ិនប្រសប់

*ស.សាក ប្រែពីភាសាបារាំង*

---

កាលគន្លងទៅហើយ មានបុរសតានាក់ប្តីប្រពន្ធជាអ្នកកំសត់ទុគ៌តក្រៃលែង មានកូនប្រុសម្នាក់ ហើយចង់យកកូននោះទៅឲ្យរៀនវិជ្ជាផ្សេងៗ ដើម្បីឲ្យបានចេះដឹងទើបគេនឹងបានជាទីពឹងពំនាក់របស់គាត់ នៅពេលដែលគាត់ចាស់ជរាធ្វើការស៊ីពុំកើត ។ ប៉ុន្តែ បើគាត់ក្រម៉្លេះ គិតអ្វីនឹងបានកើតនឹងគេ ? ។ បុរសចាស់នាំកូនទៅភូមិមួយ ដើម្បីនឹងផ្ញើកូននឹងគេ ឲ្យគេជួយបង្រៀនធ្វើការ ។ ប៉ុន្តែ គ្មានអ្នកណាមួយសុខចិត្តទទួលបង្រៀនកូនគាត់ ដោយឥតយកថ្លៃឈ្នួលសោះ ។ តាចាស់នាំកូនត្រឡប់មកផ្ទះវិញ យំសោកនឹងប្រពន្ធដោយតូចចិត្តនឹងខ្លួនក្រ ។

ក្រោយបន្តិចមក បុរសចាស់នាំកូនទៅទីក្រុងមួយទៀត, ដល់ក្លាយគាត់ជួបនឹងមនុស្សម្នាក់ដែលគាត់មិនស្គាល់សោះ ។ បុរសនោះ សួរគាត់មុនថា:

—លោកតា! ចុះហេតុម្តេច ក៏លោកតាមានទឹកមុខស្រពោនម៉្លេះ? ។

—ចុះមិនព្រួយចិត្តម្តេចអ្នកអើយ! បើខ្ញុំនាំកូនទៅគ្រប់កន្លែងអស់ហើយ គ្មានអ្នកណាគេព្រមទទួលកូនខ្ញុំឲ្យទៅរៀនធ្វើការ ដោយឥតយកថ្លៃសោះ

ហើយសោតឯខ្ញុំក៏គ្មានប្រាក់កាសអ្វីបន្តិចផងដែរ ។

-បើអ៊ីចឹងលោកតាឲ្យកូនមកខ្ញុំ ខ្ញុំបង្រៀនកូនតាឲ្យចេះប៉ុនប្រសប់គ្រប់យ៉ាងក្នុងរវាង ៣ ឆ្នាំគត់ ។ ដល់គ្រប់ ៣ ឆ្នាំ តាចាំត្រឡប់មកទទួលកូនតាយកទៅវិញចុះ ប៉ុន្តែ ចូរតាប្រយ័ត្នកុំឲ្យខកពេល បើកាលណាតាមកចំពេលវេលា ហើយតាអាចស្គាល់កូនតាបាននោះ តាទើបអាចយកកូនតាទៅវិញ បើតាមិនស្គាល់កូនតាទេ កូនតាត្រូវនៅនឹងខ្ញុំរហូត ។

តាចាស់អរណាស់ ដោយគេបានទទួលកូនយកទៅបង្រៀន ភ្លេចសួរគេថា: តើគេនៅកន្លែងណា? គេបង្រៀនកូនឲ្យចេះអ្វីខ្លះទៅទៀត ។ គាត់ប្រគល់កូនឲ្យគេ ត្រឡប់មកផ្ទះវិញ ហើយនិយាយរឿងការប្រាប់ប្រពន្ធតាំងអក្រខិបក្រខុប ។

ឱពុទ្ធោអើយ ! បុរសដែលទទួលកូនគាត់នោះ ជាមេធ្មប់ ។

ឆ្នាំ ៣ ក៏ចូលមកដល់ ។ តាចាស់ភ្លេចមិនដឹងថាដល់ថ្ងៃណាទើបត្រូវទៅទទួលយកកូនមកវិញ មិនដឹងជាពេលដែលត្រូវទទួលកូននោះ ត្រូវជាម៉ោងប៉ុន្មាន ម្ល៉ោះហើយ គាត់ចេះតែអន្ទះអន្ទែងព្រាស់ព្រាល់ៗ ប៉ុន្តែ កូនរបស់គាត់ដឹងថា «ថ្ងៃស្អែកនេះ ឪពុកអញនឹងមកទទួលយកអញទៅវិញ» ក៏ជំនែងខ្លួនជាសត្វបក្សីមួយ ហើរត្រឡប់មកផ្ទះ ទៅទន្ទិចខ្លួននឹងពំនូកដីនៅក្បែរផ្ទះ ក៏ប្រែរូបជាប្រុសកំលោះមួយយ៉ាងស្អាតចូលទៅសំពះស្ន

គា ពាស់ជាឪពុកថា:-

ពុក! ស្អែកនេះគ្រប់ ៣ ឆ្នាំហើយ សូមពុកអញ្ជើញទៅទទួលយកខ្ញុំកុំឲ្យហួសពេល ។

ឪពុកសួរថា ឯងឲ្យអញទៅត្រង់កន្លែងណា ហើយនឹងត្រូវចំណាំដូចម្តេចដើម្បីឲ្យស្គាល់ឯង ។

-ពុក! ខ្ញុំមិនមែនតែម្នាក់ឯងទេ ដែលទៅធ្វើជាសិស្សលោកគ្រូនោះ មានសិស្ស១១នាក់ទៀត ដែលឪពុកពុំចំណាំមិនបាន ហើយត្រូវនៅជាមួយនឹងលោកគ្រូនោះរហូត ឯខ្លួនខ្ញុំនេះ ពុកក៏ចំណាំមិនបានដែរ ខ្ញុំមុខជាត្រូវនៅជាមួយលោកគ្រូទៀតគំរប់ជា១២នាក់ ប៉ុន្តែព្រឹកស្អែកនេះ កាលណាពុកទៅទទួលខ្ញុំ លោកគ្រូមុខជាឲ្យកូនសិស្សគាត់ចេញមកទាំង១២នាក់ ដោយប្រែខ្លួនជាព្រាបស មានរោមស្លាបសម្បុរដូចគ្នា តាំងពីក្បាលរហូតដល់កន្ទុយ លោកគ្រូឲ្យហើរយ៉ាងខ្ពស់ហើយគាត់ឲ្យពុកចង្អុលថា ព្រាបណាជាកូនរបស់ពុក នោះសុំពុកចំណាំឲ្យច្បាស់ ព្រាបទាំងអស់ហើរខ្ពស់ៗណាស់ ប៉ុន្តែយូរៗ ខ្ញុំហើរខ្ពស់ជាងគេម្តង បើកាលណាលោកគ្រូសួរពុកថា តាស្គាល់កូនតាបានទេ សូមពុកចង្អុលភ្លាមចំពោះព្រាបណាដែលហើរខ្ពស់ជាងគេទៅ ។

តមកទៀត គាត់បញ្ចេញកូនសេះ១២សម្បុរដូចៗគ្នា បើកាលណាពុកដើរទៅជិតសេះនោះ សូមពុកគន់មើលឲ្យមែនទែន សេះទាំង

អស់ឈរស្ងៀម, ប៉ុន្តែខ្ញុំយូរៗគោះជើងស្តាំម្តង ។ លោកគ្រូខ្ញុំទើបសួរពុកថា:

តាស្គាល់កូនតាបានឬទេ ? ។ សូមពុកចង្អុលខ្ញុំភ្លាមកុំបង្អង់ ។

តមកទៀត លោកគ្រូខ្ញុំគាត់បង្ហាញកម្លោះ១២នាក់ទៀត ។ កម្លោះនេះមានមុខ មាត់ សក់ ភ្នែក ច្រមុះ សំលៀកបំពាក់ដូចៗគ្នា បើកាលណាពុកដើរទៅជិតកម្លោះទាំងនោះ សូមពុកពិនិត្យឲ្យមែនទែន ចំពោះរូបខ្ញុំបន្តិចមកមានរុយទំពាល់ម្តង បើពុកឃើញដូច្នេះ ពុកកុំសង្ស័យប្រាកដជារូបកូនហើយ ។

លុះផ្តាំឪពុកសព្វគ្រប់ហើយ កូនក៏លាឪពុកចេញទៅរង្គិចខ្លួនទឹងពិន្ទុកដី ក្លាយខ្លួនទៅជាបក្សី ហើរវិលទៅកាន់សំណាក់គ្រូខ្លួនវិញ ។

ព្រឹកឡើង តាចាស់ក្រោកពីព្រលឹម ចេញដំណើរទៅទទួលកូនហើយដើរមកដល់ផ្ទះមេធ្មប់ ។

មេធ្មប់ប្រាប់ថា តា! កូនតា ខ្ញុំបានបង្រៀនឲ្យប៉ិនប្រសប់គ្រប់យ៉ាង ប៉ុន្តែបើតាមិនស្គាល់កូនតាទេ កូនតាត្រូវនៅជាមួយខ្ញុំរហូតទៅ, ថាដូច្នោះហើយ មេធ្មប់ក៏បញ្ចេញព្រាបសទាំង១២ឲ្យហើរចេញមក ហើយសួរថា:

-តាស្គាល់ទេ ណាមួយជាកូនរបស់តា !

-ស្គាល់ម្តេចបាន បើព្រាបដូចគ្នាយ៉ាងនេះ (តាឆ្លើយ) ។

តាចាស់ខំសំឡឹងមើលយូរណាស់ បន្តិចមកគាត់ឃើញព្រាបមួយហើរខ្ពស់ជាងគេ គាត់ចង្អុលភ្លាមថា :

ហ៊ឹងហើយកូនខ្ញុំ ។

-តាអាចស្គាល់បាន ល្អហើយតា (មេធ្មប់និយាយ) ។

បន្ទាប់មកទៀត មេធ្មប់បញ្ចេញកូនសេះ១២ដូចគ្នា តាំងពីសម្បុរ រោម រូបរាង សក់បាក់ទៅទាំងខ្លួន ។

តាចាស់ខំដើរសង្កេតសេះទាំង១២ ពីសេះមួយ ទៅសេះមួយ ។

មេធ្មប់សួរថា :

-ម៉េចតា ណាមួយជាកូនតា ? ។

-មិនទាន់ស្គាល់ទេ (តាឆ្លើយ) ដល់គាត់ឃើញកូនសេះមួយគោះជើង ស្ដាំតុប គាត់ចង្អុលភ្លាមថា :

-នេះជាកូនខ្ញុំហើយមើលទៅ ។

ល្អតា តាអាចស្គាល់បានមែន (មេធ្មប់និយាយ) ។

បន្ទាប់មកទៀត មេធ្មប់បញ្ចេញកម្លោះ១២នាក់មកទៀត មានរូប រាង សម្បុរ សក់ សម្លេង មុខ មាត់ដូចគ្នាទាំងអស់ ដូចជារូបតែមួយ ។

តាចាស់ដើរសង្កេតកម្លោះទាំង ១២ នាក់ មួយលើកជាពីរលើក គ្មាន ឃើញអ្វីអាចសំគាល់បានសោះ ដល់គាត់ដើរមើលម្ដងទៀតជាលើកទីបី គាត់ឃើញរុយមួយទំថ្ពាល់ស្ដាំ គាត់ចង្អុលភ្លាមថា:

–នេះហើយជាកូនខ្ញុំ

-ល្អហើយតា តាសំគាល់កូនតាបាន, ប៉ុន្តែ មិនមែនតាទេដែលប៉ុន

ប្រសប់តែកូនតាទេដែលឆ្លាត ។

តាចាស់ក៏នាំកូនមកទីលំនៅវិញ ។ តាមផ្លូវ តានិងកូនជួបនឹងពួកអ្នកប្រដេញសត្វព្រៃ កំពុងដេញកញ្ជ្រោងមួយយ៉ាងស្វិត ។

កូននិយាយទៅនឹងឪពុកថា ពុក! ខ្ញុំប្រែខ្លួនជាឆ្កែដើម្បីនឹងទៅចាប់យកកញ្ជ្រោងនោះ បើកាលណាពួកអ្នកប្រដេញ មកដណ្ដើមយកសត្វ សូមពុកឆ្លើយថា:

លោកអ្នកព្រាន! ឆ្កែនេះជាឆ្កែរបស់ខ្ញុំ ហើយវាតែងចិញ្ចឹមខ្ញុំ ដោយសារការប្រដេញរបស់វា ឮដូច្នោះ មុខជាពួកប្រដេញសួរទិញខ្ញុំដោយឲ្យតម្លៃជាប្រាក់ច្រើន ពុកលក់ខ្ញុំឲ្យគេចុះ ប៉ុន្តែគេឲ្យអ្វីក៏ដោយសូមពុកកុំលក់ប្រទៀកនឹងខ្សែឲ្យគេឲ្យសោះ ។

ជាតែប៉ុណ្ណោះ កូនតាក៏ក្លាយខ្លួនជាឆ្កែដេញតាមកញ្ជ្រោងទាន់ហើយនាំពាំវាមកលំនៅឪពុក ។ ពេលនោះពួកប្រមាញ់មកគ្រាម ហើយសួរថា:

ហ៎ តា! ម្ដេចក៏ដណ្ដើមយកសត្វរបស់យើង

–ឆ្កែនេះ ជាឆ្កែរបស់ខ្ញុំទេលោក! ខ្ញុំរស់ដោយសារវាទេតើ!

(តាឆ្លើយ) ។

លក់ឆ្កែហ្នឹងឲ្យយើងមក (ពួកព្រាននិយាយ)។

មានតើលោក!

ថ្លៃណាស់ទៅឬ?

មួយរយប្យើស៍ (១) ។

អ្នកប្រដេញមិនបាច់តថ្លៃ រាប់ប្រាក់ឲ្យតាហើយនាំឆ្កែយកទៅ ។

តាចាស់ដោះប្រឡៅទឹងខ្សែទុក ។

ពួកព្រានសួរថា ចុះតាយកប្រឡៅទឹងខ្សែធ្វើអ្វី? ។

លោកអើយ! ខ្ញុំយកបន្លាក្រងខ្សែស្បែកជើងខ្ញុំដាច់ គ្រាន់ទឹងចងវិញ ។

បើដូច្នោះយកទៅចុះ (ពួកព្រាននិយាយ) ។

អ្នកប្រដេញបត្តូរយកខ្សែរបស់ខ្លួនចងឆ្កែបណ្ដើរទៅ ។ យូរបន្តិចមក បានឃើញកញ្ជ្រោងមួយក៏លែងឆ្កែវាស់ឲ្យដេញកញ្ជ្រោង ប៉ុន្តែឆ្កែចាស់នោះចាប់កញ្ជ្រោងមិនបានសោះ ។

អ្នកប្រដេញម្នាក់ និយាយថា:

- យើងលែងឆ្កែថ្មីយើងទៅមើល! ។

គ្រាន់តែលែងភ្លាម ឆ្កែនោះបោលយ៉ាងលឿនបាត់មួយរំពេច ។ ប៉ុន្តែឆ្កែទៅផ្លូវមួយ កញ្ជ្រោងទៅផ្លូវមួយ ។ ឆ្កែនោះត្រឡប់មកកន្ទុក ខ្ទិចខ្លួនទឹងដីក្លាយទៅជាមនុស្សដូចដើមវិញ ។ ទើបតាទឹងកូននាំគ្នាដើរទៅទៀត ។ ដើរទៅដល់មាត់បឹងមួយ ឃើញពួកអ្នកនេសាទកំពុងតែពាក់

(១) រូបិយវត្ថុស្មើ ។

ក្ងានព្រៃ ទាព្រៃ និងបក្សីផ្សេងៗ ។ នៅពេលនោះមានទាព្រៃមួយហ្វូង ហើរកាត់លើក្បាលអ្នកទាំងពីរ ។ កូននិយាយទៅកាន់ឪពុកថា:

–ពុក! ខ្ញុំដំណែងខ្លួនទៅជាប្រមង់ទៅចាប់ទាព្រៃនោះ ។ ឃើញដូច្នោះ មុខជាពួកអ្នកនេសាទមកសួរពុកទៀតហើយ ពុកត្រូវឆ្លើយដូចមុនថា ប្រមង់នេះជារបស់ខ្ញុំ វាតែងចាប់សត្វមកចិញ្ចឹមខ្ញុំគ្រប់ពេលវេលា បើកាលណាគេសួរទិញ ពុកលក់ខ្ញុំឲ្យគេទៅតែកុំឲ្យខ្សែចងឲ្យសោះ ទោះជាគេឲ្យប៉ុន្មានក៏ដោយ ។

ថាហើយកូនតាក្លែងខ្លួនជាប្រមង់ភ្លាម ហើរសំដៅទៅហ្វូងទាព្រៃចឹកទាព្រៃទម្លាក់មកដីឲ្យតា ។ តារើសប្រមូលមកគរទុក ។ ពួកអ្នកនេសាទឃើញតាបានសត្វច្រើនរត់មកសួរថា :

– ហ៊ោ ! តាម្តេចក៏តាមកដណ្តើមយកសត្វរបស់យើង ? ។

ទេលោក ! ប្រមង់នេះជាសត្វរបស់ខ្ញុំចិញ្ចឹម ហើយវាតែងចាប់សត្វមកចិញ្ចឹមខ្ញុំទេតើ ! ។

– តាសុខចិត្តលក់ប្រមង់ឲ្យខ្ញុំទេ ?

– ខ្ញុំលក់

– ថ្លៃណាស់ទៅឬ?

– តែពីររយប៊ីស៍

ពួកអ្នកនេសាទរាប់ប្រាក់ឲ្យតា ចាប់យកសត្វប្រមង់ទៅ ។ តាក៏ដោះយកខ្សែចងជើងមកវិញ ។

-តា ! ចុះខ្សែចងជើងនេះ ថ្លៃប៉ុន្មានទៅ ក៏បានជាតាដោះវិញ ? ។

-លោកអើយ ! ខ្ញុំដើរផ្លូវឆ្ងាយ ក្រែងលោដាច់ខ្សែស្បែកជើងតាមផ្លូវមានខ្សែនេះគ្រាន់នឹងចង ។

អ្នកនេសាទមិនថាអ្វី សុខចិត្តឲ្យតាដោះយកខ្សែ ហើយយកសត្វប្រមង់នោះទៅ ។ ដើរឆ្ងាយទៅៗឃើញទាព្រៃមួយហ្វូងទៀត អ្នកនេសាទលែងប្រមង់ឲ្យហើរទៅចឹកទាព្រៃដូចមុន ប៉ុន្តែប្រមង់ហើរខ្ពស់ជាងទាព្រៃទៅទៀត ហើយត្រឡប់វិលមករកតាជាឪពុកវិញ ប្រែខ្លួនទៅជាមនុស្សដូចដើម ហើយក៏នាំគ្នាដើរទៅកាន់ផ្ទះនៅជាសុខ ។

ពេលមួយជាថ្ងៃអាទិត្យកូននិយាយទៅឪពុកថា :

-ពុក ! ខ្ញុំចង់ជំរែណងខ្លួនធ្វើជាសេះ ពុកយកខ្ញុំទៅលក់ ប៉ុន្តែកុំលក់ទាំងបង្ហៀរ តែលក់ទាំងបង្ហៀរខ្ញុំលែងត្រឡប់វិញបានហើយ ។ ថាហើយ កូនតាទៅទង្គិចខ្លួននឹងដី ក្លាយទៅជាសេះមួយល្អចំណាប់ តាក៏ដឹកសេះទៅលក់ឯផ្សារ ។ អ្នកទិញសេះហាមតែតថ្លៃគាត់ ប៉ុន្តែបណ្តាអ្នកទិញទាំងអស់មេធ្មប់ហ៊ានថ្លៃជាងគេ តាចាស់ក៏លក់សេះ ប៉ុន្តែគាត់ដោះយកបង្ហៀរទុក

មេធ្មប់និយាយនឹងតានោះថា ចុះឲ្យខ្ញុំនាំសេះម្តេចបាន បើតាដោះយកបង្ហៀរហើយ ឲ្យខ្ញុំមកសិនចាំខ្ញុំដឹកដល់ក្នុងភូមិខ្ញុំ ហើយសឹមតាយកទៅវិញចុះ ខ្ញុំក៏ឥតត្រូវការដែរ ។

ពេលនោះ ពួកអ្នកលក់សេះដូចគ្នាស្តីឲ្យតាថា :

ហ៊ា តា ! មានច្បាប់ពីណាលក់សេះហើយមិនលក់បង្ហៀរ តែលក់សេះ គឺថាលក់ទាំងបង្ហៀរផងហើយ ។

លុះឃើញគេបោមពេមថា ឲ្យគាត់ច្រើនពេក តាមិនដឹងគិតដូចម្តេចក៏ឲ្យបង្ហៀរទៅ ។ មេធ្មប់នាំសេះទៅដល់ផ្ទះ យកទៅដាក់ក្នុងរោងចងសេះ ឲ្យឈរតែជើងពីរខាងក្រោយជាប់នឹងដី ជើងពីរមុខចង់ផុតពីដី ។

តមកមេធ្មប់និយាយនឹងកូនស្រីថា:

— កូនអើយ! ឪពុកទិញបានអាក្មេងខូចពីមុននោះមកវិញហើយ ។

— វានៅឯណាពុក?

— វានៅក្នុងក្រោល ។

កូនស្រីមេធ្មប់ចូលទៅមើលឃើញសេះព្យួរជើងដូច្នោះ នាងទឹកអាណិត ក៏ទៅស្រាយខ្សែបន្ធូរ ។ ប៉ុន្តែនៅពេលដែលនាងទាញខ្សែចេញពីក្រវិលដែក សេះនោះបេះតែគ្រវីក្បាលទាល់តែរបូតចេញពីចំណង ហើយក៏បោលភឹងចេញពីក្រោលទៅ ។ កូនស្រីភ័យណាស់រត់ទៅប្រាប់ឪពុកថា ។

ពុកអើយ ! សេះរួចទៅហើយ ខ្ញុំសុំទោស ខ្ញុំខុសហើយ !

ពុកភ្លាម មេធ្មប់បោកខ្លួនទៅនឹងដី ក្លាយខ្លួនជាចចកប្រផេះរត់ដេញតាមសេះ ដល់រៀបនឹងទាន់ខាំសេះបាន សេះបោកខ្លួនទៅនឹងដី ក្លាយ

ជាសត្វកង្កែបលោតចូលក្នុងទឹកទន្លេភ្លាម ។ មេធ្មប់ដំណែងខ្លួនជាត្រីមួយយ៉ាងធំ លោតចូលទៅដេញត្របាក់កង្កែបៗហែលទៅឃើញស្រីម្នាក់កំពុងបោកខោអាវ ក៏តំណែងខ្លួនធ្វើជាចិញ្ចៀនរត់ចូលទៅទីងដៃនាងបោកខោអាវ ។ មេធ្មប់ប្រែខ្លួនជាមនុស្សដូចដើមវិញ ហើយនិយាយទៅនាងបោកខោអាវថា :

— ឲ្យចិញ្ចៀនមាសមកខ្ញុំវិញ ។

យកទៅ ! (នាងបោកខោអាវនិយាយ) ហើយគ្រវាត់ចិញ្ចៀនទៅដី ប៉ុន្តែ គ្រាន់តែធ្លាក់ដល់ដីភ្លាម ចិញ្ចៀនក៏ធ្លាក់ក្លាយទៅជាត្បូងល្អិតខ្ចាត់ខ្ចាយពេញដី ។ ពេលនោះមេធ្មប់ដំណែងខ្លួនធ្វើជាមាន់គកចឹកលេបត្បូងនោះ ។ មានត្បូងមួយគ្រាប់ទៀតក្លាយទៅជាសត្វប្រមង់ចឹកមាន់គក ដែលកំពុងតែលេបត្បូងនោះស្លាប់មួយរំពេចទៅ ។ ស្រេចហើយប្រមង់ធ្វើខ្លួនទៅជាបុរសកំលោះដូចដើមវិញ ឃើញនាងបោកខោអាវល្អមានចិត្តស្រឡាញ់ក៏ដណ្ដឹង រៀបការពាហ៍ពិពាហ៍ជាមួយនឹងនាងនោះ នៅជាសុខសប្បាយតទៅ ។

---

# សត្រូវរបស់ខ្ញុំ

លោក ប៉ូ - ប៉ូ រៀបរៀង

---

សត្រូវទាំងអស់ មានចោរកំណាច ខ្លា ដំរីសាហាវជាដើម ខ្ញុំមិនសូវជាខ្លាចប៉ុន្មានទេ ព្រោះថា ខ្ញុំអាចនឹងគេចវេះពីចោរ, ពីខ្លា, ពីដំរីបាន ។ ឯសត្រូវដែលខ្ញុំខ្លាចយ៉ាងខ្លាំងបំផុតនោះ គឺជម្ងឺរោគាព្យាធិដែលកើតមាននៅក្នុងខ្លួនរបស់ខ្ញុំ ជាសត្រូវមានកម្លាំងខ្លាំងក្លាបំផុតលើសចោរ, ខ្លា, ដំរី, ទៅទៀត ព្រោះថា បើឈឺដៃ-ជើង ឬធ្មេញ ខ្ញុំមិនដឹងជានឹងគេចវេះទៅឯណា ឲ្យផុតពីដៃជើងនឹងធ្មេញរបស់ខ្ញុំដែលកំពុងតែឈឺចាប់ពេកនោះទេ ។ ហេតុនេះ បានជាព្រះពុទ្ធទ្រង់សំដែងប្រាប់ថា « គ្មានសត្រូវឯណាកាចស្មើនឹងជម្ងឺឈឺចាប់ទេ (នត្ថិ ព្យាធិសមារ៉េយា ធ.ខុ.) ” ។

ប៉ុន្តែ បណ្តាជម្ងឺរោគាព្យាធិទាំងអស់ ដែលខ្ញុំខ្លាចណាស់នោះ គង់នៅមានគ្រូពេទ្យដាក់ថ្នាំថែរក្សាឲ្យសះជាទៅបានខ្លះ ។ ចំណែករោគម្យ៉ាងទៀត ដែលមានក្នុងខ្លួនខ្ញុំ តាំងពីកើតមករហូតដល់ចាស់ជរាជិតស្លាប់ទៅហើយនោះ គ្មានគ្រូពេទ្យណាមើលជាសោះ សូម្បីគ្រាន់តែដាក់ថ្នាំថែរក្សាឲ្យអន់ស្រាល ឲ្យស្រាកស្រាន្តក៏គ្មានដែរ ។ រោគនេះ បេះតែឈឺចាប់ពេកខ្លាំងឡើង ចំរើនឡើងតាមវ័យតាមអាយុ ។ មនុស្សគ្រប់រូបទាំងគេ ទាំងខ្លួនខ្ញុំ កើតរោគម្យ៉ាងនេះ គ្មានខ្វះម្នាក់ទេ

ហើយទាំងគេ ទាំងខ្ញុំ សុទ្ធតែភ្លេចខ្លួនធ្វេសប្រហែសនឹងរោគនេះ មិនដឹងថា រោគនេះកើតកើនចំរើនទៅក្នុងខ្លួនតាំងពីក្មេងរហូតដល់ចាស់ជរាផង, ម្ល៉ោះហើយពុំបានរកគ្រូពេទ្យដាក់ថ្នាំបន្ថយកម្លាំងរោគនេះសោះ ។ បើសង្កេតឲ្យល្អិតល្អន់ទៅ ឃើញថា ទាំងគេ ទាំងខ្ញុំ សុទ្ធតែចំប្រឹងស្វែងរកគ្រូពេទ្យ ឬរកថ្នាំ រកមន្តអាគមគាថា ចំណេះវិជ្ជា ធ្វើឲ្យរោគនេះមានកម្លាំងខ្លាំងក្លាលើសដើម ។

ចុះរោគម្យ៉ាងនោះតើជាអ្វី ?

សេចក្ដីស្រេកឃ្លាន គឺជារោគម្យ៉ាង ដែលជារោគចម្លែកអស្ចារ្យ មិនដែលមានគ្រូពេទ្យណាមើលជាសោះ លើសរោគនានា ។

ដូចអតីតនិទានមួយថាៈ កាលពីព្រេងនាយ កូនសិស្សរបស់អាចារ្យទិសាបាមោក្ខប្រាំរយនាក់ នាំគ្នាចូលទៅរកកាប់អុសក្នុងព្រៃភ្នំ ។ បណ្ដាសិស្សទាំងប្រាំរយនោះ មានសិស្សម្នាក់ជាច្បងគេ ចេះមន្តអាគម-គាថាខ្លាំងពូកែជាងគេ និយាយប្រាប់សិស្សដទៃថា អ្នកពល់គ្នាចង់ដឹងឫទ្ធិខ្ញុំទេ ខ្ញុំសូត្រមន្តហៅឲ្យភ្លៀងធ្លាក់ពីអាកាសមកបានហើយភ្លៀងនោះមិនមែនជាទឹកទេ សុទ្ធតែជាដុំមាសដុំប្រាក់ ។ សិស្សទាំងពួងឆ្លើយថា យើងមិនជឿទេ ។

សិស្សជាច្បងប្រាប់ថា "អើ! បើអ្នកទាំងអស់មិនជឿទេ ចូរនៅ

ឲ្យស្ងៀមស្ងាត់ ចាំមើលមួយស្របក់ទៀត នឹងឃើញភ្លៀងបង្អុរចុះពីអាកាសមិនខាន" ថារួច ក៏ចូលទៅអង្គុយក្រោមម្លប់ឈើមួយដើម សំឡឹងមើលទៅឯអាកាស សូត្រសែកមន្តអាគមគាថារអ៊ូ , មួយស្របក់ក្រោយមក ទឹកភ្លៀងធ្លាក់ពីអាកាសទទឹកជោកដី, សិស្សដទៃរត់ជ្រកខ្លាចទទឹកខ្លួន បន្ទាប់ពីនោះ ស្រាប់តែដុំមាសដុំប្រាក់តូចខ្លះ ធំខ្លះធ្លាក់មកពេញទីស្រអំពកតូចមួយ ជិតសិស្សអ្នកកាយមន្តនោះ ។

សិស្សទាំងអស់គាត់ស្ញើចសរសើរឫទ្ធិរបស់សិស្សជាច្បង ហើយនាំគ្នារើសយកដុំមាសប្រាក់តិចខ្លះច្រើនខ្លះ រៀបស្ពាយរួចដើរចូលទៅភូមិលំនៅខ្លួនវិញ ។

អស់លោកអ្នកអានទាំងឡាយ ! ដល់ត្រង់នេះ ប្រហែលជាអស់លោក-អ្នក នឹងគាត់ស្ញើចសរសើរពុំខាន រីសិស្សទាំងនោះថាបានមាសប្រាក់ងាយៗ មិនបាច់ស្វែងរកប៉ុន្មានទេ ។ តែគំនិតអស់លោក-អ្នកនោះ បែរជាផ្ទុយស្រឡះទៅវិញ ព្រោះសិស្សទាំងនោះកាលមិនទាន់បានមាសប្រាក់ មានចិត្តមេត្រីស្មោះស្ម័គ្រនឹងគ្នាជាធ្លុងមួយ លុះបានមាសប្រាក់គ្រប់គ្នាហើយ ក៏កើតចិត្តឫស្សាប្រណែនគ្នានិយាយថា ឯងបានច្រើនចែកមកឲ្យអញខ្លះទៀត ដ្បិតអញបានតិចជាងឯង ។ ម្នាក់ទៀតឆ្លើយថា អញមិនឲ្យឯងទេ ត្រូវ

ឯងឲ្យមកអញវិញ ដ្បិតអញបានគិតជាងឯង ។ សិស្សទាំងប្រាំយេ និយាយប្រកែកគ្នាបែបនេះតាមផ្លូវ កាន់តែខ្លាំងឡើង កើតទៅជាទោសៈក្រោធចូលដាល់តប់គ្នាទៅវិញទៅមក ហេតុដល់កាប់សម្លាប់គ្នាស្លាប់បណ្ដើរតាមផ្លូវទៅ ។ នៅទីបំផុតសល់តែសិស្សពីរនាក់ គឺអ្នកស្រុកសេកមន្តហៅមាសប្រាក់ម្នាក់ និងអ្នកចេះមន្តខ្លាំងពូកែបន្ទាប់ម្នាក់ទៀត ។ សិស្សពីរនេះ ដឹងឫទ្ធិខ្លួនថា មានចំណេះវិជ្ជាស្មើគ្នា ក៏បែរជាធ្វើឧបាយកលដោយការស្និទ្ធស្នាលទៅវិញ តែក្នុងចិត្តគំនិតម្នាក់ ៗ គិតប្រុងនឹងសម្លាប់ម្នាក់ចេញ ដើម្បីនឹងយកមាសប្រាក់ឲ្យបានចូលមកលើខ្លួនម្នាក់ឯង លុះដើរទៅដល់ចុងស្រុកក៏បបួលគ្នាឈប់ក្រោមម្លប់ឈើមួយ ។ សិស្សម្នាក់ប្រើម្នាក់ទៀតឲ្យចូលទៅសុំបាយទឹកអ្នកស្រុកយកមកបរិភោគ ។ សិស្សអ្នកចូលទៅភូមិសុំបាយគេបរិភោគឆ្អែតរួចហើយ សុំបាយគេមួយកញ្ចប់ទៀតយកមកធ្វើសម្លាញ់ ទើបយកថ្នាំពុលដាក់លាយក្នុងបាយ បំណងឲ្យម្នាក់ស៊ីរួចស្លាប់ទៅ នឹងយកមាសប្រាក់តែម្នាក់ឯង ។ និយាយពីសិស្សម្នាក់នៅក្រោមម្លប់ឈើគិតថា បើអានោះវាយកបាយមកហុចឲ្យអញ ។ កាប់វាឲ្យដាច់ពាក់កណ្ដាលខ្លួនភ្លាម អញនឹងយកមាសប្រាក់តែម្នាក់ឯង ។ លុះសិស្សម្នាក់យកបាយមកហុចឲ្យ, សិស្សដែលអង្គុយចាំនោះលូកដៃខាងឆ្វេងទទួលកញ្ចប់បាយ ដៃខាងស្ដាំកាន់កាំបិតព្រាកាប់ត្រូវពាក់កណ្ដាល

ខ្លួនអ្នកហុចបាយដួលស្លាប់ភ្លាម ៗ អ្នកកាប់នោះត្រេកអរណាស់ ព្រោះដូចបំណង គិតតាំងបរិភោគបាយ មិនទាន់តាំងអស់បាយផង ស្រាប់តែប្រកាច់បែកពពុះមាត់ស្លុលស្លាប់នៅទីនោះមួយរំពេចទៅ ។ ឯសំពាយមាសប្រាក់ក៏នៅក្បែរខ្លួនខ្មោចទាំងពីរ ៗ

ថ្ងៃពីរលោកគ្រូអាចារ្យទិសាបាមោក្ខ ទន្ទឹងមើលផ្លូវសិស្សបាត់យូរពេករហូតដល់ព្រលប់ ក៏ទឹកសង្ស័យថា ប្រហែលជាមានអន្តរាយអ្វីមួយមិនខានហើយ , បានជាសិស្សទាំងនោះពុំឃើញមកវិញ ៗ ទើបលោកអាចារ្យដើរទៅតាម , ដល់ទៅចុងស្រុកឃើញខ្មោចសិស្សទាំងពីរនឹងបង្វេចមាសប្រាក់ពីរសំពាយ លោកពិចារណាយល់ហេតុការណ៍ច្បាស់ថា "សិស្សនេះ សេកមន្តហៅភ្លៀងមាសប្រាក់ឲ្យធ្លាក់មកសិស្សឯទៀតរើសយក ហើយឈ្លោះដណ្ដើមកាប់សម្លាប់គ្នាហាល់តែស្លាប់អស់ឥតសល់ម្នាក់ សូម្បីអ្នកមេគំនិតហៅភ្លៀងមាសប្រាក់ ក៏ស្លាប់ខ្លួនឯងដែរ ឱ ! សេចក្ដីស្រេកឃ្លានចង់មាន ចង់បាននេះជាភេទធំណាស់តើ ៗ ហេតុនេះហើយ បានជាព្រះពុទ្ធទ្រង់ទូន្មានថា "គ្មានរោគាឯណាខ្លាំងក្លាលើសរោគស្រេកឃ្លានទេ (ជិឃច្ឆា បរមា រោគា ធ. ខុ.) គួរតែមហាជនខ្លាចភេទស្រេកឃ្លាននេះជាទីបំផុតជាងខ្លាចភេទឯទៀត ៗ ទៀត" ៗ លោកអាចារ្យគិតសង្វេគយ៉ាងនេះហើយ លោកក៏តិះដៀលសិស្សច្បងនោះថា ហេតុតែមិនស្ដាប់ដំបូន្មាន

អញផ្ដាំផ្ដាច់ថា កុំឲ្យសេកមន្តហៅមាសប្រាក់ពីលើមេឃ បើហៅមុខជាស្លាប់ខ្លួនមិនខានទេ ឥឡូវស្លាប់មែន, រួចលោកយកសំពាយមាសប្រាក់ទៅឲ្យភរិយាលោកឯផ្ទះ លោកប្រាប់ភរិយាថា: រោគជាសត្រូវធំបំផុតលើសសត្រូវទាំងអស់; សេចក្ដីស្រេកឃ្លាន ជារោគធំបំផុតលើសរោគទាំងពួង ដូចជា សត្រូវឯទៀត យើងចៀសវាងផុត, ឯរោគ យើងចៀសមិនផុតទេ ។

«ចូរឯងស្ដាប់ពាក្យអញ មនុស្សទាំងអស់ស្រេកទឹក, ឃ្លានបាយ គឺមែនហើយ ប៉ុន្តែ កាលបើបានទឹកផឹកហើយ បានបាយបរិភោគហើយ មុខជាផ្អែតលែងស្រេកឃ្លានទៀត រហូតដល់ពេលស្រេកឃ្លានជាថ្មីវិញ ឯចិត្តដែលឃ្លានមាន, ឃ្លានបាន, ឃ្លានស្អប់ឃ្លានស្រឡាញ់នេះ គ្មានពេលណាស្រាកស្រាន្តទេ បើមានបានប៉ុណ្ណេះហើយចង់ឲ្យមានបានប៉ុណ្ណោះទៀត បើស្អប់គេហើយ គិតធ្វើឲ្យគេវិនាសឲ្យគេស្លាប់ទៅទៀត, បើស្រឡាញ់អ្នកណាហើយ ឃ្លាតមុខអ្នកនោះមិនបានទេ រឹតតែស្រឡាញ់ខ្លាំងឡើងទៀត ហេតុនេះ ត្រូវឯងចាំកុំភ្លេចថា "ជម្ងឺឈឺចាប់នឹងសេចក្ដីស្រេកឃ្លាននេះ ជាសត្រូវធំបំផុត" ។

ពុទ្ធភាសិត ធ-ខុ-

គ្មានសត្រូវអ្វីខ្លាំងពូកែជាងរោគទេ (នត្ថិ ព្យាធិ សមារោគា)

គ្មានរោគអ្វីខ្លាំងពូកែជាងសេចក្ដីស្រេកឃ្លានទេ (ជិឃច្ឆា បរមា រោគា)

# កណ្ឌទី ៣៩

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នករៀងវៃឆ្លាសបើបានអាន<br>នឹងបេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ។ |

ស៊ុនគួនថា អ្នកចូរស្រួតស្រូតលើកទ័ពឲ្យព្រមគ្នាចេញទៅចុះ ខ្ញុំនឹងលើកទ័ពជូនទៅជាខាងក្រោយ ។ ជីវយ៉ីក៏គំនាប់លាស៊ុនគួនចេញមកចាត់ចែងទាហាន ហើយបបួលខុងបេងថា ទ័ពចូឆូលើកមកគ្រានេះច្រើនសន្ធឹកសន្ធាប់ពេកណាស់ ខ្ញុំនឹងជំនួសបបួលអ្នកទៅផង ។ ខុង-បេងឮដូច្នោះក៏មានអំណរណាស់ ឆ្លើយទទួលថា ខ្ញុំព្រមទៅជាមួយនឹងអ្នក ។ ជីវយ៉ីក៏នាំខុងបេងចុះទូកចម្បាំង ១ ទៅជាមួយគ្នា ឯទៀតកៅនឹងឡោសុកឲ្យធ្វើជាបាឡាត់កងលើកទាហានជាច្រើន នាំគ្នាដង្ហែជាយទៅដល់មាត់កំពង់ស្រុកកាំងហៃ ចម្ងាយផ្លូវពីមាត់កំពង់ស្រុកសាំកាំង ៦០០ សិន

(២៤៨.ម) ជីវយើឲ្យឈប់កងទ័ពទូកបោះយុថ្កា ហើយឲ្យទាហានឡើងគោកតាំងបន្ទាយការយន្តារទៅតាមផ្លូវត្រង់ទៅទិសបស្ចិម ។ ឯខ្លួន-បេនគឺចុះទូកតូចទៅបោះយុថ្កានៅប្របទូកមេទ័ព ។

ជីវយើឲ្យហៅខ្លួនបេនឡើងមកលើទូកចម្បាំងធំ ហើយក្លែងប្រើក្បាច់ប្រាជ្ញា ប្រើខ្លួនបេនទៅឲ្យចូចូចាប់សម្លាប់ចេញ ហើយថា កាលចូចូចម្បាំងនឹងអ៊ួនសៀវនោះចូចូមានទាហានតិចជាងអ៊ួនសៀវណាស់ ចូចូក៏ធ្វើសង្គ្រាមមានជ័យជំនះអ៊ួនសៀវបាន ព្រោះបានស្តាប់ពាក្យខៅហ៊ីវពន្យល់ឲ្យទៅវាយស្បៀងនៅដំបន់គួទៅបាន គ្រានេះចូចូលើកមកទាហានច្រើនដល់១០០ម៉ឺនបាយ ឯទាហានយើងលើកមកក៏តិចបានតែ៥ម៉ឺនបាយ ឃើញថានឹងច្បាំងយកជ័យជំនះចូចូបានដោយកម្រណាស់ ត្រូវតែរិះគិតចាត់ទាហានទៅកាត់ស្បៀងចូចូឲ្យបានជាមុនសិន ទើបនឹងធ្វើការចម្បាំងតនឹងចូចូបាន ឥឡូវចូចូប្រមូលទាហានស្បៀងទុកនៅក្នុងគីសានដែនស្រុកស៊ុនយ៉ុង ឯខ្លួនអ្នកក៏នៅក្នុងដែនស្រុកស៊ុនយ៉ុងដែរ ឃើញថាចំណានខាងផ្លូវព្រៃនឹងក្នុងគ្រប់ដំបន់ ការសង្គ្រាមគ្រានេះសោត ក៏មិនមែនតែជារបស់ស៊ុនគួនចៅហ្វាយខ្ញុំតែម្នាក់ឯងទេ គឺរបស់ឡៅពីចៅហ្វាយអ្នកផងដែរ ខ្ញុំនឹងប្រគល់ទាហានឲ្យអ្នក១ពាន់ស្រួតរូតលើ ត្រឡប់ទៅប្រាប់ឡៅពី សុំយកគួនអ៊ូ, ទៀវហ៊ុយ, ជូឡុង ឲ្យលើកចេញទៅកាត់ស្បៀងចូចូចេញឲ្យបាន ខ្ញុំនឹងរិះគិតការតស៊ូច្បាំងឲ្យបានស្រួល ។

ខុនបេនបានស្តាប់គិតគិតថា ដែលដាវយ៉ែឲ្យមកល្បួងលួងលោមអញមិនបានដូចប្រាថ្នា ទើបកែងឲ្យអញទៅធ្វើការនេះ ប្រាថ្នានឹងឲ្យចុច្ចចាប់អញសម្លាប់ បើអញមិនស្លាប់ ធ្វើព្រងើយកន្តើយមិនទៅគ្រានេះ ដាវយ៉ែក៏ដំនៀលអញថាខ្លាចចុច្ច បើអញនឹងទៅតាមបង្គាប់ដាវយ៉ែក៏នឹងសើចចំអកថា អញដឹងមិនដល់គំនិត បើដូច្នេះអញត្រូវគិតទទួលទៅចុះ តែថាំរកឧបាយតែខ្លួនឲ្យបាន លុះគិតស្រេច ក៏ឆ្លើយទទួលពាក្យ ហើយលាចុះទៅទូកតូចវិញ ។

ឡោសុកក៏សួរដាវយ៉ែថា ដែលលោកប្រើខុនបេនទៅវាយស្សៀងចុច្ចះនោះ លោកគិតឃើញបានការយ៉ាងម្តេច? ។ ដាវយ៉ែថា យើងគិតនឹងសម្លាប់ខុនបេនចេញក៏ខ្លាចគេគរហានិន្ទា បានជាកែងប្រើខុនបេនទៅវាយស្សៀងនោះ ដោយប្រាថ្នានឹងខ្ញីអាវុធចុច្ចឲ្យសម្លាប់វិញ គេទៅមុខទើបយើងផុតភ័យអន្តរាយ ហើយមនុស្សទាំងឡាយក៏នឹងមិនតិះដៀលយើងបាន ។ ឡោសុកថា ខ្ញុំនឹងសុំទៅមើលកលការកិរិយាខុនបេនជានឹងដឹងខ្លួនឬទេ ហើយក៏ចុះទៅទូកខុនបេន ឃើញទឹកមុខខុនបេនគ្មានគិតភ័យអ្វីសោះ រៀបចាត់ចែងមនុស្សម្នាដែលនឹងទៅនោះបែបធម្មតាព្រងើយ ឡោសុកមានសេចក្តីអាណិតខុនបេនណាស់ក៏សួរថា ដែលដាវយ៉ែប្រើលោកឲ្យទៅវាយស្សៀងចុច្ចនោះ លោកយល់ឃើញថា បានការដូចម្តេចខ្លះ ។

ខុនបេនក៏អស់បំណើចហើយថា  យ៉ាងខ្លួនខ្ញុំនេះចំណានក្នុងការសង្គ្រាមទាំងផ្លូវគោកផ្លូវទឹក ព្រមទាំងក្បួនរេះក្បួនរថះថ្មើរជើងទាំង៤ យ៉ាងស្ទាត់ទាំងអស់  ទើបបានឈ្មោះថាជាប្រាជ្ញាក្នុងចតុរង្គសង្គ្រាម  ឯក្នុងស្រុកកាំងតាំងនេះ  ខឹងគេមនុស្សចំណានស្ទាត់ក្នុងចម្បាំងផ្លូវគោកដូចជាគ្មានឃើញ ចំណានតែខាងផ្លូវទឹក នោះប៉ុន្មានដាវយើងឯងក៏ដូចគ្នា ។ ឡោសុកថា ហេតុម្តេចបានជាលោកថា ដាវយើចំណានតែផ្លូវទឹក ខ្ញុំបានឮក្មេងៗក្នុងស្រុកកាំងតាំងធ្វើក្មេងច្រៀងទំនុកថា :

ជម្នាក់មេទ័ពគ្រប់រូបអង្គ  ត្រូវចេះចតុរង្គក្នុងសង្គ្រាម
ទើបឈ្មោះមេទ័ពគ្រប់រូបនាម  កុំធ្វើអាមមួយដូចដាវយើ ។
ស្ទាត់តែចម្បាំងខាងជើងទឹក  ជើងគោកវាវើកក្តុកក្តួចទី
នេះហៅទាហានគ្មានសម្ពី  តាមប្រវេណីមិនប៉ុស្តួន ។

ឡោសុកក៏គំណត់ចាំពាក្យ  ដែលខុនបេនអធិប្បាយនោះទៅប្រាប់ដាវយើគ្រប់ប្រការ ។ ឯដាវយើឮដូច្នោះខឹងខ្លាំងណាស់និយាយថា ខុនបេននេះចរចាមើលងាយប្រមាថយើងថាមិនចំណានខាងផ្លូវគោក បើយើងមិនទៅក្នុងគ្រានេះ ខុនបេនក៏នឹងថែមតិះដៀលយើងទៀត បើដូច្នោះយើងមិនឲ្យខុនបេនទៅឡើយ យើងនឹងលើកទាហានមួយម៉ឺន ទៅខ្លួនឯងចុះប្រយុទ្ធនឹងវីកាត់យកសៀងប៉ូចូឲ្យបាន ។ ឡោសុកឮដូច្នោះក៏ត្រឡប់ទៅប្រាប់ខុនបេនតាមពាក្យដាវយើនិយាយគ្រប់ប្រការ ។

ខ្ញុំបានគិតអស់សំណើចហើយថា ឯសេចក្ដីរិះគិតដីវយើនោះ ខ្ញុំ
ប្រើខ្ញុំដោយសុចរិតក៏ទេ គឺគ្រាន់ឲ្យខ្ញុំទៅស្លាប់ដោយថ្វីដៃ ខ្ញុំសេចក្ដីគិត
របស់ចូចពិត ដែលខ្ញុំថា ដីវយើមិនស្គាល់ក្នុងសង្គ្រាមខាងផ្លូវគោកនោះ
ព្រោះខ្ញុំគ្រាន់ញុះចិត្តដីវយើល្បងមើល ប្រាថ្នាឲ្យយល់ថាខ្ញុំក៏អាចដឹងដល់
គំនិតដីវយើដែរ គ្រានេះខ្ញុំក៏ត្រូវគិតឲ្យស៊ីនគួរខ្ញុំទៀតតែមគំនិតគិតធ្វើការ
ជាចិត្តមួយខ្ញុំគ្នា ដើម្បីខ្ញុំកំចាត់កងសត្រូវចេញប៉ុណ្ណោះ យើងទាំង
អស់គ្នាជាបាវព្រាវក៏ត្រូវតែតាំងចិត្តជួយគ្នា ជួយគិតការឲ្យបានសម្រេច
ហេតុម្ដេចដីវយើមកគិតមិត្តត្រូវស្ដខ្ញុំវិញ បើដូច្នោះការរបស់យើងហ្វាយ
នាយខ្ញុំមិនអត្ថកាយទៅទេឬ?, ប្រការ១ទៀត ឯគំនិតគិតរបស់ចូចនោះ
ចំណានក្នុងការសង្គ្រាមណាស់ រមែងធ្វើកលសឹកផ្សេងៗ តែងតែកាត់
ស្បៀងអាហារជាដើម ដែលចូចលើកទ័ពមកគ្រានេះ ខ្ញុំរិះគិតការពារ
ស្បៀងអាហារឲ្យមាំមួន បើដីវយើខ្ញុំលើកទៅខាងណោះមុខជាខូចការ
របស់ចូចជាប្រាកដ ចូរអ្នកទៅនិយាយខ្ញុំដីវយើឲ្យចំអត់ទៅរិះគិតច្បាំងត
ទល់តែខាងជើងទឹកទៅចុះ ព្រោះទាហានចូចនោះស្គាល់តែខាងផ្លូវគោក
មិនសូវប៉ិនប្រសប់ខាងផ្លូវជើងទឹកទេ ប្រសិនបើកងទ័ពយើងតទល់ច្បាំង
ខាងផ្លូវទឹក ឲ្យទាហានចូចចូលការរបស់យើងបាន ។ ទៀសុកញ្ញ
ដូច្នោះ ក៏សរសេរដេម្រេះប្រាជ្ញខ្ញុំបានថា ដឹងយល់ស្គាល់ការជ្រៅ
ខ្ពង់ណាយខ្ញុំរកអ្នកឯណាមួយផ្ទឹមស្មើគ្មាន ។

លុះវេលាយប់ ឡោស៊ុកក៏នាំយកសេចក្តីនោះទៅប្រាប់ជីវ៉យគ្រប់ប្រការ ៗ ជីវ៉យដឹងដូច្នោះក៏គ្រវីក្បាលហើយថា គំនិតរបស់ខុងបេងនោះជ្រៅទូលាយវៃវាងលើសជាងខ្ញុំ ១០ ភាគ បើប្រសិនខ្ញុំមិនគិតរកគំនិតនឹងកំចាត់ចេញឲ្យបាន តទៅមុខក៏នឹងជាសត្រូវដល់ខ្លួនខ្ញុំជាយ៉ាងខ្លាំង ៗ ឡោស៊ុកក៏លួងលោមយកចិត្តជីវ៉យថា គ្រានេះការសង្គ្រាមក៏បង្កើតមាន លោកនឹងមកធ្វើដូច្នេះមិនគួរទេ បើសិនណាជាខុងបេងគាត់ឆ្លើយឡើង គំនិតនឹងកំឡាំងរបស់យើងក៏នឹងថយចុះទៅវិញ ឃើញថាស្រុកកាំងតាំងនឹងវិនាសមុនក្រោយ ការនេះយើងត្រូវតែគិតច្បាំងឲ្យបានជ័យជំនះបួនសិនតទៅមុខ សឹមគិតធ្វើប្រការម្តេចនឹងបានដោយងាយ ៗ ជីវ៉យយល់ឃើញត្រូវក៏ឲ្យតាំងទ័ពទឹកទុកឲ្យជាប់ខ្លួន ៗ

ឯខួកកងក្រវែលស្រុកកាំងហែ ក៏នាំយកសេចក្តីទៅប្រាប់ឡេវពីឲ្យដឹង ៗ ឡេវពីបានស្តាប់ក៏គិតថា កងទ័ពស្រុកកាំងតាំងលើកមកនឹងធ្វើសង្គ្រាមតនឹងចូច ឡេវពីក៏ចាត់ចែងភាហាខត្តស្រុកកាំងហែនោះប្រមូលយកទាំងអស់ ហើយលើកចេញចាកស្រុកកាំងហែទៅតាំងនៅដំបន់ហែទៅ ហើយប្រឹក្សានឹងទាហានទាំងពួងថា ខុងបេងទៅស្រុកកាំងតាំង យើងក៏មិនបានដឹងដំណឹងថាល្អឬអាក្រក់ប្រការម្តេច ឥឡូវកងទ័ពខួកស្រុកកាំងតាំងលើកមកចតនៅកំពង់ស្រុកនេះ នរណានឹងអាចលុះលះទៅស្តាប់ដំណឹងខុងបេងឲ្យដឹងជាការប្រការម្តេចបាន ៗ ប៊ីតុកថា ខ្ញុំបាទនឹងសូម

អាសារចេញទៅ ។ ទៀតពីកំបាត់ថែនរបស់ទៅគំនាប់ជីវយើ ប្រាថ្នាទឹង បានស្លាប់ជំណាំងខុងបេងផង ។ បំតុកទទួលរបស់ហើយក៏ពុះទូកទៅដល់ កងទ័ពចម្ប៉ាំងទូក ក៏ឡើងទៅគំនាប់ជីវយើហើយជំរាបថា របស់ទាំងនេះ ទៀតពីឲ្យខ្ញុំបាទនាំមកជូនលោកទុកចែកទាហាន ។ ជីវយើក៏ទទួលអំណរ-សាទរណាស់ ទទួលយករបស់ទាំងនោះទុក ។ បំតុកក៏ជំរាបថា ក្បៀត ទៀតពីបានផ្តាំមកថា ខុងបេងមកនៅទីនេះក៏យូរហើយទឹងឲ្យទទួលត្រឡប់ ទៅវិញ ។ ជីវយើថា ការសង្គ្រាមកំពុងតែរៀបចំ ដែលខុងបេងមក នៅផងក៏ស្រួល ព្រោះទឹងបានជួយតាក់ការគ្រាំងចម្ប៉ាំងទឹងចូច្ចដោយ ទៀតពីទឹងឲ្យខុងបេងវិលត្រឡប់ទៅវិញនោះក៏អាលស័ន្ទុះ ឯខ្លួនយើង សោកក៏មានចិត្តទឹករលីកដល់ទៀតពីណាស់ដែរ បើយើងទឹងទៅក៏ពុំបាន ព្រោះជាមេទ័ពទីរព្រួយការខានត្រួតបង្គាប់ទាហាន អ្នកចូរស្រូតត្រឡប់ ទៅជំរាបទៀតពីឲ្យអញ្ជើញមកគេយើង ទឹងបានប្រឹក្សាការសង្គ្រាមផង ។ បំតុកទទួលគំនាប់ហើយក៏លាត្រឡប់ទៅវិញ ។

ទៀតសុកក៏សួរជីវយើថា លោកទឹងឲ្យទៀតពីមកជួបនោះតើទឹង ប្រយោជន៍អ្វី ? ។ ជីវយើថា ឯចិត្តទៀតពីនោះជាអ្នកមិនសូវដឹងគុណគេសោះ ប្រសិនទឹងសុំគ្រស្មោះស្មាគមនឹងទៀតពីយូរទៅ ក៏ទឹងធ្វើអន្តរាយដល់ យើងវិញ ត្រូវយើងចាប់ទឹងគង់នៅ ហើយជីវយើក៏ឡើងទៅលើបន្ទាយ ហើយលបបាត់ទាហានដែលមានថ្វីដៃ៥០នាក់ ឲ្យកាន់អាវុធបង្កប់នៅកន្ទ

ឆាកហើយផ្ដាំថា កាលណាបើឃើញលៀវពី មកស៊ីលៀងនឹងយើង ហើយអ្នកពលគ្នាឃើញយើងចោលពែងស្រាចុះកាលណា ក៏ឲ្យស្រុះគ្នាចេញមកចាប់លៀវពីសម្លាប់ចេញ ៗ ឯបិតុកកាលត្រឡប់ទៅដល់ក៏ប្រាប់លៀវពីតាមរឿងសព្វគ្រប់ហើយថា ជីវយីផ្ដាំថាឲ្យអញ្ជើញទៅជួបនឹងបានប្រឹក្សាការពងការ ៗ លៀវពីឮហើយក៏រៀបចំទាហានដែលនឹងចុះទូកទៅរកជីវយី ៗ គួនអ៊ូក៏និយាយនឹងលៀវពីថា ដែលលោកនឹងទៅរកជីវយីនោះមិនស្រួលទេព្រោះជីវយីជាមនុស្សតូចកែសំដីវៃគំនិតណាស់ ខ្លាចក្រែងគេគិតប្រទូសរ៉ាយលោកទេដឹង មួយទៀតខុងបេងក៏មិនមានដំណឹងឲ្យលោកអញ្ជើញទៅជាល្អប្អូនក្រក់ សូមឲ្យលោកផែអផង់រងចាំស្ដាប់ការសិន ៗ

លៀវពីថា យើងនឹងស៊ុនគួនក៏ជាចិត្តមួយជាមួយគ្នា នឹងរៈគិតកំចាត់ចូចូចេញ ឥឡូវជីវយីធ្វើមេទព័ឲ្យមកអញ្ជើញយើងចូលទៅប្រឹក្សាការពជការផង បើយើងនឹងមិនទៅតែម្ដង ក្រែងស៊ុនគួនសន្ទះចិត្តនឹងយើងថា ដូច្នេះដូច្នោះ ឯការដែលរួមគិតមកហើយនោះក៏នឹងខូចទៅ ៗ គួនអ៊ូថា ប្រសិនបើលោកមិនព្រមស្ដាប់នឹងប្រញាប់ទៅឲ្យបាន ខ្ញុំបាទក៏សូមយកទាហានទៅជាមួយនឹងលោកខ្លះ ដើម្បីនឹងជួយការពារអន្តរាយផ្សេងៗ ៗ លៀវពីក៏បង្គាប់ឲ្យទៀវហ៊ុយនឹងជូឡុងនៅក្រោបន្ទាយ

ហើយនាំយកគូនអ៊ូនឹងកូនទាហាន ១២ នាក់ ចុះទូកទៅដល់កន្លែងតាជីវ័យ ទៀតពីឃើញទូកចម្បាំង នឹងបន្ទាយកាយជាក្បួនពិជ័យសង្គ្រាមត្រឹមត្រូវ ក៏មានសេចក្ដីត្រេកអរណាស់ ។ ទាហានល្បាតក៏នាំយកសេចក្ដីទៅប្រាប់ជីវ័យថា ទៀតពីមកដល់ហើយ ។ ជីវ័យក៏សួរថា: ទៀតពីមកនេះ មានទាហានតិចច្រើនប៉ុន្មាន ។ ទាហានប្រាប់ថា ទៀតពីចុះទូកតូចមកនឹងទាហានប្រហែល ២០ នាក់ ។ ជីវ័យឮដូច្នោះក៏អស់សំណើច ហើយគិតថា គ្រានេះទៀតពីនឹងដល់សេចក្ដីស្លាប់ព្រោះតែគិតអញតែក្នុងដៃនេះហើយ ទើបឲ្យតាត់ដៃនឹងទាហានដែលបង្កប់ទុកនោះ ព្រមគ្នា ហើយក៏លើកគ្នាមកទទួលទៀតពីឯក្រោមបន្ទាយតំណាប់គ្នាតាមប្រវេណី ជីវ័យក៏នាំទៀតពី គូនអ៊ូ នឹងទាហាននោះចូលទៅក្នុងបន្ទាយ ហើយអញ្ជើញឲ្យទៀតពីបរិភោគអាហារ ។ ទៀតពីក៏និយាយនឹងជីវ័យថា ខ្ញុំអ្នកនេះ មនុស្សទាំងអស់នាំគ្នានិយាយសរសើរឮទូទៅថា អ្នកមានសេចក្ដីរិះគិតល្អិតជ្រៅទូលាយណាស់ ទាំងបានធ្វើជាមេទព ហើយមកកប់ខ្លួនជាមនុស្សបុណ្យតិចនេះមិនសមគួរទេ ។

ខណៈនោះឡេវខុនបេងជីវមកដល់ក្បែរបន្ទាយ ក៏ដឹងថាទៀតពីមកជួបនឹងជីវ័យ បរិភោគអាហារជាមួយគ្នាក្នុងបន្ទាយ ដូច្នោះក៏ខឹងកយ៉ណាស់ ខុនបេងក៏ចូលទៅលបមើលឃើញមុខជីវ័យនោះមាំដូចជាខឹង ហើយទាហានក្នុងផាកនោះខ្សឹបខ្សៀវគ្នាក៏រតែស្មុគបិត្តជាខ្លាំង

តែឃើញកិរិយាទៀវពីនិយាយស្ដីយ៉ាងព្រងើយកន្តើយ ហើយឃើញចាំងគ្នុងអ៊ូឈរពីក្រោយកាន់គ្រប៉ីយ៉ាងអង់អាច ខុនបែនក៏អស់កំឡាច គិតឃើញថា ទៀវពីនឹងមិនអន្តរាយទេ ហើយក៏ត្រឡប់ទៅចាំទៀវពីនៅក្បែរមាត់ទឹក ៗ

ខណៈកាលជីវយ៉ីផឹកស្រានឹងទៀវពីនោះ ក្រឡេកទៅឃើញគ្នុងអ៊ូឈរកាន់គ្រប៉ីពីក្រោយទៀវពី ៗ ជីវយ៉ីក៏សួរថា អ្នកនេះទាហានពីណា ? ៗ ទៀវពីក៏ប្រាប់ថាគ្នុងអ៊ូជាប្អូនខ្ញុំ ៗ ជីវយ៉ីសួរថាអ្នកនេះឬដែលទៅនៅនឹងចូចូ បានយកអាសាទៅសម្លាប់អាំងលៀង,ប៊ុនជីវ ជាទាហានឯករបស់អ៊ុនសៀវនោះ ៗ ទៀវពីក៏ទទួលថានេះឯងហើយ ៗ ជីវយ៉ីឮដូច្នោះក៏តក់ស្លុតក្នុងចិត្ត បេញញើសហូរស្រែតជោគសព្វសព៌ាង្គ-កាយ ហើយក៏ចាក់ស្រាហុចទៅឲ្យគ្នុងអ៊ូផឹក ៗ ខណៈ ឡាសុកចូលមក, ទៀវពីក៏សួរថា ខុនបែននៅឯណា ? សុំឲ្យអ្នកប្រាប់ឲ្យមកជួបនឹងខ្ញុំបន្តិចនឹងបានសន្ទនាគ្នា ៗ

ជីវយ៉ីឮដូច្នោះក៏ថានឹងអស់ថ្ងៃទោះហើយឬ ប៉េសម្រេចការសង្គ្រាមហើយសឹមត្រូវការជួបគ្នាចុះ ។ ទៀវពីមិនបានតបថាប្រការម្ដេច គ្នុងអ៊ូបានឮដូច្នោះក៏ចោលចុងនៃក្អែកទៅឲ្យទៀវពីដឹង ទៀវពីក្រឡេកទៅម្រេះក្អែកគ្នុងអ៊ូក៏យល់អធ្យាស្រ័យថាមិនស្រួល ទើបក្រោកឡើងគំនាប់ជីវយ៉ីហើយថា ខ្ញុំសុំលាទៅសិនចុះ បើស្រេចការសង្គ្រាមវេលាណា សឹម

មកជួបសន្ទនាគ្នាទៀត ហើយឡាវពីក៏នាំគួនអ៊ូទនឹងពាហានចេញពីបន្ទាយ លុះទៅដល់ទូកក៏ក្រឡេកឃើញខុនបែនចូលទៅនិយាយគ្នាក្នុងទូក ។

ខុនបែនឃើញឡាវពីចេញមកក៏មានអំណរណាស់និយាយថា ដែលលោកមករកដំរីបីវេលានេះ កុំតែបានគួនអ៊ូមកផងក៏កុំអំពីរយ៉ើទីនប្រទូស-រ៉ាយៈលោកឲ្យជីវិតអន្តរាយ ។ ឡាវពីថា ដែលដំរីយ៉ើនឹងគិតគំនិតអាក្រក់ដូចម្តេចនោះខ្ញុំឥតដឹងសោះ ដែលខ្ញុំមកវេលានេះ ប្រាថ្នានឹងទទួលលោកយកទៅទុកក្នុងបន្ទាយហៃទៅវិញប៉ុណ្ណោះ ។ ខុនបែនតបថា លោកកុំព្រួយនឹងខ្ញុំឲ្យសោះ ទោះបីជាខ្លួនខ្ញុំបាក់ទឹងមកចូលទៅក្នុងមាត់ខ្លាមាត់ក្រពើក្តី ក៏នៅតែមានសេចក្តីសប្បាយជាដរាបនៅក្នុងបន្ទាយទៅទៀត លោកចូរប្រុងតែទៅចាត់ចែងពាហានទូកចម្បាំងទុកឲ្យព្រមនឹងបានៈគ្រឿងការស្រួល បើដល់ខែបុស្ស ៩ កើតវេលាណា ឲ្យលោកប្រើជូ-ឲ្យនំយកទូកតូចមកចាំទទួលខ្ញុំបាក់នៅត្រើយទន្លេ ខាងទិសទក្សិណកុំខាន ឡាវពីសួរថា គំនិតរបស់លោកឃើញប្រការម្តេចបានជាសុំទុកដូច្នេះ ។ ខុនបែនឆ្លើយថា លោកចាំតែមើលទៅចុះ បើឃើញខ្យល់ដំនោរបក់មកពីទិសអគ្នេយ៍វេលាណា ខ្ញុំបាក់ទឹងទៅជួបនឹងលោកវេលានោះ ហើយខុនបែនក៏លាឡាវពីទៅទូកតូច ៗ ឡាវពីក៏ត្រឡប់ទៅវិញ ជួបនឹងទៀវហ៊ុយនាំទូកចម្បាំង ៩០ តាមមក ក៏នាំគ្នាចូលទៅក្នុងបន្ទាយហៃទៅ ។

ឯឡោស៊ុកលុះឡាវពីវិលទៅវិញហើយ ក៏ចូលទៅសួរដំរីយ៉ើថា

ខ្ញុំបានឮគេនិយាយថា គួនអ៊ីនោះមានថ្វីដៃខ្លាំងពូកែណាស់ ដូចតាហាន ខ្លា មកជាមួយនឹងឡៀតពី បើយើងនឹងចុះដៃធ្វើអន្តរាយឡៀតពី គួនអ៊ី ដែលឈរជិតនឹងធ្វើអន្តរាយយើងវិញ ។ ឡេសុកយល់ឃើញផង ។ ខណៈនោះខុលមានបំរើកូចម្នាំសំបុត្រមកឲ្យដីវយើ ។ ខុលយកសំបុត្រ នោះមកមើលឃើញការខ្វង់ថា មហាចបកជព្រះទៅហៀនគេ ឲ្យមក ជល់ដីវយើជាមេទ័ព ដីវយើឃើញដូច្នោះក៏ខឹងណាស់ ឈ្លីហែកសំបុត្រ នោះខ្ទេចខ្ទីអស់ទៅ ហើយបង្គាប់ឲ្យចាប់ខ្លួនអ្នកកាន់សំបុត្រទៅសម្លាប់ ចេញ ។

ឡេសុកថា ពាក្យបុរាណពោលទុកមកថា ទោះបីស្រុកណាជាសឹក សត្រូវនឹងគ្នាក៏ លោកមិនឲ្យធ្វើអន្តរាយដល់អ្នកកាន់សំបុត្រឬមនុស្សបំរើ ទៅមកក្រៅពីមនុស្សប្លែកប្លង់នោះជាដាច់ខាតតែម្តង ហេតុម្តេចលោកក៏ មកសម្លាប់អ្នកកាន់សំបុត្រចេញដូច្នេះ ។ ដីវយើតបថា ដែលខ្ញុំឲ្យ សម្លាប់អ្នកកាន់សំបុត្រនោះ ព្រោះហេតុថានឹងឲ្យដឹងដល់ប្អូនថា យើង មិនបានញញើតខ្លាច ទោះបីបើមិនសម្លាប់វាចេញ ព្រោះគិតខ្លាចមនុស្ស ទាំងពួង នឹងត្រឡប់ថា ឲ្យទៅហ្វាយយើងទៅសុំបណ្តុះដល់សឹកសត្រូវ សំបុត្រប្រគល់ឲ្យមនុស្សដែលមកជាមួយ ឥឡូវខ្លួនខ្ញុំតាំងចិត្តធ្វើពជការ នឹង ក៏ចាត់ប្អូនចេញឲ្យបាន ទើបខ្ញុំឲ្យសម្លាប់អ្នកកាន់សំបុត្រប្រគល់ឲ្យមនុស្ស ដែលមកជាមួយនាំក្បាលត្រឡប់ទៅឲ្យប្អូនវិញ ហើយដីវយើឲ្យចាត់ចែង

ទ័ពទូក ប្រើកាំឡេងជាទ័ពស្រួច ហាន់តុង ជាបែកស្ដាំ ជៀវឃើម ជាបែកឆ្វេង ខ្លួនជីវយីជាមេកងធំគ្រងទ័ពហ្លួង ៗ លុះវេលាព្រឹកឡើងក៏នឹង លើកចេញទៅវាយទ័ពចូវ ។

## កណ្ឌទី ៤០

តាំងពីចូវប្រើឈ្មម៉ឺនឹងទៀវអ៊ុន លើកទ័ពទូកទៅច្បាំងនឹងកាំឡេង ៗ បាញ់ ឈ្មហ៊ុន ស្លាប់ ជៀវកានមកបញ្ចុះបញ្ចូលជីវយី ៗ ត្រូវកលចូវ ៗ សម្លាប់ឈ្មម៉ឺទៀវអ៊ុន ខុងបេង ទទួលអាសាធ្វើព្រួញ ជីវយីក៏យកអ៊ុយកាយបែកខ្ទង ។

---

ឯមនុស្សបំរើក៏នាំក្បាលអ្នកកាន់សំបុត្រទៅឲ្យចូវ ហើយក្រាបទូលសេចក្ដី ដល់ចូវគ្រប់ប្រការ ៗ ចូវបានស្ដាប់ក៏ខឹងពេញកម្លាំង ទើបប្រើឈ្មម៉ឺនឹងទៀវអ៊ុនលើកទាហានស្រុកកេងជីវស្រុកសៀងជីវ ជាទ័ពទូកចេញទៅជាទ័ពស្រួច ចូវជាទ័ពហ្លួងលើកទៅដល់ដំបន់សាំកាំង ឃើញកាំឡេងជាទ័ពទូកចេញទៅជាទ័ពមុខ លើកទ័ពទូកមកជាច្រើន ៗ កាំឡេងក៏ស្រែកសួរថា ទ័ពនរណាអាចសូ៊នឹងយើង? ៗ ឈ្មម៉ឺនឹងទៀវអ៊ុនក៏ឆ្លើយថា យើងឈ្មោះឈ្មម៉ឺទៀវអ៊ុន ជាកងមុខមហាឧបរាជ លើកមកតច្បាំងនឹងអ្នកជាមុន ហើយឈ្មម៉ឺក៏ឲ្យឈ្មហ៊ុនជាប្អូនមកអង្គុយខាងក្បាលទូកជេញទាហានឲ្យចែវចូលទៅ ។ កាំឡេងក៏យកធ្នូបាញ់ត្រូវឈ្មហ៊ុនស្លាប់ ៗ

គ្រាខណៈនោះទាហានកងមុខ នឹងបែកឆ្វេងស្ដាំ កាំឡេងក៏បង្ខំទូកចម្បាំងចូលទៅ ហើយបាញ់ធ្នូព្រួញទៅដូចគ្រាប់ភ្លៀង ៗ កងទ័ពឈ្មម៉ឺ ទៀវអ៊ុន ក៏បែកខ្ចាត់ខ្ចាយទៅប្រទះនឹងទ័ពកូច្ច ៗ កាំឡេងនឹង

ហានតុង ជៀវឃើមគឹបង្ខំទូកចម្បាំងដេញចូលទៅចាក់កាប់សម្លាប់ទា-
ហានចួច ជាច្រើនពាល់ថៃត្រង់ ។ ជ័វយើឃើញដូច្នោះក៏វាយគងឃោះ
ឲ្យទាហានវិលត្រឡប់មកវិញ ។ កាំទៀងក៏សួរជ័វយើថា ទ័ពចួចបែក
ទាហាន យើងបានកលការដេញតាមទៅ ហេតុម្ដេចបានជាលោកវាយ
ឃោះឲ្យត្រឡប់វិលមកវិញ ។ ទាហានយើងតិចជាងទាហានចួច បើនឹង
បណ្ដោយឲ្យតាមទៅ ក្រែងចួចនឹងបង្កប់ទូកចម្បាំងនៅគៀនជ្រោយ យើង
នឹងខូចការ បានជាវាយឃោះឲ្យត្រឡប់មកវិញ ប្រាជ្ញានឹងយកជ័យ
ជំនះទុក ហើយក៏ឲ្យទូកចម្បាំងទាំងពួងចតទៅតាមរបៀប ។

ឯចួចលុះបែកទ័ពត្រឡប់មកក៏ទៀងទៅក្នុងបន្ទាយ ហើយនិយាយ
នឹងឈួម ទៀវអ៊ុនថា ទាហានស្រុកកាំងតាំងតិចជាងយើង ហេតុម្ដេច
ក៏បែកមកឬខ្ញុំនឹងអ្នកទាំង២មិនបានតាំងចិត្តធ្វើកជការដោយសុចរិត ក្រែង
ខ្លាចញ៉ែមកទេឬ ។ ឈួមថា ទាហានស្រុកកេងជ័វក៏មិនបានហ៊ានហាត់
ពោលចំបាត់ជាយូរហើយ ប្រការ១ទៀត ទាហានរបស់លោក ក៏សុទ្ធ
តែជាពួកអ្នកលើមិនប៉ុនប្រសប់នាំដើងទឹក បានជាខូចការនឹងជ័វយើ
ព្រោះហេតុដូច្នេះ សុំឲ្យលោកវិះគិតយកទូកមកចតគ្នាព័ទ្ធជាបន្ទាយទុក
កណ្ដាលទឹក រួចឲ្យទាហានស្រុកឈើជ័វ ស្រុកធៀងជ័វ ចូលទៅខាង
ក្នុង ឲ្យទាហានស្រុកកេងជ័វនៅពីក្រៅ ហ្វឹកហាត់ឲ្យស្ទាញស្ទាត់ក្នុងការ
ចម្បាំងជើងទឹកឲ្យបាន រចសំមតិតការធ្វើសឹកសង្គ្រាមនឹងជ័វយើតទៅ ។

ចូច្ចបានស្ដាប់ដូច្នោះក៏ថា ខ្ញុំនឹងអ្នកទាំង ២ ក៏បំណាខក្នុងការ សង្គ្រាមទាំងទ័ពគោក ទ័ពទឹក យើងក៏ទុកចិត្តតាំងឲ្យធ្វើមេទ័ពធំ ហើយ ពេះបើអ្នកយល់ឃើញការល្អប្រពៃប្រការយ៉ាងណា ក៏ចូលហ្វឹកហាត់ឲ្យ ប្រាកដទៅចុះ ។ ឈ្លួមម៉ឺនឹងទៀវអ៊ុនបានឮដូច្នោះ ក៏លាចូច្ចចេញទៅ ឲ្យយកទូកធំទៅចតវង់ជាបន្ទាយវៀងតាមជាយទន្លេ ទុកប្រឡោះសម្រាប់ ទឹងចូលចេញ ២៤ ទ្វារ ហើយចាត់ទាហានឲ្យចុះទូកចម្បាំងវែវរត់ដេញ ចេញចូលបង្ហាត់ឡើងព្រម ប្រាជ្ញាទឹងឲ្យហោសចំហានក្នុងទីចម្បាំងនោះ លុះវេលាកណ្ដាលយប់ ទាហានក្នុងកងទ័ពទឹកទ័ពគោកខាងចូច្ច ក៏ ទុកគប់ភ្លើងក៏ស្វាងរុងរឿងដូចជាពេលថ្ងៃ ឯបន្ទាយគោកនោះចូច្ចឲ្យ ទាហានតាំងកាយត្បារៀងទៅ បម្ពាយផ្លូវប្រហែល ៣ ពាន់សិន ( ១២ គ.ម. ) ។

ឯជីវយើលុះបានជ័យជំនះត្រឡប់មកដល់បន្ទាយ ក៏ឲ្យបំណាច់រង្វាន់ ដល់ទាហានធំតូចទាំងពួង ហើយធ្វើសំបុត្រជាផ្លូវរាជការទៅដល់ស៊ុខគួន តាមដែលបានគតាំងចម្បាំងឈ្នះគ្រប់ប្រការ , ក្នុងពេលយប់នោះ ជីវយើ ក្រឡេកឃើញពន្លឺភ្លើងខាងទិសបស្ចិមជាច្រើន ក៏សួរទាហានទាំងពួងថា ពន្លឺភ្លើងអ្វី ? ។ ទាហានប្រាប់ថា ពន្លឺភ្លើងនោះគឺបន្ទាយចូច្ច ។ ជីវ យើឮដូច្នោះក៏ភ័យស្លុតចិត្ត លុះព្រឹកឡើងជីវយើក៏ចាត់ទាហានដែលមានថ្វី ដៃ នឹងគ្រឿងក្លែង ១រង់ គឺចាប៉ី ប៉ី ប្រ គ្រប់ប្រដាប់ ចុះទូក ១ ថែវ

ទៅជិតកងទ័ពចិន ហើយក៏ឲ្យធ្វើភ្លេងមហោរី ចែវបន្ទឹងទូកអ្នកលក់ទំនិញវិលទៅវិលមក ឃើញទាហានចិនតាំងក្បួនទ័ពទូក ឈួមនឹងទៀវអ៊ុនជាមេបញ្ជាការទាហានតាំងពួន ជីវយីឃើញដូច្នោះក៏ភ័យស្លុតចិត្ត ទើបសួរទាហានទៅជាមួយនោះថា នរណាជាមេបញ្ជាការប្រិតប្រៀនទាំងទ័ពទឹកចិននោះ ។ ទាហានដែលស្គាល់ច្បាស់ក៏ឆ្លើយថា ឯមេទ័ពទូកចិននោះ គឺឈ្មោះឈួម , ទៀវអ៊ុនជាអ្នកបញ្ជាការទាហានតាំងពួន ជីវ-យីឮដូច្នោះក៏គិតថា ឈួមនឹងទៀវអ៊ុននេះ ពីដើមវាពួកអ្នកស្រុកតាំងតាំង ចំណានក្នុងការចម្បាំងជើងទឹកណាស់ ចាំនឹងគិតកលឧបាយកំចាត់ឈួមនឹងទៀវអ៊ុនចេញឲ្យបាន ទើបយើងនឹងបានធ្វើសង្គ្រាមតនឹងចិនតទៅខាងមុខមិនព្រួយលំបាក ។

ក្នុងខណៈនោះទាហានចិនឃើញក៏យកសេចក្ដីទៅប្រាប់ចិនថា ជីវ-យីលបមកមើលទាហានយើងដែលកំពុងហ្វឹកហាត់នោះ ចិនក៏ប្រើទាហានតាំងពួនស្រូតរូតចែវទូកទៅនឹងចាប់ជីវយី ។ ក្រឡេកឃើញទូកចំឡែកចែវចេញមក ក៏ឲ្យទាហានតាំងពួនចំចែវរត់ត្រឡប់ទៅចូលបន្ទាយ ទាហានចិនឃើញជីវយីចែវរត់ទៅឆ្ងាយប្រហែល ១០០ សិន ( ៤ គ.ម ) នឹងដេញតាមមិនទាន់ ក៏ត្រឡប់វិលទៅប្រាប់ចិន ។ ក៏ប្រឹក្សានឹងទាហានតាំងពួនថា គ្រាមុនយើងក៏បែកនឹងជីវយីរត់មក លុះយើងនឹងឲ្យហ្វឹកហាត់ទាហាន ជីវយីក៏កាន់តែកំរើបចិត្តលបមកមើលទ័ពយើងទៀត គ្រានេះ

យើងក៏បានសេចក្ដីសប្បាយណាស់ អ្នកកល់គ្នាមិនយល់ឃើញប្រការម្តេច ទើបមិនបានសងសឹកជីវយើឲ្យបាន ។

ជៀវកានទីប្រឹក្សានិយាយថា ខ្ញុំបាទមិនជីវយើនោះកាលនៅពីតូចនៅឡើយបានរៀនសិប្បុគ្រគ្រូជាមួយគ្នា ហើយក៏មានចិត្តស្នេហ៍ស្រឡាញ់រាប់អានគ្នាជាច្រើន ខ្ញុំបាទមិនសុំអាសាចេញទៅបញ្ចុះបញ្ចូលជីវយើឲ្យស្នេហ៍គ្រមកនៅនឹងលោក ។ ចូច្ចបានឮដូច្នោះក៏ពេញចិត្តណាស់និយាយថា ដែលអ្នកមិនទៅនោះមុខជាមិនបានការឬ ? ។ ជៀវកានឆ្លើយថា ខ្ញុំបាទមិនសុំអាសាទៅបញ្ចុះបញ្ចូលជីវយើឲ្យខាងតែបាន ។ ចូច្ចថា ដែលអ្នកមិនទៅនោះមិនត្រូវការអ្វីខ្លះ ? ។ ជៀវកានថា ខ្ញុំបាទសូមតែមនុស្ស ២ នាក់ឲ្យល្មមតែចែវទូកទៅបាន ហើយមិនក្មេងម្នាក់តាមក្រោយទៅផង ។ ចូច្ចក៏ឲ្យចាត់ទូកមិនមនុស្សបានគ្រប់គ្រាន់ ហើយជៀវកានក៏លាចូច្ចទៅដល់បន្ទាយជីវយើ ហើយប្រាប់ទាហានយាមថា យើងជាកឿនសំឡាញ់ជីវយើ ឥឡូវលើកមកលេងជីវយើទើបមកដល់ ឲ្យអ្នកឯងចូលទៅជំរាបជីវយើឲ្យដឹង ។ ទាហាននោះក៏ចូលទៅជំរាបជីវយើតាមការ ។

ជីវយើឮដូច្នោះក៏ប្រាប់ទាហានទាំងពួងថា ដែលជៀវកានមករកយើងនេះ ប្រាថ្នានឹងបញ្ចុះបញ្ចូលយើង ជីវយើក៏ឲ្យបង្គាប់ទាហានជាការស្ងាត់ទុកជាច្រើនៗ រួចជីវយើក៏ចេញទៅទទួលជៀវកាននាំចូលមកក្នុងបន្ទាយ ទាំងសងខាងក៏គិតរាប់ប្រាស្រ័យបញ្ហាទៅវិញទៅមក ជីវយើក៏សួរ

ជៀវការទថា ចុះអ្នកនៅនឹងចុងជាសត្រូវរបស់យើង ដែលអ្នកមកត្រានេះ នឹងមកបញ្ចុះបញ្ចូលយើងឬ? ៗ ជៀវការទឮដូច្នោះក៏ស្ទុតស្ទុងក្នុងចិត្ត ទើបឆ្លើយតបថា ខ្ញុំមកនេះនឹងបានមកបញ្ចុះបញ្ចូលអ្នកក៏ទេ តែខ្ញុំនឹងអ្នកប្រាសនិកសន្តាមកយូរហើយ ខ្ញុំមានចិត្តរលឹកនឹកដល់រឿងកំសត់ ដឹងថាអ្នកមកនៅធ្វើការក្នុងទីនេះ បានជាខ្ញុំមកប្រាប់ថានឹងសួរសុខទុក្ខប៉ុណ្ណោះ បើអ្នកសង្ស័យដូច្នោះខ្ញុំក៏សូមលាអ្នកទៅវិញឥឡូវនេះ ៗ ជីវយើចាប់ទាញដៃជៀវការទទុកហើយនិយាយថា ខ្ញុំគិតថាអ្នកទទួលអាសាប្អូនមកបញ្ចុះបញ្ចូលខ្ញុំទេតើ បើអ្នកមកសួរសុខទុក្ខតាមធម្មតាទេ នឹងប្រញាប់វិលទៅថ្វី ៗ

ជីវយើធ្វើជាពេះពយហើយដឹកដៃជៀវការទចូលទៅក្នុង អញ្ជើញឲ្យបរិភោគអាហារហើយប្រាប់ទាហានទាំងពួងថា ជៀវការទនេះជាគឿនសំឡាញ់ស្និទ្ធរបស់យើង បានរៀនសូត្រគ្រូជាមួយគ្នាពីក្មេង អ្នករាល់គ្នាមិនត្រូវសង្ស័យនឹងជៀវការទដោយប្រការអ្វីមួយឡើយ ៗ ខណៈកាលជីវយើនឹងជៀវការទកំពុងផឹកស្រាស្រវឹងនោះ ជីវយើក៏ហូតក្រេបដែលស្ពាយនោះ បង្គាប់ឲ្យថៃស៊ូជួយយក ទៅកាន់ហើយថា ជៀវការទគឿនសំឡាញ់យើងមកសួរយើងផឹកស្រាលេងឲ្យសប្បាយចិត្តម្ដងចុះ បើបានឮនរណានិយាយសេចក្ដីបញ្ចេញឈ្មោះលំចូចក្ដី · ស៊ុនគួនក្ដី ឲ្យយក

ក្របីនេះកាត់ក្បាលចេញកុំឲ្យកោតញញើតឡើយ ថៃស៊ូជូក៏ទទួលយកក្របីនោះឈរចាំនៅទីនោះ ។

ជៀវកានឮដូច្នោះក៏ខ្លាចមិនបាននិយាយចេញសេចក្ដីអ្វី ។ ជីវយ៉េក៏ក្លែងនិយាយនឹងជៀវកានថា ខ្ញុំតាំងពីត្រឹមបានជាមេទ័ពមកគ្រានេះ ស្រាសូម្បីតែ ១ ដំណក់ក៏មិនចូលក្នុងបំពង់កសោះ ទើបតែថ្ងៃនេះអ្នកជាមិត្រសំឡាញ់មកសួរខ្ញុំ ។ ក៏បានផឹកស្រាលេងបន្ដិច ហើយជីវយ៉េក៏ដឹកដៃជៀវកានចេញទៅដល់មុខទ័ព ឃើញទាហានទាំងពួងពាក់គ្រោះកាន់ការុធផ្សេង ១ ឈរនៅជាជួររៀងគ្នា ទើបសួរជៀវកានថា ទាហានរបស់យើងនេះ អ្នកឃើញជាបែបយ៉ាងដូចម្ដេចខ្លះ ? ។ ជៀវកានតបថា ខ្ញុំបាទបានឮដំណឹងគេនិយាយថា ទាហានស្រុកកាំងតាំងនេះល្អច្រើនណាស់ ហើយប្រកបដោយថ្វីដៃខ្លាំងពូកែក្នុងការសង្គ្រាម ខ្ញុំមកឃើញថ្ងៃនេះក៏ឃើញស្លាញស្លូតបីដូចជាទាហានខ្លា សមនឹងពាក្យដែលល្បីឮជាប្រាកដណាស់ គួរនឹងធ្វើសង្គ្រាមតទៅ ។ ជីវយ៉េក៏នាំជៀវកានទៅខាងក្រោយបន្ទាយហើយចង្អុលឲ្យមើល ជង្រុកស្រូវដែលដាក់ស្បៀងអាហារថា អ្នកឃើញប្រការម្ដេច ? ។ ជៀវកានថាអ្នកទុកស្បៀងអាហារនោះ ឃើញថាបរិបូណ៌មាំមួនណាស់ សមគួរជាមេទ័ពមេកងណាស់ហើយ ។ ជីវយ៉េក៏ក្លែងថា ខ្ញុំនេះពីគ្រាដែលនៅរៀនសិល្បសាស្ត្រគ្រូជាមួយគ្នានឹងអ្នកនោះ មិនបានគិតឡើយថា ខ្ញុំនឹងតាំងបាន

ជាធំដល់ប៉ុណ្ណោះ ៗ ជៀវកានតបថា ឯចំណេះប្រាជ្ញារបស់អ្នកនោះមាន ច្រើនណាស់ ដែលបានជាទីនាយទាហាននេះគឺគួរសមណាស់ហើយ ៗ

ជីវ័យព្ទបុត្រនោះក៏ដឹកដៃជៀវកានដើរចូលទៅហើយ និយាយនឹងជៀវកានថា ឯពាក្យបុរាណមានពោលទុកថា ជន្មាកើតមកជាប្រុស ប្រសិននឹងស្វែងរកចៅហ្វាយនាយដែលនឹងយកជាទីពឹងនោះ ក៏ត្រូវឲ្យពិគ្រោះមើលចិត្តថ្លើមជាអ្នកមានអធ្យាស្រ័យប្រណីអ្នកតូច ហើយទៀនត្រង់ជាសច្ចធម៌ប្រាកដ ទើបលោកឲ្យចូលទៅនៅផង ហើយឲ្យតាំងចិត្តធ្វើពលការដោយសុចរិតពិតត្រង់ ឲ្យឃើញស្នាដៃជាគុណគាប់ប្រសើរ ទើបនឹងបានសេចក្តីសុខតទៅ ប្រការ ១ ឲ្យមានចិត្តមេត្រីដល់ញាតិបងប្អូន គៀនសំឡាញ់ចាស់ថ្មីកុំឲ្យដាច់ ប្រសិនបើនឹងមានភ័យអ្វីមកដល់ខ្លួន ក៏នឹងបណ្តាលឲ្យមានអ្នកមកជួយឈឺឆ្អាលកែខៃឲ្យរួចចាកភ័យអន្តរាយបាន បើនឹងគិតការអ្វីជាលំអានក៏នឹងបានសម្រេចតាមប្រាថ្នា ហើយជីវ័យក៏អស់សំណើច ៗ ជៀវកានបានឮជីវ័យនិយាយជាពាក្យពំនឹកដូច្នោះ ក៏គិតថានឹងបញ្ចុះបញ្ចូលជីវ័យនោះមិនសម្រេច ឲ្យមានចិត្តនោះមិនដាច់ស្រេចនឹងនិយាយ រឹតតែមិនសប្បាយក្រហល់ក្រហាយក្នុងចិត្តណាស់ ជីវ័យនាំជៀវកានចូលទៅបរិភោគអាហារ ហើយអ្នកជាទីប្រឹក្សានឹងទាហានក្នុងស្រុកតាំងតាំងនេះ មានទំនិតរិះគិតពាំនរ ប្រកបតាំងថ្មីដែលក៏ទាំងតូចកែជាច្រើន ៗ

លុះដល់ពេលព្រលប់ ជីវ័យក៏ឲ្យអុជទៀនជាច្រើនដួង ហើយក្លែងធ្វើជាភាំក្រប៊ីធ្វើក្បួនថា :

ធម្មជាតិកើតមកជាប្រុសប្រាជ្ញ ត្រូវធ្វើអង់អាចកុំខ្លាចស្លាប់
ទស្សនាហើយរៀនរិះរេះពាំចប់ ក្បួនច្បាប់សឹកសាមសង្គ្រាមជ័យ ។
ទើបមានយសាបណ្ណាសក្តិ ឯកអគ្គជាធំខាំប្រពៃ
វិជ្ជាដែលរះរេះឲ្យរះរៃ កងវៃសំដែងវ៉ែងឆ្ងាយហារ្យ ។
ឲ្យគេសមនុស្សម្នាមហាជន គយគន់ឃើញបុទ្ធិសិទ្ធិសក្តា
មួយឲ្យសំដែងវែងប្រាជ្ញា រៅហារដោះស្រាយទុក្ខាយតិត ។
ខ្លួនឃើញទាំងនេះនឹងចេះដឹង ចុះបើស្រវឹងគង់ដឹងមិត្រ
ដឹងមើលយល់មិនកាន់តាំងគិត តាំងចិត្តធ្វើក្បួនលេងសប្បាយ ។

ទីប្រឹក្សាទីនដាហានតាំងគួង ឃើញជីវ័យតាំងក្បួនក្រប់ពោលដូច្នោះ ក៏នាំគ្នាបិទមាត់ស្ងៀម ។ ដៀវកានទិយាយថា ខ្លួនខ្ញុំក៏ឡើងខ្សាយ ដឹកស្រាទៀតមិនបានទេ ទីប្រឹក្សាទីនដាហានតាំងគួង ក៏លាចេញទៅខាងក្រៅអស់ ។

ខណៈកាលជីវ័យស្រវឹងស្រា តែនៅមានស្មារតីម៉ាំមួនណាស់ ទើបក្លែងបបួលដៀវកានថា: អ្នកនឹងខ្ញុំមិនបានដេកជាមួយគ្នាយូរហើយ ថ្ងៃនេះចូរអ្នកនៅដេកនឹងខ្ញុំ ១ យប់ចុះ ហើយក៏ដឹកដៃដៀវកានចូលទៅដេកជាមួយគ្នា ។ ក្នុងខណៈនោះជីវ័យក៏ក្អួតចេញមកពេញខ្នើយនឹងពូក

កន្ទួល ហើយក្លែងធ្វើជាដេកបក់ទៅវិញ ។ ជៀវគានដេកមិនលក់សោះ ព្រោះជាវត្ថុដ៏រឹងខ្លួនភារ្យប្ដូរគវ៉ា ដឹងរញ្ជួយបញ្ចុះដីយើ គឺមិនមែន ដូចសេចក្ដីប្រាថ្នា កាលបើឃើញដីយើដេកបក់មន្ទប់ បន្ទិចហើយ ជៀវគានគិតថា ដីយើរស់ដឹងខ្លួនហើយ ក៏ក្រោកទៅដក់ផ្កាទៅ ចង្កៀងប្រហែលត្រដេក ឃើញសំបុត្រ ១ ច្បាប់បិទស្រោប កាន់ដឹងសេចក្ដី ថា «ខ្ញុំបាទឈ្មោះ ទៀវអ៊ិន" ហើយជៀវគានក៏ហែកស្រោមបញ្ចេញចេញយក មកមើលឃើញសេចក្ដីថា "ឈ្មោះ, ទៀវអ៊ិនគំនាប់មកដល់ដីយើ ដ្បិត ខ្ញុំបាទមកទៅទីដំបូងនេះព្រោះសេចក្ដីថា ចិត្តតែគិតចំណងមិនស្រាយ បើបាន ទ្រាស់វេលាណា ខ្ញុំបាទនឹងកាត់ក្បាលចូចូមកជូនលោក បើមិនបាន ដូចបំណងដែលគិតនោះទេ ខ្ញុំបាទនឹងឲ្យមនុស្សលបចេញមកដកហលោក រឿង ១" លុះឃើញសំបុត្រដូច្នោះហើយក៏ដឹងថា ឈ្មោះទីងទៀវអ៊ិនប្រែ ចិត្តចេញពីចូចូ ក៏យកសំបុត្រនោះលាក់ទុកក្នុងដៃអាវ លុះឃើញដីយើប្រែ ខ្លួន ជៀវគានក៏លក់ចង្កៀងចេញ ហើយក្លែងចូលទៅដេកធ្វើជាលក់ ស្កប់ស្កល់ត្រែ ។ ឯដីយើក្លែងធ្វើជាមមើរមើរនិយាយថា ទៅ ៤-៥ថ្ងៃ ទៀត ជៀវគានចូលមកយកក្បាលចូចូកន្លងបន្ទាយហើយចុះ ។ ជៀវគានក៏ សួរបញ្ជាក់ទៅដើម្បីឲ្យច្បាស់ ។ ដីយើក៏ធ្វើជាលក់ស្កប់ទៅវិញ លុះវេលា ប្រហែលយាម ៤ បាយ អាហានចូលមកស្រែកហៅដីយើ ១ ក៏ធ្វើជាភ្ញាក់ ឡើង ហើយក្លែងសួរថា នរណាហៅអី ? ក្រឡេកទៅម្ខាងឃើញ

ជៀវការនៈដេកនៅនោះក៏ថា នរណាមកដេកលើគ្រែនេះជាមួយនឹងអញ ជៀវការក៏ធ្វើជាលក់ស្និទ្ធនៅស្ងៀម ៗ ទាហានដែលហៅដីវយ៉េតបថា ជៀវការភៀនសំឡាញ់លោកមកដេកជាមួយ លោកភ្ញាក់ហើយឬ ៗ

ដីវយ៉េក៏ធ្វើជាភ្ញាក់ខ្លួនគិតឃើញថា យប់មកហើយ ហើយនឹងមិនដែលផឹកស្រាសោះ ថ្ងៃនេះផឹកច្រើនលើសលុបគ្រឿងប់ស្រវឹងវង្វេង និយាយផ្ដេសផ្ដាសប្រហែលជាការអាថ៌កំបាំងតាំងប៉ុន្មាន បាននិយាយអស់ទៅក៏មិនដឹងឡើយ ។ ទាហាននោះក៏ប្រាប់ដីវយ៉េថា ឥឡូវមានមនុស្សបម្រើមកគេហលោក ពុំជាពួកទាហានចូចូ ។ ដីវយ៉េក៏ធ្វើជាទៅហៅដាស់ជៀវការ ៗ ក៏ធ្វើជាមិនដឹងខ្លួនសោះ ដីវយ៉េក៏ចេញទៅដល់ក្រៅក្ដាបន្ទាយ ជៀវការក៏ច្រើនលបស្ដាប់ក៏ឮទាហានប្រាប់ដីវយ៉េថា ឈួម៉, ជៀវអ៊ុនឲ្យបំរើលៗមកជំរាបលោក ពីកិច្ចការដែលគិតធ្វើនោះ នៅមិនទាន់បានសម្រេចតាមគំនិតទេ ដីវយ៉េក៏ចូលមកដាស់ជៀវការ ៗ ក៏ធ្វើជាដេកលក់ ដីវយ៉េក៏ក្រឡាដេកបក់ទៅវិញ ប្រាថ្នានឹងឲ្យជៀវការដេកចេញទៅ ។

ជៀវការក៏គិតតែក្នុងចិត្តថា ដីវយ៉េនេះមានជម្រះប្រាជ្ញាជ្រៅឆ្ងាយណាស់ បើនឹងនៅចាំឡូដល់ព្រឹក មុខជាដីវយ៉េនឹងស្រាវជ្រាវរកសំរុក បើមិនឃើញក៏នឹងបៀតបៀនដល់ខ្លួនអញមិនខាន គិតហើយក៏ប្រុងស្មារតី លុះដល់ពេលយាម ៣ ប្រាយជៀវការក៏ប្រែកាយដោះឡើងស្លៀកពាក់ស្រេច ហើយលបបើកទ្វារនេះគេបរត់ពីក្នុងបន្ទាយចេញទៅ ។

ទាហានដីវយើដែលយាមផ្លូវឃើញដៀវកានក៏ធ្វើជាសួរថា លោកទៅណាភ្នាម ? ។ ដៀវកានប្រាប់ថា បើខ្ញុំទៅដល់ព្រឹកព្រហាមក្រែងនាំឲ្យដីវយើព្រួយរវល់មិនបានចាត់ចែងការសង្គ្រោមតាមស្រួល ពេលនេះមានចំនួលគួរហើយ យើងសុំលាទៅវិញ ទាហានក៏បើកឲ្យទៅ ។

ដៀវកានដើរចេញទៅដល់ទូកក៏ចែវចេញទៅ កាលដៀវកានទៅដល់បន្ទាយបូធ្លូក៏លួមពេះមថ្ងៃ បូធ្លូក្រោកឡើងឃើញដៀវកានដើរឡើងចែបប្លែកប៉ុល្លួមក៏សួរថា ដែលអ្នកទទួលអាសារពិតការនោះបានដូចបំណងដែរឬទេ ? ។ ដៀវកានឆ្លើយថា ឯដីវយើ នោះមានដម្រេះប្រាជ្ញច្លាតណាស់ បាននិយាយល្បងល្បួងលោមមិនសមប្រកបតាមគំនិតនោះ ៗ បូធ្លូក៏ថ្លែងថាក៏ខឹងប្រឡោតស្រែកថា ទទួលការសារទៅគ្មានបានប្រយោជន៍អ្វីសោះ បើម្នីងដីវយើមិនសើចឲ្យយើងអង្វរយសទៀតទេឬ ។ ដៀវកានថា ខ្ញុំបាទក៏ទឹកឈឺក្នុងចិត្តណាស់ដែរ តែថាបើទៅបញ្ចុះបញ្ចូលដីវយើមិនបានសមដូចគិត ខ្ញុំបាទក៏មានគំនិតយ៉ាងមួយបានមកដែរ គឺជាការធំចម្លែកណាស់ បើនឹងដកបទលោកឲ្យជ្រាបច្បាប់ក្នុងគ្រានេះក៏មិនគួរ ។

បូធ្លូក៏ឲ្យដេញទាហាននឹងមនុស្សម្នាក្នុងទីនោះចេញអស់ ។ ដៀវកានក៏ហុតយកសំបុត្រឈ្លូម៉,ទៀវអ៊ុនជូនទៅឲ្យបូធ្លូមើល ។ បូធ្លូក៏ទទួលមើលដឹងសេចក្តីហើយខឹងខ្លាំងណាស់ថា យើ! ឈ្លូម៉,ទៀវអ៊ុនបានគិតធ្វើការចិនងអញដល់ទីនេះម្ដងឬ បូធ្លូឈឺចិត្តខ្លាំងណាស់ ឲ្យហៅឈ្លូម៉,ទៀវអ៊ុនចូល

មករ ហើយប្ដូរថា យើងនឹងឲ្យខ្ញុំទាំងពីរនាក់លើកកងទ័ពចូលទៅច្បាំងនឹងដីវ៉េយ៉ាទុង ឈ្មួ៎.ទៀវអ៊ិនឆ្លើយថា តាហានទាំងពួនដែលខ្ញុំបានបានជ្រើសបង្ហាត់នោះនៅមិនទាន់ស្ទាញស្ទាត់សោះ សូមលោកអនុគ្រោះបន្ថែមឈើរបន្តិចសិន នឹងបានចំប្រើបង្ហាត់ឲ្យប្រសប់ទានទូក ទើបនឹងលើកទៅធ្វើការបង្ក្រាបបាន ។ ប៊ូឆ្វាបានឮដូច្នោះក៏កើតតែមានសេចក្ដីក្រេវក្រោធជាខ្លាំងណាស់ ហើយថា ដែលខ្ញុំនឹងឲ្យបន្ថែមទុកចំពោះតាហានបានចេះស្ទាត់ក្នុងក្បួនទូកនោះ ក្បាលអញនឹងមិនទៅនៅក្នុងបន្ទាយដីវ៉េទេឬ ឈ្មួ៎.ទៀវអ៊ិនមិនបានដឹងសេចក្ដីអ្វីសោះ ក៏នៅស្ងៀមមិនឆ្លើយតបដូចម្ដេច ។ ប៊ូឆ្វាឲ្យបាត់ខ្ញុំឈ្មួ៎.ទីងទៀវអ៊ិនទៅប្រហារជីវិតមួយរំពេច តាហានក៏នាំទៅសម្រេច ហើយកាត់យកក្បាលមកជូនប៊ូឆ្វាក្រឡេកឃើញក្បាលនាយតាហានទាំងពីរក៏មានសតិនឹកលើកឃើញបានថា យើងបាញ់កលចុះបាយជីវ៉េព្រោះមិនទាន់ត្រិះរិះ ក៏ឲ្យសម្លាប់ឈ្មួ៎.ទៀវអ៊ិនចេញនោះជាខុសទទេសោះ ។ លុះនឹងហាមាត់និយាយឲ្យដឹងថាគិតខុស ក៏ខ្លាចអាក្រក់ឈ្មោះដល់ពួកតាហានក្រោមបង្គាប់នឹងមិនកោតក្រែងគេ ។

ចំប្រើក្បាលនៃតាហានទាំងពួន ឃើញប៊ូឆ្វាឲ្យសម្លាប់នាយតាហានទាំង ២ ដូច្នោះក៏មានសេចក្ដីសង្ស័យ ទើបនាំគ្នាចូលទៅជំរាបសួរប៊ូឆ្វាថា ឈ្មួ៎.ទៀវអ៊ិនខុសពីអ្វី បានជាលោកឲ្យប្រហារជីវិតដូច្នេះ ? ។ ប៊ូឆ្វាឮដូច្នោះក៏ក្លែងឆ្លើយថា ឈ្មួ៎ ទៀវអ៊ិនជាមនុស្សខិលប្រឆ្ងួស ប្រើការមិនកើត បានជា

ឲ្យសម្លាប់ចោលទៅ ។ តាបាននាំនឹងពួកពួកផងគ្នាក៏ជជែកផ្តើមចាប់គ្នាហើយ គិតថា អម្បាលឈ្មោះ ទៀតអ៊ុំនេះ ស្ងាហាន់ធ្វើការកបត់ការតាំងម្ទុះ មើលក៏នឹង ទៅខ្វិលច្រឹសួរទៀត ចំណាន់ហើយប្រយើងកល់គ្នាដឹងថាយ៉ាងម្តេច តាបាន តាំងពួកក៏ទៅស្មៀមមិនបានជាប្រាកដម្តេច ។ ពួកចុំតាំងឱ្យរឹងមាំមីការយ ដានាយតាបានទូត ឲ្យប្រៀនបង្អាក់កូនតាបានតមក ។

ឯចំពេលដែលយាមល្បាត លុះដឹងដំណឹងថា ចូចុសម្លាប់ឈ្មោះ ទៀតអ៊ុនហើយ ក៏បកបាបក្តីនោះទៅវិការដីយើងទុប្រាប ដីយើងនឹងកាផ្ទះបា ក៏មានសោមនស្សត្រេកអរណាស់ឥតប្រួយតែក្ត ។ ខខួបឡោសុក ចូលទៅសួរដីយើងថា គំនិតប្រាជ្ញារបស់លោកដែលគិតធ្វើកលឧបាយ បានយ៉ាងនេះ នឹងញាញៀតខ្លាចអ៊ូដល់ថ្ងៃរបស់ចុកនោះ ។ ដីយើងថា ដែលខ្ញុំគិតធ្វើកលគ្រោះនេះ បណ្តាតាបានពួកយើងគ្មាននរណាអាចដឹងដល់ទេ ខ្លាចមួយតែខុងបងម្នាក់ ត្រែងនឹងបេរគិតគំនិតឃ្លាំងយើងបាន ហើយបង្អាប់ឡោបុកឡោទៅនាំនិយាយមើលកលការខុសបង នឹងអាចកន្ទង ដឹងការដែលយើងគិតនេះដែរម្តេច ។ ឡោបុកខ្ចួលពាក្យហើយក៏លា ទៅជួបនឹងខុងបងនិងចួកគួចហើយថា ខ្ញុំនឹងមកសួរលោកក៏មិនបានចិនៃ ព្រោះមានការធ្វើកបាយស្បៀងអាហារឲ្យតាបានជានិច្ច ។ ខុងបងថា គ្រានេះដីយើងធ្វើការមានគាប់ប្រសើរ ខ្ញុំក៏បណ្តោយតាមចិត្តណាស់ តែនៅមិនទាន់បានទៅគំនាប់ដីយើងទទួលអំណរ ។ ឡោសុកសួរថា លោក

ត្រេកអរថា ជីវ័យមានសេចក្ដីគាប់ប្រសើរនោះដោយហេតុអ្វី ?ៗ ខុនបេង ថាជីវ័យប្រើអ្នកមកសង្កេតស្ដាប់ខ្ញុំថា ដែលគិតធ្វើការនោះខ្ញុំនឹងដឹងដែរឬទេ ខុនខ្ញុំដឹងអស់ហើយ បានជាមានសេចក្ដីត្រេកអរផង ។ ឡោសុកឮដូច្នោះ ក៏តក់ស្លុតក្នុងចិត្តមុខនោះស្រើស្លុតទៅហើយសួរថា ហេតុម្ដេចបានជា លោកដឹងសេចក្ដីដូច្នេះ ? ។ ខុនបេងតបថា គំនិតរិះគិតរបស់ជីវ័យនោះ ក្នុងបានតែយ៉ាងជៀវកាន ។ ទៅប្រាប់ប៉ូចូ ។ មិនទាន់គិតទៅសម្លាប់ឈ្លួម៉ំ, ទៀវអ៊ិនទៅ លុះប៉ូចូគិតឃើញជាក្រោយក៏មានមាត់:មិនបានហើយ ហាមាត់និយាយថាខ្លួនធ្វើខុស ឯដែលឈ្លួម៉", ទៀវអ៊ិនស្លាប់នោះ គឺជាភ័ព្វរបស់ស្រុកកាំងតាំងទើងមិនអន្តរាយ បានជាខ្ញុំព្រមត្រេកអរផងដោយហេតុនេះ ឥឡូវប៉ូចូប្រើអ៊ុតឹម,ម៉ាកយជាអាយទ័ពទូកវិញនេះឃើញថានឹងនាំឲ្យទាហានទាំងឡាយមកអន្តរាយស្លាប់ទាំងអស់ ព្រោះអ៊ុតឹមនឹងម៉ាកយនោះមិនចំណានក្នុងទ័ពទូកៈសោះឡើយ ។ ឡោសុកឮហើយក៏ត្រូវក្បាលមិនឆ្លើយថាប្រការម្ដេចសោះ ។

ខុនបេងក៏ក្រូនងាហាមឡោសុកថា ពាក្យដែលខ្ញុំនិយាយទាំងនេះ អ្នកកុំនាំទៅប្រាប់ជីវ័យឡើយ ព្រោះចិត្តថ្លើមជីវ័យនោះ ជាមនុស្សថ្មប្យា គិតតែប្រហារជីវិតខ្ញុំមិនឈប់ ។ ឡោសុកទទួលពាក្យហើយលាខុនបេងទៅ ក៏នាំយកសេចក្ដីនេះទៅអធិប្បាយប្រាប់ជីវ័យគ្រប់ប្រការ តែខដែលខុនបេងថាចិត្តជីវ័យថ្មស្យាគិតប្រទូសរ៉ាយខុនបេងនោះ ឡោសុកមិន

និយាយ ដីវយើឮពាក្យអតិប្រាយដែលឡាសុកប្រាប់ដូច្នោះក៏ស្លុតក្នុងចិត្ត ហើយថាគំនិតគិតរបស់ខុនបេងនេះជ្រៅទូលាយធ្ងាយណាស់ ត្រូវតែខំរិះគិតសម្លាប់ចេញឲ្យបាន ទើបនឹងរស់ចំរុងរំពស់ក្នុងចិត្តទៅ ។ ឡាសុកថា ខុនបេងនោះគ្មានសេចក្ដីខុសពីអ្វីសោះ លោកនឹងសម្លាប់ចេញនោះ ខ្ញុំក៏ត្រូវរិះគិតឲ្យគួរគោរ មិនទំនេរបង្អាក់នាទាន ឡាសុកសួរថា ដែលនឹងសម្លាប់ខុនបេងនោះ គំនិតរបស់លោកគិតយ៉ាងម្ដេច ? ។ ដីវយើថា អ្នកកុំបាច់សួរគេអំពីគិតរបស់ខ្ញុំឡើយ ចាំតែមើលទៅមុខចុះ ។

លុះវេលាព្រឹកឡើង ដីវយើក៏ឲ្យប្រមូលនាយទាហានទាំងពួងចូលទៅព្រះន្ទា ហើយឲ្យអញ្ជើញខុនបេងទៅជំនុំគិតការពេជ្ឈឃាតផែនដី ។ ខុនបេងដឹងដូច្នោះក៏មានសេចក្ដីសោមនស្សណាស់ ចូលទៅក្នុងបន្ទាយ ។ ដីវយើក៏សួរខុនបេងថា ដែលយើងធ្វើបង្ក្រាមដេញទឹកគងទ័ពចូចចូកគ្នានេះ ត្រូវយកការផ្លូវណាជាប្រធាន ? ខុនបេងថា បើចង់ឲ្យដីនទឹកត្រូវជាក់ទាហានឲ្យកាន់ក្ដាប់ក្រុមដៃ ដីវយើក៏ធ្វើជាត្រេកអរប្រាស្រ័យទៅទៀតថា អ្នកនិយាយនេះត្រូវនឹងគំនិតខ្ញុំគិត តែថាក្នុងកងទ័ពយើងនេះមានព្រួញក៏តិចណាស់ ការចាំងអម្បាលនេះស៊ីងជាធុរៈរបស់ទៅហ្វាយយើងចាំងសងខាងដូចគ្នា អ្នកចូរជួយរិះគិតធ្វើជានាយកង កេណ្ឌឲ្យជាងធ្វើព្រួញឲ្យទាន់ក្នុងរវាង១០ថ្ងៃឲ្យបានចំនួន១០ម៉ឺន ។ ខុនបេងឮដូច្នោះក៏ដឹងដល់ក្នុង

យោបល់របស់ដីវយើ ទីវត្ថើយថា លោកទិញយកព្រួញ ១០ម៉ឺនក្នុងរវាង១០ ថ្ងៃនោះយូរណាស់ ។

ដីវយើថា ការសឹកមកប្រភាល់គ្នាដូច្នេះ អ្នកមកនិយាយជាល្បែងលេងមិនគួរ ការទៅហួយយើងនឹងខូចទៅ ។ ខុងបេងថា ខ្ញុំនិយាយនេះជាពាក្យពិតព្រោះថា១០ថ្ងៃនោះយូរណាស់ កងទ័ពចូចូក៏មកតាំងជិតគ្នានៅនេះខ្មាំងនឹងលើកមកច្បាំងឆាប់ ព្រួញក៏គ្មានស្រាប់នឹងមិនទាន់ការទេចុះ ខ្ញុំនឹងគិតឲ្យបានព្រួញតែត្រឹមរវាង ៣ថ្ងៃ ចូរឲ្យលោកប្រើមនុស្សឲ្យទៅចាំទទួលយកចុះ ។ ដីវយើថា បើមិនបានក្នុង១០ថ្ងៃអ្នកនឹងឲ្យធ្វើម្តេច ? ។ ខុងបេងក៏ឲ្យសញ្ញាទុកដាច់ខាតថា បើប្រសិនក្នុង៣ថ្ងៃមិនបានព្រួញ១០ម៉ឺនទេ សូមឲ្យលោកសម្លាប់ខ្ញុំចោលចុះ តែថាបើខ្ញុំខុសខាតអ្វីមួយនឹងត្រូវតែមករកលោកមិនជួយ ខ្ញុំនឹងប្រាប់ត្រឹមឡោសុក សូមឲ្យលោកព្រមអនុញ្ញាតផង ។ ដីវយើឮដូច្នោះក៏ទទួលពាក្យ ទើបផ្តាំទុកដាក់ឲ្យឡោសុកដឹងហើយក៏ឲ្យចុះពាក្យថាកំណត់កត់សំដីខុងបេង ជាសំ-គាល់ ដីវយើក៏នាំខុងបេងផឹកស្រាហើយថា ការតាំងអន្សាលនេះ បើបានសម្រេចហើយអ្នកក៏នឹងបានសេចក្តីគាប់ចិត្តប្រពៃណាស់ ។

លុះខុងបេងបរិភោគហើយក៏លាដីវយើចុះទូកទៅ ។ ឡោសុកក៏សួរដីវយើថាដែលខុងបេងទទួលនឹងធ្វើព្រួញ ១០ ម៉ឺនឲ្យទាន់ក្នុង៣ថ្ងៃនោះខ្ញុំឃើញជាមុខជាមិនទាន់ ។ ដីវយើថា ខុងបេងទទួលភាសាខ្លួនឯង

បើមិនបានដូចពាក្យថានោះទេ យើងក៏ត្រូវសម្លាប់ចេញ មនុស្សទាំងពួង ក៏រកផ្លូវតែហោរាទិញ្ញាគ្មានសោះ គ្រានេះមុខជាខុនបេនទឹងអស់អាយុហើយ ពោះបើមានស្លាបហើរក៏មិនផុតពីដៃយើងបាន ហើយដីវយើលបបង្គាប់ ពាហានឲ្យស្រូតទៅប្រាប់ជាងដែលធ្វើព្រួញ ឲ្យកែកូនធ្នូជាយឺតយូរកុំឲ្យ ទាន់ក្នុងពាថ្ងៃ យើងទឹងចង់ដឹងមើល ប្រាជ្ញាខុនបេនទឹងគិតយ៉ាងម្តេចហើយ ដីវយើប្រើឡោសុកទៅស្តាប់គរតើខុនបេនទឹងរិះគិតដូចម្តេចខ្លះ ៗ

ឡោសុកក៏ទៅជួបទឹងខុនបេនៗឃើញហើយក៏និយាយថា ខ្ញុំបាន ហាមប្រាមអ្នកជាកុំឲ្យយកសេចក្តីដែលនិយាយគ្នានោះ ទៅស្រាយប្រាប់ ដីវយើឲ្យសោះ អ្នកក៏មិនស្តាប់ ឥឡូវដីវយើក្រែងគិតទឹងសម្លាប់ខ្ញុំចេញ បានជាឲ្យខ្ញុំនេះមិនធ្វើជានាយកងសាងព្រួញ ១០ ម៉ឺនឲ្យទាន់ក្នុង ៣ ថ្ងៃ ឯការនេះមុខជាធ្វើមិនទាន់ទេ មុខជាខ្ញុំនឹងមានទោសហើយ អ្នកចូរជួយ គិតដោះសារដូចម្តេច ឲ្យខ្ញុំបានរួចពីទោសនេះផងចុះ ៗ ឡោសុកតប ថា ចិត្តរបស់ខ្ញុំជាមនុស្សទៀងត្រង់ បាននាំរឿងទៅប្រាប់ដីវយើនោះវា ខុសណាស់ទៅហើយតែថាពីដើមដីវយើឲ្យធ្វើព្រួញឲ្យបានក្នុង១០ថ្ងៃលោក ទទួលកាត់ស្រូតឲ្យតិចថ្ងៃទៅវិញមិនតែប៉ុណ្ណោះ ថែមចុះសញ្ញាថានឹងធ្វើឲ្យ បានក្នុងរវាង ៣ ថ្ងៃ ដែលថាឲ្យខ្ញុំជួយកែខៃនោះឃើញថាទញ់ទល់ពេក ណាស់ ៗ ខុនបេនថាបើអ្នកមិនអាសូរករុណាក៏ទាល់គំនិតទឹងគិតហើយ តែនៅឡើយ១ខទៀត សុំឲ្យអ្នកការណាគេតចម្បើងឲ្យបានច្រើន ទឹង

សំពត់ខ្មៅឲ្យបានច្រើនជាប់ ហើយនឹងខ្លាញ់សម្រាប់នឹងជុះលាងជូតព្រួញ រួចសុំឲ្យរកទូក២០ នឹងមនុស្សចំណុះទូក៣០ឬ៤០នាក់ក្នុងទូក១ដើម្បីនឹងបានជួយផ្ទុកព្រួញនាំទៅឲ្យដំរីយ៍ចុះ ។

ឡាសុកបានស្ដាប់កំទូលពាក្យ តែនៅមានសេចក្ដីសង្ស័យមិនស្រឡះក្នុងចិត្តសោះ ព្រោះមិនបានដឹងជម្រះប្រាជ្ញាខុនបេននឹងធ្វើយ៉ាងម្ដេច ហើយក៏លាខុនបេនទៅនិយាយប្រាប់ដំរីយ៍ថា មិនបានឃើញខុនបេនចាត់ចែងឲ្យធ្វើព្រួញទេ តែខុនបេនសុំឲ្យយកទូកទៅផ្ទុកដឹកយកព្រួញមកជូនលោកឲ្យទាន់វេលា ។ ដំរីយ៍ឮដូច្នោះក៏អរណាស់ថា ខុនបេនគ្រានេះមិនរួចពីស្លាប់ ហើយក៏បង្គាប់ឡាសុកថា ខុនបេនត្រូវការរបស់អ្វីក៏ឲ្យយកទៅឲ្យចុះ ឡាសុកក៏ចេញមកចាត់ចែងរកទូកបាន ២០ នឹងទាហាននូវរបស់ទាំងពួងត្រៀមទុក លុះគំរប់ ៣ ថ្ងៃក៏មិនឃើញខុនបេននឹងធ្វើអ្វីសោះ ឡាសុករឹតតែមានសេចក្ដីសង្ស័យខ្លាំងណាស់ លុះពេលកណ្ដាលយប់ក្នុងថ្ងៃនោះ ខុនបេនក៏ឲ្យទៅអញ្ជើញឡាសុកមកហើយនិយាយថា ព្រួញឯនោះខ្ញុំធ្វើទុកបានគ្រប់ចំនួនហើយ ឲ្យយករបស់ដែលខ្ញុំបង្គាប់នោះមកឲ្យឆាប់ ៗ នឹងបានធ្វើការទាំងទូកនឹងមនុស្សដឹកជញ្ជូនព្រួញយកទៅចុះ ។ ឡាសុកក៏ឆ្លើយថា លោកកុំវិតក្កឡើយ ការទាំងអស់ខ្ញុំបានត្រៀមទុកជាស្រេចហើយ ។

ឡាសុកក៏ឲ្យទូកមក ។ ខុនបេនចុះទូកហើយក៏បបួលឡាសុកថា

អ្នកចូរទៅជាមួយនឹងខ្ញុំចុះ ដើម្បីទៅទទួលយកព្រញ្ញឲ្យដីរយ៉ ។ ទៀ សុកក៏សួរថាលោកនឹងទៅយកព្រញ្ញឯទីណា? ។ ខុនបេនថា អ្នកកុំបាច់សួរខ្ញុំឡើយ ចូរទៅជាមួយគ្នាចុះទើបនឹងដឹង ហើយខុនបេនក៏ថយទូកចម្បាំងនោះទៅ ទើបឲ្យបង់ចម្បើងទឹងស្នោក្លាប់រៀងគ្នាតាមកែមទូកទាំងសងខាង ហើយយកសំពត់ខ្មៅរុំបាច់ចម្បើងទឹងបាច់ស្នោទាំង ២០ ទូក ដូចជារូបមនុស្សអង្គុយតាមកែមទូកដិតគ្នា លុះរៀបចំស្រេចកាលណា ក៏ឲ្យយកពួចងសណ្ដោងក្លាប់ទូកទាំងអស់ ហើយចែវឡើងទៅដល់កងទ័ពចូច្ចូវេលាប្រហែលយាម ៣ ថ្នាយ ។

សម័យនោះ ជាខែកត្តិកខាងរនោចមេឃងងឹតពពកចុះអ័ព្ទ ខុនបេនក៏ឲ្យទាហានកងទ័ពទាំងពួង វាយគងស្គរ ស្រែកហោអឺងកងឡើង ។ ទៀសុកឃើញដូច្នោះក៏តក់ស្លុតស្មារតីញ័រអស់ទាំងខ្លួន បីដូចគេអង្គុយក្ដិតគំនរភ្លើង ព្រោះមិនទាន់ដឹងហេតុផលជាប្រការម្ដេច ទើបសួរខុនបេនថាទាហានឃើញមកនេះតិចណាស់ បើប្រសិនចូច្ចូលើកទ័ពទូកមកច្បាំងតើលោកនឹងគិតតតាំងយ៉ាងម្ដេច ? ។ ខុនបេនអស់សំណើចហើយថា វេលានេះមេឃចុះអ័ព្ទងងឹតណាស់ កាលណាចូច្ចូនឹងអាចលើកទ័ពទូកចេញមក អ្នកនឹងខ្ញុំត្រូវនាំគ្នាផឹកស្រាលេងឲ្យសប្បាយចិត្តទំរាំតែភ្លឺស្រាង សឹមយើងថយទូកបណ្ដែតត្រឡប់មកវិញ ។

ឯចូច្ចូលុះឮសំឡេងគងស្គរហោកញ្ជ្រៀវអឺងកងដូច្នោះ ក៏ដឹងថា

ទាហានដ៏វយ៉ៃលើកមកលុកកងទ័ព ទ្រង់ឲ្យទូកចម្បាំងចេញទៅតយុទ្ធ ប្រញាប់ ព្រោះមេឃងងឹតណាស់ មើលមិនឃើញគ្នាច្បាស់ ក្រុង ដ៏វយ៉ៃឲ្យទាហានពួនបង្កប់នៅខាងណាក៏មិនដឹង ទើបប្រើអុជគោមទីងមីកាយ យកទូកចម្បាំងចេតទុកឲ្យជាប់ ឲ្យតែទាហានទាំងពួងបាញ់ផ្ទុះចម្រុះទៅ ហើយឲ្យចៀវលៀវ ស៊ីឡូន លើកទាហានជាច្រើនចុះទៅបាញ់ទាហាន ទូកដ៏វយ៉ៃតាមប្រាំងទន្លេ ឯទាហានជើងគោកតែងទឹកទាំង២កងឃើញតែ ទូករៀងគ្នាហែរមក មិនបានឃើញទាហានជាច្រើនឬតិច ក៏ឲ្យទាហាន បាញ់ព្រួញផ្ទុះចម្រុះទៅ ហើយឲ្យចៀវលៀវ,ស៊ីឡូន លើកទាហានជា ច្រើនចុះទៅបាញ់ទាហានទូកដ៏វយ៉ៃតាមប្រាំងទន្លេ ឯទាហានជើងគោក ទឹងទឹកទាំង២កង ឃើញតែទូករៀងគ្នាហែរមកមិនបានឃើញទាហាន ជាច្រើនឬតិច ក៏ឲ្យទាហានបាញ់ព្រួញចម្រុះសំដៅទៅចំទូកចម្បាំង នោះដូចគ្រាប់ភ្លៀង ។ ខុងបេងឲ្យទាហានក្នុងទូកទាំងអស់ក្រាបបំបាំងខ្លួន រូបចម្លើងស្មៅមិនត្រូវទឹកព្រួញសោះ លុះឃើញព្រួញដែលបាញ់ធ្លាក់ មកជាប់នឹងរូបចម្លើងរូបស្មៅជាច្រើនហើយ ក៏ឲ្យបង្អង់ឈប់វាយគងស្គរ ទៅវិញ ហើយត្រឡប់បង្វិលទូកពីម្ខាងដើម្បីនឹងទទួលព្រួញម្ខាងទៀត ហើយឲ្យវាយគងស្គរអឺងកងឡើង ឃើញព្រួញជាប់ច្រើនហើយទទួល ភ្លឺស្រាង ៗ

(នៅមានត)

# ពាក្យវប្បធម៌

លោក សម-ថាំង សមាជិកគណៈកម្មការវប្បធម៌ រៀបរៀង

---

គណៈកម្មការវប្បធម៌ បានស្រង់យកពាក្យចំនួន៤ម៉ាត់ មកនាំអស់លោកអ្នកហាត់អាន ឲ្យបានរត់មាត់, ហើយនិងអធិប្បាយពន្យល់អំពីន័យរបស់ពាក្យនីមួយៗ តទៅទៀត ។

ពាក្យដែលបានស្រង់យកមកអធិប្បាយជូនក្នុងពេលឥឡូវនេះគឺ:

១- អគ្គសញ្ញាណកម្ម;

២- អគ្រានុក្កូលដ្ឋាន;

៣- អគ្រដ្ឋកាយ;

៤- អគ្គវិញ្ញាណ ។

ឥឡូវសូមយកពាក្យមួយ ១ តាមលំដាប់លេខរៀងមកអធិប្បាយៈ

១ - អគ្គសញ្ញាណកម្ម : កុំអានថា អ:- គ:- ស:- ញា- ណ:- កម្ម , ឬសាញ់ញាន- ត្រូវថា សាញ់ញ៉ាន; ត្រូវអានឲ្យអស់តួអក្សរ ព្រោះតួអក្សរ គ និងអក្សរ ញ សុទ្ធតែមានសំយោគ ។ សុំអាន អ័គ-គៈ-ស័ញ-ញ៉ាណៈ- កម្ម ។ សរសេរ = អ- គ- ជើងគ ស -ញ- ស្រះអា ជើងញ- ណ- ក ម-ជើងម ព្រោះតួសរៀងពីខាងដើម, ស សង្កត់ឬសម្លាប់ -ញ- ជាញ់ ដូចពាក្យថា សញ្ញា ជាដើមនោះដែរ, កុំថា សាញ់-

ញាន: , ត្រូវថា សាញ់-ញាំណៈ ។ អត្តសញ្ញាណកម្ម ជាពាក្យបាលី កើតមកពីសព្ទបីបទគឺ អត្ត: ប្រែថា ខ្លួន ឬចិត្ត ១,សញ្ញាណ: ការសំគាល់១,និងកម្ម: ប្រែថា អំពើ១ ។ រួមពាក្យទាំងបីមកនេះមកបានជា អត្តសញ្ញាណកម្ម ។នាមនាមដែលរួមបទច្រើនសព្ទជានាមដូច្នេះ ហៅថា សមាសនាម ។ ពាក្យនេះប្រែតាមអត្ថានុរូបថា អំពើសម្រាប់សំគាល់ខ្លួន,តាមអត្ថព្យញ្ជនរូបថា អំពើឬកិច្ចការដែលគេធ្វើ សម្រាប់សំគាល់ខ្លួនមនុស្ស ឬសត្វ;ត្រូវនឹងពាក្យបារាំងថា (Identification) ។

សុំជូនឧទាហរណ៍ ជាប្រយោគឲ្យងាយយល់ដូច្នេះ៖

ប៉ូលីសថៅដៃមួយ ដែលធ្លាប់ទុកចោល នៅមុខផ្ទះនាយ ក ឥឡូវក្រុមព្រះនគរបាលជាតិបានធ្វើអត្តសញ្ញាណកម្មទៅ ឃើញជាក់ជារបស់ឈ្មោះនាយ ខ ។

ឧទាហរណ៍ ប៉ុណ្ណេះ ជាការបញ្ជាក់ជូនអស់លោកអ្នកស្ដាប់អំពីពាក្យថា អត្តសញ្ញាណកម្ម នេះហើយ ។

សុំអញ្ជើញអានពាក្យទី២ តទៅទៀត សុំអញ្ជើញអាន !

អគ្រានុគ្គលដ្ឋានៈ កុំអាន អៈ-គ្រា-នុ-គូ លៈ ឋាន ព្រោះអក្សរគ្រជាតួតម្រួតគ្រវាត់ នឹងបមានសំយោគ ត្រូវយកចុងអណ្ដាតទល់នឹងជើងធ្មេញខាងមុខ ឲ្យឮសំឡេងថា អាត់-គ្រា-នុ-គូ-ល័ត-ឋាន។ ពាក្យ

ខេះសរសេរៈអ.ត.ដើម-រ.ស្រៈអា.ន ប្រៈ១ ក.ស្រៈអូ.ល.ជ. ស្រៈអាដើម ប មុខជៈនឹង ន ។ អត្រានុកូលដ្ឋាន ជាពាក្យសំស្រ្កឹត នឹងបាលីលាយគ្នាកើតមកពីសព្ទ៣ម៉ាត់គឺអាត្រៈ(សំ.)បាលីថា អត្តៈ១, អនុកូលៈ១ នឹងឋានៈ១ ។ អត្រៈឬអត្តៈ ប្រែថា ខ្លួនឬចិត្ត,អនុកូលៈ ប្រែថា អនុលោមតាម, បណ្ដោយតាម,ស្របតាម;ឋានៈ ប្រែថា ទីតាំង,ផ្សំចូលគ្នាទាំង៣ម៉ាត់បានជា អត្រានុកូលដ្ឋាន ជាសមាសនាម. ព្រោះរួមសព្ទច្រើនបទបញ្ចូលមកឲ្យបានជាពាក្យមួយម៉ាត់ ។ អត្រានុកូលដ្ឋាន ប្រែតាមអត្ថានុរូបថា "ទីតាំងដែលអនុលោមទៅតាមខ្លួន" តាមអត្ថប្បដិរូបសន្មតហៅបញ្ជីកើតស្លាប់នឹងអាពាហ៍ពិពាហ៍ឬអាពាហ៍វិវាហមង្គលនៃជនានុជនក្នុងកម្ពុជរដ្ឋ ត្រូវនឹងពាក្យបារាំងថា (Etat civil) បើមានពាក្យថា មន្ត្រីភ្ជាប់ពីខាងមុខទៅជាមន្ត្រីអត្រានុកូលដ្ឋាន គឺសំដៅចំពោះអ្នកធ្វើការជាអ្នកកាន់បញ្ជីកើតស្លាប់នឹងអាពាហ៍ពិពាហ៍វិញ,បានដល់មេឃុំ នឹងចៅហ្វាយក្រុងជាដើម ត្រូវនឹងពាក្យបារាំងថា (Officier de l'état civil) ។

ជូនប្រយោជន៍ជា១ឧទាហរណ៍ឲ្យយល់ដូច្នេះ ៖ យុវជនខ្មែរយើងច្រើនតែពុំសូវបានចុះអត្រានុកូលដ្ឋានទេ នៅពេលបន្ទាប់ពីថ្ងៃកើត ម្ល៉ោះហើយដល់ត្រូវការ គេនឹងត្រូវសុំសាលក្រមកំណើតទៀត ។ កាលដែលយាយតាគេទទួលមរណៈកូនប្រុសស្រីរបស់គាត់ពុំបានចុះអត្រានុកូលដ្ឋានទេ ។

នាយទ្រឹងនានេយ្យ ដែលរួមសមគ្គសង្វាសនឹងគ្នា ជាប្តីប្រពន្ធហ៊ុត

ដល់សព្វថ្ងៃ ពុំបានចុះអត្រានុកូលដ្ឋានដូចប្តីប្រពន្ធគេផងទាំងពួងទេ សមគ្គសង្វាសបែបនេះមិនទុកជាត្រឹមត្រូវតាមគន្លងច្បាប់ឡើយ ។

ពាក្យអត្រានុកូលដ្ឋាន នេះ កើតមានឡើងជាយូរឆ្នាំហើយ ប៉ុន្តែជនជាតិខ្មែរយើង ពុំបានប្រើជាទម្លាប់សោះ ។ បើត្រូវនិយាយស្តីច្រើនតែប្រើទម្លាប់និយាយជាបារាំងថា : "អេតាស៊ីវិល ។" ។ ដូចជាគេនិយាយថា ខ្ញុំនាំកូនទៅចុះ អេតាស៊ីវិល ។ ឯពាក្យថា អេតាស៊ីវិល នេះសោតទៀត ខ្មែរយើងភាគច្រើន សំគាល់ចំពោះតែត្រង់បញ្ជីអាពាហ៍ពិពាហ៍មួយមុខតែប៉ុណ្ណោះ ឯបញ្ជីកំណើតនិងមរណៈមិនហៅថា អេតាស៊ីវិលទេ ។ ការសំគាល់យ៉ាងនេះ ជាការភ័ន្តច្រឡំពិត ; បានជាថាភ័ន្តច្រឡំ ព្រោះពាក្យបារាំងថា Etat civil ត្រូវនឹងពាក្យខ្មែរយើងថា អត្រា-នុកូលដ្ឋាន ។ ដូច្នេះបើអត្រានុកូលដ្ឋាន ជាឈ្មោះនៃបញ្ជីកំណើតមរណ-ភាពនិងអាពាហ៍ពិពាហ៍ទៅហើយពាក្យថា Etat civil ក៏ជាឈ្មោះនៃបញ្ជីប្រភេទនេះដែរ ។ ហេតុដូច្នេះសុំអស់លោកអ្នកអានបំបែរស្មារតីទៅរកការត្រូវ ដូចដំកល់ខាងលើនេះវិញឲ្យបានជាទម្លាប់តរៀងទៅ ។

ឥឡូវសុំអញ្ជើញអានពាក្យក្នុងលេខរៀងទី ៣ តទៅទៀត៖

៣–អន្ត្យរាយ: សរសេរ = អ-ន-ជើង ត-ជើង យ-រ-ស្រៈ-អា និង យ ។ កុំអាន អ័ន-តន៍-ត:-រ៉ាយ ឬអាន់-ត:-យាន់-ត:-រ៉ាយ ព្រោះជើង-យ-ដែលផ្ញើក្រោមអក្សរ-ត- មានសំឡេងថា ត្យ:-ឯជើង ត

ដែលផ្ញើក្រោមអក្សរ-ន-ជាងសម្លេងជា គៈ ត្រូវអានថា អាក់-គ្នេ-គៈ-ភ័យ ។ ពាក្យនេះជាពាក្យបាលី កើតមកពីបច្ច័យបទគឺ អគ្គិ ដែលប្ដូរស្រៈឥ ជា«យ»-ព្រោះមានស្រៈ អៈ នៅខាងចុងហើយលុបដើម គ ចេញសម្រេចរូបជាអគ្យ ប្រែថា (ភ្លើង) ១, ទីឯ។ភ្នុំពរ ប្រែថា សេចក្ដីវិនាស, ខូចខាត, ខូចបង់ផ្សេង, សេចក្ដីទើសទាក់, ហេតុដែលមកជំពាប់គ្នីឯនោះ ឬគ្នីពាក់កណ្ដាល,ចំបស្គុំការណ៍ ភ័យ ១ រួមរួបគ្នាជាអគ្យភ្នុំពយតាមកពីអគ្គិនឹងភ្នុំពយ ប្រែថា សេចក្ដីអន្តរាយឬសេចក្ដីវិនាសអំពីភ្លើង ត្រូវនឹងពាក្យបារាំងថា (Incendie) ។ នាមនាមច្រើនបទ រួមបញ្ចូលគ្នាជាពាក្យចំរុះហៅថា នាមនាម ។

សុំជូនឧទាហរណ៍ ជាប្រយោគដូចខាងក្រោម៖ កាលពីឆ្នាំមុននេះមានអគ្យុទ្ធភ័យដ៏សម្បើមបណ្ដាលកើតឡើង នៅសង្កាត់លេខ៥ក្រុងភ្នំពេញ មកពីការធ្វេសប្រហែសនៃចិនម្នាក់ អ្នកធ្វើគុយទាវលក់ ។

ឧទាហរណ៍ខាងលើនេះ បញ្ជាក់ជូនដល់អស់លោកអ្នកឲ្យងាយយល់អំពីពាក្យអគ្យុទ្ធភ័យ ។

តទៅនេះ សុំអញ្ជើញអានពាក្យចម៉ាត់ទៀត៖

អង្គវិញ្ញាណ: សរសេរ=អ-ង-ជើងគ វ-ស្រៈឥ-ញ-ស្រៈអា ជើង ញ ទីងណ ។ សុំកុំអានថា អង់-វិ-ញ្ញាណ ព្រោះមានជើង“គ”

ផ្ញើពីក្រោមអក្សរ "ង" មានសំឡេងលាន់ឮថា "គ" អក្សរ "ញ" មាន
សំយោគមានសំឡេងលាន់ឮថា „គ„; អក្សរ „ញ„ មានសំយោគមាន
សំឡេងថា វិញ-ញាណ ។ ត្រូវអានថាអង់-គ វិញ-ញាន ។ ពាក្យ
នេះជាពាក្យបាលី កើតមកពីសព្ទ ២ មាត់គឺ អង្គ: ១ វិញ្ញាណ: ១ អង្គ ប្រែថា
អវយវៈ រូប, ស្វរូប, កាយ, រាងកាយ, ខ្លួន, ខ្លួនប្រាណ, ភាគ, ចំណែកនៃរាង
កាយ, ប្រភេទ; សេចក្ដីដែលចែកឲ្យឃើញចំនួន, រូបសេចក្ដី, លក្ខណៈ,
ហេតុ, ការណ៍, ដើមហេតុ, វិញ្ញាណ ប្រែថាធម្មជាតដឹងអារម្មណ៍ច្បាស់;
រួមសព្ទទាំង ២ ចូលគ្នាបានជាអង្គវិញ្ញាណ ហៅថាសមាសនាម។ ពាក្យនេះ
ប្រែតាមអក្ខរូបថា ខ្លួនធម្មជាតដឹងអារម្មណ៍, តាមអត្ថប្បដិរូបគឺជា
ឈ្មោះនៃខ្លួនវិញ្ញាណទាំង ៥ គឺ ចក្ខុវិញ្ញាណ, សោតវិញ្ញាណ, ឃានវិញ្ញាណ,
ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ត្រូវនឹងពាក្យបារាំងថា (Organes des sens) ។

សុំជូនឧទាហរណ៍ ជាប្រយោគដូចខាងក្រោមនេះ៖

មនុស្សគ្រប់រូបដោយសារតែមានអង្គវិញ្ញាណ ទើបបានជាភ្នែកមើល
ឃើញរូប, ត្រចៀកឮសំឡេង ច្រមុះទទួលដឹងក្លិន, អណ្ដាតដឹងរសជាតិ
កាយទទួលដឹងការប៉ះពាល់ ។

អស់លោកអ្នកអានទាំងឡាយ ឧទាហរណ៍ជាប្រយោគខាងលើនេះ
ល្មមអស់លោកអ្នកយល់បាន អំពីពាក្យថា អង្គវិញ្ញាណ ហើយ ។

## ផ្នែកកំណត់ដំណឹងប្រវត្តិការណ៍

# ពិធីហែសពឧកញ៉ាសោភណមន្ត្រី ជួន-នុត

លោក ចាប-ពិន រៀបរៀង

---

កាលពីថ្ងៃអាទិត្យ ៣ មករា ១៩៦០ ម៉ោង៣រសៀល មានពិធីហែសពលោកឧកញ៉ាសោភណមន្ត្រី ជួន-នុត (មន្ត្រីកិត្តិយស) ជាអតីតបុគ្គលិកនៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ (ក្រសួងធម្មការ) ដែលទទួលមរណភាពនៅថ្ងៃ៣១ ធ្នូ ១៩៥៩ ចេញពីគ្រឹះស្ថានរបស់សព លេខ ២៩ វិថីវត្តលង្កា ទៅដំកល់ដើម្បីធ្វើឈាបនកិច្ច នៅឈាបនដ្ឋាននៃវត្តខណ្ឌលោម ។

វេលានោះ ក្រៅពីក្រុមគ្រួសាររបស់សព មានភ្ញៀវជាច្រើនរូបគឺ លោក សូ-ណែម រដ្ឋលេខាធិការក្រសួងធម្មការ លោក តាន់-ងៅ, យ៉េត ស្រេង, ហ៊ុយ-ល្អុត អតីតរដ្ឋមន្ត្រី, លោកវេជ្ជបណ្ឌិត ញឹម-សុខផល, លោក ហ៊ិង-ហ៊ិន អតីតចៅហ្វាយខេត្ត លោក ម៉ែន-ចឹម អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ នឹងអស់លោកអ្នកការងារក្រុមនេះជាដើម ព្រមទាំងអស់លោកមិត្តភក្តិក្រុមឯទៀតខ្លះ បានអញ្ជើញទៅហែយ៉ាងឱឡារិក ។

វេលាហែសពទៅដល់ឈាបនដ្ឋានហើយ លោក ញ៉ុង-សឿង បានថ្លែងកថានាមឯកជនជាមិត្តមួយរូបរបស់សព ឧទ្ទេសប្រវត្តិរបស់លោកឧកញ៉ា

លោកណាមន្ត្រី ជួន-ឌុត និងរិយោគកថា ដូចតទៅនេះ :

សូមនមស្ការសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ,

ព្រះតេជព្រះគុណព្រះពោធិវង្ស ព្រមទាំងព្រះថេរានុត្ថេរៈទាំងឡាយ,

សូមជំរាបព្រះតេជព្រះគុណ និងអស់លោក-អ្នកទាំងឡាយ,

ខ្ញុំព្រះករុណា ខ្ញុំបាទតាងនាមមិត្រភក្តិរបស់សព ដែលធ្លាប់ធ្វើការរួមគ្នាក្នុងក្រុមពុទ្ធសាសនបណ្ឌិត្យ សូមថ្លែងដោយគោរព ជាការផ្តល់ជូន នូវអំណរព្រះគុណសម្តេច ព្រះតេជព្រះគុណព្រះពោធិវង្ស ព្រះថេរានុត្ថេរៈ និងអំណរគុណអស់លោក ដែលបាននិមន្ត បានអញ្ជើញមកក្នុងឱកាសនេះ ហើយសូមថ្លែងនូវប្រវត្តិសង្ខេប និងសេចក្តីសោកស្តាយស្រណោះចំពោះសពលោកសោកណាមន្ត្រី ជួន-ឌុត ដែលជាអតីតសហការីរបស់យើងខ្ញុំ យើងខ្ញុំបានស្គាល់ច្បាស់ទាំងជាតិកំណើតទាំងចរិយាធ្យាស្រ័យចិត្តថ្លើមរបស់លោកសព្វគ្រប់ដូចតទៅនេះ:

លោកជួន-ឌុក កើតឆ្នាំ ១៨៨៦ ក្នុងឃុំកោះកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បិតានាម ជួន មាតានាម យក់ ។

កាលនៅជាកុមារ បានសិក្សាអក្សរខ្មែរ នៅវត្តពោធិព្រឹក្ស ហៅវត្តពោល្ងំ ក្នុងឃុំលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ដល់អាយុប្រមាណ ១៨ឆ្នាំ បានមកនៅវត្តឧណ្ណាលោម ក្នុងសំណាក់ព្រះគ្រូធម្មសំរ៉ ព្រះនាមសោ ជាមួយសម្តេចព្រះមហាសុមេធាធិបតី.

សង្ឃនាយកជាបងបង្កើត កាលនៅជាទារកក្តុនៅឡើយ ។

ក្នុងអាយុ១៨ឆ្នាំនោះឯង លោកគ្រូសាបាននាំយកទៅថ្វាយ ជាមហាតលិកព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស កាលទ្រង់នៅជាព្រះអង្គម្ចាស់អធិបតីនៅឡើយ ។

ព្រះអង្គម្ចាស់អធិបតីមុនីវង្ស ទ្រង់ព្រះមេត្តាប្រោសទំនុកបំរុងឲ្យលោក ជួន នុត ធ្វើជាស្មៀនផ្ទាល់ព្រះអង្គ នៅព្រះរាជដំណាក់ ។ លុះដល់ព្រះអង្គម្ចាស់អធិបតី មុនីវង្ស ទ្រង់យាងទៅកាន់ប្រទេសបារាំងបាត់ទៅ លោក ជួន-នុត ក៏បានវិលត្រឡប់មកនៅក្នុងសំណាក់មាតាបិតាវិញ ហើយបានសុំរៀនអក្សរបារាំងពីលោកគ្រូម្នាក់ឈ្មោះ កែវ ដរាបដល់បានចេះសរសេរចេះនិយាយភាសាបារាំងបាន ។

ដល់ឆ្នាំ ១៩១៤ ក្នុងអាយុ ២៨ ឆ្នាំ លោកបានចូលធ្វើការជាលេខាធិការនៅក្រសួងសាធារណការ ។

ដល់ឆ្នាំ ១៩២៥ ដែលរាជការបានផ្តើមបង្កើតព្រះរាជបណ្ណាល័យកម្ពុជាជាដំបូងឡើងគឺវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យសព្វថ្ងៃនេះ អ្នកស្រីកាប៉ុ-ឡែស ដែលជាអ្នកគ្រប់គ្រង និងព្រះតេជព្រះគុណព្រះមហាវិមលធម្មថោង អតីតចាងហ្វាងសាលាបាលីជាន់ខ្ពស់ បានសុំយកលោក ជួន-នុត មកឲ្យធ្វើការនៅវិជ្ជាស្ថាននេះវិញ ក្នុងឋានៈជាលេខាធិការ ដោយយល់ឃើញថា លោកនេះមានសមត្ថភាព និងចរិយាល្អ អាចជួយធ្វើការនៅ

ព្រះរាជបណ្ណាល័យបាន ។

តាំងពីលោកចូលធ្វើការជំបូងក្នុងព្រះរាជបណ្ណាល័យកម្ពុជា ដរាបដល់ពេលឈប់ធ្វើការ លោក ជួន-នុត បានខំយកចិត្តទុកដាក់ក្នុងការស្ថាបនានិងបំពេញមុខការរបស់មន្ទីរនេះ ដោយពេញកំឡាំងពុំប្រហែសធ្វេសដល់មួងសោះឡើយ ជួនកាលមានការរវល់ច្រើន លោកធ្វើទាំងថ្ងៃទាំងយប់ផង ដរាបដល់មន្ទីរនេះបានរីកធំធូលំទូលាយជាលំដាប់ឡើងដូចយើងឃើញសព្វថ្ងៃនេះ ។

លោក ជួន-នុត មានអធ្យាស្រ័យទន់ភ្លន់ល្អ ប្រកបដោយការសង្គ្រោះជនដទៃឥតមានសេចក្តីប្រណែនឈ្នានីសក្នុងសន្តាន មានចរិយាសុភាពរាបសាស្លូតត្រង់ មានវាចាផ្អែមពីរោះ មានទឹកដម និយាយឡើងកាលណា ធ្វើឲ្យអ្នកស្តាប់ មានចិត្តសោមនស្សរីករាយជាដរាប ជាទីស្រឡាញ់រាប់អានរបស់សហការីទាំងអស់ក្នុងក្រុមជាមួយ ឥតរេសហានសោះឡើយ ព្រមទាំងជាទីស្រឡាញ់របស់ពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ ដែលទាក់ទងនឹងក្រសួងនេះ ។

ដោយលោកមានគុណសម្បត្តិនិងចរិយាសម្បត្តិដ៏ប្រពៃដូចរៀបរាប់មកនេះហើយ ទើបលោកបានទទួលការតែងតាំងក្នុងឋានន្តរស័ក្តិជាមន្ត្រីកិត្តិយសថ្នាក់ទីកញ្ញា៎ មានគោរម្យងារជាទីកញ្ញា៎សោភណមន្ត្រី តាំងពីឆ្នាំ ១៩៣៨ រហូតមក ថែមទាំងបានទទួលនូវគ្រឿងឥស្សរិយយស

ដូចតទៅនេះ :

១ – មេដាយមាស

២ – – អស្សឫទ្ធិមុនីសារាភ័ណ្ឌ

៣ – – អស្សឫទ្ធិសុវត្ថា

៤ – – អស្សឫទ្ធិក្រុងកម្ពុជាធិបតី

៥ – – សេនាក្រុងកម្ពុជាធិបតី

៦ – – អស្សឫទ្ធិប្រទេសលាវ

ដល់ថ្ងៃទី ១៦ ធ្នូ ១៩៤៣ លោកបានលាឈប់ពីមុខក្រសួងដោយ លោកកាន់តែចាស់ជរាទ្រាំនៅធ្វើការរាជការតទៅទៀតពុំបាន ។ គិតទៅ តាំងពីឆ្នាំ ១៩១៤ ដែលលោកបានចូលធ្វើការរាជការជាដំបូងមក ទល់នឹងឆ្នាំ ១៩៤៣ ដែលលោកបានលាឈប់ពីមុខដំណែងនេះរួម ជា ៣៩ ឆ្នាំ ។

រួបរួមសេចក្តីទៅ គឺថា លោកឧកញ៉ាសោភណមន្ត្រី ជួន-នុត យើងអាចសន្មតទុកជាបុគ្គលិកបុព្វការីកំសត់កម្រមួយរូប ដែលបាន ជួយបំពេញកិច្ចការរាជការនៅក្រុមពុទ្ធសាសនបណ្ឌិត្យជាដំបូងបង្អស់ ។

តាំងពីពេលឈប់ពីមុខក្រសួងមក លោក ជួន-នុត ចេះតែថមថយ កម្លាំងបន្តិចម្តងៗដោយរោគជរា លោកក៏បានទទួលមរណភាពនៅថ្ងៃទី ៣១ ធ្នូ ១៩៤៩ ក្នុងកំណត់អាយុ ៧៣ ឆ្នាំ ។

ចំពោះមរណភាពនេះ យើងខ្ញុំជាសហការីនិងជាមិត្តរបស់លោក សូមគោរពចំពោះសពដោយសេចក្តីសោកស្តាយ និងសូមចូលកាន់មរណៈ-សញ្ញាវិលេកទុក្ខមួយចំណែក ជាមួយនឹងអស់លោកអ្នកជាគ្រួសារទាំងអស់ ព្រមទាំងសូមបួងសួង ឧទ្ទិស ផ្សាយកុសលជូនចំពោះវិញ្ញាណក្ខន្ធរបស់លោកឧកញ៉ាសោភណមន្ត្រី ជួន-នុត សូមឲ្យលោកបានសមប្រកបដោយសេចក្តីសុខចំរើនក្នុងភពថ្មីអស់កាលជាអង្វែងតទៅកុំបីឃ្លៀងឃ្លាតឡើយ ។

ចប់ប្រវត្តិនិងវិយោគកថានេះហើយ ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត និងសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកជួន-ណាត បាន ថ្លែងបន្ថែមនូវសទ្ធាសំលឹកកិត្តិនាមរបស់សព និងបដិសណ្ឋារកិច្ចចំពោះភ្ញៀវទាំងឡាយដោយបរិយាយបន្តិចៗ ព្រះអង្គៗ លុះចប់សព្វគ្រប់ហើយ មានពិធីជូនផ្កាមរណៈដល់ភ្ញៀវ ដើម្បីជាគារវៈកិច្ចដល់សពតាមប្រពៃណី និងចែកជូននូវសៀវភៅធម៌ជាអនុស្សាវរីយ៍ដល់ភ្ញៀវ ហើយនិងនិមន្តព្រះសង្ឃ១០០អង្គបង្សុកូល ។

ដោយសពនេះ ជាប្អូនបង្កើតរបស់សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក សម្តេចបានដំកល់ទុកនៅក្នុងបរិវេណឈាបនដ្ឋាន ១យប់ ១ថ្ងៃ ដោយចាត់ចែងធ្វើកុសលកិច្ចតាមប្រពៃណីពុទ្ធសាសនា ក្រោមការឧបត្ថម្ភរបស់សម្តេច ។ ស្អែកឡើងវេលាម៉ោង៤ល្ងាច ទើបធ្វើឈាបនកិច្ច ។

គ្រាជួបជុំដើម្បីធ្វើឈាបនកិច្ច  មានការប្រគេន  ជូនផ្កាមរណៈ មួយទៀតចំពោះព្រះសង្ឃជាគណៈទាំងឋានានុក្រម  ទាំងគណៈមហានិ-កាយទាំងគណៈធម្មយុត្ត  ហើយទាំងចំពោះសប្បុរសជនដែលនិមន្តអញ្ជើញ ទៅកាន់ទីសន្និបាតនោះ មានការនិមន្តព្រះសង្ឃ១០០អង្គបង្សុកូលមានការ ប្រគេនស្បង់១០០  ដែលវេចនាជាផ្គុំតាមរ  ហើយទាំងសៀវភៅប្រស្នា វិន័យ១០០ក្បាល  មានការបំបួសកុលបុត្រពីរនាក់  គឺលោក នុត-ហឿន ជាបុត្ររបស់សព  និងនាយឈឹម-សុមេធ ជាចៅរបស់សព មានការទេ-សនាហូតដល់យប់ ។ ស្អែកឡើងប្រគេនចង្ហាន់សង្ឃ ៧៤ អង្គ ដូចថ្ងៃ មុនៗទៀត  បញ្ចប់កិច្ចទៅតែម្តងណោះ លោមត្រឹមប៉ុណ្ណោះ ។

ដល់ថ្ងៃព្រហស្បតិ៍ ខួប ៧ ថ្ងៃ គិតពីថ្ងៃដែលលោកជូន-នុត អនិច្ចកម្ម ទៅ  ភរិយា  បុត្រី  បុត្រារបស់សពបានធ្វើបុណ្យទក្ខិណានុប្បទាន នៅគេហដ្ឋានរបស់សពម្តងទៀត  ដោយការនិមន្តព្រះសង្ឃឆន់ចំពោះ ។

តពីនោះទៅ៖ពេលល្ងាចថ្ងៃសៅរ៍និងព្រឹកថ្ងៃអាទិត្យទី ១០.១.៦០គ្រួ-សាររបស់សព បាននិមន្តព្រះសង្ឃមកធ្វើការចំពោះ ដោយយកតែព្រះសង្ឃ អង្គណាដែលធ្លាប់ដឹងសុខទុក្ខជាមួយលោក  ជូន-នុត  ទាំងគណៈមហា និកាយទាំងគណៈធម្មយុត្តបានចំនួន២៤អង្គទៅឆាន់ ព្រមទាំងបានអញ្ជើញ ញាតិមិត្រអ្នកឡើងហាត់ក្នុងបុណ្យសពជាច្រើននាក់ទៅជប់លៀងភោជនា-ហារ  ។  គ្រាជួបជុំក្រុមបព្វជិត  និងគ្រហស្ថជាញាតិមិត្រទាំងអស់,

លោកឈឹម.ស៊ុម សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ជាកូនប្រសា នៃសពលោក ជួន-នុត ជាតំណាងគ្រួសារនេះ បានថ្លែងសេចក្តីអរគុណ ព្រមទាំងជូនបុណ្យដូចតទៅ :

សូមគោរពព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ,

សូមជំរាបព្រះតេជព្រះគុណនិងអស់លោក-អ្នកទាំងឡាយ ,

ក្រុមគ្រួសារនៃខ្ញុំព្រះករុណា ខ្ញុំបាទជាអ្នកទើបបានទទួលឧបការគុណថ្មីៗ អំពីព្រះតេជព្រះគុណ និងអស់លោក-អ្នកទាំងឡាយ ៗ ជៀត កាលលោកជួន.នុត ជាប្រធាននៃគ្រួសារនេះទទួលអនិច្ចកម្ម ; យើងខ្ញុំព្រះករុណា ខ្ញុំបាទទាំងឡាយ បានឃើញយ៉ាងជាក់នូវព្រះភក្ត្រព្រះតេជព្រះគុណគ្រប់ព្រះអង្គនិងអស់លោកទាំងឡាយ ដែលចូលមកជួយកាន់មរណសញ្ញាជាមួយផង ៗ ព្រះតេជព្រះគុណគ្រប់ព្រះអង្គ និងអស់លោកទាំងឡាយ សុទ្ធតែបានបរិច្ចាគពេលវេលា គ្រឿងបរិក្ខារ កម្លាំងកាយនិងកម្លាំងចិត្ត ជួយឧបត្ថម្ភកិច្ចបុណ្យសពនេះ ដោយស្មោះអស់ពីដួងហឫទ័យ ៗ យើងខ្ញុំទាំងឡាយ មានអំណរដ៏ក្រៃលែង សូមទទួលព្រះឧបការគុណដាក់លើសិរសាគ្រប់ ៗ គ្នា ៗ ប៉ុន្តែលាក់បាំងអ្វី, ក្នុងពេលនោះ យើងខ្ញុំទាំងឡាយ ដែលវិយោគទុក្ខកំពុងគ្របសង្កត់ ហើយថែមទាំងនឿយហត់ ព្រោះការជាទម្ងន់នេះធ្លាក់មកលើ គឺស្ទើរតែទប់កាយពុំបាន គ្រាន់តែឃើញព្រះភក្ត្រព្រះតេជព្រះគុណគ្រប់

ព្រះអង្គ ទាំងអស់លោកទាំងឡាយ ទើបមានកងកាយនឹងចិត្តនៅនឹងបាន មានឧបមាដូចជា កូនទូកតូច ៗ អណ្ដែតលើទឹករលកនៃទន្លេគង្គា លុះតែមានមហានាវាមកផែបនៃបគ្រៀបគ្រា ទើបនៅនឹងបានដូច្នោះឯង ៗ ដោយហេតុដូច្នេះ ក្រែងជួនជាយើងខ្ញុំទាំងឡាយ មានកាយវាចាពុំគប្បី ពុំសមគួរដល់ហឫទ័យនៃព្រះតេជព្រះគុណ ទាំងអស់លោកទាំងឡាយយ៉ាងណាក្ដី សូមទានមេត្តាប្រោសអភ័យទោសឲ្យទាន ៗ

មួយទៀត ដើម្បីផ្ដាច់បង់នូវសេចក្ដីសង្ស័យនៃជនខ្លះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមជំរាបដល់ក្រុមញាតិថា កិរិយាដែលព្រះសង្ឃជួយឈឺឆ្អាលចំពោះសពលោក ជួន.ទុក តាំងពីពេលដែលកំពុងមានអាពាធ ទៅទល់នឹងអនិច្ចកម្មរហូតដល់ធ្វើឈាបនកិច្ចហើយស្រេចនេះ មិនជាការខុសពាសនឹងធម៌វិន័យទេ ស័ងមានសំអាងថា :

១-គម្ពីររឿងពុទ្ធប្បវត្តិត្រង់ពុទ្ធបិតុបរិនិព្វានបរិច្ឆេទថា ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ជាប្រមុខក្នុងពិធីថ្វាយព្រះភ្លើងព្រះបរមសព នៃព្រះបាទសិរីសុទ្ធោទន៍ ៗ

២-គម្ពីរធម្មបទថា ព្រះពុទ្ធជាម្ចាស់ទ្រង់ទាត់ការធ្វើឈាបនកិច្ចសពតាបុរិយៈ ដែលជាគ្រហស្ថ ពុំមែនជាព្រះញាតិនៃព្រះអង្គសោះ ហើយទ្រង់ឲ្យសាងចេតិយបញ្ចុះធាតុតាបុរិយៈនេះត្រង់ផ្លូវត្រឡែងបែកទៀតផង ៗ

៣- ក្នុងអនាថបិណ្ឌិកោវាទសូត្រ ផ្នែកខាងព្រះសុត្តន្តបិដកថា កាលអនាថបិណ្ឌិកសេដ្ឋី មានអាពាធជាទម្ងន់ក្នុងគ្រាដែលលោកចាស់ដក មានការជួបជុំព្រះសង្ឃជាកិច្ច ដែលលោកនិមន្តទៅសួរជម្ងឺព្រមការសំដែងធម៌ឲ្យស្តាប់ , សពលោកអនាថបិណ្ឌិកសេដ្ឋីត្រូវបានទទួលការឧបត្ថម្ភពីព្រះសង្ឃជាច្រើន ។

ឯសពលោក ជួន-នុត យើងពុំអាចប្រៀបធៀបនឹងសពខាងលើនេះបានទេ ។ ប៉ុន្តែប្រហែលជាព្រះសង្ឃយល់ឃើញថា លោកជួន-នុត មានប្រយោជន៍ក្នុងផ្លូវពុទ្ធសាសនាណាស់ បានជាលោកជួយខ្វល់ខ្វាយជួយស្តាយស្រណោះ ។ យោបល់ខ្ញុំនេះ ស្របនឹងសក្ខីរបស់ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត ក្នុងថ្ងៃដែលនាំសពទៅដល់វត្តឧណ្ណាលោមថា :

«កាលពីដើមដែលលោកសង្ឃក្នុងប្រទេសកម្ពុជា សូម្បីតែមួយអង្គ ក៏ពុំទាន់ចេះអក្សរគោសាបាលីនៅឡើយ មានតែលោកជួន-នុតនេះហើយ ដែលដឹកនាំឲ្យចេះរៀងដំបូង គឺលោកបានចូលមកបង្រៀនវិជ្ជានេះដល់លោកសង្ឃក្នុងវត្តឧណ្ណាលោមពីរម៉ោងៗរាល់ៗពេលល្ងាច ដែលចេញពីធ្វើការ ដោយឥតគិតសារគុណអ្វីសោះ ។ ខ្ញុំព្រះករុណាអាត្មាហ្នឹងឯង ជាសិស្សដំបូងរបស់លោក ជួន-នុត ក្នុងការរៀនអក្សរកោសាបាលី ។

លោក ជួន នុត នេះធ្លាប់តែធ្វើប្រយោជន៍ជាទីពេញចិត្តនៃជនច្រើនគ្នា

ដូចជាកាលអ្នកស្រីកាប៉ីឡែសប្រ៊ីនិច ទទួចសុំយកលោកនេះមកធ្វើការ នៅព្រះរាជបណ្ណាល័យកម្ពុជា ដែលទើបបង្កើតឡើងដំបូង ក៏លោកបានហ្វាន ក្រសួងសាធារណការប្រឹងប្រទាញទុកឯណោះដែរ អស់កាលដ៏យូរពាល់ តែលោករ៉េប៉ុជង់ត៍ស្ទូប៉េរិយ៉េរ ប្រ៊ូដ់ស្វា-ប៊ូជូពិនជួយសុំទើបបានមក" ។

ព្រះតេជព្រះគុណគ្រប់ព្រះអង្គ! អស់លោក-អ្នកសប្បុរសទាំងឡាយ ការកុសលដែលបានធ្វើទាំងពីប៉ុន្មានថ្ងៃមកហើយ ជាបុណ្យរបស់ព្រះតេជព្រះគុណ និងអស់លោកទាំងឡាយផង ជាបុណ្យរបស់គ្រួសារនេះផងម្នា ។ ថ្ងៃនេះយើងខ្ញុំទាំងឡាយបានធ្វើបុណ្យមួយលើកទៀតដើម្បីបំពេញកិច្ចនៃមិត្តភាពរវាងគ្រួសារនេះនិងព្រះថេរានុត្តេរៈគ្រប់ព្រះអង្គហើយ និងអស់លោក-អ្នកសប្បុរសទាំងឡាយផង ដើម្បីឧទ្ទិសផលជូនដល់លោកជួន-នុតផង ។ សូមព្រះតេជព្រះគុណគ្រប់ព្រះអង្គ និងអស់លោកទាំងឡាយ ដែលបានបរិច្ចាគស៊ីវមកឧបត្ថម្ភសពនេះ ទទួលអនុមោទនានូវបុណ្យទាំងប៉ុន្មានលើកនេះ ។ សូមឲ្យបានសម្រេចនូវសម្បត្តិទាំង៣ប្រការ គឺសម្បត្តិមនុស្ស សម្បត្តិទេវតា និងសម្បត្តិព្រះនិព្វានដូចសេចក្តីប្រាថ្នានៃព្រះតេជព្រះគុណ និងអស់លោកទាំងឡាយ ។

មួយទៀត សូមឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធលោក ជួន-នុត ដែលលោកចែកឋានទៅចាប់ជាតិកំណើតកើតនៅទីណាឋានណា សូមលោកបានសម្រេចនូវផ្លែផ្កាផលវិបុលសុខគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតជាបដល់អស់ឋានជាតិ សូមឲ្យបានសម្រេចនូវព្រះនិព្វានជាទីបំផុតហោង ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

អតិក្រម បុ. កិរិយាប្រព្រឹត្តកន្លង (ទោស, វេលា) កិរិយាប្រព្រឹត្តកន្លងច្បាប់, បទល្មើស។

*អតិក្រមិន* គុ. ដែលប្រព្រឹត្តកន្លងច្បាប់, ដែលប្រព្រឹត្តល្មើស ។

អតិក្រមណ នបុ. កិរិយាប្រព្រឹត្តកន្លង (ទោស, ច្បាប់, វេលា), កំហុស ។

អតិក្រមណីយ គុ. ដែលគប្បីវៀរចេញ, ដែលចេសប្រហែស ។

អតិក្រាន្តិ ស្រី កិរិយាប្រព្រឹត្តកន្លងច្បាប់, ការប្រព្រឹត្តល្មើស ។

អតិក្រុធិ ស្ត្រី. សេចក្តីក្រោធក្រៃលែង ។

អតិក្រុទ្ធ នបុំ កិរិយាសោកក្រៃពេក ។

អតិក្រូរ គុ. ដែលខ្លាចក្រៃពេក, ដែលកក់ក្តៅមហិមា ។

អតិក្លេគ បុំ សេចក្តីទុក្ខក្រៃលែង ។

អតិខរ គុ. ដែលក្រលួចក្រៃពេក (សំឡេង) ដែលខ្លាំង ។

អតិខាទិន គុ. ដែលស៊ីច្រើន ។

អតិគ ៣. ន. អ្នកធ្លង, អ្នកកន្លង, អ្នកបំពេន ។

(នៅមានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

---

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣២ លេខ ៣ ខែមីនា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
| --- | --- | --- |

- ជីវិតសត្តិភាវិកថា របស់ព្រះវិន័យធម្ម ចោង-ឃុ . . . . ២៤១
- ព្រះអភិធម្មបិដក (គម្ពីរបុគ្គលបញ្ញត្តិ) លោក ប៊ូ-ប៊ូ រៀបរៀង . . ២៥២
- មធុរសវាហិណី (តមក) សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈឺន ពិនិត្យ. . . . . . ២៦៣
- មហោសថជាតក (តមក) លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ . . . . . . . . . . ២៧៥

ផ្នែកអក្សរសាស្ត្រ

- រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . ២៨៩
- អ្នកជំនួញរបស់នៅវ៉េនីស លោក កួច-ធីឡេង រៀបរៀង . . ២៩៧
- រឿងព្រេងសត្វក្ងានលោក . . . . . . . . ៣០៤
- រឿងសាមកុក (តមក) ១កញ៉ា ខ្ញូ-កន ប្រែ . . . . . ៣១៣
- ពាក្យវិទ្យុឆមី (តមក) លោក តាង-ហ៊ួ រៀបរៀង លោក សឹម-ហំង ពិនិត្យ ៣៣១

ផ្នែកកំណត់នឹងប្រវត្តិការណ៍

- ពិធីបុណ្យបូជាសព ព្រះមុនីកោសល សោម-ឈុន លោក ចិង-វ៉ាង រៀបរៀង ៣៣៦
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា យ៉ាំង-ខាត់ រៀបរៀង . . ៣៥៤



មួយឆ្នាំ មាន ១២ សៀវភៅ ថ្លៃជាវ ២៣០.០០

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
Publiée par l'Institut Bouddhique de Phnom Penh

## sommaire

### Partie religieuse :

— Vacisantibhava katha par Prah Vinaya dhamma THONG YU 241
— Prah Abhidhammapitaka (puggalappannatti) par M. BOU-PO 252
— Madhurasavahini (suite) traduit par Samdec Prah Dhamma-likhita LOUIS-EM, revu et corrigé par Vén-NHEAN-CHHOEUN . . . . . . . . . . . . . . 263
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON' revu par Vén-KEM-TO 275

### Partie littéraire :

—Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . . 285
—La vie privée des habitants du Jambu Dvipa par M. KUOCH-KILENG 297
— Contes et légendes «Sat kon lok» par M. THANG VONG
Mon Ennemi par M. BOU-PO. . . . . . . . . . 304
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 313
— Activités de la Commission culturelle par M. SAM-THANG. . . . . . . . . . . . . . 331

### Notes et Chroniques :

— Funérailles de l'Oknha Sobhana Montrei Choun Nouth par M. CHAP PIN. . . . . . . . . . 336
— Dictionnaire Sanscrit-khmer (suite) par Vén-PANG-KHAT 354

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

# ព្រះទិវង្គតនៃព្រះប្រិយមហាក្សត្រជាទីគោរព

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម-សុរាម្រិត ព្រះមហាក្សត្រប្រទេសកម្ពុជា ជាអម្ចាស់ជីវិ
លើត្បូង ជាទីគោរព និងជាទីស្នេហារបស់យើង ព្រះអង្គសោយព្រះទិវង្គតក្នុងព្រះបរមរាជវាំងចតុមុ
នៅថ្ងៃអាទិត្យ ទី ៣ មេសា ១៩៦០ វេលាម៉ោង ១២ និង ៤០ នាទី ថ្ងៃត្រង់ក្នុងព្រះជន្មវស្សា ៦៦ឆ្នាំ ។

កាលបានទទួលដំណឹងនេះ ក្រុមពុទ្ធសាសនបណ្ឌិត្យ មានចិត្តរំភើបញាប់ញ័រសោកស្តាយជាទីបំផុ ព្រោះព្រះអង្គជាព្រះមហាក្សត្រប្រកបដោយគតិបណ្ឌិត ទ្រង់ទសពិធរាជធម៌ ទ្រង់ប្រកបដោយព្រះមហា ករុណាទិគុណ រកព្រះមហាក្សត្រអង្គណាដែលសោយរាជសម្បត្តិប្រកបដោយការសរសើរអំពីប្រជាជាតិខ្ល ព្រះអង្គនេះពុំងាយបាន ។ ក្នុងព្រះឋានៈជាម្ចាស់រដ្ឋ ព្រះអង្គបានបំពេញព្រះរាជករណីយកិច្ចសព្វអន្លើ ក្នុ ព្រះឋានៈជាព្រះបិតារបស់ប្រជាពលរដ្ឋខ្មែរ ព្រះអង្គស្រឡាញ់រាប់អានកូនចៅរបស់ព្រះអង្គឥតរើសមុខ ទ្រ បង្កើតការិយាល័យប្រស្រ័យផ្ទាល់នឹងប្រជារាស្ត្រ ទ្រង់ព្រះរាជានុញ្ញាតឲ្យប្រជារាស្ត្រចូលគាល់ ថ្លែងទុ របស់ខ្លួនស្ទើរតែរាល់សប្តាហ៍, ជាពិសេសក្នុងរជ្ជកាលរបស់ព្រះអង្គទ្រង់ឧបត្ថម្ភផ្នែកសង្គមកិច្ច និង ព្រះអគ្គសាសនូបត្ថម្ភកផ្នែកព្រះពុទ្ធសាសនា.......... ។

អាស្រ័យដោយព្រះគុណសម្បត្តិទាំងនេះ បានជាការសោយព្រះទិវង្គតនៃព្រះអង្គនាំឲ្យរំភើបញាប់ មហិមាដល់ប្រជាពលរដ្ឋ ដែលប្រវត្តិសាស្ត្រប្រទេសកម្ពុជាបានត្រាទុកជាការបង់ខាតមួយយ៉ាងធំបំ ប្រជាពលរដ្ឋគ្រប់ប្រភេទបានស្រុះគ្នាចូលកាន់ព្រះទិវង្គតសញ្ញាដ៏ក្រៀមក្រំគ្រប់រូប ។

ក្រុមពុទ្ធសាសនបណ្ឌិត្យ សូមចូលកាន់ព្រះទិវង្គតសញ្ញា ចំពោះព្រះបរមសពជាទីស្នេហា ទីគោ ដ៏ខ្ពង់ខ្ពស់នេះ ដោយមនោសញ្ចេតនាដ៏ក្រៀមក្រំ ។ សូមសម្តេចព្រះមហាក្សត្រិយានី សេ ព្រះឧបយុវរាជ ជាទីគោរព ទីស្នេហាដ៏ខ្ពង់ខ្ពស់របស់ប្រជាពលរដ្ឋ ដែលទ្រង់កំពុងសោយទុក្ខយ៉ាងក្រៃ ព្រមទាំងព្រះរាជវង្សានុវង្ស ទ្រង់ព្រះមេត្តាប្រោសទទួលនូវការចូលកាន់ព្រះទិវង្គតសញ្ញារបស់ក្រុមនេះ មួយប្រជាពលរដ្ឋខ្មែរ ទូទាំងព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

ដោយហេតុដែលធ្លាប់មានព្រះមហាក្សត្រទាំងពីរព្រះអង្គ ជាទីស្នេហា ទីគោរព ជាម្លប់ដ៏មហាត្រ និងជាទឹកកក់ក្តៅ សុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋមកហើយ ក្រុមពុទ្ធសាសនបណ្ឌិត្យ សូមប្តូង ដោយគោរព បន្ទាប់អំពីព្រះទិវង្គតនៃព្រះប្រិយមហាក្សត្រទៅ សូមម្លប់ដ៏មហាត្រដាក់នេះ នៅមា ស្ថាពរថិតថេរចិរកាល តទៅក្នុងអនាគតអស់កាលជាអង្វែង ។

*ពុទ្ធសាសនបណ្ឌិត្យ*

# ពរសព្ទសាធុការក្នុងឱកាសចូលឆ្នាំថ្មី

ក្នុងឱកាសចូលឆ្នាំជូតនក្សត្រទោស័ក ជាឆ្នាំថ្មី នៃពុទ្ធសករាជ ២៥០៣ នេះ ក្រុមពុទ្ធសាសនបណ្ឌិត្យ សូមជូនសព្ទចំពោះគុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងពិភពលោក មានទេវតាដែលរក្សាព្រះមហាស្វេតច្ឆត្រ និងព្រះកែវមរកតនៃប្រទេសកម្ពុជាជាដើម ហើយនិងចំពោះទេវតាដែលរក្សាឆ្នាំថ្មីព្រះនាមមន្ទាទេវី សូមប្រសិទ្ធិពរជ័យ ជូន ៖

-ចំពោះសម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះឧបយុវរាជ ព្រមទាំងព្រះរាជវង្សានុវង្សគ្រប់ព្រះអង្គ សូមទ្រង់បានប្រកបដោយព្រះជោគជ័យសិរីមង្គល វណ្ណភាព ព្រះសុខុមាលភាព និងព្រះជន្មាយុយឺនយូរអស់កាលជាអង្វែង ។

-ចំពោះសម្តេចក្រុមព្រះ ជាប្រធាន និងសមាជិកក្រុមប្រឹក្សារាជានុសិទ្ធិ ព្រមទាំងគ្រួសារ សូមបានប្រកបដោយជោគជ័យ និងសេចក្តីសុខចម្រើនគ្រប់ប្រការ ។

-ចំពោះសមាជិកព្រះរាជរដ្ឋាភិបាល ព្រមទាំងគ្រួសារ ។

-ចំពោះសមាជិកសភាទាំងពីរ ព្រមទាំងគ្រួសារ ។

-ចំពោះអស់លោកអ្នករាជការខ្មែរធំ-តូច ទាំងស៊ីវិល ទាំងទាហានគ្រប់រូប ព្រមទាំងគ្រួសារ

-ចំពោះជនរួមជាតិទូទាំងព្រះរាជាណាចក្រកម្ពុជាទាំងមូល ទាំងព្រះសង្ឃទាំងគ្រហស្ថ សូមបានប្រកបដោយសិរីសួស្តី និងជោគជ័យគ្រប់យ៉ាង ។

ផ្នែកសាសនា

# វិថីសន្តិភាវកថា

សំដែងអំពីការពារនៃសេចក្តីស្ងប់ខាងផ្លូវវាចា

*របស់ព្រះវិន័យធម្ម ថោង-យុ វត្តសារាវ័នតេជោ*

---

ឆៈមោ ៣៨៥

សូមនមស្ការ ចំពោះព្រះដ៏មានបុណ្យអរហន្តសម្មាសម្ពុទ្ធព្រះអង្គនេះ (ព្រមទាំងព្រះសទ្ធម្ម មួយអន្លើដោយព្រះអរិយសង្ឃដោយសេចក្តីគោរព) ។

សូមពណ៌នាអំពី "វិថីសន្តិភាវកថា" ប្រែថា «ពាក្យជាគ្រឿងសំដែងនូវសន្តិភាពខាងផ្លូវវាចាដែលមកក្នុងគម្ពីរមង្គលត្ថទីបនី ។ ពាក្យថា «វិថីសន្តិភាព» នេះ មកអំពី "វិថី" ប្រែថា វាចា សំដី ពាក្យ ។ "សន្តិ» ប្រែថា ស្ងប់ សាន្តត្រាណ រាបទាប ស្រះជាមួយគ្នា ។ «ភាវៈ» ប្រែថា ភាព ឬដំណើរ ។ រួមពាក្យនេះចូលគ្នាថា វិថីសន្តិភាព ប្រែថា ភាព ឬដំណើរស្ងប់ ស្រះជាមួយគ្នាខាងផ្លូវវាចា ។

សូមលើកយកធម្មកថាក្នុងអត្ថបទ ដែលសំដែងបង្ហាញពាក្យថា «ស្ងប់វាចា» នេះជាទិវស្សន៍ដូចតទៅ :

វចីសន្តិភាព “ភាព ឬដំណើរស្ងប់ខាងវាចា ” ។

សេចក្តីថា   បើគ្រាន់តែស្ងប់កាយតែម្យ៉ាងប៉ុណ្ណោះ   នៅពុំទាន់បានពេញបរិបូណ៌ទេ   លុះតែមានសន្តិភាពខាងវាចាថែមទៀតផង   ទើបឈ្មោះថា “សន្តិភាពសុខទូលំទូលាយជាង” ។

៦ វាចា   ពាក្យសំដីដែលនិយាយស្តី   មានច្រើនបែបមែនប៉ុន្តែ   បើពោលតាមមាតិកាខ្លីមានតែពីរគឺៈ

១- សុភាសិតាវាចា  សំដីនិយាយខាងល្អ ;

២- ទុព្ភាសិតាវាចា  សំដីនិយាយខាងអាក្រក់ ។

បណ្តាមនុស្សក្នុងលោក, អ្នកខ្លះគាប់ចិត្តនិយាយ ឬស្តាប់ពាក្យសំដីល្អៗ ពាក្យសំដីមានប្រយោជន៍ដល់ខ្លួននិងអ្នកដទៃក៏មាន,   ពាក្យកុហកបោកបញ្ឆោតគេ,   ពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ,   ពាក្យអាក្រក់ពាក្យច្រេះគោះបោះបោកជេរប្រទេចអ្នកដទៃក៏មាន,   ពាក្យផ្អែមល្ហែមពាក្យពីរោះពិសាក៏បាន ។   ពាក្យសំដីណាដែលខុសក្របខណ្ឌមាត្រានិងច្បាប់លោកច្បាប់ធម៌ យើងមិនត្រូវយកត្រចៀកផ្ទៀងស្តាប់ពាក្យនោះទេ   ខ្លាចក្រែងវិនាសអន្តរាយដល់ខ្លួននិងអ្នកដទៃ   ត្រូវនិយាយឬស្តាប់តែពាក្យល្អពាក្យពិត ពាក្យមែន យ៉ាងនេះហៅថា សុភាសិតាវាចា ។

សាធុជនទាំងឡាយ   អ្នកប្រាថ្នាសុខ-ចំរើនក្នុងលោកនេះ   និងលោកខាងមុខ   គួរតែវៀរចាកវចីទុច្ចរិតមានពាក្យកុហកជាដើមចោល

ចេញ ទើបបានឈ្មោះថា វចីសន្តិភាព «ភាព ឬដំណើរស្ងប់នៃវាចា» ឬ វចីសោរច្ចេយ្យ «ភាពជាអ្នកស្អាតខាងវាចា», ឬក៏ វចីសាមគ្គី «ព្រមព្រៀងគ្នាដោយវាចា» ដូច្នេះក៏បាន ។

សុភាសិតវាចា នេះ តាមន័យក្នុងសុភាសិតសូត្រ ដែលព្រះលោកុត្តមាចារ្យទ្រង់សំដែងក្នុងមង្គលទី១០ ត្រង់ពាក្យថា ចតូហិ ភិក្ខវេ អង្គេហិ សមន្នាគតា វាចា សុភាសិតា ហោតិ ន ទុព្ភាសិតា អនវជ្ជា ច អននុវជ្ជា ច វិញ្ញូនំ ប្រែថា «ម្នាលភិក្ខុទាំងឡាយ! វាចាដែលប្រកបដោយអង្គ៤ ឈ្មោះថា វាចាជាសុភាសិត, មិនឈ្មោះថា វាចាជាទុព្ភាសិតទេ ។ មួយទៀត វាចាជាសុភាសិតនេះ ជាវាចាប្រាសចាកទោសមានលោភៈជាដើម ជាវាចាឲ្យមានសន្តិភាព ឲ្យមានសាមគ្គី ឲ្យមានសុខចំរើន ព្រោះមិនលុះក្នុងអគតិ៤ យ៉ាងនេះគឺៈ ស្រឡាញ់, ស្អប់ វង្វេង, ខ្លាចផង, ជាវាចាប្រាសចាកទោសដែលអ្នកប្រាជ្ញទាំងឡាយតិះដៀលផង; សុភាសិតវាចានេះ ជាវាចារបស់អ្នកប្រាជ្ញទាំងឡាយ ។

ម្យ៉ាងទៀត វាចាជាសុភាសិតនេះ តាមន័យបាលីក្នុងភាសិតបញ្ចកនិបាតថា ប្រកបដោយអង្គ ៥ ។ ឯអង្គ៥នោះគឺៈ

១– ពោលពាក្យកំណត់តាមកាលវេលា;

២– ពោលពាក្យពិតពាក្យមែន;

៣– ពោលពាក្យផ្អែមល្ហែមពីរោះដល់អ្នកស្ដាប់;

៤- ពោលពាក្យជាប្រយោជន៍ដល់ខ្លួននិងអ្នកដទៃ;

៥- ពោលពាក្យដោយគំនិតមេត្តាចិត្តផ្សាយដល់អ្នកស្តាប់ ។

ន័យមួយទៀត គម្ពីរសុត្តនិបាត ដែលព្រះពុទ្ធអង្គត្រាស់សំដែងថា វាចាប្រកបដោយអង្គ៤ ដ៏ យ៉ាងទៀតគឺ ៖

១- បុគ្គល ត្រូវពោលពាក្យជាសុភាសិតតែម្យ៉ាង, មិនត្រូវពោលពាក្យជាទុព្ភាសិតឡើយ;

២- បុគ្គល ត្រូវពោលពាក្យជាធម៌ពិត,មិនត្រូវពោលពាក្យដែលពុំមែនជាធម៌,

៣- បុគ្គល ត្រូវពោលពាក្យដែលគួរឲ្យស្រឡាញ់ពេញចិត្តតែម្យ៉ាង,មិនត្រូវពោលពាក្យដែលគេស្អប់ខ្ពើមឡើយ ។

៤- បុគ្គល ត្រូវពោលពាក្យពិតតែម្យ៉ាង,មិនត្រូវពោលពាក្យឡេះឡោះឡើយ,

សម្តេចព្រះជិនស្រី លុះទ្រង់សំដែងលក្ខណៈ របស់សុភាសិតវាចាទាំងពីរន័យនេះរួចហើយ ទើបត្រាស់ជាបំភ្លឺសេចក្តីតទៅទៀតថា:

សុភាសិតំ ឧត្តមមាហុ សន្តោ
ធម្មំ ភណេ នាធម្មំ តំ ទុតិយំ
បិយំ ភណេ នាប្បិយំ តំ តតិយំ
សច្ចំ ភណេ នាលិកំ តំ ចតុត្ថំ ។

ប្រែថា អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម តែងពោលសរសើរនូវសុភាសិតថាជាវាចាដ៏ឧត្តម (នោះជាទី ១) បុគ្គលគប្បីពោលពាក្យជាធម៌, មិនគប្បីពោលពាក្យជាអធម៌ នោះជាទី ២ បុគ្គលគប្បីពោលពាក្យដែលគួរឲ្យស្រឡាញ់ មិនគប្បីពោលពាក្យដែលគេស្អប់ នោះជាទី ៣ បុគ្គលគប្បីពោលពាក្យពិត មិនគប្បីពោលពាក្យទុះឡោះឡើយ នោះជាទី ៤ ។

៦ សុភាសិតវាចា ដែលសំដែងមកនេះ បើសប្បុរសទាំងឡាយប្រព្រឹត្តកាន់បាន រមែងកើតផលប្រយោជន៍ កើតសម្បត្តិទ្រព្យធន កើតបុណ្យយសស័ក្តិ សិរីសួស្តី ជោគជ័យមង្គលគ្រប់ទិវារាត្រី ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខពុំខានឡើយ ព្រោះជាវាចា មានវិន័យ, ឥតទោស, ជាវាចាឥតគេកេត ឥតពិសពុល ។

មួយវិញទៀត ពាក្យសំដីរបស់បុគ្គលក្នុងលោក ដែលបញ្ចេញវចីភេទបាននិយាយចេញទៅនោះ មាន ៣ ប្រភេទទៀតគឺ :

១- គូថភាណី មានសំដីដូចលាមក គឺជាប់និយាយពេលណា គិតតែជេរគេជៀលត្មះគេ ជាសំដីស្អុយគគ្រុកឬសំដីព្យួងប្រលោមចោក ប្រាសគេ រកតែគេស្អប់ រកជាគតិដាក់ខ្លួនឯងពុំកើត ។ សំដីបែបនេះ ហៅថាសំដីសជាតិអាយោទសត្វូដ (គ្រគូល) ឬហៅថា សំដីរម៉ុងរមោក, សំដីដូចពោលដីឥតទាំងផង, សំដីសោរកគ្រោះគេសជាតិ,

(សំដីគគ្រោល ) សំដីគ្មានក្របខណ្ឌ ឬសំដីគ្មានគោល ,គឺបើហានិយាយឡើងគេអាចសំគាល់ដឹងថាអាក្រក់ឬជាសំដីប្រលោមបំភាន់គេពុំខាន ។

២–បុប្ផភាណី មានសំដីដូចផ្កា គឺបើហានិយាយពេលណាមានរសជាតិក្រអូបកើតផលប្រយោជន៍ដល់ខ្លួននិងអ្នកស្តាប់ ហាក់ដូចជាផ្កាមានក្លិនក្រអូបជាទីពេញចិត្តនៃជនទាំងពួង ទាំងនាំឲ្យគេគ្រប់គ្នាដែលជាអ្នកស្តាប់ អាចស្តាប់យកជាគតិច្បាប់ដាក់ក្នុងខ្លួនក្នុងពេលនោះបាន ។

៣–មធុភាណី មានសំដីដូចទឹកឃ្មុំ គឺបើចេញវាចាហានិយាយឡើងក្តី ពីរោះពិសាមានរសជាតិនោះផ្អែមល្ហែម នាំឲ្យគេត្រជាក់ចិត្តថ្លើមគ្រប់ៗគ្នា អាចធ្វើឲ្យអ្នកស្តាប់បានសុខកាយសុខចិត្ត គួរយកទុកជាច្បាប់ក្បួន ដាក់ទុកក្នុងចិត្តបាន ។

សំដីពីរខាងចុងនេះ មនុស្សយើងជាបុថុជ្ជនសម័យសព្វថ្ងៃកម្រក្រៃក្រនឹងរកបានពេកណាស់,លុះតែបណ្ឌិតស្ងប់ទើបមានសំដីបែបនេះគឺថា បើខាងក្នុងហឫទ័យរបស់លោកប្រកបដោយមហាករុណាធម៌ មានព្រហ្មវិហារធម៌ជាដើមក្រអូបឈ្ងុយឈ្ងប់មានពណ៌ល្អ មានរសផ្អែមឆ្ងាញ់ពិសាបែបណាចេញវាចាមកខាងក្រៅក៏បែបនោះ ឥតចេះមានសំដីប្រកបដោយកលកិច្ចល្បិចអ៊ូលាក់លៀមទុកឥតមានពិសពុល (ដូចជាពិសពស់វែក , គ្រាប់ស្វែង , ឬមើមអាចម៍ត្ពឹះ)ឡើយ ។

ឯសំដីទីមួយនោះ គឺបានដល់សំដីរបស់មនុស្សបុថុជ្ជនសព្វថ្ងៃនេះ

ឯង ល្អខ្លះ,អាក្រក់ខ្លះ ផ្សេងល្អែមពីកេះមិនពីកេះផ្លូវហើយល្វើង វាលាយ ច្របល់គ្នាទាំងល្អទាំងអាក្រក់ ។ ព្រោះហេតុនោះ ទើបបានជាវាមិន ចេះមានសន្តិភាពសុខស្ងប់ក្នុងលោកសន្ទាក់សម្ព័ន្ធឯង ។

កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ
អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ ។

ប្រែថា កាលបើលោកសន្និវាស ត្រូវភ្លើងគឺរាគៈជាដើមឆេះបំពាក់នេះ ហុយត្រលោមជានិច្ច មេចក៏សើចកើត ? មេចក៏ត្រេកត្រអាលអ៊ីម្ល៉េះ ? , នាំគ្នាទាំងឡាយត្រូវងងឹតគឺអវិជ្ជារួបរឹតហើយ (ទាំងមិន ចុះមេចឡើយ)ក៏ មិនចាំប្រឹងស្វែងរកប្រទីបគឺប្រាជ្ញា ។

បុរាណសុភាសិតថា មនុស្សគេយកសំដី ដំរីគេយកភ្លុក, សំដីជា ឯក លេខជាទោ,ភ្លុកបាក់គេយកភ្លុកជួស តែសំដីហួស គេមិនដឹងជា យកអ្វីមកជួសបានទេ! ។

បុគ្គលខ្លះទៀត ក្នុងលោកនេះ ហៃតែខាននិយាយពាក្យអាក្រក់មាន ការជេរប្រទេចផ្តាសាជាដើម និយាយបង្កាច់បង្ខូចគេ និយាយដោយចិត្ត លោភចង់បានទ្រព្យគេធ្វើឲ្យគេបង់កេរ្តិ៍ឈ្មោះសក្តិយសលាភសក្ការ ។ វាជា ដែលបុគ្គលពាលហើយ ដោយអាក្រក់មានយ៉ាងនេះជាដើមហៅថា ទុព្ភាសិតាវាចា ។ បើប្រសិនជាលោកអ្នកប្រាជ្ញពាលបណ្ឌិតណា មកស្តីប្រៀនប្រដៅឲ្យលះបង់នូវពីទុច្ចរិតទាំងនោះចោលចេញ ច្រើនតែ

មិនព្រមជឿស្តាប់ប្រព្រឹត្តតាមឡើយ បុគ្គលបែបនេះឯងហៅថា ទុព្វចជាតិកាបុគ្គល «បុគ្គលពិបាកគេប្រដៅ ឬបុគ្គលពិបាកនិយាយចូល ។

ទោសរបស់បុគ្គល អ្នកនិយាយពាក្យអាក្រក់ដែលហៅថា ទុព្ភាសិតាវាចានោះ ដូច្នេះ :

១- ទោសនិយាយពាក្យមិនពិត ជាហេតុដកចោលនូវគុណគឺ: សច្ចវាទី ,

២- ទោសនិយាយពាក្យញុះញង់សិកសៀត ជាហេតុដកចោលនូវគុណគឺ ការនៅរួបរួមគ្នាដោយមិត្រសម្លាញ់ខ្លួន,

៣- ទោសនិយាយពាក្យប្រគោះអាក្រក់ ជាហេតុដកចោលនូវគុណគឺ បិយវាចា គឺវាចាដែលនាំឲ្យគេស្រឡាញ់,

៤- ទោសនិយាយពាក្យរោយរាយឥតប្រយោជន៍ ជាហេតុដកចោលនូវគុណគឺ សណ្ហវាចា គឺវាចាដែលប្រកបដោយធម៌ ។

ន័យម្យ៉ាងទៀតថា :

១- ទោសនិយាយពាក្យមុសាវាទ ជាហេតុឲ្យគេនិយាយចោទបង្កាច់បង្ខូច,

២- ទោសនិយាយពាក្យបិសុណវាទ ជាហេតុឲ្យគេបំបែកមិត្រសម្លាញ់ខ្លួន,

៣- ទោសនិយាយពាក្យផរុសវាចា ជាហេតុឲ្យគេស្អប់ព្រោះពាក្យសំដីខ្លួន,

៤- ទោសនិយាយពាក្យសម្ផប្បលាបៈ ជាហេតុឲ្យគេមិនអើពើនឹងពាក្យសំដីខ្លួន ទាំងនាំឲ្យខាតខូចប្រយោជន៍ដែលខ្លួនបានហើយ នឹងប្រយោជន៍ដែលខ្លួនកំពុងបាន ឬប្រយោជន៍ដែលត្រូវបានទៀត ត្រឡប់ទៅជាអាក់ខានមិនបានវិញ ។

យើងដែលត្រូវការនិយាយទាក់ទងដល់អ្នកដទៃ មិនត្រូវមើលងាយប្រមាថការណ៍តែអណ្ដាតឥតឆ្អឹង ចេះតែត្រលៀសនិយាយទៅៗ ឥតបើគិតនោះឡើយ ។

បុរាណសុភាសិត លោកបានប្រៅថា អណ្ដាតជាអាបិកក្នុង បានសុខទុក្ខផងពីព្រោះអណ្ដាត ។ ដ្បិតពាក្យសំដីមួយម៉ាត់ៗនេះ ហានិយាយទៅលាយទ្រព្យសម្បត្តិកេរ្តិ៍កោះអស់លើងក៏មាន, ហានិយាយឡើងបង្កើតទ្រព្យសម្បត្តិបានបុណ្យយសស័ក្តិមានសិរីសួស្តីក៏មាន ។

តាមសាសនធម៌នឹងបុរាណសុភាសិតថា ការដែលនិយាយនោះ ជួនកាលអ្នកខ្លះ និយាយផ្អែមតែមាត់ខាងក្រៅ ខាងក្នុងអាក្រក់ក៏មាន(ដែលហៅថាពោះវៀនបត់បន្ទាស), និយាយបញ្ជោរលើកដើងប្រចុបចូលក្នុងសំដីរបស់បាបមិត្រពួក ដោយគិតតែខាងបានប្រយោជន៍គឺទ្រព្យធនយស

សក្តិគឺមាន គួរតែនិយាយពាក្យជាកល្យាណមិត្រ៤ពួកវិញ គឺនិយាយឲ្យបានជាឧបការៈជួយទំនុកបំរុងគ្នានឹងគ្នា ទើបល្អប្រពៃទាំងបច្ចុប្បន្ននឹងអនាគត បុគ្គលពួកខ្លះ និយាយគ្រោតគ្រាតតែរឿងខាងក្រៅ តែខាងក្នុងហឫទ័យល្អបង់ឲ្យគេបានចំរើនតែម្យ៉ាង រឿងនេះច្រើនតែជារឿងរបស់លោកអ្នកដ៏មានគុណគឺមាតាបិតានឹងគ្រូអាចារ្យជាដើម ពោះបើលោកស្តីបន្ទោសធ្ងន់ខ្លះស្រាលខ្លះ ក៏ហឫទ័យរបស់លោកបង់ឲ្យតែបុត្តធីតាសិស្សគណបានល្អ បានសុខចំរើន, បានចេះដឹងវិជ្ជាគម្រិះធ្វើលោកធ្វើធម៌ មានបានទ្រព្យសម្បត្តិបុណ្យយសសក្តិដោយពិតប្រាកដ ។

មួយទៀតថា: សម្លឲ្យសាប អង្គុយឲ្យទាប និយាយឲ្យខ្ពស់ គឺថា សម្លបើយើងបង់អំបិលច្រើននាំឲ្យប្រែទៅជាបរិភោគពុំកើត (ពិតជាថា អំបិលជាមេខាងចំអាប ជាតិស្ករជាមេខាងបង្អែម ) មែនហើយ តែថាយើងបង់ធ្វើឲ្យល្មមៗ សិនទៅ បើនៅសាបសឹមបង់ខ្លះថែមទៀតទើបមិនខូច មិនឲ្យខកខានបរិភោគ ឯរឿងវិញទៀតសោត បើចាប់និយាយភ្លាមតូចតាងមិនកើតទេ គួរតែនិយាយសំរៀមៗ ស្ងាបៗ ទើបល្អ កុំអាលនិយាយមុនគិតមុនធ្វើនោះ ពុំប្រពៃឡើយ (គិតហើយសឹមគួរ ) ។

អង្គុយឲ្យទាប គឺថាបព្វជិតក្តី គ្រហស្ថក្តី ត្រូវប្រើកិរិយាបថទាំង៤ឲ្យសមរម្យ ត្រូវអង្គុយលើអាសនៈប្រមាណមើលចំណាស់ខ្លួននឹងវស្សាខ្លួន កុំបេះតែអង្គុយដើរតាមតែបាន ពុំសមឋានៈឬវ័យនឹងវស្សាខ្លួននោះឡើយ

ពុកណាថា : «ចង់ដំតែខ្លួន ក្រែងចាយបរាគខ្លួន នៅជា លោកិយ ។ ការដែលនិយាយស្តីនោះ ត្រូវតែពោលវាចាឲ្យមាន ឧត្តមគតិថ្លៃថ្នូរទើបជាមង្គល, កុំនិយាយមើលងាយគេដោយពាក្យមើល ងាយឬបញ្ឆិតបញ្ឆោរបំភាន់នោះឡើយ ! ដូចពាក្យថា កុំកោកា សឹកតែ មាត់ត្រដោក ធ្មេញតែពោះក្រពើ ! » គឺនិយាយច្បាប់ធម៌វានសាសនា, ក្តី ច្បាប់លោកក្តី ត្រូវកាន់គម្ពីរតម្រាច្បាប់ កាន់គោលការមាត្រា ឲ្យមានកំស្តានមានគោលពិតប្រាកដ ។

សាធុជនទាំងឡាយ គួរនាំគ្នានិយាយតែពាក្យថា សុភាសិតវាចា តែម្យ៉ាង ព្រោះជាវាចាប្រាសចាកទោសទុក្ខកង្វល់បច្ចុប្បន្នទាំងបរលោក ជាវាចានាំឲ្យមានសាមគ្គីរវាងគ្នានឹងគ្នា យ៉ាងនេះហៅថា វចី-សុចរិតភាព "ដំណើរស្មើរនៃវាចា" ឬ វចីសច្ចៈ "សេចក្តីពិតត្រង់វាចា» ដែលមានក្នុងពួកនៃបរមត្ថសច្ចៈ សច្ចំ វេ អមតា វាចា "ពាក្យពិត ជាពាក្យមិនចេះស្លាប់! ។

ការពណ៌នាអំពី "វចីសុចរិតភាព" ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

# ព្រះអភិធម្មបិដក

## គម្ពីរបុគ្គលបញ្ញត្តិ

លោក ប៊ូ-ប៊ូ រៀបរៀង

---

ធាតុប្បភេទបញ្ញាសនោ ធាតុកថាបករណំ ទេ
សយិត្វាន សម្ពុទ្ធោ ជិនបុត្តមោ ទេសេត្វា គន្ធន្តរំ
ទេសេសិ បុគ្គលបញ្ញត្តិយោ អាទិមាហា ។

សម្តេចព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គឈ្លាសវៃក្នុងការសម្តែងនូវធាតុ ព្រះអង្គជាធំជាងសត្វក្នុងលោកសន្និវាសមានមនុស្សជាដើម សម្ពុទ្ធោ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចដោយព្រះអង្គឯង ពុំមានគ្រូអាចារ្យណាប្រៀនប្រដៅព្រះអង្គឡើយ កាលព្រះអង្គទ្រង់ត្រាស់ទេសនាគម្ពីរធាតុកថាចប់ហើយ ទើបទ្រង់ត្រាស់ ទេសនាគម្ពីរបុគ្គលបញ្ញត្តិថា ឆ បញ្ញត្តិយោ បញ្ញត្តិទាំងឡាយ៦ ប្រការគឺ ខន្ធបញ្ញត្តិ ព្រះអង្គទ្រង់ត្រាស់តាំងទុកនូវខន្ធទាំងប្រាំរាប់ជាប្រការ ១ អាយតនបញ្ញត្តិ ទ្រង់ត្រាស់ទុកនូវអាយតនៈ១២រាប់ជាប្រការ១ ធាតុបញ្ញត្តិ ទ្រង់ត្រាស់តាំងទុកនូវធាតុ១៨រាប់ជាប្រការ ១ សច្ចបញ្ញត្តិ ទ្រង់ត្រាស់តាំងទុកនូវសច្ចធម៌៤រាប់ជាប្រការ ១ ឥន្ទ្រិយបញ្ញត្តិ ទ្រង់ត្រាស់តាំងទុកនូវឥន្ទ្រិយ ២២ រាប់ជាប្រការ ១ បុគ្គលបញ្ញត្តិ ទ្រង់ត្រាស់តាំងទុកនូវបុគ្គលរាប់ជាប្រការ ១ ត្រូវជាបញ្ញត្តិ ៦ ប្រការ ។

ឯបញ្ញត្តិប្រាំខាងដើម តាំងពីខន្ធបញ្ញត្តិដល់ឥន្ទ្រិយបញ្ញត្តិលើក

ទុក ពុំបានស្រង់យកមកអធិប្បាយក្នុងទីនេះទេ សូមអធិប្បាយតែបុគ្គលប្បញ្ញត្តិប្រការទី៦ មួយចំណែកប៉ុណ្ណោះ ដូចមានសេចក្តីតទៅនេះ៖

កិត្តាវតា បុគ្គលានំ បុគ្គលបញ្ញត្តិ ការតាំងទុកនូវបុគ្គលតើបុគ្គលនោះមានប៉ុន្មានចំពូក ? ព្រះអង្គទ្រង់ត្រាស់សួរដូច្នោះហើយ ទើបទ្រង់ឆ្លើយដោយព្រះអង្គឯងថា បុគ្គលនោះមានមួយពួកក៏មាន មានពីរពួកក៏មាន,មានបី, បួន ,ប្រាំ ,ប្រាំមួយ ,ប្រាំពីរ ,ប្រាំបី ,ប្រាំបួន ដប់ពួកក៏មាន ។

## ឯកកបុគ្គល

សម្តេចព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនានូវបុគ្គលមួយពួកៗមុនថា៖ សមយវិមុត្តបុគ្គល មួយពួក,អសមយវិមុត្តបុគ្គលមួយពួក, កុប្បធម្មបុគ្គល មួយពួក,អកុប្បធម្មបុគ្គល មួយពួក,បរិហានធម្មបុគ្គល មួយពួក,អបរិហានធម្មបុគ្គល មួយពួក,ចេតនាភព្វបុគ្គល មួយពួក, អនុរក្ខនាភព្វបុគ្គល មួយពួក,បុថុជ្ជនបុគ្គល មួយពួក,គោត្រភូបុគ្គលមួយពួក,ភយូបរតបុគ្គល មួយពួក,អភយូបរតបុគ្គល មួយពួក,ភព្វាគមនបុគ្គល មួយពួក អភព្វាគមនបុគ្គលមួយពួក, និយតបុគ្គល មួយពួក,អនិយតបុគ្គល មួយពួក, បដិបន្នកបុគ្គល មួយពួក, ផលេដ្ឋិតបុគ្គល មួយពួក,អរហន្តបុគ្គលមួយពួក,អរហត្តាយបដិបន្នកបុគ្គល

មួយពួក ។

អធិប្បាយ ៦ សមយវិមុត្តបុគ្គលនោះ បានដល់បុគ្គលផុតចាកកិលេសក្នុងសម័យ គឺព្រះសោតាបន្នបុគ្គល ១ ព្រះសកិទាគាមីបុគ្គល ១ ព្រះអនាគាមីបុគ្គល ១ ។

អសមយវិមុត្តបុគ្គលនោះ បានដល់បុគ្គលផុតចាកកិលេសក្នុងកាលមិនមែនសម័យ គឺព្រះអរហន្តសុក្ខវិបស្សកៈ បានសម្រេចព្រះអរហត្តកាត់កិលេសបាបធម៌ដាច់ស្រឡះហើយ ប៉ុន្តែមិនអាចហោះហើរលើអាកាសបាន ព្រោះមិនបានប្រាថនូវអភិញ្ញា ដូចជាព្រះចក្ខុបាលត្ថេរ បានសម្រេចព្រះអរហត្តក្នុងអរញ្ញប្រទេសដងព្រៃ មានចក្ខុទាំងពីរខ្វាក់ លោកមិនត្រឡប់មកស្រុកកំណើតវិញមិនរួច ក្តៅដល់ព្រះឥន្ទ្រនាំព្រះថេរៈមកដាក់ដល់វត្តដេតពនដោយទេវឫទ្ធិ ។

កុប្បជ្ឈានបុគ្គលនោះ បានដល់បុគ្គលដែលបានឈានជាលោកិយប្រកបដោយឥទ្ធិវិធិ ធ្វើឫទ្ធិបានផ្សេង ៗ ដូចព្រះទេវទត្ត ។

អកុប្បជ្ឈានបុគ្គលនោះ បានដល់បុគ្គលមានឈានមិនកម្រើកគឺមិនវិនាសសាបសូន្យទៅវិញ ។

បរិហានបុគ្គលនោះ បានដល់បុគ្គលមានឈានខ្ពស់ឡើងទៅហើយត្រឡប់ថយក្រោយចុះមកវិញ បានដល់ឈានជាន់ទាប ឬថ្នាក់ក្រោម ។

អបរិហានបុគ្គល នោះ បានដល់បុគ្គលមានឈានហើយ មិនចេះសាបសូន្យ មិនត្រឡប់ថយចុះមកក្រោយវិញ ។

ចេតឆាកត្តុបុគ្គលនោះ បានដល់ព្រះសោតាបន្នបុគ្គល, ព្រះសកិទាគាមិបុគ្គល, ព្រះអនាគាមិបុគ្គល ។

អនុរក្ខឆាកត្តុបុគ្គលនោះ បានដល់បុគ្គលមានឈានជាលោកិយ រលត់សង្ខារក្នុងមនុស្សលោកនេះហើយ ,បានទៅកើតក្នុងព្រហ្មលោកខ្ពស់ឡើងៗគ្រប់ជាន់ ។

បុថុជ្ជនបុគ្គលនោះ បានដល់បុគ្គលក្រាស់ដោយកងកិលេស ។ ឯបុថុជ្ជនបុគ្គលនេះ ឋគេឱតោ ឋឆ បើនឹងចែកចេញទៅទៀត មានច្រើនប្រភេទគឺ បុថុជ្ជនជាអន្ធពាលប្រការមួយ ,បុថុជ្ជនជាពាលប្រការមួយ, បុថុជ្ជនជាកល្យាណប្រការ១ ។

ឯបុថុជ្ជនជាអន្ធពាល នោះ បានដល់បុគ្គលជាពាលមានសន្តានចិត្តងងឹតឈ្លប់ល្ងង់ខ្លៅណាស់ មិនបានធ្វើកងការកុសលសោះព្រោះខ្លួនឥតប្រាជ្ញា ។

បុថុជ្ជនជាពាល នោះ បានដល់បុគ្គលជាបុថុជ្ជន ហើយជាពាលផង ។

បុថុជ្ជនជាកល្យាណ នោះ បានដល់បុថុជ្ជនមានសន្តានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ប្រកបដោយបញ្ញាសម្រាប់បំពេញការ

កុសល គឺឲ្យផលទាំងក្បួសីល ស្មើរគេប្រយោជន៍ជាក់ខ្លួនក្នុងជាតិនេះនិងជាតិមុខ យ៉ាងនេះក៏ឈ្មោះថាបុថុជ្ជន តែមិនមែនអន្ធពាល មិនមែនពាល ជាបុថុជ្ជនក្រាស់ទៅដោយកិលេសពិត តែជាមានសទ្ធាបសន្នាការក្នុងព្រះពុទ្ធសាសនា ។

គោត្រភូបុគ្គល នោះ បានដល់បុគ្គលអ្នកបានអរិយគោត្រភូញាណពិចារណានូវព្រះនិព្វានជាអារម្មណ៍ តំ ហិ និព្វានារម្មណំ អាវជ្ជិត្វា សេចក្ដីពិត ព្រះអរិយគោត្រភូញាណនោះពិចារណានូវព្រះនិព្វានជាអារម្មណ៍ ប្រៀបដូចមនុស្សអ្នកស្ទាត់ជំនាញក្នុងហោរាសាស្ត្រ ស្ទាត់ក្នុងសុរិយុបរាគនិងចន្ទុបរាគ ពិចារណាដួងព្រះអាទិត្យនិងព្រះចន្ទ ឃើញជាក់ច្បាស់នូវគុណនិងទោសដែលនឹងកើតមានឡើង ។ គោត្រភូញាណសឹងធ្វើព្រះនិព្វានជាអារម្មណ៍ ព្រះអរិយៈអ្នកបានសម្រេចព្រះអរិយមគ្គនិងព្រះអរិយផល ក៏បានគោត្រភូញាណមុន ទើបបានសម្រេចមគ្គនិងផលជាក្រោយ ។ គោត្រភូញាណនិងឈាននឹងមគ្គផលនោះ មិនមែនឆ្ងាយពីគ្នាទេ គោត្រភូកើតហើយ ឈាននឹងមគ្គផល ទើបកើតជាលំដាប់គ្នា ។

កល្យាណបុគ្គល នោះ បានដល់បុថុជ្ជនអ្នកមានសីល ខ្លាចអំពីទុគ្គតិភ័យ, វដ្ដភ័យ, កិលេសភ័យ និងឧបវាទភ័យ ។

ខ្លាចអំពីទុគ្គតិភ័យនោះ គឺខ្លាចអំពីទុគ្គតិភូមិ ខ្លាចនឹងទៅរងទុក្ខវេទនា

នៅក្នុងនរកនឹងតិរច្ឆានកំណើត, ប្រេតវិស័យនិងអសុរកាយ ។

ខ្លាចអំពីវដ្តភ័យនោះ គឺខ្លាចអំពីភ័យក្នុងបច្ចុប្បន្ន ខ្លាចអំពីកងទណ្ឌ នឹងកើតមានដល់ខ្លួន មានវាយដំប្រហារជាដើម ។

ខ្លាចអំពីកិលេសភ័យនោះ គឺខ្លាចនូវសៅហ្មងនៃសីលដែលខ្លួនរក្សា នឹងធ្វើអំពើអាក្រក់ ខ្លាចតែវានឹងកាក្រក់ ខ្លាចតែសីលដែលខ្លួនរក្សានឹងពពាលពព្រះ ។

ខ្លាចអំពីឧបវាទភ័យនោះ គឺខ្លាចក្រែងអ្នកប្រាជ្ញទាំងឡាយនឹងតិះដៀលខ្លួន ។

ឯបុគ្គលជាបុថុជ្ជនខ្លាចអំពីភ័យទាំងបួនប្រការដូច្នោះហើយ ក៏ខំស្វាហាប់ធ្វើតែការកុសល ឈ្មោះថា ភយូបរតបុគ្គល ហេតុខ្លាចអំពីភ័យបួនប្រការ ។

អភយូបរតបុគ្គល នោះ បានដល់ព្រះអរិយបុគ្គលអ្នកកាត់កិលេសដាច់ជាសមុច្ឆេទបហាន មិនខ្លាចអំពីភ័យបួនប្រការមានទុគ្គតិ-ភ័យជាដើមឡើយ ។

កត្តាគមនបុគ្គលនោះ បានដល់បុគ្គលអ្នកគួរនឹងសម្រេចព្រះអរិយមគ្គអរិយផល គឺបុគ្គលជាបច្ឆិមភវិកជាតិ ។

អកត្តាគមនបុគ្គលនោះ បានដល់បុគ្គលអ្នកមានវាសនានៅមិនទាន់ចាស់ក្លា មិនអាចត្រាស់ដឹងព្រះអរិយមគ្គអរិយផល បាននឹង

បុគ្គល ១១ ពួក គឺបុគ្គលជាថេយ្យសំវាស ១ តិត្ថិយបក្កន្តៈតាំងខ្លួនទៅក្នុងភាពជាសម្មាទិដ្ឋិ បព្វជ្ជាក្នុងព្រះពុទ្ធសាសនាហើយ លះបង់សិក្ខាបទសឹកមកជាឃរាវាសហើយប្រកាន់លទ្ធិនៃតិត្ថិយ ១ ខ្ទើយ ១ ឧភតោព្យញ្ជនកៈ១ សត្វតិរច្ឆាន១ ភិក្ខុនីទូសកៈ ១ បុគ្គលធ្វើបញ្ចានន្តរិយកម្មតាំងប្រាំរួមជាអភព្វបុគ្គល ១១ ពួក ។

និយតបុគ្គលនេះ បានដល់បុគ្គលអ្នកទៀងទាត់ពីរពួក គឺលត់បញ្ចក្ខន្ធហើយទៀងតែទៅនរកមួយពួក ទៀងតែទៅស្ថានសួគ៌មួយពួក ។

ក៏ឯបុគ្គលដែលទៀងតែទៅនរកនោះ បានដល់បុគ្គលអ្នកធ្វើនូវអនន្តរិយកម្មតាំងប្រាំគឺ បិតុឃាត សម្លាប់បិតា១ មាតុឃាត សម្លាប់មាតា១ អរហន្តឃាត សម្លាប់ព្រះអរហន្ត១ លោហិតុប្បាទ ធ្វើព្រះលោហិតនៃព្រះពុទ្ធឲ្យពុះពង់ឡើង ដូចព្រះទេវទត្តប្រមៀលដុំថ្មហើយទង្គិចបែកចេញត្រូវព្រះបាទព្រះពុទ្ធ១ សង្ឃភេទ ចំលាយសង្ឃឲ្យបែកចេញពីគ្នា១ ។ បុគ្គលធ្វើអនន្តរិយកម្មតាំងប្រាំនេះឈ្មោះថា និយតបុគ្គល លត់ជន្មាយុហើយ ទៀងតែទៅកើតក្នុងនរកមិនមានថ្ងៃនឹងរួចផុតពីនរកក្នុងកពជាលំដាប់នៃជាតិឡើយ ។ ចំណែកបុគ្គលអ្នកចំរើនឈាន បានសម្រេចបឋមឈានជាដើម ក៏ចាត់ជានិយតបុគ្គលចំណែកខាងកុសល គឺលត់បញ្ចក្ខន្ធហើយ ទៀងតែនឹងទៅកើតក្នុងស្ថានសួគ៌ នឹងបានទៅកើតក្នុងព្រហ្មលោកជាពិតប្រាកដ ប៉ុន្តែបុគ្គលអ្នកកើតមកក្នុងបច្ចុប្បន្នសព្វថ្ងៃ

នេះ មិនមានអ្នកណាបានសម្រេចឈានទេ កំណត់ផុតយ៉ាងទាបបំផុត ចុះទៅដល់បុគ្គលអ្នកមាននិពទ្ធកុសលបានកសាងកុសលជានិច្ច គឺសង់សាលា ជីកស្រះ ជីកអណ្តូង កសាងព្រះពុទ្ធបដិមាករ នឹងថ្វាយបក្ខិក-ភត្ត សលាកភត្ត ឧបោសថិកភត្ត ជាដើមនេះ ឈ្មោះថា និពទ្ធកុសល សូម្បីនឹងពាក់ជានិយតបុគ្គលក៏បាន ហេតុមានព្រះពុទ្ធដីកាថា យស្ស និពទ្ធំ កុសលជានិច្ចនៃត្រកូលណាមាន ត្រកូលនោះមានគតិដ៏ទៀង ជាដើម ដូចព្រះសោតាបន្នបុគ្គលរលត់ខន្ធហើយ គឺទៀងតែនឹងទៅ កើតក្នុងសុគតិ ហេតុដូច្នេះបុគ្គលប្រកបដោយនិពទ្ធកុសល ទើប ហៅថា និយតបុគ្គលក៏គួរ ។

អនិយតបុគ្គល នោះ បានដល់បុគ្គលមិនទៀងទាត់ គឺមិន បានធ្វើបញ្ចានន្តរិយកម្ម ទាំងមិនបានសម្រេចឈាន ធ្វើកុសលខ្លះ ធ្វើអកុសលខ្លះ ស្រេចតែដល់វេលារលត់បញ្ចក្ខន្ធ បើនឹកឃើញកុសល ៗ ក៏នាំទៅកាន់សុគតិ បើនឹកឃើញអកុសល ៗ ក៏នាំទៅកាន់ទុគ្គតិ តាម អំណាចនៃអាសន្នកម្ម ។

បដិបន្នកបុគ្គល នោះ បានដល់បុគ្គលអ្នកប្រតិបត្តិក្នុង សមថកម្មដ្ឋាននឹងវិបស្សនាកម្មដ្ឋានដែលនឹងឲ្យដល់នូវមគ្គផល ៗ បុគ្គល អ្នកប្រតិបត្តិនោះចាត់ជា ៤ ពួកគឺ ប្រតិបត្តិលំបាកត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិលំបាកត្រាស់ដឹងឆាប់រហ័ស ១ ប្រតិបត្តិជាសុខត្រាស់ដឹងយឺត

យូរ ១ ប្រតិបត្តិជាសុខត្រាស់ដឹងឆាប់រហ័ស ១ រួមជាអ្នកប្រតិបត្តិ ៤ ពួក ។

បដិបន្នកបុគ្គលដែលរាប់ចូលក្នុងឯកបុគ្គលដូច្នោះ ដោយអំណាចនៃបុគ្គលទាំងបានមគ្គផលក្នុងជាតិនោះ ។ ក៏ឯបុគ្គលកើតមកក្នុងកាលសព្វថ្ងៃនេះ ចំរើនសមថវិបស្សនាមានសេចក្តីព្យាយាមខ្លាំងក្លាឧស្សាហ៍ខ្ជាប់ខ្ជួនអត់ធន់ទុក្ខលំបាកជាទុក្ខាបដិបទាក៏មាន , ជាសុខាបដិបទាក៏មាន ប៉ុន្តែ មិនអាចញ៉ាំងមគ្គផលឲ្យកើតក្នុងជាតិនេះបានឡើយ តែអាចឲ្យត្រាស់ដឹងឆាប់រហ័សទាំងត្រាស់ដឹងយឺតយូរក្នុងអនាគតកាល កាលបើមូលបណិធានគ្រប់គ្រាន់តាមសេចក្តីប្រាថ្នាហើយ បុគ្គលអ្នកប្រតិបត្តិនេះឈ្មោះថា បដិបន្នកបុគ្គល ។

ប្រការមួយទៀត បុគ្គលមានសទ្ធាជ្រះថ្លាក្នុងការកុសលហើយប្រាថ្នាព្រះនិព្វាននោះ សូម្បីទាំងហៅថាបដិបន្នកបុគ្គលក៏បានដែរ ព្រោះថាបុគ្គលអ្នកមានសទ្ធាកើតមកក្នុងកាលខាងក្រោយនេះ យ៉េះដឹងច្បាស់ណាស់ហើយថា បើទុកជាខំប្រឹងប្រតិបត្តិតឹងរ៉ឹងទៅដល់ត្រឹមណាក៏ដោយ ក៏នៅតែមិនបានសម្រេចឈានទាំងមគ្គផលដែរ ប៉ុន្តែការប្រតិបត្តិនៃការកុសលដែលខំបានធ្វើនេះ នឹងបានជាឧបនិស្ស័យបច្ច័យឲ្យបានសម្រេចមគ្គផលក្នុងជាតិមុខ បើទុកជានៅមិនទាន់ឆាប់សម្រេចមគ្គផល ហេតុតែបារមីមិនទាន់ចាស់ក្លា ក៏នឹងញ៉ាំងអាត្មាឲ្យបានមនុស្សសម្បត្តិនិងសួគ៌សម្បត្តិលុះដល់ឃើញច្បាស់លាស់ដូច្នេះហើយ ទើបធ្វើការកុសលមានដើមថា

ឲ្យទាន, រក្សាសីល, ស្តាប់ព្រះសទ្ធម្មទេសនា ក៏ចាត់អនុលោមចូលក្នុងបុគ្គលដែលឈ្មោះថា បដិបន្នកបុគ្គល ។

ផលដ្ឋកបុគ្គលនោះ បានដល់បុគ្គលអ្នកតាំងនៅក្នុងផលទាំងបួនគឺ ព្រះសោតាបត្តិផល, ព្រះសកិទាគាមិផល, ព្រះអនាគាមិផល, ព្រះអរហត្តផល ។

ព្រះអរហត្តបុគ្គលនោះ បានដល់បុគ្គលអ្នកសម្រេចនូវព្រះអរហត្ត កាត់កិលេសដាច់ជាសមុច្ឆេទប្បហាន រៃកធ្លាយក្នុងបដិសម្ភិទានិងអភិញ្ញា ត្រៃវិជ្ជា ស្ទាញស្ទាត់ក្នុងព្រះត្រៃបិដក ។ ឯព្រះអរហត្តសុក្ខវិបស្សកៈ កាត់បានតែកិលេសប៉ុណ្ណោះ មិនបានដល់នូវបដិសម្ភិទាជាដើម ។

អរហត្តាយបដិបន្នកបុគ្គលនោះ បានដល់បុគ្គលអ្នកប្រតិបត្តិដើម្បីនឹងឲ្យបាននូវព្រះអរហត្តផល មានព្រះសោតាបន្នបុគ្គលជាដើម មានព្រះអរហត្តមគ្គបុគ្គលជាបរិយោសាន រួមគ្នាជា ៧ ពួក ។

សម្តេចព្រះបរមគ្រូទ្រង់ត្រាស់សំដែងបុគ្គលពួកមួយៗ ដោយសង្ខេបតែប៉ុណ្ណោះ ។

ឯកបុគ្គលសង្ខេបតែប៉ុណ្ណោះ ។

## ទុកបុគ្គល

លោកធាតោ ឯកបុគ្គលំ ឆសេដ្ឋា ទុកបុគ្គលំ ឆសេដ្ឋា ទ្វេ បុគ្គលា លោកេ សំវិជ្ជមានា កតមេ

ទ្វេ មក្ខី ច បលាសី ចាតិ ឥមេ ខោ ទ្វេ លោកេ សំវិជ្ជមានាតិ ។

លោកាឆាដោ សម្តេចព្រះបរមលោកនាថ ព្រះអង្គកំចាត់បង់នូវទុក្ខនៃសត្វលោកទាំងឡាយ ឯកាំ ធរេស្សត្ថា កាលទ្រង់ត្រាស់ទេសនាឯកបុគ្គលរួចហើយ ទើបត្រាស់ទេសនាទុកបុគ្គល គឺសំដែងនូវបុគ្គលម្តងពីរពួកៗតទៅថា ទ្វេ បុគ្គលា លោកេ បុគ្គលទាំងឡាយក្នុងលោកនេះមានពីរពួក កតមេ ទ្វេ បុគ្គលពីរពួកនោះគឺអ្វីខ្លះ? ឥមេ ខោ ទ្វេ បុគ្គលពីរពួកនេះ គឺ មក្ខីបុគ្គល មួយពួក បលាសីបុគ្គល មួយពួក ។

មក្ខីបុគ្គល នោះ បានដល់បុគ្គលអ្នកលុបលាងគុណគេ ។

បលាសីបុគ្គល នោះ បានដល់បុគ្គលអ្នកលើកខ្លួនឯង សង្កត់សង្កិនគេ ។

ទុកបុគ្គលសង្ខេបតែប៉ុណ្ណេះ ។

## មនុស្សភហិណី

សម្ដេចព្រះធម្មលិខិត ល្វី ឯម ប្រែរៀបរៀង

(តមក)

---

លុះជនទាំងបីនាក់បានឡើងមកលើគោកហើយ ក៏និយាយនឹងជនជាសប្បុរសថា អ្នកជាសម្លាញ់បានឲ្យជីវិតដល់យើងហើយ យើងមានសេចក្ដីសោមនស្សត្រេកអរពន់ពេក ព្រោះយើងបានជីវិតរស់នៅនេះ គាស្រ័យនឹងអ្នកដោយពិត បពិត្រអ្នកដំចំរើន! ចាប់ដើមពីថ្ងៃនេះទៅ សូមអ្នកសំគាល់ខ្លួនថាជាសម្លាញ់លើយើងទាំង៣នាក់ ឯយើងសោតសឹងប្រាថ្នាចង់ទៅកាន់ស្ថានជាទីនៅរបស់អ្នក ដោយសេចក្ដីកតញ្ញូពិតមែន ។

ទើបសេកបាននិយាយប្ដូជានឹងជនជាសប្បុរសជាមុនថា បពិត្រអ្នកជាសំឡាញ់! មានដើមជ្រៃធំមួយដើមនៅទៀបទ្វារខាងត្បូងនៃក្រុងពារាណសី ខ្ញុំបានធ្វើសម្បុកនៅលើដើមជ្រៃនោះ កាលបើអ្នកមានកិច្ចជាប់ខ្លួនដូចយើងដែរនោះ សូមសំឡាញ់អញ្ជើញចូលទៅកាន់សំណាក់ខ្ញុំចុះ ហើយត្រូវហៅឈ្មោះខ្ញុំថា សុវៈ ៗ ដូច្នេះ, លុះសេកបាននិយាយយ៉ាងនេះហើយ ក៏បានធ្វើសេចក្ដីស្នេហាស្រឡាញ់ជនអ្នកសប្បុរសនោះយ៉ាងមាំ ហើយហើរទៅកាន់ទីកន្លែងខ្លួនតាមប្រក្រតី ។ ឯពស់សោត ក៏បាននិយាយទៅនឹងបុរសនោះថា បពិត្រសំឡាញ់មានគុណស្មើ! ដ្បិតមានដំបូកមួយ

យ៉ាងធំនៅជិតដើមជ្រៃនោះដែរ ខ្ញុំបាននៅអាស្រ័យក្នុងជម្រកនោះអស់កាលជានិច្ច បពិត្រអ្នកជាសំឡាញ់! កាលបើអ្នកមានកិច្ចត្រូវការរកខ្ញុំ ត្រូវអ្នកចូលទៅក្នុងទីនោះ ហើយហៅខ្ញុំថា ទីឃៈៗ ដូច្នេះចុះ ខ្ញុំនឹងចេញមកទទួលអ្នកភ្លាម លុះពស់បាននិយាយយ៉ាងនេះហើយ ក៏ធ្វើសេចក្ដីកប់កានយ៉ាងមាំ ហើយលូនចេញទៅកាន់ទីកន្លែងខ្លួនដូចសេកដែរ ។

ចំណែកមនុស្សវិញ ក៏បាននិយាយទៅនឹងជនអ្នកសប្បុរសនោះថា បពិត្រសំឡាញ់មានធុរៈស្មើ! ខ្ញុំបាននៅអាស្រ័យក្នុងផ្ទះឯណោះ ផ្លូវថ្នល់ឯណោះទៀបក្រុងពារាណសី កាលបើអ្នកមានកិច្ចត្រូវការរកខ្ញុំ ចូរអ្នកមកកាន់សំណាក់ខ្ញុំចុះ មនុស្សនោះបាននិយាយយ៉ាងនេះហើយ ក៏ចៀសចេញទៅកាន់ផ្ទះរបស់ខ្លួនក្នុងកាលនោះឯង ។

លុះចំណេរមកជាខាងក្រោយ បុរសដែលមានឧបការគុណនោះ បានគិតពិចារណាចង់ល្បងមើលជនទាំងបីនាក់នោះថា អាត្មាអញត្រូវតែដឹងកិច្ចរបស់ខ្លួនដោយពិត អាត្មាអញនឹងចូលទៅកាន់សំណាក់សំ-ឡាញ់ទាំងឡាយឥឡូវនេះឯង បុរសនោះគិតដូច្នេះហើយ ក៏ដើរចេញទៅតាមតម្រុយជាគ្រឿងចំណាំដែលខ្លួនបានកំណត់ទុកហើយនោះ បានចូលទៅឈរក្នុងទីជិតដើមជ្រៃ ហើយស្រែកហៅថា សុវៈៗ ក្នុងទីនោះ ។ ឯសេកសោមសោត លុះបានឮសំឡេងហៅថា សុវៈៗ ដូច្នោះហើយ ក៏ហើរចេញមកទទួល ដោយរហ័សរួសរាន់ ទាំងមានចិត្តរីករាយ

ស្មោះសរពេកទាក់ទាក់ជាមួយនឹងបុរសនោះឯង ហើយសួរថា បពិត្រសំឡាញ់មានធុរៈស្មើ! អ្នកបាត់មុខអស់កាលយូរហើយ ពុំដែលបានជួបមុខស្មោះ ទើបតែបានជួបគ្នាវិញនេះ អ្នកអញ្ជើញមកមានការអ្វី? សូមអ្នកប្រាប់ដំណើរការនោះដល់ខ្ញុំផង ខ្ញុំនឹងបានដឹងផង ។

ទើបបុរសដែលមានទុក្ខការៈនោះក៏បានប្រាប់ថា ម្នាលសំឡាញ់មានធុរៈស្មើ! លោកប៉ានិងខ្លួនយើងសព្វថ្ងៃនេះទាល់ក្រពេកណាស់ពុំដឹងបើនឹងបានវត្ថុអ្វីឲ្យល្មមនឹងចិញ្ចឹមជីវិតខ្លួន នឹងកូនប្រពន្ធញាតិទាំងឡាយបានឡើយ ព្រោះហេតុនេះហើយ បានជាយើងចូលមកកាន់សំណាក់សំឡាញ់ក្រែងសំឡាញ់មានទ្រព្យអ្វីខ្លះល្មមបែកមកឲ្យយើងគ្រាន់ចិញ្ចឹមជីវិតតទៅ ។

ចំណែកឯសេកសោមកាលបើបានស្តាប់ហើយក៏និយាយតបវិញថា: បពិត្រសំឡាញ់មានធុរៈស្មើ! ការដែលសំឡាញ់បានធ្វើដំណើរចូលមករកខ្ញុំនេះប្រពៃហើយ, ជីវិតរបស់ខ្ញុំដែលបានរស់នៅមកដល់សព្វថ្ងៃនេះព្រោះតែសំឡាញ់បានឲ្យដោយពិត, គួរតែខ្ញុំធ្វើខ្លួនឧបាយជាគ្រឿងចិញ្ចឹមជីវិតណាមួយតបសំឡាញ់ក្នុងពេលនេះទើបគួរ., បើដូច្នេះខ្ញុំនឹងចេញទៅស្វែងរកទ្រព្យគ្រាន់នឹងតបគុណសំឡាញ់ខ្លះ បើខ្ញុំមិនទាន់ត្រឡប់មកវិញដរាបណា សូមអ្នកជាសំឡាញ់បង្អង់រង់ចាំខ្ញុំដរាបនោះ លុះបានពោលយ៉ាងនេះហើយ ក៏ហោះចេញទៅស្វែងរកឧបាយ ដើម្បីនឹងរកស្បៀងចិញ្ចឹមជីវិតឲ្យដល់បុរសនោះឯង ។

មានសេចក្តីដំណាលថា ក្នុងថ្ងៃមួយ ព្រះបាទពារាណសីបរម-ក្សត្រិយ៍ស្តេចយាងចេញទៅពីព្រះនគរ ព្រមទាំងសេវកាមាត្យទាំងឡាយ មានអង្គបួន ហោមរោមដោយសបរិវារ ដង្ហែព្រះអង្គចូលទៅកាន់ឧទ្យាន ដែលបុគ្គលបានរៀបចំដោយប្រពៃហើយ ព្រះបរមក្សត្រិយ៍ទ្រង់ត្រេកសាល សប្បាយក្សេមក្សាន្តព្រះទ័យព្រមទាំងបរិស័ទ លុះពេលថ្ងៃត្រង់ព្រះអង្គ បានទតទៅឃើញស្រះមង្គលបោក្ខរណី ដ៏ដេរដាសទៅដោយផ្កាឈូក ទាំងប្រាំពណ៌សឹងមានផ្ការីកស្គុះស្គាយ មានក្លិនក្រអូបឈ្ងុយឈ្ងប់ក្នុងស្រះ នោះ ស្តេចប្រាថ្នាបង់ស្រង់ទឹកលំហើយព្រះអង្គឲ្យគេដាក់ស្រួល ទ្រង់ ដោះឡូវគ្រឿងអម្ពរកស្ត្រា ទាំងពួងប្រគល់ឲ្យរាជបុរសនៅចាំរក្សា ហើយ ព្រះអង្គស្តេចចុះស្រង់ក្នុងស្រះមង្គលបោក្ខរណីនោះឯង ។ គ្រានោះ សេកសោមកិបានហើរទៅដល់ទីនោះ ហើយចុះទៅលើមែកឈើមួយជិតទី នោះឯង បានសម្លឹងមើលសេចក្តីប្រមាទប្រហែសធ្វេសនៃរាជបុរសទាំង ឡាយដែលចាំរក្សា លុះបានឱកាសហើយក៏ហើរចុះទៅពាំកែវមុត្តាហារ សំរាប់ប្រដាប់ព្រះអង្គ រួចហើយក៏ស្ទុះហើរចៀសចេញទៅតាមអាកាស មួយរំពេចនោះឯង, នាំកែវមុត្តាហារនោះទៅប្រគល់ឲ្យដល់បុរសជា សំឡាញ់របស់ខ្លួនស្រេច ហើយពោលថា បពិត្រសំឡាញ់មានធុរៈ ស្មើ ! អ្នកកុំប្រមាទប្រហែសធ្វេសឡើយ ចូរអ្នកយកកែវមុត្តាហារ នេះទៅប្រើប្រាស់តាមរាយជាស្បៀងលៀងជីវិតអ្នកតាមត្រូវការចុះ ។

តមក បុរសនោះបានទទួលយកកែវមុន្តាអំពីសេកស្រេចហើយ រំពឹងគិតថា អាត្មាអញនឹងយកកែវមុន្តានេះទៅទុកដាក់ក្នុងទីណា ? លុះគិតដូច្នេះហើយក៏យល់សេចក្តីថា មានមនុស្សម្នាក់ជាសំឡាញ់របស់អាត្មាអញនៅខាងក្នុងព្រះនគរ ដូច្នេះ អាត្មាអញនឹងយកកែវមុន្តានេះទៅផ្ញើទុកនឹងសំឡាញ់នោះជាការស្រួលល្អ គាត់ក៏កាន់យកកែវមុន្តាហារនោះចូលទៅតាមទីកន្លែងដែលខ្លួនបានកត់ចំណាំទុកពីមុនមក លុះបានចូលទៅជួបនឹងសំឡាញ់នោះហើយ , បានធ្វើបដិសណ្ឋារស្រួលទទួលគ្នាទៅវិញទៅមក ហើយបានសំណេះសំណាល ប្រាប់នូវឧបការដែលសេកបានធ្វើតបគុណចំពោះខ្លួនដោយសេចក្តីសព្វគ្រប់ ៗ មុននឹងបញ្ចប់ក៏និយាយថា: សូមសំឡាញ់ទទួលកែវមុន្តាហារនេះទុកឱ្យខ្ញុំឱ្យល្អផងចុះ ពោលយ៉ាងនេះហើយក៏ប្រគល់កែវមុន្តាហារឱ្យសំឡាញ់នោះទុកឱ្យក្នុងកាលនោះឯង ។

វេលាក្រោយនោះបន្តិចព្រះបរមក្សត្រិយ៍ស្តេចស្រង់ទឹករួចហើយក៏ប្រថាប់ធ្វើស្អិតស្អាងព្រះអង្គដោយគ្រឿងអម្ពរទាំងឡាយស្រាប់តែបាត់ឯកែវមុន្តាហារ ព្រះអង្គគន់រកទីធ្វើប្រដាប់ពុំឃើញឡើយ ទ្រង់ត្រាស់សួររាជបុរសដែលរក្សាក៏ពុំបានដឹង ៗ លំដាប់នោះ រាជបុរសទាំងឡាយបានដឹងថា កែវមុន្តាហាររបស់ព្រះបរមក្សត្រិយ៍ចោរលួចយកដូច្នេះហើយក៏ចាត់គ្នាឱ្យដើរទៅល្បាតគយឃ្លាំពិនិត្យមើល ជនជាបរិសទ្យទាំងឡាយទាំងខាងក្នុងខាងក្រៅព្រះនគរពុំបានឃើញកែវមុន្តាហារនោះឡើយ ទើប

ពាក់មនុស្សទាំងឡាយ ឲ្យរាយសួរគ្រប់ទៅក្នុងព្រះនគរទាំងមូលថា៖បើអ្នកណាទីមួយបានរកកែវមុត្តាហាររបស់ព្រះបរមក្សត្រិយ៍ឃើញ ហើយនាំមកថ្វាយព្រះអង្គ ព្រះអង្គនឹងប្រទានយសសក្តិយ៉ាងធំដល់អ្នកនោះឯង ៗ

ឯមិត្តទុព្ភិ មនុស្សអ្នកប្រទូស្តមិត្ត មានសន្តានចិត្តជាអកតញ្ញូឥតមានដឹងគុណឧបការគេនោះ បានឃើញគេរាយសួរឲ្យដំណឹងដូច្នេះក៏ភ្លេចគុណគេមួយរំពេចដោយលោភចង់បានយសសក្តិ ទើបគិតដូច្នេះថា អញសព្វថ្ងៃនេះ មានសេចក្តីទុក្ខលំបាកក្រពន់ពេកណាស់ ណ្ហើយចុះត្រូវតែអញយកកែវមុត្តាហារនេះចូលទៅថ្វាយព្រះមហាក្សត្រិយ៍ ១ គង់នឹងប្រទានយសសក្តិ ឬទ្រព្យរបស់ដល់អញ ៗ នឹងបានទៅជាសុខសប្បាយដោយពិត ៗ ឯបុរសជាសំឡាញ់ដែលយកកែវមុត្តាហារមកផ្ញើទុកនៅលើអញនេះ មិនជាប្រយោជន៍អ្វីដល់អញទេ លុះបុរសអ្នកប្រទូស្តមិត្តនោះគិតដូច្នេះហើយ ក៏ពុំមានសតិរលឹកដល់គុណូបការ ដែលបុរសជាសំឡាញ់បានធ្វើដល់ខ្លួនឡើយ ហើយបានដើរចូលទៅកាន់សំណាក់រាជបុរសទាំងឡាយនិយាយប្រាប់សេចក្តីនោះសព្វគ្រប់ថា បពិត្រលោកទាំងឡាយដ៏ចំរើន ! កាលពីថ្ងៃមុន មានបុរសម្នាក់យកកែវមុត្តាហារមកផ្ញើទុកនឹងខ្ញុំ ដូច្នេះសូមលោកអញ្ជើញទៅយកកែវនឹងបុរសនោះ មកពិនិត្យមើលតាមច្បាប់រាជការចុះ ៗ

ឃរំ ហិ អសប្បុរិសសំសគ្គោ ទុក្ខោ សេចក្តីពិតថា បុគ្គល

អ្នកសេពគប់ ឬនៅប្រឡូកប្រឡល់ដោយបុគ្គលជាអសប្បុរស តែមិនបានខូច សេចក្ដីក្ដុកយ៉ាងនេះឯង, ហេតុដូច្នោះ បានជាពួកព្រះអរហន្តដែល លោកបានទិតទៀងនេះពោលអាងព្រះគាថាទាំងឡាយថា: យថា សិ-ញ្ចតោ និម្ពោ មធុរេនគសិញ្ចា ន យាតិ មធុរំ តដោ-បការមសតំ ការំ ដូច្នេះជាដើម អធិប្បាយថា: ដើមស្ដៅមានរស ល្វីង ព្រោះបើបុគ្គលស្រោចទឹកផ្អែមឲ្យចំរើនច្រើនឡើងដល់ប៉ុន្មានក្ដី គឺគង់ មិនត្រឡប់ទៅជាឈើមានរសផ្អែមវិញឡើយ គង់នៅជាឈើមានរសល្វីង ដដែល មានឧបមាយ៉ាងណា គុណឧបការៈដែលបុគ្គលបានធ្វើដោយ ស្មោះចិត្តចំពោះជនជាអសប្បុរសច្រើនដល់ប៉ុន្មានក្ដី គុណឧបការៈនោះមិន ត្រឡប់ទៅជាពោសវិញ ឯជនជាអសប្បុរសក៏គង់នៅជាអសប្បុរសវិញ ដដែល មានឧបមេយ្យដូចដើមស្ដៅនោះឯង ។ ជាតិជាសត្វអសិ-រពិស ព្រោះបើបុគ្គលចិញ្ចឹមរក្សាឲ្យទឹកដោះគោដ៏មានរសផ្អែមផឹកស៊ីជានិច្ច ច្រើនដល់ប៉ុន្មានក្ដី ជាតិពិសនោះក៏គង់ពុំសាបរលាបទៅ រឹតតែចំរើន ពិសច្រើនឡើងទៀត មានឧបមាយ៉ាងណា, ឧបការគុណដែលបុគ្គល បានធ្វើចំពោះជនជាអសប្បុរសច្រើនដល់ប៉ុន្មានក្ដី គុណនោះមិនចំរើន ប្រយោជន៍ជាលទ្ធផលអ្វី មិនអាចធ្វើជនជាអសប្បុរសនោះឲ្យត្រឡប់ទៅ ជាសប្បុរសវិញបានឡើយ មានឧបមេយ្យដូចពិសពស់នោះឯង ។ ជាតិជាភ្លើង ព្រោះបើបុគ្គលដុតបង្កាត់ . ឲ្យឆេះឡើងដោយខ្លួនឯងក្ដី

ភ្លើងនោះក៏គង់មិនត្រជាក់ លុះតែទៅចាប់ពាល់ហើយ មុខជានឹងឆេះរលាកខ្លួនឯងវិញពុំខានឡើយ មានឧបមាយ៉ាងណា? ជាតិជាអសប្បុរសនោះបើគេធ្វើគុណឧបការដល់ខ្លួនច្រើនប៉ុន្មានក្តី តែមានចិត្តកាកអន់តិចតួចហើយ អសប្បុរសនោះតែងនឹងត្រឡប់ធ្វើទ្រុស្តដល់បុគ្គលដែលមានគុណនោះវិញ មានឧបមេយ្យដូចភ្លើងនោះឯង ។ ព្រោះហេតុដូច្នេះបុគ្គលជាសប្បុរសដែលមានប្រាជ្ញាល្អ ត្រូវតែពិចារណាមើលដោយប្រពៃហើយគប្បីសេពគប់នឹងជន ដែលមានចិត្តមេត្រីរាប់អាន ស្មោះត្រង់ជាមិត្តឲ្យបាន ទើបនឹងបានសុខក្សេមក្សាន្តដោយពិត ។ បុគ្គលកើតមកក្នុងលោកនេះ មិនដែលមានជនណាមួយបានសេចក្តីសុខក្សេមក្សាន្តអំពីសំណាក់ជនជាសត្រូវមានសន្តានចិត្តជាអសប្បុរសនោះឡើយ ។

ព្រោះហេតុដូច្នេះ ទើបរាជបុរសទាំងឡាយបានចូលទៅកាន់យកតែមុត្តាហារ ហើយចាប់ចងបុរសដែលមានឧបការគុណយ៉ាងមាំ តាមពាក្យបង្គាប់មិត្តទាំងបីរបស់អ្នកពាណិជ្ជ ទ្រុស្តមិត្តនោះ ហើយនាំយកទៅថ្វាយបរមក្សត្រិយ៍ក្នុងកាលនោះឯង ។

ឯព្រះបរមក្សត្រិយ៍ ព្រះអង្គបានទតទៅឃើញហារព្រមទាំងទ្រព្យដែលរាជបុរសបាននាំមកដូច្នោះហើយ ស្តេចក៏ទ្រង់ព្រះពិរោធខ្លាំងខ្លាំងពន់ពេក ពុំបានពិចារណាឲ្យជ្រុងជ្រៅជាមុន ក៏មានព្រះរាជឧង្ការត្រាស់បង្គាប់រាជបុរសទាំងឡាយថា: អ្នកទាំងឡាយត្រូវនាំយកបុរសចោរកំណាច

នេះទៅឲ្យដេកនៅលើចុងដែកស្រួចទាំងរស់ទៀបទ្វារខាងត្បូងព្រះនគរជាដាច់ ទើបពួកបុរសទាំងឡាយបានធ្វើតាមព្រះអាជ្ញាព្រះបរមក្សត្រិយ៍ បានចាប់នូវឧបការបុរសនោះ ហើយបណ្ដើរនាំចេញទៅតាមទ្វារខាងត្បូងនោះហោង ។

ឯឧបការបុរស កាលបើពួកបម្រើទាំងឡាយគេនាំទៅតាមផ្លូវទ្វារខាងត្បូងទីក្រុងហើយ ក៏បាននឹករលឹកដល់ពស់នាគរាជជាសំឡាញ់ថា បើអាត្មាអញបានទៅដល់ទីសំណាក់នៃពស់ជាសំឡាញ់ហើយ សេចក្ដីសុខសួស្ដីគិតគួរគង់នឹងមានប្រាកដដល់អាត្មាអញពុំខានឡើយ លុះរំពឹងគិតយ៉ាងនេះហើយ ក៏បាននឹកស្រាវជ្រាវរកវិធីដែលពស់នាគរាជបាននិយាយផ្ដាំទុកពីកាលមុន កាលបើគេនាំទៅដល់ជិតជម្រកនោះក៏បានឃើញស្គាល់ជាក់ហើយស្រែកហៅថា: សម្មទីយ ម្ចាលទីយៈជាសំឡាញ់អើយ! សំឡាញ់នៅទីណាៗ ពស់នាគរាជនោះបានស្ដាប់ហើយក៏ចេញទៅមួយរំពេច បានឃើញបុរសជាសំឡាញ់ខ្លួនគេចាប់ចងនាំទៅដូច្នោះហើយ ក៏មានសេចក្ដីសំវេគស្លុតចិត្តអាណិតសំឡាញ់ខ្លួន ដល់នូវសេចក្ដីទុក្ខជាទម្ងន់ទើបគិតជាថ្មីថា ថ្ងៃនេះត្រូវតែអាត្មាអញយកខ្លួនធ្វើជាទីពឹងគប់សំឡាញ់វិញទើបគួរ លុះគិតដូច្នេះហើយ ក៏លះបង់អត្តភាពខ្លួនចេញចាកពស់នាគរាជនិម្មិតជាបុរសមិនឲ្យអ្នកណាមួយស្គាល់ឡើយ ។ ហើយដើរចូលទៅកាន់សំណាក់ពួកបុរសទាំងអស់ និយាយយ៉ាងថា

អ្នកចាំងឡាយត្រូវនៅចាំខ្ញុំមួយរំពេចសិន កុំអាលសំឡាប់បុរសនេះឡើយ នាគបុរសបានពោលឃាត់ដូច្នេះហើយ ក៏ត្រេចទៅកាន់ទីលំនៅព្រះអគ្គមហេសីនៃព្រះបរមក្សត្រដោយកាលមួយរំពេចពុំយឺតយូរឡើយ ហើយនិម្មិតភេទជាពស់វែកចឹកព្រះនាងទេវីនោះឯង កាលបើព្រះនាងទេវីនោះសន្ទប់បាត់ស្មារតីដោយកម្លាំងពិសហើយ ក៏និម្មិតត្រឡប់ភេទជាមនុស្សវិញមួយរំពេច ហើយនិយាយប្រាប់ពពួកបរិសទ្យចាំងឡាយថា ពិសពស់នេះគ្មានអ្នកណាមួយអាចបេះស្តោះបានឡើយ មានតែបុរសដែលត្រូវទោសទើបដឹងការចាំងពួងកន្លងរឿងពិសពស់នេះបាន លុះបាននិយាយដូច្នេះហើយ ចូលទៅសំណាក់ទបការបុរសជាសំឡាញ់របស់ខ្លួនដោយឆាប់មួយរំពេច និយាយប្រាប់សំឡាញ់ថា កាលបើស្តេចត្រាស់បង្គាប់ឲ្យហៅសំឡាញ់ចូលទៅស្តោះពិសពស់នោះ បើសំឡាញ់បានចូលទៅដល់ហើយត្រូវយកបាទដៃក្បងទឹក ហើយប្រោះលើសិរៈព្រះនាងទេវីនោះ បើបានប្រោះទឹកយ៉ាងនេះហើយ អាចនឹងធ្វើពិសពស់នោះឲ្យវិនាសបាត់ទៅមួយរំពេចនោះឯង នាគរាជបានប្រាប់កិច្ចសព្វគ្រប់ហើយក៏ហោះត្រឡប់ទៅកាន់ទីលំនៅខ្លួនវិញក្នុងមួយរំពេចនោះដែរ ។

ក្រោយពីនោះមកព្រះបរមក្សត្រិយ៍ ទ្រង់បានជ្រាបថាពស់ចឹកព្រះនាងទេវីសន្ទប់បាត់ស្មារតីដូច្នោះហើយ ព្រះអង្គមានព្រះទ័យភិតភ័យជាខ្លាំងទើបត្រាស់បង្គាប់សេវកាមាត្យឲ្យស្វែងរកពេទ្យពស់ ក៏រកពុំបាន

ពុំមានគ្រូណាមួយអាចនឹងហាននៈស្ដោះពិសឡើយ ហើយស្ដេចបានជ្រាបដំណឹងថា មានតែបុរសដែលត្រូវទោសម្នាក់នោះទើបអាចស្ដោះពិសពស់នេះធ្វើឲ្យស្រះជាបាន, លុះទ្រង់ជ្រាបដូច្នេះហើយ ក៏ត្រាស់បង្គាប់ឲ្យទៅដោះលែងទោចការបុរសនោះនាំចូលមកថ្វាយព្រះអង្គ ហើយទ្រង់ត្រាស់បញ្ជានូវទោចការបុរសដូច្នេះថា : អ្នកឯងត្រូវធ្វើពិសពស់ដែលមានក្នុងសរីរៈព្រះនាងទេវីនេះឲ្យបានជាសះស្បើយក្នុងកាលឥឡូវនេះឯង ។

ឯទោចការបុរសនោះលុះបានទទួលព្រះរាជឱង្ការហើយក៏យកបាទដៃក្បង់ទឹកប្រោះលើសរីរៈព្រះនាងទេវី តាមន័យដែលនាគរាជបានពោលបង្គាប់នោះហើយ ពិសពស់សាយជ្រុះចុះអំពីសរីរៈព្រះនាងទេវី ក្នុងមួយរំពេចនោះឯង ។ ឯព្រះនាងទេវីសោតក៏បានដល់នូវសេចក្ដីសុខសប្បាយឥតមានរោគាព្យាធិដូចប្រក្រតីវិញក្នុងកាលនោះហោង ។

រីឯព្រះបាទពារាណសីព្រះបរមក្សត្រិយ៍ ព្រះអង្គបានឃើញព្រះនាងទេវីនោះជាសះស្បើយឥតមានរោគដូច្នោះហើយ ក៏មានព្រះរាជហឫទ័យត្រេកអរពន់ពេក ហើយស្ដេចទ្រង់ធ្វើសក្ការៈយ៉ាងធំ តបគុណទោចការបុរសនោះ ដោយព្រះរាជទានទ្រព្យសម្បត្តិនិងយសសក្តិមានស្រែចម្ការយានពាហនៈជាដើមសមគួរតាមហេតុនោះឯង ។

លុះដល់មកកាលជាខាងក្រោយទោចការបុរសនោះក៏បានចូលទៅកាន់សំណាក់ព្រះបរមក្សត្រិយ៍លើកអញ្ជលីឡើងក្រាបបង្គំទូលថ្វាយនូវអំពើទាំង

អស់ ដែលខ្លួនបានធ្វើហើយសូត្រជាបទព្រះគាថាថា៖ ឯកាទសហំ មហារាជ នរកាម្មេន កោធចិ តតោទ្ធសំ មហាភដេ បតិតំ សុវះទោតកាំ ដូច្នេះជាដើម អធិប្បាយថា បពិត្រមហារាជ!, ក្នុងកាលថ្ងៃមួយ ខ្ញុំព្រះអង្គបានចូលទៅក្នុងព្រៃធំដោយនវកម្មទីមួយ ហើយបានឃើញនូវជនទាំងបីនាក់គឺសេកសោមមួយ ពស់នាគរាជមួយ មនុស្សម្នាក់ ធ្លាក់ក្នុងអណ្ដូងធំមានជម្រៅហុកសិបហត្ថ ជនទាំងបីនាក់នោះកំពុងបានទុក្ខវេទនាជាទម្ងន់, ខ្ញុំព្រះអង្គមានសេចក្ដីករុណាអាណិតពន់ពេកក៏បានកាត់វល្លិ៍ធ្វើជាសង្រែកដាក់តញ្ញើសំយុងចុះទៅក្នុងអណ្ដូង យោងយកជនទាំងបីនាក់ស្រង់ឡើងពីអណ្ដូងនោះបាន លើកមកដាក់ទៀបមាត់អណ្ដូង ហើយជនទាំងបីនាក់ក៏មានសេចក្ដីសោមនស្សត្រេកអរ ព្រោះបានរួចពីមរណៈបាននិយាយប្ដេជ្ញានឹងខ្ញុំព្រះអង្គថា យើងទាំងឡាយមានជីវិតរស់នៅព្រោះតែសំឡាញ់បានឲ្យជីវិតដល់យើង គឺសំឡាញ់មានគុណឧបការៈដល់យើងច្រើនពន់ពេកថ្លឹងថ្លែងពុំបានឡើយ. ហើយជនទាំងបីនាក់បានផ្ដាំនឹងខ្ញុំព្រះអង្គថា បើសំឡាញ់មានការក្រង៉ាយទូលាយចង្អៀតដូចម្ដេចក្ដី ត្រូវសំឡាញ់ចូលទៅកាន់សំណាក់យើងចុះ ឯទូលព្រះបង្គំជាខ្ញុំ, កាលបើជនទាំង ៣ នាក់បានពោលផ្ដាំដូច្នេះហើយ លុះដល់មកកាលជាខាងក្រោយ ខ្ញុំព្រះអង្គមានប្រាថ្នាចង់ល្បងមើលជនទាំង ៣ នាក់នោះ ។

(នៅមានត)

# មហោសថជាតក

(តមក)

លោកអ៊ឹម-ភន ចម្លងពីសាស្ត្រស្លឹករឹត ព្រះពុទ្ធវង្ស កឹម-ធួរ ពិនិត្យ

---

ម្ល៉ោះហើយ ទើបសិរីវឌ្ឍកសេដ្ឋីនោះ អ្នកតែងឲ្យធ្វើនូវសារពើការស៊ើ ជាមង្គលដំកល់សណ្ឋិតនៅចៅមហោសថរួចហើយ ទើបសិរីវឌ្ឍកសេដ្ឋីនោះ ឲ្យជ្រើសរើសយកនូវកូនមេទំផង់ទាំងឡាយបាន៦៤នាក់ តែងឲ្យបំបៅបំពេញពោធិសត្វនោះ រៀងរាបដកបទៅហោង ៗ

ពោធិសត្វចំរើនអាយុធំឡើងបាន៧ឆ្នាំ ឲ្យទៅនាំអស់កូនផងទាំងមួយពាន់ដាក់ណាន់សម្រាប់ឲ្យបំរើពោធិសត្វ ៗ រីពោធិសត្វនោះសោត អ្នកតែងលេងនូវល្បែងផង មួយអន្ទើទីនឹងអស់កូនទាំងមួយពាន់នោះឯង ជាប្រក្រតីសព្វថ្ងៃហោង ៗ រីពោធិសត្វនោះ សឹងជំមានព្រះអង្គនោះល្អប្រពៃពីដូចមាសឆ្អិន គឺអ្នកឲ្យដីថ្មីប្រពៃប្រសើរហោង ពោធិសត្វអ្នកដើរទៅលេងមួយអន្ទើទីនឹងអស់កូនផងទាំងឡាយ ឮដល់កណ្ដាលស្រុកនោះឯង ៗ កាលនោះ មានដីស្រុកមួយ ពាមកៈបាបកេចបុកថៃនសាលាបាន ល្បែងអ្នកតែងលេងនោះ លុះដល់បាក់បែកអស់ទៅហើយ ម្ល៉ោះហើយ កូនទាំងឡាយនោះ សឹងនឿយព្រួយលំបាក ហេតុតែត្រូវភ្លៀងខ្យល់ អំពល់នូវកំដៅព្រះអាទិត្យ កើតត្រូវអាត្មាទីទៃៗនោះហោង ៗ

បពិត្រអើយ ឮដីកាលនោះ មានសម័យថ្ងៃ១នោះគូរ ពោធិសត្វ

អ្នកលីលា ដើរទៅលេងទូរល្បែងមួយអន្លើនឹងអស់ក្មេងផងទាំងមួយពាន់ នោះក្រូវមហាមេឃឯងជាលស្រឡប់នឹងតបង្អុរភ្លៀងធ្លាក់ចុះមកពីកណ្ដាល អាកាសពាសទាំងកំឡុងមហាប្រថពី ។ ក្មេងទាំងមួយពាន់នោះ សឹងបបួលគ្នារត់ទៅកម្ងប់គ្រប់ក្បាលគ្នាទៃ ៗ ហោង ។ ព្រះមហាសត្វ អ្នកមានកំឡាំងខ្លាំងមហិមា បីដូចដំរីសារ អ្នករមិលមើលភ្លៀងនោះហើយ អ្នករត់ចូលទៅកាន់ឋានសាលាមួយ ។ អស់ក្មេងឯទាំងឡាយដទៃនោះ សឹងរត់តាមទៅដោយក្រោយនៃពោធិសត្វនោះវិញ សឹងជិមានខ្លួននោះនឿយព្រួយលំបាកណាស់ ដោយដីអិលជើងទីងជាន់ពុំជាប់ក្រឡាប់ដួលត្រូវចុះ ជង្គង់រលាត់មាត់ដូចជាគេខាំដី គេសីជាប់ទឹងភក់ប្រវាមម្នាម្នាងើបងោះឡើង រត់ទៅដួលចុះវិញទៀត ដូចគេប្របៀតជ្រៀតលើគ្នាទៅវិញទៅមក ទីងរកឲ្យចំនេរដល់ម្នាក់នោះគ្មានឡើយ ។

ពោធិសត្តោ ឥមស្មឹ ឋានេ តីឡូនសាលំ កាតុំវដ្ដតិ ឯវំ ច កិលមិស្សាមាតិ ចិន្តេត្វា តេ ទារកេអាហ ឥមស្មឹ ឋានេ សីតេន ច វស្សេន ច អាតបេន ច កិលមិស្សាម ឋានំ និសជ្ជនសយនក្ខមំ ឯកំ សាលំការេស្សាម ឯកេកំ កហាបណំ អាហរថាតិ ។

បពិត្រអើយ ក្នុងកាលនោះ ព្រះពោធិសត្វមហាបុរសរតនវិសេសអ្នកទ្រង់ព្រះចិន្តាពិចារណាថា អស់យើងទាំងអម្បាលនេះ សឹងជិមាន

អាត្មានោះព្រួយលំបាកណាស់ពេកក្តាត់ហៈទូ.ពុំកាលនោះត្រូវខ្យល់ព្យុះ
ផ្ទះភ្លៀងធ្លាក់ចុះមកអំពីកណ្តាលអាកាសក្តី សូម្បីកំដៅព្រះអាទិត្យចែង
ចាំងមកក្តី ក៏កើតលំបាកពេកក្តាត់ហៈ អាត្មាគិតទៅហើយ គួរគប្បីអញ
នឹងឲ្យធ្វើសាលាល្វែងតែងលេងនៅក្នុងវិហារនេះបន្តិចក៏បានអេះ , ពោធិ
សត្វអ្នកគិតនូវប្រការអម្បាលនោះហើយ ទើបអ្នកបបួលអស់គ្រួសផងទាំង
ឡាយថា អ្នកទាំងឡាយអើយ ! ចូលអ្នកទាំងឡាយទៅយកនូវមាស
ធ្មិនខ្មួនទាំងឡាយសព្វគ្រប់ៗ យើងនឹងជួលជាងឲ្យធ្វើសាលានៅវិហារ
នេះបាន ១ ប្រយោជន៍ដើម្បីនឹងជាបន្ទប់ល្វែង យើងអង្គុយដេកចេញ
ចូលនៅវិហារនេះឯង ក្រែងភ្លាចភ្លៀងធ្លាក់ព្យុះខ្យល់អំពាល់នូវកំដៅព្រះ
អាទិត្យជាគមកបៀតបៀនអាត្មា ឲ្យលំបាកក្នុងវិហារនេះហោង ។ រីអស់
គ្រួសផងទាំងឡាយនោះ ស្តាប់ពាក្យពោធិសត្វហើយ សឹងចូលចិត្តព្រម
យកនូវមាសមកឲ្យព្រះមហាសត្វ ដូចអ្នកបង្គាប់ប្រាប់គ្នានោះហោង ។

មហាសត្តោ មហាវិត្ថតំ បញ្ញាសាបេត្វា តាត
ធមស្មឹ ឋានេ សាលំ ការាបេតិ តស្ស សមាសន្ន
អនាសិ ។ ទើបពោធិសត្វអ្នកឲ្យទៅហៅគេអស់ជាងឈើ សឹងបេះធ្វើ
នូវការផងទាំងពួងមកជល់ៈហើយ ទើបអ្នកបន្ទូលថា ម្នាលជាងទាំងឡាយ
អើយ! ចូរអ្នកទាំងឡាយធ្វើនូវសាលាជាឋានពំនាក់ឲ្យយើងនៅក្នុងវិហារ
នេះ ហើយយើងនឹងឲ្យមាសធ្មិនមួយពាន់ជំឡឹងដល់អ្នកឯង រីជាងនោះ

សោត ទទួលយកពាក្យពោធិសត្វស្រេចហើយថា សាធុៗគាប់ហោង
ទើបជាងនោះទទួលយកមាសនោះ ជាងទាំងនោះគិតដឹកជញ្ជូកបូកចាំង
ក្ដីនោះឲ្យពេចពាបស្មើល្អ ទើបទូនដៃកន្ទ្រៃខ្សែបន្ទាត់បោះឈើខ្នាត ដឹក
រណ្ដាក់សសរបញ្ឈរលើកឡើងក្ដី ៗ ពោធិសត្វអ្នកទតមិលមើលទៅ
យល់អស់ជាងនោះ មិនចេះទូនខ្សែបន្ទាត់នោះឡើយ ពោធិសត្វបន្ទូលថា
តាត ម្នាលជាងអើយ ! ចូរព្រះស្ដេចទូនខ្សែបន្ទាត់ឲ្យត្រង់ កុំបី
ប្រហែសឡើយ ៗ ជាងឆ្លើយថា សាមិ បពិត្រអម្ចាស់អើយ ! រីអស់
យើងខ្ញុំនេះ ទឹងចេះទូនខ្សែបន្ទាត់ឲ្យស្មាត់ប្រពៃក្រៃលែងនេះ ពុំបាន
ឡើយ សព្វពេលជាយទូវចេះតែម្ទុំះឯងអម្ចាស់ ទើបពោធិសត្វអ្នកបន្ទូលវិញ
ថា ហៃជាងអើយ ! ថាបើព្រះស្ដេច មិនដឹងប្រមាណក្រៃលែងនេះហើយ
តើព្រះស្ដេចនឹងយកម្រេញនៃយើងទាំងអម្បាលនេះធ្វើបែង កព្រះស្ដេចនឹង
ធ្វើសាលានោះតើម្ដេចហ្នឹង ថាបើដូច្នោះ ក៏ចូរព្រះស្ដេចឲ្យយកទូវខ្សែ
បន្ទាត់នោះមកឲ្យអញ ៗ នឹងទូនគម្រង់ឲ្យព្រះស្ដេចបង្ហិចលងមើល ៗ ទើប
ពោធិសត្វមហាបុរសរតន៍ អ្នកឲ្យយកទូវខ្សែបន្ទាត់នោះមក ហើយ
ទើបអ្នកទូនគម្រង់ដោយទូវប្រាជ្ញាចិត្តវិសេសថ្លៃនៃអ្នកឯងហោង រីខ្សែ
បន្ទាត់នោះសោត សឹងត្រង់ល្អស្មើ តើនឹងឧបមាបីដូចអ្វី ថាឧបមា
បីដូចខ្សែបន្ទាត់ គឺព្រះពិស្ណុការ មកទូនគម្រង់ឲ្យឯងហោង ៗ
លំដាប់នោះ ព្រះមហាសត្វអ្នកបន្ទូលទៅនឹងអស់ជាងផងថា ម្នាលជាង

អើយ! ចូរព្រះស្ដេចឯងខ្លួនទូរខ្សែបន្ទាត់នេះដូច្នេះឯង តើបានឬទេ? ទើបអស់ជាងឆ្លើយថា សាមិ បពិត្រអម្ចាស់ អស់យើងខ្ញុំទាំងនេះ មិនខ្លួនពុំបានម៉្លោះហើយ ទើបព្រះមហាសត្វអ្នកបន្ទូលវិញទៀតថា បើដូច្នេះ ចូរព្រះស្ដេចឯងអាចទទួលយកបង្គាប់ធ្វើដោយខ្លួនពិចារណានៃអញនេះឯង រីអស់ជាងទាំងឡាយឆ្លើយវិញថា បពិត្រអម្ចាស់អើយ ! ថាបើដូច្នេះ យើងខ្ញុំអាចធ្វើតាមដោយខ្លួនបង្គាប់អម្ចាស់ហោង, ៗ ទើបពោធិសត្វមហាបុរសកែវ ទ្រង់ព្រះចិន្តាពិចារណាថា រីឋានសាលានេះគប្បីធ្វើដូច្នេះៗ, រីឋានសាលា ១ នោះអ្នកបង្គាប់ឲ្យជាងផងប្រដាប់ធ្វើជាលំៈនៅអស់ឈ្មួញផងមកអំពីចម្ងាយហើយតែងឲ្យចតឈប់សម្រាន្តនៅឋានសាលានោះ អ្នកឲ្យប្រដាប់សម្រាប់ជាលំនៅនៃអស់ស្រមណ៍ព្រាហ្មណាចារ្យទើបមកដល់ថ្មី រីសាលា ១ នោះសោតអ្នកឲ្យប្រដាប់ទុកជាឋានលំនៅអ្នកកំសត់ទុគ៌តទូវស្រីមានគភ៌ផងតែងឲ្យមកប្រសូតកូននៅក្នុងឋាននោះហោង; រីសាលា ១ នោះ សោតអ្នកឲ្យប្រដាប់ស-ម្រាប់ទុកជាឋានតែងពិភាក្សាពិចារណា នូវអាថ៌សេចក្ដីនៃអ្នកផងទាំងឡាយ រីឋានបរមសាលាធំ ១ នោះ អ្នកឲ្យប្រដាប់សម្រាប់ទុកជាឋានល្បែងនៃអស់គ្រួផងទាំងឡាយនោះ មានក្នុងកណ្ដាលសាលាផងទាំងពួងនោះហោង ៗ រីអស់សាលាផងនោះសោត សឹងប្រដាប់ជុំវិញនៃឋានសាលាគ្រឡាល្បែងធំនោះឯង ហើយ សឹងប្រឈមប្រែមុខចេញទៅក្រៅទាំងអស់ធ្វើរួចស្រេចបរិបូណ៌បានតាំបីថ្ងៃ ហើយ ទើបអ្នកឲ្យហៅនូវអស់ជាងនោះចេះគ្រូ

ក្បាច់របនាផងទាំងពួងមកដល់ហើយ ទើបពោធិសត្វទ្រង់ព្រះចិន្តាពិចារណាដោយនូវព្រះប្រាជ្ញាអធ្យាស្រ័យនៃព្រះអង្គឯងហោង ទើបអ្នកឲ្យឈ្នួលអស់ជាងគំនូរស្រេចហើយអ្នកបន្ទូលបង្គាប់ថា តាត ម្នាលជាងគំនូរអើយ! ចូរព្រះវិស្ណុឯងគិតគូរនូវគំនូរនោះ ឲ្យល្អពិចិត្របនាជាភាពទេវតាភាពគ្រុឌ ភាពនាគ, នូវមហាសមុទ្ទ នូវមច្ឆាកញ្ឆូរ,មករ,ពិន្ទង, នូវសារពើសត្វម្រឹគ,បក្សី,កិន្នរី,កិន្នរ, យក្សា,ពិទ្យាធរផង មាននៅព្រំប្រទេសព្រៃខ្ទមព្រះហិមពាន្តផង ឲ្យស្រណុកគាប់ចិត្តបីដូចធម្មសភាសាលា នៃទេវតាមាននៅព្រំនាពិភពត្រៃត្រឹង្សសួគិនាយ ។

លំដាប់ពីនោះទៅសោត រីពោធិសត្វអ្នកគិតថា មិនគួរធ្វើតែប៉ុណ្ណោះទេ ។ គួរអញជួលជាងឲ្យធ្វើនូវស្រះបោក្ខរណី ឲ្យល្អប្រពៃពន្លឺហានខេះកូវគាប់ហោង ម្ល៉ោះហើយទើបពោធិសត្វអ្នកឲ្យហៅនូវជាងផងមកហើយអ្នកឲ្យឈ្នួលជាងស្រេច ទើបអ្នកពិចារណាបង្គាប់ជាងថា ចូរព្រះវិស្ណុជីកធ្វើស្រះនេះឲ្យមានមុមវៀចវង់ មានជ្រុងជាសារពើស្បូត្រនោះមួយពាន់ ហើយឲ្យមានកំពង់ពបតែងឡើងចុះនោះមួយពាន់អន្ទើ ហើយអ្នកឲ្យដាំនូទៅនូវឈូកសឈូកប្រាល នូវព្រលិតកុម្មុទ ឧត្បល ទាំង៥ពណ៌ ដ៏មានផ្កានោះរីកល្អប្រពៃពេក ៗ រីជាងផងប្រដាប់ធ្វើស្រះនោះល្អបីដូចនន្ទបោក្ខរណី មាននៅនាសួគ៌ទេវលោកឆាយនោះហោង ហើយអ្នកឲ្យដាំនូវពពួកឈើផងទាំងឡាយល្អរុងរឿងដ៏មានពណ៌នោះផ្សេងៗ ហើយទ្រង់

នីះទៅនូវផ្លែផ្កា ដ៏មានក្លិនះនោះពិដោរឈ្ងុយឈ្ងប់ត្រឡប់ប្រពៃនៅឮដំខ្មែរ ស្រះនោះឯងហោង ហើយអ្នកឲ្យប្រដាប់នូវចង្ក្រានបាននោះសឹងដ៏យល់ប្រពៃហោលទីងនូវចេចង្ក្រានមាននៅឧបានស្ថិតទេវលោកនាយហោង ហើយអ្នកឲ្យប្រដាប់នូវគ្រែពេងទានដល់សមណព្រាហ្មណាចារ្យ នូវអ្នកបេះធម៌ករថ៌ព្រះបាលី នូវអ្នកទើបមកដល់ថ្មី នូវអ្នកចេញទៅព្រៃផងទាំងឡាយផងដើមសឹងឲ្យអាស្រ័យចតសម្រាន្តនៅឰដ៏ឋានបរមេសាលានោះឯងៗ បពិត្រអើយអែតើអស់ទាំងនេះសឹងកើតប្រាកដ ហេតុប្រាជ្ញាបារមីនៃពោធិសត្វនោះហោងៗ បពិត្រអើយ ឮដ៏កាលនោះ រមនុស្សម្នាមហាជនផងទាំងឡាយណាៗក្តី សឹងចូលមកអាស្រ័យពំនាក់ទីនមហាសត្វនោះសព្វថ្ងៃជាប្រក្រតីទៅហោងៗ ព្រះមហាសត្វនោះសោត អ្នកតែងមកអង្គុយនៅសាលានោះ សឹងតែបង្គាប់នូវសេចក្តីកិច្ចកលប្រការសារពើអ្វីៗ បរិបូណ៌ពុំបរិបូណ៌នូវអ៊ះតើជាហេតុអគ្គិពុំជាហេតុជាគួរពុំគួរនោះក្ត សឹងកើតជាពំនាក់នៃអស់មហាជនផងទាំងឡាយនោះហើយ ក៏សឹងកើតជាអស្ចារ្យ អ្នកផងដំកល់ទុកក្នុងចិត្តទៃៗគិតតពាណរណាថា មហាសត្វថ្ងៃនេះដូចកំណើតព្រះពុទ្ធអង្គឯងមកកើត បានត្រាស់ទេសនាប្រោសសត្វហោង ៗ

វិធេហាកជាបឋ សត្តវស្សច្ចយេន បត្តោភេ បណ្ឌិតា អម្ហ អភិករិត្វា បញ្ញោ បណ្ឌិតោ ឧប្បជ្ជិស្សតីតិ មេ តាថយីសុ តាត្វេសោ ឋិតរហីតិ សរិត្វា តស្ស វសន-

ដ្ឋានំ ជានជាតិ ចតូហិ ទ្វារេហិ ចត្តារោ អមច្ចេ បេសេសិ ។ បពិត្រអើយ ក្នុងកាលនោះ ព្រះបាទវិទេហរាជ ស្តេចមានព្រះរាជហឫទ័យត្រូវពាក្យអ្នកប្រាជ្ញទាំង៤នោះហើយ ស្តេចទ្រង់ព្រះចិន្តាពិចារណារំពឹងជញ្ជឹងថា ឱ! កាលអ្នកអាចារ្យទាំង៤ស្រដីនឹងអញនេះថា នឹងមានអ្នកប្រាជ្ញមួយមកជាគំរប់៥ នឹងកើតមាន ហើយនឹងបានផ្ចាញ់ឲ្យអស់យសនៃអ្នកប្រាជ្ញអញទាំង៤នេះវិញ គឺឥឡូវនេះ តើអ្នកប្រាជ្ញនោះនៅឯណាទេះ ស្តេចទ្រង់ព្រះចិន្តារំពឹងស្រេចនូវប្រការអម្បាលនោះហើយ ទើបត្រាស់ប្រើរាជអមាត្យទាំង៤នាក់ ឲ្យចេញទៅដោយនូវទ្វារព្រះនគរទាំង៤នោះ ហើយស្តេចបន្ទូលផ្តាំថា ម្នាលអមាត្យទាំង៤អើយ ចូរអ្នកទាំងឡាយ ចេញទៅរកឋានលំនៅនៃអ្នកប្រាជ្ញនោះ ឲ្យដឹងជាក់ប្រាកដកុំលែងឡើយ ។ គ្រាណោះ រាជអមាត្យនោះក្រាបថ្វាយបង្គំប្រណម្យព្រះមហាក្សត្រាធិរាជ ដើរទៅរកឋានលំនៅនៃចៅអ្នកប្រាជ្ញដោយនូវទ្វារសំណាន់លេងនោះពុំយល់ចៅអ្នកប្រាជ្ញឡើយ ។ រាជអមាត្យមួយនោះ ដើរចេញទៅដោយនូវទ្វារព្រះនគរខាងឯកើតនោះ រមិលរមើលយល់ផណ្តើរបរមសាលានោះជាដើម ហើយរាជអមាត្យនោះមកគិតជញ្ជឹងរំពឹងក្នុងចិត្តថា របរមសាលានេះ មិនអន្លឹអ្នកល្ងង់ខ្លៅជួជាតិណាគិតធ្វើបានឡើយ របរមសាលានេះ សុភាពពិតគឺអ្នកបេះតំរិះមានប្រាជ្ញាច្រើន ទើបគិតពិចារណាធ្វើបរមសាលានេះបានដូច្នេះ តោះយោច

អ្នកធ្វើទីនេះតាំងឯងក្ដី ពោះបង្គាប់ប្រើឲ្យអ្នកដទៃធ្វើក្ដី នេះគួរគប្បីដំកល់ទុកអ្នកនោះថាជាអ្នកប្រាជ្ញបានហោង ។ ទើបរាជអមាត្យនោះ ដណ្ដឹងសួរទៅកាន់មហាជនផងទាំងឡាយនោះថា ម្នាលអ្នកទាំងឡាយអើយ ដោយយើងខ្ញុំបានយល់បានឮរៀនមកមិនដែលឃើញដូច្នេះ រីរមសាលានេះ តើគឺជាងឯណាគិតធ្វើល្អម្ល៉េះហ្ន៎? ។ ទើបអស់មហាជនផងទាំងឡាយនិយាយសំដែងថ្លែងប្រាប់ថា អ្នកអើយ! រីរមសាលានេះ មានជាងឯណានឹងបេះធ្វើនោះក៏ឥតអង្គិមានឡើយ, រីឯសាលានេះ គឺអ្នកជាងធ្វើតាមដោយនូវពិចារណាចំណេះប្រាជ្ញានៃចៅមហោសថបណ្ឌិតកុមារ អ្នកជាបុត្រនៃសិរីវឌ្ឍកសេដ្ឋីនោះឯងហោង គាត់គាត់តែងគិតធ្វើដោយនូវកំឡាំងប្រាជ្ញាគាត់នោះឯង ។ រីរាជអមាត្យស្ដាប់ពាក្យនោះហើយ ឆ្លើយវិញថា យើអ្នកអើយ រីអ្នកនោះតើមានអាយុប៉ុន្មានឆ្នាំហើយហ្នះអ្នក ? ។ ទើបអស់អ្នកផងទាំងឡាយប្រាប់ថា អ្នកអើយ ! រីអាយុចៅបណ្ឌិតអ្នកប្រាជ្ញនោះជាគំរប់៧ឆ្នាំហើយអម្ចាស់ ។ រីរាជអមាត្យនោះស្ដាប់ហើយ ទើបមកគិតគណនារាប់ឆ្នាំអំពីស្ដេចយល់សប្ដិនោះដួបគ្រប់ជា៧ឆ្នាំ ព្រមល្មមត្រូវនឹងអាយុពោធិសត្វនោះឯង ។ រីរាជអមាត្យនោះ បានដឹងដំណើរសព្វគ្រប់ដូច្នោះហើយ ក៏ជញ្ជឹងគិតថា អយមេវ សោ បណ្ឌិតោ អមាត្យនោះគិតថា រីអ្នកនេះឯងប្រាកដពិតជាអ្នកប្រាជ្ញមែនហោង កាលណា បើរាជអមាត្យនោះ គិតស្រេចនូវប្រការអម្បាលនោះហើយ ទើប

ប្រើរាជទូតចូលទៅទូលព្រះមហាក្សត្រនោះវិញថា ៖ បពិត្រមហារាជអើយ! រីសម្តេចមហារាជអម្ចាស់ត្រាស់ប្រើរាជអាមាត្យចេញទៅស្វែងរកហានលំនៅនៃចៅអ្នកប្រាជ្ញនោះ, ឥឡូវនេះ ដោយយើងខ្ញុំបានយល់បរម-សាលាថា មានអ្នកប្រាជ្ញមួយនោះ ឈ្មោះចៅមហោសថបណ្ឌិតកុមារ កើតមកអាយុបាន៧ឆ្នាំហើយ ក៏យល់ហាក់ព្រមល្មមនឹងអម្ចាស់ទ្រង់ព្រះសុបិននោះហោង កុមារនោះសោត ជាកូននៃសិរីវឌ្ឍកសេដ្ឋីប្ដីនាងសុមនទេវី នៅស្រុកបាចីនយវមជ្ឈគ្រាមនោះឯង, បពិត្រអម្ចាស់អើយ! រីចៅមហោសថអ្នកប្រាជ្ញនោះសោត អាចបង្គាប់ឲ្យធ្វើបរមសាលាមានសុភាពបង្គួរល្អប្រពៃប្រការដូច្នេះៗ ហើយលើកធ្វើជាស្រះស្រង់មង្គលឧទ្យានមានប្រការនោះផ្សេងៗ, បពិត្រអម្ចាស់អើយ ព្រះអង្គឲ្យទៅនាំយកចៅបណ្ឌិតអ្នកប្រាជ្ញនោះមក ឬអម្ចាស់កុំឲ្យទៅនាំយកនោះ ក៏តាមសព្វព្រះរាជហឫទ័យព្រះអង្គហោង ៚

រីព្រះមហាក្សត្រាធិរាជ ស្តេចស្តាប់ពាក្យនៃរាជទូតនោះហើយ មានព្រះហឫទ័យនោះត្រេកអរសោមនស្សមហិមាពេក ហើយមានព្រះបន្ទូលឲ្យទៅហៅនូវអាចារ្យសេនកៈនោះមកដល់ហើយ ទើបស្តេចប្រាប់នូវសេចក្តីដោយដំណើរពាក្យរាជទូតនោះ ហើយស្តេចបន្ទូលដណ្តឹងអាចារ្យសេនកៈវិញថា សេនក ហៃអាចារ្យសេនកៈអើយ បើដូច្នេះតើយើងនឹងឲ្យទៅនាំយកចៅបណ្ឌិតអ្នកប្រាជ្ញនោះមកឬ? ៚ (នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងមរណមាតា

(តមក)

លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត

រូបរាងល្អល្អះ ត្រចាំងត្រចះ ចរញ្ចងដួងភ័ក្ត្រ ដូចចន្ទ្របូណ៌មី ពីសីជាអគ្គ នារីគ្រប់លក្ខណ៍ គ្រប់គ្រងភាព ៗ ស្ដេចទតសព្វា ព្រះទ័យស្រែងស្រូប ព្រឺព្រើតកេមា ក្ដួចកើតកិសវង្ស ត្រេកត្រង់ធំតា ហើយត្រាស់ទៅថា វៃហៃនាងកុមារី ៗ ដើមឈើមាសពីរ នោះជានាងវៃថ ដាំទុកឬអ្វី នាងថាខ្ញុំដាំ ក្សត្រក្សាត្តស្ដួរទី ស្ដួរថាហេតុអ្វី នាងដាំទុកនោះ ៗ មានគុណឧបការ ហេតុម្ដេចធីតា នាងប្រាប់ឲ្យស្មោះ នាងគប់ទូលក្ករ ទូលថាឈើនោះ ម្ដាយខ្ញុំចិះពោះ ធ្លាក់ទឹកស្លាប់ទៅ ៗ ចាប់ជាតិជាត្រី សត្វត្រីតិរយ ចិត្តកាចៈឃោរឃៅ វាចាប់ពិឃាត ជនជាតិទៀតទៅ ទើបសល់តន់នៅ ស្រកាពីរនោះ ៗ ខ្ញុំដាំកើតជា ដើមគ្រប់ទ្វេហា សត្រូវមិត្តទ្រុស្ត វាផតទៅបុក គ្រលុកពោលចុះ សបើឫសពីនោះ ខ្ញុំដាំកើតជា ៗ ល្មួសមាសពីរ ដើមដុះនៅទី នោះខ្ញុំរក្សា ពុំបេរព្រះអង្គ ជ្រាបក្នុងចិត្តា ស្ដេចស្ដាប់កុមារិកា ទូលទៀតជាក់ស្ដែង ៗ យល់ថាអស្ចារ្យ អស់ចិត្តគ្រកាល គួរកោតគួរស្ញែង ទើបត្រាស់ថាកើ ដើមឈើនោះ

ឯង ល្អល្អះចាំពូន មុខគួរស្រឡាញ់ ៗ ហៃកុមារិកា ដើមឈើទ្វេហា ធានឲ្យមកអញ ធានស្តាប់ទុក្ខ៏ ជីតាំទូលវិញ បើម្ចាស់ស្រឡាញ់ ថ្វាយតាមព្រះទ័យ ៗ ទើបស្តេចប្រទាន មាសប្រាក់ធនធាន សំពត់អាវស្បៃ នូវគ្រឿងប្រដាប់ សម្រាប់ស្រីថ្មី ហើយទ្រង់ត្រាស់ថា បង្គាប់សេនា ៗ ឲ្យរកជ្រទីក រកចបមកជីក គាស់ដើមព្រឹក្សា អមាត្យប្រញាប់ ជីកគាប់មិនា គាស់ដើមព្រឹក្សា មិនរួចឡើងសោះ ៗ តាំងពួកពាហាន ដែលហៃក្សត្រក្សត្រ ជួយព្រួតតាំងអស់ គាស់មិនកក្រើក គំរើកតិចសោះ ស្តេចទៅគណ្ឋអស់ អ្នកស្រុកសព្វហាន ៗ មនុស្សម្នាខ្មៅខ្មួល ច្រើនច្រុះជន្លួល ជួយលើកពុំបាន ម៉ាវមកគគុក ជួយបុករញ្ជ្រាន ខ្លះមើលខ្លួនប្រាណ សើចលេងជាល្បែង ៗ ខ្លះថាកាផ្អក ហុចឈើស្នែងមក ឲ្យអាឯង អញលើកតែអញ ពោលចេញស្លួយស្នែង ហើយលើកឈើស្នែង ដាក់ផ្ទប់ផ្ទាល់ក ៗ ប្រឹងលើកហាបហត់ ឈើស្នែងសង្កត់ ជួលស្រែកឡូ ៗ លោកអើយជួយផង ស្នែងជង់គាបក ដង្ហើមឃុះខ ស្រងល់ស្រងើ ៗ ខ្លះស្តីជៀលផាន ថាមើលតែពាន អួតឯងគ្រាន់បើ ទីងលើកតែឯង ស្លួយស្នែងទៅគើប្រទះលើឈើ ស្នែងកិនបត់ក ៗ ខ្លះស្តីឡាយឡក ចំអន់ចំអក ឲ្យគ្នារីករាយ ខ្លះថាអ្នកម៉ែ មើលហើយចំហ ម្ទោះតែអៀនឈារ កកែះក្រចក ៗ ខ្លះមានប្រាជ្ញា ស្រដីយាត់ថា កុំតាលលេងឡក រាំពាស់ជិហរ គាត់. ឈរមិនរេក ដង្ហើមរស់ដក ចុំណេះស្ទើរដៃ ៗ អមាត្យសេនា

យល់ហេតុអស្ចារ្យ សល់សែនសង្ស័យ នាំគ្នាទូលក្សត្រ ចក្រពត្តិ ដៀសជ័យ តាមហេតុសង្ស័យ សព្វគ្រប់ប្រការ ។ ជាការត្រាស់ប្រើ យើងខ្ញុំគាស់ឈើ តាំងពីស្រុវណ្ណ ពុំមានកំរើក របើករសោះសា តាមតែមេត្តា ទ្រង់ជ្រាបព្រះទ័យ ។ ស្ដេចស្ដាប់អមាត្យ ទូលព្រះភូវនាថ ព្រះទ័យសង្ស័យ យល់ហេតុអស្ចារ្យ ហោមហាធ្ងន់ក្រៃ បន្ទូលថាហៃ មរណាមាតា ។ អញឲ្យទៅកេណ្ឌ ពលពាលកប់សែន ព្រួតលើកព្រឹក្សា មិនមានកំរើក រលើករទៅណា គិតៈម្ដេចណា នាងលើករួចទេ ។ នាងស្ដាប់ឱង្ការ ត្រាស់សួរមាត្រា ទូលស្នងជូនថៃ ជាបើព្រះអង្គ ស្ដេចទ្រង់ប្រើប្រែ ពោះខ្សាយពូកែ ប្រកែកម្ដេចបាន ។ ស្ដេចត្រាស់ថាអើ បើនាងលើកឈើ នេះរួចដោយក្សាន្ត អញនឹងសងគុណ ស្រើតទំកល្យាណ ឲ្យពេញចិត្តស្មាន ស្មោះដូចប្រាថ្នា ។ អញនឹងអភិសេក លើកឡើងជាឯក ជាអគ្គជាយា នាងស្ដាប់បន្ទូល ទទួលក្រាបលា ដើរដល់ព្រឹក្សា រលួសមាសផ្ដៅ ។ ហើយនាងផ្គុំហត្ថាប្រណម្យ ចំពោះទិសទៅ ដល់គុណមាតា រក្សាបិតនៅ រលួសមាសផ្ដៅ ផ្គុំថៃថា ។ បពិត្រព្រះម៉ែ មានគុណស្និទ្ធស្នេហ៍ នៅដើមព្រឹក្សា បើបុណ្យខ្ញុំមាន នឹងបានឡើងជា ឯកអគ្គជាយា ប្រាកដមែនមាន ។ ខ្ញុំលូកហត្ថា ទៅពាល់កាលណា ឲ្យអំណ្ដែតបាន ចេញពីរណ្ដៅ ឡើងទៅដល់ឋាន អាកាសស្មោះស្មាន ដូចខ្ញុំសច្ចា ។ ផ្សង

ស្រេចហើយក្តាន់ ដើរទៅទៀតទាន់ រលួសសុវណ្ណ ហើយនាង
ប្រណម្យ បង្គំនមស្ការ ហើយធ្វើហាក់ជា នឹងដកលើកឡើង ៗ
គេផងពាក្យសត្យ កុមារីរូបរត្ន នឹងបានបុណ្យច្រើន រលួសអណ្តែត
ត្រសែតខ្ពស់ឡើង ភ្លឺផ្លេករុងរឿង កណ្តាលវេហាស៍ ៗ រីអស់
មន្ត្រី សេនាសេនីយ នៅអស់ប្រជា បានយល់ចំឡែក អនេក
អស្ចារ្យ សើងស្រែកឲ្យសា – ធុការអឺងកង ៗ ឯដើមព្រឹក្ស
តាំងគូនោះណា អណ្តែតត្រសង កណ្តាលអាកាស វេហាស៍
ឥតហ្មង លឿនលន់គន្ធង ទៅដល់ក្សត្រា ៗ ហើយឈប់និត្យ
នៅ ពុំលឿនទៀតទៅ លើអាកាសា ដូចអ្នកថ្កល់ទុក នៅមុខក្សត្រា
ស្តេចយល់អស្ចារ្យ ទ្រង់ព្រះអំណរ ៗ ឯកុមារិកា មរណមាតា
លាក្សត្របវរ នាងនឹងទៅឃ្វាល គោកាលមុនមក ហើយនាងនឹកកេក
ទេពទសទិសា ៗ នឹកគុណជននិ ផ្សងថាបើទី ជាហានមាតា
ឯកអគ្គក្សត្រី មែនឬទ្រព្យ ដែលព្រះពជា ប្រទានខ្ញុំនោះ ៗ
ឲ្យអណ្តែតជោយ អាកាសតាមក្រោយ តាមខ្ញុំចំពោះ នាងនឹកចិន្តា
សច្ចាដូច្នោះ អស់ទ្រព្យតាំងនោះ អណ្តែតតាមទៅ ៗ នាងដើរ
ដល់ទី រលួសជននី បិតបាននិត្យនៅ នោះនឹកជននី ទេវីហ្មងសៅ
ថាឲ្យកូននៅ ឥតមានទីពឹង ៗ ម្ល៉េះសមកូនស្លាត់ អ្នកម៉ែទៅបាត់
ឲ្យកូននៅនឹង នរណាកំដរ ស្រករគ្រាន់ពឹង គ្មានសោះកូននឹង

ធ្វើម្ដេចឥឡូវ ៗ ពីដើមបានម៉ែ បានមកស្និទ្ធស្នេហ៍ ស្និទ្ធស្នាល ខេះក្លៅ នេះគិតទុកតែង ការក្រែងសត្រូវ គ្រានេះឥឡូវ កូនពឹង នរណា ៗ នាងនឹកដូច្នោះ រំជួលក្នុងពោះ សែនសោកផ្សះផ្សា ផ្សាយផ្សព្វសល់សែន ចុកណែនទ្រូង រលឹកមាតា ស្រងូតស្រងាត់ ៗ ទល់ទុក្ខម្នាក់ឯង ដល់នេត្រហូរល្ហែង មិនស្បើយមិនបាត់ មុខគួរអនិច្ចា កុមារិការូបរ័ត្ន ស្ងប់ស្ងួតស្ងៀមស្ងាត់ ក្នុងព្រៃអដ្ឋា ៗ ស្ងួនទំរំសោយ ទុក្ខ សោកភាំងឡាយ ហើយយកគន្លា ស្រប់កក្រស្រីថ្ងៃ វិលវិលីលា គៀនះតាមូលគ្នា មិនឲ្យចង់បាត់ ៗ ហើយចូលកាច់ទស ក្នុងព្រៃ រះបាះ ឯកឯងស្ងប់ស្ងាត់ បានហើយចង់បាច់ ចង់ស្រេចវិលថ្លាត់ រគម្ទប់ឈប់បាត់ ស្បើយទុក្ខសោកា ៗ ឯអង្គព្រះបាទ វិមលនរ-ខាថ ប្រើរៀបសេនា សេនីយរួចថ្វាត់ ពាក្យត្រយាត្រា ផ្ដោះផ្កាន គាក ដល់ទាប់ពុំលង់ ៗ ឯដើមឈើមាស សាត់ដោយអាកាស គ្រប:គ្រចង់ តាមក្យក្រថ្កើងថ្កល់ លុះដល់បិតគ្រង់ ទីពំងពុំចង់ ពុំចុះ មកដី ៗ នៅលើអាកាស ភ្លឺផ្លេកផ្គុះផ្ទាស រុងរឿងរង្សី ឯ មនុស្សក្នុងពំង ពោះទាំងប្រុសស្រី ឃើញ:ហើយស្រដី សរសើរគ្រប់ គ្នា ៗ ថាអម្ចាស់យើង មានបុណ្យថ្កល់ថ្កើង នាំអស់យោធា ចេញទៅប្រពាត រុក្ខជាតិអត្ថា បានឃើញថ្ងៃហា សឹងមាសឆ្អិនឆ្អៅ ៗ សម្ដេចក្សត្រា យល់ឈើសុវណ្ណា ស្នេហ៍ស្និទ្ធនិត្យនៅ ត្រាស់ប្រើ

មន្ត្រី សេនីយ៍ឲ្យទៅ យកអាសនមាសផ្កា មករងព្រឹក្សា ។ ហើយឲ្យ
រៀបគ្រឿង បុប្ផារុងរឿង ទង់ឆត្រត្រៀបត្រា ភ្លេងផ្លូវដន្ត្រី ចំណី
អាហារ យកទៅព្រឹក្សា អញ្ជើញឲ្យចុះ ។ រីដើមព្រឹក្សា សុវណ្ណទេព្ហា
ឋិតនឹងនៅនោះ ទើបហៅចាស់ទុំ មកជុំច្រើនច្រុះ ក្បួនសួងចំពោះ អង្វរ
ទៅថា ៗ បពិត្រសុវណ្ណ ពជព្រឹក្សសោភ័ណ អញ្ជើញមកពី ឯព្រឹក្សា
នោះព្រះបុត្រក្សត្រា រីងព្រួយចិន្តា ព្រះទ័យតោកក្រៃ ៗ ហេតុបុណ្យ
សំណាង បុព្វនៃនាង កុមារីកាថ្លៃ ឲ្យកើតជាហេតុ កិច្ចៈការ
ឈ្មោះថៃ ទើបក្សត្រជៀសស្លន័យ ទឹកដល់ធីតា ៗ នាងថ្វាយឈើមក
ស្តេចឲ្យគាស់ដក ពុំរួចសោះសោ ទឹកការនាងផ្សង អង្វរសច្ចា
ទើបដកព្រឹក្សា បានរួចមកដល់ ៗ គិតហើយក្សត្រា ត្រាស់ប្រើអមច្ចា
អករ៍យាយខ្វាយខ្វល់ ឲ្យរៀបពាហន មូមាមកដល់ រៀបយាន
មណ្ឌល សុពណ៌ៈសរិកាយ ៗ ហើយមានខ្ពស់ក្តុំ ឆើតឆាយកំរម្យ ស្រីង្គារ
តាំងឡាយ អមាត្យរៀបចាប់ ប្រញាប់ខ្វល់ខ្វាយ រៀបៈភ្លេងតាំងឡាយ
តាំងប្រាំប្រការ ៗ ភ្លេងសៀមភ្លេងខ្មែរ ភ្លេងចិនជង្ហែ ភ្លេងមនលក្ខ
ឲ្យរៀបនាំទៅ ហំទៅធីតា ជង្ហែកុមារីកា ចូលមកថ្វាយក្សត្រ ៗ
រៀបគ្រូថគ្រឿងទៃហែ ព្រហ្មធ្មុំក្រៃ ផ្ទុំស័ង្ខស្រងាត់ សេនាពាហន
មីរមានច្រើនក្តាត់ កម្រង់ផ្ដោះកាត់ ត្រង់ផ្ទះកុដម្ពិក៍ ៗ មន្ត្រីលើក
ពល អស់ពួកអាកល បញ្ជប់សេនីយ ឆ្ងៀតណាកុចសុរិយា វេលា

រាត្រី បតជិតទាចី ចណ្ឌនិទ្រា ។ ឈប់ស្ងួនទុកទេ និទានទៅឯ
មណោមាតា នាងបរិបូណ៌បាន ប្រទានក្សត្រា មាសប្រាក់ទ្រព្យា
អនន្តអនេក ៗ ការស្បៃពត្ត្រា ហូលព្រែជា ១ ថ្ងៃ ១ យ៉ាងឯក
ទឹមទាត់ចរបោប ចំណាប់ល្អពេក នាងមានចិត្តត្រេក ត្រឹមត្រូវចិន្តា ៗ
នាងស្មៀកហើយផ្ទាស់ គន្ធបកញ្ចាស់ ចេញចាកកាយា លុះល្ងាចវិល
ទៅ លំនៅគន្ធា គៀងគោយាត្រា ដល់ក្រោលភប់រៀប ៗ
ហើយនាងរៀបផ្ទាស់ នាងស្មៀកកញ្ចាស់ យកថ្មីលាក់លៀប នាង
រៀបមាសប្រាក់ ទុកដាក់របៀប សព្វគ្រប់នាងរៀប ទៅបរិភោគ្គា ៗ
ឯមេគាលី ជាស្រីអប្រិយ ដេរពោលធីតា មិនដឹងដើមដាន នាង
មានវាសនា ស្តេចទ្រង់មេត្តា ប្រទានមាសប្រាក់ ៗ លុះព្រឹក្ស
សុរិយា ចន្ទ្រីសេនា យោធាអស់អ្នក អក់យោយស្រឹង្គារ បរិពារ
ភ្ញាក់ភ្ញាក់ លើកពលឆ្ពោះភក្ត្រ ត្រង់ផ្ទះធីតា ៗ វឯកាលី កុជ្ជិកតិរ្ច
បានឃើញសេនា ពួកពលទាហាន មិនមានគ្រៀបត្រា ឆាត់ជំក្រទា
ក្រតើនតើនតក់ ៗ ពាក់អាវក្រោះក្រាយ ក្បាច់ក្បូរផើតឆាយ ដាស
ដាំគញ្ចក់ ពាក់មួកត្រៃ ឆើសើរស្រក់ ក្រុមក្បាយក្ងឹកក្ងក់ ក្ដិតាំង
កាយា ៗ មើលឃើញប្រាកដ កិតភ័យខ្ទត់ ចុះពោលត្រឹហា
វត់រកព្រែពួន ញ័រខ្លួនមហិមា គិតថាក្សត្រា ឲ្យលើកមកចាប់ ៗ
ឯអស់ទាហាន ដើរដល់គ្រឹះឋាន ច្រើនប្រាំងតាន់តាប់ ក្រោយនោះ

គំរូតត្រាត្រួតប្រញាប់ ក្រោយទៀតបន្ទាប់ សុខសីងមន្ត្រីៗបន្ទាប់នោះនាង សំស្ងួនស្រីងស្រាន់ អក់យាយសារស្រី ហែហមចំនាំង ត្រែស័ន្ទគន្ត្រី លុះដល់អស់ស្រី ស្រីគ្គាអក់យាយ ៗ ចូលទៅជម្រាប ជីតាឲ្យជ្រាប ដ្បិតខ្សត្រគណ្ណកាប ប្រើយើងនាំយាន សុរិគន្ធសិវិកាយ នាំមកដល់ កាយ អញ្ជើញអ្នកម្ចាស់ ៗ ឡើងគង់លើយាន ហែនាំទៅឋាន គាល់ក្សត្រហ័ស ជីតាបានជ្រាប ដកបដាក់ច្បាស់ ហើយនាងទៅ ផ្លាស់ សំពត់ចាស់ចេញ ៗ ហើយនាងពាក់គ្រឿង ទិព្វទសរុងរឿង សុខសីងថ្មីវិញ ដែលមហាក្សត្រក្សាន្ត ប្រទានឲ្យនោះមិញ ហើយនាង ចរចេញ ចុះតាកត្រីហា · រឹងកុដុម្ពក ទីងមេកាលី នាងពុំបានលា ដ្បិត រត់ពួនបាត់ ទោលស្ងាត់ត្រីហា នាងចុះលីលា ឡើងគ្រែសិវិកាយ ៗ បើកបាំងក្ងស់ក្ង ត្រែសង្ខ័រងំ ភ្លេងភ្លាត់ពុទ្ធាយ ស្រីស្នំគ្រួមការ បរិពារ តាំងឡាយ អក់យាយប្រញាយ ហែហមចំនាំង ៗ មន្ត្រីសេនា ពហាន យោធា ហែហែហ៊ាព្ធខ្ញាំង ហែនាងទំមិល នាំដល់ក្រៅកំង បញ្ឈប់ ទុកតាំង ពួកពលពហាន ៗ មន្ត្រីឡើងទៅ ឡើងទូលព្រះចៅ ចក្រ ពត្តិក្សត្រក្សាន្ត ស្តេចជ្រាបត្រេកអរ សាទរត្រីប្រាណ ត្រីព្រួចបើក បាន បន្ទូលត្រាស់ថា ៗ ឲ្យចូលមកឆាប់ ហើយត្រាស់បង្គាប់ ដោយក្តីស្នេហា ខុនណាងពិក្ខុង រហង់ត្រៀបត្រា ទៅហែជីតា ចរចូល ទៅវៃ ៗ ហើយស្តេចចេញគង់ ចុងពេនភិម-ង្គលគាប់ប្រពៃ មន្ត្រីព្រះ

វង្ស ចតុរង្គក្រាស់ក្រៃ ស្រីឆ្គារសោរវៃដ គាល់ជុំត្រៀបត្រា ៗ ឯនាងទេវី
កុមារីពីសី មរណមាតា នាងចរចូលដល់ មណ្ឌលក្រឡា គំនាល់
ក្សត្រា នាងថ្វាយបង្គំ ៗ អក់យោយគាល់ហៅ នាំនាងចូលទៅ អង្គុយ
គួរសម ក្សត្រក្សត្រាទ្របានយល់ នាងដល់បង្គំ ស្ដេចទ្រង់ ព្រះគំ–ណរ
ណាស់ត្រាស់ទៅ ៗ ថាហៃកុមារិកា មរណមាតា ឈើងាសនិត្យះទៅ
បិតលើអាកាស វេហាសឆ្គិនឆ្ពៅ ជូរបោះនាងទៅ អញ្ជើញចុះមក ៗ
ត្រាស់ហើយមហាក្សត្រ បង្គាប់ទៅថ្វាត់ លើអស់យោយអក់
ឲ្យរៀបក័ស្គុការ កូផ្កាយកមក ដល់ហើយនាំយក ទៅជូនធីតា ៗ
រៀបគ្រឿងគ្រឿ ខុនណាងនារី ស្អិតស្អាងអាត្មា នាំនាងរលុំគួណ
មរណមាតា ទៅជើ្មរមស្សការ សុវណ្ណព្រឹក្ស ៗ ដើរដល់ព្រឹក្សា
មរណមាតា នាងទឹករលឹក ដល់គុណជននី នៅទីពដព្រឹក្ស ហើយ
នាងគិតទឹក ដល់ទេពទេសា ៗ នាងលើកករផ្គន់ ផ្គន់ផ្គុំគំបន់ ដាក់លើ
សិរសា អក់យោយបាស់ទុំ ប្រណម្យពល់គ្នា បន់ស្រន់សព្ទា សព្វ
អកាស ៗ សុវណ្ណព្រឹក្សា ទទួលវាចា ចុះដល់អាងមាស ដូចនាង
សព្ទា សេនាពញពាស មន្ត្រីទូរពស្រ្គ សូបស្សែងអស្ចារ្យ ៗ
ស្រេចហើយព្រះបាទ វិមលធម្មជា -តិវង្សក្សត្រា បង្គាប់មន្ត្រី គរ
ហោក ឲ្យកេពេលា មង្គលអភិសេក ៗ មរណមាតា ទេវីថ្ងៃថា
លើកឡើងជាឯក ជាអគ្គមហេសី ក្សត្រីអនេក ហើយឲ្យបាត់បែក

គ្រួតគ្រប់ភ្នាក់ងារ ៗ ឡើងកេជាគជ័យ ភូមិកពព្រៃពៃ សង់ប្រាង្គ សុវណ្ណ តែងជាមុខបួន ធំធួនសោភា មណ្ឌលមុខពហ៍ មុខដាច់ សរពើ ៗ មានកេនឹកយកាច កេងរម្យដកាច អស់ជាងបានធ្វើ កេងរៀប ចុងនៅ ឯក្រៅសរពើ ឡើតែងជាងធ្វើ ដំណាក់រយឯក ៗ សម្រាប់ ក្សត្រា រយឯកកជា ហើយឡើបាត់បែក សង់កេងប្រាំរយ ល្វែងឡើបំបែក បម្នាក់ល្អពេក ទទួលពាណិជ្ជ ៗ រឿណហ្វូងសេនា ទទួលទក្ការ វិលមក វិពេប តែងគ្រប់ភ្នាក់ងារ គ្រប់ការសម្រេច មានទាំងក្បូរក្បាច់ មណ្ឌប មុខបួន ៗ ស្រេចសង់ជាធ្នឹម កេងដូរតម្រឹម ប្រដាប់ធំធួន បិទមាសរទ្វាល ពព្រោលសមសួន សមសក្តិមាំមួន ល្អល្អះចែតឆាយ ៗ ឯប្រាង្គធំទោះ ក្បាច់ក្បូរសេព្តស្មុះ ដាំត្បូងពព្រោយ បិទមាសត្រចះ ល្អល្អះចែតឆាយ គ្រឹស្ទ-ល័គានឃ្វាយ ស្រួចស្រស់ខ្ពស់ខ្ពង់ ៗ កំពូលធំស្រួច កណ្ដាលត្រដួបកែវក៏ ធ្មឹងវរទ្វាលឆ្អិនឆ្អែ ដាំត្បូវកែវចុង បិទមាសរលង់ លើបះស៊ូរស្រក់ ៗ ជហ្វា ដងក្តារ មុខធាតមុខពហ៍ ក្បាច់ដាំកញ្ចក់ ហោជាងតាំងបួន សមសួនក្នុងក្នុក បិទមាសស្រិលស្រក់ ស្រិបស្រស់ស្មើ ៗ ជាសរពើសុត្រ ពីលើបង្ហ៊ូត បង្ហែដល់ដី ជាដើងកោសត្រូ ល្អះល្អពីសី ទ្រទ្រង់ប្រាំបី សឹងត្រុឌគន្ធូរវង្វេង ស្ដាំជណ្ដើរ ដាងឆ្ងាក់ឆ្ងៅធ្វើ សីង្ហគោឈានឈរ លាបព្រុយអងឯក ចម្លែក ល្អះល្អ មានក្បាច់ពេជ្រទ្រ ជើងផ្កាធ្វើងស្ដាំ ៗ ខ្វាងទ្វារតាំងបួន ធំខ្ពស់ មាំមួន រូបយក្សឈរចាំ មួយខាងក្រអើត ស្ដាំងស្មើគមួនមាំ ហាក់ស្ទុះមកទាំ

សម្បើមតិតភ័យ ៗ ហើយរៀបផើងផ្កា តាមថ្នល់មាគ៌ា ជាជួរប្រពៃ
ពីជណ្តើរប្រាង្គ សងខាងច្រើនក្រៃ ហើយឲ្យសែងដី គកូចសចាក់
ជះ ៗ មុខប្រាង្គធ្វើភ្នំ ខ្ពង់ខ្ពស់ធាធំ គ្រដួចស្រឡះ លាបថ្នាំសុទ្ធថ្ម
ទៀសជាក់ច្បាស់ កំពូលខ្ពស់ណាស់ ស្មើត្រីសូល៍ប្រាង្គ ៗ ធ្វើ
ជណ្តើរគាប់ ឡើងភ្នំសម្រេច សម្រាប់បែបយ៉ាង កំពូលភ្នំលើ ឲ្យ
ធ្វើជាប្រាង្គ មុខបួនស្អាតស្អាង បិទមាសរចនា ៗ ឯគុម្ពនោះ ដាំ
ឈើសឹងសេ់ ខ្លះផ្លែខ្លះផ្កា ទុំទុំច្រើនប្រុះ គ្រប់ៗសព្រឹក្សា ឲ្យសួន
សិតជា រូបម្រឹគបក្សី ៗ រមាសរមាំង ប្រើសក្រោយទីងទាំង គោ
សេះដំរី ទន្សាយទន្សោង ខ្លាខ្លាងក្របី សិង្ហគជសីហ៍ ជ្រូកក្តាន់
ប្រមា ៗ គ្រប់រូបសត្វម្រឹគ ច្រើនពេកពន្ទឹក រៀបរៀងត្រៀបត្រា
ដាក់ឲ្យឈរស្រប់ ក្រោមម្លប់ព្រឹក្សា ខ្លះធ្វើជល់គ្នា បែរបាលប្រឡែង ៗ
ឯចុងភ្នំឈ្លូង ជ្រោះជ្រោយធ្វើរូង រូងហើយជាននៃគង រូបពស់លូនល
លើកកជាក់ស្តែង មើលទៅគួរញ្ញើន ភ្ញាក់ព្រឺតតិតភ័យ ៗ ពស់វែក
ដំបូក ខ្លួនវែងធំស្លូក សុទ្ធសត្វវិស័យ ពស់វែករនាម លលាមលូនវៃ
ពស់កុកពស់ព្រៃ ពស់ថ្លាសទះឡាង ៗ ហើយយកចំប្រក រល្ងើប្រាក់
បាទមក ដាំដុះសំពោង មានផ្កាំងថ្មជា សាខាំរលោង ដើមភ្នំ
ជ្រោយឈ្មួង ដាំស្មៅស្មើផង ៗ ឯរូបបក្សា គោមទុំសារិកា
ប្រមង់អកក្ងួន ក្រួចក្រៀលពញ្ញាក់ សត្វពាក់កន្សែង ត្លូវែកក្រៀលង

គ្រលោងមាន់ព្រៃ ៗ រូបសត្វបក្សា ច្រើនឥតឧបមា អនេកក្រាស់ព្រៃ ធ្វើហាក់ផ្ទៀនផ្ទួន សាសនវិស័យ ទុំលើព្រឹក្សព្រៃ ចឹកចាប់ផលា ៗ ហើយជាន់យកឈើ ខ្ទឹមជាប់មកធ្វើ មកអារជាក្តារ បោះផ្តុំបួនជ្រុង ជិតស្លុងសោះសា បូកបិទធ្វើជា ស្រះប្រង់បោក្ខរណី ៗ ហើយសែនដីដាក់ ដងទឹកមកចាក់ ដាំឈូកប្រាលស សែនដាក់ដើង ក្ដុំ ដន្ទុំផ្កាស ហើយចាប់ត្រីមក ដាក់ស្រះនោះណា ៗ ហើយឲ្យលើកថ្នល់ ពីប្រាង្គមកដល់ ដើងភ្នំធំធារ ដើងផ្កាស្អាតស្អាង សងខាងមាគ៌ា សឹងឈើផ្លែផ្កា ស្គុះស្គាយប្រកិត ៗ ល្អល្អះអនេក គាក់តែងចំឡែក សប្បាយអស់ចិត្ត អស្ចារ្យត្រកាល ត្រកាលពេកពិត ដូចបានទុសិត ស្រុតមកបានអាយ ៗ ជាងសង់ជំណាក់ រយឯកចម្លាក់ ចម្លែកស្រុះសាយ មើលដហ្វា ដងក្តារកក្លាយ បិទមាសពព្រាយពព្រោងល្អល្អះ ៗ ខ្វាត់ខ្វែងទទឹង បណ្តាយត្រដឹង ត្រដែតប្រឡះខ្លោងទ្វារប្រការ ត្រៀបត្រាល្អល្អះ ខ្ពស់ធំស្រឡះ ស្រឡូងសប្បាយ ៗ ជញ្ជាំងរៀបឥដ្ឋ បាយអលាបជិត បង្អួចរៀងកាយ តែងកែវផ្កាលារយ៉ាព្រោងព្រាយ គោមកែវឆើតឆាយ កញ្ចក់ត្រៀងតាំង ៗ មានក្រុមភ្នាក់ងារ ច្រើនពលរក្សា ថែទាំរួសរាំង ជាអចិន្ត្រៃយ សព្វថ្ងៃរាំងរវាតមិនខ្ជាំង មិនគេចអាត្មា ៗ

(នៅមានត)

# អ្នកជម្ពូទីបរស់នៅប្លែកគេមែន

លោក គួច - គីឡេង រៀបរៀង

---

អ្នកជម្ពូទីបដែលថា រស់នៅប្លែកពីជនជាតិឯទៀតៗនោះ មិនមែនសំដៅយកការដកដង្ហើមចេញ-ចូល ខុសពីគេទេ, បានដល់សេចក្ដីប្រកាន់ សេចក្ដីប្រព្រឹត្ត ការស្ដាប់បង្គាប់គ្នាជាដើម ដូចរៀបរាប់តទៅនេះ :-

ការប្រតិបត្តិទ្វេធា: អ្នកជម្ពូទីបដែលខ្មែរយើងច្រើនតែហៅថា ឥណ្ឌៀនោះ មានជីពជនរស់នៅ ទំនងជាដូចជាខ្មែរយើងសុទ្ធសាធក៏បាន ទំនងជាខុសគ្នាស្រឡះក៏បាន ។ ទី១ដែលថា: ដូចគ្នា ត្រង់គេគោរពសីល ៥ ដូចពុទ្ធសាសនិកជនដែរ; ទី២ដែលថា ខុសគ្នា ត្រង់គេប្រកាន់វណ្ណៈខ្ពស់ទាប ទោះបីមិនមាំទាំដូចអតីតកាលក៏ដោយ ។

ត្រង់ទី១: អ្នកជម្ពូទីបបានជ្រើសយកពីគោលរបស់ព្រះពុទ្ធសាសនាទៅគោរពប្រតិបត្តិ ទុកដូចជាជីវសិក្ខាបទរាល់ថ្ងៃ (Principle of daily life) របស់គេ, ព្រោះគេជឿថា សិក្ខាបទរបស់ព្រះពុទ្ធសាសនានេះ ជាសិក្ខាបទ ដែលធ្វើជីវិតមនុស្សឲ្យមានឧត្តមភាពជាទីគាប់ចិត្ត ទោះបីខ្លួនគេមិនមែនជាអ្នកកាន់ព្រះពុទ្ធសាសនាក៏ដោយ ។ ដូច្នេះ ជនជាតិឥណ្ឌៀបង្ហាញសេចក្ដីបញ្ជាក់ឲ្យឃើញថា ការប្រតិបត្តិនេះ " មិនមែនជាជំនឿទេ " គឺជាសេចក្ដីយល់ឃើញច្បាស់តាមផ្លូវបញ្ញា

បើតាមគន្លងព្រះពុទ្ធសាសនាវិញថា· ជំនឿដែលប្រកបដោយសេចក្តីយល់ឃើញច្បាស់ គឺ «សទ្ធាប្រកបដោយបញ្ញា» ហៅថា «ជំនឿប្រកបទៅតាមគន្លងព្រះពុទ្ធសាសនា» ដែលព្រះសក្យមុនីគោតមបរមសម្មាសម្ពុទ្ធតែងទ្រង់ទេសនាសរសើរ ។

ត្រង់ន័យទី ២: អ្នកជម្ពូទ្វីបគេប្រកាន់តាមជើងគម្ពីររបស់គេ គេថាមិនមែនជាកំហុសរបស់គេទេ ព្រោះគម្ពីរ ( មនុស្សតិ ) របស់គេបានចែងទុកអំពីដើមមក ។ គេហាមដល់ទៅជជែកថា អ្នកស ល្អជាងអ្នកខ្មៅ, អ្នកក្រៅមិនគ្រាន់បើជាងអ្នកក្នុងប្រទេស, អ្នកមានទ្រព្យប្រសើរជាងអ្នកក្រ, អ្នកមានចំណេះវិជ្ជាជាទីគោរពជាងអ្នកល្ងង់ខ្លៅជាដើម ។ ការប្រកាន់នេះមិនមែនខុសទេ បើយើងសង្កេតឲ្យមែនទែនទៅ គឺគេគ្រាន់តែប្រកាន់តាមគោត្រត្រកូលខ្សែស្រឡាយប៉ុណ្ណោះ ។

**ការប្រតិបត្តិក្នុងផ្ទះ** នៅក្នុងតែផ្ទះ នៃជនជាតិអ្នកជម្ពូទ្វីបមានការប្រតិបត្តិល្អណាស់រវាងគ្រួសារគេ ។ គេមានសណ្តាប់ធ្នាប់របៀបរយដ៏ជាទីគាប់ចិត្តនៃជនគ្រប់រូប មិនថាជាតិគេ ឬអ្នកបរទេសទេ ។ កូនតែងគោរពប្រតិបត្តិមាតាបិតាជីដូនជីតា ដូចជាឧបាសក-ឧបាសិកាក្នុងប្រទេសយើងគោរពព្រះសង្ឃដែរ ។ រីឯមាតាបិតាជីដូនជីតា ក៏មានសង្គហធម៌តបទៅកូនចៅវិញដ៏ជាទីគាប់ចិត្ត ។ ទោះបីគេមិនជាពុទ្ធសាសនិកមែនទែន តែសង្គហធម៌ដែលគេផ្តល់ដល់គ្នានិងគ្នានោះ មិន

ខុសគ្នាប៉ុន្មានពីសង្គហធម៌ ដែលព្រះបរមគ្រូទ្រង់សំដែងទុកនៅក្នុងសិង្គាលោវាទសូត្រនោះទេ បងប្រុសស្រីស្រឡាញ់រាប់អានបងប្អូនតាមឋានៈដ៏សមគួរ, រីឯបងប្អូនវិញ ក៏គោរពបងប្រុសៗ មិនឲ្យមានការឃ្លៀសឃ្លាតចិត្តពីគ្នាឡើយ ។ សរុបដោយសង្ខេបទៅបានសេចក្តីថា ការរស់នៅក្នុងគ្រួសាររបស់អ្នកជម្ពូទ្វីបមួយៗ សុខស្រួលនឹងគ្នាណាស់ តាមឋានៈនៃគ្រួសារ ។ ការឈ្លោះទាស់ទែងគ្នាក្នុងគ្រួសារកម្រនឹងមានណាស់ ទំនងជាស្ទើរតែគ្មានក៏សឹងតែបាន ។ ជនជាសាធារណៈមានទាស់ទែងគ្នាដែរ តែតិចពេកណាស់, គេច្រើនមានអធ្យាស្រ័យដល់គ្នា ទោះបីជនជាតិឥណ្ឌាមានចំនួនមនុស្សដល់ទៅជិត៤០០លាននាក់ក៏ដោយ ។ តែសូមអ្នកអានជ្រាបថា "ការគោរពរបស់អ្នកជម្ពូទ្វីប មិនមែនគោរពឲ្យទាល់តែខូចតម្លៃរបស់មនុស្សទេ" គឺគេគោរពគ្នានៅក្នុងឋានៈខ្ពង់ខ្ពស់ដដែល ។ បើខ្ញុំផ្លាស់ពាក្យ "គោរព" ជាក់ពាក្យស្តាប់បង្គាប់វិញក៏បាន ។ ចំណែកអំពីការអនិច្ចកម្មទៅនៃបុគ្គលម្នាក់ៗ ក្នុងគ្រួសារ ជនជាតិឥណ្ឌាច្រើនតែមិនមានការឈ្លោះទាស់ទែងខ្វែងគំនិតពីការបែងទ្រព្យសម្បត្តិចែកគ្នាដែលទាល់តែនាំឲ្យមានកើតការក្តីក្តាំ ជារឿងរ៉ាវទៅសាលាតុលាការនោះទេ ។ មេគ្រួសារច្រើនតែទុកដាក់កូនចៅនឹងបែងចែកទ្រព្យសម្បត្តិទុកឲ្យហើយជាមុន, បើមិនបានធ្វើទុកជាមុនឲ្យហើយទេ គេច្រើនតែមានខតារទុកជាច្បាប់ហៅថា ច្បាប់សម្រាប់ប្រតិ-

បត្តិក្នុងគ្រួសារ (Law of succession of the family) ដែលបុគ្គលម្នាក់ត្រូវទទួលភារៈមើលការខុសត្រូវបន្ត បន្ទាប់ពីមរណភាពនៃមាតាបិតាទៅ ជាច្បាប់ដែលមិនទាន់កើតមាននៅឡើយក្នុងប្រទេសខ្មែរយើង, បើមានក៏នៅមិនទាន់គ្រប់គ្រាន់ដែរ ដោយអាស្រ័យហេតុដូចពោលមកនេះ បានជាសាលាតុលាការនៅឥណ្ឌា មិនសូវមានការរវល់នឹងរឿងក្តី. ដែលបណ្តាលមកអំពីគ្រួសារនេះពេកទេ ។ នេះជាឧត្តមគតិច្បាប់សំខាន់បំផុត គួរតែគ្រួសារខ្មែរយើង ទំពិចារណាឲ្យបានជ្រៅជ្រះបន្តិច ព្រោះដើម្បីជាសេចក្តីសុខ សេចក្តីចំរើនដល់គ្រួសារ ហើយដើម្បីនឹងជួយរំលែកសេចក្តីកង្វល់របស់តុលាការជាតិផង ។

សេចក្តីប្រតិបត្តិជាអារ្យធម៌ៈ- មានប្រពៃណីជាច្រើនថែមច្រើនយ៉ាង ដែលអ្នកជម្ពូទ្វីបជឿជាក់ដឹងជាក់ដោយបច្ចវេក្ខណញាណ ហើយប្រតិបត្តិទុកជាប្រពៃណីដ៏ល្អដូចពោលដោយសង្ខេបទៅនេះ:-

១ - ការស្លៀកពាក់ៈ ការស្លៀកពាក់នៅប្រទេសឥណ្ឌាមិនមានការប្រែប្រួលដូចនៅប្រទេសយើងទេ ; គេស្លៀកពាក់តែសំលៀកបំពាក់ជាប្រពៃណីរបស់គេរៀងពីដើមមក ទោះបីចក្រពត្រាធិរាជអង់គ្លេសគ្រប់គ្រងអស់កាលដ៏យូរឆ្នាំ តាំងពីឆ្នាំ១៧៧១មកដល់១៩៤៧ ដែលជាឱកាសមួយដ៏ប្រសើរបំផុត ដែលនាំឲ្យជនជាតិស្បែកសនាំមកនូវថ្នាំបំពុលដ៏ខ្លាំងក្លាគឺសំលៀកបំពាក់បែបថ្មីមកបំពុល គឺអ្នកជម្ពូទ្វីបមិនពុលទៅតាម

គេទេ , មានខ្លះដែរ តែតិចតួចពេកណាស់ ចំពោះតែពួកជនដែលបដិសេធអារ្យធម៌ វប្បធម៌ និងសាសនារបស់ខ្លួនពោលប៉ុណ្ណោះ ។ ការស្លៀកពាក់ជាបែបប្រពៃណីរបស់គេនេះ គឺទូទៅគ្រប់រូប មិនថាអ្នកមាន ឬអ្នកក្រ , នាម៉ឺនឬក្សត្រទេ ដូចជាជនជាតិភូមានិងចិនដែរ ។

ការស្លៀកដណ្ដប់នៅប្រទេសឥណ្ឌាផ្នែកខាងស្ត្រីមាន ២ ប្រការ គឺ: បែបសារី ១ បែបបញ្ចាបី ១ ។ ការស្លៀកពាក់បែបសារីនោះគឺគេយកផ្ទាំងសំពត់ប្រវែងបណ្ដោយប្រមាណជា ៦ ម៉ែត្រ ទទឹងប្រហែលប្រមាណជា១ម៉ែត្រ គន្លះមករុំពទ្ធជុំវិញខ្លួន ហើយបង់ទៅលើស្មាខាងឆ្វេងទំលាក់ទៅខាងក្រោយបោលចុងបន្តិច ដើម្បីឲ្យល្អមើលក្នុងពេលដើរទៅ ។ ឯការស្លៀកពាក់បែបបញ្ចាបីនោះ គឺមានខោ អាវ(ដៃខ្លីក៏បាន វែងក៏បាន) និងកន្សែងវែងបង់កព្ទុំបោលទៅខាងក្រោយ ។ បែបនេះមានសណ្ឋានច្រងំព្រោយ ដូចសំលៀកបំពាក់យួនអាវផាយ ។ ស្ទើរតែទាំងអស់គ្នា ស្រីៗស្លៀកពង្រីកត្រគាកឲ្យឃើញធំ និងដោះឲ្យឃើញស្រួច ៗ ចុង ព្រោះគេជឿថា បែបនេះជាលំអរបស់ស្ត្រី ។

ការស្លៀកពាក់របស់ប្រុសមាន ២ បែបដែរគឺ: សំពត់ចងក្បិនដូចខ្មែរយើង១, ខោជើងតូច១ ។ សំពត់ដែលគេយកទៅស្លៀកចងក្បិននោះ គេហៅថា ដោទី (Dhoti) ។ ពេលស្លៀកគេអាចយកជាយទាំងសងខាងលើកញាត់ទៅខាងក្រោយក៏បាន តែម្ខាងក៏បាន ។ ទាំងសងខាងដូច

ប្រធានាធិបតីស្លៀកសំពត់ថៃ តែម្ដង ដូចអនុប្រធានាធិបតីស្លៀកពាក់សំពត់ថៃ ឯបែបខោជើងវែងនោះគឺ ដូចជាបណ្ឌិតនេហរូនាយករដ្ឋមន្ត្រីស្លៀកសំពត់ថៃ ៗ ជនអ្នកជម្ពូទ្វីបទាំងប្រុសស្រី ចូលចិត្តស្លៀកពាក់ពណ៌ស ខៀវ ក្រហម លឿងណាស់ ឯពណ៌ខ្មៅពុំសូវមានទេ ៗ

ការអុតសក់របស់ស្រី ៗនៅជម្ពូទ្វីប គេមិនកប់ឥនទេ មានអ្នកអុតសក់ខ្លះដែរ តែតិចពេកណាស់ ៗ គេចូលចិត្តទុកសក់វែង ហើយក្រងជាកំប៉ោយពីរចម្លាក់ទៅខាងក្រោយ ៗ បើសក់ខ្លី គេយកសក់ក្លែងក្លាយទៅបន្តទៀត ល្មមតែធ្លាក់ទៅដល់កញ្ចុញគូថ ៗ ប្រុសៗចូលចិត្តទុកពុកមាត់ណាស់ ៗ

២-ការមិនប្រព្រឹត្តិអបាយមុខៈ ព្រះពុទ្ធដីកា ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ឃាត់មិនឲ្យប្រព្រឹត្តអបាយមុខ ៤ ប្រការនោះ បានឋិតនៅក្នុងសន្តានចិត្តនៃអ្នកជម្ពូទ្វីប ជាយូរឆ្នាំមកហើយ ៗ គេមិនបានអញ្ជើញអបាយមុខ៤ ឲ្យទៅរួបរួមក្នុងគ្រួសារគេផងទេ គេមិនចូលចិត្តផឹកសុរានឹងទឹកស្រវឹងណាមួយទេ សូម្បីតែបារី ក៏គេកប់ចូលក្នុងគ្រឿងស្រវឹងទាំងអស់ ម្ល៉ោះហើយបើគេឃើញលោកសង្ឃសាសនាណាមួយឆាន់បារីគេរិះគន់ណាស់ , បើដល់ៈទៅឆាន់សាច់ឈាមផងទៀត គេថាមិនមែនជាលោកសង្ឃទេ ៗ រឿងបារីនេះ បើប្រុសៗ មានទទួលទាន

ច្រើនដែរ តែស្រីៗក្រុមមាខណាស់ទីនីជាគ្មានសោះគឺសឹនតែបាន ព្រោះ ជាបើគេឃើញស្រីណាជក់បារីគេថា ស្រីនោះទីនីខាតដំណើរទៅអនាគត យ៉ាងធំ ៗ ពិសេសជាងនេះគឺការយល់ឃើញមាតាគេដូចមាតាឯង , ការទុកដាក់ប្រពន្ធគេដូចប្រពន្ធឯង, ទីឯការយល់ឃើញកូនក្រមុំគេដូចកូនក្រមុំខ្លួន រាប់ថាជាអំពើមួយដ៏ពិសិដ្ឋ ដែលអ្នកជម្ពូទ្វីបនៅតែប្រព្រឹត្តប្រតិបត្តិយ៉ាងតឹងរឹងរហូតមកដល់សព្វថ្ងៃនេះ ។

## តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# រឿងព្រេងសត្វក្ងានលោក(១)

លោក ថង-វង រៀបរៀង

---

សត្វក្ងូរលោកជាបក្សីម្យ៉ាង ស្រដៀងនឹងសត្វគ្រលីងគ្រលោង តែមានមាឌធំជាងសត្វគ្រលីងគ្រលោងបន្តិច, សម្បុរវាសក្រហមរទុះៗ ច្រើនអាស្រ័យនៅក្នុងព្រៃភ្នំ ឬព្រៃស្រោងស្រើន ។ សត្វនេះ ខ្មែរយើងបាននិយាយតៗមកថា មានដើមកំណើតមកពីមនុស្ស ដូចមានសេចក្តីដំណាលតទៅនេះ :-

កាលពីព្រេងនាយ មានកសិករពីរនាក់ប្តីប្រពន្ធ ជាមនុស្សក្រលំបាក មានកូនស្រីបីនាក់នៅតូចៗ ។ កូនទី ១ ចេះដងទឹកដាំបាយ, កូនទី ២ ចេះនាំប្អូនដើរលេង, កូនទី ៣ ចេះរត់លេង ។

ក្រោយមកប្តីស្លាប់ចោលទៅ ។ នាងប្រពន្ធនៅមេម៉ាយជាមួយនឹងកូនស្រីបីនាក់ តែងទៅកាប់អុសបេះបន្លែ ទូលទៅលក់ឯផ្សាររាល់ថ្ងៃ ។ ថ្ងៃមួយ នាងបានទៅជួបនឹងអ្នកលេងស៊ីផឹកម្នាក់ ដែលតែងតែដើរលួចឆក់អ្នកដំណើរឆ្ងាយជិត បានលុយកាក់យកមកស៊ីផឹកហ៊ុហា ៗ អ្នកលេងនោះ កាលបើក្រឡេកឃើញនាងៈហើយ ក៏សំដែងអាកប្បកិរិយាជាអ្នក

---

១- តាមសេចក្តីព្យាការណ៍អំពីចំណាស់ៗ នៅស្រុកជិតភ្នំខ្លះថា សត្វនេះ អ្នកខ្លះគេហៅថាសត្វ "ឈាលោក" ។

គូសេម សួរនាងថា ចុះនាងនៅភូមិណា? ឆ្ងាយឬជិត? ហេតុអ្វីក៏មិនឲ្យប្ដីជួយផែត ប្រឹងផ្ទុកទូលម្នាក់ឯងច្រើនម្ល៉េះ ។

នាងក៏ឆ្លើយប្រាប់ដោយត្រង់ថា ខ្ញុំជាស្រីមេម៉ាយ ប្ដីស្លាប់ហើយទៅ សព្វថ្ងៃក្រលំបាកណាស់ប្រឹងកាប់ទសរបេះបន្លែលក់ គ្រាន់បានប្រាក់បន្តិចបន្តួចយកទៅទិញអាហារចំណីឲ្យកូនស្រី៣នាក់បរិភោគ ។

ឮដូច្នោះ អ្នកលេងទឹកអរព្រួចក្នុងចិត្តគិតថា នាងនេះមេម៉ាយមែន ប៉ុន្តែមានរូបស្អាតគ្រាន់បើ គួរអញតាមទៅនិយាយដល់ផ្ទះយកជាប្រពន្ធឲ្យបាន ហើយក៏និយាយថា នាង! ខ្ញុំមានចិត្តអាណិតនាងណាស់ ខ្ញុំសុំជូន ១០ កហាបណៈសម្រាប់ទិញគីវ៉ាន់ផ្ញើកូន ។ នាងមេម៉ាយក៏ទទួលយកភ្លាម ដោយសេចក្ដីត្រេកអរ, លុះលក់ទសនិងបន្លែអស់ហើយ នាងត្រឡប់មកផ្ទះវិញ ។ ឯអ្នកលេងក៏លបដើរមកតាមក្រោយដើម្បីគន់មើលផ្ទះ លុះពេលព្រលប់ក៏ទៅជួបឯផ្ទះនាង និយាយគ្នាត្រូវមាត់កហើយ យកគ្នាជាប្ដីប្រពន្ធតទៅ ។

ចាប់តាំងពីថ្ងៃនោះមក អ្នកលេងតែងចេញទៅរកស៊ីលួចប្លន់អ្នកស្រុក ២-៣ ថ្ងៃមកផ្ទះម្ដងក៏មាន កន្លះខែ មកម្ដងក៏មាន ។ នាងនោះមានមាសប្រាក់ចាយវាយបរិបូណ៌ ស្លៀកពាក់សុទ្ធតែសំពត់ល្អ ។ ទៅជាធំចិត្តឡើងបាន ដើរលេងស៊ីផឹកជាមួយប្ដីនៅទីផ្សារ ភ្លេចគិតដល់កូនក៏សត់ទាំង ៣ នាំបណ្ដាលចិត្តឲ្យក្ដៅក្រហាយ ស្អប់កូនស្រីរបស់ខ្លួន

ឃើញមុខកូនពេលណា ចង់តែយកកាំបិតមកកាប់ឲ្យដាច់កទាំង ៣ នាក់ ពេលដាំស្លឆ្អិនហើយ នាំប្ដីបរិភោគតែពីរនាក់ ៗ សល់បាយក្ដាំងបន្តិចបន្តួច កូនទាំង ៣ នាំបងប្អូនកេះកាយស៊ី ខ្លះដេកលក់ក្បែរជើងក្រាន ខ្លះដេកលក់នៅល្វែងផ្ទះខាងក្រៅ មូសសុចខាំពុរពេញខ្លួន ៗ ពេលព្រឹកនាងនោះគាត់តែងខ្លួនប្រាណ ទៅស៊ីផឹកនៅឯផ្សារជាមួយប្ដីរាល់ថ្ងៃ ៗ

ថ្ងៃមួយ ប្ដីបាននិយាយរំលឹកថា បងមានសេចក្ដីអៀនខ្មាសចំពោះមិត្រភក្ដិខ្លាំងណាស់ ព្រោះប្អូនចេះតែតាមបងទៅស៊ីផឹកឯផ្សារ ដូច្នេះ បងសូមអង្វរចិត្តប្អូន សូមនៅផ្ទះថែទាំកូនស្រីទាំង៣នេះចុះ ៗ

ឮប្ដីនិយាយយ៉ាងនេះ នាងនោះគិតឃើញថា ប្ដីអញគាត់ហ៊ឺហាណាស់ ពួកស្រីខូចក្នុងផ្សារស្គាល់គាត់ទាំងអស់ បើអញបណ្ដោយគេទៅថ្ងៃមុខ គាត់នឹងបោះបង់ចោលអញពុំខាន ៗ គួរអញរកឧបាយសម្លាប់កូនស្រីទាំង៣នេះចោល កុំឲ្យគាត់មានពាក្យជាក់ដោតថា ឲ្យអញនៅចាំផ្ទះ ព្រោះតែកូននេះឡើយ ៗ

លុះដល់ខែពិសាខមានភ្លៀងធ្លាក់ជោកជាំ នាងនោះនិយាយបញ្ឆោតកូនថា កូនអើយ ! កាលឪពុកឯងរស់នៅ តែដល់រដូវនេះហើយ គាត់តែងនាំម្ដាយទៅសាបព្រោះស្រូវនៅត្រពាំងទឹកក្នុងព្រៃជិតជើងភ្នំ មានខ្ទមលំហាដេកចាំស្រូវ ស្អែកនេះ ម្ដាយនឹងយកស្រូវពូជទៅសាបព្រោះ ចូរ

កូនទៅដេកចាំចាបព្រាបលលក កុំឲ្យស៊ីស្រូវ ។ លុះព្រឹកឡើង នាងនោះនាំកូនចូលទៅក្នុងព្រៃហោហានជិតជើងភ្នំ យកស្រូវបាចសាចទៅក្នុងត្រពាំងរួចផ្តាំទាំងកូនថា នែហានកល់គ្នា! ត្រូវនៅចាំស្រូវ កុំទៅណាឆ្ងាយ កុំទៅផ្ទះ បើទៅអញវ៉ាយសម្លាប់ ផ្តាំហើយនាងនោះទុកបាយឲ្យ ១ចំអែតម្នាក់ អង្ករញាបាន ពោតបួនដប់គ្រាប់ កូនឆ្នាំងដី១ ទាំងអំបិលប្រហុកបន្តិចបន្តួច ហើយគិតថា យប់នេះ ខ្លាវ៉ាំនឹងមកខាំស៊ីពុំខាន បើមិនស្លាប់ដោយខ្លាស៊ី គឺគង់ស្លាប់ដោយអត់បាយ លុះផ្តាំកូនស្រេចហើយក៏ត្រឡប់មកផ្ទះវិញ ដេកចាំមើលផ្លូវប្តីមកពីរកស៊ី ។ លុះប្តីមកដល់ក៏សួរថា កូនស្រីទាំងពីរដើរទៅលេងឯណាពុំឃើញមកផ្ទះ ។ ប្រពន្ធប្រាប់ថា ខ្ញុំប្រើវាឲ្យទៅចាំស្រូវជាមួយតាសទុំជាច្រើន លុះស្រូវទុំទើបត្រឡប់មកវិញ ។

ចំណែកកុមារីទាំង ២ នាំបងប្អូនយកគ្រាប់ពោតទៅកប់តាមក្បែត្រពាំង ពេលយប់នាំគ្នាឡើងទៅដេកលើខ្ទម ។ ឮសូរតែមាត់ដំរីបបកស្រែកពេចច្រហឹមអឹងកងពេញព្រៃស្មសាន នាងបងលួងលោមប្អូនៗកុំឲ្យយំខ្លាចសត្វសាហាវទាំងនេះវាមកខាំសម្លាប់ នាងមានសេចក្តីភិតភ័យញ័រខ្លួនដូចកូនសត្វស្ទើរគ្មានព្រលឹងនៅក្នុងខ្លួន ។

គ្រានោះ អារក្សទេវតាដែលឋិតនៅក្នុងព្រៃស្មសានគិតថា នាងនេះហេតុអ្វីក៏យកកូនតូចៗមកព្រោះពោលក្នុងព្រៃដូច្នេះ បើអញមិនជួយកុមារ

ទាំង៣នេះផង មុខជាម្រឹគពាឡឃ្លង់ឃ្លួនស៊ីពុំខាន ហើយចុះ គួរសង្គ្រោះទៅចុះចម្រាំផុតពេលរាត្រីនេះ ទើបទៅក្រាបទូលសម្តេចឥន្ទ្រាធិរាជ ៗ គិតស្រេច អារក្ខទេវតាសំដែងឫទ្ធិស្រែកគម្រាមពួកសត្វសាហាវឲ្យរត់ខ្ចាត់ខ្ចាយទៅ លុះព្រឹកឡើងក៏ចូលទៅកាន់សំណាក់ទេវរាជឈ្មោះវរុណៈ នៅទិសឦសានដើម្បីឲ្យទេវរាជឈ្មោះវរុណៈនេះ នាំដំណើរទៅក្រាបទូលដល់ព្រះឥន្ទ្រាធិរាជ ៗ

វរុណៈទេវរាជរំពឹងឃើញថា ការនេះមិនចាំបាច់ទៅ ក្រាបទូលព្រះឥន្ទ្រាធិរាជទេ ព្រោះកុមារីទាំង៣នេះ ត្រូវក្លាយខ្លួនទៅជាសត្វបក្សី, ហើយបង្គាប់ថា ត្រូវអ្នកឯងជួយការពារកុមារីទាំង ៣ ឲ្យមត្យ័តកុំឲ្យសត្វសាហាវបៀតបៀនបាន ចំម្រាំវាក្លាយខ្លួនទៅជាសត្វ បើវាឃ្លានអាហារត្រូវនិម្មិតត្រីក្រឹមទន្លាយខ្យងខ្ចៅដាក់ក្នុងត្រពាំងមួយឲ្យវាស៊ីទៅ ៗ អារក្ខទេវតាក៏ត្រឡប់មកវិញធ្វើតាមបង្គាប់វរុណៈទេវរាជ ៗ

ឯកុមារីទាំង៣នៅចាំស្រូវបាន៣យប់៣ថ្ងៃក៏អស់អង្ករ ៣ ចានដែលម្ដាយទុកឲ្យស៊ី ប្អូនយំរកបាយស៊ី បងស្រីបានដើរទៅបេះស្លឹកថ្នឹងចុះទៅក្នុងថ្លុកក្ដិបត្រួយត្រកួននឹងដើមអំពៅជៀប យកមកចែកគ្នាស៊ី ប្អូនស្រីបង្អស់ក៏នៅតែស្រែកយំ ក៏នាំគ្នាចុះទៅចាប់ត្រីក្រឹមទន្លាយបានមួយយ៉ាងធំយកមកប្រុងដុតស៊ី តែភ្លើងដែលម្ដាយបង្កាត់ទុកឲ្យក៏រលត់អស់ទៅ នាំបងប្អូនរហែកស៊ីនៅបន្តិចម្នាក់ ៗ ប្អូនក៏បេះតែយកខ្ទុកកន្ទ្រញបង់ទៅផ្ទះ បងថាមិន

ហ៊ានទៅទេ ខ្លាចម៉ែវាយ លុះប្អូនតាំង២ស្រែកយំខ្លាំង បងក៏នាំមកផ្ទះ ។

ឯម្ដាយកាលបើឃើញកូនស្រីទាំងពីរបណ្ដើរគ្នាមកដូច្នោះ ក៏មួម៉ៅស្រែកដេរពីលើផ្ទះថា មីកូនចង្រៃ! អញថា យកវាទៅព្រោះចោលឲ្យស្លាប់ព្រាត់ប្រាសអស់ទៅ ឥឡូវមិនស្លាប់បែរជានាំគ្នាត្រឡប់មកវិញ អញវាយសម្លាប់ឥឡូវហើយ កុំឲ្យឃើញមុខមាត់ អញមិនឲ្យហ៊ានឡើងផ្ទះសំបែងទេ នាងបងអង្វរថា សូមអ្នកម្ដាយករុណាកូនចុះ ព្រោះប្អូនចេះតែយំឃ្លានបាយ អត់២.៣ថ្ងៃមកហើយ ស៊ីតែស្លឹកឈើជំនួសបាយ ក្អឹងក៏រលត់អស់ បើម៉ែមិនឲ្យនៅ កូនសុំតែអង្ករទឹងក្អឹងត្រឡប់ទៅវិញ សូមកុំធ្វើបាបកូន កូនសូមទោស ។

ឯកូនប្អូននិយាយប្រាប់ម្ដាយថា ម៉ែ! បងចាប់បានសាយស៊ីអែត ។

ម្ដាយឮកូនប្រាប់ថា ចាប់បានទន្សាយស៊ីឆ្អែត ក៏រឹតតែមួម៉ៅខ្លាំងណាស់ទៅទៀត ដេរបញ្ចោរថា មីកូនចង្រៃ! វាបានទន្សាយចែកគ្នាស៊ី ម្ដេចក៏មិនយកមកឲ្យអញស៊ីផង និយាយតែប៉ុណ្ណោះ ក៏ស្ទុះទៅវាយកូនទាំងពីរ ហើយដាក់ច្រំ បណ្ដេញឲ្យទៅព្រៃវិញ របស់អ្វីបន្តិចបន្តួចក៏មិនឲ្យសោះ ចំណាំឲ្យតែស្លាប់បាត់បង់ទៅតែប៉ុណ្ណោះ ។

មុខគួរឲ្យករុណាតដល់កុមារីទាំងពីរ ម្ដាយវាយដេញឈាមហូរស្រោក ក៏ទៅតែមិនបាត់វាចាថា ម៉ែៗ ឥតដឹងថា ម្ដាយប្រុងសម្លាប់ចោលសោះ ។ ឯកុមារីប្អូនទៅតែអួតប្រាប់ម្ដាយថា បានសាយស៊ីអែត សាយ

នោះគឺត្រីក្រឹមទន្សាយ នេះហេតុតែក្មេងតូចៗ ប្រហែលនឹងសត្តិរច្ឆាន ។

នាងបងប្រឹងអូសទាញប្អូនទាំងពីរនាក់ទៅ ដោយចេះគិតឃើញថា បើព្រាំនៅ មុខតែម្ដាយសម្លាប់មិនខាន ក៏នាំគ្នាទៅនៅក្នុងខ្ទមដែល ស្រាប់តែសន្ទប់បាត់ស្មារតីទាំង៣នាក់ដោយត្រាំត្រានឹងម្ដាយវាយសំពង ។

អារក្សទេវតា កាលបើឃើញដូច្នោះ ក៏យកទឹកមកប្រោះព្រំកុមារីទាំង ៣ ឲ្យមានស្មារតីឡើងវិញ ។

កុមារីទាំង៣នាក់លុះដឹងស្មារតីឡើងវិញហើយ ស្រែកទ្រហោយំទាំងអស់គ្នា ឯនាងបងក៏ចុះទៅចាប់ត្រីក្រឹមទន្សាយនឹងការគខ្យងខ្ទៅមកវាហែកបែកបងប្អូនស៊ីជំនួសបាយផងនិច្ចកល់ថ្ងៃ ត្រីនឹងខ្យងខ្ទៅចេះតែមានមិនអស់ ព្រោះទេពតានិម្មិតឲ្យ កាលណាថ្ងៃក្ដៅល្អ ស្រន់យកមកហាលថ្ងៃឲ្យតែក្រៀមៗ វាយចំបែកហែកបែកគ្នាស៊ីទៅ ។

នាងបងកៀកកប្អូននិយាយលួងលោមថា អូនអើយ! យើងទាំង៣នាក់នេះ ពុំបានជួបមុខម៉ែទៀតទេ ព្រោះគាត់មានប្ដីទៀត បានជាគាត់ស្អប់យើង ហើយរករឿងសម្លាប់យើងចោល យើងកុំសង្ឃឹមថា មានជីវិតរស់នៅតទៅថ្ងៃមុខទៀត ណាមួយសំពត់អាវមានតែមួយម្នាក់សំរាប់ស្លៀកដណ្ដប់ ឥឡូវដាច់ដាចអស់ទៅហើយ តទៅមុខយើងនឹងនៅខុបក្បាលជង្គង់ ហើយនឹងអាក្រាតកាយនៅតែខ្លួនទទេដូចសត្តិរច្ឆាន ។

អំពីពាក់ដែលនាងបានជាំជុំវិញក្នុងត្រពាំងនោះ បាន ៣ ខែ ក៏មាន

ផ្លែចាស់ខ្ចី សត្វជ្រូក ក្តាន់ ស្វា កំប្រុក ពុំហ៊ានទៅស៊ីឡើយ ព្រោះការគុ
រទេវតាតែងថែរក្សា នាងបងនៃនាងទៅបេះយកមកបរិភោគជាមួយនឹងត្រី
ក្រឹមទន្សាយហើយនឹងវល្លិ៍ខ្ទៅ ៗ លុះបាន ៦ ខែកុមារទាំង ៣ ស្រាប់
តែដុះចេញរោមពេញខ្លួន ដៃសងខាងដុះចេញទៅជាស្លាប ទទះហើរទៅ
ដល់ចុងឈើ ចាប់ប្រតោងបេះផ្លែឈើបានទាំង ៣ នាក់ តែហើរទៅឆ្ងាយ
ពុំរួច បច្ចូរមាត់ដុះចេញទៅជាចំពុះ រីឯមាត់និយាយភាសាមនុស្សពុំកើត
គ្រាន់តែនៅដឹងខ្លួនថា ខ្លួនជាមនុស្ស តែដល់និយាយទៅជាសំឡេង
សត្វតិរច្ឆាន យូរ ៗ ទៅកាន់តែហើរបានឆ្ងាយបន្តិចម្តង ៗ ហើយរកស៊ីតែ ៣
នាក់បងប្អូន វេលាយប់មកដេកនៅលើខ្ទម ភាសាមនុស្សចេះតែភ្លេចបន្តិច
ម្តង ៗ ព្រោះតាំងពីបច្ចូរមាត់ដុះចេញទៅជាចំពុះ មិនដែលនិយាយ
ភាសាមនុស្សសោះ បើសិនជាមនុស្សនិយាយទៅគេនៅស្តាប់បាន ៗ

ឯប្តីចុងរបស់នាងនោះ តែងប្រព្រឹត្តអំពើចោរកម្មជានិច្ច ៗ ថ្ងៃមួយ
មានអ្នកជិតខាងគេប្តឹងដល់ពជការ ៗ ក៏ចាប់យកទៅដាក់គុកមួយជីវិតទៅ ៗ
ឯនាងនោះ ដេកព្រួយចិត្ត នឹកអាណិតដល់កូនកំសត់ទាំង ៣ ដែលខ្លួនបាន
ធ្វើទុក្ខបុកម្នេញក៏ដើរទៅក្នុងព្រៃឃើញកូននៅញញឹកក្នុងខ្ទម ស្គាល់ច្បាស់ជា
កូន ព្រោះមានទម្រង់ជាមនុស្ស តែដុះស្លាបមានចំពុះជាសត្វតិរច្ឆានក៏ស្រែក
ហៅថាកូនអើយផ្សេវម្តាយមកទទួលកូនទៅវិញ ម្តាយលែងឲ្យកូននៅក្នុង

ព្រៃផ្សេងទៀតហើយ ។

កូនទាំងពីរឮមាត់ម្ដាយហៅ ស្គាល់ជាក់ជាម្ដាយ ហើយក៏គិតគ្នាថា ម៉ែយើងមករកសម្លាប់ទៀតហើយ ត្រូវយើងកុំទុកចិត្តគាត់ នាំគ្នាហើរទៅល្អជាង គិតដូច្នោះ ក៏នាំគ្នាហើរត្រសងទៅទំលើចុងឈើខ្ពស់១ដើម ស្រែកប្រាប់មកម្ដាយ ដោយបំណាន់និយាយថា «យើងផុតនិស្ស័យជាកូនលោកម្ដាយហើយ យើងនៅជាសត្វតិរច្ឆានល្អជាង អ្នកកុំមកជិតយើង ចុះនៅសំដីដែលស្រែកប្រាប់ម្ដាយនោះ មិនច្បាស់លាស់ជាសំដីរបស់មនុស្សទេ ទៅជាស្រែកថា «កូនលោកៗ» ទៅវិញ កាលបើម្ដាយចូលទៅជិតក៏នាំគ្នាហើរទៅទំនៅដើមឈើដទៃទៀត ស្រែកថា «កូនលោកៗ» ។ នាងនេះ ចេះតែដើរស្រែកហៅកូនទាល់តែអស់កម្លាំងដើរពុំរួច ណាមួយអត់អាហារបរិភោគផង ក៏ដួលស្លាប់ទៅ ។

តាមសេចក្ដីរបស់លោកគង់-ចណ្ណន: សមាជិកឆ្លើយឆ្លងនៃក្រុមជំនុំទំនៀមទម្លាប់នៅឃុំជ្រៃវៀន ស្រុកព្រៃឈរ កំពង់ចាម ដែលមានស្រុកកំណើតនៅខេត្ត បានសរសេរឯកសារនេះឲ្យការណ៍មកថា: នៅក្រុងខេត្តមានជ័យ ពេលរដូវរំហើយ សត្វនេះ វាតែងហើរមកចុះរើសឡឹងខ្ញាស៊ីតាមវាលស្រែ តែពុំដឹងកន្លែងវានៅព្រៃឯណា កាលណាវាផ្អើលនឹងមនុស្ស ឬសត្វដូចគ្នាវាស្ទុះហើរស្រែកយំថា កូនលោក!កូនលោក!, លុះរាត្រីស្ងាត់វាថ្ងូចថ្ងូរមុខគួរឲ្យស្រណោះពន់ពេក ។

---

# រឿងសាមកុក

## កណ្ឌទី ៤០

ចៅញាវិបុលរាជសេនា នូ-កាន់ ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នករាជការផ្លាស់បើបានអាន<br>នឹងបេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ។ |

ខុងបេងក៏បង្គាប់ទាហានឲ្យស្រែកចំអកថា សូមអរគុណទីងមហាឧបាជដែលបានឲ្យព្រួញមកយើងជាច្រើន ឯព្រួញនេះក៏គង់នឹងត្រឡប់វិលទៅតបគុណវិញទេ ហើយក៏ស្រូតបែរទូកត្រឡប់ឡើងទៅវិញ ឯទាហានចូឆូឃើញទូកចម្បាំងឌីវើត្រឡប់ទៅវិញដូច្នោះ ក៏យកសេចក្ដីទៅជូនចូឆូគ្រប់ប្រការ ចូឆូក៏ប្រើទាហានចុះទូកតូចស្រូតតាមទៅមើល បន្ទាយផ្លូវប្រហែល២០០សិន(៨គ ម.)ក៏មិនទាន់ ។

ខណៈនោះចូឆូនឹកតូចចិត្តថា ចាញ់សេចក្ដីគិតរបស់សត្រូវបានសេចក្ដីអប្បយសណាស់ ។ ឯខុងបេងកាលបណ្ដាយទូកមកវិញ ក៏និយាយ

នឹងឡោស៊ុកថាខ្ញុំរិះគិតការនេះមិនបានឲ្យខូចតាហានដល់ម្នាក់ នឹងព្រួយការជាន់ជើងទូក ២០ នោះ បានព្រួញក្នុងទូក ១ ប្រហែល ៥ ពាន់ ៦ ពាន់ទាំង ២០ ទូក គិតជាព្រួញប្រហែលជាង ១០ ម៉ឺនដើមទៀត ។ ឡោស៊ុកបានឃើញដូច្នោះ ក៏លើកដៃឡើងគំនាប់ហើយសរសើរខុងបេងថា មានគម្រិះប្រាជ្ញដូចទេវតាមកបញ្ចូលចិត្ត ឲ្យដឹងថាថ្ងៃនេះពពកនឹងចុះអ័ព្ទប្លែកមេឃងងឹតទើបរិះគិតធ្វើការដូច្នេះបាន ។

ខុងបេងថា ធម្មតាជាតិទាហាន បើមិនដឹងគ្នូរការឃើញឫក-ពោកខ្ពស់នឹងទាប ហើយក៏មិនត្រូវហៅថាអ្នកមានគម្រិះប្រាជ្ញ ដែលខ្ញុំមកធ្វើការនេះ ព្រោះដឹងថាថ្ងៃនេះមេឃងងឹតខ្លាំង ខ្ញុំក៏តាំងចុះសញ្ញាទទួលខុសត្រូវនឹងជីវ៉យមិនមានបារម្ភ ជីវ៉យប្រើខ្ញុំជានាយកងធ្វើព្រួញក្នុងរវាង ១០ ថ្ងៃ ឲ្យបាន ១០ ម៉ឺននោះ ទោះបីនឹងជ្រើសរើសឲ្យជាងធ្វើដូចម្តេចក៏មិនស្រេចទាន់ការ ហេតុទាំងនេះក៏ព្រោះជីវ៉យចស្យាគិតនឹងប្រហារជីវិតខ្ញុំចេញ តែហាក់ជាទេវតាចុះមកជួយខ្ញុំវិញ ខ្ញុំក៏ដឹងថាថ្ងៃនេះមេឃនឹងងងឹត ខ្ញុំក៏អាចគិតបន្ថយមកឲ្យត្រូវនឹង ៣ ថ្ងៃ ឥឡូវសំណាងខ្ញុំថ្ងៃបានជារួចខ្លួនតាមសញ្ញា ។ ឡោស៊ុកក៏សរសើរគម្រិះប្រាជ្ញដែលខុងបេងរិះគិតនោះជាអនេកប្បការ លុះទូកទាំងអស់លឿនមកដល់ចន្លាយកាលណា ឡោស៊ុកក៏ឡើងទៅអធិប្បាយប្រាប់ជីវ៉យតាមដំណើរសព្វគ្រប់ ហើយថា ព្រួញនោះបានគ្រប់អស់ហើយ ឲ្យទាហានចុះទៅជញ្ជូនពីទូក

យកមកចុះ ដរយ៉ក៏ប្រើពាហានស្រូតស្រុះចុះទៅជញ្ជូនព្រួញឡើងមក ហើយឱ្យរាប់គ្រួតមើលក៏ឃើញច្រើនជាង ១០ ម៉ឺនទៅទៀត ។

ឡោសុកក៏ពណ៌នាសេចក្តីដែលខុងបេងប្រើឧបាយកល ឱ្យដរយ៉ស្តាប់គ្រប់ប្រការ ដរយ៉ដឹងដូច្នោះក៏គ្រវីក្បាលដកដង្ហើមធំ ហើយថា គំនិតរបស់ខុងបេងនេះជ្រៅឆ្ងាយលើសហួសខ្ញុំច្រើនណាស់ ទទួលឃើញខុងបេងដើរចូលមក ដរយ៉ក៏ក្រោកចេញទៅទទួលឱ្យអង្គុយក្នុងទីសមគួរ ហើយទើបសរសើរថា គម្រិះប្រាជ្ញារបស់អ្នកទៅធ្វើការទាំងអម្បាលនេះ ទឹងកេអ្នកឯណាស្មើក៏ពុំបាន ។ ខុងបេងតបថា គំនិតដែលគិតការទ្រើមប៉ុណ្ណោះ ទឹងកប់ថាជាជ្រៅជ្រះនោះមិនបានទេ ។ ដរយ៉ក៏បបួលខុងបេងផឹកស្រាហើយប្រាប់ថា ពេលថ្ងៃម្សិលមិញមានសំបុត្រស៊ុនគួនមកដល់ខ្ញុំថា ឱ្យខ្ញុំរិះគិតយកជ័យជំនះចូចូឱ្យបានចុះ អ្នកចូរឃើញដល់កិច្ចការជួយរិះគិតតាត់ការទឹងទៅច្បាំងឱ្យបានជ័យជំនះចុះ ។ ខុងបេងតែងតបថា ដ្បិតគម្រិះប្រាជ្ញាខ្ញុំខ្ទះតិចណាស់ ដែលទឹងឱ្យជួយរិះគិតការសង្គ្រាមនោះខ្លាចក្រែងមិនទុះធ្លាយការសម្ងាយទឹងខូចកាសាទៅ ។

ដរយ៉ថា ឯកងទ័ពចូចូគ្រានេះ ធំសន្ធឹកសន្ធាប់ណាស់ បើទឹងចូលកាច់កំទេចវាយច្បាំងតទល់មុខគ្នានោះ ឃើញជាកម្រក្រៃណាស់ ខ្ញុំបានគិតឃើញកលឧបាយច្បាស់១យ៉ាង អ្នកទឹងឃើញដូចខ្ញុំដែរឬប្រការម្តេច ។ ខុងបេងថា ខ្ញុំទឹងសុំគិតល្បងមើលលោកទឹងខ្ញុំ ចូរសរសេរ

អក្សរតាមគំនិតដែលគិតនោះ ដាក់ក្នុងបាតដៃហើយប្រែបញ្ចេញមកមើលឲ្យព្រមគ្នា ទីងត្រូវដូចគ្នាឬទេ ជីវយ៉ីយល់ឃើញត្រូវ ទាំង ២ នាក់ក៏សរសេរអក្សរ ១ តួចុះក្នុងបាតដៃថា «ភ្លើង» ហើយប្រែត្រឡប់ផ្កាដៃទល់គ្នាមើលឃើញត្រូវគ្នា ជីវយ៉ីនិងខុងបេងក៏អស់សំណើចទាំង២នាក់ ជីវយ៉ីថា យើងទាំងពីរនាក់គិតត្រូវគ្នាណាស់ អ្នកកុំឲ្យខ្ចរខ្ចាយសេចក្ដីនេះទៅឲ្យខូចការឡើយ ៗ ខុងបេងថា លោកកុំវិតក្កឡើយ ខ្ញុំមិនឲ្យសេចក្ដីនេះបែកសាទៅឯណាទេ លោកចូរខំរិះគិតធ្វើឲ្យឆាប់ទៅចុះ ហើយខុងបេងក៏លាត្រឡប់ចុះទៅវិញ ៗ

ឯចូចូលុះខូបសេចក្ដីគិត ខាតបងទាំងព្រួញជាច្រើនដូច្នោះ ក៏មានសេចក្ដីអព្សយសមិនសប្បាយ ៗ ស៊ុនហ៊ុវក៏និយាយនឹងចូចូថា ឥឡូវជីវយ៉ីនិងខុងបេងមានគម្រិះប្រាជ្ញាជាច្រើន ជួយរិះគិតគ្នាធ្វើការសង្គ្រាម ហើយយើងនឹងច្បាំងយកជ័យជំនះ ក៏ឃើញថាកម្រក្រៃក្រណាស់ សូមឲ្យលោកប្រើទាហានធ្វើជារត់ទៅចុះចូលនៅក្នុងកងទ័ពជីវយ៉ីឲ្យរិះគិតជាកលសឹក ទើបយើងនឹងធ្វើការសង្គ្រាមបានម៉ាំ ៗ ចូចូយល់ឃើញត្រូវផង ទើបនិយាយថា អ្នកឃើញមានខេរណាដែលល្មមនឹងយកគាសាទៅ ធ្វើការទាំងនេះបាន ៗ ស៊ុនហ៊ាវក៏និយាយថា ឥឡូវលោកឲ្យសម្លាប់ឈួម៉ស្ចាប់ទៅហើយ នៅតែឈួគុន ឈួហោជាប្អូនដែលជាពលទាហាន លោកចុះយកខ្លួនមកនិយាយពន្យល់ឲ្យចូល

ហើយឲ្យធ្វើជារត់ទៅចុះចូលនៅនឹងដីវយ៉េស៊ិន ឃើញថាដីវយ៉េក៏ដឹង មិនមានសេចក្តីសង្ស័យ ដោយឃើញថាឈួតុង ឈួហោ មានចិត្តឈឺចាប់ថា លោកសម្លាប់ឈួម៉ជាបងខ្ញុំ ៗ ចូចួយល់ឃើញគ្រាវ ក៏ហៅឈួតុង ឈួហោចូលមកហើយតាំងឲ្យធ្វើជានាយទាហាន ឲ្យមាសប្រាក់គ្រឿងសម្លៀកបំពាក់តាមសមគួរ ៗ

លុះកន្លងមកថ្ងៃមួយនោះ ចូចួក៏និយាយនឹងឈួតុង ឈួហោថា អ្នកចូរតាំងចិត្តគិតធ្វើកិច្ចការនឹងយើងដោយសុចរិត កុំគិតឈឺចិត្តប្អិតថើមថាយើងសម្លាប់បងអ្នកស្លាប់ ឥឡូវយើងចាត់តែងទាហានឲ្យអ្នកធ្វើជារត់ទៅនៅនឹងដីវយ៉េ បើប្រសិនដីវយ៉េគិតកលសឹកយ៉ាងណា អ្នកចូរឲ្យដំណឹងយ៉ាងស្ងាត់មកឲ្យយើងដឹងផង បើការសម្រេចហើយយើងនឹងចិញ្ចឹមឲ្យដល់ខ្នាត ៗ ឈួតុង ឈួហោឆ្លើយថា មហាឧបរាជកុំបីគិតសង្ស័យឆ្ងល់នឹងយើងខ្ញុំឡើយ ឯបុត្រភរិយារបស់យើងខ្ញុំក៏នៅក្នុងស្រុកកេងជីវទាំងអស់ បីដូចនៅក្នុងកណ្ដាប់ដៃលោក ទោះបីយើងខ្ញុំគិតធ្វើការជាចិត្ត ពីរ ក៏ឲ្យសម្លាប់បុត្រភរិយាយើងខ្ញុំទាំងអស់ទៅចុះ យើងខ្ញុំសូមតាំងចិត្តនឹងយកអាសាចេញទៅធ្វើកិច្ចការ យកក្បាលដីវយ៉េនិងខុងបេងមកជូនលោកឲ្យបាន ចូចួមានសេចក្តីត្រេកអរពន់ប្រមាណ ទើបចាត់តែងទាហានស្រុកកេងជីវ ៥០០ នឹងទូកចម្បាំង ៥ ឲ្យឈួតុង-ឈួហោ លុះពេលកណ្ដាលយប់ស្ងាត់ ឈួតុង ឈួហោចុះទូកហើយបើកក្ដោងតាម

ខ្យល់ចុះទៅដល់ក្រោយបន្ទាយដីវយ័ ។

ក្នុងខណៈនោះ ដីវយ័ក៏ពុំប្រើកញ្ញាការសង្គ្រាមនឹងទាហានទាំងពួង ទទួលទាហានឃាមចូលមកប្រាប់សេចក្ដីថា ដ្បិតឃើញឈួគុន ឈួហោ ប្អូនឈួម៉នាំទាហានប្រហែល ៥០០ រត់ពីចូចូមក សូមមកនៅធ្វើកជការនឹងលោក ។ ដីវយ័ឮដូច្នោះក៏ប្រើទាហានចេញទៅទទួលឈួគុន ឈួហោ ឲ្យចូលមកក្នុងបន្ទាយ អ្នកទាំង ២ ក៏គំនាប់ដីវយ័ហើយយំជំរាបថា ឈួម៉បងខ្ញុំបាទទាំង២នាក់ គ្មានទោសខុសពីអ្វីសោះ ស្រាប់តែចូចូឲ្យសម្លាប់ចេញ ខ្ញុំបាទមានសេចក្ដីឈឺចិត្តគិតព្យាបាទចូចូមិនភេច តែមិនដឹងធ្វើម្ដេចនឹងសម្លាប់ចូចូបាន ទាល់តែទិតនឹងគិតការមិនសម្រេចតាមប្រាថ្នា ទើបនាំគ្នារត់មកជ្រកបុណ្យលោក ប្រាថ្នានឹងយកជាទីពឹងធ្វើកជការតទៅ ប្រសិនបើលោកនឹងលើកទ័ពចេញទៅច្បាំងវេលាណា ខ្ញុំបាទទាំង២នឹងសូមយកអាសាចេញទៅជាទព័ស្រួច ។ ដីវយ័ឮសំដីក៏ទឹកព្រួចជីនគល់ទុបាយក៏ធ្វើជាកេះកយគ្រែកអរហើយក្នុងថា ផែលចិត្តអ្នកស្មោះសរមកនៅនឹងយើង ព្រោះមានកំហឹងនឹងចូចូនោះ យើងក៏គាប់ចិត្តណាស់ហើយ រួចដីវយ័ក៏យកមាសប្រាក់ គ្រឿងសម្លៀកបំពាក់ឲ្យឈួគុន ឈួហោតាមសមគួរ រួចចាត់ឲ្យឈួគុន ឈួហោទៅនៅក្នុងកងទព័ស្រួចកាំទ្បេង ។ ឈួគុន ឈួហោក៏នាំទាហានរបស់ខ្លួនទៅនៅក្រោមបង្គាប់កាំទ្បេង ហើយគិតតែក្នុងចិត្តថា គ្រានេះយើងយកអាសាចូចូ

មកមុខៗជាទឹងបានសមប្រកបទឹងគំនិតគិតជាប្រាកដហើយ ។

ឯដំរយ៉ីក៏ឲ្យហៅខ្លួនកាំឡេងទៅជួប ហើយនូនខ្សឹបប្រាប់ថា ដែលឈ្មួតុង, ឈ្មួះហោ មកនៅទឹងយើងនេះ មិនមែនទឹងពិតត្រង់ដូចមាត់និយាយនោះទេ ព្រោះមិនបានយកគ្រួសារមកផង ឯពាក្យដែលវានិយាយតាំងអស់នោះ ជាកលល្បិចបាយបួច្ឆៈប្រមែក ត្រូវយើងគិតកលត្រួតលើកលបួច្ឆ យកខ្លួនឈ្មួតុង, ឈ្មួះហោទុកឲ្យត្រឡប់ទៅបញ្ឆោតបួច្ឆវិញដោយមិនដឹងខ្លួន ទើបយើងទឹងធ្វើការបានមាំ ដែលយើងឲ្យឈ្មួតុង, ឈ្មួះហោទៅនៅទឹងអ្នកនោះ អ្នកត្រូវតែជួយទំនុកបំរុងកុំឲ្យមន្ទិលចិត្តពាស់ចិត្តឡើយ ហើយឲ្យវាំងគយគន់ហេតុការណ៍ទំព័យើងរិះគិតឲ្យបានបន្ទោះយកជ័យជំនះបួច្ឆវិញ រួចសឹមយើងកាត់ក្បាលឈ្មួតុង, ឈ្មួះហោសែនទទង់ជ័យ កាំឡេងទទួលពាក្យហើយក៏ត្រឡប់ទៅបន្ទាយវិញ ។

ឡោសុកក៏ជំរាបសួរដំរយ៉ីថា ឈ្មួតុង,ឈ្មួះហោមកនៅទឹងលោកនេះ ជាកលល្បិចបាយទេ កុំឲ្យលោកយកទុកឡើយ ដំរយ៉ីឮហើយក៏ទឹងណាស់ស្រែកគំហកឲ្យឡោសុកថា ពីដើមឈ្មួម៉ាជាបងគេគ្មានទោសខុសអ្វីសោះ បួច្ឆឲ្យសម្លាប់បងទៅ ឥឡូវឈ្មួតុង, ឈ្មួះហោមានសេចក្ដីតូចចិត្តទើបមកនៅទឹងយើងចង់ទឹងសងសឹកបួច្ឆវិញ ហេតុម្ដេចខ្លួនអ្នកមកមានមន្ទិលសង្ស័យទឹងគេដូច្នេះ យូរទៅមានអ្នកណាដែលមានគំនិតទឹង

ចង្រៃ នឹងអាចនឹងហ៊ានចូលមកនៅនឹងយើងបានទៀត ហើយធ្វើជាក្រោកដើរចូលទៅក្នុង ។

ឡោសុកក៏នាំយករឿងរ៉ាវដែលជីវយ៉ីនិយាយនេះ ទៅជំណាលឲ្យខុងបេងស្ដាប់គ្រប់ប្រការ ខុងបេងឮហើយក៏អស់សំណើច មិននិ-យាយថាអ្វីសោះ ឡោសុកឃើញដូច្នោះក៏សួរ ហេតុម្ដេចបានជាលោកសើច? ខុងបេងតបថា ខ្ញុំអ្នកគ្រង់ពេកណាស់ មិនចេះរិះគិតឲ្យឃើញគំនិតជីវយ៉ីសោះ ឥឡូវជីវយ៉ីដឹងក្នុងកលឧបាយចូចូ ដែលចាត់ប្រើឈួកុង, ឈួហោមកស្ម័គ្រនៅផងនោះ ព្រោះហេតុថាកងទ័ពជីវយ៉ីនឹងចូចូតាំងនៅទីនេះជាជាយទន្លេ ពិបាកនឹងប្រើមនុស្សទៅមកយាមល្បាតស៊ើបការ បានជាចូចូក្លែងឲ្យឈួកុង, ឈួហោធ្វើជារត់មកនៅនឹងជីវយ៉ីប្រាថ្នានឹងបានដំណឹងការទៅចូចូ ឯជីវយ៉ីបានជាយកទុកនោះ ព្រោះនឹងគិតកលត្រួតលើកលចូចូវិញ ដែលអ្នកទៅនិយាយហាមរំលឹកជីវយ៉ីមិនឲ្យទទួលយកឈួកុង, ឈួហោទុកនោះ ជីវយ៉ីក៏ក្លែងធ្វើជាខឹងសម្បារប្រាថ្នាមិនឲ្យអ្នកយល់ទេ ឡោសុកថា កាលជីវយ៉ីខឹងនោះ ខ្ញុំក៏មិនបានដឹងយោបល់សោះ លុះតែលោកបានប្រសាសន៍បំភ្លឺទើបគិតទៅឃើញគំនិតជីវយ៉ីតាមលោកហើយ ឡោសុកក៏លាខុងបេងទៅកាន់ទីកន្លែង ។

លុះពេលកណ្ដាលយប់ ជីវយ៉ីចេញមកអង្គុយគិតរាជការ ទទួល

ឃើញអ៊ីយកាយដើរចូលមក ជីវយ៉េសួរថា អ្នកចូលមកនឹងដាស់តឿនស្មារតីយើងឬប្រការម្ដេច ? ។ អ៊ីយកាយថា បណ្ដាពបានចូចូដែលលើកមកធ្វើសង្គ្រាមគ្រានេះច្រើនជាងយើងណាស់ បើជាលោកនឹងតាំងនៅឲ្យយូរមិនគិតទំលុះទំលាយរកចុងបាយនឹងឡាំងជាប្រញាប់ទេ ខ្ញុំបាទឃើញថានឹងខូចការរបស់សត្រូវជាប្រាកដមិនខាន ហេតុម្ដេចលោកមិនគិតការយកភ្លើងដុតទំពចូចូឲ្យឆាប់ទៅ ។

ជីវយ៉េឮដូច្នេះក៏សួរថា យោបល់ដែលអ្នកគិតដូច្នេះ តើនរណាប្រាប់ឲ្យអ្នកមកនិយាយ ។ អ៊ីយកាយឆ្លើយថា សេចក្ដីនេះខ្ញុំបាទគិតឃើញខ្លួនឯងគ្មាននរណាមកពន្យល់ទេ ជីវយ៉េឮដូច្នេះក៏គិតថា យោបល់របស់អ្នកនេះត្រូវនឹងគំនិតយើង ហើយថាយើងក៏គិតឃើញដូចអ្នកដែរ តែថានៅមិនទាន់មានឱកាសល្មមនឹងធ្វើបាន ឥឡូវឈ្មួគុង, ឈ្មួហោមកនៅនឹងយើងហើយ គឺជាកលល្បិចរបស់ចូចូ ប្រាថ្នាចង់ដឹងហេតុការណ៍កងទ័ពយើង ដែលយើងទទួលឈ្មួគុង, ឈ្មួហោនៅនោះ ព្រោះនឹងចង់ធ្វើកលត្រួតលើកលចូចូ ។ អ៊ីយកាយថា លោកកុំរិះគន់ឡើយ បើលោកនឹងប្រើខ្ញុំបាទៗក៏សូមទទួលការ ។ ជីវយ៉េថា បើអ្នកព្រមទទួលយកការហើយ ត្រូវតែអត់ធន់ការជារបស់យើងឲ្យជាយ៉ាងរហ័ស ទើបការតាំងពួងនឹងសមគួរតាមគំនិតបាន ព្រោះដ្បិតចូចូក៏មិនមានមន្ទិលសង្ស័យអ៊ីយកាយថា ស៊ុនគួនមានឧបការគុណជាទម្ងន់លើ

ខ្លួនខ្ញុំបាទ ព្រោះលោកឧបត្ថម្ភទំនុកបំរុងផ្គង់ផ្គើមឲ្យជាសុខរៀងរាបដរាប មក ខ្ញុំបាទក៏នៅមិនទាន់បានធ្វើគុណបំណាច់អ្វីជាទីតបស្នងសងគុណលោកសោះ គ្រានេះទោះបីលោកនឹងត្រូវការឲ្យខ្ញុំបាទយកអាយុជីវិតទៅថ្វាយ ខ្ញុំបាទក៏សូមស៊ូដោយឥតអាចពុំខ្លាចស្លាប់ ហេតុនេះសូមឲ្យលោកចាត់ប្រើខ្ញុំបាទចុះ ខ្ញុំបាទនឹងសូមយកអាសាយកលោហិតទៅក្រាលផែនពសុធា ជាទីតបស្នងសងគុណលោកឲ្យប្រាកដកេរ្តិ៍ឈ្មោះចំពោះទៅខាងមុខ ។ ជីវយ៉េឮដូច្នោះក៏សោមនស្សសាទរ ក្រោកឡើងឈរហើយលុតជង្គង់ចុះគំនាប់អ៊ុយកាយនិយាយថា បើអ្នកតាំងចិត្តធ្វើការដោយសុចរិតប្រាកដ យើងក៏ឃើញថាការសឹកសង្គ្រាមគ្រានេះ អាចសន្មត់បានថានឹងមានជ័យជំនះ ព្រោះខ្លួនអ្នកជាបឋម អ្នកគប្បីខំផ្ចង់ចិត្តគិតប្រយុទ្ធខ្លួនប្រាណតាមដែលយើងត្រូវធ្វើគ្រានេះចុះ លុះនិយាយហើយក៏ចុះសញ្ញាទុកជាទីសំខាន់ ។ អ៊ុយកាយក៏ទទួលប្រកាន់តាមពាក្យសំដីស្រេចក៏លាជីវយ៉េទៅកាន់ទីសំណាក់វិញ ។

លុះពេលព្រឹកឡើង ជីវយ៉េក៏ចេញនិយាយរាជការ ទីប្រឹក្សាទាំងសេនាទាហានទាំងពួងក៏ទៅជួបជុំព្រមគ្នា ហើយអញ្ជើញខុងបេងចូលទៅប្រឹក្សាផង ។ ជីវយ៉េក៏និយាយថា ចូចូលើកទ័ពមកគ្រានេះ មានទាហានប្រមាណ ១០០ម៉ឺននាក់ រៀបតាំងបន្ទាយរៀងគ្នាជាលំដាប់ជាប់ប្រវែង ៣០០០សិន ( ១២០គ-ម ) ឯទាហានយើងមានតិចជាងគេ

ណាស់ ដែលខ្ញុំរិះគិតច្បាំងឲ្យហើសនោះ មិនមែនបានសម្រេចក្នុង១ ថ្ងៃទេ យើងខ្ញុំចែកស្បៀងអាហារឲ្យបណ្ដាទាហានគ្រប់នាយទ័ព នាយកងទាំងពួង ឲ្យលើសកំណត់ក្នុងកំណត់ ៣ខែ ទើបខ្ញុំកែប្រែលើកទៅច្បាំងបានស្រួល ។ អ៊ុយកាយឮដូច្នោះក៏ក្លែងឆ្លើយថា កុំថាលោកចែកស្បៀងឲ្យតែត្រឹម៣ខែប៉ុណ្ណោះឡើយ ទោះបើលោកគ្មានគិតចែករលែកឲ្យលើសគំរប់ដល់ ៣០ខែទៀតក៏ដោយ ក៏គង់ខ្ញុំធ្វើការសឹកសង្គ្រាមពុំសម្រេច គំនិតរបស់ខ្ញុំបាទបានគិតទុកជាស្រេចហើយថាត្រូវតែចែកឲ្យអស់ក្នុង ១ខែ ទើបខ្ញុំនឹងគិតកែខែតតាំងច្បាំងនឹងកងទ័ពចូឆ្ឆុឲ្យបរាជ័យទៅបាន បើមិនដូចគំនិតដែលគិតមានដូច្នេះទេ ត្រូវតែកែប្រែធ្វើតាមពាក្យទៀវទៀវនិយាយ អស់យើងខ្ញុំទាំងឡាយក៏ត្រូវដោះគ្រោះបោះអាវុធពីដៃ នាំគ្នាទៅពឹងអាស្រ័យចំណុះចុះចូលនឹងចូឆ្ឆុតែម្ដងទៅ នឹងនៅឲ្យអំពល់រវល់ធ្វើអ្វីទៀត ។

ជីវយើបានឮដូច្នោះ ក៏ក្លែងធ្វើជាខឹងខ្លាំងណាស់ ដើម្បីមិនឲ្យមនុស្សទាំងផ្ដាសមន្ទិលសង្ស័យ និយាយថាសព្វថ្ងៃស៊ុនឃួនឲ្យយើងកាន់អាជ្ញាសិទ្ធិ លើកទាហានមកធ្វើមេកងទ័ព អាចខ្ញុំប្រើបណ្ដាប់ដាត់ការកុងការសង្គ្រាមតនឹងចូឆ្ឆុ បើមាននរណារឹងទទឹងពាលោ ត្រូវតែប្រហារជីវិតតាមអាជ្ញាសិទ្ធិ ស្រេចលើយើង ឥឡូវយើងនិយាយជាការកដការដោយយល់ឃើញត្រឹមត្រូវដូច្នេះ ហេតុអ្វីអ៊ុយកាយនេះអង់អា

មិនបានគោរពខ្លាចយើងជាមេទ័ព មកនិយាយពន្យល់បង្អាប់យើង កណ្តាលទីប្រជុំ ដើម្បីឲ្យពលទាហានតូចធំមានសេចក្តីញញើរញញើត ខឹងធ្វើការ បើតាមសំដីវោហារដែលពោលនេះ ហាក់បីដូចជាណែនាំពន្យល់ឲ្យរេហ៍ពល ប្រែវិចិត្តមិនហ៊ានគិតតតាំង ហើយជាទីញុំាងសត្រូវឲ្យដឹងការ អាចនឹងក្លៀវក្លាលើកទ័ពមកសង្កត់សង្កិនយើង ដោយពលការ ដំរយ៉ក៏ស្ទុះស្ទាទៅបង្គាប់ទាហានឲ្យចោមចាប់ខ្លួនអ៊ុយកាយទៅប្រហារជីវិត ។

អ៊ុយកាយឮដូច្នោះ ក៏ក្នុងធ្វើជាខឹងតបយ៉ាងខ្លាំងស្រែកថា ខ្លួនអញក៏បានតាំងចិត្តគិតធ្វើការយកអាសាក្នុងសឹកសង្គ្រាម តាំងពីគ្រាស៊ិនគៀនជាបិតាស៊ិនគួនផ្ទួនជាប់មក ៣ ត ហើយ ទាល់តែស្រុកកាំងតាំងទីខ្ជាប់ខ្ជួន លុះស៊ិនគៀនស្លាប់ទៅ អញក៏មកនៅនឹងស៊ិនសេកហួត មកដល់ស៊ិនគួន គ្រានេះមកប្រជួនឲ្យអភ័ព្វធ្លាក់មកនៅក្រោមបង្គាប់ ដំរយ៉ជាមនុស្សថ្មី មានសេចក្តីលោភគ្រប់សង្កត់និយាយឲ្យឯងបាត់មាត់កុំឲ្យឆ្លើយបាន បើត្រូវស្លាប់អញក៏មិនខ្វល់ស្លាប់នឹងខ្លាចប៉ុន្មាន កើតមករមែងស្លាប់មិនខានតាមយថាកម្មទៅចុះ ។ ដំរយ៉ឮដូច្នោះ ក៏រឹងរឹតតែធ្វើខឹងពន់ប្រមាណណាស់ បង្គាប់ទាហានឲ្យរហ័សយកខ្លួនអ៊ុយកាយទៅសម្លាប់ ។

តាំងឡេងក៏និយាយឃាត់ថា អ៊ុយកាយនេះជាខុនពលការចាស់មក

យូរហើយ  វេលានេះបានជានិយាយដោយពាក្យល្មើសលើសលោះ ខ្ញុំសូមឲ្យលោកអនុគ្រោះលើកទោសទោលម្ដងទៅចុះ  ឯកំហុសនោះ ព្រោះវិស័យមនុស្សពាសរមែងមានយ៉ាងនេះឯងជាធម្មតា ៗ ជីវយើបាន ស្ដាប់ក៏ឆ្លើយថា  ដែលអ្នកមកសូមទោសអ៊ុយកាយនេះ  ដូចជានាំឲ្យ មនុស្សកាំងញ៉ឹងតែបានចិត្តគិតមើលងាយយើងតទៅមុខទៀត  ហើយ ក៏បង្គាប់ឲ្យពាហានបណ្ដេញកាំងទ្បេងចេញទៅ ៗ ចំព្រើក្បាទីនសេនា ពាហានទាំងពួងក៏នាំគ្នាគិតទាស់ជីវយើហើយជំរាបថា  ដែលអ៊ុយកាយបាន ជានិយាយដូច្នេះ  ក៏ឃើញថាជាពាក្យទ្រគោះផ្សុសរ៉ាមើលងាយលោក ខ្លាំងណាស់  គួរទំងប្រហារជីវិតកុំគិតករុណាគេឡើយ  តែគ្រានេះបាន ជាខុសទៅហើយ  យើងខ្ញុំសូមឲ្យរួចអាយុជីវិតម្ដងចុះ  បើលោកនឹង សម្លាប់តាមទោសកំហុសក៏សឹងតែបាន  តែថាគ្រានេះជាពេលនៅកង វ៉េងកងទ័ព  ក្រែងទំងកើតអបមង្គលដល់ការដែលកំពុងធ្វើ  បើកាល ណាយើងបានកំចាត់ខ្មាំងស្រេចហើយ  សឹមលោកសម្លាប់អ៊ុយកាយ ចេញចុះ ៗ

ជីវយើតបថា  អស់អ្នករាល់គ្នានិយាយនេះក៏គួរហើយ  តែបើយើង ទំងលើកទោសអ៊ុយកាយឲ្យរួចតែម្ដង  តទៅមុខមនុស្សផងក៏ទំងកំរើបរឹង ទទឹងទៀតតែថាទោសដែលត្រូវសម្លាប់នោះ  យើងក៏អនុញ្ញាតទុកមួយ អន្លើសិនចុះ  ហើយបង្គាប់ពាហានឲ្យយកអ៊ុយកាយទៅវ៉ាយ ១០០ ខ្វាប់

ទាហានក៏ចាប់ទៅចន់វាយបាន ៥០ ឈប់ ១ លើក ទីប្រឹក្សាទាំងពួង ក៏បេះតែអង្វរសុំទោស ។

## សាមកុកខ្សែ ៤១

តាំងពីជីវយីឲ្យចាប់អ៊ុយកាយទៅវាយ ៥០ ខ្វាប់ ខុងបេងឃើញក៏មិនស្ដី ព្រោះដឹងថាជីវយីធ្វើកលឧបាយ រហូតដល់ពួធូនិងទីប្រឹក្សាសេនាទាហានប្រជុំគ្នាស៊ីផឹកក្នុងផែនទ័ពរវិតជាសប្បាយក្នុងវេលាយប់ ។

---

ជីវយីក៏ក្រោកឡើងជេរអ៊ុយកាយជាពាក្យអស្រពេះផ្សេង ៗ ហើយថា គ្រានេះអញបានឲ្យវាយតែ ៥០ ខ្វាប់ គេទៅមុខបើឯងនៅមិនកាន់ចាល កាចរឹងទទឹងម្ដងទៀត អញនឹងឲ្យកាត់ក្បាលឯងជាតង្វាល ហើយក៏ដើរចូលទៅខាងក្នុង ។ ទីប្រឹក្សានឹងសេនាទាហានទាំងពួង ក៏នាំគ្នាចូលទៅគ្រាអ៊ុយកាយនាំទៅទីកន្លែងដែលនៅ ។ ឯរបួសដែលវាយនោះ ក៏បែករលុះរលួយហូរឈាមពេញអស់ទាំងខ្លួន អ៊ុយកាយក៏សន្លប់បាត់ស្មារតីដល់ ២-៣ ដង ។ មនុស្សទាំងពួងក៏មានសេចក្ដីករុណាតអនាថយំទាំងអស់គ្នា ហើយនាំគ្នាចាប់តេះតេតាល់តែជីងខ្លួនឡើងវិញ ។ ឯខុងបេងឃើញដូច្នោះ ក៏មិនបាននិយាយថាដូចម្ដេច ត្រឡប់ចុះទៅទូកវិញ ។ ល្ងាចស៊ុកក៏ចុះតាមខុងបេងដល់ទូកហើយសួរថា ខ្លួនខ្ញុំនៅក្រោមបង្គាប់ជីវយី ឃើញជីវយីឲ្យវាយអ៊ុយកាយ ក៏មានសេចក្ដីអាណិតខ្លោចចិត្តតែមិននិយាយសុំទោសក៏មិនបាន ម្យ៉ាងខ្លួនលោកជាភ្ញៀវមកពីចម្ងាយ ហេតុ

ម្ដេចមិនជួយសុំទោសអ៊ុយកាយផង បានជានៅស្ងៀម ។

ខុនបេនស្ដាប់ហើយក៏អស់សំណើចថា ខ្ញុំនឹកគិតថា យើងដឹងមិនដល់ឬ បានជាមកនិយាយមើលងាយយើងដូច្នេះ ។ ឡោស៊ុកតបថា តាំងពីខ្ញុំទៅនាំលោកមក នៅក្នុងស្រុកកាំងតាំង រហូតមកដល់ធ្វើការទីតាំងនេះ ខ្ញុំបាទក៏មិនដែលនិយាយមើលងាយប្រមាថលោកឲ្យទាស់ចិត្តពីរឿងអ្វីសោះ ហេតុម្ដេចបានជាលោកមានប្រសាសន៍ថាខ្ញុំមើលងាយដូច្នោះ ។ ខុនបេនថា កាលដីវ៉ៃឲ្យវ៉ាយអ៊ុយកាយនោះ គឺជាកលឧបាយរបស់ដីវ៉ៃគិតត្រូវលើកលចួច បានជាខ្ញុំនៅស្ងៀមមិនបាននិយាយសុំទោសអ៊ុយកាយ ដែលដីវ៉ៃប្រើឧបាយដូច្នោះ ប្រាថ្នាចង់ឲ្យឈ្មួញគុំឈ្មួញហោះឃើញពិត ទីងបានប្រើល្បិចទៅប្រាប់ចួធឲ្យដឹង ហើយទីងឲ្យអ៊ុយកាយធ្វើជាទៅចំណុះចុះចូលចួច បើប្រសិនជាអ្នកទី៣ទៅជួយដីវ៉ៃ គុំបើប្រាប់ដីវ៉ៃថាខ្ញុំដឹងដល់កលទាំងនេះឡើយ ចូរប្រាប់ថា ខ្ញុំឃើញដីវ៉ៃឲ្យវ៉ាយអ៊ុយកាយនោះ ខ្ញុំអាណិតសព្វគ្រប់ចិត្តណាស់ ព្រោះដីវ៉ៃមិនបានស្រឡាញ់រាប់អានទាហាន ។

ឡោស៊ុកក៏ឆ្លើយទទួលពាក្យ ហើយលាខុនបេនត្រឡប់ទៅជួបនឹងដីវ៉ៃ ។ គឺនាំឡោស៊ុកចូលទៅខាងក្នុង ឡោស៊ុកក៏ក្មួនសួរដីវ៉ៃថា អ៊ុយកាយជាខ្ញុំរាជការជាន់ចាស់ បានជានិយាយក្បាំងក្បាត់ទៅប៉ុណ្ណោះ ហេតុម្ដេចលោកមិនអធ្យាស្រ័យក៏ឲ្យធ្វើទោសដល់ទំនេះ ។ ដីវ៉ៃត្រឡប់

សួរទេព្វសុកវិញថា ដែលខ្ញុំឲ្យវាយអ៊ុយកាយនោះ អ្នកបានឮមនុស្សទាំងអស់គ្នានិយាយថាដូចម្ដេចខ្លះ? ។ ទេព្វសុកថា ខ្ញុំបានឮគេពល់គ្នានិយាយថា គួរឲ្យអាណិតអ៊ុយកាយណាស់ ដោយហេតុថាលោកឲ្យធ្វើទោសអ៊ុយកាយវាយដំជាដំណំគ្រាំគ្រា ។ ជ័យសួរថា អ្នកបានឮខុនបេននិយាយដូចម្ដេចខ្លះដែរឬទេ ។ ទេព្វសុកថា ខុនបេនមានសេចក្ដីតូចចិត្តច្រើន ពីព្រោះថាលោកមិនមានអាណិតមេត្តាខាន ។ ជ័យឮដូច្នោះ ក៏ទះដៃអស់សំណើចហើយថា ខ្ញុំធ្វើឧបាយគ្រានេះ ខុនបេនគ្មានដឹងខ្លួនសោះ ។ ទេព្វសុកថា លោកមានប្រសាសន៍ថា ខុនបេនមិនដឹងនោះ គឺលោកធ្វើយ៉ាងម្ដេច ។

ជ័យថា ដែលខុនបេនមិនដឹងដល់ឧបាយយើង ។ គិតធ្វើទោសអ៊ុយកាយនោះ ព្រោះហេតុថាទីងត្រូវគកល់ចូច ដើម្បីឲ្យអ៊ុយកាយទៅចុះចូលនៅទីងចូចឯឧបាយដែលខ្ញុំគិតនេះ ឈ្មួញ ឈ្មោះហាងដឹងគឺទីង លបទៅប្រាប់ចូច ។ គឺគង់យល់ថាពិត ខ្ញុំនឹងយកក្បួនដុតចំពួនចូចឲ្យមានជ័យជំនះ ។ ទេព្វសុកបានឮដូច្នោះក៏ពេកតែគន់ចិត្តថា ឯកម្រិះប្រាជ្ញខុនបេននៅជ្រៅឆ្ងាយទូលាយយ៉ាងវិសេស លើសជ័យទៅទៀតដែលខុនបេនធ្លាំនោះ ទេព្វសុកក៏មិនបាននិយាយឲ្យជ័យដឹងការសោះ ហើយលាទៅវិញ ។

ឯអ៊ុយកាយដែលត្រូវគេវាយរបួសដំណំគ្រាំគ្រានោះ ក៏ដេកឈឺនៅ

ក្នុងបន្ទាយមនុស្សទាំងឡាយក៏នាំគ្នាទៅសួរនាំជាច្រើន អ៊ុយកាយក៏មិនបានសាស្រាយដោយកិច្ចការអ្វី ធ្វើជាទាំញញុមៗ មាត់ចែបទំនេរក្រកដ ទីនឹងដីវយើធ្វើបាបខ្លួននោះ ។

ក្នុងខណៈនោះ ឆាំគេកដែលជាទីប្រឹក្សាដីវយើ ជាគៀនសំឡាញ់ ទីនឹងអ៊ុយកាយឆាំគេកនេះ ជាមនុស្សទៀងត្រង់សុចរិតណាស់ មានវោហារ ប៉េះនិយាយចេញទៅអស់ក៏ចូលទៅ ។ អ៊ុយកាយក៏បណ្ដេញបាវព្រាវ របស់ខ្លួនឲ្យចេញអស់ទៀត, ហើយហៅឆាំគេកចូលទៅជិត ។ ឆាំគេក ក៏សួរសាកថា ពីដើមរៀងមកខ្លួននឹងដីវយើមានសាហេតុអ្វីនឹងគ្នាដែរឬទេ បានជាដីវយើឲ្យធ្វើទោសទណ្ឌកម្មអ្នកដល់ទំនេះ ? ។ អ៊ុយកាយឆ្លើយថា គ្មានសាហេតុអ្វីនឹងគ្នាទេ ។ ឆាំគេកថា បើគ្មានទោសហេតុព្យាបាទ គ្នាទេ ដែលដីវយើឲ្យធ្វើទោសអ្នកជាសហ័សដូច្នេះ តើជាបាយឬ ? ។ អ៊ុយកាយថាអ្នកបានដឹងឬ ? ។ ឆាំគេកថា ដែលដីវយើធ្វើទោស អ្នកដូច្នេះ ខ្ញុំយល់ឃើញជាផ្លូវ ១០ ចំណែក តែខ្ញុំដឹងដល់តែពាក់ កណ្ដាល មិនដឹងដល់ពាក់កណ្ដាល ។

អ៊ុយកាយថា ពីដើមចូចចូគិតគលឧបាយឲ្យឈ្មួញ, ឈ្មួញហៅមក នៅនឹងដីវយើ ។ ក៏ប្រឹក្សានឹងខ្ញុំថានឹងគិតគ្រួតកលចូច ឯខ្លួនខ្ញុំនេះគឺស៊ីន គៀន, ស៊ីនសេក មានគុណឧបការដោយបានចិញ្ចឹមរក្សារៀងមក ។ លុះស៊ីនគៀន, ស៊ីនសេកអនិច្ចកម្មទៅ ស៊ីនគួនក៏បានចិញ្ចឹមរក្សាតមក

ទៀត គុណឧបការក៏មានជាច្រើន ខ្ញុំមិនទាន់មានគុណបំណាច់អ្វីសោះ បានជាយកខ្លួនស៊ូប្តូរជីវិតតបគុណទទួលអាសាធ្វើការជាកលឧបាយ បើនឹងនឹងឲ្យកងទ័ពចូលជួយបរាជ័យ ខ្ញុំក៏ស៊ូទ្រាំលំបាករូបកាយឲ្យឈឺដំណំគ្រាំគ្រាជាសហ័ស ព្រោះនេះខ្ញុំក៏ពិព្រោះឃើញថាបណ្តាទាហានដែលមានក្នុងកងទ័ពយើងគ្មាននរណាល្មមនឹងទុកចិត្តបានឡើយ ខ្ញុំគិតទៅហើយឃើញតែអ្នក ១ នឹងជួយធុរៈដោយសុចរិតប្រាកដនឹងនាយចៅហ្វាយ ខ្ញុំក៏សុំនិយាយប្រាប់ការអាថ៌កំបាំងនេះឲ្យអ្នកជ្រាបទៅចុះ ព្រោះបើអ្នកទទួលជួយយកអាសាបាន ខ្ញុំក៏នឹងបានប្រាប់ឲ្យអស់សេចក្តី ។

ឆាំគេតថា ដែលអ្នកមានប្រសាសន៍និយាយនោះ នឹងចង់ឲ្យខ្ញុំទៅល្បួងបញ្ឆោតបច្ចុ ? ។ អ៊ុយកាយតបថា ប្រសាសន៍នេះត្រូវនឹងគំនិតដែលខ្ញុំគិតនោះឯង តែថាចិត្តអ្នកនឹងយល់ព្រមតាមឬដូចម្តេច ? ។ ឆាំគេតថា ចៅហ្វាយនាយមានឧបការគុណមកហើយមានតែត្រូវជួយ តែថាខ្លួនខ្ញុំសព្វថ្ងៃមានតែរូបនឹងចិត្តជីវិតវិញ្ញាណ បើត្រូវការយ៉ាងណា ខ្ញុំក៏អាចហ៊ានស៊ូប្តូរឲ្យមានកេរ្តិ៍ឈ្មោះទុកក្នុងផែនដី ដើម្បីនឹងទទួលអាសាទៅល្បួងបញ្ឆោតបច្ចូគាមការ បើប្រសិនណាបច្ចូនឹងដឹងដល់កលដែលគិត នឹងប្រហារផ្តាញជីវិតក៏តាមការចុះ ខ្ញុំមិនទញ់ទុះមិនញញើតខ្លាចទេ សូមតែឲ្យមានកេរ្តិ៍ឈ្មោះប្រាកដគង់ ។

(នៅមានត)

## ពាក្យវប្បធម៌

លោក នាង-ហ៊ូ រៀបរៀង

លោក សម-ថាំង ពិនិត្យ

---

យើងបានទទួលសំបុត្រមួយច្បាប់ របស់លោក ប្រាក់ ផាន់ នាយឯកនៅកងវរសេនាតូចនៃទាហានប្រះជញ់លេខ១០ ដែលបានសួរយើងអំពីពាក្យ ៦ ម៉ាត់ គឺ៖

១- អន្តរធាន

២- អន្តរជាតិ

៣- សន្តិសុខ

៤- សន្តិភាព

៥- ទណ្ឌកម្ម

៦- ទារុណកម្ម

ពាក្យសួរទាំង ៦ ម៉ាត់នេះ នាំឲ្យយើងមានសេចក្ដីរីករាយនឹងអធិប្បាយជូនជាសណ្ដាប់ដូចតទៅ :

១. ចំពោះពាក្យ អន្តរធាន នឹងអន្តរជាតិទាំងពីរសព្ទនេះ លោក ប្រាក់-ផាន់ មានសេចក្ដីងឿងឆ្ងល់ថា ហេតុអ្វីក៏ពាក្យទាំងពីរនេះជាក់អក្សរដូចគ្នាតែដល់ពេលអានក៏ខុសគ្នា? គឺអន្តរធានគេអានថា,

អន់-ដរ-ធាន ឯពាក្យអន្តរៈជាតិ ម្ដេចក៏អានថា អន់-តៈ-រៈជាតិទៅវិញ ?

យើងសូមឆ្លើយថា: ពាក្យទាំងពីរម៉ាត់នេះ មានដើមកំណើតតែមួយដូចគ្នា គឺមកពីសព្ទ "អន្តរៈ" ដែលប្រែថា "ចន្លោះ,រវាង,រយៈ-ប្រហោង, រូង, រន្ធ, ពោសក្ដាំងក្ដាត់, ឱកាស, ចំណែកខាងក្នុង, ចិត្ត-វិញ្ញាណ, សំពត់,សំលៀក ។

រួមសព្ទទាំង ២ គឺអន្តរៈ នឹង ធាន: ជាអន្តរធាន: ជាកិត្តនាម ប្រែថា ការខូច, ការបាត់, សេចក្ដីវិនាស ។ ឯសព្ទ អន្តរៈជាតិ នេះក៏មកពីសព្ទ អន្តរៈ ដូចន័យមុននឹងសព្ទ "ជាតិ" រួមគ្នាជា "អន្តរជាតិ" ជាសមាសនាមប្រែថា រវាងជាតិ ។ ឯការដែលអានខុសថា អន់-ដរៈ-ធាន នឹង អន្តៈ-រៈ-ជាតិដូច្នេះនេះ គឺជាទម្លាប់តាមស្រួលមាត់ ។ ម្យ៉ាងទៀត ការអានថា អន្តៈរៈជាតិដូច្នេះនេះ ដើម្បីចៀសវាងកុំឲ្យដូចពាក្យជេរខ្លះដែលធ្លាប់មានមកហើយដូចពាក្យថា អន្តរធាន អន្តរកប្ប, អន្តរជោគជាដើម ព្រោះបើពាក្យ អន្តរៈជាតិ ឲ្យអានថា អន់-ដរ-ជាតិ ក៏ហាក់ដូចជាឲ្យស្ដាប់សេចក្ដីបានថា "អន្តរធានជាតិ" ទៅវិញ ។ ហេតុនេះហើយបានជាគួរអានថា "អន្តៈរៈជាតិ" ដូច្នេះវិញចុះ ។

មែនពិត, សព្ទជាភាសាបាលីឬសំស្ក្រឹតដែលមានជាប់ដោយអក្សរ "ត" ទន្តជៈ ហើយដែលប្រើក្លាយមកជាពាក្យខ្មែរយើងអក្សរ "ត" ទន្តជៈនោះឯងតែងតែត្រូវអានបញ្ចេញសំឡេងជាអក្សរ "ដ" មុទ្ធជៈទៅវិញដោយ

ច្រើនណាស់ ។ ឧទាហរណ៍: ដូចពាក្យ: អធិបតីក្លាយជាអធិបដី, មាតា បិតា ជាមាដាបិដា, ពីតា ជាពីដា, ទេវតា ជាទេវដា, សន្តាន: ជាសណ្តាន, សន្តោស: ជាសណ្តោស; អន្តរៈកប្ប ជាអន់-ដរ កប្ប ជាដើម ។

យើងសូមបញ្ជាក់ថែមទៀតថា សព្ទបាលី «អន្តរ:» នេះតែងរួមជាមួយនឹងសព្ទដទៃទៀតជាច្រើន ហើយដែលខ្មែរយើងនិយមប្រើតាំងពីសម័យបុរាណរៀងដរាបមក ស្ទើរតែក្លាយទៅជាភាសាខ្មែរសុទ្ធៗទៅហើយ ។ ប៉ុន្តែសព្ទ «អន្តរ:» នោះ ជួនគេដាក់រៀងទៅខាងដើមសព្ទដទៃដូចពាក្យ អន្តរធាន, អន្តរកប្ប, អន្តរជាតិ, អន្តរវដ្ដជា ដើម ។ ជួនកាលគេដាក់រៀងនៅខាងចុងសព្ទដទៃវិញតាមសមគួរដល់ដំណើរសេចក្តី ដូចពាក្យ ពុទ្ធន្តរ, លោកន្តរជាដើម ។

អំពីវិធីដែលគួរសង្កេតក្នុងការអានពាក្យដែលមានអក្សរតម្រួតគ្នា ។

តាមអក្ខរវិធីព្យញ្ជនៈទីបំផុតវគ្គនីមួយៗត្រូវតម្រួតនៅក្រោមព្យញ្ជនៈក្នុងវគ្គរបស់ខ្លួនតាំងពីជួនតួទីនិងលើតួឯងបាន (វៀរលែងតែតួ«ង»ចេញដែលមិនធ្លាប់ឃើញមានប្រើតម្រួតលើតួឯង)។ ឧទាហរណ៍ដូចពាក្យបាលី«អន្តរ: សន្តាន:,កន្តារ:,ពុទ្ធន្តរ:,លោកន្តរ: នឹងពាក្យខ្មែរបន្តឹងតិចឡើងតិច,បណ្តឹង ពាក្យដែលគេបន្តឹងទឹងពាក្យថាកណ្តាលជាដើម ។ សព្ទទាំងនេះគេអាចកំណត់ដឹងបានថាជាជើង«ត»ទន្ត:ឬជាជើង«ដ»មុទ្ធ: ដោយឥតក័ន្ត ដោយសំគាល់តួអក្សរដែលជតម្រួតគ្នានោះៗ;ដូចពាក្យ សន្តាន: កន្តារ;

អន្តរធានៈ; អន្តរកប្បៈ; អន្តរជាតិ; ពុទ្ធន្តរៈ; លោកន្តរៈ; ជាដើម, ពាក្យទាំងអស់នេះសុទ្ធតែមានតួ «ន» តម្រួតលើជើង «ត» ដូចៗគ្នា មិនមែនជើង «ដ» ទេ ៗ ដែលគេអាចកំណត់ដឹងបានដូច្នេះ ព្រោះគេដឹងថា អក្សរ «ត» និង «ន» នេះ នៅក្នុងវគ្គជាមួយគ្នាគឺ: ត ថ ទ ធ ន ជា តៈវគ្គ ហើយកើតក្នុងឋានជាមួយគ្នា គឺជាទន្តជៈ ប្រែថា កើតត្រង់ធ្មេញដូចគ្នា, ប៉ុន្តែពាក្យខ្លះដែលប្រែក្លាយមកជាភាសាខ្មែរយូរៗទៅ ការអានក៏បានប្រែក្លាយទៅតាមទម្លាប់ស្រួលមាត់គឺសំឡេង «ត» ទន្តជៈ ក្លាយទៅជាសំឡេង «ដ» មុទ្ធជៈ ដូចពាក្យៈ សន្តានៈ; អន្តរធាន; ពុទ្ធន្តរៈ ដែលសុទ្ធតែមានជើង «ត» ផ្ញើក្រោមតួ «ន» នេះជាដើម គេច្រើនអានថា: សន់-ដាន; អន់-ដ-រៈ-ធាន, ពុទ្ធន ដរ ទៅវិញ ៗ សព្ទដែលអានក្លាយខុសពីបៀបវេយ្យាករណ៍ដូច្នេះ គេហៅថាអញ្ញត្រសព្ទឬសព្ទពិសេសឬក៏ពាក្យពិសេស គឺសព្ទដែលមានសូរអានផ្សេងពីសរសេរ–ពាក្យខ្មែរមានតិចដែរទេ ៗ

២ – អំពីពាក្យសន្តិភាព និងសន្តិសុខ ៗ សន្តិភាព ប្រែថាភាពស្ងប់: សាន្តត្រាណឬសេចក្ដីស្ងប់ការពេបពាបឬជាដំណើរសះជានឹងគ្នា ៗ

ប្រយោគខាងក្រោមនេះជាឧទាហរណ៍ក្នុងការប្រើពាក្យ «សន្តិភាព» សម័យសព្វថ្ងៃនេះ ប្រជាជនក្នុងសកលលោក កំពុងត្រូវការចង់បាន សន្តិភាព ដើម្បីកសាងប្រទេសជាតិរៀងខ្លួនឲ្យបានចំរើនរុងរឿង ៗ

ឯពាក្យ «សន្តិភាព» ប្រែថា សេចក្ដីសុខដែលកើតឡើងអំពី

សន្តិភាព ឬគំពារសេចក្ដីសុខ សេចក្ដីរៀបរយរាបទាប ។ មិនពិបាក យល់ប៉ុន្មានទេ ព្រោះពាក្យនេះមានន័យពក់ស្រួលណុកយល់ ។

៣- អំពីពាក្យ: "ឧណ្ហាកម្ម" និង "ទារុណកម្ម" ។ ទណ្ឌកម្ម ប្រែថា ការធ្វើទោសបង្គាល់ ដល់មនុស្សណាមួយតាមសមគួរដែលកំហុស ដែលបានប្រព្រឹត្តល្មើសវិន័យបញ្ញត្តិ ឬល្មើសច្បាប់សម្រាប់រដ្ឋ ។ ពាក្យនេះជាពាក្យងាយយល់ ងាយប្រើ ទើបយើងមិនបាច់ទាញ ឧទាហរណ៍មកពន្យល់ក្នុងទីនេះទេ ។

ឯពាក្យ "ទារុណកម្ម" ប្រែថា: អំពើកាច, អំពើអាក្រក់ សាហាវ, យង់ឃ្នង គឺអំពើដែលពុំត្រឹមត្រូវតាមគន្លងមនុស្សធម៌ ។

ការប្រើពាក្យ "ទារុណកម្ម" ដូចឧទាហរណ៍ខាងក្រោមនេះ

ក្នុងសម័យអសន្តិសុខ , កងទ័ពអាណានិគមនិយមបានចាប់ប្រជា ពស្ត្រស្លូតត្រង់ជាច្រើនយកមកឃុំឃាំងធ្វើទារុណកម្មជាទម្ងន់ មានអ្នក ខ្លះត្រូវគេចងព្យួរសំយុងក្បាលចុះក្រោម ហើយវាយដំចង្អុកទឹកត្រីឬដាក់ឲ្យ ខ្សែភ្លើងឆក់ដពបរិកលចរិត ឬដល់ក្ស័យជីវិតក៏សឹងមាន ។

ឧទាហរណ៍ប៉ុណ្ណេះ ល្មមឲ្យអស់លោកអ្នកស្ដាប់យល់ខ្លឹមអត្ថន័យនៃ ពាក្យ "ទារុណកម្ម" នេះបានហើយ ។

# ផ្នែកកំណត់ដឹងប្រវត្តិការណ៍

ពិធីបុណ្យបូជាព្រះសពព្រះមុនីកោសល សោម-ឈុន

លោក ថន វ៉ន រៀបរៀង

---

ព្រះមុនីកោសល សោម-ឈុន វិមលបញ្ញោ រាជាគណៈថ្នាក់ទោ អធិបតីវង្សនៃក្រុមជំនុំប្រែព្រះត្រៃបិដក មេគណខេត្តកណ្ដាល ចៅអធិការវត្តនិគ្រោធវង្ស ឃុំព្រែកអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដែលទទួលអនិច្ចធម្មពីថ្ងៃអង្គារ ៤ កើត ខែអស្សុជ ឆ្នាំកុរឯកស័ក ព.ស. ២៥០២ ត្រូវនឹងថ្ងៃទី ៦ តុលា គ.ស.១៩៥៩ នៅវេលាម៉ោង ១០ និង ៤៥ នាទី ក្នុងជន្មាយុគំរប់ ៧៥ ឆ្នាំ ហើយដែលបានដំកល់ព្រះសពទុកធ្វើទក្ខិណា-នុប្បទានដរាបមកនោះ នៅថ្ងៃទី ១០ មីនា ១៩៦០ នៅវត្តនិគ្រោធវង្សក្នុងកុដិផ្ទាល់របស់សព មានធ្វើពិធីកិច្ចព្រះសពទៅដំកល់លើរថយន្តវិចិត្រមាលា ធ្វើពិធីដង្ហែចេញទៅក្រៅវត្ត ដើម្បីបំពេញសទ្ធានិងសេចក្ដីជ្រះថ្លារបស់ពុទ្ធបរិស័ទនិងសិស្សានុសិស្ស ។

មុនពេលធ្វើពិធីនេះ ចាប់តាំងពីម៉ោង ១២ ទៅ ចំណែកខាងព្រះសង្ឃ យើងបានសង្កេតឃើញជាអាទិ៍ គឺ សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណមហានិកាយ ព្រះពោធិវង្ស ហួត.តាត ព្រះ

ឧបាលិវង្ស ស្វាហាយ ព្រះតេជព្រះគុណ សរ ញ៉ែម ជាមេគណស្តីទី ខេត្តកណ្តាល ។ ផ្នែកខាងគ្រហស្ថ យើងសង្កេតឃើញវត្តមានមន្ត្រីអ្នករាជការគ្រប់ដំណែង ឧបាសក ឧបាសិកា ទាំងវត្តមានជាច្រើនពាន់នាក់ បាននិមន្ត បានអញ្ជើញមកជាកិត្តិយសក្នុងពិធីនេះ ។

បន្ទាប់មកនៅម៉ោង២និង៣០នាទីរសៀល បាននិមន្តព្រះសង្ឃ ៧៧ អង្គបង្សុកូល ហើយរំកិលព្រះសពទៅដំកល់លើរថយន្តវិចិត្រមាលា ។ ក្នុងខណៈកំពុងរំកិលសពនេះ ក្រុមភ្លេងគងកាជគម្រួគបាន ប្រគំបទភ្លេងមានសូរសព្ទលាន់ឮរន្ទាប់ព្រៃលេង ។

លុះរៀបចំខ្បួនហែរួចហើយ នៅវេលាម៉ោង៣និង៣០នាទីរសៀល ពិធីដង្ហែព្រះសពក៏បានហែចេញទៅក្រៅវត្ត បត់ទៅខាងលិចរហូតដល់ស្ពានព្រះមុនីវង្សត្រើយខាងកើត រួចដង្ហែត្រឡប់ចូលមកដំកល់ក្នុងបារាំកំពូលក្នុងវត្តវិញ នៅវេលាម៉ោង៥និង៤៥នាទី ។

យើងសូមជំរាបថា ពិធីដង្ហែព្រះសពនេះ បានប្រព្រឹត្តទៅក្នុងសភាពដ៏មហោឡារិកក្រៃលែង គឺក្បួនបានដង្ហែចេញទៅដល់ស្ពានព្រះមុនីវង្សត្រើយខាងកើតហើយ កន្ទុយក្បួននៅក្នុងវត្តនៅឡើយ ។

លុះដល់ម៉ោង ១៩ និមន្តព្រះសង្ឃចំរើនព្រះបរិត្ត រួចនិមន្តសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណមហានិកាយ សំដែងធម៌ទេសនាព្រះធម្មគោរព ។

ថ្ងៃសុក្រទី១១មីនា១៩៦០ ម៉ោង៧ព្រឹកប្រគេនយាគូចំពោះព្រះសង្ឃ ។ ម៉ោង១០-៣០នាទី អង្គាសចង្ហាន់ព្រះសង្ឃ ៣៧ អង្គ ។ ម៉ោង ១៩ និមន្តព្រះសង្ឃ ៣៧ អង្គចំរើនព្រះបរិត្តរួចនិមន្តលោកអាចារ្យទៀវជុំ វត្តលង្កាសំដែងធម៌ទេសនាទសជាតក៍ ៖

ថ្ងៃសៅរ៍ទី១២មីនា១៩៦០ ពេលព្រឹកមានកម្មវិធីដូចថ្ងៃមុន ។ លុះដល់ពេលរសៀល តាំងពីម៉ោង៣ទៅមានការជួបជុំឥស្សរជនជាច្រើន ដែលយើងបានសង្កេតឃើញជាអាទិ៍ លោកជួប-ហែល ប្រធានរដ្ឋសភា ព្រមទាំងសមាជិកខ្លះនៃសភាទាំង ២ លោកស៊ិន-សាន ឧបនាយករដ្ឋមន្ត្រី លោកគួ-រុន ទេសរដ្ឋមន្ត្រី លោកលឹម-គ្រី អេងហ៊ុន ស៊ូ-ណៃម ហង់ ផាន់ សរ-គឹមកួយ ឌី ប៉ែលឡុង សមាជិករាជរដ្ឋាភិបាល លោកឃឹម-ទិត លោកប៉ូល់-ដួន ចៅហ្វាយខេត្តកណ្ដាល ព្រមទាំងមន្ត្រីកិត្តិយស មន្ត្រីនៅក្នុងខេត្ត គណកម្មការរៀបចំពិធីបុណ្យឈាបនកិច្ចសព តាហានស៊ីវិល ក្រុមតាហានគង់ខេមរភូមិន្ទ ក្រុមតាហានរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យ ព្រមទាំងពុទ្ធបរិស័ទជាច្រើននាក់ ផ្នែកខាងព្រះសង្ឃ យើងសង្កេតឃើញសម្ដេចព្រះសង្ឃនាយកទាំង២គណៈ ព្រះរាជាគណៈ ឋានានុក្រម ព្រមទាំងភិក្ខុ-សាមណេរជាច្រើនអង្គ នៅក្នុងវត្តនិរោធរង្សី និមន្តអញ្ជើញទៅគោរពព្រះសពព្រះមុនីកោសល សោម-ឈុន វិមលបញ្ញា ព្រះរាជាគណៈថ្នាក់ទោ អធិបតីនៃក្រុមជំនុំ

ព្រះត្រៃបិដក មេគណខេត្តកណ្តាល និងជាចៅអធិការវត្តនិគ្រោធវង្ស ឃុំច្បារអំពៅ ស្រុកកៀនស្វាយ (កណ្តាល) ដែលត្រូវធ្វើពិធីបុណ្យបូជាក្នុងវត្តនេះ ។

នៅវេលាម៉ោង៤ រសៀលនៃថ្ងៃនេះ សម្តេចមហាជីវិន ដោយមានឯកឧត្តមជុំ ព្រឿង ឯកឧត្តមមៀច-គន្ធ ជាសមាជិកឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ លោកស៊ឹង ហុងសាង នាយលេខាធិការដ្ឋាន ការិយាល័យសម្តេចសហាជីវិន និងលោកវរសេនីយទោ មាស-ហុល កងរក្សហែហមព្រះអង្គផង ស្តេចយាងមកដល់កន្លែងប្រកបពិធី ។

ក្រោយដែលព្រះអង្គបានទទួលគារវកិច្ច និងការក្រាបថ្វាយបង្គំអំពីឥស្សរជន មន្ត្រីរាជការនិងប្រជារាស្ត្រ ដែលនៅរង់ចាំក្រាបថ្វាយបង្គំសំដែងសេចក្តីស្វាមីភក្តិ ចំពោះព្រះអង្គនៅក្នុងព្រះវិហារនៃវត្ត រួចហើយសម្តេចសហាជីវិន ស្តេចចូលទៅក្នុងវត្តដោយមានក្រុមទាហានរក្សាព្រះអង្គ គង់ទេវមហេក្សិទ្ធ យ៉ាំង យ៉ាតី និងក្រុមតន្ត្រីព្រះរាជទ្រព្យលើកភ្លេងបន្ទុំបទយាត្រា និងបន្ទន់កាយគោរពថ្វាយជាព្រះរាជកិត្តិយស ហើយស្តេចយាងលើកម្រាលស ចូលមកព្រះពន្លាពិសេស ដែលពេលនោះនារីកញ្ញា ៤ រូប បានបាចផ្កា លើសំពត់ស ថ្វាយព្រះអង្គជាព្រះកិត្តិយស រហូតដល់ព្រះពន្លាពិសេស រួចស្តេចយាងថ្វាយបង្គំព្រះសព និងទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជន និងប្រជារាស្ត្រជាកូនចៅ

ហើយស្តេចយាងថ្វាយបង្គំព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃនាយក ទាំងពីរគណៈជាប្រធាន ។

បន្ទាប់មក ក្រុមមន្ត្រីព្រះរាជទ្រព្យ ក៏បានបន្លឺបទនគរាជថ្វាយព្រះអង្គជាទីគោរព ។

ក្រោយដែលទ្រង់គោរពភ្លេងជាតិរួចហើយ សម្តេចសហជីវិន ទ្រង់សព្វព្រះទ័យយាងទតតុ ដែលតាំងនៅជុំវិញមេរុដំកល់ព្រះសព រួចហើយស្តេចយាងចូលប្រថាប់គង់ក្នុងព្រះពន្លាពិសេស ។

លុះព្រះអង្គស្រួលព្រះឥរិយាបថហើយ ព្រះពោធិវង្ស ហួត-តាត អធិបតីនៃក្រុមជំនុំព្រះត្រៃបិដក ថ្លែងសុន្ទរកថាមួយ មានសេចក្តីដូចតទៅនេះ ៖

សូមនមស្ការសម្តេចទាំងពីរព្រះអង្គ ,

សូមថ្វាយព្រះពរសម្តេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ,

ឱកាសនេះ ខ្ញុំព្រះករុណា ករុណាភាព ក្នុងឋានៈជាអធិបតីក្រុមជំនុំព្រះត្រៃបិដក តំណាងនាមនៃសមាជិកក្រុមជំនុំព្រះត្រៃបិដកទាំងអស់ តំណាងអ្នករាជការក្រុមពុទ្ធសាសនបណ្ឌិត្យ និងតំណាងពុទ្ធបរិស័ទ គឺព្រះសង្ឃនិងគ្រហស្ថជាសិស្សានុសិស្ស និងជាឧបាសកឧបាសិកាទាំងអស់ សូមថ្លែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះសម្តេចទាំងពីរព្រះអង្គ និងសម្តេចព្រះបិតាឯករាជ្យជាតិ ដែលបាននិមន្តមក ស្តេចយាងមកជាព្រះ

កជាធិបតី គណៈកម្មការនៃពិធីឈាបនកិច្ចព្រះសពព្រះមុនីកោសល សោម-ឈុននេះ ។

សូមថ្វាយព្រះពរ,

មុននឹងថ្លែងថ្វាយនូវគុណសម្បត្តិ នៃព្រះមុនីកោសលកាលមានជីវិតរស់នៅ ខ្ញុំសេចក្ដីស្ដាយអាល័យចំពោះព្រះមុនីកោសលដែលរលត់សង្ខារទៅហើយ អាត្មាភាពសូមព្រះរាជទានព្រះរាជវរោកាសបន្តិច ដើម្បីថ្លែងរៀបរាប់ថ្វាយដោយសង្ខេបអំពីជីវប្រវត្តិនៃព្រះមុនីកោសលដូចមានតទៅនេះ ៖

ព្រះមុនីកោសល សោម-ឈុន កើតនៅថ្ងៃសុក្រ ៥ កើតខែស្រាពណ៍ ឆ្នាំរកាសប្តស័ក ព.ស ២៤២៩ គ.ស. ១៨៨៥ ក្នុងភូមិវាលស្បូវ ឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។ បិតារបស់លោកឈ្មោះ សោម ជាអ្នករាជការក្នុងព្រះបរមរាជវាំង ក្នុងរជ្ជកាលនៃព្រះបាទសម្ដេចព្រះនរោត្តម (ព្រះសុវណ្ណកោដ្ឋ) មានងារជាខុនញ៉ាពិភក្ដិបម្រើក្សត្រ មាតារបស់លោកឈ្មោះ មុំ ។

ព្រះមុនីកោសល កាលនៅពីកុមារអាយុ ១២ ឆ្នាំ បានចូលទៅនៅសិក្សាអក្សរសាស្ត្រជាតិក្នុងវត្តនិពេធារង្សី ឃុំច្បារអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្ដាល លុះដល់អាយុ ១៥ ឆ្នាំ បានបួសជាសាមណេរក្នុងវត្តដដែល ដោយមានលោកគ្រូ ឃាស់-គីម ជាព្រះឧបជ្ឈាយ៍ ។ លុះដល់អាយុគំរប់ ២១ ឆ្នាំ បានបួសជាភិក្ខុ ក្នុងពទ្ធសីមាវត្តនិពេធារង្សី

បានទទួលនាមថា វិមលប្បញ្ញោ ដោយមានលោកគ្រូ ហាស់-គឹម ដែលជាព្រះឧបជ្ឈាយ៍ ។

ភិក្ខុ សោម-ឈុន ក្រោយដែលបានឧបសម្បទហើយ ៤ ឆ្នាំ ក៏បានចូលមកនៅសិក្សាព្រះបរិយត្តិធម៌ក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

ដោយវិរិយភាពនិងឆន្ទៈដ៏ខ្លាំងក្លាចំពោះការសិក្សា ភិក្ខុវិមលប្បញ្ញោ (សោម-ឈុន) ក៏បានសម្រេចផលល្អក្នុងរយៈកាលត្រឹម ៣ ឆ្នាំ ហើយបានចូលប្រឡងបរិយត្តិធម៌ ដែលហៅថា «ដេញប្រយោគ» ក្នុងសម័យនោះ នៅក្នុងវិហារព្រះកែវមរកត ក្នុងព្រះបរមរាជវាំងនៃព្រះករុណាជាអម្ចាស់ជីវិត បានទទួលឋានៈជាមហា ៣ ប្រយោគ ។ ព្រះមហា សោម-ឈុន ក្រោយដែលបានទទួលឋានៈជាមហា ៣ ប្រយោគហើយ ក៏បានខំប្រឹងបន្តការសិក្សាទៅមុខទៀត ដរាបតាល់តែមានការចេះដឹងជ្រៅជ្រះខាងចំណេះព្រះពុទ្ធសាសនា បានទៅជាពហុស្សូត ១ អង្គអាចធ្វើជាសាស្ត្រាចារ្យបង្ហាត់បង្រៀនបានគ្រប់គ្រាន់ ។ ដោយសារពហុស្សូតភាពនេះ ព្រះមហា សោម-ឈុន ក៏បានទៅជាធម្មកថិកមួយអង្គមាននាមល្បីល្បាញក្នុងប្រទេសកម្ពុជា ។

សូមទ្រង់ព្រះមេត្តាប្រោស,

កាលក្រោយដែលព្រះឧបជ្ឈាយាចារ្យរបស់លោកនៅវត្តនិគ្រោធវ័ន្ត បាស់ ទទួលអនិច្ចធម្មអស់ទៅ ព្រះមហា សោម-ឈុន ត្រូវទទួលការ

គ្រប់គ្រងវត្តនិរោធរង្សីជាជំនួសតមក ។ តាំងពីកាលនោះមក លោកត្រូវទទួលភារៈធ្ងន់ណាស់ គឺត្រូវរុះរើវត្តចាស់ដែលនៅក្បែរមាត់ទន្លេមកធ្វើ ២លើក ដោយច្រាំងទន្លេធ្លាក់ គឺធ្វើម្ដងមុនសង់រួចស្រេចហើយ មិនយូរប៉ុន្មានច្រាំងធ្លាក់មកដល់ទៀត ទើបត្រូវធ្វើជាលើកទី២មកសង់នៅកន្លែងសព្វថ្ងៃនេះ ។ កន្លែងវត្តនេះ កាលពីដើមជាទីបាតបឹងព្រៃស្ងាត់រហោឋាន-មានជម្រៅជ្រៅស្រឡូង ដូចជាជម្រៅខាងមុខវិហារសព្វថ្ងៃនេះ ប៉ុន្តែដោយកម្លាំងវីរិយភាពដ៏ខ្លាំងក្លា និងបុញ្ញានុភាពរបស់លោក ដែលមានពុទ្ធបរិស័ទជាចំណុះជើងវត្ត និងក្រៅជើងវត្តជាបង្អែកផង ទីដីក្នុងវត្តប៉ុនេះក៏ត្រឡប់ទៅជាមានកំពស់ស្មើនឹងថ្នល់ជាតិ ហើយបរិបូណ៌ដោយទីសេនាសនៈតូច-ធំ សមជាទីវត្តដ៏ថ្លៃថ្លាក្នុងព្រះពុទ្ធសាសនា ក្នុងបណ្ដាវត្តដ៏ប្រសើរទាំងឡាយក្នុងប្រទេស ។

ព្រះមហា សោម-ឈុន ដែលមានការកិច្ចក្នុងការស្ថាបនាទីសេនាសនៈផ្សេងៗក្នុងអាវាសវត្តនេះ មិនទាន់ចប់នៅឡើយទេ នៅមានកិច្ចការដែលបានគ្រោងទុក ដូចជាបណ្ណាល័យ សម្រាប់ដំកល់គម្ពីរដីកាក្បួនច្បាប់ ខាងព្រះពុទ្ធសាសនាជាដើមតទៅទៀត ប៉ុន្តែកិច្ចការរបស់មនុស្សក្នុងលោកមែនតែសល់នៅយ៉ាងនេះជាធម្មតា ព្រោះអាយុមនុស្សវែងពុំស្មើនឹងកិច្ចការរបស់មនុស្សឡើយ ។

សូមទ្រង់ព្រះមេត្តាប្រោស,

ដោយអាស្រ័យការចេះដឹង ទាំងសមត្ថភាពរបស់លោកគ្រប់គ្រាន់ ទើបព្រះមហា សោម.ឈុន ត្រូវបានទទួលឋានៈជាសមាជិកនៃក្រុមជំនុំព្រះត្រៃបិដក ក្នុង គ.ស. ១៩៣១ ។

ដល់មក គ.ស. ១៩៤០ បានទទួលសមណសក្តិជាព្រះពុទ្ធវង្ស ក្នុងរជ្ជកាលនៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស ក្នុងបរម. ខត្តិយកោដ្ឋ ។

ដល់មក គ-ស-១៩៥២ បានទទួលតំណែងជាមេគណខេត្តកណ្តាល ។

ដល់ គ-ស- ១៩៥៣ បានទទួលសមណសក្តិជាព្រះមុនីកោសល រាជាគណៈថ្នាក់ទោ ។ ក្នុងគ-ស- ដដែលនេះ លោកបានទទួលឋានៈ ជាអធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដក ។

ព្រះមុនីកោសល សោម–ឈុន តាំងពីបានចូលធ្វើជាសមាជិកនៃក្រុមជំនុំព្រះត្រៃបិដក ជាអធិបតីរងនៃក្រុមជំនុំនេះ រហូតដល់ទីបំផុតមានរយៈកាល ចំនួន ២៩ឆ្នាំ ។ ក្នុងរយៈកាលនេះ ព្រះមុនីកោសលសោម-ឈុន ដែលបានធ្វើការរួបរួមជាមួយនឹងព្រះសង្ឃទាំងពីរគណៈ ដែលជាក្រុមជំនុំជាមួយគ្នាបានបញ្ចេញគុណសម្បត្តិឲ្យព្រះសង្ឃទាំងឡាយ កើតសេចក្តីជ្រះថ្លារាប់អានស្រឡាញ់ពេញចិត្តដោយឃើញថា:

១ -ព្រះមុនីកោសល ជាព្រះថេរៈមួយអង្គដែលមានការចេះដឹង ស្ទាត់ជំនាញយ៉ាងម៉ាំមួនក្នុងព្រះត្រៃបិដក ។

២-ព្រះមុនីកោសល ជាព្រះថេរៈមានចិត្តស្មោះត្រង់នឹងព្រះពុទ្ធសាសនាហ្មានប្រគល់កាយជាយជីវិតបូជាចំពោះព្រះពុទ្ធសាសនា១ជីវិត ។

៣-ព្រះមុនីកោសល ជាព្រះថេរៈមានចិត្តនឹងធឹងធ្ងន់ធ្ងរ ពុំដែលមានសេចក្ដីក្រោធខឹងក្រៅហេតុ ។

៤-ព្រះមុនីកោសល ជាព្រះថេរៈយកព្រះទ័យទុកដាក់ជាទីបំផុតក្នុងការងារ តាំងពេលវេលាធ្វើការ ក៏ពុំដែលមានការធ្វេសប្រហែស ។

៥-ព្រះមុនីកោសល ជាព្រះថេរៈដែលមានអធ្យាស្រ័យពេញចិត្តប្រារព្ធនិយាយតែពីធម៌វិន័យមិនត្រូវការនិយាយអំពីតិរច្ឆានកថា ។

សូមទ្រង់ព្រះមេត្តាប្រោស,

ព្រះសង្ឃគ្រប់រូបជាសមាជិកក្រុមជំនុំព្រះត្រៃបិដក មានសេចក្ដីជ្រះថ្លាប្រកបដោយសេចក្ដីគោរពចំពោះព្រះមុនីកោសល ដែលប្រកបដោយគុណសម្បត្តិដូចខាងលើនេះ មិនតែប៉ុណ្ណោះឡើយ ពុទ្ធបរិស័ទទូទៅ ក៏មានសេចក្ដីស្រឡាញ់រាប់អានព្រះមុនីកោសល ដោយសង្កេតឃើញថា លោកជាមហាថេរ ១ អង្គដែលមានបរិយាសណ្ឋានថ្លាប់ឬកពារថ្លៃថ្នូរ មានឥន្ទ្រិយស្រគត់ស្រគំសមរម្យជាសមណៈ មានចិត្តទូលាយស្មើទូទៅចំពោះសិស្សានុសិស្ស មានអធ្យាស្រ័យធ្ងន់ធ្ងរគោរពប្រតិបត្តិតាមវិន័យសិក្ខាតឹងរ៉ឹងណាស់ ។

ក្រៅពីនេះ រៀនពល់ថ្ងៃ១ពោសថ លោកតែងឲ្យទៅដល់

ឧបាសក ឧបាសិកា ឲ្យស្គាល់តម្លៃនៃព្រះពុទ្ធសាសនា តែងរំលឹកជាស់តឿនសិស្សានុសិស្សឲ្យជាប់ចិត្តស្រឡាញ់ការសិក្សា ឲ្យចេះចងចិត្តគ្នាតាមផ្លូវសាមគ្គីធម៌ ក្នុងការបំពេញកិច្ចដែលនាំឲ្យកើតប្រយោជន៍ដល់ប្រទេសជាតិនិងព្រះពុទ្ធសាសនា ទាំងក្នុងបច្ចុប្បន្នទាំងបរលោក ។

សរុបសេចក្តីទៅ ឃើញថាព្រះមុនីកោសល ក្នុងជីវិតរបស់លោក លោកបានបំពេញកិច្ចការដែលមានប្រយោជន៍ដ៏ច្រើនណាស់ គួរចាត់ទុកជាគំរូមួយដ៏ប្រសើរក្នុងព្រះពុទ្ធសាសនា ។

មនុស្សដែលប្រកបដោយគុណសម្បត្តិ និងជាទីពេញចិត្ត នៃព្រះសង្ឃ គ្រហស្ថច្រើន ហើយបានបំពេញកិច្ចការច្រើន ដូចព្រះមុនីកោសល សោម-ឈុន នេះ គួរតែឲ្យមានសេចក្តីសង្ឃឹមថា នឹងត្រូវបានសេចក្តីអនុគ្រោះនឹងការលោះលាគ្រាប្រណី អំពីសំណាក់នៃមច្ចុរាជតីសេចក្តីស្លាប់ ប៉ុន្តែផ្ទុយទៅវិញ ទុកជាមានសេចក្តីសង្ឃឹម ក៏ឥតបានផលអ្វី ព្រោះសេចក្តីស្លាប់ ឥតមានធម៌មេត្តាករុណា ឥតមានការយោគយល់ ឥតយកចិត្តទុកដាក់ម្នាក់ណាមួយឡើយ សេចក្តីស្លាប់នេះជាធម្មជាតិមួយយ៉ាងខ្លាំងក្លា សម្រាប់តែផ្តាច់ផ្តិលអាយុសង្ខារនៃមនុស្សសត្វគ្រប់ប្រភេទដោយឥតរើសមុខ ។ ដូច្នេះហើយបានជាព្រះមុនីកោសល សោម ឈុន ចោលព្រះសង្ឃ គ្រហស្ថ សិស្សានុសិស្ស ពុទ្ធបរិស័ទត្រូវការចង់ឲ្យមានជីវិតរស់នៅវែងទៅ ហើយខំប្រឹងព្យាបាលដោយវិធី

យ៉ាងណា ក៏មិនអាចនឹងរួចផុតពីមរណធម៌បាន ។

ក្នុងពេលដែលព្រះមុនីកោសល ទទួលមរណភាពទៅនេះ ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ឈ្មោះថាខាតបង់សមាជិកមួយរូប ដែលមានសមត្ថភាពបរិបូណ៌ គួរឲ្យព្រះសង្ឃនិងពុទ្ធសាសនិកជនទាំងឡាយ មានសេចក្ដីស្ដាយក្រៃលែង ។

លំដាប់ពីនេះ អាត្មាភាព សូមព្រះរាជទានព្រះរាជវរោកាសបន្តិច ដើម្បីថ្លែងចំពោះទៅព្រះមុនីកោសល ។

លោកគ្រូមុនីកោសល, អវសានកិច្ចរបស់លោកគ្រូ នឹងផុតក្នុងពេលបន្តិចទៀតនេះ ។

ឥឡូវនេះ សម្ដេចទាំងពីរព្រះអង្គ ដែលធ្លាប់ទុកលោកគ្រូជាកល្យាណមិត្រ ក៏បាននិមន្តមកជួបជុំក្នុងទីនេះ សម្ដេចព្រះបិតាឯករាជ្យជាតិ ដែលលោកគ្រូតែងតែមានសេចក្ដីស្វាមីភក្ដិ និងតែងតែសរសើរមិនដាច់នោះ ក៏ស្ដេចមកគង់ជាអធិបតីក្នុងទីនេះដែរ ទាំងឥស្សរជនទាំងឡាយ ព្រះសង្ឃគ្រហស្ថជាមិត្រ និងជាសិស្សានុសិស្សទាំងឡាយ ក៏បានមកប្រជុំគ្នាក្នុងទីនេះទាំងអស់ ដោយមានសេចក្ដីអាឡោះអាល័យ ចំពោះលោកគ្រូដែលនិមន្តចេញពីលោកនេះទៅកាន់លោកដទៃ ។

សូមលោកគ្រូតាំងចិត្តអនុមោទនាចំពោះការកុសល ដែលពុទ្ធបរិ·

សទ័ឧទ្ទិសប្រគេននេះចុះ ។

សូមលោកគ្រូកុំមានទោមនស្សចំពោះការរំលាយខន្ធនេះ ព្រោះលោកគ្រូជ្រាបស្រាប់ហើយ ព្រះពុទ្ធជាបរមគ្រូរបស់យើង ទ្រង់បានសំដែងថា ខន្ធ ៥ របស់សត្វលោក សុទ្ធតែត្រូវរលាយរលត់ទៅដូចគ្នាទាំងអស់ ។

មួយវិញទៀត ព្រះអង្គសំដែងថា រូបំ ជីរតិ មច្ចានំ នាមគោ–ត្តំ ន ជីរតិ រូបកាយសព្វសត្វទាំងឡាយ រមែងចាស់គ្រាំគ្រារលាយរលត់បាត់បង់ទៅ ឯកេរ្តិ៍ឈ្មោះ ទើបមិនចាស់ មិនរលាយរលត់ គឺជាអាចឋិតនៅបុះរហូតដល់កប្បាវសាន ។

លោកគ្រូកាលមានជីវិតរស់នៅ បានធ្វើកិច្ចការដែលល្អ ដែលមានប្រយោជន៍ច្រើនណាស់ អ្នកណាក៏ដឹងដែរ លោកគ្រូបាត់បង់តែរូបកាយទេ ឯកេរ្តិ៍ឈ្មោះអាចឋិតនៅបានជាដរាបតទៅ ។

ឥឡូវនេះ យើងទាំងអស់គ្នាសូមលាហើយ សូមលោកគ្រូនិមន្តទៅកាន់សុគតិភពចុះ ។

សូមទ្រង់ព្រះមេត្តាប្រោស,

នៅអវសាននេះ ពុទ្ធបរិស័ទទាំងឡាយបានចាត់ចែងធ្វើការកុសលនេះចំនួន ៥ ថ្ងៃ ពិតជាធ្វើឧទ្ទិសផលប្រគេនទៅព្រះមុនីកោសលមែន ប៉ុន្តែបានតាំងចិត្តចែកភាគផលនៃកុសលនេះ ថ្វាយចំពោះព្រះករុណាជា

អម្ចាស់ជីវិតទាំងពីរព្រះអង្គនិងសម្តេចព្រះបិតាឯករាជ្យជាតិ សូមទ្រង់បានឋិតនៅជាសុខសាន្តក្នុងសិរីរាជសម្បត្តិអស់កាលជាអង្វែងទៅ ព្រមទាំងសូមទ្រង់បានប្រកបដោយជោគជ័យ និងសុភមង្គលគ្រប់ប្រការ អស់កាលជានិច្ចនិរន្តរ៍ គ្រប់ទិវារាត្រី តទៅ ។

លុះចប់សុន្ទរកថាព្រះពាធិរ័ង្សហើយ សម្តេចសហជីវិនទ្រង់សព្វព្រះហឫទ័យ ថ្លែងព្រះរាជយោគកថាមួយ ឆ្លើយតបវិញ ដែលមានសេចក្តីដូចតទៅនេះ :

សូមថ្វាយបង្គំសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ដោយគោរពជាទីបំផុត ព្រមទាំងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ។

សូមជម្រាបអស់លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ និងជាសិស្សានុសិស្សនៃព្រះសព ។

ក្នុងព្រះបរមនាម នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ ក្នុងនាមនៃរាជរដ្ឋាភិបាល និងក្នុងនាមផ្ទាល់នៃខ្ញុំព្រះករុណា-ខ្ញុំ , ខ្ញុំព្រះករុណា-ខ្ញុំសូមថ្លែងនូវៈសេចក្តីសោកស្តាយជាទីបំផុត ចំពោះព្រះតេជព្រះគុណ ព្រះមុនីកោសល សោម-ឈុន អធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដក និងជាមេគណខេត្តកណ្តាល ដែលបានទទួលអនិច្ចធម្មពីថ្ងៃទី៦ តុលា ១៩៥៩ ហើយដែលត្រូវធ្វើពិធីឈាបនកិច្ចព្រះសពលោកក្នុងថ្ងៃនេះ ។

គិតតាំងពីថ្ងៃដែលព្រះតេជព្រះគុណព្រះមុនីកោសល ទទួលអនិច្ច

ឆ្នាំទៅ មកទល់នឹងថ្ងៃទី១២ មីនា ១៩៦០ នេះត្រូវជា៥ខែបាយហើយ ។

ពិតមែនហើយ តែកាលវេលាកន្លងទៅយូរថ្ងៃ-ខែ ប៉ុន្តែ យើងកទៀង ហាក់ដូចជាឃើញព្រះអង្គកំពុងគង់បំពេញកិច្ចការ ដែលជាទីពេញព្រះទ័យព្រះអង្គនៅឡើយ ។

ជីវប្រវត្តិ គុណសម្បត្តិសមត្ថភាពរបស់ព្រះអង្គ ព្រះតេជព្រះគុណ ព្រះពោធិវង្ស ជាទីគោរព បានថ្វាយប្រគេនជូនជ្រាបសព្វគ្រប់អស់ហើយ ខ្ញុំព្រះករុណា-ខ្ញុំគ្រាន់តែសុំថ្វាយប្រគេន ជូន អំពីតម្លៃនៃព្រះត្រៃបិដក ដែលព្រះសពបានចូលរួមប្រែពីបាលីមកជាភាសាជាតិនេះ មានទំហំធំ មហិមា ហើយមានសារៈសំខាន់បំផុត ព្រោះបានផ្ដល់កិត្តិយសប្រសើរ ដល់ប្រទេសជាតិយើង ក្នុងចំណោមប្រទេសជាពុទ្ធសមាជិកដូចគ្នា ។ ក្រៅពីកិច្ចការដទៃទៀតជាច្រើន ព្រះមុនីកោសល បានទុកស្នាព្រះហស្ត ជាក់ស្ដែងមួយ គឺអាគារវត្តនិរោធនេះដែលកសាងឡើងបានដោយលំបាក ក្រៃលែង ជាវត្តមួយមានទេសភាពស្អាតស្អំល្អ ជាទស្សនីយភាពមួយ ដ៏ប្រសើរ ។

ព្រះថេរៈអង្គនេះ ជាបព្វជិតមួយរូបមានឥន្ទ្រីយស្រគត់ស្រគំ សមជាសមណភេទពេញលក្ខណៈ បានបញ្ចេញអាកប្បកិរិយាឲ្យឃើញថា ព្រះអង្គលោកមានអធ្យាស្រ័យល្អ ជាពហុស្សុតមួយរូបបានបូជាជីវិតចំពោះ ព្រះពុទ្ធសាសនា និងប្រទេសជាតិ គួរចាត់ទុកជាព្រះសង្ឃគំរូមួយរូបដ៏

ប្រសើរ ព្រះមហាថេរអង្គនេះ បានយល់ច្បាស់ថា ការបេះដឹងជាការចាំ-បាច់ដើម្បីវឌ្ឍនភាពនិងសេចក្តីរុងរឿងនៃព្រះពុទ្ធសាសនានិងជាតិ ។

ក្នុងព្រះបរមនាម នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ ក្នុងនាមនៃរាជរដ្ឋាភិបាល និងនាមខ្ញុំព្រះករុណា-ខ្ញុំផ្ទាល់ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្លែងជាឧឡារិកនូវសេចក្តីសរសើរយ៉ាងក្រៃលែង និងកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅ ចំពោះស្នាព្រះហស្តរបស់ព្រះតេជព្រះគុណព្រះមុនីកោ-សលនេះ ហើយសូមចូលកាន់មរណសញ្ញា យ៉ាងក្រៀមក្រំ ជាមួយ គ្រួសារញាតិនិងសិស្សានុសិស្ស ដែលកំពុងមានវិយោគទុក្ខគ្របសង្កត់ ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា-ខ្ញុំ សូមបូជាបច្ច័យក្នុងបុណ្យព្រះសព ៥០០០រ ហើយបូជាបច្ច័យ ១០.០០០រ ក្នុងការស្ថាបនាវត្តទិពេធរង្សី ដែលជាការបន្តសកម្មភាពនិងពលិកម្មដ៏ប្រសើរ នៃព្រះតេជព្រះគុណព្រះមុនីកោសល សោម ឈុន ហើយសូមប្រមូលកុសលរាសីទាំងអស់ ដែលបានបំពេញមកទាំងប៉ុន្មានដែលជាកល្យាណកម្ម ប្រគេនចំពោះដួងវិញ្ញាណក្ខន្ធរបស់ព្រះសព សូមព្រះអង្គបានប្រកបដោយសេចក្តីសុខក្នុងលោកសមតាមបំណងកុំបីឃ្លាតឡើយ ។

លុះចប់ព្រះវិយោគកថាហើយ នារីកញ្ញាមួយរូបយកផ្កាបន្ទន់ថ្វាយសម្តេចសហជីវិន, យុវជនយកបាច់ផ្កាបន្ទន់ប្រគេនសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ រួចស្តេចយាងប្រគេនផ្កាបន្ទន់ដាក់លើមឈូសព្រះសព

សម្តេចព្រះសង្ឃនាយកទាំងពីរគណៈនិមន្តប្រគេនផ្កាចន្ទន៍ដាក់លើមឈូស ព្រះសព ។ គមកទៀត ឥស្សរជនមន្ត្រីអគ្គរាជការទាហានស៊ីវិលនិង ពុទ្ធបរិស័ទទាំងឡាយ ក៏បានអញ្ជើញទៅប្រគេនផ្កាចន្ទន៍ជាបន្តបន្ទាប់ ដាក់លើមឈូសនៃសពរូបព្រះសង្ឃ ៧៧ អង្គបង្សុកូល ។ ក្រោយដែល បូជាផ្កាចន្ទន៍រួច សម្តេចសហជីវិនទ្រង់ស្តេចយាងប្រគេនភ្លើងដល់មឈូស នៃព្រះសព ដែលពេលនោះក្រុមតន្ត្រីព្រះរាជទ្រព្យបានបន្លឺបទភ្លេង ព្រះសូរ ស័ព្ទលន្លង់លន្លោចជាសញ្ញាថា រូបនៃព្រះសពដែលជាទីពេញចិត្តនិងជាទី គោរពបូជាខ្ពង់ខ្ពស់ក្រៃលែងនៃសិស្សានុសិស្ស នឹងរលាយបាត់បង់ឈឹង ធ្វើឱ្យមានចិត្តតក់ស្លុតស្រណោះដល់សង្ខារនៃសព្វសត្វ ដែលតាំងនៅក្នុង អនិច្ចតាធម៌ ។

យើងសូមជម្រាបថា ក្នុងឱកាសពិធីឈាបនកិច្ចនៃព្រះសពនេះ ព្រះតោជរង្ស៊ី ហួត តាត បានរៀបរៀងបោះពុម្ពសៀវភៅ ឈ្មោះ រដ្ឋបាលសូត្រ ដោយក្រុមសិស្សានុសិស្សនិងញាតិមិត្តចេញថ្លៃបោះពុម្ព ព្រះវិបុលវង្ស សូរ-ហាយ បានរៀបរៀងសៀវភៅមួយ ឈ្មោះ ពុទ្ធោវាទកថា ដោយលោក ឆន-សុខុម អគ្គលេខាធិការនៅមន្ទីរ ពេទ្យហាយក្រុង ចេញប្រាក់ជាតម្លៃបោះពុម្ព និងសៀវភៅពុទ្ធជីវប្រវត្តិ ដោយលោក ម៉ុញ-ឈួក បានចេញប្រាក់ថ្លៃបោះពុម្ព ចែកផ្សាយជូនពុទ្ធ- សាសនិកជនទាំងឡាយ ដែលបានអញ្ជើញទៅរួមរួមក្នុងពិធីឈាបនកិច្ច

នៅវេលាម៉ោង៥ល្ងាចថ្ងៃដដែល សម្តេចសហជីវិនដោយមានព្រះរាជបរិពារផងដែលហែហមព្រះគន្ធផង ទ្រង់ស្តេចយាងមកកាន់ព្រះធំណាក់វិញ ដោយមានធ្វើពិធីគារវកិច្ចជាព្រះកិត្តិយសដូចកាលស្តេចយាងទៅ ។

ដល់ម៉ោង១៩អុជកាំជ្រួចក្រាំទៀន ។ ម៉ោង២១និមន្តព្រះមហាប៉ាង-ខាត់ វត្តឧណ្ណាលោម សំដែងធម្មទេសនាអំពីអរិយសច្ចកថា ។

ថ្ងៃអាទិត្យទី១៣មីនា១៩៦០ វេលាម៉ោង៦ព្រឹក និមន្តព្រះសង្ឃ៧៧អង្គបង្សុកូល រួចហើយរើសអដ្ឋិធាតុនៃព្រះសពដាក់ក្នុងកោដ្ឋ រួចដំកល់លើបុស្បុកក្នុងបាពាំកំពូលដដែល ។ ម៉ោង៧ប្រគេនយាគូចំពោះព្រះសង្ឃ ។ ម៉ោង១០.៣០នាទី អង្គាសចង្ហាន់ព្រះសង្ឃ៧៧អង្គ ។ ម៉ោង១៩ចំរើនព្រះបរិត្ត ហើយបាននិមន្តព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត សំដែងធម្មទេសនាអំពីបឋមត្រាស់ រួចធ្វើពិធីពុទ្ធាភិសេក ។

ថ្ងៃចន្ទទី១៤មីនា១៩៦០ពេលព្រឹកមានកម្មវិធីដូចថ្ងៃមុន ។ ពេលល្ងាចនៅម៉ោង១៩.៣០នាទីនិមន្តព្រះធម្មឋឹក ៣ អង្គ គឺ ព្រះធម្មលិខិត ម៉ុន-សែស ចៅអធិការវត្តមហាមន្ត្រី ព្រះឃោសធម្ម កៅ-ស៊ឹម ចៅអធិការវត្តលង្កា និងព្រះសាសនសំវរ កាន់-ឯល ចៅអធិការវត្តបទុមភាកម (ចុងព្រែកកោះកោង) អនុគណស្រុកមុខកំពូល (កណ្តាល) ទេសនាសង្គាយនា ជាកិច្ចបញ្ចប់ពិធីបុណ្យតែប៉ុណ្ណោះ ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

អតិគមិ ធាតុ. ទៅក្រៃពេក, ប្រព្រឹត្តកន្លង (វេលា) ។

អតិគម្ភីរ គុ. ដែលជ្រាលជ្រៅក្រៃពេក, ដែលមានអាថ៌កំបាំង, ដែលធ្ងន់ក្រៃពេក ។

អតិគរីយស៍ នបុំ. តម្លៃក្រៃពេក ។ *អតិគរីយសា* (តតិ.) ដោយតម្លៃថ្លៃ ។

អតិគទិ ធាតុ. និយាយក្រៃលែង, គម្រាម ។

អតិគធិ បុំ អតិគាធ្យ នបុំ លោភក្រៃលែង ។

អតិគហន គុ, ដែលជ្រៅក្រៃលែង, ដែលសាំញ៉ាំក្រៃពេក ។

អតិគា ធាតុ. កន្លង (វេលា), ស្លាប់, ឆ្លង ។

អតិគាឍម ក្រិ. វិ. ក្រៃពេកណាស់ ។

អតិគុណ គុ. ដែលមានគុណក្រៃលែង ។

អតិគុរុ គុ. ធ្ងន់ក្រៃលែង ធ្ងន់ណាស់ ។

អតិគ្រហ អតិគ្រាហ បុំ. គោរ៍ងាមួយ ក្នុងគោរ៍ងាទាំង ៨ នៃពួកគ្រហៈ ។

អតិឃន គុ, ឃនក្រៃលែង ។

អតិឃោរ គុ. ឃោរឃៅក្រៃពេក ។

(នៅមានត)

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

---


ឆ្នាំទី ៣២ លេខ ៤ ខែមេសា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ


*ផ្នែកសាសនា* — បញ្ជីរឿង — ទំព័រ

- ពុទ្ធចរិយាវត្ត ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . . ៣៦៧
- ព្រះអភិធម្មបិដក (គម្ពីរបុគ្គលបញ្ញត្តិ) (តមក) លោក ប៊ូ-ប៉ូ រៀបរៀង . ៣៧៧
- មធុរសវាហិនី (តមក) សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ . . . . . ៣៨៩
- មហោសថជាតក (តមក) លោក អ៊ឹម-ភេន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ . . . . . . . . . ៤០៤
- ប្រវត្តិព្រះនាងឥសិទាសីថេរី លោក យូ-អ៊ុង ប្រែចាកភាសាបាលី . . ៤១៣

*ផ្នែកអក្សរសាស្ត្រ*

- រឿងមរណមាតា (តមក) លោក ប៉ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . ៤២៣
- រឿងព្រេងប្រទេសស៊ុយអែដ ភិក្ខុ ម៉ែន-រៀម ប្រែចាកភាសាអង់គ្លេស . ៤៣១
- ស្នាដៃទំពុក លោក ស៊ុន-ធូ រៀបរៀង លោក ចាប-ពិន ពិនិត្យ . . ៤៣៨
- រឿងសាមកុក (តមក) ឧកញ៉ា ទួ-កេន ប្រែ . . . . . ៤៥៧
- ពាក្យប្រែធម៌ (តមក) លោក នាង-ហ៊ួ រៀបរៀង លោក សម-ថាំង ពិនិត្យ ៤៦១

*ផ្នែកកំណត់និងប្រវត្តិការណ៍*

- មហាសន្និបាតសមាគមមិត្តពុទ្ធិកវិទ្យាល័យលើកទី ១១ លោក ភ៉ុយ-ប៊ុក រៀបរៀង ៤៦៨
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . ៤៨០



មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជា រ ២៣០.០០

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
Publiée par l'Institut Bouddhique de Phnom Penh


## sommaire

### Partie religieuse :


— La Vie du Buddha par Prah maha PANG-KHAT. . . 361

— Prah Abhidhammapitaka (Puggalappannatti) (suite) par M. BOU-PO 377

— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM, revu et corrigé par Vén-NHEAN CHHOEUN . . . . . . . . . . . . . 389

— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON' revu par Vén-KEM-TO 404

— L'histoire de Prah Neang Isidasi theri traduite du pali par M. YOU-OUN . . . . . 413


### Partie littéraire :


— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . . 423

— Contes et Légendes suédois traduits de l'anglais par le bonze MEN RIEM . . . 431

— L'oeuvre du père par M. SIN-PHO revu et corrigé par M. CHAP-PIN . . . . . . 438

— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 457

— Activités de la Commission culturelle par M. NEANG-HU revues et corrigées par M. SAM-THANG. . . . 461


### Notes et Chroniques :


— Onzième assemblée générale de l'Association des Amis du Lycée bouddhique par M. RAY BUC. . . . . 468

— Dictionnaire Sanscrit-khmer (suite) par Vén-PANG-KHAT 480


---


Prix d'abonnement annuel (comprenant 12 numéros): 230$00 .

ផ្នែកសាសនា

# ពុទ្ធជីវប្បវត្តិ

ព្រះមហា ជាំង-ខាត់ រៀបរៀង

## ជម្ពូទ្វីប

តាំងពីបុរាណកាល ភូមិប្រទេសដ៏ធំទូលាយ មានអារ្យធម៌ចំរើនបរិបូណ៌ ជាទីប្រជុំកើតនៃសាសនាធំៗ ដូចព្រាហ្មណសាសនា ពុទ្ធសាសនាជាដើម ជាទីកើតចំណេះវិជ្ជា ប្រពៃណី រឿងនិទានផ្សេងៗ ផ្សាយទូទៅពេញសកលលោក នៅក្នុងកាលបច្ចុប្បន្ននេះហៅថាឥណ្ឌៀ។

កាលដើមឡើយ គេមិនហៅថាឥណ្ឌៀទេ គេហៅថាភារតវស៌ ឬជម្ពូទ្វីប, ពាក្យថា ឥណ្ឌៀនេះ ក្លាយចេញមកពីពាក្យដើមថា សិន្ធុ ជាឈ្មោះទន្លេមួយ ជាគោលចារឹកសំខាន់នៅភាគខាងលិចប្រទេសឥណ្ឌៀសព្វថ្ងៃនេះ ។ អ្នកអស្សិរិកប្រទេស កាលគេមកកាន់ជម្ពូទ្វីប បានស្គាល់ទន្លេនេះមុន តែគេហៅឈ្មោះទន្លេមិនច្បាស់ ហៅក្លាយទៅជាឥណ្ឌុស (Indus) វិញ ។ ពាក្យថាឥណ្ឌុសនេះ បានយារក្លាយមួយលើកទៀតទៅជាពាក្យថាឥណ្ឌៀ (India) ក្នុងបច្ចុប្បន្ននេះ ។ លោកទាំងមូលសព្វថ្ងៃបបួលគ្នាហៅប្រទេសនេះថា ឥណ្ឌៀ ឬឥណ្ឌូស្ថាន (Hindoustan) ។

## ប្រជាជនឥណ្ឌៀ

ពីសម័យបុរាណ គេចែកជម្ពូទ្វីបជា ២ ជនបទធំៗគឺ មជ្ឈិមជនបទ១

បច្ចន្តជនបទ ។ ការចែកជា២នេះ មានមកយូរអង្វែងហើយ តាមទំនង ប្រហែលជាចែកតាំងជំនាន់ពួកអរិយកៈ ដែលលុកលុយចូលមកប្រទេសឥណ្ឌា ។ កាលនោះមានរឿងដំណាលថា ពួកអរិយកៈតាំងទីឋាននៅខ្ពង់រាបបព៌តាប៉ាមីរ (Pamir) ដែលជាដំបូលពិភពលោក ជាទោលិកាកកើតអរិយកជន មានជាតិភូមិនៅអុក្សុស ( Oxus) ភូមិកាគកូកាស (Caucase) ។ ចំណោមក ពួកអរិយកជនទាំងនេះ ជាពួកភានេចរធ្វើដំណើរចេញពីទីឋានកំណើតរបស់ខ្លួនទៅកាន់ទីឋានផ្សេងៗ នៃពិភពលោក ដើម្បីតាំងទីឋានលំនៅអាស្រ័យចិញ្ចឹមជីវិត ។ ដំណើរពនេចរនេះ កើតទៅជាប្រពៃណីប្រទេសឥណ្ឌាដែលមានប្រាកដក្នុងទិនានជាតកផ្សេងៗ ថា ព្រះរាជាអង្គនោះ មានព្រះអគ្គមហេសី មានព្រះរាជបុត្រព្រះរាជធីតា, លុះព្រះអគ្គ-មហេសីទ្រង់ទិវង្គតទៅ ព្រះរាជាទ្រង់លើកព្រះនាងដទៃទៀតទុកក្នុងឋានៈជាអគ្គមហេសី បើមានព្រះរាជបុត្រ ព្រះអគ្គមហេសីអង្គនេះ តែងតែចូលទៅគាល់ព្រះរាជស្វាមី ហើយសូមព្រះរាជ្យថ្វាយព្រះរាជបុត្ររបស់ខ្លួន ឯព្រះរាជាតែងតែភ្លាត់ព្រះឱស្ឋថ្វាយរាជ្យដល់ព្រះរាជបុត្រអង្គ ជាអនុជនេះជាធម្មតា ហើយតែងតែត្រាស់បញ្ជាឱ្យព្រះរាជបុត្រព្រះរាជធីតាច្បងៗឲ្យទៅសាងរាជធានីថ្មីតាមតាប់ចិត្ត ។ រឿងភ្លាត់ព្រះឱស្ឋនេះ មិនមែនជាការភ្លាត់ធម្មតាទេ គឺជាប្រពៃណីរបស់ព្រះរាជា ដែលទ្រង់មានព្រះរាជបំណងនឹងពង្រីកព្រះរាជាណាចក្រព្រះអង្គឲ្យធំទូលាយទៅទៀត ។

រឿងនេះកើតចេញពីពួកអរិយកជន ក្នុងកាលដែលធ្វើដំណើរទៅកាន់ទីផ្សេង ៗ តាមប្រវត្តិសាស្ត្រ យើងបានដឹងថា អរិយជននេះបែកសាខាជា២ មួយទៅខាងលិចទៅខាងអឺរ៉ុប មួយទៅខាងកើតទៅខាងអាស៊ី ៗ ពួកនេះគេហៅថាអរិយៈ ខ្លះសរសេរថា អារ្យៈ អរិយ៉ែន ឬអរ្យ៉ែន ឬក៏អារ្យ៉ែន (f. Aryas ou Aryens; A. Aryan) ពួកអរិយៈនេះហើយជាបុព្វបុរសនៃត្រកូលធំដែលហៅថា ហិណ្ឌូ-អឺរ៉ុប ឬហិណ្ឌូ-អរ្យ៉ែន ៗ សាខាអរិយៈធំមួយ ដែលពនេចរទៅខាងកើត ក៏បានទៅអាស្រ័យនៅប្រទេសឥណ្ឌា ហើយបែងចែកភូមិប្រទេសឥណ្ឌាឲ្យទៅជាពីរដូច្នេះ ឲ្យឈ្មោះទីខ្លួនទៅថា មជ្ឈិមជនបទ ឲ្យឈ្មោះទីអ្នកនៅដើមថា បច្ចន្តិមជនបទ តែមជ្ឈិមជនបទនេះ មានសីមាព្រំប្រទល់មិនប្រាកដទៀងទាត់ទេ ជួនកាលរីកធំទៅ ជួនកាលរួញតូចមកវិញ តាមជំនាន់ផ្សេងដែលមានអំណាចតិចច្រើន ៗ បើនិយាយក្នុងសម័យពុទ្ធកាលមានសេចក្ដីមួយចែងក្នុងគម្ពីរមហាវគ្គចម្មក្ខន្ធកថា:(១)

"ម្នាលភិក្ខុទាំងឡាយ! បច្ចន្តិមជនបទនោះគឺ ទិសខាងកើត មាននិគមឈ្មោះកជង្គល ខាងនាយកជង្គលនិគមនោះ មាននិគមឈ្មោះមហាសាល ខាងនាយនិគមឈ្មោះមហាសាល

១ មហាវគ្គ ចម្មក្ខន្ធកៈសៀវ.ភ ទំព័រ:២១៤ ។

នោះជា បច្ចន្តិមជនបទ ខាងអាយចូលមកជា មជ្ឈិមជនបទ ។ ក្នុងទិសអាគ្នេយ៍ មានស្ទឹងឈ្មោះ សល្លវតី ខាងណាយស្ទឹងឈ្មោះសល្លវតីនោះជា បច្ចន្តិមជនបទ ខាងអាយចូលមកជា មជ្ឈិមជនបទ ។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះ សេតកណ្ណិក ខាងណាយនិគមនោះជា បច្ចន្តិមជនបទ ខាងអាយចូលមកជា មជ្ឈិមជនបទ ។ ក្នុងទិសខាងលិច មានស្រុកព្រាហ្មណ៍មួយឈ្មោះ ថូណគ្រាម ខាងណាយស្រុកថូណគ្រាមនោះជា បច្ចន្តិមជនបទ ខាងអាយចូលមកជា មជ្ឈិមជនបទ ។ ក្នុងទិសខាងជើង មានភ្នំឈ្មោះឧសីរធជ ខាងណាយភ្នំនោះទៅជា បច្ចន្តិមជនបទ ខាងអាយចូលមកជា មជ្ឈិមជនបទ” ។

*បើនិយាយតាមភូមិសាស្ត្រ គេបែកជា២ដូច្នេះគឺៈ*

*ក)អាយាវត៌ ឋិតៈនៅចន្លោះភ្នំហិមាល័យនឹងភ្នំវិន្ធ្យា ដែលហៅសព្វថ្ងៃនេះថា ហិណ្ឌូស្ថាន គឺប្រទេសនៅភាគខាងជើង;*

*ខ)ទក្ខិណាបថ បានដល់ទីឋានដែលហៅសព្វថ្ងៃនេះថា ដេកង់*

(Dekkan) គឺប្រទេសឥណ្ឌាភាគខាងត្បូង ។

តាមដំណើរនិទាននេះ យើងឃើញថា " អរិយជន " នោះមិនមែនជាអ្នកដើមកំណើតប្រទេសឥណ្ឌាទេ ឯអ្នកដើមកំណើតប្រទេសនោះ គឺជាតិមួយឈ្មោះ ទ្រាវីឌ ជាជនធ្លាប់មានអរិយធម៌ខ្ពង់ខ្ពស់ ហើយមិនចុះថយជាងអរិយជនដែលចូលមកថ្មីនោះទេ ។ តាមប្រវត្តិសាស្ត្រលោកថា ជនទ្រាវីឌដែលសុខចិត្តចាញ់អរិយជននោះ ដោយខ្លួនមិនចេះធ្វើគ្រឿងចក្រ (១) សម្រាប់ច្បាំងតយុទ្ធនឹងសត្រូវប៉ុណ្ណោះ ឯពួកអរិយជនចេះធ្វើរថមានកង់កាត់ផ្ទះ ហើយចូលតយុទ្ធសត្រូវ ។ លុះពួកអរិយជនបានជ័យហើយក៏តាំងនិវាសនទីលំនៅ គេប្ដូរចិញ្ចឹមជីវិត ចែកភូមិប្រទេសឥណ្ឌាជាបច្ចន្តជនបទនិងមជ្ឈិមជនបទផ្លូវច្បាស់ មិនតែប៉ុណ្ណោះទេ ដើម្បីកុំឲ្យលាយជាតិខ្លួន ពួកអរិយជនបានចែកបាន មនុស្សជាជាន់ថ្នាក់ទៀត ដូចមានសេចក្ដីប្រាកដថា

" ព្រះព្រហ្មយកមាត់មកសាងជាព្រាហ្មណ៍ យកដើមដៃមកសាងជា

---

១ អ្នកប្រាជ្ញប្រវត្តិសាស្ត្រយល់ថា ពួកអរិយៈចេះធ្វើកង់មុនគេ ដោយយកទេពតាសុរិយមកប្រតិស្ឋមុនដំបូង ហើយកង់ក កង់នេះកើតទៅជាព្រះសីលធម៌ ច្បាប់ ពុំនេះជាព្រះគ្រឿងសំគាល់សេចក្ដីចំរើនដែលហៅថា ស្វស្តិកៈ 卐 ។ ព្រះគុរុជាម្ចាស់យើង ក៏ទ្រង់យកចក្រជាសីលធម៌ដែរ គឺចទ្រង់ប្រកាសធម្មចក្កប្បវត្តនសូត្រ។ពុទ្ធសាសនាលទ្ធិមហាយានធ្លាក់ស្វស្តិកៈនេះ នៅលើព្រះឧរព្រះពុទ្ធរូប ។ ព្រះបាទអសោកមហារាជ ក៏យកចក្រនេះធ្វើត្រា គឺជាអំណាចរបស់ព្រះអង្គដែរ ។

ក្ស័ត្រ យកភ្លៅមកសាងជាវេស្សៈ យកបាទជើងមកសាងជា សុទ្ទៈ(អ្នកគ្រូអ្នកស៊ីឈ្នួល ) ហើយបញ្ញត្តគ្រឿងស្លៀកពាក់ឲ្យមានពណ៌ខុសគ្នា គឺព្រាហ្មណ៍ស្លៀកពាក់ពណ៌ស, ក្សត្រស្លៀកពាក់ពណ៌ក្រហម; វេស្សៈស្លៀកពាក់ពណ៌លឿង, សុទ្ទៈស្លៀកពាក់ពណ៌ខ្មៅ " ។

ដោយហេតុនេះ ជាន់ថ្នាក់មនុស្ស ទើបហៅថា "វណ្ណ" (១) ។ តាមតួព្យញ្ជនៈ ពាក្យថាវណ្ណៈនេះប្រែថា "ពណ៌" ព្រោះយកគ្រឿងស្លៀកពាក់មានពណ៌ខុសគ្នាជាគ្រឿងសំគាល់ តែក្នុងបច្ចុប្បន្នកាលនេះ ពាក្យថា វណ្ណៈ ប្រែថា „គេ„ ទៅតាមន័យសព្វនេះវិញ (ឬថា ពួកអរិយៈជាស្បែកស ជនទ្រាវីឌជាស្បែកខ្មៅ ) ។ កាលពួកអរិយៈបានជាធំនៅលើផែនដីនេះហើយ ចាប់យកអ្នកដើមកំណើតប្រទេស ដែលឈ្មោះថាទ្រាវីឌនោះមកធ្វើឈ្លើយរបស់ខ្លួន ហើយហៅថា ទស្យុ ប្រែថា "សត្រូវរបស់ព្រះឥន្ទ្រ" ព្រោះព្រះឥន្ទ្រជាទេពតារបស់ខ្លួន ឬថា ឈ្លើយតមកពាក្យថា ទស្យុ នេះ ក្លាយទៅជាទាសៈប្រែថា „ខ្ញុំ„ ទៅវិញ ដូចសព្វថ្ងៃនេះ ។ មួយទៀត ពួកអរិយជន ហៅជនទ្រាវីឌថា មិលក្ខ ប្រែថា អ្នកស្រុកក្នុង ទៅជា „អ្នកព្រៃ„ វិញ ជាការបន្ថោកបន្ទាបមើលងាយ។

ព្រះសម្មាសម្ពុទ្ធនៃយើងទ្រង់យកកំណើតក្នុងត្រកូលក្ស័ត្រ អរិយក-

---

១-អម្ពដ្ឋសូត្រ ទីឃ. សៀវ. ១៤ ទំព័រ ២២៦ ។

ជាតិ កាលទ្រង់បានត្រាស់ដឹងជាអង្គព្រះសម្មាសម្ពុទ្ធហើយ ទ្រង់ពុទ្ធដំណើរប្រោសវេនេយ្យសត្វ តែក្នុងប្រទេសឥណ្ឌៀភាគខាងជើង ដែលហៅថា អារ្យាវតិ បានជាមានរឿងនិយាយច្រើន តែបែកខាងជើងជាងខាងត្បូង ។

រដ្ឋទាំងឡាយទាំងតូចទាំងធំ ក្នុងសម័យពុទ្ធកាលមាន ៣៥ រដ្ឋគឺ

១– រដ្ឋ អង្គៈ រាជធានី ចម្ប៉ា

២ " មគធៈ " រាជគ្រឹះ

៣ " កាសី " ពារាណសី

៤ " កោសល " សាវត្ថី

៥ " វជ្ជី " វេសាលី

៦ " មល្លៈ " កុសាវតី ( តមកបែកជា២គឺកុសិនារា និងបាវ៉ា )

៧ " ចេតីយ " សោត្ថិវតី

៨ " វង្សៈ " កោសម្ពី

៩ " កុរុ " ឥន្ទបត្ត

១០ " បញ្ចាល " កម្បិលៈ

១១ " មច្ឆៈ " សាគលៈ

១២ ដែន សុរសេន: ភាសាទី មធុរា

១៣ " អស្សក: " ប៉ោតលិ

១៤ " អវន្តី " ឧជ្ជេនី

១៥ " គន្ធារ: " តក្កសិលា

១៦ " កម្ពោជ: " ទ្វារក:

១៧ " សក្ក: " កបិលវត្ថុ

១៨ " កោលិយ: " ទេវហ:ឬ រាមគ្រាម

១៩ " ភគ្គ: " សុង្សុមារគីរ:

២០ " វិទេហ: " មិថិលា

២១ " អង្គុត្តរាប: " អាបណ: ( ជានិគម)

២២ " សិវិ (១) " ( មិនប្រាកដ )

២៣ " សោវីរ: " រោរុក:ឬ រោរុវ:

២៤ " វិរាត: " ( មិនប្រាកដ)

២៥ " មច្ឆ: " ហតល:

២៦ " ទុព្រាន: " ( មិនប្រាកដ )

---

១. លោករីសដេវីដ (Rhys Davids) រកឃើញ តាំងពីលេខ ២២ ដល់លេខ ២៨ (Pali English Dictionary Pali lext Sosiety) ។

២៧ រដ្ឋ ពូលិ រាជធានី អលកប្បៈ

២៨ ,, កាឡាមៈ ,, កេសបុត្តៈ

២៩ ,, ភគ្គៈ (១) ,, (តាំងនៅបេគ្គាល់សព្វថ្ងៃ)

៣០ ,, មោរិយៈ (២) ,, បិប្ផលិវន

៣១ ,, សុហ្មៈ (៣) ,, ប៉ូរី

៣២ ,, សមតដ ,, (មិនប្រាកដ)

៣៣ ,, កាមរូប ,, (មិនប្រាកដ)

៣៤ ,, បុណ្ឌ្រ ,, (មិនប្រាកដ)

៣៥ ,, សាកៈ ,, វិទិសា ។

រដ្ឋដែលមានឥទ្ធានុភាពខ្លាំងជាងគេមាន ២ គឺ

ក) រដ្ឋកោសលជារដ្ឋធំទីមួយផ្សាយឥទ្ធានុភាពទៅលើរដ្ឋច្រើនមាន រដ្ឋកាសីជាដើម នឹងត្រកូល២គឺ ត្រកូលកោលិយ ទីក្រុងរាមគ្រាម ១ នឹងត្រកូលសក្កៈ ទីក្រុងកបិលពស្តុ ១ ។ រដ្ឋកោសលនេះ មានអាណាខេត្រធំទូលាយជាងរដ្ឋមគធៈ,

ខ) រដ្ឋមគធៈ ជារដ្ឋធំទីពីរ មានឥទ្ធានុភាពប៉ុនគ្នានឹងរដ្ឋកោសល

---

១ - លោកតោមាស (Ed. thomas) រកឃើញរដ្ឋមួយគឺលេខ ២៩ ។ ២ - លោក ពិមលចរ័ន ឡ (Bimala Charan Law) រកបាន ១ គឺលេខ ៣០ ។ ៣ - លោក ល្វី-ហ្វីណូត៍ (L. Finot) រកឃើញ ៥ រដ្ឋគឺលេខ ៣១ ទៅដល់លេខ ៣៥ ។

ដែរ តែក្រោយសម័យពុទ្ធកាល រដ្ឋមគធៈ វាយដណ្តើមយករដ្ឋកោសលបាន ត្រឡប់ជាធំជាងរដ្ឋកោសលទៅវិញ ។

សម័យពុទ្ធកាល រដ្ឋទាំងឡាយនៅប្រទេសឥណ្ឌាច្រើនតែរួមចូលគ្នា ដូចជាដែនអង្គៈរួមនឹងដែនមគធៈ ព្រះបាទពិម្ពិសារជាស្តេច ក្រុងរាជ-គ្រឹះជារាជធានី, ដែនកាសីរួមនឹងដែនកោសល ព្រះបាទបសេនទិជាស្តេច ក្រុងសាវត្ថីជារាជធានី, ដែនវជ្ជីរួមនឹងដែនមល្លៈ, ដែនចេតិយរួមនឹងដែនវំសៈ, ដែនកុរុរួមនឹងដែនបញ្ចាលៈ, ដែនមច្ឆៈរួមនឹងដែនសុរសេនៈ ជាដើម ។ ក្នុងសម័យចែកព្រះធាតុ យើងឃើញថា ដែនវជ្ជីនិងមល្លៈ ផ្សេងរដ្ឋបាលគ្នា មិនមានស្តេចសោយរាជ្យទេ មានតែនាយកត្រួតត្រា ។

ឯសក្កជនបទ ក្រុងកបិលពស្តុជាជាតិភូមិនៃព្រះបរមសាស្តាចារ្យនៃយើងទាំងឡាយ ឋិតនៅទិសនិរតីប្រទេសនេប៉ាល់ ខាងជើងប្រទេសឥណ្ឌា ជារដ្ឋតូចមួយនៅក្រោមអំណាចព្រះបាទបសេនទិកោសលរាជ ។ កាលទ្រង់គង់ធរមាននៅឡើយ ក៏ទ្រង់មានព្រះពុទ្ធដីកា ត្រាស់ចំពោះវាសេដ្ឋៈថា (១)

«ម្នាលវាសេដ្ឋៈ! ព្រះរាជាបសេនទិកោសលជ្រាបថា ព្រះសមណគោតមជាបុគ្គលខ្ពង់ខ្ពស់ ចេញចាកសក្យត្រកូលមក

១ អគ្គញ្ញសូត្រ បាដិកវគ្គ ទីឃ. សៀវ. ១៨ ទំព័រ ១៦៨ ។

ទ្រង់ព្រះផ្នួស ពួកសក្យជាអ្នកនៅជិត នៅក្រោមអំណាចនៃព្រះបាទបសេនទិកោសល តែងធ្វើបដិសណ្ឋារៈ ធ្វើអភិវាទនកម្ម ក្រោកឡើងទទួលធ្វើអញ្ជលីកម្ម និងសាមីចិកម្មចំពោះព្រះរាជាបសេនទិកោសល ។ ម្នាលវាសេដ្ឋៈ ! ពួកសក្យធ្វើបដិសណ្ឋារៈជាដើម ចំពោះព្រះរាជាបសេនទិកោសលយ៉ាងណា ព្រះរាជាបសេនទិកោសលធ្វើបដិសណ្ឋារៈជាដើមចំពោះតថាគត ( កាលតថាគតបួសហើយ) យ៉ាងនោះដែរ " ។

*មួយទៀត , កាលព្រះបរមពោធិសត្វទ្រង់ទើបបព្វជ្ជាថ្មី ៗ ទ្រង់បាន សន្ទនានឹងព្រះបាទពិម្ពិសារក្នុងក្រុងរាជគ្រឹះថា* (១)

"បពិត្រមហារាជ! ត្រង់ទៅមានជនបទមួយនៅប្របភ្នំហិមវន្ត ជាជនបទបរិបូណ៌ដោយទ្រព្យ និងអ្នកមានព្យាយាម អាស្រ័យនៅនឹងដែនកោសល មានជនមួយពួក ជាអាទិច្ចគោត្រ មានជាតិជាសាកិយៈ តថាគតបានចេញចាកត្រកូលនោះមកបួស"។

១- បព្វជ្ជាសូត្រ មហាវគ្គ សុត្តនិបាត សៀវ. ៥៥ ទំព័រ ១៣៤ ។

# ដើមកំណើតសក្យវង្ស

*កាលពីអតីតកាលយូរណាស់ហើយ មានព្រះរាជាមួយព្រះអង្គព្រះនាមព្រះបាទឧក្កាករាជ[១] សោយរាជសម្បត្តិក្នុងនគរមួយ លើកព្រះរាជកតិទីជាព្រះអគ្គមហេសី មានព្រះរាជបុត្រ ៤ ព្រះអង្គ[២] ។ លុះព្រះអគ្គមហេសីអង្គនេះទិវង្គតទៅ ព្រះរាជាលើកព្រះនាងដទៃទៀតជាព្រះអគ្គមហេសី មានព្រះរាជបុត្រ ១ អង្គ ព្រះនាមថាជន្តុ ដូចមានសេចក្តីប្រាកដក្នុងអម្ពដ្ឋសូត្រថា[៣]*

«ម្នាលអម្ពដ្ឋ! កាលពីដើមមានព្រះរាជាព្រះនាមឧក្កាកៈ មានព្រះមហេសីជាទីស្រឡាញ់ ជាទីពេញព្រះទ័យ មានបំណងនឹងបង្វែររាជសម្បត្តិ ថ្វាយព្រះរាជបុត្ររបស់ព្រះមហេសីអង្គនោះ ហើយក៏បង្វេះពួកព្រះរាជកុមារជាច្បង ៤ ព្រះអង្គ គឺព្រះរាជកុមារនាមឧក្កាកមុខៈ ១ ករណ្ឌៈ ១ ហត្ថិនិកៈ ១ សិនិបុរៈ ១ ឲ្យចេញពីដែន ។ ព្រះរាជបុត្រទាំងនោះ លុះព្រះវរបិតាបង្វេះចេញអំពី

---

១. សំ. ឥក្សាកុ ។ ២. គម្ពីរជំនាន់ក្រោយថា «មានព្រះរាជធីតា ៥ អង្គគឺ បិយា សុប្បិ-យា អានន្ទា ១ វិជិតា ១ វិជិតសេនា ១ ។ ៣- អម្ពដ្ឋសូត្រ ទីឃ. សៀវ ១៤ ទំព័រ ២២៧ ។

ដែនហើយ ក៏នាំគ្នាទៅអាស្រ័យនៅក្នុងដងព្រៃឈ្មោះ មហាសាក ទៀបឆ្នេរស្រះបោក្ខរណីរជិតខាងហិមវន្តប្រទេស ។ ព្រះរាជបុត្រទាំងនោះ បានសម្រេចការរួមនៅជាមួយនឹងពួកព្រះភគិនីរបស់ខ្លួន ព្រោះខ្លាចក្រែងក្លាយខូចជាតិ ។

ម្នាលអម្ពដ្ឋ ! គ្រានោះ ព្រះបាទឱក្កាករាជបានត្រាស់ហៅពួកអាមាត្យមកសួរថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ! កុមារទាំងឡាយទៅនៅក្នុងទីណា ? រាជអាមាត្យក្រាបទូលថា ៎បពិត្រព្រះសម្មតិទេព ! មានដងព្រៃមួយឈ្មោះមហាសាក នៅទៀបឆ្នេរស្រះបោក្ខរណីខាងហិមវន្តប្រទេស ឥឡូវនេះ ព្រះរាជកុមារទៅនៅក្នុងទីដងព្រៃនោះ ព្រះរាជកុមារទាំងនោះ សម្រេចការនៅរួមជាមួយនឹងពួកព្រះភគិនីរបស់ខ្លួន ដោយហេតុខ្លាចក្រែងក្លាយខូចជាតិ ។

គ្រានោះ ព្រះបាទឱក្កាករាជបន្លឺឧទានវាចាថា ៎អើហ្ន៎! កុមារទាំងឡាយពេញជាអង់អាច អើហ្ន៎! កុមារទាំងឡាយ

ពេញជាមោះមុតមែន" ។

ម្នាលអម្ពដ្ឋ! ចាប់ដើមពីកាលនោះមក ពួកសក្យវង្សក៏កើតប្រាកដឡើង ។ ព្រះបាទឱក្កាករាជនោះហើយ ជាបុព្វបុរសរបស់ពួកសក្យៈ" ។

ឯព្រះជេដ្ឋភគិនីមានព្រះច័យប្រតិព័ទ្ធ នឹងព្រះរាជាក្រុងពារាណសី ហើយសម្រេចការនៅរួមជាមួយគ្នា កើតបានទៅជាវង្សមួយទៀត ហៅថា កោលិយវង្ស(១) ។

បំណោរចីរកាលតមក ព្រះរាជាច្រើនអង្គសោយរាជសម្បត្តិក្នុងក្រុងកបិលព័ស្តុជាលំដាប់តរៀងគ្នាមក រហូតដល់ព្រះបាទជយសេន ។ ព្រះរាជាអង្គនេះ មានព្រះរាជបុត្រមួយអង្គ ព្រះនាមសីហហនុរាជ និងព្រះរាជធីតា១អង្គព្រះនាមយសោធរា ។ អំណើះតអំពីព្រះបាទជយសេនទៅ ព្រះបាទសីហហនុឡើងសោយរាជ្យ បានព្រះនាងកាញ្ចនាជាព្រះរាជធីតា

១–ព្រះរាជាក្រុងពារាណសីមួយព្រះអង្គ ទ្រង់កើតព្រះរោគព្យាធិ ហើយលះបង់រាជសម្បត្តិទៅនៅព្រៃ ដោយរកផលក្នុងព្រៃជាអាហារ ដោយទៅប្រទះផ្លែឈើថ្នាំ បានជាព្រះរោគនោះទៅ ហើយស្តេចចរយាត្រាតទៅមុខទៀត បានជួបព្រះរាជធីតាជាព្រះជេដ្ឋភគិនីនៃសាក្យវង្ស ដែលកើតរោគព្យាធិដែរ ទ្រង់បានជួយព្យាបាលឲ្យជាព្រះរោគហើយក៏សម្រេចការនៅរួមសំវាសជាមួយគ្នា ។

នៃព្រះបាទជនាធិបតិរាជវាន់កោលិយវង្សជាព្រះអគ្គមហេសី មានព្រះរាជបុត្រ៤ព្រះអង្គគឺ សុទ្ធោទន ១ សុក្កោទន ១ អមិតោទន ១ ធោតោ-ទន ១, ព្រះរាជធីតា ២ ព្រះអង្គគឺ អមិតា ១ បមិតា ១ ។

ព្រះរាជវាន់ៈកោលិយវង្ស សោយរាជសម្បត្តិជាសន្តតិវង្ស រៀងរហូតមកទល់ព្រះបាទជនាអធិបតិរាជ ។ ព្រះរាជាអង្គនេះ មានព្រះរាជបុត្រ ១អង្គព្រះនាមអញ្ជនៈ, ព្រះរាជធីតា១អង្គព្រះនាម កាញ្ចនា ។ ព្រះបាទអញ្ជនៈ បានអភិសេកជាមួយនឹងព្រះនាងយសោធរា ជាព្រះរាជធីតានៃព្រះបាទជ័យសេនជាព្រះអគ្គមហេសី មានព្រះរាជបុត្រ២អង្គគឺសុប្ប-ពុទ្ធ១ទណ្ឌបាណិ១ មានព្រះរាជធីតា២ព្រះអង្គគឺ មាយា១បជាបតិ១ ។

ព្រះបាទសុទ្ធោទនៈ បានអភិសេកជាមួយនឹងព្រះនាងមាយា ជាព្រះរាជធីតានៃព្រះបាទអញ្ជនៈ ជាព្រះអគ្គមហេសី ។ ក្រោយដែលព្រះបរមពោធិសត្វប្រសូតបាន ៧ ថ្ងៃ ព្រះនាងមាយាជាព្រះវរមាតាទិវង្គតទៅ ព្រះបាទសុទ្ធោទនៈ បានលើកព្រះនាងបជាបតី ជាព្រះរាជកនិដ្ឋភគិនីនៃព្រះនាងមាយាជាព្រះអគ្គមហេសី មានព្រះរាជបុត្រ១អង្គគឺនន្ទកុមារ, មានព្រះរាជធីតា ១ អង្គគឺ នាងជនបទកល្យាណីរូបនន្ទា ។

ឯសុប្បពុទ្ធកុមារ[១] បាននាំអមិតាជាព្រះរាជធីតានៃព្រះបាទសីហហនុរាជជាព្រះជាយា មានព្រះរាជបុត្រ១អង្គគឺទេវទត្ត មានរាជធីតា១អង្គគឺពិម្ពាយសោធរា ។

សុក្កោទនៈ មានរាជបុត្រ១អង្គគឺអានន្ទ, អមិតោទនៈមានព្រះរាជបុត្រ២អង្គគឺ មហានាម១ អនុរុទ្ធ១ មានរាជធីតា១ អង្គគឺ រោហិណី ។

១-ព្រះនាមក្សត្រទាំងពីរវង្សនេះក្នុងគម្ពីរទាំងឡាយជាថេរវាទក្តី មហាយានក្តី មិនប្រាកដដូចគ្នាទេ ផ្សេងគ្នាច្រើនអន្លើណាស់ ទាំងចំនួនក៏មិនស្របគ្នាផង នេះតែមានលើសខ្វះគ្នាជាដរាប ។

(នៅមានត)

# ព្រះអភិធម្មបិដក

## គម្ពីរបុគ្គលបញ្ញត្តិ

(តមក)

លោក ប៊ូ-ប៊ូ រៀបរៀង

---

### តិកបុគ្គល

ក្នុងលំដាប់អំពីទុកបុគ្គល ព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់សំដែងនូវបុគ្គលម្តងបីពួក ៗ មានដូចថា បុគ្គលមានចក្ខុខ្វាក់ទាំងពីរខាងមួយពួក, បុគ្គលមានចក្ខុខ្វាក់ម្ខាងមួយពួក, បុគ្គលមានចក្ខុភ្លឺទាំងពីរខាងមួយពួក ។

បុគ្គលមានចក្ខុខ្វាក់ទាំងពីរខាងនោះ បានដល់បុគ្គលឥតបញ្ញា មិនបានដឹងនូវបុណ្យនិងបាប ។

បុគ្គលមានចក្ខុខ្វាក់ម្ខាងនោះ, បានដល់បុគ្គលដឹងតែបុណ្យ មិនដឹងបាប និងដឹងតែបាប មិនដឹងបុណ្យ ។

បុគ្គលមានចក្ខុភ្លឺទាំងពីរខាងនោះ បានដល់បុគ្គលមានបញ្ញា ដឹងនូវបុណ្យ និងបាបទាំងពីរប្រការ ។

បុន ច បរំ ប្រការមួយទៀត តយោ បុគ្គលា បុគ្គលបីពួកទៅមានទៀត គឺ អវកុជ្ជបញ្ញាបុគ្គល មួយពួក, ឧច្ឆង្គបញ្ញាបុគ្គល មួយពួក, ពុថុបញ្ញាបុគ្គល ពួកមួយ ។

អវកុជ្ជបញ្ញាបុគ្គល នោះ បានដល់បុគ្គលមានបញ្ញាដូចឆ្នាំងផ្កាប់ ។

ឧច្ឆង្គបញ្ញាបុគ្គល នោះ បានដល់បុគ្គលមានបញ្ញាដូចថ្នក់ ។

ភូរិបញ្ញាបុគ្គល នោះ បានដល់បុគ្គលមានបញ្ញាដ៏ក្រាស់ជ្រាលជ្រៅដូចផ្ទៃផែនដី ។

ចតុក្កបុគ្គល

សម្តេចព្រះមហាមុនី ទ្រង់ត្រាស់ទេសនានូវបុគ្គលបីពួករួចហើយ ទើបទ្រង់សំដែងនូវបុគ្គលបួនពួកតទៅទៀតថា៖

ឆេកោ ច បុគ្គលឈ្លាសវៃប៉ិនប្រសប់មួយពួក, អឆេកោ បុគ្គលមិនឈ្លាសប្រសប់មួយពួក, សម្បជានោ បុគ្គលដឹងជុំវិញឬដឹងសព្វគ្រប់មួយពួក, បដិស្សតោ បុគ្គលប្រកបដោយស្មារតីតាំងមាំមួនមួយពួក ។

ទក្ខបុគ្គលនោះ បានដល់បុគ្គលអ្នកឈ្លាសវៃក្នុងសិល្បសាស្ត្រ អាចធ្វើការឲ្យសម្រេចប្រយោជន៍ដល់ខ្លួនបាន ដូចព្រះបាទកដ្ឋវាហនរាជកាលដើមឡើយ ជាអ្នកចេះដឹងឈ្លាសវៃក្នុងសិល្បសាស្ត្រខាងវិជ្ជាជាងឈើ មានសេចក្តីដំណាលថា ៖ ។

គោតាម្ពុធំ ឯកម បាសាទំ កាត្វា មានមេជាងឈើម្នាក់ឈ្មោះមិនប្រាកដ បានធ្វើប្រាសាទមួយខ្នងថ្វាយព្រះពោធិរាជកុមារ

ឈ្មោះថា គោគុទុទប្រាសាទ ល្អអស្ចារ្យហាក់ដូចជាអណ្តែតនៅឯអាកាស ។ ព្រះរាជកុមារសួរមេជាងឈើថា តយា កតបុព្វោ ប្រាសាទបែបនេះ អ្នកឯងធ្លាប់បានធ្វើឲ្យអ្នកឯទៀតរួចហើយដែរឬទេ ? ឬអ្នកទើបតែធ្វើម្តងនេះជាគ្រាដំបូង ? ។

មេជាងឈើក្រាបទូលថា បឋមសិប្បំ ឯវៈ សិល្បសាស្ត្រ គឺការធ្វើខ្ញុំប្រាសាទនេះជាគ្រាដំបូងបំផុត ទូលព្រះបង្គំមិនដែលធ្វើថ្វាយព្រះមហាក្សត្រអង្គណាទេ ។ ព្រះរាជកុមារបានទ្រង់ព្រះសណ្តាប់ហើយ ក៏ទ្រង់ព្រះចិន្តាថា បើអញមិនសម្លាប់ជាងឈើនេះ ឬមិនឆ្កៀលភ្នែកទាំងពីរខាងរបស់ជាងនេះឲ្យខ្វាក់ទេ ប្រាសាទនៃអញមុខជាមិនល្អអស្ចារ្យ, ទ្រង់ដំណាលប្រាប់សេចក្តីនេះឲ្យមាណពឈ្មោះសញ្ជ័យបុត្រជាសម្លាញ់បានដឹងផង ។ មាណពនឹកអាណិតអាសូរមេជាងឈើនោះខ្លាំងពេក អត់ទ្រាំពុំបាន ក៏ប្រាប់អាថ៌កំបាំងនេះឲ្យមេជាងដឹងខ្លួន ។ មេជាងដឹងរឿងនេះហើយ ក៏ឥតនិយាយប្រាប់អ្នកណាម្នាក់សោះ ។ កាលព្រះរាជកុមារ ចូលទៅសាកសួរមេជាងអំពីកិច្ចការសង់ប្រាសាទនោះឲ្យបានជ្រាបថា ធ្វើរួចហើយ ឬនៅឡើយ ។ មេជាងក្រាបទូលថា ធ្វើមិនទាន់ស្រេចទេព្រោះខ្វះឈើស្រាល ៗ ឥតខ្លឹម សូមព្រះអង្គឲ្យគេយកឈើស្រាល ៗ ឥតខ្លឹមមកឲ្យទូលព្រះបង្គំ ៗ នឹងធ្វើឲ្យហើយស្រេចផាច់ ៗ ។ ព្រះរាជកុមារត្រាស់ប្រើរាជបុរសឲ្យយកឈើស្រាល ៗ

ឥតខ្ចីមទៅឲ្យមេដាន៍ ហើយបង្គាប់ឲ្យឡោមព័ទ្ធប្រាសាទនោះជុំវិញ កុំឲ្យមេដាន៍ចេញទៅណារួច ។

មេដាន៍ក្រាបទូលថា ទូលព្រះបង្គំធ្វើការនេះល្អិតសុខុមណាស់សូមព្រះអង្គហាមប្រាមកុំឲ្យអ្នកណាម្នាក់ចូលមកគេហ៍ទូលព្រះបង្គំឡើយ បើក ឲ្យតែភរិយានៃទូលព្រះបង្គំម្នាក់ យកអាហារមកឲ្យប៉ុណ្ណោះ ព្រោះថា បើមានគេចូលមកនាំនិយាយ កិច្ចការដ៏ល្អិតសុខុមនេះមុខជាខុសខូចទៅ មិនបានជាល្អស្អាត ។ ព្រះពោធិកុមារក៏ធ្វើតាមពាក្យមេដាន៍គ្រប់ប្រការ ។ មេដាន៍បានឱកាសស្ងាត់ល្អ ក៏ពួនសម្ងំនៅក្នុងបន្ទប់នៃប្រាសាទតែម្នាក់ឯង ខំចាត់ចែងធ្វើរូបគ្រុឌយន្តដោយឈើស្រាល ១ ធំល្មមខ្ទង់ផ្ទុកប្រពន្ធកូនអង្គុយបាន លុះធ្វើស្រេចហើយ ប្រាប់ប្រពន្ធឲ្យលក់ជួរវត្ថុផ្សេង ១ យកតែប្រាក់និងមាស ហើយឲ្យនាំកូនចូលទៅក្នុងប្រាសាទ ។ នាងប្រពន្ធធ្វើតាមពាក្យស្វាមីសព្វគ្រប់ ។ ស្វាមីនាំប្រពន្ធនិងកូនប្រុសស្រីចូលអង្គុយនៅលើខ្នងរូបគ្រុឌយន្ត ហើយចេញពីប្រាសាទ ហោះហើរទៅតាមអាកាស វាទៅចុះនៅព្រៃហិមពាន្ត កសាងនគរនៅក្នុងអរញ្ញប្រទេស ចំណេរចូរមកក៏បានជាក្សត្រនៅក្នុងព្រៃហិមពាន្ត មានព្រះនាមថាព្រះបាទកដ្ឋវាហនរាជ ។ បុគ្គលអ្នកចេះស្ទាត់ក្នុងសិល្បសាស្ត្រ តែងយកនិងខ្លួនឲ្យរួចផុតអំពីមរណភ័យ ហើយបានធ្វើជាធំយ៉ាងនេះ ។

បុគ្គលមិនខ្ជិលច្រអូស, បុគ្គលដ៏ជុំវិញ និងបុគ្គលមានស្មារតី

មាំមួន បើមិនទាន់បានសម្រេចសម្បត្តិជាលោកុត្តរនៅឡើយទេ ក៏គង់តែបានសម្រេចសម្បត្តិជាលោកិយមិនខានដែរ ទម្រាំបានសម្រេចសម្បត្តិជាលោកុត្តរកើតជាអវសាន ។

## បញ្ចកបុគ្គល

សម្តេចព្រះបរមសាស្តាទ្រង់សំដែងបុគ្គលបួនពួកចប់ហើយ ទើបទ្រង់សំដែងបុគ្គលប្រាំពួកតទៅទៀតថា ៖

បុគ្គលកំណាញ់អាវាសមួយពួក, កំណាញ់ត្រកូលមួយពួក, កំណាញ់លាភមួយពួក, កំណាញ់ពណ៌ សម្បុរនិងសេចក្តីសរសើរមួយពួក, កំណាញ់ធម៌មួយពួក ។

ឯបុគ្គលកំណាញ់អាវាសនោះមានពីរពួក គឺបព្វជិតមួយពួក,គ្រហស្ថមួយពួក ។

បព្វជិតកំណាញ់អាវាស គឺកំណាញ់ទីលំនៅ ឃើញភិក្ខុអាគន្តុកៈមកដល់ហើយ ក៏ហាមប្រាមប្រាប់ថា ទីនេះ ជាកន្លែងសម្រាប់ទុកដាក់របស់សង្ឃ, ទីនេះ ជាកន្លែងសម្រាប់ទុកដាក់របស់ចេតិយ ។ បេតោ វា អជគរោ វា ហុត្វា និព្វត្តិ ភិក្ខុកំណាញ់អាវាសនោះ លុះរលត់បញ្ចក្ខន្ធហើយ រមែងទៅកើតជាប្រេតឬជាពស់ថ្លាន់ ។

គហដ្ឋា បន ចំណែកបុគ្គលកំណាញ់អាវាស ជាគ្រហស្ថនោះ ឃើញអ្នកដទៃមានទីលំនៅ មានទីសំណាក់អាស្រ័យ ក៏កើតចិត្តលោភ

បង់បាន ចូលទៅបៀតបៀនគេ ឬរាស់រំដៃបន្ថិតគោលចូលទៅឲ្យលើស ព្រំដែនតែបន្ទំយកទីរបស់គេមកធ្វើជារបស់ខ្លួន ។ គ្រហស្ថអ្នកមានចិត្តលោភបែបនេះ លុះក្ស័យជីវិតហើយក៏ទៅកើតជាប្រេត នៅសេសសល់បាបនោះ មកកើតជាមនុស្សកំសត់ទុគ៌តអនាថា ។

ចំណែកអ្នកកំណាញ់ត្រកូលនោះ ជាហេតុឲ្យនិយាយបេសុញ្ញវាទ ពាក្យព្រោះញុះញង់បង្កាច់បង្ខូចកេរ្តិ៍ឈ្មោះគេ ហេតុនោះ អកុសលនេះតែកើតមានច្រើន ៗ ឡើងរាល់ថ្ងៃ ។

អ្នកកំណាញ់លាភ ច្រើនតែមានចិត្តប្រណែនច្រណែនគេ បើឃើញអ្នកដទៃបានលាភ ក៏នឹកក្តាញ់ក្នុងចិត្តនិយាយសំដីអាក្រក់ចាក់ដោតដេរប្រទេចផ្តាសាគេ ខំគិតកេះបាយធ្វើឲ្យគេខូចខាតលាភនោះ ថែមទាំងនិយាយព្រោះញង់កាចកិនគេ ទើបធ្វើអទិន្នាទានលួចលាក់បំបាត់លាភរបស់គេទៀតផង ។ ឯអទិន្នាទានគឺការលួចនោះ មិនមែនសំដៅយកតែត្រង់ការលួចលាក់បំបាត់បន្ទំយកទ្រព្យសម្បត្តិដែលម្ចាស់គេមិនបានឲ្យប៉ុណ្ណោះទេ សូម្បីគ្រាន់តែធ្វើឲ្យអ្នកដទៃខូចខាតលាភគឺវត្ថុដែលគេនឹងត្រូវបានក៏ឈ្មោះជាអទិន្នាទានដូចគ្នាដែរ ។

អ្នកកំណាញ់ពណ៌សម្បទានឹងសេចក្តីសរសើរនោះ កាលបើឮគេនិយាយសរសើរអំពីពណ៌សម្បុររូបកាយរបស់អ្នកណា ថាល្អស្រស់ណាស់ ក៏បែរជាឆ្លើយជំទាស់បន្តុះបង្អាប់ ពណ៌សម្បុររូបកាយអ្នកនោះមិនល្អទេ

ឬមួយបើឮគេសរសើរអំពីគុណធម៌របស់អ្នកណា ក៏កើតចិត្តឫស្យាឆ្លើយកាត់គេថា អ្នកនោះចិត្តល្អមែនហើយ ប៉ុន្តែកាលដើមគាត់ប្រព្រឹត្តអាក្រក់យ៉ាងនេះខ្លះ យ៉ាងនោះខ្លះ យើងមិនគួរសរសើរអ្នកនោះទេ ។

ចំណែកអ្នកកំណាញ់ធម៌នោះ លោកសំដៅយកកំណាញ់ព្រះបរិយត្តិធម៌គឺធម៌សម្រាប់រៀនសូត្រ ។ អ្នកកំណាញ់ធម៌នេះគិតថា អ្នកនេះបើអញប្រាប់ធម៌ឲ្យចេះដឹងទៅហើយ មុខជាដឹងសួរដេញដោលផ្ចាញ់ផ្ចាលអញក្នុងទីប្រជុំជនមិនខាន ឬនឹងល្បីកេរ្តិ៍ឈ្មោះថាជាអ្នកចេះដឹងធម៌ជាងអញ លុះគិតយល់យ៉ាងនេះហើយ ក៏លាក់ធម៌ទុកចេះតែម្នាក់ឯង សូម្បីអ្នកណាសួរដូចម្ដេចក៏មិនប្រាប់អ្នកនោះឲ្យចេះដឹងដែរ ។ មនុស្សបែបនេះហៅថាអ្នកកំណាញ់ធម៌ ។

បុគ្គលកំណាញ់ទាំងប្រាំពួកដូចរៀបរាប់មកហើយនេះ បើហៅតាមភាសាបាលីដែលមានក្នុងគម្ពីរព្រះអភិធម្មបុគ្គលបញ្ញត្តិថា៖

១- អាវាសមច្ឆរិយបុគ្គល បុគ្គលអ្នកកំណាញ់ទីលំនៅ

២- កុលមច្ឆរិយបុគ្គល -ដ- ត្រកូល

៣- លាភមច្ឆរិយបុគ្គល -ដ- លាភ

៤- វណ្ណមច្ឆរិយបុគ្គល -ដ- ពណ៌ឬកិត្តិគុណ

៥- ធម្មមច្ឆរិយបុគ្គល -ដ- ព្រះបរិយត្តិធម៌

អ្នកកំណាញ់ទាំងប្រាំពួកនេះ ស្លាប់ហើយ រមែងទៅកើត

ក្នុងអបាយភូមិ ។

នៅមានបុគ្គលទាំងប្រាំពួកទៀត ដែលអស់ជីវិតហើយ តែមិនបាន ទៅកើតក្នុងស្ថានសួគ៌ គឺ បុគ្គលបរិបូណ៌ដោយញាតិមួយពួក, បរិបូណ៌ ដោយសម្បត្តិមួយពួក, បរិបូណ៌ដោយការមិនមានរោគមួយពួក បរិបូណ៌ ដោយសីលមួយពួក បរិបូណ៌ដោយសម្មាទិដ្ឋិមួយពួក ។

បុគ្គលអ្នកបរិបូណ៌ដោយញាតិនោះ គឺញាតិទាំងឡាយជាមនុស្ស មានចិត្តជាកុសល ជាមនុស្សសង្គ្រោះញាតិ ជាមនុស្សសប្បុរស ទើប ហៅអ្នកសម្បូណ៌ញាតិបានទៅកើតនៅស្ថានសួគ៌ៈ ដ្បិតអ្នកនោះមានសន្តាន ច្រើនមែនហើយ ប៉ុន្តែញាតិទាំងនោះ ជាមនុស្សចិត្តអកុសលជាមនុស្ស មិនជួយសង្គ្រោះញាតិ ជាមនុស្សអសប្បុរស ក៏មិនបានទៅកើតក្នុងស្ថាន សួគ៌ដែរ ព្រោះខ្លួនជាមនុស្សអសប្បុរសទៅតាមញាតិទាំងនោះ ។

បុគ្គលអ្នកបរិបូណ៌ដោយទ្រព្យសម្បត្តិនោះ សំដៅយកអ្នកមាន ទ្រព្យសម្បត្តិច្រើន ហើយមានសទ្ធាជ្រះថ្លា ជឿកម្មផលផង បើមានតែ ទ្រព្យសម្បត្តិច្រើន ហើយគ្មានសទ្ធាជ្រះថ្លា ក៏មិនបានទៅកើតនៅស្ថាន សួគ៌ដែរ ។ ចំណែកអ្នកក័លក្រខ្សត់ធនធាន ប៉ុន្តែជាមនុស្សមានសទ្ធា ជ្រះថ្លាបាន ឈ្មោះថាអ្នកនោះមានទ្រព្យធន សមតាមព្រះពុទ្ធភាសិតថា សទ្ធានេះ ក៏ជាអរិយទ្រព្យប្រការមួយ ព្រោះថាបុគ្គលគ្មានសទ្ធាជ្រះ ថ្លា បើទុកជាមានធនធានច្រើនដល់ប៉ុន្មាន ៗ ក៏មិនអាចនឹងធ្វើកង៏ការ

កុសលអ្វីមួយបានដែរ លុះតែមានបញ្ញាទើបអាចនឹងធ្វើការកុសលទាំង
ពួងបាន ដែលជាបច្ច័យនឹងឲ្យបានលោកិយសម្បត្តិនិងលោកុត្តរសម្បត្តិ ។

បុគ្គលអ្នកបរិបូណ៌ដោយការមិនមានរោគនោះ គឺជាអ្នកមិនមានរោគ
ប្រចាំនៅក្នុងខ្លួនជាប់ជាមួន មិនដែលឈឺធ្ងន់ដល់ទៅជិតស្លាប់ មានជម្ងឺឈឺ
ជាប់ខ្លះដែរ ប៉ុន្តែឈឺស្រាលៗបន្តិចបន្តួចក៏បាត់ទៅវិញ ។ អ្នកឥតរោគនេះ
ជាហេតុនឹងឲ្យបានទៅកើតទៅស្ថានសួគ៌ ព្រោះថាបើខ្លួនឥតជម្ងឺហើយ
នឹងធ្វើកុសលអ្វីៗក៏ចេះតែធ្វើបានតាមចិត្តប្រាថ្នា នេះបើយកបុគ្គលអ្នក
មានបញ្ញាចេះគិតឃើញអនិច្ចំ ទុក្ខំ អនត្តា ជាអ្នកមិនប្រមាទ មិនស្រវឹង
វង្វេង ។ បើបុគ្គលឥតរោគជាប់ប្រចាំនៅក្នុងខ្លួនហើយ ប៉ុន្តែជាអ្នក
ប្រមាទស្រវឹងវង្វេងមិនសំគាល់ថាខ្លួនឥតជម្ងឺឈឺជាប់អ្វីនោះ ហើយចេះតែប្រ
ព្រឹត្តអំពើទុច្ចរិតផ្សេងៗជានិច្ចទៅមិនបានគិតឃើញសង្ខារថា អនិច្ចំ ទុក្ខំ
អនត្តានោះ ។ អ្នកឥតរោគបែបនេះមិនបានទៅកើតទៅស្ថានសួគ៌ទេ
ព្រោះខ្លួនមិនបានធ្វើកុសលណាមួយ ។

ចំណែកអ្នកមានបញ្ញានោះ បើទុកជាខ្លួនឥតឈឺជាប់អ្វីមានសេចក្ដី
សុខកាយសប្បាយចិត្តយ៉ាងណាក៏ដោយ ក៏នៅតែពិចារណាឃើញថាបើ
អាត្មាអញមិនទាន់បានដល់ព្រះនិព្វានដរាបណា រូបកាយរបស់អាត្មាអញ
ឈ្មោះថាមានរោគទៅប្រចាំជាប់ជានិច្ចគ្រប់ពេលវេលាដរាបនោះ ។ ឯរោគ
ធំបំផុតដែលកើតមាននៅក្នុងខ្លួនអាត្មាអញជានិច្ចនោះ គឺរោគស្រេកឃ្លាន

ដូចស្រេកទឹកឃ្លានបាយជាដើម សមតាមព្រះពុទ្ធភាសិតថា ជិឃច្ឆា បរមា រោគា គ្មានរោគឯណាខ្លាំងក្លាលើសរោគស្រេកឃ្លានទេ (ធ.ខុ) ។ អ្នកស្រេកទឹក ឬឃ្លានបាយបណ្ដាលឲ្យអស់កម្លាំងទន់ដៃជើង ធ្វើការងារសូម្បីបន្តិចបន្តួចក៏មិនកើត ទាល់តែរកបាយទឹកមកបរិភោគឲ្យបាត់ឃ្លាន ទើបធ្វើការងារកើត ។ ឯបុណ្យកុសលទាំងពួងក៏ដូចជាការងារដែរ ។ មានបញ្ញាយល់ឃើញថា ខ្ញុំមានរោគជានិច្ចទាល់តែដល់ព្រះនិព្វាន ទើបគ្មានរោគទាំងអស់ លុះយល់យ៉ាងនេះហើយ ក៏ធ្វើកុសលប្រាថ្នាឲ្យបានដល់ព្រះនិព្វាន បើមិនទាន់ដល់ព្រះនិព្វានទេ នៅត្រាច់ក្នុងវដ្ដសង្សារនៅឡើយ ក៏នឹងបានសោយនូវសុខសម្បត្តិ ។

បុគ្គលអ្នកបរិបូណ៌ដោយសីលនោះជាហេតុនឹងឲ្យបានទៅកើតនៅស្ថានសួគ៌ដែលមានអានិសង្សប្រាំប្រការ សមតាមពាក្យព្រះសារីបុត្តត្ថេរថា ឥធ សីលវា សម្បន្នោ សីលេន កុលបុត្តក្នុងព្រះពុទ្ធសាសនានេះ ជាអ្នកមានសីលបរិបូណ៌ដោយសីលដែលខ្លួនរក្សា ដោយសេចក្ដីមិនប្រមាទរមែងបាននូវភោគសម្បត្តិដ៏ធំ នេះជាអានិសង្សដំបូង ។

សីលវតាយ សីលសម្បន្នាយ បុគ្គលអ្នកមានសីលបរិបូណ៌ដោយសីលនោះ មានកិត្តិសព្ទពាក្យសរសើរល្បីល្បាញទូទៅគ្រប់ទិសថា អ្នកនេះ ជាមនុស្សរក្សាសីលបរិសុទ្ធបរិបូណ៌ប្រពៃ នេះជាអានិសង្សគំរប់ពីរ ។

បុគ្គលអ្នកមានសីលបរិសុទ្ធបរិបូណ៌ប្រពៃនោះ បើនឹងចូលទៅជិត

បរិស័ទណា១ គឺខត្តិយបរិស័ទ, ព្រាហ្មណ៍បរិស័ទនិងសមណបរិស័ទក៏ ក្លៀវក្លាឥតគត់ស្លុត មិនសំយុងមុខជ្រប់ នេះជាអានិសង្សគំរប់បី ។

អសម្មូឡ្ហោ កាលំ ករោតិ បុគ្គលអ្នកមានសីល ជិតនិងក្ស័យជីវិតមិនវង្វេងស្មារតី នេះជាអានិសង្សគំរប់បួន ។

បុគ្គលអ្នកមានសីល កាលបើអស់ជីវិតហើយ រមែងបានទៅកើតទៅស្ថានសួគ៌ នេះជាអានិសង្សគំរប់ប្រាំ ។

ចំណែកបុគ្គលអ្នកបរិបូណ៌ដោយសម្មាទិដ្ឋិនោះ តែងពិចារណាឃើញថា ខ្លួនមានកម្មជារបស់ខ្លួនៗ ជាអ្នកទទួលនូវផលនៃកម្ម បើខ្លួនធ្វើកម្មល្អក៏រមែងបានផលជាសុខ បើខ្លួនធ្វើកម្មអាក្រក់ ក៏រមែងបានផលជាទុក្ខ, សុខនិងទុក្ខនេះ ជាផលនៃកម្មល្អនិងអាក្រក់ដែលខ្លួនធ្វើដោយខ្លួនឯង គ្មានអ្នកណាឲ្យខ្លួនទេ កាលបើឃើញយ៉ាងនេះជាដើមហើយ ក៏ខំប្រឹងធ្វើនូវការកុសល តាំងពួងដែលជាចំណែកខាងកម្មល្អ លុះអស់ជីវិតហើយរមែងបានទៅកើតទៅស្ថានសួគ៌ ។

សម្តេចព្រះបរមសាស្តាទ្រង់ទេសនានូវបុគ្គលប្រាំពួក គឺអ្នកបរិបូណ៌ដោយញាតិ ដោយសម្បត្តិ ដោយការមិនមានរោគ ដោយសីល និងអ្នកបរិបូណ៌ដោយសម្មាទិដ្ឋិ តែងបានទៅសោយសុខសម្បត្តិទៅស្ថានសួគ៌ ។

## ឆក្កបុគ្គល

ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងនូវបុគ្គលប្រាំពួកចប់ហើយ ព្រះអង្គទ្រង់សំដែងនូវបុគ្គលប្រាំមួយពួកតទៅទៀត ប៉ុន្តែ ទ្រង់ពន្យល់នូវសារាណីយធម៌ជាមុនថា ៖

ឆ សារាណីយា ធម្មា ធម៌ជាទីតាំងនៃសេចក្តីរឭកមាន ៦ ប្រការ គឺ –

១– មេត្តាកាយកម្ម ជួយធ្វើការងារគ្នាទាំងចំពោះមុខ ទាំងកំបាំងមុខដោយចិត្តមេត្តា ;

២ មេត្តាវចីកម្ម ជួយបង្ហាត់បង្រៀនប្រាប់ពន្យល់ឬប្រដៅ

៣– មេត្តាមនោកម្ម ជួយគិតគូរនូវកិច្ចការ ដែលជាប្រយោជន៍ឲ្យដល់គ្នា ទាំងចំពោះមុខ ទាំងកំបាំងមុខដោយចិត្តមេត្តា

៤– លាភៈ វត្ថុដែលខ្លួនរកបានមកដោយធម៌ ឲ្យដល់គ្នីគ្នា មិនលាក់លៀមទុកបរិភោគតែម្នាក់ឯង ។

៥– សីលៈ រក្សាសីលឲ្យបរិសុទ្ធស្មើគ្នា មិនឲ្យគេរង្កៀសនឹងសីលរបស់ខ្លួន ។

៦– ទិដ្ឋិ មានសេចក្តីយល់ឃើញត្រូវគ្នា មិនឈ្លោះប្រកែកតាស់តែងនឹងអ្នកណា ព្រោះតែការយល់ឃើញខុសគ្នា ។ (នៅមានត)

## មធុរសកហាណី

### សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

---

ខ្ញុំព្រះអង្គ បានចូលទៅកាន់សំណាក់សេកៈសាមៗនោះក៏មានចិត្តកតញ្ញូពុំភ្លេចគុណខ្ញុំព្រះអង្គឡើយ បានឃាត់ខ្ញុំព្រះអង្គឲ្យនៅរង់ចាំក្នុងទីជិតដើមជ្រៃនោះ ហើយហើរចេញទៅស្វែងរកទ្រព្យ បានពាំនាំកែវមុត្តាហារ យកមកឲ្យជាការតបគុណខ្ញុំព្រះអង្គៗក៏បានយកកែវមុត្តាហារនោះទៅធ្វើទុកនឹងមនុស្សជាសំឡាញ់ដែរ ហើយបាននិយាយប្រាប់រឿងដែលសេកៈសាមបានយកកែវនោះមកតបគុណខ្ញុំព្រះអង្គដោយសព្វគ្រប់ ឥឡូវនេះ ព្រោះហេតុតែមនុស្សនោះឯង បានជាខ្ញុំព្រះអង្គដល់នូវទោសត្រូវសម្លាប់ លុះពជបុរសទាំងឡាយនាំខ្ញុំព្រះអង្គទៅតាមផ្លូវ ខ្ញុំព្រះអង្គក៏នឹកគិតដល់ពស់ ស្រាប់តែខ្ញុំព្រះអង្គបានជួបប្រទះនឹងពស់នាគរាជ ដែលជាសំឡាញ់នឹងខ្ញុំព្រះអង្គនោះ ។ នាគរាជនោះក៏មានចិត្តកតញ្ញូកតវេទីដឹងឧបការគុណនៃខ្ញុំព្រះអង្គ ខំស្វះស្វែងរកឧបាយដោះឲ្យរួចអំពីសេចក្ដីស្លាប់ ព្រមទាំងអាចញ៉ាំងខ្ញុំព្រះអង្គ ឲ្យបានសម្បត្តិទ្រព្យធំបរិបូណ៌ ជាសុខសប្បាយឥតមានទុក្ខទោសអ្វីឡើយ ។

ឆកាធិបៈ បពិត្រព្រះអង្គជាធំជាងនរជន! សុជនោ ធម្មតាឯ

ជនល្អជាសប្បុរស ព្រោះបើជាសត្វតិរច្ឆានក្តី ជាមនុស្សជាតិក្តី ក៏បុគ្គលមិន គប្បីមើលងាយថា តូច ថាថោកទាបឡើយ ។ ឧទាហរណ៍ដូចយ៉ាងជនទាំង ពីរនេះគឺ សេកសោមមួយ ពស់ខាតពជមួយ ដែលបានស្ថិតនៅក្នុងមិត្ត- ធម៌ ដែលជាធម៌ល្អគឺបណ្ឌិតគប្បីរាប់ ជាអ្នកមានឧស្សាហ៍ប្រកបដោយ ហេតុល្អ ប្រព្រឹត្តតាមធម៌ អាចធ្វើបដិការតបគុណដល់ខ្ញុំព្រះអង្គដែលជា អ្នកបានធ្វើគុណដល់ខ្លួនជាមុនដោយពិត ៗ ចំណែកឯមនុស្សជាតិជា អ្នកថោកទាបមានសន្តានចិត្តជាពាលក្រាស់ដូចបាបមិត្តនេះ ព្រោះបើមាន ជាតិស្មើដោយខ្ញុំព្រះអង្គ អ្នកបានធ្វើឧបការគុណចំពោះខ្លួនដល់ប៉ុន្មានក្តីគង់ បាបមិត្តជាមនុស្សថោកទាបនោះ ក៏ពុំដឹងគុណដែលមិត្តល្អមានឧបការដល់ ខ្លួនឡើយ ស៊ីងប្រែត្រឡប់ប្រទូស្តដល់មិត្តដែលមានគុណចំពោះខ្លួនវិញ ដោយចំណែកមួយ, បពិត្រព្រះសម្មតិទេព! បុគ្គលជាអសប្បុរសពុំបានធ្វើ ឧបការតបដល់ខ្ញុំព្រះអង្គឡើយ ប្រែត្រឡប់ទៅជាចិត្តប្រទូស្តដល់ខ្ញុំព្រះអង្គ វិញ ឯពួកជនជាសប្បុរសតែងមានសេចក្តីជ្រះថ្លាប្រាថ្នាតែសេចក្តីសុខ សេចក្តីចំរើនដល់ខ្ញុំព្រះអង្គដោយពិត មួយទៀតបុគ្គលពាលទាំងឡាយ ដែលមានចរិតជាអសប្បុរស ក៏ពុំបានដឹងគុណទេ ពោសជាប្រក្រតីក្នុង លោកយ៉ាងនេះឯង ៗ បពិត្រមហារាជ! ចំណែកឯមិត្តជាបណ្ឌិតអ្នកមានចិត្ត សប្បុរស ព្រោះបើជាមនុស្សក្តី ជាសត្វតិរច្ឆានក្តី តែបានស្និទ្ធស្នាលនឹងអ្នក ណាមួយហើយ តែងមានសន្តានចិត្តស្រឡាញ់ស្មោះត្រង់អ្នកនុ៎ះ ប្រកាន់

ខ្ជាប់ជាជាសំឡាញ់មែនពិត ៗ ឧបការបុរសនោះបានសម្តែងព្រឹត្តិការណ៍របស់ខ្លួនថ្វាយព្រះមហាក្សត្រិយ៍សូមទ្រង់ព្រះសណ្តាប់ក្នុងកាលនោះឯង ៗ

លុះព្រះបរមក្សត្រិយ៍ ទ្រង់បានសណ្តាប់ពាក្យឧបការបុរសក្រាបទូលដូច្នោះហើយ ស្តេចក៏មានព្រះហឫទ័យជ្រះថ្លា មានព្រះរាជឱង្ការត្រាស់បង្គាប់សេវកាមាត្យទាំងឡាយថា: ម្នាលអ្នកទាំងឡាយដ៏ចំរើន! អ្នកត្រូវបញ្ជាដល់នាយជាងទាំងឡាយឲ្យជាត់តែងធ្វើគេហស្ថាន ឲ្យធំ ឲ្យល្អផើត ប្រគល់ឲ្យដល់បុរសនេះជាដាច់ ៗ ឯចំណែកឧបការបុរសនោះក៏បានក្រាបថ្វាយបង្គំលាព្រះមហាក្សត្រិយ៍ចេញទៅ ហើយនិយាយប្រាប់នាយជាងទាំងនោះថា សូមអ្នកទាំងឡាយធ្វើផ្ទះឲ្យខ្ញុំត្រង់ចន្លោះដើមជ្រៃនិងដម្បូកធំនេះចុះ លុះបាននិយាយហើយ ក៏ឲ្យនាយជាងចាត់សង់ផ្ទះក្នុងទីនោះដរាបតែហើយស្រេច ទើបទៅនៅអាស្រ័យក្នុងផ្ទះនោះជាសុខសប្បាយ ៗ បុរសនោះបរិបូណ៌ដោយទ្រព្យសម្បត្តិនិងបរិវារហោមរោមបំរើជានិច្ច ហើយតែងចូលទៅគាល់បំរើព្រះបរមក្សត្រិយ៍ជាប្រក្រតីបានរីករាយស្មោះសរជាមួយនឹងសំឡាញ់ទាំងពីរ គឺសេក សោមនឹងពស់នាគរាជនោះអស់កាលជានិរន្តរ៍ គាត់តែងចិញ្ចឹមរក្សាឲ្យបាយចំណីទឹកឃ្មុំដល់សំឡាញ់ទាំងពីរបរិភោគឆ្អែតស្កប់ស្កល់ដរាបដល់អស់ជីវិតទៅ ៗ អាយុបរិយោសានេ កាលបើជនទាំងបីនាក់ បានធ្វើមរណកាលក្ស័ណក្ស័យជីវិតហើយ ក៏បានឡើងទៅកើតក្នុងស្ថានសួគ៌ សោយទិព្យសម្បត្តិដ៏

សមគួរតាមកម្មរបស់ខ្លួនៗ ។ ព្រោះហេតុដូច្នេះ ទើបព្រះអរហន្តទាំងឡាយបានពោលនូវបទព្រះគាថាដូច្នេះថា:

ឥតិ បតិតសុខម្ហា អត្តតោ ច ធនម្ហា
បរមតរបតិដ្ឋា ហោតិ មិត្តាសមានំ
វិរហិតសទ្ធិនម្ហា នត្ថិ យស្មា ហិ វុទ្ធិ
បិនថ កុសលធម្មំ មិត្តវន្តោ មហន្តំ(១)

អធិប្បាយថា: បពិត្រសប្បុរសទាំងឡាយដ៏ចំរើន ! ចំពោះដំទុក្ខវិសេសហួសពេកចុះមកអំពីសេចក្តីសុខខ្លះ អំពីខ្លួនឯងខ្លះ អំពីទ្រព្យសម្បត្តិខ្លះ តែងតែគប្រកបដោយមិត្តសំឡាញ់ទាំងឡាយ សេចក្តីពិតថា បើបុគ្គលមិនមានមិត្តសំឡាញ់ទេ នឹងបានសេចក្តីចំរើនសួស្តីមកពីហេតុណា, ព្រោះហេតុនោះ បើអ្នកទាំងឡាយបានមិត្តសំឡាញ់ល្អហើយ ត្រូវតែបំពេញកុសលធម៌ឲ្យច្រើនដោយពិត ៗ

សម្តែងរឿងនេះទាំងប៉ុន្មាន ក្នុងវគ្គបឋម និទានដោតរបស់ គឺចប់សេចក្តីជាសង្ខេបតែប៉ុណ្ណោះឯង ។

៤- ពុទ្ធេណីវគ្គកថា សម្តែងរឿងនិទាននានពិតា ឈ្មោះពុទ្ធេណី ជាតំរប់៤តទៅទៀត ដោយបទបាលីថា: ជម្ពុទីបេ គាំរ ដូច្នេះជាដើម អធិប្បាយថា: បានឮរឿងមកពីកាលមុន ក្នុងជម្ពូទ្វីប

---

១- មាលិនីឆន្ទ ១៤ ភ. ។ វុត្តោទយទំព័រ ៦៤ ។

មានត្រកូលសេដ្ឋីមួយ មានទ្រព្យកប់ទុកចំនួនប៉ែតសិបប្រាំពីរកោដិ នៅអាស្រ័យក្នុងនគរបាតលីបុត្រ ។ សេដ្ឋីនោះមានធីតាមួយរូបឈ្មោះនាងពុទ្ធេណី ។ លុះដល់នាងពុទ្ធេណីនោះចំរើនវ័យធំឡើង បានអាយុ៧ឆ្នាំហើយ សេដ្ឋីជាមាតាបិតាក៏ធ្វើមរណកាលក្ស័យជីវិតទៅ នាងធីតានៅកំព្រាតែម្នាក់ឯង ។

ឯទ្រព្យសម្បត្តិទាំងអស់ក្នុងត្រកូលនោះ ក៏បានទៅជារបស់ទ្រព្យនាងពុទ្ធេណីនោះឯង, ឯនាងពុទ្ធេណីនោះសោត នាងមានរូបឆោមទ្រង់ទ្រាយល្អត្រជាទីត្រេកអរដល់ប្រជុំជនដែលបានឃើញនាង ប្រកបដោយពណ៌សម្បុរដ៏ឧត្តមប្រសើរ មានដំណើរប្រៀបផ្ទឹមប្រហែលស្រីទេពអប្សរ នាងជាទីស្រឡាញ់ពេញចិត្តដល់ជនទាំងឡាយ, ហើយជាស្ត្រីមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ជាស្ត្រីគោរពប្រតិបត្តិគប់អានទូគុណព្រះរតនត្រ័យគឺព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាប់ជានិច្ច ឥតមានចិត្តកម្រើកឡើយ ។ ចំណែកឯជនទាំងឡាយក្នុងព្រះនគរនោះ មានសេដ្ឋីសេនាបតីស្តេចឧបពជជាដើមសឹងមានសេចក្តីប្រាថ្នាចង់បាននាងពុទ្ធេណីនោះ ដើម្បីធ្វើជាភរិយានៃខ្លួនទីទៃ បានចាត់មនុស្សអ្នកបំរើទាំងឡាយ ឱ្យនាំគ្រឿងបណ្ណាការទៅឱ្យដល់នាងពុទ្ធេណីនោះ ហើយឱ្យនិយាយល្បួងលួងនាងតាមការប្រឡោមរៀងៗខ្លួន ។

ឯនាងពុទ្ធេណីនោះ នាងបានស្តាប់ដំណឹងនោះហើយ ក៏គិតពិចារ-

ណាដោយសេចក្តីសំរេចថា ៖ អាត្មាអញអើយ! មាតាបិតាលោកបាន សន្សំទ្រព្យសម្បត្តិទុកជាច្រើន ដល់វេលានឹងស្លាប់ក៏ស្លាប់ទៅចោលទ្រព្យ សម្បត្តិទាំងអស់ទុកនៅកាយយកទៅផងពុំបានឡើយ គឺទៅតែខ្លួនម្នាក់ឯង ដោយពិត ។ ដំណើរអាត្មាអញទៀតក៏គង់នឹងត្រូវទៅតាមទំនងនោះ ឯង, បើដូច្នេះ អាត្មាអញប្រយោជន៍អ្វីនឹងមានប្តី ប្រយោជន៍អ្វីនឹងទ្រព្យ សម្បត្តិទាំងនេះ, ត្រូវតែអាត្មាអញយកទ្រព្យសម្បត្តិទាំងអស់នេះ កប់ទុក ក្នុងព្រះពុទ្ធសាសនា ឲ្យជាកំណប់ត្រៀងទៅខាងមុខប្រសើរជាង ។

លុះនាងបានរំពឹងគិតយ៉ាងនេះហើយ ក៏ឃាត់មនុស្សអ្នកបំរើទាំង នោះថា អើ! អ្នកទាំងឡាយ, ត្រូវនាំយកគ្រឿងបណ្ណាការត្រឡប់ទៅវិញ ចុះ ខ្ញុំមិនត្រូវការនឹងមានប្តីសោះឡើយ នាងពោលដូច្នេះហើយ ក៏បញ្ជូន មនុស្សទាំងឡាយទៅក្នុងកាលនោះឯង ។

ចាប់ដើមតាំងពីកាលនោះមក នាងពុទ្ធណីបានបរិច្ចាគទ្រព្យធនញ៉ាំង មហាទានឲ្យប្រព្រឹត្តទៅពុំដាច់ អាចធ្វើសមណៈនឹងព្រាហ្មណ៍ទាំងពួងឲ្យ ឆ្អែតបរិបូណ៌ដោយបច្ច័យទាំងឡាយតាមប្រាថ្នាឥតមានខ្វះខាតវត្ថុអ្វីឡើយ ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយលោកពោលជាបទព្រះគាថាថា៖ ចតុទ្ទិសា យាគជិនត្រ្តជាធំ ឱចាឧក្ខតំ យរមាសិ ត· ស្សា ជាដើម អធិប្បាយថា៖ ទីផ្ទះរបស់ឧបាសិកាឈ្មោះពុទ្ធណីនោះ កើត ប្រាកដដូចជាអណ្តូងទឹកសម្រេចដល់ស្រមណ៍ទាំងឡាយ ដែលជាបុត្រ

ព្រះជិនស្រី និមន្តមកអំពីទិសទាំងបួនតាមតែត្រូវការ បើប្រាថ្នាបច្ច័យណា ក៏បានបច្ច័យនោះតាមប្រាថ្នា បីដូចជាដើមកល្បព្រឹក្សជាហេតុឲ្យសម្រេចលាភទឹងបច្ច័យទាំងពួងតាមសមគួរដល់សេចក្តីប្រាថ្នាបាន, ម្យ៉ាងទៀត សាលាទានដ៏ប្រសើររបស់នាងពុទ្ធណីនោះ សឹងមានអានុភាពធំទូលាយ ប្រដាប់ដោយពិតានសំពត់ ដ៏វិចិត្រមានក្បូរក្បាច់រំយោលផ្កាភ្ញីជាដើម មានរបៀបតោមកែវប្រទីបផ្កាលា ចង់សំយុងចុះសម្រាប់អុជដ៏ភ្លឺរុងរឿងល្អ ដែលនាងតែងតាំងបំរុងទុកជាស្រេច ព្រមទាំងប្រដាប់ដោយរបៀបគ្រឿងកម្រាលសម្រាប់ដេកអង្គុយជាសុខស្រួលឥតមានខ្វះ, ឯនាងពុទ្ធណីឧបាសិកាសោតសឹងមានដៃបានលាងស្អាតបម្រុងទឹងឲ្យទានជានិច្ច, នាងមានចិត្តដ៏ស្អាតផូរផង់បានរក្សាសីល៥ជាប់ជានិច្ចសព្វកាលទាំងពួង, នាងមានកិត្តិស័ព្ទដ៏ប្រសើរខ្ពង់ខ្ពស់ល្បីខ្ចាយទូលាយ ដោយគុណមានករុណាគុណជាដើម ព្រោះបានឲ្យនូវមហាទានដ៏វិសេស ដែលព្រះអរិយទាំងឡាយតែងសរសើរដោយពិត ។

លុះចំណេរមកក្នុងកាលជាខាងក្រោយ មានឈ្មួញសេះម្នាក់នាំសេះចេញមកអំពីទិសខាងកើត ចូលមកទិសខាងលិច នៃក្រុងបាតលីបុត្តនោះ ដើម្បីនឹងលក់សេះ ក៏បានមកសំណាក់នៅគេហស្ថានរបស់នាងពុទ្ធណីឧបាសិកានោះឯង ។

គ្រានោះ ឈ្មួញសេះបានឃើញកិរិយាមារយាទនាងហើយមានសេចក្តី

ស្នេហាស្រឡាញ់ដូចជាជីតាបង្កើតរបស់ខ្លួន បានធ្វើឧបការជាប្រយោជន៍ដល់នាងជីតា ដោយប្រដាប់សម្រាប់តែងកាយទាំងឡាយមានគ្រឿងក្រអូប ផ្កាកំរងនិងសំពត់ស្បៀកដណ្តប់ជាដើម, លុះដល់ពេលដែលនឹងត្រឡប់ទៅវិញក៏បាននិយាយនឹងនាងជីតានោះថា: ម្នាលនាង! បណ្តាសេះរបស់យើងទាំងអស់នេះ បើនាងត្រូវការដោយសេះណាមួយ ចូរនាងរើសយកតាមគាប់ចិត្តរបស់នាងចុះ ។

នាងតុណ្ឌណីបានស្តាប់ហើយ ក៏មានចិត្តត្រេកអរ បានពិនិត្យមើលសេះទាំងនោះ បានឃើញកូនសេះសិន្ធពមួយជាទីពេញចិត្តខ្លួន ហើយនិយាយតបថា បពិត្របិតា! សូមលោកឲ្យកូនសេះនេះដល់នាងខ្ញុំចុះ ។

ឈ្មួញសេះនោះ បានពោលផ្ទួនទៀតថា ម្នាលនាងអើយ! កូនសេះនេះជាកូនសេះសិន្ធពពិត ដូច្នេះ ត្រូវនាងកុំប្រមាទប្រហែសធ្វេសឡើយ ត្រូវនាងខំយកចិត្តទុកដាក់ថែទាំរក្សាកូនសេះនេះឲ្យល្អចុះ ។ លុះពាណិជបានពោលយ៉ាងនេះហើយ ក៏បានប្រគល់កូនសេះនោះដល់នាងតុណ្ឌណីទាសិកានោះឯង ហើយក៏នាំសេះដទៃក្រៅពីនេះចៀសចេញទៅក្នុងកាលនោះឯង ។ ចំណែកឯនាងជីតាក៏ខំយកចិត្តទុកដាក់ថែទាំកូនសេះសិន្ធពនោះដោយប្រពៃ ហើយបានដឹងច្បាស់ថា កូនសេះសិន្ធពនេះមានឫទ្ធិច្រើនអាចហោះត្រេចទៅតាមអាកាសបានដោយពិត នាងបានរំពឹងគិតទៀតថា អាត្មាអញនឹងបានកូនសេះសិន្ធពនេះជាសំឡាញ់ក្នុងការធ្វើ

បុញ្ញកម្មរបស់អាត្មាអញក្នុងកាលជាខាងក្រោយ ដ្បិតទីកន្លែងដើមពោធិព្រឹក្ស នៃព្រះមានព្រះភាគដែលព្រះអង្គបានកំចាត់បង់មារពិភពជាបុគ្គលបាបលាមក ព្រមទាំងពលសេនារបស់មារបានឈ្នះស្រឡះហើយ ព្រះអង្គបានត្រាស់ជាព្រះពុទ្ធប្រាកដក្នុងលោកនេះ ទីកន្លែងដើមពោធិព្រឹក្សនោះ អាត្មាអញពុំដែលបានឃើញ ពុំដែលបានគោរពដល់ម្ដងឡើយ បើដូច្នេះ ត្រូវតែអាត្មាអញទៅក្នុងទីនោះទង់ថ្វាយបង្គំពោធិព្រឹក្ស នៃព្រះមានព្រះភាគនោះឯង លុះនាងពុទ្ធណីបានសិការគិតយ៉ាងនេះហើយ ក៏បានបរិច្ចាគទ្រព្យឲ្យពួកជាងទងចាត់ចែងធ្វើគ្រឿងបូជា មានផ្កាកម្រងមាសប្រាក់ជាដើមយ៉ាងច្រើន ៗ សម័យថ្ងៃមួយ នាងក៏បានឡើងជិះលើខ្នងសេះសិន្ធព ហោះទៅតាមអាកាសដោយកម្លាំងពាប់រហ័សតែមួយស្របក់ក៏បានដល់ពោធិព្រឹក្ស ហើយនាងចុះពីលើខ្នងសេះទៅស្ថិតនៅក្នុងទីមណ្ឌលជិតដើមពោធិព្រឹក្សនោះ ហើយស្រែកប្រកាសឃោសនាកេព្រះសង្ឃទាំងឡាយថា: បពិត្រព្រះសង្ឃដ៏ចំរើន! សូមលោកទាំងឡាយនិមន្តទទួលយកផ្កាកម្រងមាសប្រាក់នេះ ហើយបូជាព្រះមហាពោធិព្រឹក្សក្នុងកាលឥឡូវនេះឯង ៗ ព្រោះហេតុដូច្នេះបានជាព្រះអរហន្តទាំងឡាយពោលជាបទព្រះគាថាដូច្នេះថា: យសោ បដ្ឋាយ សត្ថុ សាសនេ សុទ្ធមានសា បសន្នា តេន សច្ចេន មមានុក្កហា ពន្ធិយា ជាដើម អធិប្បាយថា ខ្ញុំមានចិត្តស្អាត មានចិត្តជ្រះថ្លាក្នុងសាសនាព្រះ

សម្មាសម្ពុទ្ធជាម្ចាស់ បានផ្តើមឡើងដោយពាក្យសច្ចៈឯណា សូមលោកម្ចាស់ទាំងឡាយនិមន្តមកនមស្ការបូជាពោធិព្រឹក្ស ដោយផ្កាកម្រងមាសប្រាក់ទាំងឡាយ ដើម្បីភ្ជាប់នូវសេចក្តីអនុគ្រោះចំពោះខ្ញុំម្ចាស់ ដោយពាក្យសច្ចៈនោះ ។ ចំណែកឯព្រះអរិយសាវកជាពុទ្ធបុត្រទាំងឡាយដែលនៅក្នុងជម្ពូទ្វីបទាំងប៉ុន្មាន លុះបានស្តាប់ពាក្យនាងពុទ្ធណីឧបាសិកាពោលយ៉ាងនោះហើយ ក៏សឹងចូលមកប្រជុំគ្នាក្នុងទីនោះមួយរំពេចហើយបាននមស្ការថ្វាយបង្គំបូជាព្រះមហាពោធិព្រឹក្ស ដោយផ្កាកម្រងមាសប្រាក់ របស់នាងពុទ្ធណីឧបាសិកានោះឯង ។

ចាប់ដើមតាំងពីកាលនោះមក នាងធីតានោះមានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនាពន់ពេក តែងឡើងជិះសេះហោះទៅបូជាព្រះពោធិព្រឹក្សជាមួយនឹងព្រះអរិយសាវកទាំងឡាយអស់កាលជានិច្ច ។

គ្រានោះ មនុស្សទាំងឡាយមានប្រើរៃព្រជាដើមដែលបានត្រេចទៅក្នុងទីជិតក្រុងបាតលីបុត្តទាំងប៉ុន្មាន កាលបើបានឃើញរូបសម្បត្តិដ៏មានសិរីសួស្តីរបស់នាងពុទ្ធណីនោះរឿយៗហើយ ក៏យកសេចក្តីទៅក្រាបបង្គំទូលដល់ព្រះបរមក្សត្រិយ៍ដូច្នេះថា: បពិត្រព្រះសម្មតិទេព! ដ្បិតឥឡូវនេះមាននាងកុមារីកាម្នាក់មានរូបល្អ មានសភាពសមរម្យល្មមធ្វើជាអគ្គមហេសីព្រះសម្មតិទេពបាន សូមព្រះអង្គទ្រង់ជ្រាប ។ ព្រះបរមក្សត្រិយ៍ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ក៏ចាត់សេវកាមាត្យឱ្យបញ្ជានូវបុរសទាំងឡាយ

ដើម្បីពួនចាប់នាងនោះ ដោយព្រះរាជឱង្ការត្រាស់បង្គាប់ដូច្នេះថា ម្នាលនាយធំចំរើនអើយ! បើដូច្នេះត្រូវអ្នកទាំងឡាយបបួលគ្នាព្រួតចាប់នាងធីតានោះឲ្យតែខានបាន យើងនឹងអភិសេកជាអគ្គមហេសីឲ្យវានេះឯង ។

ឯរាជបុរសដែលបានទទួលព្រះរាជបញ្ជាទាំងប៉ុន្មាន ក៏បានយកចិត្តទុកដាក់ព្រមគំនិតគ្នាថា យើងទាំងឡាយនឹងព្រួតចាប់នាងធីតានៅវេលាដែលបានធ្វើបូជាព្រះពោធិព្រឹក្សរួចហើយត្រឡប់មកវិញ ឲ្យបានតាមព្រះបញ្ជានោះឯង, លុះរាជបុរសទាំងនោះគិតដូច្នេះហើយ ក៏លាក់ខ្លួនពួនក្នុងទីកំបាំងមួយនៅសងខាងផ្លូវ ប្រុងប្រៀបនឹងចាប់យកនាងធីតានោះ ។

គ្រានោះ នាងពុទ្ធណីកុមារិកាក៏បានឡើងជិះលើខ្នងសេះ ហើយបរហោះទៅតាមអាកាស នាងបានទៅដល់មណ្ឌលមហាពោធិព្រឹក្សហើយ ក៏បូជាផ្កាកម្រងជាមួយនឹងព្រះអរិយទាំងឡាយរួចស្រេចហើយ ថ្វាយបង្គំត្រឡប់មកវិញ ។

កាលនោះមានព្រះអរហន្តមួយអង្គ ព្រះនាមធម្មរក្ខិតត្ថេរ លោកបានជ្រាបហេតុនោះជាក់ច្បាស់ ទើបលោកមានថេរវាចានឹងនាងពុទ្ធណីនោះថា ម្នាលឧបាសិកា! អាត្មាភាពបានឮថាក្នុងពាក់កណ្ដាលផ្លូវខាងមុខនោះ មានចោរទាំងឡាយច្រើន បង្កប់ពួនលាក់ខ្លួនស្ងាត់នៅក្នុងទីនោះដើម្បីចាប់នាង បើនាងបានទៅដល់ទីនោះហើយ ត្រូវកុំប្រមាទប្រហែសធ្វេសខ្លួនឡើយ ត្រូវបរសេះទៅឲ្យលឿនឲ្យរហ័សទើបរួចខ្លួន ។

ចំណែកឯនាងតុរទ្ទណីទុច្ចសិកាសោត កាលបើបានទៅដល់ទី នោះហើយ ស្រាប់តែចោរទាំងឡាយចេញមកអំពីផ្ទៃទាំងសងខាងគេ ដេញប្រដិតជាប់តាមពីខាងក្រោយ នាងៗក៏ឲ្យសញ្ញា យកកែងគោះសេះៗ នោះក៏ស្ទុះទៅដោយរហ័ស ចោររាំងឡាយរត់ដេញជាប់តាមក្រោយពុំ លែងឡើយ ។

ឯសេះសិន្ធពសោត ក៏ញុំាងកម្លាំងយ៉ាងខ្លាំងឲ្យកើតឡើង ហើយ ស្ទុះហោះទៅលើអាកាសដោយសំទុះដ៏ឆាប់រហ័សនោះ ។

នាងតុរទ្ទណីកុមារិកា ពុំអាចទប់អាត្មានៅលើខ្នងសេះបាន ក៏ភ្លាត់ ធ្លាក់ខ្លួនចុះអំពីខ្នងសេះ នាងស្រែកហៅសេះសិន្ធពថា នែកូនអើយ ! អ្នកត្រូវនឹករលឹកឧបការគុណ ដែលម្ដាយបានធ្វើដល់អ្នកកុំភ្លេចឡើយ ។ កូនសេះសិន្ធពនោះបានស្ដាប់ហើយ ក៏ត្រឡប់ហោះបន្ទាបចុះមកដោយ ឆាប់រហ័សយកខ្នងទទួលនាងតុរទ្ទណី ដែលធ្លាក់ចុះមកនោះឲ្យជិះនៅ លើខ្នងវិញដដែលពុំឲ្យធ្លាក់ចុះដល់ដីឡើយ ហើយស្ទុះហោះទៅលើអា កាសវិញតែម្ដងរំពេច នាំនាងទៅឲ្យស្ថិតនៅក្នុងទីលំនៅរបស់នាងវិញ ដដែល ពុំមានសេចក្ដីអន្តរាយអ្វីឡើយ ។ ព្រោះហេតុនោះព្រះអរហន្ត ទាំងឡាយលោកពោលបទព្រះគាថាដូច្នេះថា:

តិរច្ឆានគតា ចេវ សរន្តិ ឧបការំ តំ
ន ជហន្តិ មន្ទាន កតញ្ញូ ហោន្តិ ទាណិនោ

អធិប្បាយថា: សត្វទាំងឡាយបានដឹងថា ពួកសត្វតិរច្ឆានកាលរំលឹកនូវឧបការគុណគេ ហើយរមែងពុំលះបង់ចោលបុគ្គលដែលមានគុណនោះឡើយ លុះបានដឹងដូច្នេះហើយ ត្រូវតែធ្វើកតញ្ញូកតវេទីនឹងលោកអ្នកមានឧបការគុណដល់ខ្លួនដោយពិត ។ ឯនាងពុទ្ធណីកុមារិកាចាប់ដើមតាំងពីកាលនោះមក នាងបានចំណាយទ្រព្យទាំងប៉ែតសិបប្រាំពីរកោដិ ឲ្យប្រព្រឹត្តទៅក្នុងព្រះពុទ្ធសាសនាតែម្យ៉ាង ហើយបានរក្សាសីលប្រាំ ធ្វើនូវឧបោសថសីលពុំដែលដាច់ដរាបដល់អស់ជីវិត ។ លុះនាងពុទ្ធណីឧបាសិកានោះ ច្យុតអំពីអត្តភាពនោះក៏ឡើងទៅកើតក្នុងស្ថានទេវលោកនាយសោយទិព្វសម្បត្តិទាំងដប់ប្រការ មានរូបទិព្វជាដើម នាងប៉ិតនៅក្នុងប្រាសាទកែវទាំង៧ប្រការ ដ៏ពេញដោយស្រីទេពអប្សរជាបរិវារគេស្ងាប្រក្នុងពេលមួយរំពេច ដូចជាភ្ញាក់អំពីដេកលក់ដូច្នោះ ។

ព្រោះហេតុនេះ បានជាព្រះអរហន្តទាំងឡាយលោកពោលប្រារព្ធផលានុផលដោយបទព្រះគាថាដូច្នេះថា :

អតីតបុណ្ណាវយា កោ មាតុគាមាបិ ឃរំ
វិវិធកុសលកម្មំ កត្វា សគ្គំ វជន្តិ
កុសលផលមហន្តំ មញ្ញមានា ភវន្តា
ភវេ កតបុញ្ញា ឆណមានាធិកាមេ

អធិប្បាយថា បពិត្រអ្នកដ៏ចំរើន ! សូម្បីស្ត្រីមានវ័យក្មេងពេក ម៉្លេះ គង់ចេះមានប្រាជ្ញាឃើញត្រូវ អាចលះបង់ទ្រព្យជាច្រើន ធ្វើអំពើជាកុសលផ្សេងៗ ហើយបានឡើងទៅកាន់ស្ថានសួគ៌ សោយទិព្យសម្បត្តិយ៉ាងនេះ, ចុះអ្នកដ៏ចំរើនទាំងឡាយ កាលបើបានដឹងថា ផលរបស់កុសលមានច្រើនយ៉ាងនេះហើយ ទឹងធ្វើព្រងើយកន្តើយក្នុងកុសលកម្មមានទានខទឹងការបូជាជាដើមដូចម្តេចកើត ត្រូវតែខំខ្វល់ខ្វាយចំណាយទ្រព្យធ្វើទានជាដើមទើបគួរ ។

សម្តែងរឿងនិទាន នាងពុទ្ធណី ។ បាសិកាជាគំរប់បួន ក្នុងវគ្គទី១ :នេះ ក៏ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណោះឯង ។

៥– អហិតុណ្ឌិកវត្ថុគាថា សម្តែងរឿងនិទានព្រានពស់ដូចមានគេហៅថា ឥមស្មឹ កិរ ភទ្ទកប្បេ ដូច្នេះជាដើម សេចក្តីថា នៅក្នុងភទ្ទកប្បនេះ មានព្រះបរមគ្រូសាស្តាចារ្យមួយព្រះអង្គ ទ្រង់ព្រះនាមកស្សបៈ ព្រះអង្គបានត្រាស់ឡើងប្រាកដក្នុងលោក ព្រះអង្គតែងសម្តែងធម៌ទេសនា ចម្លងមនុស្សលោក ព្រមទាំងទេវលោក ឲ្យឆ្លងផុតកាត់សមុទ្ទសាគរគឺសំសារវដ្តឲ្យបានដល់ត្រើយគឺព្រះនិព្វាន ព្រះអង្គញុំាងពុទ្ធកិច្ចឲ្យសម្រេចស្រេចហើយ ទ្រង់ចូលព្រះបរមនិព្វានទៅ បីដូចជាព្រះអាទិត្យអស្តង្គតដូច្នោះឯង ។

កាលនោះ មនុស្សទាំងឡាយដែលនៅក្នុងជម្ពូទ្វីបបានកសាងព្រះ

ចេតិយមានកំពស់មួយយោជន៍ គឺយកថ្មនោសិលាមកធ្វើជាជ័ស្អិត យកប្រេងមកធ្វើជាទឹក លាយរៀបភ្ជាប់ឥដ្ឋមាសមួយដុំ ៗ មានតម្លៃមួយកោដិ ៗ ទាំងវិចិត្រដោយកែវផ្សេង ៗ ពីខាងក្រៅ ហើយភ្ជាប់ឥដ្ឋមាសមួយដុំ ៗ មានតម្លៃប្រាំបីកោដិ ៗ ញដីផ្ទៃខាងក្នុង ស្រេចហើយធ្វើសក្ការបូជាយ៉ាងធំបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធអង្គនោះ ។

កាលនោះ មានព្រានពស់ម្នាក់ តែងចាប់ពស់យកបានមក ហើយក៏បង្ហឹកបង្ហាត់ប្រើពស់ឲ្យលេងល្បែងផ្សេង ៗ យកឈ្នួលពីប្រទេសនានា មានស្រុកនិគមពជនបទជាដើម ជាស្បៀងចិញ្ចឹមជីវិតខ្លួននិងកូនប្រពន្ធជានិច្ច លុះបានចូលទៅដល់ស្រុកមួយ ក៏បានឲ្យពស់លេងល្បែងផ្សេង ៗ ក្នុងស្រុកនោះ អ្នកស្រុកទាំងឡាយក៏មានសេចក្តីត្រេកអរបានឲ្យរង្វាន់ជាច្រើន ព្រានពស់នោះបានបរិភោគខាទនីយៈនិងភោជនីយៈឆ្អែតបរិបូណ៌ ហើយ ទើបសំណាក់អាស្រ័យនៅក្នុងស្រុកនោះឯង ។

បានឮមកថា មនុស្សទាំងឡាយដែលនៅក្នុងស្រុកនោះសុទ្ធតែជាមនុស្សសម្មាទិដ្ឋិ អ្នកកាន់គោរពប្រតិបត្តិព្រះរតនត្រ័យទាំងបីដោយច្រើន , ព្រោះហេតុដូច្នោះ ក្នុងវេលារាត្រី មនុស្សជាឧបាសកឧបាសិកាទាំងឡាយ កាលបើដេកនិងទទួលដំណេកគេសូត្រនមស្សការរំលឹកគុណព្រះរតនត្រ័យថា:

(នៅមានត)

លោកអ៊ឹម-គន ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស កឹម-តួរ ពិនិត្យ

---

វីអាឯចារ្យសេនកស្តាប់ព្រះបន្ទូលមហាក្សត្រហើយ ហេតុតែជាអ្នកលោភស័ក្តិយសទ្រព្យរបស់ច្រើន ចង់បានលាភសក្ការៈនោះម៉ែញ ក៏មកគិតទូលថា បពិត្រមហារាជអើយ នាបីលោកហៅជាអ្នកប្រាជ្ញសុភាព មាត្រាបានធ្វើសាលាប៉ុណ្ណោះម៉្លោះទេគូរ លោកមិនគប់ហៅជាអ្នកប្រាជ្ញបានឡើយ បពិត្រមហារាជអើយ រឺអំពើការតម្រិះអ្នកនោះតែអម្បាលម៉្លោះ ហៅចំណេះនោះតិចណាស់ណាមហារាជ ។ រីមហាក្សត្រស្តេចស្តាប់ពាក្យអាចារ្យសេនកទូលដូច្នោះហើយ ក៏ស្តេចគង់ស្ងៀមនៅវិញហោង ទើបស្តេចបន្ទូលថា នែអ្នកតាំងឡាយអើយ ចូរទៅកាន់រាជអមាត្យនៅស្រុកបាចិនយវមជ្ឈគ្រាម ហើយចូលឲ្យរាជអមាត្យតាំងឡាយនោះមើលគលចំណាំ ចៅបណ្ឌិតអ្នកប្រាជ្ញនោះ ក្រែងមានហេតុការណ៍ម្តេចៗវិញទៀតនោះ ចូរឲ្យមានដំណឹងមកដល់អញឲ្យបានដឹងផង ។ រីរាជទូតនោះ ក្រាបថ្វាយបង្គំប្រណម្យលាមហាក្សត្រ ទៅប្រាប់ពតិមានដូចមហាក្សត្របន្ទូលផ្តាំនោះហោង ។

តត្រិទំ វិមំសនធុតាធំ បតិគ្រោះហើយ ក៏យើងនឹងស្រដីដំណើរ ដំណាលកាលព្រះបាទវិទេហរាជ ស្តេចត្រាស់ប្រើឲ្យរាជអាមាត្យទៅនៅ ចាំមើលល្បែងនៃព្រះមហោសថ ប្រាកដកាលព្រះអង្គយកជាតិកំណើត ជាពោធិសត្វនោះឯង ។

មំសំ គោណោ គន្ធិ សុត្តំ បុត្តំ គោធំ រថេន ច
ទណ្ឌោ សីសំ អហិ ចេវ កុក្កុដោ មណី វិជាយនំ
ឱទនំ ពាលុកញ្ចាបិ តាឡាកំ ឧយ្យានំ គទ្រភោ
មណីតិ ។

មំសំ គឺល្បែងសាច់ ១, គោណោ គឺល្បែងគោ ១, គន្ធិ គឺល្បែងសង្ហារ ១, សុត្តំ គឺល្បែងអំបោះ ១, បុត្តំ គឺល្បែងកូន ១, គោធំ គឺល្បែងគោធកាឡ ១, រថេនច គឺល្បែងរទេះ ១, ទណ្ឌោ គឺល្បែងកំណាត់ឈើ ១, សីសំ គឺល្បែងក្បាលខ្មោច ១, អហិ ចេវ គឺល្បែងក្បាលពស់១, កុក្កុដោ គឺល្បែងមាន់១, មណី គឺល្បែងកែវមណីតែខ១ វិជាយនំ គឺល្បែងការប្រសូតកូន១, ឱទនំ គឺល្បែងបាយជូរ១, ពាលុកាញ្ចាបិ គឺល្បែងខ្សែខ្សាច់ ១, តាឡាកំ គឺល្បែងស្រះ ១ ឧយ្យានំ គឺល្បែងឧទ្យាន១, គទ្រភោ គឺល្បែងលា១, មណីបិ គឺល្បែងមណីជាគ១ ។ រីអស់ការល្បែងផងទាំងឡាយនោះ ឯក្នុងវី-សតិ មាន១៩គត់, ឡើយទីលែងល្បែងផងទាំងឡាយនោះ យើងទុក

ស្មុះនៅនេះសិន, នេះខឹងស្រដីល្បែងសាច់ឯងជាដើម ។

ឯកាទិវសំ ពោធិសត្តោ គាមឡ្យាមណ្ឌលំ គច្ឆន្តោ ឯកោ សេតោ សុខជលកាគោ មំសបេសី គហេត្វា អាកាសេន បក្កន្តិ ។ មានកាលសម័យថ្ងៃមួយព្រះពោធិសត្វមហាបុរសរតនវិសេស អ្នកដើរទៅកាន់ឋានមណ្ឌលល្បែងអ្នកនេងលេងសព្វថ្ងៃនោះ ។ កាលនោះ មានអ្នកជងមកចតសម្រាន្តនៅបរមសាលានៃព្រះមហាសត្វនោះ ហើយហាលសាច់នៅព្រំចុងក្តារបែនបរមសាលានោះហោង ។ កាលនោះ មានសត្វខ្លែងមួយ ពាំហើរមកឆាបឆក់យកនៀតសាច់អំពីចុងក្តារបែននោះ ស្ទុះហោះហើរនាំឡើងទៅនាកណ្តាលអាកាសនោះហោង ។ រីអស់ក្មេងជងជាបរិវារនៃពោធិសត្វនោះមិញ កាលណាឃើញមើលឃើញខ្លែងពាំឆាបឆក់សាច់នោះហើយ ពាំស្រែកហៅហៅគ្នាទៅវិញទៅមក ឲ្យដេញយកនៀតសាច់អំពីខ្លែងនោះហោង ស្ទុះហើយរីអស់ក្មេងជងទាំងឡាយនោះ នាំគ្នាដេញតាមដោយក្រោមខ្លែងហើរនោះឯង ។ រីខ្លែងនោះ ពាំពុំខ្លាចអំណាចក្មេងដេញនោះឡើយ ហើយពាំហើរអំពីនោះទៅកាន់ឋានឯណា ៗហើយ រីអស់ក្មេងជងទាំងនោះ ក៏ពាំពុំលែងឡើយ ដើរពាំតែងរត់ វក្កុតពាំតែងមើលឯលើ តាមដោយក្រោមខ្លែង ដ៏មានដើរនោះដំពប់ទីងដុំដី ដុំថ្ម កំណាត់ឈើ អម្បែងចែស អម្បែងចាន ក្រួសរាំងគល់ឈើ ចុះឈើ នោះពាំដួល

ភ្នែកចុះ ជន្ទឹងវេលាក់ មាត់នោះដូចជាគេទាំងដី ផង់ចូលទ្វារចក់កក់ជាប់មុខ ស្រមូញស្រមាញ ប្រាប់ហើយឡើងម៉ឺនម្ចាស់ដេញទៅទៀត ។

ឮដឹកាលនោះ រីព្រះពោធិសត្វអ្នកស្រដីទៅនឹងអស់ក្មេងទាំងឡាយថា ម្នាលក្មេងទាំងឡាយអើយ ចូរអ្នកទាំងឡាយមើលអញ អញនឹងដេញខ្លែងនោះឯងឥឡូវនេះ ឲ្យខ្លែងនោះមានខ្ទួនភិតភ័យ ហោះទៀតសាច់នោះឥឡូវនេះមិនខានឡើយ ទោះហើយអស់ក្មេងទាំងឡាយស្រដីថាសាមិ បពិត្រអង្គម្ចាស់អើយ ចូរម្ចាស់ធ្វើឲ្យខ្លែងនោះរាប់ប្រោសលះបង់ចោលនូវនៀតសាច់នោះល្បងមើលម្ចាស់ ។ រីព្រះមហាសត្វស្តាប់ព្រះហើយឆ្លើយថា អើបើដូច្នោះ ចូរអ្នកទាំងឡាយមើលអញណា ។ ទើបពោធិសត្វអ្នកលីលាចុះពីប្រាសាទនោះ ហើយអ្នកសំឡឹងមើលឡើងទៅលើ ហើយអ្នករត់តាមដោយនូវកម្លាំងនៃអ្នកនោះឆាប់ស្មើខ្យល់ ព្រះអង្គយល់ស្រមោលខ្លែងនោះហើយ អ្នកទះនូវព្រះហស្តផាំងៗហើយអ្នកស្រែកនូវសំឡេងសំរែកនោះខ្លាំងក្រៃ រីសំឡេងនោះទ្រហឹងទៅដល់ខ្លែងនោះរាក់តិតស្លុតហាក់ដូចគេតុះទំលាយទ្រូងចេញ ហើយខ្លែងនោះភិតភាំងវីងភាំងអស់ទាំងចំណេងស្មាច មិនប្រឹងហើរទៅរួចឡើយ ដោយនូវតេជះព្រះប្រាជ្ញាបារមីនៃអ្នកនោះហោង ។ ពោធិសត្វអ្នកមើលមើលតែស្រមោលខ្លែងហើរនោះហើយអ្នកទះស្រមោលខ្លែងនោះក្តី ខ្លែងក៏ប្រឹងវែងពុំបាន ក៏ជំរុះនូវនៀតសាច់ស្រាប់ហើយ អ្នកស្ទុះឡើងទៅទទួល

ចាប់យកនូវដុំសាច់នោះអំពីកណ្ដាលអាកាសនោះឯងបានហោង ពុំអាច ដើម្បីនឹងឲ្យជ្រុះចុះដល់ដីឡើយ ។ បពិត្រអ័យ រីអស់មហាជនផងទាំងឡាយនោះ យល់ឃើញហេតុមានជាអស្ចារ្យដូច្នោះហើយ សឹងស្រែកទូរស័ព្ទសំរែកនោះខ្លាំង ឲ្យសាធុការមហិមាកងរំពងក្រពេក ។

រីរាជអាមាត្យនោះ បានដឹងយល់ស្គាល់ប្រាកដហើយ ប្រើរាជទូតចូលទៅក្រាបទូលព្រះបាទវិទេហរាជ ដោយដំណើរដែលអាត្មាបានយល់ប្រាកដនោះហោង ។ ព្រះបាទវិទេហរាជជ្រាបសុភាពដូច្នោះហើយ មានព្រះហឫទ័យនោះត្រេកអរសាទរមហិមា ហើយបន្ទូលទៅកាន់អាចារ្យសេនកថា នៃអាចារ្យសេនក ឥឡូវនេះ យើងនឹងឲ្យទៅនាំយកនូវចៅអ្នកប្រាជ្ញនោះមកឬម្ដេចហ្ន៎ ? ។ រីអាចារ្យសេនកនោះ ហេតុតែជាអ្នកកំណាញ់យសលាភនោះមិញ ក៏គិតក្នុងចិត្តថា បើអញគិតព្រមលួមឲ្យទៅនាំចៅអ្នកប្រាជ្ញនោះមកហើយ រីអស់យើងជាអ្នកប្រាជ្ញទាំង ៤ នេះ គឺសឹងកើតជាអ័ប្បយសចុះលាភសក្ការៈផងពុំបានដូចកាលអំពីមុននោះឡើយ ពោះយោបីស្ដេចជ្រាបថាជាអ្នកប្រាជ្ញក្ដី ពោះពុំថាជាអ្នកប្រាជ្ញក្ដី យើងគិតឲ្យស្ទះទុកនៅនោះសិនហោង ។

រីអាចារ្យនោះគិតដូច្នោះហើយ ក៏ក្រាបទូលឃាត់ពុំឲ្យមហាក្សត្រស្ដេចឲ្យទៅនាំចៅមហោសថអ្នកប្រាជ្ញនោះមកឡើយ ។ រីអាចារ្យសេនកកាមិន្ទ, ទេវិន្ទ, បុក្កុស គិតព្រមគ្នាដូច្នោះហើយទូលថា

បពិត្រមហារាជអើយ , នាយលោកហៅថាអ្នកប្រាជ្ញផង មានប្រការអម្បាលនោះហើយ លោកក៏មិនគប្បីហៅថាជាអ្នកប្រាជ្ញឡើយ, បពិត្រអម្ចាស់អើយ តែព្រះចៅមហោសថតែប៉ុណ្ណោះ ដូច្នេះនោះ គឺហៅតព្រះតិចណាស់គាត់ណាមហារាជ ។ ព្រះមហាក្សត្រស្ដេចស្ដាប់ពាក្យអាចារ្យទាំង៤នោះហើយ ស្ដេចគង់ស្ងៀមនៅហោង, ទើបស្ដេចត្រាស់ប្រើរាជទូតនោះ ឲ្យនាំពាក់មាន់ទៅកាន់រាជសាមាត្យនោះវិញទៀត ប្រយោជន៍ដើម្បីនឹងឲ្យដឹងទូវដំណឹងនៃចៅអ្នកប្រាជ្ញនោះហោង ។

ឯកោ ចាបិឧយវឌ្ឍគាមកសបុរិសោ ។ល។ ទិត្ថមិ ។ បពិត្រអើយ រឿងស្រដីល្បងគោសោត កាលនោះមានបុរសកំសត់មួយចិញ្ចឹមជីវិតអាត្មា នៅស្រុកបាចីនយវមជ្ឈគ្រាមនោះ លុះដល់ខែហោរទូវដូវក្លៀងឥទ្ធិបុះគូរ បុរសនោះគិតក្នុងចិត្តឯងថា អញអើយ ឥឡូវនេះមិញក្ដី ដូវក្លៀងឥទ្ធិបុះហើយ ដូច្នេះតែអញបានឮថាគោជាគ្រឿងនឹងធ្វើស្រែនឹងគេអេះ បុរសនោះគិតដូច្នោះហើយ ក៏យកនីទៅខ្ចីមាសប្រាក់ ដើរសេស្រាក់ទៅគេទិញគោគេអំពីស្រុកឯទៀត ជើរនោះបានហើយ កាស្រ័យនាំមកបានដល់នេះអាត្មា លុះព្រឹកឡើងវិញទៀតហើយ ទើបបុរសនោះនាំគោចេញទៅទឹះឲ្យធីស្មៅនេះពួងព្រៃបឹងក្រោម បុរសនោះដិះលើខ្នងគោនោះទៅ ដ៏មានខ្លួននោះនឿយព្រួយលំបាក ហេតុត្រូវខ្យល់អំពល់ទូកំដៅព្រះអាទិត្យជិតបៀតបៀនអាត្មា ហើយមិនមាចុះចេញ ហើយលែងគោទៅឲ្យធីស្មៅ ហើយទៅអង្គុយ

ក្រោមម្លប់ឈើមានពួដំកូមិចាស់មួយក្លាំ  ចាប់ជួនត្រូវខ្យល់បក់មកត្រជាក់ ហើយត្រសៀកា  ក៏ប្រះខ្លួនដេកវុះលក់ស្រមុកខ្ញុរៗ នៅក្រោមម្លប់ឈើ នោះហោង ។ ពួដំកាលនោះសោត មានអាចារម្នាក់ពាលមកលួចយក បានគោនោះដឹកនាំពង្រត់ទៅហោង ។ រីឯម្ចាស់គោនោះវិញ ភ្ញាក់រលឹក ដោះឡើងអំពីដេក  ក្រឡេកមើលមើល ទៅមិនឃើញគោនោះឡើយ ហើយក្រោកដោះឡើងមើលទៅឯណាឯណោះហើយក្លាំ  យល់អាចារ វាដឹះបំបោលគោនោះចេញទៅហោង ។

រីឯបុរសនោះវិញ  រត់ដេញតាមទៅដោយខ្ទូវកំឡាំងនោះឆាប់ក្ដាត់ ផិតៈទៀបហៀបនឹងដល់ក្លាំ  ក៏ស្រែកទៅថា  វះយៗឯងយកគោអញទៅឯ ណាហ្នឹង ? ។ ឯអាចារនោះត្បៈហើយឆ្លើយថា  យើ ! ឯណាគោព្រះស្ដេង នោះហ្នឹង ! គោអញអេះ, ក៏ម្ដបព្រះស្ដេងមកថាគោព្រះស្ដេងដូច្នោះហ្នឹង! ម្នោះហើយបុរសទាំង ២ នោះកើតពាក្យជំលោះប្រកែកទៅមកកាន់គ្នានោះ ត្រៃគក, វែសមហាជនទាំងពួង  សឹងឮគូវស័ព្ទជំលោះប្រកែកនៃបុរស ទាំង ២ នោះហើយ  សឹងជំនុំគ្នានៅបរមសាលានៃចៅអ្នកប្រាជ្ញនោះ លុះ បុរសទាំង ២ នោះប្រកែកគ្នាទៅដល់ទ្វារសាលានោះហើយ  ទើបពោធិ- សត្វឲ្យហៅបុរសទាំង ២  នោះមកហើយ  ព្រះមហាសត្វអ្នកយល់ បុរសទាំង ២ នោះហើយ  អ្នកស្គាល់ដោយនូវព្រះប្រាជ្ញាឯងថា អ្នក នោះឯងជាចោរ  បុរសនោះឯងជាម្ចាស់គោ  រីពោធិសត្វសួរអ្នកជឹង

ហើយក៏អ្នកធ្វើជាមិនដឹងវិញ, ហើយមានព្រះបន្ទូលថ្លែងថា ម្នាលបុរសទាំង ២ អើយ នាព្រះស្ដែងទាំង២ ធ្វើពាក្យដំណោះប្រកែកនឹងគ្នានេះ តើហេតុប្រការអ្វីហ្នឹង ? រីបុរសជាម្ចាស់គោនោះមិញ ដំណាលប្រាប់មកពោធិសត្វវិញថា សាមិ បពិត្រម្ចាស់អើយ, រីអញខ្ញុំទិញគោនេះ អំពីស្រុកនោះឈ្មោះដូច្នោះ ៗ ហើយអញខ្ញុំមកទុកក្នុងផ្ទះ លុះព្រឹកឡើងខ្ញុំនាំទៅភូមិចាស់ខាងមានស្មៅល្អ អញខ្ញុំលែងគោឲ្យស៊ីស្មៅ ហើយខ្ញុំទៅដេកក្រោមម្លប់ឈើមួយប្រណុក កាលណាបើខ្ញុំដេកលក់ហើយក្ដី គាត់នេះយកគោអញខ្ញុំនាំពង្រត់ទៅហោង ៗ កាលនោះ រីអាចោរនោះមិញទូលថា បពិត្រម្ចាស់អើយ រីគោខ្ញុំនេះវាកើតក្នុងផ្ទះខ្ញុំឯង រីគាត់នេះសោត មកស្រដីពាក្យភូតបំភោតវហ្វ គោខ្ញុំទេអម្ចាស់ , លំដាប់នោះរីចៅមហោសថអ្នកប្រាជ្ញ ស្រដីទៅនឹងបុរសទាំង ២ ថា ម្នាលបុរសទាំង ២ អើយ ចូរព្រះស្ដែងស្ទែះសណ្ដិតសេចក្ដីនេះទុកមួយអន្លើសិន , ឥឡូវនេះព្រះស្ដែងទាំង ២ ប៉ិតទៅដោយបង្គាប់ពាណិទានៃអញនេះឬទេ? ៗ បុរសទាំង ២ នោះឆ្លើយថា សូមទានបើដូច្នោះ យើងខ្ញុំទាំង ២ នេះនឹងប៉ិតព្ធដំហាននេះ ដូចបង្គាប់អម្ចាស់ហោង ៗ រីព្រះមហាសត្វអ្នកគិតថា គួរអញនឹងយកចិត្តនៃបុរសទាំង ២ នេះ ហើយនឹងដណ្ដឹងអាចោរឯងជាមុន , ទើបអ្នកដណ្ដឹងទៅចោរថា ម្នាលបុរសអើយ រីគោព្រះស្ដែងនោះ ឲ្យស៊ីអ្វីផឹកអ្វីខ្លះ ៗ ហ្នឹង ? ឯអាចោរឆ្លើយថា អម្ចាស់អើយ ! គោខ្ញុំនេះ ខ្ញុំឲ្យផឹកតែយាគូ ឲ្យស៊ីតែស្លឹកសណ្ដែកបំណែកល្ងនោះហោង ៗ

ព្រះមហាសត្វអ្នកទៀតកត់សំគាល់ស្រេចហើយ ទើបអ្នកដណ្ដឹងទៅបុរស ម្ចាស់គោនោះជាខាងក្រោយវិញ បុរសជាម្ចាស់គោនោះឆ្លើយថា អម្ចាស់អើយ, រីយោគូនេះ ខ្ញុំជាអ្នកកំសត់ទុគ៌តដូច្នេះ គេទិញបានយោគូនោះអំពីណា រីគោនេះ នឹងតែស្លាប់នោះហោង ។ ពោធិសត្វឲ្យកត់ពាក្យអ្នកទាំង ២ នោះស្រេចហើយ ទើបប្រើខ្ញុំបុរសអ្នកបំរើគាត់ ឲ្យយកទឹកដាក់ទឹកដាសស្រេចហើយ អ្នកឲ្យយកប្រិយង្គុមកដុកប្រឡាក់ទឹកឲ្យបំផឹកគោនោះហោង គោនោះកាលណាបើផឹកទឹកនោះហើយ ក៏ក្អួតចេញមកសឹងតែស្លាប់ឯងហោង ឯចៅអ្នកប្រាជ្ញដណ្ដឹងទៅកាន់អស់មហាជនទាំងឡាយថា ម្នាលអ្នកទាំងឡាយអើយ ចូរអ្នកទាំងឡាយមើលមើលចុះ ម្ល៉ោះហើយអ្នកដណ្ដឹងឯការចោរថា ម្នាលបុរសអើយ ព្រះស្តែងជាចោរឬមិនជាចោរ, ឯការចោរនោះគេឆ្លើយថា អម្ចាស់អើយ ខ្ញុំម្ចាស់ជាចោរពិតហោង ទើបពោធិសត្វមហាបុរសគន់អ្នកឲ្យដំដើង-ដៃនៃបុរសនោះឲ្យរាប់ថយកំឡាំង ទើបអ្នកឲ្យដំបូន្មានថា ម្នាលបុរសអើយ ចូរអ្នកចល់ទុក្ខនាលោកិយនេះក្សណ ដោយខ្លួសភាពចល់ប្រាកដឯង លុះព្រះស្តែងទឹងចល់ទុក្ខវេទនានៅក្នុងមហានរក ជាទូរទំក្រលែងជាងនេះទៅទៀត, ចាប់ដើមអំពីនោះទៅ កុំបីព្រះស្តែងធ្វើអំពើដូច្នេះឡើយ ។ ក្សណនោះ រាជទូតនាំពត៌មានទៅទូលព្រះបាទវិទេហរាជនោះ ។

(នៅមានត)

# ប្រវត្តិនាងឥសិទាសីថេរី

ឃុនសុវត្ថិវេទី យូរ-អ៊ុន

ប្រែចាកថេរីគាថា ត្រង់ចត្តាឡីសនិបាត

នៃសុត្តន្តបិដក ខុទ្ទកនិកាយ

---

បុរសស្ត្រីក្នុងលោកិយលុះតណ្ហា
ក្នុងកាមាធិការមេជាធំងគេ
តែងរងទុក្ខក្នុងនរកគ្មានស្រាកល្ហែ
តមកប្រែកើតជាប្រេតតិរច្ឆាន ។
រួចពីនោះកើតជាមនុស្សមានភេទខ្ទើយ
លុះបង្ហើយទើបមានភេទស្រីប្រុសប្រាណ
តែគង់វៀរតាមផ្ដន្ទាយ៉ាងក្លាហាន
ចៀសពុំបានដូចនិទានតទៅនេះ ៖-

ក្នុងនគរកុសុមបាដលិបុត្ត ដែលជាមណ្ឌលនៃផែនដី មានភិក្ខុនីពីររូប ជាធីតាក្នុងសាក្យត្រកូល ជាអ្នកមានគុណសម្បត្តិក្នុងពុទ្ធសា-សនា ។ បណ្ដាភិក្ខុនីទាំងពីររូបនោះ ភិក្ខុ១រូប ឈ្មោះ ឥសិទាសិ

ភិក្ខុនីទី២ ឈ្មោះ ពោធិ ជាអ្នកបរិបូណ៌ដោយសីល ត្រេកអរដោយការរំពឹងក្នុងឈាន ជាពហុស្សូត មានកិលេសកំចាត់បង់ជ្រះស្រឡះហើយ ។ ក្នុងថ្ងៃមួយ ភិក្ខុនីទាំងពីររូបនោះត្រាច់ទៅបិណ្ឌបាត ហើយធ្វើនូវភត្តកិច្ច លុះលាងបាត្រហើយ ក៏អង្គុយជាសុខស្រួលក្នុងទីស្ងាត់ ។ នាងពោធិភិក្ខុនីបានផ្តើមសួរថា ម្នាលឥសិទាសី នាងជាស្ត្រីមានរូបល្អស្រស់ គួរជ្រះថ្លា ចំណែកវ័យរបស់នាងក៏មិនទាន់ចាស់ទេ អ៊ីចុះ នាងឃើញទោសដូចម្តេច ទើបមកប្រកបខ្លួនក្នុងបព្វជ្ជាទេ ?

ឥសិទាសីភិក្ខុនីនោះ ជាអ្នកឈ្លាសវៃក្នុងធម្មទេសនា កាលបើពោធិភិក្ខុនីសាកសួរ ក្នុងហេតុជាប្រយោជន៍យ៉ាងនេះហើយ ក៏បានពោលនូវពាក្យនេះថា ម្នាលនាងពោធិ នាងចូរស្តាប់តាមដំណើរដែលខ្ញុំបួសចុះ ខ្ញុំនឹងសំដែងដូចតទៅនេះ :-

បិតារបស់ខ្ញុំ ជាសេដ្ឋី អ្នកសង្រួមសីល នៅក្នុងបុរីដ៏ប្រសើរឈ្មោះឧជ្ជេនី ក្នុងដែនអវន្តិ ។ ខ្ញុំជាធីតាម្នាក់ដែលជាទីស្រឡាញ់ពេញចិត្តបិតា ជាអ្នកគួរទទួលសេចក្តីអនុគ្រោះរបស់បិតានោះ ។ លុះចំណេរមកខាងក្រោយ មានសេដ្ឋីម្នាក់មានត្រកូលឧត្តម មានទ្រព្យច្រើន នៅឯនគរសាកេត បានមកដណ្តឹងខ្ញុំ ។ បិតាក៏បានឲ្យខ្ញុំជាកូនប្រសាររបស់សេដ្ឋីនោះ ។ ខ្ញុំចូលទៅក្រាបក្បាលថ្វាយបង្គំនូវជើងម្តាយក្មេកនិងឪពុកក្មេករាល់ល្ងាចព្រឹក តាមដំណើរដែលមាតាបិតាប្រដៅខ្ញុំ ។ ខ្ញុំកាលបើបាន

ឃើញនូវអ្នកដែលមកដណ្តឹងខ្ញុំ សូម្បីម្នាក់ ជាបងប្អូនប្រុស ឬបងប្អូនស្រី ឬក៏ជាបរិវាររបស់ស្វាមី ខ្ញុំក៏រលះរលាំងក្រាលអាសនៈទទួល ហើយអង្គាសផ្គត់ផ្គង់ ឲ្យបាយទឹកនឹងបន្ថែម ដែលមានក្នុងទីលំនៅនោះ តាមសមគួរដល់តែដែលគេត្រូវការ ៗ ខ្ញុំតែងក្រោកឡើងតាមកាលគួរ ហើយចូលទៅគោរពប្រណិបត្តន៍ប្តី ខ្ញុំជូតលាងដៃជើងប្តី ចាំជូតសំអាតនូវធរណីទ្វាររាំងដើម ៗ ខ្ញុំយកស្និតសក់ ម្សៅសម្រាប់លាបមុខ ថ្នាំសម្រាប់បន្តក់ភ្នែកទឹកកញ្ចក់ ស្អិតស្អាងប្តីដោយខ្លួនឯង ហាក់ដូចជាខ្ញុំស្រីដែលធ្វើនូវការបំរើម្ចាស់ ៗ ខ្ញុំដាំបាយខ្លួនឯង លាងកាដន់ខ្លួនឯង ខ្ញុំថ្នមកស្តា ដូចមាតាបិតាថ្នមកូនខ្ចី ៗ តែកស្តាខ្ញុំ តែងរឹងសម្បាទងខ្ញុំ ដែលជាស្រីបំរើបាយ គ្មានស្រីណាលើស ជាស្រីធ្វើការគ្រប់យ៉ាង ជាស្រីមិនមានសេចក្តីប្រកាន់ មានសេចក្តីព្យាយាមមិនខ្ជិលច្រអូស មានមារយាទត្រឹមត្រូវយ៉ាងនេះ ៗ ស្វាមីនៃខ្ញុំនោះ និយាយនឹងមាតាបិតារបស់គេថា ខ្ញុំសូមលាលោកឪពុកលោកម្តាយ ទៅនៅក្នុងទីណាមួយហើយ ព្រោះខ្ញុំមិនអាចនៅរួមគ្នាក្នុងផ្ទះមួយ ជាមួយនាងឥសិទាសីជាប្រពន្ធខ្ញុំឡើយ ៗ មាតាបិតានៃប្តីខ្ញុំ ពោលថា នែកូនប្រុសសំឡាញ់ កូនកុំពោលយ៉ាងនេះឡើយ នាងឥសិទាសី ប្រពន្ធកូនឯង ជាបណ្ឌិតឈ្លាសវៃ ជាស្រីមានសេចក្តីព្យាយាម មិនខ្ជិលច្រអូសទេ ទកូនអើយ ហេតុអ្វីក៏កូនមិនពេញចិត្ត

ខឹងប្រពន្ធ ៗ ប្ដីខ្ញុំពោលថា ឱលោកម្ដាយលោកឪពុក នាងឥសិទាសី មិនបៀតបៀនអ្វីដល់ខ្ញុំទេ ប៉ុន្តែខ្ញុំមិនអាចនៅជាមួយនឹងនាងឥសិទាសី ព្រោះនាងឥសិទាសីជាស្ត្រីសំអប់របស់ខ្ញុំ ខ្ញុំមិនគួរនឹងនៅរួមឡើយ ខ្ញុំសូមលាទៅហើយ ៗ ម្ដាយក្មេកនឹងឪពុកក្មេកខ្ញុំបានស្ដាប់ពាក្យប្ដីខ្ញុំនោះហើយ ក៏សួរមកខ្ញុំថា នៃកូនស្រី ចុះនាងមានធ្វើខុសអ្វីនឹងប្ដីនាងទេ នាងចូរប្រាប់កំហុសដែលនាងធ្វើហើយ តាមសេចក្ដីពិតមកចុះ ៗ

ខ្ញុំក៏តបថា ឱលោកម្ដាយលោកឪពុក ខ្ញុំមិនបានប្រទូស្តទេ ខ្ញុំមិនបៀតបៀន មិនពោលពាក្យអាក្រក់ទៅរកគាត់ទេ បើកស្ដាខ្ញុំស្អប់ខ្ញុំ តើឲ្យខ្ញុំធ្វើអ្វីត្រូវចិត្តគាត់ ៗ ម្ដាយក្មេកនឹងឪពុកក្មេកខ្ញុំនោះ ក៏អាក់អន់ចិត្តត្រូវសេចក្ដីព្រួយគ្របសង្កត់ ក៏នាំខ្ញុំត្រឡប់ទៅប្រគល់ឲ្យមាតាបិតាខ្ញុំវិញ ដើម្បីរក្សាចិត្តកូនប្រុសរបស់គាត់ ដោយគិតថា នឹងរកឲ្យបាននូវស្ត្រីមានរូបឆោមដ៏មានសិរី មកធ្វើជាប្រពន្ធនៃកូនគាត់ ៗ គ្រាក្រោយមកមាតាបិតាបានឲ្យខ្ញុំមានប្ដីម្ដងទៀត ប្ដីគ្រាទី ២ នេះ ជាអ្នកស្ដុកស្ដម្ភបានជូនជំនូនចំនួនពាក់កណ្ដាលអំពីជំនូនដែលសេដ្ឋីឲ្យកាលមុន បានជូនមកខ្ញុំនោះ ៗ ខ្ញុំនៅក្នុងផ្ទះនៃប្ដីទី ២ នោះ បានតែ១ខែគត់ គ្រានោះប្ដីខ្ញុំបែរជាស្អប់ខ្ញុំ លែងខ្ញុំចោល ដែលជាស្ត្រីខ្នះខ្នែងបំរើដូចទាសី ជាស្ត្រីមិនប្រទូស្ត មានមារយាទល្អ ៗ

ក្នុងថ្ងៃមួយ បិតារបស់ខ្ញុំ បានឃើញបុរសម្នាក់ ជាអ្នកប្រព្រឹត្តទូន្មានចិត្ត ទូន្មានកាយនិងវាចា ដែលកំពុងត្រាច់ទៅដើម្បីភិក្ខា បិតាខ្ញុំពេញចិត្តនឹងបុរសនោះ ទើបនិយាយបបួលថា អ្នកចូរមកធ្វើជាកូនប្រសារបស់ខ្ញុំចុះ អ្នកចូរបោះបោលខ្ទេកំណាត់សំពត់នឹងឆ្នាំងទៅ ។ បុរសនេះក៏បានទទួលធ្វើតាមពាក្យបិតាខ្ញុំ ហើយចូលមកនៅរួមនឹងខ្ញុំ ។ ស្វាមីទី៣ បាននៅជាមួយនឹងខ្ញុំអស់កន្លះខែ ក៏និយាយនឹងបិតាខ្ញុំថា អ្នកចូរឲ្យកំណាត់សំពត់ ឆ្នាំងនឹងអំបែងមកខ្ញុំ ខ្ញុំសូមលានឹងត្រាច់ទៅដើម្បីភិក្ខាវិញពីថ្ងៃនេះទៅ ខ្ញុំឈប់នៅក្នុងផ្ទះនេះហើយ ។ គ្រានោះមាតាបិតានឹងពួកញាតិទាំងអស់របស់ខ្ញុំ និយាយនឹងបុរសនោះថា អ្នកណាមិនធ្វើតាមអ្នកក្នុងទីនេះឬ អ្នកចូរប្រាប់ហេតុដែលគេធ្វើនោះ ដល់យើងឲ្យឆាប់ ។ បុរសនោះកាលបើគេសួរយ៉ាងនេះហើយ ក៏ពោលតបថា បើខ្លួនខ្ញុំអាចនៅបាន ក៏នាងឥសិទាសីមិនគួរនៅរួមជាមួយនឹងខ្ញុំ ព្រោះហេតុនោះខ្ញុំមិននៅជាមួយនាងឥសិទាសីក្នុងផ្ទះមួយជាមួយគ្នាទេ ។ បុរសនោះកាលបើពោលយ៉ាងនេះ រួចក៏លាបិតារបស់ខ្ញុំធ្វើដំណើរចេញទៅបាត់ទៅ ។

ចំណែកខាងខ្ញុំ ជាស្ត្រីនៅតែម្នាក់ឯង មានទុក្ខធ្ងន់ខ្លាំង គិតថា អាត្មាអញត្រូវលាមាតាបិតាទៅស្លាប់ ឬទៅបួស ។ គ្រានោះ មានថេរីមួយរូបឈ្មោះ ជិនទត្តា ជាអ្នកទ្រទ្រង់នូវវិន័យ ជាពហុស្សុត បរិបូណ៌ដោយ

សីល កាលគ្រាប់ទៅដើម្បីភិក្ខាហារ ក៏បាននិមន្តមកកាន់ត្រកូលនៃបិតារបស់ខ្ញុំ ។ ខ្ញុំកាលនាងជិនទត្តាថេរីនោះនិមន្តមកដល់ ក៏ក្រោកឡើង ក្រាលអាសនៈប្រគេន លុះព្រះនាងគង់ហើយ ខ្ញុំក៏ថ្វាយបង្គំនូវព្រះបាទា ហើយប្រគេនភោជន ។ ខ្ញុំញុំាងជិនទត្តាថេរីឲ្យឆ្អែតស្កប់ស្កល់ដោយបាយទឹកបន្ថែមដែលមានក្នុងទីលំនៅខ្ញុំនោះ ហើយទូលថា បពិត្រព្រះនាងជាម្ចាស់ ! ខ្ញុំចង់បួសឲ្យបានដូចលោកម្ចាស់ដែរ ។ គ្រានោះបិតាពោលនឹងខ្ញុំថា ម្នាលកូនស្រីបិតា កូនកុំបួស នាងចូរប្រព្រឹត្តធម៌នោះក្នុងផ្ទះនេះវិញចុះ ហើយចូរធ្វើបុណ្យឲ្យទាន ដោយញុំាងសមណៈទាំងឡាយផង ព្រាហ្មណ៍ទាំងឡាយផង ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹកចុះ ។ លំដាប់នោះ ខ្ញុំក៏ប្រណម្យអញ្ជលីយំពោលនឹងបិតាថា បពិត្របិតា ! សូមបិតាអនុញ្ញាតខ្ញុំ ខ្ញុំនឹងញុំាងបាបកម្មដែលខ្ញុំធ្វើហើយនោះឲ្យវិនាស ។ គ្រានោះ បិតាបានយល់ព្រមតាមពាក្យខ្ញុំ ហើយពោលនឹងខ្ញុំថា ព្រះសម្មាសម្ពុទ្ធព្រះអង្គប្រសើរជាងសត្វជើងពីរ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ណា នាងចូរបានលុះនូវពោធិញ្ញាណនិងអគ្គធម៌ ព្រមទាំងព្រះនិព្វាននោះចុះ ។

វេលានោះ ខ្ញុំថ្វាយបង្គំលាមាតាបិតា នឹងពពួកនៃញាតិទាំងអស់ ហើយចេញទៅបួសក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធ លុះបួសបាន ៧ ថ្ងៃ

កំបានសម្រេចវិជ្ជាថា ៗ ខ្ញុំដឹងជាតិរបស់ខ្លួនបាន ៧ ជាតិ ៗ ផលវិបាកនេះរបស់កម្មណា ខ្ញុំនឹងប្រាប់នូវកម្មនោះដល់នាង ហេតុនេះ នាងចូរមានចិត្តមូលតែមួយ ចាំផ្ទៀងសោតស្តាប់នូវកម្មនោះ ដូចតទៅនេះ

នែនាងពោធិ! ក្នុងអតីតជាតិ ខ្ញុំជាកោវប្រុស ធ្វើជាជាងមាសមានទ្រព្យច្រើននៅក្នុងនគរឯកគច្ចៈ ៗ ខ្ញុំនោះជាមនុស្សស្រវឹងវ័យ បានប្រព្រឹត្តសេពសម្ពន្ធនឹងប្រពន្ធបុគ្គលដទៃ ៗ លុះខ្ញុំឃ្លាតចាកអត្តភាពនោះហើយ ក៏ទៅធ្លាក់ក្នុងនរកអស់កាលយូរ លុះច្យុតចាកនរកនោះហើយ មកចាប់បដិសន្ធិក្នុងផ្ទៃនៃមេស្វា ៗ ស្វាឈ្មោលធំ ជាម្ចាស់នៃហ្វូង បានចាំផ្តាច់នូវគ្រឿងជាតរបស់ខ្ញុំ ដែលទើបនឹងកើតបាន ៧ ថ្ងៃ ៗ នេះជាផលនៃកម្មរបស់ខ្ញុំនោះ ដែលសេពគប់នូវប្រពន្ធនៃបុគ្គលដទៃ ៗ ខ្ញុំនោះលុះច្យុតចាកកំណើតនៃស្វានោះហើយ ក៏បានមកចាប់បដិសន្ធិក្នុងផ្ទៃនៃមេពពែ ៗ ខ្ញុំជាពពែខ្វាក់ផង ខ្វកផង ក្នុងដែននៃស្តេចសិន្ធវៈ ៗ ខ្ញុំត្រូវគេព្រាននាក់កូនក្មេងអស់ ១២ ឆ្នាំ ត្រូវគេក្រៀវមានដង្កូវបៀតបៀន ព្រមទាំងឈឺចាប់ខ្លោចផ្សាក្រៃលែង នេះព្រោះតែអំពើដែលខ្ញុំសេពនូវប្រពន្ធរបស់បុគ្គលដទៃ ៗ ខ្ញុំនោះកាលច្យុតចាកកំណើត នៃពពែនោះហើយ ក៏កើតជាកូនគោអំពីមេគោ របស់ឈ្មួញគោ ខ្ញុំជាកូនគោខ្វាក់ ខ្វក ៗ កាលខ្ញុំកើតបាន ១៦ ខែ មានរោមក្រហមដូចជ្រលក់ល័ខ ក៏ត្រូវគេ

គ្រៀវ ៗ ខ្ញុំតែងទាញនង្គ័លនឹងរទេះទៅតាំងខ្ពក់តាំងទួក ឈើចាប់ ៗ នេះព្រោះតែខ្ញុំសេពទូវប្រពន្ធនៃបុគ្គលដទៃ ៗ ខ្ញុំនោះលុះច្យុតចាកកំណើតនៃគោះនោះហើយ ក៏បានមកកើតក្នុងផ្ទៃនៃទាសីម្នាក់នៅក្នុងផ្ទះវៃស្យថ្មល់ ៗ ខ្ញុំមានភេទមិនប្រាកដជាស្រី មិនប្រាកដជាប្រុស (ខ្ទើយ) ៗ នេះព្រោះតែខ្ញុំសេពទូវប្រពន្ធ នៃបុគ្គលដទៃ ៗ ខ្ញុំស្លាប់ក្នុងអាយុ ៣០ ឆ្នាំ ហើយក៏បានមកកើតជាទារិកា ក្នុងត្រកូលនៃអ្នករទេះ ដែលជាត្រកូលកំព្រា គ្មានភោគសម្បត្តិ ត្រូវនាយឈ្មួញជាម្ចាស់ទ្រព្យរឹបជាន់ ៗ កាលកាប្រាក់ចំរើនឡើងហើយ នាយឈ្មួញនេះ ក៏អូសទាញខ្ញុំអំពីផ្ទះនៃត្រកូលដែលកំពុងយំខ្សឹកខ្សួល ៗ គ្រានោះ បុត្ររបស់ឈ្មួញនេះឈ្មោះ គិរិទាសៈ បានឃើញខ្ញុំជាស្ត្រីនៅក្រមុំ មានវ័យចំរើន ក្នុងឆ្នាំជាគំរប់ ១៦ ក៏ហួងហែងរក្សាខ្ញុំទុកក្នុងផ្ទះរបស់ខ្លួន ៗ ប្រពន្ធធំរបស់គិរិ-ទាសៈ ជាស្ត្រីមានសីលផង មានគុណផង ជាស្ត្រីប្រព្រឹត្តតាមភស្ត ខ្ញុំក៏បានធ្វើការស្អប់ប្រពន្ធធំរបស់គាត់ ៗ ខ្ញុំលុះកន្លងជាតិពីនោះមកបានមកកើតជាធីតានៃសាក្យត្រកូលនេះ ប្ដីតាំងឡាយលះលែងខ្ញុំ ដែលជាអ្នកខ្ពះខ្ពែងបំរើដូចទាសី ព្រោះផលនៃកម្មឯណា នេះជាផលកម្មរបស់ខ្ញុំនោះ ៗ ទីបំផុតនៃកម្មនោះឯង ខ្ញុំបានធ្វើហើយ ៗ

សូមបំប្រួញឲ្យរួញទ្វីនៃរឿងនេះ
ដើម្បីបេះគត់ចំណាំចាំអង្វែង
ទុកគ្រាន់ហាត់ពត់ចិត្តខ្លួនដោយខ្លួនឯង
ឲ្យវៃឆ្លៃក្រែងអាពាសកាមេ ។

៨.បិតាសីកិទ្ទុីស្រស់ប្រសើរ
មុនទឹងដើរចូលមកបួសផ្នួសទឹវគេ
នាងយកប្ដីដល់បីលើកជាហូរហែ
ប្ដីមួយៗនាងតែងតែគោរពជាប់ ។

ផ្គាប់ផ្គុនតាំងឧត្តុកដ្ឋាះញាតិខាងប្ដី
គ្មានខុសអ្វីពីច្បាប់ស្រីតាមទម្លាប់
តែស្វាមីតាំងបីប្រាណប្រែប្អុះស្អប់
គ្មានចិត្តរាប់ចងមេត្រីស្នេហា ។

ប្ដីប្រែស្អប់ៗឃើញមុខមាត់ពុំបាន
វែងកល្យាណបោលឲ្យនៅម៉ាយកាយា
នេះគឺពៀរនៃអំពើលួចស្នេហា
លួចសម្ផស្សនៃភរិយារបស់គេ ។

កាលដែលនាងកើតជា ជាងមាសជាតិមុន
បានភ្លាត់ស៊ិនប្រព្រឹត្តខុសក្នុងកាមេ
ពៀរនោះឯងតាមមកផ្តល់ឲ្យប្តីប្រែ
ស្អប់មាសស្នេហ៍លះលែងពោលគ្មានអាល័យ ។

ប្រុសៈលង់ស្រីស្រីលង់ប្រុសដោយផ្លូវកាម
បើដោយតាមទិដ្ឋនេះគួរភិតភ័យ
គួរលះពោលឈប់ប្រព្រឹត្តល្បែងចង្រៃ
ទើបធ្វើជាតិឲ្យប្រពៃបានសុខហើយ ។

---

# រឿងមរណមាតា

(តមក)

លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត

---

ឯជាងប្រដាប់ សង់សឹងសម្រាប់ លៀងគៀរកក្រា ប្រប
ផើងបាយស ព័ណ៌សរចនា ធំខ្ពស់មហិមា ត្រដាបត្រដឹង ។
មានល្អែងច្រើនជាន់ រាប់រយរាប់ពាន់ បណ្តាយទទឹង មានទីដំណេក
តែងដេកពួនពឹង គ្រែពូកត្រដឹង សម្រាប់សព្វថ្ងៃ ។ ទីលៀងចំណី
រនាបថ្មី ថ្មកែវចរណៃ ជើងតាំងសឹងថ្ម ខ្មៅសច្រើនក្រៃ កៅអី-
ស្បែកស្បែ រាប់ម៉ឺនរាប់សែន ។ មានការកាលណា លើកតាំងត្រៀបត្រា
ពេញក៏ងចុកណែន អ្នកម្នុខអ្នកការ នាំគ្នារៀបសែន អង្គុយលើខែន
លើតាំងមិនអស់ ។ ការទឹកដាក់គ្រប់ ល្អែនក៏ងសឹងអប់ ត្រដាក់មាន
រស មានមេកំណាន់ ប្រកាន់ក៏ងនោះ គេព្រះរៀបអស់ តុតាំងកៅអី ។
ពោសប្រាសទោប កន្ទេលជពប មិនឲ្យជាប់ដី គ្រឿងកែវចញ្ចាក់
ស្មើស្រក់ស្មើ តាំងទុកប្រក្រតី ភ្លើងផ្លេកពព្រាល ។ គោមកែវផ្កាលា

បើយប់កាលណា អុជភ្លើងខ្នាល រន្ទះចាំងភេង ពព្រោងពព្រាល

ពព្រាតដូចកាល ថ្ងៃរះសន្ធៅ ៗ ភ្ញាក់ផ្អើលបាត់បែក ឲ្យត្រូវចំណែក

សង់ភេងចុងគៅ ធេងធំក្រលែង ច្រើនល្វែងកប់ទៅ ប្រមាណជាត្រូវ

ដល់ពាន់គណនា ៗ រោហកចាំងបួន គន់គូរពល់ខ្លួន ផ្លៀងជួនជាតា

ទិនកែវទិនក្បៀយ ជោគជ័យកជា សិទ្ធីជោគមហា សិរីឫទ្ធិជ័យ ៗ

ហ៊ួនឈៀនហ៊ួនឈរ បៀសទិនកាលមរណ៍ ចំឡួលប្រពៃ បើកបាន

គ្រប់ពារ ពេលាល្អក្រៃ ទូលមកក្សត្រថ្ងៃ ប្រាប់គ្រប់ប្រការ ៗ

ត្រាស់ប្រើទូតទៅ នគរស្រុកក្រៅ រឯក្សត្រា ឲ្យចូលមកគាប់

ប្រញាប់មិមា ដង្ហែស្ដេចមានការ មង្គលអភិសេក ៗ មន្ត្រី

វេហ៍ពល កដទូតទៅដល់ ក្សត្រារយឯក បានស្ដាប់ទុក្ករ

កដការបាត់បែក ក្សត្រារយឯក ចូលមកគ្រៀងគ្រា ៗ សឹងនាំស្លួយ

វៃ ទ្រព្យល្អប្រពៃ ត្បូងកែវមុក្តា គ្រឿងទិព្វគ្រឿងទេស វិសេស

ជា ១ ឡើងគាល់ក្សត្រា ក្រាបទូលថ្វាត់ថ្វាយ ៗ ព្រះបាទបពិត្រ

ធិកដឿងរឿងរិទ្ធិ យល់ស្ដេចតាំងឡាយ ឡើងគាល់ក្សត្រក្សាន្ត ហើយ

មានជង្ហាយ ទ្រង់ត្រេកសប្បាយ សាកសួរមេត្រី ៗ បរមរាជា

ពេះកាយទុក្ករ ត្រាស់ទ្រង់ចេតី រយឯកកជា ពណ៌នាសេចក្តី

សាទរមេត្រី តបព្រះទុក្ករ ៗ ហើយថាមកគង់ មកគាល់គ្រប់អង្គ

រៀបរៀងគ្រឿងត្រា ដោយទំនួរគាប់ គំនាប់កដា ហើយក្រាបលុតពក
វិលមកបាទទី ៗ បរមក្សត្រា ត្រាស់ប្រើអាជ្ញា ទៅប្រាប់នាយពីរ
ឈ្មោះបាឌពិភក្តិ ខ្ទរក្រមន្ទីរ ភ្នាក់ងារទាំងពីរ ឲ្យរៀបដំណាក់ ៗ
សម្រាប់ក្សត្រា ទាំងរយឯកា យកគ្រឿងទៅដាក់ ឲ្យក្រាលចៀមចំ
ព្រៃព្រំភាមសក្តិ ឲ្យគ្រប់ដំណាក់ រយឯកក្សត្រា ៗ ភ្នាក់ងារទាំងពីរ
តាក់តែងមន្ទីរ រៀបតាំងផ្កាលា គោមកែវអុជព្រោត ក្តីស្អាតមហិមា
កម្រាលល្អផា ចៀមចំល្អពេក ៗ ប៉ាំងព្រះសុរិយា គ្រឿងគ្រប់ទុកថា
សម្រាប់អនេក អញ្ជើញស្តេចគង់ គ្រប់អង្គរយឯក គ្រឿងតាំងល្អពេក
ល្អពិមានខ្ពះ ៗ រៀបរួចជម្រាប នាយធំបានជ្រាប កិច្ចការដាក់ច្បាស់
ហើយឡើងជំទុំ ចតុស្តម្ភក្រៃក្រាស់ សង់គាល់អម្ចាស់ ឥសូរសោរសោ ៗ
ហើយវិលមកជុំ មកជួបជំទុំ ខ្ទង់ព្រះសាលា មានចតុស្តម្ភ ឡើងជំទុំការ
ស្តាប់អស់សេនា សម្រាប់ផែនដី ៗ ឯអស់សេនា បង្គាប់ភ្នាក់ងារ
សព្វមុខមន្ត្រី ឲ្យធ្វើសំបុត្រ កំណត់សេចក្តី គ្រប់ឯកទោត្រី ចត្វា
ហើយបោះ ៗ ត្រាប្រើប្រាប់ទៅ ទៅហ្វាយស្រុកក្រៅ ឲ្យមកទាំងអស់
បំរើស្តាប់ច្បាស់ សំពះលាស្មោះ ដើរត្រួតប្រាប់អស់ សព្វមុខមន្ត្រី ៗ
ទទួលប្រសាសន៍ សម្រេចឲ្យច្បាស់ កិច្ចការផែនដី រៀបតែងចុតហ្មាយ
សព្វសាយសេចក្តី គ្រប់ឯកទោត្រី ចត្វាបោះត្រា ៗ ពាក់ប្រើបំរើ

ឲ្យប្រាប់ទៅលើ ខេត្តក្រៅនាមា ឲ្យចូលមកឆាប់ ប្រញាប់ម៉្ងា បំរើ
នាំសារ ចុតហ្មាយទៅដល់ ៗ ចៅហ្វាយស្រុកក្រៅ គ្រប់ខេត្តសរៅ
រៀបខ្ទង់រចល់ រិះរកដង្វាយ តាំងឲ្យយកស្គុផល បរចូលមកដល់
ជួបជុំគ្រៀបគ្រា ៗ រៀបគស់ដង្វាយ ស្វាខ្ទីតាំងឲ្យាយ គ្រុបមៀនផលា
មានបេកពងមាន់ ចុំនាន់វេលា ដំឡូងដូងស្វា គ្រឡាបល្ពៅ ៗ
លុតត្តោគ្គៈស្វាយ វែកសែនលំស្ពាយ ដើរហែរតាមទៅ ដល់នាហ្មឺនធំ
ជួបជុំនុំទៅ នាំឡើងគាល់ហ្វៅ ស្ដាប់ព្រះឱង្ការ ៗ ចូលថ្វាយដង្វាយ
ចៅហ្វាៈជស្រុកឆ្ងាយ ថ្វាយក័ស្គុផលា ទ្រង់ប្រោបជាក់ច្បាស់ មានព្រះ
ឱង្ការ ចៅហ្វាយពល់គ្នា សង់ពេនជាក់ទស ៗ ចៅហ្វាយគ្រាមា
ទទួលឱង្ការ បង្គំលាចុះ មកសង់ពេនខោល តាំនោលច្រើនប្រុះ ខ្វះត្រូវ
នាំទស នាំឲ្យដល់ទៅ ៗ ប្រគល់សួស្ដី ចៅហ្វាយបញ្ជី បើកឲ្យចូនកៅ
បើខ្វះទសនោះ វាស្ទុះក្រឡៅ ក្រឡើកតទៅ តាមកោះយកការ ៗ ខ្វះសែន
ទឹកទៅ ចាក់ពយដោយឆ្នូរ មកពាំងពេញពាស កុំឲ្យធុលី ហុយទំតាំងផ្ដាស
ខ្វះកាន់ពោសព្រាស សំរាមបោលទៅ ៗ ខ្វះចូកជំរះ ពោសជាត់ឲ្យជ្រះ
ទំនួសទីតាប ព្រាបពបធេនទៅ មិនឲ្យមានស្មៅ ដុះដកកាប់កាត់ ៗ ហេតុ
ស្ដេចឯកពជ វិនីទ្ធិអំណាច បារមីច្រើនក្ដាត់ មែនមានពាណិជតែងត្រាច់
ប្រវាត់ ចូលជួញច្រើនក្ដាត់ ក្នុងក្រុងភាព ៗ សំពៅប៉ារយ ចូលចតរដយ

ពាសពេញត្រៀបត្រា សឹងទ្រព្យថ្ងៃ ១ ក្រៃក្រៃគណនា ត្បូងកែវមុក្តា
មកុដទិព្វរត្ន ៗ កាសាយមនា ទៀនព្រៃជា១ ទឹមទាបកាត់ឡាត់ គុង
ខ្លួនកាំមី រស្មីប្រពាត់ កាមរិទ្ធិច្រើនគ្នាត់ សាក្យាតជាតិ ៗ ជាមួនទទឹម
សឹងទៀនសង់ទឹម មួកតាតស្មើ សត្វបៃបៅប្រាប់ ចំណាប់ឥតបី យ៉ាង
ល្អថ្មី ១ ស្រស់ស្រៀបត្រឹមត្រូវ ៗ មានព្រៃចំឡែក ជាឱបទេសឯក
ទេសល្បែកផ្កាថ្មី គ្រឿងមាសគ្រឿងប្រាក់ រើជាក់ត្រឹមត្រូវ រលែកនាំ
ទៅ សែងឡើងដាក់ផ្សារ ៗ ដង្ហើចំនោះ ដីងជាក់ចំពោះ ជាមហា
ក្សត្រា ស្ដេចរៀបអភិសេក អគ្គឯកជាយា តិតគ្នាមីម៉ា ឡើងគាល់ក្សត្រ
ត្រាន្ត ៗ យកអស់ទ្រព្យជា កាសាយមនា ត្បូងកែវស៊ុរិកាន្ត ដាក់
គុតាំងតែង ឲ្យសែងតាមប្រាណ ខ្លះរើកបាន ក្រៃឡើងកមាស ៗ
ខ្លះយកគ្រឿងតាំង គ្រឿងតុសំរាំង សម្រេចពេញពាស ខ្លះបានផ្កា
ប្រាក់ ផ្កាលំដាក់តុមាស ខ្លះយកផ្កាមាស តុប្រាក់ថ្វាយទៅ ៗ ខ្លះសែង
ស្គរស ថាំចិនយ៉ាងល្អ កញ្ចប់ហោប៉ៅ ប្រកបាឲ្យសែង ច្រើនស្មែង
នាំទៅ ឯខ្លួនដង្ហើ បង់បោយដើមុខ ៗ ដង្ហើកេត្រា នោះច្រើនកាសា
យួនជ្វាច្រើនស្រុក បារាំងចិនបាម ក្លឹងព្រាហ្មណ៍គ្រប់មុខ ចូលមក
ពីស្រុក មានទីលក្ខឡា ៗ ភូមាសៀមលាវ អង់គ្លេសក្លឹងក្រៅ
ច្រើនក្រៃត្រៀបត្រា បណ្ដើរគ្នាដល់ មណ្ឌលសីមា រៀនហ៊ុងយាត្រា

នាំទៀនគាល់ក្សត្រ ៗ ចូលថ្វាយដង្វាយ ដង្ហែថ្វាយ១ ចូលមកប្រាប់ ស្ដេចជ្រាបច្រើនអរ សាទរពេកក្លាត់ បន្ទូលទៅថ្វាត់ ដោយក្ដីករុណា ៗ ដង្ហែទាំងឡាយ យល់ស្ដេចសប្បាយ រោះរាយទន្ទ្ការ មានចិត្តត្រេកអរ សាទរពល់គ្នា បន្តិក្រោបណា រិលចុះសំពៅ ៗ ឯអន្ទ្រព្រះបាទ រីមលទរពាថ ធិពដបម:ចៅ មានព្រះទន្ទ្ការ ឲចាក្រម ត្រាស់បង្គាប់ទៅ ឯកអគ្គមន្ត្រី ៗ ឲ្យត្រួតក្លាក់ឆ្ការ នាយពួកក្រយា ឲ្យរៀបចំណី ភ័ស្តុភោជនា ទុជាពីសី ពិសេសចំណី ថ្វាយក្សត្រយឯក ៗ ហើយៈរៀបសម្រាប់ រយឯកគ្គ័ត្ដាប់ ចំណីចំឡែក រៀបឆ្គងពាណិជ សម្រេចឲ្យថែក ភោក្ដាចំឡែក ហើយ សាលេខភាសា ៗ ដង្ហែបាពិន បារាំងរៀបតាំង លៀងជប់អាហារ ដង្ហែ សៀមសុទ្ធ សៀមឆ្គត់គេ្យា ដង្ហែកូឡា កូឡាឆ្គត់ឆ្គង់ ៗ ដង្ហែភូមា ភូមា រក្សា ជប់លៀងបម្រុង ដង្ហែឃួនត្រូវ ចុងភៅយួនឆ្គង់ ដង្ហែចិនចុង ភៅ ចិនបម្រើ ៗ ដង្ហែចាមជ្វា ចាមជ្វារក្សា ភោជន៍ភស្តុសារពើ ដង្ហែជប៉ុន ជប៉ុនបម្រើ ដង្ហែព្រាហ្មណ៍លើ ចុងភៅព្រាហ្មណ៍ផង ៗ ដង្ហែលន្ទា អង់គ្លេសមេដ្ឋា និត្យនៅត្រូវចុង- ភៅតាមភាសា រក្សាបម្រុង ដង្ហែកុឹង ចុង- ភៅកុឹងលៀងជប់ ៗ ស្ដេចបើកប្រដាប់ ប្រាក់ព្រះរាជទ្រព្យ ប្រទាន ឲ្យគ្រប់ ចុងភៅភាសា រក្សាលៀងជប់ មិនឲ្យធុញថប់ សព្វថ្ងៃប្រក្រតី ៗ ដៀតស្ដេចមានការ ជ័យដោគអាពាហ៍ ពិពាហ៍សួស្ដី មង្គលអភិសេក

អគ្គឯកទេសី រៀបលៀនចំណី ពាណិជស្រុកឆ្ងាយ ៗ ដោយ
សាសន៍ភាសា ចំណីគោត្ត តាមចិត្តសប្បាយ តាំងកេនចុងគោ
ឯក្រៅទូហោយ ទំហាំជំឆាយ កប់សែវទេណនា ៗ ឯកអគ្គមន្ត្រី សម្រាប់
ផែនដី ទទួលទុក្ខារ គ្រាស់ទ្រង់បង្គាប់ ប្រញាប់ម៉្ញា បង្គំក្រាបលា
ពះថយចាកចេ ៗ ចុះដើរដល់ផ្ទុំ សាលាជំនុំ សព្វមុខមន្ត្រី ឡើងជំនុំការ
គៀបគ្រាប្រក្រតី ទើបមុខមន្ត្រី ត្រួតត្រប់ភ្នាក់ងារ ៗ ឯនាយព្រះក្រាល
ឲ្យរៀបកំរាល ចៀមជំសយនា នាយពួកពិសេស គ្រឿងទេសក្រយា
នាយវេនក្រឡា មន្ទីរក្រមវាំង ៗ គ្រប់នាយបាទស្គាប់ ទទួលបង្គាប់
ស្រេតគ្រឿងក្តាំង ខ្ទារសៀមចិនជ្វា កូឡាចុះវាំង គ្រប់សាសន៍រៀបតាំង
ចូលជំធ្វើការ ៗ នាយពួកពិសេស រៀបសំងគ្រឿងទេស គ្រឿងទិព្វ
ក្រយា ខ្ទាតាបុងគោ គោឡៅយាំងជា រៀមរៀបធា រៀបហុង
សាច់ជ្រូក ៗ ទឹមឆាន់ទឹមតា ខ្វះបកបន្ត ខ្វះឆាកគ្រាប់ឈូក អ្នកខ្វះ
ប្រញាប់ ខ្វះកាប់ដើងជ្រូក ខ្ទឹងគ្រាប់ឈូក ឆ្អិនលើកទុកទៅ ៗ ខ្វះពុះ
ត្រឡាច ចិតបេញសស្ងាច ខ្វះពុះល្ពៅ ខ្វះពុះដំឡូង ផ្ទុំរូងល្ហុកឡៅ
ផែប៉ីរមើមត្រាវ ព្រះកាយសណ្តែក ៗ នាំគ្នាដើរហែ ទៅទិញបន្លែ
ពីផ្សារថ្មែក ១ មេស្រូវតាំហ៊ុន ឆ្កាចឆ្កាចេក ពពុះសណ្តែក តៅហ៊ូ
តាំងឆាយ ៗ ទិញឈើងសមុទ្រ ឈាមមោសសុទ្ធ អណ្តើកកន្លាយ

ស៊ិតមាន់ស៊ិតទា បង្គាព្រានលាយ សែនវែកប្រញាយ ប្រញាប់ពន់ពេក ៗ ដល់ពេលរៀបដាក់ ស្រាយបាវចូកចាក់ ចេញហើយចាត់ចែក រៀបតុដើរក្រាន គ្រប់ប្រាណចំឡែក ចំណាំនាយផ្នែក ដោយមុខដោយខ្លួន ៗ រៀបស្ងួតណ្ណាំ ដោយពួកចំណាំ ចំណាប់ម៉ាំមួន ថ្ងៃយប់ប្រុងប្រាណ មិនបានដកពួន ដោយពួកដោយខ្លួន គ្រប់សាសន៍ភាសា ៗ ចុងភៅខ្មែររៀប ចំណីស្រស់ស្រៀប ខ្លះញាំភ្លា សំឡប្រហើរ ខ្លះធ្វើកប់សា ចៀនអាំងធ្លុះធា ហើយធ្វើការម៉ុក ៗ អាំងសាច់ខ្លះធ្វើ ឡូក្រៀមទុកទើ ស្ងោគ្រឿក ខ្លះធ្វើនំបុក ចំឡែកដោយមុខ ធ្វើឡូងសារុក នំបង់ខ្ញាញ់ផង ៗ ខ្លះធ្វើអន្សម ស្ងោចិនផ្លែល្ហុង ខ្លះខ្លួបង្កង ខ្លះញាំពស់ប្រា ខ្លះភ្លាក្រង្កង ល្ងកក្ដាមម្ពង ៗ ក្រែងសាច់ប្រែពេក ៗ ខ្លះហាន់សាច់ជ្រូក ស៊ុកចង្កឹះបង់ឆ្អូក ជូរប្រៃផ្អែក ស្ងោខ្យងត្រាវ ល្ពៅសណ្ដែក ស្ងោដាយចំណែក គ្រប់មុខបន្លែ ៗ ខ្លះចិត្តផ្លែម្រះហាន់សាច់ដាក់ខ្លះ គ្រវែងផ្អប់ផ្អេ លើងគ្រាប់សណ្ដែក បុកបែកម៉ត់ម៉ែបង់ពៅហើយថៃ បន្ទាយភ្លើងចេញ ៗ ស្លុកឆ្កឹះលើង គ្រកាលសាច់ឆ្សេងក្លិនឈ្ងប់ឈ្ងុយឆ្ងាញ់ ខ្លះដស់ស៊ិតទា ដាក់ឆានងខ្ញាញ់ ឆ្អិនស្របដាក់ចេញ ឈ្ងុយឈ្ងប់ពីសា ៗ

(នៅមានត)

# រឿងព្រេងប្រពៃណីស៊ុយអែដ

## បែងអ៊ិពី អ៊ិបិល និង និប៉ុង

គិត្តុ ម៉ែន-ហៀម

សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

ប្រែចាកភាសាអង់គ្លេស

---

សម័យមួយ មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់មានព្រះរាជធីតា ៣ ព្រះអង្គ ៗ បណ្ដាព្រះរាជធីតាទាំងនោះ ព្រះរាជធីតាពៅ បានជាទីស្រឡាញ់ពេញព្រះរាជហឫទ័យយ៉ាងខ្លាំង នៃព្រះមហាក្សត្រ ជាព្រះបិតា ជាងព្រះរាជបុត្រីច្បងទាំងពីរ ។ ម្ល៉ោះហើយព្រះរាជបុត្រីច្បងទាំងពីរនោះ ក៏កើតសេចក្ដីប្រណែន នឹងប្អូនពៅខ្លួន, បានចំណាយពេលជាច្រើន នឹងសេចក្ដីព្យាយាមដ៏មាំ ដើម្បីនឹងបំផ្លាញនូវសេចក្ដីស្នេហា រវាងព្រះមហាក្សត្រ នឹងប្អូនពៅនោះឲ្យវិនាសបាត់ទៅ ។ ព្រះនាងទាំងពីរ ខំព្យាយាមដើម្បីទាញយកនូវសេចក្ដីស្នេហា នឹងឋានៈនេះឲ្យបានមកខ្លួនវិញ, មិនគួចសោះ នូវឱកាសដើម្បីណែនាំព្រះមហាក្សត្រជាព្រះបិតាខ្លួនឲ្យឃ្លាតព្រះទ័យពីព្រះនាងពៅ ដោយបង្កាច់

ថា " នាងពៅឥតស្រឡាញ់ព្រះមហាក្សត្រ ដូចដែលទ្រង់ស្រឡាញ់នាងនោះទេ " ។ ការប្រព្រឹត្តដំណាមករបស់ព្រះនាងទាំងពីរ មិនអនុញ្ញាតឲ្យព្រះនាងសម្រាកសោះ ។ ទីបំផុតព្រះមហាក្សត្រកាលទ្រង់ឮពាក្យមួលបង្កាច់នោះពីព្រះរាជបុត្រីច្បងទាំងពីរ ទ្រង់ក៏ខ្វល់ព្រះរាជហឫទ័យជាខ្លាំង ។

ថ្ងៃមួយ កាលដែលព្រះរាជបុត្រីទាំងអស់ បានមកជួបជុំគ្នានៅចំពោះព្រះភ័ក្ត្រព្រះអង្គ ទ្រង់ក៏ពិសោធមើលទំហំសេចក្ដីស្នេហានៃព្រះរាជធីតាទាំងនោះផ្ចាល់ព្រះអង្គ ។

ដំបូង ទ្រង់ចាប់សួរអំពីទំហំសេចក្ដីស្នេហារបស់ព្រះរាជបុត្រីច្បងចំពោះព្រះអង្គ តើខ្លាំង - ធំ - ថ្លៃ យ៉ាងណា ។ ព្រះនាងឆ្លើយថា៖

– « បពិត្រព្រះបិតា, ខ្ញុំម្ចាស់សូមថ្វាយតម្លៃព្រះបិតា ដូចតម្លៃទេពតានៅឋានសួគ៌" ។

ចម្លើយនេះ បានញុំាងព្រះមហាក្សត្រឲ្យទ្រង់សព្វព្រះទ័យជាខ្លាំង ។ រួចទ្រង់សួរទៅព្រះរាជបុត្រីបន្ទាប់ ដូចមុនទៀត ព្រះនាងឆ្លើយថា៖

– " បពិត្រព្រះបិតា, ខ្ញុំម្ចាស់ សូមថ្វាយតម្លៃព្រះបិតា ស្មើនឹងតម្លៃជីវិតរបស់ខ្ញុំម្ចាស់ ! » ។

ចម្លើយនេះ ក៏ធ្វើព្រះមហាក្សត្រឲ្យសោមនស្សដែរ ។

បន្ទាប់ពីនេះ ទ្រង់បែរទៅសួរព្រះរាជបុត្រីពៅថា « តើនាងឲ្យតម្លៃបិតាដូចអ្វីដែរ ? » ។ ព្រះនាងឆ្លើយថា ៖

– « ឱព្រះបិតា, ខ្ញុំម្ចាស់សូមថ្វាយតម្លៃព្រះអង្គស្មើនឹងតម្លៃនៃនំប៉័ងនឹងអំបិល ! » ។

ចម្លើយនេះ បណ្ដាលឲ្យមហាក្សត្រ រំភើប ភ្ញាក់ យ៉ាំងពន្លឹក ។ ពេលនោះ ទ្រង់ខ្ញាល់នឹងព្រះរាជបុត្រីពៅក្រៃពេក ដោយទ្រង់យល់ថា « នាងគ្មានគាំពារព្រះកិត្តិយសព្រះអង្គ ឲ្យបានលើសពីវត្ថុគម្រក់បំផុត ដែលគេតែងតែគិតគល់លើតុបុរសទុគ៌តនោះសោះឡើយ » ។ ព្រះពិរោធរបស់ទ្រង់ ដូចព្យុះសង្ឃ្រក ដោយហេតុទ្រង់ស្ដាយចំពោះសេចក្ដីស្នេហាដ៏សម្បើមរបស់ទ្រង់ ដែលបង់ខាតដោយខ្ជះខ្ជាយទៅលើព្រះរាជបុត្រីពៅ ហើយទ្រង់បានទទួលនូវសេចក្ដីស្នេហាតបដ៏តិចបំផុត ដូច្នេះវិញ ។ ទ្រង់ព្រះរាជបញ្ជាឲ្យពួកទាសកម្មករ បណ្ដេញព្រះនាងពៅចេញពីព្រះដំណាក់របស់ទ្រង់ ។ ពួកទាសាទាសីក៏បានធ្វើតាមព្រះរាជបញ្ជា ដោយនាំព្រះនាងទៅបំបរបង់ចោលក្នុងព្រៃ ។

គ្រានោះ ព្រះរាជបុត្រីច្បងទាំងពីរសប្បាយព្រះទ័យណាស់ព្រោះសម្រេចតាមគោលបំណងរបស់ទ្រង់ ។

នៅក្នុងព្រៃ, ព្រះរាជបុត្រីពៅ ប្រកបដោយសេចក្ដីតោកយ៉ាកនឹងការភិតភ័យយ៉ាងក្រៃលែង ។ កាលណាព្រះនាងទឹកអំពីដំណាក់

ដែលធ្លាប់គន់ អំពីព្រះរាជបិតាដ៏ជាទីស្នេហារបស់ទ្រង់, សម្ដេចយំខ្សឹកខ្សួលក៏កើតមានឡើង ។ ព្រះនាងមិនបានដឹងសោះថា តើព្រោះហេតុអ្វីបានជាព្រះបិតាខ្វាល់នឹងព្រះនាង? ហើយព្រោះហេតុអ្វីបានជាខ្លួនព្រះនាងត្រូវគេបំបរបង់ចោល? ។ ពេលនោះ ព្រះនាងដើរត្រាច់ទៅក្នុងព្រៃតែមួយព្រះអង្គ ឥតមានទីពឹង ហើយទីបំផុត ដោយខ្លាចសត្វព្រៃបៀតបៀន ព្រះនាងក៏ឡើងទៅពួនលើដើមឈើខ្ពស់មួយ ។

ក្សិណនោះ មានព្រះមហាក្សត្រមួយព្រះអង្គនៃប្រទេសដទៃទៀត ទ្រង់ចេញបរបាញ់សត្វក្នុងព្រៃ ។ កាលទ្រង់គង់សេះ បរតាមព្រៃនោះហូរហែរមក ទ្រង់បានឮសំឡេងឆ្កែរបស់ព្រះអង្គ ព្រុះឡើង ដោយអាការក្រាក់ផ្អួល ។ ទ្រង់បរសេះយ៉ាងរួសរាន់ ឆ្ពោះទៅតាមសម្លេងឆ្កែ ស្រាប់តែឃើញពួកឆ្កែនោះ នៅចោមព័ទ្ធជុំវិញដើមឈើ ដែលព្រះរាជបុត្រីលាក់ព្រះអង្គ ។ ដោយសង្ស័យថា នឹងបានឃើញខ្លាឃ្មុំ ទ្រង់ក៏ងើបព្រះភក្ត្រទតទៅលើ ។ តែជំនួសខ្លាឃ្មុំ, ទ្រង់បានយល់នូវផ្ទៃភក្ត្រដ៏ឆើតឆាយនៃស្ត្រីក្មេង ដែលមានអាការប្រកបដោយទុក្ខព្រួយទៅវិញ ។ ពេលនោះព្រះអង្គបានពោលទៅកាន់ព្រះនាងដោយសុភាព សុំឲ្យព្រះនាងចុះមកក្រោម ។ លុះព្រះនាងចុះមក ព្រះអង្គបានលើកព្រះនាងដាក់លើខ្នងសេះបញ្ឆិះយកទៅកាន់ប្រាសាទព្រះអង្គ ។ នៅក្នុង

ប្រាសាទ, ទ្រង់ឲ្យព្រះនាងសោយអាហារ, ធ្វើឲ្យព្រះនាងកក់ក្ដៅបាត់រងារដោយភ្លើងសម្រាប់អាំង ។ ទីបំផុត ដោយអំពើសប្បុរសរបស់ព្រះមហាក្សត្រអង្គនោះ គ្របមកលើព្រះនាង, ព្រះនាងក៏បញ្ចេញជឿនទ្រង់ទូលព្រះមហាក្សត្រប្រាប់សព្វគ្រប់ ។

អំពើដ៏ល្អ និងលំអដ៏ចេតនារបស់ព្រះនាងធ្វើឲ្យព្រះមហាក្សត្ររំភើបព្រះទ័យយ៉ាងក្រៃលែង ។ ទ្រង់ថែរក្សាព្រះនាងទុកក្នុងប្រាសាទ, ហើយក្រោយមក ទ្រង់សុំឲ្យព្រះនាងរៀបអភិសេកសមរសជាមួយព្រះអង្គ ។

ព្រះរាជធីតាក្មេងនេះ ដោយធ្លាក់ចុះក្នុងសេចក្ដីស្នេហាដែរនោះ ក៏ទ្រង់ទទួលព្រមរៀបអភិសេកជាមួយទ្រង់ ។

ដូច្នេះហើយ, កាលបរិច្ឆេទនៃព្រះរាជពិធីមង្គលអភិសេក ក៏ត្រូវបានគេកំណត់ទុកជាស្រេច, សំបុត្រអញ្ជើញភ្ញៀវ ក៏ត្រូវគេចាត់ការផ្ញើទៅក្រុមព្រះរាជវង្សានុវង្ស នៃព្រះរាជាណាចក្រជិតខាង ចំនួនប្រាំពីរអាណាចក្រ ។

កាលថ្ងៃនៃមង្គលអភិសេកមកដល់ ភ្ញៀវជាព្រះរាជវង្ស ក៏បានមកដល់ត្រៀបត្រា ។ ក្នុងបណ្ដាភ្ញៀវទាំងនោះ ព្រះមហាក្សត្រជាព្រះបិតានៃព្រះនាងសាម័ខ្លួនក្នុងអាពាហ៍វិវាហមង្គល ទ្រង់ព្រះរាជបុត្រីច្បងទាំងពីរនៃទ្រង់ ក៏ទ្រង់យាងមកជាភ្ញៀវជាន់ខ្ពស់មួយដែរ ។ ទាំងញាអង្គនេះ

ឥតមានអ្នកណានឹកឃើញចំពោះព្រះនាងសាមុទ្ទនឡើយ, ព្រោះទ្រង់ជឿជាក់ថា ព្រះរាជបុត្រីពៅអង្គនោះ វិនាសបាត់បង់ព្រះជន្មក្នុងព្រៃទៅហើយ ។

ពេលដែលភ្ញៀវអង្គុយរៀបរយ នៅនាតុជប់លៀងភោជនាហាររួចរាល់អស់ហើយ, ម្ហូបដ៏ល្អគ្រប់បែប បានត្រូវគេលើកដាក់លើតុមុខភ្ញៀវទាំងនោះ ។ ចំពោះភោជនាហារទាំងនោះ គ្មានម្ហូបណាមួយប្រៃសោះ គឺសុទ្ធតែសាប ៗ ទាំងអស់ ហើយថែមទាំងគ្មានដាក់អំបិលប្រចាំការទៀតផង, ទំប័ងក៏គ្មានដែរ ។

ព្រះមហាក្សត្រជាព្រះបិតាព្រះនាងពៅ ដោយទ្រង់មិនអាចទប់ព្រះទ័យក្នុងការសួរគេ ក៏ទ្រង់បន្ទូលថា:

—« យីអើហ្ន៎ ! ខ្ញុំមិនយល់សោះ ម្តេចបានជាគេភ្លេចដាក់វត្ថុប្រណីតបំផុតពីមុខ ក្នុងពិធីជប់លៀងនេះហ្ន៎ ? » ។

ព្រះនាងពៅ ដែលពេលនោះ ជាតួព្រះខត្តិយានី ឆ្លើយថា ៖

« ចុះ ! ព្រះអង្គត្រូវការអ្វី ? » ។

—« អាសំខាន់ពីមុខ គឺអំបិលនឹងទំប័ងណា៎ ! » ព្រះមហាក្សត្រឆ្លើយ

—« ពិតហើយក្រាបទូល », ព្រះនាងបន្ថែម, « អំបិលនឹងទំប័ងហ្នឹងឯង:ហើយ ដែលយើងស្គាល់ថា ជាវត្ថុប្រណីតថ្លៃបំផុត, តែប៉ុន្តែ នៅ

គ្រាមួយនោះ ដោយសារតែខ្ញុំថ្វាយតម្លៃយ៉ាងថ្លៃ ទៅព្រះបិតាខ្ញុំស្មើនឹងវត្ថុទាំងនេះ ខ្លួនខ្ញុំក៏ត្រូវលោកបណ្ដេញចេញពីព្រះដំណាក់ឲ្យទៅនៅក្នុងព្រៃ ដើម្បីសម្លាប់ខ្លួនខ្ញុំទៅវិញ» ។

ទ្រង់ឮពាក្យនេះ ព្រះមហាក្សត្រក៏ស្ងៀមមួយសន្ទុះ រួចដល់ព្រះអង្គស្គាល់ព្រះនាងច្បាស់ ក៏ទ្រង់ស្ទុះទៅឱបព្រះនាងដោយសម្រែកពេញទៅដោយសេចក្ដីសប្បាយរីករាយព្រះទ័យជាអនេក ព្រោះទ្រង់ទើបនឹងបានជ្រាបថា ព្រះនាងមានព្រះជន្មរស់នៅឡើយ ។ ពេលនោះ ព្រះអង្គសុំឲ្យព្រះនាងអភ័យទោស ចំពោះការណ៍ដែលទ្រង់មិនយល់នូវពាក្យពេញទៅដោយសេចក្ដីស្នេហារបស់ព្រះនាងចំពោះព្រះអង្គ និងនូវការបណ្ដេញព្រះនាងចេញពីព្រះដំណាក់របស់ព្រះអង្គ ។

អំពើអាក្រក់នៃព្រះរាជបុត្រីច្បងទាំងពីរដែលរួមគំនិតប្រឆាំងនឹងព្រះរាជបុត្រីពៅនោះក៏ត្រូវទទួលលទ្ធផលអាក្រក់យ៉ាងសមរម្យ ។ វេនដែលត្រូវឃ្លាតចេញចាកព្រះដំណាក់នៃព្រះបិតាខ្លួន ក៏វិលមកដល់នាងទាំងពីរវិញ ។ ម្យ៉ាងទៀត តាំងពីពេលនោះមក ដំណើរនិទាន សូម្បីតែបន្តិចបន្តួចពីនាងទាំងពីរ ក៏លែងលេចឮសោះ ។ ទុកជានាងត្រូវស្ដេចបរបាញ់ណាមួយ ជួយសង្គ្រោះឲ្យរស់ពីមានជីវិតក្ដី ក៏គ្មានអ្នកណាមួយបានដឹងបានឮឬបានឃើញសោះឡើយ ។

ស្នាដៃឪពុក

# ចែងអំពីរបៀបប្រដៅកូនប្រុសស្រី

លោក ស៊ុន-ផូ រៀបរៀង

លោក ចាប-ពិន ពិនិត្យ

---

## ជំពូក ១

### ដំបូន្មានកូនប្រុស ។

· បទពាក្យ ៧

ហៃកូនពន្លកមាសឪពុក    ចូរបាចាំទុកគ្រប់រូបកាយ
នូវពាក្យឪពុកដែលអធិប្បាយ    តាមពុទ្ធបរិយាយត្រាស់ទេសនា ។

ទី ១- សមាននាយ:    ចូរចាំឲ្យជាក់តាមតម្រា
ពីក្មេងអ្នកនៅទីនមាតា    តាមតែចិត្តបាត្រអាលលេង ។
ឥឡូវខ្លួនអ្នកមានប្រពន្ធ    រៀនចិត្តឲ្យធ្ងន់ជាងពីក្មេង
លើកមុខប្រពន្ធឲ្យចំពេញ    គឺតក្រែងអាណិតចិត្តភរិយា ។
កុំអាងតែខ្លួនឯងជាប្រុស    គួរដឹងត្រូវខុសផងនានា
ត្រូវសួរពីគ្រោះដល់ភរិយា    គិតគ្នាធ្វើការផងទាំងឡាយ ។

ទី ២. អវិមាននាយ: ក្បួនចាំឲ្យជាក់ពាក្យអធិប្បាយ
ទោះបើកិរិយាធ្ងន់ទាយណាយ កុំបីមើលងាយជេរផ្ដាសា ៗ
ត្រូវប្រៀនប្រដៅដោយស្មោះសរ ប្រកបដោយធម៌ព្រះទេសនា
កុំធ្វើវិស័យក្មេងពាលា អាងជេរកិរិយាគ្រប់តែថ្នាក់ ៗ

ទី ៣. បាលីព្រះវចនថា អនតិចារិយាយ:
ធម៌នេះលោកប្រាប់ស្ដាប់ឲ្យជាក់ កុំឲ្យចិត្តស្ម័គ្រប្រាថ្នាស្ងន់ ៗ
ទីងកូនប្រពន្ធអ្នកដទៃ កុំបីរំពៃគិតកប់កាន់
ពោលប្រពន្ធឯងឲ្យអាក់អន់ ទោសនេះធាន់ហាន់ឃើញហើយតើ ៗ

ទី ៤ - ឥស្សរវោស្សគេន: ប្រគល់ទុកដាក់នូវសារពើ
កិច្ចការក្នុងផ្ទះសព្វអន្ទើ ដាច់មុខទៅលើនាងភរិយា ៗ
មុខងារដាំស្លអង្ករបាយ ចំណូលចំណាយនាងគោជទា
ប្រគល់ការផ្ទះគ្រប់វេលា ទៅឲ្យភរិយាជាមេទ្រព្យ ៗ

ទី ៥ - ពោលគឺអលង្កា- រានុប្បទានេន: គាប់
ឲ្យគ្រឿងស្លៀកពាក់គ្រប់ប្រដាប់ ល្អៗចំណាប់ហើយថ្មីៗ ៗ
ចិញ្ចៀនការកងក្ដងស្លៀតសក់ ទាំងក្រាសកញ្ចក់ប្រេងកាណី
ម្សៅទឹកអប់ក្នុងក្លែបពីសី គ្រឿងស្រីឲ្យស្រស់បស់ល្អៗ ៗ
ចំហូត្បូងពេជ្រលេចសមសួន ខ្សែដៃខ្សែខ្លួនកន្ទាស់ក

អាវខ្ចីអាវវែងតែងលំអ　　លាតឡោឡាញ់សង្កិរបី ។
រៀបចំឲ្យសមចិត្តភរិយា　　ទៅទិសនានាពេញមុខស្រី
កើតកេរ្តិ៍ពីពេះខ្ពស់មុខប្តី　　នៅនាលោកិយល្បីសុះសាយ ។
　　វិសេដ្ឋហេតុមិតាំងជ៍នេះ　　ចូរប្រចាំបេះគ្រប់រូបកាយ
បេះហើយត្រូវកាន់គ្រប់គម្រាយ　　ប្រយ័ត្នឃ្លាតខ្លាយជាតិកំណើត ។
បំណាច់សំណាងបានជាមនុស្ស　　ទោះស្រីទោះប្រុសសឹងក្រកើត
ត្រូវកាន់ចិត្តធម៌ឲ្យល្អផេត　　កសាងកំណើតឲ្យថ្កើងថ្កាន ។
　　សង្ខេបបែបបទគត់សញ្ញា　　បិតាចែងទុកតាមលំអាន
ឲ្យកូនប្រុសៗខំរះព្យាន　　ប្រតិបត្តិតាមស្ពានទីងបានសុខ ។
ថ្កើងពូជថ្កើងពង្សវង្សក្តាន　　សាបញាតិប៉ុន្មានៈនាក្នុងស្រុក
នៅនាលោកិយឥតគល់យុត　　អនាគតមុខក៏សុខហោង ។

## បំពួក២

### ដំបូន្មានកូនស្រីៗ

បទពាក្យ ៧

　　ហៃអស់ពួកនាងកូនស្រីៗ　　ចូរនាងឃ្លាតខ្ចីកុំប្រមាទ
កិច្ចការក្នុងផ្ទះត្រូវឲ្យស្អាត　　សង្វាតគ្រប់គ្រងណាកូនស្រី ។

ឪពុកតាវែងថ្លែងអធិប្បាយ បរិយាយតាមបែបបទបាលី
ឲ្យជំបូន្មានដល់កូនស្រី សង្ខេបបែបថ្មីយ៉ាងនេះឯង ៗ

១ សុសំវិហិតកម្មន្តា ប្រែថាស្រីចេះការចាត់ចែង
រៀបចំកិច្ចការផ្ទះសម្បែង ទុកដាក់គ្រឿងល្វែងជាខាងគ្រឿង ៗ
ជើងក្រានចានឆ្នាំងពានក្រឡ កន្ទក់អង្ករបាវការុង
អំបិលប្រហុកដាក់ពាងអុង បំរុងទៅមុខទុកមានខ្នាត ៗ
ខាងក្រៅរៀបចំឲ្យសមស័ក្តិ ពែងក្បាក់ដាក់ក្បែរគ្រែសំអាត
កន្ទេលបៀមចំព្រំសក្លាត បោសប្រាសសំអាតរាល់រាត្រី ៗ
ទោះការសំពត់បត់ដោយបែប ទើបខ្ទល់កល់តែបមានចាស់ថ្មី
គ្រឿងស្លៀកគ្រឿងពាក់ការប្តី មានបុណ្យឆ៉ានគ្ញីប្តីស្លៀកទៅ ៗ
មួយទៀតប្តីចេញចាកគ្រឹហា ជិតឆ្ងាយក្តីណាខ្លួននាងទៅ
ចាំផ្ទះថែទាំឃ្លាំមើលផ្លូវ មកដល់លំនៅចុះទន្ទួល ៗ
ទឹកមុខស្រស់បស់ញញឹមស្អាត ប្រណិបត្តន៍គ្រប់ខ្នាតដោយទំនួល
បើមានចំណីគ្រឿងដោយស្រួល គួរលើកទទួលជូនជាមុន ៗ
ចូរនាងចងចាំតាមច្បាប់ស្រី ប្រណិបត្តន៍ស្វាមីកុំទម្រង់
មានកេរ្តិ៍ពេះឈ្មោះល្អលន់ ស្រីគន់ជួបស្ថានសួគ៌ធំធេង ៗ

២–សង្គហិតបរិជនា កុំធ្វើកិរិយាដូចពីកេង

បើញាតិខាងប្ដីគេមកលេង ថ្វីក្រែងមានបើរកការអ្វី ៗ
ចូរនាងសស្រស់ដោះដាក់គួរសម រៀបចំហិបស្លាជាំបារី
សួរសាកឲ្យដឹងដើមហេតុ រកអ្វីលៃលកមើលមុខក្រោយ ៗ
បង្អោរថ្ងៃក្រោយយើងទានការ បានញាតិការពារជួយគិតឲ្យ
ហេតុនេះត្រូវយើងធ្វើអំណោយ ពេលក្រោយយើងក្រគ្រាន់គេយគន់ ៗ
តែពាក្យបុរាណមានមួយផ្នែក ថាសប្បុរសពេកច្រើនចាញ់ផង
អ្នកណាប្រស្រាច់ត្រើន បានក្ដីមូនចាញ់ឥឡើយ ៗ

៣ - គោរពគឺមនុគិត- រីឯស្រីណាចិត្តសោភី
រួមក្យស្ម័គ្រចិត្តពិតពេញទី មានចិត្តរម្មណីយប្ដីពិតៗ ៗ
ទោះខ្មៅទោះសក្អិលខ្ទប ប្ដូរតាមភាពគួបគំប៉ូលចិត្ត
បើញប្រុសដទៃគ្មានចិត្តគិត ចង់ផិតចង់ផាយហោលប្ដីឯង ៗ
បើនាងផិតប្ដីខុសទំនប្រាប់ ព្រះពុទ្ធទ្រង់ប្រាប់ស្ដាប់ឲ្យស្ដែង
ត្រូវស្ដាយកេរ្ដិ៍ឈ្មោះយសខ្លួនឯង ព្រោះទោសនោះតែងបានបាបធ្ងន់ៗ

៣ – សន្ស្តំអន- ក្ខតមានលក្ខណ៍ធ្វើប្រពន្ធ
បេះរៀបទុកដាក់កន្សាជន ទ្រព្យអ្វីស្រោលធ្ងន់មិនខ្ចបខាត ៗ
ប្ដីរកបានមកទុកដោយបទ គិតក្រែងក្រខ្សត់មានសំចាត
សំអាងកុំចាយឲ្យហួសខ្នាត ឲ្យសមបទបាទខ្លួនជាស្រី ៗ

កុំអាងទ្រព្យច្រើនក្រើនតាយ ក្រែងមានអន្តរាយក្រោយក្តី
បើយើងមានទ្រព្យនោះគប្បី ប្រាជ្ញាធ្វើអ្វីបានដូចចិត្ត ។
បើយើងក្រខ្សត់អត់ទ្រព្យធន មានការខ្វះខ្វល់ព្រួយរិះគិត
បុណ្យណាលោកបង់ជាការពិត ជាទ្រព្យគង់ល្បីតែពីស្រី ។

៥- ខ្លាអនលសា

កូនស្រីគ្រប់គ្នាគួរគប្បី
ស្តាប់តាមពុទ្ធដីកាព្រះជិនស្រី ត្រូវចំឃ្លាតខ្ញុំបម្រើ ។
រៀនដេរផ្ទុលបាក់ចាក់ជាក្បាច់ ក្រវិលរំលេចភាពខ្ទង់វិល
សំអាងសំអាតបាតមន្ទីរ កុំខ្ជិលឲ្យខ្ជះជាប់កល់ថ្ងៃ ។
កុំធ្វើប្រកាន់ជាតាបថោក ចំរៀនចំរេករៀបក្រៀមយ៍
កុំរើសរេការណាថោកថ្លៃ សព្វថ្ងៃដំរៃកេះចាំងអស់ ។
កុំរលោកបុព្វបុរសមនុស្សកើតមក គេចំរៀនគេពាំងស្រីប្រុស
គេកប់តែអ្នកមានរបស់ តែយើងគ្មានសាវរទីងខ្វះស៊ុ ។
សូម្បីបង់ប្រុសសារលោហិត សាច់ញាតិជុំជិតបំនៅទី
គេតែងពប់គេធ្វើគ្នាគ្នី អាប់ខ្ទមតំពាក់ពីខ្លួន ។
សន្សើមថែបបខ្វះពាក្យប្រដៅ ទុកគ្រាន់កូនចៅដាប់ច្បាប់ក្បួន
កូនស្រីត្រូវចាំបណ្តាំជូន ទីងបានទាំងខ្លួនទៅសួគ៌ា ។
លោកិយប្រុសប្រើរើងសព្វមុខ ចាំងម្តាយឪពុកញាតិមិត្តមា

ឲ្យគេគាប់មុខកូនកប់គ្នា ចប់ពាក្យពណ៌នាស្ទះម៉ែហោង ។

## ជំពូក ៣

### បណ្ដាំឪពុក

បទព្រហ្មគីតិ

ឱ! កូនស្ងួនពន្លក ចូរអ្នកយកពាក្យបិតា
ទៅកាន់ថែរក្សា កុំបីបាប្រហែសឡើយ ។
ឪពុកចាស់ហើយណា៎ មានតែបាបុត្រត្រាណត្រើយ
ស្ងួនខ្ញុំឪពុកហើយ ប្រុងប្រយ័ត្នណា៎កូនណា៎ ។
ត្រូវខំរករៀនច្បាប់ ចាំឲ្យខ្ជាប់ក្នុងអាត្មា
ខំប្រឹងរៀនសិក្សា ពាក្យបិតាទុកក្នុងប្រាណ ។
បើកូនស្ងួនពន្លក អ្នកកាន់យកដំបូន្មាន
បិតាកូននឹងបាន សុខក្សេមក្សាន្តយ៉ាងឧត្ដម ។
ហើយកូនស្ងួនឪពុក ពេញមាត់មុខថ្កើងមួនមាំ
ឥតមានក្ដីធុរម្ភ បានរុងរឿងកេរ្តិ៍បិតា ។
អ្នកកុំអាងយសស័ក្តិ អាងមាសប្រាក់ពាលប្រាជ្ញ

ម្ដេចកាន់កិរិយា ទុកសុភាពទើបប្រពៃ ។
ធ្វើដំណើរធ្វើរូបអង្គ ធ្វើពួតពង្រឹងពុកក្រៃ
មានស្លូតទន់ជោគជ័យ ក្នុងលោកិយនេះណា បា! ។

ក)(១) លោកឲ្យត្រាប់ពុតកង់ ដែលវិលវង់ត្រូវគ្រប់គ្នា
កុំត្រាប់ពុតសត្វខ្លា ឃើញតែសាច់ចង់ស៊ីនោះ ។

ខ) កុំត្រាប់ពុតដើមជ្រៃ ពឹងប្រស្រ័យឈើណាផ្ដោះ
យួរទៅរែតឈើនោះ ឲ្យដល់ស្លាប់នោះមិនល្អ ។

គ)- ឲ្យត្រាប់ឯកុកសាប កុំបីត្រាប់ឯកុកស
ឲ្យត្រាប់ឬស្សីល (២) កុំបីត្រាប់កន្ទ្រាញស្នាយ ។

ឃ)- ឲ្យត្រាប់សត្វក្ងោក កុំបីយកពុតទន្សាយ
ឲ្យត្រាប់ខ្មុំប្រាជ្ញប្រាយ កុំបីត្រាប់ជនពាលា ។

## ពាក្យពន្យល់

ក)- លោកឲ្យត្រាប់ពុតកង់ វិលត្រូវអង្គគ្រប់អាត្មា
ឲ្យមានចិត្តជ្រះថ្លា ត្រជាក់ជាក្នុងសន្ដាន ។

---

១ អក្សរនេះ គ្រាន់តែដាក់ឲ្យដឹងប៉ុណ្ណោះ មិនឲ្យអានទេ ។

២ ឬស្សី ១ ដុំគុម្ពដែលលិចរលង់ចុះទៅក្នុងទឹក ហើយដែលមើលទៅឃើញតែចុងដើមភ្ញីរ ស្នៀតឡើង ដោយសារទឹកហូរ នោះហៅថាឬស្សីល ។ ឬស្សីលនេះ បើបាប់លើកឡើង គេតែងបានច្រើនដើម ។

កុំឲ្យគ្រាប់ពុកខ្វា

ប្រាជ្ញាចង់តែបាន

ខ)-កុំឲ្យគ្រាប់ពុកតៃជ្រ

រូបតែជិតលុះគ្រា

គ)-ឲ្យគ្រាប់ពុកកុកសាប

ឲ្យគ្រាប់ឫស្សីលេ

អំពើពុកកុកសាប

គឺមិនអួតប្រាជ្ញប្រាយ

កុកសសម្បុរថ្លា

ពុំឫកបែបកលកិច្ច

អួតអាងអត្តអាត្មា

ទុកចិត្តជឿមនុស្សក្រៅ

រឹងឫស្សីលេ

អ្នកផងគិតសម្រាំង

រឹងស្វាយកន្ទ្រាញ

កម្រមានអ្នកណា

ក្មេកលោកពប់អាន

ឃើញមន៍ក្ងាសីងតែឃ្មាន

ដូចមនុស្សលោកក្រៅគម្រោ ៗ

ពីនប្រស្រ័យដើមណើណា

តែឈើនោះលុះផលមរណ៍ ៗ

កុំបីគ្រាប់ពុកកុកស

កុំបីគ្រាប់កន្ទ្រាញស្វាយ ៗ

ប្រសើរតាប់លបលាក់កាយ

ចេះអាគមមន្តគលកិច្ច ៗ

ពោះយាគ្រាគ្រប់ហើរហិច

កលនោះម្តេចដូចមនុស្សខ្មៅ ៗ

កូតកថាដោយសៅសៅ

ទ្រព្យផងនៅពុំកំបាំង ៗ

គល់វាល្អរៀនពល់ថ្នាំង

សម្រួលពៅត្រូវប្រាជ្ញា ៗ

នោះសឹងសាញដូចបន្ទា

ប៉ុនប្រាជ្ញាធ្វើការអ្វី ៗ

ថាបើបានយកមកខ្មី

| | |
|---|---|
| កន្ទុយល្អពីសី | មានស្មើទៀតសោះពឿង ៗ |
| អ្នកផងរីរេងចូលចិត្ត | បានមកគិតទុកជាគ្រឿង |
| គាត់តែងរៀនរុងរឿង | ធ្វើដំកើងយសបរិវារ ៗ |
| ទន្សាយពុកភ្លូនទៅ | គោរគាត់ស្រូវស្រែចំការ |
| គេឃើញទីងសម្បូរ | នាំគ្នាដាក់បង្អាក់បាន ៗ |
| ហេតុនេះលោកប្រដៅ | កុំបីទៅចូលផ្សំប្រាណ |
| ទីងអ្នកខ្ទៅសាមាន្យ | នាំអសោចកើតគ្នា ៗ |
| ហៃអស់ក្ខុខាំងឡាយ | កុំពាយមាយខំសក្រហ៍ |
| វិះរកវៀនមាត្រា | ច្បាប់ទម្លាប់ឲ្យចាំបែង ៗ |
| ប្រុងចិត្តប្រុងបញ្ញា | កុំម្សាឲ្យវង្វេង |
| យកតែទីងចិត្តឯង | មិនគិតក្រែងគ្រូបរិយាយ ៗ |
| មិនយកតាមសណ្តាប់ | មិនគ្រាប់ច្បាប់លោកពីនាយ |
| គួរបេះវិះជោះប្រាយ | ពាក្យទំនៀមទំនាយនោះ ៗ |
| យកទុកកងចិត្តា | ពិចារណាឲ្យចំពោះ |
| វិពីងឲ្យសាយសុះ | សព្វសេចក្តីកុំបីធ្លោយ ៗ |
| កុំយកតាមចិត្តឯង | មិនគិតក្រែងក្រក្រោយ |
| ចិត្រទីងកុំបណ្តោយ | បណ្តែតឲ្យកើតទោសា ៗ |

កុំលោភកុំចង់បាន ធ្វើបំពានក្រៅគម្រោ
កុំគាំងមានប្រាជ្ញា ថាគេល្ងង់មិនចេះស្មើ ។
ឃើញក្មេងកុំមាក់ងាយ ឃើញអ្នកធ្លាយកុំសើរើ
មានក្មែកឲ្យចេះប្រើ មើលឲ្យសព្វកុំទំនេរ ។
ខឹងឈានឲ្យមានខះប់ ពោះខឹងឈប់ឲ្យគិតគ្នេរ
ខឹងធ្លួលកុំគាលជេរ មើលទៅគេកុំមាក់ងាយ ។
ក៏ខុសកុំគាលខំ ក៏សុខមកុំចែងចាយ
រំពឹងឲ្យវែងឆ្ងាយ នេះទើបហៅអ្នកប្រាជ្ញ ។
កុំធ្វើការបំពាន លោភចង់បានក្រៅគម្រោ
កុំគាំងយសសក្តា បុណ្យអំណាចធ្វើគេបាន ។
មិនគិតគ្រង់បាបបុណ្យ ទោសទុក្ខធ្ងន់ដួចដល់ប្រាណ
ចំណោរទៅទឹងមាន ទោសទុក្ខភ័យពុំឃ្លាតឃ្លា ។
ដូច្នេះអស់កូនចៅ ចាំតទៅគ្រប់គ្នា
ត្រូវផ្ចង់ប្រុងកាយា តាមមាត្រាច្បាប់ប្រដៅ ។
កុំធ្វើតាមចិត្តពាល កុំស្រើបស្រាលដោយមនុស្សខ្លៅ
គេប្រាប់កុំគាលទៅ ព្នះគេហៅកុំគាលអរ ។
ខឹងណាស់ឲ្យខំអត់ បើខ្ជួនខ្សត់ឲ្យខំរក ,

គេឲ្យកុំអាលយក　　ទ្រព្យបានមកឲ្យទុកដាក់ ។
ថែទាំទើបគង់ទ្រព្យ　　មានប្រដាប់ទើបច្រើនស័ក្តិ
ធ្វើការទើបបានប្រាក់　　មានបុណ្យស័ក្តិព្រោះខំស្វាហ៍ ។
បាត់យសព្រោះក្តីខ្ជិល　　បាត់ទានសីលព្រោះសេពស្រា
ទីដ៏ច្រើនបាត់ប្រាជ្ញា　　ចិត្តមោហាភ្លេចគិតនឹក ។
ផ្សំទាំដាក់ក្នុងប្រាណ　　គ្រាន់ទូន្មានខ្លួនយប់ព្រឹក
បើភ្លេចឲ្យរំលឹក　　រិះគិតនឹកពាក្យប្រដៅ ។
របស់ឪពុកម្តាយ　　គ្រូបាធ្យាយក្រែងខ្លួនខ្លៅ
អ្នកប្រាជ្ញលោកចេះជ្រៅ　　ចងជាច្បាប់នេះទុកមក ។
ប្រដៅកូនគ្រប់គ្នា　　ឲ្យខំស្វាហ៍រះរៀនរក
រៀនច្បាប់ចាប់ចាំយក　　ជាពន្លកពន្លឺខ្លួន ។
កូនណាខំស្វាហ៍ស្តាប់　　គេគ្រងគ្រាប់ទុកជាក្បួន
កូននោះនឹងមាំមួន　　បានសុខខ្លួនក្នុងលោកិយ ។
ឥតទុក្ខឥតទោសា　　ល្អថ្លៃថ្លាទាំងប្រុសស្រី
ទោះទៅនាលោកីយ　　បរលោកក្តីបានសួគ៌ា ។

# ជំពូក ៤

## បកិណ្ណកៈដំបូន្មាន

## ស្តីពីគុណនៃសេចក្តីព្យាយាម

បទពាក្យ ៧

នេះពាក្យទំនៀមបុរាណមុន ទូន្មានពួកជនតទៅមុខ
ឲ្យអស់គ្នានៅចងចាំទុក ទើបបានទីសុខដោយស្មោះស្ម័គ្រ ៗ
ព្យាយាមសិក្សាទើបបានចេះ ព្យាយាមត្រិះរិះទើបយល់ជាក់
ព្យាយាមធ្វើការរកបានប្រាក់ ព្យាយាមរាក់ទាក់ទើបបានមិត្ត ៗ
ព្យាយាមទន្ទេញទើបបានចាំ ព្យាយាមចំណាំទើបមិនភ្លាត់
ព្យាយាមរួបរួមទើបមិនព្រាត់ ព្យាយាមផ្ចៀងផ្ចាត់ទើបបានត្រង់ ៗ
ព្យាយាមរក្សាទើបមិនបាត់ ព្យាយាមហ្វឹកហាត់ទើបបានធ្លាប់
ព្យាយាមចូលគាល់ទើបបានគាប់ ព្យាយាមថែទ្រព្យទើបមិនខាត ៗ
ព្យាយាមដុសលាងទើបបានជ្រះ ព្យាយាមជំរះទើបបានស្អាត
ព្យាយាមប្រយ័ត្នគ្មានប្រមាទ ព្យាយាមឧហាតទើបបានសុខ ៗ
ព្យាយាមសង្កេតទើបយល់ការ ព្យាយាមវិចារណ៍[1] យល់ទៅមុខ
ព្យាយាមខ្វាយខ្វល់រួចចាកទុក្ខ ព្យាយាមរុលរុកឈ្នះឧបសគ្គ ៗ

---

១ ពិចារណា ៗ

ព្យាយាមធ្វើល្អទើបបានពរ(១)
ព្យាយាមស្មោះសរគេស្មោះស្ម័គ្រ
ព្យាយាមកាប់កាន់គេកាត់ដាក់
ព្យាយាមគារវៈបានសំណាប ។
ព្យាយាមតស៊ូទើបបានឈ្នះ
ព្យាយាមមានៈទើបអន់អាប
ព្យាយាមម៉ឺងម៉ាត់មានគេខ្លាច
ព្យាយាមលះកាចបានការុណ(២) ។
ព្យាយាមសន្សំទើបបានមាន
ព្យាយាមធ្វើទានទើបបានបុណ្យ
ព្យាយាមរៀនមិនជាប់ជុន
ព្យាយាមធ្វើគុណទើបគ្មានទោស ។

## ជំពូក ៥

### បកិណ្ណកៈដំបូន្មាន

### ស្តីពីកិច្ចត្រូវស្គាល់គ្រប់លក្ខណៈ

បទកាកគតិ

កើតមកជាមនុស្ស
គួរស្គាល់ត្រូវខុស
ស្គាល់ធ្ងន់ស្គាល់ស្រាល
ស្គាល់បាបស្គាល់បុណ្យ
រីឯជនប្រាជ្ញពាល
ដើមចុងកណ្តាល
ស្គាល់ខ្លាចស្គាល់ហ៊ាន ។

ស្គាល់តិចស្គាល់ច្រើន
សង្កាត់ក្រវើន
ស្គាល់អត់ស្គាល់ឃ្លាន
ស្គាល់វៀចស្គាល់ត្រង់
ស្គាល់បង់ស្គាល់បាន
ស្គាល់ដីស្គាល់ដាន

---
១ ល្អ ។ ២ សេចក្តីករុណា ។

ស្គាល់ព្រៃស្គាល់ក្រាញ់ (¹) ។

ស្គាល់គាប់ស្គាល់ខុស ស្គាល់ស្លាប់ស្គាល់រស់
ស្គាល់ឈ្នះស្គាល់ចាញ់ ស្គាល់ក្រញ់ស្គាល់ប្រោះ
ស្គាល់ដោះស្គាល់ដេញ ស្គាល់ចូលស្គាល់ចេញ
ស្គាល់ក្រស្គាល់មាន ។

ស្គាល់តិចស្គាល់ធូរ ស្គាល់ខាប់ស្គាល់យូរ
ស្គាល់មានស្គាល់គ្មាន ស្គាល់ដើរស្គាល់ដេក
ស្គាល់ស្រេកស្គាល់ឃ្លាន ស្គាល់ខ្ពស់ទាបមាន
ស្គាល់ទ័លស្គាល់ក្រ ។

កិច្ចត្រូវស្គាល់នេះ គួរត្រូវចាំចេះ
ហើយត្រូវកាន់យក ត្រង់បទជាបុណ្យ
ជាគុណល្អៗ លះបទមិនល្អ
ឲ្យឆ្ងាយចេញហោង ។

## ជំពូក ៦

### បកិណ្ណកៈដំបូន្មាន

ស្តីពីព្យញ្ជនៈ (ក) ទីងស្រ (¹)

ផ្សំបានជាពាក្យ (ក៏)

---

១-រាំលក្អួច ១ មានស្មៅទាបៗ ។

បទពាក្យ ៧

នេះគឺពួកគួរគប្បី«កុំ» ចូរកូនចាំកុំបីភយមាយ
ពាក្យនេះទុកដូចជាសំពាយ ទៅបរលោកនាយគ្រាន់ជាស្បៀង ៗ
កុំគិតស្រេពេកវាបែកបាក់ កុំឲ្យថ្កាំងថ្កាក់វាបាត់សួន
កុំខ្ជិលឆយឆោកវាទោកខ្វន កុំឲ្យរេះពួនវាបាត់មុខ ៗ
កុំមានះពេកវាបែកមិត្ត កុំឲ្យទ្រុស្តស្និទ្ធវាបាត់សុខ
កុំឲ្យលើកខ្លួនវាផ្ទួនទុក្ខ កុំឲ្យបាត់មុខវាអប្រិយ ៗ
កុំឲ្យរាត់ស្នេហ៍វាបែរឃ្លាត កុំឲ្យទ្រុស្តញាតិវាកើតក្តី
កុំឲ្យភានហួសអាយុខ្ចី កុំឲ្យពាយស្រីវាខូចឫក ៗ
កុំឲ្យស្ងៀមដៃវាធ្លាប់លួច កុំឧបជន្ទន់វាធ្លាប់ស្ពើក
កុំឲ្យយឺតពេកវាទ្រមឹក កុំឲ្យឆ្អើងឫកគេខ្ពើមស្អប់ ៗ
កុំឲ្យស៊ីច្រើនវាបែកពោះ កុំឲ្យលេះលោះវាខូចទ្រព្យ
កុំឲ្យខុសបរៀយវាអគតិ កុំឲ្យលេលាប់វាធ្លាប់ចិត្ត ៗ

## ជំពូក ៧

បកិណ្ណកៈដំបូន្មាន

ស្តីពីស្រះ (ឧ)និងព្យញ្ជនៈ(យ)

ផ្សំបានជាពាក្យ (ឧយ)

បទពាក្យ ៧

នេះគឺពួកតួអក្សរឲ្យ កូនចៅខានក្រោយត្រូវរក្សា
ទុកជាសម្បត្តិកេរ្តិ៍ជូនគា គម្រោបគម្រាបច្បាប់ចាស់ថ្មី ។
ឲ្យរៀនអក្ខរពាក្យជូនគា ឲ្យរៀនវិជ្ជាការលោកិយ
ឲ្យរៀនចិត្តល្អកុំខ្វះខ្វី ឲ្យខំឃ្មាតខ្មីរកទ្រព្យធន ។
ឲ្យរៀននូវច្បាប់ប្រពៃណី ឲ្យខំរកស៊ីកុំលួចប្លន់
ឲ្យសង្គ្រោះញាតិមានអាសន្ន ឲ្យចេះអត់ធន់កុំតាំងឡាយ ។
ឲ្យចាំទំនៀមទំនងព្រេង ឲ្យចេះចាំវិន័យបរិយាយ
ឲ្យចេះរាប់ព្រៀងលានជិតឆ្ងាយ ឲ្យផ្សាយមេត្តាដល់ជនផង ។
ឲ្យស្គាល់ខ្ពស់ទាបដកថយទៅ ឲ្យស្គាល់ប្រាជ្ញខ្លៅនូវរៀមច្បង
ឲ្យចងចាំចិត្តនឹកខ្លាចហ្មង ឲ្យក្រាបឲ្យក្រង់ច្បាប់ធម្មា ។
ឲ្យមានមេត្តាប្រយ័ត្នទោស ឲ្យមានសន្តោសលះលោភ
ឲ្យមានមេត្រីប្រណីគ្នា ឲ្យមានចិត្តជាជាប់ខ្ទី ។

## ជំពូក ៨

### បកិណ្ណកៈដំបូន្មាន

ស្តីពីព្យញ្ជនៈ ( ប ) និងស្រៈ ( ើ )

ផ្សំបានជាពាក្យ ( បើ )

បទពាក្យ ៧

នេះគឺពួកអក្សរ " បើ " មានគុណលើសលើកពដែនដី
កូនចៅប្រុស ១ នឹងស្រី ១ គប្បីចងចាំចណ្ដាំពិត ៗ
បើម៉ែនឹងបេះឲ្យគេគោត បើម៉ែនឹងដោតឲ្យគេគាណិត
បើម៉ែនឹងហ៊ានឲ្យមានចិត្ត បើម៉ែនឹងគិតឲ្យថ្លៃថ្នូ ៗ
បើម៉ែនឹងកាចឲ្យពេញវង្ស បើម៉ែនឹងល្ងង់ឲ្យផុតថា
បើម៉ែនឹងបេះឲ្យហានក្លា បើម៉ែកប់គ្នាឲ្យទៅមក ៗ
បើចិត្តគិតស្អប់កុំឲ្យបាញ់ បើចិត្តស្រឡាញ់កុំឲ្យគេ
បើស្រីប្ដីលែងកុំឲ្យយក បើថ្កុបធំម្ចាស់មកកុំគេច ៗ
បើនាមបាក់គ្រាន់នឹងជួស បើសំដីហួសបន់ទ្រព្យ
បើធ្វើទានហានត្រូវណានា ការជាតិសាសនា ព្រះមហាក្សត្រិយ៍ ៗ
ពាក្យនេះបុរាណលោកទូន្មាន កូនចៅគ្រប់ប្រាណចូរប្រណិប័តន៍
ចងចាំគ្រប់បទដោយមធ្យ័ត កុំបីភ្លាំងភ្លាត់បទណាឡើយ ៗ

## ជំពូក ៩

### បកិណ្ណកៈដំបូន្មាន

### ស្ដីពីមេអំបៅជៀសផ្លូវ

បទកាកគតិ

មេអំបៅថា អាចោរចោហា សត្វដង្កូវនេះ រូបកង្អាក្រក់
ក្រខ្វក់អីម្ល៉េះ ក្លិនខ្ទុយផ្អាបផ្អេះ អញទើមណាស់ណា ។
ទៅណាខ្រែលខ្រែល អាក្រាលខនល ជាអនាថា ម្ដេចកិតឃើន
ព្រះហើនមហិមា វារលើផ្កាណា ផ្កានោះបាត់ក្លិន ។
ទៀសចេញឲ្យឆាប់ ទំនៅទីងស្ងាប់ ទីងិវិទ្ធិកមរិទ(១) ចិញ្ចឹមដីកំ
ទីងផ្កាមានក្លិន ជាតិឯងជាតិហិន ទៅស៊ីលាមកទៅ ។

ដង្កូវថាឃើ! តីម្រិលមិញតើ! ក្លិចខ្លួនហើយចៅ ស្អាបខ្លួនទៅ
អ្នក គ្រជាក់ថ្មក្ដៅ សត្វមេអំបៅ ចេញទៅពីណា ? ។
ឲ្យដឹងជាតិខ្លួន សំមលេងសំនួន ជៀលគ្នាទោពី កុំអាលគ្នះគេ
ជាមេជាបា ដូចបាចខ្សាច់ណា+ ប្រាសខ្យល់វិញទៅ ។

រឿងនេះព្រះច្បាប់ លោកមិនឲ្យគ្រាប់ តាមមេអំបៅ
ជាសត្វដែលកើត កំណើតដង្កូវ ហើយជៀលគ្នះទៅ
កំណើតដើមឯង ។

---

១- កក្ខង ។

# រឿងសាមកុក

## កណ្ឌទី ៤១

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្ដានស្នេហាជាតិ។

អ៊ុយកាយឮដូច្នោះក៏រសាយជម្ងឺក្នុងខ្លួន ខំផ្ទប់ខ្លួនក្រោកឡើងអង្គុយ ខំទះចាប់ឃាំតេកហើយថា ដែលអ្នកទទួលសារភាពជួយទំនុកបំរុងការទាំងអម្បាលនេះខ្លួនអ្នកមិនបង់កំឡាំងដែលបានតាំងខ្លួនមកធ្វើជាទាហានទេ ។ ឃាំតេកថា ការនេះនឹងបង្អង់ឲ្យយូរមិនបាន បើអ្នកមានកិច្ចត្រូវពន្យល់បំភ្លឺយ៉ាងម្តេច ក៏ឲ្យប្រញាប់ប្រាប់ឲ្យធ្វើជាសំបុត្របុតហោយឲ្យមកចុះ ខ្ញុំនឹងអាលទៅរិះគិតឲ្យបានប្រយោជន៍ក្នុងពជការរបស់នាយទៅហូយយើង ។ អ៊ុយកាយក៏ខំប្រឹងសរសេរសំបុត្រ ហើយបិទស្រោម ហុចទៅឲ្យឃាំតេក ហើយប្រាប់ថា ចូរអ្នកខំទៅគិតឲ្យបានសម្រេចការពជការរបស់នាយទៅ

ហ្វាយយើងចុះ ៗ នាំគេកខ្ទួលសំពុត្រហើយក៏លាទៅកាន់ទីសំណាក់ លុះវេលាយប់ក៏តែងខ្លួនស្លៀកពាក់បន្លំជាព្រានប្រម៉ង់ ចុះទូកចែវតម្រង់ទៅជិតបន្ទាយចូឆ ៗ

ខណៈនោះខ្ទួលពួកតាហានយាមល្បាតកងទ័ពចូឆ ឃើញមនុស្សថ្មែកចែវទូកតូចចូលទៅក៏ចាប់យកខ្លួនទៅសាកសួរ ហើយចូលថ្លឹងជល់ចូឆតាមការថា យើងខ្ញុំចាប់មនុស្សបង់ត្រីបានម្នាក់ បានសួរបញ្ជាក់ថាឈ្មោះនាំគេកជាទីប្រឹក្សាស៊ិនគួនទីងបង់ចូលមកជំរាបការអាថ៌កំបាំង ដល់លោក ចូឆ ពួជូព្រោះក៏ថា នាំគេកមកនោះ ប្រាថ្នានឹងស៊ើបស្តាប់ការក្នុងកងទ័ពយើង ទើបឲ្យយកខ្លួននាំគេកចូលទៅក្នុងបន្ទាយ ប្រហែលយាម ៣ បាយ សួរថាខ្លួនអ្នកមកក្នុងទីនេះដោយហេតុអ្វី ? ។ នាំគេកឆ្លើយថា ខ្ញុំបាទបានឮគេនិយាយជាច្រើនគ្នាថា មហាចបកជនេះ មានតម្រិះប្រាជ្ញាជ្រៅទូលាយណាស់ ប្រកបទាំងចិត្តក៏សុចរិតល្អ មានអធ្យាស្រ័យសុភាពរៀបរយ គួរសមនឹងខ្ញុំរាជការតូចដ៏មិនរើសមុខ ខ្ញុំបានដឹងទុកដូច្នេះ បានជាចូលមកដល់លោក ឧបមាដូចមនុស្សខ្ញុំពាល់ដើរផ្លូវ ហើយស្រេកទឹកណាស់ លុះបានទៅប្រទះឃើញស្រះមានទឹកនៅថ្លា ក៏ប្រាថ្នានឹងដងទទួលទានដោយអំណរនេះដូចខ្ញុំបាទបានមកឃើញមុខមហាចបកជបីល្អ ប្រកបដោយអំណាច ខ្ញុំឃើញថាជាអ្នកប្រកាន់ទិដ្ឋិមានះ មិនបានស្គាល់ច្បាស់ជាមនុស្សល្អនឹងអាក្រក់សោះ បើនឹងពីគ្រោះមើលឲ្យ

សព្វ កំមិនគាប់តាមពាក្យដែលគេកប់សរសើរអ្នកនោះសោះ ដែលគំនិតអ៊ុយកាយទឹងខ្ញុំបាទបានរិះគិតចាត់ប្រើឲ្យខ្ញុំបាទមកនេះ កំព្រួយការអសារប្រយោជន៍ទៅទទេ ៗ

ចូឆូព្វជូហោះកំសួរថា យើងទឹងស៊ុនគួនទៅហ្វាយស្រុកកាំងតាំង កំជាខាំងសត្រូវធ្វើសឹកសង្គ្រាមនឹងគ្នា ខ្លួនអ្នកឯងកំជាទីប្រឹក្សារបស់ស៊ុនគួនដូចជាគូសត្រូវទឹងយើងដែរ ដែលអ្នកឯងមកនេះ ហេតុម្តេចកំមិនសាកសួរឲ្យដឹងសេចក្តីពីក្រៅឲ្យច្បាស់ជាចូលមកនេះ ទឹងល្អឬអាក្រក់ជាមុនសិន ឬទឹងមកសន្ទិតសន្ទិនបន្តិចឲ្យយើងរត់ចុះទៅទទួលអ្នកឯងនោះ ជាគួរសមទឹងអព្យាស្រ័យនៃមេទ័ពដ៏ជាធំហើយឬ ៗ ឆាំតេកព្វជូហោះកំធ្វើជាសរសើរចូឆូថា លោកមានប្រសាសន៍នេះត្រូវណាស់ហើយជាអ៊ុយកាយនោះ បានទៅធ្វើកដការតាំងពីគ្រាស៊ុនគៀនទឹងស៊ុន-សេកតហ្វូតមកដល់ស៊ុនគួន ត្រឹមអំណាចស៊ុនគួនកំនៅមិនដែលមានបាបទោសខ្លួនពីរ៉ូសោះ ឥឡូវត្រាក់មកដល់មុខឆាំជីវយី បានធ្វើជាមេទ័ពប៉ុណ្ណោះ ដោយស៊ុនគួនលើកមុខកប់ថា មានតម្រិះប្រាជ្ញា ជីវយីកំក្បៀវក្លាកំរើបចិត្តឥតកោតក្រែង តាំងតែបញ្ចោញរោហារកំហែងប្រើបង្គាប់អ៊ុយកាយដែលជាខ្ញុំកដការចាស់ ឲ្យលុះក្នុងអំណាចខ្លួនបានសេចក្តីអំបួយសង្វែង ១ ពាល់តែបណ្តាលចិត្តវង្វេងឲ្យចាប់អាឃាតព្យាបាទជីវយីវិញ ឯអ៊ុយកាយទឹងខ្ញុំបាទនោះ គឺជាកៀនសំឡាញ់គ្នាដ៏ស្និទ្ធ

ធ្លាប់ស្គាល់ចិត្តកក់ក្ដៅនៅនឹងគ្នាដូចបងប្អូនបង្កើតមកយូរហើយ គ្រានេះអ៊ុយកាយក៏មានទុក្ខតោមស្រៃ លុះនឹងលបរត់មកនៅជ្រកកោននឹងលោក ក៏ពុំអាចដឹងថាចិត្តលោកមានសេចក្ដីអាណិតអាសូរករុណាដែរ ឬយ៉ាងម្ដេច តាល់គំនិតគិតមិនដាច់ស្រេច ព្រោះត្រូវទណ្ឌកម្មដោយអាជ្ញាធរយ៉េវ៉ុយ ដំគ្រាំគ្រាជាទម្ងន់ណាស់ ចេះតែគិតមិនស្រេចស្រឡះជាយូរថ្ងៃណាស់មកហើយ ទើបវេលានេះក៏ប្រថុយប្រើខ្ញុំបាទឲ្យមកជំនួស មានទាំងសំបុត្រ ១ ច្បាប់មកផង ដើម្បីនឹងគំនាប់ជូនលោក ។

ចូឆុញជួបោះសួរថា សំបុត្រអ៊ុយកាយដែលឲ្យមកនោះ ឥឡូវនៅឯណា ? ៖ ឆាំគេកក៏ដកជូនទៅចូឆុ ។ ទទួលហើយក៏បើកស្រោមលា មើលឃើញមានសេចក្ដីថា:

« ខ្ញុំបាទអ៊ុយកាយ សូមគំនាប់មកដល់មហាទេពកដជ្រាង, ព្រោះខ្ញុំបាទបាននៅធ្វើជាការតាំងពីស៊ុនគៀននឹងប៊ុនសេក រហូតមកដល់ស៊ុនគួន ៣ ចៅហ្វាយនាយនេះហើយ មិនដែលបានទទួលទូរៈភ័យអន្តរាយអ្វីសោះ គុណរបស់សេស៊ុនជាទម្ងន់កេអ្វីប្រៀបពុំបាន ខ្ញុំបាទតាំងចិត្តនឹងគិតធ្វើជាការតបស្នងសងគុណគេជានិច្ច ដែលលោកលើកគងទ័ពមកគ្រានេះ មានទាហានរាប់រយម៉ឺន តម្រិះប្រាជ្ញាលោកក៏ជ្រៅទូលាយ ទុកមាដូចជាដុំថ្មសិលាដ៏ធំមិនរលើករម្រើក ឯទាហានគងស្រុកកាំងតាំងក៏មានតិច ទុកមាដូចជាស្មៅដីតូច . . . . . . .

(នៅមានត)

# ពាក្យវប្បធម៌

លោក នាង-ហ៊ូ រៀបរៀង

លោក សម-ថាំង ពិនិត្យ

---

អស់លោកអ្នកទាំងឡាយ !

ក្នុងវេលានេះ គណៈកម្មការវប្បធម៌ សូមធ្វើអត្ថាធិប្បាយ ដោះស្រាយនឹងសំនួររបស់លោក គង់-ម៉ន គ្រូបង្រៀន នៅសាលាបឋមសិក្សាបំពេញវិជ្ជា «សម្ពោធិញ្ញាណ» ក្នុងឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ដែលបានផ្ញើជាសំនួរមកឲ្យគណៈកម្មការវប្បធម៌ ដោះស្រាយ-រំគាយសេចក្ដីផ្សាយ តបនឹងសេចក្ដីសង្ស័យរបស់ខ្លួន ។

មុននឹងដោះស្រាយតបនឹងសំនួរនោះ គណៈកម្មការវប្បធម៌ សុំថ្លែងនូវសេចក្ដីគ្រេកអរដោយសុទ្ធចិត្ត ចំពោះលោក គង់-ម៉ន ដែលជាម្ចាស់សំនួរ ។

ក្នុងសំបុត្ររបស់លោក គង់-ម៉ន មានសេចក្ដីសង្ស័យចំពោះពាក្យដូចខាងក្រោមនេះ :

១-មត្តេយ្យសាលា

២– ហោសប្បាយ

៣– បេតិកកណ្ឌ

៤– កញ្ញា នារី នឹងយុវតី

ពាក្យទាំងបីម៉ាត់នេះ តើជាស្រដីផ្សេងគ្នាដូចម្ដេច ឬមួយជាពាក្យសម្រាប់ហៅបានច្រើនម៉ាត់ ៗ ឯពាក្យ ទី ១ ទី ២ នឹងទី ៣ ខាងលើ លោក គង់–ម៉ន ពុំបានបញ្ជាក់អំពីការជឿនធ្លល់របស់លោកផងទេ ប៉ុន្តែលោកអ្នកសួរនេះប្រហែលជាចង់ឲ្យយើងបកស្រាយពន្យល់អំពីអត្ថន័យ ក្នុងពាក្យទាំងនោះ ឲ្យបានយល់ច្បាស់ឡើងទៀត ។

៥– សួរថា ពាក្យជាភាសាខ្មែរសុទ្ធ ដែលពុំមានក្លាយមកពីបាលីនឹងសំស្ក្រឹតទេ ហើយសរសេរត្រូវដាក់អក្សរ " រ " ពីមុខ តើមានលក្ខណៈ ឬមេរៀនអ្វីជាគ្រឿងចំណាំឲ្យពិតប្រាកដដែរឬទេ ?

យើងសុំឆ្លើយតបវិញតាមសំនួរទាំងអស់ដូចតទៅ :

ទី១– ពាក្យថា មត្តេយ្យសាលា=សរសេរៈ ម ស្រៈអេ–ត ជើង ត–យ ជើង យ– ស–ស្រៈ អា–ល– ស្រៈអា ។ ពាក្យនេះ ជាពាក្យ បាលី , កើតមកពីសព្ទ ២ ម៉ាត់ គឺ មត្តេយ្យៈ ១ នឹងសាលា១ ។ សំរេចមកពីរូបដើមថាមាតាតាមវេយ្យាករណ៍បាលី គេស្គាល់បានថាជាពួកការតទ្ធិតចុះ " ណៈ " បច្ច័យ ។ បើចង់ថាបទវិគ្រោះថា មាតុយា

ការ៉ា , មត្តេយ្យ ប្រែថា ភាពនៃមាតា ។ សាលា ប្រែថា រោងឬផ្ទះ ។ ប្រើរួបចូលគ្នាជាសមាសនាម បានជាមត្តេយ្យសាលា, ប្រែតាមអត្ថានុរូបថា សាលាមានភាពដូចជាមាតា ; តាមអត្ថប្បដិរូប បានទៅជាឈ្មោះនៃសាលារៀនពិសេសមួយយ៉ាង ដែលគេសម្រាប់បង្រៀន ឬ អប់រំកុមារ-កុមារីតូច ៗ ដែលមានវ័យពុំទាន់ល្មមនឹងរៀនអក្សរសាស្ត្រនៅឡើយ ហៅថា មត្តេយ្យសាលា បារាំង ថា (Ecole Maternelle) ។

ទី២ រហស្សូបាយ= សរៈសរ= រ ហ-ស-ជើងស ស្រៈអូ ប ស្រៈអា ជើង យ ។ ពាក្យនេះ ជាពាក្យបាលីកើតមកពីសព្ទ ២ ម៉ាត់គឺ រហស្សៈ ១ នឹង ឧបាយៈ ១ រហស្សៈ ប្រែថា សេចក្តីស្ងាត់ , ការសម្ងាត់ , ការកំបាំង, ឧបាយៈ ប្រែថា ល្បិច, កិច្ចកល, ផ្លូវគំនិត ។ រួបចូលគ្នាជាសមាសនាម បានជា រហស្សូបាយ ប្រែថា ល្បិច , កិច្ចកល ជាការសម្ងាត់ ។ បារាំង (Intrigue) ។

សុំជូនឧទាហរណ៍ ជាប្រយោគដូច្នេះ ដើម្បីឲ្យងាយយល់ ៖

ក្នុងពេលថ្មី ៗនេះ, ទោះបីពួកក្បត់មានរហស្សូបាយយ៉ាងណា ក៏រាជរដ្ឋាភិបាលនៅតែឈ្លាសវៃជាងពួកសត្រូវ រហូតដល់ចាប់បានពួកអ្នកសមគំនិតឥតមានសល់ ។

ឧទាហរណ៍ ជាប្រយោគប៉ុណ្ណេះ បញ្ជាក់ជូនអស់លោកអ្នកឲ្យ

យល់អំពីពាក្យថា ហេស្សប្បទាយ ។

ទី៣ - ពាក្យថា បេតិកភណ្ឌ = ប៉េះ-ប៉េ = ស្រៈ អេ-ត ស្រៈអ-ក ភ-ណ-ដើង ។ ពាក្យនេះជាពាក្យបាលី, កើតមកពីសព្ទ ២ គឺ បេតិកៈ ១ និង ភណ្ឌៈ១ ។ បេតិកៈ តាមវេយ្យាករណ៍បាលីជាពួកតទ្ធិត, សំរេចមកពីរូបដើមថា "បិតា" ។ បើចង់ជាបទវិគ្រោះថា បិតុនោ សន្តកំ, បេតិកំ ប្រែថា ជារបស់ ឬជាចំណែកខាងបិតា ; ភណ្ឌៈ ប្រែថា ទ្រព្យ, របស់, គ្រឿងប្រើប្រាស់, ផ្សំចូលគ្នាជាសមាសនាម បានជា បេតិកភណ្ឌ ប្រែថា ទ្រព្យ, របស់ជាចំណែកខាងបិតា, បារាំងថា (Patrimoine) ។

សុំជូនឧទាហរណ៍ ជាប្រយោគឲ្យងាយយល់ដូចខាងក្រោមនេះ ឯករាជ្យ នៃប្រទេសកម្ពុជា ជាបេតិកភណ្ឌរបស់ពលរដ្ឋខ្មែរគ្រប់រូប ព្រោះជាគុណសម្បត្តិបានមកដោយសារស្នាព្រះហស្ត របស់សម្តេចសហជីវិនជាព្រះបិតានៃពលរដ្ឋខ្មែរទាំងអស់គ្នា ។

យើងសុំបញ្ជាក់ជូនទៀតថា ទ្រព្យរបស់ផ្សេងៗទាំងអស់ ដែលជាចំណែក ឬជាកេរ្តិ៍ដំណែលខាងឪពុក ហៅថា បេតិកភណ្ឌទាំងអស់ ។ ក្នុងភាសាបាលី ដូនតាយើងមានប្រើសំដៅទៅលើទ្រព្យរបស់ទាំង២ ចំណែក គឺទាំងចំណែកខាងមាតានិងចំណែកខាងបិតា គឺហៅថា បេតិ-

គកណ្ឌដែរ ។

សេចក្ដីអធិប្បាយប៉ុណ្ណេះល្មមអស់លោក-អ្នកអាន អាចយល់បាន អំពីពាក្យ បេតិគកណ្ឌនេះហើយ ។

សំនួរទី ៤ លោកគង់–ម៉ីន សួរថាពាក្យ៣ម៉ាត់គឺ កញ្ញា–នារី និងយុវតី តើជាស្រីផ្សេងគ្នាដូចម្ដេច,? យើងឆ្លើយជូនវិញដូចតទៅនេះ

សូមអស់លោក-អ្នកអានទាំងឡាយជ្រាបថា ពាក្យទាំង៣ម៉ាត់ខាងលើនេះ មានអត្ថន័យមិនដូចគ្នាទេ ។ ពាក្យថា កញ្ញា ជាស្ត្រីភេទដែរ ប៉ុន្តែសំដៅទៅលើស្ត្រីក្រមុំ ដែលនៅជំទង់ពុំទាន់ពេញការនៅឡើយ ។ ឯពាក្យ យុវតី ក៏ជាស្ត្រីភេទដែរ ប៉ុន្តែសំដៅស្ត្រីក្រមុំគ្រប់ការហើយៗ ដែលពុំទាន់មានគូស្រករនៅឡើយ ត្រូវគ្នានឹងពាក្យខ្មែរថា "ស្រីក្រមុំ" នេះឯង ។ ចំពោះពាក្យយុវតីនេះ យើងតែងសង្កេតឃើញមានប្រើក្លាយទៅជា យុវនី ក៏មានដែរ ។ ពាក្យយុវនីក្នុងភាសាបាលីមិនមានប្រើសោះតែម្ដង យើងឃើញមានតែយុវៈឬយុវនៈដែលក្លាយមកជាយុវជនប៉ុណ្ណោះ ប្រែមកថា កំលោះ-ប្រុសកំលោះ, ឯចំណែកពាក្យជាគូគ្នានឹងពាក្យថា យុវៈ យុវនៈនោះ គឺពាក្យយុវតីនេះឯង ត្រង់ពាក្យថា យុវនី ពុំឃើញមានប្រើក្នុងភាសាបាលីទេ ។ ដូចគ្នានឹងពាក្យថាមិត្ត ពាក្យនេះជាពាក្យបាលីដែរ ប្រែថាអ្នកដែលរាប់អានគ្នាជិតដិត ។ ពាក្យមិត្តនេះជាពាក្យកណ្ដាល

ពុំមែនជាពាក្យសំរាប់ប្រើបានតែខាងប្រុសហើយខាងស្ត្រីប្រើពុំបានទេ ឧទាហរណ៍ ដូចជា បាបមិត្ត មិត្តអាក្រក់, កល្យាណមិត្ត មិត្តល្អ គឺសំដៅទៅលើមនុស្សប្រុស ស្ត្រីទាំងអស់គ្នា ពុំមែនបានតែខាងប្រុសតែមួយផ្នែកនោះទេ. ព្រោះយើងពុំដែលឃើញមានពាក្យបាលីថា «បាបមិត្តនី កល្យាណមិត្តនី» សំរាប់ខាងស្ត្រីគេទេ នោះគាល់តែសោះ ផ្ទុយទៅវិញ ស្រាប់តែឃើញខ្មែរយើងនាំគ្នាប្រើដោយច្រើនថាមិត្ត និងមិត្តនី សំដៅសេចក្តីថា មិត្តប្រុស មិត្តស្ត្រីទៅវិញ ។

ហេតុដូច្នេះ គួរយើងនាំគ្នាប្រើឲ្យបានត្រឹមត្រូវឡើងវិញ គឺប្រើតែត្រឹម មិត្តៗ តែប៉ុណ្ណោះបានន័យថា មិត្តទាំងប្រុសទាំងស្រីទៅហើយ ។ ដូចគ្នានឹងពាក្យថា មនុស្ស-បុគ្គល-កស្ត្រ—ខេមរៈ ។ល។ ដូច្នេះដែរ យើងមិនចាំបាច់ បំបែកឲ្យទៅជា មនុស្សី បុគ្គលី កស្ត្រី-ខេមរីដើម្បីឲ្យទៅជាស្ត្រីភេទនោះឡើយ គឺគ្រាន់តែថា មនុស្ស-បុគ្គល កស្ត្រ-ខេមរៈ តែប៉ុណ្ណោះ បានសេចក្តីទូទៅទាំងប្រុសទាំងស្រីទៅហើយ ។ ឯពាក្យថា នារី ប្រែថា ស្ត្រី ១ ម៉ាត់ប៉ុណ្ណោះឯង ជាគូគ្នានឹងពាក្យថា «នរៈ» នរៈ ថាមនុស្សប្រុស នារី ថាមនុស្សស្រី ។ ទោះបីស្ត្រីចាស់ ឬ ក្មេងក៏ហៅថានារីបានទាំងអស់ ។

សំនួរទី ៤ លោក គង់-ម៉ន សួរថាពាក្យខ្មែរសុទ្ធដែលយើងសរសេរ

ត្រូវដាក់អក្សរ(រ)ពីមុខដូចជាពាក្យថា សរសេរ ផ្ការ–គំនរ-ទំនេរៗលៗ

ពាក្យទាំងនេះ តើមានលក្ខណៈអ្វីជាមេរៀនឬទេ ? ដើម្បីឲ្យគ្រាន់តែក្រឡេកឃើញក្តាម អាចសំគាល់បានថាពាក្យនេះត្រូវមានអក្សរ (រ) ពីមុខ ឬមិនមានអក្សរ (រ) ពីមុខ ? ។

ត្រង់សំនួរនេះ យើងសុំឆ្លើយតបវិញថា ពុំទាន់មានលក្ខណៈអ្វីជាមេរៀន ឲ្យបានទៀងទាត់ពិតប្រាកដនៅឡើយទេ ។ បើតាមការពិចារណាដេញដោលតាមផ្លូវគំនិត ដែលធ្លាប់សំគាល់មកក៏គង់តែអាចឲ្យមានការកត់សំគាល់បានដោយអន្លើៗដែរ ប៉ុន្តែទោះបីមានការកត់សំគាល់បានខ្លះដូច្នោះ គឺយើងមិនអាចនឹងយកមកបកស្រាយជូនជាផ្លូវការបានឡើយដែរ ព្រោះវចនានុក្រម ដែលជាក្បួនធំបំផុត នៃអក្សរសាស្ត្រយើង លោកពុំមានឲ្យគន្លងអ្វីសោះអំពីរឿងនេះ ។ ហេតុដូច្នេះ បើយើងបកស្រាយជូនតាមផ្លូវគំនិតនោះទៅ ខ្លាចក្រែងផ្ទុយគ្នានឹងគំនិតរបស់វចនានុក្រម ។

ដូច្នេះ សុំអស់លោក-អ្នករៀននិយមទៅតាមការចំណាំរបស់ខ្លួនរៀងៗទៅចុះ ព្រោះករណីនេះពុំទាន់ជាការហួសវិស័យរបស់យើងម្នាក់ៗ ដែលជាអ្នករៀនសូត្រនៅឡើយទេ បើយើងប្រៀបធៀបរឿងនេះទៅនឹងអក្សរសាស្ត្របារាំងវិញឃើញថាពុំទាន់ស្មើគ្នា នឹងពាក្យរបស់បារាំងមួយម៉ាត់ៗ ដែលអ្នករៀនត្រូវកត់ចំណាំឲ្យចាំថា ពាក្យនេះជាបុល្លិង្គ ឬជាឥត្ថីលិង្គនោះផងឡើយ ។

---

# ផ្នែកតំណាត់ដឹងប្រវត្តិការណ៍

## មហាសន្និបាតសមាគមមិត្តពុទ្ធិកវិទ្យាល័យលោក ទី ១១

លោក ក៊យ-ប៉ុក រៀបរៀង

កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ ១៩៦០ វេលាម៉ោង ១៦ នៅសា-លាបាលីរងត្រលក្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ ។ មានគេជួបជុំពុទ្ធបរិស័ទទាំងភេទបព្វជិត និងគ្រហស្ថចំនួនច្រើន ក្រោមបរិយាកាសយ៉ាងស្និទ្ធស្នាល ។

មានព្រះសង្ឃមានសម្ដេចព្រះសង្ឃនាយកគណៈមហានិកាយជាប្រធាន ព្រមទាំងភិក្ខុសាមណេរជាច្រើន ដែលយើងសុំអភ័យទោសដោយពុំអាចរាយព្រះនាមឲ្យអស់បាន ។

មានគ្រហស្ថមានលោក ក៊យ-លឹត តំណាងក្រសួង ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ និងលោក ក៊យ-ប៉ុក ប្រធានសមាគមមិត្តពុទ្ធិកមហាវិទ្យាល័យជាដើម និងអស់លោកមន្ត្រីធំតូច ឧបាសកឧបាសិកា ជាច្រើនទៀតដែលយើងសុំអភ័យទោស ដោយពុំបានរាយនាមឲ្យសព្វគ្រប់បាន ។

ម៉ោង ១៦ និង ៣០ នាទី មហាសន្និបាតក៏បានបើកសម័យឡើង ។

ដើមដំបូងលោកកើយ-ប៊ុក ចាប់ថ្លែងសុន្ទរកថាមួយរៀបរាប់អំពីស្ថានការណ៍សមាគមក្នុងឆ្នាំ ១៩៥៩ ដោយសង្ខេប ហើយនឹងបញ្ជាក់ នូវកិច្ចការជាសារប្រយោជន៍ ដែលសមាគមបានបំពេញមកហើយ និងជំហានមិត្តភាពខាងពុទ្ធសាសនានៅកម្ពុជរដ្ឋនឹងពុទ្ធសាសនានៅបរទេសផង ដែលគេបានទទួលស្គាល់សមាគមយើងពេញលក្ខណៈ ។

ទីបំផុតលោក កើយ-ប៊ុក អំពាវនាវដល់មហាសន្និបាតថា សូមឲ្យអស់លោក ជាពុទ្ធបរិស័ទមេត្តាជួយទំនុកបំរុងសមាគមនេះឲ្យបានរឹងជំហារឋិតថេរចិរកាលជាយូរអង្វែងតទៅអនាគត ។

លំដាប់ពីនោះលោកម៉ៅ-ម៊ី ក្នុងឋានៈជាអគ្គហេរញ្ញិកក៏ចាប់ថ្លែងរៀបរាប់ពីស្ថានភាពហិរញ្ញវត្ថុ របស់សមាគមក្នុងឆ្នាំ១៩៥៩ដូចតទៅនេះ ៖

១– ប្រាក់ចំណូលមានចំនួន ១០១.៨៩៦៛០០

២– ប្រាក់ចំណាយមានចំនួន ៦២.៣៦០៛០០

៣ ប្រាក់នៅសល់មានចំនួន ៣៩.៥៣៦៛០០ ក្នុងហិបសមាគមសព្វថ្ងៃ ។

ចប់សេចក្តីថ្លែងការណ៍ហើយលោក ម៉ៅ.ម៊ី ថ្លែងអំណរគុណចំពោះមហាសន្និបាត ។

លំដាប់តទៅទៀត មហាសន្និបាតបានរៀបចំពិធីបោះឆ្នោត រើស

គណៈកម្មាធិការ [illegible] ប្រចាំឆ្នាំ ១៩៦០ បានតាំងគណៈកម្មការ បោះឆ្នោតមួយ មានលោក កែប អ៊ុល អាចារ្យវត្តលង្កាជា ប្រធាន លោក ស៊ូ ស៊ុនន និងលោក ផៃ ទៀ ជាលេខាធិការ ។

តាមបញ្ជីឈ្មោះ [illegible] មានបេក្ខជន ២០ រូបឈរឈ្មោះសម្រាប់ឱ្យ ជ្រើសរើសយក ១៥ រូប ធ្វើជាគណៈកម្មាធិការ [illegible] សម្រាប់ឆ្នាំថ្មី ។

លទ្ធផលនៃការបោះឆ្នោត បានសម្រេចដូចតទៅនេះ ៖

១- អ្នកស្រី [illegible] បានឆ្នោត ៤៦
២- លោក [illegible] -ដ- ៤៣
៣- – [illegible] -ដ- ៤២
៤- – [illegible] -ដ- ៤២
៥- – [illegible] -ដ- ៤០
៦- – [illegible] -ដ- ៣៩
៧- អ្នកស្រី [illegible] -ដ- ៣៩
៨- លោក [illegible] -ដ- ៣៧
៩- អ្នកស្រី [illegible] -ដ- ៣៧
១០- លោក ផៃ-ទៀ -ដ- ៣៦
១១- – ស៊ូ-ស៊ុនន -ដ- ៣៥

១៦– – ទាយ.គុំ –ដ– ៣៤

១៧– – សៅ-វ៉ែន –ដ– ៣៤

១៨ លោកស្រី ម៉ៅញ.ធាត –ដ– ៣២

១៩– លោក ជា.ទន់ –ដ– ៣១

រួចហើយលោកប្រធានក៏បានប្រកាស ជម្រាបមហាសន្និបាតថា: បេក្ខជនទាំង ១៩ រូបខាងលើនេះ ដែលបានឆ្នោតច្រើនជាងគេ ត្រូវបានតែងតាំងជាគណ:កម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៦០ ។

បន្ទាប់ពីការប្រកាសលទ្ធផលមក សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណ:មហានិកាយ បាននិមន្តឡើងលើវេទិកាថ្លែងរៀបរាប់អំពីសមាគម ដែលគាត់ចងគ្នាទៅវិញទៅមកនៃសមាគមដូចគ្នា ព្រមទាំងប្រទានដំបូន្មានដល់អស់លោកសមាជិកសមាជិកា ហើយបានរៀបរាប់អំពីផ្លូវលោក និងផ្លូវធម៌ ដើម្បីជាគ្រឿងប្រតិបត្តិតទៅ ។ លុះចប់ហើយ សម្តេចប្រទានពរសព្ទសាធុការចំពោះអស់លោកដែលបានជាប់ឆ្នោតថ្មីនេះឲ្យបានប្រកបដោយសេចក្តីសុខចំរើនតទៅ ។

មហាសន្និបាតបានលើកពេលប្រជុំ នៅវេលាម៉ោង ១៨ ក្រោមបរិយាកាសយ៉ាងរីករាយបំផុត ។

# សុន្ទរកថា នៃលោកប្រធានសមាគម

សូមនមស្ការសម្តេច និងព្រះថេរានុត្ថេរៈទាំងឡាយ សូមជំរាបព្រះតេជគុណ លោក-អ្នក លោកស្រី អ្នកស្រីទាំងឡាយ ។

សមាគមមិត្តពុទ្ធិកវិទ្យាល័យ សូមថ្លែងនូវសេចក្តីសោមនស្សក្រៃពេកចំពោះសម្តេច ចំពោះព្រះថេរានុត្ថេរៈទាំងឡាយ និងព្រះតេជគុណលោក-អ្នក លោកស្រី-អ្នកស្រី ដែលបាននិមន្តបានអញ្ជើញមកកាន់មហាសន្និបាតនេះ ដើម្បីជាកិត្តិយសចំពោះសមាគមយើង សមាគមសូមសំដែងនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅ ហើយជាលំដាប់តទៅ សមាគមសូមពិតថ្លែងដល់សម្តេច ព្រះថេរានុត្ថេរៈទាំងឡាយ និងជំរាបអស់លោកអ្នកដូចតទៅ ៖

១ សមាគមបានព្យាយាមប្រមូលសិស្សានុសិស្ស និងមិត្តសាលាបាលីទាំងឡាយ ដែលមានប្រាថ្នាលើកដំកើងភាសា និងអក្សរជាតិ បាន ចំនួនសមាជិកដូចតទៅនេះ ៖

- កិត្តិយសសមាជិក ៨ នាក់
- ជនក — ៨ នាក់
- ឧបការី — ៥ នាក់
- ទាយក — ៥២ នាក់

- កម្មិក សមាជិក ៦០៥ នាក់
- បាសាទិក - ៨២៧ នាក់

បូករួម ១.៥៤០ នាក់ ឆ្នាំ ១៩៥៩

ក្នុងឆ្នាំ ១៩៥៨ មានចំនួន ១ ៤៥២ នាក់ ឃើញកើនជាងឆ្នាំ ចាស់ ៨៨ នាក់ ។

២– បានឧបត្ថម្ភអ្នកសិក្សាភាសាបាលីទីនការសាជាតិ ដោយសក្ការៈ ទីនសីលធម៌ គឺ

កាលពីថ្ងៃទី ១៦-១៧ ឧសភា ១៩៥៩ សមាគមបានធ្វើពិធីបុណ្យព្រហ្មទានចែករង្វាន់ដល់សមណសិស្សពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ចំនួន ៤៥ រូប ដែលទើបនិមន្តទៅបន្តការសិក្សានៅគ្រឹស្ថាននេះ ជាលើកដំបូងបង្អស់ ដើម្បីញុំាងទឹកព្រះទ័យលោកឱ្យខំព្យាយាមសិក្សាត-ទៅទៀត ។

៣ - បានបង្កើតឱ្យមានការបោះពុម្ពទស្សនាវដ្ដី និងសៀវភៅផ្សេងៗ ដើម្បីពង្រីកអក្សរសាស្ត្រខ្មែរ ។

ចំពោះបញ្ហាទស្សនាវដ្ដីនេះ សមាគមបម្រុងនឹងបោះពុម្ពនៅថ្ងៃក្រោយជាមិនខាន តែក្នុងឆ្នាំ ១៩៥៩ នេះ បានជាខានព្រោះសមាគមមានថវិកាទន់ខ្សោយ ។

៤- បានបង្កើតឲ្យមានបណ្ណាល័យសម្រាប់សមាគម បណ្ណាល័យនេះបានចំរើនតាមលំដាប់រៀងរាល់ឆ្នាំដោយមានអ្នកសប្បុរសធ្វើអំណោយសៀវភៅជាច្រើន ។

៥- បានសង្គ្រោះដល់លោក-អ្នកមានប្រាជ្ញាវាងវៃឲ្យទៅបេញសិក្សានៅប្រទេសក្រៅ ។

សមាគមបានបម្រុងនឹងចញ្ចូនកង ពលផាច់-ផាប់នេះ ឆ្ពោះព្រះមហាស៊ីន សារៀម វត្តលក្ក ដោយសាហាវឫកពោកនៃរដ្ឋាភិបាលប្រទេសដណ្ហៀ ។ ះបុគ្គលភាពនៃព្រះមហាក្សត្រនេះបានទទួលសេចក្ដីយល់ព្រមពីមន្ត្រីស្ដីការនាយករដ្ឋមន្ត្រី នឹងព្រះរាជានុញ្ញាត នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ហើយនៅតែកំណត់កាលបរិច្ឆេទនឹងនិមន្តទៅ ។

៦-កាលពីថ្ងៃទី ៤-៥ មេសា ១៩៥៩ សមាគមបានរួបរួមជាមួយពុទ្ធិកសមាគមកម្ពុជរដ្ឋ បានធ្វើទក្ខិណានុប្បទានដាក់ថ្វាយ ព្រះសង្ឃ ថ្វាយព្រះរាជកុសលព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះឧបយុវរាជ ដោយពេលនោះ សម្ដេចព្រះឧបយុវរាជទ្រង់កំពុងមានព្រះអាពាធបានស្ដេចយាងទៅប្រទេសបារាំង ដើម្បីព្យាបាលរោគព្រះអង្គ ។

៧-កាលពីថ្ងៃទី ១៩ ធ្នូ ១៩៥៩ សមាគមមិត្តពុទ្ធិកវិទ្យាល័យបានធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសលចំពោះវិញ្ញាណក្ខន្ធ ព្រះសពព្រះ

តេជគុណព្រះមុនីកោសល សោម-ឈុន វិមលបញ្ញោ អធិបតីនៃក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ មេគុណខេត្តកណ្ដាល ចៅអធិការវត្តនិរោធរង្សី ដែលទទួលអនិច្ចធម្មពីថ្ងៃអង្គារ ទី ៦ តុលា ១៩៥៩ ដោយព្រះតេជព្រះគុណអង្គនេះ លោកជាបុព្វការីចំពោះសមាគមយើង ។

៨- សមាគមបានធ្វើការប្រស្រ័យទាក់ទងនឹងស្ថានឯកអគ្គរាជទូតប្រទេសឥណ្ឌា ប្រចាំក្រុងកម្ពុជា ដើម្បីសុំអាហារូបករណ៍ចំពោះសមណនិស្សិតដែលនិមន្តទៅសិក្សាឯមហាវិទ្យាល័យនាលន្ទា ខេត្តបត្នៈប្រទេសឥណ្ឌា គឺព្រះមហា ភាំ-យ៉ាវ ១ ព្រះមហាប៉ែន-សាអឿន និងព្រះមហាអ៊ុក-អ៊ឹន ក្នុងឆ្នាំ ១៩៦០-៦១ ។

៩-សមាគមបានធ្វើការប្រស្រ័យទាក់ទងនឹងក្រុមមូលនិធិអាស៊ី ដើម្បីឲ្យក្រុមនេះជួយឧបត្ថម្ភអាហារូបករណ៍ ចំពោះសមណនិស្សិត អាំ-សួន និងមាស-ចន ដែលនិមន្តទៅសិក្សាឯមហាវិទ្យាល័យពារាណសី-ប្រទេសឥណ្ឌា ក្នុងឆ្នាំ ១៩៦០-៦១ ។

ម្យ៉ាងទៀត ក្រុមមូលនិធិអាស៊ីបានសន្យាថា ក្នុងឆ្នាំ១៩៦០នេះ នឹងធ្វើអំណោយចំពោះសមាគម នូវម៉ាស៊ីនអង្គុលីលេខភាសាបារាំង មួយគ្រឿងទុកសម្រាប់ប្រើប្រាស់ក្នុងការិយាល័យសមាគម ។

នេះជាលទ្ធផលដែលក្រុមអភិបាលនៃសមាគមបានព្យាយាមបំពេញករណីយកិច្ចសព្វគ្រប់ក្នុងឆ្នាំ១៩៦០ ខ្ញុំសូមសរសើរចំពោះសមាជិកក្រុម

អភិបាលថា ព្រះតេជគុណ-លោកអ្នក-លោកស្រី-អ្នកស្រីបានព្យាយាមធ្វើតាមមុខការរៀងៗខ្លួន ជាយ៉ាងម៉ឺនម៉ាត់គ្រប់ៗគ្នា ។ សមាគមដែលនឹងអាចចំរើនទៅបាន មកពីសមាជិកនៃក្រុមអភិបាលខំស្វាហ៍អញ្ជើញមកប្រជុំដើម្បីទឹងប្តូរយោបល់គ្នា ។ ម្យ៉ាងវិញទៀត សូមជំរាបថា សមាជិកនៃសមាគមទាំងមូលត្រូវធ្វើកិច្ចជាប្រយោជន៍សមាគមគ្រប់គ្នា ព្រោះមនុស្សម្នាក់ធ្វើការមិនមានអានុភាពស្មើនឹងសមាគម ដែលធ្វើការដោយសាមគ្គីធម៌នោះទេ, ឯសមាគមបើចេះរៀបចំអង្គការឲ្យបានស្រួលនឹងបានឡើងទៅកាន់វឌ្ឍនធម៌ដោយឆាប់រហ័សមិនខាន ។

បើពិចារណាឲ្យហ្មត់ចត់ទៅទៀត សមាគមយើងមានវត្ថុធាតុពីរបែប

១– ក្រុមអភិបាល,

២– សមាជិក សមាជិកាសមាគម ។

ក្រុមអភិបាលដែលនឹងធ្វើឲ្យចំរើនសមាគមបានលុះតែក្រុមនោះមាន :

ក– កម្មវិធី សកម្មភាព ហើយត្រូវប្រព្រឹត្តប្រតិបត្តិឲ្យបានសម្រេចនូវលទ្ធផលដ៏ប្រសើរនៃកម្មវិធីនោះ ៗ ។

ខ– ត្រូវប្រព្រឹត្តតាមមុខការរៀងៗខ្លួន ហើយញ៉ាំងសកម្មភាពឲ្យមានឡើងចំពោះកិច្ចការនោះ ៗ ។

គ– ត្រូវខំស្វាហ៍មកប្រជុំរឿយៗ ដោយសេចក្តីអញ្ជើញពីប្រធាន

សមាគម ។

ឃ- ត្រូវរិះរកនូវមធ្យោបាយដែលប្រព្រឹត្តទៅ ហើយចេតនាសមាគមឲ្យមានវឌ្ឍនធម៌តទៅ ។

ង- ត្រូវពន្យល់បំភ្លឺញាតិមិត្តឲ្យយល់ជាក់ច្បាស់ថា ការចូលមកជាសមាជិកនៃសមាគមជាការប្រសើរ ព្រោះថា កិច្ចធ្វើការដោយគ្នាច្រើន ហើយព្យាយាមធ្វើដោយសាមគ្គីធម៌ តែងបានផលប្រយោជន៍ជាងអ្នកដែលធ្វើការម្នាក់ៗ បើការនោះធ្វើដោយសេចក្តីពេញចិត្ត ដោយគិតតែប្រយោជន៍សមាគមយ៉ាងផងទៀត នោះរឹតតែគាប់ប្រសើរ ។

២- សមាជិក-សមាជិកានៃសមាគម

សមាជិក-សមាជិកា នៃសមាគមត្រូវទុកសមាគមនេះដូចជាគ្រួសារ ហើយត្រូវទុកសមាជិក-សមាជិកាទាំងឡាយ ជាបងប្អូនរួមសាច់ឈាម ជាមួយគ្នា ការសុខទុក្ខបងប្អូនក្នុងគ្រួសារ ត្រូវជួយឧបត្ថម្ភគ្នាទៅវិញទៅមកដោយការគោរព មិត្តភាព សាមគ្គីធម៌យ៉ាងណាមិញ សមាជិក-សមាជិកាក៏ដូច្នោះដែរ ។ សមាជិក-សមាជិកា ទាំងអស់នៃសមាគមត្រូវប្រមូលជាពួក ជាក្រុមធ្វើកិច្ចការអ្វីមួយជាប្រយោជន៍សមាគមមានការស្វែងរកសមាជិកថ្មី ១ ការបោះពុម្ពទស្សនាវដ្តីជាសំឡេងសមាគម ១ ការចូលមកក្នុងក្រុមឃោសនា ១ ការធ្វើអ្វីមួយជាប្រយោជន៍ពុទ្ធសាសនា ១ ។ល។

ការរំលឹកដាស់តឿនមហាសន្និបាតមកប៉ុណ្ណេះ ដើម្បីជាគតិទុកសម្រាប់ឲ្យមហាសន្និបាត យកសេចក្ដីនេះទៅពិចារណាសាកសួរដេញដោលឲ្យអស់សង្ស័យ ដើម្បីនឹងរិះរកនូវមធ្យោបាយផ្សេងៗ ដើម្បីជាប្រយោជន៍ដល់សមាគមយើងតទៅអនាគត ។

អវសាន ខ្ញុំសូមឧទ្ទិសកុសលរាសីដែលសមាគមធ្វើតាំងពីឆ្នាំ១៩៤៩ មក ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្ដេចព្រះមហាក្សត្រិយានី និងសម្ដេចព្រះឧបយុវរាជ សូមព្រះអង្គគង់ជាសុខក្នុងសិរីរាជសម្បត្តិអស់កាលជាអង្វែងតទៅ ។

សូមឲ្យពុទ្ធមាមកជនទាំងឡាយ ទាំងបុរស-ស្រី-ទាំងបព្វជិត-គ្រហស្ថ បានប្រកបដោយសិរីសួស្ដីជ័យមង្គលទាំងឡាយគ្រប់ប្រការ !

សូមឲ្យសមាគមចម្រើនស្ថិតស្ថេរចរកាលតទៅអនាគត !

## សមាសភាពនៃគណៈកម្មាធិការនាយកថ្មីសម្រាប់ឆ្នាំ១៩៦០

១- លោក ក៉យ-បុក ប្រធាន

២- លោក អ៊ឹង-ទួន អនុប្រធានទី ១

៣- លោកស្រី តូច-ស្អាត អនុប្រធានទី ២

៤- លោក ហ៊ៅ-ម៉ី អគ្គហេរញ្ញិក

៥- លោក ចឹង-ហារិត លេខាធិការ

៦- លោក ស្វរ-ស៊ុផន អនុហោរញ្ញិក

៧- លោក សៅ-វ៉ែន - - - - -

៨- លោក ផៃ.វង្ស អនុលេខាធិការ

៩- លោក ហង្ស-ចេត - - - - -

១០- លោក ជា-ខន់ បណ្ណារក្ស

១១- លោក មាឃ-គុំ . . . .

១២- លោក ផេង.ជ្រីវ ស្នងការ

១៣- លោកស្រី សម-ណៃ . . . .

១៤- លោកស្រី ព៉យ-ប៊ុក . . . .

១៥- លោកស្រី ម៉ៅញ-ធាត . . . .

---

---

អតិឃ្មី ស្រី. កិរិយាក្មេច ។

អតិបត្ថុរ គុ. ដែលលឿនក្រៃលែង ។

អតិបរី ផ គុ. ប្រព្រឹត្តក្រៃពេក, ប្រព្រឹត្តកន្លង ។

អតិបាបល្យ នបុំ កិរិយាក្រឡប់ក្រឡិន, កិរិយាឡេះឡោះ ។

អតិបិត្រម ក្រិ. វិ. ដោយវិចិត្រផ្សេង ៗ ។

អតិបិរ គុ. ដែលយូរក្រៃលែង ។ *អតិចិរស្យ* ឬ *អតិចិរម៍* ក្រិ វិ. អស់កាលយូរណាស់ហើយ ។

អតិបេក្ត៌ ណគុ. ប្រឹងប្រែងក្រៃលែង ។

អតិប្រន្ធ ពុំ. ចិត្តស្រាល, ចិត្តរហស់; សេចក្ដីប្រាជ្ញាក្រៃពេក ។

អតិប្រន្ធស៍ គុ. ដែលមានឆន្ទក្រៃលែង ។ នបុំ. ស្រី. ឈ្មោះរង្វាស់ ។

អតិប្រេទ ពុំ. ការមុតក្រៃពេក, ការផ្ដិលផ្ដាច់ ។

អតិប្រេទ្យ គុ. ដែលគប្បីមុតក្រៃពេក ។

អតិជគតី ស្រី. ឈ្មោះរង្វាស់ ។

អតិជន គុ. ដែលឥតមានមនុស្ស ។

(នៅមានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣២ លេខ ៥ ខែឧសភា

ព.ស. ២៥០៣ គ.ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|


- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . ៤៨៣
- ព្រះអភិធម្មបិដក (គម្ពីរបុគ្គលបញ្ញត្តិ) (តមក) លោក ប៊ូ-ប៊ូ រៀបរៀង . ៤៩៤
- មធុរសវាហិណី (តមក) សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ . . . . . ៥១២
- មហោសថជាតក (តមក) លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-ត្លារ ពិនិត្យ . . . . . . . . . ៥២៥

ផ្នែកអក្សរសាស្ត្រ

- រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . ៥៣៣
- រឿងព្រេងវត្តបញ្ញាជី លោក មាស-ហាំ រៀបរៀង . . . . ៥៥៣
- រឿងព្រេងរុស្ស៊ី ភិក្ខុ ម៉ែន-រៀម ប្រែពីភាសាអង់គ្លេស . . ៥៥៩
- រឿងសាមកុក (តមក) ទាកញ៉ា ទូ-កន ប្រែ . . . . . ៥៦៨
- ពាក្យវិញ្ញធម៌ លោក តាង-ហ៊ួ រៀបរៀង លោក សម-ប៉ាង ពិនិត្យ ៥៨០

ផ្នែកកំណត់ទំនិប្រវត្តិការណ៍

- បុណ្យឆ្លងស្ដារព្រះសក្យមុនីចេតិយ លោក ចិង វិង រៀបរៀង . . ៥៨៩
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . ៥៩៨



មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជាវ ២៣០៛០០

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
Publiée par l'Institut Bouddhique de Phnom Penh


## sommaire

### Partie religieuse :


— La Vie du Buddha (suite) par Prah maha PANG-KHAT . . . 483

— Prah Abhidhammapitaka (Puggalappannatti) (suite) par M. BOU-PO 494

— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM, revu et corrigé par Vén-NHEAN CHHOEUN . . . . . . . . . . . . . 512

— Prah Mahesothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu par Vén-KEM-TO 525


### Partie littéraire :


— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . 533

— Légende de Vat Panha chi par M. MEAS-HAM (d'après le document de la Commission des Moeurs et Coutumes . . . 553

— Contes et Légendes russes traduits de l'anglais par le bonze MEN-RIEM . . . . . . 559

— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 568

— Activités de la Commission culturelle par M NEANG HOU revues par M SAM THANG. . . . 580


### Notes et Chroniques :


— Cérémonie «Namaskar Preah Sakyamunichedy» célébrée à Phnom-Penh, par M. THANG-VONG . . . . 589

— Dictionnaire Sanscrit-khmer (suite) par Vén-PANG-KHAT 598



Prix d'abonnement annuel (comprenant 12 numéros): 230$00 .

**ផ្នែកសាសនា**

# ពុទ្ធជីវប្បវត្តិ

(តមក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

## ទូរេនិទាន តុសិតកថា ទី ១

១-សុមេធពោធិសត្វ ២-សុមេធពោធិសត្វវៀរណាយចាកកាម ៣ សុមេធពោធិសត្វបានពុទ្ធព្យាករណ៍ ៤ សន្តុសិតទេវបុត្រប្រមើលមហាវិលោកនៈទាំង៥ប្រការ ៥-សេចក្តីអស្ចារ្យចំឡែក ។

## ១-សុមេធពោធិសត្វ

ក្នុងអតីតកាលយូរលង់ណាស់ហើយ ប្រមាណជា៤អសំខេយ្យកំរៃមួយសែនកល្បអំពីភទ្រកល្បនេះ ក្នុងកាលនោះ ព្រះបរមសាស្តាចារ្យនៃយើងទាំងឡាយ ស្តេចយោនយកកំណើតជាសុមេធកុមារ ក្នុងត្រកូលសេដ្ឋីមាត់ជំស្តុកស្តុកក្នុងអមរវតីនគរពេជជាន ក្នុងសាសនកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមទីបង្ករ ។ លុះអំណើះតន្តពីមាតាបិតាទៅ សុមេធកុមារកំពុងស្ថិតនៅក្នុងវ័យក្មេង, ពួកអ្នកកាន់បញ្ជីថ្លែងប្រាប់ចំនួនមត៌កទាំងពីរចំណែកទាំងខាងមាតាបិតារាប់តាំងពីជីដូនជីតា៧ជួរគោត្រមក ។ សុមេធកុមារភ្ញាក់ស្តាប់ហើយគិតថា «មាតាបិតាជីដូនជីតាអាត្មាអញទំប្រឹងប្រែង

ប្រមូលទ្រព្យសម្បត្តិគរទុក ឥឡូវធ្វើដំណើរទៅកាន់បរលោកអស់ហើយ សូម្បីតែមួយកហាបណៈក៏យកទៅមិនបាន បើដូច្នេះគួរតែអាត្មាអញយកទ្រព្យសម្បត្តិនេះទៅជាមួយទើបគួរ" ។ សុមេធកុមារគិតហើយក៏បង្គាប់អ្នកបំរើឲ្យទៅក្រាបទូលព្រះរាជា សូមឲ្យទ្រង់ត្រាស់បង្គាប់ឲ្យប៉ាវគងជូនគេ ប្រាប់អ្នកនគរឲ្យមកទទួលយកទាន, ហើយសុមេធកុមារដាក់ទ្រព្យសម្បត្តិជាទានទាល់តែអស់រលីងគ្មានសល់អ្វីបន្តិច ។

## ២-សុមេធពោធិសត្វនឿយណាយចាកកាម

ថ្ងៃមួយ សុមេធកុមារឡើងទៅលើប្រាសាទជាន់ខ្ពស់ ជាទីរហោឋានចាកកាមារម្មណ៍ គង់ក្នុងពេលបាតទូន្មានខ្លួនថា "នែបណ្ឌិត ! ការកើតក្នុងភពថ្មីទៀតមានទៀត !, ការកើតនេះ ជាផ្លូវបង្ហូរមកនូវសេចក្តីទុក្ខ ការកើតស្លាប់នេះសុទ្ធតែជាសេចក្តីទុក្ខទាំងអស់, ខ្លួនអាត្មាអញមានភ្លើងគឺជាតិជរា ព្យាធិ មរណៈជាធម្មតា, គួរតែអាត្មាអញនឹងស្វែងរកអមតនិព្វានជាទីសុខត្រជាក់ត្រជុំក្សេមក្សាន្តទើបគួរ , ធ្វើដូច្នេះ ទើបខ្លួនអាត្មាអញនឹងរួចស្រឡះចាកភពជាបេពិត ។

សុមេធកុមារពិចារណាតទៅទៀតថា "ក្នុងលោកនេះ មានសេចក្តីសុខជាបដិបក្ខនឹងសេចក្តីទុក្ខ, បើភពមានព្រះនិព្វានដែលជាបដិបក្ខនឹងភពក៏មាន, បើក្តៅមានត្រជាក់សម្រាប់រំលត់ក្តៅក៏មាន ព្រះនិព្វានជាធម៌សម្រាប់រំលត់ភ្លើងកិលេសមានរាគៈជាដើមក៏មាន, កល្យាណធម៌ដែលមិនមានទោស

ជាបដិបក្ខនឹងអកុសលធម៌ ជាធម៌លាមកក៏មាន, បើជាតិមាន ព្រះនិព្វាន ដែលជាធម៌មិនមានជាតិ សម្រាប់ផ្តាច់ផ្តិលជាតិកំណើតឲ្យអស់ក៏មាន ។

សុមេធកុមារ ប្រៀបធៀបខ្លួនទ្រង់លោកតទៅទៀតថា «បើមានបុរសម្នាក់ធ្លាក់ក្នុងរណ្ដៅគូថ, បុរសនោះមើលអំពីចម្ងាយឃើញមានស្រះមួយធំប្រកបដោយទឹកបរិបូណ៌ថ្លាឈ្វង គួរគប្បីគិតថា អាត្មាអញទៅកាន់ស្រះនេះ ដើម្បីដុសជម្រះលាងកាយឲ្យជ្រះមន្ទិលសៅហ្មង បើមិនគិតទៅស្រះនោះដើម្បីដុសជម្រះលាងកាយខ្លួនទេ នេះមិនមែនជាទោសស្រះទេ ជាទោសបុរសទេតើ មានឧបមាយ៉ាងណា? មានឧបមេយ្យដូចជានិព្វានដែលជាគុណជាតសម្រាប់ដុសជម្រះលាងនូវមន្ទិលគឺកិលេស បុរសប្រកបដោយគ្រាក់គឺកិលេស បើមិនចេញទៅស្វែងរកមហាស្រះគឺព្រះអមតមហានិព្វាននោះដើម្បីដុសលាងមន្ទិលក្នុងសន្តានខ្លួនទេ នេះមិនមែនជាទោសព្រះនិព្វានទេ ជាទោសបុរសទេតើ ។

បុរសម្នាក់ មានចោរឡោមព័ទ្ធ ផ្លូវសម្រាប់គេចរត់ចេញបានមានដែរ, បើបុរសនោះមិនគេចរត់ចេញទៅតាមផ្លូវនោះទេ នេះមិនមែនជាទោសផ្លូវទេ ជាទោសបុរសទេតើ មានឧបមាយ៉ាងណា? មានឧបមេយ្យដូចជាបុរស ដែលចោរគឺកិលេសឡោមព័ទ្ធហើយ ផ្លូវដ៏ក្សេមក្សាន្ត ជាផ្លូវសម្រាប់ដើរទៅកាន់ព្រះនិព្វានក៏មានដែរ ហើយបុរសនោះ មិនដើរទៅតាមផ្លូវក្សេមក្សាន្តគឺព្រះនិព្វាននោះទេ នេះមិនមែនជា

ទោសផ្លូវទេ ជាទោសបុរសទេតើ ។

បុរសម្នាក់ មានជម្ងឺបៀតបៀន ពេទ្យជាអ្នកថែរក្សាជម្ងឺក៏មាន។ បើបុរសនោះ មិនទៅរកពេទ្យនោះឲ្យគេថែរក្សាជម្ងឺខ្លួនទេ នេះមិនមែនជាទោសពេទ្យទេ ជាទោសបុរសទេតើ មានឧបមាយ៉ាងណា? មានឧបមេយ្យដូចជាបុរស ដែលមានជម្ងឺគឺកិលេសបៀតបៀន បើមិនស្វែងរកអាចារ្យដែលជាអ្នកឆ្លៀវឆ្លាស ក្នុងការរម្ងាប់នូវជម្ងឺគឺកិលេសទេ នេះមិនមែនជាទោសអាចារ្យទេ ជាទោសបុរសទេតើ ។

បុរសម្នាក់ ជាអ្នកធ្លាប់ស្អិតស្អាងខ្លួនយ៉ាងស្អាត តែមានសាកសពគំរង់មួយនៅជាប់លើក ក៏ផ្តាច់សាកសពនោះបោះចោលទៅ ហើយដើរចេញទៅយ៉ាងសុខស្រួល មានឧបមាយ៉ាងណា? មានឧបមេយ្យដូចអាត្មាអញនេះ គួរតែបោះចោលរូបពងកាយស្អុយនេះចេញ ហើយដើរចូលទៅកាន់ព្រះនិព្វានដោយឥតមានអាឡោះអាល័យទើបប្រសើរ ។

នរប្រុសស្រី តែងបន្ទោរបង់ឧច្ចារបស្សាវៈចោលក្នុងបង្គន់ មិនដកយកឧច្ចារបស្សាវៈក្នុងថ្លក់ហើយយកមកវិញទេ ជាអ្នកខ្ពើមរអើម លះបង់ចោលឥតអាឡោះអាល័យ ហើយដើរចេញទៅ មានឧបមាយ៉ាងណា? មានឧបមេយ្យដូចជាអាត្មាអញនេះ គួរតែលះបង់ចោលរូបពងកាយស្អុយ ហើយដើរចេញទៅកាន់អមតនិព្វានទើបគួរ ។

នាយសំពៅលះបង់ចោលសំពៅចាស់ជាក មិនខ្វីអាឡោះអាល័យ

ហើយដើរចេញទៅ មានឧបមាយ៉ាងណា មានឧបមេយ្យដូចជាអាត្មាអញនេះ គួរតែបោលរូបកាយដែលមានទុក្ខដ៏ចៅ ៩ ឥតអាឡោះអាល័យ ហើយដើរសំដៅទៅកាន់ព្រះនិព្វានទើបប្រសើរ ។

បុរសម្នាក់ កាន់យករតនៈច្រើនប្រការ ដើរតាមផ្លូវទៅជាមួយនឹងពួកចោរ គេបរត់ចោលពួកចោរទាំងឡាយនោះ ដោយខ្លាចវិនាសអន្តរាយទ្រព្យខ្លួន ហើយដើរទៅកាន់ផ្លូវមួយដ៏ក្សេមក្សាន្ត មានឧបមាយ៉ាងណា មានឧបមេយ្យដូចជាករជកាយអាត្មាអញនេះ ប្រាកដដូចជាចោរជាអ្នកចាំប្លន់រតនៈផ្សេង ១ ជាបើអាត្មាអញស្រឡាញ់ករជកាយជាចោរនេះ រតនៈគឺអរិយមគ្គជាកុសលធម៌នឹងវិនាសបាត់បង់ទៅ ព្រោះហេតុនោះអាត្មាអញគួរលះបង់កាយដែលប្រាកដដូចជាចោរនេះ ហើយដើរទៅស្វែងរកព្រះនិព្វានវិញទើបគួរ " ។

លុះសុមេធកុមារ ពិចារណាឃើញទោសនៃវត្ថុសង្ខារដូច្នេះហើយក៏កើតសេចក្តីអាក្នុងសន្តាន ទើបណាយក្នុងកិរិយាគ្រប់គ្រងគេហដ្ឋានលះបង់គំនរទ្រព្យសម្បត្តិដាក់ទៅជាទាន ដល់ស្មូមយាចកអ្នកកំសត់ទុគ៌តដូចបានពណ៌នាមកហើយ ចេញអំពីអមរវតីមហានគរតែមួយព្រះអង្គឯងដើរសំដៅទៅកាន់ខេត្រទ័ណ្ឌហេមពាន្ត លះបង់ការស្លៀកពាក់សំពត់ដែលប្រកបដោយទោសគ្រប់ប្រការវ័ណ្ឌសំបកឈើព្រៃឥតគេប្រាថ្នាហើយបួសជាតាបសឥសី ចំប្រើនវិធីឃ្មាតសាងព្រតព្រឹត្តបំពេញព្រហ្មចរិយធម៌

មិនយូរប៉ុន្មានក៏បានឈានសមាបត្តិ ហោះហើរដើរលើអាកាសបាន ។

## ៣–សុមេធពោធិសត្វបានពុទ្ធព្យាករណ៍

ថ្ងៃមួយ, ពួកមហាជនកំពុងតាក់តែងផ្លូវធ្វើជាថ្នល់ថ្វាយព្រះពុទ្ធទីបង្ករ សុមេធតាបសហោះតាមអាកាសវេហាស៍ឃើញដូច្នោះ ក៏ទៅសូមភូមិភាគមួយកន្លែងចាត់ចែងថ្វាយនឹងគេផង, គាប់ចួនពេលនោះ តាបសរៀបចំមិនទាន់ហើយស្រេច នៅមានទីខ្វះ ប្រកបដោយភក់ល្បាប់នៅឡើយ ទទួលតាំងពុទ្ធអង្គ ព្រមទាំងព្រះខីណាស្រព៤សែនអង្គធ្វើដំណើរមកដល់ ទើបយកស្បែកខ្លាឃ្មុំដែលជាទង់ជ័យតាបស មកក្រាលពីលើភក់ល្បាប់ ព្រាលពីលើធ្វើជាស្ពានថ្វាយ ហើយក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស! ស្តេចកុំជាន់លើភក់ឡើយ សូមទ្រង់ពុទ្ធដំណើរលើខ្នងខ្ញុំព្រះអង្គតាងស្ពាន ព្រមទាំងភិក្ខុសង្ឃជាបរិវារប្រមាណ៤សែនអង្គចុះ"។ ព្រះពុទ្ធទីបង្ករទ្រង់ទតព្រះនេត្រឃើញសេចក្តីអស្ចារ្យដូច្នេះ ទើបទ្រង់ពុទ្ធព្យាករណ៍ថា «តាបសនេះ មិនខ្សត់ខ្សោយទេ, តទៅអនាគតកំណត់៤អសង្ខេយ្យកំរៃ ១ សែនកប្ប នឹងបានជាព្រះពុទ្ធង្កុរបណ្ឌិតសពេជ្ញ បានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គក្នុងលោក ព្រះនាមសមណគោតម ព្រះវរបិតាទ្រង់ព្រះនាមសុទ្ធោទនៈ ព្រះវរមាតាទ្រង់

ព្រះនាមមហាមាយា នៅក្នុងនគរឈ្មោះ កបិលព័ស្តុ ។ ចំណែកមក. ព្រះបរមពោធិសត្វស្តេចអន្ទោលទៅមកក្នុងសង្សារវដ្ត ទ្រង់បានពុទ្ធព្យាករណ៍អំពីព្រះពុទ្ធ២៣ព្រះអង្គថែមទៀតគឺ ព្រះកោណ្ឌញ្ញៈ, សុមង្គលៈ, សុមនៈ, រេវតៈ, សោភិតៈ, អនោមទស្សី បទុមៈ, នារទៈ, បទុមុត្តរៈ, សុមេធៈ, សុជាតៈ, បិយទស្សី, អត្ថទស្សី, ធម្មទស្សី, សិទ្ធត្ថ. តិស្សៈ, ពុស្សៈ,[១] វិបស្សី, សិខី, វេស្សភូ, កកុសន្ធៈ កោនាគមនៈ កស្សបៈ ។ លំដាប់តមក, ព្រះពោធិសត្វទ្រង់ខំសន្សំបំពេញពុទ្ធការកធម៌៣០[២]ប្រការឲ្យពាស់ក្លា រៀងរាបជាបមកគ្រប់ជាតិ ទើបយកព្រះកំណើតជាវេស្សន្តរពោធិសត្វនៅក្នុងជេតុត្តរនគរ, ទ្រង់បានបំពេញមហាបរិច្ចាគទាំង៥ប្រការ មានប្រទាននាងមទ្រីនិងនាងកណ្ហាជាលីជាដើម ជាទានអស្ចារ្យចំឡែក អាចញុំាងផែនពសុធាឲ្យកំរើកញាប់ញ័រអស់វារៈ៧ដង, ស្តេចទ្រង់ឋិតជាសុខក្សេមក្សាន្តក្នុងរាជសម្បត្តិ ដរាបដល់អស់ព្រះជន្មាយុ ទើបស្តេចទិវង្គតទៅកើតក្នុងឋានឈ្មោះតុសិតមាននាមថា សន្តុសិតទេវបុត្រ ។

## ៤-សន្តុសិតទេវបុត្រប្រមើលមហាវិលោកនៈទាំង៥ប្រការ

សន្តុសិតទេវបុត្ត ស្តេចសោយទិព្វសម្បត្តិក្នុងទេវលោក ប្រកប

---

១- គម្ពីរខ្លះថា ផុស្សៈ ។ ២- បារមី១០ប្រការ ។

ដោយសេចក្តីសុខរៀងរហូតមក លុះដល់បារមីចាស់ក្លាទើបបានត្រាស់ជាព្រះពុទ្ធ កាលនោះ ពួកទេវតានិករសែនកោដិចក្រវាឡ មានស្តេចអមរិន្ទ្រាធិរាជជាប្រធាន ចូលមកកាន់ទីសោភាសក្នុងតុសិតទេវលោក ក្រាបទូលអារាធនាសន្តុសិតទេវបុត្ត ឲ្យស្តេចច្យុតមកចាប់បដិសន្ធិក្នុងឧទរព្រះមាតាក្នុងមនុស្សលោក ដោយសុភាសិតថា "បពិត្រព្រះមហាវីរៈ! កាលនេះជាកាលគួរទ្រង់ត្រាស់ជាព្រះពុទ្ធហើយ សូមអញ្ជើញស្តេចច្យុតទៅឧប្បត្តិក្នុងមនុស្សលោក ទើបបានត្រាស់ដឹងនូវអមតនិព្វានក្នុងគ្រានេះ ដើម្បីញ៉ាំងសត្វនិករឲ្យឆ្លងផុតសង្សារ" ។

លំដាប់នោះ ព្រះបរមពោធិសត្វទ្រង់សណ្តាប់ពាក្យអារាធនាហើយ ទ្រង់ព្រះតម្រិះថាគួរអាត្មាអញត្រាស់សព្វញ្ញុតញ្ញាណប្រោសវេនេយ្យសត្វក្នុងកាលឥឡូវនេះ ទើបទ្រង់ប្រមើលមើលមហាវិលោកនៈទាំង៥ប្រការគឺ:

១– កាលៈ កាលគួរទើបត្រាស់ដឹងគឺបើសត្វលោកមានអាយុច្រើនជាងមួយសែនឆ្នាំឡើងទៅ នេះមិនមែនជាកាលគួរ ព្រោះសត្វលោកមិនអាចកំណត់សំគាល់នូវសាមញ្ញលក្ខណៈបាន ព្រះធម៌មិនមានប្រយោជន៍ធំទូលាយ ធម្មាភិសម័យមិនកើតឡើងបាន ព្រះធម៌មិនមែនជានិយ្យានិកធម៌ ,បើសត្វលោកមានអាយុតិចជាង១០០ឆ្នាំចុះមកនេះក៏មិនមែនជាកាលគួរដែរ ព្រោះសត្វលោកមានកិលេសក្រាស់ ល្អក់ទៅក្នុងកាម មិនអាចតាំងនៅ

ក្នុងពុទ្ធសាសនាបាន ។ បើសត្វលោកមានអាយុយ៉ាងច្រើនត្រឹមមួយសែនឆ្នាំ យ៉ាងតិចចុះមកត្រឹម១០០ឆ្នាំនេះ ទើបជាកាលគួរ ព្រោះសត្វលោកមានសន្តានចិត្តល្អបរិសុទ្ធអាចដឹកនាំទៅក្នុងផ្លូវរបស់ព្រះពុទ្ធបាន ។

២– ទីបៈ ទ្វីបមាន៤គឺៈ បុព្វវិទេហទ្វីប១, ជម្ពូទ្វីប១, អមរគោយានទ្វីប(១)១, ឧត្តរកុរុទ្វីប១ បណ្តាទ្វីបទាំង៤នោះ ព្រះពុទ្ធជាម្ចាស់ពល់ព្រះអង្គទ្រង់មិនឧប្បត្តិកើតក្នុងទ្វីប៣ កើតតែក្នុងជម្ពូទ្វីបនៃមណ្ឌលចក្រវាឡតែមួយប៉ុណ្ណោះ តាមធម្មតា ទ្រង់មិនដែលឧប្បត្តិឡើងក្នុងទ្វីបដទៃឡើយ ។

៣ ទេសៈ ប្រទេសគឺព្រះពុទ្ធជាម្ចាស់ពល់ព្រះអង្គទ្រង់ឧប្បត្តិឡើងតែក្នុងមធ្យមប្រទេស ទ្រង់មិនដែលកើតឡើងក្នុងបច្ចន្តប្រទេសទេ ហេតុដូច្នេះទើបទ្រង់កំណត់យកមធ្យមប្រទេស ក្រុងកបិលពស្តុ ។

៤ កុលៈ ត្រកូល គឺធម្មតាព្រះពុទ្ធពល់ព្រះអង្គ ទ្រង់មិនកើតក្នុងត្រកូលថោកទាបមានវេស្សត្រកូល និងសុទ្ទត្រកូលជាដើមទេ ទ្រង់កាន់យកបដិសន្ធិតែក្នុងត្រកូល ដែលគេសន្មតថាជាត្រកូលខ្ពង់ខ្ពស់ច្បងជាងគេ, សម័យនោះខត្តិយត្រកូល និងព្រាហ្មណត្រកូលកំពុងរុងរឿង ទើបទ្រង់កំណត់យកខត្តិយត្រកូល ។

៥– មាតា ព្រះមាតាគឺ ព្រះពុទ្ធមាតារបស់ព្រះពុទ្ធគ្រប់ព្រះអង្គ

---

១–អបរគោយានទ្វីប ក៏មាន ។

សុទ្ធតែបានបំពេញបារមីធម៌មកគ្រប់បរិបូណ៌ ក្នុងបច្ឆិមជាតិបានដម្កល់នៅក្នុងបញ្ចង្គិកសីលដ៏បរិសុទ្ធ ហេតុដូច្នោះ ទើបទ្រង់កំណត់យកព្រះនាងមាយាជាពុទ្ធមាតា ដែលបរិបូណ៌ដោយគុណគ្រប់យ៉ាង ។

កាលព្រះបរមពោធិសត្វ ស្ដេចប្រមើលមើលនូវបញ្ចមហាវិលោកនៈស្រេចហើយ ទ្រង់ស្ដេចទទួលពាក្យអារាធនាពួកទេវតាទាំងឡាយ ទើបស្ដេចច្យុតចុះចាកតុសិតពិភព មកចាប់បដិសន្ធិក្នុងឧទរព្រះនាងមហាមាយា អគ្គមហេសីព្រះបាទសុទ្ធោទនសក្កជាត្រកូល ក្នុងក្រុងកបិលពស្តុ នៅថ្ងៃព្រហស្បតិ៍ ពេញបូណ៌មីខែអាសាឍ្ហ ឆ្នាំរកា ។

## ៥– សេចក្ដីអស្ចារ្យចំឡែក

កាលព្រះបរមពោធិសត្វ ចុះមកចាប់បដិសន្ធិ កើតអព្ភូតច្ឆរិយធម៌ចំឡែក ដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ថា(១)

ម្នាលអានន្ទ! កាលព្រះពោធិសត្វច្យុតចុះចាកតុសិត ទ្រង់មានសតិសម្បជញ្ញៈចូលទៅកាន់គភ៌ព្រះមាតា, កាលនោះ ក្នុងលោកនេះនឹងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទេវតា ព្រមទាំងមនុស្ស មានពន្លឺ

---

១- អច្ឆរិយព្ភូតធម្មសូត្រ, សុញ្ញតវគ្គ, មជ្ឈិម. ឧប. សៀវ ២៣ ទំព័រ ៤៥ (មើលសត្តមសូត្រ ភយវគ្គ តតិយបណ្ណាសក ច.អំ-៦៦) ។

រស្មីភ្លឺព្រោងព្រាតដ៏ក្រៃលែងប្រមាណមិនបាន ក្រៃលែងជាងទេវានុភាព សូម្បីនៅក្នុងលោកន្តរិកនរក ដែលធ្លាប់តែងងឹតអន្ធការសូន្យសុងជានិច្ច ចក្ខុវិញ្ញាណរាប់មិនធ្លុះ ពន្លឺព្រះអាទិត្យព្រះចន្ទ្រចោលរស្មីទៅមិនដល់, ក្នុងទីនោះ ពន្លឺភ្លឺព្រោងព្រាតក្រៃពេកប្រមាណមិនបាន ក្រៃលែងជាងទេវានុភាពក៏កើតឡើង ។ សត្វដែលកើតក្នុងនរកនេះ បានឃើញនូវគ្នានឹងគ្នាដោយពន្លឺនោះ បបួលគ្នានិយាយអឺងកងឡើងថា "ម្នាលអ្នកដ៏ចំរើនទាំងឡាយ! បានឮថា សត្វដទៃក្រៅពីអាត្មាយើងដែលកើតក្នុងទីនេះ មានដែរតើហ្ន៎!" ។ លោកធាតុទាំងឡាយ ១ម៉ឺននេះក៏រំភើបញាប់ញ័ររន្ធត់ ។ ម្នាលអានន្ទ! នេះជាហេតុអស្ចារ្យទី ១ ដែលមិនធ្លាប់កើត ក៏កើតឡើង ព្រោះកិរិយាកើតនៃតថាគត-អរហន្តសម្មាសម្ពុទ្ធ ។

(នៅមានត)

# ព្រះអភិធម្មបិដក

## (គម្ពីរបុគ្គលបញ្ញត្តិ)

(តមក)

លោក ប៊ូ.ប៊ូ រៀបរៀង

---

បុគ្គលណា កាន់ធម៌ ៦ ប្រការនេះបាន បុគ្គលនោះ អ្នកផងតែងស្រឡាញ់រាប់អានគោរពបូជា ទាំងឈ្មោះថាជាបុគ្គលជួយសង្គ្រោះគ្នា ធ្វើឲ្យមានសេចក្តីព្រមព្រៀងគ្នា ឲ្យបានសុខសប្បាយគ្រប់គ្នាជានិច្ចកាល ។

នៅមានបុគ្គល ៦ ពួកទៀតគឺ បុគ្គលគោរពក្នុងព្រះពុទ្ធមួយពួក, គោរពក្នុងព្រះធម៌មួយពួក, គោរពក្នុងព្រះសង្ឃមួយពួក, គោរពក្នុងសិក្ខាបទមួយពួក, គោរពក្នុងបដិសណ្ឋារៈមួយពួក, គោរពក្នុងអប្បមាទមួយពួក ។

បុគ្គលអ្នកមានសេចក្តីគោរពទាំង ៦ ពួកនេះ តែងបានសេចក្តីសុខសេចក្តីចំរើនក្នុងលោកនេះ និងលោកខាងមុខ មិនមានសេចក្តីទុក្ខសោក មិនវិនាសសាបសូន្យឡើយ ។

ព្រះបរមសាស្តាទ្រង់ទេសនាបុគ្គល ៦ ពួកម្តង ៗ ជាច្រើនពួក ប៉ុន្តែស្រង់យកមកពណ៌នាដោយសង្ខេបប៉ុណ្ណោះ ។

### សត្តកបុគ្គល

សម្តេចព្រះសព្វញ្ញូ ទ្រង់សំដែងនូវបុគ្គល៦ពួកចប់ហើយ ទ្រង់

ត្រាស់ទេសនានូវបុគ្គល ៧ ពួកតទៅទៀតថា សត្តិមេ បុគ្គលា អា-ហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករ-ណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

បុគ្គល៧ពួកនេះ ឈ្មោះថាជាបុគ្គលគួរបូជា គួរនូវគ្រឿងទទួលភ្ញៀវ គួរនូវទក្ខិណាទាន គួរធ្វើអញ្ជលីប្រណម្យ ជាស្រែបុណ្យដ៏ប្រសើររបស់លោក ។

ឥធេកច្ចោ បុគ្គលោ បុគ្គល៧ពួកនោះ គឺបុគ្គលពួកមួយក្នុងលោកនេះ សព្វសង្ខារេសុ អនិច្ចានុបស្សី មានប្រក្រតីពិចារណាឃើញថា មិនទៀងក្នុងសង្ខារធម៌ទាំងពួង នឹងសំគាល់ថា មិនទៀងក្នុងសង្ខារធម៌ទាំងឡាយ បានសេចក្តីថា បញ្ញាពិចារណាស្ទង់ចុះក្នុងសង្ខារធម៌ទាំងឡាយថា មិនទៀង ហើយធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តផល នឹងបានព្រះលោកុត្តរធម៌គឺឈាន សម្រេចកិរិយាបថនៅដោយសេចក្តីសុខក្នុងព្រះអរហត្តផលនោះ ។

បុគ្គលពួកមួយ មានប្រក្រតីពិចារណាឃើញថា មិនទៀងក្នុងសង្ខារធម៌ទាំងឡាយ ហើយស្ទង់ចុះដោយបញ្ញា អស់អាសវកិលេសនឹងតណ្ហាអស់ជីវិតព្រមគ្នា ។

បុគ្គលពួកមួយ មានប្រក្រតីពិចារណាឃើញថា មិនទៀង ក្នុង

សង្ខារធម៌ទាំងឡាយ ហើយលះបង់នូវសំយោជន៍ខាងចុងប្រាំប្រការបាន ចូលកាន់ព្រះនិព្វានក្នុងមនុស្សនេះ ។

បុគ្គលពួកមួយជា ឧបហច្ចបរិនិព្វាយី ,

បុគ្គលពួកមួយជា អសង្ខារបរិនិព្វាយី ,

បុគ្គលពួកមួយជា សសង្ខារបរិនិព្វាយី ,

បុគ្គលពួកមួយជា ឧទ្ធំសោតោ អកនិដ្ឋគាមី ។

បុគ្គល ៧ ពួកនេះ ឈ្មោះថាជាបុគ្គលគួរបូជា ព្រោះថា បើអ្នកណាបានបូជាដល់លោកហើយ អ្នកនោះឯងរមែងបានផលយ៉ាងច្រើន តិលមត្តំ មេរុប្បមាណំ បានបូជាលោកតែប៉ុនគ្រាប់ល្ងទឹងមានផលច្រើនប៉ុនភ្នំព្រះសុមេរុ រមែងញុំាងទាយកឲ្យត្រេកអរដោយបានសោយផល ហេតុនោះ សម្តេចព្រះបរមទសពលទ្រង់ត្រាស់ថា បុគ្គល៧ពួកនេះ ជាអ្នកគួរបូជា ។

ជាបុគ្គលគួរនូវគ្រឿងទទួលភ្ញៀវនោះ អធិប្បាយថា ជនទាំងឡាយ ដែលមានភ្ញៀវចូលមករកតាមលោកវិស័យ ជាភ្ញៀវឆ្ងាយៗ មិនមែនក្រទេ គេបំណាយប្រាក់កាសចិញ្ចឹមបំណី ទុកទទួលភ្ញៀវនោះក៏មាន ជួនកាលភ្ញៀវនាំយកវត្ថុផ្សេងៗ មកឲ្យអ្នកម្ចាស់ផ្ទះយ៉ាងច្រើន

ពាល់តែបរិភោគប្រើប្រាស់មិនអស់ក៏មាន ប៉ុន្តែទុកជាភ្ញៀវឲ្យរបស់ទ្រព្យច្រើនប៉ុន្មានក៏ដោយ ក៏គ្រាន់តែចិញ្ចឹមជីវិតក្នុងបច្ចុប្បន្នកាលប៉ុណ្ណោះ ទីងយករបស់នោះទៅកតមុខទៀតមិនបានឡើយ ។

ឯភ្ញៀវគឺបុគ្គល ៧ ពួកនោះ សូម្បីយកទ្រព្យមកឲ្យអ្នកម្ចាស់ផ្ទះ ក៏ឲ្យបានក្នុងបច្ចុប្បន្នទីងអនាគតកាល មិនចេះខ្វះខាត មិនចេះរលោះអស់ចេះតែមានរហូតដល់ព្រះនិព្វាន ព្រោះលោកនាំយកតែទ្រព្យដ៏មានខ្លឹមសារមកឲ្យ គឺលោកទូន្មានប្រៀនប្រដៅឲ្យតាំងនៅក្នុងសម្មាចរិយា ទីងធម្មចរិយា ។

ម្យ៉ាងទៀត ភ្ញៀវធម្មតា ទៅមករកគ្នាឥតកំណត់ពេលវេលាទេ កាលណាក៏ចេះតែមានដែរ ។ ឯភ្ញៀវគឺបុគ្គល ៧ ពួកនោះ ចេះខុសកាលហើយគ្មានទេ គឺមានចំពោះតែក្នុងពុទ្ធុប្បាទកាលប៉ុណ្ណោះ ហេតុដូច្នោះបានជាឈ្មោះថាជាអ្នកគួរទីងទទួលនូវគ្រឿងទទួលភ្ញៀវ ។

សង្ឃគតា ទក្ខិណា ទក្ខិណាទានដែលបុគ្គលជ្រះថ្លាបានថ្វាយដល់ភិក្ខុសង្ឃ មានផលទីងប្រមាណមិនបាន យ៉ាងហោចណាស់គ្រាន់តែបានឲ្យដល់គោត្រភូសង្ឃ ក្នុងកាលព្រះពុទ្ធសាសនាជិតនឹង·រលត់បាត់អស់ ។ ឯគោត្រភូសង្ឃនោះ គឺសង្ឃដែលគេនិយមពាក់កានថាជាបព្វជិតអ្នកបួសគ្រាន់តែចងកំណាត់សំពត់កាសាវៈទៅកដៃប៉ុណ្ណោះ ប្តូ·

កំសៀតគ្រាបៀកទុកជាសំគាល់ ហើយគេស៊ីធ្វើការចិញ្ចឹមបុត្រនឹងភរិយា តាមភាពជាគ្រហស្ថ យ៉ាងនេះ ក៏ឈ្មោះថាជាទានតាំងនៅក្នុងសទ្ធា ប៉ុន្តែ ត្រូវតាំងចិត្តថាជាសទ្ធា កុំឲ្យមានចិត្តគិតសង្ស័យ ។

ឯអ្នកដែលធ្វើទានឲ្យទៅជាសទ្ធាទាននោះ ត្រូវតាំងចិត្តឲ្យជាទ. បេក្ខាណាស់ គឺតាំងចិត្តឲ្យល្អថា អាត្មាអញនឹងថ្វាយទានឲ្យជាសទ្ធាទាន ទប់ចិត្តកុំឲ្យមានសោមនស្សឬទោមនស្ស ។ ទាននោះទើបហៅជាសទ្ធាទានបាន មហាជេរំ លភិត្វា បើបានព្រះមហាថេរមកទទួលទាន ទើបត្រេកអរ បើបានភិក្ខុវិសព្វមកទទួលទានអាក់អន់តូចចិត្ត ទានបែបនេះមិនមែនជាទានទទួលដល់សទ្ធាទេ ។

ការដែលនឹងធ្វើទានឲ្យបានជាសទ្ធាទាននោះ ត្រូវហាមឃាត់ចិត្ត កុំឲ្យទោមនស្ស ទើបជាទានមានផលានិសង្សច្រើន ។ ការធ្វើសទ្ធាទាននេះ ជាការលំបាកធ្វើណាស់ មិនងាយធ្វើទេ លុះតែអ្នកមានបញ្ញា បានស្តាប់បានរៀនឲ្យចេះដឹង ទើបអាចធ្វើទានឲ្យទៅជាសទ្ធាទានបាន ដូចមានក្នុងគម្ពីរបរិវារៈ ក្នុងព្រះវិន័យបិដក មានសេចក្តីដំណាលថា ៖

១ បុរសម្នាក់ ជាសមុទ្ទពាណិជ គឺឈ្មួញសំពៅដើរផ្លូវសមុទ្រ មានទ្រព្យសម្បត្តិច្រើន មានសទ្ធាជ្រះថ្លា សាងមហាវិហារទុកក្បែរឆ្នេរមហាសមុទ្រ ជាទីចាំវស្សាសំណាក់អាស្រ័យនៃភិក្ខុទាំងឡាយ ដែល

គោចរមកអំពីទិសទាំងបួន ឧបាសកនោះថ្វាយសង្ឃទានដល់ភិក្ខុទាំងឡាយជាប់ជានិច្ចអស់កាលដ៏យូរអង្វែង ។

គ្រានោះ មានភិក្ខុមួយរូប ប្រព្រឹត្តអសុទ្ធសមាចារ ទើងករិយាវៃ ឧបាសកនោះ និមន្តមកទទួលសង្ឃទាន ។ ឧបាសកឃើញភិក្ខុនោះមកទទួលសង្ឃទានរបស់ខ្លួនគិតថា ភិក្ខុនេះប្រព្រឹត្តមិច្ឆាចារស្រឡាញ់ប្រពន្ធអញមកទទួលសង្ឃទាន ប្រសិនបើអញមានចិត្តសៅហ្មង វត្ថុទានរបស់អញនឹងមានផលតិច គួរអញឲ្យទានដោយចិត្តជ្រះថ្លាស្មើនឹងសង្ឃឯកមានសីលបរិសុទ្ធចុះ ឲ្យបានផលច្រើន លុះគិតឃើញយ៉ាងនេះហើយ ក៏និមន្តភិក្ខុនោះឡើងទៅលើផ្ទះ លាងព្រះបាទរួចនិមន្តឲ្យគង់លើអាសនៈដ៏សមគួរ ហើយធ្វើសេចក្ដីគោរពគ្មានវិមតិកង្ខាក្នុងភិក្ខុនោះ មានព្រះសង្ឃគុណជាអារម្មណ៍ អង្គាសដោយខាទនីយភោជនីយាហារ ។ ភិក្ខុនោះទទួលសង្ឃទានរួចហើយ ក៏និមន្តត្រឡប់ទៅវត្តវិញ គិតស្មានក្នុងចិត្តថា ឧបាសកមិនដឹងជាខ្លួនស្រឡាញ់ប្រពន្ធទេ ។

លុះដល់វេលារសៀល ភិក្ខុនោះមករកខ្ចីចបឧបាសកយកទៅជីករណ្ដៅសសរធ្វើកុដិ ។ ឧបាសកប្រាប់ថា លើផ្ទះនេះគ្មានចបទេ បើលោកចង់បានចបចូលទៅយកពីក្រោមផ្ទះខ្ញុំចុះ ។ ភិក្ខុឆ្លើយថា អ្នកយកចបមកឲ្យអាត្មាផង ព្រោះអាត្មាជាសមណៈមិនត្រូវចូលក្រោមផ្ទះគ្រហស្ថទេ ។

ឧបាសកក៏ចុះពីលើផ្ទះមកដល់ដីមិនថ្វាយបង្គំភិក្ខុនោះសោះ យកមេជើង ថ្មៀបបបោះទៅឲ្យភិក្ខុ ៗ លុះភិក្ខុនោះទទួលទៅវត្តវិញ ជនទាំងឡាយ និយាយថា តើ ឥកោសិ សទ្ធោ អ្នកជាមនុស្សមានសទ្ធាជ្រះថ្លា គោរពក្នុងព្រះសង្ឃ ហេតុអ្វីបានជាអ្នកធ្វើយ៉ាងហ្នឹង ? ឧបាសកឆ្លើយថា នៃអ្នកដ៏ចំរើន ! កាលពីព្រឹកមិញចិត្តយើងជាកុសល ព្រោះយើងគោរព ទានដើម្បីនឹងឲ្យទានរបស់ខ្លួនមានផលច្រើន មិនមែនយើងគោរពភិក្ខុឥត សីលនោះទេ ដ្បិតភិក្ខុនោះធ្វើមេថុនធម្មនឹងប្រពន្ធរបស់យើង ៗ អ្នកទាំង ឡាយចូរដឹងថា បុគ្គលនឹងធ្វើទានឲ្យជាសង្ឃទាន ត្រូវធ្វើដូចឧបាសក នេះចុះ ទើបនឹងមានកុសលកសីច្រើន ៗ

កិរិយាដែលនឹងបូជាដល់ព្រះធម៌សោតទៀត ក៏គម្រនឹងធ្វើឲ្យបាន ទៅជាធម្មបូជាណាស់ ព្រោះអ្នកខ្លះមានចិត្តសទ្ធាជ្រះថ្លា ប៉ុន្តែប្រាសចាក បញ្ញាមិនដឹងថានឹងត្រូវធ្វើដូចម្តេច ៗ លោកអ្នកសំដែងធម៌នោះជាលេង ទៅតាមអំពើចិត្ត លើកយករឿងមិនមែនជាធម៌មកសំដែង មនុស្សល្ងង់ ខ្លៅក៏សំគាល់ថាជាធម៌មានខ្លឹមសារ ជាក្រសែព្រះពុទ្ធដីកា ហើយបូជា ដោយវត្ថុបច្ច័យ ដូច្នេះមិនបានឈ្មោះថាបូជាព្រះធម៌ទេ ៗ

ការបូជាព្រះធម៌នោះ ចំពោះបូជានូវបុគ្គលអ្នកទ្រទ្រង់ធម៌, អ្នក ប្រតិបត្តិធម៌, អ្នករៀនធម៌, អ្នកសំដែងធម៌ មិនចំពោះតែភិក្ខុទេ ដោយ

ហោចទៅ សូម្បីជាឧបាសក ឧបាសិកា មានបញ្ញាចាំបទនៃព្រះធម៌បាន បុគ្គលមានចិត្តសទ្ធាជ្រះថ្លាបានបូជា ក៏ឈ្មោះថាបូជាព្រះធម៌ សមដោយពាក្យក្នុងតិកនិបាតអង្គុត្តរនិកាយថា ធម្មធរំ បុគ្គលំ ឧបដ្ឋហិត្វា អ្នកណាមានសទ្ធាជ្រះថ្លា បានបម្រើបុគ្គលទ្រទ្រង់ធម៌យ៉ាងតិចណាស់តែត្រឹមបាទមួយក្តី យ៉ាងនេះឈ្មោះថាជាបុគ្គលទ្រទ្រង់ធម៌ ព្រោះថាព្រះធម៌នោះកម្រដែលបុគ្គលនឹងទ្រទ្រង់ចងចាំទុកបានណាស់ សូម្បីតែបុគ្គលអ្នកមានឧបនិស្ស័យនឹងបានសម្រេចព្រះអរហត្តក្នុងជាតិនោះហើយ ក៏នៅតែមិនអាចនឹងទន្ទេញឲ្យចាំបាន ដូចជាព្រះចូឡបន្ថកត្ថេរ ព្រះមហាបន្ថកត្ថេរជាបងឲ្យទន្ទេញគាថាតែមួយ មានបាទបួន ចំនួន ៣២ តួអក្សរប៉ុណ្ណោះមិនចាំ ហេតុតែអកុសលកម្មដែលខ្លួនបានធ្វើទុកមកពីជាតិមុន គឺសើចចំអកចំអន់ឡកឡឺយឲ្យសាមណេរមួយរូប កំពុងរៀនធម៌ឲ្យកើតសេចក្តីអៀនខ្មាស់ពាល់តែឈប់លែងរៀនធម៌ ។

ហេតុនោះ ការបូជាព្រះធម៌ត្រូវនឹករឭកដល់ព្រះធម្មគុណជាអារម្មណ៍ ហើយបូជាបុគ្គលអ្នកទ្រទ្រង់ធម៌ ទើបបានឈ្មោះថា បូជាព្រះធម៌ ។ សូម្បីនឹងស្តាប់ធម៌ ក៏ត្រូវតាំងចិត្តស្តាប់តែព្រះធម៌ កុំស្តាប់ពាក្យដែលមិនមែនជាធម៌ ទើបជាធម្មស្សវនមយកុសលរាប់ចូលក្នុងបុញ្ញកិរិយាវត្ថុ ។

បុគ្គល ៧ ពួកដូចរៀបរាប់មកខាងដើមនេះ ឈ្មោះថាជាស្រែបុណ្យ

ប្រសើរ ព្រោះលោកខ្ញុំនានប្រៀនប្រដៅឲ្យដឹងបុណ្យនិងបាប ប្រាប់ផ្លូវសួគ៌និងផ្លូវព្រះនិព្វាន ។

សម្ដេចព្រះជិនស្រីសម្មាសម្ពុទ្ធ ទ្រង់សំដែងបុគ្គល ៧ ពួកនេះចប់ហើយ ទើបទ្រង់ទេសនានូវបុគ្គល ៧ ពួកតទៅទៀតថា សត្ត បុរិសស្ស ភរិយា ស្ត្រីជាភរិយានៃបុរសក្នុងលោកនេះមាន ៧ ពួកគឺ៖

១-វធកា ភរិយា ប្រពន្ធគិតតែសម្លាប់ប្ដីនិងមាតាបិតារបស់ប្ដី,

២-ចោរី ភរិយា ប្រពន្ធជាចោរគិតតែលួចសម្បត្តិរបស់ប្ដី,

៣-អយ្យា ភរិយា ប្រពន្ធមានអាការស្មើនិងម្ចាស់នៃប្ដី,

៤ មាតា ភរិយា ប្រពន្ធប្រព្រឹត្តក្នុងប្ដីស្មើនិងមាតា,

៥-ភគិនី ភរិយា ប្រពន្ធស្មើនិងប្អូនស្រីរបស់ប្ដី,

៦-សខី ភរិយា ប្រពន្ធស្មើនិងសម្លាញ់របស់ប្ដី,

៧-ទាសី ភរិយា ប្រពន្ធដូចជាខ្ញុំស្រីរបស់ប្ដី ។

ភរិយាបីពួកគឺ វធកា ភរិយា១ ចោរី ភរិយា១ អយ្យា ភរិយា១ ជាភរិយាអាក្រក់ បុរសមិនគួរយកធ្វើជាប្រពន្ធទេ គួរតែលះលែងចោលចេញ ។ ឯភរិយាបួនពួកខាងចុងគឺ មាតា ភរិយា ១ ភគិនី ភរិយា ១ សខី ភរិយា ១ ទាសី ភរិយា ១ ជាភរិយាល្អ បុរសត្រូវយកធ្វើជាប្រពន្ធ

រហូតទៅ ហើយបុរសត្រូវទំនុកបំរុងប្រពន្ធនេះដោយកិច្ច ៥ យ៉ាងដូចមាន៖ សេចក្ដីពិស្ដារក្នុងសិង្គាលោវាទសូត្រ ជាហេតុនាំឲ្យកើតចិត្តប្រតិព័ទ្ធទីនេះ សេចក្ដីសុខក្នុងលោកនេះ ទីនោះ លោកខាងមុខ ព្រោះថាអ្នកប្រាជ្ញពោធិញ្ញាណត្រូវអាស្រ័យនូវកិរិយាបរិច្ចាគទាននិងវត្ថុបរិច្ចាគ ទើបនឹងបានសម្រេចដូចសេចក្ដីប្រាថ្នា ។

## សត្តកបុគ្គល សង្ខេបចំណោះ ។

## អដ្ឋកបុគ្គល

អដ្ឋ ទក្ខិណេយ្យា សោតាបត្តិមគ្គសោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នា សកទាគាមិមគ្គសកទាគាមិផលសច្ឆិកិរិយាយ បដិបន្នា អនាគាមិមគ្គអនាគាមិផលសច្ឆិកិរិយាយ បដិបន្នា អរហត្តមគ្គអរហត្តផលសច្ឆិកិរិយាយ បដិបន្នាតិ ។

សម្ដេចព្រះមានព្រះភាគ កាលទ្រង់ទេសនាសត្តកបុគ្គលចប់ហើយ ទើបទ្រង់សំដែងនូវអដ្ឋកបុគ្គលតទៅទៀតថា ៖

អដ្ឋ ទក្ខិណេយ្យា បុគ្គលទាំងឡាយប្រាំបីពួកឈ្មោះថា ទក្ខិណេយ្យបុគ្គល គឺបុគ្គលទទួលនូវទក្ខិណាទាន ។ ឯទក្ខិណេយ្យបុគ្គលប្រាំបីពួកនោះគឺ ព្រះសោតាបត្តិមគ្គ ១ ពួក លោកអ្នកប្រតិបត្តិដើម្បីឲ្យបានសម្រេចនូវសោតាបត្តិផល ១ ពួក ព្រះសកិទាគាមិមគ្គ ១ ពួក

លោកអ្នកប្រតិបត្តិដើម្បីឲ្យបានសម្រេចព្រះសកិទាគាមិផល ១ ពួក ព្រះអនាគាមិមគ្គ ១ ពួក លោកអ្នកប្រតិបត្តិដើម្បីឲ្យបានសម្រេចព្រះអនាគាមិផល ១ ពួក ព្រះអរហត្តមគ្គ ១ ពួក លោកអ្នកប្រតិបត្តិដើម្បីឲ្យបានសម្រេចព្រះអរហត្តផល ១ ពួក រួមជាប្រាំបីពួក ឈ្មោះថាទក្ខិណេយ្យបុគ្គល ផលនៃកុសលនោះមិនបានធ្លាក់ទៅទីទាបទេ តែនឹងញុំាងទាយកឲ្យបានសោយផលយ៉ាងច្រើនបរិបូណ៌ ។

អដ្ឋទានវត្ថុ ហេតុជាទីតាំងនៃទានរបស់ទាយក មានប្រាំបីប្រការ គឺ អាសជ្ជទានំ ទេតិ ឲ្យដោយខានមិនបាន ១ ភយា ទានំ ឲ្យដោយខ្លាច ១ អទាសិ មេតិ ទេតិ គិតថាអ្នកនេះបានឲ្យដល់អញពីមុនហើយឲ្យតបវិញ ១ ទស្សតិ មេតិ ទេតិ ឲ្យដោយគិតថាអញឲ្យគេ ៗ នឹងឲ្យអញវិញ ១ ឲ្យដោយគិតថាល្អជាងមិនឲ្យ ១ អហំ បចាមិ គិតថាអញចំអិនបាន អ្នកនេះចំអិនមិនបានហើយឲ្យ ១ គិតថាអញបំពេញទានហើយ កិត្តិសព្ទពាក្យសរសើរនឹងកើតមានដល់អញ ១ ឲ្យគ្រឿងប្រដាប់ចិត្តនឹងបរិក្ខារនៃចិត្ត ១ រួមជាទានវត្ថុប្រាំបីប្រការ ។

អដ្ឋទានុប្បត្តិយោ ទានុប្បត្តិហេតុនៃទានមានប្រាំបីប្រការគឺ ឥធេកច្ចោ បុគ្គលពួកមួយក្នុងលោកនេះ ឲ្យបាយទឹកភោជនាហារ សំពត់កាវសាវស្ស យានជំនិះ នឹងកម្រងផ្កាគ្រឿងក្រអូបគ្រឿងលាបប្រស់ព្រំ

ទីសេយ្យាសន៍ ទីលំនៅនឹងប្រទីបផ្កាលាជាទាន ដល់សមណៈព្រាហ្មណាចារ្យទាំងឡាយ ឲ្យរបស់អ្វីចង់ឲ្យបានរបស់នោះវិញ ដើម្បីឲ្យបានទៅកើតក្នុងត្រកូលខត្តិយមហាសាល ព្រាហ្មណមហាសាល និងគហបតីមហាសាល ដ៏បរិបូណ៌ដោយបញ្ចកាមគុណ ។ ពួកមួយទៀតឲ្យទានប្រាថ្នានឹងទៅកើតក្នុងជាន់ចាតុមហារាជិកា ។ ពួកមួយឲ្យទានប្រាថ្នានឹងទៅកើតក្នុងជាន់តាវត្តិង្ស ។ ពួកមួយឲ្យទានប្រាថ្នានឹងទៅកើតក្នុងជាន់យាមា ។ ពួកមួយឲ្យទានប្រាថ្នានឹងទៅកើតក្នុងជាន់តុសិត ។ ពួកមួយឲ្យទានប្រាថ្នានឹងៈទៅក្នុងជាន់បរនិម្មិត ។ ពួកមួយឲ្យទានប្រាថ្នានឹងៈទៅកើតក្នុងជាន់បរនិម្មិតវសវតី ។ ពួកមួយឲ្យទានប្រាថ្នានឹងទៅកើតក្នុងពួកនៃព្រាហ្ម ។

សម្ដេចព្រះបរមសាស្ដាត្រាស់ទេសនានូវហេតុដែលញុំាំងបុគ្គលឲ្យបំពេញទាន ដើម្បីទៅកើតក្នុងត្រកូលមហាសាល, ក្នុងទេវលោកនិងព្រហ្មលោក ជាហេតុប្រាំបីប្រការដូច្នេះហើយ លំដាប់ពីនេះទៅ ព្រះអង្គទ្រង់ត្រាស់ទេសនានូវស្ត្រីដែលនឹងចងចិត្តបុរសឲ្យប្រតិព័ទ្ធមកលើខ្លួនមានប្រាំបីពួក គឺ ស្ត្រីរូបល្អស្រស់ ១ ឆ្លាតក្នុងមាយារបស់ស្ត្រី ១ ឆ្លាតក្នុងការនិយាយ ១ ស្ត្រីអ្នកៈច្រៀងពំ ១ ស្ត្រីធ្វើអាការជំស្នេហ៍ស្និទ្ធឲ្យជង់ចិត្ត ១ ស្ត្រីមានកិរិយាល្អ ១ មានសម្ផស្សល្អ ១ (ច្បាប់ដើមមានតែត្រឹម

៧ ពួក  បាត់ ១ ពួកខាងចុង) ស្ត្រីទាំង ៨ ពួកនេះ រមែងចងចិត្តបុរសឲ្យប្រតិព័ទ្ធនឹងខ្លួន ។

ឥត្ថី ពន្ធតិ ចំណែកបុរសវិញ រមែងចងចិត្តស្ត្រីឲ្យស្រឡាញ់ខ្លួនដោយហេតុ ៨ ប្រការ ដូចរៀបរាប់មកខាងដើមនេះដែរ ។

អដ្ឋហិ ធម្មេហិ សមន្នាគតោ មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការគឺមាតុគ្រាមក្នុងលោកនេះ ប្រព្រឹត្តល្អអនុគ្រោះគោរពទន់លំទោនដល់មាតាបិតារបស់ខ្លួន មាតាបិតារបស់ស្វាមីនិងដល់ប្ដី បំយក់ទទី ពោលពាក្យជាទីស្រឡាញ់ មិនពោលពាក្យឲ្យទើសទាស់ចិត្ត ប្រការ១ ។

យេ តេ គរុនោ រមែងធ្វើគារវៈសក្ការៈបូជាដល់បុគ្គលទាំងឡាយដែលមាតាបិតានិងស្វាមីគោរពប្រការ១ ។

ភត្តកម្មន្តា ការងារក្នុងផ្ទះរបស់ស្វាមី ក៏ចាត់ចែងតាក់តែងឲ្យបានរៀបរយល្អ មិនខ្ជិលច្រអូស ប្រការ ១ ។

អន្តោជនា អន្តោជនគឺទាសៈទាសីអ្នកបម្រើ ក៏សង្គ្រោះដោយបាយទឹកសំពត់អាវ ទឹងមានជម្ងឺឈឺចាប់ជួយថែរក្សាព្យាបាលតាមការគួរដល់យសសក្តិនិងទ្រព្យសម្បត្តិរបស់ខ្លួន ប្រការ១ ។

យំ អាភតំ របស់ទ្រព្យណាដែលស្វាមីរកបានមកហើយ ១ស្ប្រាហ៍មើលថែទាំទុកដាក់ឲ្យគង់នៅមិនឲ្យបាត់បង់ទៅដោយឥតហេតុអ្វីប្រការ១ ។

អធុត្តិ អចេជ្ជី មិនជាស្ត្រីអ្នកលេងនឹងមិនជាចោរ ប្រការ១ ។

សីលវតី ជាស្ត្រីមានសរណគមន៍នឹងសីលប្រាំសីលប្រាំបីប្រការ១ ។

ចាគវតី ជាស្ត្រីបរិច្ចាគនូវទាន មានសទ្ធាចិត្តឥតកំណាញ់ ប្រការ ១ ។

មាតុគ្រាមប្រកបដោយធម៌ប្រាំបីប្រការនេះ ធេវាធំ បរិសុទ្ធិ ទេវតានឹងមនុស្សទាំងឡាយរមែងសរសើរនូវមាតុគ្រាមនោះ កាយស្ស ភេទា បរម្មណា លុះចំណាយបញ្ចក្ខន្ធហើយ រមែងមានស្ថានសួគ៌ ជាខាងមុខ ។

សម្តេចព្រះមានព្រះភាគ ទ្រង់ត្រាស់ទេសនានូវអដ្ឋកបុគ្គលបម្តង ប្រាំបីពួកៗដោយអនេកន័យ ទើបត្រាស់នូវធម៌ជាឧបការប្រាំបីប្រការ ធម៌ត្រូវឲ្យចម្រើនច្រើនឡើងប្រាំបីប្រការ, ធម៌ត្រូវលះបង់ចេញប្រាំបីប្រការ, ធម៌ប្រកបក្នុងចំណែកពិសេសហើយបុគ្គលនឹងដឹងបានក្រ, ធម៌ដែលបុគ្គលនឹងឲ្យបង្កើតឡើងដោយលំបាក, ធម៌ដែលបុគ្គលនឹងគប្បីដឹងដោយបញ្ញាដ៏ក្រៃលែង នឹងធម៌ដែលបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ ៗ បណ្តាធម៌ទាំងនោះ ធម៌មួយៗមានប្រាំបីៗប្រការ ។

ព្រះបរមសាស្តាទ្រង់ទេសនាធម៌មានឧបការច្រើនប្រាំបីប្រការជាមុន ថា អដ្ឋ ពហុបការា ធម្មា ធម៌មានឧបការច្រើនប្រាំបីប្រការនោះ គឺហេតុនឹងបច្ច័យប្រាំបីប្រការ ។

ឯហេតុបច្ច័យជាបឋមនោះ គឺ ភិក្ខុក្នុងពុទ្ធសាសនានេះអាស្រ័យនូវគ្រូនិងអាចារ្យជាអ្នកប្រៀនប្រដៅឲ្យសិក្សា ហើយធ្វើសេចក្តីគោរពចំពោះគ្រូអាចារ្យនោះ មិនបានគោរពកប់អាងគ្រូអាចារ្យដទៃដែលជាមនុស្សប្រ. ព្រឹត្តមិច្ឆាប្រតិបត្តិ គឺប្រព្រឹត្តខុសគន្លងធម៌ ។

ហេតុបច្ច័យជាគំរប់ពីរថា កាលេន កាលំ ឧបសង្កមិត្វា ចូលទៅកាន់សំណាក់នៃគ្រូនិងអាចារ្យក្នុងកាលទាំងពួង គឺសព្វកាល ហើយសាកសួរអដ្ឋកថាបាលីនិងធម៌ទាំងឡាយដែលខ្លួនសង្ស័យ ។

ហេតុបច្ច័យជាគំរប់បីថា ភិក្ខុបានស្តាប់ធម៌ហើយធ្វើឲ្យយល់ច្បាស់ក្នុងសន្តានចិត្ត ។

ហេតុបច្ច័យជាគំរប់បួនថា ភិក្ខុសង្រួមក្នុងព្រះបាដិមោក្ខសំវរសីលជាដើម ។

ហេតុបច្ច័យជាគំរប់ប្រាំថា ភិក្ខុជាពហុស្សូតបានស្តាប់ច្រើន និងទ្រទ្រង់ធម៌ទាំងឡាយដ៏ពីរោះក្នុងខាងដើមកណ្តាល និងទីបំផុត ។

ហេតុបច្ច័យជាគំរប់ប្រាំមួយថា ភិក្ខុមានព្យាយាមមិនបន្ធូរបន្ថយក្នុងការលះបង់អកុសលធម៌និងញុំាងកុសលធម៌ឲ្យចំរើនឡើង ។

ហេតុបច្ច័យជាគំរប់ប្រាំពីរថា ភិក្ខុប្រកបដោយសតិនិងបញ្ញាដ៏ចាស់ក្លា នឹករឭកដល់កិច្ចការដែលខ្លួនធ្វើរួចហើយ និងសំដីដែលខ្លួននិយាយ

រួចហើយ អស់កាលជាយូរអង្វែងបាន ។

ហេតុបច្ច័យជាគំរប់ប្រាំបីថា ភិក្ខុមានប្រក្រតីពិចារណាឃើញនូវការកើតនិងការរលត់នៃបញ្ចក្ខន្ធ ។

ហេតុបច្ច័យទាំងប្រាំបីប្រការនេះ ឈ្មោះថា ពហុបការធម៌ ប្រព្រឹត្តទៅដើម្បីនឹងឲ្យបាននូវភាវនាដែលខ្លួនមិនទាន់បាន នឹងធ្វើភាវនាដែលខ្លួនបានរួចហើយឲ្យរឹតតែចំរើនច្រើនៗ ឡើង ។

ក៏ឯធម៌ដែលភិក្ខុគប្បីធ្វើឲ្យចំរើនប្រាំបីប្រការនោះ បានដល់ព្រះអដ្ឋង្គិកមគ្គ គឺសម្មាទិដ្ឋិ បញ្ញាឃើញត្រូវ ១ សម្មាសង្កប្បៈ ត្រិះរិះត្រូវ ១ សម្មាវាចា សំដីត្រូវ ១ សម្មាកម្មន្ត ការងារត្រូវ ១ សម្មាអាជីវៈ ចិញ្ចឹមជីវិតត្រូវ ១ សម្មាវាយាមៈ ព្យាយាមត្រូវ ១ សម្មាសតិ រឭកត្រូវ ១ សម្មាសមាធិ តាំងចិត្តត្រូវ ១ គ្រប់ជាធម៌ប្រាំបីប្រការ ដែលភិក្ខុគប្បីធ្វើឲ្យចំរើនឡើងក្នុងខន្ធសន្តាន ។

បរិញ្ញេយ្យា អដ្ឋ ធម្មា ធម៌ទាំងឡាយប្រាំបីប្រការដែលភិក្ខុគប្បីកំណត់ដឹងនោះ បានដល់លោកធម៌ប្រាំបីប្រការ គឺមានលាភ ១ ឥតលាភឬខូចខាតលាភ ១ មានយស ១ ឥតយសឬថោះយស ១ និន្ទា ១ សរសើរ ១ សុខ ១ ទុក្ខ ១ ។ លោកធម៌ទាំងប្រាំបីប្រការនេះ គឺភិក្ខុគប្បីកំណត់ដឹងដោយបញ្ញា ។

ធម៌ដែលភិក្ខុគប្បីលះបង់ប្រាំបីប្រការនោះ បានដល់មិច្ឆាទិដ្ឋិ ១ មិច្ឆាសង្កប្បៈ ១ មិច្ឆាវាចា ១ មិច្ឆាកម្មន្តៈ ១ មិច្ឆាអាជីវៈ ១ មិច្ឆាវាយាម ១ មិច្ឆាសតិ ១ មិច្ឆាសមាធិ ១ ។

ធម៌មានចំណែកគ្គឹងទិទឹងឲ្យវិនាសសាបសូន្យ ប្រាំបីប្រការនោះ បានដល់ហេតុខ្ជិលច្រអូសនៃភិក្ខុប្រាំបីប្រការគឺ

១-គិតថា អាត្មានឹងធ្វើការ គួរតែសម្រាកសិន ហើយដេក,

២-គិតថា អាត្មាធ្វើការរួចហើយ គួរឈប់ឲ្យសប្បាយ ហើយដេក,

៣ គិតថា អាត្មានឹងដើរទៅផ្លូវឆ្ងាយ គួរតែសម្រាកសិន ហើយដេក,

៤-គិតថា អាត្មាដល់ទីកន្លែងហើយ គួរតែឈប់ឲ្យសប្បាយ ហើយដេក,

៥-គិតថា អាត្មាបរិភោគអាហារតិចពេក ធ្វើការមិនកើតទេ ហើយដេក,

៦-គិតថា អាត្មាបរិភោគអាហារច្រើនពេក គួរតែឈប់សម្រាកឲ្យអាហាររលាយរលួយស្រួលបួលសិន ហើយដេក,

៧-គិតថា អាត្មាមិនសូវស្រួលខ្លួនទេ ចេះតែរកកល់ឈឺ គួរតែសម្រាកសិន ហើយដេក,

៨-គិតថា អាត្មាទើបតែងើបពីឈឺថ្មីៗ គួរតែបង្អង់ធ្វើការសិន ហើយដេក ។

ធម៌មានចំណែកក្នុងកិរិយានឹងឲ្យបានដល់នូវគុណវិសេសជាហេតុឲ្យធ្វើនូវសេចក្ដីព្យាយាម មានប្រាំបីប្រការ គឺភិក្ខុគប្បីធ្វើនឹងត្រូវធ្វើសេចក្ដីព្យាយាម១ ដែលធ្លាប់ធ្វើរួចមកហើយមិនលះបង់ចោល១ ផ្លូវដែលមិនធ្លាប់ទៅក៏ខំស្វាហ៍ទៅ១ ផ្លូវដែលធ្លាប់ទៅរួចហើយ ក៏ខំស្វាហ៍ទៅ១ ស្រុកនិគមដែលមិនធ្លាប់ទៅ ក៏ខំស្វាហ៍ទៅ១ ដែលធ្លាប់ទៅរួចហើយ ក៏គិតថាធ្លាប់បានទៅរួចហើយ បានអាហារបិណ្ឌបាតល្មមនឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដើម្បីនឹងធ្វើសេចក្ដីព្យាយាមឲ្យដល់នូវធម៌វិសេស គិតដូច្នោះហើយ ក៏ខំស្វាហ៍ទៅ១ បើឈឺតាប់បន្តិចបន្តួចនឹកខ្លាចក្រែងឈឺច្រើនធ្ងន់ ខំស្វាហ៍ចំរើនភាវនា១ បើឈឺធ្ងន់ក្រោកពីជម្ងឺ ។ គិតថាអាពាធនឹងត្រឡប់រើឡើងទៀត ក៏តាំងចិត្តចំរើនភាវនា១ គ្រប់ជាធម៌ឲ្យបានសម្រេចនូវគុណវិសេសប្រាំបីប្រការ ។

អង្គសម្ដេចព្រះបរមលោកុត្តមាចារ្យ ទ្រង់ត្រាស់ទេសនានូវធម៌ទាំងឡាយប្រាំបីនេះ មិនមែនចំពោះតែពួកបព្វជិតភិក្ខុសាមណេរទេ ចំពោះទូទៅដល់ពុទ្ធបរិស័ទទាំងបួន ប៉ុន្តែដែលទ្រង់ត្រាស់ចំពោះភិក្ខុដូច្នោះ ព្រោះភិក្ខុនោះនៅជិតព្រះអង្គ សូម្បីគ្រហស្ថទាំងឡាយធ្វើតាមព្រះពុទ្ធដីកា ក៏ឈ្មោះថាប្រតិបត្តិតាមព្រះពុទ្ធោវាទ អ្នកប្រាជ្ញទាំងឡាយគប្បីសន្និដ្ឋានចូលចិត្តដោយន័យនេះចុះ ។

អដ្ឋកបុគ្គល សង្ខេបប៉ុណ្ណេះ ។

(នៅមានត)

# មធុរសវាហិណី

សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

នមោ ពុទ្ធាយ នមោ ធម្មាយ នមោ សង្ឃាយ ប្រែថា ខ្ញុំព្រះករុណាសូមនមស្ការថ្វាយបង្គំព្រះពុទ្ធជាម្ចាស់ ខ្ញុំព្រះករុណាសូមនមស្ការថ្វាយបង្គំព្រះធម៌ជាម្ចាស់ ខ្ញុំព្រះករុណា សូមនមស្ការថ្វាយបង្គំព្រះសង្ឃជាម្ចាស់ ។ មនុស្សទាំងឡាយនោះពោលយ៉ាងនេះ ដោយសំឡេងលាន់ឮគឹកកងក្នុងពេលនោះឯង ។

ចំណែកឯព្រានពស់ ជាមនុស្សមិច្ឆាទិដ្ឋិពុំបានជឿ ពុំបានដឹងគុណព្រះរតនត្រ័យឡើយ ព្រោះហេតុដូច្នោះ ព្រានពស់បានស្តាប់ពាក្យគេនមស្ការគុណព្រះរតនត្រ័យហើយ ក៏សើចចំអកឡកលេងស្រស់ស្រាយ ពោលត្រាប់មាត់តាមថា នមោ ពុទ្ធាយ ។ ដោយពាក្យចំអកសើចលេងនោះឯង ។

លុះថ្ងៃមួយជាខាងក្រោយ ព្រានពស់នោះដើរចេញទៅអំពីផ្ទះចូលទៅក្នុងព្រៃដើរស្វែងរកចាប់ពស់ក្នុងព្រៃនោះ ។ ដើម្បីនឹងយកទៅឲ្យរាំលេងឲ្យមនុស្សមើល គ្រាន់នឹងយកថ្លៃឈ្នួលដូចគ្រាមុនៗ ក៏ទំដើរ

ស្វែងរៀងៗទៅក្នុងព្រៃនោះ ។

កាលនោះ មានពស់នាគរាជមួយមានឫទ្ធានុភាពៈច្រើន មានសេចក្តីជ្រះថ្លាប្រាថ្នានឹងទៅធ្វើការកិច្ចបូជានមស្ការព្រះចេតិយ ដែលបញ្ចុះព្រះធាតុព្រះពុទ្ធកស្សបអង្គនោះ លុះបានទៅដល់ បានបូជាថ្វាយបង្គំស្រេចហើយ ក៏ត្រឡប់មកវិញលូនទៅស្វែងរកជម្រកដើម្បីនឹងជ្រកពួន ។

ឯព្រានពស់បានឃើញពស់នាគរាជនោះហើយ ក៏ស្ទុះចូលទៅជិតដោយរហ័ស ហើយសូត្រស្វាធ្យាយទក់យមន្ត ផ្សាយទៅបម្រុងនឹងចាប់យកពស់នាគរាជនោះឯង ។

ពស់នាគរាជលុះបានស្តាប់មន្តហើយ ក៏គ្រោធខឹងនឹងព្រានពស់មហិមា មានប្រាថ្នានឹងសម្លាប់ព្រានពស់នោះ ក៏ដកពារស្ទុះរត់ដេញតាមទៅក្នុងកាលនោះឯង, ។ ព្រានពស់បានឃើញដឹងថា នាគរាជពុំបានស្តាប់បង្គាប់មន្តអាគមរបស់ខ្លួន ហើយស្ទុះដេញមកជួះធ្លោះហើយ ក៏ភិតភ័យខ្លាំងពន់ពេកប្រឹងរត់ទៅដោយរហ័ស ស្រាប់តែប៉ះទង្គិចជើងលើផែនថ្មមួយក៏ដួលចុះទៅ ហេតុតែការផ្ចាប់សំខ្សឹនពាក្យចំអកសើចលេងដែលខ្លួនបានពោលត្រាប់ពីមុនមក លុះដួលហើយក្តាត់មាត់សូត្រថ្ងូរៗថា នមោពុទ្ធាយៗ ក្នុងពេលនោះឯង ។

ពស់នាគរាជកាលបើកំពុងតែខឹងដេញតាម ប្រុងនឹងចឹកព្រាននោះ

ក៏បានឃើញព្រានទន្ទិចនឹងដុំថ្មួលចុះហើយលាន់មាត់សូត្រថា នមោ ពុទ្ធាយ ។ ដូច្នោះ ក៏សំឡេងដែលសូត្រនោះត្រជាក់បីដូចជាទឹកអម្រឹតហូរចូលទៅក្នុងត្រចៀកនៃពស់នាគរាជនោះ អាចរលត់នូវសេចក្តីក្រោធខឹងមួយរំពេចនោះបាន ។ ពស់នាគរាជនោះក៏បានរលត់សេចក្តីក្រោធខឹងក្នុងព្រានចាស់នោះ ដោយអានុភាពការគោរពនូវគុណព្រះរតនត្រ័យ ក្នុងកាលនោះឯង ហើយបែរជាពោលថា ម្នាលសំឡាញ់! អ្នកកុំខ្លាចភិតភ័យអ្វីឡើយ យើងបានដាច់ដោយអន្ទាក់ទាញកន្ត្រាក់មកដោយមន្តគឺគុណព្រះរតនត្រ័យហើយ ព្រោះហេតុនោះ យើងមិនគួរខឹងចំអ្នកឡើយ ថ្ងៃនេះយើងមានសេចក្តីសោមនស្សជ្រះថ្លាចំពោះអ្នកពន់ពេក យើងនឹងឲ្យគ្រឿងបណ្ណាការដល់អ្នក ត្រូវអ្នកទទួលយកចុះ ។ នាគរាជបានពោលយ៉ាងនេះហើយ ក៏ឲ្យផ្កាមាសបីដុំទៅព្រានពស់នោះឯង ។

បពិត្រអើយ ឯនាមព្រះរតនត្រ័យនេះវិសេសថ្លៃថ្លាណាស់ បីដូចជាទឹកអម្រឹតដ៏ត្រជាក់ សម្រាប់ស្រោចរំលត់នូវសេចក្តីក្រោធខឹងនៃពស់ដែលមានពិសក្លៀវក្លាដូច្នេះឯង ។ ព្រោះហេតុដូច្នោះ បានជាព្រះអរហន្តទាំងឡាយពោលសរសើរគុណព្រះរតនត្រ័យ ដោយបទព្រះគាថាដូច្នេះថា :

ពុទ្ធោតិវចនំ សេដ្ឋំ ពុទ្ធោតិវចនុត្តមំ

នត្ថិ តេន សមំ លោកេ អញ្ញំ សោតរសាយនំ ។

សេចក្តីថា ពាក្យពោលថា ពុទ្ធោ ដូច្នេះ ជាពាក្យដ៏ប្រសើរវិសេស ពាក្យពោលថា ពុទ្ធោ ដូច្នេះ ជាពាក្យដ៏ឧត្តមពិត, ពាក្យដទៃ ដែលជាទីនាំមកនូវរសដល់ត្រចៀកអ្នកស្តាប់ ក្នុងលោក ដ៏ស្មើដោយពាក្យថា ពុទ្ធោ ដូច្នេះ ពុំមានឡើយ ។

ធម្មោតិវចនំ សេដ្ឋំ ធម្មោតិវចនុត្តមំ
នត្ថិ តេន សមំ លោកេ អញ្ញំ សោតរសាយនំ ។

សេចក្តីថា ពាក្យពោលថា ធម្មោ ដូច្នេះ ជាពាក្យដ៏ប្រសើរវិសេស . . ., ជាពាក្យដ៏ឧត្តម ពាក្យដទៃដែលជាទីនាំមកនូវរសដល់ត្រចៀកនៃអ្នកស្តាប់ក្នុងលោក ដ៏ស្មើដោយពាក្យថា ធម្មោ ដូច្នេះពុំមានឡើយ ។

សង្ឃោតិវចនំ សេដ្ឋំ សង្ឃោតិវចនុត្តមំ
នត្ថិ តេន សមំ លោកេ អញ្ញំ សោតរសាយនំ ។

សេចក្តីថា ពាក្យពោលថា សង្ឃោ ដូច្នេះ ជាពាក្យដ៏ប្រសើរដោយវិសេស . . ., ជាពាក្យដ៏ឧត្តមពិត, ពាក្យដទៃដែលជាទីនាំមកនូវរសដល់ត្រចៀកនៃអ្នកស្តាប់ក្នុងលោក ដ៏ស្មើដោយពាក្យថា សង្ឃោ ដូច្នេះ ពុំមានឡើយ ។

តស្ស មុខំ មុខំ ជាត យំ វត្តតិ មុខេ សទា

ទុល្លភំ ពុទ្ធវចនំ សព្វសម្បត្តិទាយកំ
តស្ស មនោ មនោ នាម យស្ស មនសិ វត្តតិ
ទុល្លភំ ពុទ្ធវចនំ សព្វសម្បត្តិទាយកំ ។

ពាក្យថា ព្រះពុទ្ធជាពាក្យដែលសត្វលោករកបានដោយក្រ អាចឲ្យនូវសម្បត្តិទាំងពួង រមែងប្រព្រឹត្តទៅក្នុងមាត់នៃបុគ្គលណាសព្វកាល, មាត់របស់បុគ្គលនោះបានឈ្មោះថាមាត់ល្អប្រពៃ មាត់មានលាភដោយពិត, ពាក្យពោលថាព្រះពុទ្ធជាពាក្យដែលសត្វលោករកបានដោយក្រ អាចឲ្យនូវសម្បត្តិទាំងពួងរមែងប្រព្រឹត្តទៅក្នុងចិត្តបុគ្គលណាហើយ ចិត្តរបស់បុគ្គលនោះបាន ឈ្មោះថាចិត្តល្អប្រពៃ ចិត្តមានលាភដោយពិត ។

តស្សេវ សោតំ សោតញ្ញា យំ សុណាតិ ជិនោ(១) អយំ
ទុល្លភំ ពុទ្ធវចនំ សព្វសម្បត្តិទាយកំ

សេចក្តីថា បុគ្គលណាបានស្តាប់នូវពាក្យថា ព្រះពុទ្ធជាពាក្យដែលបុគ្គលរកបានដោយក្រ អាចឲ្យនូវសម្បត្តិទាំងពួងដូច្នេះថា: "បុគ្គលនេះជាអង្គព្រះជិនស្រី" សោតប្បសាទរបស់បុគ្គលនោះបានឈ្មោះថា សោតប្បសាទល្អប្រពៃ សោតប្បសាទមានលាភដោយពិត ។

ឯពស់នាគរាជ មានពិសដ៏ក្លៀវក្លាពន្លឹកគ្រប់កាលទាំងពួង លុះបានស្តាប់ពាក្យថា ពុទ្ធោ ដូច្នេះ ក៏ត្រឡប់មានចិត្តត្រេកអរសោមនស្ស

១– យល់ថា (ជនោ) ទើបល្អ ។

វិញ បានឲ្យជីវិតដល់ព្រានពស់ មិនត្រឹមតែឲ្យជីវិតប៉ុណ្ណោះ ថែមទាំងបានឲ្យនូវផ្កាមាសបីកម្រង ក្នុងកម្រងនីមួយៗ មានដំឡៃមួយពាន់ៗ ដល់ព្រានពស់នោះ ដោយអានុភាពផលានិសង្សនៃគាថាដែលខ្លួនពោលថា ពុទ្ធោៗ ដូច្នេះឯង ។

លុះពស់នាគរាជ បានឲ្យផ្កាមាសដល់ព្រានពស់នោះរួចហើយក៏ពោលទៅនឹងព្រានពស់ថា ម្នាលសំឡាញ់មានគុណៈស្មើ! ជំនុំផ្កាមាសទាំងបីកម្រងនេះ អ្នកត្រូវយកមួយកម្រងទៅបូជាព្រះចេតិយ ជាបុណ្យផ្ទាល់ខ្លួនរបស់អ្នកចុះ ត្រូវយកមួយកម្រងទៅបូជាព្រះចេតិយដែរ ដើម្បីជាបុណ្យដល់ខ្ញុំ ត្រូវយកមួយកម្រងទៅលក់យកប្រាក់មកទិញដូរស្បៀងអាហារ ចិញ្ចឹមជីវិតខ្លួននឹងកូនប្រពន្ធជាសុខសប្បាយចុះ, ហើយអ្នកត្រូវកុំប្រមាទប្រហែសធ្វេសក្នុងការជាកុសល មានទានជាដើមឡើយ ត្រូវចិញ្ចឹមជីវិតប្រកបដោយធម៌ ត្រូវលះបង់ចិត្តជាមិច្ឆាទិដ្ឋិឲ្យស្រឡះចេញ ហើយខំខ្វល់ខ្វាយតែក្នុងកុសលកម្មដរាបដល់អស់ជីវិត, លុះពស់នាគរាជបានពោលទូន្មានប្រដៅយ៉ាងនេះ ក៏ចៀសចេញទៅកាន់ជំពូករបស់ខ្លួនតាមធម្មតា ។ ចំណែកឯព្រានពស់ក៏បានដល់នូវសេចក្ដីសោមនស្សជ្រះថ្លា បានបូជាព្រះចេតិយដោយផ្កាមាសពីរកម្រង តាមពាក្យបណ្ដាំរបស់នាគរាជនោះឯង ។

បានយកផ្កាមាសមួយកម្រងដទៃទៀតលក់បានប្រាក់បួនពាន់កហាបណៈ យកមកចិញ្ចឹមជីវិតរបស់ខ្លួនទឹងប្រពន្ធកូនខ្លះ ចំណាយឲ្យទានដល់ជនកំព្រា ជនដើរផ្លូវឆ្ងាយទឹងជនអ្នកសូមទាំងឡាយខ្លះ ហើយលះបង់អំពើដែលធ្វើជាព្រានពស់ចោលចេញជាស្រឡះពុំបានប្រព្រឹត្តធ្វើទៀតឡើយ រមែងសន្សំអំពើជាកុសលកម្មតែម្យ៉ាង, លុះដល់អស់ជីវិតហើយក៏បានទៅកើតក្នុងឋានសួគ៌ទេវលោក សោយនូវទិព្វសម្បត្តិជាសុខក្សេមក្សាន្ត តាំងតែពីកាលនោះមកដរាបដល់កាលឥឡូវនេះហោង ។

ព្រោះហេតុដូច្នោះ ទើបព្រះអរហន្តទាំងឡាយ ពោលជាបទព្រះគាថាដូច្នេះថា ឥតិ អវិទិតសេត្ថោ កិញ្ចិ ឥត្ថានុភាវំ លភតិ ធនវិសេសំ យស្ស នាមព្យាកាសា វិទិតជននិកាយោ កិន្នុ តស្សានុភាវំ ន លភតិ ជិននាមំ កិច្ចមត្របព្យហាយ , សេចក្តីថា សូម្បីសត្វពុំបានដឹងនូវអានុភាពនៃព្រះជាម្ចាស់តិចតួចយ៉ាងនេះសោះ ក៏គង់បាននូវសម្បត្តិដ៏វិសេស គឺផ្កាមាសទាំងបីកម្រងមានតម្លៃមួយពាន់ៗ, ព្រោះបានប្រកាសសម្តែងនូវព្រះនាមនៃព្រះពុទ្ធជាម្ចាស់ទាំងឡាយអន្តណា ឯប្រជុំជនដែលបានដឹងច្បាស់នូវអានុភាពនៃព្រះពុទ្ធជាម្ចាស់អង្គនោះ ទាំងពុំបានលះបង់នូវកិច្ចគឺសេចក្តីសំគាល់នូវព្រះនាមនៃព្រះជិនស្រីផងទៀត ទឹងពុំបាននូវទ្រព្យសម្បត្តិដ៏វិសេសដូចម្តេចបាន មុខជាទឹងបាននូវទ្រព្យសម្បត្តិ

ដ៏វិសេសក្រៃលែងជាងនេះដោយពិត ។

សម្ដែងរឿងនិទានព្រានពស់ ជាតំរប់ប្រាំក្នុងវគ្គទីមួយ ក៏ចប់សេចក្ដីជាសង្ខេបតែប៉ុណ្ណេះឯង ។

៦–សរណត្ថេរវត្ថុ សម្ដែងរឿងនិទានសរណត្ថេរតទៅទៀតដោយបទបាលីថា: សាវត្ថិយំ កិរ សុមនោ នាមេកោ គហបតិកោ អហោសិ ដូច្នេះជាដើម ប្រែថា: សេចក្ដីថា កិរ ដូចបានឮរឿងៗមកថា: មានគហបតីម្នាក់ឈ្មោះសុមនៈ នៅអាស្រ័យក្នុងក្រុងសាវត្ថី ។ ភរិយារបស់គហបតីនោះឈ្មោះនាងសុជម្បកា ជនទាំងពីរនាក់នោះក៏បាននៅគ្រប់គ្រងផ្ទះតាមធម្មតា លុះក្នុងយូរទៅក៏បានកូនប្រុសមួយ ស្រីមួយ ឯកូនទាំងពីរនោះពុំទាន់បានធំដឹងក្ដីគ្រប់គ្រាន់នៅឡើយ, ស្រាប់តែសុមនគហបតីនិងនាងសុជម្បកាជាមាតាបិតាមានជម្ងឺឈឺជាទម្ងន់ ក៏បានហៅកូនប្រុសច្បងឲ្យចូលមកហើយនិយាយផ្ដាំថា ម្នាលបាអើយ! យើងមានជម្ងឺឈឺនេះជាទម្ងន់ពន់ពេកណាស់ មិនអាចនឹងរស់នៅយឺនយូរ ដើម្បីនឹងរៀបចំទុកដាក់អ្នកឲ្យមានផ្ទះសម្បែងគ្រួសារដ៏សមគួរបានឡើយ សម្បត្តិទ្រព្យរបស់យើងដែលមានក្នុងផ្ទះនេះទាំងប៉ុន្មាន ត្រូវបាជាបងទទួលយកគ្រប់គ្រងរក្សាទុកចុះ, លុះថ្ងៃជាខាងក្រោយ បើប្អូនស្រីរបស់អ្នកចំរើនវ័យវឌ្ឍនាការធំឡើងហើយ ត្រូវអ្នកទទួលភារៈរៀបចំទុកដាក់ឲ្យមានប្ដី

ចែកទ្រព្យរបស់ឲ្យល្មមសមគួរផងចុះ លុះបានធំយ៉ាងនេះហើយក៏ប្រគល់កូនស្រីជាប្អូនដល់កូនប្រុសច្បងនោះឲ្យថែទាំរក្សា ហើយក៏ធ្វើមរណកាលក្សីណក្ស័យជីវិតទៅក្នុងកាលនោះឯង ។

គ្រានោះកូនប្រុសជាច្បងបានចាត់ចែងធ្វើឈាបនកិច្ចបូជាសពមាតាបិតារបស់ខ្លួនស្រេចហើយ ក៏នៅគ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់នោះជាសុខសប្បាយ, លុះកន្លងកាលយូរទៅក៏បានចងសម្ពន្ធមិត្តមេត្រីនឹងពួកញាតិ បានរៀបចំប្អូនស្រីរបស់ខ្លួនឲ្យមានប្ដីក្នុងត្រកូលដ៏សមគួរ ហើយចែកទ្រព្យសម្បត្តិឲ្យតាមបណ្ដាំរួចហើយបញ្ជូនប្អូនស្រីនោះឲ្យទៅនៅជាមួយនឹងត្រកូលប្ដី, ឯខ្លួនឯងសោត ក៏បានគ្រប់គ្រងផ្ទះសម្បែងចិញ្ចឹមគ្រួសារដោយសុវត្ថិភាពដែរ ។

លុះចំណេរមកកាលជាខាងក្រោយ, ប្អូនស្រីនោះមានគភ៌ជាដំបូង, និមិត្តតែគភ៌ចាស់ខែហើយ មានថ្ងៃមួយក៏បាននិយាយទៅនឹងស្វាមីរបស់ខ្លួនថា សាមិ បតិត្រូអ្នកជាស្វាមីអើយ! ខ្លួនខ្ញុំមានប្រាថ្នាចង់ទៅឃើញបងរបស់ខ្ញុំ ដ្បិតខ្ញុំមានគភ៌កាន់តែចាស់ខែហើយ នឹងទៅប្រសូតកូនឲ្យជួបជុំបងប្អូនឯណោះ ។

ចំណែកឯបុរសជាស្វាមីក៏ព្រមទទួលតាមថា ម្នាលនាងដ៏ចំរើន! ពាក្យដែលនាងពោលមកនេះ ប្រពៃហើយ ។ ទើបចាត់ចែងគ្រឿងបណ្ណា-

ការដ៏សមគួរ ហើយបណ្ដើរស្វាមីភរិយាដើរចេញពីគេហស្ថានរបស់ខ្លួន សំដៅទៅគេហស្ថានរបស់បងនោះទៅ ។

កាលនោះ ព្រះមានព្រះភាគទ្រង់ស្បៀតដណ្ដប់ចីវរដោយប្រពៃ មានព្រះភិក្ខុសង្ឃច្រើនចោមរោមជាយសបរិវារ ទ្រង់បញ្ចេញនូវរស្មីទាំងប្រាំមួយពណ៌ ដ៏ភ្លឺស្វាងរុងរឿងផ្សាយទៅក្នុងទិសនានា ទ្រង់ពុទ្ធដំណើរចូលទៅកាន់ព្រះនគរដើម្បីបិណ្ឌបាតក្នុងវេលានោះដែរ ។

លំដាប់នោះជនទាំងពីរនាក់ស្វាមីភរិយាបានឃើញព្រះមានព្រះភាគ ហើយក៏មានចិត្តជ្រះថ្លា បានចូលទៅក្រាបថ្វាយបង្គំដោយដំកល់ចុះនូវអង្គទាំងប្រាំ(១) ដោយសេចក្ដីគោរព ហើយស្ថិតនៅក្នុងទីដ៏សមគួរ ។

គ្រានោះព្រះមានព្រះភាគទ្រង់ជ្រាបនូវឧបនិស្ស័យសម្បត្តិនៃជនទាំងពីរនាក់នោះហើយ ក៏ទ្រង់សម្ដែងអនុបុព្វីកថាជាទីសណ្ដាប់នៃជនទាំងនោះ ហើយទ្រង់ញ៉ាំងឲ្យស្ថិតនៅក្នុងសរណគមន៍ និងសីលទាំងប្រាំឲ្យខ្ជាប់ខ្ជួនមាំមួនហើយទ្រង់ត្រាស់ថា, ម្នាលអ្នកទាំងឡាយ ! កាលបើសេចក្ដីទុក្ខលំបាកកើតឡើង ដល់អ្នកពល់គ្នាក្នុងកាលណាមួយ ត្រូវនាំគ្នានឹករឭកដល់ព្រះតថាគតចុះ សេចក្ដីទុក្ខលំបាកនោះនឹងវិនាសបាត់ទៅៗ

១-ពប់យកកែងដៃទាំងសងខាង ក្បាលជង្គង់ទាំងសងខាង និងត្បូងសិរសាមួយរួមជា ៥ ក្រាបផ្ទាល់កន្ទេលឬផ្ទាល់ដីត្រង់ទីនោះ ៗ ។

ព្រោះហេតុនោះ ទើបព្រះអរហន្តទាំងឡាយពោលជាបទព្រះគាថាដូច្នេះថា៖

យំ កិញ្ចិ ភយមុប្បន្នំ រាជចោរាទិសម្ភវំ

តទា សរេយ្យ សម្ពុទ្ធំ និច្ចល្តោ តទុបទ្ទវំ ។

សេចក្តីថា ភ័យណាទីមួយដែលកើតឡើងហើយ គឺកើតឡើងអំពីស្តេចនិងចោរជាដើម ក្នុងកាលណា បុគ្គលមានប្រាជ្ញាមិនចង់ឲ្យភ័យឧបទ្រពចង្រៃទាំងនោះកើតឡើងបាន ត្រូវនឹករឭកនូវអង្គព្រះសម្មាសម្ពុទ្ធ ក្នុងកាលនោះឯង ។

សចេ ឧបទ្ទវ ហោតិ យក្ខបេតាទិសម្ភវំ

តទា សរេយ្យ សម្ពុទ្ធំ និច្ចល្តោ តទុបទ្ទវំ ។

សេចក្តីថា បើសេចក្តីចង្រៃឧបទ្រពដែលកើតឡើង គឺកើតឡើងអំពីយក្ខនិងប្រេតជាដើម ក្នុងកាលណា, បុគ្គលមានប្រាជ្ញាមិនចង់ឲ្យមានឧបទ្រពចង្រៃទាំងនោះកើតឡើងបាន ត្រូវនឹករឭកនូវអង្គព្រះសម្មាសម្ពុទ្ធ ក្នុងកាលនោះឯង ។

យំបិ សីហាទិព្យគ្ឃាទិ បុណ្ណារកាទិសម្ភវំ

តទា សរេយ្យ សម្ពុទ្ធំ និច្ចល្តោ តទុបទ្ទវំ ។

សេចក្តីថា បើភ័យឧបទ្រពណា ដែលកើតឡើង គឺកើតឡើងអំពីសត្វសាហាវ មានសត្វសីហខ្លាធំខ្លាដម្បង៍ជាដើម ក្នុងកាល

ណា បុគ្គលមានប្រាជ្ញាមិនចង់ឲ្យមានសេចក្ដីភ័យឧបទ្រពចង្រៃទាំងនោះកើតឡើងបាន ត្រូវនឹករឭកនូវអង្គព្រះសម្មាសម្ពុទ្ធក្នុងកាលនោះឯង ។

សុវាតាតបគ្គិកត– ឧទកាសនិសម្ភវំ
តទា សរេយ្យ សម្ពុទ្ធំ ឆិន្ទន្តោ តទុបទ្ទវំ ។

សេចក្ដីថា ភ័យឧបទ្រពចង្រៃណាដែលកើតឡើង គឺកើតឡើងអំពីភ្លើងព្រៃ ពពកកាច កំដៅថ្ងៃ ភ្លើង ខ្យល់ព្យុះ ទឹកជន់ នឹងរន្ទះផ្គរជាដើម ក្នុងកាលណា បុគ្គលមានប្រាជ្ញាមិនចង់ឲ្យមានភ័យឧបទ្រពចង្រៃទាំងនោះកើតឡើងបាន ត្រូវនឹករឭកនូវអង្គព្រះសម្មាសម្ពុទ្ធក្នុងកាលនោះឯង ។

បជ្ជុកទីហិ រោគេហិ វិសយោគ្គកិសម្ភវំ
តទា សរេយ្យ សម្ពុទ្ធំ ឆិន្ទន្តោ តទុបទ្ទវំ ។

សេចក្ដីថា ភ័យឧបទ្រពចង្រៃណាដែលកើតឡើងអំពីរោគទាំងឡាយ មានរោគចុះផ្ទៃយ៉ាងខ្លាំងជាដើម នឹងរោគកើតអំពីថ្នាំពុល ក្នុងកាលណា, បុគ្គលមានប្រាជ្ញាមិនចង់ឲ្យមានសេចក្ដីភ័យឧបទ្រពចង្រៃទាំងនោះកើតឡើងបាន ត្រូវនឹករឭកនូវអង្គព្រះសម្មាសម្ពុទ្ធក្នុងកាលនោះឯង ។

អត្តគោធ យថា យុទ្ធំ ការោន្តេ ហិ ជន្តុនា
សរិតព្វោ តទា ពុទ្ធោ បត្ថេន្តេនត្តនោ ជយំ

សេចក្ដីថា បើភ័យគឺចម្បាំងតយុទ្ធដោយសត្រូវតបដល់ខ្លួនដែល

កើតឡើងក្នុងកាលណា ព្រះពុទ្ធគុណដែលសប្បុរសអ្នកធ្វើបម្រុងមានប្រាថ្នានូវជ័យជំនះដល់ខ្លួន ត្រូវតែនឹករឭកថា "ពុទ្ធោ ៗ" ក្នុងកាលនោះឯង រមែងអាចផ្ចាញ់នូវសត្រូវតបដល់ខ្លួននោះបានដោយពិត ។

លំដាប់នោះ ជនទាំងពីរនាក់ស្វាមីភរិយាក៏បានទទួលដោយរីករាយនូវព្រះពុទ្ធដីកានៃព្រះមានព្រះភាគហើយ ថ្វាយបង្គំលាដើរចេញទៅតាមផ្លូវ សំដៅទៅកាន់ស្រុករបស់បងថ្លៃខ្លួននោះឯង ។

កាលនោះ បងប្រុសជាធំ បានឃើញជនទាំងពីរនាក់មកដល់ហើយ ក៏បានធ្វើបដិសណ្ឋារៈដ៏សមគួរដល់ប្អូនថ្លៃនឹងប្អូនស្រីរបស់ខ្លួនតាមសមគួរដល់សេចក្ដីរឭក ចំណែកឯប្អូនថ្លៃនោះ បាននៅអាស្រ័យក្នុងគេហស្ថានរបស់បងបានពីរបីថ្ងៃ ហើយក៏ប្រគល់ភរិយារបស់ខ្លួនឲ្យបងប្រុសថែទាំរក្សាទុក ហើយនិយាយផ្ញើផ្ដាំថា ខ្ញុំមានកិច្ចរវល់ច្រើនក្នុងស្រុកឯណោះ មិនត្រាំនៅយូរពុំបានឡើយ លុះចប់ពាក្យហើយ ក៏លាបងថ្លៃត្រឡប់ទៅកាន់ស្រុកខ្លួនវិញក្នុងកាលនោះហោង ។

គ្រានោះ បងប្រុសបានហៅភរិយារបស់ខ្លួនមក ហើយនិយាយបង្គាប់បញ្ជាថា ម្នាលនាងដ៏ចំរើន ! ត្រូវនាងធ្វើនូវកិច្ចទាំងពួងដល់ប្អូនស្រីរបស់យើងផង កុំប្រហែសធ្វេសឡើយ ។

(នៅមានត)

## មហោសថជាតក

(តមក)

លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស កឹម-តួរ ពិនិត្យ

---

ក្សណនោះ រាជទូត នាំពត៌មានទៅទូលព្រះបាទវិទេហរាជនោះ ទើបស្ដេចផ្ដាំងថា ម្នាលអាចារ្យសេនកអើយ! ឥឡូវនេះ តើយើងនឹងឲ្យទៅយកចៅអ្នកប្រាជ្ញនោះមកឬម្ដេច ? អាចារ្យសេនកទូលថា បពិត្រមហារាជអើយ! នាប៊ីពិចារណាតែត្រឹមបញ្ហាគោជ្លួះនេះ លោកមិនពប់ហៅថាអ្នកប្រាជ្ញឡើយ ចូរអម្ចាស់ស្ងៀមឈប់ក្សណហោង ៗ ព្រះបាទវិទេហ-រាជសោត ស្ដេចគង់ស្ងៀមនៅ ហើយស្ដេចឲ្យនាំពត៌មានទៅឲ្យរាជ-អាមាត្យនោះវិញទៀតហោង ៗ ឯវំ រីអំពើនេះ បណ្ឌិតោ គឺអ្នកប្រាជ្ញ វេទិតព្វំ គប្បីដឹង សព្វវិជាឯ ពួងវិធីទាំងពួង ៗ បពិត្រអើយ! ចាប់ដើមដំណើរទុំពីកាលថ្ងៃសំដែងល្បងគោនោះមិញបប់ស្រេចហើយហោង ៗ

គច្ចិត វិនិស្រដ៏ល្បងសង្ហារ ៗ ឯកោ បង ឧក្កត្ថី

ឆាឆាវណ្ណោហិ សុត្តោហិ . . . បពិត្រអើយ!

កាលនោះ មានស្ត្រីម្នាក់ ជាអ្នកកំសត់ទុគ៌ត មានចំណង់នឹងបង់

ប្រដាប់ប្រដាអាត្មា យកអម្បោះមកចងជាសង្វារ បណ្ដាលដ៏មានពណ៌នោះល្អផ្សេងៗស្រេចហើយ មេនោះពាក់ដើរទៅដើរមក ប្រយោជន៍នឹងទៅងូតទឹកស្រះបោក្ខរណីនៃព្រះមហោសថអ្នកប្រាជ្ញ កាលបើទៅដល់ស្រះបោក្ខរណីនោះហើយ ក៏ផ្លាស់សំពត់ពីបង្កើះ ដោះសង្វារអំពីកមកដាក់លើសំពត់ហើយ មេស្រីនោះឯង ចុះទៅងូតទឹកស្រះបោក្ខរណីនោះប្រយោជន៍ដើម្បីនឹងបន្ទោងនូវញើសក្អែល ។ អបរា តរុណិត្ថី តំ ទិស្វា លោភំ ។ល។ បក្កាមិ កាលនោះ មានមេស្រីដទៃក្រមុំម្នាក់ មកអំពីទីណាក៏ពុំដឹងឡើយ នៅមាត់ស្រះ មេស្រីនោះឯងយល់សង្វារហើយ ក៏បង្កើតចិត្តលោភចង់បានសង្វារនោះ ហើយស្រដីទៅនឹងមេស្រីជាម្ចាស់ ៗ ស្រីជាម្ចាស់សង្វារស្ដាប់ហើយថា សំឡាញ់អើយ អញធ្វើខ្លួនឯងទេ មេស្រីកំណាចនោះថា សំឡាញ់អើយ សុំមើលបន្តិចបានទេហះ? ។ ឯមេម្ចាស់សង្វារថា អញកំណាញ់អ្វី ចូរសំឡាញ់មើលហោង ម្ល៉ោះហើយកូវ មេស្រីកំណាចនោះយកសង្វារមកពាក់នៅកល្អហើយ យល់ម្ចាស់សង្វារក្រវើនតែងូតទឹកពុំបានចាប់ភ្នែកមើលមើលខ្លួន មេកំណាចនោះនាំតែយកសង្វារនោះដើរព្រងើយទៅ ៗ ឯមេម្ចាស់សង្វារនោះ ចាប់ភ្នែកលើកដល់សង្វារ យល់មេកំណាចនាំពង្រត់យកទៅដូច្នោះកូវ ឧត្តរិត្វា ក៏ឡើងអំពីស្រះបោក្ខរណីមួយរំពេចនោះ

ហើយផ្លាស់សំពត់, ឧបជាវិត្ថា ក៏រត់ទៅតាមទាន់ហើយចាប់ជាយ
សំពត់មេកំណាចនោះខ្ជាប់ ហើយស្រដីថា ហន៎ឯងនាំពង្រត់យកសង្ហារ
អញទៅឯណា? ។ ឯមេស្រីកំណាចនោះស្តាប់ហើយឆ្លើយគម្រាមតាំង
បំពានទៅថា យើ ៗ មេនេះ មកអំពីឯណាលលាក់លលើអ្វីមាល្បាយ៉ាះ
សង្ហារនេះ អញប្រដាប់ប្រដាតែនាំអំពីផ្ទះឋានលំនៅអញឯង របស់អញ
ស្រឡាញ់ អញទៅឯណា។ អញពុំដែលឃ្លាតអំពីខ្លួនអញឡើយ ។ រីមេ
តាំង ២ ក៏បង្កើតនូវពាក្យជំលោះឈ្លោះប្រកែកជជែកគ្នាវៀងកបងកបទៅ
ហោង ៗ អថ បណ្ឌិតោបិ ធារគោឃាំ សទ្ធិ . . . .
កាលនោះ មេស្រីតាំង ២ ទៅទៀបទ្វារសាលា ៗ ពោធិសត្វគង់ពុំលេង
មួយអន្ទើនឹងក្មេងតាំង ១ ០០០ ចោមរោមជាបរិវារ កាលបើឮមេតាំង ២
បង្កើតនូវពាក្យជំលោះឈ្លោះប្រកែកជាហេតុកេទនឹងគ្នាហើយ ពោធិសត្វ
មហាបុរសត្រាស់ទៅវិសេសប្រាប់ហើយ ឲ្យហៅមេតាំង ២ នោះចូលមកដណ្តឹង
នូវអាថ៌ជំលោះប្រកែកនោះ ព្រះអង្គជ្រាបហើយថា មេនេះឯងជាចោរ មេ
នេះឯងជាម្ចាស់សង្ហារ តែព្រះអង្គទ្រង់ចង់យល់ឲ្យអស់ចិត្តអ្នកផងបានដឹង
ទើបព្រះអង្គមានព្រះបន្ទូលដណ្តឹងថា នែអ្នកទាំងសងខាង ! បើដូច្នោះ
នាងថិតដោយនូវបង្គាប់អញឬម្តេច ? មេតាំង ២ ស្តាប់ព្រះឱស្ឋពោធិសត្វ
ហើយឆ្លើយថា យើងខ្ញុំថិតដោយនូវបង្គាប់អម្ចាស់ហោង ៗ បដមំ

ចោរី បុច្ឆិ ។ ពោធិសត្វមហាបុរសរ័តន៍ អ្នកដណ្ដឹងទៅមេចោរនេះ ឯងជាមុនថា នៃមេអើយ! នាសង្ការមេះនោះ តើមេតែងទិងអប់នូវក្លិនគន្ធពិដោរអ្វីៗ មេចោរកំណាចស្ដាប់ព្រះបន្ទូលពោធិសត្វហើយឆ្លើយថា បពិត្រអម្ចាស់អើយ! ខ្ញុំតែងទិងអប់នូវគន្ធពិដោរផងតាំងពួងជាដើម គឺក្របេះចួងចន្ទន៍គ្រឿងក្រអូបជាប្រក្រតីៗ ពោធិសត្វជ្រាបហើយ ឲ្យកត់សំគាល់ពាក្យនោះទុកៗ

តតោ ឥតរំ បុច្ឆិ ។ លំដាប់នោះពោធិសត្វអ្នកដណ្ដឹងនូវមេម្ចាស់សង្ការនោះវិញ សា អាហ កុតោ មយ្ហំ ទុគ្គតាយ សព្វ-សោ ហារិកា អត្ថិ ។ រីមេស្រីម្ចាស់សង្ការ ហេតុតែជាអ្នកលំបាកកំសត់ទុគ៌ត ស្ដាប់ព្រះឱស្ឋព្រះមហោសថហើយទូលពោធិសត្វថា បពិត្រអម្ចាស់អើយ ខ្ញុំទិងបានអំពីឯណា នូវក្របេះចួងចន្ទន៍គ្រឿងក្រអូបនោះ ខ្ញុំជាអ្នកលំបាកកំសត់ទុគ៌ត សព្វថ្ងៃអាស្រ័យយកតែផ្កាប្រយង្គុ នូវផ្កាយុក្កាអប់សព្វថ្ងៃជាប្រក្រតីនោះហោង ៗ បណ្ឌិតោ តាសំ វចនំ តាហាបេត្វា ឧធកាចាដិ . . . បពិត្រអើយ រីព្រះមហោសថបណ្ឌិតអ្នកប្រាជ្ញ ស្ដាប់ពាក្យមេទាំង ២ នោះហើយ ពោធិសត្វឲ្យយកភាជន៍មាសមកដាក់បំពេញនូវទឹកស្រេចហើយ ស្ដេចឲ្យហៅអ្នកជាងតែងហោះនូវក្លិនគន្ធពិដោរមកហើយ ស្ដេចឲ្យពិចារណានូវក្លិនសង្ការ មាន

ព្រះបន្ទូលថា ចូរជាងមើលក្អិននេះ តើជាក្អិនក្របេះបួនចន្ទន៍គ្រឿងក្រអូប ឬ អច់ក្អិនប្រយង្គុយុក្កាទេហ៎ះ ៗ ជាងស្តាប់ព្រះបន្ទូលព្រះមហោសថបណ្ឌិតអ្នកប្រាជ្ញហើយ ពិចារណាក្អិនសង្ការ មិនធុំក្អិនក្របេះបួនចន្ទន៍គ្រឿងក្រអូបឡើយ សភាពត្រឡប់ធុំតែក្អិនប្រយង្គុយុក្កានោះជាប្រាកដ ហើយជាងទូលពោធិសត្វវិញថា បពិត្រព្រះមហោសថបណ្ឌិតអើយ សង្ការនេះមិនធុំក្អិនក្របេះបួនចន្ទន៍គ្រឿងក្រអូបនោះឡើយ ត្រឡប់ធុំតែក្អិនប្រយង្គុយុក្កាប្រាកដហោង ៗ

អថ មហាសត្តោ តំ ការណំ មហាជនំ ជានាបេត្វា តំ ចោរំ សីតិ បុច្ឆិត្វា ចោរភាវំ បដិជានាបេសិ ៗ ពោធិសត្វមហាបុរសរតនវិសេសជ្រាបនូវគាថិសេចក្តីនោះហើយ មានព្រះបន្ទូលដណ្តឹងទៅមេស្រីលួចសង្ការថា ម្នាលមេអើយ! មេឯងថាជាម្ចាស់សង្ការអប់ក្របេះបួនចន្ទន៍គ្រឿងក្រអូប ឥឡូវនេះ មិនធុំក្អិនក្របេះបួនចន្ទន៍គ្រឿងអូបឡើយ ធុំតែក្អិនផ្កាយុក្កាប្រយង្គុវិញ បើដូច្នេះហើយមេឯងជាចោរលួចសង្ការគេពិតហើយ ៗ មេកំណាចស្តាប់ព្រះបន្ទូលពោធិសត្វហើយ ពុំអាចដើម្បីទងលាក់ខ្លួននោះបានឡើយ ក៏លន់តួទោសប្រាប់ពោធិសត្វថា សាមិ បពិត្រព្រះមហោសថបណ្ឌិតម្ចាស់អើយ ! ខ្ញុំជាចោរលួចសង្ការគេមែនពិតហោង ៗ ឥតោ បដ្ឋាយ

មហាសត្តស្ស បណ្ណាឝកាកេ មហាជនស្ស ឆាតកោ ជាតោ ។ បពិត្រអើយ! ចាប់ដើមអំពីនេះទៅ អស់អ្នកផងទាំងពួងគេដឹងជាក់ប្រាកដថាព្រះមហោសថជាអ្នកប្រាជ្ញហោង ទើបព្រះពោធិសត្វប្រដៅឲ្យទៅទងដំបូន្មានមេស្រីលួចសង្វារនោះថា នែមេកាយ! មេកុំធ្វើអំពើជាចោរលួចគេឡើយ នាលោកិយនេះ មេនឹងខ្មាសគេ ដល់បរ-លោកនាយ មេនឹងទៅរងទុក្ខវេទនាក្នុងនរកនាយហោង ។ បពិត្រអើយ! រីរាជអាមាត្យដែលព្រះមហាក្សត្រឲ្យទៅឃ្លាំចាំមើលពោធិសត្វនោះ ក៏យល់ពោធិសត្វជំនុំពិចារណាកាត់សេចក្តីមេស្រីទាំង ២ នោះប្រាកដជាចោរ ជាម្ចាស់សង្វារហើយ ក៏ប្រើរាជទូតឲ្យនាំពត៌មានជាដំណើរទៅទូលស្តេចៗ រីរាជទូតស្រួតរូតទៅទូលដោយដំណើរនេះៗ រីព្រះមហាក្សត្រជ្រាបហើយមានព្រះហឫទ័យនោះត្រេកអរនូវអំណរនោះ ហើយមានព្រះបន្ទូលទៅហើយហៅទៅកាន់អាចារ្យសេនកថា សេនក ម្នាលអាចារ្យសេនកអើយ! ឥឡូវនេះ រាជអាមាត្យឲ្យរាជទូតស្រួតរូតមកប្រាប់អញថា មហោសថកូនសិរីវឌ្ឍកសេដ្ឋីមានប្រាជ្ញាចេះជំនុំសេចក្តីមេស្រីទាំង ២ នាក់លួចសង្វារគ្នាជាក់ច្បាស់ប្រាកដជាចោរ ជាម្ចាស់សង្វារ បើដូច្នោះតើយើងនឹងឲ្យទៅនាំយកមហោសថនោះមកដាក់ទុកជាអ្នកប្រាជ្ញឬម្តេច? អាចារ្យសេនកស្តាប់ហើយ ហេតុតែខ្លួនជាអ្នកលោភកំណាញ់ខសលាភសក្ការៈ ក៏

ទូលទាស់ព្រះមហាក្សត្រថា បពិត្រព្រះមហារាជ! មហោសថបុត្រសិរិវឌ្ឍកសេដ្ឋីនោះ ចេះតែពិចារណាសេចក្តីប៉ុណ្ណោះ មហារាជអើយ មិនគប់ហៅថាជាអ្នកប្រាជ្ញឡើយ បើទ្រង់សព្វព្រះរាជហឫទ័យនឹងមហោសថរីឯសព្វអ្នកស្រៅទៅក្រុមសភាមិនមានប្រាជ្ញាចេះដំទុក្តិ អ្នកផងទាំងឡាយយកមកដាក់ទុកជាអ្នកប្រាជ្ញអស់ហោង, មហាក្សត្រស្តាប់ពាក្យសេនកហើយស្តេចមានព្រះបន្ទូលផ្តាំរាជទូតដែលអាមាត្យប្រើមកថា ម្នាលរាជទូតអើយ! ចូរទៅទៅប្រាប់រាជទូតអាមាត្យឲ្យចាំឃ្លាំមើលមហោសថទៀត បើយល់ហេតុនោះត្រកាលហើយ សឹមព្រះស្តេចមកប្រាប់អញវិញហោងៗ

សុត្តន្តិ ទី៤ ស្រដីអំពីការប្រឡងអម្បោះ ៗ ឯកា ឥត្ថី កប្បាស-ខេត្តរក្ខិកា ខេត្តំ រក្ខន្តី តត្ថ បរិសុទ្ធកប្បាសំ គហេត្វា សុខុមសុត្តំ កន្តិត្វា . . . . បពិត្រអើយ! កាលនោះ មានស្ត្រីម្នាក់ជាអ្នកឃ្លាំចម្ការកប្បាស តែងចេះប្រឡេះទូរកប្បាសនោះដ៏ពងសល្អហើយ រើសបោះធ្វើចម្ងូរជាសំឡី កន្តិត្វា គឺរវៃ សុខុមសុត្តំ នូវអម្បោះឆ្មារល្អ ហើយធ្វើជាម្ងូរអម្បោះឆ្មារនោះ ហើយយកកញ្ចើដាក់ក្រោមទន្ទាប់ក្នុងបាតកញ្ចើនោះ ហើយយកម្ងូរអម្បោះដាក់លើក្រោមទន្ទាប់នោះឯង, ឋបេត្វា កណ្ដៀតពួងចំបង្កើះហើយដើរមកកាន់ស្រុកផ្ទះឋានលំនៅ បានយល់ស្រះបោក្ខរណីនៃព្រះពោធិសត្វហើយ

កំដាក់កញ្ចើអម្បោះចុះ ផ្លាស់សំពត់ដាក់នៅលើកញ្ចើនោះ ឱតរិត្វា ចុះទៅងូតទឹកបន្ទោបង់នូវញើសក្លែអាត្មា ៗ អបរា ឥត្ថី តំ ទិស្វា លុទ្ធចិត្តា តាយ តំ គហេត្វា អហោ មធាបំ ....

បពិត្រអើយ! កាលនោះ មានស្រីម្នាក់ដទៃ យល់អម្បោះឆ្មារល្អនោះ ក៏មានចិត្តលោភចង់បាន ហើយស្រដីថា អម្ម ម្នាលសំឡាញ់អើយ! អំបោះនេះ ឆ្មារល្អីមាលព្វាយម៉្លេះ ហើយយកដៃមកស្ទាបកាន់បើកមើលស្រដីថា សំឡាញ់អើយ! សូមមើលបន្តិចហ្ន៎ះ ៗ ឯមេម្ចាស់អម្បោះថា យើ! កុំចង់ដឹងអ្វី, កាលនោះ ម្ចាស់អម្បោះនោះក្រវើនតែងូតទឹករួច មកំណាចនោះយកកញ្ចើកណ្ដៀតនាំពង្រត់ទៅ ៗ សេសំ បុរិម-នយេនេវ វិត្ថារេតព្វំ ៗ បពិត្រអើយ រឿងមហោសថអ្នកប្រាជ្ញ អាចយល់អាថ៌ធម៌អាថ៌សេចក្ដី វិត្ថារេតព្វំ ឲ្យទូលាយឆ្ងាយពិស្ដារ អាចដំនុំពិចារណាអាថ៌សេចក្ដីមេស្រីលួចអម្បោះ នូវមេស្រីម្ចាស់អម្បោះ ហើយមានបន្ទូលផ្ដាំទៅមេស្រីចោរជាមុនថា អើមេកាយ! ថាបើឯងដ៏ជាម្ចាស់អម្បោះ ចុះនៅក្នុងកញ្ចើនោះ តើមដាក់វត្ថុអ្វីខ្លះហ្ន៎ះ? មេកំណាចនោះគិតពិចារណាថា មេអ្នកបម្កាននេះវាមុខជាដាក់គ្រាប់កប្បាស ល្មុះគិតដូច្នោះហើយ ទើបទូលពោធិសត្វថា បពិត្រព្រះមហោសថហើយ ខ្ញុំដាក់គ្រាប់កប្បាស ពោធិសត្វព្រះអង្គ ឲ្យកត់ពាក្យមេស្រីនោះហោង ៗ

(នៅមានត)

# រឿងមរណមាតា

(តមក)

លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រស្លឹករឹត

---

ពួករៀបបន្ថែម ផ្លែឈើសួនឲ្យសើម សួនឲ្យស៊ីតផលា ជាផ្លែមង្ឃុត ល្មុតសេដា ធូរេនត្រា ទទឹមចេកពាន់ ។ ទម្លាប់សាវម៉ាវ បង្គា បង្គៀ គូលេនសិរមាន់ មាក់ដោកមាក់ប្រាង មាក់សាងគ្រាន់ ទ្រមូងសណ្តាន់ មាក់ប៉ែនមាក់ប៉ាត ។ សួនឲ្យផ្លែម្ទេសល័ង ពិនិត្យមើល ជាក់ វិស័យសុខសាង ធ្វើទឹងខ្ទិះដូង រសរួងសំអាត ផ្អែមល្ហុយ មានជាតិ ៩ជាប្អូនចន្ទន៍ ។ ខ្ទិះសួនឲ្យជាផ្កា ចំប៉ីចម្បា រំដួលក្រាន់ ម្លិះលាម្លិះរួត ច្រើនត្រួតច្រើនជាន់ ផ្កាចួងផ្កាច័ន្ទ ស្រឡិតដកម៉ៃ ។ សំណូនចំណី ក្នុកមនុស្សប្រុសស្រី មើលសុខវិស័យ ផ្ទុកជានសព្វ ជន គ្រឿងទេសតម្លៃ សម្បូណ៌ច្រើនក្រៃ ក្លិនក្អុបផ្ទុំកាយ ។ ចំណី ស្រស់ជា សុខសៀមសន្ធ្យា ពាហ៊ុយសាកាយ គ្រាប់ជីសក្លូវ តៅ ហូផ្ទុំកាយ ក្រអៀវកែវក្លាយ រៀបរួចទុកទៅ ។ ឯនាយព្រះក្រាល

ក្រាលចៀមខ្នាល សឹងមាសឆ្អិនឆ្អៅ រៀបតែងចង្កៀង រៀបរៀងទុក
ទៅ ធុជភ្លើងសន្សៅ ពេញចុងពេងរត្ន ៗ ធុជកែវលំផ្លូង ផ្កាលាធុជព្រោង
ធុជព្រោតច្រើនក្តាត់ តោមកែវយោ ភ្លឺថ្លាប្រវាត់ ក្រមពំងប្រយ័ត្ន
រង្គាត់មកទៅ ៗ នាយរៀបបើកដាក់ ពីឃ្លាំងមាសប្រាក់ ផញ្ជូនយក
ទៅ មករៀបមកតាំង ក្នុងពំងនោះក្រូវ កុញ្ញកក្នុងក្រៅ អាងទឹក
គ្រៀបត្រា ៗ សែងទឹកបាក់គ្រុប ទឹកអប់ឈ្មុយឈ្មប់ ហើយទៅបេះផ្កា
បង់ក្នុងទឹកអាង ទឹកពាងបេនា ពេញប្រៀបគ្រៀបត្រា ថិទគ្រប
ទុកទៅ ៗ ឯនាយព្រះចន្ទ គ្រឿងតែងប្រការ ដាក់លើតាំងនៅ រាប់ពាន
រាប់ម៉ឺន រៀបច្រើនទុកទៅ ថ្លាំចិនតាំងថៅ មានខ្សៀដាក់ខាង ៗ ចង្កៀង
ធុជផុត មិនឡេះលត់ ដើរថែប្រុងប្រាង ហើយលើកតាំងទៀប រៀង-
រៀបដាក់ខាង រៀបបំមានយ៉ាង មានបែបចម្លែក ៗ ហើយមានស្លាដិប
ដាក់ឡុងប៉ាក់គ្រឹប ក្បាច់ក្បូរយ៉ាងឯក ថ្កល់ទឹងពានប្រាក់ លើកដាក់
ដោយបែក ដោយពួកចំឡែក រៀបរង់គ្រៀបត្រា ៗ ទើបឯកមន្ត្រី បង្គាប់
សេនីយ រៀបប្រាង្គសុវណ្ណា ឲ្យនាយព្រះក្រាល ចៀមក្រាលលាត
លា ប៉ាំងព្រះសន្ធិយា រស្មីប្រវាត់ ៗ ហើយចងពិតាន រំយោលមាស
មាន ភ្លឺព្រោតច្រើនក្តាត់ នាយវេនចង្កៀង រៀបរៀងសង្កាត់ តោម
កែវប្រវាត់ ពេញប្រាង្គសុវណ្ណា ៗ ធុជភ្លើងភ្លឺព្រោង តែងកែវលំផ្លូង

គោមកែវរយ៉ា កែវឯកច្រើនប្រុះ ក្តីប្រុះផ្កាឈា ហើយច្រើក្នាក់ផ្ការ តាំង
យាមប្រយ័ត្ន ៗ ដោយពួកដោយក្រុម មូលមកជួបជុំ លើកតាំងច្រើនក្តាត់
គ្រឿងកែងរៀបរៀង បង្កៀងប្រាក់ ថ្នាំចិនសង្កាត់ មានខ្សៀសស្រោប ៗ
ស្លាដីបតាំងពាន ថ្កល់ទុកឲ្យមាន កៅអីរៀបស្រោប តាំងពាន់តាំងម៉ឺន
រៀបច្រើនប្រដាប់ រៀបរួចដាក់ផ្គាប់ ដោយជួរសង្កាត់ ៗ ពួកលើក
ឆត្រត្រួ ច្រើនជាន់ច្រើនត្រួត បោះទ្រប់កដវិត ផើងផ្ការៀបខាង ថែប
យ៉ាំងល្អក្តាត់ ខ្ទះយករូបសត្វ ទៅរៀបឯក្នុ ៗ ឯកំពូលលើ ដែលឲ្យ
ជាងធ្វើ ជាប្រាង្គសុខសម នោះនាយកម្រាល ទៅក្រាលបៀមចំ
រំយោលរំយំ គោមកែវច្រើនក្តាត់ ៗ អុជភ្លើងព្រោងព្រាត ប្រដូច
ប្រាសាទ សួគ៌ឋានតុសិត បើយប់ក្តីឆ្ងាយ ដូចផ្កាយប្រកិត ឆត្រត្រួត
កដវិត ហែជុំត្រៀបត្រា ៗ បណ្តើរទៀនក្នុ គីគ្នាជួបជុំ កន្ទេល
ក្រាលណា ចុះចប់ដល់ដី ដោយទីមាគ៌ា គោមកែវត្រៀបត្រា តាមផ្លូវ
ក្នុងនុះ ៗ អុជភ្លើងច្រើនក្រៃ តាំងយប់តាំងថ្ងៃ ភ្លឺព្រោងព្រាតប្រុះ
ព្រាតព្រេងដូចផ្កាយ ភ្លឺសាយផ្លាស់ផ្ទុះ បង្កៀងច្រើនប្រុះ ឥតឯ
ឥណានា ៗ ឯទីដើងក្នុ មានស្រះពេញជុំ ដាំឈូកសឹងផ្កា រុងរឿង
ខ្ទាបេ សុប្រាណបុប្ផា មហោមហា ហែបហែលសប្បាយ ៗ គាំជ្រូបខ្ទា
ភ្ញៀវទៀនផើងផ្កា គុហារៀងរាយ ភ្ញីសែមនាគព័ន្ធ ច្រើនជាន់ភ្ញីក្លាយ

គ្រាប់កែវដូចផ្កាយ ល្អល្អះចំឡែក ៗ ផ្តោបណ្តើរកូន មករនាគល្អូន
ជណ្តើមកែវបែក ជាកែវផ្កាយព្រឹក ពន្លឺកក្លុះពេក ហើយមានសំវែក
សត្វសត្វព្វាយ ៗ ចូលផ្ទៃទៅប្រាង្គ តាំងតុសង់ខាង តាមផ្លូវរៀង
រាយ គ្រឿងតាំងល្អពេក ចម្លែកឆើតឆាយ ក្លុះផ្លុកសប្បាយ ឥត
ឯតណានា ៗ ហើយនាយប្រើពល ប្រយ័ត្នខ្វាយខ្វល់ ចាំយាមរក្សា
រៀបរួចឡើងទៅ គាល់ហៅក្សត្រា ក្រាបទូលប្រការ សព្វគ្រប់
សេចក្តី ៗ ព្រះបាទបពិត្រ ឆិកជ័រឆ័រវង្ស ចមទៅបូរី ប្រាថសព្វប្រការ
ក្សត្រាធិបតី ត្រាស់ប្រើមន្ត្រី សម្រេចរាជការ ៗ ឲ្យរើសនារី កុមា
រិកាបុត្រី នូវរាជកញ្ញា នូវកូនសេដ្ឋី មន្ត្រីបណ្តា សុខសីងកញ្ញា រូបរាង
ឆើតឆាយ ៗ ឲ្យស្អាងអាត្មា ដង្ហែធីតា ឡើងប្រាង្គពណ្ណរាយ មាន
ផ្លូវជន្ត្រី កើរសព្វសាយ រៀបយានសិវិកាយ សម្រាប់ធីតា ៗ
រើសពួកពាហាន សេនាឲ្យមាន គ្រប់សាសន៍ភាសា ហើយក្សត្រ
ក្សេមក្សាន្ត មានព្រះឧង្ការ ត្រាស់ប្រើបណ្តា ជំពាវខុនណាង ៗ ឲ្យ
យកគ្រឿងឯក គ្រឿងអភិសេក ឲ្យគ្រប់ទៅស្អាង មរណមាតា
ស្អាងស្អាតរូបរាង រួចហើយហែនាង ឡើងប្រាង្គសុវណ្ណា ៗ ឯកអគ្គ
មន្ត្រី សម្រាប់ផែនដី ទទួលឧង្ការ ទៅត្រួតគ្រប់ក្រុម ជួបជុំភ្នាក់ងារ
ហើយរៀបយោធា រហ័តពលស្តាំឆ្វេង ៗ រើសរៀបធីតា ឲ្យឯក

ក្សត្រា នារីក្មេងៗ រើសកូនមន្ត្រី សេដ្ឋីរៀបផ្សេង កូនព្រាហ្មណ៍ ស្ដាំឆ្វេង រៀបរង់ចាំ ៗ ខុនណាងចាស់ៗ អករ៍យាយហែស នៅស្រីស្រឹង្គារ នាំគ្រឿងទៅដល់ មណ្ឌលកុមារិកា អញ្ជើញធីតា ចេញស្រង់ទឹកអប់ ៗ ខ្ទះដុសកាយា ខ្ទះខាត់កក្រា ម៉ែតខ្ទិ លាបលុប រួចយកគ្រឿងទេស វិសេសមកអប់ មកឲ្យនាងលុប នាងលាបកាយា ៗ ស្រេចទ្រង់ព្រះពស្ត្រ ប្រពៃស្រេចស្រស់ ប៉ាក់ធ្លាក់ចេនា ខ្សែសយលួសមាស ទុកាសផុសផ្កា ទ្រង់ស្បៃក្រសា សង្វារកងកាយ ៗ មកុដរ័ត្នថ្លាថ្លៃ កន្ទុតកែវថ្លៃ កណ្ឋល ពិតាយ ព្រះករពីរទ្រង់ ទំរង់កុំសាយ ដាំត្បូងពព្រាយ ពព្រោង ល្អអ្រះ ៗ លុះស្អាងគ្រប់គ្រឿង ភ្លឺផ្លេករុងរឿង ដួងកក្រុគ្រប់ ដូចចន្ទបូណ៌មី ស្មើប្រឡះ ស្រ.បុតអគ្គ: អគ្គល្អាសល្អន់ ៗ ទ្រង់ គោមពារ ដូចទេពអប្សរ ចុះពាកពីមេ· ណ្ឌលទីផែនដី ប្រិមប្រិយ ល្អលន់ ល្អលើសជាតិជន ជាតិខត្តិយា ៗ សូរ្យសាយណ្ហ រសៀល តាមទេរ ទៀបទីបច្ឆិមា មន្ត្រីធំតូច រៀបរួចយាត្រា នាំអស់សេនា តាមហែទាំងឡាយ ៗ ឡើងទូលក្សត្រក្សត្ត ស្ដេចជ្រាបហើយទាន្ទ ព្រះទ័យសប្បាយ ត្រាស់ប្រើឲ្យហៅ ស្នំនៅអករ៍យាយ ហែនាងនោម ឆាយ ឡើងប្រាង្គប្រញាប់ ៗ អករ៍យាយខុនណាង ស្រឹង្គារស្អិតស្អាង

រូបឆោមចំណាប់ អញ្ចើញធីតា កុមារិកាគួរគាប់ គង់យានសម្រាប់ ដង្ហែ
ចេញទៅ ៗ ភ្លេងសៀមភ្លេងជ្វា ភ្លេងមនលង្កា ភ្លេងខ្មែរទ័ត្យ នៅ
ភ្លេងចិនផ្កាពាំង ពួរខ្លាំងនៃក្រែក្រៅ ភ្លេងខែកហែទៅ មានីលគួឡា ៗ
ហែមុខទាហាន កម្រួតហើយមាន គ្រប់សាសន៍ភាសា ហែអមទីនាំង
សុទ្ធសឹងកញ្ញា កូនព្រាហ្មណ៍ទេវហា ឆ្វេងស្តាំដើរឆាយ ៗ ក្រោយ
នោះបុត្រី រយឯកនារី ស្អិតស្អាងអង្គកាយ បុត្រក្សត្រយឯក ល្អប្លែក
ដើរឆាយ ក្រោយទៀតរៀបរាយ សឹងកូនមន្ត្រី ៗ បើកបាំងក្លស់ក្លុំ
ចាមរបាយមន សុរ្យសែនសែនក្លាន់ ធាវធាយឆ័ត្រមៀ ជួបជុំនារី អស់
ទាំងមន្ត្រី ហែក្រោយត្រៀបត្រា ៗ ក្រុមរាំងសងខាង ហែដល់មុខ
ប្រាង្គ ប្រាសាទវេចនា ទក្សិណព្រះនគរ ជុំវលើលា ជួបចប់បើត្រា បើ
ជុំចូលទៅ ៗ អករ៍យាយស្រីង្គារ ស្ទុំស្ទិទ្ទស្នេហា ដំណាក់ក្នុងក្រៅ
អញ្ចើញធីតា កុមារិកាល្អញល្អៅ ឲ្យនាងឡើងទៅ គង់លើផ្ចុកគ្ន ៗ
ហើយយកពពិល មាសបកបង្វិល ប្រាំពីរជុំថ្វាក់ ស្រេចសង្ឃស្វូត្រ
មន្ត្រ ទិព្វគន់រ៉ៃត្រ មង្គលប្រសិទ្ធិ ប្រសើរសោភា ៗ ប្រគំដន្ត្រី ពិណ
ពាទ្យមហោរី លើកល្បើកវៃងតារ ហើយអុជកាំជ្រួច រៀបរួចរន្ទា កាំ
ទៀនទេនផ្កា គុបាអុជគ្រប់ ៗ ហើយប្រើឲ្យលេង ឲ្យគ្រប់អស់ល្បែង
សម្រាប់លេងយប់ គោមកៃវចង្កៀង អុជរៀងគ្រាន់គ្រប់ ក្លប្រុះធ្លុះសព្វ

ព្រោងព្រាតផូចផ្កាយ ៗ អស់រាស្ត្រប្រុសស្រី ទោះចាស់ក្មេងក្តី ស្រើប
ស្រួលសប្បាយ សរសើរសំណាង បុណ្យនាំនោមធាយ ឲ្យពរពណ្ណ
កយ ពល់មាត់ពល់គ្នា ៗ ខ្វះជាកូនគេ រាស្ត្រសុខសោះទេ ស្រីស្រែចំ-
ការ ហេតុបុណ្យបុរាណ គេមានវាសនា មហាក្សត្រមេត្តា អភិសេកជា
ស្តេច ៗ អស់យើងពល់គ្នា ព្រោះមិនសង្កា ធ្វើបុណ្យសម្រេច សម្រាំង
តាំងចិត្ត មូលមិត្តការកិច្ច ឲ្យស្អាតសម្រេច ជាបុណ្យពល់គ្នា ៗ ទើប
កើតជារាស្ត្រ ដើរដីកខ្លាស តូចទាបពង្សារ មិនបុនជាធំ ឧត្តមអាត្មា ម្ល៉ោះ
ហើយរាប់គ្នា ទំសាងសីលទៅ ៗ លុះព្រឹកព្រាងព្រះ សុរិយារៀងរះ ពី
បូព៌ាប្រាលផ្អៅ អក៏យាយខុនណាង ហៃនាងចេញទៅ ស្រង់ទឹកអប់ផ្អៅ
គ្រឿងគ្រប់គន្ធា ៗ ស្រេចនាយពិសេស ចុងភៅគ្រឿងទេស គ្រឿងទិព្វ
ក្រយា សម្រាប់រៀបជូន ជាបួនប្រការ ឯកះទោចត្វា ត្រីត្រឹមប្រក្រតី ៗ
សម្រាប់ឯកទោ លើកឡើងពេញតោរ ថ្វាយព្រះចក្រី ឯករាជឧត្តម ធំ
ក្នុងបុរី ទៅព្រះមហេសី ស្តេចសោយសាកល ៗ សម្រាប់ទោទុក រៀប
លើកជាមុខ ថ្វាយក្សត្រសម្ពល តាំងរយឯក ក្រយាសួស្តិ៍សល់ ស្តេច
សោយសាកល សប្បាយខយា ៗ សម្រាប់យ៉ានីបី នោះលៀងមន្ត្រី ធំតូច
នានាផងលៀងពាណិជ សម្រេចភោគ្គា អ្នកមុខអ្នកការ តាមចិត្តសប្បាយ ៗ
លៀងផងភោគ្គា មន្ត្រីសេនា ពលរេហ៍តាំងឡាយ រាស្ត្រស្រែចំការ

នានានៅឆ្ងាយ ចរកោតសប្បាយ តាមចិត្តចិត្តា ៗ លង់លុះសុរិយេ
សុរិយាតាចទេរ ទៀបទៅបច្ចិមា អករយាយចាសទុំ ស្ទុះស៊ីស្នេហា សៅ
ផៃស្រីង្គារ ខុនណាងទាំងឡាយ ៗ រៀបស្អាងជីតា គ្រឿងគ្រប់ប្រការ
គ្រគូលចេតឆាយ ពួកស្នែងពួកយាម សុវណ្ណសិរីកាយ មន្ត្រីទាំងឡាយ
ស្លូសរៀបស្នែងណា ៗ គ្រប់ពួកទាហាន ចតុរង្គមែខមាខ អង្គអង្គ
យោធា ជួរជន្ត្រីត្រៃ សង្ខៃហជីតា ទក្សិណខគភ បជាទជុំផ្ចាត់ ៗ
ហើយហែឡើងប្រាង្គ អញ្ជើញអង្គទាង ជីតារូបរត្ន មរណមាតា កន្ត្រាផ្ទូរ
ផាត់ គង់លើផ្ចុករត្ន បង្វិលរាពិល ៗ បំរើនព្រះមន្ត វិសេសទិព្វគន់ បំបាត់
មន្ទិល ឲ្យកើតសួស្តី សិរីសុរិល មិនមានមន្ទិល សោះសឹងសួស្តី ៗ
ហើយផ្ទុំត្រៃស័ង្ខ កេរពីងតាំង ស្គូរជួរជន្ត្រី គ្រប់ល្បែងសព្វគ្រប់
លេងយប់ប្រក្រតី គ្រប់ម៉ោងត្រ សព្វគ្រប់ទិវា ៗ ដង្ហែសព្វថ្ងៃ ជប់លៀង
ចំណី តាំងបវេលា មិនមានមន្ទិល អស់រាស្ត្រប្រជា សប្បាយ
មហិមា ថ្វាយតេជោថ្វាយជ័យ ៗ លុះព្រឹកឡើងនោះ មង្គលធំស្មោះ
បើកថ្មុកប្រពៃ អករយាយខុនណាង នាំនាងស្រីថ្លៃ គង់ផ្ចុករត្នខៃ
រង់ចាំពេលា ៗ ឯអង្គព្រះបាទ ព្រះបរមនាថ ចមចក្រភជា ស្តេច
រយឯករដ្ឋ ហែក្សត្រសោភា មន្ត្រីយោធា ព្រះវង្សទាំងឡាយ ៗ គរី
បណ្ឌិតព្រាហ្មណ៍ ប្រាជ្ញបុរោហិត ហែក្សត្រវៀនរាយ ឡើងលើប្រាង្គមាស

ទកាសធើតធាប ស្តេចគង់សប្បាយ ព្រះទ័យក្សេមក្សាន្ត ៗ លុះដល់គ្រប់ការ ជោគជ័យពេលា នក្ខត្តឫក្សបាន ប្រតិជត្រី កេរ៉ៃខមាន ផ្ទុំក្រែស័ង្ខសារិន រំពឹងអាកាស ៗ គរ៉េបណ្ឌិត ព្រាហ្មណ៍ប្រាជ្ញបុរោហិត សូត្រសាសិល្បសាស្ត្រ សត៌ថ្វាយពរ បវរឱកាស មង្គលអភិកាស ជាបទគាថា ៗ អាយុវណ្ណំ សុខំពលំ ទីឃាយុកា ជយតុភវំ ពជ់ខត្តិយា សោត្ថិសទា គវិនុតេ ៗ ព្រាហ្មណ៍ព្រឹទ្ធស្សុំត្រសព្ទ សូរសាយស្ដួចបប់ ថ្វាយពរខត្តិយេ មន្ត្រីទាំងឡាយ សឹងថ្វាយវ៉េរ ស្រេចហើយរៀបហែ ឡើងគ្រឹះវេទា ៗ ស្រោចទឹកថ្វាយនាម ធីតាទៀតតាមនាមដើមនោះថា សម្តេចក្សត្រី សិរីខត្តិយា មរណមាតា បរមេដពិត្រ ៗ សម្រេចជាធំ ជាធ្ងើមអស់ស្នំ ស្រីគ្គារស្នេហ៍ស្និទ្ធ ស្នំទាំងមួយពាន់ គំណាន់ស្រីរត្ន ហើយហែវិលថ្វាត ឡើងប្រាង្គវេទា ៗ ហើយលើកសម្រាប់ សម្រាំងផ្គូផ្គាប់ ទាំងបួនប្រការ យ៉ាងឯកទោត្រី គិសីក្រយា សម្រាប់ធីតា រៀបដោយអណ្តាថ ៗ ចៅហ្វាយឃុំងបាយ រួចរៀបប្រញាយ ពួកពិសេសភព់ រៀបអស់ជង្ហាយ គ្រឿងថ្វាយសម្រាប់ ព្រះស្វាយលើកធាប់ ថ្វាយព្រះរាជា ៗ ហើយថ្វាយមហេសី ស្រេចថ្វាយចំណី ឃេឯកក្សត្រា សោយរួចមន្ត្រី សេនីយសេនា អស់ទាំងក្សត្រា គ្រៀមគ្រើមណាស់ណាន់ ៗ ក្រុមរាំងតម្រួត តម្រូវត្រូវ

គ្រួត ត្រូវត្រាប្រកាន់ ដើរថែដើរថែម សិនសែមតាប់តាន់ ខ្វះតារ
រនាទ់ សំឡូពាសា ៗ ខ្វះថាហុនជ្រូក មិនទាន់បានល្អក អស់ហើយមក
ក៏ ពួកថែមវាខឹង សំឡូងទៅថា លោកកុំពីសា ហុនជ្រូកឲ្យស៊ីន ៗ
ប្រយ័ត្នវាកន់ ដកក្បិនមិនទាន់ វាហួសទៅមុខ ខ្លាញ់ជ្រូករអិល
ពព្រឹលលឿនលន់ លឿនហួសទៅមុខ កូនក្មួយព្រួយណាស់ ៗ ម្ដោះខឹង
សំឡុក ថាអាប្រមក់ តិចបាប់ដាក់ឃ្នង់ អានោះវាចេញ ឆ្ងាយវិញភាស
វាង មន្ត្រីៈនៅខាង សើចសិនពល់គ្នា ៗ ឯពួកចុងភៅ ប្រាំរយពេរីគ្រៅ
គ្រប់សាសន៍ភាសា ដប់លានពាណិជ សម្រេចភោគ្គា បានជូនពាណិនា
ពីមុខមកស្រេច ៗ ឯអស់ហើយពល នូវពស្ត្រមណ្ឌល ស្រុកក្រៅសម្រេច
ទទួលព្រះទាន គ្រប់គ្នាស្រាប់ស្រេច ដោយសារបុណ្យស្ដេច ច្រើស
ច្រើនករុណា ៗ ស្រេចស្ដេចទំមិល យាងរៀងមណ្ឌល ចមចន្ទាយា
ទតរៀងមហោស្រព ល្បែងគ្រប់ប្រការ មន្ត្រីសេនា ចតុរង្គថៃ
ក្សត្រ ៗ គន់ចន្ទាយា ស្ដេចរយឯកា គន់គាល់ច្រើនក្លាត
ស្រីក្ដារខុនណាង គាល់ខាងមហាក្សត្រ ព្រះមហេសីវត្ត គាល់ជិតក្សត្រា ៗ
ស្ដេចទតអស់ល្បែង ពំនោលគញោង ផ្កាគួផ្កាលា ហក់ដាវសួព្រ័ត្រ
ស៊ើតស្ទាត់វេក វាលយួនលទ្ធា ដាំដូងម៉ូនគ្រុំ ៗ វាំសួងខេឡាង ជើត
ល្បើករយាលពាន កន្ដោរ៉ឹង កន្លែងហក់គុន បាយខុនពង់ គ្រស័ន្ធ

ប្រគំ ពីកេះល្វើយល្វែង ។ ស្តេចទតមហោស្រព ចំណាប់ផាល់តប់
សប្បាយគ្រប់ល្បែង មន្ត្រីសេនា ក្នាក់ផ្គារព្រះស្នែង ហែក្សត្រតម្កែង
ចូលពុទ្ធកេងវត្ត ។ ពួកពលបតុស្តក្ក ព្រះវង្សគាល់ជុំ ព្រាហ្មណ៍ព្រឹទ្ធ
ប្រេចក្តាត់ អក់យាយខុទ្ទណាង គាល់ខាងមហាក្សត្រ ព្រះមហេសីវត្ត
គង់គាល់ក្សត្រា ។ ព្រះបាទបពិត្រ ធិកដរីងរឹទ្ធ មានព្រះឧង្ការ បង្គាប់
មន្ត្រី សេនីយសេនា ឲ្យរៀបក័ស្តុការ អភិសេកឈើមាស ។ អគ្គ
ឯកសេនា ទទួលឧង្ការ រួតរត់រកស ចាត់ប្រើកូនកុយ វជួយពេញពាស
សែនផ្ចិតត្រួតមាស កដវត្តិផែងផ្កា ។ ខ្ទះសែងរៀងតាំង គ្រឿងគុសម្រាំង
ល្អឥតឧបមា ដល់ដើមឈើមាស ពេញពាសគ្រៀបគ្រា ប្រើពួកនាយច្បារ
រៀបផើងផ្កាតាំង ។ រៀបបោះកដវត្តិ ហើយលើកទង់ធ្ចត្រ ត្រូវពួកក្រុម
រាំង មានជូរ្យដន្ត្រី គេរពីងពាំង ពិណពាទ្យត្រែស័ង្ខ ចម្រៀងស្រីគ្ការ ។
ស្រេចក្សត្រឧត្តម ស្តេចបាតកេងរម្យ គង់យានសុវណ្ណា នាំអគ្គ
មហេសី ក្សត្រីលក្ខណា ស្រីគ្គារស្រីការ ហែក្សត្រដល់ទៅ ។
ទីទីងអភិសេក ឈើមាសផាឯក ក្សត្រក្សាន្តបមបៅ ក្រះស់ប្រើអក់
យាយ តាំងឲ្យាយចូលទៅ លើកគ្រឿងប្រេងម្សៅ ទឹងរៀបបូជា ។
ឯមហាក្សត្រី បរមទេវី មរណមាតា ចូលទៅបង្គំ ប្រណម្យវន្ទា
ឈើមាសមាតា ទៅព្រឹក្សាសាខ ។ ឯពួកអ្នកក្មេង រៀបតាំងហើយ

លេង ភ្លេងសាធុការ ភ្លេងគោះស្គរពេទ៌ តាំងហោ៊ស័ព្ទសាទ គូច ក្រាប់ប្រុងប្រាណ វាយក្រាប់ពល់គ្នា ៗ ហ៊ុំរោងហើយច្រៀង យក ស្រីចម្រៀង ចេះរៀងស៊ីផា គូចក្រាប់ស្រើបស្រួល ទទួលបទណា មានតាំងសកវាទ៌ រប៉ាំលេងគ្រប់ ៗ ហើយឲ្យយកល្បែង សម្រាប់ តែងលេង គ្រប់រឿងមហោស្រព មិនឲ្យមានខ្វះ ទើបព្រះចមកព ស្ដេចឲ្យ លើកគ្រប់ ភ័ស្តុភោជនា ៗ រៀបដាក់ដំកល់ ភាជន៍មាសទៅដល់ ទៅដាក់ ពូការ ខុនណាងតាស់ទុំ ជួបជុំបូជា អង្វរទៅថា អញ្ជើញសេពសោយ ៗ សែនគ្រប់បីដង គ្រប់គ្នាអង្គកង ពីមុខពីក្រោយ ពីឆ្វេងពីស្ដាំ ច្រៀងរាំ បណ្ដោយ ស្រេចទើបស្ដេចឲ្យ ព្រាហ្មណ៍ព្រឹទ្ធប្រាជ្ញប្រាយ ៗ កវីបណ្ឌិត សូត្រសាស្ត្រសិល្បសិទ្ធ ព្រះឥសូរព្រះនារាយណ៍ មកកត់ស្កុត វិធី សព្ទសាយ អភិសេកហើយថ្វាយ ព្រះនាមឈ្មោះថា ៗ សុវណ្ណភជព្រឹក្ស វិសេសអធិក ពីថ្ងៃនោះណា ហើយក្សត្រុងរឿង តែងគ្រឿងបូជា សឹង តែវេទនា ព្រោងព្រាយប្រក្រតី ៗ ប្រែនាយរក្សា ថ្ងៃសីលកាលណា ប្រតិជន្ទ្រ ស្រោចសឹងទឹកអប់ យាមយប់រាត្រី សព្វថ្ងៃប្រក្រតី រាល់ ៗ វេលា ៗ មង្គលអភិសេក អនន្តអនេក លុះបីមាសា ស្រេច គ្រប់អភិសេក រយេឯកក្សត្រា ថ្វាយបង្គំលា វិលថ្កានបុរី ៗ ឯនាយ ព្រះឃ្មាំង ប្រើពលសែនតាំង ប្រញាប់ឃ្មាតខ្មី ទូវគ្រឿងប្រដាប់ សម្រាប់

ចាស់ថ្មី ពុកខ្មើយអ៊ី ៗ ដុះលាងរៀបទុក ៗ ព្រះបាទចក្រី នូវ
ព្រះមហេសី ស្មោះស្មានសាន្តសុខ កំរៀកក្រៀមក្សាន្ត ពុំមានភ័យទុក្ខ
មន្ត្រីមាត្យមុខ គាល់សព្វវេលា ៗ ស្នំសិទ្ធទាំងឡាយ ចាស់ទុំអករ
យាយ មានចិត្តស្នេហា ស្រឡាញ់មហេសី ក្សត្រីធីតា ផ្សិតនាង
កំព្រា ឥតញាតិសន្តាន ៖ បបួលគ្នាទៅ ជុំជិតគាល់ហៅ រំលឹកទុក្ខនាន
ឲ្យត្រូវរាជក្រឹត្យ មហាក្សត្រប្រទាន ទាន់ប្រាប់ទូន្មាន បង់ហាំចិន្តា ៗ
ហើយនាងឡើងទៅ បម្រើគាល់ហៅ ព្រះរាជជេដ្ឋា ស្ដេចសោក
ប្រណី មេត្រីស្នេហា ព្រះរាជធីតា មហេសីស្និទ្ធស្នំ ៗ ឥតានតែងគិត
ពីខ្សែត្រីរមក៏ កាលក្សត្រឧត្តម អភិសេកមហេសី ក្សត្រីស្នូស្តិ៍សម
បរិបូណ៌ជួបជុំ ជាខ្សែប្រីបាន ៗ

## បទកាកគតិ

នេះទឹងស្រដី តាំងតខ្សែបី បើកបទនិទាន ពីព្រះបពិត្រ
ចក្រពត្តិក្សត្រក្សាន្ត ស្ដេចទ្រង់ប្រទាន ស័ក្តិយសមហេសី ៗ ប្រទាន
ស្រីស្នំ មួយពាន់ជួបជុំ គាល់ហៅប្រក្រតី ប្រទានគ្រឿងមាស
ធុះធ្លាស់ស្មើ ប្រទានព្រះស្រី ព្រះកនិដ្ឋា ៗ ប្រទានព្រះពស្ត្រ
ព្រះសទ្ទីសេ ក្បូរក្បាច់ចេនា ដាំត្បូងព្រោងប្រុះ ធ្លាស់ធុះជ្រះថ្លា

ចាំងចែងសុរិយា រុងរឿងរស្មី ៗ ប្រពាន់មាលី សម្រាប់ថ្នល់ក្សី
ក្ខិនក្លែបពីសី ប្រពាន់សំគាង់ ដៃជាងសម្ភារ ល្អល្អះឥតប ឥតបើ
ឧបមា ៗ ប្រពាន់ភាជុន៍ធាស ព្រះស្មោយថ្នុះធ្លាប់ សុទ្ធសឹងសុវណ្ណ
ប្រពាន់តន្ទ្រី មាសម៉ររចនា ដាំត្បូងមុក្តា ចែងចាំងរស្មី ៗ ប្រពាន់រាជ
យាន សុទ្ធសឹងមាសមាន ក្ងំផ្លូតរស្មី សុវណ្ណសិរីកាយ ទើតធាយ
រស្មី ព្រះក្ងស់នោះក្តី សឹងមាសរចនា ៗ ឲ្យរើសចាស់ទុំ ខុនណាង
ស័ក្តិសម ធ្លាប់ដឹករាជការ កងព្រះរាជវាំង ឲ្យតាំងស័ក្តា រក្សាព្រះ
មហោ មហេសីប្រិមប្រិយ ៗ ឲ្យឡើងងារថា យសស័ក្តិនោះជា
សម្រាប់ស័ក្តិស្រី អ្នកអក់រស្មូនស័ក្តិ ពិក័ក្តិនារី មន្តិលទេវី សិរីសេដ្ឋា ៗ
ប្រពាន់ស័ក្តិយស ពួកអ្នកខ្ពង់ខ្ពស់ ឲ្យធ្វើរាជការ ទៅកងរាជវាំង
ទោះតាំងបរិវារ ស្រីង្គារក្តីណា អ្នកអក់ត្រួតលើ ៗ ឲ្យថែរក្សា
សម្ដេចព្រះមហា មហេសីប្រសើរ ក្រែងមានកិច្ចការ រាជការសារពើ
ដេរប៉ាក់ត្បាញធ្វើ ព្រះពស្ត្រក្សត្រី ៗ ត្រូវមុខអ្នកអក់ ចាត់ចែងរៀប
រក ធ្វើថ្វាយបក្រី ទោះបីរាជការ ព្រះមហាមហេសី យាងទៅណាក្តី
អ្នកអក់ហែទៅ ៗ ស្ដេចរៀបស័ក្តិយស តាមតបតាមខ្ពស់ មាន
កងមានគ្រៅ សម្រាប់មហេសី ក្សត្រីបមហៅ ស្ដេចប្រពាន់ះទៅ
មហេសីឧត្តម ៗ

## បទព្រហ្មគីតិ

លុះជួបចូលកត្រី ព្រះបក្រីធិកជរម្យ នាំអាន់នាថកុត្ដម ចូលបង្គំ សយនា ។ អាន់គាល់គត់ប្រយាត់ ទើបសម្ដេចព្រះពជា ស្ដេចមាន ព្រះឧង្ការ សួរមះហាស័ព៌ដើមកាត ។ សួរនាមនៃបិតា ទីធ្លាកាពង្សា ញាតិ សួរគាលអាន់ឃ្លាឃ្លាត ព្រាត់ជនទីពុំមូលមិត្ត ។ ហេតុម្ដេចអ្នកខាតា ធ្លាក់តង្គាក់ប្រយជីវិត ចូរអាន់ប្រាប់ដោយពិត ដោយពាក្យពេចន៍គោល វាទី ។ អាន់ស្ដាប់ព្រះឧង្ការ ទើបធីតាលើកជុលី បង្គំព្រះភូមី ថ្វាយ សេចក្ដីនៃខ្លួនថា ។ សូមទានឯជនក ខ្ញុំនៅស្រុកនោះនាមា កាសិក រាជា ជាស្រុកក្រៅបុរីជនបទ ។ បានជាសេដ្ឋីធំ មហាធនជុំខ្លាច ប្រាកដ ឯនាមនោះសន្មត ឈ្មោះកុលគោដ៍កុដុម្ពិក ។ មាតានាមវិសេស ឈ្មោះកុលកេសីនារី ជនកទ្វៃជនទី បង្កើតបានខ្ញុំមក ។ ជននីជនក រឿង រើសក៏លៀងនៅមនំ គេក្រលុះខ្ញុំធំ បាន ៧ ឆ្នាំកំណត់ ។ បិតា មានភរិយា មួយនៅនាស្រុកជនបទ ឯនាមនោះសន្មត ឈ្មោះកាលី ស្រីឫស្យា ។ ទុកជាប្រពន្ធចុង គេក្រមអង្គរមាសនា តាំងតែពីបិតា បានកាលីជាគូគាប់ ។ រីនាបខ្ញុំប្រុសស្រី សេះជីរគោសីងស្ងាប់ រលោះសម្បត្តិទ្រព្យ ធន ៥ កោដិសោតខ្លាត់ខ្លាយ ។ រលំឃ្លាំងមាសប្រាក់ ដូចគបាក់បោលអន្តកាយ អស់ខ្ញុំពលពាំងឡាយ ណាដែលរស់គេ

បាត់ទៅ ៗ បិតាប្រែជាខ្សត់ ក្សិណប្រាកដកើតហ្មងសៅ សព្វថ្ងៃ អាស្រ័យនៅ តែភរិយាទាំងពីរពង្ស ៗ ព្រួយចិត្តព្រួយអាត្មា ទីក អនិច្ចាអាណិតអង្គ ដឿតព្រាត់សម្បត្តិបង់ ឥតគ្មានទីពឹងចិញ្ចឹមជន្ម ៗ បបួលភរិយាពីរ រិះរកស៊ីដោយតំបន់ បានទ្រព្យចិញ្ចឹមជន្ម ប្រពន្ធ កូនតាមកំសត់ ៗ រីឯមេកាលី មានកូនស្រីពីរប្រាកដ មួយនោះ សោភសន្ត ឈ្មោះចន្ទាសាលិណី ៗ មួយទៀតឈ្មោះចន្ទី ចិត្តអប្រិយ កាចតិរ្យ រីឯមេកាលី គិតហឹនក្រមាតាខ្ញុំ ៗ វាប្រាប់បិតាថា អ្នកមាតាខ្ញុំក្សត់ពី មានប្រុសទៅសេពសម ពល់កត្រើទំនេវ៉ា ៗ រីឯបិតាខ្ញុំ ជឿតគុំពិចារណា ទឹងខានប្រចណ្ឌគ្នា ឈ្មោះសព្វថ្ងៃ ដែលខាន ៗ ដេរវ៉ាយមាតាខ្ញុំ ឃោរទឹងទំលាក់ប្រំប្រាណ ឯម្ដាយខ្ញុំ ពុំហ៊ាន ធ្ងង់ធ្ងើយឈ្មោះបោះបោកបែរ ៗ បិតាក្ដួចកាន់ចិត្ត ទឹង ហើយនាត់នាំយកម៉ែ ទៅបង់សំណាញ់ឯ ទឹករនេងគង្គាជ្រៅ ៗ ដល់ ហើយបិតានោះ គាត់នាំឈ្មោះទឹងឃោរឃៅ វាយម្ដាយខ្ញុំធ្លាក់ទៅ កង់ទឹកស្លាប់កាលនោះណា ៗ កើតជាត្រីដរី មេកាលីចិត្តឫស្យា ប្រើ កូនឈ្មោះចន្ទា· សាលិណីឲ្យទៅចាប់ ៗ បានត្រីជាមាតា ខ្ញុំហើយ ណាវ៉ាសម្លាប់ លុះក្សយប្រល័យធាប់ សល់ស្រកាពីនោះណា ៗ ខ្ញុំយកទៅដាំដុះ កើតឡើងស្ពោះជាព្រឹក្សា ដើមត្រប់ចាំងទ្វេហា មាន

បុប្ផាផលាទៅ ៗ កាលីប្រើកូនជក ត្រប់យកមកក្បែរទៀតទៅ គង់
សល់ឬសតែទៅ ខ្ញុំដាំកើតជាព្រឹក្សា ៗ រលួសមាសទាំងទ្វេ នោះពុំចេ
ព្រះករុណា ទ្រង់ប្រោចព្រះទ័យ ដោយប្រការនេះបញ្ច្រប់ ៗ នាងទូល
សព្វសេចក្តី ហើយក្សត្រីនាងសញ្ចប់ កន្ត្រាំនាងស្ងួតស្ងប់ សោកខ្សឹក
ខ្សុលអួលទឹក ៗ ជលនេត្រហូរហៃហោហើយ ពុំលង់ឡើយនាងសោកា
ក្សិណក្សត្រនុចប្រាប់ ថោសឥន្ទ្រនាងល្អងលោមយាត់ ៗ មាស
អើយកុំសោយសោក កុំវិយោគឡើយប្អូនរតន៍ ក្រែងកើត
ជាឈើថ្កាត់ ទីងកើតលំបាកណាំទៅ ៗ សោកសៅនៅក៏យកិត
នាងលើកចិត្តចោលចេញទៅ កុំទុកឲ្យហ្មងសៅ កុំសង្រែងសង្រែ
ឡើយ ៗ នាងស្តាប់ព្រះនគ្គារ វរជាយានាងបានស្បើយ ស្រាក
ស្រាន្តបានហ្វៃល្ហើយ កៀកកេសកើយថ្នលក់សល់ ៗ លុះព្រឹក
ព្រះសុរិយា ទើបព្រះមហាក្សត្រទិមិល តើនចាកបន្ទំស្អល់ ស្រប់ព្រះ
ក័ក្រ្តព្រះអង្គស្អាត ៗ ស្តេចសោយព្រះស្រីស្រេច ទើបសម្តេចព្រះក្បៀ
នាថ ចេញស្រង់គន្ធាជាតិ ទាំងមហេសីធិធីតា ៗ ស្តេចចេញចុងពេង
រត្ន ពួកបរិស័ទបុត្រីបុត្រា គង់គាល់ព្រះរាជា ច្រើនតាប់តាទ់រៀងរាល់ថ្ងៃ ៗ
មានកាលមួយទៀត ព្រះរាជាក្នុកព្រះទ័យ ចង់ចេញប្រពាតព្រៃ ព្រឹក្សា
សានទាក់ជ័រ ៗ ស្តេចមានព្រះឱង្ការ ប្រើអមច្ចារៀបសេនីយ ឲ្យ

ប្រាប់ហ្វង់វី រៀបប្រកាំផ្លាក់កុញ្ជរ ៗ អមាត្យស្តាប់ឲ្យង៉ារ ក្រាបលុត លាព្រះភូធរ ប្រាប់ធាយផ្លាក់កុញ្ជរ ទូវចតុរង្គពួកទាហាន ៗ គ្រានោះ ហ្លួងមាក់ បានស្តាប់ដាក់រៀបប្រុងប្រាណ សេនាពួកទាហាន រៀប ស្រាប់ស្រេចទៀងក្រាបទូល ៗ ព្រះបាទព្រះបពិត្រ ទ្រង់សណ្ឋិតស្តាប់ទំ-ទំនូល អមាត្យបង្គំទូល សព្វសេចក្តីទ្រង់អំណរ ៗ លុះព្រឹកព្រាងស្រាង ស្រេច ទើបសម្តេចព្រះភូធរ ជុំពលពាលទិក ហ្លួងមាក់ច្រើនត្រៀបត្រា ៗ ស្តេចផ្តាំមុខមន្ត្រី ទូវអស់ស្រីស្នំស្នេហា អក់យាយទ្យេរក្យា ព្រះមហេ-សីទេវិត្ន ៗ ស្រេចស្តេចហាយក្រយា ទើបឲ្យជាសេពកក្តាត់ សោយ ស្រេចព្រះមហាក្សត្រ ទ្រង់គ្រឿងគ្រប់ពិព្វបវរ ៗ ទ្រង់គ្រឿងរួបជាប់ ស្រេច ទើបសម្តេចព្រះភូធរ ទៀងគង់គជេន្ទ្រជរ កញ្ចោងចងចម្លង សឹក ៗ សេនាពួកទាហាន ពង់រូបប្រាណធំពន្លឹក ចិត្តមុតមិនខ្លាចសឹក វែហង្គងស្តាំមកត្រៀបត្រា ៗ ទង់ជ័យលាត្រដួច ជាទំពស្រួចឯកសេនា ធាត់ងំមាំក្លៀវក្លា ចេះសិល្បសាស្រ្តមន្តខ្លុតក្តាត់ ៗ ជុំព្រៃផុំស័ង្កសម សួរវើសពួស្រអាក់ ភ្លូងផងហែមហាក្សត្រ ចេញចុះចាកបរល័លា ៗ ចូលព្រៃព្រោងស្រអាក់ សព្វមាត់សត្វគង់អញ្ជា ហ្លុំស្នែងច្រៀងជា បទ បន្ទិកស្នែងលូងល្វើយ ៗ ពីពេះស្រណោះក្តាត់ ឆ្អន់ឆ្អែតចិត្តមិនមាន ស្បើយ សម្លេងច្រៀងត្បៀល្វើយ កង់រំពង់គាំងបព្វតា ៗ សង្វែគគ្គង

ព្រះជ័យ ក្បែរណាក្សត្រថ្ងៃស្អុលខាក ភ្លក់ទឹកកែវកែវទិព្វា មហាមហេសីនៅ
ក្រុងត្រៃក្រ ៗ ខេមរណាមាតា ដួងកញ្ញាស្រស់ម៉ៃប្រែ រូបដូចកែវចរណៃ
នៅឯកឯងក្នុងការ ៗ បង់មកតែម្នាក់ឯង ឯកកណ្ដានក្នុងអដ្ឋា ទើបខ្ញុំមក
ផងក៏ ទឹងនាំនាងមៀងមើលសត្វ ៗ នឹកក្នុងព្រះទ័យា ព្រះកន្ត្រាស្ទុត
ស្ងប់ស្ងាត់ ស្រេចហើយព្រះមហាក្សត្រ រំសាយទុក្ខទតព្រឹក្សា ៗ បក្សា
បក្សីសោត ហើរលេងលោតលើរុក្ខា ចាប់ចឹកក៏ស្គុផលា ទាំងឈ្មោល
ញីទឹមគ្នាចុំ ៗ ពញ្ញសត្វពញ្ញក់ ឈប់សម្រាកហើយយាសយំ បេក
មេសបេកខ្ចុំ ជាទ្រនិទ្ទនិត្យនៅ ៗ ដើមក្រដើមក្រូចក្រោយ
គ្រួចប្រញាយប្រញាប់ទៅ ទាំងគូ ៗ និត្យនៅ ទឹងសំកុកសំកាំង
ស្វាច ៗ ត្រយង ៗ ហើរ ទ្រើទើរទំទៀបទាច ព្រោបព្រៃចំ
ក្អែកព្រាប ក្រៀលក្រសាទំក្រសាំង ៗ ឥជ្រីងឥជ្រីងជ្រៀវ
ហើរឡើរឡេវហើយសំកាំង ភ្ញាក់សត្វភ្ញាំង ចំរទ្រឹមទានគ្នា ៗ
បង្អើបគោរចំ ជាទ្រនំលើរុក្ខា ចចាតហើរវេក ចំចលោងចឹក
ចាប់ ៗ តពេលតញ្ញុលចំ ជាទ្រនំចាំងគ្នាលាប់ ឥរលោកឥឡូវចាប់ ចំសំ.
ណាក់លើរុក្ខា ៗ ចាក់គូចាគូចំ ជាទ្រនំទទ្រឹមគ្នា សត្វទៀវទំទៀប
គ្នា ចំទទ្រឹមជាសុខសេយ្យ ៗ ចាបចៀបកញ្ញាសទៅ ចំក្រពៅ
ក្រចាសព្រៃ យាសយំ ៗ គងក្រៃ ក្រែក្រាស់ក្រែលក្នុងព្រឹក្សា ៗ កន្ទុប

កក្កុតខ្មៅ ទំទិត្យនៅតាំងគួរ នៅចុងព្រឹក្សសាខា សត្វកង់កេងហើរ ទៅឋាន ៗ តាមូតតាមូតធំ ដើមទ្រទំតាមូតបាន សំកុកសំកកប្រាណ តាំងគួគាប់ទទ្ទឹមនៅ ៗ សត្វម្រឹគតាំងឈ្មោលញី ត្រាច់រកស៊ីដោយ ព្រៃជ្រៅ រមាសរមាំងនៅ ក្រោមម្លប់ឈើព្រឹក្សសាន ៗ ដៃខ្លាៗធំក្រាប ក្រាបស្រប៉ាប់ប្រួបប្រុនប្រាណ ដើមគុលក្តាំនសម្រាន្ត សម្រឹងនៅក្រោម សាខា ៗ ក្រពៅក្របីនៅ ឈរឈប់នៅក្រោមព្រឹក្ស ទទន្សាយជ្រូក ទន្សាយ ដើមទទៃទ្រទន្សោងនៅ ៗ រកទឹកផឹកគោក្តា ក៏ស្តុះផលាហើយហើរទៅ ស្វាក្រែះស្វាព្រាមនៅ ដើមស្វាយមាសបេះគោក្តា ៗ ព្រៃព្រលសព្រើស ប្រែបប្រាណ បៀតបះបានរើសផលា ធុំៗ បរិភោគ្គា បានឆ្អែតឆ្អល់ ស្កល់ស្កប់កាយ ៗ គោមួយមែកត្រៃឈ សត្វគោព្រៃស្របសព្វាយ ជ្រូកព្រៃខ្វល់ខ្វាយ ឈ្លូសស៊ីមើមក្រវាញជ្រូក ៗ ដើមស្វាដើមស្វាច់ ផ្ទេ ស្វានបៀតបែរលលំទូលូក ស៊ីស្មៅក្រវាញជ្រូក ឈប់ក្រោម ម្លប់ព្រៃព្រឹក្ស ៗ ដំរីកើតទ្រហឹង ស្របសម្រឹងក្រោមវុក្ខា ឈប់ឈរ ឈោងហត្ថា បោចវល្លិ៍ទំដំរីស៊ី ៗ ស្តេចទតសត្វបក្សា សត្វម្រឹគា តាំងឈ្មោលញី បណ្តើរគ្នាគេស៊ី ដើរដោយហ្វូងដោយគូរ ៗ ស្តេចទឹកដល់មហេសី មហាក្សត្រីនៅកាក ជាដួងចិត្តចិន្តា កែវកបិដ្ឋ មាសបងអើយ ៗ

(នៅមានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## រឿងព្រេងវត្តបញ្ញាជី

លោក មាស-ហាំ រៀបរៀង

---

មានភូមិមួយឈ្មោះថា ភូមិបញ្ញាជី នៅក្នុងឃុំត្បូងក្រពើ ស្រុកកំពង់ស្វាយ (កំពង់ធំ) ។ នៅចំកណ្ដាលភូមិនោះ មានវត្តមួយហៅថា វត្តបញ្ញាជី ។ ពាក្យថា បញ្ញាជីនេះ គឺកើតពីសាមណេរនៅវត្តនោះ ដូចមានសេចក្ដីរៀបរាប់តទៅនេះ ៖

ក្នុងសម័យដែលប្រាក់សុទ្ធក្រក្រៃលែង គឺក្នុងសម័យដែលប្រទេសខ្មែរយើងប្រើកាស ស្ពាន់ ឬសំណនៅឡើយ , កាលនោះ មានពួកចាម ១ ក្រុមនាំគ្នាចូលទៅក្នុងខែត្រកំពង់ធំ ដើម្បីទិញគោ ក្របី នាំយកទៅលក់ក្នុងដែនកូសាំងស៊ីន ។ លុះធ្វើដំណើរមកដល់វត្តនេះ ដែលទើបនឹងធ្វើមកសាងថ្មី ពុំទាន់ដាក់នាមវត្តនៅឡើយ, ពួកចាមទាំងនេះនាំគ្នាចូលទៅសុំសំណាក់ក្នុងវត្តនោះ ។

ពេលព្រលប់ កូនសិស្សរបស់លោកគ្រូចៅអធិការ ក៏ដឹកគោឈ្មោលកម្រៀវ ១ ទឹម ដែលមានសម្បុរទឹងរាងរៅយ៉ាងល្អលើសគេឯទៀត មកចងក្រោមកុដិ ដែលនៅក្បែរសាលាពួកចាមសំណាក់ ។ ពេលនោះ ពួកចាមកំពុងតែដណ្ដាំបាយក្រឡេកឃើញគោលោកគ្រូមេវត្ត

កំពាប់ចិត្តស្រឡាញ់ទឹកថា បើទិញពីលោកគ្រូមេវត្តនេះបានទៅ មុខជាបានប្រាក់ ១ ណែន ជាស្រេច ។ លុះគិតដូច្នេះហើយ មេឈ្មួញម្នាក់ក៏ដើរទៅកាន់កុដិលោកគ្រូមេវត្ត ដើម្បីនិយាយទិញ ។ តែពេលដែលចូលទៅនោះ ក៏ធ្វើជាបត់ជើងថ្វាយបង្គំលោកតាមទំនៀមខ្មែរ ហើយនិយាយសរសើរសាសនាខ្មែរថា ព្រះសង្ឃគ្រប់វត្តមានព្រះទ័យមេត្តាករុណាដល់អ្នកដំណើរណាស់ មិនប្រកាន់ថា សាសន៍ណាជាសាសន៍ណាទេ, ខ្ញុំព្រះករុណា បានជាជ្រុលទៅកើតក្នុងសាសនាចាម ប្រសិនបើកើតមកជាខ្មែរ ប្រហែលជាបួសមួយជីវិតដូចលោកគ្រូមិនខាន ។

លោកគ្រូមេវត្ត ពុំបានជ្រាបពីពាក្យបញ្ឆោតលើកជើងរបស់ឈ្មួញនេះ ក៏ឆ្លើយថា «ឬមែន សាសនាខ្មែរ» ហើយមានព្រះភក្ត្រញញឹមហាក់ដូចជាសប្បាយក្នុងព្រះទ័យណាស់ ដោយសារបានឮបំពេរបស់ចាមនេះ, យូរៗ លោកគ្រូឆ្លើយថា «ចាំរៀនតពេកមែនខ្មែរយើង» ។

ចាមយល់ថា លោកគ្រូពាប់ព្រះទ័យនឹងសំដីខ្លួនហើយ ក៏និយាយថា ពេលក្រោយ បើខ្ញុំព្រះករុណាចូលមកទិញគោក្របីមួយលើកទៀត នឹងទិញល័ក្ខសម្រាប់ជ្រលក់ចីវរមកប្រគេនពុំខាន ។ លោកគ្រូថា អាត្មាអរណាស់ ព្រោះនៅស្រុកស្រែពុំសូវសម្បូណ៌ល័ក្ខទេ ។ ចាមផ្តើមនិយាយ

ទៀតថា សុំទោសលោកគ្រូ គោលោកគ្រូចងក្រោមកុដិ សូមដាក់ទុកឲ្យខ្ញុំព្រះករុណាមក ! ទុកធ្វើអី ! លោកគ្រូកេតកូនសិស្សឯទៀតគង់តែបាន ដារ៉ៃយកបច្ច័យសំរាប់កសាងវត្ត ខ្ញុំព្រះករុណាប្រគេន១០បាទៗ លោកគ្រូគិតថា គោរកទៀតបាន ហើយគោនេះ កូនសិស្សគេប្រគេនទទេផង បើតាមឲ្យថ្លៃ ១១ រៀលគួរលក់ណាស់ហើយ ព្រោះគ្មានអ្នកណាឲ្យថ្លៃលើសនេះទៀតទេ ។ គិតស្រេច លោកគ្រូមានពុទ្ធដីកាថា ចំរើនពរមិនអីទេ អាត្មាទុកដាក់ឲ្យដង្ហើបាន ។ តាមត្រេកអរណាស់ដកប្រាក់ ២ រៀលកក់ ។ ឯលោកគ្រូក៏មានចិត្តត្រេកអរណាស់ដែរ ដោយគិតថាមុខជាបានប្រាក់នេះយកមកកសាងវត្តហើយ ។ តាមនិយាយនឹងលោកគ្រូមេវត្តថា សុំសន្យា ៧ ថ្ងៃទៀត ខ្ញុំព្រះករុណានឹងវិលមកយកគោ នឹងប្រគេនបច្ច័យគ្រប់ចំនួន ព្រោះត្រូវការធ្វើដំណើរតទៅទៀត ។

ក្រោយថ្ងៃដែលពួកតាមចេញផុតពីវត្តមួយថ្ងៃ, ជួនជាថ្ងៃសីលពួកឧបាសក ឧបាសិកាដើរវត្ត មកជួបជុំគ្នាក្នុងទីវត្តនោះ ។ លោកគ្រូមានពុទ្ធដីកាថា អាត្មាជាវគោទៅឲ្យពួកតាមហើយ តម្លៃ ១០ បាទវាបញ្ចាំ ២ បាទ នៅខ្វះ ៨ បាទ, ក្នុង ៧ ថ្ងៃទៀត នឹងមកចូលយកគោព្រមទាំងប្រគល់ប្រាក់ឲ្យគ្រប់ចំនួន អាត្មាជាវនេះ បានថ្លៃណាស់ ព្រោះ

ត្រូវការយកប្រាក់កសាងវត្តផង ។ ពួកឧបាសក ឧបាសិកា បន្ទោសលោកគ្រូថា លោកគ្រូម្ចាស់ គិតខុសហើយ គោនេះល្អណាស់ មិនគួរលក់ដំឡៃប៉ុណ្ណឹងសោះ, បើលក់បែបនេះ តើលោកគ្រូរកពីណាបានទៀត ។

ពេលនោះ លោកគ្រូចៅអធិការមិនចេញវាចាមួយម៉ាត់សោះ នឹកថា អញគិតខុសមែន, ក៏មួម៉ៅក្នុងចិត្តនឹកថា អញធ្លាប់តែស្តីឲ្យគេ ពេលនេះ គេតិះដៀលគំនិតអញវិញបាន ។

លុះដល់ពួកឧបាសក ឧបាសិកាត្រឡប់ទៅផ្ទះវិញ លោកគ្រូមេវត្តចូលទៅក្នុងបន្ទប់ចាក់សោជិតមិនចេញក្រៅសោះ ។ ពេលនោះ ព្រះសង្ឃក្នុងវត្តមានសេចក្តីឆ្ងល់ជាខ្លាំង, ស្រាប់តែមានសាមណេរមួយអង្គមានបញ្ញាឆ្លាត ជាសិស្សសំណប់របស់លោកគ្រូ ឆ្លើយតបចំពោះព្រះសង្ឃថា ខ្ញុំព្រះករុណាមានឧបាយមួយ អាចនឹងពិតត្រូវដីកាលោកគ្រូកុំឲ្យខ្វាល់បាន ។ ព្រះសង្ឃឯទៀត ក៏ព្រមឲ្យសាមណេរនោះធ្វើឧបាយកុំឲ្យលោកគ្រូខ្វាល់ តមកសាមណេរនោះ ក៏ចូលទៅគោះទ្វារលោកគ្រូទូលថា: "សូមព្រះតេជព្រះគុណនិមន្តមកឆាន់ចុះ បើខ្លាចពួកចោរមកយកគោ ខ្ញុំព្រះករុណាមានឧបាយកុំឲ្យវាយកគោនេះបាន តែសុំព្រះតេជ-

ព្រះគុណនិមន្តទៅកាន់ទីណាឲ្យឆ្ងាយ យកចាំងគោទៅជាមួយផង ទុកឲ្យពួកចោរមកគងលង់នឹងខ្ញុំព្រះករុណាចុះ " ។

លោកគ្រូជ្រាបថា គំនិតនេះត្រូវ ក៏បើកទ្វារបន្ទប់និមន្តចេញទៅកាន់វត្តឯទៀត, ឯគោយកទៅទុកកន្លែងផ្សេង ។

គ្រប់ ៧ ថ្ងៃ ពួកចោរក៏វិលមកដល់ ចូលទៅសួរកេលោកគ្រូសាមណេរនោះនិយាយប្រាប់ចោរថា លោកគ្រូមានការនិមន្តទៅវត្តដទៃទៅហើយ តើចៅកែមានការអ្វី ? ។ ចោរថា ខ្ញុំព្រះករុណាមកយកគោដែលលោកគ្រូលក់ឲ្យពីថ្ងៃមុន ។ សាមណេរនោះនិយាយថា យកចុះ ! តែសូមចៅកែប្រគល់ប្រាក់ឲ្យគ្រប់ចំនួនមក ។ ចោរហប់ប្រាក់ ៨ រៀលប្រគេនសាមណេរ ។ ថា ទេ ! កាលលោកគ្រូនិយាយនោះគឺ ១០បាទ (សាច់ប្រាក់រាល់ឲ្យពេញបាត្រទើបលោកគ្រូទទួលយក) មិនមែន ១០ បាទជាប្រាក់ ១០ រៀលទេ ។ ចោរប្រកែកថាមិនមែនទេ ខ្ញុំព្រះករុណា និយាយនឹងលោកគ្រូថា ១០ បាទ គឺ ១០ រៀល ហើយបានដាក់កក់ ២ រៀល នៅខ្វះ ៨ រៀលទៀត ។ សាមណេរថា: នៅស្រុកនេះ លោកសង្ឃត្រូវការជាតែពាក្យ បើនិយាយថ្លៃថាគិតជាបាទ គឺយកសាច់ប្រាក់មកវាល់នឹងបាត្រលោកប៉ុណ្ណោះទើបបាន ពុំមែន

១ បាទ គិតជា ១ រៀលទេ ,  ចំណែកប្រាក់ ១០ រៀល ធ្វើម្តេចនឹងយកទៅកសាងវត្តបាន បើទៅកែពុំព្រមរាល់ប្រាក់ឲ្យទេ អាត្មាក៏ពុំព្រមឲ្យគេដែរ ឯប្រាក់ ២ រៀលដែលកក់នោះ អាត្មាសុខចិត្តចេញជំនួសលោកគ្រូ ណេះ! យកទៅចុះប្រាក់ ២ រៀល ។

ពួកបាយពាលក៏គិតឥតមានពាក្យអ្វីជជែកតទៅទៀត ក៏នាំគ្នាចុះពីកុដិធ្វើដំណើរតទៅទៀត ។

កាលបើបាយចេញផុតពីវត្តហើយ សាមណេរនេះ ក៏ទៅនិមន្តលោកគ្រូមកវិញ ទូលតាមដំណើរ ។

ឯលោកគ្រូក៏និមន្តមកកាន់វត្តវិញ មានសេចក្តីកោតញញើតដល់ប្រាជ្ញាសាមណេរនោះជាច្រើន ឈប់ហៅសាមណេរនោះថាលោកនេនហៅថា ជីមានបញ្ញា ។ ចំណែកអ្នកស្រុកជិតឆ្ងាយ ហៅយារក្លាយមកថា បញ្ញាជី ហើយវត្តថ្មីនោះ គេដាក់ជាប់ថា វត្តបញ្ញាជី ។ ចំណែកភូមិក្បែរវត្តនោះ ក៏ហៅថា ភូមិបញ្ញាជី ជាប់រហូតដល់សព្វថ្ងៃ ។

តាមទំនៀមខ្មែរយើងថា: បុរសណា បានបួសជាសាមណេរឬភិក្ខុទោះច្រើនវស្សាក្តី តិចក្តី អ្នកស្រុកពុំហ៊ានហៅ អា·មីង ឡើយ បើជាសាមណេរ គេហៅថាលោកនេន ជាភិក្ខុ ថា លោកភិក្ខុ ។ បើសឹកពីនេនឬពីភិក្ខុ គេហៅបណ្ឌិត ហើយជាពិសេសទៀត គឺសឹកពីនេន គេហៅថា ជី , ពីភិក្ខុ គេហៅថា អ្នក ។

# រឿងព្រេងរុស្ស៊ី

## បែងអំពីពស់នឹងការយល់សប្តិ

ភិក្ខុ ម៉ែន-រៀម សិស្សពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ

ប្រែពីភាសាអង់គ្លេស

---

គ្រាមួយ មានព្រះមហាក្សត្រនៃប្រទេសមួយ ទ្រង់ព្រះសុបិន ប្លែកចម្លែកអស្ចារ្យណាស់ ។ កាលទ្រង់ផ្ទំ ទ្រង់បានយល់ព្រះសុបិននិមិត្ត ឃើញសត្វកញ្ជ្រោងមួយ ព្យួរកន្ទុយឡើង ដាក់ក្បាលសំយុងចុះ ពីលើដំបូលប្រាសាទមក ។ ពេលដែលព្រះអង្គតើនចាកព្រះបន្ទំ ទ្រង់នៅចាំព្រះសុបិននិមិត្តនោះជាក់ច្បាស់, ជាប់ក្នុងព្រះហឫទ័យ បំភ្លេចមិនភ្លេចសោះ ពេលនោះ ទ្រង់ត្រាស់ឲ្យហៅសេនាបតី និងពួកទីតវិទូមកចំពោះព្រះភក្ត្ររបស់ព្រះអង្គ ដើម្បីត្រាស់សួរឲ្យគាត់សុបិននិមិត្ត អំពីកញ្ជ្រោង ព្យួរកន្ទុយឡើង ដាក់ក្បាលសំយុងចុះពីដំបូលប្រាសាទនោះ តើមានន័យយ៉ាងណា ។

ពួកទីតវិទូ មិនអាចកាត់យល់នូវព្រះសុបិននិមិត្តនោះសោះឡើយ ម្ល៉ោះហើយ កាលដែលអនុស្សាវរីយ៍នៃព្រះសុបិននោះ ចេះតែបន្តសកម្មភាព ធ្វើឲ្យខ្វល់ព្រះហឫទ័យព្រះអង្គ មិនស្រាកសោះនោះ, ទីបំផុត ព្រះ

អង្គចេញព្រះរាជប្រកាសថា ទ្រង់នឹងប្រជុំមហាសន្និបាតមួយ ក្នុងទីក្រុង ឲ្យជនគ្រប់រូប ក្នុងព្រះរាជអាណាចក្រ ទៅចាំមហាសន្និបាតនោះ ។ ព្រះរាជបំណង ដែលទ្រង់ឲ្យប្រជុំនោះ គឺទ្រង់មានសង្ឃឹមថា ក្នុងបណ្ដាប្រជារាស្ត្រនៃព្រះរាជអាណាចក្ររបស់ព្រះអង្គ តើនឹងមានជនណាមួយឈ្លាសវៃ អាចកាត់ព្រះសុបិននោះថ្វាយបានជាពុំខាន ។

កាលបរិច្ឆេទនៃមហាសន្និបាត បានមកដល់ហើយ, មហាជនក៏ចាប់ផ្ដើមធ្វើដំណើរទៅកាន់មហាសន្និបាតនោះ ។

ក្នុងចំណោមជន ដែលបានមកកាន់មហាសន្និបាត មានកសិករកំសត់ម្នាក់ឈ្មោះ អៃវ៉ាន់ (IVAN) បានមកជាមួយគេដែរ ។ ក្នុងដំណើរទៅកាន់ទីក្រុង អៃវ៉ាន់បានដើរតាមផ្លូវដើរចង្អៀតមួយ ដែលប្រកបទៅដោយព្រៃដ៏ស្ងប់ ស្រាប់តែឃើញពស់មួយ លូនស្ទូកនៅកណ្ដាលផ្លូវ ។ ឃើញដូច្នោះ អៃវ៉ាន់ឈប់នឹក ហើយកាលដែលគាត់ឈប់យ៉ាងនេះ ពស់ក៏ចាប់និយាយទៅកាន់គាត់ថា ៖

- « ទិវាសួស្ដី ! អ្នកកំពុងតែអញ្ជើញទៅណា ? » ។

អៃវ៉ាន់ បានរៀបរាប់ប្រាប់ពស់ អំពីព្រះរាជប្រកាសនោះដោយសព្វគ្រប់ រួចសួរទៅពស់វិញថា ៖

— « ចុះវាមានប្រយោជន៍អ្វីចំពោះមហាសន្និបាតនោះ ? ហើយឲ្យ

ខ្ញុំទូលស្តេច អំពីព្រះសុបិនមិនិមិត្តនោះ ជាមិចទៅហ៎ ? ។

" ទេ! មានប្រយោជន៍ណា!" ពស់ឆ្លើយ, " អ្នកណាអាច

កាត់ព្រះសុបិននិមិត្តនោះបាន នឹងបានទទួលព្រះរង្វាន់ពីតព្រះកដ, អ្នក

ឯងសន្យាថា ចែករង្វាន់នោះឲ្យខ្ញុំផងទៅ ខ្ញុំនឹងប្រាប់ន័យរបស់សុបិននោះ

ដល់អ្នកឯង " ។

ផៃអាំន ត្រេកអរណាស់, គាត់ឆ្លើយថា ៖

— "ពិតណាស់ ខ្ញុំនឹងចែកឲ្យអ្នក, ឲ្យតែអ្នកប្រាប់ន័យនោះមកចុះ,

ខ្ញុំនឹងឲ្យអ្នកពាក់កណ្តាល ខ្ញុំយកទុកពាក់កណ្តាល ហើយខ្ញុំនឹងអរគុណ

អ្នកឯង រកទីបំផុតគ្មានថែមទៀត " ។

—" បើដូច្នោះ" ពស់ឆ្លើយ , អ្នកឯងចាំស្តាប់ចុះ, តទៅនេះ ជា

ន័យរបស់ព្រះសុបិននោះ ៖

ព្រះកជាដែលទ្រង់ព្រះសុបិន ឃើញសត្វកញ្ជ្រោងព្យួរកន្ទុយឡើង

ដាំក្បាលចុះពីដំបូលប្រាសាទនោះ បានសេចក្តីថា "ព្រះកជអាណា-

ចក្រ នឹងកើតមានការប្រវ័ញ្ចន៍ ការក្បត់ នឹងការបាតវិស្វាសភាព

មិនខាន" ។

ពេលនោះ ផៃអាំន បានអរគុណនឹងពស់ រួចហើយគាត់ក៏យាត្រា

ទៅទីក្រុង ។ លុះដល់វាំងត្រូវខ្ទុនគាត់ក្រាបទូលស្តេចពីរឿងសុបិននោះ

គេបាននាំខ្លួនគាត់ទៅបិតនៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ហើយគាត់ក៏បានមកស្រាយព្រះសុបិនទិមិត្តថ្វាយ តាមពាក្យពស់ប្រាប់នោះដោយសព្វគ្រប់ ។

ព្រះរាជាទ្រង់សោមនស្សយ៉ាំងក្រៃលែង, បានព្រះរាជទានរង្វាន់ដ៏មានតម្លៃជាច្រើនដល់អៃក៉ាំទ់ ។ ប៉ុន្តែ កាលដែលអៃក៉ាំទ់រួចពីកិច្ចនេះហើយចេញដំណើរទៅផ្ទះវិញនោះ ។ គាត់គិតថា អញបែករង្វាន់ឲ្យពស់បានប្រយោជន៍អ្វី ។ ពេលនោះ អៃក៉ាំទ់ ក៏ដើរគេចតាមផ្លូវដទៃក្រៅពីកន្លែងដែលពស់នៅ ហើយឆ្ពោះទៅផ្ទះគាត់វិញ ។

ពេលក្រោយមក ព្រះមហាក្សត្រទ្រង់សុបិនម្តងទៀតធ្វើឲ្យព្រះអង្គខ្វល់ព្រះទ័យដូចមុន ។ ក្នុងព្រះសុបិនទិមិត្តនោះ ទ្រង់ឃើញដាវមួយព្យួរសំយុងចុះពីដំបូលប្រាសាទមក ។

ពេលនេះ អៃក៉ាំទ់ត្រូវព្រះមហាក្សត្របង្គាប់ឲ្យចូលខ្លួនមកកាន់ទីក្រុងយ៉ាំងរួសរាន់ ព្រោះទ្រង់ជ្រាបថា អៃក៉ាំទ់ឈ្លាសវៃបានបកស្រាយព្រះសុបិនទិមិត្តមុនថ្វាយទ្រង់ជ្រាប ។

ឥឡូវនេះ អៃក៉ាំទ់ផិតពោរ ព្រោះគាត់ដឹងថាខ្លួនគាត់មិនប៉ុនប្រសប់កាត់ព្រះសុបិននោះសោះ ។ ប៉ុន្តែ អៃក៉ាំទ់គាត់ចិត្តខំដើរទៅរកពស់ទៀត គាត់ដើរទៅកាន់ផ្លូវដើរដ៏ចង្អៀតត្រង់កន្លែងពស់នៅ ប៉ុន្តែមិនបានឃើញ

ពស់នោះ ។ គាត់ប្រកួកហៅពស់ថា៖

-«ពស់ ! អីពស់ ! អញ្ជើញមកនេះមួយភ្លែត ខ្ញុំត្រូវការនិយាយនឹងអ្នក !» ។ គាត់បេះតែហៅយ៉ាងនេះ ដកបដល់ពស់ចេញពីរន្ធវាមក ហើយសួរថា៖

-«ស្អីវានាំឱ្យអ្នកខ្វល់ ? មានការអ្វីបានជាត្រូវការជួបខ្ញុំ ?» ។

-«ស្ដេចមានព្រះសុបិននិមិត្តមួយទៀតហើយ», អៃក៉ាន់ឆ្លើយ, «ខ្ញុំមិនដឹងជាទូលព្រះអង្គដូចម្ដេចទេ !» ។

-«ខ្ញុំនឹងប្រាប់អ្នកឯង លុះត្រាតែអ្នកឯងព្រមចែករង្វាន់ឱ្យខ្ញុំខ្លះផង ទើបបាន», ពស់ឆ្លើយ ។

-«ខ្ញុំសន្យាថាចែកឱ្យតែអ្នកប្រាប់មកចុះ», អៃក៉ាន់និយាយ ។

-«បើយ៉ាងហ្នឹងមែន ចូរអ្នកទូលស្ដេចថា ព្រះសុបិននិមិត្តដែលទ្រង់ឃើញ ជាដាវព្យួរសំយុងពីដំបូលប្រាសាទនោះ បានសេចក្ដីថា នឹងកើតមានសង្គ្រាម, សត្រូវទាំងឡាយ ទាំងខាងក្រៅនិងខាងក្នុងព្រះរាជាណាចក្រ នឹងប្រឆាំងតតាំងក្បត់ចំពោះព្រះអង្គ, ការបង្ហូរឈាមគ្នា កាន់តែជិតមកដល់ហើយ, ព្រះមហាក្សត្រ ត្រូវរៀបចំការពារប្រទេសឱ្យមែនទែន» ។

អៃក៉ាន់ អរគុណពស់រួចហើយ ទើបដើរទៅកាន់ទីក្រុង ។

កាលស្តេចត្រាស់សួរ , អៃហ៊ាន់ ក៏រៀបរាប់ចូលតាមពាក្យពស់ឥតខ្លោះ ។ ព្រះរាជា ទ្រង់រំភើបហ៊ានពន្ទឹក ចំពោះហេតុដែលទ្រង់បានសវនាពីអៃហ៊ាន់ ហើយទ្រង់ព្រះរាជទានរង្វាន់ដ៏មានតម្លៃជាច្រើន ដល់អៃហ៊ាន់ម្តងទៀត ។

ប៉ុន្តែ កាលណាអៃហ៊ាន់ គិតពីរឿងដែលត្រូវចែករង្វាន់នោះ ដល់ពស់ តាមពាក្យសន្យា , គាត់ទៅជាមួយមៅក្តៅចិត្ត ។ គាត់បានដើរទៅត្រង់កន្លែងពស់រង់ចាំ , ពស់ឃើញគាត់ហើយ និយាយថា ៖

– « ឥឡូវនេះ ត្រូវឲ្យរង្វាន់ពាក់កណ្តាលជាចំណែកខ្ញុំមក ! » ។

អៃហ៊ាន់ ស្រែកគំហកថា ៖

– « អញឥតត្រូវការឲ្យអ្វីដល់ឯង ក្រៅពីសេចក្តីទុក្ខព្រួយទេ » ។

ពេលនោះ អៃហ៊ាន់ហូតកាំបិតចេញមក រួចគាត់យារកាប់ពស់នោះ ដែលគ្នាក៏ពុំនៃតែត្រឡប់បែរក្បាលចូលរន្ធវិញដោយរួសរាន់ , តែកុសល ! ពេលដែលពស់លូនចូលរន្ធមិនទាន់ផុតបាត់នោះ , កាំបិតអៃហ៊ាន់ អាចផ្តាច់បានត្រឹមតែកន្ទុយពស់ប៉ុណ្ណោះ ។ រួចស្រេច ដោយឥតខ្វល់ពីអ្វីសោះនោះ អៃហ៊ាន់ សប្បាយចិត្តនឹងសម្បត្តិថ្មីរបស់គាត់ ត្រឡប់ទៅផ្ទះអាត្មាវិញ ។

កាលវេលា ចេះតែកន្លងទៅ ៗ ។ សង្គ្រាមពេញដោយលោហិត ក៏បានផ្ទុះឡើង ដូចទំនាយពស់មែន, ប៉ុន្តែកងទ័ពខាងស្តេច មានជ័យ

ជំនះលើខ្មាំង ។

កាលនោះ ព្រះមហាក្សត្រ ទ្រង់សុបិនម្តងទៀត ។ ម្តងនេះ ព្រះអង្គទ្រង់ឃើញថា មានសត្វចៀមមួយព្យួរខ្លួនសំយុងក្បាល ពីដំបូលប្រាសាទ ។ ម្ល៉ោះហើយ អៃកាំង ត្រូវស្តេចត្រាស់ឲ្យគេហៅម្តងទៀត ។ ក្សណនោះ អៃកាំង សែនខ្វល់អំពល់ព្រួយចិត្តឥតអ្វីប្រៀប ។ គាត់និយាយថា: ឥឡូវនេះ តើអញឲ្យពស់ជួយគិតដូចម្តេច បានទៀត, បើអញបានបៀតបៀនធ្វើឲ្យមានរបួស ទឹងសស្ត្រាំងអញដល់កាលនៅហើយ ។

ប៉ុន្តែ គាត់ខំកាត់ចិត្តម្តងទៀត ហើយដើរសំដៅទៅតាមផ្លូវដែលឆ្ពោះទៅកន្លែងពស់រូបស្រែកហៅពស់ ដកបដល់ទីបំផុត ពស់ក៏ចេញមក ។ អៃកាំងបានរៀបរាប់បញ្ជាប្រាប់ពស់, ហើយពស់ក៏និយាយដូចពីមុនថា :

-" ឲ្យតែអ្នកឯងសន្យាថា ព្រមចែករង្វាន់ពាក់កណ្តាលដល់ខ្ញុំ, ខ្ញុំនឹងប្រាប់ន័យព្រះសុបិននិមិត្តនោះ ដល់អ្នកឯង " ។

- "នឹងចែកឲ្យអ្នកខ្លះ " ។

- "បើអីចឹង ចាំស្តាប់ចុះ គទៅនេះ ជាចម្លើយដ៏ត្រឹមត្រូវកង់ព្រះសុបិននោះ :

ចៀមដែលព្យួរខ្លួនពីដំបូលប្រាសាទនោះ បានន័យថា " ឥឡូវនេះ

សន្តិភាព នឹងកើតមានគ្រប់ទីកន្លែង , ប្រជារាស្ត្រ នឹងមានសេចក្តីរីករាយសប្បាយគ្រប់ ១ គ្នា " ។

វៃអាំនយកចម្លើយនេះ ទៅក្រាបទូលស្តេច ក្នុងព្រះបរមរាជវាំង ហើយដោយព្រះរាជាទ្រង់រីករាយសោមនស្សនឹងក្រៃលែងនោះ ទ្រង់ព្រះរាជទានដល់វៃអាំន នូវរង្វាន់ប្រាក់យ៉ាងច្រើនជាងមុន ១ ទៅទៀត ។

ម្តងនេះ វៃអាំនត្រឡប់ទៅផ្ទះខ្លួនវិញ តាមផ្លូវដដែល ហើយបានឃើញពស់នៅរង់ចាំ ត្រង់កន្លែងផ្លូវចង្អៀតនោះ ។ គាត់បានបែករង្វាន់ពាក់កណ្តាល ឲ្យទៅពស់ ដោយនិយាយថា ៖

- " អ្នកឯង មានខន្តីចំពោះរូបខ្ញុំ ទុកណាជាខ្ញុំបៀតបៀនធ្វើទុក្ខទោសយ៉ាងណា ក៏មិនថា, នេះជាចំណែកពាក់កណ្តាល ពីចំណែកដែលខ្ញុំបានទទួលនៅលើកនេះ , ហើយកាលណាខ្ញុំទៅផ្ទះ ខ្ញុំនឹងបញ្ជូនរង្វាន់ពាក់កណ្តាល ពីរង្វាន់ដែលខ្ញុំបានទទួលពីមុននោះ មកឲ្យអ្នកទៀត សូមអ្នកអភ័យទោសដល់ខ្ញុំ ពីការដែលខ្ញុំប្រព្រឹត្តមិនសមគួរចំពោះរូបអ្នកនោះ ដល់ខ្ញុំផងចុះ " ! ។

ពស់ស្តាប់ហើយ ឆ្លើយថា :

- " សូមកុំបាច់ព្រួយបារម្ភចំពោះហេតុការណ៍ដែលកើតឡើងនោះឲ្យសោះ ពីព្រោះមិនមែនជាកំហុសរបស់អ្នកទេ, ហាំ លើកដំបូងតាម

ដែលអ្នកនៅចាំ គឺព្រះពជាទ្រង់សុបិនពីសត្វកញ្ជ្រោង, ពេលៈនោះផែនដីពេញទៅដោយការប្រវញ្ចន៍, ការលាក់ពុតត្បុតនិងការក្បត់, ជាន់នោះខ្លួនអ្នកហ្នឹងឯងក៏ជាអ្នកប្រវញ្ចន៍មួយរូបដែរ ពីព្រោះអ្នកឯងដើរត្រឡប់ទៅផ្ទះតាមផ្លូវវៀច គេបង្ខំមិនឲ្យជួបខ្ញុំតាមពាក្យសន្យា, ប៉ុន្តែដោយហេតុអ្នកឯងជាមនុស្សសាមញ្ញដូចគេឯងដែរនោះ ការប្រវញ្ចន៍ក៏វិនាសបាត់ទៅក្នុងអាកាសទៅ ។ លើកទីពីរតាមដែលអ្នកនៅចាំបាន គឺជាពេលកើតសង្គ្រាម, វិវាទនិងឃាតកម្ម, អំពើកំណាចៈឃោរឃៅ ផុសឡើងគ្រប់ទីកន្លែង, ពេលៈនោះខ្លួនអ្នកឯងក៏ជាអ្នកកំណាចម្នាក់ ក្នុងចំណោមមនុស្សកំណាចទាំងនោះដែរ ព្រោះអំពើកំណាចរបស់អ្នកឯងក្នុងការកាប់កន្ទុយរបស់ខ្ញុំ ក៏គឺអំពើកំណាច ដែលមាននៅក្នុងជនគ្រប់រូប នោះឯង ប៉ុន្តែ ឥឡូវនេះ សន្តិភាពបានបិតនៅលើយើងគ្រប់គ្នាហើយ, អ្នកឯងក៏បានត្រឡប់ជាមនុស្ស មានចិត្តទូលំទូលាយ ប្រកបដោយយុត្តិធម៌ត្រឹមត្រូវល្អដូចជាអ្នកឯងទៀតដែរ ព្រោះអ្នកឯង បានយកស្បៀងមកចែកឲ្យខ្ញុំតាមពាក្យសន្យា, អញ្ជើញចុះ បងប្រុស! សូមឲ្យសន្តិភាពជារបស់ព្រះអាទិទេព សណ្ឋិតជាមួយអ្នកតរៀងទៅ, ខ្ញុំឥតត្រូវការចង់បានសម្បត្តិទ្រព្យអ្វី ពីអ្នកទេ!" ។

ជាហើយ, ពស់ក៏លូនចូលរន្ធបាត់ទៅវិញហោង ។

# រឿងសាមកុក

## កណ្ឌទី ៤១

ឧកញ៉ាវិបុលរាជសេនា ញ៉ុក-ថែម ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកវាងវៃធ្លាប់បានអាន<br>និងចេះឧបាយកលបំណាន<br>ទាំងមានសន្ដានស្នេហាជាតិ។ |

អ្នកដែលមានប្រាជ្ញាខ្លះ ក៏គិតថាស៊ូច្បាំងនឹងកងទ័ពលោកតទៅ ដែលគិតដូច្នេះ ដូចគេយកពងមាន់ទៅជល់នឹងថ្ម មុខជានឹងបែកខ្ទេចខ្ទីអស់ ទើបប្រឹក្សាព្រមគ្នាថា នឹងចេញមុខមកសុំចំណុះ ចុះចូលលោកយកសេចក្ដីសុខតទៅ នៅតែដ៉ាវយើ ១ មានចិត្តអង់អាចមិនខ្លាចក្រែងគិតសុំទាហានស៊ិនគួនលើកមកធ្វើសង្គ្រាមនឹងលោក ដ៉ាវយើនោះជាមនុស្សក្អឹងចិត្តគិតតែតាំងខ្លួនធំ ហាថា មានប្រាជ្ញាស្មារតី នឹងរកអ្នកឯណាត្រឹមស្មើគ្នា តាំងតែបង្គាប់បញ្ជាការសង្គ្រាមទៅតាមអំពើចិត្ត ខ្ញុំបាទ

គ្មានទោសកំហុសអ្វីសោះ ក៏ចុះខណ្ឌកម្មវាយដំទាល់តែគ្រាំគ្រាជាទម្ងន់ ឥឡូវខ្ញុំបាទ នឹងធន់ទ្រាំតទៅទៀតពុំបាន ព្រោះមានសេចក្ដីក្ដៅរំជួល ឈួលឆេះស្មើរនឹងប្រេះទ្រូងស្លាប់ បានឮកិត្តិសព្ទថា លោកមានចិត្តអាសូរ ករុណាដល់សត្វ ឧបមាដូចញាតិសន្ដានបងប្អូន មនុស្សទាំងឡាយតែង ចូលមកជ្រកកោនពឹងបុណ្យលោកនៅជាសុខក្សេមក្សាន្ត បីដូចជាគ្រាប់ ភ្លៀងធ្លាក់មកលើឋានមនុស្សលោក ដោកត្រជាក់ព្រៃព្រឹក្សាលតាវល្លិ៍ ផងទាំងពួងដូច្នោះ គ្រានេះ ខ្លួនខ្ញុំបាទនឹងមកសុំចំណុះចុះចូលនៅនឹង លោកតទៅ តែថាគ្រានេះនឹងមកពុំទាន់បាន ព្រោះមានរបួសរលុះរលួយ អស់ទាំងខ្លួន ដោយដំរីយីឡាក់យ បើរបួសទាំងឡាយសះជាគ្រាន់បើថ្ងៃ ណា ខ្ញុំបាទនឹងនាំយកស្បៀងអាហារផ្លុកផ្លូកលបរតមកចូលនឹងលោកឲ្យ បាន កុំឲ្យលោកមានមន្ទិលសង្ស័យនឹងខ្ញុំបាទឡើយ " ៗ

លុះមើលសំបុត្រចប់ហើយ ចូច្នះនឹងណាស់ គិតត្រឡប់ទៅត្រឡប់ មកប្រហែល៤-១០សា ក៏ស្រែកតំហាកហើយថា ដំរីយីតិតកលខបាយឲ្យ អ៊ុយកាយធ្វើជាសំគ្រេប្រើនកានមកនេះជាទំឡកចំរូកឲ្យយើង ហើយ បង្គាប់ទាហានឲ្យចាប់ខ្លួនវាគេកទៅសម្លាប់ ៗ ខណៈនោះ ទាហាន ក៏ចូលទៅចាប់នាំគេក ៗ ក៏មិនបានគោតញញើត ធ្វើអាការជាងើយ មុខឡើងមើលទៅលើអាកាសហើយអស់សំណើច ៗ ចូច្នះឃើញដូច្នោះ

គឺសង្ស័យ ទើបហៅពាហានឲ្យយកខ្លួនអាំគេគមកវិញ ហើយគំរាមសួរថា យើងដឹងថា ជាយើងនឹងអ៊ុយកាយរួមគំនិតគ្នា ក្លែងធ្វើកលុបាយមកបញ្ឆោតយើង ៗ ត្រូវឲ្យសម្លាប់ខ្លួនចេញ ហេតុម្ដេចបានជាថា អ៊ុយកាយមិនមែនស្គាល់មនុស្សចេះល្បួងនិងល្អអាក្រក់ដូច្នោះ ។ អាំគេគឆ្លើយថា លោកកុំបាច់សួរជជីកឲ្យយូរការធ្វើអី នឹងសម្លាប់ខ្ញុំបាទក៏សម្លាប់ឲ្យឆាប់ទៅចុះ ។

ចួនថា ខ្លួនយើងរៀនពិជ័យសង្គ្រាមជំនាញមកតាំងពីក្មេងច្រើនណាស់ឥឡូវយើងក៏ដឹងកងការសឹកផ្សេង ៗ បានជាធ្វើធំជាមេគេដល់ទីនេះ ដែលខ្លួនមកវៃគិតកលុបាយបញ្ឆោតយើង ៗ ក៏អាចដឹងលើសគំនិតខ្លួនទៅទៀត បើខ្លួននឹងគិតលេងដូច្នេះ ចូរទៅល្បួងបញ្ឆោតក្មេងកង្វាលគោទៅចុះ ។ អាំគេគឆ្លើយថា លោកក៏មានគម្រិះប្រាជ្ញាជាចំបងលើមនុស្សទាំងអស់ ដែលអ៊ុយកាយឲ្យសំបុត្រមកលោកនោះ លោកពិគ្រោះឃើញថាជាយ៉ាងម្ដេច បើថាមិនពិតនោះចូរលោកមានប្រសាសន៍ទៅចុះ ។ ចួនថា បើយើងនឹងមិនប្រាប់វេលានេះឲ្យអស់ ហើយស្រាប់តែសម្លាប់ខ្លួនជាមុនទៅ ខ្លួនគឺនៅតែគិតតូចចិត្តថាយើងមិនបានពន្យល់ចំភ្លឺឲ្យឃើញទោសកំហុស ឯសំបុត្រដែលឲ្យមកនោះ បើអ៊ុយកាយនិងខ្លួនមានចិត្តស្ម័គ្រមកសុំនៅនឹងយើងដោយសុចរិតមែន ៗ គង់មានកំណត់ពេល

យប់ ថ្ងៃ ខែ ឆ្នាំ ដែលឯងនាំគ្រួសារទូវសរពើទ្រព្យជាតិកតាង នេះ មិនឃើញមានជាផងសោះ បានជាយើងយល់ថា អ៊ុយកាយឯងខ្លួននោះ បញ្ឆោតយើង ។ ឆាំតេកញ្ជូវជ្រោះ ក៏អស់សំណើចម្តងទៀតហើយថា ដែលលោកអួតខ្លួនលោកថា បានចេះដឹងគម្រាពជ័យសង្គ្រាមស្ទាត់ជំនាញ នោះ ខ្ញុំបាទឃើញថាលោកចេះតែមាត់ខាងក្រៅទេ ខ្ញុំបាទនឹកស្តាយ ណាស់ ព្រោះលោកបានធ្វើជាមហាឧបរាជហើយនៅមិនដឹងទីបង់ទីបាន ខ្ញុំបាទឯងជួយដាស់តឿនស្មារតីលោកទុក សុំឲ្យលោកលើកទ័ពត្រឡប់ទៅ វិញ បើលោកមិនស្តាប់ពាក្យខ្ញុំបាទទេ ដីវយើងឯងចាប់ខ្លួនលោកបានជា ប្រាកដ ឯខ្លួនខ្ញុំបាទជាមនុស្សឆោតទៅ ទោះបីឯងស្លាប់ទៅដោយអាជ្ញា របស់លោកក៏គ្មានល្បីឈ្មោះជាអ្វីប៉ុន្មាន ។ ចូឆ្ងតបថា ហេតុម្តេចបាន ជាខ្លួនមកមើលងាយយើងដូច្នេះ ? ។ ឆាំតេកថា លោកមិនចេះគិតអ្វី សោះ បានជាមិនបានដឹងការល្អិតល្អន់ក្នុងកិច្ចការសឹកសង្គ្រាមទាំងពួង គឺមិនដឹងសេចក្តីរៀបចំទ័ពត្រង់ពិត ទឹងគ្នេរចិត្តគំនិតមនុស្សថាជាពិតឬត្រង់ ៗ

ចូឆ្ងសួរថា ដែលថាយើងមិនដឹងការនោះយ៉ាងម្តេច ? ។ ឆាំតេក ថា លោកជាទ័ពមហាឧបរាជ មនុស្សល្អមានតម្រិះប្រាជ្ញាមករកលោកក៏មិន បានរាប់អានស្រឡាញ់ ខ្ញុំបាទនឹងជាតទៅធ្វើអឲ្យព្រួយការ ព្រោះខ្លួនខ្ញុំ បាទក៏ត្រូវស្លាប់ទៅហើយ ។ ចូឆ្ងតបថា ដែលខ្លួនអួតថាមានតម្រិះ

ប្រាជ្ញានោះ ចូរនិយាយឲ្យអស់សេចក្ដីដើម្បីនឹងឲ្យឃើញច្បាស់យ៉ាងម្ដេច យើងនឹងបានរាប់អានស្រឡាញ់ខ្លួនតទៅ ។ ឆាំគេកថា លោកមិនជ្រាបទេឬ? ធម្មតាមនុស្សដែលនឹងរត់ចោលទៅឆ្ងាយនាយទៅៗនៅទីឯទៀត យកអ្នកដទៃជាទីពឹងនោះ នរណានឹងបេះទៅកំណត់ពេលយប់ថ្ងៃខែឆ្នាំបាន គ្មានទំលាប់ចាំទៀងសោះឡើយ បើសិនណានឹងឲ្យកំណត់ថ្ងៃ ឬយប់នឹងមកក៏ក្រែងគ្មានបន្ទោះឱកាស បើថាទៅហើយលុះដល់កំហិតសញ្ញាត្រឡប់ជាមកមិនបានវិញ អ្នកដែលចាំមើលផ្លូវនោះនឹងមិនខាតពេលវេលាទេឬ? សូម្បីតាំងអ្នកដែលទទួលសំបុត្រចុតហ្មាយសោត ក៏គង់ត្រឡប់ទៅជាខុសអស់ទៅ ។ ក្ដួចក្ខុដ្ឋពោះក៏យល់ឃើញត្រូវ រសាយសេចក្ដីខឹងបន្តិចវិញ ទើបក្រោកទៅដឹកដៃឆាំគេកឲ្យចូលទៅអង្គុយទីសមគួរ ហើយសូមខមាទោសថា ដែលយើងបានប្រមាថក្ដាំងក្ដាត់ទៅហើយនោះ អ្នកកុំបីគិតតូចចិត្តនឹងខឹងនឹងយើងឡើយ អត់ទោសយើងចុះ ។ ឆាំគេកថា ឯចិត្តអ៊ីយកាយនឹងខ្ញុំបាទនោះឧបមាដូចទារកស្រេកទឹកដោះ ឯខ្លួនលោកដូចជាមាតា អ៊ីយកាយនឹងខ្ញុំបាទដែលតាំងចិត្តគិតប្រាថ្នាមកជ្រកនៅនឹងលោកនោះ ដូចទារកមានចិត្តអំណរនឹងបៅដោះមាតាដូចម្ដេចមិញ ក៏ឧបមាដូច្នោះ អ៊ីយកាយនឹងខ្ញុំបាទនោះ នឹងបានគិតជាកលឧបាយដូចម្ដេចកើតទេ ។

ជូជកព្រាហ្មណ៍នោះ ក៏អស់សង្ស័យៈហើយថា ដែលអ៊ុយកាយនឹងអ្នកឯង បានតាំងចិត្តសុចរិត មកជ្រកៈនៅធ្វើជាការនឹងៈយើងនេះ បើបានសំរេចការលើកវេលាណា យើងនឹងទំនុកបំរុងអ្នកទាំង ២ ជាធំជាងតាហានទាំងពួង ៗ ឆ្លើយតបថា ឯខ្ញុំបាទដែលរំពឹងគិតប្រឹងនឹងមកជ្រកនៅនឹងលោកនោះ មិនមែនប្រាថ្នាតែត្រឹមយសស័ក្តិប៉ុណ្ណោះទេ ព្រោះឃើញថា ការផែនដីសព្វថ្ងៃនេះ នឹងវៀវរកាយអស់ហើយ បាក់បានលោកមកទំនុកបំរុងតាណាប្រជានុកស្ត្រ ទើបបានស្ងិតនៅដល់ប៉ុណ្ណោះ ខ្ញុំបាទតាំងចិត្តរំពឹងគិតថា នឹងមកប្រាថ្នាតែជ្រកកោនជើងខននឹងលោកឲ្យបានសេចក្តីសុខប៉ុណ្ណោះទេ ៗ

ជូជកព្រាហ្មណ៍នោះក៏សោមនស្សត្រេកអរ ហៅនាំគេឲ្យចូលបរិភោគអាហារជាមួយ ៗ ទទួលមានមនុស្សបំរើស្និទ្ធចូលមកខ្សឹបប្រាប់ជូជកថា ឥឡូវឈ្មោះតុង, ឈ្មោះហោ ប្រើឲ្យនាំពត៌មានជាអាថ៌កំបាំងមកដល់លោក ហើយយកសំបុត្រហុចឲ្យទៅជូជក ៗ មើលមិនឲ្យនាំគេឃើញ ៗ ក្នុងសំបុត្រនោះសេចក្តីថា ឈ្មោះតុង, ឈ្មោះហោ សូមប្តឹងពីកិច្ចការគង់ទ័ពដំរីយើមកជូនមហាចេកជប្រាប ព្រោះដំរីយើធ្វើទោសអ៊ុយកាយរាយដំមានរបួសជាដំណំត្រាំត្រា ៗ ជូជកៈឃើញព្រហ្មណ៍នោះក៏គិតថា សមប្រកបនឹងពាក្យនាំៈគេនិយាយ ជូជកក៏រឹតតែពេះពាយរីកមុខជ្រះថ្លា ៗ នាំគេកៈឃើញ

ភរិយា ចូច្ចូត្រេកអរសប្បាយក៏គិតឃើញថា សំបុត្រនោះប្រហែលជា របស់ឈ្មួតុនី, ឈ្មួះហោយកប្ដីនមក អំពីជីវ័យយើធ្វើពាសអ៊ុយកាយជាប្រាកដ ឃើញថាសំបុត្រនោះត្រូវនឹងពាក្យយើង ការតាំងខ្លួនដែលគិតទុកមុនជា នឹងសម្រេចមិនខាន ។

ចូច្ចូក៏និយាយនឹងនាំតេកថា អ្នកចូរវិលត្រឡប់ទៅប្រាប់អ៊ុយកាយឲ្យ រំសាយទុក្ខក្ដៅក្រហាយចុះ ហើយឲ្យអ៊ុយកាយសប្បាយចិត្តខំគិតរកពេល ដែលនឹងលបរត់មកនោះ ជាយប់ម្ដៃថ្ងៃណា បានហើយ ឲ្យដំណឹងមក យើងៗនឹងឲ្យពួកទាហាននាំគ្នាទៅទទួល ។ នាំតេកថ្លែងតបថា ខ្ញុំបាទ គិតនឹងនៅក្នុងទីនេះមិនចង់ត្រឡប់ទៅវិញទេ ព្រោះការដែលទៅមក នោះ មានសេចក្ដីលំបាកណាស់ បើទៅមកញឹកញាយដូចគេនាំឲ្យ ជីវ័យដឹងការតាំងខ្លួនក៏នឹងបែកទៅជាឥតសារផលការ សុំលោកប្រើទាហាន ក្នុងកងទ័ពនេះ លបទៅយកកំណត់អ៊ុយកាយវិញស្រួលល្អជាង ។

ចូច្ចូថា ទាហានរបស់យើងច្រើនតែពួកអ្នកលើ បើនឹងប្រើទៅមក ក្រែងជីវ័យដឹង ព្រោះឃើញចរិយកនឹងបែកការ បើអ្នកឯងទៅវិញនឹង បានការជាស្រួល ។ នាំតេកធ្វើបែបជាព្រងើយកន្តើយឲ្យយូរ ហើយថា បើលោកនឹងឲ្យខ្ញុំទៅក៏ត្រូវប្រញាប់កុំឲ្យបង្អង់ ។ ចូច្ចូពួជូហោះក៏ត្រេកអរ ណាស់ ទើបបាត់យកព្រែយ៉ាងល្អនឹងមាសប្រាក់ឲ្យជារង្វាន់នាំតេក ។

គឺថា ដែលមហាចោរបកដឲ្យបំណាច់ឆ្នាំទខ្ញុំបាទទាំងអស់នេះ ព្រះគុណជាទម្ងន់ខ្លាំងណាស់ លុះខ្ញុំបាទនឹងទូលយកទៅឥឡូវនេះក៏ឃើញថាមិនស្រួល ព្រោះជាការប្រញាប់នឹងរៀបត្រឡប់វិលមកវិញ ក្រែងមនុស្សទាំងពួងឃើញនឹងសង្ស័យ ។

ឆាំតេកក៏ចងថ្វិលរបស់ទាំងនោះឲ្យបួចធូរវិញ ហើយក៏លាចុះទូកទៅរកអ៊ុយកាយក្នុងបន្ទាយដីវ៉យ ឆាំតេកក៏និយាយរ៉ាយរ៉ាប់រឿងដែលបានដោះស្រាយនឹងចួចុះនោះឲ្យអ៊ុយកាយស្តាប់គ្រប់ប្រការ ។ អ៊ុយកាយពុជូយោះក៏សោមនស្សណាស់ និយាយនឹងឆាំតេកថា គ្រាន់នេះបើកុំតែបានអ្នកមកជួបជាមុន ខ្ញុំក៏បានចំណេញតែឈើសាច់ទៅទទេ ។ ឆាំ-តេកថា ខ្ញុំនឹងលាទៅបន្ទាយកាំឡេងមើលកិរិយាឈ្មួតុង, ឈ្មួហា តើនឹងរិះគិតប្រការម្តេចខ្លះ ។ អ៊ុយកាយយល់ឃើញផង ។ ឆាំតេកក៏ចុះទៅឯបន្ទាយកាំឡេង ហើយក្លែងនិយាយនឹងកាំឡេងប្រាប់នឹងឲ្យឈ្មួតុង, ឈ្មួហាដឹងថា កាលដីវ៉យធ្វើទោសទណ្ឌកម្មអ៊ុយកាយនោះ គឺមិនមានសេចក្តីខុសអ្វីសោះ អស់លោកមុខមន្ត្រីឃើញសេចក្តីមិនគាប់គំបបួលគ្នាគិតទាប់ស៊ុំទោស ដីវ៉យត្រឡប់ខឹងស្រែកគំហកឲ្យលោកវិញ ហើយនិយាយជាពាក្យប្រទេះគោះមើលងាយ ឲ្យលោកបានសេចក្តីឈឺចិត្តថែមថែមទៀត ខ្ញុំបាទក៏នឹកខឹងណាស់ទៅដែរ ។

កាំឡេងព្នូថ្នោះក៏អស់សំណើច  មិនទាន់នឹងឆ្លើយថាប្រការម្ដេច ទទួលឈ្លូតុង, ឈ្លូហាដើរចូលមក ៗ នាំគេកក៏មិនក្រែកឲ្យកាំឡេង ៗ ដឹង កលនាំគេកក៏ធ្វើជានិយាយថា  ជីវយ៉ៅនោះជាមនុស្សអួតបេះអួតដឹង  ខឹង អួតថា  ខ្លួនមានប្រាជ្ញាមិនមានអ្នកឯណាស្មើ  ហើយក៏មិនបានស្រឡាញ់រាប់អានយើងជាមនុស្សខ្ញុំរាជការចាស់  រមែងពោលពាក្យប្រគោះ មើលងាយឲ្យយើងបានសេចក្ដីអៀនខ្មាសដល់មន្ត្រីទាំងពួង  ហើយកាំឡេងក៏ធ្វើជាសង្កៀតធ្មេញថាមិនប៉ុន្មានទេ ៗ នាំគេកក្រែងធ្វើជាខ្សឹបដាក់ ត្រចៀកកាំឡេងថាដូចនឹងហាមប្រាមថាកុំឲ្យនិយាយ  ក្រែងសេចក្ដីនោះ នឹងលាន់ឮទៅ ៗ កាំឡេងក៏ធ្វើជាងក់ក្បាលទទួល  ហើយសង្កៀត ធ្មេញ ៗ ឈ្លូតុង, ឈ្លូហាឃើញកិរិយានាំគេកចេញមកដូច្នោះក៏គិតថា ប្រហែលអ្នកទាំងនេះប្រែចិត្តគិតដោះចេញពីជីវយ៉ៅ  ដោយកំហឹងខឹង គុំគួន ហើយបានជានិយាយគ្នាយ៉ាងនេះ  ក៏ក្លែងល្បងសួរថា  ខ្ញុំឃើញ លោកទាំង ២ មិនសប្បាយដោយទុក្ខធុរៈក្នុងចិត្តយ៉ាងម្ដេចខ្លះ ៗ នាំគេក ឆ្លើយថា  យើងមានសេចក្ដីខឹងផុះនៅក្នុងចិត្ត  ដែលអ្នកនឹងមកចង់ដឹង នោះមិនត្រូវទេ  ឈ្លូតុង, ឈ្លូហាថា  យើងដឹងអស់ហើយថាលោកទាំង ២ នាក់នេះ  គិតស្ម័គ្រទៅនៅនឹងបុច្ចជាមហាឧបរាជ  តែគិតមិនសម តាមប្រាថ្នាទើបមិនសប្បាយ យើងនឹងនាំរឿងនេះទៅជំរាបជីវយ៉ៅឲ្យជ្រាប ៗ

ឆាំគេកឮដូច្នោះក៏ធ្វើជាតក់ស្លុតភ័យស្លក់មុខ សំឡឹងមើលមុខកាំឡេងធ្មឹងនៅនោះ កាំឡេងក៏ធ្វើជាខឹងហូតក្រប៊ីចេញហើយថា ការរបស់យើងតែងទុកជាការជាក់កំបាំង ហេតុម្តេចមកនាំឲ្យបែកសាយសុះទៅដូច្នេះ បើនឹងសម្ងំទុកឲ្យយូរ វាក៏នឹងយកពត៌មានទៅប្រាប់ដាវយ៉ីមែន យើងក៏នឹងដល់នូវសេចក្តីស្លាប់ ហេតុនេះ ត្រូវតែយើងសម្លាប់វាចេញសិន ហើយក៏ធ្វើជាស្ទុះទៅតាមនឹងកាប់ឈួតុង,ឈួហោ ។ ក៏ភ័យតក់ស្លុតស្ទុះរត់ចេញ ហើយថាលោកកុំអាលខឹង ខ្ញុំនឹងសុំជំរាបការពិតឲ្យជ្រាប។ កាំឡេងថា សេចក្តីពិតរបស់អ្នកទាំង ២ ដូចម្តេចខ្លះ ឲ្យឆ្លើយមកឆាប់ បើមិនឆ្លើយទេ យើងនឹងសម្លាប់ឥឡូវនេះ ។ ឈួតុង,ឈួហោថា ដែលខ្ញុំស្ម័គ្រមកនៅនឹងដាវយ៉ីនេះ មិនមែននឹងតាំងចិត្តមកនៅដោយសុច-រិតទេ មហាឧបរាជប្រើកលឧបាយឲ្យធ្វើជារត់មកចុះចូលនៅនឹងដាវយ៉ី ប្រាថ្នានឹងយកការរាក់ជ្រៅនឹងធ្ងន់ស្រាលក្នុងកងទ័ពដាវយ៉ី លបទៅប្រាប់ខាងណោះឲ្យដឹងនឹងគិតការតទៅ បើលោកនឹងស្ម័គ្រទៅនៅនឹងមហាឧបរាជមែន យើងខ្ញុំនឹងនាំទៅ ។ កាំឡេងសួរថា ដែលអ្នកនិយាយនេះជាសេចក្តីពិតត្រង់ឬ ? ។ ឈួតុង, ឈួហោក៏ទទួលស្បថស្បែថាមែនណាស់ ។ កាំឡេង,ឆាំគេកធ្វើជាទទួលអំណរក្រោកឈរគំនាប់ឈួតុង, ឈួហោ ហើយឱបរឹតខ្លួនទៅវិញទៅមក ហើយថាដែលអ្នកទាំង ២

និយាយនេះ ទើបមាដូចទេព្តាមកបញ្ចូលចិត្តឲ្យជួយយើង គ្រានេះយើងក៏អស់កំហឹងខឹងទឹងផ្អកហើយ ឯសេចក្តីដែលដំរីយើធ្វើទោសអ៊ុយកាយ យើងក៏ឲ្យលបទៅដំកប់មហាឧបកដចុះ ។ នាំគេកថា ខ្លួនខ្ញុំឯងជាអ្នកបានទៅដល់មហាឧបកដ ។ ឲ្យខ្ញុំវិលត្រឡប់មកឲ្យកំណត់ពេលយប់ថ្ងៃដែល ដែលអ៊ុយកាយទឹងចូលទៅនៅខាងណោះ ឥឡូវអ៊ុយកាយឲ្យខ្ញុំមកបបួលកាំទ្បេង ។

កាំទ្បេង, នាំគេកក៏បបួលឈ្មួតុង, ឈ្មួហោបរិភោគអាហារ ទាំងអស់គ្នាក៏ប្រឹក្សាទៅវិញទៅមក ។ លុះបរិភោគរួចហើយឈ្មួតុង, ឈ្មួហោក៏លាមកទីសំណាក់ ហើយតែងជាសំបុត្រសម្ងាត់ប្រើមនុស្សស្និទ្ធលបចេញទៅប្រាប់ចូច្ចថា ខ្ញុំបាទឈ្មួតុង, ឈ្មួហោ ដែលទៅនៅក្នុងកងទ័ពដំរីយើ បានបញ្ចុះបញ្ចូលកាំទ្បេងដែលជាមេទ័ពស្រួច មានចិត្តកំហឹងដំរីយើផ្សេងៗ កាំទ្បេងទទួលធ្វើជាកលសឹកខាងក្នុង បើមហាឧបរាជទឹងលើកកងទ័ពទៅច្បាំងនឹងដំរីយើវេលាណា កាំទ្បេងក៏ទឹងលើកទាហានចេញវាយខ្នងដំរីយើ ។ ឯនាំគេកក៏តែងសំបុត្រប្រើទាហានយកទៅដល់ចូច្ចសេចក្តីថា ខ្ញុំបាទ នាំគេកនឹងអ៊ុយកាយនឹងបាត់បែងទូកផ្ទុកស្បៀងអាហារចូលមកដល់បន្ទាយមហាឧបរាជឲ្យចាំមើលសំគាល់ បើឃើញទង់ក្អួបខៀវជាតមកនឹងក្បាលទូក គឺជាទូកខ្ញុំបាទហើយ សូមឲ្យលោកបាត់

ទាហានទៅទទួលចុះ ។

ឯចូនដំនឹងតាមសំបុត្រទាំង ២ ច្បាប់ដូច្នោះ ក៏ប្រឹក្សាទឹងមុខមន្ត្រីទាំងពួងថា គ្រានេះឈ្មុតុង, ឈ្មួរហាបកសំបុត្រមកដល់យើងថា កាំឡេងជាមេទ័ពស្រេច ទឹងទទួលជាគលសឹកក្នុងទ័ពដំរីយើ, មួយទៀតអ៊ុយកាយឲ្យនាំគេគមកដល់យើងថា អ៊ុយកាយទឹងមកចុះចូលនៅនឹងយើង ឥឡូវនាំគេគក៏ឲ្យសំបុត្រមកថា អ៊ុយកាយនឹងនាំគេគកំពុងរៀបទូកផ្ទុកស្បៀងអាហារ ដោតទង់ក្លែបខៀវជាសំគាល់នៅក្បាលទូកចេញមកជាសំគាល់ឲ្យយើងចាំទទួល តើសេចក្ដីទាំង ២ ប្រការនេះយ៉ាងម្ដេចយើងនៅមន្ទិលសង្ស័យណាស់ បើអ្នកឯណាដែលមានជម្រះប្រាជ្ញាគាប់ហានបន្ទិចូលទៅស្ដាប់ដំណឹងមើល ជាវៀចធ្វើត្រង់ក្នុងគងទ័ពដំរីយើបាន ។ ដៀវកានធ្វើយថា កាលមុនខ្ញុំបាទបានទទួលអាសាទៅនិយាយបញ្ចុះបញ្ចូលដំរីយើក៏មិនបានសម្រេចដូចប្រាថ្នា ដែលលោកមិនយកទោសនោះក៏ល្អហើយ តែខ្ញុំបាទនៅមានសេចក្ដីវិតក្កព្រួយក្នុងចិត្តខ្លាំងណាស់ គ្រានេះខ្ញុំបាទសុំយកអាសាតែខ្លួនទៅស៊ើបយកការណ៍មកឲ្យបានច្បាស់ ។

(នៅមានត)

# ពាក្យវប្បធម៌

លោក នាន-ហ៊ួ រៀបរៀង

លោក សម-ថាំង ពិនិត្យ

---

បណ្ណទូត ៖

ពាក្យនេះ ខ្មែរយើងទម្លាប់ប្រើមកដោយតម្រូវទៅនឹងពាក្យបារាំងថា (Planton) ។

ពាក្យថា "បណ្ណទូត" នេះ មិនដឹងប្រាកដ ជាកើតចេញមកពីប្រភពណា ឬ អង្គការណាមួយទេ ។ ប៉ុន្តែសព្វថ្ងៃនេះ ឃើញមានប្រើប្រាស់ពេញពាស តាមផ្លូវការ និងផ្លូវសារពត៌មាន រត់ដៃ រត់មាត់ទៅហើយ ។ គេទម្លាប់ប្រើពាក្យនេះសព្វថ្ងៃ សម្រាប់សំគាល់គោរងារ របស់បុគ្គលិករាជការក្នុងក្របខ័ណ្ឌជាន់តាបមួយផ្នែក ក្នុងពួកក្របខ័ណ្ឌភ្នាក់ងាររាជការជាតិដែលស្ថិតនៅក្រោមការត្រួតត្រាផ្ទាល់ នៃរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

បុគ្គលិកក្នុងក្របខ័ណ្ឌជាន់តាបនេះ មានមុខការខាងនាំកិច្ចការ, លិខិត, សំបុត្រចុតហ្មាយ ពីការិយាល័យមួយទៅការិយាល័យមួយ, ពីក្រសួងមួយ ទៅក្រសួងមួយ, ពីក្រុមមួយ ទៅក្រុមមួយ ។

បណ្ណទូត ជាពាក្យមគធៈ "សមាសនាម" ដោយរួមមកពីសព្ទ២គឺ "បណ្ណ" និង "ទូត"; "បណ្ណ" ប្រែតាមអក្ខរាទរូបថា "ស្លឹកឈើ",

ក្រដាស ឬបន្ទះលោហធាតុ ដែលគេផែរស្តើងៗ . . . , ជាឧត្តមប្បដិរូបថា សៀវភៅ, ក្រាំង . . កំបុន, ខ្មែរយើងទម្លាប់គានថា "ប័ណ្ណ"ៗ

"ទូត" ប្រែថា អ្នកដែលគេបញ្ជូន, ដែលគេប្រើទៅ, អ្នកនាំការ, នាំដំណឹងពីម្ខាងទៅម្ខាង ៗ

កូនវចនានុក្រមខ្មែរ ពាក្យថា "ទូត" នេះ លោកពន្យល់ថា មន្ត្រីសក្តិធំ ដែលរាជការចាត់ទៅជាតំណាង ដើម្បីនិយាយការផ្ទាល់នឹងរដ្ឋបាលប្រទេសដទៃ ៗ តាមសេចក្តីពន្យល់នេះ ឃើញថាពាក្យ ទូត ប្រើបានចំពោះតែមន្ត្រីជាន់ខ្ពស់ ដែលជាទីទុកចិត្តនៃរាជរដ្ឋាភិបាល ទឹងជាទីគាប់ព្រះរាជហឫទ័យនៃអង្គព្រះមហាក្សត្រ ហើយទ្រង់ចាត់ជាតំណាងប្រទេស ឲ្យទៅប្រាស្រ័យការផ្ទាល់នឹងរដ្ឋបាលនៃប្រទេសជាមិត្តណាមួយ ៗ

តាមការសង្កេតរៀងរាមមកឃើញថាពាក្យ ទូត នេះ បើអង្គការណា ឬបុគ្គលណាមួយចាត់ប្រើទៅ ទូតនោះជារបស់អង្គការ ឬរបស់បុគ្គលនោះ ម៉្លោះហើយតែងយកនាមរបស់អង្គការ ឬបុគ្គលអ្នកចាត់ប្រើនោះ មកដាក់ពីខាងដើមនៃពាក្យជាដរាប ពុំដែលចន្លោះសោះឡើយ ៗ

សូមលើកឧទាហរណ៍ខ្លះមកបង្ហាញដូចតទៅនេះ ៖-

មន្ត្រីជាន់ខ្ពស់ ដែលព្រះរាជាទ្រង់ចាត់ឲ្យទៅប្រាស្រ័យកិច្ចការផ្ទាល់

ជាមួយនឹងរដ្ឋបាលប្រទេសដទៃជាមិត្ត មន្ត្រីនោះហៅថា « រាជទូត », ១. រាជទូតប្រទេសកម្ពុជា ប្រចាំនៅប្រទេសឥណ្ឌា ឬហៅថាឯកអគ្គរាជទូតក៏បាន ។

មន្ត្រីសក្តិធំក្នុងប្រទេសណាមួយ ដែលគ្មានព្រះមហាក្សត្រសោយរាជ្យ ហើយដែលប្រមុខរដ្ឋនៃប្រទេសនោះ ចាត់ប្រើទៅប្រាស្រ័យកិច្ចការផ្ទាល់នឹងរដ្ឋបាលប្រទេសដទៃជាមិត្ត មន្ត្រីនោះហៅថា "រដ្ឋទូត" ឬឯកអគ្គរដ្ឋទូតក៏បាន , ១. រដ្ឋទូតប្រទេសឥណ្ឌាប្រចាំប្រទេសកម្ពុជា ។

ទេវបុត្រ ឬទេវតាអង្គណា បើព្រះឥន្ទ ឬទេវតាចាត់ប្រើមក ទេវបុត្រ ឬទេវតាអង្គនោះហៅថា « ទេវទូត » ១. ទេវទូត ដែលមកនិម្មិតជារូបមនុស្សចាស់ , មនុស្សឈឺ, មនុស្សស្លាប់ នឹងអ្នកបួស បង្ហាញព្រះសិទ្ធត្ថកុមារ ក្នុងកាលដែលស្តេចទៅប្រពាតសួនឧទ្យាន ជាមួយនឹងនាយសារថី នាំព្រះទ័យព្រះអង្គធុញទ្រាន់នឹងរាជសម្បត្តិ រហូតដល់ចង់យាងចេញទៅទ្រង់ព្រះផ្នួស ។

បើជាព្រះភិក្ខុសង្ឃអង្គណា ដែលសង្ឃប្រមុខចាត់ប្រើឲ្យទៅធ្វើកិច្ចការអ្វីមួយ ព្រះភិក្ខុសង្ឃអង្គនោះហៅថា „សមណទូត" ១ ព្រះសោណត្ថេរនឹងព្រះឧត្តរត្ថេរជាសមណទូត ដែលព្រះមោគ្គលីបុត្តតិស្សត្ថេរជាសង្ឃប្រមុខ បានចាត់ឲ្យនាំវប្បធម៌ព្រះពុទ្ធសាសនាមកផ្សាយ នៅជ្រោយ

សុវណ្ណភូមិក្រោមរជ្ជកាលនៃព្រះបាទធម្មាសោក ជាមហាក្សត្រប្រទេស ផណ្ដៀសម័យបុរាណ ។

ឧទាហរណ៍ ដែលទាញយកមកបង្ហាញយ៉ាងខ្លីប៉ុណ្ណេះ ជាការបញ្ជាក់ឲ្យឃើញថាពាក្យ ទូត នេះ បើអង្គការណា ឬបុគ្គលណាបាត់ប្រើទៅ ទូតនោះជារបស់អង្គការនោះ, ជារបស់បុគ្គលនោះ គឺតែងមាននាមរបស់អង្គការ ឬរបស់បុគ្គលនោះ ដាក់នៅពីមុខជាគ្រឿងសំគាល់ជាដរាបតាំងដែលមាន ។

បើយើងវិលមកមើលពាក្យដែលគេប្រើសព្វថ្ងៃថា «បណ្ណទូត» ម្ដងទៀត តើទូតក្នុងនេះជារបស់អ្នកណា ?, ឆ្លើយថា ជារបស់ «បណ្ណៈ» ។ ចុះ «បណ្ណៈ» នេះ គឺអ្នកណា? ថា «បណ្ណៈ» គឺស្លឹកឈើ, ក្រដាស សៀវភៅ ។ល។ បើដូច្នេះ មានតែបណ្ណទូតនេះ ជាទូតរបស់វត្ថុទាំងលើនេះឯង ។

តាមរបៀបមគធភាសា កាលបើចង់ដឹងសព្ទណាមួយ ដែលជាសមាសនាមយ៉ាងនេះជាខុស ឬត្រូវ លោកបង្គាប់ឲ្យបំបែកជាបទវិគ្រោះមើល ។ បើបំបែកសព្ទនោះជាបទវិគ្រោះទៅហើយ ឃើញថាមិនទទឹងទាស់នឹងក្បួនវេយ្យាករណ៍ទេ ហើយឯសេចក្ដីនៃបទវិគ្រោះនោះសោតក៏ស្ដាប់បានផង ទើបលោកកំណត់ពាក្យនោះជាត្រឹមត្រូវបាន ។

សព្ទថា រាជទូត, រដ្ឋទូត, ទេវទូត និងសមណទូត នេះជាបទវិគ្រោះបានដូចតទៅនេះ :-

"រាជទូត" បានជាបទវិគ្រោះថា រញ្ញោ·ទូតោ > រាជទូតោ អ្នកនាំការរបស់ស្តេច ។

"រដ្ឋទូត" បានជាបទវិគ្រោះថា រដ្ឋស្ស·ទូតោ > រដ្ឋទូតោ អ្នកនាំការរបស់រដ្ឋ ។

"ទេវទូត" បានជាបទវិគ្រោះថា ទេវានំ·ទូតោ > ទេវទូតោ អ្នកនាំការរបស់ទេវតាទាំងឡាយ ។

"សមណទូត" បានជាបទវិគ្រោះថា សមណស្ស ទូតោ > សមណទូតោ អ្នកនាំការរបស់សមណសង្ឃ ។

បទវិគ្រោះដូចខាងលើនេះ លោកហៅថា ឆដ្ឋី តប្បុរិសសមាស ។

ចំណែកពាក្យថា "បណ្ណទូត" ក៏គេអាចបានវិគ្រោះជាឆដ្ឋី តប្បុរិសសមាសទៅបានដែរ ប៉ុន្តែទាស់នឹងស្តាប់សេចក្តីក្នុងបទវិគ្រោះនោះពុំបាន ។ "បណ្ណទូត" បានជាបទវិគ្រោះថា បណ្ណស្ស-ទូតោ បណ្ណទូតោ > អ្នកនាំការរបស់បណ្ណ ។ ឃើញថាសេចក្តីនេះ ស្តាប់ពុំបានទាល់តែសោះ ព្រោះហេតុថា "បណ្ណ" មិនមែនជាមេបញ្ជាការរបស់ "ទូត" ទេ ។ កាលបើបទវិគ្រោះមានសេចក្តីស្តាប់មិនបានដូច្នេះហើយ តាមរបៀបវេយ្យាករណ៍បាលីលោកទុកសមាសនាមនោះជាខុស ។

ឥឡូវ យើងវិភាគមកពិចារណាតាមការសំគាល់ឃើញរបស់យើងវិញ ថា តើភ្នាក់ងារកូនក្របខ័ណ្ឌដែលយើងនាំគ្នាហៅថា "បណ្ណទូត" នេះ ជាអ្នកនាំកិច្ចការរបស់បណ្ណ ឬមួយក៏នាំកិច្ចការរបស់ក្រសួង,របស់ក្រុម? ឆ្លើយថា ភ្នាក់ងារប្រភេទនេះ មិនមែនជាអ្នកនាំកិច្ចការរបស់បណ្ណទេ ប្រាកដជាអ្នកនាំកិច្ចការរបស់ក្រសួង, របស់ក្រុមដោយពិត ។ បើដូច្នោះ ភ្នាក់ងារប្រភេទនេះ គឺជាអ្នកនៅក្រោមបង្គាប់របស់ចៅក្រសួង នាយក្រុម ហើយមានមុខងារជាអ្នកនាំកិច្ចការរបស់ក្រសួង របស់ក្រុម ដែលខ្លួននៅធ្វើការ ទៅកាន់ក្រសួង កាន់ក្រុមដទៃ ៗ ដូចជាយើងធ្លាប់ឃើញមកស្រាប់ ។

ដោយហេតុដូចបានអធិប្បាយ ជាសង្ខេបមកពីខាងលើនេះហើយ បានជាគណៈកម្មការវប្បធម៌ យល់ថាមិនគួរយកសព្ទថា «បណ្ណទូត» នេះមកប្រើជាគោរមងាររបស់បុគ្គលិក កូនក្របខ័ណ្ឌ ជាន់ទាបមួយពួក ដែលថា « (Planton) » នេះឡើយ ព្រោះថា :

១- គណៈកម្មការវប្បធម៌ មានសេចក្ដីស្ដាយចំពោះពាក្យ ទូត នេះពន់ពេក ព្រោះពាក្យនេះខ្មែរយើងធ្លាប់ប្រើធ្លាប់ហៅនិយាយស្ដី ជាយូរអង្វែងមកហើយ ៗមានព្រំដែនខ័ណ្ឌសីមាជាក់ច្បាស់ណាស់ ។ គឺថាកាលបើយើងឮគេនិយាយថាពួកទូត, អគ្គទូត, ឡានទូត ដូច្នេះជាដើម យើងស្ដាប់ន័យរបស់ពាក្យនេះបានភ្លាមថា អ្នកនោះឯងជាមន្ត្រីជាន់ខ្ពស់ ជា

អ្នកបំរើរបស់រដ្ឋបាលប្រទេសណាមួយ ឬក៏របស់បន្ទនោះឯងជារបស់លោក អ្នកបំរើប្រទេសណាមួយ ៗ លុះយើងយកពាក្យ ទូត នេះដោយគ្រាន់តែថែមសព្ទមួយពីខាងមុខថា „បណ្ណ" ភ្ជាប់មកប៉ុណ្ណោះមកហៅប្រើជាគោរមងាររបស់អ្នកងារជាន់ទាបនេះទៅវិញ ឃើញថាជាការនាំឲ្យខូចទំហំន័យរបស់ពាក្យផង ទាំងជាការនាំឲ្យយើងលែងស្គាល់សេចក្ដីរបស់ពាក្យនេះបានដោយភ្លាមៗផង ព្រោះត្រូវតែចាំសួរបញ្ជាក់ថែមទៀតសិនថា ទូត នោះគឺជានរណា? ៗ

សូមអភ័យទោស ! ក្នុងដែលជំរាបខាងលើនេះ ពុំមែនគណៈកម្មការវប្បធម៌ មិនចង់ឲ្យបុគ្គលិកតូចតាច ឆានណោះ, មានគោរមងារប្រហាក់ប្រហែលនឹងអ្នកធំនោះទេ ការប្រកាន់វណ្ណៈខ្ពស់ ទាប ដូច្នេះពុំចូលក្នុងចេតនាបញ្ញារបស់គណៈកម្មការវប្បធម៌ឡើយ ៗ ដោយចំពោះ គឺគណៈកម្មការវប្បធម៌ គ្រាន់តែមានសុទ្ធចិត្តចង់រក្សាទុកនូវទំហំន័យរបស់សព្ទនីមួយៗ កុំឲ្យរលាយលក់ត្រាំដែនខណ្ឌសីមាតែម្យ៉ាងប៉ុណ្ណោះឯង ៗ សូម្បីក្នុងវចនានុក្រមខ្មែរ ក៏បានពន្យល់ថាទូតគឺជាមន្ត្រីសក្ដិធំដែលរាជការតាំងទៅជាតំណាងដើម្បីនិយាយការផ្ទាល់នឹងរដ្ឋបាលប្រទេសដទៃដែរ ៗ

៦ - គណៈកម្មការវប្បធម៌ត្រិះរិះទៅឃើញថាពាក្យ បណ្ណទូត នេះមានដំណើរមិនស្របទៅតាមក្បួនវេយ្យាករណ៍បាលីផង ទាំងសេចក្ដីល្អិត

របស់សត្វនេះក៏ស្លាប់មិនបានផង ដូចបានជំរាបមកហើយខាងលើនេះស្រាប់ ។

ហេតុដូចបានជំរាបមកខាងលើនេះហើយ បានជាគណៈកម្មការវប្បធម៌ ជ្រើសយកពាក្យមួយមាត់ថា « លេខហារី » មកជាជំនួសពាក្យថា "បណ្ណ« នេះទៅវិញ ។ លេខហារីបើផ្ទឹមទៅនឹងពាក្យបារាំង មានន័យដូចគ្នានឹងពាក្យថា (Planton) ។

"លេខហារី" ជាពាក្យមគធ: រួមមកពីសព្ទពីរគឺ: លេខ: ១ សព្ទ នឹង ហារី ១ សព្ទ ។ លេខ: ប្រែតាមអត្ថានុរូបថា «ការសរសេរ,ការគូស, គូរ,ពាស,គំនូរ,ស្នាម,គំនូស,អក្សរ,សំបុត្រ,បុតហ្មាយ ។ អត្ថប្បដិរូបថា «ទេវតា» ។ ហារី: ប្រែថា អ្នកដែលនាំយកអ្វីៗទៅ, រួមសព្ទទាំងពីរចូលគ្នាជា «លេខហារី» (ជាសមាសនាម) បានន័យថា បុរសដែលមានភារៈនាំយកសំបុត្របុតហ្មាយ ។ លេខហារី សរសេរ "ស្រៈអេ–ល នឹង ខ, ហ ស្រៈ អា រ- នឹង ភ្លៀ អានថា (លេ-ខ័ក-ហារី) បើជាស្ត្រីហៅថា „លេខហារិនី" ដូចនេះពាក្យបារាំងថា (Planton) ខ្មែរយើងថា «លេខហារី„ បើភ្នាក់ងារនេះជាស្ត្រីគេហៅថាលេខហារិនី ។

សព្ទនេះអាចប្រើបានជាសាធារណៈមិនមែនចំពោះតែភ្នាក់ងាររបស់រាជការទេ សូម្បីតែភ្នាក់ងារក្នុងក្រុមជាឯកជន ដែលមានមុខការជាអ្នកនាំ

លិខិតសំបុត្រស្នាមរបស់ក្រុមពីនេះទៅនោះ គឺហៅថាលេខហារី ឬ លេខហារិនីបានដូចគ្នា ។

ក្នុងវចនានុក្រមភាគទី១ មានពាក្យមួយសំរាប់ទៀតដែរថា "គណ្ឌិល" សរសេរ (ក-ណ-ជើងឌ-ស្រៈឥ និង-ល) លោកពន្យល់ថា អ្នកនាំដំណឹងទៅមក អ្នកនាំសំបុត្រ អ្នករត់សំបុត្រ (ហៅថាគណ្ឌិលជន ឬ គណ្ឌិលបុរស ក៏បាន) ។ ក៏ប៉ុន្តែ គណៈកម្មការវប្បធម៌ ពុំបានរើសយកពាក្យគណ្ឌិលនេះ មកជំនួសពាក្យបារាំងថា (Planton) នោះឡើយ ព្រោះហេតុពាក្យគណ្ឌិលនេះមានអត្ថរូបជ្រាលជ្រៅពេក ហើយថែមទាំងសូរសំឡេងក៏ពុំសូវពិរោះដល់ត្រចៀកផង ដូច្នេះទើបគណៈកម្មការដំកល់គណ្ឌិលនេះទុកមួយអន្លើ ហើយជ្រើសរើសពាក្យថា លេខហារី មកជំនួសពាក្យបារាំងថា (Planton) ទៅវិញ ។

ក្នុងអវសានកថានេះ តាងនាមគណៈកម្មការវប្បធម៌ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកអ្នកអានដោយយកចិត្តទុកដាក់ទាំងឡាយ ហើយសូមសន្យាថា តទៅបើមានឱកាសល្មមទៀតបាន ខ្ញុំនឹងដកយកពាក្យខ្លះដែលគណៈកម្មការវប្បធម៌បានប្រែ ឬបង្កើតរួចហើយនោះ មកពន្យល់ជាសេចក្ដីឲ្យងាយស្ដាប់ជាមិនខាន ។ ក្នុងទីនេះសូមបញ្ចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

---

ផ្នែកកំណត់និងប្រវត្តិការណ៍

# បុណ្យនមស្ការព្រះសក្យមុនីចេតិយ

លោក ចង-វង រៀបរៀង

ដោយព្រះរាជក្រឹត្យលេខ ៧៣ ន.ស- ចុះថ្ងៃទី ២៤ មករា ១៩៥៨ ទ្រង់កំណត់ទុកជាផ្លូវការថា នៅថ្ងៃ១៥ កើត និងថ្ងៃ ១ រោច ខែពិសាខ រៀងរាល់ឆ្នាំតទៅ ត្រូវធ្វើបុណ្យនមស្ការព្រះសក្យមុនីចេតិយ នាមុខស្ថានីយរាជអយស្ម័យយានក្រុងភ្នំពេញ ជាទីប្រតិស្ឋានព្រះបរមសារីរិកធាតុ នៃព្រះសក្យមុនីសម្ពុទ្ធបរមគ្រូនៃយើង ទើបបុណ្យនេះ បានធ្វើឡើងក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ចំនួន ២ ឆ្នាំមកហើយ គឺនៅ ព.ស. ២៥០១-២៥០២ (គ.ស. ១៩៥៨-១៩៥៩ ) ក្រោយពីបុណ្យ ព-ស-២៥០០ មក ។

ឯបុណ្យនមស្ការព្រះសក្យមុនីចេតិយ នៅ ព.ស- ២៥០៣ (១៩៦០) នេះ បានប្រារព្ធធ្វើដូចតទៅនេះ ៖

ថ្ងៃទី ១ :

ថ្ងៃ១៥កើតខែពិសាខ ព.ស. ២៥០៣ (១០-៥-៦០)

ពេលរសៀលម៉ោង ១៧ - ៣០ មានការជួបជុំព្រះសង្ឃ ៨០ អង្គ

ព្រះរាជវង្សានុវង្ស ប្រធានសភាទាំងពីរ នាយករដ្ឋមន្ត្រី ថានហ្វានគុណាការជាន់ខ្ពស់ សមាជិករដ្ឋាភិបាល សមាជិកសភាទាំងពីរ ប្រធាននៃពុទ្ធិ-កសមាគមទាំង ៣ មន្ត្រីគ្រប់តំណែង ទាំងទាហានទាំងស៊ីវិល លោកស្រី ព្រមទាំងឧបាសក ឧបាសិកា និមន្ត ស្តេចយាង អញ្ជើញមកដល់កន្លែងប្រគបពិធីបុណ្យ រង់ចាំគោរពសម្តេចក្រុមព្រះមុនីរេតប្រ-ធានក្រុមប្រឹក្សារាជានុសិទ្ធិ ។

លុះដល់ម៉ោង ១៨ ·០០ សម្តេចក្រុមព្រះមុនីរេត ប្រធានក្រុមប្រឹក្សារាជានុសិទ្ធិ ស្តេចយាងដល់ ដោយមានព្រះរាជបរិពារផ្តល់ព្រះអគ្គតាមហៃ ។

ទាហានក្រុមរក្សាព្រះអគ្គ ក្រុមខេមរកូមិន្ទ ក្រុមក្មេងកងវរសេនាតូចរក្សាព្រះអគ្គ ក្រុមតន្ត្រីព្រះរាជទ្រព្យ ធ្វើការកិច្ចតាមទម្លាប់ ។

លុះសម្តេចក្រុមព្រះមុនីរេត ប្រធានក្រុមប្រឹក្សារាជានុសិទ្ធិ ទ្រង់គង់ប្រថាប់លើព្រះពន្លាហើយ ក៏ធ្វើពិធីគោរពទង់ជាតិ ទង់សាសនា ដោយមានសិស្សប្រុស-ស្រី បន្លឺបទនគររាជ និងបទសរភញ្ញ ។ គ្រានោះព្រះសង្ឃ គ្រហស្ថ ក៏បានក្រោកឈរបែរព្រះភក្ត្រ-មុខគោរពព្រះសក្យមុនីចេតិយ ។ តមក ឯកឧត្តម ជូ ព្រឿង នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ ថ្លែងក្នុងនាមនៃព្រះរាជរដ្ឋាភិបាលខូវសុនរេកថា សំដែងសេចក្តីគោរពចំពោះព្រះសក្យមុនីចេតិយ មានសេចក្តីដូចតទៅនេះ៖

សូមព្រះរាជទានក្រាបបង្គំទូល សម្តេចក្រុមព្រះ ជាប្រធាន ក្រុមប្រឹក្សារាជានុសិទ្ធិ-

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ក្នុងនាមនៃព្រះរាជរដ្ឋាភិបាល ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានទទួលអំណរយ៉ាងជ្រាលជ្រៅចំពោះព្រះករុណាធិគុណ នៃសម្តេចជាម្ចាស់ ដែលបានស្តេចយាងមកជាព្រះអធិបតីភាព ទីងជាព្រះរាជកិត្តិយសក្នុងពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ នាថ្ងៃនេះ ។

សូមទ្រង់ព្រះមេត្តាប្រោស,

ព្រះបរមសារីរិកធាតុនេះ ពិតជាព្រះអដ្ឋិធាតុនៃព្រះសម្ពុទ្ធបរមគ្រូជាម្ចាស់នៃយើង ដែលសម្តេចព្រះឧបយុវរាជ បានទ្រង់ព្រះមេត្តាប្រោសព្រះរាជទានឲ្យមានពិធីដង្ហែជាឧឡារិកពីព្រះបរមរាជវាំង មកដំកល់លើព្រះសក្យមុនីចេតិយ ក្នុងឱកាសពិធីបុណ្យពុទ្ធសករាជ ២.៥០០ វស្សា កាលពីថ្ងៃទី ១២ ឧសភា ១៩៥៧ ។

លំដាប់មក ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យលេខ ៧៣ ន.ស ចុះថ្ងៃទី ២៤ មករា១៩៥៨ កំណត់ឲ្យធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយនេះ នៅថ្ងៃ ១៥ កើត ទីងថ្ងៃ ១ រោចខែពិសាខរៀងរាល់ឆ្នាំ តាំងតាំងទុកបុណ្យនេះជាបុណ្យជាតិ ។

ជាកិច្ចអនុវត្តន៍តាមព្រះរាជក្រឹត្យខាងលើនេះ ក្រសួងធម្មការ ដោយ

រួបរួមទាំងរដ្ឋមន្ត្រីក្រសួងនានា ព្រមទាំងសាលាក្រុង ទាំងសមាគមពុទ្ធសាសនា បានចាត់វិធានការបុណ្យនេះចំនួន ២ ឆ្នាំ កន្លងមកហើយ ឃើញថា ពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ មានអាយុតំរប់ ៣ ឆ្នាំ ទាំងឆ្នាំនេះ ។

សូមទ្រង់ព្រះមេត្តាប្រោស ,

ឱកាសនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជតានព្រះរាជកាស សម្តេចជាម្ចាស់ ថ្វាយសេចក្តីគោរពចំពោះព្រះបរមសារីរិកធាតុ ទាំងព្រះគុណដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ តាមន័យដូចតទៅនេះ ៖

សូមនមស្ការព្រះសមណគោតមបរមគ្រូជាម្ចាស់ ថ្ងៃនេះ ជាថ្ងៃ ១៥ កើតខែពិសាខ ដែលព្រះអង្គទ្រង់ប្រសូត្រ ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ ទាំងទ្រង់ព្រះបរិនិព្វាន ជាឧត្តមឫក្សប្រកបដោយសុភមង្គលយ៉ាងខ្ពង់ខ្ពស់ ដែលពួកពុទ្ធបរិស័ទបានចងចាំទុកជាទិច្ចកម្មដួងចិត្តរបស់ខ្លួន នូវព្រឹត្តិហេតុដ៏អស្ចារ្យរបស់ព្រះអង្គ ឥតមានភ្លេចសោះឡើយ ។

បពិត្រព្រះសម្ពុទ្ធបរមគ្រូជាម្ចាស់,

ព្រះអង្គទ្រង់បរិនិព្វានទៅ ២៥០៣ ឆ្នាំហើយ ប៉ុន្តែព្រះពុទ្ធសាសនាដែលជាធម៌របស់ព្រះអង្គក្តី, ព្រះបរមសារីរិកធាតុរបស់ព្រះអង្គក្តី, ព្រះពុទ្ធរូបជាទីរឭកចេតិយសួងព្រះអង្គក្តី បានបិតនៅគង់វង់តាំងអស់

ស្ទើរតែគ្មានខ្វះអក្ខរៈ ឬបទបាឋព្រះគាថាណាមួយឡើយ ។

សាសនធម៌របស់ព្រះអង្គ បានមកប្រតិស្ឋាននៅក្នុងប្រទេសកម្ពុជា អស់រយៈកាលជាយូរអង្វែងឆ្នាំហើយ គឺតាំងពីសតវត្សរ៍ទី ១០ នៃពុទ្ធសករាជម៉្លេះ គិតទៅជាង ១.០០០ ឆ្នាំហើយ តែអាស្រ័យហេតុដោយគុណធម៌ គឺជំនឿនិងការគោរពយ៉ាងមុតមាំនៃព្រះមហាក្សត្រខ្មែរនិងប្រជាជាតិខ្មែរទាំងឡាយ ព្រះបរមពុទ្ធោវាទរបស់ព្រះអង្គ សឹងនៅមានថិរភាពនិងវឌ្ឍនភាពរុងរឿងជាលំដាប់ ហាក់បីដូចជាកាលព្រះអង្គគង់ធមាននៅឡើយ ។

បពិត្រព្រះសម្មាសម្ពុទ្ធបរមគ្រូ,

ថ្ងៃនេះ ជាអភិលក្ខិតកាល ប្រកបដោយសិរីសួស្ដីជ័យមង្គលដ៏ប្រសើរ ប្រជាជាតិខ្មែរតាំងមូល មានសម្ដេចក្រុម ព្រះជាប្រធានក្រុមប្រឹក្សាភពជាទុសិទ្ធិ បានស្ដេចយាង-អញ្ជើញមកជួបជុំក្នុងទីនេះ ដើម្បីធ្វើពិធីនមស្ការបូជា ចំពោះព្រះបរមសារីរិកធាតុរបស់ព្រះអង្គដែលប្រតិស្ឋាននៅលើព្រះសក្យមុនីចេតិយនេះ ដោយគ្រឿងសក្ការបូជាមានទៀនធូប និងផ្កាកម្រងជាដើម ដើម្បីជាទីរលឹកដល់ព្រះអង្គ ដែលទ្រង់ប្រកបដោយមហាករុណាគុណជាអនន្ត ហើយបានប្រតិស្ឋានព្រះបរមពុទ្ធោវាទ ឲ្យសព្វសត្វគ្រប់រូបក្រេបជញ្ចក់យកអត្ថរស គឺប្រតិបត្តិតាម ដរាបមកដល់សព្វថ្ងៃនេះ ។

បពិត្រព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់,

ក្នុងព្រះបរមនាមនៃសម្តេចព្រះមហាក្សត្រិយានី សម្តេចក្រុមព្រះប្រធានក្រុមប្រឹក្សារាជានុសិទ្ធិ, ក្នុងនាមនៃសម្តេចឧបយុវរាជ និងក្នុងនាមនៃ នៃព្រះរាជរដ្ឋាភិបាល រដ្ឋសភា ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំងប្រជាជាតិខ្មែរទាំងមូល ខ្ញុំព្រះអង្គសូមបួងសួងចំពោះគុណព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិ សូមជួយអភិបាលសម្តេចទាំង ២ ព្រះអង្គនិងក្រុមប្រឹក្សារាជានុសិទ្ធិ ឲ្យបានប្រកបដោយសេចក្តីសុខចំរើន រុងរឿងជាភិយ្យោភាពតទៅ ។

មួយវិញទៀត សូមគុណព្រះរតនត្រ័យជួយប្រោសព្រំពិភពលោកទាំងមូលឲ្យបានសន្តិភាព ប្រាសចាកការចងពៀរព្យាបាទគ្នាទៅវិញទៅមកតាំងពីពេលនេះតទៅ ។

មួយវិញទៀត ទូលព្រះបង្គំជាខ្ញុំ សូមប្រមូលកុសលរាសីទាំងអស់ដែលកើតអំពីពិធីបុណ្យនេះ ក្រាបបង្គំថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធ នៃព្រះសពព្រះករុណាព្រះមហាកាត្ថានគោដ្ឋ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសទទួលនូវឥដ្ឋមនុញ្ញផលនេះ ដោយព្រះរាជហឫទ័យប្រកបដោយសោមនស្សចេតនា ហើយសូមព្រះអង្គបានទទួលនូវព្រះបរមសុខក្នុងសម្បត្តិទាំង៣ប្រការ គឺសម្បត្តិមនុស្ស សម្បត្តិទេវតា និងសម្បត្តិព្រះនិព្វានជាអវសានជាតិរបស់ព្រះអង្គ កុំបីឃ្លាតឡើយ ។

លុះចប់សុន្ទរកថា នៃឯកឧត្តម ជូ-ព្រឿង នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការហើយ គឺធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយ ជាឧឡារិក ដោយលោក ឈឹម ស៊ុមទ៌ សាស្ត្រាចារ្យនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ជាអ្នកនាំពុទ្ធបរិស័ទ មានសម្តេចក្រុមព្រះមុនីវេត ប្រធានក្រុមប្រឹក្សាពជានុសិទ្ធិជាដើម ទ្រង់ទទួលតាមសូត្រតាម ៗ បន្ទាប់ពីនេះ បានធ្វើពិធីប្រទក្សិណព្រះសក្យមុនីចេតិយបូជាផ្កាកម្រង ដោយសម្តេចក្រុមព្រះមុនីវេតប្រធានក្រុមប្រឹក្សាពជានុសិទ្ធិ ព្រមទាំងវរៈជនទាំងអស់ មានលោកអាចារ្យដែលជាអ្នកនាំព្រះរាជដំណើរ ៗ ឯព្រះសង្ឃ មន្ត្រីពុទ្ធបរិស័ទ បានចេញពីវេទិកាមកឈរគោរពចំពោះព្រះសក្យមុនីចេតិយ តាមទីកន្លែងដែលគណៈកម្មការរៀបចំប្រគេន-ជូនក្នុងពេលនោះ ៗ

សម្តេចក្រុមព្រះមុនីវេតប្រធានក្រុមប្រឹក្សាពជានុសិទ្ធិ ស្តេចយាងប្រថាប់លើព្រះពន្លាវិញ ៗ ព្រះសង្ឃ ៨០អង្គ ត្រឡប់មកគង់លើវេទិកាវិញដែរ ៗ

តមក ព្រះសង្ឃក៏បានចំរើនពុទ្ធជ័យមង្គលគាថា ៗ

សម្តេចក្រុមព្រះមុនីវេតប្រធានក្រុមប្រឹក្សាពជានុសិទ្ធិ ស្តេចយាងត្រឡប់ ដោយមានព្រះរាជបរិពារដែលតាមហែ ៗ

បន្ទាប់ពីនេះមក បានបើកឱកាសឲ្យពុទ្ធបរិស័ទគ្រប់ប្រភេទចូលធ្វើសក្ការបូជារហូតដល់ម៉ោង ២១ ៗ ចាប់តាំងពីម៉ោង ២០ មក ពិធី

វិសាខបូជា ក្រោមកិច្ចចាត់ចែងនៃពុទ្ធិកសមាគមតាំង ៣ ក្នុងការឧបត្ថម្ភនៃក្រសួងធម្មការ រហូតដល់ម៉ោង ១ ជាង អធ្រាត្រ ។

ថ្ងៃទី២:

ថ្ងៃ ១ រោចខែពិសាខ ព.ស–២៥០៣ (១១–៥–៦០)

ពេលព្រឹក ម៉ោង ៨ ៣០ ជួបជុំព្រះសង្ឃ ៨០ អង្គ ព្រះរាជវង្សានុវង្ស ប្រធានសភាតាំង២ នាយករដ្ឋមន្ត្រី ចាន់ហ្វាន់គុណការជាន់ខ្ពស់ សមាជិករដ្ឋាភិបាល សមាជិកសភាតាំង ២ ប្រធាននៃពុទ្ធិកសមាគមតាំង ៣ មន្ត្រីគ្រប់តំណែង តាំងទាហាន តាំងស៊ីវិល លោកស្រី ព្រមតាំងឧបាសក ឧបាសិកា និមន្ត ស្តេចយាង អញ្ជើញដល់ រង់ចាំគោរពសម្តេចព្រះមហាក្សត្រិយានី និងសម្តេចក្រុមព្រះប្រធានក្រុមប្រឹក្សារាជានុសិទ្ធិ ។

ម៉ោង ៨.៤៥ សម្តេចព្រះមហាក្សត្រិយានី សម្តេចក្រុមព្រះប្រធានក្រុមប្រឹក្សារាជានុសិទ្ធិ ស្តេចយាងដល់ ដោយមានព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមហែ ។

ទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរភូមិន្ទ ក្រុមកុងកងវរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យ ធ្វើគារវកិច្ចតាមទម្លាប់ ។

សម្តេចព្រះមហាក្សត្រិយានី សម្តេចក្រុមព្រះប្រធានក្រុមប្រឹក្សារាជានុសិទ្ធិទ្រង់ស្តេចយាងប្រថាប់លើព្រះពន្លា ។

ពិធីសមាទានសីល ដោយលោកឈឹម-ស៊ុមន៍ ជាអាចារ្យ អារាធនា, សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ថ្វាយសីល ។

ម៉ោង ៩.០០ ព្រះរាជពិធីដាក់បាត្រព្រះសង្ឃ ៥០ អង្គ ។

សម្តេចព្រះមហាក្សត្រិយានី សម្តេចក្រុមព្រះប្រធានក្រុមប្រឹក្សារាជានុសិទ្ធិ ស្តេចយាងប្រថាប់លើសុវណ្ណកោដ្ឋៈវិញ ។ ឯព្រះសង្ឃ លុះទទួលចង្ហាន់រួចហើយ និមន្តត្រឡប់មកគង់លើកៅអីវិញដែរ ។

កាលបើព្រះសង្ឃអត្ថានុមោទនា អាចារ្យ យកកិច្ចរួចហើយ មានធ្វើពិធីដាក់ទង់ជាតិ ទង់សាសនា ដោយសិស្សប្រុស-ស្រី មន្ទីរបទនគររាជ និងបទសារកញ្ញាដូចថ្ងៃទី១ ។ ព្រះសង្ឃគ្រហស្ថ ក្រោកឈរបែរព្រះភក្ត្រ-មុខគោរពចំពោះសក្យមុនីចេតិយ ។

លុះដល់ម៉ោង ១០.០០ សម្តេចព្រះមហាក្សត្រិយានី សម្តេចក្រុមព្រះប្រធានក្រុមប្រឹក្សារាជានុសិទ្ធិ ទ្រង់ស្តេចយាងត្រឡប់ ដោយមានព្រះរាជបរិពារដដែលតាមហែ ។

បន្ទាប់ពីនេះ ពួកបរិស័ទដាក់បាត្រព្រះសង្ឃចំនួន ៥០០អង្គ ក្រោមកិច្ចចាត់ចែងពុទ្ធិកសមាគមទាំងឡាយ ក្នុងការទុបត្ថម្ភនៃក្រសួងធម្មការ ។

ចប់ពិធីបុណ្យឧទ្ទេសក្មុងព្រះសក្យមុនីចេតិយតែប៉ុណ្ណេះ ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

**អតិជរ** គុ. ដែលរឹងក្រៃលែង, ដែលចាស់ក្រៃលែង ។

**អតិជល** គុ. ដែលមានទឹកក្រៃពេក៖ ដែលមានទឹកច្រើន ។

**អតិជវ** គុ. ដែលមានសន្ទុះក្រៃលែង ។–**តា**, ស្ត្រី. ការដែល . . . មានសន្ទុះក្រៃលែង ។

**អតិជវន** គុ. ដែលមានសន្ទុះក្រៃលែង ។ –**តា**, ស្ត្រី. ការដែល . . . មានសន្ទុះក្រៃលែង ។

**អតិជាត** គុ. ដែលកើតក្រៃលែង, ដែលប្រសើរជាង ។

**អតិជិតកាឝិន៑** គុ. ដែលនាំឲ្យមានជ័យក្រៃលែង ។ *អតិកាឝិតា*, ស្រ្តី. កិរិយានាំឲ្យមានជ័យក្រៃលែង ។

**អតិជីវ៑** ធាតុ. រស់នៅដោយក្រៃលែង, រស់នៅប្រសើរ ។

**អតិជីវម្ឫតក** គុ. ដែលស្លាប់ប្រសើរជាងរស់ ។

**អតិឌីន** នបុំ. កិរិយាហើរលឿន ។

**អតិតត** គុ. ដែលឆ្អែតក្រៃលែង ។

(នៅមានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

---

ឆ្នាំទី ៣២ លេខ ៦ ខែមិថុនា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង


| ផ្នែកសាសនា | ទំព័រ |
|---|---|
| - វិហារណកថា របស់ព្រះពុទ្ធវង្ស កឹម-តួរ | ៦០១ |
| - ពុទ្ធដីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង | ៦០៨ |
| - ព្រះអភិធម្មបិដក (គម្ពីរបុគ្គលបញ្ញត្តិ) (តមក) លោក ប៊ូ-ប៉ូ រៀបរៀង | ៦១៧ |
| - មធុរសវាហិនី (តមក) សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈឺន ពិនិត្យ | ៦២៨ |
| - មហោសថជាតក (តមក) លោក អ៊ឹម-កន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-តួរ ពិនិត្យ | ៦៤៥ |
| **ផ្នែកអក្សរសាស្ត្រ** | |
| - រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត | ៦៥៣ |
| - អំពីទំនៀមប្រណាំងទូកង នៅស្រុកជាហាក់ ខែត្រឃ្លាំង (វួឈាំងស៊ុន) លោក ចាប់ ម៉ែន រៀបរៀង | ៦៧៣ |
| - រឿងព្រេងប្រទេសអេហ្ស៊ីប ភិក្ខុ ម៉ែន-វៀន ប្រែពីភាសាអង់គ្លេស | ៦៩៣ |
| - រឿងសាមកុក (តមក) ឧកញ៉ា វួ-កន ប្រែ | ៧០៤ |
| - ពាក្យវិញ្ញធម៌ លោក នាង-ហ៊ូ រៀបរៀង លោក សម-ចាំង ពិនិត្យ | ៧១០ |
| **ផ្នែកកំណត់ទិនប្បវត្តិការណ៍** | |
| - ពតិមានផ្សេងៗរបស់ក្រសួងធម្មការ | ៧១៧ |
| - វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ភាង-ខាត់ រៀបរៀង | ៧១៨ |



មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជា ២៣០៖០០

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
Publiée par l'Institut Bouddhique de Phnom-Penh


## sommaire

### Partie religieuse :


— Editorial par le vén.KEM-TO . . . . . . . . . . . . . . 601
— La Vie du Buddha (suite) par Prah maha PANG-KHAT . . . 608
— Prah Abhidhammapitaka (Puggalappannatti) (suite) par M. BOU-PO 617
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM, revu et corrigé par le Vén-NHEAN CHHOEUN . . . . . . . . . . . . . 628
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu par le Vén-KEM-TO 645


### Partie littéraire :


— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . . 653
— La Course des Pirogues à Bassac (Cochinchine) par M. THAC-PEN 673
— Contes et Légendes de l' Ethiopie traduits de l'anglais par le bonze MEN-RIEM . . . . . . . 693
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 704
— Activités de la Commission culturelle par M NEANG HOU revues par M. SAM-THANG. . . . 710


### Notes et Chroniques :


— Nouvelles diverses du Ministère des Cultes . . . . . . 717
— Dictionnaire Sanscrit-khmer (suite) par le Vén-PANG-KHAT 718



Prix d'abonnement annuel (comprenant 12 numéros): 230$00 .

**ផ្នែកសាសនា**

# វិចារណកថា

*របស់ព្រះពុទ្ធរក្ស គឹម-ត្រូ*

---

## ដែលគិតឆ្ងល់?

## អំពីការចំរើនឡើងនិងការសាបសូន្យនៃពន្លឺព្រះច័ន្ទ អាស្រ័យដោយហេតុអ្វី?

អាស្រ័យដោយហេតុ ដូចមានសេចក្ដីអធិប្បាយតទៅនេះ

ធម្មជាតិ ៣ យ៉ាង ជាពន្លឺដែលអាចបំភ្លឺសត្វលោកឲ្យភ្លឺជាក់ច្បាស់ក្នុងលោកទៅបាន អាស្រ័យដោយមិនមានគ្រឿងមន្ទិលសៅហ្មងអ្វីចូលមកបៀតបៀន; ឯធម្មជាតិ ៣ យ៉ាងនោះគឺ ៖

១- សុរិយមណ្ឌល មណ្ឌលព្រះអាទិត្យ,

២- ចន្ទមណ្ឌល មណ្ឌលព្រះចន្ទ ។

ព្រះអាទិត្យនិងព្រះចន្ទទាំងពីរ រមែងរះឡើងក្នុងវេលាបានតែតាមវេលា, ព្រះអាទិត្យរះឡើងក្នុងវេលាបានតែក្នុងវេលាថ្ងៃ ដល់វេលាយប់ងងឹតវិញ, ឯព្រះចន្ទពេញបូណ៌មីរះឡើងក្នុងវេលាបានតែក្នុងវេលាយប់ ដល់វេលាថ្ងៃងងឹតវិញ, ព្រះអាទិត្យ និងព្រះចន្ទ ដែលអាចរះឡើងក្នុង

រឿងបានតាមវេលានោះសោតទៀត ព្រោះតែគ្មានសភាវៈអ្វីដទៃចូលមកបៀតបៀនប្រៀតជ្រែកបិទបាំងកំនិត ប្រសិនបើ មានខ្យល់ព្យុះភ្លៀងផ្គរមេឃស្រទំ ចុះគប់ផែកផ្សែងងងឹតភ្លៀងធ្លាក់ចុះមកក្នុងវេលាណា រស្មីព្រះអាទិត្យនិងព្រះចន្ទនោះឯង ក៏វិនាសបាត់ទាំងអស់ អាចញុំាងលោកទាំងមូលឲ្យងងឹតសូន្យឈឹងទៅមួយរំពេចក្នុងវេលានោះពុំខាន ។

៣- តថាគតប្បវេទិតំ ពុទ្ធវចនំ ពុទ្ធវចនៈ គឺធម៌និងវិន័យដែលព្រះតថាគតបានត្រាស់ដឹងហើយ ទ្រង់សំដែងទុកដាក់ដើម្បីជាពន្លឺសំរាប់បំភ្លឺសត្វលោក ។ អាចយកពន្លឺគឺធម៌និងវិន័យនោះមកបញ្ចាំងឆ្លុះបំភ្លឺ មើលហេតុពិតនិងមិនពិត, អំពើល្អនិងអាក្រក់, គុណនិងទោស, ខុសនិងត្រូវគ្រប់យ៉ាង ឲ្យឃើញជាក់ច្បាស់ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក ហើយអាចត្រឡប់ត្រឡាស់ញុំាងចិត្តឲ្យផ្លាស់បែរចេញ ពីសេចក្តីយល់ខុស ហេតុដែលមិនពិត អំពើអាក្រក់ប្រកបដោយទោសនោះចោលចេញ ហើយនឹងបានកាន់យកតែហេតុដែលពិតនិងអំពើល្អដែលប្រកបដោយគុណនោះ មកប្រព្រឹត្តប្រតិបត្តិតាម ដើម្បីជាប្រយោជន៍ប្រពៃក្នុងលោកនេះ និងលោកខាងមុខទៅបាន អាស្រ័យដោយពន្លឺគឺធម៌និងវិន័យនេះឯង ។

ឯធម៌និងវិន័យ ដែលអាចប្រតិស្ឋានតាំងនៅដោយសេចក្តីរុងរឿងអស់កាលជាយូរអង្វែងទៅបាននោះ លុះតែអាស្រ័យដោយពួកពុទ្ធបរិស័ទទាំង

បព្វជិតទាំងគ្រហស្ថ ឬ សប្បុរសជនជាអធិបតីក្នុងសង្គមនីមួយៗមិនព្រងើយកន្តើយគឺជួយឧបត្ថម្ភទំនុកបំរុងផង ទាំងកុលបុត្រអ្នករៀនសូត្រក៏មានកុះករដេរដាសជាច្រើន ហើយខំព្យាយាមបង្ហាត់បង្រៀនសិស្សានុសិស្សតៗគ្នាទៅផង ខំព្យាយាមរំលឹកដាស់តឿន ណែនាំអ្នកដទៃឲ្យមានសេចក្តីប្រព្រឹត្តប្រតិបត្តិត្រឹមត្រូវផង ទើបធម៌និងវិន័យរបស់ព្រះសម្មាសម្ពុទ្ធនោះនឹងរុងរឿងឋិតថេរចិរកាលទៅបាន ។

មួយទៀត បុគ្គលជាធម្មកថិកក្តី មិនមែនជាធម្មកថិកក្តី មានសេចក្តីយល់ខុស ប្រកបដោយមានះចចេសរឹងត្អឹង ហាមឃាត់ការសិក្សាទៅសាសនារបស់ព្រះពុទ្ធ ឬជាអ្នកកំណាញ់ធម៌លាក់លៀមចំណេះវិជ្ជាមិនចង់ឲ្យអ្នកណាមួយគេចេះដឹងលើសខ្លួន ឬស្មើនឹងខ្លួន ដោយខ្លាចខាតលាភសក្ការៈរបស់ខ្លួនក្តី ជាអធម្មវាទី ពោលឲ្យហេតុដែលមិនមែនធម៌ មិនមែនវិន័យ ថាជាធម៌ ជាវិន័យទៅវិញក្តី បុគ្គលបែបនេះបានឈ្មោះថាបិទបាំងពន្លឺ គឺធម៌និងវិន័យរបស់ព្រះសម្មាសម្ពុទ្ធឲ្យស្រអាប់បាត់ពន្លឺរស្មី គឺជាហេតុដ៏ដឹកនាំមនុស្សទាំងពួងឲ្យវង្វេងក្តីគំនិតសំគាល់ខុសថាជាត្រូវ សំគាល់ត្រូវថាជាខុសវិញដោយច្រើន ដូចគ្នានឹងព្រះអាទិត្យព្រះចន្ទរះឡើងក្នុងអាកាសរស្មីត្រចះ បើមានសភាវៈដទៃមានពពកអសុរិន្ទជាដើម ចូលមកបៀតបៀនជ្រៀតជ្រែកបិទបាំងព្រះអាទិត្យ និងព្រះចន្ទគ្រាលណាហើយ ពន្លឺរស្មីដែលភ្លឺរុងរឿងល្អនោះ ក៏ប្រែទៅជា

ស្រគាប់ផ្ទាត់ពន្លឺវិនាសសូន្យទៅមួយរំពេចក្នុងកាលនោះឯង, ឯធម៌និងវិន័យរបស់ព្រះសម្មាសម្ពុទ្ធ ក៏ដូច្នោះដែរ ។ រួមសេចក្តីដែលបានពណ៌នាមកថា ធម៌និងវិន័យដែលបានចំរើនរុងរឿងឡើង ឬវិនាសសាបសូន្យទៅ ក៏ដោយសារតែពួកពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថនោះឯង ។

គួរឡែងចង់ដឹងថា ពុទ្ធសាសនាគឺធម៌និងវិន័យ ដែលអាចរុងរឿងតាំងនៅអស់កាលជាអង្វែងទៅបាន អាស្រ័យដោយសារ បរិយត្តិ ( ការរៀនសូត្រ ) ជាមូលគល់ ឬក៏អាស្រ័យដោយសារ បដិបត្តិ ( ការប្រតិបត្តិ ) ជាមូលគល់ ។ បញ្ហានេះ សូមទាញយករឿងដែលមានក្នុងគម្ពីរមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ មកឆ្លើយបញ្ជាក់ថា មានភិក្ខុពីរពួកគឺភិក្ខុខាងបរិយត្តិមួយពួក, ភិក្ខុខាងប្រតិបត្តិកាន់ធុតង្គមួយពួក មានបញ្ហាកើតឡើងដល់ភិក្ខុទាំងនោះថា បរិយត្តិ ជាមូលគល់នៃសាសនា ឬក៏ បដិបត្តិ ជាមូលគល់នៃសាសនា ? ។ ពួកភិក្ខុខាងប្រតិបត្តិកាន់ធុតង្គឆ្លើយឡើងថា បដិបត្តិ ជាមូលគល់នៃសាសនា ។ ឯពួកភិក្ខុខាងបរិយត្តិឆ្លើយថា បរិយត្តិ ជាមូលគល់នៃសាសនា ។ ខណៈនោះ ព្រះថេរៈទាំងឡាយដែលតាំងនៅជាកណ្តាលប្រកាសឡើងថា យើងមិនទាន់យល់ព្រមតាមពាក្យរបស់លោកទាំងសងខាងទេ សូមលោកទាំងឡាយលើកយកសូត្រជាភាសិតនៃព្រះជិនស្រីមកពោលអាងផង

ទើបបាន ។

លំដាប់នោះ ពួកភិក្ខុខាងកាន់ធុតង្គលើកយកសូត្រពីរនេះឡើងមកពោលគាថាថា ឥមេ ច សុភទ្ទ ភិក្ខូ សម្មា បដិបជ្ជេយ្យុំ អសុញ្ញោ លោកោ អរហន្តេហិ អស្ស "ម្នាលសុភទ្ទ! ប្រសិនបើ ភិក្ខុទាំងឡាយនេះ មានការប្រតិបត្តិដោយប្រពៃជាប្រក្រតី, លោក (នេះ) មិនគប្បីសូន្យចាកព្រះអរហន្តទាំងឡាយឡើយ" ។ បដិបត្តិមូលកំ មហារាជ សត្ថុ សាសនំ បដិបត្តិយំ ធរន្តេ តិដ្ឋតិ "បពិត្រមហារាជ! សាសនារបស់ព្រះសាស្តា មានសេចក្តីប្រតិបត្តិជាឫសគល់ ឋិតនៅក្នុងបុគ្គលអ្នកទ្រទ្រង់សេចក្តីប្រតិបត្តិ" ។

ឯពួកភិក្ខុខាងបរិយត្តិ ក៏នាំយកសូត្រដូចខាងក្រោមនេះ មកពោលគាថាថា:

យាវ តិដ្ឋន្តិ សុត្តន្តា វិនយោ យាវ ទិប្បតិ
តាវ ទក្ខន្តិ អាលោកំ សុរិយេ អព្ភុដ្ឋិតេ យថា ។
សុត្តន្តេសុ អសន្តេសុ បមុដ្ឋេ វិនយម្ហិ ច
តមោ ភវិស្សតិ លោកស្ស សុរិយេ អត្ថង្គតេ យថា ។
សុត្តន្តេ រក្ខិតេ សន្តេ បដិបត្តិ ហោតិ រក្ខិតា

បដិបត្តិយំ ឋិតោ ធីរោ យោគក្ខេមា ន ធំសតិ ។

“ព្រះសូត្រទាំងឡាយឋិតនៅដរាបណា, ព្រះវិន័យនៅរុងរឿងដរាបណា, សត្វលោកក៏អាចនៅឃើញពន្លឺបានដរាបនោះ ដូចជាព្រះអាទិត្យដែលរះខ្ពស់ត្រដែតឡើងដូច្នោះឯង ។ កាលបើព្រះសូត្រទាំងឡាយមិនមាន ទាំងព្រះវិន័យក៏ភិក្ខុភ្លេចភាំងរសាត់ទៅហើយដែរ, ងងឹតអន្ធការក៏នឹងកើតមានដល់សត្វលោក ដូចជាព្រះអាទិត្យដែលអស្តង្គតបាត់ពន្លឺដូច្នោះឯង ។ កាលបើភិក្ខុ នៅរក្សាព្រះសូត្របាននៅឡើយ , សេចក្តីប្រតិបត្តិ ក៏ឈ្មោះថាជាគុណជាតិ ដែលភិក្ខុនៅរក្សាបានដែរ , ធីរជន អ្នកឋិតនៅក្នុងសេចក្តីប្រតិបត្តិ រមែងមិនខ្លាត់ឃ្លាតចាកធម៌ជាដែនក្សេមចាកយោគៈឡើយ ' ។

កាលពួកភិក្ខុខាងបរិយត្តិ នាំយកព្រះសូត្រមកសំដែងការដូច្នេះហើយ , ពួកភិក្ខុខាងប្រតិបត្តិកាន់ធុតង្គ ក៏យល់ស្របជាមួយគ្នាហើយនៅស្ងៀម ។ សេចក្តីនេះ អដ្ឋកថាចារ្យបានអធិប្បាយបន្ថែមដោយសេចក្តីប្រៀបធៀបបំភ្លឺថា ហ្វូងគោ ដែលមានសុទ្ធតែគោបាទាំងរយទាំងពាន់ កាលបើមិនមានមេគោជាសត្វរក្សាតំណបវេណីនៅក្នុងហ្វូងគោបានោះផងទេ វង្សបវេណីឬពូជគោនោះឯង ក៏មុខជានឹងដាច់សូន្យទៅយ៉ាងណាមិញ, ពុទ្ធសាសនានេះក៏ដូច្នោះដែរ, ទោះបីមានភិក្ខុច្រើនរូបដល់

រយៈកាន់ក៏ដោយ បើសុទ្ធតែជាអ្នកប្រាជ្ញនូវវិបស្សនាកម្មដ្ឋាន ធុតង្គរុក្ខមូលទៅអាស្រ័យក្នុងព្រៃ , តែបើមិនមានភិក្ខុអ្នកទ្រទ្រង់បរិយត្តិជាពូជទេ ឬក៏ព្រះបរិយត្តិអន្តរធានទៅដោយហេតុណាមួយហើយ , ការចាក់ធ្លុះ ឬការត្រាស់ដឹងនូវអរិយមគ្គ អរិយផលក៏ពុំមានដែរ ព្រោះមិនមានបរិយត្តិជាច្បាប់សម្រាប់បង្អួលបង្ហាញនូវប្រតិបត្តិត្រង់ទៅបាន ។ ន័យមួយទៀត លោកប្រៀបថា អក្សរដែលគេចាក់ក្ដាប់នៅលើផ្ទាំងថ្ម ដើម្បីជាគ្រឿងសំគាល់ឲ្យដឹងនូវទីដែលមានផ្ទាំងកំណប់ទ្រព្យ ដែលគេកប់ទុក, ដរាបណា អក្សរទាំងនោះនៅមិនទាន់រលុបរលាយបាត់ទៅទេ ដរាបនោះផ្ទាំងកំណប់ទ្រព្យនោះ ឈ្មោះថាមិនទាន់វិនាសបាត់ទៅនៅឡើយ យ៉ាងណាមិញ, ឯពុទ្ធសាសនានេះក៏យ៉ាងនោះដែរ, បើបរិយត្តិនៅមានភិក្ខុទ្រទ្រង់សិក្សារៀនសូត្រនៅឡើយ ឬមិនទាន់អន្តរធានទៅដោយហេតុណាមួយទេ, សាសនារបស់ព្រះសម្មាសម្ពុទ្ធ ក៏មិនទាន់អន្តរធានសាបសូន្យទៅដែរ ព្រោះអាស្រ័យបរិយត្តិជាប្រមាណ គឺបរិយត្តិជាឫសគល់របស់សាសនាដូចបានពណ៌នាមកនេះឯង ។

គម្ពីរមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ ។

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

## អវិទូរេនិទាន គព្ភាភិនិក្ខមនកថាទី ២

១-ព្រះនាងមហាមាយាទេវីទ្រង់សុបិននិមិត្ត ២-ព្យាករណ៍សុបិននិមិត្ត ៣-ទ្រង់ស្ថិតនៅក្នុងគភ៌ ៤ ទ្រង់ប្រសូត ៥ សេចក្ដីអស្ចារ្យចំឡែក ។

### ១-ព្រះនាងមហាមាយាទេវីទ្រង់សុបិននិមិត្ត

ក្នុងអាសាឡ្ហបុណ្ណមី ប្រកបដោយអាសាឡ្ហនក្ខត្តឫក្ស មហាជនក្នុងក្រុងកបិលពស្ដុ បបួលគ្នាលេងនក្ខត្តឫក្សគគ្រឹកគគ្រេងគគ្រេកគំពើកទូទាំងផ្ទៃព្រះនគរ ព្រះនាងមាយាទេវី ស្ដេចទ្រង់សុនទ្ឋរលេងនៈក្រសាលនក្ខត្តឫក្សកំសាន្តព្រះទ័យ ដល់ថ្ងៃទី ៧ ស្ដេចទ្រង់អធិដ្ឋានឧបោសថសីលហើយ ស្ដេចចូលកាន់មហាសិរីសយ្យាសន៍ លុះវេលារាត្រីទៀបបច្ចូសសម័យ ព្រះនាងកំពុងផ្ទំលក់ស្កប់ ស្ដេចទ្រង់សុបិននិមិត្តឃើញថា ស្ដេចចាតុម្មហារាជិកៈទាំង ៤ ចូលមកលើកយកព្រះនាងទាំងព្រះខែនគ្រឡាបន្ទំទៅប្រតិស្ឋានទៅលើមនោសិលាអាសន៍ធំ ក្រោមសាលព្រឹក្សមួយដើម នាខែត្រចន្លោះព្រៃហេមពាន្ត មានពួកនាងទេពធីតា នាំព្រះនាងទៅស្រង់ក្នុងអនោតត្តស្រះ ជម្រះព្រះកាយស្អាតហើយ ក៏ដង្ហែនាំមកផ្ទំនៅក្នុងប្រាសាទមាសមួយ ដែលស្ថិតនៅលើកំពូលរជតបព៌ត បែរព្រះសិរ្ស

ទៅកាន់បាចីនទិស ។ កាលនោះ មានសេតហត្ថី ១ មានប្រមោយ
ប្រដាប់ដោយផ្កាឈូក ចុះពីសុវណ្ណគិរីឡើងទៅលើកំពូលហិរញ្ញបព៌តនោះ
ហើយចូលទៅក្នុងប្រាសាទមាស ប្រទក្សិណព្រះនាង ៣ ជុំហើយ
ហាក់ដូចជាចូលទៅកាន់ទីប្រទេសខាងស្តាំនៃព្រះនាង ។ ព្រះបរម
ពោធិសត្វ ចុះមកចាប់បដិសន្ធិក្នុងពេលនោះ ទ្រង់មានសតិសម្បជញ្ញៈ
ចុះមកកាន់ផ្ទៃព្រះមាតា ៕

## ២–ព្យាករណ៍សុបិននិមិត្ត

លុះព្រឹកព្រាង ព្រះនាងមាយាទេវីយកសុបិននិមិត្តនោះចូលទៅ
ក្រាបទូលព្រះភស្តា កាលនោះ ព្រះបាទសុទ្ធោទនៈទ្រង់ព្រះសណ្តាប់
ហើយ ទ្រង់ត្រាស់បង្គាប់ឲ្យអញ្ជើញព្រាហ្មណ៍ចំនួន ៦៤ នាក់ មក
ក្រាបបង្គំគាល់ ឲ្យព្យាករសុបិននិមិត្តថ្វាយ, ព្រាហ្មណ៍ចំនួន ៦៤ នាក់
ក្រាបទូលថា ព្រះអគ្គទេពីទ្រង់គភ៌, ឯព្រះរាជបុត្រក្នុងគភ៌នោះ ជាអគ្គ
បុរស ទ្រង់ប្រកបដោយបុញ្ញានុភាពច្រើន បើស្តេចនៅគ្រប់គ្រងគេហ-
ដ្ឋានទ្រង់បានជាស្តេចចក្រពត្រាធិរាជ, បើស្តេចចេញចាកគេហដ្ឋានទៅ
សាងព្រះផ្នួស ទ្រង់នឹងបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធប្រាកដក្នុង
លោក ។ ព្រះបាទសុទ្ធោទនៈទ្រង់ព្រះសណ្តាប់ហើយ មានព្រះទ័យ

*សោមនស្សត្រេកអរ ហើយត្រាស់បង្គាប់ឱ្យថែរក្សាព្រះគភ៌ព្រះអគ្គទេវី ដោយម៉ឺនម៉ាត់ ។*

## ៣–ទ្រង់ស្ថិតនៅក្នុងគភ៌

*តាំងពីពេលដែលព្រះនាងមហាមាយាទ្រង់ព្រះគភ៌មក ព្រះបាទសុទ្ធោ-ទនៈ ទ្រង់តាក់តែងរក្សាបរិហារគ្រប់ប្រការ មិនឱ្យមានហេតុអ្វីនាំឱ្យមានមោះហ្មងទេ ដូចក្នុងគាថាដែលទ្រង់ត្រាស់ទុកថា (១)*

" មានទេវបុត្រ ៤ អង្គ ថែរក្សាពោធិសត្វក្នុងទិសទាំង៤មិនឱ្យមនុស្សឬអមនុស្សមកបៀតបៀនព្រះពោធិសត្វបាន ។ ចាប់ដើមពីកាលពោធិសត្វមកចាប់បដិសន្ធិ ព្រះមាតាតែងរក្សាបញ្ចង្គិក-សីលជានិច្ច ព្រះនាងមិនមានចិត្តត្រេកអរក្នុងបញ្ចពិធកាមគុណទៀតឡើយ ព្រោះព្រះនាងធ្លាប់ស្កប់ស្កល់ក្នុងបញ្ចពិធកាមគុណហើយ ព្រះនាងឥតមានរោគាពាធមោះមែអ្វី តែងប្រកបដោយសេចក្តីសុខសម្រាន្តឥតលំបាកកាយ ហើយអាចមើលឃើញពោធិសត្វសព្វអវយវៈតូចធំ ហាក់ដូចជាពោធិសត្វស្តេចស្ថិតនៅក្រៅផ្ទៃ បានប្រៀបដូចជាកែវមណីនឹងកែវពៃទូរ្យដ៏ល្អ មាន

១ អច្ឆរិយព្ភូតធម្មសូត្រ, សុញ្ញតវគ្គ អដ្ឋកថា, នប មជ្ឈិម សៀ.២៣ ទំព័រ៤៦ ។

ពន្លឺ មានជ្រុង ៨ ដែលគេច្នៃដោយល្អ ហើយបុគ្គលយកសូត្រមានពណ៌ខៀវ, លឿង, ក្រហម, ស, លឿងទុំទៅដោតក្នុងកែវនោះ បុគ្គលអាចមើលឃើញសូត្រមានពណ៌ផ្សេងៗនោះជាក់ប្រាកដនឹងភ្នែកបាន, ព្រះមាតាពោធិសត្វពរផ្ទៃគ្រប់ទសមាស ទើបប្រសូតពោធិសត្វ មិនជួបស្ត្រីឯទៀតឡើយ"ៗ

*លុះព្រះមហាមាយា (១) ទ្រង់ព្រះគភ៌គ្រប់ទសមាសហើយ ស្តេចក្នុងព្រះទ័យនឹកចង់ទៅក្រាបបង្គំគាល់ព្រះវរបិតាមាតានៅក្រុងទេវទហៈ ព្រះនាងចូលទៅទូលសូមអនុញ្ញាតអំពីព្រះរាជស្វាមី, កាលបានព្រះរាជានុញ្ញាតហើយ, វេលាព្រឹក ព្រះនាងមហាមាយាស្តេចឡើងគង់លើព្រះរាជយានដ៏វិចិត្រដោយប្រការផ្សេង ១ ចាយាត្រាចេញអំពីនគរឆ្ពោះព្រះភក្ត្រទៅទេវទហនគរ ព្រមដោយស្រីស្នំនាងកាយស្អិតស្អាងគួរពេញចិត្តរមិលមើលនឹងចតុរង្គសេនាសេវកាមាត្យ, ស្តេចព្រះរាជដំណើរទៅដល់សួនលុម្ពិនីវន(២) ជាចន្លោះព្រំដែនព្រះរាជធានីទាំងពីរ គឺនគរកបិលពស្តុ និងទេវទហៈ ។*

---

១ នេះជាទំនៀមព្រាហ្មណ៍ កាលបើស្ត្រីមានគភ៌គ្រប់ទសមាសហើយ តែងតែទៅសម្រាលនៅត្រកូលខ្លួន ហេតុនោះបានជានាងមាយាទវីលាព្រះស្វាមីទៅកាន់នគរព្រះអង្គ ។ ២. សព្វថ្ងៃនេះជិតភូមិតូច ១ ហៅថា បទរសា (Padarsa) ទីក្រុងពាស្តិ ប្រទេសនេបាល មិនមែនហៅ " រុម្មិនទេ " ទេ ។ ទីវាលនេះ អ្នកប្រាជ្ញអង្គ្លេសឈ្មោះហ្វូរើរ (Furer) រកឃើញក្នុង ព.ស ២៤៣៩ ជាដើម មានសិលាលេខព្រះបាទអសោកមហារាជជាពស្តុតាង ។

## ៤ ទ្រង់ប្រសូត្រ

ព្រះនាងមាយាទេវី ស្ដេចទស្សនាឃើញព្រៃព្រឹក្សាលតាជាតិ មានផ្ការយោងរយាង មានក្លិនក្រអូបល្ហើងល្ហើយ មានសត្វកខៀវខ្ចីបក់រវិចៗដោយរាយរយា ហាក់ដូចជាជង្រោយ ហៅព្រះនាងឲ្យស្ដេចចុះក្រសាល គន់មើលទៅតំណជាតិដុះដិតផែនពសុធា កំពុងលូតលាស់សន្លឹកខៀវខ្ចី ប្រកបដោយផ្កាមានពណ៌ផ្សេងៗ មុខគួរឲ្យគយគន់ ដូចគេយកបៀមចាំព្រៃព្រំទៅក្រាលពាសពេញទាំងធរណី, មានខ្យល់អប់ក្លិនផ្កាបក់មកក្រអូបឈ្ងុយរហើយត្រសៀកគួរឲ្យរីករាយសប្បាយ, ពួកភមរជាតិហោចហើរត្រៀលត្រាត់ក្រេបលំអងផ្កាពីមួយទៅមួយ, ពួកសត្វកេះស្រែកតបន្ទំដោយមាត់សត្វបក្សីយាសយំពួសូររងំ គួរឲ្យស្រណោះ, ព្រះនាងក្នុងព្រះទ័យចង់ឈប់ប្រពាតក្រសាលក្នុងទីនោះ, ស្ដេចចុះចាកព្រះរាជយានទៅសណ្ឋិតឈរនៅក្រោមសាលព្រឹក្សមួយដើម ប្រកបដោយផ្ការីកស្គុសស្គាយ ទ្រង់លើកព្រះហស្ដម្ខាងឡើងទៅចាប់មែកសាលព្រឹក្សនោះ, ឯមែកទាំងនោះហាក់ដូចជាមានចិត្តល្អ កំពោរទន់បន្អោនមែកចុះមកកាន់ព្រះហស្ដព្រះនាង, ក្នុងពេលនោះ ព្រះនាងកំពុងសណ្ឋិតឈរ ខ្យល់កម្មជវាតក៏បក់ព្រះគព្ភោទរៈបំរុងនឹងប្រសូតព្រះរាជឱរស, ពួកព្រះរាជបរិវារយល់អាការដូច្នោះហើយក៏រៀបតាក់តែងទីប្រសូតថ្វាយតាមសមគួរ, ព្រះពោធិសត្វប្រសូតចាកឧទរ

*ព្រះវរមាតាក្នុងទីនោះ  ឥតមានទុក្ខវេទនា  ឥតមានមោះមៃត្រី  ត្រូវនា ដូចព្រះធម្មកថិកចុះអំពីគ្រែធម្មាសនៈ  បរិសុទ្ធស្អាតឥតមានមន្ទិលឡើយ ដូចពុទ្ធដីកាដែលទ្រង់ត្រាស់ចំពោះព្រះអានន្ទត្ថេរថា (១)*

« ម្នាលអានន្ទ! កាលដែលពោធិសត្វប្រសូតចាកផ្ទៃព្រះមាតា មិនប្រឡាក់ដោយរំអិល ដោយស្លេស្ម ដោយឈាម ដោយខ្ទុះ ឬដោយវត្ថុណាមួយ ដែលមិនស្អាតល្អនោះឡើយ ប្រៀបដូចជាកែវមណីដែលគេដាក់លើកាសិកពស្ត្រ ឥតប្រឡាក់ដូច្នោះឯង ។ មានឧទកធារាពីរមុខគឺ ក្តៅនឹងត្រជាក់ ហូរចាកនភាល័យប្រទេស ចុះមកស្រោចស្រង់ព្រះនាងមាយាទេវីនឹងព្រះពោធិសត្វ » ។

*ក្នុងពេលដែលព្រះពោធិសត្វប្រសូតភ្លាម (២) មហាព្រហ្មទាំង៤(៣) យកបណ្តាញមាសមកទទួល ស្តេចចាតុម្មហារាជិក យកស្បែកឈ្លូសមក*

---

១–អច្ឆរិយព្ភូតធម្មសូត្រ. សុញ្ញតវគ្គ. អត្ថកថា, ឧប. មជ្ឈិម. សៀវ. ២៧ ទំព័រ៥៣។

២ ក្នុងអដ្ឋកថាជាតកថា  ព្រះពោធិសត្វប្រសូតហើយភ្លាមពោលអាសភិវាចា  មាន ៣ជាតិ គឺ ១. កាលសោយព្រះជាតិជាមហោសថកុមារ. មានសេចក្តីថា កាលព្រះពោធិសត្វប្រសូតមាតាសួរថា៖ « ម្នាលប! អ្នកបានអ្វីយកមកក្មេង! កុមារឆ្លើយថា អ្នកម៉ែ! ឱសថ, បានជាគេថ្វាយព្រះនាមថា មហោសថកុមារ, ២.កាលសោយព្រះជាតិជាវេស្សន្តរកុមារ  មានសេចក្តីថា៖

ទទួលទានអំពីព្រហ្ម ពួកស្រីស្នំក្រមការបំរើរ យកសំពត់កាសេយ្យពស្ត្រ ទទួលតមកទៀត ។ ព្រះពោធិសត្វសណ្ឋិតឈរលើផែនពសុធាសិលមិនក្រេតក្រោតព្រះអង្គ ស្តេចឈាន ៧ ជំហាន (១) ឆ្ពោះព្រះភក្ត្រទៅកាន់ឧត្តរទិស ទតព្រះនេត្រក្រឡេក មើលទិសទាំង ១០ ដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះព្រះអានន្ទថា (២)

"ម្នាលអានន្ទ! ពោធិសត្វប្រសូតហើយសណ្ឋិតឈរលើប្រឹថពីដោយបាទាទាំងពីរ បែរឆ្ពោះទៅកាន់ឧត្តរទិស ហើយដើរទៅ ៧ ជំហានមានគេបាំងក្លស់សម្ងាយ ក្រឡេកមើលទិសទាំងពួង ហើយទើបបន្លឺនូវអាសភិវាចាថា

អគ្គោហមស្មិ លោកស្ស
ជេដ្ឋោហមស្មិ លោកស្ស
សេដ្ឋោហមស្មិ លោកស្ស
អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

---

ពោធិសត្វរួចមាតាថា អ្នកម៉ែក្នុងផ្ទះយើងមានទ្រព្យអ្វីទេ ខ្ញុំនឹងឲ្យទាន, ៣. កាលក្នុងបច្ឆិមជាតិនេះ ។ ៣. អច្ឆរិយព្ភូតធម្មសូត្រ សុញ្ញតវគ្គ អដ្ឋកថា ខប. មជ្ឈិម. សៀវ. ២៧ ទំព័រ ៩២, មានសេចក្តីថា កាលព្រះពោធិសត្វប្រសូត មានទេព្តាទទួលមុន ទើបមនុស្សទទួលក្រោយ ពោធិសត្វមិនទាន់ដល់ដី ទេវបុត្ត ៤ អង្គទទួលយកមកដាក់លើទុកនៅចំពោះព្រះភក្ត្រព្រះមាតា ពោលថា សូមព្រះនាងទេវីត្រេកអរចុះ ! ព្រះរាជបុត្រមានសក្តិធំរបស់ព្រះនាងកើតហើយ ។

១-គម្ពីរជាន់ក្រោយមានសេចក្តីថា " មានផ្កាឈូកផុះទ្រព្រះបាទ ,, តែគម្ពីរបាលីមិនមានទេ (មើល Borobudur par M. Mus Page 483) ។ ២,អច្ឆរិយព្ភូតធម្មសូត្រ សុញ្ញតវគ្គ ខប. មជ្ឈិម. សៀវ. ២៧ ទំព័រ ៩៤ ។

ប្រែថា អាត្មាអញជាកំពូលនៃលោក អាត្មាអញជាច្បងនៃលោក អាត្មាអញជាបុគ្គលប្រសើរលើសគេក្នុងលោក ជាតិនេះ ជាជាតិទីបំផុត អាត្មាអញមិនមានភពថ្មីទៀតឡើយ" ។

ព្រះពោធិសត្វប្រសូតនៅថ្ងៃសុក្រ ១៥ កើតខែពិសាខ ឆ្នាំច មុនពុទ្ធសករាជ ៨០ ឆ្នាំ ។ សហជាតិ ៧ ពួកគឺកើតឡើងព្រមគ្នាគឺ ព្រះនាងយសោធរា ១ ព្រះអានន្ទ ១ ឆន្នអមាត្យ ១ កាឡុទាយីអមាត្យ ១ សេះកណ្ឋកៈ ១ ដើមពោធិព្រឹក្ស ១ កំណប់ទ្រព្យទាំងបួន ១ ។

លំដាប់នោះ ព្រះបាទសុទ្ធោទនៈបានជ្រាបថា ព្រះនាងទេវីទ្រង់ប្រសូតព្រះរាជឱរសដូច្នោះហើយ ក៏ទ្រង់ត្រាស់បង្គាប់ឲ្យក្បួនហែព្រះនាងត្រឡប់មកកាន់ក្រុងកបិលពស្តុវិញ ហើយរៀបចំតាក់តែងការថែរក្សាព្រះរាជបុត្រដោយប្រពៃ ។

## ៥-សេចក្តីអស្ចារ្យចំឡែក

កាលព្រះបរមពោធិសត្វប្រសូត កាលនោះ មានសេចក្តីអស្ចារ្យចំឡែកប្លែកក្រៃពន់កើតឡើង ដូចព្រះពុទ្ធដីកាដែលទ្រង់ត្រាស់ចំពោះព្រះអានន្ទថា (១) ។

១-គម្ពីរយុត្តធម្មសង្វេគ សុញ្ញតវគ្គ ១២· ឧច្ឆុម សៀវ. ទំព័រ ៥៥ មើលសត្ថាយូត្រ ភយវគ្គ គតិយេបណ្ណាសក ច. អំ. ៨៦ ។

«ម្នាលអានន្ទ! កាលព្រះពោធិសត្វប្រសូតចាកគភ៌ព្រះមាតា កាលនោះ ក្នុងលោកនេះ ក្នុងមារលោកនិងព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទេវតាព្រមទាំងមនុស្ស មានពន្លឺភ្លឺព្រោងព្រាតប្រមាណមិនបាន ក្រៃលែងជាងទេវានុភាព សូម្បីនៅក្នុងលោកន្តរិកនរក ដែលធ្លាប់តែងងឹតអន្ធការសូន្យសុងជានិច្ច ចក្ខុវិញ្ញាណចាក់ធ្លុះមិនបាន ពន្លឺព្រះអាទិត្យព្រះចន្ទ្រ ពោលរស្មីទៅមិនដល់ ក្នុងទីនោះ ពន្លឺភ្លឺព្រោងព្រាតប្រមាណមិនបាន ក្រៃលែងជាងទេវានុភាព ក៏កើតឡើង សត្វដែលកើតក្នុងនរកនោះ បានឃើញនូវគ្នានឹងគ្នាដោយពន្លឺនោះ បបួលគ្នានិយាយអឺងកងឡើងថា នែអ្នកទាំងឡាយ! បានឮថា សត្វដទៃក្រៅពីយើងដែលកើតក្នុងទីនេះមានដែរហ្ន៎! លោកធាតុទាំង ១ ម៉ឺនក៏កក្រើករំពើកញាប់ញ័រ ម្នាលអានន្ទ! នេះជាហេតុអស្ចារ្យទី ២ ដែលមិនធ្លាប់កើតក៏កើតឡើង ព្រោះកិរិយាកើតឡើងនៃតថាគតជាអង្គអរហន្តសម្មាសម្ពុទ្ធជាម្ចាស់» ។ (នៅមានត)

# ព្រះអភិធម្មបិដក

## (គម្ពីរបុគ្គលបញ្ញត្តិ)

(តមក)

*លោក ប៊ូ.ប៊ូ រៀបរៀង*

---

### នវកបុគ្គល

"អាឃាតំ ពន្ធនកា នវបុគ្គលា ។ អនត្ថំ មេ អចរិ, អនត្ថំ មេ ចរតិ, អនត្ថំ មេ ចរិស្សតីតិ ។ បិយស្ស មេ មនាបស្ស អនត្ថំ អចរិ, បិយស្ស មេ មនាបស្ស អនត្ថំ ចរតិ, បិយស្ស មេ មនាបស្ស អនត្ថំ ចរិស្សតីតិ ។ អបិយស្ស មេ អមនាបស្ស អត្ថំ អចរិ, អបិយស្ស មេ អមនាបស្ស អត្ថំ ចរតិ, អបិយស្ស មេ អមនាបស្ស អត្ថំ ចរិស្សតីតិ អាឃាតំ ពន្ធតីតិ" ។

*អង្គសម្ដេចព្រះសព្វញ្ញូ ទ្រង់ទេសនាបុគ្គលប្រាំបីពួកចប់ហើយ ទើបទ្រង់ត្រាស់សំដែងនូវបុគ្គលប្រាំបួនពួកតទៅទៀតថា :-*

អាឃាតំ ពន្ធនកា បុគ្គលទាំងឡាយអ្នកចងអាឃាត ចន

ទៀតនឹងគ្នានោះ មានប្រាំបួនពួក អាស្រ័យអាឃាតវត្ថុ គឺហេតុជាទីតាំងនៃអាឃាត ៩ ប្រការគឺៈ

១- អ្នកនេះ បានប្រព្រឹត្តសេចក្ដីវិនាសឲ្យដល់អញហើយ,

២- អ្នកនេះ កំពុងតែប្រព្រឹត្តសេចក្ដីវិនាសឲ្យដល់អញ,

៣- អ្នកនេះ នឹងប្រព្រឹត្តសេចក្ដីវិនាសឲ្យដល់អញ,

៤- អ្នកនេះ បានប្រព្រឹត្តសេចក្ដីវិនាស ឲ្យដល់មនុស្សជាទីស្រឡាញ់ពេញចិត្តរបស់អញរួចហើយ,

៥- អ្នកនេះ កំពុងតែប្រព្រឹត្តសេចក្ដីវិនាស ឲ្យដល់មនុស្សជាទីស្រឡាញ់ពេញចិត្តរបស់អញ,

៦- អ្នកនេះ នឹងប្រព្រឹត្តសេចក្ដីវិនាស ឲ្យដល់មនុស្សជាទីស្រឡាញ់ពេញចិត្តរបស់អញ,

៧- អ្នកនេះ បានប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនជាទីស្រឡាញ់ពេញចិត្តរបស់អញរួចហើយ ,

៨- អ្នកនេះ កំពុងប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនជាទីស្រឡាញ់ពេញចិត្តរបស់អញ,

៩- អ្នកនេះ នឹងប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនជាទីស្រឡាញ់ពេញចិត្តរបស់អញ ។

បុគ្គលអ្នកចងអាឃាដដោយអំណាចអាឃាដវត្ថុ ៩ ប្រការនេះ នឹងជាបច្ច័យឲ្យវិនាស ដូចជានាងមាគន្ទិយាព្រាហ្មណី កាលដើមឡើយមានចិត្តអាក្រក់ គិតចងពៀរព្យាបាទព្រះពុទ្ធអង្គ លុះដល់ខាងក្រោយខ្លួនបានធ្វើជាអគ្គមហេសីនៃព្រះបាទឧទេន ដែលសោយរាជសម្បត្តិក្នុងនគរកោសម្ពី ឃើញព្រះរាជស្វាមីទុកព្រះទ័យនឹងព្រះនាងសាមាវតី ជាអគ្គមហេសីរួមព្រះរាជស្វាមីជាមួយគ្នា គោរពរាប់អានព្រះពុទ្ធជាម្ចាស់ ថ្វាយចង្ហាន់បិណ្ឌបាត នឹងធ្វើសក្ការបូជា ព្រះនាងមាគន្ទិយាព្រាហ្មណីគិតថាស្ត្រីទាំងឡាយមានព្រះនាងសាមាវតីជាដើមនេះ គោរពរាប់អានព្រះសមណគោតម ធ្វើប្រយោជន៍ឲ្យដល់សមណៈទាំងឡាយ គួរតែអញសាងអកុសលកម្មបំផ្លិចបំផ្លាញឲ្យវិនាស គិតដូច្នេះហើយ ទើបចងអាឃាដព្យាបាទធ្វើឧបាយផ្សេង ៗ ញុះញង់ឲ្យព្រះបាទឧទេនដាក់ព្រះរាជអាជ្ញាដល់ព្រះនាងសាមាវតីព្រមទាំងស្ត្រីជាបរិវារ ។ ព្រះបាទឧទេនទ្រង់ព្រះសណ្តាប់ជឿជាក់ក៏ខ្ញាល់ណាស់ ទ្រង់ថ្វៃធ្នូសរបំណងឲ្យក្ស័យជីវិតព្រះនាងសាមាវតី ប៉ុន្តែហេតុអំណាចមេត្តាចិត្តនៃព្រះនាងសាមាវតីនោះ សរមិនទៅត្រូវរូបកាយនៃស្ត្រីទាំងឡាយមានព្រះសាមាវតីជាប្រធាន ។

ខាងក្រោយទៀត ព្រះនាងមាគន្ទិយាព្រាហ្មណីគិតឲ្យចូឡបិតាគឺឪពុកមារបស់ខ្លួន យកអគ្គីមកដុតនិវេសន៍ទីលំនៅនៃព្រះនាងសាមាវតីនេះ

ខ្ទេចខ្ទី ៗ ព្រះនាងសាមាវតី នឹងស្ត្រីបរិវារក្ស័យជីវិតក្នុងភ្លើងប្រាសាទនោះទាំងអស់ទៅ ។ ព្រះបាទឧទេនទ្រង់ជ្រាប ត្រាស់បង្គាប់ពួកអាមាត្យឲ្យដឹករណ្ដាប់ដុតភ្លើង ដុតព្រះនាងមាគន្ទិយាព្រាហ្មណីនឹងស្ត្រីបរិវារទាំងពួង ។ ព្រះនាងមាគន្ទិយាព្រាហ្មណី គិតប្រទូសរ៉ាយព្រះនាងសាមាវតីនោះដោយហេតុថា ខ្លួនគិតប្រទូសរ៉ាយព្រះពុទ្ធអង្គ ប៉ុន្តែប្រទូសរ៉ាយមិនបាន លុះឃើញព្រះនាងសាមាវតីមានសទ្ធាជ្រះថ្លានឹងព្រះពុទ្ធជាម្ចាស់ក៏ផ្សំគំនិតគិតចងអាឃាតព្យាបាទសម្លាប់ព្រះនាងសាមាវតីវិញ ។ លុះព្រះនាងមាគន្ទិយាព្រាហ្មណីក្ស័យជីវិតហើយ ក៏ទៅកើតក្នុងនិរយាបាយ ។

បុគ្គលអ្នកចងអាឃាតគេនោះ ព្រោះអាស្រ័យវត្ថុ ៩ ប្រការ ដូចពណ៌នាមកខាងដើម ហេតុនោះ អ្នកប្រាជ្ញគួររកឧបាយហាមឃាត់ចិត្តដោយខន្តីបារមីតែបន្តិចៗ ក៏ប្រសើរណាស់ហើយ ។ ម្យ៉ាងទៀត ឧបាយដែលនឹងបន្ទោបង់ចោលនូវអាឃាតព្យាបាទនោះ មាន ៩ ប្រការ ដូចតទៅ គឺ ៖

១ អ្នកនេះ បានប្រព្រឹត្តសេចក្ដីវិនាសឲ្យដល់អញហើយ នឹងគប្បីបានអំពីទីណា (គឺថា ធ្វើឲ្យអញវិនាសមិនកើតទេ) ,

២- អ្នកនេះ កំពុងប្រព្រឹត្តសេចក្ដីវិនាសឲ្យដល់អញ នឹងគប្បីបានអំពីទីណា,

៣- អ្នកនេះ នឹងប្រព្រឹត្តសេចក្ដីវិនាសឲ្យដល់អញ នឹងគប្បី

បានអំពីទីណា,

៤– អ្នកនេះ បានប្រព្រឹត្តសេចក្តីវិនាស ដល់មនុស្សជាទីស្រឡាញ់ពេញចិត្តរបស់អញហើយ នឹងគប្បីបានអំពីទីណា ,

៥– អ្នកនេះ កំពុងតែប្រព្រឹត្តសេចក្តីវិនាស ឲ្យដល់មនុស្សជាទីស្រឡាញ់ពេញចិត្តរបស់អញ នឹងគប្បីបានអំពីទីណា ,

៦· អ្នកនេះ នឹងប្រព្រឹត្តសេចក្តីវិនាស ឲ្យដល់មនុស្សជាទីស្រឡាញ់ពេញចិត្តរបស់អញ នឹងគប្បីបានអំពីទីណា ,

៧– អ្នកនេះ បានប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនជាទីស្រឡាញ់ពេញចិត្តរបស់អញហើយ នឹងគប្បីបានអំពីទីណា ,

៨– អ្នកនេះ កំពុងតែប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនជាទីស្រឡាញ់ពេញចិត្តរបស់អញ នឹងគប្បីបានអំពីទីណា ,

៩– អ្នកនេះ នឹងប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនជាទីស្រឡាញ់ពេញចិត្តរបស់អញ នឹងគប្បីបានអំពីទីណា ។

គ្រប់ជាឧបាយបន្ទោបង់អាឃាត ៩ ប្រការ ។ លុះបន្ទោបង់អាឃាតបានហើយ ក៏នឹងលះបង់នូវពៀរវេរព្យាបាទបាន ។

ប្រការមួយទៀត បុគ្គលនឹងបន្ទោបង់អាឃាតបាននោះ ក៏អាស្រ័យកម្មស្សកតាញាណ ពិចារណាឃើញថា សត្វដែលកើតមកក្នុងវដ្តសង្សារ

នេះ មានកុសលនិងអកុសលជារបស់ខ្លួនគ្រប់គ្នា គិតឃើញយ៉ាងនេះ ហើយ ក៏នឹងលះបង់នូវអាឃាដឋាន ដោយអំណាចតទង្គបហាន និង វិខម្ភនបហាន ។

ធម៌មានឧបការច្រើន, ធម៌ដែលបុគ្គលគប្បីធ្វើឲ្យចម្រើនឡើង, ធម៌ដែលបុគ្គលគប្បីលះបង់ចេញ, ធម៌ដែលបុគ្គលគប្បីកំណត់ដឹងដោយបញ្ញា, ធម៌ជាចំណែកនឹងឲ្យសាបសូន្យចាកគុណវិសេស, ធម៌ជាហេតុនឹងឲ្យបានសម្រេចគុណវិសេស, ធម៌ដែលបុគ្គលគប្បីធ្វើឲ្យកើតឡើង, ធម៌ដែលបុគ្គលគប្បីធ្វើឲ្យជាក់ច្បាស់, ធម៌ទាំងអស់នេះមួយៗមាន ៩ ប្រការៗ ដូចគ្នា ។

ធម៌មានឧបការច្រើន ៩ ប្រការនោះ គឺធម៌ដែលមនសិការកំណត់ទុកក្នុងចិត្តដោយឧបាយនៃបញ្ញា ប្រាមោជ្យរីករាយ ១ កាលកំណត់ដឹងដោយឧបាយនៃបញ្ញា មានចិត្តរីករាយ ហើយបីតិក៏កើតឡើង ១ កាលបើចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ ១ កាលបុគ្គលមានកាយស្ងប់រម្ងាប់បានសោយសេចក្ដីសុខហើយ ចិត្តក៏តាំងនៅមាំមួន ១ កាលចិត្តតាំងនៅមាំមួនហើយ ក៏ដឹងឃើញតាមសេចក្ដីពិត ១ កាលបើដឹងឃើញតាមសេចក្ដីពិតហើយ ចិត្តក៏នឿយណាយ ១ កាលបើចិត្តនឿយណាយហើយ ក៏ប្រាសចាកត្រេកអរ ១ កាលបើចិត្តលែងត្រេកអរហើយ ក៏ផុតចាកតម្រេក ១ ត្រូវជា ៨ ប្រការ ។ ជាគំរប់ ៩ ប្រការនឹងកិរិយា

ធ្វើមនសិការកំណត់ទុកក្នុងចិត្ត ដោយឧបាយនៃបញ្ញាជាមូលដូច្នេះ ។

ធម៌ដែលបុគ្គលគប្បីឲ្យចម្រើនឡើងនោះ មាន ៩ ប្រការ បាន ដល់វិសុទ្ធិទាំង ៩ ។

ធម៌ដែលបុគ្គលគប្បីលះបង់ចេញនោះមាន ៩ ប្រការ បានដល់ធម្ម ជាមូលនៃតណ្ហា ៩ ។

ធម៌ដែលបុគ្គលគប្បីកំណត់ដឹងដោយបញ្ញានោះ មាន ៩ ប្រការ បានដល់សត្តាវាស ៩ ។

ធម៌ជាចំណែកទីឲ្យសាបសូន្យចាកគុណវិសេសនោះ មាន ៩ ប្រការ បានដល់អាឃាតវត្ថុ ៩ ។

ធម៌ជាហេតុនាំឲ្យបានសម្រេចគុណវិសេសនោះ មាន ៩ ប្រការ បានដល់អាឃាតបដិវិន័យ គឺធម៌សម្រាប់បន្ទោបង់អាឃាត ៩ ។

ធម៌ដែលបុគ្គលគប្បីធ្វើឲ្យកើតឡើងនោះ មាន ៩ ប្រការ បាន ដល់ធម្មសញ្ញា ៩ ។

ធម៌ដែលបុគ្គលគប្បីធ្វើឲ្យជាក់ច្បាស់នោះ មាន ៩ ប្រការ បាន ដល់មគ្គ៤ ផល៤ និងព្រះនិព្វាន ១ ។

សម្តេចព្រះបរមលោកុត្តមាចារ្យ ទ្រង់ត្រាស់ទេសនាឲ្យបុគ្គល ៩ ពួកៗទីនឹងធម៌ ៩ ប្រការៗ ដោយអនេកបរិយាយដូច្នេះ ។

នវកបុគ្គល សង្ខេបប៉ុណ្ណេះ ។

## ទសកបុគ្គល

លំដាប់អំពីនេះតបុគ្គលមក សម្តេចព្រះបរមគ្រូទ្រង់ត្រាស់ទេសនាទសកបុគ្គលគឺបុគ្គលពួកដប់ៗថា ៖

គហបតយោ ម្នាលគហបតីទាំងឡាយ ! បុគ្គលអ្នកបរិភោគកាមគុណមានដប់ពួកក្នុងលោកនេះ គឺ ៖

១_ស្វែងរកទ្រព្យសម្បត្តិមិនត្រឹមត្រូវតាមធម៌ រកបានមកដោយកម្មដ៏អាក្រក់ ហើយញ៉ាំងខ្លួនឲ្យតាំងនៅក្នុងសេចក្តីសុខ មិនបានចែកទានធ្វើកុសល ,

២- ស្វែងរកទ្រព្យសម្បត្តិមិនត្រឹមត្រូវតាមធម៌ ដោយកម្មដ៏អាក្រក់ ញ៉ាំងខ្លួនឲ្យបានសុខដោយកម្មដ៏អាក្រក់ មិនឲ្យទាន មិនធ្វើការកុសល ,

៣- ស្វែងរកទ្រព្យសម្បត្តិមិនត្រឹមត្រូវតាមធម៌ ញ៉ាំងខ្លួនឲ្យតាំងនៅក្នុងសេចក្តីសុខ ហើយឲ្យទានធ្វើការកុសល ,

៤- ស្វែងរកទ្រព្យសម្បត្តិត្រូវតាមធម៌ខ្លះ, ខុសពីធម៌ខ្លះ ញ៉ាំងខ្លួនឲ្យតាំងនៅក្នុងសេចក្តីសុខ ដោយកម្មដ៏អាក្រក់ខ្លះ ល្អខ្លះ មិនឲ្យទាន មិនធ្វើការកុសល ,

៥- ស្វែងរកទ្រព្យសម្បត្តិត្រូវតាមធម៌ខ្លះ, ខុសពីធម៌ខ្លះ មិនឲ្យទាន មិនធ្វើការកុសល ,

៦- ស្វែងរកទ្រព្យសម្បត្តិត្រូវតាមធម៌ខ្លះ , ខុសពីធម៌ខ្លះ , ញ៉ាំង

ឲ្យតាំងនៅក្នុងសេចក្ដីសុខដោយកម្មដ៏អាក្រក់ខ្លះ, ល្អខ្លះ, ឲ្យមានធ្វើការកុសល ,

៧- ស្វែងរកទ្រព្យសម្បត្តិត្រូវតាមធម៌ ញុំាងខ្លួនឲ្យបានសុខដោយកម្មដ៏ល្អ ប៉ុន្តែមិនបានឲ្យមាន មិនធ្វើការកុសល ,

៨- ស្វែងរកទ្រព្យសម្បត្តិត្រូវតាមធម៌ ធ្វើខ្លួនឲ្យបានសុខដោយកម្មដ៏ល្អ ឲ្យមាន ធ្វើការកុសល ប៉ុន្តែ ឥតបញ្ញាមិនចេះរើខ្លួនឲ្យរួចចេញចាកភព ,

៩- មានបញ្ញាពិចារណាឃើញទោស ,

១០- មានបញ្ញាចេះរើខ្លួនឲ្យរួចចេញពីភព ។

អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា បុគ្គលទាំងដប់ពួកនេះ ពួកជាប្រថមនោះ អ្នកប្រាជ្ញតិះដៀលតែម្យ៉ាង ,ពួកជាគំរប់ពីរ ដល់គំរប់ប្រាំបី អ្នកប្រាជ្ញតិះដៀលខ្លះសរសើរខ្លះ ។

ពួកទី ៩ និងទី១០ អ្នកប្រាជ្ញមិនតិះដៀលទេ សុទ្ធតែសរសើរដោយហេតុបួនប្រការ គឺស្វែងរកទ្រព្យត្រូវតាមធម៌ ១ ធ្វើខ្លួនឲ្យបានសុខដោយកម្មដ៏ល្អ ១ ឲ្យមានធ្វើការកុសល ១ ជាមនុស្សមិនវង្វេងនឹងទ្រព្យសម្បត្តិ មានបញ្ញាចេះរើខ្លួនឲ្យរួចផុតពីភពវដ្តសង្សារ ១ ។

ព្រះមានព្រះភាគត្រាស់ទេសនាបុគ្គលដប់ពួកចប់ហើយ ទើបទ្រង់ទេសនាធម៌ដប់ពួកតទៅទៀតគឺ ពហុបការធម៌ , ធម៌ដែល

បុគ្គលគប្បីធ្វើឲ្យបម្រើន , គប្បីកំណត់ដោយបញ្ញា , គប្បីលះបង់ , ជាចំណែកទីនឹងឲ្យសាបសូន្យចាកគុណវិសេស , ជាហេតុទីនឹងឲ្យបានសម្រេចនូវគុណវិសេស , គប្បីឲ្យកើតមានឡើង , គប្បីធ្វើឲ្យជាក់ច្បាស់ ។

ឯពហុបការធម៌នោះ បានដល់ធម៌ធ្វើទីពឹងដប់ប្រការ (នាថករណធម៌១០) គឺ ៖

១- ភិក្ខុមានសីលសង្រួមក្នុងបាដិមោក្ខ បរិបូណ៌ដោយមារយាទនឹងគោចរ ,

២- ភិក្ខុជាពហុស្សូត ,

៣- ភិក្ខុជាអ្នកប្រដៅងាយ ,

៤- ភិក្ខុសេពគប់តែនឹងកល្យាណមិត្ត ,

៥- ភិក្ខុខំយកចិត្តទុកដាក់ក្នុងកិច្ចធុរៈទាំងឡាយ ,

៦- ជាអ្នកប្រាថ្នាក្នុងធម៌ល្អប្រពៃ ,

៧- ព្យាយាមដើម្បីលះបង់សេចក្តីអាក្រក់ ធ្វើតែសេចក្តីល្អ ,

៨- សន្តោសដោយបច្ច័យបួន ,

៩- មានស្មារតីចាំកិច្ចការដែលធ្វើ នឹងសំដីដែលនិយាយយូរហើយបាន , ។

១០- បញ្ញាដ៏នឹងដឹងវិញ្ញូក្នុងសង្ខារតាមការកើតពិតយ៉ាងណា ។

ធម៌ដែលបុគ្គលគប្បីធ្វើឲ្យចម្រើននោះ បានដល់កសិណដប់ប្រការ ។

ធម៌ដែលបុគ្គលគប្បីកំណត់ដឹងដោយបញ្ញានោះ បានដល់អាយតនៈដប់ លើកមនាយតនៈនិងធម្មាយតនៈពីរប្រការចេញ ។

ធម៌ដែលបុគ្គលគប្បីលះបង់ចោលនោះ បានដល់មិច្ឆត្តធម៌ដប់ប្រការ មានមិច្ឆាទិដ្ឋិជាដើម មានមិច្ឆាញាណៈនិងមិច្ឆាវិមុត្តិជាទីបំផុត ។ ធម៌ជាចំណែកដែលនាំឲ្យសាបសូន្យចាកគុណវិសេសនោះ បានដល់អកុសលកម្មបថដប់ប្រការ គឺកាយទុច្ចរិតបី វចីទុច្ចរិតបួន មនោទុច្ចរិតបី ។ ធម៌ជាចំណែកដែលនាំឲ្យបានសម្រេចគុណវិសេសនោះ បានដល់កុសលកម្មបថដប់ប្រការ ។

អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា គម្ពីរព្រះបុគ្គលបញ្ញត្តិនេះ សម្តេចព្រះជិនស្រីត្រាស់ដោយបញ្ញត្តិប្រាំមួយប្រការ មានខន្ធបញ្ញត្តិជាដើម មានបុគ្គលបញ្ញត្តិជាបរិយោសាន ។ គន្ថិបុគ្គលបញ្ញត្តិ ត្រាស់ដោយបុគ្គលតាំងអំពីពួកមួយដល់ពួកដប់ ចែកចេញទៅដោយអនេកន័យ ប្រកបដោយព្រះធម្មក្ខន្ធប្រាំពាន់ប្រាំមួយរយព្រះធម្មក្ខន្ធ ត្រាស់ទេសនាប្រាំមួយថ្ងៃទើបចប់ ទេវតាបានសម្រេចមគ្គផលប្រាំបីកោដិ ។

ព្រះអភិធម្មបិដក គម្ពីរព្រះបុគ្គលបញ្ញត្តិ ចប់តែប៉ុណ្ណេះ ។

# មធុរសវាហិណី

សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

ចាប់ដើមតាំងពីកាលនោះមក ស្រ្តីជាបងថ្លៃនោះ តែងធ្វើនូវការបំរើដោយកិច្ចសព្វយ៉ាង មានឲ្យគ្រឿងអប់ងូតទឹកសម្រាប់ងូតជាដើមពុំដាច់ឡើយ លុះយូរថ្ងៃ មានសេចក្តីលោភចង់បានគ្រឿងអម្ពរតាំងឡាយ សំរាប់ប្រដាប់ក្នុងដៃជើងនិងកនៃស្រ្តីជាប្អូនថ្លៃនោះ ខានពុំអាចនឹងរម្ងាប់នូវសេចក្តីលោភនោះបានឡើយ សេចក្តីលោភនោះ រឹងរឹតតែចំរើនច្រើនឡើងទៀត, ក៏សម្តែងអាការៈធ្វើជាឈឺ អត់បាយអត់ទឹកសន្ធឹកសន្ធៃ ដេកឱបគៀកគ្រែហាក់ដូចពុំជំនួនប្រាណឡើយ ។

កាលនោះបុរសជាស្វាមី ដែលទៅធ្វើការឯក្រៅផ្ទះបានត្រឡប់មកផ្ទះ ឃើញភរិយាខ្លួនដេកសន្ធឹកសន្ធៃដូច្នោះ ក៏អង្គុយលើគ្រែជិតហើយសួរថា ម្នាលនាងដ៏ចំរើន ! នាងឯងមិនសប្បាយអផ្សុកឬកើតរោគអ្វី ? ។ ឯភរិយានោះបានស្តាប់ហើយក៏ស្ងៀមនៅពុំស្តីថាអ្វីឡើយ ដល់ប្តីសួរតពីរបីដងទើបនិយាយថា ការនេះខ្ញុំមិនអាចនឹងនិយាយប្រាប់អ្នកបានឡើយ ។

កាលបើប្តីអង្វរសួរទៀតយ៉ាងនាំហើយ ភរិយានោះក៏គិតពិចារណាថា បើអញនិយាយប្រាប់ត្រង់ថា ខ្ញុំចង់បានគ្រឿងប្រដាប់ប្អូនស្រីរបស់អ្នក ពាក្យពោលយ៉ាងនេះ ជាពាក្យពុំគួរពោលសោះឡើយ , កាលបើអញនិយាយប្រាប់ថា ខ្ញុំចង់បានមធុរមំស សាច់ដីមានទុជាសេឡាញ់របស់ប្អូនស្រីអ្នក ហើយអញបង្គាប់ប្តីនេះឲ្យសម្លាប់ទូវប្អូនស្រីនោះបានហើយ គ្រឿងប្រដាប់តាំងឡាយរបស់នាងនេះ នឹងបានដល់អញទាំងអស់ដោយពិត, ភរិយានោះបានគិតពិចារណាយ៉ាងនេះហើយ ក៏និយាយប្រាប់ប្តីខ្លួនក្នុងកាលនោះថា សាមិ បពិត្រអ្នកជាម្ចាស់ ខ្ញុំលាក់បាំងអ្វី ផ្សេង ខ្ញុំប្រាថ្នាចង់បានមធុរមំស សាច់ដីមានទុជាសេឡាញ់ទាំងប្រាំរបស់ប្អូនស្រីអ្នកនឹងបរិភោគ កាលបើខ្ញុំពុំបានសាច់នោះបរិភោគហើយ ជីវិតរបស់ខ្ញុំពុំមានឡើយ មុខជាស្លាប់ពិត ។

ឯបុរសជាស្វាមីនោះ បានស្តាប់ពាក្យភរិយាប្រាប់ដូច្នោះហើយ ក៏និយាយតបវិញថា ម្នាលនាងដ៏ចំរើន ! អំពើដែលសម្លាប់មនុស្សនីមួយៗនេះ ជាអំពើមានទោសធ្ងន់ ដោយហេតុច្រើនប្រការណាស់ កាលបើតយ៉ាងនេះ ក៏គង់ពុំអាចនឹងឃាត់ប្រពន្ធនោះបានឡើយ ហើយមានចិត្តជាប់ចំពោះប្រពន្ធខ្លួននោះឯង មានចិត្តជ្រប់ទៅក្នុងកាមគុណរងើង ងងឹតសូន្យឈឹងដោយមោហៈ ហើយទទួលព្រមតាមពាក្យបង្គាប់ប្រពន្ធ

នោះថា សាធុ ទីពឹងសម្រាប់បុរសស្រីខ្លួននោះពុំមាន ។

ព្រោះហេតុដូច្នេះ ព្រះអរហន្តទាំងឡាយលោកពោលទុកនូវព្រះគាថាទាំងឡាយដូច្នេះថា:

ភាយន្តិ ឥធ លោកស្មា ភាយន្តិ បរលោកស្មា
ភាយន្តិ ឧភតោ អត្ថា យេ ឥត្ថីនំ វសំគតា ។

សេចក្តីថា ជនទាំងឡាយឯណា លុះតាមអំណាចនៃស្ត្រីទាំងឡាយហើយ ជនទាំងឡាយនោះ រមែងខ្វាចចាកប្រយោជន៍ក្នុងឥធលោក ខ្វាចចាកប្រយោជន៍ក្នុងបរលោក ខ្វាចចាកប្រយោជន៍ទាំងពីរ ។

ការណាការណោន្តំ កត្តុំ វា ន វា ឥធំ
កាមន្ធា ច ជហន្តិ យេ ឥត្ថីនំ វសំគតា ។

ជនទាំងឡាយឯណា លុះតាមអំណាចនៃស្ត្រីទាំងឡាយហើយ ជនទាំងឡាយនោះ ពុំបានដឹងនូវហេតុគួរធ្វើ និងហេតុមិនគួរធ្វើដូច្នេះថា អំពើនេះ អញគប្បីធ្វើផង អំពើនេះ អញមិនគប្បីធ្វើផង ព្រោះតែខ្លួនវង្វេងងងឹតជ្រប់ទៅក្នុងកាមគុណពិត ។

បាណំ អតិបាតេន្តិ វា ហោន្តិ វា បរទារិកា
ភាសន្តិ អលិកំ វចំ យេ ឥត្ថីនំ វសំគតា ។

ជនទាំងឡាយឯណា លុះតាមអំណាចនៃស្ត្រីទាំងឡាយហើយ

ជនទាំងឡាយនោះ ហ៊ានសម្លាប់សត្វផង ហ៊ានលួចយកប្រពន្ធកូនគេផង ហ៊ានពោលពាក្យកុហកបញ្ឆោតបោកប្រាស់គេ ឲ្យខូចប្រយោជន៍ផង ។

សន្ធិច្ឆេទានិ ការេយ្យុំ មជ្ជបានញ្ច បេសុណំ
ការោន្តិ សាហសំ កម្មំ យេ ឥត្ថីនំ វសំ គតា ។

ជនទាំងឡាយឯណា លុះតាមអំណាចនៃស្ត្រីទាំងឡាយហើយ ជនទាំងឡាយនោះ គប្បីហ៊ានធ្វើនូវអំពើអាក្រក់ មានកាត់ទីតនៃជញ្ជាំងលួចយកទ្រព្យគេជាដើមផង, ផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យផង, ពោលពាក្យញុះញង់បំបែកបំបាក់អ្នកដទៃផង, ហ៊ានធ្វើនូវអំពើដែលប្រព្រឹត្តទៅហួស មានកាប់សម្លាប់គេជាដើមផង ។

អហោ អច្ឆរិយំ លោកេ សវណ្តំ កយាវហំ
ករិយាយ វសំ គន្ត្វា សោធរំ ហន្តុមិច្ឆតិ ។

ឱកម្មជាអស្ចារ្យ ! សប្បុរសទាំងឡាយ គួរតែនឹករឭកនូវអំពើកម្មដែលជាទីនាំមកនូវភ័យអន្តរាយក្នុងលោកិយ, ដ្បិតបុរស ដែលលុះតាមអំណាចនៃកិរិយាឯណានោះ អាចហ៊ានសម្លាប់ប្អូនប្រុសរបស់ខ្លួន ឥតមានមេត្តាករុណាប្អូនដល់តិចតួចឡើយ ព្រោះតែលុះក្នុងអំណាចនៃស្ត្រីចុះណោះឯង ។

កាលនោះ បុរសដែលប្រកបដោយសាហសិកម្មដ៏អាក្រក់នោះ ក៏និយាយទៅនឹងប្អូនខ្លួនថា អម្ម ម្នាលនាងអើយ! នាងឯងត្រូវចូលមកយើងទាំងឡាយត្រូវទៅជំរះបំណុល ដែលគេដាក់មាតាបិតារបស់យើងទាំងឡាយ ឯជនអ្នកដាក់បំណុលទាំងឡាយ បើបានឃើញយើងទាំងឡាយហើយ គេនឹងសងបំណុលនោះដល់យើងទាំងឡាយមួយរំពេច ។

ឯប្អូនស្រីនោះសោត កាលបើបានស្តាប់ពាក្យបងនោះហើយ ក៏ពុំបានដឹងកិច្ចកលថា បងគិតនឹងសម្លាប់ខ្លួនឡើយ ក៏ទទួលព្រមតាមបងនោះឯង ។ ឯបុរសជាបងក៏លើកប្អូនឲ្យជិះលើរទេះ ហើយបរចេញទៅអំពីស្រុក ធ្វើអាការហាក់ដូចជានឹងទៅកាន់ស្រុកនៃជនទាំងឡាយអ្នកដាក់បំណុលដោយពិត លុះទៅដល់ពាក់កណ្តាលដងព្រៃដ៏ស្ងាត់ហើយ ក៏បររទេះឡើងទៅលើខ្នងផ្លូវ ហើយចាប់ដៃប្អូនខ្លួននោះទាញទំលាក់ពីលើរទេះនោះ ។ នាងក៏ភិតភ័យស្រែកយំជំខ្លាំង ៗ បុរសជាបងក៏ទាញកន្ត្រាក់ អូសនាំទៅកាន់ស្បាតនៃព្រៃមួយដោយគំនិតថា អញនឹងយកកាំបិតកាត់ក្បាលនាងនេះក្នុងទីនេះឯង ។

លុះដល់ចាប់នាងផ្ដួលឲ្យដេកទៅលើផែនដីហើយ ខ្យល់កម្មជវាតទាំងឡាយនៃធីតានោះ ក៏កំរើកឡើងក្នុងកាលនោះឯង ។

បពិត្រអើយ ! គួរអាសូរនាងធីតានោះពន់ពេក, នាងធីតានោះ

កាលបើខ្យល់កម្មជវាតកំរើកឡើងក្នុងផ្ទៃហើយ ក៏ខំនិយាយអង្វរបង ដោយពាក្យទន់សុភាពថា បពិត្រអ្នកបងអើយ! សូមអ្នកបងអាណិតអាសូរប្អូនផង ដ្បិតខ្យល់កម្មជវាតទាំងឡាយកំរើកក្នុងផ្ទៃខ្ញុំខ្លាំងណាស់ហើយ ខ្ញុំនឹងប្រសូតកូនឥឡូវនេះឯង, សូមអ្នកបងរើចាំខ្ញុំសម្រាលកូនរួចដរាបណា អ្នកបងត្រូវពិចារណាធ្វើតាមការអ្នកដរាបនោះចុះ, នាងពោលយ៉ាងនេះហើយ ក៏ពុំអាចនឹងចៀសចេញទៅបានឡើយ ខំអត់ទ្រាំសម្រាលកូនហើយក្នុងទីនោះហោង ។ គ្រានោះបុរសជាបង ក៏ចាប់ទាញអូសប្អូនស្រីខ្លួននោះនាំយកទៅជិតដើមជ្រៃធំមួយ ដោយគំនិតគិតនឹងសម្លាប់ទៀបគល់ជ្រៃធំនោះឯង ។

ខណៈនោះ នាងធីតានោះក៏និយាយអង្វរបងនោះទៀតដោយពាក្យទន់គួរអាសូរពន់ពេកថា បពិត្រអ្នកបងជាម្ចាស់! សូមអ្នកជាម្ចាស់កុំអាលសម្លាប់ខ្ញុំ សូមអ្នកបងមេត្តាឲ្យខ្ញុំបានឃើញមុខកូនតូចជាក្មួយរបស់អ្នកបងសិន ដ្បិតខ្ញុំ មានសេចក្ដីស្នេហាស្រឡាញ់បុត្រនោះពន់ពេកណាស់ ។ ចំណែកឯបុរសជាបងនោះ ជាមនុស្សមានចិត្តរឹងរូសកាចអាក្រក់ កាលបើបានស្ដាប់ពាក្យប្អូនស្រីនោះអង្វរគួរឲ្យករុណាអាណិតអាសូរពន់ពេក ក៏ធ្វើហាក់ដូចជាពុំបានឮសោះ គិតតែព្យាយាមនឹងសម្លាប់ប្អូនតែម្យ៉ាង ។

ខណៈនោះ នាងកុមារិកា ឥតមានទីពឹងជ្រកកោនឡើយ ហើយគិតថា បើអញនឹងស្រែកឲ្យគេជួយ មុខជានឹងមានបុគ្គលណាមួយគេនឹងមកដោយសំឡេងដែលអញស្រែក ហើយធ្វើនូវសេចក្តីអន្តរាយដល់បងអញពិត, អំពើដែលអញធ្វើយ៉ាងនេះមិនសមគួរឡើយ, នាងគិតដូច្នេះហើយ ក៏ខំអត់ទ្រាំសេចក្តីទុក្ខលំបាកពុំបានស្រែកមាត់កថាអ្វី ដោយសេចក្តីស្នេហាស្រឡាញ់បងនោះឯង, ខំរំពឹងគិតពិចារណានឹករឭកនៃគុណព្រះរតនត្រ័យតាំងពីមានវេទនាគិតថា ពុទ្ធំ សរណំ គច្ឆាមិ ជាដដែលៗ ដែលខ្លួនបានកាន់យក រក្សាទុកក្នុងចិត្តមកយូរហើយដែរនៅក្នុងទីនោះឯង ។

កាលនោះ មានទេវតាមួយនៅអាស្រ័យលើដើមជ្រៃនោះ ដោយអនុភាពដែលនាងធីតានោះមានចិត្តមេត្តាក្នុងបងផង ដោយអនុភាពដែលនាងធីតានោះបាននឹករឭករឿយៗ នូវគុណព្រះរតនត្រ័យផង, ទេវ-តានោះក៏គិតពិចារណាថា ស្ត្រីដែលមានសភាពយ៉ាងនេះ បើអញមិនជួយផង ហើយបណ្តោយឲ្យបុរសនេះសម្លាប់ក្នុងទីនេះ អាត្មាអញនឹងមិនអាចចូលទៅកាន់ទីប្រជុំនៃទេវតាទាំងឡាយបានឡើយ ក្បាលអញនឹងបែកទៅជាប្រាំពីរចំណែកដោយពិត, ទេវតាគិតយ៉ាងនេះហើយក៏និម្មិតខ្លួនធ្វើហាក់ដូចជាប្តីនៃនាងធីតានោះ ដៃកាន់ដំបងដេញប្រហារ

ចុះសេដ្ឋីបងនោះឲ្យតែទៅ ហើយនិយាយលួងលោមធីតាថា ម្នាលប្អូន! នាងកុំខ្លាចអ្វីឡើយ ហើយលើកធីតា ព្រមទាំងកូនតូចឲ្យជិះលើរទេះ បរចូលទៅកាន់នគរសាវត្ថីក្នុងថ្ងៃនោះឯង ។ លុះបានដល់ហើយ ក៏ឲ្យធីតា នឹងកូនតូចដេកនៅក្នុងសាលា ជាខាងក្រៅនៃព្រះនគរ រួចស្រេចហើយ បាត់ទៅក្នុងទីនោះហោង ។

សេចក្តីពិតដូច្នេះហើយ បានជាព្រះអរហន្តទាំងឡាយពោលជាបទព្រះគាថាដូច្នេះថា

សព្វសម្បត្តិទាតារំ សព្វលោកេកនាយកំ
មនុស្សាបិ យេ ការេន្តិ តេ វេ បាលេន្តិ ទេវតា
មហន្តមបិ យេ មេត្តំ ការេន្តិ យទិ សាធុកំ
តេ វេ បាលេន្តិ ទេវាបិ តោសេន្តិច្ចិតទាយិនោ ។

សេចក្តីថា បើមនុស្សទាំងឡាយឯណា បានចំរើនគារវៈ នាំគោរពនូវព្រះពុទ្ធគុណដែលជានាយកក្នុងលោកទាំងពួង អាចឲ្យនូវសម្បត្តិទាំងពួងដល់សត្វលោក ទេវតាទាំងឡាយរមែងរក្សានូវមនុស្សទាំងឡាយនោះឲ្យបានសេចក្តីសុខដោយពិត ។ ម្យ៉ាងវិញទៀតថា បើមនុស្សទាំងឡាយឯណា បានចំរើនភាវនានូវមេត្តាចិត្ត សូម្បីតែមួយរំពេច ទេវតាទាំងឡាយក៏តែងរក្សានូវមនុស្សទាំងឡាយនោះ ឲ្យបានសេចក្តី

សុខសប្បាយ ហើយអាចឲ្យនូវសម្បត្តិគឺមនុស្សទាំងឡាយប្រាថ្នាហើយតាមប្រាថ្នាបាន ហើយឲ្យត្រេកអរស្រស់ស្រាយដោយពិត ៗ

លំដាប់នោះ បុរសជាប្តីនៃធីតានោះ ក៏បានចេញទៅអំពីនគរហើយបានឃើញនូវភរិយានៃខ្លួន ដេកនៅក្នុងសាលានោះ ក៏មានចិត្តត្រេកអរសួរថា ម្នាលនាង! នាងឯងមកពីកាលណា អ្នកណានាំនាងមកក្នុងទីនេះ? ៗ ឯនាងធីតានោះ ក៏ពុំបានដឹងថា ខ្លួនគឺទេវតានាំមកឡើយ ហើយនិយាយតបទៅនឹងប្តីថា បពិត្រអ្នកជាស្វាមី! អ្នកពោលថ្មីដូច្នេះ ខ្លួនខ្ញុំគឺអ្នកបានទៅយកមកក្នុងទីនេះមិនដូច្នេះទេឬ? ៗ ប្តីបានស្តាប់ហើយសួរទៀតថា ម្នាលនាងដ៏ចំរើន! នាងនិយាយថាដូចម្តេច ចាប់ដើមតាំងពីកាលដែលអញបានទៅឃើញស្រុកបងរបស់នាង កន្លងទៅបាន ៤ ខែហើយ អញពុំដែលបានឃើញនាងដល់មុខឡើយ, នាងឯងបានមកជាមួយនឹងអញដោយហេតុដូចម្តេច? ៗ ឯភរិយានោះបានស្តាប់ពាក្យស្វាមីពោលដូច្នោះហើយ ក៏និយាយយាក់ស្វាមីថា បពិត្រអ្នកជាម្ចាស់! បើដូច្នេះអ្នកកុំនិយាយប្រាប់ហេតុដ៏កំបាំងនេះដល់បុគ្គលដទៃឡើយ សូមអ្នកស្ងៀមទៅចុះ! នាងពោលយ៉ាងនេះហើយ ក៏និយាយប្រាប់រឿងខ្លួនទាំងអស់ ដែលបងបង្កើតរបស់ខ្លួនបានធ្វើអំពើអាក្រក់ដល់ខ្លួន ឲ្យស្វាមីបានស្តាប់ដោយពិស្តារក្នុងកាលនោះឯង ៗ

ចំណែកស្វាមីរបស់នាងធីតានោះ បានស្ដាប់ពាក្យនោះហើយ, ក៏មានសេចក្ដីស្ងួតស្ងប់ជ្រប់ក្នុងចិត្តហើយ ដល់នូវភ័យខ្លាចពន់ពេក ក៏បាននាំនាងធីតាជាភរិយារបស់ខ្លួន និងកុមារតូចនោះ ចូលទៅកាន់ផ្ទះរបស់ខ្លួនក្នុងវេលានោះឯង ។

ឯជនទាំងពីរនាក់ប្ដីប្រពន្ធ កាលបើបានឈប់សំរាកកាយបានពីរបីថ្ងៃហើយ ក៏នាំគ្នាទៅនិមន្តព្រះសាស្ដាមកទទួលភត្ត ហើយចាត់ចែងថ្វាយមហាទាន ដល់ព្រះដ៏មានបុណ្យព្រមទាំងព្រះភិក្ខុសង្ឃស្រេចហើយ ក្រាបថ្វាយបង្គំព្រះសាស្ដាដោយគោរព ក៏អង្គុយនៅក្នុងទីដ៏សមគួរមួយ លុះជនទាំងពីរនាក់បានអង្គុយក្នុងទីដ៏សមគួរដូច្នេះហើយ ក៏យកសេចក្ដីដែលខ្លួនបានជីវិតរស់នៅ ដោយអានុភាពគុណវិសេសនៃសរណៈនិងសីល ដល់ព្រះមានព្រះភាគទ្រង់ព្រះសណ្ដាប់ ដោយសេចក្ដីសព្វគ្រប់ហើយ ញុំាងកូនតូចរបស់ខ្លួន ឲ្យក្រាបសំពះថ្វាយបង្គំព្រះមានព្រះភាគ ហើយឲ្យឈ្មោះកូនរបស់ខ្លួនថា សរណកុមារ ជាមង្គលសួស្ដីក្នុងកាលនោះហោង ។

ចំណែកព្រះបរមសាស្ដាចារ្យជាម្ចាស់ ព្រះអង្គក៏បានជ្រាបច្បាស់នូវអធ្យាស្រ័យនៃជនទាំងពីរនាក់នោះហើយ ក៏សំដែងធម៌ទេសនាដ៏សម

គួរតាមអធ្យាស្រ័យនោះឯង ។

ទេសនាវសានេ លុះដល់ចប់ព្រះធម៌ទេសនាស្រេចហើយ ជនទាំងពីរនាក់នោះក៏បានសម្រេចសោតាបត្តិផល ដ៏សមគួរតាមឧបនិស្ស័យធម៌របស់ខ្លួននោះឯង ។ លុះដល់កាលជាខាងក្រោយមក សរណកុមារជាបុត្រនៃជនទាំងពីរនោះ បានចំរើនវ័យធំឡើងគ្រប់អាយុ ៧ ឆ្នាំ ក៏បានលាមាតាបិតាចេញទៅបួស ក្នុងសំណាក់ព្រះពុទ្ធសាសនាជាសាម-ណេរ ពុំទាន់បានយូរប៉ុន្មានក៏បានចំរើននូវវិបស្សនាកម្មដ្ឋានបានសម្រេចនូវព្រះអរហត្ត កំចាត់បង់នូវកិលេសជាអង្គព្រះអរហន្តដ៏វិសេសក្នុងលោក ប្រាកដនាមថា ព្រះសរណត្ថេរដោយពិត ។

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយលោកពោលជាបទព្រះគាថាដូច្នេះថា:

ឧទិសមយំ មនុស្សា ទេវទេវំ សរន្តា
បរមវរបតិដ្ឋំ ចាបុណន្តីតិ មន្តា
ភគវតិ គុណភាសី ជាតមាតា ជតា កោ
ភជថ សរណសីលំ ឧត្តមំ សព្វកាលំ ។

សេចក្តីថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ! អ្នកទាំងឡាយ ជាជនកាលបើបានពិចារណាដឹងនូវគំនរនៃគុណ នៃព្រះដ៏មានព្រះភាគជា

មនុស្សទាំងឡាយ កាលបើបានទឹករព្រកនូវព្រះសម្មាសម្ពុទ្ធជាទេវតាធំជាងទេវតា មានគុណវិសេសប្រាកដដូច្នេះ តែងបានដល់នូវទីពឹងដ៏ប្រសើរឧត្តមពិត ហើយត្រូវសេពគប់នូវសរណៈទាំងសីលដ៏ឧត្តមជាទីពឹងខ្លួនក្នុងកាលទាំងពួង ដោយប្រការដូច្នេះឯង ។

សម្តែងរឿងសរណគមន៍ជាគំរប់ ៦ ក្នុងវគ្គទីមួយ គឺចប់សេចក្តីជាសង្ខេបតែប៉ុណ្ណេះឯង ។

៧. វេស្សាមិត្តាយ វត្ថុកថា សំដែងរឿងនិទាន អគ្គមហេសីទ្រង់ព្រះនាមវេស្សាមិត្តា តាមបទព្រះបាលីថា ជម្ពូទីបេ តាវេកា កោសម្ពិយំ រញ្ញោ វេស្សាមិត្តា នាម អគ្គមហេសី អហោសិ ដូច្នេះជាដើម អធិប្បាយស្រាយជាសេចក្តីថា បានឮរឿងមកថា មានព្រះនាងទេវីមួយ ព្រះនាមវេស្សាមិត្តា ជាព្រះអគ្គមហេសីនៃព្រះបាទកោសម្ពិយរាជ សោយរាជសម្បត្តិក្នុងនគរកោសម្ពី ក្នុងជម្ពូទ្វីបនេះឯង ។

គ្រាកាលនោះ ព្រះដ៏មានព្រះភាគព្រះអង្គគង់នៅទៀបក្រុងកោសម្ពី ហើយព្រះអង្គត្រាច់ទៅកាន់បារិកជនបទ ព្រមទាំងភិក្ខុសង្ឃមានប្រមាណច្រើន ហោមហែមដោយសមរិការ យាងទៅតាមផ្លូវដើម្បីបិណ្ឌបាតស្រេចហើយ ព្រះអង្គត្រឡប់មកគង់ទីព្រះវិហារវិញហោង ។

សម័យថ្ងៃនោះ ព្រះអគ្គមហេសីនោះក៏បានចូលទៅកាន់ព្រះវិហារ

ជាមួយនឹងព្រះបរមគ្រូត្រៃយ៍ជាស្វាមី ហើយបានស្ដាប់ព្រះធម៌ទេសនានៃព្រះមានព្រះភាគ ព្រះអង្គទ្រង់សម្ដែង ដោយព្រះសូរសំឡេងដ៏ពីរោះក្បោះក្បាយ ឥតមានអាក់ ដោយដំណើរយានយាសនៃព្រះពុទ្ធឧបមាពុំបានឡើយ, ហើយព្រះនាងទេវីមានព្រះទ័យជ្រះថ្លាបានស្ថិតនៅក្នុងព្រះត្រៃសរណគមន៍តាំងពីឥតកំរើកឡើយ. ជាស្ត្រីរាប់អានបូជាព្រះសម្មាសម្ពុទ្ធជាប្រក្រតី ត្រាច់ទៅត្រាច់មកពុំបានដាច់ឡើយ ។ លុះដល់កាលជាចំណោរមកខាងក្រោយទៀត មានស្ដេចបច្ចន្តរាជមួយព្រះអង្គដទៃ ប្រាថ្នាចង់បានរាជសម្បត្តិនៃព្រះបាទកោសម្ពិយរាជនោះឯង ហើយស្ដេចបច្ចន្តរាជនោះក៏ចាត់ចែងសេនាទាហាន រៀបជាក្បួនព្យូហ៍ចូលទៅដើម្បីច្បាំង ហើយបញ្ជូនរាជទូតឲ្យចូលទៅទូលព្រះបាទកោសម្ពិយរាជនោះថា បើព្រះអង្គនឹងលើករាជសម្បត្តិ នូវស្វេតច្ឆត្រប្រគល់ឲ្យយើងក៏ប្រគល់ឲ្យមក បើត្រូវការតតាំងច្បាំងនឹងយើងក៏ត្រូវលើកកងទ័ពចេញមក ដើម្បីនឹងច្បាំងឥឡូវនេះឯង ។

ឯព្រះបាទកោសម្ពិយរាជ ទ្រង់បានស្ដាប់ពាក្យរាជទូតនោះហើយស្ដេចក៏ចាត់សេនាយោធាជាច្រើនហែមរោម ព្រះអង្គលើកចេញទៅ ។ កាលដែលចេញទៅកាន់យុទ្ធភូមិទីច្បាំងនោះ ក៏ទៅជាមួយព្រះអគ្គមហេសីផង, លុះស្ដេចបានលើកកងទ័ពដល់ហើយ ក៏បោះកងទ័ពក្នុងមន្ទាយហើយ ស្ដេចមានបន្ទូលទៅនឹងនាងទេវីថា ម្នាលនាងដ៏ចំរើនអើយ !

ធម្មតាធ្វើការសង្គ្រាមនេះ ការដែលមានជ័យជំនះនិងអបរាជ័យនេះគឺបុគ្គល មិនអាចនឹងដឹងបានឡើយ, ថាបើបងចេញទៅធ្វើសង្គ្រាមអបរាជ័យចាញ់គេហើយ បងនឹងលើកទង់ជ័យមានពណ៌ក្រហមជាទីសំគាល់ នាងត្រូវសំគាល់ដឹងដោយទង់ជ័យនោះចុះ បើបានឃើញទង់ជ័យលើកឡើងមានពណ៌ក្រហមហើយ ត្រូវនាងគេចខ្លួន តែចូលទៅក្នុងក្រុងព្រះនគរកោសម្ពីវិញឲ្យឆាប់ ទើបរួចអំពីសត្រូវកៀតកៀនពុំបាន ។

ស្ដេចទ្រង់បានផ្ដាំព្រះអគ្គមហេសីស្រេចហើយ ក៏លួងលោមព្រះនាងទេវីពុំបានឲ្យនាងភិតភ័យឡើយ ហើយស្ដេចលើកកងទ័ពចេញពីបន្ទាយទៅកាន់សង្គ្រាមមណ្ឌល ដល់ទ័ពគត់តាំងច្បាំងនឹងស្ដេចជាបច្ចាមិត្តប្រហារគ្នាទៅវិញទៅមក ហើយព្រះអង្គបានជ្រាបថានឹងអបរាជ័យចាញ់ដៃស្ដេចជាបច្ចាមិត្ត ហើយបាននឹកដល់ព្រះនាងទេវីជាអគ្គមហេសី, ព្រះអង្គបានចាត់ឲ្យអាមាត្យលើកទង់ជ័យមានពណ៌ក្រហមឡើងសំគាល់ ដល់ព្រះនាងទេវី ស្រេចស្ដេចតយុទ្ធទៀត ក៏ត្រូវដោយកូនសរស្ដេចជាបច្ចាមិត្រក៏ដួលចុះក្នុងស្ពាម ហើយទ្រង់សោយទិវង្គតទៅក្នុងកាលនោះឯង ។

គ្រាកាលនោះ ព្រះនាងទេវីបានឃើញទង់ជ័យលើកឡើងមានពណ៌ក្រហមដូច្នោះហើយ ក៏បានជ្រាបច្បាស់ថា ព្រះស្វាមីអញអបរាជ័យចាញ់ដៃបច្ចាមិត្តហើយ ក៏គិតខ្លាច ព្រោះគេដើររឿទឹងតែទៅក្នុង

កាលនោះឯង ។

លំដាប់នោះ មនុស្សទាំងឡាយជាអាមាត្យនៃស្ដេចចោរនោះក៏បាន ដឹងជាក់ច្បាស់ថា ព្រះនាងទេវីនេះ ជាព្រះអគ្គមហេសីនៃស្ដេចពិត ក៏ប្រមូលគ្នាដេញតាមព្រះនាងទេវីទាល់តែបាន ហើយនាំយកទៅថ្វាយ ស្ដេចជាម្ចាស់នៃខ្លួនក្នុងកាលនោះឯង ។

ឯស្ដេចដែលជាបច្ចាមិត្តនោះបានទតឃើញព្រះនាងទេវីមានវ័យវណ្ណ-នាការដ៏ល្អជាអស្ចារ្យ ប្រកបដោយលក្ខណៈ ហើយ ក៏មានព្រះទ័យបដិព័ទ្ធស្នេហាស្រឡាញ់ពេញព្រះទ័យ ប្រាថ្នានឹងយកធ្វើជាព្រះអគ្គមហេសីព្រះ-អង្គ ហើយត្រាស់បង្គាប់អាមាត្យទាំងឡាយថា អ្នកទាំងឡាយត្រូវចាត់ចែងរៀបអភិសេកព្រះនាងទេវីនេះ ឲ្យជាព្រះអគ្គមហេសីរបស់អញក្នុងកាលឥឡូវនេះឯង ។ ឯអាមាត្យទាំងឡាយ ក៏និយាយលួងលោមព្រះនាងទេវីនោះដើម្បីធ្វើអភិសេកឲ្យជាអគ្គមហេសី ដល់ស្ដេចជាម្ចាស់នៃខ្លួន ។

ចំណែកឯព្រះនាងទេវីក៏ពុំបានទទួលព្រមឡើយ ពោលឃាត់ថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ! ប្រយោជន៍ដោយការអភិសេកមិនត្រូវការដល់អញឡើយ ។

ព្រះបាទបច្ចត្ថកទ្រង់ព្រះសណ្ដាប់ហើយ ក៏ត្រាស់បង្គាប់អាមាត្យ

ឲ្យហៅព្រះនាងទេវីនោះចូលមក ហើយសួរថា: ម្នាលនាងដ៏ចំរើន ! ព្រោះហេតុអ្វីបានជានាងមិនប្រាថ្នា នូវការអភិសេកជាអគ្គមហេសីអញ ។

ឯព្រះនាងទេវីនោះក៏ក្រាបទូលតបវិញថា: បពិត្រព្រះសម្មតិទេព ! សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ ពាក្យដែលខ្ញុំក្រាបទូលព្រះអង្គឲ្យប្រពៃចុះ ដ្បិតព្រះបរមក្សត្រិយ៍ដែលទ្រង់ព្រះទិវង្គតទៅនោះ ជាព្រះស្វាមីចិញ្ចឹមរក្សាខ្ញុំបានឲ្យឥស្សរិយសម្បត្តិទាំងពួងដល់ខ្ញុំ ហើយបានបាត់ធ្វើអភិសេកខ្ញុំឲ្យជាអគ្គមហេសី ជាទីស្រឡាញ់ពេញព្រះរាជហឫទ័យព្រះអង្គ ក៏តែងចិញ្ចឹមរក្សាខ្ញុំឲ្យបានសេចក្ដីសុខក្សេមក្សាន្តរៀងមកដល់ឥឡូវនេះ ហើយស្ដេចក្ស័យព្រះជន្មទៅ បពិត្រមហារាជ ! ទោះបីខ្លួនខ្ញុំបានជាអគ្គមហេសីនៃស្ដេចដទៃដែលស្នេហាក្ដី តែខ្ញុំនឹករឭកនូវព្រះស្វាមីនោះហើយកើតនូវសេចក្ដីសោកនឹងឆេះរោលរាលនូវសាច់ហឫទ័យខ្ញុំជានិច្ច, ខ្លួនខ្ញុំមានសេចក្ដីទុក្ខព្រួយលំបាក ព្រោះព្រាត់ប្រាសព្រះស្វាមីជាទីស្រឡាញ់ ហើយតែងគិតរឿយ ៗ នឹងរួចចាកសេចក្ដីទុក្ខដូចម្ដេចបាន ព្រោះហេតុដូច្នេះឯង ខ្ញុំពុំប្រាថ្នានូវការអភិសេកនោះឡើយ សូមព្រះអង្គទ្រង់ជ្រាប ។

ឯព្រះបាទព្រហ្មទត្តរាជ ស្ដេចបានស្ដាប់ព្រះនាងទេវីក្រាបទូលដូច្នោះហើយ, ក៏ដល់នូវសេចក្ដីក្រោធពិរោធខ្លាំងគ្របសង្កត់ ព្រះអង្គត្រាស់ថា

បើនាងឯងមិនប្រាថ្នានូវអតិរេកទេ អញនឹងប្រោសនាងឯងទៅក្នុងគំនរភ្លើងឲ្យឆេះវិនាសក្ស័ណក្ស័យជីវិតដោយពិត ស្ដេចត្រាស់ដូច្នេះហើយ ក៏ចាត់សេវកាមាត្យទាំងឡាយឲ្យប្រោះដើងថ្កូរគរនូវគំនរអុសយ៉ាងធំ ហើយឲ្យយកភ្លើងដុត លុះដល់ដុតឆេះឡើងជាអណ្ដាតភ្លើសន្ធោសន្ធៅហើយ ក៏ត្រាស់បង្គាប់នាងទេវីថា នាងឯងត្រូវចូលទៅក្នុងគំនរភ្លើងនេះឲ្យឆាប់ ចំណែកឯព្រះនាងទេវីនោះ កាលអង្គស្ដេចប្រាប់នោះក៏ពោលជាបទព្រះគាថាដូច្នេះថា៖

អាទោ និព្ពាបិតំ រជ អាតគំ ខលុ អាវគោ
ហោតិ អាបផលត្តស្ស បច្ចាគ្គោ បរត្ថ ច ។

សេចក្ដីថា បពិត្រព្រះអង្គជាស្ដេច បានឮរៀនមកថា កិរិយាសម្លាប់ចុះនូវបុគ្គលទាំងឡាយ ឥតមានបាបណាមក ដោយចំណែកមួយទៅក្នុងគំនរភ្លើងជាអំពើបាបពេកមកពេកណាស់ ផលបាបរបស់បុគ្គលនោះ នឹងឲ្យផលជាទុក្ខលំបាកក្នុងលោកនេះផង ក្នុងលោកខាងមុខផង ដ៏ជាក់ស្ដែងពុំខានឡើយ ។

ព្រោះហេតុដូច្នេះ បពិត្រព្រះសម្មតិទេព! ខ្លួនខ្ញុំជាបុគ្គលមិនគួរដល់កិរិយាសម្លាប់ ខ្ញុំពុំបានចូលទៅក្នុងគំនរនៃភ្លើងនេះឡើយ ។

(នៅមានត)

# មហោសថជាតក

(តមក)

លោក គឹម-គន ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស គឹម-តួរ ពិនិត្យ

---

អា សាមិ គព្ភបុសដលមេវ បក្ខិបិត្វា គហេមីតិ អាហា ។ ពោធិសត្វជណ្តើងសួរទៅមេស្រីម្ចាស់អម្បោះនោះថា នែមេកាយ នាគ្គនឹកញ្ញើនោះ តើមេដាក់អ្វីខ្លះហ្ន៎ ? ។ ទើបមេម្ចាស់អម្បោះទូលថា បពិត្រព្រះមហោសថអើយ នាគ្គនឹកញ្ញើនោះខ្ញុំម្ចាស់ដាក់គ្រាប់ទន្ទាប ជឿតខ្ញុំម្ចាស់ទឹងសង្កត់អម្បោះខ្ញុំម្ចាស់ ។ ទើបពោធិសត្វព្រះអង្គឱ្យកត់ពាក្យនោះទុក ។ សោ ឧក្កិដ្ឋិបិ គាថំ បរិសំ គាហា. បេត្វា ... ពោធិសត្វជ្រាបហើយ ព្រះអង្គឱ្យពេទ្យឱ្យលស់ជាគ្រាប់ទន្ទាប់ហើយ ស្តេចមានបន្ទូលទៅទីងមេហោរនោះថា នែមេកាយ, មេថាដាក់គ្រាប់កប្បាសក្នុងនឹកញ្ញើ អញឱ្យវេរមិនយល់ជាគ្រាប់កប្បាសឡើយ យល់តែគ្រាប់ទន្ទាប់វិញ, បើដូច្នេះ គឺមេឯងជាចោរពិតហើយ ។ ឯមេស្រីកំណាចនោះពុំអាចលាក់ខ្លួន គឺលន់តួទោសទូលពោធិសត្វថា បពិត្រព្រះមហោសថអើយ ខ្ញុំនេះជាចោរមែនពិតហោង ។ បពិត្រអើយ

ចាប់ដើមអំពីនោះទៅ  រីព្រះមហោសថអ្នកប្រាជ្ញ  គាប់ប្រដៅឲ្យខ្ញុំទ ដំបូងនាងមេស្រីចោរនោះហើយ  ព្រះអង្គឲ្យគេញែកអំបោះនោះទៅមេម្ចាស់អំបោះនេះវិញហោង ។ សាធូតិ សម្បដិច្ឆិត្វា អគមាសិ ។ មេម្ចាស់អំបោះនោះទទួលអំពីពោធិសត្វហើយ  ក្រាបលាពោធិសត្វទៅកាន់ហាន់ទំលំនៅអាត្មា ។ មហាជនោ  ហដ្ឋតុដ្ឋោ  អស់មហាជនទាំងឡាយយល់ហើយមានចិត្តត្រេកអរ ។ អប្ផោដេសិ  គឺទះដៃជួយឲ្យជ័យសព្ទសាធុការដ៏កងរំពងជាយជាពាន់ជាសែនគុណហោង  ។ បតិត្រអើយ  រីពួកអាមាត្យដែលព្រះមហាក្សត្រត្រាស់ប្រើឲ្យចាំឃ្លាំមើលលុះយល់ត្រកាលជាអស្ចារ្យមើលមិនវិស័យជាក្មេងអាយុ ៧ ឆ្នាំនោះឡើយក៏ប្រើកជខ្ញុំតឲ្យស្រូតរូតទៅ  ទូលព្រះបាទវិទេហរាជ ។ ស្ដេចជ្រាបហើយមានតម្រាស់ត្រាស់ទៅកាន់ហៅអាចារ្យសេនកថា  សេនក  ម្នាលអាចារ្យសេនកអើយ  បើដូច្នោះ  តើយើងឲ្យទៅនាំយកមហោសថជាអ្នកប្រាជ្ញមកឬ ម្ដេច ? ។ រីអាចារ្យសេនក  ហេតុតែជាអ្នកកំណាញ់យសលាភសក្ការៈ  ក៏ទូលថាស់មិនឲ្យនាំពោធិសត្វជាអ្នកប្រាជ្ញមកឡើយ  ។

បុត្តន្តិ  ទីងស្រដីអំពីល្បងកូន ។ ឯកា  ឥត្ថី បុត្តំ  អាទាយ  មុខធោវនត្ថាយ  បណ្ឌិតស្ស  បោក្ខរណឹ  គន្ត្វា បុត្តំ  នហាបេត្វា  អត្តនោ  សាដកេ  និសីទាបេត្វា

មុខំ ធោវិត្វា ឱតរេ ៗ បពិត្រអើយ, កាលនោះ មានស្ត្រីម្នាក់ ទើបមានកូនម្តង មេៈនោះឯង ពកូនទៅផ្ទូតទឹកលាងមុខទាត់កូនហើយ ចេញទៅ កាលបើទៅដល់ស្រះព្រះមហោសថអ្នកប្រាជ្ញ ហើយផ្ទាស់ សំពត់សំលៀកកាត្តាឲ្យមកូនទៅផ្ទូតទឹកលាងមុខមាត់ស្រេចហើយ យក មកដាក់អង្គុយលើសំពត់កាត្តា ហើយម៉ែម្តាចុះទៅផ្ទូតទឹកបន្តោបខ្លួនញើស ក្អួលសរីលងន៍ទាំងន៍ដួង ៗ តស្មិំ ខណេ ឯកា យក្ខិនី តំ ទិស្វា ទារកកាមា ហុត្វា ឥត្ថីវេសំ គហេត្វា . . . ឮថាកាលនោះ មានមេយក្ខិនីមួយ វាដើរមកអំពីឯណាមិនដឹងឡើយ វា ឃើញកូននោះហើយ វាមានចំណង់នឹងបង់ធីកូននោះ ក៏វាយកកៀស កាត្តាជាស្រីមួយហើយ វាផណ្តឹងទៅថា គ្រាកសំឡាញ់អើយ រីក្មេងនេះ ល្អក្រៃ ជាកូនគាននា: ៗ រីម្តាយនោះថា អើកូនអញ ៗ ដូច្នោះក្តី យក្ខិនីនោះថា អញបំបៅណា ៗ មេនោះថា អើការបំបៅហោង៍ៗ យក្ខិនី ពក្មេងនោះធ្វើអំពើជាបន្ទួន៍ទៅមកបន្តិច ក៏នាំពង្រត់ទៅហោង ៗ ឯ ម្តាយនោះវិញ ឃើញគេនាំពង្រត់កូនទៅដូច្នោះ ក៏ដោះឡើងអំពីទឹកម្នី ម្នាប្រវាប់បាទសំពត់តែតាមទៅស្រែកហៅថា មេកាយ: យកកូនអញ ទៅឯណាហ្នឹង ៗ មេនោះរត់ទៅតាន់ចាប់ដាយសំពត់ខ្លាច ៗ រីមេយក្ខិនី ស្រដីថា មេបានកូននេះពីឯណា នេះកូនអញទេតើ ៗ រីមេទាំង ២

ឈ្មោះគ្នា ទៅដល់ក្បែរទ្វារបរមសាលានៃព្រះមហោសថ ។ កាលនោះ ព្រះអង្គឮនូវស័ព្ទមេចាំង ២ នោះហើយ អ្នកឱ្យហៅមក ហើយដណ្ដឹងសួរថា ហេតុម្ដេចហ្នឹង? ។ រីមេចាំង ២ នោះក្រាបដោយដំណើរសេចក្ដីសព្វគ្រប់ ។ ពោធិសត្វអ្នកស្ដាប់មេចាំង ២ នោះហើយ អ្នកក៏ស្គាល់ជាក់ថា មេមួយនេះជាយក្ខិនី, នាអ្នកស្គាល់នោះ ហេតុវាពុំបីប្រិចភ្នែក, ហេតុវាមានភ្នែកក្រហម, ហេតុវាឥតញើស ឥតស្រមោលហើយអ្នកថា នែមេចាំង២បិតនៅដោយបង្គាប់អញឬម្ដេច? ។ ឯមេចាំង២នោះថា បពិត្រអម្ចាស់ យើងខ្ញុំបិតនៅដោយបង្គាប់អម្ចាស់ហោង ។ រីពោធិសត្វមិញ អ្នកឱ្យគូសដីជាគ្នើង ហើយអ្នកឱ្យយកក្មេងនោះមកផ្ដេកកណ្ដាលគំនូសនោះ ហើយអ្នកឱ្យយក្ខិនីកាន់ឯដៃ ឱ្យម្ដាយនោះកាន់ឯជើង ទើបបង្គាប់ថា នែ! ចូរមេចាំង ២ ទង់ទាញមើល! ថាបើនរណាទង់ទាញបានហើយ យើងនឹងដឹងជាកូនអ្នកនោះហោង ។ រីមេចាំង ២ ក៏ប្រទង់ប្រទាញកូននោះទៅវិញទៅមក កូននោះក៏ស្រែកយំនូវសព្ទសំរែកនោះខ្លាំងក្រៃ, ឯម្ដាយកាលបើឮកូនយំស្រែកដូច្នោះហើយ ដ៏មានទ្រូងដូចនឹងបែកសភ្នែក ស្រែកយំឈរស្ងៀមនៅហោង ។ ចៅមហោសថអ្នកប្រាជ្ញ អ្នកដណ្ដឹងសួរអស់អ្នកផងទាំងឡាយថា ម្នាលអ្នកទាំង-ឡាយអើយ រីហ្ឫទ័យថ្លើមដង្ហើមម្ដាយទន់នឹងកូនឬទេហ្នឹង ឬមេថ្មី

ផង្ហើមហ្ញ័យម្ដាយមិនទទ់ទឹកដូនទេហ ? ។ អស់មហាជនផងទាំងឡាយ
ថា បពិត្រអ្នកប្រាជ្ញអើយ! រីឯទ្រូមផង្ហើមហ្ញ័យនៃម្ដាយនេះ សុទ្ធតែ
តោងទន់ទៅទឹកដូននោះពេកហោង ។ រីព្រះមហាសត្វអ្នកថាដូច្នេះ ឥឡូវ
នេះ រីនៃដែលកាន់កូនហើយឈរព្រងើយនោះជាម្ដាយឬមិនមែនជាម្ដាយ?
ឯមេដែលលែងកូននោះ ហើយឈរស្រែកទ្រហោយំនៅ, មេនោះជា
ម្ដាយឬមិនមែនជាម្ដាយ? ។ អស់បណ្ដាមហាជនផងទាំងឡាយថា បពិត្រ
ចៅអ្នកប្រាជ្ញអើយ រីស្រីដែលលែងកូនហើយឈរទ្រហោយំនៅ មេនោះ
ឯងជាម្ដាយហោង ។ ព្រះមហាសត្វថា អ្នកទាំងឡាយស្គាល់ស្រីជា
ចោរលួចកូនឯនេះឬទេ? ។ អស់បណ្ដាមហាជនផងថា បពិត្រចៅអ្នក
ប្រាជ្ញអើយ យើងខ្ញុំពុំស្គាល់ឡើយ ។ ព្រះមហាសត្វថា ម្នាលអ្នក
យើងអើយ! មេនេះជាយក្ខិនីទេ វាយកកូនឯនេះទៅទំពា ។ អស់
បណ្ដាមហាជនផងទាំងឡាយថា បពិត្រចៅអ្នកប្រាជ្ញអើយ ទានម្ចាស់
ស្គាល់ទូលគុណៈម្ដេចអេះ? ។ ព្រះមហាសត្វថា អញស្គាល់បង់មិន
បំប្រិចភ្នែក, មួយសោត បង់មានភ្នែកក្រហមហើយឥតស្រមោល,
មួយសោត បង់មិនមានញញើត, មួយសោត បង់ឥតករុណា
នេះហោង ។ លំដាប់នោះ ព្រះមហាសត្វអ្នកដណ្ដឹងថា មេអាយ
មេឯងជាអ្វី ? ។ វាថា បពិត្រអម្ចាស់អើយ ខ្ញុំជាយក្ខិនី ។ អ្នកថា

មេយកក្មេងនេះទៅធ្វើអ្វី ៗ ឯមេយក្ខិនីថា បពិត្រអម្ចាស់អើយ អញខ្ញុំយកទៅទំពាស៊ីហោង ៗ លំដាប់នោះ ព្រះមហាសត្វអ្នកទើបឲ្យដំបូន្មានថា ហៃមេយក្ខិនីអើយ មេឯងអន្ធពាលកំឡៅស្មើខ្លាក់ មេបានធ្វើបាបអំពីមុនមក ទើបមេបានកើតជាយក្ខិនីអប្រិយកាស្រូវដូច្នោះ, ឥឡូវនេះ មេមកធ្វើបាបវិញទៀត, ឱមេអើយ! មេខ្លៅល្ងង់ពន់ពេកហ: ៗ លំដាប់នោះ អ្នកដំកល់មេយក្ខិនីនោះ ឲ្យឋិតនៅក្នុងបញ្ចសីលហើយឲ្យដំណើរទៅហោង ៗ រីមេម្តាយនោះ សរសើរគុណព្រះមហាសត្វថា បពិត្រអម្ចាស់ជាអ្នកប្រាជ្ញប្រសើរអើយ! សូមឲ្យអម្ចាស់មានព្រះជន្មប្រកបនូវបុណ្យឋិតថេរចិរកាលទៅហោង ៗ មេនោះស្រដីអម្បាលនោះហើយក៏យកកូនអាត្មាហើយលាទៅហោង ៗ រីការល្បងកូនម៉ាញ សុំរេចនូវប្រការអម្បាលនេះឯងហោង ៗ

គោណោតិ រឿងល្បងអំពីគោធកាឡ មានសេចក្តីដូច្នេះ ៗ ឃគោ គិរ បុរិសោ លក្ខណកតាយ ចេវ កាឡ-វណ្ណតាយ ច គោធកោឡោ នាម ៗ បពិត្រអើយ កាលនោះ មានបុរសម្នាក់ មានខ្លួននោះទាបកន្តិលខ្មៅ មានខ្លួននោះទ្រុងកណ្តាល ហេតុនោះទើបគេហៅថា អា-គោធកាឡ, រីអា-គោធកាឡនោះ ទៅធ្វើការបំរើគេ ៧ ឆ្នាំទើបបានភរិយា, រី

មេករិយានោះ គេហៅថា មេ ទីឃគាហណា ដ្បិតមេនោះគាត់ ហើយខ្ពស់បង្គ្រោង ៗ មានកាលសម័យថ្ងៃមួយ គោជកាឡបុរស ទិនទៅស្រុកឆ្ងាយនោះ សូម្បីករិយាយាត់ជាគំរប់តីរ បីជនក្តី ក៏ប្រើឲ្យចំអិនចំណីអាហារស្បៀងលៀងទៃ យកខ្ទប់បញ្ចប់ណ្តាំមួយអន្ទើ ទិនករិយា ដើរដោយខ្លួនផ្លូវទៅហោង, ដើរវៀង ៗ ទៅ យល់ ស្ទឹងមួយនោះហៅ គ្មានពាហិនី ស្ទឹងនោះពក់ តែគីមោះទឹកហូរ ខ្លាំង បុរសនោះហេតុតែជាអ្នកខ្លាចកំឡាចទឹក ហេតុនោះពុំអាច ទិនចុះទឹកនោះបានឡើយ ក៏ឈរនៅមាត់ច្រាំងនោះហោង ៗ បពិត្រ អើយ ឮដំណាលនោះ មានបុរសម្នាក់ទៀតឈ្មោះ អា-ទីឃបិដ្ឋ ហេតុវាមានខ្នងនោះវែងគោងខ្ពស់បង្គ្រោង វាដើរមកដោយឆ្មោស្ទឹង មកដល់ឋាននោះហើយ, វដនតីនាក់ ប្តី-ប្រពន្ធនោះមិញ កាលណា បើយល់ អា-ទីឃបិដ្ឋនោះមកដល់ហើយក៏ដណ្តឹងថាហៃ ចាស់អើយ ស្ទឹង នេះតើជ្រៅប៉ុណ្ណាក់ ? អា.ទីឃបិដ្ឋវាដឹងថាអ្នកទាំងពីរនោះខ្លាចទឹកដូច្នោះ ហើយ វាឆ្លើយថា ក្មើអើយ ទឹកនេះជ្រៅណាស់ ដំមានត្រីផងសោត ច្រើនកាចសាហាវ, អា.គោជកាឡថា ក្មើបើដូច្នោះ តើក្មើទិនទៅម្តេច បាន, ឯអា-ទីឃបិដ្ឋថា ក្មើអើយក្មើ វិសត្វផងមានចំនើប គីក្រពើ ធ្លាះមករង្គ្រាតផង សីនឹងបទិស្សួយទិនយើង វាពុំអាចទិនបៀតបៀន

យើងឡើយ បើអ្នកដទៃហើយ វាកាត់ខាំបរិភោគជាចំណីវាហោង ៗ រីគោធកាឡ្យបុរសថា បើដូច្នោះ គេនាំចម្លងយើងទៅផង គេបានឬទេ ? ទីឃបិដ្ឋបុរសនោះ ទទួលពាក្យថា យើងចម្លងបានហោង ៗ លំដាប់នោះ អ្នកតាំងពារ ប្ដី ប្រពន្ធមិញក៏រៀបចំណីដល់ទីឃបិដ្ឋបុរសនោះបរិភោគ, កាលបើបរិភោគរួចហើយ ទីឃបិដ្ឋបុរសសួរថា អ្នកអើយ ចម្លងនរណាទៅមុន ? ឯគោធកាឡ្យបុរសថា អ្នកនាំម្រាក់អ្នកទៅមុនចុះ រួចហើយអ្នកមកនាំអញទៅជាឯក្រោយ, ទីឃបិដ្ឋបុរសថា គាប់ហោង ៗ ទីឃបិដ្ឋបុរសបានដៃ ក៏យកមេទីឃគាហលាបញ្ចុះលើស្មា ហើយយកថង់ស្បៀងបញ្ចើបណ្ដាំ តាំងពួនទោះទៅផង ហើយចុះទៅក្នុងកំពង់ស្ទឹងនោះ, វាដើរទៅបានបន្តិចហើយ វាលុតជង្គង់ប្រហោង ដើរវិលិ ១ ទៅដូច្នោះហើយ ធ្វើឲ្យដូចជាទឹកជ្រៅណាស់, ឯគោធកាឡ្យបុរសនៅលើច្រាំង រមិលមើលយល់ទីឃបិដ្ឋបុរសនោះហើយគិតថា អេះស្ទឹងនេះ ជ្រៅពេកហ: អម្បាលគេខ្ពស់ម្ល៉ោះធ្ងន់ស្ទើរមិនបានចំណង់បើអញ្ញែតាបម្ល៉េះ ម្រាងឡើយនឹងធ្លងទៅបាន ៗ ឯទីឃបិដ្ឋបុរសនោះមិញ ទៅដល់កណ្ដាលទឹកនោះហើយ ក៏ស្រដីប្រហោមលួងមេទីឃគាហលាថា ហៃម្រាក់ អញនឹងចិញ្ចឹមរក្សាព្យាបាលម្រាក់ឯងអញនេះប្រកបនឹងទ្រព្យធនច្រើន ៗ (នៅមានត)

# រឿងមរណមាតា

(តមក)

លោក ប៉ី សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត

---

ពុំគួរបងបោះបង់ ឲ្យនាងនៅឯងឥតត្រើយ មិនមិត្រមិនមូលឡើយ មិនគង់គួរដូចហ្វូងសត្វ ៗ បក្សីបក្សាផង មានគូគ្រងមិនប្រាសប្រាត់ តែបងនឹងប្អូនទៃត្ន បោលនាងនៅឯងឯកា ៗ រលឹកទឹកខ្សឹកខ្សួល វែងរំជួលក្នុងកាយា រន្ធត់ក្នុងចិន្តា ជាអស្ចារ្យអស្ចារ្យក្រៃ ៗ ចំឡែកក្នុងព្រះអង្គ ស្តេចវែងវ្រង់ព្រួយព្រះទ័យ វែងទឹកវែងកាល័យកាឡោះលន់ពន់ប្រមាណ ៗ ព្រោះហេតុនឹងព្រាត់ប្រាស ប្រាសនិពសនាងកល្យាណ កម្មនាងពីបូពណ នាងបានធ្វើអំពើគ្គង ៗ កម្មនោះតាមមកដល់ នាងនិមលឲ្យមានហ្មង នឹងព្រាត់ប្រាសច្បាស់ច្បង ទើបកើតហេតុដូច្នេះឯង ៗ អន់ស្អួលព្រះទុក ខ្វល់សែនមហាខ្វល់ស្រប់ស្រែង ពុំមានបន្ទូលថ្លែង ទំរំសាយព្រះទ័យា ៗ ទតក្នុងយានបណ្តើរ ព្រះដំណើរ

ទំលីលា ដល់ឋានមានព្រៃក្បា ដុះជាជ្រុំត្រសុំល្អ ។ ដីរាបជ្រះស្អាតឃន់
មានស្រះស្រង់វន្សរុក្ខាពិសិ បញ្ចប់ពលទិករ សង់បន្ទាយថ្វាយក្សត្រ
ថ្ងៃ ។ សង់រូបស្តេចឡើងគង់ ពេលាមន្ត្រីល័រជ័យ សេនាពលនោះ
នៃ ហោះទ័ពតាយកបជុំជិត ។ រានក្អឹងក្ដីត្របះ ក្ដីជាក់ច្បាស់ពុំងងឹត
ប្រយ័ត្នក្សត្របពិត្រ យាមគយល្បាតរាល់រាត្រី ។ ព្រឹកព្រោងស្នានសុរិយា
ចាកនិទ្រាព្រះចក្រី ស្រប់ក័ក្ដិសោយព្រះស្រី ស្រេចចេញគង់ព្រះពន្លា ។
មន្ត្រីគាល់គាប់គាន់ ដោយជួរជាន់ត្រឹមត្រៀបត្រា ស្តេចបើកព្រះឱង្ការ
ប្រើអាមាត្យរៀបពលយាន ។ ប្រាប់ពួកហ្មត្រមាក់ ឲ្យរៀបធ្លាក់គជេន្ទ្រ-
ហាន រៀបស្រេចទូលក្សត្រក្សាន្ត ជ្រាបស្រេចស្តេចសោយព្រះស្ងោយ ។
សោយស្រេចស្តេចឡើងគង់ យានទន្តីសឹងសុវណ្ណ មន្ត្រីហែត្រៀប
ត្រា ចូលព្រឹក្សព្រៃត្រៃឈឹង ។ ឯនាយពួកគ្រមាក់ ជះសឹងធ្លាក់ណា
នាំទីង រូបរាងធំស្លូកស្តឹង ខ្លាំងពេកពិតចិត្តហានក្លា ។ បរកាត់ក្កាត់រៃព
ឃើញដំរីព្រៃត្រៀបត្រា បរធ្លាក់ចូលតុះតារ ពះសម្រេចគេចហ្វូងទៅ ។
តាក់បាចបានឈ្មោលមក ឃុំនាំយកកូនសុំស្ទោ ព្រ័ត្រជ្រាមតាម
ទុកនៅ ផ្សាំងផ្ដាច់ព្រៃថ្វាយក្សត្រថ្ងៃ ។ ស្តេចទតទូន់អំណរ ប្រទាន
ហ្មប្រាក់ច្រើនក្រៃ ហ្មបានស្ងើចនៃ តែងទៅតាក់សព្វវេលា ។ បាន
ច្រើននាំមកថ្វាយ ស្តេចសប្បាយព្រះទ័យា ប្រពាតតាក់គជសា សឹង

សោមនស្សក្សត្រក្សេមក្សាន្ត ។

បទពំនោល

ន័យនេះឈប់ស្ទុះទុកមាន ទៀតទើបនិទាន ទៅឯកុដុម្ពិកកាលី ។ កាលក្រោយអស់មុខមន្ត្រី លើកពលសេនីយ ដង្ហែមរណមាតា ។ វិលថ្វាត់ឃើញស្វាត់ត្រឹមហា នាំគ្នាល័លា មកដល់មណ្ឌលឋានថ្វាត់ៗ គេមើលអស់ទ្រព្យសម្បត្តិ ឃើញនៅមិនខ្វាត់ មិនខ្វាយអន្តរាយឡើយណា ។ បាត់តែមរណមាតា ទើបដើរសួរសា សួរអស់អ្នកស្រុកជិតគ្នា ។ គេប្រាប់សាស័ព្ទទៅថា មរណមាតា រាសនានាងច្រើនក្រាស់ក្រៃ ។ បានបុណ្យផ្តើមផលទន់ប្រពៃ ជាក្សត្រីថ្លៃ វិសេសលើសលែងគន្ធ ។ ដ្បិតក្សត្រវរពជប្ញាស់ឲ្យង ប្រើមន្ត្រីផង បើកពលចតុរង្គសេនា ។ អញ្ជើញមរណមាតា គង់យានចរនា ដង្ហែចូលទៅអភិសេក។ អ្នកបានមរណាបាត់បែក ឃ្លាលគោស្មុក ។ ដូច្នេះគិតម្ដេចអ្នកស្រី ។ ខ្ញុំឡូកចំអកកាលី ថាអ្នកក័យថ្វី ទៅស្ដីមនុស្សហ្វូងយកមក ។ ខ្ញុំអ៊ីមនុស្សហ្វូងកុញកក បើអ្នកទៅរក ហ្វូងថាម្ដាយក្មេកហ្វូងឲ្យ ។ ខ្ញុំឡូកលក្សក់ពីក្រោយ ខ្ញុំពេបមាត់ឲ្យ កាលីពុំដឹងខ្លួនសោះ ។ លាក្រោកដើរមកផ្ទះស្មោះ ប្រាប់ប្ដីដឹងអស់ ដំណើរមរណមាតា ។ កុដុម្ពិកស្ដាប់ហើយថា អើឯងរាយរ៉ា ធ្វើទុក្ខបុកបែនសល់ខ្នាត ។ ឥឡូវ

ត្រូវបានកាស្អាត បានស្អាងពីជាតិ មនមកឲ្យបានជាស្តេច ៗ រុងរឿង
ថ្កល់ថ្កើងជាស្រេច ជាច្រពន្ធស្តេច ធំលើអស់រាស្ត្រប្រុសស្រី ៗ ម៉្លោះ
ហើយវាមិនប្រណី ក្បាលហាងឯងក្តី ទីទៃគង់ទីងរូបទៅណា ៗ វាពិត
វាទូលក្សត្រា ស្តេចជ្រាបក្រាជា ធ្វើតុក្ខមិនមានសទោស ការបីពុទ្ធ
បន្ទោស ខេរខឹងគោះមោះ សំឡក់សំឡឹងហើយស្តី ៗ មើលមុខគ្រាន់
ថើជាងស្រី ម្ល៉ោះ ៗ ហានស្តី ទទឹងទទែងជូរជោះ ៗ ខ្ញុំចម្ចុំបុណ្យស្រី
ចុំណ្ណោះ ចុំនអាចម៍ប្រមុះ គឺគេះទោលចេញទៅបាត់ ៗ ថើល្ងង់ទៅ
សៀមកុំមាត់ កុំដេរពេកក្តាត់ ចាំមើលប្រាជ្ញាកាលី ៗ អ្នកឯងព្រួយ
ចិត្តឈឺថ្វី នរណាស្រដី គេពីងឲ្យអ្នកឯងថា ៗ ខ្ញុំចម្ងឺអម្បាលប្រាជ្ញា
មរណមាតា ប្រាជ្ញាវាវែងពុំខាន ៗ អញឯងចាំតាំងឲ្យបាន មិនឲ្យ
កើតមាន ទុក្ខទោសលំបាកដល់អ្នក ៗ បើគិតឲ្យកើតគុណៈ កើតទោស
ដល់អ្នក ទីងធ្វើជាមនុស្សផ្ដួចផ្ដេច ៗ កាលបើស្តីហើយសម្រេច សៀម
ស្ងាត់ពាក្យពេចន៍ គឺមោះកូនពោះក្តៅផ្សា ៗ ព្យាបាលមរណមាតា ជាអត់
ឲ្យវា អញគិតផ្ចាញវាឲ្យបាន ៗ ថាហើយចង់ក្បិនចូលក្រាន ដាំបាយ
ធម៌បាន បរិភោគប្រើកូនឃ្វាលគោ ៗ ក្តៅក្តាត់ដោយចិត្តពាលោ ពោ-
សោមោហោ មទោមានះមិនបាត់ ៗ ញ៉ាំបើថែមដង្ហើមប្រមាត់ គុំគួនស្រី
រ័ត្ន រិះគិតកេតលសព្វថ្ងៃ ៗ មិនស្តីប្រាប់អ្នកដទៃ គិតម្នាក់ឯងនៃ គិត

ពៃលគិតល្មុះ ៣ ឆ្នាំ ។ កាលីជាស្រីមានគម្ភ កើតទុក្ខ ៣ ឆ្នាំ រំលែរល់
គុំនិងចិត្តឥតអាក់ ។ កាលីមានស្រីបន្ទាប់ម្នាក់ មេមាយអបលក្ខណ៍ ហៅ
ឈ្មោះកាលិណីយា ។ រួមគន្ធរួមឯកទេរក ម៉ែមួយមូលគ្នា គំនិតកំណាច
កាចផង ។ កាលីនិយាយដើមរាន ថាបងជួយផង បំផ្លាញកូនកសត្រូវ ។
កុំទុកទៅមុខឲ្យនៅ ឲ្យគន់វែងទៅ ពន់ទីងព្យាបាទមិនខាន ។ គិតកិច្ច
ធ្វើម្តេចឲ្យបាន ធ្លាញាក់សមាន្យ ឲ្យលុះក្ស័ណក្ស័យអន្តរាយ ។ កាលី
ណីយាធ្វើឧបាយ គល់កិច្ចឃើញឆាយ គំនិតគិតជាពេកក្តាត់ ។ កាលី
ស្តាប់ហើយធ្វើយថ្វាត់ បងថាឆាយក្តាត់ ឧបាយដូចម្តេចអ្នកបង ។
កាលិណីយាធ្វើយស្នង ថានាងស្តាប់បង យើងប្រើកូនយើងទូហារ ។
ទៅប្រាប់មរណមាតា បញ្ឆោតពាក់ថា បិតាចុះឈើខ្វាំង ។ ដុនជាបដួលដេក
ក្តីកក្តាំង តាប ។ កម្លាំង ស្តាំងស្តមអត់តាំកអាហារ ។ បាយទឹកពុំបាន
គោក្តា ពុំលក់និទ្រា សោកាកេអ្នកសព្វថ្ងៃ ។ គាត់ទឹកលើកអ្នកក្រៃ
បើសេះបើក្សយ ឲ្យបានឃើញមុខអ្នកម្តង ។ រៀបគាត់ប្រើយើងមកផ្គង
មកទូលអ្នកបង ឲ្យភ្ញាន់ប្រញាប់កិច្ចការ ។ ឯមេមរណមាតា មិនដឹង
ហើយពាក់ ទីងដើរឥតមានសង្ស័យ ។ បញ្ឆោតឲ្យបានដល់ដៃ យើងទីង
ដឹកដៃ ឧបាយគល់កិច្ចសុខុម ។ យើងជីករណ្តៅឲ្យធំ ក្រោមផ្ទះហើយ
ហ៊ុម កុំឲ្យនរណាដឹងគល ។ ហើយយើងយកខ្ទះមកដល់ មកដាក់ដម្កល់

លើគុករណ្តៅនោះចុះ ៗ ហើយយើងឲ្យកូនរកខុស ផុនមកហើយចុះ ទៅរៀបដាក់ក្ទងគុកលាក់ ៗ ស្រេចហើយយកប្រេងមកចាក់ ឲ្យពេញខ្ទះ ដាក់ គុកហើយដុតភ្លើងឲ្យពុះ ៗ រួចហើយធ្វើការយន្តនោះ វាដើរជាន់ចុះ ក៏ហាក់ធ្លាក់ក្ទងប្រេងស្លាប់ ៗ ទើបយើងយកគ្រឿងប្រដាប់ ពីទើបសម្រាប់ ដែលវាតែងពាក់ប្រក្រតី ៗ រួចស្អាងមេចន្ទូណី តាងមេតិរ្យ មរណ-មាតានោះណា ៗ ហើយជូនទៅថ្វាយក្សត្រា សម្តេចស្នេហា យើងបាន សម្បត្តិច្រើនក្រៃ ៗ ថ្កើងកេរ្តិ៍ថ្កើងយសប្រពៃ ឥតអ្នកដទៃ ណាទឹង ស្មើបានឡើយណា ៗ ក្ទងខែត្រកាសិកកជា សឹងខ្វាចចេស្តា នៃយើង ក៏ថ្កើងឥតស្មើ ៗ ល្បីឈ្មោះពីរោះប្រសើរ អញគិតនោះតើ គិតទិតជា ខុសឬត្រូវ ៗ កាលជាស្រីចៃចូវ រវែរវៃ ថាគិតនេះត្រូវពេកក្តាត់ ៗ ថាហើយលាទៅផ្ទះថ្វាត់ ដល់ប្តីឃើញស្វាត់ ខ្សឹបខ្សៀវប្រាប់ប្តីអាត្មា ៗ សព្វសុសសេចក្រេចវាតា ដែលរិះគិតគ្នា កាលណាយាដាបង ៗ ហើយ ប្រាប់រៀបរាប់ទំនង ថាមេដកចង មរណមាតាអ្នក ៗ កាលដើម ស្រឡាញ់ឥតអាក់ មិនថ្នាំងមិនថ្នាក់ អ្នកថ្នមដូចដួងចិន្តា ៗ វាគក់ប្រហាច បាត ថែតាំងព្រេត្យ ជាកូនគំនាប់អ្នកឯង ៗ វាបានបុណ្យធំចំពែង គ្មានគិតមកឯង ដល់បុណ្យកេសីឡើយណា ៗ វាស្អប់អ្នកឯងបិតា ម៉េះ សមឃើញថា ជំនួនចំណីមកដល់ ៗ នេះបាត់សូន្យស្វាត់ពុំយល់

សមរាំធ្វើកល ធ្វើការធ្វើកិច្ចម្តេចម្តា ។ ទើបបាត់សូន្យស្ងាត់សោះសា

គួរយើងធ្វើវា ជាមុនឲ្យហើយទើបបាន ។ បើទុកទៅមុខនឹងមាន ទោស

ពាល់ដល់ប្រាណ លុះក្ស័យប្រល័យអាសា ។ កាលីបេះស្តីពៅហារ

ឧបាយប្រាជ្ញា កុដុម្ពីកទប់ជឿពុំបាន ។ កុដុម្ពីកផ្ទៀងស្តាប់សាសាន

ទើបឆ្លើយវិញថ្កាន ថាអើមែនដូចនាងវ៉ា ។ នាងគិតឧបាយប្រាជ្ញា

នឹងផ្កាញត្តួរ៉ា គំនិតនោះគាប់ពេកក្តាត់ ។ ម្ល៉ោះហើយនាងប្រុងប្រយ័ត្ន

ពាក្យពេចន៍ឲ្យស្ងាត់ កុំឲ្យលិចឮទៅណា ។ កាលីស្តាប់ហើយឆ្លើយថា

កុំព្រួយចិន្តា គំនិតខ្ញុំគិតសុខុម ។ ត្រង់ណោះទុកឆាឲ្យខ្ញុំ វែលងវែត

អ្នកសម គំនិតស្រុះស្រួលផងគ្នា ។ ហេតុកម្មវិពជជាយា ពីព្រេង

មហិមា នឹងដល់ក្សិណក្ស័យជីវី ។ កម្មនោះមកនាំកុដុម្ពីក មិនបាន

ស្រដី អាណិតអាសូរសួនគ្នា ។ ក្មេងបុត្រកំសត់កំព្រា គិតស្រុះព្រម

គ្នា នឹងមេកាលីតិរិយ ។ ប្រាជ្ញាប្រយោជន៍លោកិយ បងជាសេដ្ឋី

ធំលើសការសិករដ្ឋ ។ មិនដឹងនឹងធ្លាក់ចតុក · បាយបាបវេទនា មហា

នរកសូន្យសោះ ។ ស្មានថានឹងបានរបស់ ទ្រព្យប្អូនកាដ៏នោះ មក-

លុះកណ្តាប់ហត្ថា ។ កុដុម្ពីកអរផតឧបមា គង់ចិត្តគិតថា ជតាអញ

ឡើងឯតាស់ ។ នឹងបានធនធានក្រៃក្រាស់ គោដំឃ្លាំងស្រឡះ ក្រឡាប់

មកវិញមិនខាន ។ ពួកខ្ញុំប្រុសស្រីប៉ុន្មាន ដែលគេចាកឋាន នឹងបាន

មកលុះប្រាថ្នា ។ គិតហើយហៅកូនទេវហារ ហៃកូនសង្សារ សំណូត សំឡាញ់ផុតភ័យ ។ ចូរកូនខ្ញុំមខ្លួនមកតាយ ផងនឹងប្រះប្រាយ ប្រាប់ប្រើប្រញាប់ម្នីម្នា ។ កាលនោះឯកុមារិកា លុះឮបិតា ហៅហើយចរចូលមកថ្វាត់ ។ កុដម្ពីក៏ថាហៃកូនរត្ន ចូរនាងទៅថ្វាត់ ទៅដល់លំនៅក្សត្រី ។ មរណាមាតាមហេសី ឲ្យវរក្សត្រី អញ្ជើញប្រញាប់ម្នីម្នា ។ ថាដ្បិត-បិតាពុំងា កើតមានរោគា ជម្ងឺក្តៅខ្លួនខ្លាំងក្រៃ ។ ដល់ដួលដាច់ដកសង្វៃ វែបបុកជើងដៃ លិ្ហតល្ហែអត់តាំងអាហារ ។ ពុំបានបាយបរិភោគា ជន់ជាបន្ទិត្រា នឹងក្រោកពុំបានឡើយនៃ ។ គាត់នឹករលឹកអ្នកក្រៃ បើរស់បើក្ស័យ ឲ្យបានឃើញមុខអ្នកបង ។ ទើបគាត់ប្រើយើងមកឆ្លង អញ្ជើញអ្នកបង ឲ្យស្តេចប្រញាប់យាត្រា ។

## បទកាកគតិ

កុមារីតីរស្តាប់ អាពុកបង្គាប់ ចង់តាំងចិត្តា រូបរៀបស្អិតស្អាង រូបរៀងអាត្មា លុបលាងគង្គា ស្រេចស្លៀកសំពត់ ។ លាបប្រេងក្រមួន ផាត់ម្សៅថែនខ្លួន សិតសក់បួងបទ ហើយយកកញ្ចក់ ឆ្លុះមុខហ្មត់ចត់ ចេញមកលំអុត លុតលាបិតា ។ ចរចុះសំដៅ ចំពោះមុខទៅ ដើរដោយមាគ៌ា ខំស្រូតដើរដល់ ឃើញយល់ផ្លូវថ្លា សងខាងមានផ្កា ផ្សែផ្សងរៀងរាយ ។ កុមារីប្រាណ ខំដើរពុំហ៊ាន មើលផ្កាទាំងឡាយ

ខ្លាចពាក្យបិតា ប្តេជ្ញាពីនាយ ដើរដល់ថ្នាយ ជាន់ក្រោមឫស្សី ។ នាយទ្វារមើលយល់ កុមារីវិមល រូបកាងស្រៀវស្រស់ មានពាក្យមេត្រី ស្រដីស្នូត្រស្មោះ ថានាងស្រីស្រស់ នាងមកពីណា ។ កុមារីតបប្រាប់ ថាយើងប្រញាប់ ចូលគាល់ជីតា បរមក្សត្រ មហាសិទ្ធិយា ចូរអ្នក មេត្តា បើកយើងប្រញាប់ ។ នាយទ្វារបើកបាន ដើរដល់ទីឋាន ជាន់គន្លឹបន្ទាប់ កុមារីនិយាយ ថែងតាមរៀបរាប់ ចរចាប្រាយប្រាប់ អ្នកទាត់ទ្វារក្រៅ ។ អ្នកចាំទ្វារលើង សាសួរដណ្ដឹង រៀង ៗ ដល់ទៅ ដកបគ្រប់គ្រាន់ ប្រាំជាន់ទ្វារក្រៅ ចំដើរទៀតទៅ បានដល់កំផែង ។ កំផែងគន្លឹបឫស្សី ខ្លាងទ្វារស្រួចស្រស់ ចំខ្ពស់ចំពែង ចរ៉ាចផ្សូរផ្សេង មណ្ឌបខ្ចាត់ខ្ចែង មើលសូប់មើលសែង ត្រឹះត្រឹតសិរសា ។ ឯពួក ទាហាន ចាំទ្វារសោតភាន យល់កុមារីកា រូបកាងល្អល្អះ គ្រចះកំព្រា សំឡក់សួរថា ហៃនាងក្រមុំ ។ នាំគ្នាទៅណា មកអាយសុំស្វា និយាយសុខុម កុមារីតបឆ្លើយ អ្នកអើយអ្នកកុំ ស្ដីលេងនឹងខ្ញុំ ក្រែងខុសសេចក្តី ។ ខ្ញុំមិនស្រីផ្តាស ខ្ញុំមិនកូនក្សត្រ ដូចអស់ទាំងស្រី ខ្ញុំជាអនុជ ព្រះមហាមហេសី អ្នកកុំស្រដី ក្រែងមានទោសធ្ងន់ ។ នាយ ទ្វារបានស្ដាប់ កុមារីតបប្រាប់ ភិតភ័យពេកពន់ ទើបឆ្លើយដោះសា ជាអ្នក កុំអន់ យើងបានជាសុន ចំអន់លេងផង ។ សូមឱ្យអ្នកថ្លៃ មេត្តា

អភ័យ អត់ទោសយើងម្ដង បានជាខាតខុស លើសលស់ធ្គាំធ្គង ប្រណីយើងផង កុំទូលក្សត្រ ៗ កុមារឆ្លើយថា យើងអត់ទោសា អាសូរ ប្រណី ប៉ុន្តែអ្នកចូរ ទៅទូលក្សត្រី សម្ដេចមហេសី ឲ្យជ្រាបប្រការ ៗ ថាយើងពីរពង្ស អនុជព្រះអង្គ មានចិត្តស្នេហា រលឹកព្រះបង ប៉ុន ប៉ងប្រាថ្នា ឡើងគាល់ធីតា ឥឡូវនេះថ្កាត់ ៗ នាយទ្វារទទួល ពាក្យ ពេចន៍ស្រាកស្រួល រួតរត់ឆាប់ក្តាត់ ប្រាប់ពួកក្រុមមៀង ឲ្យឡើងប្រណិ-បត័ន៍ ទូលក្សត្រីរត្ន័ ជ្រាបគ្រប់ប្រការ ៗ សម្ដេចចក្រី ត្រាស់ប្រើទាសី ថាហង្សម្នា ចេញទៅឲ្យឆាប់ ប្រញាប់លីលា ទទួលអនុជា នាំ ឡើងមកឋ្កាន ៗ ទាសីបានស្តាប់ ទទួលបង្គាប់ លុតលាតាកហាន ដើរ ដល់ធីតា បរបាស្មោះស្មាន ថាដៀកទ្រង់មាន ព្រះកជសវនីយ ៗ ប្រើ យើងមកហៅ អញ្ជើញអ្នកទៅ ឥឡូវនេះខ្ញី កុមារស្រាកស្រួល ទទួលមេត្រី ទៅនឹងទាសី ដើរដល់ដំណាក់ ៗ ឡើងគាល់ក្សត្រី ឯព្រះ មហេសី ផ្ទៀងផែព្រះភក្ត្រ សួរកុមារិកា ស្នេហាស្មោះស្ម័គ្រ កុមារី ពីរនាក់ លើកករបង្គំ ៗ បង្ហសណ្ឋារ សំពោះសំណាល សេចក្តីសួរសម ឯព្រះមហេសី ក្សត្រីភិរម្យ សាកសួរដោយដំ-ណើរនៃកុមារ ៗ ហៃ ប្អូនពីសី នាងមករកខ្ញី ចូរថែងចរចា កុមារពីរស្ដាប់ សាសព្ទឆ្លើយ ថា យើងខ្ញុំទូលហារ រលឹកព្រះអង្គ ៗ តាំងតែពីឃ្លាត ឆ្ងាយនឹងព្រះបាទ

ព្រះបងយូរលង់ យើងខ្ញុំតែងទឹក រលឹកព្រះអង្គ នាំគ្នាត្រាប់ត្រង់ មក
សួរបាទម្តង ៗ ពុំមានក៏សូម ឲ្យជាដំរី មកថ្វាយអ្នកបង កុមារទេវ
ហារ ចរចាស្នេហ៍ស្នង ធ្វើហាក់ចិត្តបង ចាំចាប់ស្នេហា ៗ រួចទូលពី
ទុក្ខ ជាអ្នកកាពុក គាត់មានវេទនា ដម្បីជាជូន ទុរទុក ដួលដាប
ទំព្រា ទីងក្រោកពុំបាន ៗ អត់បាយអត់ទឹក សង្វៃសង្វឹក សង្វឹងអង្គ
ប្រាណ កម្លាំងតិចតាប ដួលដាបពុំក្សាន្ត ប្រើយើងមកថ្កាន អញ្ចើញ
ស្តេចទៅ ៗ គាត់ទឹកផឹកអាក់ ចង់បល់ព្រះភក្ត្រ ព្រះរៀមចមទៅ
ក្រែងគាត់ពុំរស់ ជាមនុស្សគង់ទៅ អញ្ចើញស្តេចនៅ ប្រញាប់កុំខាន ៗ
ក្សត្រីវលក្ខណ៍ បានដឹងជ្រាបជាក់ កើតទុក្ខពុំក្សាន្ត សញ្ជប់សញ្ជឹង
រំពឹងក្នុងប្រាណ ថាឪមាន គុណគាប់កូនអើយ ៗ អ្នកឈឺដូចម្តេច
ធ្ងន់ស្រាលខ្លាំងតិច ទុក្ខកូនពុំស្បើយ ក្សត្រីផ្ចាញឹង រំពឹងម្នោះហើយ ត្រាស់
ថាប្អូនអើយ រង់ចាំរិះគិត ៗ ស្រេចទើបក្សត្រី ប្រើពួកសាវស្រី ទៅហៅស្នំ
ស្និទ្ធ អករយាយតាស់ទុំ មកជុំជួបជិត ទើបក្សត្រីត្រាស់ បន្ទូលត្រាស់ថា ៗ អ្នក
ម៉ែទាំងឡាយ ខ្ញុំពុំសប្បាយ ចិត្តដូរតបិតា គាត់ឈឺថ្កាត់ជូន ទុរនមហា-
មា ដួលដាបទំព្រា ទីងក្រោកពុំបាន ៗ អត់ទាំងអាហារ ស្គាំង
ស្គមកាយា ពុំដឹងខ្លួនប្រាណ តិចតាបកម្លាំង ក៏នូទាំងវិញ្ញាណ ក្តីក
កាំងក្តួចប្រាណ បីដងមួយថ្ងៃ ៗ មួយព្រះបពិត្រ កណ្តាមហាមិត្រ

បរមក្សត្រថ្ងៃ ស្តេចចេញប្រពាត រុក្ខជាតិព្រឹក្សព្រៃ ពុំបានវិលវៃ វិល
វិលមកឋាន ៗ ក្តីនេះក្រតិត ខ្ញុំថប់ពេកពិត ក្នុងចិត្តពុំក្សាន្ត អ្នកម៉ែជួយ
គិត ពិនិត្យគ្រប់ប្រាណ ធ្វើម្តេចទើបបាន ទៅសួរបិតា ៗ អក់យាយ
តាស់ខ្ញុំ គិតហើយបង្គំ ទូលទៅវិញថា ស្តេចកុំបារម្ភ យើងខ្ញុំគ្រប់គ្នា
ជផ្ទៃធីតា អញ្ជើញស្តេចឋាន ៗ ទៅសួរបិតា ទោះទោសទុក្ខា យើង
ខ្ញុំពលប្រាណ កុំបីព្រះអង្គ ការងំរទាន ម្តេចៗយើងហ៊ាន ណានា
តាំងគ្រប់ ៗ ទោះព្រះចក្រី ភស្តាស្វាមី ក្រេវក្រោធស្អួស្អប់
ខ្ញាល់គុំគួន យើងខ្ញុំលាក់លុប តាមតែស្តេចសព្វ ព្រះទ័យយាត្រា ៗ
ក្សត្រីទ្រង់លាក់ ទ្រង់ស្តាប់ជឿងជាក់ ចូរក្នុងទុក ទើបមានសវនីយ
ត្រាស់ទើងអនុជា ថាប្អូនទេហារ នាងទៅជាមុន ៗ ព្រឹកសឹមបងទៅ
ឲ្យដល់លំនៅ បិតាមានគុណ កុំព្រួយចិត្តណា រិះគិតពេកពន់ ហើយ
នាងប្អូនគន់ ជម្រាបផុង ៗ សម្តេចមហេសី បរមក្សត្រី នាងស្ងួត
កន្ទង តុំដឹងប្រាជ្ញា មាយាគេល្បង បញ្ឆោតលោមបង ឲ្យ
ក្ស័យជន្មា ៗ កុមារីតាំងពីរ ក្រញ្ញូក្រាបទូនសេរ -បង្គំលុតលា ចរចុះ
ដើរដល់ មណ្ឌលគ្រឹហា ប្រាយប្រាប់បិតា មាតាសព្វគ្រប់ ៗ កុដុ-
ម្ពិកកាលី បានស្តាប់កូនស្រី និយាយសព្វគ្រប់ ក្រេកអរក្នុងកាយ
រសាយធូរថប់ ទើបរៀបធ្វើម្ហូប ឯក្រៅរបង ៗ ទុកឲ្យបរិវារ ដែល

ហៃព្រះមហា មហេសីជាច្បង មិនទៀចូលទៅ លំនៅឡើយហោង

ក្រងដឹងទំនង ដំណើរពុតពាល ៗ រិះរករៀបផ្ទះ ពោសប្រាសជំរះ

ស្មៅព្រៃទ្បពល ហើយយកក្តារច្នៃ ធ្វើយន្តកណ្តាល ផ្ទះទុកដូច

កល និងខមុនស្រាប់ ៗ ទើបយកកំពល ថ្មីៗថ្នាល មក

រៀបផ្គុំផ្គាប់ ក្រាលលើក្តារយន្ត ក្តារច្នៃទុកស្រាប់ រួចរៀបប្រដាប់ ឯ

ក្រោមគ្រឹហា ៗ យកប្រេងដងតាក់ ពេញខ្ទះលើកដាក់ លើតុម្មា

យកភ្លើងបង្កាត់ នេះក្តាត់មហិមា ប្រេងត្រូវក្តៅ ពុះពោរពេញពេក

រួចហើយកាលី ធ្វើថ្នាំឡប្តី បញ្ចុះអនេក ឲ្យធំកហូរគុណ ចុះស៊ុន

ខ្ទង់ភ្នែក ពិសថ្នាំខ្ទាំងពេក ទំពុំប្រកាំ ៗ ដល់ដេរទ្វារ សំពត់

ហើយថ្វរ ទុរនំអប្រិយ ប្រដូចហាក់ឈឺ ជម្ងឺលោកិយ ភ្នែកសដូចត្រី

ឈើកទឹកស្ទុខសាប ៗ ស្ងួតដៃស្ងួតជើង សម្បុរស្មាំងលឿង ស្គាំងស្គម

ហួតខ្វាត ថ្ពាល់ទាំងមុខមាត់ សាក្រក់ដូចជាតិ ហេតុចិត្តប្រមាទ ព្រះ

មហាមហេសី ៗ

## បទព្រហ្មគីតិ

ន័យនេះល្មមស្ទះទូរ និទាននេះភាពីស្ត្រី ព្រះមហាអគ្គមហេសី

នាមនាងមាណមាត ៗ លុះលង់ទំហព្រាន ភ្ញាស្រេចស្រាងព្រះ

ស្ពុំយា នាងតើនចាកគ្រឡា បន្ទូរទំនាស្បី ៗ ស្រប់ក្រដ្ឋាសោយ

ព្រះស្ងួន ស្រង់សុគន្ធវារី ស្រេចទ្រង់គ្រឿងមណី- រត្នលេចសុ-
វណ្ណ ៗ ហើយសោយឲជារស ទើបស្រេចស្រស់កជធីតា ឡើងគង់
គ្រែរចនា នាយព្រះក្លស់បើកបាំងលៀ ៗ គ្រែសន្ធ័ដួរ្យដទ្រី ក្មេង
មហោរីវែកប្រគំ ខុនណាងអក់យោយជុំ មុខមន្ត្រីហែគ្រៀបត្រា ៗ ក្រុម
រាំងពួកតំរួត ហែត្រាត្រួតមុខធីតា ស្រីស្នំក្រុមបរិវារ អមចីនាំងកែវជុំជិត ៗ
ព្រះពានព្រះសិទ្ធរស ពានព្រះពស្ត្រដ៏វិចិត្រ ដាំត្បូងសព្វប្បពិត្រ ពានព្រះ
ស្រីព្រះគន្ធិជ្ជា ៗ មន្ត្រីធំតូចព្រម ដើរហែហមក្រោយធីតា ឆ្វេងស្តាំសឹង
សេនា ពួកពាហានច្រើនក្រាស់ក្រៃ ៗ ចេញចាកប្រាំងសុវណ្ណ តាមមា-
គ៌ាសំដៅនៃ កាសិកដ្ឋពិជ័យ លុះបានដល់ដូចប្រាថ្នា ៗ រីឯក្នុងស្រុក
នោះ ដឹងចំពោះថាព្រះមហា មហេសីស្ដេចយាត្រា បានមកដល់ស្រុក
ដូច្នោះ ៗ ទាំងចាស់ទាំងក្មេងក្ដី ទាំងប្រុសស្រីច្រើនច្រូងច្រុះ នាំគ្នាបរ
ចូលចុះ ចូលមកមើលរាជធីតា ៗ ខ្លោខ្លូលមើលជុំជិត ច្រើនប្រកិត
ប្រកៀកគ្នា ឯពួកគម្រួតរាំ ស្រែកឲ្យក្រាបមុខដល់ដី ៗ រាស្ត្រខ្លះហ៊ាន
ជម្រាប សូមលោកជ្រាបប្រោសប្រណី យើងចង់មើលក្សត្រី ឲ្យឃើញ
ម្តងសូមមេត្តា ៗ ក្រុមរាំងឆ្លើយថាអើ បើនឹងមើលតាមមាត្រា បើស្រី
នោះមិនថា ចូលមកចុះមកជិតអញ ៗ ឯប្រុសពាលគម្លោះ ទៅឯ
ណោះឲ្យឆ្ងាយចេញ កុំចូលមកជិតអញ ឲ្យចាប់វាយបង់តំនិត ៗ មិន

ដឹងប្ដូរក្សត្រី អគ្គមហេសីព្រះបពិត្រ ព្រះចៅក្រុងទ្រង់ប្ដូរ ម្ចាស់ជីវិតលើគ្រប់
គ្នា ៗ ខ្ញុំអ្នកទីនិចាហាន ចូលបេលណានមើលខ្ញុំឃ្លា មិនខ្លាចកជសម្ភារ
ចៀសឲ្យធាប់ឲ្យឆ្ងាយទៅ ៗ មកមើលច្រើនម្ដងម្ដេះ ចៀសអាផេះចោរ
កំឡៅ ប្រុស ៗ ចៀសចេញទៅ ឲ្យស្រីចូលមកវិញណា ៗ អស់ពស្ត្រ
ចាស់ក្មេងក្ដី ពួកស្រី ៗ ចូលគៀបគ្រា ចាស់ខ្លះសំពះថា ជម្រាបសួរ
នាងជាទេ ? ៗ គេសើចលាន់ទ្រហឹង ម្ទោះឈរស្ដឹងរឹងខ្លាសគេ ខ្លះកេះ
គ្នាហើយជេរ ថាចាស់ព្រើលហ៊ានស្ដីផ្ដាសៗ នាងមានព្រះសវនីយ ចាស់
ស្រី ៗ សើងធ្វើយចាះ គេសើចឯងអៀនខ្លាស កេះគ្របកក្លែកម៉ក់ ៗ ៗ
ហេតុស្រុកស្រែសាកគ្រោក មិនដឹងពាក្យល្អអាក្រក់ ខ្លះស្ដីខ្លះសំឡក់
បន្ទោសគ្នាឯងវីវរ ៗ ខ្លះមើលក្មេចវិញ្ញាណ ភ្ញាំងក្លែកប្រាណក្រេសក្រាក
ឈរ សរសើរថាយើល្អ ល្អភាំងនេះល្អទាំងព្រម ៗ កាលនាងនូវផាកស្ត្រ
គ្នាខគ្រឿងមាសហាក់ផាល្ចម ហើយផោយខ្លួនក៏ស្ដម មេកាលីប្រើ
ខៀយណាស់ ៗ ឥឡូវបានអភិសេក ល្អចំក្សែកសាច់សង្រះ មុខមាត់
ថ្មាត្រចះ ដូចខែរះពេញបូណ៌មី ៗ ខ្លះថាយ៉េមើលក្មួច មើលដូចម្ដេច
មិនគេគ្មី មកថ្វាយមហាក្សត្រី សូមឲ្យម្ចាស់ឲ្យទីសុខ ៗ កុំឲ្យអស់គាថា
ស្ដីពផការពេធ្វើទុក្ខ ខ្លះបានចែកអំបុក ទៀបទទឹមគ្មោតជូនខ្ញី ៗ មក
ថ្វាយច្រើនតាប់តាន់ ពប់យោភាទ់ទាំងប្រុសស្រី សម្ដេចមហាក្សត្រី

ស្តេចប្រមានអស់សេនា ៗ នាហ្មឺនទាំងធំតូច ចែកគ្នារួបបរិភោគ្គ អករ៍
យាយស្នំស្នេហា សឹងភោគ្គាផ្អែតស្កប់ស្កល់ ៗ យាត្រាតិចទៀតទៅ
ពស្រ្តស្រុកក្រៅមើលចល់ សឹងថ្វាយភ័ស្តុការផល ច្រើនអនេកតាម
មាតិ ៗ ស្តេចយាងជិតដល់ទី ផ្ទះកុដុម្ពិកនាងជាយា បញ្ឈប់យានយោធា
នឹងនៅក្រៅរបងនោះ ៗ រីឯមេកាលី យល់ក្សត្រដល់ដូច្នោះ ក្រោកដើរ
ឈានចេញចុះ ពីផ្ទះទៅទទួលនាង ៗ ដល់ទីក្រៅរបង ដើរញ៉ឹងញ៉ឹង
មើលរូបកង ដល់ហើយស្រដីក្លាង ថាអ្នកមាសម្តាយកូនណា ៗ
ស្តេចមកដល់ហើយនៃ អ្នកមាសថ្ងៃតែតុំហ៊ា ម្តាយនឹករលឹកជា និត្ត៍
មិនដែលដាច់ ៗ សព្វថ្ងៃទេះល្ងាចព្រឹក គិតញឹក ៗ ម្តាយមិនភ្លេច
ស្មើថ្លើមស្មើស្ងួតសាច់ ស្ងួនសម្លាញ់តែកល្យាណ ៗ ឥឡូវបិតាអ្នក
មានផ្ទុះឈើគង់ប្រាណ ខ្ញាំងស៊ិនពន់ប្រមាណ ដល់ផ្លូវដេកតាម
មហិមា ៗ អញ្ជើញអ្នកចូលក្នុង តែព្រះអង្គឯកអង្គ កុំឲ្យអស់-
មនុស្សម្នា ចូលទៅក្នុងរបងឡើយ ៗ ថាហើយនាំក្សត្រ យាងដោយ
ដីដើរដល់ហើយ ឡើងផ្ទះពុំយូរឡើយ ទើបកាលីស្តីទៅថា ៗ
អ្នកមាសមកពីឆ្ងាយ ក្រែងក្រហាយក្តៅកាយា អញ្ជើញស្រង់គង្គា
រួបសើមស្ងួតបិតាចុះ ៗ សម្តេចមហាក្សត្រ ស្តាប់កាលីទូលដូច្នោះ នាង
ជឿពាក្យគេស្មោះ ស្មានពាក្យពេចន៍ឥតសង្កា ៗ នាងផ្លាស់គ្រឿង

ប្រដាប់ ទិព្វសម្រាប់ពីកាយា ស្រេចនាងយានយាត្រា ជាន់លើក្តារ
នោះក្តុតទៅ ៗ គន្ធិះយន្តនោះភ្លាត់ ហាក់គ្រវាត់ធ្លាក់ស្ទុងស្មៅ
សិរយុនព្រះកេសទៅ កងខ្នះប្រេងក្តៅពោរពុះ ៗ នាងកិតបាតវិញ្ញាណ
ពុំដឹងប្រាណកាលគ្រានោះ ធ្លាក់ដល់ប្រេងក្តៅពុះ ភ្ញាក់ដឹងប្រាណក្តៅ
ខ្លោចផ្សា ៗ នាងប្រឹងប្រែបម្រះ តើតក្តៅណាស់អន្ទះសា ល្វើយថ្លើម
ទីយា រំពេចផាច់ខ្យល់ស្លាប់ទៅ ៗ អនិច្ចាមហាក្សត្រី ព្រះមហេសី
ត្រូវប្រេង ក្តៅ នាងវេលំបាកនៅ កងខ្នះប្រេងឥតគណនា ៗ រីមេ-
កាលិណីយៈ កាលីវាបាននាំគ្នា យកគ្រឿងវេជាយា ដែលនាងដោះទុក
នោះខ្ចី ៗ ស្អាងកូនស្រីវានោះ ឯនាមឈ្មោះចន្ទណី រូបពងសុទ្ធក្សត្រី
តែនលើក្ខណ៍ខុសពីគ្នា ៗ ទំហំទូវកំពស់ សាច់សស្រស់សមុខជ្រះថ្លា
ដូចមណ្ឌមាតា មិនឃ្លៀងឃ្លាតដល់ប៉ុនល្អង ៗ ស្អាងរួបយូរបានតិច
ទើបនាំត្រាច់ដើរញ៉ែងញ៉ង ជូនដល់ក្រៅវេង បានជួបជុំមន្ត្រីគ្រា ៗ
ខុនណានអក់យាយជុំ ស្រីព្រះសុំក្រុមបរិវារ បានយល់អគ្គធិតា យាង
មកហើយរៀបរាប់ ៗ ហេតុកម្មក្សត្រី ស្អាងអំពីមុនមកផ្តល់ បំបាំង
ក្នុកវេហ៍ពល នូវអក់យាយស្រីស្រីង្គារ ៗ មិនដឹងជាកាលី ស្អាងកូនស្រី
គាងធិតា គង់អន្តរវង្សក្រ្កា មិនមានឃ្លាតឥតសង្ស័យ ៗ អញ្ចេញម្ចាស់
ឡើងគង់ យានវេមង្គលមានដម្លៃ ដំរីច្ចូលក្រុងត្រៃ ហេតុពុំបានដា

ពិនិត្យ ៗ រីឯកជព្រឹក្សា ពីនោះណាកើតនិមិត្ត សន្ទឹកស្រពោនស្អិត ជ្រុះរង្គោះអស់សោះឆេង ៗ សម្បកដើមក្រៀមក្រស់ រែកបាក់អស់ជ្រុះរលីង រែកបាក់ធ្លាក់គគ្រេង នៅតែដើមតាំងទ្រហោរ ៗ រីឯនាយច្បារនោះ ឃើញឈើជ្រុះស្លឹកសោះសា ក៏យកគិតស្លុតតក្កមា ប្រើពួកពលឲ្យរត់ទៅ ៗ ដងទឹកមកស្រោចស្រប់ រៃងរម្ងាប់បាក់មិននៅ ទើបនាយច្បាររត់ទៅ ប្ដឹងនាហ្មឺនធំឱកាស ៗ សូមប្ដឹងព្រះបាទម្ចាស់ បានជ្រាបច្បាស់ដ្បិតឈើមាស តាំងពីក្ស័យវិនាស គិតធ្វើម្ដេចសូមមេត្តា ៗ ឯអស់សេនាស្ដាប់ នាយច្បារប្រាប់គិតតក្កមា ប្រើស្មៀនត្រមភ្នាក់ងារ រៀបក៏ស្ដការទៅបន់ស្រន់ ៗ មិនមានហៅអន់ជ្រុះ រៃងតែរុះគស់តោកពន់ រឹងក៏យកើតទុក្ខជូន ប្រើឲ្យពួកពលបាំងម្ចប់ ៗ ពីព្រឹកល្មុះថ្ងៃត្រង់ មិនបង្អង់មិនឈរឈប់ ពីថ្ងៃល្មុះដល់យប់ សឹងគិតភ័យតែកល់ក្ដា ៗ ខ្វះថាទុះយើងអើយ កាលណាស្បើយពីភយា បើស្ដេចដល់កាលណា ឃើញស្លាប់ហាលញាតិដៅផង ៗ ខ្វះកើតទុក្ខខ្ញាយំថៃថប់ធំមុខសៅហ្មង តាំងនាយតាំងពលផង តែងជាទុក្ខទំនួញសោក ៗ ពាមបាយតាំងទឹកក្ដែក មិនហ៊ានដេកអង្គុយកោក ខ្វះបន់ថាឱលោកអស់អ្នកតានៅស្រុកអាយ ៗ សូមជួយអស់យើងខ្ញុំ រួចទុក្ខធំធូរកងកាយ យើងខ្ញុំថ្វាយក្បាលបាយ មួយគុជំនឹងផ្អកម៉ាំ ៗ ខ្វះអុចទៀនធូបបន់

លែងប្រពន្ធបួសមួយឆ្នាំ ខ្ទះបន់ថ្វាយរបាំ ថ្វាយក្ងួនក្ងាត់តាមតែថា ៗ
កាលក្រោយមហាក្សត្រី អគ្គមហេសីក្ស័យជន្មា កន្ទងបីទិវា ទើបព្រះ
មហាក្សត្រមកដល់ ៗ ចូលក្នុងព្រះកជកាំង ព្រះនេត្រទាំងពីរនិមល
រមិលមើលពោយល់ ឈើមាសមិញក្ស័យដូច្នោះ ៗ ស្តេចមានព្រះ
ទុក្ខារ សួរនាយបា្យត្រាស់ថាចុះ ចៅអើយថ្វីឈើនោះ ហេតុដូចម្តេច
គឺក្ស័ណក្ស័យ ៗ នាយបា្យថ្វាយបង្គំ ក្រាបប្រណម្យទូលក្សត្រថ្វៃ
ពុំះបក្សត្រជៀស្តជ័យ សូមទ្រង់ប្រោសទ្រង់មេត្តា ៗ កាលថ្ងៃព្រះ
មហេសី មហាក្សត្រថ្ងៃស្តេចយាត្រា ចេញទៅស្ងួបិតា ឈើនោះ
ក្ស័យពីថ្ងៃនោះ ៗ ស្តេចស្តាប់ពាក្យនាយបា្យ ទូលប្រការដើមដូច្នោះ
បានទ្រង់ជ្រាបសព្វស្រុះ ព្រះទ័យនឹកដល់មហេសី ៗ ទុមរណមាតា
ជួនក្រ្តាស្រស់ប្រិមប្រិយ នឹងមានហេតុប្អូនស្រី បើមិនមានមិនបេះថា ៗ
ទ្រង់ព្រះចិន្តាស្រេច ទើបសម្តេចព្រះចក្រា យាងឡើងប្រាង្គសុវណ្ណា
ចូលក្រឡាគំនាល់ក្នុង ៗ អស់យាយស្រីស្រីគ្គារ ស្នំស្នេហាគាល់រហង់
ខានតែគ្រូព្រះអង្គ អគ្គមហេសីពុំឃើញគាល់ ៗ ស្តេចទ្រង់ព្រះចិន្តា
សែនសង្កាគិតពិតល់ ព្រះនេត្រទតរៀងពល់ ពុំយល់ឡើយត្រាស់សួរ
ថា ៗ ហៃអស់ហាងទាំងឡាយ មានអន្តរាយដល់អាត្មា នៃមរណមាតា
ឬមានពេគជម៉ឺ ៗ អស់ស្នំស្និទ្ធទូលថា អង្គព្រះមហាព្រះមហេសី ឥត

ពេកបៀតក្សត្រី ព្រះអង្គគង់សុខសប្បាយ ៗ ស្តេចស្តាប់រងើរងើចូល សែន
កន្ទុល់កង់ព្រះកាយ ព្រះទ័យពុំសប្បាយ ទ្រង់សន្និដ្ឋានសណ្ឋិតនៅ ៗ

## បឋកាកគតិ

លង់លុះសុរិយេ សុរិយាទន់ទេរ ទន្ទាបតិចទៅ ព្រលប់ងងឹត ចាំងចិតខែព្រៃជ្រៅ ចន្ទូណីនៅ រៀបស្ពានអាត្មា ៗ ស្រេចហើយឡើងទៅ គង់គាល់ព្រះពៅ ព្រះចមបក្រា ៗ ស្តេចទតទៅយល់ កិច្ចកលកិរិយា ហ្វ្រូកទឹងនេត្រា ដណ្តឹងទៅខ្ញុំ ៗ ថាខែនាងទុំ ពាក់គ្រឿងគ្រោងប្រុះ នាងឯង ឈ្មោះអ្វី នាងស្តាប់ក្ដាំងក្ដាត់ កិតប្ដាត់ស្មារតី ជ្រួសមាត់ទូលខ្ញី ថាខ្ញុំព្រះអង្គ ៗ ឈ្មោះចន្ទូណី ស្តេចសួរទៀតខ្ញី ថាស្ដីឲ្យត្រង់ ប្រាប់អញឲ្យជាក់ នាងភ្ញាក់អស់អង្គ ដឹងខ្លួនទូលធ្ងន់ ដោយពាក្យមុសា ៗ វេះវេចភូតព្រាង ថាខ្ញុំឈ្មោះនាង មរណមាតា ស្តេចស្តាប់នាងទូល ទំនូលថែថា កើតទោមនស្សា ក្តាញ់ក្នុងព្រះទ័យ ៗ នាងគាល់បាតតិច បានដឹងជាស្ដេច ពុំកិស្សម័យ នាងខ្លាសស្រីស្នំ ព្រះក្រុមជាំខែ ក្រាបលាវិលវៃ លំនៅអាត្មា ៗ ក្រោយនាងចន្ទូណី សម្តេចចក្រី មានព្រះឱង្ការ ឲ្យហៅស្រីស្នំ ចាស់ទុំជុំគ្នា ស្តេចដណ្តឹងថា ហែនាងចាំងរួយ ៗ (នៅមានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## អំពីទំនៀមប្រណាំងទូកង

*នៅស្រុកបាសាក់ ខែត្រឃ្លាំង (កម្ពុជាក្រោម)*


និពន្ធដោយលោក ថាច់-ប៉ែន ហៅ ប៉ាង

នៅពុទ្ធសាសនបណ្ឌិត្យ ដែនកូសាំងស៊ីន


---

រឿងល្បែងទូកង គឺជាទំនៀមមួយសម្រាប់ប្រទេសជាតិ មានតាមកជាច្រើនសតវត្សរ៍ណាស់ហើយ ទើបមានជាទំនៀមទម្លាប់ក្នុងស្រុកបាសាក់មកដល់សព្វថ្ងៃនេះ ។

បើតាមផ្នែកនៃរឿងទូកងនោះ បានពិនិត្យតាមគោលដើម គឺមិនមែនជាទូកសម្រាប់ប្រណាំងនោះទេ គឺជាទូកជំនិះទ័ពស្រួចពួកទាហានជើងទឹកសម្រាប់ច្បាំងសឹកជារបស់ស្ដេចក្រាញ់ខ្មែរ នៅស្រុកបាសាក់អំពីបូរាណ ។

រឿងទាំងនេះ បានផ្ទៀងផ្ទាត់តាមទំនៀមទម្លាប់ខ្លះ ហើយស្រង់យកតាមសេចក្ដី ដែលមានទាក់ទងក្នុងរឿងទូកង ដែលមានក្នុងសៀវភៅ ប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ ដែនកម្ពុជាក្រោម ស្រុក

បាសាក់ ខេត្រឃ្លាំង (គួសាំងស៊ុខ) ត្រង់ទំព័រ ២៥ និង ៣២ មានទៅក្នុងពុទ្ធសាសនបណ្ឌិត្យរង ខេត្រឃ្លាំង ។ សៀវភៅប្រវត្តិសាស្ត្រនេះមានបញ្ជាក់ឲ្យច្បាស់ទៅខាងចុង ។

តាមសេចក្តីយល់របស់អ្នកតែង ត្រូវចែកវិភាគរឿងនេះជា ៣ ភាគ ដូចតទៅនេះ ៖

ភាគទី ១ រៀបរៀងតាមសាវតារខ្លះ តាមទំនៀមខ្លះ ;
ភាគទី ២ អំពីការផ្លាស់ប្តូរទីកន្លែង និងការកែប្រែឲ្យបានចំរើន ,
ភាគទី ៣ បញ្ជាក់អំពីល្បែង ជំនាង ជំនិះទូក និងកម្មវិធី ។

## ប្រារព្ធរឿង

ភាគទី១ មានសេចក្តីដំណាលក្នុងទំព័រ ២៥ នោះថា:

កាលពុទ្ធសករាជ ២០៧១ គ្រិស្តសករាជ ១៥២៨, គ្រានោះព្រះបាទអង្គចន្ទទី ១ ស្តេចតាំងបន្ទាយលង្វែកជាទីក្រុង ព្រះអង្គជាព្រះមហាក្សត្រប្រកបដោយព្រះរាជហឫទ័យសប្បុរស ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាយ៉ាងមាំមួន ។

ក្នុងសម័យនោះ នៅស្រុកបាសាក់ មានលោកចៅអធិកវង្សានាមទេព ធ្វើជាចៅហ្វាយស្រុក, លុះលោកអនិច្ចកម្មទៅ រឿងនេះ ក៏ទ្រង់ជ្រាបដល់ព្រះបាទអង្គចន្ទ ព្រះអង្គទ្រង់ព្រះរាជតាំងយសសក្តិដល់ព្រះ

រាជបម្រើជិតស្និទ្ធនឹងព្រះអង្គម្នាក់ឈ្មោះពញា តាត ងារជាស្និទ្ធភូបាល ហើយព្រះរាជទានឲ្យមានអំណាចដូចស្តេចត្រាញ់ក្នុងស្រុកបាសាក់ ។

## អំពីលោកស្និទ្ធភូបាល តាត

លោកស្និទ្ធភូបាល ទៅធ្វើជាស្តេចត្រាញ់ នៅស្រុកបាសាក់នោះ លោកចាត់ការរៀបចំស្រុកឲ្យមានមណ្ឌលមួយនៅចំកណ្តាល ហើយនឹងខេត្ត ៤ នៅទិសទាំង ៤ ។ ឯមណ្ឌលកណ្តាលនោះ គេហៅថា ពស្ត្រ ក្នុងរបងសំរាប់បំរើស្តេចត្រាញ់ ហើយតាំងឲ្យមានមន្ត្រីគ្រប់ខេត្ត ៤ នោះ គឺ

ទី ១- មន្ត្រីសេនាបរទេស ត្រួតត្រាទិសខាងកើត តាមទន្លេបាសាក់ទៅដល់សមុទ្រ ;

ទី ២-មន្ត្រីអធិកសេនា ត្រួតត្រាទិសខាងត្បូង តាមសមុទ្របាក់លើ ក្រមួនស ;

ទី ៣- មន្ត្រីអញ្ញិកសេនា ត្រួតត្រាទិសខាងលិច តាមសមុទ្រក្រមួនស ដល់ខេត្តត្រពាំង ;

ទី ៤ -មន្ត្រីសេនាសង្គ្រាម ត្រួតត្រាទិសខាងជើង តាមទន្លេបាសាក់ ដល់មាត់ជ្រូក ។

## អំពីច្បាប់សម្រាប់ស្រុក

ក្នុងសម័យដែលរៀបមន្ត្រីឲ្យត្រួតត្រាទិសទាំង ៤ នោះ លោកសិទ្ធក្បាលចាត់ឲ្យរៀបក្បួនទ័ពចំបាំងជើងគោកនិងជើងទឹក ក្នុងខេត្រទាំង៤ ទិសនោះ ហើយបញ្ញត្តិឲ្យរៀបគ្រឿងសស្ត្រាវុធសម្រាប់ការពារ និងរាស្ត្រប្រជាគ្រប់ភូមិ ក៏ត្រូវមានប្រដាប់គ្រប់គ្នាទាំងអស់ គឺ ធ្នូ ស្នា ដាវ លំពែង ផ្គាក់ ខែល ។ល។

## អំពីទាហានជើងគោក

ទាហានជើងគោកនាជាសេនាតជ័យសង្គ្រាម មានសេនារងៗទៀត គឺ មេកងដប់ មេរយ មេពាន់ ។ ឯគ្រឿងស្លៀកពាក់ទាហាននោះ ត្រូវស្លៀកសំពត់ចងក្បិន ពាក់អាវកណាយ(១) ឯឡេវអាវ គេប៉ាក់ទឹងសំពត់លឿងឬក្រហម គេច្រើននិយមប្រើឡេវ ៩ ១១ឬ១២ ចំណែកឯគ្រឿងសំគាល់យសស័ក្តិរបស់ទាហាននោះ គេប៉ាក់សំពត់ក្រហមនៅកអាវ ឯនាយទាហានត្រូវមានឆ្នូតសំពត់ពណ៌ក្រហម ១ ជាន់ ២ ឬ ៣ ជាន់ តាមបុណ្យស័ក្តិរបស់នាយទាហាននោះៗ ។

## អំពីទាហានជើងទឹក

ទាហានជើងទឹក ក៏មានគ្រឿងសស្ត្រាវុធដូចគ្នានឹងទាហានជើងគោក

---

(១) អាវណាយមានក្នុងសម័យមុន សម័យនេះពុំមានប្រើទេ ។

ដែរ ប៉ុន្តែខុសគ្នាទីនស្លៀកពាក់ខោ ស្នាប់ភ្លៅ ពាក់អាវបំពង់ត្រឹមចង្កេះ ។ ពួកគាហានដើនទឹកនេះ ចែកជា៣ក្រុម គឺ

ក្រុមទី១ ហៅទ័ពស្រួច ហាត់ចំបាំងទីនទូកអុំ មានទំននដូចទូកងយើងសព្វថ្ងៃនេះ,

ក្រុមទី ២ ហៅទ័ពជំនួយ ហាត់ចំបាំងទីនទូកចែវពីរជួរ មានទំ. ននដូចទូកចែវប្រណាំងសព្វថ្ងៃនេះ;

ក្រុមទី ៣ ហៅទ័ពបាសាក់ គឺទូកធំមានដំបូលផង មានចែវផង មានក្ដោងផង (ពងទូកបាសាក់) បែបដូចទូកប៉ុកបាយ តែកងស្តួបវែង ដំបូលមួយកាត់ខាងមុខឥតជញ្ជាំង សម្រាប់ដាក់ដើនចែវ ៨ ឬ ១០ ។ ទូកនេះសម្រាប់ដាក់ស្បៀងអាហារ (នៅមានប្រើកងរហូត ៣០ ឬ ៤០ ឆ្នាំមុន ឥឡូវគេបោលកងនេះហើយ) ។

របៀបបង្ហាត់ចំបាំង ទីនរក្សាពលរដ្ឋ ស្រួចលើមន្ត្រីទាំង ៤ ទិស. ចំណែកខាងមន្ត្រីទាំង ៤ ទិស ត្រូវបើកនៅកន្លែងរបស់លោកសុទ្ធតែ-បាលគ្រប់ចំពូក ។ សម័យនោះ មានបញ្ញត្តច្បាប់សម្រាប់ស្រុកមួយបែប គឺ

១- កំណត់នៅថ្ងៃពេញបូណ៌មីខែអស្សុជដល់ចេញវស្សា ត្រូវអ្នកត្រីតាចារ្យ ទីនខាម៉ឺន ព្រះ ពញាគ្រប់ខែត្រទាំងអស់មកជួបជុំគ្នា

នៅមន្ទីរលោកស្និទ្ធគូបាល ហើយលោកក៏នាំអ្នកទាំងអស់នោះ ទៅកាន់ទីអាកម ដើម្បីធ្វើពានសីលតាមច្បាប់ព្រះពុទ្ធសាសនា ។

២– កំណត់ថ្ងៃពេញបូណ៌មី ខែកត្តិក រដូវអកអំបុកនោះមន្ត្រីទាំង ៤ ទិស កេណ្ឌពាហនជើងគោក ជើងទឹក ប្រជុំនៅមុខបន្ទាយស្ដេចត្រាញ់ ប្រឡងឫទ្ធិគ្នាមួយថ្ងៃ មួយយប់ ។

ចំណែកពាហនជើងទឹក ឲ្យល្បងឫទ្ធិ ឯទន្លេពាមកណ្ដាល ក្នុងខែត្រឃ្លាំង ផ្សិតកន្ទួងនោះ ជាទីប្រជុំផ្លូវទឹកគ្រប់ខែត្រ ទឹងទៅមកបានដោយងាយ ។

តាមលក្ខន្តិកសញ្ញានោះ ត្រូវ ១ ឆ្នាំប្រជុំពីរលើកល់តែឆ្នាំតទៅ ។

អំពីលោកស្និទ្ធគូបាល គាត់ ជាទីស្ដេចត្រាញ់នៅស្រុកបាសាក់នោះ ឃើញមានក្នុងសាវតារលោកអធិករង្សី អ្នូង ប្រាប់ថាលោកស្និទ្ធគូបាល បានចាត់ការថែរក្សាស្រុកទាំងប៉ុន្មាន ដូចរៀបរាប់មកខាងលើហើយ គឺលោកធ្វើតាមក្បួនច្បាប់របស់លោកក្រឡាពាសនាម មោះធ្វើជាស្ដេចត្រាញ់ក្នុងដែនបាសាក់ កាលរាជ្យព្រះមហាក្សត្រព្រះនាមព្រះបាទ បទុមសុរិយវង្ស មានឫទ្ធិចេស្ដាខ្លាំងណាស់ ។

សេចក្ដីត្រង់នេះ ខ្ញុំបានចម្លងមកពីសៀវភៅ ប្រវត្តិសាស្ត្រ ទំព័រ ៣២ ។

កាលលោកស្ដិទ្ធកូបាល តាត រៀបកិច្ចការរក្សាស្រុកយកតាមក្បួនលោកក្រឡាពាស នោះ ស្រុកមានសេចក្ដីក្សេមក្សាន្ត ពុំដែលមានចោរប្លន់សឹកសត្រូវអ៊ូអរចូលក្នុងប្រទេសម្ដងសោះ ឯការហាត់ច្បាំងសឹកសង្គ្រាមដោយក្បួនទូកនោះ លុះយូរៗទៅក៏ខាប់ជាទំនៀមប្រពៃណីទូកទៅវិញ ។

លោកស្ដិទ្ធកូបាល ដល់កំណត់ជរាហើយ ក៏ទទួលអនិច្ចកម្មទៅ លោកមានបុត្រប្រុសម្នាក់ ឈ្មោះចៅពញាឡុង ទទួលទីជាអធិករាជ្យ ។ លោកនេះក៏បានរៀបចំតាមច្បាប់អំពីដើមរៀងមក ពេលដែលលោកជរាទៅលោកមិនមានបុត្រាបុត្រីស្នងលោកតទៅទៀតឡើយ ។

សម័យនោះ ក្នុងរាជ្យព្រះជ័យជេដ្ឋា ទ្រង់គង់ក្នុងក្រុងឧដុង្គមានជ័យ ទ្រង់ជ្រាបថាស្រុកបាសាក់មិនមានទាម៉ឺន ព្រោះពញាទឹងត្រួតត្រាស្រុកតទៅទៀត ទើបទ្រង់ត្រាស់ប្រើម៉ឺនជ័យ ទីជាចៅពញាទេសរាជ្យ ឡើងទៅឈរនៅខែត្រដែនបាសាក់កាល ព.ស ២១៦៣ គ.ស ១៦២០ កាលចៅពញាទេសរាជ្យទៅត្រួតត្រា ស្រុកក៏បរិបូណ៌ដោយភោគសម្បត្តិ មហាជនទាំងឡាយសុខសប្បាយ ចំណែកឯច្បាប់សម្រាប់ស្រុក ក៏បណ្ដែតបណ្ដោយរឿរពេយបាត់អស់ទៅ នៅតែប្រឡងទូក ក៏ទៅជាល្បែងប្រពៃណីលេងទៅវិញ ។

សូមរៀបរាប់ពីចៅហ្វាយស្រុក ដែលលេនទូកតៗមកនោះ គឺ

១- ពញា តាត ទីជា ស្តុកបាល,

២- ពញា ឡុង " អធិករនិក,

៣- ម៉ឺន ជ័យ " ចៅពញាខេសរនិក,

៤- ពញា ពេជ្រ " អធិករនិក,

៥- ពញា មៅ " "

៦- ពញា តាត ទី ២ " "

៧- ម៉ឺន សួរ " "

៨- ចៅហ្វាយ ណឹម " "

៩- " សុខ " "

១០- " អួន " "

១១- " អួ " "

ក្នុងពង្សាវតារនេះដំណាលថា ចៅហ្វាយស្រុកទាំង ១១ រូបនេះ សុទ្ធតែបានទទួលយសសក្តិអំពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនៅក្រុងកម្ពុជាតៗ រៀងមក ៗ កាលលោកចៅហ្វាយស្រុក អួ ធ្វើជាចៅហ្វាយស្រុកក្នុងព-ស-២៤២៣គ-ស ១៨៨០ បានតែពីរឆ្នាំក៏ឈប់ធ្វើទៅ ៗ ចាប់ដើមតាំងពីឆ្នាំនោះមក មិនមាននាម៉ឺនអំពីស្រុកខ្មែរទៅត្រួតត្រាស្រុកនោះ

ទៀតឡើយ ។ ឯចំនៀមចំលាប់ផ្សេងៗនោះ ឃើញនៅតែល្បែងលេងទូកង មានលេងរៀងរាបមក មិនដែលអាក់ខានឡើយ ។

## អំពីអុកញ៉ា សឹង–ខៀប

លោកឡើងជាអុកញៀន ក្នុងព.ស២៤៣១ គ.ស.១៨៨៨ លោកបានរៀបក្បួនច្បាប់ចំនៀមទម្លាប់ខ្មែរជាច្រើន ឯល្បែងទូកងនោះ លោកជានាយកចេញបាត់ការរៀបលេង ឲ្យមានរបៀបរៀបរយល្អ ទូកងក្នុងខែត្រឃុំាង បាក់លាវ ក្រមួនស ក៏រឹងរឹតតែចំរើនច្រើនឡើងទៀត ។ ទូកងក្នុងប៉ុន្មានខែត្រនេះសុទ្ធតែល្អៗណាស់ដែរ ។ ឯស្រុកបាសាក់គេធ្វើបណ្ដោយប្រមាណ ១៨ដល់ ២១ ម៉ែត្រ ក្បាលកន្សែងឡើងជាងទូកស្រុកទាំងពួងខាងលើនេះ ហើយមានធ្វើក្បាច់ចេញផង មានចំណុះពី៤៥ ដល់៤៨នាក់ ។

របៀបលេង ១ឆ្នាំមានពីរដងគឺ ដង្ហែចេញវស្សាទីងអកអំបុក មកប្រជុំគ្នានៅទន្លេពាមកន្ទោ ក្នុងពេលពិធីលើកនៃការអុំទូកនេះ មានទូកមួយពួកឈប់នៅស្រុកអំពូយា មានស្ពានមួយវែង ទន្លេកំពូលាយ មានមាត់ទន្លេទាំងសងខាង ។ មានផ្លូវធំចេញ-ចូលស្រួល, អុំនៅទីនេះ១យប់ថ្ងៃគោរ ហើយក៏ចូលគ្នាទៅលេងនៅពាមកន្ទោ ។ មកដល់ព.ស. ២៤៤១ គ.ស១៩០៤ លោកឡើងស័ក្តិជាអុកញ៉ា ក៏បានមកធ្វើជាសេនា-

បតីនៅក្រុងភ្នំពេញទៅ ។ ក្រោយនោះលោកឡឹម ឯម ជាបុត្ររបស់ លោកសឺន-ឌៀប កាន់កាប់ទំនៀមទម្លាប់ខ្មែរតទៅទៀត ។

## អំពីលោកដុកភ្លូស ឡឹម ឯម

កាលព.ស.២៤៦៦ គ.ស ១៩២៣លោកឡៀងទីជាដុកភ្លូស បាន ធ្វើការតាមទំនៀមទម្លាប់រឿងមក ដល់ផ្លូវចេញវស្សា លោកអញ្ជើញ ទៅរៀបលេងទូក ឲ្យមានរបៀបរៀបរយល្អមើលហើយសប្បាយជាង បែបមុនដែលលេងអំពីមុនៗមកផង ពីព្រោះពេលយប់ មានអុជប្រទីប ហែផ្កាដោយក្បួនទូក ប្រគំភ្លេងលេងជាទីសប្បាយរីករាយគ្រប់គ្នា ។

## អំពីកិច្ចដែលប្រជុំគ្នា

នៅឱកាសលេងទូកក្នុងរដូវចេញវស្សា កាលព.ស ២៤៦៧ គ.ស.១៩២៤ មហាជនទាំងឡាយ មកប្រជុំគិតគ្នាថា "ឯទំនៀមលេង ទូកនេះ គឺមានមកអំពីដូនជីតាយើងរាល់ៗគ្នា ចំណែកមនុស្សដែល មកលេងឆ្នាំនេះ ប្រហែលជាង១ម៉ឺននាក់, ចំណែកឯទូកដែលចូល គឺង ខែវ អុំ ប្រហែលជាង១ពាន់ទូក ល្មមយើងរួមគ្នាសន្មតល្បែងនេះ ឲ្យបានស្រួលតាមបែបភាពការប្រទេសក្នុងសម័យនេះផង" ។ ក្នុងពេល សន្និបាតនោះ បានព្រមព្រៀងគ្នាថា៖

១-ផ្លូវៈចេញវស្សា មានប្រណាំងទូកហែផ្កាភ្លើងបណ្ដែតគក់ខ្ទោងលើ

ទឹក សន្មតថាធ្វើសក្ការបូជារំលឹកដល់ព្រះពុទ្ធបាទ ក្នុងគង្គាមហានទី ។

២-ផ្លូវអកអំបុករបៀបលេងដូចគ្នា សន្មតហៅថាបុណ្យសំពះព្រះខែ(១)

៣-ផ្លូវចេញវស្សា ត្រូវលេងនៅពាមកន្ទោ តាមទំនៀមចាស់ទុំរៀងមក ។

៤-ផ្លូវអកអំបុក ត្រូវទៅលេងឯព្រែកអំពូយោ មានអញ្ជើញនាម៉ឺនបារាំង ចិន យួន ទៅលេងផង ។

ដល់គ.ស. ១៩២៨ ក៏បោលទឹកខ្ទង់ពាមកន្ទោ ហើយឈប់អុំទូកផ្លូវចេញវស្សាហូតមកដល់សព្វថ្ងៃ នៅលេងតែផ្លូវអកអំបុក ។

## អំពីកន្លែងលេងទូកពីបុរាណ

ទីធ្លាប់ប្រណាំងទូកពីបុរាណរៀងមកនោះ ឈ្មោះពាមកន្ទោ នៅស្រុកកំពង់ដួង ឃុំថាមខ្លួន ខណ្ឌពញាឮ ខែត្រ[illegible] ។ ទីនេះមានពាមបែកជា៣, ពាម ១ ទៅភាបលាវ (ចៅលៀវ ឬ ព្រែកលីវ) ពាម ១ ទៅខែត្រក្រមួនស ១ ទៅខែត្រឃ្លាំង ។ ទទឹងពាមនោះប្រហែល៣រយម៉ែត្រមានបេតស្រៃល្អណាស់ ។ ទ្រនំខ្ទង់នោះជាទីហោស្ថាន មានតែព្រៃព្រឹក្សានិងសត្វផ្សេងៗ ។ បើដល់ផ្លូវលេងទូកនោះ គឺបរិបូណ៌ដោយមហាជនទាំងឡាយ ព្រមទាំងទំនិញលក់ដូរមានគ្រប់បែបគ្រប់យ៉ាង ក្នុងពេលនោះ

(១) ការសន្មតនេះមិនឃើញមានច្បាប់អ្វីទេ គឺកើតដោយគតិមហាជន ។

បើនឹងធៀបទៅ ប្រហែលដូចជាទីក្រុង១ បរិបូណ៌ដោយភោគសម្បត្តិ និងសេចក្តីក្សេមក្សាន្ត ។ ហេតុនោះ បានជាមហាជនទាំងឡាយបាក់ចិត្តជាប់គំនិតទៅលេងគ្រសាលជាកំសាន្តរៀងមក ។

## របៀបលេងទូកតាមវជ្ជិរ

សម័យក្រោយៗមក ការលេងទូកនេះ មិនចាំបាច់បបួល ឬសន្មតគ្នាឡើយ តែដល់រដូវធ្លាប់លេងហើយ គឺរៀបចំស្បៀងអាហារ ទូកក្តារ ប្រវាវែរតែរៀងរាល់ភូមិ រាល់ស្រុកទៅលេង បើអ្នកណាទៅដល់មុនក៏លេងមុន អ្នកដែលទៅដល់ក្រោយក៏លេងបណ្តោយតាមគ្នាទៅ ៗ គង់ពេលលេងឮស្នូរស្រែកហៅកញ្ជ្រៀវខ្ទៀវខ្ទា, គរគ្រោកគ្រោកបាចសាចទឹក ឮសន្ធឹកគឹកកងរំពងទាំងថ្ងៃយប់ ។ ពេលយប់មានអុជចង្កៀងគោម ប្រទីប ទៀន ធូប ដំរៀបគ្នាជាជួរហែផ្កាភ្លើងដោយក្បូនទូកបណ្តែតតាមទឹក អុជកាំជ្រួចរន្ទាក្លៀវក្លាទៀន ។ ចំណែកខាងភ្លេងដូរ្យតន្ត្រីសោតក៏ប្រគំ ស្នូរសព្ទទ្រហឹងអឺងកងរំពងខ្ទរប្រថពី ទាំងព្រះសង្ឃក៏សូត្រព្រះបរិត្តពុទ្ធមន្តតាមទូកហែផ្កាភ្លើងនោះ ។

ក្បូនដែលដង្ហែផ្កាភ្លើងទៅមកចំនួន ២-៣ លើកប៉ុណ្ណោះ ក៏ឈប់បង្អង់សិន នៅសល់តែការប្រណាំងទូកង រហូតដល់ពេលព្រឹកហើយ នាំគ្នាអង្គាសចង្ហាន់ដល់ព្រះសង្ឃជាការស្រេច ។ តមក គេសន្មតគ្នាថា

ដល់ពេលមកអំបុកកុងខែកត្តិកនេះ យើងត្រូវតែរៀបសង់ពេង ឬបាំ
នៅក្បែរវត្តអំពូយានោះ ដើម្បីទឹងធ្វើជាទីសម្រាប់ទទួលនាម៉ឺន បាំង
ចិន យួន មកទស្សនា ទឹងបង្ហាញល្បែងចាំងនេះដល់នានាជាតិផង,
លុះសន្ទត្កាស្រេចហើយ ក្នុងវេលាថ្ងៃត្រង់ ត្រូវទឹងទឹកជំនោរជោរ
ឡើងពីសមុទ្រមក, ពួកជនដែលនៅខែត្រឃ្លាំង ក៏បណ្តែតទូកតាមខ្សែ
ទឹកហូរទៅខែត្រនោះ ៗ

ឯបណ្តាជននៅខែត្រក្រមួនស ក៏ទៅតាមពាមព្រែកអំពូយានោះ
បណ្តោយតាមខ្សែទឹកជោរចូលទៅខែត្រនោះ ៗ ចំណែកខាងបណ្តាជន
ខែត្របាក់លីវ ត្រូវរង់ចាំទម្រាំថ្ងៃរសៀលទឹកនាចវិញ ទើបទៅតាម
ទឹកនោះបាន ៗ

## អំពីការផ្លាស់ប្តូរទីកន្លែង និងការកែប្រែឲ្យបានបំរើន

ព្រែកអំពូយា, នៅឃុំថាញ់គួ ទីរួមខែត្រឃ្លាំង ទីនោះជាផ្លូវធំ
មានចាក់កៅស៊ូល្អស្អាតណាស់ ចម្ងាយពីខែត្រឃ្លាំងជាង ១៧ គីឡូម៉ែត្រ
មានទំហំទទឹងព្រែកជាងមួយរយម៉ែត្រ មានស្ពានដែកមួយធំទទឹងថ្ង បើ
ឈរហើយមើលទៅខាងកើតខាងលិច ក៏ឃើញព្រែកនោះត្រង់ល្អណាស់
នៅត្រង់ក្បាលស្ពានខាងត្បូង មានផ្ទះផ្សារពីរជួរបណ្តោយតាមថ្នល់ ៗ
ឯថ្នល់នោះទៅកាន់ខែត្របាក់លីវ, តាមមាត់ព្រែកទៅខាងលិច មានផ្ទះ

ផ្សារជាផ្លូវបណ្ដោយតាមព្រែក មានវត្តព្រះសង្ឃខ្មែរមួយ នៅចុងផ្សារខាងលិច ក្នុងទីផ្សារមានសាលាឃុំមួយ និងសាលាខ័ណ្ឌមួយ ។

## អំពីការរៀបបំទឹកភ្លេងថ្មី

លុះជិតដល់វេរអកអំបុក លោកចៅហ្វាយខ័ណ្ឌ លោកចាត់ការរៀបចំឲ្យរាស្ត្រសង់រោងមួយចំនួន ៣ ល្វែង សម្រាប់ទទួលនាម៉ឺន, ក្នុងទីវត្ត ឲ្យរៀបសាលាមួយសម្រាប់ទទួលព្រះសង្ឃ ហើយលោកធ្វើសំបុត្រចុតហ្មាយកំណត់ពេលវេលា និងអញ្ជើញលោកចៅហ្វាយខេត្ត ព្រមទាំងនាម៉ឺនចិន-យួនផង ។

លុះដល់ថ្ងៃពេញបូណ៌មីខែកត្តិក វេរអកអំបុក បណ្ដាជនទាំង ៣ ខេត្តមកប្រមូលជួបជុំគ្នា អុំលេងកំសាន្តតាមធម្មតា ដល់ពេលម៉ោង ២ រសៀល រៀបរោងទទួលមន្ត្រីឯសាលាវត្ត, លុះពេលជិតម៉ោង ៤ ល្ងាច ផ្ទុកជាគូៗ សំឡេងព្រួសស្ទូរបាញ់កាំភ្លើងត្រើងធំជ័យនៅមុខចាកំ អុំមួយគូម្ដងៗយកឈ្នះចាញ់ ។ ដល់ពេលម៉ោង ៥ រសៀល លោកចៅហ្វាយខេត្តនិងនាម៉ឺនខ្មែរ-យួនអញ្ជើញទៅដល់ព្រមគ្នា, តមកកំបាញ់កាំភ្លើងត្រើងធំជាសញ្ញា, ពួកអ្នកអុំៗជាគូៗ យកឈ្នះចាញ់ដល់ចុងព្រ័ត្រ ទោះឈ្នះក្ដី ចាញ់ក្ដី ទូកទាំងពីរនេះត្រូវអុំទន្ទឹមគ្នា គេហៅថា ប្រាស់ប្រវា សាឡើងវិញ នោះមានអ្នកឈរកាន់គងវាយម្នាក់ ហើយ

មានអ្នកឈរច្រៀងបន្ទរ ជាពាក្យកាព្យឃ្លោងឆ្លើយឆ្លងគ្នា ចាក់ក្បាច់ឲ្យកញ្ជាក់មុខដាក់គ្នាទៅវិញទៅមក ឯអ្នកឈរមើលទាំងសងខាងផ្លូវថ្នល់នោះ អើតករហាង មើលទាំងស្ដាប់ចំរៀង ។ ឯមនុស្សចំណុះទូកងនោះ ចំនួន ៤៦ ឬ ៤៨ នាក់ ក៏ច្រាស់ច្រវ៉ាតិចៗ ហើយចាំទទួលពាក្យបន្ទរខាងចុងឃ្លាថា ហៃយ៉ឺៗ ហៃយ៉ឺៗ ។ បន្ទាប់ពីនេះគេក៏ចែកស្លាដល់អ្នកអុំទូក ។ ឯស្លាដែលឲ្យនោះ មានតែចំណីអាហារស្រាបាយ, ហើយត្រូវលៀងទំទឹកតែដល់ក្រុមមន្ត្រីទាំងឡាយ, តទៅទៀតមានអុជកាំជ្រួចកំទៀនហែផ្កាភ្លើងដោយក្បួនទូក ដូចកាលដង្ហែភ្លើងឯពាមកន្ទោងដែរ ។ ក្នុងអាពាធវិញ មានពួកឧបាសកឧបាសិកា នមស្ការសមាធាន តាមរបៀបបែបផែនប្រពៃណីតមក, រួចក៏ឲ្យស្លាដល់ម្ចាស់ទូកដែលហែផ្កាភ្លើងនោះទៀត ។ រីឯស្លាសម្រាប់ឲ្យនោះ គឺពួកចិន-យួនក្នុងផ្សារ ឃោសនាគ្នាទិញគ្រឿងប្រដាប់ប្រដាផ្សេងៗ ចែកជាស្លា ។ នៅឱកាសដែលចែកស្លាមានលោកចៅហ្វាយខែត្រ លោកសួរអំពីទំនៀមទម្លាប់ខ្មែរដែលលេងទូកនេះជាសេចក្ដីត្រួសៗ ។ ពេលនោះមានលោកជុកកូសី ឡឹម-ឯម លោកក៏បាននិយាយពន្យល់អំពីទំនៀមទម្លាប់ខ្មែរ ដែលមានមកជាច្រើនសតវត្សរ៍ហើយ ។ ទើបពួកអ្នករាជការទាំងអស់គ្នាមានលោកចៅហ្វាយខែត្រជាដើម ក៏ទទួលត្រេកអរកោតយ

ហើយលោកពោលថា ល្បែងនេះ គួរកត់បញ្ចូលក្នុងរឿងប្រវត្តិសាស្ត្រក្នុងប្រទេសបាន បើសិនជារាជការមានធ្វើបុណ្យអ្វីមួយ ត្រូវតែយកទូកងទៅលេងកំដរបុណ្យរាជការផង បានឬទេ ? រាជការនឹងឲ្យរង្វាន់ ។ ទើបលោកដុកកូស៊ី ទឹងជនជាតិខ្មែរទាំងអស់ក៏ទទួលព្រមព្រៀងគ្នាក្នុងពេលនោះ ។

ចាប់តាំងពីឆ្នាំនោះមក រាជការតែងតែត្រូវការ ក្នុងមួយឆ្នាំពីរដង ឬ ៣ ដង គឺនៅថ្ងៃ ១៤ កក្កដាអុំម្តង ថ្ងៃ ១១ វិច្ឆិកាម្តង, បើឆ្នាំណាមានតាំងតុលក់ទំនិញ នោះ ត្រូវអុំឲ្យរាជការ ៣ ដង ៗ បើគិតរួមទាំងទំនៀមខ្មែរពីរដងផង ត្រូវជា ១ ឆ្នាំអុំទូក ៤ ឬ ៥ ដង ។ រាជការតែងតែបែករង្វាន់ជាប្រាក់ឬក្រមាលទឹងរូបផ្សេងៗជាធម្មតា, ការលេងល្បែងទូកនេះ ក៏កាន់តែចំរើនឡើងជាដរាបមកមិនដែលអាក់ខានឡើយ, សូម្បីតែស្រុកទេសកើតអសន្តិសុខដូចកាលឆ្នាំ ១៩៤៥-៤៦-៤៧ នេះ ក៏នៅតែមានលេងគ្រាក់ទូកដែលធ្លាប់លេងពីមុននោះ ទោះបីប្រកបដោយអន្តរាយច្រើន ក៏នៅតែរកឲ្យបានលេងទាល់តែបាន ប៉ុន្តែលេងដោយភិតភ័យ ។ បើកាលណាដល់រដូវត្រូវលេង ហើយអ្នកដែលនៅស្រុកណាភូមិណាក៏នាំគ្នាលេងទៅស្រុកនោះភូមិនោះ ប៉ុន្តែមានកន្លែងខ្លះគេលេងតែពេលថ្ងៃ ។

គឺពីទូកវិញ បើកន្លែងណាមានទូកង គេក៏រៀបលេងតាមទំនៀមទៅ បើកន្លែងណាមិនមានទូកងទេ គេយកសុទ្ធតែទូកចែវពីរ-បី ឬចែវបួន ហើយគេយកដីស្អិតមកបូកៈលើក្បាល-កន្សៃ ធ្វើកងក្បាលដូចជាទូកងមែនទែន ទើបយកក្រដាសពណ៌ខៀវ ក្រហម លឿង បិទពីលើដីស្អិតនោះ ហើយគេរៀបស្លាធម៌ បាយសី នៅក្បាលទូក រួចនាំគ្នាអុំលេងតាមភូមិស្រុកទៅ ។

## អំពីល្បែងទូក រាងពៅ-ជិះទូក និងកម្មវិធី

ទូកនៅស្រុកបាសាក់ក៏មានទ្រង់ទ្រាយបែបផែនដូចទូកង នៅកម្ពុជាដែរ ឯគ្រឿងប្រដាប់តាក់តែងទូក អ្នកជិះក្បាល និងអ្នកច្រៀងបើកបទបន្ទរ មានប្លែកគ្នាខ្លះ ដូចរៀបរាប់តទៅនេះ ៖

គេយកសំពត់ពណ៌ផ្សេងៗ ទំហំប៉ុនទទឹងក្បាលឬកន្សៃ បណ្ដោយ ៤០ ឬ ៦០ សង់ទីម៉ែត្រ, គេយកអង្កាំឬខ្សែសយ-ឌិន ប៉ាក់ជារូបផ្សេងៗ ហើយចងព្យួរ មានផ្កាខ្ពុកពីរនៅសងខាង, ឯក្បាលទូកមានស្លាធម៌ ១, ទូកខ្លះទៀតមានរៀបទៀន ៤ ធូប ៤ បាយសី និងមានក្រសាំកាយប៉ាំងផង ។ មុននឹងដាក់ចុះពីបង្គងរោង គេប្រគំភ្លេងលេងច្រៀងកំមួយយប់សិន ព្រឹកឡើងទើបដាក់ចុះលេង ខាងក្បាលមានប្រពៃពីរដោតឈមក្បាលទូក សំរាប់អ្នកជិះក្បាល បន្ទាប់អ្នកជិះក្បាលហៅស្នា

ឯក ដះតែម្នាក់ឯងដែរ, បន្ទាប់ស្នាឯកហៅស្នាទីមមានពីរនាក់, បន្ទាប់ស្នាទីមទៅហៅកូនគូ គឺ មួយគូៗរហូតដល់កណ្ដាលទូកនោះ មានខ្ទង់មួយ គេចែកពីរក្បាលពីរកន្សៃឲ្យខ្ទង់ស្មើភាគគ្នា ហើយនៅសេសមួយ គេហៅថាខ្ទង់ប្រាំធាន ខ្ទង់នោះគេអាចដឹងសាច់ទូកទន់ឬរឹងលឿនឬមិនលឿន ត្រូវថែមថយ ឈើទល់ឬមិនបាច់ទល់, ត្រង់ខ្ទង់ប្រាំធាននោះ មានមនុស្សពីរនាក់ ម្នាក់វាយគង ម្នាក់ទៀតច្រៀងបើកបទបន្ទរ បន្ទាប់ពីខ្ទង់ប្រាំធានទៅ គេហៅថាកូនលុក គឺលុកជើងម្នាងលើខ្ទង់ ជើងម្នាងឈរជាគូៗ ទៅដល់អ្នកស្រង់យោង ៤-៥ ឬ ៦ នាក់ក៏មាន, ឯអ្នកស្រង់យោងចាំស្ដាប់អ្នកកាន់កន្សៃ ស្រែកត្រូវស្ដាំ ឯអ្នកកាន់កន្សៃមើលអ្នកដះក្បាល ។ បើអុំផ្ទួនទូកដទៃ អ្នកដះក្បាលចាប់ប្រវាអុំ អ្នកកន្សៃក៏អុំដែរ ដើម្បីយកឈ្នះចាញ់ ។

## កម្មវិធី

កម្មវិធីនេះ ជាទំនៀមមួយកើតឡើងដោយសាមគ្គីនៃមហាជន ដែលអាស្រ័យនៅក្នុងបច្ចន្តគ្រាម (ស្រុកបាសាក់) ព្រមព្រៀងមូលមតិគ្នា បង្កើតឲ្យមានជាបែបភាពតាមសម័យនិយមដូចតទៅនេះ :-

១-ថ្ងៃពេញបូណ៌មីខែអស្សុជដដែលចេញវស្សា ត្រូវលេងទូកនៅតាមកន្ទ្រា ហៅថាធ្វើសក្ការបូជារំលឹកដល់ពុទ្ធបាទក្នុងទឹក ។

២- ថ្ងៃពេញបូណ៌មីខែកត្តិក ត្រូវលេងទូកនៅអំពូយា ហៅថា បុណ្យសំពះព្រះខែ ។

៣- ប្រជាពស្រ្តនៅឃុំនោះ តែងតែដល់កំណត់ ត្រូវនាំគ្នាសង់ពេងមួយចំនួន ៣ ល្វែងក្នុងទីវត្ត ជំរះស្មៅឲ្យស្អាត រៀបចំសាលាមួយលំអដោយផ្កាទីងប្រទីបផ្សេងៗ ជាគ្រឿងបូជាទៅតាមស្រុក ។

៤- ថ្ងៃពេញបូណ៌មីត្រូវមកឲ្យជុំគ្នា ដើម្បីទីងប្រគេនចង្ហាន់ដល់ព្រះសង្ឃ ហើយរៀបបាយ ៣ ល្វែងទីងមហាវត្ត ។

៥- ដល់ម៉ោង ២ រសៀល ត្រូវអុំប្រណាំងគ្នាលេងឲ្យជីងកំលាំងទូក ដើម្បីទីងផ្គូផ្គងត្រូវគ្នា ។

៦- ម៉ោង ៥ នាម៉ឺនធំ-តូច អញ្ជើញទៅមូលគ្នា ត្រូវអុំមួយគូម្តងៗ យកឈ្នះចាញ់ ។

៧- ម៉ោង ៦ ល្ងាច ទូកទាំងអស់ មកតម្រៀបនៅខាងមុខបាយ ដើម្បីទីងទទួលរង្វាន់ ។

៨- ម៉ោង ៧ យប់ លៀងគោជនាហារដល់នាម៉ឺន បាយង ខ្មែរ ចិន យួន, ឯក្នុងវត្តប្រគេនគេសជ្ជ: គឺ តែ កាហ្វេ ទឹកកកជាដើម ដល់ព្រះសង្ឃ ។

៩- ម៉ោង ៨ យប់ មានហែផ្កាភ្លើងដោយក្បួនទូក អុជកាំជ្រួច រន្ទា

ភ្លីទៀន បណ្ដែតតាមទឹក ។

១០- ម៉ោង ៩ យប់ ឲ្យរង្ហាន់ដល់ទូកហែផ្កាភ្លើង, ពេលនោះ ក្នុងទីវត្ត ឧបាសក ឧបាសិកា និមន្តព្រះសង្ឃចំរើនព្រះបរិត្ត សំដែងធម៌ទេសនារហូតដល់ភ្លឺ ។

ឯមន្ត្រីអកកជការ ពេលម៉ោង ៨ នោះ គេត្រឡប់ទៅគេហដ្ឋានរៀងៗខ្លួនទៅ ។ ឯទូកងទៅលេងដល់ភ្លឺ ។

ព្រឹកឡើងថ្ងៃ១ រោច គេប្រគេនចង្ហាន់ព្រះសង្ឃពេលព្រឹកនឹងថ្ងៃត្រង់ សន្ទុតជាដួងបុណ្យ ។ ឯទូកងក៏រសាយគ្នា ទៅតាមទីឋានរៀងៗខ្លួនទៅ ។

## សេចក្ដីបញ្ជាក់

ល្បែងទូកងដែលបានរៀបរាប់មកនេះ ខ្ញុំបានផ្ទៀងតាមទំនៀមផង តាមសាវតារផង, ប៉ុន្តែ សេចក្ដីនឹងរឿងទាំងនេះឃើញថា កាលពីជំនាន់បុរាណនោះ ចាស់ទុំបានយកតម្រាប់តាមបែបក្នុងកម្ពុជរដ្ឋទាំងអស់ ប៉ុន្តែ ដល់មកសម័យក្រោយៗ ក៏មានការវិបត្តិឃ្លៀងឃ្លាត ខុសពីគ្នាខ្លះៗដោយអន្ទើ ។

រឿងនេះ សមាគមបានស្រាវជ្រាវរកខ្ចី លោកចៅហ្វាយអ្នង យកមកចម្លង ទុកជាកេរ្ដិ៍ដំណែលតទៅ, ដល់លោកចៅហ្វាយនោះអនិច្ចកម្មទៅ សាវតារនេះបានជូនទៅកូនចៅរបស់លោកនៅភូមិកគោ, ប៉ុន្តែ ភូមិនោះ ឥឡូវនេះ ផេះខ្ទេចខ្ទីអស់ហើយ ។

---

# រឿងព្រេងប្រទេសអេហ្ស៊ីព(១)

## ចែងអំពីរឿងក្មេងលើក្ដី

ភិក្ខុ ម៉ែន-រៀម

សិស្សពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ

ប្រែចាកភាសាអង់គ្លេស

---

ចំនួនជាច្រើនថ្ងៃកន្លងទៅហើយ គេដំណាលថា នៅក្នុងទីក្រុង អាដ់ដិស-អាបាបា មានបុរសកំឡោះម្នាក់ឈ្មោះ អាហា ៗ បុរសនេះមកពីប្រទេស គូកាហ្ស មកនៅធ្វើជាអ្នកបំរើចៅកែម្នាក់ឈ្មោះ ហាប់តុម-ហាស៊ី ក្នុងទីក្រុង អាដ់ដិស-អាបាបា នោះ តាំងតែពីកុមារ ៗ

ហាប់តុម-ហាស៊ី ជាចៅកែម្នាក់ស្តុកស្តម្ភបំផុត មានកម្មសិទ្ធិលើវត្ថុគ្រប់យ៉ាង ដោយសារទឹកប្រាក់របស់គាត់, ហើយគាត់តែងអផ្សុកចិត្ត ដោយគ្មានវត្ថុអ្វីមួយថ្មីកប្លែកក្នុងគាត់ ក្រៅពីវត្ថុដែលគាត់មានហើយនោះឡើយ, ការងារដែលគាត់ត្រូវធ្វើ ក៏គ្មានថែមទៀត ៗ

ក្នុងរាត្រីកាលដ៏ត្រជាក់មួយ កាលដែលព្រះពាយលាយៈដោយ

---

១-អេហ្ស៊ីពជាអាណាចក្រអាហ្វ្រិកខាងកើត ។ ពីដើមគេហៅថាអាប៊ីស៊ីនី ។

ទឹកសន្សើម បក់កាត់ខ្លួនពប ។ ចៅកែ ហាប់គុម បានហៅអ្នកបំរើរបស់គាត់ គឺ អាហោ ឲ្យយកឧសមកបង្កាត់ភ្លើងកំដៅ ។ កាលអាហោ បង្ហើយកិច្ចនេះរួច, ចៅកែក៏ចាប់និយាយលេង, ដំបូងគាត់និយាយនឹងខ្លួនគាត់ថា:

–« យីអើហ្ន៎ ! ត្រជាក់ដល់ថ្នាក់ប៉ុន្មានទៅ ដែលមនុស្សនៅត្រាំបាន? ” , រួច គាត់បន្តទៅទៀតថា:

–“ អញដូចជាសង្ស័យណាស់ថា បើអ្នកណាមួយទៅឈរលើកំពូលភ្នំ ម៉ោនអ៊ុនថតូ ដ៏ខ្ពស់បំផុត ដែលមានខ្យល់យ៉ាងត្រជាក់អនេកអនន្ត បក់បោកមកលើ ឲ្យបានពេញមួយយប់ពាល់ភ្លឺ ដោយកុំដណ្ដប់ភួយ ឬស្លៀកពាក់ខោ អាវ តើវាស្លាប់ឬមិនស្លាប់ ? ” ។

–« ទេ, ខ្ញុំមិនដឹងដែរ”, អាហោឆ្លើយ, « ប៉ុន្តែបើគេទៅធ្វើដូច្នោះ តើអំពើនោះ មិនមែនជាអំពើឆ្កួតក្ដិះក្ដុះ ឬដូចម្ដេច ? ” ។

–« អើ, អាចឹងមែនហើយ” , ចៅកែឆ្លើយតប, “បើធ្វើដូច្នោះទៅ ហើយវាគ្មានបានទទួលកំរៃអ្វីពីការធ្វើនោះ, អំពើនោះ ជាអំពើឆ្កួតលីលាមែន, ប៉ុន្តែអញហ៊ានភ្នាល់ថា គ្មាននរណាអាចទៅឈរដូច្នោះបានឡើយ” ។

-«ទេ, ខ្ញុំហ៊ាន, ខ្ញុំជឿជាក់ថា រូបខ្ញុំក្លាហានល្មមទៅឈរស្រាតលើភ្នំនោះពេញមួយយប់បាន», អាហោនិយាយ, «ប៉ុន្តែ វាមិនមែនជាកិច្ចការរបស់ខ្ញុំទេ ដោយហេតុថា ខ្ញុំគ្មានអ្វីសំរាប់ភ្នាល់នឹងលោក» ។

-«ល្អ! ល្អ!», ថៅកែនិយាយ, «ឲ្យតែឯងពិតប្រាកដជាហ៊ានធ្វើការនេះបាន អញនឹងភ្នាល់ជាមួយឯងតាមរបៀបណាមួយ, គឺថាបើឯងអាចទៅឈរលើកំពូលភ្នំដែលដេរដាសដោយថ្ម ឲ្យបានពេញមួយយប់ ដោយគ្មានម្ហូបអាហារ គ្មានទឹក គ្មានសំលៀកបំពាក់ គ្មានភួយនឹងគ្មានភ្លើងសំរាប់កំដៅ ហើយមិនស្លាប់ព្រោះកិច្ចនេះ, ពេលនោះ អញនឹងឲ្យឯងនូវដី ១០ អា ដែលជាដីចំការដ៏ល្អ ១ ព្រមទាំងសេះមួយ នឹងពាហនៈខ្លះទៀតជាកម្មសិទ្ធិរបស់ឯង» ។

អរៈពក, អាហោ គេគល់ស្ទើរតែមិនជឿពាក្យដែលខ្លួនបានស្ដាប់, វាសួរថៅកែថា:

-«តើពាក្យនេះ មានន័យពិតដូច្នេះមែនឬលោក?» ។

-«ហើ! អញជាបុរស តាំងនៅក្នុងពាក្យរបស់ខ្លួនណា!», ថៅកែឆ្លើយ ។

-«បើដូច្នោះមែន ល្ងាចស្អែក ខ្ញុំនឹងទៅធ្វើការនេះ, ហើយ

បន្ទាប់មក គឺនៅឆ្នាំ ៗ ទៅ ខ្ញុំនឹងបានជាម្ចាស់កម្មសិទ្ធិ អាចមានដីរបស់ខ្ញុំនោះ ធ្វើការលៀងអាជីពទៅអនាគត » ។

តែ អារហា ព្រួយចិត្តចំពោះការក្លាល់នេះជាពន់ពេក ពីព្រោះខ្យល់ដែលបក់បោកលើកំពូលភ្នំម៉ោន-អ៊ុនថតថូ កំណាចខ្លាំងណាស់ ។ ម្ល៉ោះហើយ ក្នុងពេលព្រលឹមឡើង អារហា បានចូលទៅរកតាចាស់ដំបុនម្នាក់ ជាកុលសម្ពន្ធរបស់ខ្លួន ដើម្បីប្រាប់រឿងក្លាល់នេះ ឲ្យតានោះជួយខ្លួន ។ តាចាស់ ស្ដាប់អារហានិយាយប្រាប់រឿងនេះ ដោយស្ងប់ស្ងៀមនឹងដោយការរិះគិត, ទីបំផុត កាលអារហានិយាយចប់គាត់ពោលថា :

—« មិនអីទេ ! កុំព្រួយ, ខ្ញុំនឹងជួយអ្នកឯងក្នុងរឿងនេះ : ចុងរំលងជ្រលងភ្នំ ម៉ោន-អ៊ុនថតថូទៅមានថ្មាំងសិលាមួយដុំយ៉ាងខ្ពស់ ដែលគេអាចមើលទៅឃើញក្នុងវេលាថ្ងៃ ។ ល្ងាចស្អែក នៅពេលព្រះអាទិត្យអស្ដង្គត ខ្ញុំនឹងទៅបង្កាត់ភ្លើងនៅទីនោះ ដែលជាទីអាចមើលទៅឃើញពីកន្លែងដែលអ្នកឋិតនៅ ។ ពេញមួយរាត្រីនោះ អ្នកឯងត្រូវបោលភ្នែកក្រឡេកមើលទៅភ្លើង ដែលខ្ញុំបង្កាត់នោះ, កុំបិទភ្នែកឲ្យដំណេកធ្ងន់ពាត់អ្នកឲ្យសោះ ។ ពេលដែលអ្នកមើលភ្លើង ត្រូវគិតពីកំដៅភ្លើង គិតពីរូបខ្ញុំជាសំឡាញ់អ្នកឯង ដែលកំពុងតែថែទាំភ្លើងនោះឲ្យអ្នក ។

បើអ្នកធ្វើតាមបែបនេះ អ្នកនឹងអាចរស់នៅបាន ទុកណាជាខ្យល់យប់នោះ កំណាចយ៉ាងណាក៏ដោយ " ។

សារ៉ោ ទទួលអំណរគុណតាចាស់ រួចត្រឡប់ទៅផ្ទះថៅកែហាប់តុមវិញ ដោយមានបេះដូងយ៉ាងត្រចះរីករាយ ។ វាបានប្រាប់ថៅកែហាប់តុមថា វាប្រុងប្រៀបនឹងទៅធ្វើកិច្ចនោះហើយ ។

នៅសាយណ្ហសម័យ, ថៅកែបានបញ្ជូន សារ៉ោ ឲ្យទៅឈរលើកំពូលភ្នំ ម៉ោន-អ៊ិនថតថូ ដោយមានខ្ញុំកំដរជាច្រើននាក់ ទៅចាំឃ្លាំមើលផង ។ នោះលើកំពូលភ្នំ, កាលដែលរាត្រីកាល បានគ្របដណ្ដប់មកហើយ សារ៉ោ ក៏ប្រមូលសំលៀកបំពាក់ខ្លួនដាក់មួយដុំ រួចចាប់ផ្ដើមឈរកណ្ដាលខ្យល់សើមត្រជាក់ ដែលបោកបក់កាត់ធ្លុងខ្លួនពប ក្នុងអស្ដង្គតកាល នៃព្រះអាទិត្យ ។ រំលងជ្រលងភ្នំ ចំនួនជាច្រើនម៉ៃល៍[១] ទៅទីមួយឆ្ងាយ, សារ៉ោបានឃើញពន្លឺភ្លើងរបស់សំឡាញ់វា ដែលចោលពន្លឺភ្លឺព្រិប ៗ ដូចជាផ្កាយក្នុងខែងងឹត ។

ព្រះពាយ ចេះតែត្រជាក់ឡើង ៗ ហើយហាក់ដូចជាទំលុះចូលទៅក្នុងសាច់ ចាក់ចុចឆៅដល់ខួរក្នុងឆ្អឹង នៃសារ៉ោ ។ ថ្ម ដែលវាឈរជាន់នោះ ប្រែក្លាយជាទឹកកក ។ គ្រប់តែពេលដែលឈានចូលមក ភាពត្រជាក់ចេះតែបង្កើនសកម្មភាព ធ្វើឲ្យសារ៉ោស្ពឹកខ្លាំងឡើងៗ

១, ១ ម៉ៃល៍ គឺ ១៦០៩ ម៉ែត្រ ។

ដរាបដល់វាភ័យថា ខ្លួនវាប្រហែលជាលែងមានកំដៅទៀតទេដឹង; ប៉ុន្តែ វាចំបើកភ្នែកក្រឡេកមើលទៅភ្លើង ដែលហាលពន្លឺផ្លុង ៗ ក្នុងទីឆ្ងាយនោះ ហើយធ្វើទុកក្នុងចិត្តថា សំឡាញ់ចាស់វាគង់តែថែទាំភ្លើងនោះសំរាប់ខ្លួនវា ៗ ជួនកាល មានដុំពពកស្តើង ១ អណ្តែតត្រសែតមកគ្របពន្លឺនោះបាត់មួយសន្ទុះ ធ្វើឲ្យអាហោសន្លឹងខ្សែបក្ខុំមើល ដរាបដល់ដុំពពកតូច ១ នោះឃ្លាតចេញពីពន្លឺ ៗ ពេលនោះ អាហោទៅជាក្អកក្រដាស់ រួចគ្រុនញ័រ ចាប់មិនស្រួលខ្លួនតែម្តង ៗ ក៏ប៉ុន្តែពេញមួយយប់នោះ វាទ្រាំឈរស្រាតនៅទីនោះបានដរាបដល់ភ្លឺស្រាង ៗ ទើបវាស្លៀកពាក់ខោ-អាវ ចុះពីកំពូលភ្នំ រួចដើរត្រឡប់ទៅផ្ទះចៅកែវាវិញ ៗ

ឃើញអាហោឧកដល់, ចៅកែ ហាប់តុម ក៏ស្រាប់តែភ្ញាក់ព្រើត, គាត់សួរទៅខ្ញុំកំដរគាត់ឯទៀត ដោយមច្ឆរិយថាៈ-

–"ភ្នូ! វាបានទៅឈរលើកំពូលភ្នំ ពេញមួយយប់ ដោយឥតមានម្ហូបអាហារ ទឹក ភួយ និងសំលៀកបំពាក់ អីចឹងមែនហ៎?" ៗ

-"អីចឹងមែន លោក!", អ្នកបំរើឆ្លើយ, "គាត់បានបំពេញលក្ខណសម្បត្តិទាំងនេះ ត្រឹមត្រូវមែន" ៗ

–"ល្អ! អ្នកឯងជាមនុស្សពូកែមែន", គាត់និយាយទៅកាន់

អាហោ, ចុះអ្នកឯង ធ្វើដូចម្ដេច បានជាត្រាំឈរបាន? " ។

-" ខ្ញុំក្រឡេកមើលទៅភ្លើងផ្លុង ១ មួយ បិតនៅលើភ្នំតូចមួយ ឆ្ងាយពីកន្លែងខ្ញុំ", អាហោឆ្លើយ ។

-« ថាម៉េច? ឯងមើលភ្លើង? អ្ហូ! ឯងចាញ់ភ្នាល់ហើយ បើដូច្នោះ.... ឯងត្រូវនៅជាខ្ញុំកំដរអញតទៅទៀត, មិនត្រូវបានដីបានខ្មោចទីទេ!" ... ។

-« ទេលោក, ភ្លើងនោះនៅទីឆ្ងាយ·ឆ្ងាយពីខ្ញុំ គឺឆ្លងវាលជ្រលងភ្នំមួយទៅទៀតទើបដល់, វាមិនអាចឲ្យកំដៅសូម្បីបន្តិចដល់ខ្ញុំឡើយ", អាហោ តប ។

-« ទេ, អញមិនឲ្យដីឯងទេ ព្រោះឯងមិនធ្វើតាមលក្ខខណ្ឌនៃការភ្នាល់...., ព្រោះតែភ្លើងនោះហើយ បានជាឯងអាចឈរបាន..." ។

ពេលនោះ អាហោ ព្រួយចិត្តពន់ពេក ។ វាបានចូលទៅរកសំឡាញ់ចាស់វាម្នាក់ទៀត រួចប្រាប់សំឡាញ់នោះពីហេតុការណ៍ដែលកើតឡើង ។

តាចាស់ ទូន្មានវាថា ឲ្យយករឿងក្ដីនោះ ទៅប្ដឹងចៅក្រម ។ អាហោ បានចូលទៅប្ដឹងរឿងនេះដល់ចៅក្រម ។ ក៏កោះហៅចៅកែ

ហាប់តុម ឲ្យចូលខ្លួនកាន់ទីតុលាការ ។ កាលដែល ហាប់តុម ប្រាប់រឿងខ្លួនដល់ចៅក្រម ហើយខ្ញុំក៏ជម្រាបបន្ថែមថា អាតហា បានមើលភ្លើង ដែលបិតនៅឆ្ងាយរំលងជ្រលងភ្នំទៅទៀតនោះ ។ ចៅក្រម គាត់ឲ្យអាតហាចាញ់ដោយខុសខាងលក្ខណសម្បត្តិនៃការភ្នាល់ ត្រង់ចំណុចថា ត្រូវឈរដោយឥតមានពន្លឺសំរាប់អាំង ។

អាតហា ចូលទៅរកសំឡាញ់ចាស់នោះម្តងទៀត ដើម្បីប្រាប់នូវដំណឹងទុក្ខព្រួយដល់សំឡាញ់ថា ខ្លួនត្រូវគេផ្តន្ទាទោសឲ្យបិតនៅក្នុងជីវភាពជាខ្ញុំកំដរគេតទៅទៀត ទុកណាជាខ្លួនបានបំពេញពិធីកម្មនៅលើកំពូលភ្នំដុះច្បារហើយក៏ដោយ ។

បុរសចាស់ និយាយទៅកាន់អាតហាថា កុំអាលអស់សង្ឃឹម, ទុកណាជាខ្លួនជាមនុស្សព្រៃ តែនៅមានប្រាជ្ញាមិនខាន់អន់ជាងចៅក្រម ដែលនៅក្នុងទីក្រុងប៉ុន្មានទេ ។

និយាយហើយ គាត់ក្រោកពីទីដែលអង្គុយ រួចដើរទៅរកជួប បុរសម្នាក់ទៀតឈ្មោះ ហេលុយ ដែលគាត់ធ្លាប់នៅបំរើ កាលគាត់នៅពីកុមារភាព ដើម្បីនិយាយរឿងក្តាល់រវាងចៅកែ ហាប់តុម និង អាតហា ឲ្យគាត់ជួយគិតពីរឿងនេះផង ។

ហេលុយ គិតមួយសន្ទុះហើយឆ្លើយថា៖

—«កុំខ្វល់ពីរឿងនេះឲ្យសោះ, ចាំខ្ញុំជួយយកអាសាអ្នកឯង» ។

នៅថ្ងៃមួយក្រោយមក, ហេលុយ បានបញ្ជូនសំបុត្រទៅអញ្ជើញភ្ញៀវក្នុងទីក្រុង ដើម្បីឲ្យមកចូលការជប់លៀងភោជនាហារ នៅផ្ទះគាត់ ។ ក្នុងចំណោមភ្ញៀវដែលត្រូវអញ្ជើញ, ចៅកែ ហាប់តុម និងចៅក្រមដែលកាត់ក្ដីឲ្យអាហោ ចាញ់ក្នុងរឿងក្ដាល់ ក៏បានត្រូវគេអញ្ជើញដែរ ។

កាលបរិច្ឆេទនៃពិធីជប់លៀងភោជនាហារ មកដល់ហើយ, ភ្ញៀវទាំងឡាយ ដំប្រដាប់កាយដោយគ្រឿងអលង្ការយ៉ាងសង្ហា ។ ជិះសេះទេសញី ដើរហែហមដោយហ្វូងបរិវារពីក្រោយ គគ្រឹកគគ្រេង ឆ្ពោះទៅកាន់ពិធីជប់លៀង ។

ចៅកែ ហាប់តុម យើង ដែលកំដរស្រេករដោយបរិវារ ២០ នាក់ គឺម្នាក់ជាអ្នកបាំងឆត្រការពារកំដៅព្រះអាទិត្យជូនលោក ហើយមានអ្នកវាយស្គរ ៤ នាក់ទៀត គិតតែពីវាយស្គរកំទេះកូម៉ិឲ្យលាន់ឮឡើង ជាសញ្ញាប្រាប់ពួកជនឲ្យដឹងថា លោកចៅកែធំនាម ហាប់តុម អញ្ជើញទៅរួមក្នុងពិធីជប់លៀងភោជនាហារនោះឯង ។

អតិថិជនទាំងឡាយ, បានចូលទៅអង្គុយតាមលំដាប់លំដោយលើកំរាលដ៏ទន់ល្មើនយ៉ាងស្អាត ដែលគេក្រាលរួចពីមុនហើយស្រេចនោះ,

បែកក្រោកប្រាជ្ញល្ហាចទៅវិញទៅមកតាមរឿងរបស់គេ ។

ភោជនាហារដ៏មានរសជាតិទាំងឡាយ ដែលចំអិននៅក្នុងចង្ក្រានក្រៃរនោះ ដូចជាសាច់ពពែឆា, ពោតឆា, ផុក, ទំ អ៊ុងបង្គា ទីងប្រកពចម្លាញ់ដទៃទៀតជាច្រើន បានបោលក្លិនឈ្ងុយឈ្ងប់លើសលុបអស្ចារ្យ នាំឲ្យកើតសម្រេកគំលានឃ្លានស្ទើរស្រេកទឹកមាត់ ដល់ពួកភ្ញៀវទាំងនោះៗ ពេលវេលាចេះតែកន្លងទៅៗ , ការដែលត្រូវលើកភោជនាហារមកជូនភ្ញៀវបរិភោគ ក៏ល្មមពេលហើយ តែមិនមានម្ហូបចេញមកឲ្យភ្ញៀវឃើញសោះ មានតែក្លិនឈ្ងុយឈ្ងប់ប៉ះចេញពីចង្ក្រានមកតែប៉ុណ្ណោះ ។ ពេលល្ងាច ឈានចូលមកហើយ តែភោជនាហារ មិនទាន់ចេញមកទទួលភ្ញៀវនៅឡើយទេ ។ ភ្ញៀវទាំងឡាយ ក៏ចាប់ផ្ដើមខ្សឹបខ្សៀវគ្នាទៅវិញទៅមក, គេឆ្ងល់ចង់ដឹងថា ប្រហែលជាលោកហេលុយ ឥតមានភោជនាហារអ្វីទីនាំចេញមកទទួលពួកគេទេដឹង ។ ក្លិនឈ្ងុយនៃសាច់ចៀនឆាក៏ចេះតែបក់ក្លិនមិនឈប់សោះ ។ ទីបំផុត ភ្ញៀវម្នាក់ក្នុងចំណោមភ្ញៀវទាំងឡាយនោះ និយាយឡើងថា ៖

– « លោកហេលុយ, ម៉េចក៏លោកធ្វើការអ៊ីចឹង ? ក្រែងលោកអញ្ជើញពួកយើង ឲ្យមកទទួលការជប់លៀង , ចុះហេតុម៉េចបានជាមិនឃើញមានម្ហូបអាហារអ្វីសោះដូច្នេះ ? » ។

– "ម៉េចក៏និយាយយ៉ាងហ្នឹង ?", ហេលុយឆ្លើយ, "លោកគ្រាន់តែហិតក្លិនទៅមិនបានឬ ?" ។

– "ពិតហើយ យើងហិតបាន, តែការហិតក្លិន មិនមែនជាការបរិភោគទេ; វាគ្មានការឆ្អែតពោះ ដោយការហិតក្លិនទេ !" ។

– "ចុះកំដៅរបស់ភ្លើង ដែលយើងមើលទៅឃើញដោយពិបាក អាចកក់ក្ដៅដល់យើងបានដែរឬអី?", ហេលុយសួរ, "បើប្រសិនជាអារហាបានកក់ក្ដៅដោយភ្លើងដែលវាមើលទៅឃើញ គ្រាដែលវាឈរនៅលើភ្នំ មោន·អ៊ុនថត់ថូ នោះមែន, ពេលនេះ អស់លោកក៏អាចឆ្អែតបាន ដោយគ្រាន់តែហិតក្លិនភោជនាហារបេកមកពីចង្ក្រានជូនអារហោដែរ" ។

ផងទាំងឡាយ បានយល់ស្របតាមពាក្យហេលុយ , ឯចៅក្រមក៏យល់ខុសកំហុសរបស់ខ្លួន ហើយថៅកែហាងតុមកើតអៀនខ្មាសក្រៃលែង ចៅក្រម បានសម្ដែងសេចក្ដីអរគុណចំពោះហេលុយដែលបានឲ្យដំបូន្មានដល់ខ្លួន ។ រួចប្រកាសសេចក្ដីជាថ្មីថា ! អារហោត្រូវជាអ្នកមានជ័យជំនះក្នុងការក្ដីពេលនោះ, ត្រូវបានដី បានផ្ទះ និងសត្វពាហនៈក្នុងកិច្ចការ ។

រួចហើយ ហេលុយបានបង្គាប់ឲ្យគេលើកភោជនាហារមកជូនភ្ញៀវ, ពិធីជប់លៀងក៏ចាប់ផ្ដើមដោយបរិយាកាសដ៏រីករាយតទៅ ។

រឿងសាមកុក

# កណ្ឌទី ៤១

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកផងវៃឆ្លាសបើបានអាន<br>នឹងបេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ។ |

ចូចូឮដូច្នោះក្រេកអរណាស់ ទើបចាត់ចែងទូកតូចរហ័សឲ្យជៀវកានៗ ក៏ចុះទូកនោះទៅដល់ក្នុងកងទ័ពជីវយី ហើយប្រាប់តាហានថា យើងសុំចូលទៅជួបនឹងជីវយីមេទ័ព ៗ តាហានក៏ចូលទៅប្រាប់សព្វសេចក្តីថា ឥឡូវជៀវកានចូលមករកលោកទៀត ៗ ជីវយីឮដូច្នោះក៏ក្រេកអរ តែគិតក្នុងចិត្តថា ដែលជៀវកានមានការមកម្តងទៀតឃើញថា ការរបស់យើងដែលគិតធ្វើមកនោះ ក៏នឹងបានសម្រេច ព្រោះជៀវកាននេះឯង, ជីវយីក៏ប្រើឲ្យតាហានត្រឡប់ទៅប្រាប់ជៀវកានថា: យើងនៅដេក ៗ តាហានក៏ទៅប្រាប់ជៀវកានតាមពាក្យដែលជីវយីបង្គាប់ ៗ ជៀវកានក៏

ចេញទៅនៅក្រោមថ្នាយ ។

ក្នុងខណៈកងទ័ពចូឆូ លើកចុះមកដល់ដែនស្រុកកេងជីវនោះ ចាំងថងភ្វាចចា ហានចូឆូធ្វើអន្តរាយ ក៏រត់ចេញទៅនៅក្នុងស្រុកកាំងតាំង ៗ ឡោសុក បានទៅសួរចាំងថងថា ទីងរិះគិតតាំងច្បាំងទីងចូឆូ យ៉ាងម្តេច ទើបទីងបានជ័យជំនះចូឆូ ? ។ ចាំងថងថា ឲ្យយកច្រវ៉ាក់ លាមតាក់សោទូកចម្បាំងចូងភ្ជាប់គ្នា ហើយយកក្តារបង់ទូកឲ្យទីងគ្រប់ទូក ហើយឲ្យយកភ្លើងដុតបំផ្លាញ ទើបចូឆូទីងបែក ៗ សេចក្តីទាំងនោះ ឡោសុក ក៏បាននាំទៅប្រាប់ជីវយើ ៗ ក៏សរសើរថា ចាំងថងមានជម្រេះប្រាជ្ញា ជីវយើក៏ពប់គានចាំងថងថាចេះដឹងយ៉ាងវិសេស លុះជីវយើលើកកងទ័ពមកគ្រានេះ ចាំងថងក៏មករៀបចំទូកនៅជាមួយទីងជីវយើ ៗ

កាលជៀវកានៈទៅរកជីវយើនោះ ជីវយើក៏ប្រើទាហានទៅប្រាប់ជៀវកានថា ជីវយើទៅដេកមិនទាន់ភ្ញាក់ ជៀវកានក៏នៅចាំខាងក្រោមថ្នាយ ៗ ជីវយើ ក៏ឲ្យហៅឡោសុកមកជួបហើយបង្គាប់ថា ឥឡូវជៀវកានមកបញ្ឆោតទៀតហើយ គឺមកមើលបៈហាតុភេទធ្ងន់ស្រាលក្នុងកងទ័ពយើង ៗ ទីងក្លែងឲ្យបេកខ្ទបជៀវកានទៅបន្ទំទុក ចូរអ្នកទៅនិយាយអង្វរចាំងថងឲ្យនិយាយនឹងជៀវកានជាមេត្រីគ្នា បើឃើញជៀវកាននាំចាំងថងរត់ទៅ

ចូលបួច្ចុក្នុងបន្ទាយ ឲ្យចាំនឹងគិតឧបាយបញ្ឆោតបួច្ចុ ឲ្យយកប្រាក់រយ បង្គាប់ទូកចាក់សោឲ្យជាប់គ្នាទាំងអស់ យើងនឹងបានយកភ្លើងដុតឲ្យឆេះទូកក្នុងកងទ័ពឲ្យអស់កុំឲ្យសល់ ឡាសុកក៏ចេញទៅទទួលជៀវកាន ។

ជៀវកានក៏គិតឃើញថា ចិត្តជីវយីមិនមានជាប្រក្រតីដូចពីដើម ទើបឲ្យពាហានដែលដូនទូកមកនោះ នាំទូកទៅចតក្នុងកងទ័ពជីវយី ហើយជៀវកានក៏ដើរចូលទៅក្នុងបន្ទាយ ឃើញមុខជីវយីបែបក្រញូវ ៗ ឯជីវយីក៏ធ្វើជាខឹងហើយនិយាយនឹងជៀវកានថា អ្នកឯងគ្មានគិតដល់ផ្លូវមេត្រីពីកាលនឹងយើងសោះ ហានមើលងាយយើង ៗ ជៀវកានឮដូច្នោះក៏អស់សំណើចហើយតបថា ខ្លួនខ្ញុំនឹងលោកប្រាកដជាគៀនសំឡាញ់គ្នាមកពីក្មេង គ្រានេះខ្ញុំនៅចាំចិត្តស្រឡាញ់ពេញពោះទុកដូចប្អូនបង្កើត បានជាខំស្រូតទៅមកសាកសួរសុខទុក្ខ ដែលលោកថាខ្ញុំបង្អាប់មើលងាយប្រមាថនោះគឺយ៉ាងម្ដេច ? ៗ ជីវយីថា កាលអ្នកឯងមកពីថ្ងៃមុន ខ្ញុំក៏ដឹងទ័យថា បួច្ចុឲ្យមកបញ្ចុះបញ្ចូលខ្ញុំ ឯគំនិតរបស់ខ្ញុំនេះ ក្រែងតែទឹកក្នុងមហាសមុទ្រនឹងស្ងួត ទើបខ្ញុំព្រមទៅចុះចូលបួច្ចុ តែថាខ្ញុំគិតការណ៍តអ្នក ព្រោះជាគៀនសំឡាញ់ បានជាខ្ញុំហាមប្រាមអ្នកមិនឲ្យអ្នកយកឈ្មោះបួច្ចុមកនិយាយ ប្រយោជន៍នឹងកាត់បំបិទផ្លូវសេចក្ដីដែលអ្នកប្រុងនឹងនិយាយបញ្ចុះបញ្ចូលខ្ញុំនោះ ខ្ញុំក៏បបួលអ្នកផឹកស្រាហើយនាំគ្នាចូល

ទៅដេកលើគ្រែជាមួយ លុះខ្ញុំដេកលក់អ្នកក៏លួចយកសំបុត្រដែលឈ្មួញ ទីងទៀងអ៊ុនផ្ញើមកខ្ញុំទៅបាត់ កាលដែលទីងទៅក៏មិនបានលាខ្ញុំសោះ លបតែទៅក្នុងពេលអធ្រាត្រស្ងាត់ ហើយយកសំបុត្រនោះទៅឲ្យប្ចូ ៗ ក៏សម្លាប់ឈ្មួញ ទៀងអ៊ុនខូចអសារ ការធំរបស់ខ្ញុំដែលគិតគ្នាទុកក៏ខូចទាំងអស់ព្រោះតែខ្លួនអ្នកមួយ ឥឡូវខ្លួនគិតមកទីងធ្វើប្រទូសរ៉ាយយើងទៀតប្រ បើយើងគិតមិនដល់ថាខ្លួនជាកៀងសំឡាញ់មកពីដើម ក៏ទីងឲ្យកាត់ក្បាលផ្ដាលទុកនៅមុខបន្ទាយ បើទីងបណ្ដោយទៅដោយយោគយល់ខ្លួនក៏នាំយកសេចក្ដីទៅប្ដឹងវិទ្ធល់ឲ្យប្ចូដឹងក្នុងគំនិតយើងទាំងអស់ យើងទីងធ្វើសឹកគតទៅក៏គ្មានបន្ទោះទីងយកការឲ្យបាន ហើយបង្គាប់ពាហានឲ្យនាំខ្លួនដៀវកានទៅឃុំទុកប្រាប់ថា បើកាលណាវ៉ាយទ័ពប្ចូវែក ទើបបើកលែងខ្លួនកាលណោះ ដីវ៉ៃយើក៏ដើរចូលទៅខាងក្នុង ៗ ឯពាហាន ២ នាក់ក៏នាំខ្លួនដៀវកានទៅឃុំទុកក្នុងវត្តលើកំពូលភ្នំ ។

ខណៈនោះដៀវកានក៏មានទុក្ខព្រួយសុំមិនបានដេកមិនលក់ លុះពេលកណ្ដាលយប់ស្ងាត់ឃើញខែភ្លឺ ក៏ចេញដើរទៅលេងខាងក្រោយវត្ត ប្រាថ្នាទីងឲ្យស្បានទុក្ខព្រួយចិត្ត ទទួលឮសំឡេងមនុស្សក្នុងខ្ទមប្រឹបនោះ ដេកមើលក្បួនពិជ័យសង្គ្រាមជំជ្រៅទូលាយ ហើយអធិប្បាយចេញទៅជាច្រើន ៗ ដៀវកានផ្ទៀងស្ដាប់ក៏ចាប់ចិត្តគិតថា អ្នកមើលតម្រានេះ

មានដម្រេះប្រាជ្ញាច្រើនណាស់ ក៏ដើរចូលទៅគោះទ្វារប្រាថ្នានឹងចូលទៅសន្ទនាផង ។ ឯប៉ាំងថងបានឮបុរគោះទ្វារក៏ម៉្មាសួរថា នរណាមានការអ្វី? ។ ជៀវកានក៏ឆ្លើយថា ខ្ញុំឈ្មោះជៀវកានមានការមករកអ្នក ។ ប៉ាំងថងក៏បើកទ្វារហៅឲ្យចូលទៅ ។ ជៀវកានជូនគំនាប់ហើយសួរថា អ្នកឈ្មោះអី ? ។ ប៉ាំងថងឆ្លើយថា ខ្ញុំឈ្មោះប៉ាំងថង ។ ជៀវកានសួរថា អ្នកនេះឬដែលគេហៅអាចារ្យ «ហាំងស៊ូ» នោះ ។ ប៉ាំងថងថា ខ្ញុំនេះឯង ។ ជៀវកានថា មនុស្សគ្នាល្បីកេរ្តិ៍ឈ្មោះអ្នកថា មានដម្រេះប្រាជ្ញាច្រើនណាស់ ហេតុម្តេចអ្នកមកនៅកន្ទីមិនសមគួរដូច្នេះ? ។ ប៉ាំងថងថា ដីវយ៉េនោះជាមនុស្សកាន់ខ្លួនអ្នកទេ អ្នកដ៏ទីងទឹងកេនរណាស្គាល់ ហើយមើលងាយប្រមាថមនុស្សតាំងពួង បានជាខ្ញុំលបគេចមកលាក់ខ្លួនពួននៅកន្លែងនេះ ប្រាថ្នាឲ្យបានសេចក្ដីសប្បាយ ។

ជៀវកានថា ខ្លួនអ្នកមានដម្រេះប្រាជ្ញាហើយចំណានក្នុងពិជ័យសង្គ្រាមដែលមកស្ងួននៅដូច្នេះ ក៏ដូចជាមនុស្សអប្បឥតប្រាជ្ញាសោះ ឯចិត្តខ្ញុំនោះស្រឡាញ់អ្នកមានដម្រេះប្រាជ្ញាណាស់ នឹងចង់សន្ទនាផង ប្រសិនបើអ្នកទៅនៅនឹងខ្ញុំ ហើយគង់នឹងបានសេចក្ដីសុខ ខ្ញុំនឹងនាំអ្នកយកទៅ ហើយនឹងស្នើសេចក្ដីគាប់ប្រសើរឲ្យអ្នកទៀត ។ ប៉ាំងថងតែងតបថា ខ្ញុំក៏គិតនៅជាដរាបថា នឹងគេចវេះចេញទៅឲ្យផុតដែនស្រុកកាំង

តាំង តែមិនមានទេណាទីជួយណែនាំទៅបាន ឥឡូវបើអ្នកមកទទួលចុះពិតហើយ ខ្ញុំក៏ទទួលអំណរជាទីបំផុត បើនឹងបង្អង់ឲ្យយូរខ្លាចក្រែងដីវយើដឹងការ កំនឹងធ្វើអន្តរាយយើងទាំង ២ ឲ្យបានសេចក្តីលំបាក ។ ជៀវកានថា អ្នកកុំព្រួយឡើយ ហើយក៏នាំប៉ាំងថងលបរត់ចេញទៅចុះទូកស្រួតថែវទៅដល់បន្ទាយចូចូ ជៀវកានក៏ចូលទៅថ្លែងពត៌មានប្រាប់ចូចូដែលបានគប់ផ្តើយគ្នានឹងដីវយើ ហើយនិយាយពីបានបញ្ចុះបញ្ចូលប៉ាំងថងនាំមកផងនោះឲ្យចូចូស្តាប់ ។

ចូចូព្រះហើយក៏ពេញអំណរណាស់ ទើបចេញមកគំនាប់ទទួលប៉ាំងថងនាំចូលទៅឲ្យអង្គុយទីសមគួរ ហើយថាអាយុដីវយើក៏នៅក្មេងណាស់ តែចិត្តតាហានអង់អាចមិនខ្លាចអ្វីសោះ លើកដំកើងខ្លួនថាមានជម្រេះប្រាជ្ញាតែម្នាក់ឯង មិនបានយកគំនិតប្រឹក្សាដែលមានជម្រេះប្រាជ្ញាសោះ ឥឡូវខ្លួនអ្នកបានមកដល់ខ្ញុំហើយ ចូរគណិតចុះការអ្វីដែលខ្ញុំធ្វើ បើ-ឃើញត្រូវខុសក៏ឲ្យអ្នកជាសច់តៀនប្រាប់ ។ ប៉ាំងថងថា ខ្ញុំបាទបានឮកិត្តិស័ព្ទជោះគេនិយាយឮល្បីថា មហាទេបកដមានជម្រេះប្រាជ្ញាស្មារតីរាងរៃកងការសង្គ្រាម ទោះបីនឹងតាំងក្បួនទ័ពគ្រាណា ក៏រមែងត្រូវតាមគម្រាពិជ័យសង្គ្រាមមិនដែលខុស ខ្ញុំបាទមកឥឡូវនេះ ក៏នៅមិនទាន់បានឃើញច្បាស់ដូចពាក្យគេនិយាយ បើបានឃើញរបៀបបន្ទាយហើយទើបអាចថាខុសនឹងត្រូវបាន ។

(នៅមានត)

# ពាក្យវប្បធម៌

លោក ទាន-ហ៊ួ រៀបរៀង

លោក សម.ថាំង ពិនិត្យ

---

## អស់លោកអ្នកអានទាំងឡាយ!

គណៈកម្មការវប្បធម៌ទើបនឹងបានទទួលសំបុត្រពីលោក សុខ-សេង នៅឃុំស្វាយពល ស្រុកពារាំង ខេត្រព្រៃវែង សូមឲ្យអធិប្បាយពន្យល់ពាក្យ ៥ ម៉ាត់នេះគឺ: សន្និបាត, សន្និសីទ, សន្ធថា, បាឋកថា នឹង សុន្ទរកថា ។ លោក សុខ.សេង ចង់ដឹងឲ្យច្បាស់ថា តើអត្ថន័យរបស់ពាក្យនីមួយ ៗ ខុសប្លែកពីគ្នាយ៉ាងណាខ្លះ? ។

មុននឹងបំពេញបំណងរបស់លោក សុខ-សេង, ក្នុងនាមគណៈកម្មការវប្បធម៌, ខ្ញុំសូមថ្លែងអំណរគុណចំពោះម្ចាស់សំបុត្រ ដែលមានសេចក្តីឆ្ងល់ចង់ដឹងទុកជាគ្រឿងបណ្តុះគំនិតប្រាជ្ញា ។

ពាក្យសួររបស់លោក សុខ-សេង នេះ នាំឲ្យយើងសប្បាយចិត្តពន់ពេក ព្រោះលោកចេះចង់ដឹងសួរបញ្ជាក់ទៅយើងផង ទាំងជាហេតុនាំឲ្យយើងមានគំនិត នឹងរើសរកពាក្យមកអធិប្បាយតម្រូវតាមគំនិតរបស់អ្នកអានផងទៀត ។

ឥឡូវ យើងសុំលើកពាក្យរបស់លោក សុខ-សេង មកអធិប្បាយជូនដូចមានខាងក្រោម :

១– សន្និបាត ពាក្យនេះក្នុងវចនានុក្រមខ្មែរភាគទីពីរ លោកពន្យល់ថា មកពីមគធៈនិងសំស្ក្រឹតថា សំនិបាត ឬ សន្និបាត គឺការប្រជុំ, ការជួបជុំ, ការប្រមូលប្រមូលគ្នា, ការណាយផ្សំគ្នា ។ គណៈកម្មការដែលរើសយកពាក្យនេះ ដោយផ្ទួនទៅនឹងពាក្យបារាំងថា (Assemblée) ថា (Réunion) ដែលមានន័យថា ៖

ក - (ASSEMBLÉE) ការជួបជុំនៃមនុស្សច្រើននាក់ក្នុងទីតែមួយ ដើម្បីជជែកពិភាក្សាពីបញ្ហាណាមួយ ហើយសម្រេចដោយគិតយកតាមមតិភាគច្រើន ។ សន្និបាតក្នុងសមាគមពាណិជ្ជកម្ម ឬគណៈបក្សនយោបាយ, តាមធម្មតា, មានបីប្រការគឺ មហាសន្និបាត (Assemblée générale) សន្និបាតសាមញ្ញ (Assemblée ordinaire) និងសន្និបាតវិសាមញ្ញ (Assemblée extraordinaire) ។

មហាសន្និបាត បានដល់ការប្រជុំធំរៀងរាល់ឆ្នាំរបស់សមាគម ឬគណៈបក្សនយោបាយដោយមានសមាជិកច្រើន ឬប្រតិភូជាតំណាងសមាជិកដែលមានធុរៈមិនបានចូលមកប្រជុំផង ។

សន្និបាតសាមញ្ញ ជាការប្រជុំរបស់សមាជិកតាមចំនួននិងកាលបរិច្ឆេទដែលកំណត់ ដើម្បីពិភាក្សាបញ្ហាតាមរបៀបវារៈដែលក្រុមអភិបាលដាក់ស្នើជូនមក ។ ការប្រជុំនេះ បើសមាជិកដែលចូលមកពុំបាន

គ្រប់គ្រាន់តាមចំនួនដូចកំរិតទេ ត្រូវលើកទៅថ្ងៃមុខយ៉ាងតិចត្រឹម១៥ថ្ងៃ ។ ការប្រជុំលើកទីពីរនេះ ទោះមានសមាជិកតិចជាងលើកមុនទៀត ការពិភាក្សាទាំងសេចក្តីសម្រេចដែលធ្វើឡើងនោះយកជាការដែរ ។

គ- សន្និបាតវិសាមញ្ញ ជាការប្រជុំដែលត្រូវធ្វើទៅតាមរូបមន្តដូចខាងលើ ប្លែកគ្នាតែត្រង់មិនត្រូវលើពេលវេលាដែលកំណត់នៅក្នុងលក្ខន្តិកៈប៉ុណ្ណោះ ។ ការប្រជុំបែបនេះមិនសូវមានជាញឹកញយទេ វៀរលែងតែមានករណីពិសេសដែលបង្ខំឲ្យធ្វើខានពុំបាន ដូចជាការរំលាយសមាគម ឬករណីដែលកើតមានឯទៀតតាមកាលៈទេសៈ ។

១- (RÉUNION) ជាការជួបជុំនូវមនុស្សច្រើននាក់ទោះឥតជជែកពិភាក្សាពីរឿងអ្វីក៏ដោយ ។ ការប្រជុំបែបនេះក៏ហៅថាសន្និបាតបានដែរ ។

២- សន្និសីទ ពាក្យនេះគ្មាននៅក្នុងវចនានុក្រមទេ ជាពាក្យដែលគណៈកម្មការវប្បធម៌ទើបនឹងបង្កើតដោយផ្គួបទៅនឹងពាក្យបារាំងថា (conférence) ។ ឯពាក្យ (conférence) ដែលគណៈកម្មការប្រែថា សន្និសីទនេះមានន័យថា :

ក- ការជួបគ្នាដើម្បីជជែកពីបញ្ហាណាមួយដែលពុំទាន់សម្រេចនៅឡើយ រវាងប្រទេសនានា លោកហៅថា សន្និសីទរវាងអ្នកការទូត ។

១. កាលពីពាក់កណ្តាលខែកក្កដាឆ្នាំមុន គណៈប្រតិភូខ្មែរ

ដែលមាន ឯ.ឧ. សឺន-សាន ជាប្រធាន បានទៅកាន់ក្រុងប៉ារីសដើម្បីធ្វើសន្និសីទអំពីការពាក់ព័ន្ធនៃសេដ្ឋកិច្ច រវាងប្រទេសបារាំងនឹងកម្ពុជា ។

១ - ការបរិយាយអធិប្បាយពីរឿងណាមួយ ដើម្បីឲ្យមនុស្សដែលនៅជួបជុំនោះស្តាប់សម្រាប់ជាគ្រឿងបណ្តុះសតិបញ្ញា ។

២. កាលពីប៉ុន្មានឆ្នាំមុននេះ លោកគេង-វណ្ណសាក់, បានធ្វើសន្និសីទអំពីបញ្ហាអក្សរសាស្ត្រខ្មែរ ក្រោមការឧបត្ថម្ភនៃក្រុមអភិបាលនៃសមាគមសិស្សចាស់ នៃវិទ្យាល័យព្រះស៊ីសុវត្ថិ ដើម្បីរកការដោះស្រាយពីការសិក្សាជាភាសាខ្មែរ ។

៣ សន្ដ្ឋថា ពាក្យនេះក៏ជាពាក្យថ្មីដែរ ។ គណៈកម្មការរើសយកដោយគ្រូទីនពាក្យបារាំងថា (Allocution) ដែលមានន័យថាពាក្យនិយាយដោយសង្ខេប មិនបានអធិប្បាយពន្យល់ឲ្យវែងឆ្ងាយទូលាយឡើយ ។ ដូចយ៉ាងការឲ្យជំបូន្មានខ្លីៗ ដែលអ្នកធំធ្វើដល់អ្នកនៅក្រោមបង្គាប់ឬក៏ការថ្លែងអំណរគុណយ៉ាងខ្លី ដែលភ្ញៀវជនជាអ្នកទទួលបដិសណ្ឋារកិច្ចអំពីអ្នកដទៃប្រារព្ធទៅអ្នកដែលរៀបទទួលខ្លួន ដោយពុំបានព្រាងទុកជាមុនប៉ុណ្ណោះ ។ ប៉ុន្តែនៅពេលសព្វថ្ងៃ ពាក្យសន្ដ្ឋថានេះ គេគល់នឹងខុសពីន័យដើមអស់ទៅហើយ មកពីអ្នកប្រើច្រើនពេកឃ្លាតឆ្ងាយពីគំនិតដើម ។

ឧទាហរណ៍   នៅពេលដែលទើបនឹងអញ្ជើញមកដល់ស្ថានីយ អាកាសយានពោធិចិនតុង   លោកសីការណូ ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី បានថ្លែងសន្ទកថាមួយ ។

២—ទាបកថា   ពាក្យនេះគ្មានក្នុងវចនានុក្រមទេ ។ គណៈ-កម្មការទើបនឹងបង្កើតថ្មីដោយផ្ទឹមទៅនឹងពាក្យបារាំង (Causerie)   ដែលមានន័យថា   ការសន្ទនាទៅមកនៅក្នុងគ្រួសារ,   ការនិយាយយ៉ាងងាយដល់អ្នកស្តាប់   ដើម្បីពន្យល់ពីរឿងណាមួយ   ហើយញុំាងអ្នកស្តាប់ឲ្យធ្វើតាម ដើម្បីជាប្រយោជន៍ ។

ឧទាហរណ៍   នៅពេលដែលមានរោគរាតត្បាតម្តង ១ ក្រសួងសុខាភិបាល   តែងចាត់ភ្នាក់ងារទៀតទៅកាន់ភូមិស្រុក   ដែលជាទីរាតត្បាតនៃរោគដើម្បីពន្យល់ឲ្យគេចាត់បង្ការជម្ងឺតាមវិធីអនាម័យ   ព្រមទាំងឲ្យគេព្យាបាលខ្លះ   នៅពេលដែលគ្រូពេទ្យទៅដល់   ឬមុនដែលដឹកអ្នកជម្ងឺទៅព្យាបាលរោគក្នុងមន្ទីរពេទ្យ

៣—សុន្ទរកថា   ពាក្យនេះមានពីរបទគឺ   សុន្ទរ   ជាគុណនាម ប្រែថា ល្អ, ប្រពៃ, ពិរោះ, ដែលគួរចង់ឮ, គួរចង់ស្តាប់,   ពិរោះជាប់ចិត្ត, ដែលគួរស្រឡាញ់, គួររីករាយ,   ហើយនឹងពាក្យ កថា   នាមនាម មានន័យថា   ពាក្យ, សំដី, ពំនោល,   ការសំដែង, រឿង ។ រួមបទទាំងពីរមកទៅជាសមាសនាមថា   សុន្ទរកថា ប្រែថា សំដីពីរោះ  សំដីគួរចង់

ស្តាប់ ខ្មែរសំដៅយកត្រង់សំដីសូត្រ, ថ្លែងក្នុងទីប្រជុំជន ។

ពាក្យនេះគណៈកម្មការ ប្រែដោយផ្គូទៅនឹងពាក្យបារាំងថា (Discours) ឯពាក្យ (Discours) នេះ មានន័យច្រើនប្រការណាស់ដូចតទៅ ៖

ក-ពាក្យសំដីដែលគេនិយាយកាន់គ្នាទៅវិញទៅមក,

ខ-សេចក្តីថ្លែង ជាពាក្យដោះស្រាយរបស់មេធាវី ក្នុងរឿងក្តីមួយ ៗ នៅចំពោះមុខសាលាជំនុំ,

គ-ការពង្រីកសេចក្តីជាបទពន្យល់ក្នុងរឿងណាមួយ,

ឃ-ដំណើរគេភ្ជាប់ពាក្យសព្ទនៅក្នុងភាសា,

ង-( តាមវេយ្យាករណ៍ ) សំដីរបស់ជនណាមួយដែលគេយកមកពោលជាបំណងត្រង់ ៗ តែម្តង លោកហៅថាសំដីផ្ទាល់,

ច-សំដីរបស់ជនណាមួយ ដែលគេលើកមកពោលសារដែរ តែមិនយកមកតាំងស្រុងត្រង់ ៗ តែម្តងទេ លោកហៅថា សំដីមិនចំពោះ ឬសំដីប្រយោលដូចជាពាក្យថា នៅពេលនោះលោក . ... បានមានប្រសាសន៍ថា យ៉ាងនេះយ៉ាងនោះ . . . ,

គណៈកម្មការដែលរើសពាក្យសុន្ទរកថាមកផ្គូនឹងពាក្យបារាំង (Discours) ឥតមានគំនិតសំដៅថា ឲ្យបានសេចក្តីអស់សព្វគ្រប់ទៅតាមបារាំងទេ គឺគ្រាន់តែសំដៅចំពោះត្រង់ " សំដីដែលគេបានព្រាងទុកជាមុន ហើយ

ទៅថ្ងៃយ៉ាងវែងល្អិតល្អន់គង់ទីប្រជុំជនច្រើននាក់ប៉ុណ្ណោះ ។

ដូច្នេះយើងសូមរំលឹកដល់លោកអ្នក ដែលយកពាក្យដូចខាងលើនេះ ទៅប្រើនោះ សូមឲ្យលៃលកទៅតាមករណីដ៏គួរផងចុះ ដើម្បីកុំឲ្យប្រទូកប្រទាំគ្នា នាំឲ្យស្មុគសេចក្តីស្តាប់មិនបាន អ្នកសរសេរចង់ថាយ៉ាងនេះ ហើយប្រែថា បានន័យទៅជាយ៉ាងនោះទៅវិញ ។

សេចក្តីអធិប្បាយពន្យល់ពាក្យទាំង ៤ ម៉ាត់នេះពុំទាន់ពិស្តារ សព្វគ្រប់ទេ ។ អស់លោកអ្នកអានមានលោកសុខ-សេង ដែលជាម្ចាស់សំបុត្រផ្តើមបង្កើតការតបឆ្លើយនេះ ប្រហែលជាពុំទាន់ពេញចិត្តសមតាមអធ្យាស្រ័យនៅឡើយទេដឹង ? ប្រសិនបើការស្មាននេះត្រូវពិត យើងសូមអំពាវនាវដល់អស់លោក-អ្នកអាន សូមផ្ញើសំបុត្រថ្លែងពីការខ្វះចន្លោះទៅគណៈកម្មការវប្បធម៌ត្រង់តែម្តង ឬផ្ញើទៅក្រសួងឃោសនាការជាតិឲ្យប្រគល់ទៅយើងក៏បាន ។ គណៈកម្មការទឹងទទួលឆ្លើយដំកបមកវិញដោយសេចក្តីរីករាយ ។

សេចក្តីថ្លែងរបស់លោក-អ្នកអានដែលផ្ញើទៅឲ្យយើងនេះ ទុកដូចជាគ្រឿងដាស់គំនិតយើងឲ្យកែកំហុសខ្វះប្រសិនបើមាន, ឬឲ្យគណៈកម្មការវប្បធម៌បែកគំនិតយោបល់ ហើយនឹងបានកែតម្រូវឲ្យសមតាមអធ្យាស្រ័យរបស់សាធុជនអ្នកអានផងទៀត ។

## ផ្នែកកំណត់ដំណឹងប្រវត្តិការណ៍

### ពត៌មានផ្សេងៗរបស់ក្រសួងធម្មការ

### អំពីការតាំងមន្ត្រីសង្ឃ

– បានតាំងភិក្ខុ អឿ-សំអាន អាយុ ៣៨ ឆ្នាំ វស្សា ១៨ នៅវត្តគោកអញ្ចាន់ ឃុំពាមពៅ ជាព្រះសមុហ៍អនុគណ ស្រុកភ្នំពេញកណ្ដាល តាមសញ្ញាបត្រលេខ ២៩៣០ ចុះថ្ងៃទី៦ ៩ ៦០ ។

– បានតាំងភិក្ខុ អ៊ុម-ប៉ុណ្ណ អាយុ ៣៧ ឆ្នាំ វស្សា ១៦ នៅវត្តកំពង់ក្ដុល ឃុំសាក់អំពៅ ជាព្រះគ្រូធម្មរក្ខិតាចារ្យ ជាសហការីនៃអនុគណស្រុកភ្នំពេញ កណ្ដាល តាមសញ្ញាបត្រលេខ ២៩២៩ ចុះថ្ងៃទី ៦-៩-៦០ ។

– បានតាំងភិក្ខុ ឡុង-ជិប អាយុ ៥៨ ឆ្នាំ វស្សា ៣៦ នៅវត្តល្អួស ជាទីព្រះវិន័យធរអនុគណ ស្រុកសូទ្រនិគម សៀមរាប តាមសញ្ញាបត្រលេខ ២៩៣៦ ចុះថ្ងៃទី៦-៩-៦០ ។

– បានតាំងភិក្ខុ ហោង-ឡឿន អាយុ ៤៨ ឆ្នាំ វស្សា ២៨ នៅវត្តល្អួស ជាទីព្រះសមុហ៍អនុគណ ស្រុកសូទ្រនិគម សៀមរាប តាមសញ្ញាបត្រលេខ ២៩៣៧ ចុះថ្ងៃទី ៦-៩-៦០ ។

– បានតាំងភិក្ខុ ប៉ែន-គឹមហ៊ាង អាយុ ២៧ ឆ្នាំ វស្សា ៤ នៅវត្តល្អួសជាទីអនុលេខាធិការអនុគណ ស្រុកសូទ្រនិគម សៀមរាប តាមសញ្ញាបត្រលេខ ២៩៣៨ ចុះថ្ងៃទី ៦-៩-៦០ ។

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិតបិ ធាតុ ឆេះក្រៃលែង, ក្តៅក្រៃលែង ។ - តប្ត, គុ. ដែលក្តៅ, ស្អា ( សំឡេង )

អតិតបស្វិន គុ. ដែលប្រព្រឹត្តតប:ក្រៃលែង ។

អតិតរាម ក្រ.វិ. ក្រៃពេកណាស់ ។

អតិតានវ នបុំ. កិរិយាស្គមក្រៃពេក ។

អតិតារ គុ. ដែលពិបាកឆ្លងក្រៃពេក ។

អតិតិក្សា ស្ត្រី. សេចក្តីខ្លាញ់ ។

អតិតិតីប្សុ គុ. ដែលចង់:គេចចេញក្រៃពេក ។

អតិតីក្ឝ្ន គុ. ស្រួចក្រៃពេក, ដែលមុតក្រៃពេក ។ - តីក្ឝ្នតា, ស្រី. ភាពនៃ.. ស្រួចក្រៃពេក ។

អតិតីវ្រ គុ. ដែលយង់ឃ្នងក្រៃពេក (ចម្បាំង) ។

អតិតុទិ ភា. ន. អ្នកសម្លាប់ដ៏សាហាវ ។

អតិតឫ្ឝ្ណា គុ. ក្តៅក្រៃពេក ។

អតិតឫប្តិ ធាតុ. ចំអែត ។